UNODC
United Nations Office on Drugs and Crime
IAWP
Australian Aid
UN WOMEN

# សៀវភៅណែនាំ ស្តីពីសេវានគរបាល ដែលឆ្លើយតបនឹងយេនឌ័រ

## សម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា



# សេចក្តីថ្លែងអំណរគុណ

ការបង្កើតសៀវភៅណែនាំនេះអាចសម្រេចទៅបានដោយមានការចូលរួមចំណែកពី៖

ការរាយការណ៍របស់ស្ត្រីជាច្រើនដែលធ្លាប់រងគ្រោះដោយអំពើហិង្សានិងការលាតត្រដាងពីបទពិសោធន៍រងគ្រោះរបស់ពួកគេព្រមទាំងសកម្មជន ជាពិសេសសកម្មជនមកពីអង្គការស្ត្រីនៅទូទាំងសកលលោកដែលបានធ្វើសកម្មភាពទាក់ទាញការគាំទ្រមតិឱ្យមានការផ្តល់សេវាសមស្រប និងការគាំទ្រដល់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា។

កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដែលកំពុងចាត់វិធានការដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈកំណែទម្រង់ច្បាប់ គំនិតផ្តួចផ្តើមគោលនយោបាយ និងការអនុវត្តកម្មវិធីទប់ស្កាត់ និងឆ្លើយតប។ រដ្ឋាភិបាលអូស្ត្រាលី ដែលជាម្ចាស់ជំនួយដ៏ធំមួយនៃកម្មវិធីរួមរបស់អង្គការសហប្រជាជាតិស្តីពី សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា។

ប្រព័ន្ធអង្គការសហប្រជាជាតិដែលបាននឹងកំពុងបង្កើតកម្មវិធី និងសកម្មភាពឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ទីភ្នាក់ងារអង្គការសហប្រជាជាតិដែលចូលរួមក្នុងការគាំទ្រដល់ការបង្កើតសៀវភៅណែនាំនេះ បានចំណាយពេលវេលា និងផ្តល់ចំណេះដឹងរបស់ពួកគេដើម្បីធានាថា យើងបន្តកែលម្អការផ្តល់សេវាសំខាន់ៗដែលមានគុណភាពដល់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា។ យើងសូមថ្លែងអំណរគុណដល់តំណាងស្ថាប័ននានាចំពោះការប្តេជ្ញាចិត្ត និងមតិយោបល់របស់ពួកគេ ៖ Kalliope Mingeirou, Caroline Meenagh, Charlotte Hemmestad Ludt Lea Biason, Beatrice Duncan, Sadiq Syed, Melissa Alvarado, A.H. Monjurul Kabir, Bridget Hancock និង Alejandro Sanchez (UN Women), Shruti Majumdar (មូលនិធិ Trust Fund របស់អង្គការសហប្រជាជាតិដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី), Valerie Lebaux, Claudia Baroni និង Sven Pfeiffer (UNODC), Sofiene Bacha (UNDP) និង Cameron Sigley (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ ផ្នែកនគរបាល)។

យើងសូមអគុណយ៉ាងស្មោះស្ម័គ្រចំពោះសមាជិកនៃក្រុមផ្តល់ប្រឹក្សា ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស៖ Alessandra Aresu (Humanity & Inclusion), Cheryl Thomas, Melissa Scaia, Laura Wilson និង Helen Rubenstein (Global Rights for Women), Jennifer Long (AEquitas), Marai Larasi (សម្ព័ន្ធបញ្ឈប់អំពើហិង្សាលើស្ត្រី), Maureen Curtis និង Kimberlina Kavern (Safe Horizon), Eileen Skinnider និង Ruth Montgomery (មជ្ឈមណ្ឌលអន្តរជាតិសម្រាប់កំណែទម្រង់ច្បាប់ព្រហ្មទណ្ឌ និងគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ វែនឃូវ័រ កាណាដា), Maria Victoria 'Mavic' Cabrera Balleza និង Agnieszka Fal-Dutra Santos (បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី), Raluca Popa និង Rea Abada Chiongson (អង្គការច្បាប់អភិវឌ្ឍន៍អន្តរជាតិ), Alison Eaton (Safeguarding Against Abuse Ltd.)Cassandra Altagracia Martha, Sarah Louise Neil និង Shamima Begum (សមាគមអន្តរជាតិនៃនគរបាលជាស្ត្រី) និង Deborah Friedl (នាយកសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី)។

យើងសូមអរគុណចំពោះការរួមចំណែករបស់ Graham Goulden, Gerry Campbell និង Neelam Sarkaria ដែលបានផ្តល់ការលះបង់ និងការគាំទ្រយ៉ាងច្រើនលើផ្នែកបច្ចេកទេសសម្រាប់ការចង្អុលបង្ហាញ និងការបង្កើតសៀវភៅណែនាំនេះ។

អ្នកនិពន្ធ ៖ Mirko Fernandez (ប្រធានក្រុមទីប្រឹក្សា) និង Jane Townsley (ទីប្រឹក្សានគរបាលជាន់ខ្ពស់ និងជានាយកប្រតិបត្តិសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី)។

# ពាក្យកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACE | បទពិសោធន៍មិនល្អនៅវ័យកុមារ (ចក្រភពអង់គ្លេស) |
| APT | សមាគមទប់ស្កាត់ការធ្វើទារុណកម្ម |
| BAWP | សមាគមអង់គ្លេសដើម្បីស្ត្រីក្នុងសេវានគរបាល |
| BiH | បូស្នី និងហឺហ្សេហ្គូវីណា |
| BME | ជាតិពន្ធុស្បែកខ្មៅ និងភាគតិច (ចក្រភពអង់គ្លេស) |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CEFM | អាពាហ៍ពិពាហ៍កុមារ និងអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ |
| CDC | មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង (សហរដ្ឋអាមេរិក) |
| CRC | គណៈកម្មាធិការសិទ្ធិកុមារ |
| CCTV | កាមេរ៉ាសុវត្ថិភាព |
| CLSPD | ក្រុមប្រឹក្សាសន្តិសុខទប់ស្កាត់បទល្មើសក្នុងមូលដ្ឋាន |
| CR-VAWG | អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ |
| CSI | ការស៊ើបអង្កេតនៅកន្លែងកើតហេតុ |
| CSO | អង្គការសង្គមស៊ីវិល |
| CPS | សេវាអយ្យការ Crown (ចក្រភពអង់គ្លេស) |
| CVF | ក្របខណ្ឌសមត្ថភាព និងគុណតម្លៃ (ចក្រភពអង់គ្លេស) |
| DASH | ឧបករណ៍ស្តីពីការរំលោភបំពានក្នុងគ្រួសារ ការឈ្លបចាប់ ការបៀតបៀន និងអំពើហិង្សាផ្អែកលើកិត្តិយស (ចក្រភពអង់គ្លេស) |
| DCAF | មជ្ឈមណ្ឌលហ្សឺណែវដើម្បីអភិបាលកិច្ចវិស័យសន្តិសុខ |
| DIWA | អង្គការស្ត្រីមានពិការភាពនៅអាហ្វ្រិក |
| DNA | ឌីអុកស៊ីរីបូនុយក្លេអ៊ីកអាស៊ីត |
| DPET | ផ្នែកគោលនយោបាយ វាយតម្លៃ និងបណ្តុះបណ្តាល-នាយកដ្ឋានប្រតិបត្តិការ សន្តិភាពនៃអង្គការសហប្រជាជាតិ |
| DRC | សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ |
| DV | អំពើហិង្សាក្នុងគ្រួសារ |
| DVPNs | ការជូនដំណឹងអំពីការការពារអំពើហិង្សាក្នុងគ្រួសារ (ចក្រភពអង់គ្លេស) |
| DVPOs | ដីកាការពារសម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារ (ចក្រភពអង់គ្លេស) |
| EIGE | វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ |
| ESP | កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព |
| EWPA | សមាគមអាប៉ប់រួមនៃនគរបាលជាស្ត្រី |
| EVD | ជំងឺអេបូឡា |
| FDV | អំពើហិង្សាក្នុងគ្រួសារ (អូស្ត្រាលី) |

| | |
|---|---|
| FGM/C | ការវះកាត់ប្រដាប់បន្តពូជស្ត្រី |
| FLO | មន្ត្រីទំនាក់ទំនងគ្រួសារ |
| FSU | អង្គភាពគាំពារគ្រួសារនៃនគរបាលសៀរ៉ាឡេអូន |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GNWP | បណ្ដាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី |
| HM | មហាក្សត្រី (រដ្ឋាភិបាលចក្រភពអង់គ្លេស) |
| HMIC | អធិការដ្ឋាននគរបាលមហាក្សត្រី (ចក្រភពអង់គ្លេស) |
| HMICFRS | អធិការដ្ឋាននៃសេវាពន្លត់អគ្គីភ័យ និងសង្គ្រោះនៃនគរបាលមហាក្សត្រី (ចក្រភពអង់គ្លេស) |
| IACP | សមាគមអន្តរជាតិនៃស្នងការនគរបាល |
| IAWP | សមាគមអន្តរជាតិនៃនគរបាលជាស្ត្រី |
| IBSA | ការរំលោភបំពានផ្លូវភេទផ្អែកលើរូបភាព |
| ICC | តុលាការឧក្រិដ្ឋកម្មអន្តរជាតិ |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| ICVS | ការអង្កេតជាអន្តរជាតិលើជនរងគ្រោះដោយសារបទល្មើស |
| ID | អត្តសញ្ញាណ |
| IDVA | ទីប្រឹក្សាឯករាជ្យទទួលបន្ទុកអំពើហិង្សាក្នុងគ្រួសារ (ចក្រភពអង់គ្លេស) |
| IHRL | ច្បាប់សិទ្ធិមនុស្សអន្តរជាតិ |
| IHL | ច្បាប់មនុស្សធម៌អន្តរជាតិ |
| IFVCC | ក្រុមប្រឹក្សាសម្របសម្រួលអំពើហិង្សាក្នុងគ្រួសារនៅ Illinois (សហរដ្ឋអាមេរិក) |
| ILo | អង្គការអន្តរជាតិខាងការងារ |
| IPV | អំពើហិង្សាលើដៃគូស្និទ្ធស្នាល |
| ISA | កិច្ចព្រមព្រៀងស្ដីពីការចែករំលែកព័ត៌មាន |
| ISP | អ្នកផ្ដល់សេវាអ៊ីនធឺណិត |
| KRPA | សម្ព័ន្ធសុវត្ថិភាពទីសាធារណៈ (ឥណ្ឌូនេស៊ី) |
| LGBTI | ក្រុមស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្ដូរយេនឌ័រ និង អ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរភេទ |
| LSC | ក្រុមប្រឹក្សាសន្តិសុខក្នុងមូលដ្ឋាន |
| M&E | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MARAC | សន្និសីទស្ដីពីការវាយតម្លៃហានិភ័យពហុស្ថាប័ន (ចក្រភពអង់គ្លេស) |
| MINUSCA | បេសកកម្មរក្សាសន្តិភាពពហុជាតិរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋអាហ្វ្រិកកណ្ដាល |
| MINUSMA | បេសកកម្មរក្សាសន្តិភាពពហុជាតិរបស់អង្គការសហប្រជាជាតិនៅម៉ាលី |
| MINUSTAH | បេសកកម្មរក្សាសន្តិភាពពហុជាតិរបស់អង្គការសហប្រជាជាតិនៅហៃទី |
| MoI | ក្រសួងមហាផ្ទៃ |
| MONUSCO | បេសកកម្មរក្សាសន្តិភាពពហុជាតិរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ |
| MPS | សេវានគរបាលម៉ាឡាវី |
| MSC | ក្រុមប្រឹក្សាសន្តិសុខរដ្ឋធានី |
| MSCJ | Mesa de Seguridad de Cd. Juárez (ម៉ិចស៊ិក) |

| | |
|---|---|
| MWCI | គណៈកម្មការស្រាវជ្រាវរកស្ត្រីដែលបាត់ខ្លួន ( British Columbia កាណាដា ) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NOSPI | ស្តង់ដារលទ្ធផលថ្នាក់ជាតិសម្រាប់អន្តរាគមន៍លើជនបង្ក (អូស្ត្រាលី) |
| NPCC | ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល ( ចក្រភពអង់គ្លេស ) |
| OHDIR | ការិយាល័យស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៃ OSCE |
| OSCE | អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប |
| PPE | បរិក្ខារការពារបុគ្គល |
| PSVW | សប្តាហ៍ភ្ញៀវប្រចាំប៉ុស្តិ៍នគរបាល |
| RCMPស | កងរាជអាវុធហត្ថកាណាដា |
| RS | Republika Srpska ( បូស្នី និងហឺហ្សីហ្គូវីណា ) |
| SALW | អាវុធធុនតូច និងធុនស្រាល |
| SARC | មជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស |
| SEESAC | មជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ និងបូព៌ា |
| SGBV | អំពើហិង្សាផ្លូវភេទទាក់ទងនឹងយេនឌ័រ |
| SGF | ក្របខណ្ឌណែនាំយុទ្ធសាស្ត្រសម្រាប់នគរបាលរក្សាសន្តិភាពអន្តរជាតិ(អង្គការសហប្រជាជាតិ) |
| SLP | នគរបាលសៀរ៉ាឡេអូន |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដារ |
| SSR | កំណែទម្រង់វិស័យសន្តិសុខ |
| SVRI | គំនិតផ្តួចផ្តើមស្រាវជ្រាវអំពើហិង្សាផ្លូវភេទ |
| UK | ចក្រភពអង់គ្លេស |
| UN | អង្គការសហប្រជាជាតិ |
| UNAMID | ប្រតិបត្តិការកូនកាត់របស់អង្គការសហប្រជាជាតិនៅតំបន់ដាហ្វ៊ូរ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| UN DESA | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ |
| UN DPO | នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ |
| UN ECOSOC | ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| UNHCR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន |
| UNIFIL | កងកម្លាំងបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសលីបង់ |
| UNMEER | បេសកកម្មសហប្រជាជាតិសម្រាប់ឆ្លើយតបទៅនឹងគ្រោះអាសន្នជំងឺអេបូឡា |
| UNMIL | បេសកកម្មអង្គការសហប្រជាជាតិនៅប្រទេសលីបេរីយ៉ា |
| UNMIS | បេសកកម្មអង្គការសហប្រជាជាតិនៅប្រទេសស៊ូដង់ |
| UNMIT | បេសកកម្មចម្រុះរបស់អង្គការសហប្រជាជាតិនៅប្រទេសទីម័រខាងកើត |
| UN OCHA | ការិយាល័យសម្របសម្រួលកិច្ចការមនុស្សធម៌នៃអង្គការសហប្រជាជាតិ |
| UNODC | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| UN OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |

| | |
|---|---|
| UN OROLSI | ការិយាល័យស្ថាប័ននីតិរដ្ឋ និងស្ថាប័នសន្តិសុខនៃអង្គការសហប្រជាជាតិ |
| UN SCR | សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ |
| U.S. | សហរដ្ឋអាមេរិក |
| VAWG | អំពើហិង្សាលើស្ត្រី និងក្មេងស្រី |
| WCU | អង្គភាពគាំពារសាក្សី |
| WHO | អង្គការសុខភាពពិភពលោក |
| WLB | ការិយាល័យច្បាប់ និងសិទ្ធិមនុស្សរបស់ស្ត្រី |
| WPON | បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៅអឺរ៉ុបអាគ្នេយ៍ |

# មាតិកា


សេចក្តីថ្លែងអំណរគុណ.......................................................................................................១
ពាក្យកាត់ និងពាក្យបំព្រួញ...............................................................................................២-៥

ជំពូកទី ១ ៖ សេចក្តីផ្តើម...................................................................................................១១-១៧
ជំពូកទី ២ ៖ ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម..............................១៩-៥៥
ជំពូកទី ៣ ៖ ការទប់ស្កាត់.....................................................................................................៥៧-៨៩
ជំពូកទី ៤ ៖ ទំនាក់ទំនងដំបូង...............................................................................................៩១-១១៧
ជំពូកទី ៥ ៖ ការស៊ើបអង្កេត..................................................................................................១១៩-១៦៨
ជំពូកទី ៦ ៖ សុវត្ថិភាព និងការការពារ....................................................................................១៦៩-១៩៩
ជំពូកទី ៧ ៖ ការគាំទ្រនិងជំនួយ.............................................................................................២០១-២៣០
ជំពូកទី ៨ ៖ ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌.................................................២៣១-២៥៤
ជំពូកទី ៩ ៖ ទំនាក់ទំនង.......................................................................................................២៥៥-២៨៦
ជំពូកទី ១០ ៖ ការកសាងស្ថាប័នដើម្បីជានាការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព..........................................................................២៨៧-៣៤៧
ជំពូកទី ១១ ៖ បញ្ហាប្រឈមនិងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ..៣៤៩-៣៧៦
ជំពូកទី ១២ ៖ ការបន្តផ្តល់យុត្តិធម៌.........................................................................................៣៧៧-៤១៤
ជំពូកទី ១៣ ៖ បញ្ហាដែលលេចឡើងក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី..................៤១៥-៤៦២
ជំពូកទី ១៤ ៖ វិបត្តិសុខភាពសាធារណៈនិងវិបត្តិមនុស្សធម៌ក្នុងស្ថានភាពមិនមែនជម្លោះ................៤៦៣-៥១៤
ជំពូកទី ១៥ ៖ សទ្ទានុក្រម និង ឯកសារយោង ( Glossary and Bibliography )........................៥១៥-៥៤៨

# 1

# សេចក្តីផ្តើម

ជាយូរមកហើយដែលអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាបញ្ហាសិទ្ធិមនុស្សជាសកល និង ទូលំទូលាយដែលបណ្តាលមកពីវិសមភាពនៃទំនាក់ទំនងអំណាចវិសមភាពផ្នែករចនាសម្ព័ន្ធ និងការរើសអើង។ គេប៉ាន់ស្មានថាក្នុងចំណោមស្ត្រី ៣ នាក់នៅទូទាំងពិភពលោកមានស្ត្រីម្នាក់ (៣៥%) ទទួលរងអំពើហិង្សាផ្លូវកាយ ឬអំពើហិង្សាផ្លូវភេទ ដែលភាគច្រើនបង្កឡើងដោយដៃគូស្និទ្ធស្នាល[1] ហើយស្ថិតិនេះ មិនរួមបញ្ចូលការបៀតបៀនផ្លូវភេទនោះទេ។ ទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីរួមមានការសម្លាប់ដែលពាក់ព័ន្ធនឹងយេនឌ័រ (ឬហៅថា "ការសម្លាប់ទារកក្នុងផ្ទៃភេទស្រី") អំពើហិង្សាផ្លូវភេទមិនបង្កឡើងដោយដៃគូការជួញដូរសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃពលកម្មដោយបង្ខំ ការ

វះកាត់ប្រដាប់បន្តពូជស្ត្រី និងការអនុវត្តដែលបង្កគ្រោះថ្នាក់ផ្សេងទៀត ដូចជាអាពាហ៍ពិពាហ៍កុមារ អាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ និង "ការសម្លាប់ដើម្បីរក្សាកិត្តិយស"។ ជាញឹកញាប់ ស្ត្រី និងក្មេងស្រីទទួលរងទម្រង់ចម្រុះនៃអំពើហិង្សាជាបន្តបន្ទាប់ ទាំងនៅក្នុងពេលមានសន្តិភាព ឬជម្លោះ ឬក្រោយពេលមានជម្លោះ និងក្នុងមជ្ឈដ្ឋានចម្រុះ ដូចជា ក្នុងគ្រួសារ នៅកន្លែងធ្វើការ នៅសាលារៀន ក្នុងសហគមន៍ តាមប្រព័ន្ធអ៊ីនធឺណិត និងនៅទីសាធារណៈ[2]។

មានភស្តុតាងបង្ហាញថា កត្តា និងលក្ខខណ្ឌបុគ្គល សហគមន៍ និងសង្គមជាច្រើនពាក់ព័ន្ធនឹងហានិភ័យខ្ពស់នៃការទទួលរង ឬការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ឧ. ជំនឿ និងបទដ្ឋានជាលក្ខណៈបុគ្គល និងជាសមូហភាពជុំវិញភាពជាបុរស និងភាពជាស្ត្រី និងតួនាទីយេនឌ័រមិនស្មើភាពនិងតឹងរ៉ឹងក្នុងជីវិតសាធារណៈ និងជីវិតឯកជន ដែលផ្តល់អំណាចឱ្យបុរសច្រើនជាងស្ត្រីក្នុងទិដ្ឋភាពផ្សេងៗនៃជីវិត។ កត្តាហានិភ័យផ្សេងទៀតអាចរួមមានសង្គមដែលទទួលយកអំពើហិង្សាក្នុងគ្រួសារ អសន្តិសុខសេដ្ឋកិច្ច ការប្រើប្រាស់គ្រឿងស្រវឹង និងសារធាតុញៀនផ្សេងទៀតដែលបង្កគ្រោះថ្នាក់ កង្វះលទ្ធភាពរបស់ជនរងគ្រោះក្នុងការទទួលបានសេវាសំខាន់ៗ និងមានគុណភាព និងគោលនយោបាយ និង ក្របខណ្ឌច្បាប់ដែលរើសអើងយេនឌ័រដែលបណ្តាលមកពីបទដ្ឋានបិតាធិបតេយ្យ[3]។ ក្រៅពីនេះ មានភស្តុតាងច្បាស់លាស់ដែលបង្ហាញថា ការប្រឈមនឹងអំពើហិង្សា និងបទដ្ឋានយេនឌ័រអវិជ្ជមាននៅវ័យកុមារ និងវ័យជំទង់ បង្កើនលទ្ធភាពនៃការប្រព្រឹត្តឬរងគ្រោះដោយអំពើហិង្សានៅដំណាក់កាលក្រោយមកទៀតក្នុងជីវិត។

ទោះបីជាអំពើហិង្សាបង្កការខាតបង់យ៉ាងធ្ងន់ធ្ងរលើជនរងគ្រោះដោយសារអំពើហិង្សាក្តីក៏វាមិនមែនជាបញ្ហាតែសម្រាប់ស្ត្រីនោះឡើយ។ វិសមភាពផ្អែកលើយេនឌ័រ និងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបង្កផលវិបាកអវិជ្ជមានជាច្រើនដល់គ្រួសារ សហគមន៍ និងសង្គម។ ឧ. ការខាតបង់ជាសកលនៃអំពើហិង្សាលើស្ត្រីត្រូវបានប៉ាន់ស្មានថាមានតម្លៃ ១,៥ ទ្រីលានដុល្លារអាមេរិក (US$1.5 trillion) នៅឆ្នាំ ២០១៦[4]។

ក្រៅពីនេះ វិសមភាពយេនឌ័រក៏ពាក់ព័ន្ធនឹងការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស ភាពអយុត្តិធម៌ផ្នែកសេដ្ឋកិច្ចភាពអយុត្តិធម៌ផ្នែកអាកាសធាតុនិងប្រព័ន្ធគៀបសង្កត់ផ្សេងទៀតផងដែរ។ ដូច្នេះ ច្បាស់ណាស់ថា ការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនត្រឹមតែជាគោលបំណងមួយ និងជាផ្នែកមួយនៃការសម្រេចបានសមភាពយេនឌ័រ ដែលជាគោលដៅមួយនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសារៈសំខាន់សម្រាប់ការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀតដូចជាការលុបបំបាត់ភាពក្រីក្រ លទ្ធភាពទទួលបាន

---

1. អង្គការសុខភាពពិភពលោក (២០១៣) ការប៉ាន់ស្មានថ្នាក់សកល និងថ្នាក់តំបន់ស្តីពីអំពើហិង្សាលើស្ត្រី ៖ https://www.who.int/publications/i/item/9789241564625.
2. UN Women (២០២០) ជំងឺកូវីដ ១៩ និងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី https://www.unwomen.org/en/digital-library/publications/2020/04/issue-brief-covid-19-and-ending-violence-against-women-and-girls.
3. UN Women (២០២០) ការទប់ស្កាត់ ៖ អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជំងឺកូវីដ ១៩ https://www.unwomen.org/en/digital-library/publications/2020/05/brief-prevention-violence-against-women-and-girls-and-covid-19.
4. UN Women (2016) "ការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារអំពើហិង្សាលើស្ត្រី" ការលើកឡើងរបស់ Lakshmi Puri អគ្គលេខាធិការជំនួយការនៃអង្គការសហប្រជាជាតិ និងនាយកប្រតិបត្តិរងនៃUNWomenក្នុងកិច្ចពិភាក្សាកម្រិតខ្ពស់ស្តីពី "ការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារអំពើហិង្សាលើស្ត្រី"https://www.unwomen.org/en/news/stories/2016/9/speech-by-lakshmi-puri-on-economic-costs-of-violence-against-women.

ការថែទាំសុខភាព និងការអប់រំ ការងារសមរម្យ និងការកសាងសង្គមដែលយុត្តិធម៌ និងមានសន្តិភាពទៀតផង[5]។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជំងឺរាតត្បាតកូវីដ ១៩

ការផ្ទុះឡើងនៃវីរុសកូរ៉ូណា (ជំងឺកូវីដ ១៩) បានបង្កើនកម្រិតនៃកត្តាហានិភ័យជាច្រើនដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ។ ទិន្នន័យថ្មីៗបង្ហាញថា ចាប់តាំងពីការផ្ទុះជំងឺកូវីដ ១៩ អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ កើតឡើងកាន់តែច្រើនជាអ្វីដែលគេហៅថា "ជំងឺរាតត្បាតអន្ទោលតាមប្រាណ"[7]។ ស្ត្រី និងក្មេងស្រីត្រូវបានបិទខ្ទប់នៅក្នុងផ្ទះជាមួយជនបំពាន មិនអាចរាយការណ៍ពីអំពើហិង្សា និងគ្មានមធ្យោបាយទទួលបានការគាំទ្រដូចពីមុន។នៅខែមេសា ឆ្នាំ ២០២០ អ្នកជំនាញព្យាករណ៍ថា សម្រាប់ការអនុវត្តវិធានការបិទខ្ទប់រយៈពេល ៣ ខែ នៅជុំវិញពិភពលោក មានស្ត្រី និងក្មេងស្រីចំនួន ១៥ លាននាក់បន្ថែមទៀតដែលប្រឈមនឹងអំពើហិង្សា ។ នៅប្រទេសមួយចំនួន ការទូរស័ព្ទរកសេវាជំនួយកើនឡើង ៥ ដង[10] ។

តាំងពីមុនពេលមានជំងឺរាតត្បាតនេះមកម្ល៉េះដែលស្ត្រី និងក្មេងស្រីជាច្រើនមិនសូវមានលទ្ធភាពទទួលបានសេវាសំខាន់ៗជាមូលដ្ឋានដោយមិនគិតថ្លៃដើម្បីធានាសុវត្ថិភាព ការការពារ និងការស្តារឡើងវិញរបស់ខ្លួន ដូចជា ខ្សែទូរស័ព្ទជំនួយ ការឆ្លើយតបទាន់ពេលវេលាដោយនគរបាល និងវិស័យយុត្តិធម៌ ការថែទាំសុខភាព កន្លែងស្នាក់នៅដែលមានសុវត្ថិភាពទីជម្រកនិងការប្រឹក្សាផ្នែកចិត្តសង្គម។ ប្រសិនបើមាន ជាទូទៅគឺសេវាទាំងនោះខ្វះខាតមូលនិធិ ខ្វះបុគ្គលិកគ្មានការសម្របសម្រួលឬគ្មានគុណភាពគ្រប់គ្រាន់។ភស្តុតាងបង្ហាញថាក្នុងចំណោមស្ត្រីដែលរងគ្រោះដោយអំពើហិង្សា មានស្ត្រីតែ ៤០% ប៉ុណ្ណោះដែលស្វែងរកជំនួយណាមួយ ហើយក្នុងចំណោមស្ត្រី ១០ នាក់មានស្ត្រីម្នាក់ស្វែងរកជំនួយពីនគរបាល។ ស្ត្រីជាច្រើនមិនបានរាយការណ៍ពីបញ្ហារបស់ខ្លួនទៅយន្តការផ្លូវការនោះទេ ដោយសារតែភាពអាម៉ាស់ ការភ័យខ្លាចការសងសឹក ឬកង្វះចំណេះដឹងស្តីពីរបៀបទទួលបានជំនួយដែលមាន។ ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយសារទម្រង់ចម្រុះ និងភាពប្រទាក់ក្រឡាគ្នានៃការរើសអើង ដូចជា ស្ត្រីចំណាកស្រុក ស្ត្រីមានពិការភាព ឬស្ត្រីរស់នៅទីជនបទ និងទីដាច់ស្រយាល កាន់តែងាយទទួលរងអំពើហិង្សា និងមិនសូវទទួលបានការគាំទ្រទៅតាមតម្រូវការ។

ដោយសារតែអ្នកផ្តល់សេវាសុខាភិបាល សេវានគរបាល និងសេវាយុត្តិធម៌រ៉ាប់រងបន្ទុកយ៉ាងធ្ងន់នៃករណីជំងឺកូវីដ ១៩ និងផលវិបាកពាក់ព័ន្ធនឹងជំងឺនេះការគ្រប់គ្រងគ្លីនិកលើករណីរំលោភសេពសន្ថវៈការវាយតម្លៃសុខភាពផ្លូវចិត្ត ការថែទាំជនរងគ្រោះដោយសារអំពើហិង្សា និងលទ្ធភាពទទួលបានយុត្តិធម៌ ត្រូវបានបង្អាក់។ ជំងឺរាតត្បាតនេះធ្វើឱ្យបុគ្គលិកជួរមុខជាស្ត្រីរាប់លាននាក់ក្នុងវិស័យសុខាភិបាល និងសង្គមកិច្ច ប្រឈមនឹងហានិភ័យកាន់តែខ្ពស់នៃការឆ្លងជំងឺ កូវីដ ១៩ អសន្តិសុខសេដ្ឋកិច្ចកាន់តែខ្លាំងសម្រាប់ស្ត្រី រួមទាំងស្ត្រីដែលកំពុងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយគ្មានឬមានកិច្ចគាំពារសង្គមតិចតួច ឬជម្រើសបម្រុង និងបណ្តាលឱ្យក្មេងស្រីរាប់លាននាក់ដែលមិនបានរៀនសូត្រជាប់លាប់ប្រឈមនឹងហានិភ័យនៃអាពាហ៍ពិពាហ៍វ័យក្មេង។ តាមការប៉ាន់ប្រមាណ ជំងឺរាតត្បាតនេះនឹងធ្វើឱ្យស្ត្រី និងក្មេងស្រីចំនួន ៤៧ លាននាក់បន្ថែមទៀតធ្លាក់ក្រោមបន្ទាត់នៃភាពក្រីក្រ[11] ។ បញ្ហានេះគូសបញ្ជាក់ពីភាពចាំបាច់នៃការចាត់វិធានការបន្ទាន់ក្នុងការធានាវឌ្ឍនភាព ការដោះស្រាយនិទណ្ឌភាព និងតម្រូវការរបស់ជនរងគ្រោះ ព្រម

5. របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការបង្កើនកិច្ចខិតខំប្រឹងប្រែងលុបបំបាត់អំពើហិង្សាគ្រប់ទម្រង់លើស្ត្រី និងក្មេងស្រី (២០២០) https://undocs.org/en/A/75/274
6. របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការបង្កើនកិច្ចខិតខំប្រឹងប្រែងលុបបំបាត់អំពើហិង្សាគ្រប់ទម្រង់លើស្ត្រី និងក្មេងស្រី (២០២០) https://undocs.org/en/A/75/274។
7. សូមមើល ឧ. ការលើកឡើងរបស់លោកអគ្គលេខាធិការ Antonio Guterres ក្នុងទិវាអន្តរជាតិលុបបំបាត់អំពើហិង្សាលើស្ត្រី (២០២០) https://www.un.org/sg/en/content/sg/speeches/2020-11-25/remarks-international-day-forelimination-of-violence-against-women.
8. UNFPA (២០២០) ផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ លើការរៀបចំផែនការគ្រួសារ និងការបញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ ការវះកាត់ប្រដាប់បន្តពូជស្ត្រី និងអាពាហ៍ពិពាហ៍កុមារ https://www.unfpa.org/sites/default/files/resource-pdf/COVID-19_impact_brief_for_UNFPA_24_April_2020_1.pdf
9. UN Women (២០២០) ការពិត និងតួលេខ ៖ ការបញ្ចប់អំពើហិង្សាលើស្ត្រី https://www.unwomen.org/en/what-we-do/ending-violence-against-women/facts-and-figures#notes។
10. https://unstats.un.org/unsd/gender/downloads/WorldsWomen2015_report.pdf
11. UN Women (២០២០) ពីចំណេះដឹងឆ្ពោះទៅរកសកម្មភាព ៖ សមភាពយេនឌ័រក្រោយការផ្ទុះឡើងនៃជំងឺកូវីដ ១៩ https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/gender-equality-in-the-wake-of-covid-19-en.pdf?la=en&vs=5142.

ទាំងឆ្លុះបញ្ចាំងពីភាពចាំបាច់នៃការវិនិយោគកាន់តែច្រើនលើកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់។ មានភស្តុតាងច្រើនជាងពេលណាៗទាំងអស់ដែលបញ្ជាក់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីគឺអាចទប់ស្កាត់បាន[12] ។

## កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗ

ការលុបបំបាត់ទម្រង់ផ្សេងៗនៃអំពើហិង្សាទាមទារវិធីសាស្ត្រពហុវិស័យ ដោយមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមតួអង្គផ្សេងៗ។ចំណុចនេះត្រូវរួមបញ្ចូលយុទ្ធសាស្ត្រទប់ស្កាត់គ្រប់ជ្រុងជ្រោយពហុវិស័យ និងពង្រឹងឱ្យគ្នាទៅវិញទៅមកដែលដោះស្រាយឫសគល់នៃអំពើហិង្សា។ ការផ្តល់លទ្ធភាពទទួលបានការថែទាំសុខភាពដែលមានគុណភាព សេវាយុត្តិធម៌ និងសេវានគរបាល ព្រមទាំងសេវាចិត្តសង្គម អាចជួយឱ្យស្ត្រី និងក្មេងស្រីបំបែកវដ្តដដែលៗនៃអំពើហិង្សា និងសម្រាលផលវិបាកនៃអំពើហិង្សា។ កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ក្រោមភាពជាដៃគូរវាង UN Women, UNODC, UNFPA, WHO និង UNDP មានគោលបំណង ឆ្លើយតបទៅនឹងចំណុចខ្វះខាត និងបញ្ហាប្រឈមទាំងនេះ។ កម្មវិធីនេះផ្តល់ការណែនាំស្តីពីរបៀបអនុវត្តបទដ្ឋានជាសកលស្តីពីសេវានិងការឆ្លើយតបពហុវិស័យ ដោយផ្តោតសំខាន់លើសេវាសុខាភិបាល សេវានគរបាល សេវាយុត្តិធម៌ និងសេវាសង្គម ក៏ដូចជាយន្តការសម្របសម្រួលដែលផ្សារភ្ជាប់នឹងវិស័យទាំងនេះ។

ដំណាក់កាលទី ១ នៃកម្មវិធីរួមនេះ (២០១៣-២០១៧) ផ្តោតលើការកំណត់សេវាសំខាន់ៗនិងស្តង់ដារគុណភាពពាក់ព័ន្ធនិងឧបករណ៍សម្រាប់ការផ្តល់សេវាក្នុងមជ្ឈដ្ឋានផ្សេងៗ។ កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ សមាសធាតុសំខាន់ៗ និងគោលការណ៍ណែនាំស្តីពីគុណភាព (ESP) ត្រូវបានអនុវត្តនៅចុងឆ្នាំ ២០១៥។ កញ្ចប់សេវាទាំងនេះត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីទីប្រឹក្សាជំនាញតាមរយៈការពិគ្រោះយោបល់ផ្នែកបច្ចេកទេសនៅថ្នាក់សកល និងថ្នាក់តំបន់ជាមួយអ្នកជំនាញសំខាន់ៗមកពីរដ្ឋាភិបាល សង្គមស៊ីវិល ជនរងគ្រោះ ស្ថាប័នសិក្សាស្រាវជ្រាវ ព្រមទាំងអ្នកជំនាញមកពីវិស័យពាក់ព័ន្ធក្នុងគោលបំណងគាំទ្រដល់ការអនុវត្តកញ្ចប់សេវាទាំងនេះជាសកល។ នៅដើមឆ្នាំ ២០២១ កញ្ចប់ សេវាសំខាន់ៗកំពុងត្រូវបានប្រើប្រាស់ដោយប្រទេសជាង ៥០ ដើម្បីគាំទ្រដល់ការអនុវត្តបទដ្ឋាន និងស្តង់ដារជាសកលស្តីពីសេវា និងការឆ្លើយតបពហុវិស័យ។

នៅដើមឆ្នាំ ២០១៩ ក្នុងផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមដែលរកឃើញពីបណ្តាប្រទេសសាកល្បងកម្មវិធីនេះសម្រាប់ការអនុវត្តនៅឆ្នាំដំបូងក្នុងវិស័យយុត្តិធម៌ UN Women បានបង្កើតការណែនាំស្តីពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រដោយផ្តោតសំខាន់លើការពង្រឹងសេវានគរបាលសម្រាប់ស្ត្រី និងក្មេងស្រីដែលទទួលរងអំពើហិង្សា។

ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងអនុវត្តកញ្ចប់សេវាសំខាន់ៗក្នុងប្រទេសជាច្រើនក្តី ក៏នៅតែមិនសូវមានបទបញ្ញត្តិដែលមានប្រសិទ្ធភាព និងនីតិវិធីច្បាស់លាស់ពាក់ព័ន្ធនឹងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយប្រទេសមួយចំនួនមិនសូវមានការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយស្តីពីការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់។អ្នកប្រើប្រាស់លើកឡើងថាម៉ូឌុលទី ៣ (យុត្តិធម៌ និងនគរបាល) នៃកញ្ចប់សេវាសំខាន់ៗ ជាសមាសធាតុដែលលំបាកអនុវត្តជាងគេ។

នៅថ្ងៃទី ១៨-១៩ ខែ មិថុនា ឆ្នាំ ២០១៩ UN Women បានរៀបចំកិច្ចប្រជុំក្រុមអ្នកជំនាញ នៅទីស្នាក់របស់ UN Women ក្នុងទីក្រុងញូវយ៉កដើម្បីឱ្យដៃគូ និងអ្នកពាក់ព័ន្ធសំខាន់ៗ (សង្គមស៊ីវិល អង្គការស្ត្រី និងអង្គការជនរងគ្រោះ កងកម្លាំងនគរបាលទ្វេភាគី ស្ថាប័នយុត្តិធម៌

12. សម្រាប់ព័ត៌មានលម្អិត សូមមើល RESPECT Women ៖ ការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩) និងកញ្ចប់អនុវត្តន៍ដែលភ្ជាប់មកជាមួយ (២០២០) https://www.unwomen.org/en/digital-library/publications/2020/07/respect-women-implementation-package។ សូមមើលបន្ថែមទៀត UN Women (២០២០) ការទប់ស្កាត់ ៖ អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជំងឺកូវីដ ១៩ https://www.unwomen.org/en/digital-library/publications/2020/05/brief-prevention-violence-against-women-and-girls-and-covid-19.

ព្រហ្មទណ្ឌនិងស្ថាប័នអង្គការសហប្រជាជាតិ)មានឱកាសផ្តល់ធាតុចូលលើពង្រាងក្របខណ្ឌសម្រាប់ការរៀបរៀងសៀវភៅណែនាំនេះ រួមទាំងធាតុចូលលើបញ្ហាចំពោះមុខរបស់នគរបាលក្នុងការស៊ើបអង្កេតបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការដោះស្រាយភាពលម្អៀងក្នុងស្ថាប័ន និងផ្នត់គំនិតយេនឌ័រ និងការទទួលបាន "ការទទួលយក" ក្នុងស្ថាប័នកម្រិតខ្ពស់ និងការវាយតម្លៃការប្រើប្រាស់សៀវភៅណែនាំនេះជាឯកសារយោងសម្រាប់នគរបាល និងវិស័យយុត្តិធម៌ ក៏ដូចជាដៃគូផ្តល់សេវាសុខាភិបាលនិងសេវាសង្គមនិងការសម្របសម្រួលវិស័យទាំងនេះ។

## វិធីសាស្ត្រនៃសៀវភៅណែនាំនេះ

**សៀវភៅណែនាំនេះមានគោលបំណង ៖**

- ផ្តល់ការណែនាំជាក់ស្តែងដល់នគរបាល(ក្រុមគោលដៅបឋម)ក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគិតគូរពីយេនឌ័រទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈការចែករំលែកការរៀនសូត្រដែលលើកកម្ពស់វប្បធម៌ឆ្លុះបញ្ចាំង និងរៀនសូត្រ ដែលនាំទៅរកការផ្លាស់ប្តូរស្ថាប័ន។
- លើកកម្ពស់សេវានគរបាលដែលខិតខំរក្សាតុល្យភាពរវាងប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈការពិនិត្យឡើងវិញ ការវាយតម្លៃ និងការពិនិត្យតាមដានឧបករណ៍ស៊ើបអង្កេតយុទ្ធសាស្ត្រ គោលនយោបាយ និងអភិក្រម ដោយមានជំនួយពីតួអង្គខាងក្រៅមកពីសង្គមស៊ីវិល អង្គការស្ត្រី និងអង្គការជនរងគ្រោះ និងស្ថាប័នសិក្សាស្រាវជ្រាវ។

## ទ្រឹស្តីនៃការផ្លាស់ប្តូរ

សៀវភៅណែនាំនេះខិតខំបំផុសការផ្លាស់ប្តូរឥរិយាបថឆ្ពោះទៅសេវានគរបាលផ្តោតលើការទប់ស្កាត់ ដែលឆ្លើយតបនឹងយេនឌ័រ ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងផ្តោតលើជនបង្ក។

ដើម្បីសម្រេចបានការផ្លាស់ប្តូរឥរិយាបថសៀវភៅណែនាំនេះនឹងផ្តល់ការណែនាំបែបផ្លាស់ប្តូរឆ្ពោះទៅសម្រេចបានលទ្ធផល ៣ ដូចខាងក្រោម ៖

- នគរបាលសហការ និងសម្របសម្រួលបែបប្រតិសកម្មជាមួយសហគមន៍ រួមទាំងអង្គការសិទ្ធិស្ត្រីដើម្បីយល់ច្បាស់ពីបញ្ហា និងការផ្សព្វផ្សាយសារ "មិនអត់ឱន" ចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបង្ហាញការប្តេជ្ញាចិត្តចាត់វិធានការនៅពេលមានអំពើហិង្សា។
- ការប្តេជ្ញាចិត្តរបស់នគរបាលក្នុងការអនុវត្តអភិក្រមដែលផ្តោតលើជនបង្ក និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងប្រសិទ្ធភាពក្នុងការរារាំងការប្រព្រឹត្តអំពើហិង្សា។
- ការបណ្តុះបណ្តាល និងការអប់រំនគរបាលស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីផ្អែកតាមសិទ្ធិ ការគិតគូរពីយេនឌ័រដោយផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងឆ្លងកាត់ការពិគ្រោះយោបល់ទូលំទូលាយ។

ដោយផ្តោតដំបូងលើអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល[13] សៀវភៅណែនាំនេះនឹងគ្របដណ្តប់លើក្រុមនគរបាលគំរូដែលបំផុសការផ្លាស់ប្តូរពីថ្នាក់ក្រោមដោយផ្អែកលើការសិក្សាថ្មីៗទៅលើអ្វីដែលជាចំណុចសកម្មគំរូពីវិទ្យាសាស្ត្រនៃការផ្លាស់ប្តូរឥរិយាបថ។ សៀវភៅណែនាំនេះអាចប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាលអ្នកគ្រប់គ្រងជាន់ខ្ពស់ និងភ្នាក់ងារឆ្លើយតបជួរមុខ និងអាចប្រើប្រាស់ក្នុងបណ្ឌិតសភានគរបាលដើម្បីបំពេញបន្ថែមលើកម្មវិធីបណ្តុះបណ្តាលជាប្រចាំ។ ក្រុមគោលដៅទីពីររួមមានអង្គការសង្គមស៊ីវិល អង្គការស្ត្រី និងយន្តការត្រួតពិនិត្យថ្នាក់ជាតិ ដូចជា ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ និងស្ថាប័នអង្គការសហប្រជាជាតិ។

ដូចការកត់សម្គាល់ក្នុងកញ្ចប់សេវាសំខាន់ៗ ស្ត្រី និងក្មេងស្រីគ្រប់រូបគួរទទួលបាន និងងាយស្រួលទទួលបានការឆ្លើយតបប្រកបដោយគុណភាពខ្ពស់ពីនគរបាល និងវិស័យយុត្តិធម៌ ជាពិសេសស្ត្រី និងក្មេងស្រីដែលជួប

13. ក្រុមគោលដៅគឺអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ហើយជំពូកទី ២ដល់៩ នៃសៀវភៅណែនាំនេះត្រូវបានរៀបរៀងឡើងដោយពិចារណាពីមេបញ្ជាការប៉ុស្តិ៍នគរបាល ឬអង្គភាពនគរបាល។

ការលំបាកបំផុត និងងាយប្រឈមនឹងអំពើហិង្សា។ អ្នកផ្តល់សេវាទាំងនេះត្រូវបង្ហាញថា ពួកគេនិងប្រព័ន្ធប្រតិបត្តិការរបស់ខ្លួនប្តេជ្ញាជានាការពិចារណាល្អិតល្អន់លើបណ្តឹងរបស់ស្ត្រី និងក្មេងស្រី ហើយស្ត្រី និងក្មេងស្រីទទួលបានការគាំទ្រនៅពេលស្វែងរកជំនួយពីប្រព័ន្ធយុត្តិធម៌ដែលស្មុគស្មាញ។

ជំពូកនីមួយៗក្នុងសៀវភៅណែនាំនេះមានគោលបំណងផ្តល់ការណែនាំទៅវិញទៅមកស្តីពីការស៊ើបអង្កេតដែលមានគុណភាព ដល់មន្ត្រីគ្រប់គ្រងក្នុងជួរនគរបាល។ ដូច្នេះសៀវភៅណែនាំនេះនឹងណែនាំក្របខណ្ឌនៃកញ្ចប់សេវាសំខាន់ៗដែលលើកឡើងក្នុងម៉ូឌុលទី ៣ ( យុត្តិធម៌ និងនគរបាល)ដោយបង្ហាញការណែនាំប្រតិបត្តិការសម្រាប់មន្ត្រីនគរបាលក្នុងផ្នែកដូចតទៅ៖ យុទ្ធសាស្ត្រទប់ស្កាត់ទំនាក់ទំនងដំបូងជាមួយនគរបាលការស៊ើបអង្កេតដែលឆ្លើយតបនឹងយេនឌ័រ ការពិចារណាពីសុវត្ថិភាព និងការការពារការគាំទ្រ និងជំនួយចាំបាច់ យុទ្ធសាស្ត្រទំនាក់ទំនងនិងដំណោះស្រាយផ្អែកលើការ សម្របសម្រួល។ ក្រោមបរិបទនៃជំងឺរាតត្បាតកូវីដ ១៩ សៀវភៅណែនាំនេះក៏បានដាក់បញ្ចូលការណែនាំស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានវិបត្តិ រួមទាំងជំងឺរាតត្បាត។

ជំពូកនីមួយៗនៃសៀវភៅណែនាំនេះនឹងចែកចេញពីផ្នែករងដែលបញ្ជាក់ច្បាស់ពីនិយមន័យ និងក្របខណ្ឌនានា និងលើកឡើងពីសមត្ថភាពចាំបាច់របស់អ្នកគ្រប់គ្រងក្នុងជួរនគរបាលសម្រាប់ការផ្តល់សេវានគរបាលដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល ក៏ដូចជាអនុសាសន៍ស្តីពីសូចនាករអនុវត្តន៍ការងារសំខាន់ៗនិងការកំណត់រកចំណុចខ្វះខាតខាងសមត្ថភាព។ សៀវភៅណែនាំនេះផ្តោតសំខាន់លើការណែនាំជាក់លាក់ទាំងសម្រាប់ការអនុវត្ត និងការវាយតម្លៃ។

ការណែនាំគ្នាទៅវិញទៅមកលើផ្នែកប្រតិបត្តិការនឹងលេចឡើងក្នុងជំពូកនានាសម្រាប់នគរបាលដែលមានតួនាទីដឹកនាំ។ ការណែនាំនឹងផ្តោតលើអ្វីដែលមន្ត្រីនគរបាលក្នុងតួនាទីដឹកនាំឬត្រួតពិនិត្យនិង/ឬតួនាទីឆ្លើយតបដំបូងអាច និងគួរគ្រប់គ្រង នៅពេលប្រឈមនឹងឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្រៅពីនេះនឹងមានការប្រើប្រាស់ករណីសិក្សាដើម្បីបង្ហាញពីនវានុវត្តន៍ ការអនុវត្តល្អ និងការលះបង់របស់នគរបាលដើម្បីជានាការទទួលខុសត្រូវចំពោះបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រមទាំងសុវត្ថិភាព និងការការពារជនរងគ្រោះ។ ចុងបញ្ចប់ ជំពូកនីមួយៗនឹងផ្តល់ឯកសារយោងដើម្បីឱ្យអ្នកអាន យល់ដឹងពីនិន្នាការ ការស្រាវជ្រាវ និងការអនុវត្តថ្មីៗ។

ផ្អែកតាមក្របខណ្ឌកញ្ចប់សេវាសំខាន់ៗសៀវភៅណែនាំនេះកត់សម្គាល់ពីភាពជំទូលាយ និងភាពស្មុគស្មាញនៃទម្រង់អំពើហិង្សាដែលបង្កលើស្ត្រី និងក្មេងស្រី ក៏ដូចជាភាពចាំបាច់នៃការឆ្លើយតបយ៉ាងរស់រវើកក្នុងជួររបស់រាជរដ្ឋាភិបាលដើម្បីជានាការទប់ស្កាត់ការស៊ើបអង្កេត និងការផ្តន្ទាទោសដោយ ប្រសិទ្ធភាព។

សៀវភៅណែនាំនេះទទួលស្គាល់ក្របខណ្ឌច្បាប់ជាតិនានាចម្រុះដែលកំណត់លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រមូលភស្តុតាង និងលក្ខណៈចម្រុះនៃបរិបទសង្គម វប្បធម៌ និងសេដ្ឋកិច្ចក្នុងយុត្តាធិការដូចគ្នាទាំងនេះដែលជះឥទ្ធិពលលើទង្វើរបស់នគរបាលក៏ដូចជាភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រីទាក់ទងទៅនឹងបទល្មើសអំពើហិង្សា។

ដើម្បីគ្របដណ្តប់លើភាពស្មុគស្មាញ និងលក្ខណៈចម្រុះនេះ ជំពូកខាងក្រោមមានគោលបំណងពង្រឹងស្តង់ដារ និងបទដ្ឋានអន្តរជាតិដែលរំលេចស្តង់ដារអប្បបរមាដែលអាចអនុវត្តបានចំពោះបច្ចេកទេសស៊ើបអង្កេតទាំងអស់របស់នគរបាលក្នុងករណីពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី [14]។ សៀវភៅណែនាំនេះនឹងបង្ហាញជូនអ្នកអាននូវនីតិវិធីស៊ើបអង្កេតថ្នាក់ជាតិ រួមទាំងពិធីសារស្តីពីសុវត្ថិភាពជនរងគ្រោះក៏ដូចជាពិធីសារដែលទទួលស្គាល់ជាអន្តរជាតិនិងការអនុវត្តល្អបំផុតសម្រាប់ជាការណែនាំឯកទេសនិងការណែនាំគ្រប់ជ្រុងជ្រោយដល់នគរបាល។

គួរចាត់ទុកនិងអនុវត្តការណែនាំក្នុងសៀវភៅណែនាំនេះ

ជាចំណុចបំពេញបន្ថែមដែលគាំទ្រពេញទំហឹងដល់គោលការណ៍ណែនាំថ្នាក់ជាតិ ពិធីសារ និងសៀវភៅណែនាំសម្រាប់ស្ថាប័ននានារបស់រាជរដ្ឋាភិបាលទាំងអស់ដែលទទួលខុសត្រូវលើការបន្តផ្តល់យុត្តិធម៌។

14. ខណៈដែលទិដ្ឋភាពមួយចំនួននៃសេវានគរបាលដែលគិតគូរពីយេនឌ័រនិងពាក់ព័ន្ធនឹងកុមារ ត្រូវបានលើកឡើងក្នុងសៀវភៅណែនាំនេះ គួរកត់សម្គាល់ថា ក្របខណ្ឌច្បាប់អន្តរជាតិដែលអនុវត្តចំពោះកុមារ គឺខុសពីក្របខណ្ឌច្បាប់ដែលអនុវត្តចំពោះស្ត្រី និងមនុស្សពេញវ័យ។ ដូច្នេះ អភិក្រមដែលគិតគូរពីកុមារ និងយេនឌ័រ និងការប្រព្រឹត្តដាក់ផ្សេងៗគ្នា គួរផ្តោតតែលើកុមារប៉ុណ្ណោះ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ កំណត់ថា កុមារជាមនុស្សគ្រប់រូបដែលមានអាយុក្រោម ១៨ ឆ្នាំ។ ក្មេងប្រុស និងក្មេងស្រីគួរទទួលបានអត្ថប្រយោជន៍ដូចគ្នាពីការការពារពិសេសដូចមានចែងក្នុងច្បាប់អន្តរជាតិ អនុលោមតាមចំណុចដៅទី១៦.២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(បញ្ឈប់អំពើហិង្សាគ្រប់ទម្រង់លើកុមារ)។ សម្រាប់ការណែនាំបន្ថែមស្តីពីសិទ្ធិកុមារ ដែលអាចយកជាឯកសារយោងបន្ថែមសម្រាប់អ្នកជំនាញក្នុងផ្នែកនេះ (ឧ. យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារក្នុងបរិបទនៃការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ២០១៥ កម្មវិធីបណ្តុះបណ្តាលរបស់ UNODC-UNICEF សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពីការប្រព្រឹត្តចំពោះកុមារដែលជាជនរងគ្រោះ និងជាសាក្សីនៃបទល្មើស)។

# ការធ្វើឱ្យមានភាពខុសគ្នា ក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម

"មានការពិតជាសកលមួយសម្រាប់ប្រទេស វប្បធម៌ និងសហគមន៍ទាំងអស់ ៖
អំពើហិង្សាលើស្ត្រីគឺមិនអាចទទួលយកបាន មិនអាចមានលេសដោះសារ
និងមិនអាចអត់ឱនបាន"។

អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន (២០០៨)

# គោលបំណងនៃជំពូកទី ២

**ពង្រឹងទស្សនៈវិស័យជាយុទ្ធសាស្ត្ររបស់នគរបាលក្នុងការអនុវត្តក្របខណ្ឌកញ្ចប់សេវា សំខាន់ៗដើម្បីធានាថាជនរងគ្រោះគ្រប់រូបដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានលទ្ធភាពទទួលបានសេវាសំខាន់ៗ និងមានការសម្របសម្រួលប្រកបដោយគុណភាព។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- យល់ពីអ្វីជាចំណុចស្នូលនៃការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី
- គោលការណ៍ក្របខណ្ឌកញ្ចប់សេវាសំខាន់ៗនិងលក្ខណៈរួមជាចំណុចស្នូលនៃការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ មានន័យថា ការស៊ើបអង្កេតនៅតែផ្តោតសំខាន់លើសកម្មភាពរបស់ជនបង្កដែលរងការចោទប្រកាន់មិនមែនបុគ្គលិកលក្ខណៈអាកប្បកិរិយាឬភាពអាចជឿទុកចិត្តបានរបស់ជនរងគ្រោះឡើយ។
- ការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចបណ្តាលមកពីភាពលម្អៀងយេនឌ័ររបស់នគរបាល ដែលអាចរាំងស្ទះដល់ការប្រឹងប្រែងរបស់ក្រុមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាប្រកបដោយប្រសិទ្ធភាព។
- នគរបាលឆ្លើយតបដំបូង និងមន្ត្រីទំនាក់ទំនងសហគមន៍ត្រូវទទួលបានសារដែលស៊ីសង្វាក់គ្នាពីថ្នាក់ដឹកនាំថា ការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីនឹងមិនត្រូវបានអត់ឱន និងប្រឈមនឹងផលវិបាកធ្ងន់ធ្ងរ។
- ការរៀបចំផែនការប្រតិបត្តិការដែលរួមបញ្ចូលការវិភាគដែលឆ្លើយតបនឹងយេនឌ័រ និងភាពប្រទាក់ក្រឡាគ្នា នឹងជួយបង្អាក់ការពង្រឹងការអនុវត្តបែបរើសអើងកន្លងមក។
- ការប្រមូលទិន្នន័យបែងចែកតាមភេទ និងសូចនាករ ជាគន្លឹះសំខាន់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ការប្តេជ្ញាចិត្តអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនឹងបង្កើនទំនុកចិត្ត និងកិច្ចសហការជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។



**សេចក្តីផ្តើម**

ជំពូកនេះមានគោលបំណងផ្តល់បរិបទសម្រាប់ការណែនាំក្នុងសៀវភៅណែនាំនេះ ដែលផ្តោតលើអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដែលជាអ្នកដាក់បទបញ្ជាប្រតិបត្តិការលើមន្ត្រីនគរបាលឆ្លើយតបក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ដើម្បីកំណត់បរិបទ ជំពូកនេះនឹងពង្រឹងទស្សនៈវិស័យជាយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដើម្បីជួយដល់ការអនុវត្តឬដំណើរការក្របខណ្ឌដែលផ្តល់ដោយអង្គការសហប្រជាជាតិ (កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា៖សមាសធាតុសំខាន់ៗនិងគោលការណ៍ណែនាំស្តីពីគុណភាព-ESP)។ក្របខណ្ឌនេះមានគោលបំណងផ្តល់លទ្ធភាពកាន់តែច្រើនដល់ជនរងគ្រោះគ្រប់រូបដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងការទទួលបានសេវានគរបាល សេវាយុត្តិធម៌ និងសេវាគាំទ្រសំខាន់ៗ និងមានការសម្របសម្រួល។

រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

ការណែនាំនេះមានគោលបំណងធ្វើឱ្យមានការផ្លាស់ប្តូរ។ ពេលគឺខិតខំបំផុសឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលក្លាយជាចលករនៃដំណើរការដែលផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រមិនស្មើភាពទៅជាវប្បធម៌នៃការបែងចែកអំណាច ការគ្រប់គ្រងធនធាន ការធ្វើសេចក្តីសម្រេចចិត្តនិងការគាំទ្រសម្រាប់ការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងសេវានគរបាលប្រចាំថ្ងៃ។

ដើម្បីសម្រេចគោលបំណងខាងលើជំពូកនេះនឹងបង្ហាញនិងកំណត់និយមន័យពាក្យគន្លឹះជាច្រើនក៏ដូចជាពិភាក្សាពីរបៀបដែលពាក្យទាំងនេះ (នៅពេលយកទៅប្រើប្រាស់) អាចរួមចំណែកដល់ឬប្រាស់ចាកពីការផ្លាស់ប្តូរដែលឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹយេនឌ័រនិងការប្រឹងប្រែងជារួមឆ្ពោះទៅរកការបង្កើតស្ថាប័ននគរបាលបែបទំនើប។ ពាក្យទាំងនេះត្រូវបានប្រើប្រាស់ក្នុងសៀវភៅណែនាំដើម្បីផ្តល់បរិបទដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល។

ជំពូកនេះនឹងបង្ហាញពីគោលការណ៍ និងលក្ខណៈទូទៅនៃក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ ដែលជាមូលដ្ឋាននៃការណែនាំ។គោលការណ៍និងលក្ខណៈទូទៅទាំងនេះនឹងជះឥទ្ធិពលលើសមត្ថភាពសំខាន់ៗនិងបណ្តុំជំនាញទន់ដែលត្រូវបានលើកឡើងក្នុងសៀវភៅណែនាំនេះ ព្រោះគោលការណ៍ និងលក្ខណៈទូទៅទាំងនេះឆ្លើយតបនឹងយេនឌ័រ និងផ្អែកតាមសិទ្ធិ។ ក្រៅពីនេះ មានការណែនាំគ្នាទៅវិញទៅមក និងឧទាហរណ៍សូចនាករដើម្បីជួយដល់ការអនុវត្ត និងពិនិត្យតាមដានសមត្ថភាព និងបណ្តុំជំនាញទន់ដែលស្នើឡើង។

សមត្ថភាពសំខាន់ៗនិងបណ្តុំជំនាញទន់ទាំងនេះកើតចេញពីការគូសផែនទីជាសកល ដែលជាការអង្កេត ឬការសម្ភាសន៍នគរបាលយ៉ាងច្រើនដែលកំពុងបម្រើការ និងមិនបម្រើការ ក៏ដូចជាអ្នកជំនាញផ្នែកយេនឌ័រ រួមទាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ/អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលធ្វើការជាមួយនគរបាល។ ព័ត៌មានដែលប្រមូលបានត្រូវបានធ្វើការប្រៀបធៀបបែបត្រីកោណទៅនឹងអនុសាសន៍នៃស្ថាប័ននគរបាល ក្នុងការពិនិត្យឡើងវិញ និងវាយតម្លៃយុទ្ធសាស្ត្រ អភិក្រម និងឧបករណ៍របស់ខ្លួនសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ករណីសិក្សាស្តីពីការពិនិត្យឡើងវិញ និងការវាយតម្លៃរបស់ស្ថាប័ននគរបាល ត្រូវបានជ្រើសរើសជាពិសេសសម្រាប់សៀវភៅណែនាំនេះក្នុងជំពូកខាងក្រោមព្រោះវាបង្ហាញពីការប្តេជ្ញាចិត្តជានាគណនេយ្យភាព តាមរយៈការដាក់បញ្ចូលអ្នកពាក់ព័ន្ធខាងក្រៅដូចជាអង្គការសង្គមស៊ីវិល អង្គការស្ត្រី ក៏ដូចជាស្ថាប័នសិក្សាស្រាវជ្រាវ និង/ឬក្រុមជនជាតិភាគតិចក្នុងដំណើរការទាំងនេះ។ ករណីសិក្សាទាំងនេះត្រូវបានជ្រើសរើសដោយផ្អែកតាមតម្លាភាពព្រោះករណីសិក្សាទាំងនេះអាចរកបានក្នុងប្រព័ន្ធអ៊ីនធឺណិតបើកទូលាយ។

## ការណែនាំគ្នាទៅវិញទៅមក

ក្នុងនាមអ្នកជាអ្នកគ្រប់គ្រងប៉ុស្តិ៍នគរបាលនាយកដ្ឋានឬស្រុកដែលផ្តល់សេវានគរបាលអ្នកមានការទទួលខុសត្រូវជារួមលើការឆ្លើយតបរបស់នគរបាលក្រោមឱវាទចំពោះស្ត្រី និងក្មេងស្រីដែលទទួលរងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ហេតុអ្វីត្រូវដោះស្រាយបទល្មើសទាំងនេះ? អ្នកនឹងមានអាទិភាពចំពោះមុខជាច្រើនខណៈដែលធនធានរបស់អ្នកមានកម្រិត។ ដូច្នេះ សេវាដែលអ្នកផ្តល់ជូនសហគមន៍មូលដ្ឋានត្រូវតែមានប្រសិទ្ធភាព។ បើគ្មានទំនុកចិត្ត និងភាពជឿជាក់ពីសហគមន៍មូលដ្ឋានទេ ការងាររបស់អ្នកក្នុងនាមជាមន្ត្រីនគរបាល នឹងកាន់តែលំបាក និងមិនងាយសម្រេចបានលទ្ធផល។

> **"ជាធម្មតា ជនភៀសខ្លួនជាស្ត្រីមិនត្រូវបានទទួលយកសម្រាប់ការព្យាបាលផ្នែក វេជ្ជសាស្ត្រ និងជាញឹកញាប់រងការប្រមាថនៅពេលពួកគាត់ទៅមន្ទីរពេទ្យនិងមិនទទួលបានការយកចិត្តទុកដាក់ពីនគរបាល នៅពេលដាក់បណ្តឹង"។**
> ***ករណីសិក្សា ៖ ការគាំទ្រជនរងគ្រោះជាជនភៀសខ្លួន ជនជាតិអាស៊ី ជនជាតិស្បែកខ្មៅ ជនជាតិភាគតិច និងជាតិពន្ធ***
> (Imkaan ចក្រភពអង់គ្លេស)

ការសិក្សាថ្នាក់ជាតិភាគច្រើនស្តីពីកម្រិតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានបញ្ជាក់ថា ស្ត្រីភាគច្រើនមិនបានរាយការណ៍ពីបញ្ហារបស់ខ្លួនទៅសេវាផ្លូវការឡើយ។



រូបថតទទួលបានពី Force International (ប្រទេសបង់ក្លាដេស)

មានករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតែមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានរាយការណ៍ទៅនគរបាលហើយមានករណីតិចតួចដែលនាំទៅរកការចោទប្រកាន់លើជនបង្ក និងមានករណីកាន់តែតិចទៅទៀតដែលឈានដល់ការផ្តន្ទាទោស។ យោងតាមរបាយការណ៍ឆ្នាំ ២០១៥ ដែលចេញផ្សាយដោយ UNDESA ក្នុងប្រទេសភាគច្រើនដែលមានទិន្នន័យមានស្ត្រីតែ៤០%ប៉ុណ្ណោះដែលស្វែងរកជំនួយណាមួយបន្ទាប់ពីទទួលរងអំពើហិង្សា។ ក្នុងចំណោមនេះ ស្ត្រីភាគច្រើនពឹងពាក់គ្រួសារ និងមិត្តភក្តិ ប៉ុន្តែមិនពឹងពាក់ស្ថាប័ន និងយន្តការផ្លូវការឱ្យផ្តល់ជំនួយនេះឡើយ។ ក្នុងចំណោមស្ត្រីដែលស្វែងរកជំនួយបន្ទាប់ពីទទួលរងអំពើហិង្សា មានស្ត្រីមិនដល់ ១០% ទេដែលស្វែងរកជំនួយពីនគរបាល។

ការស្ទាក់ស្ទើរមិនរាយការណ៍ពីឧប្បត្តិហេតុ និងស្វែងរកជំនួយ អាចដោយសារតែអំពើហិង្សាលើស្ត្រី និងក្មេងស្រីត្រូវបានទទួលយកជាទូទៅ និងពាក់ព័ន្ធផងដែរនឹង "ការស្តីបន្ទោសនិងការបង្កភាពអាម៉ាស់"លើជនរងគ្រោះជាច្រើន បន្ទាប់ពីពួកគេប្រឈមនឹងអំពើហិង្សា និងកង្វះទំនុកចិត្តថានឹងមានការពិចារណាដិតដល់លើបណ្តឹងរបស់ខ្លួន។ ក្រៅពីនេះ វាអាចបណ្តាលមកពីកង្វះចំណេះដឹងរបស់ស្ត្រី និងក្មេងស្រីស្តីពីសេវា និង/ឬសិទ្ធិដែលមាន។

ការរាយការណ៍ពីចំនួនករណីដែលមានតិចជាងចំនួនករណីពិតប្រាកដឃើញថាមានភាពស្រួចស្រាវក្នុងចំណោមក្រុមមួយចំនួនដែលប្រឈមនឹងការរើសអើងក្នុងទម្រង់ចម្រុះ និងប្រទាក់ក្រឡា ដែលធ្វើឱ្យពួកគេងាយប្រឈម

នឹងការទទួលរងអំពើហិង្សា។ ៤.៤បសគ្គទំនាក់ទំនងសម្រាប់ស្ត្រីនិងក្មេងស្រីមានពិការភាពដែលអាចបង្កផលប៉ះពាល់លើគំហើញការស្តាប់ឬការយល់ដឹងរបស់ពួកគេធ្វើឱ្យស្ត្រីនិងក្មេងស្រីទាំងនោះងាយរងគ្រោះដោយសារការដែលជឿថា ពួកគេមិនអាចដាក់បណ្តឹងបាន[16] ។

## រូប ១ ៖ និយមន័យនៃអំពើហិង្សាលើស្ត្រី [17]

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ**

អំពើហិង្សាលើស្ត្រី ជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រោះវាបង្កឡើងដោយអតុល្យភាពអំណាច រវាងស្ត្រី និង បុរស ជំនឿ និងក្តីរំពឹងទុកដ៏តូចចង្អៀតអំពីការប្រព្រឹត្តរបស់ស្ត្រី និងបុរស។

**ការបង្កការឈឺចាប់លើស្ត្រី**

អំពើហិង្សាទាក់ទងនឹងយេនឌ័រ ភាគច្រើនលើសលប់ បង្កឡើងដោយបុរសលើស្ត្រី។បុរសក៏អាចរងគ្រោះដោយអំពើហិង្សា ដែលប្រព្រឹត្តដោយស្ត្រីផងដែរ ប៉ុន្តែវាជាករណីកម្រ។

**តើអ្វីជាអំពើហិង្សាលើស្ត្រី?**

“ការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបង្កជា ឬនឹងបង្កជាគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី មិនថាកើតឡើងក្នុងជីវិតសាធារណៈ ឬជីវិត ឯកជននោះទេ។”

មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៣

**ការឈឺចាប់ផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត**

អំពើហិង្សាលើស្ត្រីអាចមានទម្រង់ជាច្រើន ដូចជាការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានផ្លូវចិត្ត ឬផ្លូវអារម្មណ៍។

**កើតឡើងក្នុងជីវិតសាធារណៈ ឬជីវិតឯកជន**

អំពើហិង្សាលើស្ត្រីគ្រប់ទម្រង់គឺមិនអាចទទួលយកបានឡើយ និងត្រូវបញ្ឈប់ជាបន្ទាន់ មិនថាអំពើហិង្សាទាំងនោះកើតឡើងនៅក្នុងផ្ទះឬនៅទីសាធារណៈនោះទេ។

សេវានគរបាលផ្តោតសំខាន់លើការផ្តល់សុវត្ថិភាព និងសន្តិសុខដល់សហគមន៍មូលដ្ឋានតាមរយៈការធ្វើការជាមួយ និងដើម្បីសហគមន៍ ការកសាងទំនុកចិត្ត ការអនុលោមតាមច្បាប់ការទប់ស្កាត់បទល្មើសការឆ្លើយតបទៅនឹងគ្រោះអាសន្ន ការផ្តល់សេវាគាំទ្រ និងការថែរក្សាសង្គមដែលមានសន្តិភាព។ ដើម្បីឱ្យមានប្រសិទ្ធភាពពិតប្រាកដ នគរបាលត្រូវការការគាំទ្រពីសហគមន៍មូលដ្ឋាន។ ធ្វើដូច្នេះទើបនគរបាលអាចទទួលបានព័ត៌មាន និងចារកម្មសំខាន់ៗ និងឈានដល់ការស៊ើបអង្កេត និងការទប់ស្កាត់បទល្មើសទាំងអស់ប្រកបដោយជោគជ័យ។

ស្ត្រី និងក្មេងស្រីគឺជាមូលដ្ឋានគ្រឹះរបស់សហគមន៍ជាច្រើន។ ប្រសិនបើអ្នកមិនទទួលបានទំនុកចិត្ត និងភាពជឿជាក់ពីប្រជាជនមូលដ្ឋានយ៉ាងតិច ៥០% ទេនោះ តើអ្នកនឹងបាត់បង់អ្វីដែលអាចជាព័ត៌មាន និងចារកម្មច្រើនប៉ុណ្ណា? តើអ្នកអាចធានានូវលទ្ធផលដែលមានប្រសិទ្ធភាពដោយរបៀបណា? ព័ត៌មាននិងចារកម្មទាន់ពេលវេលា សុក្រឹត ងាយស្រួលទទួលបាន និងអាចជឿទុកចិត្តបាន នឹងជួយដល់អ្នកក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសគ្រប់ប្រភេទរួមទាំងទម្រង់ជាច្រើននៃបទល្មើសដែលមានអង្គការចាត់តាំងនិងការប្រឆាំងនឹងអំពើហិង្សាជ្រុលនិយម។ ដូច្នេះ អ្នកមិនត្រូវមើលស្រាលអត្ថប្រយោជន៍នៃការឆ្លើយតបដោយប្រសិទ្ធិភាពដោយបុគ្គលិករបស់អ្នកទាក់ទងទៅនឹងបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីនោះទេ។

16.សូមមើល “ការសិក្សាតាមប្រធានបទស្តីពីបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងពិការភាព។ របាយការណ៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស” ( A/HRC/20/5 )

17.សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ( សេចក្តីសម្រេចលេខ ៤៨/១០៤ របស់មហាសន្និបាត ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ) មាត្រា ១-២។

**អ្នកដឹកនាំអាចបណ្ដុះគំនិតថ្នាក់ក្រោមរបស់ខ្លួន។ អ្នកដឹកនាំមានទាំងសមត្ថភាពផ្នែកបច្ចេកទេស និងភាពជាមនុស្ស ដែលទទួលបានការគោរពកោតសរសើរពីអ្នកផងទាំងពួង។**

មន្ត្រីនគរបាលមានភារកិច្ចប្រកបដោយក្រមសីលធម៌ក្នុងការធានាការពារសិទ្ធិរបស់ជនរងគ្រោះគ្រប់រូបដោយមិនគិតពីសាវតាររបស់ពួកគេ។ ជាញឹកញាប់ សហគមន៍មានលក្ខណៈចម្រុះ ដូច្នេះ អភិក្រមសេវានគរបាលត្រូវគិតគូរ និងឆ្លើយតបទៅនឹងលក្ខណៈចម្រុះនេះ ដូចជា ការយល់ថា ក្នុងសហគមន៍មានបុគ្គលជាច្រើនដែលត្រូវបានផាត់ចេញ និងជួបការលំបាកតាមរបៀបចម្រុះ និង ប្រទាក់ក្រឡា ហើយពួកគេកាន់តែងាយទទួលរងអំពើហិង្សា។ ៤.បុគ្គលនិងក្រុមមួយចំនួនអាចជួបការលំបាកដោយសារកត្តាផ្សេងៗ ដូចជា យេនឌ័រ អាយុ ជាតិពន្ធុ ទំនោរផ្លូវភេទ ដើមកំណើតជាតិ និង/ឬពិការភាពរបស់ខ្លួន ហើយកត្តាទាំងនេះអាចបង្កផលប៉ះពាល់ផ្ទាល់លើលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសុវត្ថិភាពសន្តិសុខនិងយុត្តិធម៌ ។ដើម្បីធានាការគោរពសេចក្តីថ្លៃថ្នូរនិងឯកជនភាពរបស់ជនរងគ្រោះគ្រប់រូប និងធានាការផ្ដោតអាទិភាពលើសុវត្ថិភាព និង សន្តិសុខផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ មន្ត្រីនគរបាលគួរពិចារណា និងគិតគូរពីបទពិសោធន៍ និង កាលៈទេសៈចម្រុះរបស់បុគ្គលម្នាក់ៗ[18] ។

ដូច្នេះ ការសំខាន់គឺអ្នក និងបុគ្គលិករបស់អ្នកត្រូវយល់ពីសមាសធាតុស្មុគស្មាញនៃសហគមន៍ មូលដ្ឋានរបស់អ្នក ដើម្បីកំណត់កត្តាផ្សេងៗដែលអាចរួមចំណែកដល់ការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

តើមានជនជាតិអ្វីខ្លះក្នុងតំបន់ប្រតិបត្តិការរបស់អ្នក? តើអ្នកដឹងថាតើទំនាក់ទំនងរបស់ជនរងគ្រោះទៅនឹងប្រពៃណី ជំនឿ និង/ឬវប្បធម៌ អាចជះឥទ្ធិពលដូចម្តេចលើទិដ្ឋភាពទាំងអស់នៃជីវិតរបស់ពួកគេ ដូចជាថាតើពួកគេស្វែងរកជំនួយ ឬទេ? ប្រសិនបើមិនដឹង តើអ្នកអាចធានាដូចម្តេចថា បុគ្គលិករបស់អ្នកកំពុងផ្តល់សេវានគរបាលដែលមានប្រសិទ្ធភាព? តើអ្នកយល់ពីសាវតាររបស់ជនរងគ្រោះដោយសារបទល្មើស ឬទេ? តើអាចបែងចែកទិន្នន័យរបស់ជនរងគ្រោះទៅតាមប្រភេទបទល្មើស យេនឌ័រ អាយុ ជាតិពន្ធុ ពិការភាព សាសនា សម្ព័ន្ធភាព និងតំបន់បានដែរ ឬទេ? ៤. អ្នកត្រូវការទិន្នន័យច្បាស់លាស់ដើម្បីកំណត់ថាតើមានអតុល្យភាពរវាងអ្វីដែលអាចជាតម្រូវការរបស់ជនរងគ្រោះ និងការរកបានមន្ត្រីដែលមានការបណ្តុះបណ្តាលគ្រប់គ្រាន់ ឬទេ។

សៀវភៅណែនាំនេះកត់សម្គាល់ពីផលប៉ះពាល់វិជ្ជមាននៃការដឹកនាំប្រកបដោយគុណភាពដែលមានលើជនរងគ្រោះតាមរយៈការសម្របសម្រួលសេវាពហុវិស័យប្រកបដោយប្រសិទ្ធភាព។ជំពូកនេះផ្តល់ជាមូលដ្ឋានសម្រាប់ការយល់កាន់តែច្បាស់ពីអភិក្រម ជំនាញ និងសមត្ថភាពសំខាន់ៗដែល ស្ថាប័ននគរបាល និងអ្នកជំនាញផ្សេងទៀតដែលធ្វើការក្នុងវិស័យនេះ កំណត់យកជាចំណុចស្នូលនៃការផ្លាស់ប្តូរទៅរកសេវានគរបាលដែលកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបនឹងយេនឌ័រ តាមរយៈការឆ្លុះបញ្ចាំង និង ការរៀនសូត្រក្នុងស្ថាប័ន។

អភិក្រម បណ្តុំជំនាញ និងសមត្ថភាពដែលលើកឡើងក្នុងជំពូកនេះ និងសៀវភៅណែនាំទាំងមូល នឹងរំលេច **គោលការណ៍**នៃក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ ដែលគូសបញ្ជាក់ពីសេវានគរបាលនិងសេវាយុត្តិធម៌សំខាន់ៗទាំងអស់ (សូមមើលរូប ២)។ ការណែនាំក្នុងសៀវភៅណែនាំនេះយោង**តាមលក្ខណៈទូទៅ** (សូមមើលរូប ២) ដែលកញ្ចប់សេវាសំខាន់ៗកំណត់ជាមូលដ្ឋាននៃសកម្មភាព និងអភិក្រមទាំងអស់នៅគ្រប់ផ្នែកនៃការបំពេញមុខងារ និងការផ្តល់សេវាសំខាន់ៗ។

18. សូមមើលកំណត់សម្គាល់ទី ២។

## រូប ២ ៖ គញ្ចប់សេវាសំខាន់ៗ ៖ ដ្យាក្រាមក្របខណ្ឌរួម

| | | | |
|---|---|---|---|
| **គោលការណ៍** | អភិក្រមផ្អែកតាមសិទ្ធិ | ការពង្រឹងសមភាពយេនឌ័រ និង ការបង្កើនភាពអង់អាចរបស់ស្ត្រី | សមស្រប និងគិតគូរពីវប្បធម៌ និងអាយុ |
| | អភិក្រមអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះតាមសិទ្ធិ | សុវត្ថិភាពជាចម្បង | ការទទួលខុសត្រូវរបស់ជនបង្ក |

| | | |
|---|---|---|
| **លក្ខណៈទូទៅ** | ភាពអាចរកបាន | ភាពអាចទទួលបាន |
| | ភាពអាចសម្របតាមបាន | ភាពសមស្រប |
| | ផ្តោតលើអាទិភាពសុវត្ថិភាព | ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ |
| | ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន | ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |
| | ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល | |

ការអនុលោមតាមគោលការណ៍នៃក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ និងលក្ខណៈទូទៅនឹងក្លាយជាចំណុចស្នូលនៃការជានាការ**ចូលរួមប្រកបដោយអត្ថន័យ**របស់ជនរងគ្រោះក្នុងការស៊ើបអង្កេតបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ភាពអនុលោមតាមមិនត្រឹមតែជាកត្តាកំណត់ក្នុងការស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ញើសារដ៏សំខាន់ដល់សហគមន៍ថា នគរបាលពិចារណាផិតដល់លើការរាយការណ៍របស់ជនរងគ្រោះតាមរយៈការអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនៅពេលមានការចោទប្រកាន់ពីករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ជាលទ្ធផល ជនរងគ្រោះ សហគមន៍របស់ពួកគេ និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតនឹងយល់ថា ស្ថាប័នរបស់អ្នកជាស្ថាប័នស្របច្បាប់ ពាក់ព័ន្ធនឹងការ កសាងទំនុកចិត្ត និងការពង្រឹងភាពជាដៃគូក្នុងការឆ្លើយតបទៅនឹងបទល្មើស។

ការសំខាន់គឺនគរបាលត្រូវក្លាយជាផ្នែកមួយនៃដំណោះស្រាយ ដែលជនរងគ្រោះ និងសហគមន៍របស់ពួកគេយល់ថា ពួកគេទទួលបានសិទ្ធិអំណាចក្នុងការបង្ហាញពីក្តីរំពឹងទុក និងតម្រូវការរបស់ខ្លួនពាក់ព័ន្ធនឹងការទទួលបានយុត្តិធម៌សម្រាប់ករណីពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការបង្កើនទំនុកចិត្តតាមរយៈការបង្កើនសិទ្ធិអំណាចធ្វើឱ្យជនរងគ្រោះដោយសារអំពើហិង្សាដោយដៃគូស្និទ្ធស្នាល ងាយនឹងរាយការណ៍ករណី និងបង្ហាញភស្តុតាងក្នុងតុលាការ[19] ។

សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងបទល្មើសផ្សេងទៀតគ្របដណ្តប់លើសកម្មភាពទប់ស្កាត់និងសកម្មភាពស៊ើបអង្កេតរបស់នគរបាល។

### បញ្ហាប្រឈមក្នុងស្ថាប័ននគរបាលនៅពេលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

"ឫសគល់ទូទៅមួយនៃបរាជ័យរបស់នគរបាលក្នុងការស៊ើបអង្កេតករណីស្ត្រីដែលបាត់ខ្លួនគឺកង្វះបុគ្គលផ្តើមក្នុងស្ថាប័ន។ ខ្ញុំប្រើពាក្យ "ភាពចាំបាច់" នៃការដឹកនាំ ដើម្បីគូសបញ្ជាក់ពីការស៊ើបអង្កេតដែលត្រូវមានការដឹកនាំ ហើយការដឹកនាំជាអ្វីដែលត្រូវការជាចាំបាច់។ ខណៈដែលខ្ញុំប្រើពាក្យ "កង្វះការដឹកនាំ" ព្រោះពាក្យនេះងាយ

19. Nathan Birdsall, Stuart Kirby and Michelle McManus (2017), 'Police - victim engagement in building a victim empowerment approach to intimate partner violence cases' (Police Practice and Research, 18:1, 75-86) and Roberts, J., and Hough, M. (2005), 'Understanding public attitudes to criminal justice', (Maidenhead: Open University Press). VOLUME IIB, 'Nobodies: How and Why We Failed the Missing and Murdered Women Part 3, 4 and 5' (British Columbia, Canada, 2012).

និយាយចេញ ហើយវាមិនមានអំណាចដូចគ្នានោះទេ។ បញ្ហានេះមានទំហំធំធេងណាស់។ វាមិនត្រឹមតែជាបញ្ហានៃភាពគ្រប់គ្រាន់នោះទេ ប៉ុន្តែជាបញ្ហានៃភាពគ្មានការដឹកនាំ”[6]។

ស្នងការ Wally T. Oppal, Q.C., ក្នុងរបាយការណ៍របស់គាត់ដែលមានចំណងជើងថា "FORSAKEN-របាយការណ៍ របស់គណៈកម្មការស្រាវជ្រាវរកស្ត្រីដែលបាត់ខ្លួន"[20] ។

**“នៅពេល [ស្ត្រីម្នាក់] ទៅរកនគរបាល ដំបូង នគរបាលសួររកអត្តសញ្ញាណប័ណ្ណរបស់គាត់ រួចសួរថា ៖ ដូចម្តេច? ហេតុអ្វី? អ្វី?... នៅពេលចាប់ផ្តើមដំបូង នគរបាលធ្វើដូចជាគាត់ទទួលខុសត្រូវលើអ្វីដែលបានកើតឡើងចំពោះខ្លួនគាត់។**

ស្ត្រីអាយុ ៣៨-៥៥ ឆ្នាំ មកពីតំបន់ប្រជុំជនដែលរងផលប៉ះពាល់ដោយសារជម្លោះនៅបូស្នី និងហឺហ្សេហ្គូវីណា

ប្រភព ៖ ការអង្កេតដែលដឹកនាំដោយ OSCE ស្តីពីអំពើហិង្សាលើស្ត្រី ៖ របាយការណ៍គោល (OSCE, Vienna, 2019)

កង្វះការឆ្លើយតបរបស់ស្ថាប័នអនុវត្តន៍ច្បាប់នៅតែជាបញ្ហាប្រឈមដ៏ធំមួយក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលនាំទៅរកនិទណ្ឌភាពសម្រាប់ជនបង្ក កង្វះការបែងចែកធនធានដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងកង្វះការពិនិត្យតាមដាន និងសម្របសម្រួលគំនិតផ្តួចផ្តើមសម្រាប់ដោះស្រាយបញ្ហានេះ។

បទពិសោធន៍មិនល្អសម្រាប់ជនរងគ្រោះអាចបង្កអន្តរាយធ្ងន់ធ្ងរដល់ទំនុកចិត្ត និងភាពជឿជាក់របស់សហគមន៍ទាំងមូលលើនគរបាល និងអាចបង្កការលំបាកដល់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចក្រភពអង់គ្លេសផ្តល់បទពិសោធន៍រៀនសូត្រល្អៗចេញពីការពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃអភិក្រមសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីផ្ទាល់។

នៅឆ្នាំ ២០១៣ UK Home Secretary បានបញ្ជាឱ្យអធិការដ្ឋាននគរបាលមហាក្សត្រី (HMIC)[21] ចុះធ្វើអធិការកិច្ចលើការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាក្នុងគ្រួសារ បន្ទាប់ពីទទួលបានបន្ទុកករណីធំៗដែលការការពារជនរងគ្រោះ មានកម្រិតក្រោមស្តង់ដាររំពឹងទុក។

ចំណុចខាងក្រោមដែលផ្អែកតាមលទ្ធផលរកឃើញក្នុងរបាយការណ៍ចុងក្រោយ[22] (២០១៤) របស់ HMIC គូសបញ្ជាក់ពីបរាជ័យរបស់ស្ថាប័នមួយចំនួន ថានៅពេលអ្នកគ្រប់គ្រងក្នុងជួរនគរបាលមិនធ្វើការដោះស្រាយ វាជាការឆ្លើយតបដែលគ្មានប្រសិទ្ធភាពទៅនឹងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**“ខ្ញុំយល់ថា ស្ត្រីមិនស្វែងរកជំនួយពីស្ថាប័នទេ ព្រោះពួកគាត់មិនទុកចិត្តស្ថាប័នទាំងនោះ។ ខ្ញុំមិនដែលលឺពីលទ្ធផលវិជ្ជមានឡើយ។ ខ្ញុំមិនដែលបានលឺថាស្ត្រីទទួលបានជំនួយពីស្ថាប័ននោះទេ។ ខ្ញុំមិនទុកចិត្តស្ថាប័នទាំងនោះទេ”។**

ស្ត្រីអាយុ ៣០-៥០ ឆ្នាំ មកពីទីជនបទ ប្រទេសម៉ុងតេណេហ្គ្រោ

ប្រភព ៖ ការអង្កេតដែលដឹកនាំដោយ OSCE ស្តីពីអំពើហិង្សាលើស្ត្រី ៖ របាយការណ៍គោល (OSCE, Vienna, 2019)

- ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ មិនអាចបញ្ជាក់ច្បាស់ពីយុទ្ធសាស្ត្រស្នូលសម្រាប់ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជាលទ្ធផល បានដាក់គោលដៅដែលមិនអាចសម្រេចបានសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល និងមិនផ្តល់ធនធានគ្រប់គ្រាន់សម្រាប់ការធ្វើប្រតិបត្តិការដោយឯករាជ្យ និងកាន់តែមានប្រសិទ្ធភាព។
- ថ្នាក់គ្រប់គ្រង ដែលទោះជាបានដឹងពីបញ្ហា ឬចំណុចខ្វះខាតក្នុងយុទ្ធសាស្ត្ររបស់ខ្លួនក្តីក៏មិនបានចាត់វិធានការដោះស្រាយ (ឧ.ការអត់ឱនចំពោះការនិយាយប្រមាថដោយមន្ត្រីពាក់ព័ន្ធលើមនុស្ស ឬក្រុមមួយចំនួន[23])។

21. នាដើរខែក្តៅ ឆ្នាំ ២០១៧ HMIC បានចុះធ្វើអធិការកិច្ចសេវាពន្លត់អគ្គីភ័យ និងសង្គ្រោះរបស់អង់គ្លេសដើម្បីវាយតម្លៃ និងរាយការណ៍ពីប្រសិទ្ធផល ប្រសិទ្ធភាព និងការដឹកនាំរបស់សេវាទាំងនេះ។ ដើម្បីឆ្លុះបញ្ចាំងពីតួនាទីថ្មីនេះ HMIC បានប្តូរឈ្មោះទៅជាអធិការដ្ឋាននៃសេវាពន្លត់អគ្គីភ័យនិងសង្គ្រោះនៃនគរបាលមហាក្សត្រី (HMICFRS)។
22. សូមមើល ‘កិច្ចការរបស់មនុស្សគ្រប់រូប ៖ ការបង្កើនការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ’ (HMIC, 2014)។

**ភាពជាអ្នកដឹកនាំផ្តោតសំខាន់លើការមានភាពប្រតិសកម្ម និងការកសាងភាពជាដៃគូដើម្បីដោះស្រាយបញ្ហាកង្វះធនធាន។**

- មន្រ្តីបញ្ជាការនៅកម្រិតខ្ពស់ និងកម្រិតកណ្តាល មិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីច្បាប់ថ្មីដែលបង្កផលប៉ះពាល់ផ្ទាល់លើយុទ្ធសាស្រ្តទប់ស្កាត់ និងនីតិវិធីស៊ើបអង្កេតរបស់នគរបាលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការសំខាន់គឺអ្នកគ្រប់គ្រងក្នុងជួរនគរបាលត្រូវទទួលបានការបណ្តុះបណ្តាលស្តីពីថាតើពួកគេនិងបុគ្គលិករបស់ពួកគេត្រូវអនុវត្តច្បាប់ថ្មីដោយរបៀបណា ដើម្បីលើកឡើងពីសមភាពយេនឌ័រ និងបង្កើនការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក។
- ខណៈដែលមានការបង្ហាញច្បាស់ថា អាទិភាពផ្តោតលើបទល្មើសធំៗមានមេបញ្ជាការនគរបាលតែមួយចំនួនតូចប៉ុណ្ណោះដែលអាចផ្តល់សារយុទ្ធសាស្រ្តច្បាស់លាស់ស្តីពីរបៀបដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងស្តង់ដារគុណភាពអប្បបរមាដែលចាំបាច់សម្រាប់ការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ភស្តុតាងដែលបញ្ជាក់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនមែនជាអាទិភាព ស្តែងឡើងក្នុងរបៀបដែលមន្ត្រីជួរមុខ (ឬមន្ត្រីឆ្លើយតប) ត្រូវបានប្រជុំពិភាក្សាមុនចាប់ផ្តើមសកម្មភាពនិងចាត់តាំងភារកិច្ច។
- រចនាសម្ព័ន្ធស្ថាប័ន អង្គភាព និងនាយកដ្ឋានដែលមានភាពបែកខ្ញែក និងមិនច្បាស់លាស់ ធ្វើឱ្យបុគ្គលិកជួរមុខមានចំណេះដឹងតិចតួចស្តីពីបុគ្គលក្នុងស្ថាប័នដែលទទួលខុសត្រូវលើការស៊ើបអង្កេតអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយប្រសិទ្ធភាពការផ្តន្ទាទោសជនល្មើស និងសុវត្ថិភាពរបស់ជនរងគ្រោះ។
- សូម្បីតែក្នុងករណីដែលមានការបង្ហាញសារ និងអាទិភាពច្បាស់លាស់នៅកម្រិតកំពូលរបស់ស្ថាប័នក៏ដោយ ក៏វប្បធម៌នៃការគ្រប់គ្រងការអនុវត្តការងារ ធ្វើឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ផ្តោតសំខាន់ទៅតែលើបទល្មើសធំៗ មិនមែនការរំលោភបំពានក្នុងគ្រួសារ ដូចជាអំពើហិង្សាអន្តរបុគ្គលនោះទេ។
- មេបញ្ជាការនគរបាលមាន "ទស្សនៈវិស័យតូចចង្អៀត" ពោលគឺផ្តោតសំខាន់លើបទល្មើសតែមួយ និងការគ្រប់គ្រងជនបង្កជាជាងការផ្សារភ្ជាប់បទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីទៅនឹងអ្វីដែលអាចជាសកម្មភាពឧក្រិដ្ឋផ្សេងទៀត និងការរក្សាសុវត្ថិភាពរបស់ជនរងគ្រោះ។
- កង្វះការត្រួតពិនិត្យលើរបៀបដែលនគរបាលធ្វើការបញ្ជូនជាកត្តារាំងស្ទះការយល់ដឹងស៊ីជម្រៅពីមូលហេតុដែលនគរបាលបញ្ជូនជនរងគ្រោះទៅរកសេវាសង្គម ជាជាងសម្របសម្រួលឱ្យពួកគេទទួលបានដំណោះស្រាយផ្លូវច្បាប់។

**ការអនុវត្តច្បាប់តាមរបៀបដែលស៊ីសង្វាក់គ្នា និងមិនលម្អៀងជាយុទ្ធសាស្រ្តទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាពបំផុតរបស់នគរបាល។**

សារដ៏សំខាន់មួយពីរបាយការណ៍ឆ្នាំ ២០១៤ របស់ HMIC សម្រាប់អ្នកគ្រប់គ្រងក្នុងជួរនគរបាលគឺត្រូវធានាថា សម្រាប់បទល្មើសនេះ ក៏ដូចជាបទល្មើសផ្សេងទៀត ចំណុចសំខាន់គឺសកម្មភាពរបស់ជនបង្ក មិនមែនចរិតលក្ខណៈ ឥរិយាបថ ឬភាពអាចជឿទុកចិត្តបានរបស់ជនរងគ្រោះនោះទេ[24]។

របាយការណ៍នេះបន្ថែមទៀតថា ខណៈដែលកន្លងមកការស៊ើបអង្កេតផ្តោតសំខាន់លើឥរិយាបថរបស់ជនរងគ្រោះ តថភាពនៃបទល្មើសដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីគឺ ជាញឹកញាប់ ជនរងគ្រោះស្គាល់ជនបង្កដែលរងការចោទប្រកាន់ ហើយនគរបាលអាចកំណត់

23. ការនិយាយប្រមាថ ជាពិសេសការប្រមាថស្ត្រី ហាក់កាន់តែទូលំទូលាយ នៅពេលដែលច្បាប់ជាតិដែលគាំទ្រសមភាពយេនឌ័រ ក្លាយជាកម្មវត្ថុនៃការជជែកដេញដោលជាសាធារណៈ។ នៅអំឡុងពេលនោះហើយដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាល គួរឆ្លើយតបទៅនឹងការនិយាយប្រមាថទាំងនោះក្នុងជួរនគរបាលនិងមានភាពប្រតិសកម្មជាងមុនដោយពន្យល់ពីអត្ថន័យនៃច្បាប់ថ្មីដែលត្រូវអនុវត្ត និងការពារស្ត្រី និងក្មេងស្រី។

24. សូមមើលកំណត់សម្គាល់ទី ៩។

អត្តសញ្ញាណរបស់ជនបង្កបានយ៉ាងងាយ។ តាមទ្រឹស្តី ចំណុចនេះអាចឱ្យនគរបាលយកជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេតលើសកម្មភាពរបស់ជនបង្កដែលរងការចោទប្រកាន់ដែលគួរតែនាំមកជួបជាមួយនគរបាលស៊ើបអង្កេតដូចជនរងគ្រោះដែរ។

សម្រាប់ផ្នែកភាគច្រើននិងមិនគិតពីការបែងចែកធនធានទូទៅ បញ្ហាប្រឈមក្នុងស្ថាប័ននគរបាល ដូចជា បញ្ហាដែលលើកឡើងខាងលើ អាចរងឥទ្ធិពលវិជ្ជមានពីអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលក្នុងស្ថាប័ននោះ។ ដូច្នេះអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដែលមានតួនាទីបញ្ជា និងដឹកនាំ ត្រូវផ្សារភ្ជាប់គោលនយោបាយរបស់ស្ថាប័នទៅនឹងការអនុវត្តផ្នែកប្រតិបត្តិការនិងទទួលខុសត្រូវទាំងលើអ្នកស៊ើបអង្កេត និងការស៊ើបអង្កេត។

ភាគច្រើន ថ្នាក់ដឹកនាំនគរបាល រួមទាំងអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលអាចតាមដានការកាត់បន្ថយផលប៉ះពាល់ទូទៅដែលបណ្តាលមកពីបញ្ហាផ្ទៃក្នុងទាំងនេះ នៅពេលឆ្លើយតបនឹងបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ឧទាហរណ៍នៃវិធានការកាត់បន្ថយផលប៉ះពាល់រួមមាន ប៉ុន្តែមិនកំណត់ត្រឹម ៖

- ➢ ការកំណត់វិធានការជាសមូហភាពឱ្យផ្តោតលើការយល់ច្បាស់ពីឫសគល់នៃអំពើហិង្សា ឫសគល់ និងផលវិបាកនៃអំពើហិង្សានិងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នានិងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រីនិងក្មេងស្រី។
- ➢ ការមានភាពប្រតិសកម្មក្នុងការទទួលខុសត្រូវលើការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេត នៅពេលមានការចោទប្រកាន់ពីករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ➢ ការធានាការពង្រឹងអន្តរាគមន៍មិនលម្អៀង និងរៀសរវៃ ដោយមន្ត្រីនគរបាលឆ្លើយតប តាមរយៈការរៀនសូត្រជាប្រចាំ និងការពិគ្រោះជាមួយក្រុមរងផលប៉ះពាល់។

ដូចការបញ្ជាក់ក្នុងរបាយការណ៍ឆ្នាំ២០១៤របស់HMIC ផលវិបាកនៃការមិនដោះស្រាយ បញ្ហាប្រឈមផ្ទៃក្នុងទាំងនេះនឹងនាំទៅរកការចោទប្រកាន់ជាពិសេស ពីស្ត្រីនិងក្មេងស្រីពីការរំលោភសិទ្ធិពលរដ្ឋ ឬសិទ្ធិមនុស្ស កង្វះទំនុកចិត្តលើស្ថាប័ននគរបាលផ្ទាល់និងកង្វះភាពអាចជឿទុកចិត្តបានរបស់នគរបាល ។

កង្វះទំនុកចិត្ត និងភាពអាចជឿទុកចិត្តបានលើស្ថាប័ននគរបាល នឹងធ្វើឱ្យផលប៉ះពាល់ដល់ សមត្ថភាពនៃក្រុមរបស់អ្នកក្នុងការប្រមូលព័ត៌មានចាំបាច់ដែលផ្អែកតាមចារកម្ម។

ឧ.ដំណោះស្រាយតាមសហគមន៍លើអន្តរាគមន៍បទល្មើសនានា នឹងចុះខ្សោយទៅតាមភាពផុយស្រួយនៃភាពជាដៃគូរបស់អ្នកជាពិសេសភាពជាដៃគូជាមួយស្ថាប័នដែលតំណាងឱ្យបុគ្គល ឬក្រុមដែលយល់ថាទទួលបានសេវានគរបាលច្រើនពេក ឬតិចពេក។

> **“មន្ត្រីនគរបាលមិនមានចំណេះដឹងឯកទេសគ្រប់សព្វនោះទេ ប៉ុន្តែពួកគេត្រូវដឹងពីកន្លែងដែលត្រូវបញ្ជូនជនរងគ្រោះ។ ឧ. សេវាឯកទេសគាំទ្រការរំលោភបំពានក្នុងគ្រួសារ គឺជាញឹកញាប់ គ្រប់គ្រងដោយក្រុមសហគមន៍សម្រាប់ជនរងគ្រោះជាជនជាតិស្បែកខ្មៅ ជនជាតិភាគតិច បុរស និងក្រុម LGBT។**
>
> “កិច្ចការរបស់មនុស្សគ្រប់រូប៖ការបង្កើនការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ” (HMIC, 2014)

**ឧទាហរណ៍នៃដំណោះស្រាយតាមសហគមន៍ នឹងលេចឡើងក្នុងផ្នែកផ្សេងទៀតនៃសៀវភៅណែនាំនេះជាពិសេសក្នុងជំពូកទី ៣ (ការទប់ស្កាត់) ជំពូកទី ៥ (ការស៊ើបអង្កេត) ជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) និងជំពូកទី ១២ (ការបន្តផ្តល់យុត្តិធម៌)។**

ជារួម គេអាចកាត់បន្ថយបញ្ហាប្រឈមក្នុងស្ថាប័ននគរបាលនៅពេលឆ្លើយតបទៅនឹងបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបានយ៉ាងច្រើនតាមរយៈថ្នាក់ដឹកនាំនគរបាលដ៏មានប្រសិទ្ធភាព ដែលយល់ពីឫសគល់នៃអំពើហិង្សា

លើស្ត្រី និងក្មេងស្រី និងត្រៀមខ្លួន "ម្ចាស់ការលើបញ្ហា" និងដោះស្រាយបញ្ហានេះដោយផ្ទាល់តាមរយៈការជានា និងការរៀនសូត្រពីការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេត។

ថ្នាក់ដឹកនាំនគរបាលប្រកបដោយប្រសិទ្ធភាពក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ធានាបានផងដែរថា ការស៊ើបអង្កេតផ្តោតលើការទទួលខុសត្រូវ[25] របស់ជនបង្កតាមរយៈការប្រមូលភស្តុតាងឱ្យបានច្រើនពីជនបង្កដែលរងការចោទប្រកាន់ទន្ទឹមនឹងការធានាសុខុមាលភាពរបស់ជនរងគ្រោះជាដែលចំណុចស្នូលនៃការស៊ើបអង្កេត។ ការដឹកនាំបែបនេះ គឺអនុលោម តាមគោលការណ៍រួមជាអន្តរជាតិនៃការបង្កើនសុវត្ថិភាព និងភាពអង់អាចរបស់ជនរងគ្រោះ ទន្ទឹមនឹងការធានាការទទួលខុសត្រូវរបស់ជនល្មើស[26] ។

គន្លឹះសំខាន់គឺសមត្ថភាពរបស់ថ្នាក់ដឹកនាំនគរបាលក្នុងការបង្កើត និងលើកកម្ពស់វប្បធម៌ក្រុម និង/ឬគោលការណ៍ដែលផ្តោតសំខាន់លើសមត្ថភាពស្នូល និងបណ្តុំជំនាញវិជ្ជាជីវៈដែលកំណត់ច្បាស់ពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទន្ទឹមនឹងការដោះស្រាយភ្លាមៗនូវឥរិយាបថអវិជ្ជមាន និងភាពលម្អៀងនានាដែលកើតឡើងដោយមិនដឹងខ្លួនដែលរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរួម។

**ភាពលម្អៀងយេនឌ័រ ៖ តើភាពលម្អៀងយេនឌ័រអាចរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលដោយរបៀបណា?**

ភាពលម្អៀងយេនឌ័រ សំដៅលើទំនោរទៅរក ឬភាពលម្អៀងលើយេនឌ័រមួយជាងយេនឌ័រផ្សេងទៀត[27]។

**យេនឌ័រសំដៅលើតួនាទី អាកប្បកិរិយា សកម្មភាព និងគុណលក្ខណៈដែលកំណត់ដោយសង្គមមួយនៅពេលណាមួយដែល សមស្របសម្រាប់បុរស និងស្ត្រី។**

ភាពលម្អៀងយេនឌ័រ មិនថាស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយមិនដឹងខ្លួន) ឬស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយដឹងខ្លួន) រងឥទ្ធិពល និងផ្អែកតាមផ្នត់គំនិតយេនឌ័រ និងឥរិយាបថដែលកំណត់បុគ្គលិកលក្ខណៈ តួនាទី និងអាកប្បកិរិយាផ្សេងៗលើបុរសធៀបនឹងស្ត្រី និងរួមបញ្ចូលតួនាទី និងឥរិយាបថផ្លូវភេទ[28]។

**"ការលុបបំបាត់ភាពលម្អៀងយេនឌ័រក្នុងសេវានគរបាល ជាសមាសធាតុស្នូលនៃការប្រយុទ្ធប្រឆាំងការប្រទូស្តកេរខ្មាស និងអំពើហិង្សាក្នុងគ្រួសារ និងអាចបង្កផលប៉ះពាល់ជាក់ស្តែង និងភ្លាមៗលើសុវត្ថិភាពរបស់ជនរងគ្រោះម្នាក់ៗ"។**

ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ២០១៥

ការប្រព្រឹត្តអំពើប្រទូស្តកេរខ្មាស និងអំពើហិង្សាអន្តរបុគ្គលអាចបណ្តាលមកពីភាពលម្អៀង យេនឌ័ររបស់នគរបាលចាប់ពីការខកខានមិនចុះបញ្ជីករណីទៅតាមនីតិវិធីក្នុងអំឡុងពេលទំនាក់ទំនងដំបូង រហូតដល់ការបង្កភាពអាម៉ាស់ និងការស្តីបន្ទោស ក៏ដូចជាការចោទប្រកាន់ជនរងគ្រោះថា រាយការណ៍មិនពិត[29]។ ស្ត្រី និងក្មេងស្រីដែលមានពិការភាពងាយនឹងត្រូវបានចោទសួរពីភាពអាចជឿទុកចិត្តបានរបស់ពួកគេដោយសារផ្នត់គំនិតអវិជ្ជមានលើយេនឌ័រ និងពិការភាព[30]។

យោងតាមក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ភាពលម្អៀងយេនឌ័រដែលស្តែងចេញឱ្យឃើញច្បាស់ និងមិនស្តែងចេញឱ្យឃើញច្បាស់ត្រូវបានដាក់បង្កប់ក្នុងវប្បធម៌របស់

25. កញ្ចប់សេវាសំខាន់ៗចាត់ទុកការទទួលខុសត្រូវរបស់ជនបង្ក ជាការដាក់ទណ្ឌកម្មសមស្របដើម្បីរក្សាការទទួលខុសត្រូវរបស់ជនបង្កលើសកម្មភាពរបស់ខ្លួន និងផ្តល់ដំណោះស្រាយដែលយុត្តិធម៌ និងមានប្រសិទ្ធភាពដល់ជនរងគ្រោះ សម្រាប់ការរងគ្រោះដោយសារគ្រោះថ្នាក់ ឬការខាតបង់។
26. យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ (សេចក្តីសម្រេចលេខ ៦៥/២២៨ (២០១០) របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឧបសម្ព័ន្ធ កថាខណ្ឌ ១៣ (ក))។
27. Huhtanen, H., Lonsway, K.A., Archambault, J. (2017), 'Gender Bias in Sexual Assault Response and Investigation, Training Bulletin Series: Part 1' End Violence Against Women International
28. Ibid
29. ទិន្នន័យដែលមានគូសបញ្ជាក់ពីហានិភ័យកាន់តែខ្លាំងនៃការកំណត់ថា របាយការណ៍នៃការប្រទូស្តកេរខ្មាសជារបាយការណ៍មិនពិត ជាងរបាយការណ៍មិនពិតជាក់ស្តែង។ សូមមើល Jordan, J. (2004), 'Beyond belief: Police, rape and women's credibility', Criminal Justice 4(1), 29-59 in Huhtanen, H., Lonsway, K.A., Archambault, J. (2017), 'Gender Bias in Sexual Assault Response and Investigation, Training Bulletin Series: Part 3', End Violence Against Women International.
30. សារណារបស់ Women Enabled International ផ្ញើជូនអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិជនពិការ ៖ ការអនុវត្តល្អសម្រាប់ការបង្កើនលទ្ធភាពប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី និងក្មេងស្រីមានពិការភាពក្នុងការទទួលបានយុត្តិធម៌ (ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៩)។

យើង។ ពាក់ព័ន្ធនឹងសេវានគរបាល ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ពិពណ៌នាភាពលម្អៀងយេនឌ័រជាទម្រង់នៃការរើសអើងដែលបណ្តាល មកពីនគរបាលផ្តល់ការការពារតិចតួចដល់ជនរងគ្រោះមួយចំនួនដោយសារយេនឌ័ររបស់ពួកគេមិនឆ្លើយតបទៅនឹងបទល្មើសដែលបង្កគ្រោះថ្នាក់ខ្លាំងលើពួកគេឬផ្តល់សេវាតិចជាងមុនឬមិនពេញលេញ ដោយសារផ្នត់គំនិតយេនឌ័រ[31]។

ភាពលម្អៀងយេនឌ័រអាចរួមបញ្ចូល ឬប្រទាក់ក្រឡានឹងភាពលម្អៀងផ្សេងទៀត ដូចជា ភាពលម្អៀងដែលអាចបណ្តាលមកពីជាតិពន្ធុ ពិការភាព ផ្លូវភេទ អាយុ និងសាសនា។ ក្នុងការអនុវត្ត ចំណុចនេះអាចនាំទៅរកការសន្មតលើក្រុមស្ត្រីដែលភាគច្រើនអាចផ្តល់សេវាផ្លូវភេទហេតុដូច្នេះនឹងនាំទៅរកការ "សុំសេវានេះ" ឬមានន័យថាក្រុមបុរសដែលភាគច្រើនមានចរិតហិង្សាឬកេងប្រវ័ញ្ច។ ខណៈដែលមន្ត្រីនគរបាលជាច្រើនមានឥរិយាបថ និងគុណតម្លៃដែលគាំទ្រលទ្ធភាពស្មើភាព មិនលម្អៀង និងយុត្តិធម៌ក្នុងការទទួលបានយុត្តិធម៌ ភាពលម្អៀងយេនឌ័រដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងភាពលម្អៀងផ្សេងទៀតអាចបង្កឧបសគ្គយ៉ាងធំលើការធានាលទ្ធភាពទទួលបានយុត្តិធម៌ដោយស្មើភាព។ អ្នកជំនាញជឿថានេះគឺដោយសារតែភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់ កើតឡើងដោយមិនដឹងខ្លួន មានន័យថាអ្នកអាចធ្វើការវិនិច្ឆ័យភ្លាមៗ ក្នុងរយៈពេលមួយវិនាទីនិងអាចជាញឹកញាប់ ផ្ទុយពីជំនឿ និងគុណតម្លៃផ្ទាល់ខ្លួនរបស់អ្នក[32]។

ឧ. Hohl and Stanko (២០១៥)[33] ក្នុងការវិភាគលំនាំអាទ្រីត (attrition patterns) ក្នុងករណីរំលោភសេពសន្ថវៈនៅចក្រភពអង់គ្លេសកត់សម្គាល់ថា "ជាតិពន្ធុរបស់ជនសង្ស័យក៏ចោទជាបញ្ហាដែរ។ ជនសង្ស័យមិនមែនជនជាតិស្បែកស មានអត្រាទាបជាង ៧០% នៃការមិនជាប់ទោសព្រហ្មទណ្ឌ ដោយមិនគិតពីជាតិពន្ធុរបស់ជនរងគ្រោះ។ បើបញ្ចូលឥទ្ធិពលនៃអន្តរកម្មរវាងជាតិពន្ធុរបស់ជនសង្ស័យ និងជនរងគ្រោះក្នុងការវិភាគ មានការបង្ហាញថា ធៀបនឹងជនសង្ស័យមិនមែនជនជាតិស្បែកស ជនសង្ស័យជាជនជាតិស្បែកស មានអត្រាមិនជាប់ទោសព្រហ្មទណ្ឌ[34]លើសពីរដងច្រើនជាងជនរងគ្រោះជាជនជាតិស្បែកស និងមានអត្រា ១១ ដងក្នុងការមិនជាប់ទោសព្រហ្មទណ្ឌប្រសិនបើជនរងគ្រោះមិនមែនជនជាតិស្បែកស។ លទ្ធផលរកឃើញនេះបង្ហាញថា ជនសង្ស័យជាជនជាតិស្បែកសងាយនឹងរួចខ្លួនពីការស៊ើបអង្កេតបន្ថែមជាងជនសង្ស័យមិនមែនជនជាតិស្បែកស ជាពិសេសប្រសិនបើជនរងគ្រោះមិនមែនជាជនជាតិស្បែកស"។

**អ្នកដឹកនាំមានភាពប្រុងប្រយ័ត្ន ក្នុងការធ្វើយ៉ាងណាមិនឱ្យភាពលម្អៀងរបស់ខ្លួនជះឥទ្ធិពលលើសមាជិកក្រុមក្រោមបង្គាប់។**

ការស្រាវជ្រាវរបស់ Hohl and Stanko's[35] គូសបញ្ជាក់ថា (ក្នុងករណីចក្រភពអង់គ្លេស) កត្តាសំខាន់ៗក្នុងលំនាំអាទ្រីត (attrition patterns) រួមមានជាតិពន្ធុរបស់ជនសង្ស័យ ព្រមទាំងអ្វីដែលមន្ត្រីនគរបាល និងអយ្យការសន្មតជាភស្តុតាងធៀបនឹងសច្ចភាពនៃការចោទប្រកាន់។

ក្នុងនាមជាអ្នកដឹកនាំ ការជម្នះភាពលម្អៀងយេនឌ័រ និងភាពលម្អៀងផ្សេងទៀត មិនមែនជារឿងងាយស្រួល

31. ការកំណត់រកនិងការទប់ស្កាត់ភាពលម្អៀងយេនឌ័រក្នុងការឆ្លើយតបរបស់ស្ថាប័នអនុវត្តច្បាប់ទៅនឹងការប្រទូស្តកេរខ្មាសនិងអំពើហិង្សាក្នុងគ្រួសារ (ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ២០១៥)។
32. Ibid
33. Hohl, K. and Stanko, E. (2015), 'Complaints of rape and the criminal justice system: Fresh evidence on the attrition problem in England and Wales', European Journal of Criminology, 12(3), pp. 324-341. doi: 10.1177/1477370815571949.
34. នៅចក្រភពអង់គ្លេស "ការមិនជាប់ទោសព្រហ្មទណ្ឌ" កើតឡើងនៅពេលបទល្មើសដែលបានកត់ត្រា ត្រូវបានរកឃើញថាមិនមែនជាបទល្មើស និងត្រូវបានលុបចោល ដោយសន្មតថាមានព័ត៌មានដែលអាចផ្ទៀងផ្ទាត់បានថា គ្មានការប្រព្រឹត្តបទល្មើសនោះ។ សូមមើល https://www.theguardian.com/lifeandstyle/womens-blog/2014/nov/21/police-letting-rape-victims-down-too
35. Hohl, K. and Stanko, E. (2015), 'Complaints of rape and the criminal justice system: Fresh evidence on the attrition problem in England and Wales', European Journal of Criminology, 12(3), pp. 324-341. doi: 10.1177/1477370815571949.
36. សម្រាប់ការណែនាំលម្អិតស្តីពីយេនឌ័រ និងការត្រួតពិនិត្យនគរបាលក្នុងស្ថាប័ន សូមមើល ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រ ក្នុង "ឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ" (Geneva: DCAF, OSCE/ODIHR, UN Women, 2019) និង "ការដាក់បញ្ចូលយេនឌ័រក្នុងការត្រួតពិនិត្យនគរបាលក្នុងស្ថាប័ន" (OSCE/ODIHR, 2014)។

ឡើយ។ ចំណុចនេះទាមទារការរួមបញ្ចូលសមាសធាតុជាច្រើនដូចជាការពិនិត្យឡើងវិញនិងការកែសម្រួលការអនុវត្តគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ក៏ដូចជាការបណ្តុះបណ្តាលនគរបាល និងការកសាងការយល់ដឹងដែលធ្វើឱ្យនគរបាលបានដឹងពីឥរិយាបថរបស់ពួកគេ និងផលប៉ះពាល់ទៅលើអ្នកដទៃក្នុងការងារប្រចាំថ្ងៃរបស់នគរបាល[36]។ ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកបានផ្តល់គន្លឹះល្អៗមួយចំនួនសម្រាប់ការកាត់បន្ថយភាពលម្អៀងយេនឌ័រក្នុងសេវានគរបាល (សូមមើលប្រអប់ ១)។

### ប្រអប់ ១: គន្លឹះក្នុងការកាត់បន្ថយភាពលម្អៀងយេនឌ័រក្នុងការផ្តល់សេវានគរបាលប្រចាំថ្ងៃ

អ្នកគ្រប់គ្រងក្នុងជួរនគរបាលអាច ៖

- កត់សម្គាល់ និងលើកឡើងពីភាពលម្អៀង ការសន្មត និងផ្នត់គំនិតចំពោះជនរងគ្រោះ
- ធានាថាពួកគេមិនផ្អែកការវិនិច្ឆ័យផ្ទាល់ខ្លួនពាក់ព័ន្ធនឹងភាពអាចជឿទុកចិត្តបាននៃការរៀបរាប់របស់ជនរងគ្រោះលើការសន្មត ឬផ្នត់គំនិតស្តីពី "ប្រភេទ" មនុស្សដែលអាចជាជនរងគ្រោះដោយសារការប្រទូសកេរខ្មាស ឬស្តីពីថាតើជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស និងអំពើហិង្សាក្នុងគ្រួសារ "គួរ" ឆ្លើយតប ឬប្រព្រឹត្តដោយរបៀបណា។
- ដឹង និងផ្សព្វផ្សាយដល់ក្រុមរបស់ខ្លួនថាតើភាពលម្អៀងយេនឌ័រជះផលអវិជ្ជមានដូចម្តេចលើការងាររបស់នគរបាល រួមទាំងរបៀបដែលភាពលម្អៀងយេនឌ័រជះឥទ្ធិពលលើគុណភាពនៃការស៊ើបអង្កេត និងការយល់ឃើញទូទៅរបស់នគរបាល។
- ធានាថា ក្រុមរបស់ខ្លួនយល់ពីផលប៉ះពាល់អវិជ្ជមាននៃភាពលម្អៀងយេនឌ័រលើការរាយការណ៍ពីចំនួនករណីតិចជាងចំនួនករណីពិតប្រាកដនៃបទល្មើសស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសការរាយការណ៍ដោយស្ត្រី និងក្មេងស្រីដែលមកពីក្រុម ឬ សហគមន៍ជួបការលំបាក។

ប្រភព ៖ ក្រសួងយុត្តិធម៌ចេញសេចក្តីណែនាំស្តីពីការកំណត់រក និងការទប់ស្កាត់ភាពលម្អៀងយេនឌ័រក្នុងការឆ្លើយតបរបស់ស្ថាប័នអនុវត្តន៍ច្បាប់ទៅនឹងការប្រទូស្តកេរខ្មាស និងអំពើហិង្សាក្នុងគ្រួសារ (ក្រសួងយុត្តិធម៌សហរដ្ឋ អាមេរិក ការិយាល័យកិច្ចការសាធារណៈ ២០១៥) https://www.justice.gov/opa/pr/justice-department-issues-guidance-identifying-and-preventing-gender-bias-law-enforcement

**សូមមើលជំពូកទី ១០ (ការកសាងស្ថាប័ន) សម្រាប់អនុសាសន៍ស្តីពីគោលនយោបាយស្ថាប័នដែលមានគោលបំណងគ្រប់គ្រងផលប៉ះពាល់នៃភាពលម្អៀងយេនឌ័រក្នុងសេវានគរបាល និងជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រសម្រាប់ការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ការពិភាក្សាស្តីពីផ្នត់គំនិតយេនឌ័រដែលបង្កប់ក្នុងវប្បធម៌របស់នគរបាល។**

មហាវិទ្យាល័យសេវានគរបាលរបស់ចក្រភពអង់គ្លេសគូសបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់បុគ្គលិកលក្ខណៈដូចជា ការគិតពីអារម្មណ៍ និងការយល់ឃើញក្នុងសេវានគរបាលតាមរយៈការ ផ្តោតសំខាន់លើរបៀបបញ្ចៀសការបង្កើតផ្នត់គំនិត ភាពលម្អៀងផ្ទាល់ខ្លួន និងការរើសអើង និងការដឹងពីប្រតិកម្មតបផ្សេងទៀត[37]។

សកម្មភាពជាក់លាក់ផ្សេងទៀតដែលថ្នាក់ដឹកនាំនគរបាលអាចធ្វើឡើង រួមមាន ៖

➔ ធានាថាការកំណត់បទល្មើសមិនផ្តល់លទ្ធភាពឱ្យមានការបកស្រាយខុសឬបណ្តែតបណ្តោយឱ្យមានការយល់ខុស ឬផ្នត់គំនិត រួមទាំងការធានាថា អំពើផ្លូវភេទទាំងអស់ដែលប្រព្រឹត្តលើស្ត្រីដែលមិនយល់ព្រមដោយមិនគិតពីសាវតាររបស់ស្ត្រី សូម្បីតែនៅពេលដែលស្ត្រីមិនបង្ហាញសញ្ញាប្រឆាំងតបត ត្រូវបានចាត់ទុកជាអំពើហិង្សាផ្លូវភេទ និងជាប់ទោសព្រហ្មទណ្ឌ ។

➔ បង្កើត និងអនុវត្តវិធានការដើម្បីការពារស្ត្រីក្នុងក្រុមរបស់ខ្លួនពីអំពើហិង្សា និងការបៀតបៀន។

➔ អនុវត្តអភិក្រម "មិនអត់ឱន" សម្រាប់អាកប្បកិរិយា និងសកម្មភាពដែលមិនអាចទទួលយកបាន។

➔ ដំឡើងតំណែង និងទទួលស្គាល់មន្ត្រីដែលឆ្លង

កាត់ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពដែលគិតគូរពីយេនឌ័រជាប្រចាំ និងក្នុងស្ថាប័ន រួមទាំងការបណ្តុះបណ្តាលជាក់លាក់នៅពេលច្បាប់ថ្មីត្រូវបានអនុម័ត [39]។

ចរិតមាយាទទាំងនេះដែលឆ្លុះបញ្ចាំងពីសត្យានុម័តភាព និងភាពមានវិជ្ជាជីវៈ នឹងជួយពង្រឹងទំនុកចិត្តរបស់ជនរងគ្រោះ និងអាចសម្រួលដល់ការរាយការណ៍ និងការចូលរួមកាន់តែច្រើនក្នុងការស៊ើបអង្កេត និងការកាត់ទោសបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្នុងសៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់នគរបាលនៅប្រទេសម៉ិចស៊ិក UNODC (២០១៧)បានរៀបរាប់ពីភាពលម្អៀងញឹកញាប់បំផុត(ដែលផ្អែកតាមក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក[40])

ដែលមន្ត្រីនគរបាលអាចបង្ហាញឡើងនៅពេលសួរចម្លើយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

ប្រអប់ ២ ខាងក្រោមផ្អែកលើប្រភពទាំងពីរ និងរៀបរាប់ពីភាពលម្អៀងទូទៅបំផុតក្នុងសេវានគរបាលដែលជះផលអវិជ្ជមានលើការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[41]។

### ប្រអប់ ២

### *ភាពលម្អៀងញឹកញាប់បំផុត ដែលត្រូវបានកត់សម្គាល់ក្នុងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី**

- ការពន្យារពេលរាយការណ៍ដោយជនរងគ្រោះ។
- ជនរងគ្រោះធ្លាប់រាយការណ៍ស្រដៀងគ្នាកាលពីមុនមក។
- ការស្លៀកពាក់របស់ជនរងគ្រោះនៅពេលមានបទល្មើសដែលរងការចោទប្រកាន់និងរបៀបស្លៀកពាក់ទូទៅ។
- ការជំទាស់របស់ជនរងគ្រោះ មិនឱ្យដាក់បណ្តឹង។
- ប្រវត្តិផ្លូវភេទរបស់ជនរងគ្រោះ។
- ស្ថានភាពផ្លូវចិត្តរបស់ជនរងគ្រោះ (ឧ. ប្រសិនបើគាត់ហាក់ស្ងៀមស្ងាត់ ឬ ក្រៀមក្រំ)។
- កង្វះការប្រឆាំងតបតពីសំណាក់ជនរងគ្រោះ។
- កំណត់ត្រាបទល្មើសរបស់ជនរងគ្រោះ ឬការពាក់ព័ន្ធរបស់គាត់ក្នុងពេស្យាចារ។
- ការជឿថា ជនរងគ្រោះ មានជំងឺផ្លូវចិត្ត។
- ការជឿថា ជនរងគ្រោះ អាចស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬគ្រឿងញៀន។
- កម្ពស់របស់ជនរងគ្រោះ ប្រហែលគ្នានឹងកម្ពស់របស់ជនប្រព្រឹត្ត។
- មិនសូវមានសញ្ញាច្បាស់លាស់នៃគ្រោះថ្នាក់លើរាងកាយរបស់ជនរងគ្រោះ។
- ថាតើជនរងគ្រោះត្រូវបានវាយប្រហារដោយអ្នកដែលមានភេទដូចគ្នា ឬយ៉ាងណា។
- ទំនោរផ្លូវភេទឬអត្តសញ្ញាណយេនឌ័ររបស់ជនរងគ្រោះ។

*ប្រភព ៖ សូមមើល "សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់កម្មវិធីពង្រឹងមន្ត្រីនគរបាលដើម្បីធានាសន្តិសុខរបស់ក្រុមងាយរងគ្រោះ" (UNODC សហការជាមួយរដ្ឋាភិបាលម៉ិចស៊ិក ២០១៧)។ សូមមើលផងដែរ ការកំណត់រក និងការទប់ស្កាត់ភាពលម្អៀងយេនឌ័រក្នុងការឆ្លើយតបរបស់ស្ថាប័នអនុវត្តន៍ច្បាប់ទៅនឹងការប្រទូស្តកេរខ្មាស និងអំពើហិង្សាក្នុងគ្រួសារ (ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ២០១៥)

ក្រៅពីនេះ អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរពិចារណាថាតើសាវតារសង្គមរបស់ជនរងគ្រោះជះឥទ្ធិពលកម្រិតណាលើភាពលម្អៀង ជាពិសេសប្រសិនបើគាត់មកពីសាវតារងាយរងគ្រោះ។

---

37. សូមមើល "ការស៊ើបអង្កេត ៖ ការធ្វើការជាមួយជនរងគ្រោះ និងសាក្សី មហាវិទ្យាល័យសេវានគរបាល https://www.app.college.police.uk/app-content/investigations/victims-and-witnesses/
38. សូមមើល "ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (ញូវយ៉ក ការិយាល័យ អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ២០១៤)។
39. ការសំខាន់ត្រូវធានាថា ការបណ្តុះបណ្តាលឆ្លងកាត់ការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាដែលធ្វើការងារគាំទ្រជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។សម្រាប់សកម្មភាពជាក់លាក់បន្ថែមទៀតសម្រាប់ការដោះស្រាយភាពលម្អៀងយេនឌ័រក្នុងសេវានគរបាល និងសេវាយុត្តិធម៌សំខាន់ៗ សូមមើល "ការកាត់ទោសអំពើរំលោភសេពសន្ថវៈ ៖ ការស្វែងយល់ពីការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាផ្លូវភេទក្នុងប្រទេសថៃ និងវៀតណាម (UN Women, UNDP, UNODC ២០១៧)។
40. ក្នុងករណីជាច្រើន ភាពលម្អៀងយេនឌ័រដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងស្តែងចេញឱ្យឃើញច្បាស់ អាចរារាំងមិនឱ្យអ្នកស៊ើបអង្កេតប្រកាន់ខ្ជាប់ការអនុវត្តល្អបំផុត ឬផ្តួចផ្តើមការស៊ើបអង្កេត (ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ២០១៥)។
41. សូមមើល "សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់កម្មវិធីពង្រឹងមន្ត្រីនគរបាលដើម្បីធានាសន្តិសុខរបស់ក្រុមងាយរងគ្រោះ" (UNODC សហការជាមួយរដ្ឋាភិបាលម៉ិចស៊ិក ២០១៧)។ សូមមើលផងដែរ "សៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់សេវាអយ្យការទៅនឹងអំពើហិង្សាលើស្ត្រិ និងក្មេងស្រី" (UNODC សហការជាមួយ UN Women ២០១៤)។

គាត់អាចទទួលរងទង្វើមិនល្អ ជាពិសេសប្រសិនបើជនប្រព្រឹត្តមកពី "គ្រួសារល្អ" មាន "ស្ថានភាពសង្គម" មួយចំនួនឬជាមន្ត្រីនគរបាលឬសមាជិកនៃកងកម្លាំងសន្តិសុខ។

ភាពលម្អៀងរបស់នគរបាល អាចជះឥទ្ធិពលលើការបកស្រាយរបស់នគរបាលស្តីពី "ភាពល្អឥតខ្ចោះ" នៃភិនភាគ និងការប្រព្រឹត្តរបស់ជនរងគ្រោះ។ ឧ.មានការយល់ខុសថា ស្ត្រី "បរិសុទ្ធ" និង "ថ្លៃថ្នូរ" ដែលទទួលរងអំពើហិង្សាផ្លូវភេទ គួរទទួលបានការស៊ើបអង្កេតយ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនេះ មានការយល់ខុសមួយផ្សេងទៀតថា ការពន្យារពេលរាយការណ៍ដោយស្ត្រីក្រោយពីគាត់ទទួលរងអំពើហិង្សា មានន័យស្មើនឹងការរាយការណ៍មិនសមហេតុផល ឬមិនពិត។

ការសិក្សារបស់ UNHCHR កត់សម្គាល់ពីលទ្ធផលរកឃើញរបស់អង្គការមិនមែនរដ្ឋាភិបាលដែលគូសបញ្ជាក់ថា ឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងស្ត្រី និងក្មេងស្រីមានពិការភាព គឺជាញឹកញាប់មិនត្រូវបានស៊ើបអង្កេត ដោយសារឧបសគ្គជាច្រើនដូចជាការខកខានរបស់នគរបាលក្នុងការដាក់បណ្តឹងព្រហ្មទណ្ឌដែលបណ្តាលមកពីការយល់ឃើញបែបលម្អៀងចំពោះស្ត្រី និងក្មេងស្រីមានពិការភាព និងឧបសគ្គផ្នែករចនាសម្ព័ន្ធ ដូចជា លក្ខខណ្ឌតម្រូវផ្នែកសមត្ថភាពដើម្បីអាចចាត់ទុកជា "សាក្សីដែលមានសមត្ថភាព"[42]។

ឯកសារជំនួយស្មារតីស្តីពីយេនឌ័ររបស់ UNPOL ដែលមានចំណងជើងថា "ស្តង់ដារនៃការអនុវត្តល្អបំផុតសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព សេចក្តីសង្ខេបឧបករណ៍គម្រោង" (២០១៥) ផ្តល់ចំណេះដឹងល្អៗស្តីពីថាតើការយល់ខុសមួយចំនួន អាចជះឥទ្ធិពលដូចម្តេចលើឥរិយាបថរបស់មន្ត្រីនគរបាល និងបង្កើតជាឧបសគ្គក្នុងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទ ជាពិសេសនៅពេលមន្ត្រីមិនយល់ច្បាស់ថា អំពើហិង្សាផ្លូវភេទ (មិនថាបង្កឡើងជសាធារណៈ ឬជាឯកជននោះទេ) គឺជាបទល្មើសនិងមិនយល់ថាពួកគេមានភារកិច្ចបើកការស៊ើបអង្កេតល្អិតល្អន់ កត់ត្រា និងចងក្រងសំណុំរឿង ក៏ដូចជាចាប់ខ្លួនជនបង្កដែលរងការចោទប្រកាន់[43]។ ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃការយល់ខុសពាក់ព័ន្ធនឹងអំពើរំលោភសេពសន្ថវៈ ក្នុងឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL។

**ប្រអប់ ៣**
**ការយល់ខុសពាក់ព័ន្ធនឹងអំពើរំលោភសេពសន្ថវៈ ដកស្រង់ចេញពីឯកសារជំនួយស្មារតីស្តីពីយេនឌ័ររបស់ UNPOL (២០១៥)**

| ការយល់ខុស | ការពិត |
|---|---|
| ការរួមភេទជាកត្តាចម្បងដែលនាំទៅរកការរំលោភសេពសន្ថវៈ។ | អំណាច កំហឹង ការត្រួតត្រា និងការគ្រប់គ្រង ជាកត្តាធំៗដែលជំរុញឱ្យមានការរំលោភសេពសន្ថវៈ មិនមែនការរួមភេទនោះទេ។ |
| មានតែស្ត្រីប្រភេទខ្លះប៉ុណ្ណោះដែលត្រូវបានរំលោភសេពសន្ថវៈ។ | ស្ត្រីណាក៏អាចជាជនរងគ្រោះ ដោយសារការរំលោភសេពសន្ថវៈដែរ ប៉ុន្តែមនុស្សជាច្រើនជឿថា ស្ត្រីដែលមានសីលធម៌ខ្ពស់ (ក្មេងស្រីចរិតល្អ) មិនត្រូវបានរំលោភសេពសន្ថវៈឡើយ ហើយស្ត្រីដែលមិនសូវមានសីលធម៌ (ក្មេងស្រីចរិតមិនល្អ) នឹងត្រូវបានរំលោភសេពសន្ថវៈ។ |
| ស្ត្រីរាយការណ៍ប្រឌិតពីការរំលោភសេពសន្ថវៈ។ | ភាគតិចបំផុតនៃករណីរំលោភសេពសន្ថវៈ ដែលបានរាយការណ៍ ត្រូវបានចាត់ទុកជាការរាយការណ៍មិនពិត។ |
| ការរំលោភសេពសន្ថវៈបង្កដោយអ្នកមិនស្គាល់គ្នា។ | អំពើរំលោភសេពសន្ថវៈភាគច្រើនលើសលប់ បង្កឡើងដោយជនវាយប្រហារដែលស្គាល់គ្នា។ |

42. សូមមើលកំណត់សម្គាល់ទី ២។
43. អង្គការសហប្រជាជាតិ ឯកសារជំនួយស្មារតីស្តីពីយេនឌ័រសម្រាប់នគរបាល "ស្តង់ដារនៃការអនុវត្តល្អបំផុតសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព សេចក្តីសង្ខេបឧបករណ៍គម្រោង" (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ ២០១៥)

**ប្រអប់ ៣ (ត)**

**ការយល់ខុសពាក់ព័ន្ធនឹងអំពើរំលោភសេពសន្ថវៈ ដកស្រង់ចេញពីឯកសារជំនួយស្មារតីស្ដីពីយេនឌ័ររបស់ UNPOL (២០១៥)**

| ការយល់ខុស | ការពិត |
|---|---|
| ការរំលោភសេពសន្ថវៈពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវកាយយ៉ាងច្រើន និងការប្រើអាវុធ។ | ការរំលោភសេពសន្ថវៈភាគច្រើនមិនពាក់ព័្ធនឹងការប្រើកម្លាំងបាយច្រើននោះទេ។ ជនរងគ្រោះភាគច្រើនរាយការណ៍ថា ពួកគេខ្លាចរងរបួសធ្ងន់ធ្ងរ ឬត្រូវគេសម្លាប់។ ដូច្នេះហើយពួកគេមិនសូវតដៃទេ។ ចំណុចនេះ អាចពន្យល់ពីមូលហេតុដែលជនបង្កត្រូវប្រើកម្លាំង ឬអាវុធតិចតួចដើម្បីបង្ក្រាបជនរងគ្រោះ។ |
| ការរំលោភសេពសន្ថវៈបន្សល់ស្នាមរបួសច្បាស់ក្រឡែត។ | ដោយសារការរំលោភសេពសន្ថវៈភាគច្រើនមិនពាក់ព័ន្ធនឹងការប្រើកម្លាំងបាយច្រើន វាអាចមិនបន្សល់របួសស្នាម។ ការដែលមនុស្សម្នាក់គ្មានរបួសស្នាម មិនមែនន័យថាពួកគេមិនត្រូវបានរំលោភសេពសន្ថវៈនោះទេ។ ជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈតែ ១/៣ ប៉ុណ្ណោះដែលមានរបួសស្នាម។ |
| នៅពេលស្ត្រីនិយាយថា "ទេ" ចំពោះការរួមភេទមានន័យថាពួកគេចង់ "រួមភេទ"។ | "ទេ" គឺទេ។ ដូច្នេះ គួរគោរពបំណងប្រាថ្នារបស់ស្ត្រីគ្រប់ពេលវេលាទាំងអស់។ |
| អ្នកប្រកបរបរផ្លូវភេទ មិនអាចរងការរំលោភសេពសន្ថវៈទេ។ | បុរស ឬស្ត្រីគ្រប់រូប (ដោយមិនគិតការពាក់ព័ន្ធរបស់គាត់ក្នុងឧស្សាហកម្មផ្លូវភេទ) សុទ្ធតែអាចត្រូវបានរំលោភសេពសន្ថវៈ។ ការសិក្សាបង្ហាញថា បុរសនិងស្ត្រីយ៉ាងច្រើនដែលជាអ្នកប្រកបរបរផ្លូវភេទ ត្រូវបានរំលោភសេពសន្ថវៈដោយអតិថិជនរបស់ខ្លួន នគរបាល ឬដៃគូ។ |
| ប្ដីមិនអាចរំលោភប្រពន្ធរបស់ខ្លួនបានឡើយ។ | រាល់សកម្មភាពរួមភេទ ឬសកម្មភាពផ្លូវភេទដោយបង្ខំ សុទ្ធតែជាការរំលោភសេពសន្ថវៈដោយមិនគិតថាតើស្ត្រីនោះរៀបការជាមួយជនបង្កឬយ៉ាងណានោះទេ។ គួរឱ្យសោកស្ដាយដែលយុត្តាធិការជាច្រើន ផាត់ចេញការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ពីក្នុងច្បាប់របស់ខ្លួន។ ទោះបីជាស្ត្រីដែលរៀបការហើយប្រឈមនឹងការរំលោភសេពសន្ថវៈដោយស្វាមីក្តីក៏ច្បាប់ពាក់ព័ន្ធមិនទទួលស្គាល់ដូច្នោះដែរ។ |
| ការរំលោភសេពសន្ថវៈត្រូវបានរាយការណ៍ភ្លាមៗទៅនគរបាល។ | ការរំលោភសេពសន្ថវៈភាគច្រើន មិនត្រូវបានរាយការណ៍ទៅនគរបាលឡើយ។ ក្នុងចំណោមករណីដែលបានរាយការណ៍ ករណីភាគច្រើនត្រូវបានរាយការណ៍ក្នុងរយៈពេលលើស ២៤ ម៉ោងក្រោយឧប្បត្តិហេតុនេះ។ ជនរងគ្រោះ អាចមិនរាយការណ៍ ឬពន្យារពេលរាយការណ៍ ព្រោះពួកគេយល់ថា គ្មានប្រយោជន៍ ជនបង្កអាចគំរាមកំហែងពួកគេ ឬក្រុមគ្រួសារ ពួកគេភ័យខ្លាចការឆ្លើយតបពីគ្រួសារ ឬសហគមន៍ ឬក៏ពួកគេអាម៉ាស់មុខ។ ជនរងគ្រោះមួយចំនួនយល់ថាវាជាបញ្ហាឯកជន ឬមិនដឹងថាត្រូវរាយការណ៍នៅទីណា។ |

http://repository.un.org/handle/11176/387374 p. 197។ សូមមើលផងដែរ គោលការណ៍ណែនាំរបស់ WHO សម្រាប់ការថែទាំផ្នែកវេជ្ជសាស្ត្រ-ច្បាប់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ (២០០៣)។



រូបថតទទួលបានពី Force International (ប្រទេសកូសូវ៉ូ)

## ការកំណត់អាទិភាព និងគោលដៅសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

ការកំណត់អាទិភាពជាក់ស្តែង និងគោលដៅពាក់ព័ន្ធ ជាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការរក្សាសន្ទុះក្នុងក្រុមរបស់អ្នក។ ទោះជាយ៉ាងណា ភាពជោគជ័យនៃក្រុមរបស់អ្នករងឥទ្ធិពលពីប្រភេទនិងគុណភាពនៃគោលដៅដែលអ្នកបានកំណត់ក្នុងនាមជាប្រធានក្រុម។ ប្រភេទនិងគុណភាពនៃគោលដៅរបស់អ្នកនឹងរងឥទ្ធិពលពីអាទិភាពជាយុទ្ធសាស្ត្ររបស់ស្ថាប័នអ្នក និងកែសម្រួលទៅតាមតម្រូវការសន្តិសុខរបស់សហគមន៍មូលដ្ឋាន។

**ការយល់ពីទំនាក់ទំនងយេនឌ័រថា ជាចំណុចស្នូលនៃការពង្រឹងសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី និងការសម្រេចបានលទ្ធផលវិជ្ជមានពីសេវានគរបាល។**

**ការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រដែលគ្មានសមភាពកើតចេញពីការធ្វើសេចក្តីសម្រេចចិត្តរួម និងការបែងចែកធនធានបានសមស្រប។**

ការដឹងពីតម្រូវការសន្តិសុខផ្សេងៗ ក្នុងសហគមន៍ មូលដ្ឋានគឺជាកត្តាគន្លឹះដែលកំណត់ភាព ជោគជ័យនៃប្រតិបត្តិការរបស់អ្នក។ ឥរិយាបថអវិជ្ជមានឬលម្អៀងរបស់សមាជិកក្រុម ដែលនាំទៅរក ឬបណ្តាលឱ្យមានការរើសអើងលើ សមាជិកមួយចំនួន ឬក្រុមណាមួយក្នុងសហគមន៍ នឹងបង្អាក់ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់អ្នក។

ផ្ទុយទៅវិញ ឥរិយាបថវិជ្ជមាន និងអាកប្បកិរិយារបស់នគរបាលដែលបង្ហាញពីឆន្ទៈក្នុងការធ្វើការជាមួយ និងគាំទ្រជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីនឹងជួយផ្តល់ភាពស្របច្បាប់ដល់ការប្រឹងប្រែងរបស់នគរបាលក្នុងសហគមន៍របស់អ្នក។ ការយល់ និងការបង្ហាញការពិចារណាលើតម្រូវការសន្តិសុខផ្សេងៗរបស់សហគមន៍ នឹងអាចឱ្យមានការផ្តល់សេវានគរបាលកាន់តែប្រសើរព្រោះនគរបាលនឹងទទួលបានព័ត៌មានកាន់តែច្រើនស្តីពីនិន្នាការបទល្មើសក្នុងមូលដ្ឋាន រួមទាំងរបៀបដែលអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចត្រួតគ្នានឹងបទល្មើសផ្សេងទៀត ដូចជាការជួញដូរមនុស្ស និងទាសភាពសម័យទំនើប។

ឥរិយាបថវិជ្ជមាន និងអាកប្បកិរិយារបស់នគរបាលក្នុងការឆ្លើយតបដោយមានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីគួរលេចធ្លោក្នុងសមត្ថភាពនិងបណ្តុំជំនាញសំខាន់ៗដែលត្រូវបានផ្សព្វផ្សាយ និងបញ្ជ្រាបក្នុងស្ថាប័នរបស់អ្នក ព្រោះវាឆ្លុះបញ្ចាំងពីអាទិភាពថ្នាក់ជាតិ។

ទោះជាយ៉ាងណា អាទិភាព ទាមទារការយល់ដឹងជារួម អំពីបញ្ហា និងមូលហេតុដែលត្រូវដោះស្រាយបញ្ហានោះ។ ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការសំខាន់ គឺថ្នាក់ដឹកនាំនគរបាលជាន់ខ្ពស់ត្រូវកសាងការយល់ដឹង ជារួម និងផ្អែកតាមព័ត៌មានត្រឹមត្រូវស្តីពីធម្មជាតិនៃ អំពើហិង្សាលើស្ត្រីនិងក្មេងស្រីឫសគល់និងផលវិបាកនៃ អំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ សម្រាប់ អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ចំណុចនេះ នឹងផ្តល់ភាពស្របច្បាប់ដល់ស្ថាប័នរបស់អ្នកនិងកាត់បន្ថយ ភាពលម្អៀងអវិជ្ជមានដែលបង្កដោយបុគ្គលិករបស់អ្នក ក្នុងដំណើរការនេះ។

ក្រៅពីនេះ អាទិភាព ត្រូវការទស្សនៈវិស័យយុទ្ធសាស្ត្រ ច្បាស់លាស់ ដែលអាចឱ្យ ស្ថាប័ននគរបាល ទាំងមូល (មិនថាលំដាប់ថ្នាក់ណា) ដឹងថាត្រូវបង្កើនកិច្ចខិតខំ ប្រឹងប្រែងក្នុងទិសដៅមួយណា។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការផ្លាស់ប្តូរស្ថាប័ននគរបាល ឱ្យឆ្លើយតបនឹងយេនឌ័រ សូមមើលជំពូកទី១០ (ការកសាងស្ថាប័ន) និងជំពូកទី ១១ (បញ្ហាប្រឈម និង យុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតប នឹងយេនឌ័រ)។

ខាងក្រោមនេះ ជាឧទាហរណ៍បែបសម្មតិកម្មមួយនៃ ទស្សនៈវិស័យជាយុទ្ធសាស្ត្ររបស់ស្ថាប័ននគរបាលក្នុងការ ឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ការកើនឡើងនៃការរាយការណ៍និងការបង្អាក់អំពើហិង្សា លើស្ត្រី និងក្មេងស្រីបណ្តាលមកពីសេវានគរបាលដែល មានប្រសិទ្ធភាព និងគ្រប់គ្រាន់ ដែលផ្តោតអាទិភាពលើ តម្រូវការរបស់ជនរងគ្រោះ និងផ្សារភ្ជាប់ពួកគេទៅនឹង សេវាសំខាន់ៗដែលធានាសុខុមាលភាពរបស់ពួកគេ។**

ផ្អែកលើទស្សនៈវិស័យបែបសម្មតិកម្មនេះ គេនឹងអាច កំណត់អាទិភាព គោលដៅ និង យុទ្ធសាស្ត្រ។ រូបទី ៣ ខាងក្រោមជាឧទាហរណ៍សាមញ្ញមួយនៃការកំណត់គោល ដៅសម្រាប់សេវានគរបាលដែលឆ្លើយតបទៅនឹងយេនឌ័រ ក្នុងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលឆ្លុះបញ្ចាំង ពីគោលការណ៍និងលក្ខណៈទូទៅនៃកញ្ចប់សេវាសំខាន់ៗ។

**រូប ៣ ៖ ឧទាហរណ៍នៃការកំណត់គោលដៅសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី**

**អាទិភាព**
ការថយចុះប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី

**គោលដៅទី ១**
ជនរងគ្រោះ និងសហគមន៍របស់ពួកគេដែលរងផលប៉ះពាល់យល់ថានគរបាលជាអ្នកផ្តល់សេវាសំខាន់ៗ ដែលស្របច្បាប់ និងឆ្លើយតបនឹងយេនឌ័រ។

**គោលដៅទី ២**
ជនរងគ្រោះ រាយការណ៍ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីទៅនគរបាល ព្រោះពួកគេត្រូវបានបង្កើនភាពអង់អាចឱ្យចូលរួម និងសហការជាមួយនគរបាល។

**គោលដៅរងទី ១**
ការធ្វើទំនើបកម្មស្ថាប័ន មានលក្ខណៈឆ្លើយតបនឹងយេនឌ័រ និងឆ្លងកាត់ការពិគ្រោះយោបល់ទូលំទូលាយ។

**គោលដៅរងទី ២**
សេវាសំខាន់ៗរបស់នគរបាលគឺការធានាសុខុមាលភាពនិងការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៅពេលសម្របសម្រួលការឆ្លើយតបរបស់ពួកគេក្នុងការបន្តផ្តល់យុត្តិធម៌។

**គោលដៅរងទី ៣**
ការស៊ើបអង្កេតពី អំពើហិង្សាលើស្ត្រី និងក្មេងស្រី មានលក្ខណៈស្តង់ដារ និងឆ្លងកាត់ការគ្រប់គ្រងផ្ទៃក្នុង ដើម្បីឱ្យផ្តោតលើជនបង្ក និងផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត។

**យុទ្ធសាស្ត្រទី ១ របស់នគរបាល**
ការជំរុញការចូលរួមបែបប្រតិសកម្មរបស់អ្នកពាក់ព័ន្ធខាងក្រៅដូចជាអង្គការសង្គមស៊ីវិលស្ថាប័នសិក្សាស្រាវជ្រាវក្រុមរងផលប៉ះពាល់ និងតួអង្គគាំទ្រអន្តរជាតិសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលផ្អែកតាមព័ត៌មានត្រឹមត្រូវ ។

**យុទ្ធសាស្ត្រទី ២ របស់នគរបាល**
កំណត់ស្តង់ដារនិងគ្រប់គ្រងផ្ទៃក្នុងប្រកបដោយតម្លាភាពលើសមត្ថភាពស៊ើបអង្កេត និងជំនាញ ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្អែកតាមសិទ្ធិ។

**យុទ្ធសាស្ត្រទី ៣ របស់នគរបាល**
ពង្រឹងការបណ្តុះបណ្តាល និងការអប់រំស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីឱ្យមានការ ឆ្លើយតបនឹងយេនឌ័រផ្អែកតាមសិទ្ធិ និងតាមការប៉ះទង្គិចផ្លូវចិត្ត។



រូបថតទទួលបានពី UNMIT/Martine Perret (ប្រទេសទីម័រខាងកើត)

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃសកម្មភាពជាយុទ្ធសាស្ត្រចាំបាច់សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលក្នុងការសម្រេចបានគោលដៅដែលស្នើឡើងខាងលើ ៖

១. បង្កើតទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធខាងក្រៅ ដូចជា អង្គការស្ត្រី ឬអង្គការសង្គមស៊ីវិល ស្ថាប័នសិក្សាស្រាវជ្រាវ ក្រុមភាគតិច និងក្រុមងាយរងគ្រោះ និងតួអង្គសំខាន់ៗផ្សេងទៀតដើម្បីធានានូវការឆ្លើយតបដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ ក្នុងការការទប់ស្កាត់ និងការស៊ើបអង្កេតអំពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

២. ធានាការកំណត់កំណត់ស្តង់ដារ និងការគ្រប់គ្រងគុណភាពនៃសមត្ថភាពសំខាន់ៗនិងកម្រងជំនាញទន់ដែលប្រើប្រាស់ក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីធានាថា ការស៊ើបអង្កេតផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្អែកតាមសិទ្ធិ។

៣. ផ្តល់ឧទាហរណ៍ និងពង្រឹងការបណ្តុះបណ្តាល និងការអប់រំស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីឱ្យមន្ត្រីឆ្លើយតប ជំរុញការចូលរួមរបស់ជនរងគ្រោះតាមរបៀបដែលផ្អែកតាមសិទ្ធិ ឆ្លើយតបនឹងយេនឌ័រ ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងមិនរើសអើង។

## ការចូលរួមប្រកបដោយអត្ថន័យគឺជាចំណុចស្នូលនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

ដូចការពិភាក្សាកន្លងមកការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលមានប្រសិទ្ធភាព និងឆ្លើយតបនឹងយេនឌ័រ ទាមទារការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រពីថ្នាក់ដឹកនាំនគរបាល ដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ។

ការចូលរួមប្រកបដោយអត្ថន័យមានន័យថា បុគ្គល និងសហគមន៍របស់ពួកគេមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចដែលបង្កផលប៉ះពាល់ផ្ទាល់លើពួកគេរួមទាំងការចូលរួមក្នុងការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដានអន្តរាគមន៍។ ការចូលរួមនេះអាចមានទម្រង់ផ្សេងៗ ដូចជា ការផ្តល់ព័ត៌មានដែលមានតុល្យភាព និងសត្យានុម័តដល់ជនរងគ្រោះ ដើម្បីឱ្យពួកគេមានភាពម្ចាស់ការលើការសម្រេចចិត្តសំខាន់ៗ ដែលបង្កផលប៉ះពាល់លើសុខុមាលភាពរបស់ពួកគេ និងអាចពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមួយជនរងគ្រោះ ដើម្បីទទួលបានយោបល់ត្រឡប់ពីដំណើរការធ្វើការសម្រេចចិត្តរួមទាំងការបង្កើត និងការរិះរកដំណោះស្រាយជំនួស។



រូបថតទទួលបានពី Carolyn Kovacs Anderson (សហរដ្ឋអាមេរិក)

គោលគំនិត "ប្រកបដោយអត្ថន័យ" តម្រូវឱ្យស្ត្រី និងក្មេងស្រីមានវត្តមាន ហើយមានអ្នកស្តាប់ និងពិចារណាពីកង្វល់របស់ពួកគេ។ ស្ត្រីនិងក្មេងស្រីគួរមានឱកាសលើកឡើងពីបទពិសោធន៍ និងចំណេះដឹងពីអ្វីដែលពួកគេត្រូវការសម្រាប់ជនរងគ្រោះផ្ទាល់ដូចជាពួកគេ និងសង្គមទាំងមូល។

ឧ.ជាទូទៅស្ត្រីមានសមាសធាតុតិចតួចក្នុងជួរនគរបាលនៅជុំវិញពិភពលោក។ ឧបសគ្គផ្នែករចនាសម្ព័ន្ធ និងស្ថាប័ន និងផ្នត់គំនិតអវិជ្ជមានជុំវិញយេនឌ័រ បង្កផលប៉ះពាល់យ៉ាងខ្លាំងលើបរិយាកាសការងាររបស់ស្ត្រី ហើយកត្តាទាំងនេះជះផលអវិជ្ជមានកាន់តែខ្លាំងលើស្ត្រីមានពិការភាព និង/ឬស្ត្រីមកពីក្រុម ឬសហគមន៍ជនជាតិភាគតិច។

ស្ថាប័ននគរបាលកាន់តែមានភាពស្របច្បាប់ នៅពេលដែលក្រុម និងសហគមន៍ដែលពួកគេផ្តល់សេវាជូន អាចចូលរួមជាមួយនគរបាល និងយល់ថា ពួកគេមានអ្នកតំណាង។

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រត្រូវមានលក្ខណៈបរិយាបន្ន និងមានភាពតំណាង ដែលទាមទារឱ្យមានការបង្កើតយន្តការចែករំលែកព័ត៌មានជាមួយអ្នកតស៊ូមតិក្នុងសង្គមស៊ីវិលទន្ទឹមនឹងមានការកត់សម្គាល់ផងដែរថា អង្គការសង្គមស៊ីវិលខ្លួនឯងមិនរួមបញ្ចូលជនមានពិការភាព។

ដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ជនរងគ្រោះ និងសហគមន៍របស់ពួកគេក្នុងយុទ្ធសាស្ត្រ និងវិធានការរបស់នគរបាល សៀវភៅណែនាំនេះស្នើឱ្យថ្នាក់គ្រប់គ្រងនគរបាលយោងតាមលក្ខណៈទូទៅទាំង៩ ចំណុចដែលគួរស្តែងឡើងក្នុងសេវាសំខាន់ៗទាំងអស់។ លក្ខណៈទូទៅទាំងនេះដែលមានចែងក្នុងកញ្ចប់សេវាសំខាន់ៗ បន្សុីគ្នានឹងកិច្ចខិតខំប្រឹងប្រែង ផ្តល់សេវាសំខាន់ៗទាំងអស់ក្នុងការបង្កើនផលប៉ះពាល់វិជ្ជមានតាមរយៈការខិតខំធានាថាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការយុត្តិធម៌។ វិធានការ និងសកម្មភាពទប់ស្កាត់ និងស៊ើបអង្កេតដោយប្រសិទ្ធភាពរបស់នគរបាល នៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានសារៈសំខាន់ណាស់។

**រូបទី ៤ ៖ លក្ខណៈទូទៅនៃការឆ្លើយតបប្រកបដោយគុណភាពរបស់នគរបាល ដែលគាំទ្រការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី**



ខាងក្រោមនេះជាលក្ខណៈទូទៅដែលបានកំណត់ក្នុងកញ្ចប់សេវាសំខាន់ៗ ៖

១. **ភាពអាចរកបាន** ៖ សេវាសំខាន់ៗទាំងអស់ត្រូវផ្តល់ឱ្យក្នុងបរិមាណគ្រប់គ្រាន់ និងមានគុណភាពដល់មនុស្សគ្រប់រូបដោយមិនគិតពីទីកន្លែងរស់នៅសញ្ជាតិ ជាតិពន្ធុវណ្ណៈ ឋានៈ ស្ថានភាពជាជនចំណាកស្រុក ឬជនភៀសខ្លួន ស្ថានភាពជាជនជាតិដើមភាគតិច អាយុ សាសនា ភាសា និងកម្រិតអក្ខរភាព ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ពិការភាព ឬលក្ខណៈផ្សេងទៀតដែលមិនបានពិចារណា។

២. **ភាពអាចទទួលបាន** ៖ ទាមទារនូវសេវាសំខាន់ៗទាំងអស់ដែលអាចទទួលបានសម្រាប់មនុស្សគ្រប់រូបដោយគ្មានការរើសអើង។ សេវាត្រូវតែអាចទទួលបានជាក់ស្តែង (មានសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រីគ្រប់រូប) អាចទទួលបាន ក្នុងតម្លៃសមស្រប និងអាចទទួលបាន ព័ត៌មានដែលផ្តល់ជាភាសា និងក្នុងទម្រង់ផ្សេងៗ [44]។

៣. **ភាពអាចសម្របតាមបាន** ៖ សេវាសំខាន់ៗទាំងអស់ត្រូវទទួលស្គាល់ផលប៉ះពាល់ខុសៗគ្នានៃអំពើហិង្សាលើក្រុមស្ត្រី និងសហគមន៍ផ្សេងៗ។ សេវាទាំងនោះត្រូវឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះ តាមវិធីដែលដាក់បញ្ចូលសិទ្ធិមនុស្សនិងគោលការណ៍ដែលគិតគូរពីវប្បធម៌។

៤. **ភាពសមស្រប** ៖ សេវាសំខាន់ៗទាំងអស់ត្រូវគោរពសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ រក្សាការសម្ងាត់ គិតគូរពីតម្រូវការ និងទស្សនវិស័យរបស់ពួកគេ និងកាត់បន្ថយការរងគ្រោះដែលអាចកើតឡើងម្តងទៀត។

ប្រអប់ ៤

**ភាពអាចទទួលបានក៏រួមបញ្ចូល ៖**

ភាពអាចទទួលបានជាក់ស្តែង ៖ ទីតាំងរបស់សេវា ច្រកចូល និងទីចំណត ត្រូវផ្តល់ភាពងាយស្រួលដល់ស្ត្រី និងក្មេងស្រីដែលមានកម្សោយចល័តភាព។ បំលាស់ទីក្នុងទីតាំងនេះត្រូវតែអាចធ្វើទៅបានសម្រាប់អ្នកប្រើឧបករណ៍បំលាស់ទី និង/ឬមានពិការភាពវិញ្ញាណ។

ភាពអាចទទួលបានព័ត៌មាន និងការផ្សព្វផ្សាយ៖ ព័ត៌មានត្រូវតែផ្តល់ជូនស្ត្រី និងក្មេងស្រីដែលមានពិការភាពគ្រប់ប្រភេទ។ ត្រូវមានមធ្យោបាយផ្សេងៗ ដូចជា សេវាបកប្រែការប្រើភាសាសាមញ្ញ សំឡេង តួអក្សរធំៗ អក្សរសម្រាប់ជនពិការភ្នែក ងាយស្រួលអាន និងភាសាជារូបភាព។ល។ គួរប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សមាជិកគ្រួសារ ឬអ្នកថែទាំជាអ្នកបកប្រែ លុះត្រាតែមានការយល់ព្រមច្បាស់លាស់ ដោយសេរី និងផ្អែកតាមព័ត៌មានត្រឹមត្រូវពីជនរងគ្រោះព្រោះសមាជិកគ្រួសារឬអ្នកថែទាំអាចជាជនបង្កអំពើហិង្សា។

៥. **សុវត្ថិភាពជាចម្បង** ៖ ជនរងគ្រោះ ប្រឈមនឹងហានិភ័យជាច្រើនលើសុវត្ថិភាពផ្ទាល់និងជាបន្តបន្ទាប់របស់ខ្លួន។ ហានិភ័យទាំងនេះនឹងមានភាពជាក់លាក់ទៅតាមកាលៈទេសៈផ្ទាល់ខ្លួនរបស់បុគ្គល។ ការប៉ាន់ប្រមាណ និងគ្រប់គ្រងហានិភ័យអាចកាត់បន្ថយកម្រិតហានិភ័យបាន។ ការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យប្រកបដោយការអនុវត្តល្អបំផុតរួមមានអភិក្រមស៊ីសង្វាក់គ្នា និងមានការសម្របសម្រួលក្នុង និងរវាងវិស័យសង្គមកិច្ច វិស័យសុខាភិបាល វិស័យនគរបាល និងវិស័យយុត្តិធម៌។

៦. **ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់** ៖ សេវាសំខាន់ៗទាំងអស់ត្រូវផ្តល់តាមវិធីដែលការពារឯកជនភាពរបស់ជនរងគ្រោះ រក្សាការសម្ងាត់ និងបង្ហាញព័ត៌មានដោយមានការយល់ព្រមត្រឹមត្រូវពីពួកគេ ក្នុងកម្រិតសមស្របបំផុត។ ព័ត៌មានស្តីពីជនរងគ្រោះដោយសារអំពើហិង្សា អាចប៉ះពាល់អារម្មណ៍ខ្លាំង។ ការចែករំលែកព័ត៌មានទាំងនេះ

44. សេវាសំខាន់ៗទាំងអស់គួរតែអាចទទួលបានសម្រាប់មនុស្សគ្រប់រូប រួមទាំងស្ត្រី និងក្មេងស្រីមានពិការភាព។ គួរមានពិធីសារសម្រាប់ប្រភេទកម្សោយនីមួយៗ (គ ំហើញ ការស្តាប់ ចល័តភាព សុខភាពផ្លូវចិត្ត ចិត្តសង្គម។ល។) ហើយមន្ត្រីគួរត្រូវបានបណ្តុះបណ្តាលដើម្បីសម្របសម្រួលតម្រូវការរបស់ស្ត្រី និងក្មេងស្រី មានពិការភាពផ្សេងៗ។ សូមមើល "ស្ត្រី និងយុវជនមានពិការភាព ៖ គោលការណ៍ណែនាំសម្រាប់ការផ្តល់សេវាផ្អែកតាមសិទ្ធិ និងឆ្លើយតបនឹងយេនឌ័រដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ" (UNFPA-WIE, 2018)។

ដោយមិនសមស្របអាចបង្កការគំរាមកំហែងធ្ងន់ធ្ងរ ដល់ជីវិតរបស់ស្ត្រី និងក្មេងស្រី និងបុគ្គលដែល ជួយដល់ពួកគេ។

៧. **ទំនាក់ទំនង និងការចូលរួមប្រកបដោយប្រសិទ្ធភាព របស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា៖** ជនរងគ្រោះ ត្រូវដឹងថា គាត់មានអ្នកស្តាប់យោបល់ ហើយតម្រូវការរបស់គាត់ត្រូវបានស្វែងយល់ និងដោះស្រាយ។ ព័ត៌មាន និងវិធីផ្សព្វផ្សាយ អាចជំរុញឱ្យជនរងគ្រោះស្វែងរកសេវាសំខាន់ៗ។ រាល់ទំនាក់ទំនងទាំងអស់ជាមួយជនរងគ្រោះ ត្រូវលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងគោរពដល់ពួកគេ។

៨. **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន** ៖ ការប្រមូលទិន្នន័យជាប្រចាំនិងត្រឹមត្រូវស្តីពីសេវាដែលផ្តល់ឱ្យស្ត្រី និងក្មេងស្រី ពិតជាសំខាន់ណាស់ សម្រាប់ការជួយឱ្យមានការកែលម្អសេវាជាបន្តបន្ទាប់[45]។ សេវាសំខាន់ៗទាំងអស់ត្រូវមានដំណើរការចងក្រងច្បាស់លាស់សម្រាប់កំណត់ត្រាត្រឹមត្រូវ និងការរក្សាទុកព័ត៌មានរបស់ជនរងគ្រោះនិងសេវាដែលផ្តល់ដល់ពួកគាត់ជាសម្ងាត់និងមានសុវត្ថិភាព។

៩. **ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល៖** ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល មានដូចជា វិធីបញ្ជូន និងជួយដល់ស្ត្រី និងក្មេងស្រីឱ្យទទួលបានសេវាទាន់ពេលវេលានិងសមស្រប។ ដំណើរការបញ្ជូនត្រូវរួមបញ្ចូលស្តង់ដារសម្រាប់ការយល់ព្រមត្រឹមត្រូវ។ដើម្បីជានាការបែងចែកសេវាសំខាន់ៗដោយរលូនដល់ជនរងគ្រោះ ត្រូវមានពិធីសារ និងកិច្ចព្រមព្រៀងស្តីពីដំណើរការបញ្ជូន ដែលរួមមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវានីមួយៗ។



រូបថតទទួលបានពី UN Photo/Eskinder Debebe ( សាធារណរដ្ឋអាហ្វ្រិកកណ្តាល )

45. Humanity &Inculsion ស្នើឡើងថា សេវាសំខាន់ៗទាំងអស់គួរប្រមូលទិន្នន័យបែងចែកតាមពិការភាព។ សូមមើល www.hius.org/

## ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើមពីការជម្រុញការចូលរួមរបស់សហគមន៍ និងការទទួលបានព័ត៌មានស្តីពីបរិបទមូលដ្ឋាន

ខណៈដែលគោលនយោបាយសន្តិសុខជាតិកំណត់អាទិភាព ជាយុទ្ធសាស្ត្រគោលនយោបាយនេះគួរផ្តល់គោលបំណងស្នូលដល់អ្នកគ្រប់គ្រងប្រតិបត្តិការក្នុងជួរនគរបាលដែលត្រូវប្រែក្លាយទៅជាការអនុវត្តក្នុងតំបន់បញ្ជាការនៅមូលដ្ឋានក្រោមការសម្របសម្រួលជាមួយដៃគូក្នុងមូលដ្ឋាន[46]។

តាមទ្រឹស្តី គួរមានយន្តការពិគ្រោះយោបល់ដែលលើកកម្ពស់ការចូលរួមប្រកបដោយអត្ថន័យរបស់អ្នកពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មាន និងពិគ្រោះជាមួយនគរបាលស្តីពីអាទិភាពសន្តិសុខ។ យន្តការទាំងនេះអាចមានទម្រង់ផ្សេងៗ ដូចជា វេទិកាសាធារណៈនៅថ្នាក់ក្រុង ឬគណៈកម្មាធិការសេវានគរបាលក្នុងសហគមន៍។ ល្អបំផុតគឺសហគមន៍គួរផ្តល់ព័ត៌មានដល់នគរបាលស្តីពីតម្រូវការសន្តិសុខរបស់ខ្លួនហើយនគរបាលគួរខិតខំស្វែងយល់ពីតម្រូវការសន្តិសុខផ្សេងៗរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។

**ភាពជាអ្នកដឹកនាំផ្តោតសំខាន់លើមនុស្សមិនមែនដំណើរការ គោលនយោបាយ ឬឯកសារនោះទេ។**

នៅពេលមានយន្តការទាំងនេះ ពួកគេ និងគណៈកម្មាធិការពាក់ព័ន្ធ ត្រូវបញ្ចូលបុគ្គលដែលមានសាវតារចម្រុះ និងទុកមួយអន្លើនូវការជំរុញការចូលរួមរបស់"មេដឹកនាំសហគមន៍" ដែលច្រើនតែជាបុរស និងចាត់តាំងដោយខ្លួនឯង។ ថ្នាក់ដឹកនាំនគរបាលគួរដឹងពីរបៀបដែលយន្តការពិគ្រោះយោបល់អាចជាប្រភពព័ត៌មានដ៏មានតម្លៃនិងការកសាងភាពជាដៃគូ ដើម្បីឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

នៅពេលគ្មានយន្តការពិគ្រោះយោបល់ក្នុងមូលដ្ឋាន ថ្នាក់ដឹកនាំនគរបាលគួរខិតខំតស៊ូមតិឱ្យមានការបង្កើតយន្តការនេះ ឬជម្រុញការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីលើកកម្ពស់ការបង្កើតយន្តការនោះ។ នគរបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់បែបប្រតិសកម្មនូវចំណុចចាប់ផ្តើមនៃកិច្ចសហការជាមួយសហគមន៍ដែលពួកគេផ្តល់សេវាជូន ដែលនឹងជួយទប់ស្កាត់បទល្មើស និងអំពើហិង្សាជារួម។ ដូចគ្នានេះដែរ នគរបាលមានតួនាទីធានាថាក្រុមសហគមន៍ ឬសមាជិក សហគមន៍ដែលប្រឈមនឹងហានិភ័យខ្ពស់នៃបទល្មើសហិង្សា ដូចជា ជនមានពិការភាព ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទអ្នកប្តូរយេនឌ័រនិងអ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរភេទ (LGBTI) ចាស់ជរា យុវជនប្រឈមនឹងហានិភ័យ និងអ្នករស់នៅទីដាច់ស្រយាលចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការពិគ្រោះយោបល់។

**សូមមើលជំពូកទី ៣ (ការទប់ស្កាត់) និងជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) សម្រាប់ឧទាហរណ៍បន្ថែមទៀតនៃយន្តការពិគ្រោះយោបល់។**

គួរពិភាក្សាការយល់ដឹងអំពីឫសគល់នៃអំពើហិង្សា មូលហេតុ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី ក្នុងដំណើរការពិគ្រោះយោបល់ទូលំទូលាយ។ ដំណើរការនេះ ទាមទារការចូលរួមប្រកបដោយអត្ថន័យពីសហគមន៍ចម្រុះអង្គការស្ត្រីនៅមូលដ្ឋាន អង្គការដែលតំណាងឱ្យជន និងក្រុមភាគតិច ព្រមទាំងជនរងគ្រោះដែលធ្លាប់ឆ្លងកាត់ប្រព័ន្ធតុលាការផ្ទាល់ (ជានាការយល់ព្រម ការរក្សាការសម្ងាត់ និងការការពារ)។

នៅពេលទទួលបានព័ត៌មានទាំងនេះមានភាពជាតំណាងព្រមទាំងការពិគ្រោះយោបល់ដ៏ទូលំទូលាយ ថ្នាក់ដឹកនាំនគរបាលអាចធ្វើការកែសម្រួលអភិក្រមដោយផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ[47] ដើម្បីអាចបំពេញតម្រូវការរបស់ជនរងគ្រោះបានកាន់តែប្រសើរ នៅពេលមានអំពើហិង្សាលើស្ត្រី និងក្មេងស្រីកើតឡើង។

46. យុទ្ធសាស្ត្រមួយស្តីពីការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវផ្តល់គោលដៅដែលអាចសម្រេចបាន ដែលដាក់បញ្ចូលក្នុងក្របខណ្ឌយុទ្ធសាស្ត្រផ្សេងទៀត ដូចជា ការផ្សារភ្ជាប់ទៅនឹងផែនការសេវាកុមារ និងយុទ្ធសាស្ត្រសុខភាពជាតិ។ ក្នុងន័យនេះ អាជ្ញាធរត្រូវធានាថា ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាបញ្ហាអាទិភាព "ទូទាំងរដ្ឋាភិបាល" មិនមែនត្រឹមតែជាបញ្ហាបទល្មើស និងសុវត្ថិភាពសាធារណៈនោះទេ។

**ចងចាំថាក្នុងនាមជានគរបាលអ្នកជាសមាសភាពសំខាន់របស់សហគមន៍ ហើយសហគមន៍ក៏ជាសមាសភាពសំខាន់របស់អ្នក!**

ក្នុងករណីមានអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការចូលរួមយ៉ាងសកម្មជាមួយសហគមន៍រងផលប៉ះពាល់ និងការអនុវត្តស្តង់ដារនៃអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនឹងធ្វើឱ្យសហគមន៍ដែលនគរបាលផ្តល់សេវាជូន យល់ថានគរបាលជាអ្នកផ្តល់សេវាដ៏សំខាន់ដែលស្របច្បាប់ និងឆ្លើយតបនឹងយេនឌ័រ។

ដូច្នេះ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រជាការប្រុងប្រយ័ត្នក្នុងការសហការជាបន្តបន្ទាប់របស់នគរបាលជាមួយក្រុមចម្រុះមកពីសហគមន៍ដែលពួកគេផ្តល់សេវាជូន ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះដោយសារអំពើហិង្សា ក្នុងការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក និងផ្អែកតាមសិទ្ធិ។

សេណារីយ៉ូខាងក្រោមផ្តល់ឧទាហរណ៍ពីភាពជោគជ័យផ្នែកប្រតិបត្តិការ នៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**សេណារីយ៉ូទី ១ ៖**

១ សេវានគរបាលបំពេញតម្រូវការរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការធានាការចូលរួមនិងការពិគ្រោះយោបល់ជាមួយពួកគេដោយគ្មានការរើសអើងក្នុងដំណើរការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក និងក្រោមការសម្របសម្រួលជាមួយសមាជិកសហគមន៍និងតួអង្គគាំទ្រក្នុងវិស័យសុខាភិបាល សេវាសង្គម និងវិស័យយុត្តិធម៌។

**សេណារីយ៉ូទី ២ ៖**

២ ការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក បូករួមនឹងកិច្ចសហការបែបប្រតិសកម្មរវាងនគរបាល និងសហគមន៍ ក្នុងការរារាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានបង្កើនភាពអង់អាចរបស់ជនរងគ្រោះជាច្រើនឱ្យរាយការណ៍ទៅនគរបាល និងចូលរួមក្នុងដំណើរការតុលាការ។

**សេណារីយ៉ូទី ៣ ៖**

៣ ហានិភ័យនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានកាត់បន្ថយ ព្រោះនគរបាល និងសហគមន៍សហការគ្នាយ៉ាងសកម្មក្នុងការធានាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដែលអាចបំពេញតម្រូវការចម្រុះរបស់ជនរងគ្រោះ ហើយជនបង្កត្រូវទទួលខុសត្រូវ និងប្រឈមមុខនឹងផលវិបាកនៃអំពើហិង្សារបស់ខ្លួន។

**សេណារីយ៉ូទី ៤ ៖**

៤ ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា អំពើហិង្សាអន្តរបុគ្គល មិនសូវប្រព្រឹត្តល្មើសឡើងវិញទៀយ ព្រោះនគរបាលពង្រឹងការអនុវត្តដីកាការពារពលរដ្ឋប្រកបដោយប្រសិទ្ធភាពដែលផ្តល់សារយ៉ាងច្បាស់ថាមានផលវិបាកសម្រាប់ការរំលោភដីកា និងការប្រព្រឹត្តល្មើសឡើងវិញលើជនរងគ្រោះដដែល ឬជនរងគ្រោះម្នាក់ផ្សេងទៀត។

---

47. យោងតាមក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ផ្តោតសំខាន់លើសិទ្ធិ តម្រូវការ និងបំណងប្រាថ្នារបស់ស្ត្រី និងក្មេងស្រីក្នុងការផ្តល់សេវា។ចំណុចនេះត្រូវមានការពិចារណាពីតម្រូវការចម្រុះរបស់ជនរងគ្រោះ ហានិភ័យ និងភាពងាយរងគ្រោះផ្សេងៗ ផលប៉ះពាល់នៃសេចក្តីសម្រេចចិត្ត និងវិធានការដែលធ្វើឡើង និងធានាថា សេវាសមស្របនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងក្មេងស្រីម្នាក់ៗត្រូវបានផ្តល់ឱ្យស្របទៅតាមបំណងប្រាថ្នារបស់ស្ត្រី និងក្មេងស្រី។ សូមមើល https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2015/essential-servicespackage-module-1-en.pdf?la=en&vs=3347 p. 13.

## ការជួយសម្រួលដល់កិច្ចការរបស់អ្នក៖ សូចនាករដែលគិតគូរពីយេនឌ័រក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

ការរៀបចំផែនការជានាភាពជោគជ័យរបស់ក្រុមនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ផ្អែកលើសមត្ថភាពនៃក្រុមរបស់អ្នកក្នុងការគ្រប់គ្រងសកម្មភាពដែលកំពុងអនុវត្ត។ មានន័យថា សមាជិកក្រុមទាំងអស់យល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាតួនាទី និងការទទួលខុសត្រូវរបស់គ្នាទៅវិញទៅមកនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

សៀវភៅណែនាំនេះកត់សម្គាល់ថា តួនាទី និងការទទួលខុសត្រូវរបស់ក្រុមនឹងប្រែប្រួលទៅតាមស្ថាប័ននគរបាល។ ទោះជាយ៉ាងណាសមាជិកក្រុមទាំងអស់គួរខិតខំបង្ហាញបណ្តុំជំនាញទន់និងសមត្ថភាពដែលគាំទ្រដល់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព និងដោយមិនគិតពីតួនាទីក្នុងក្រុម។ បណ្តុំជំនាញ និងសមត្ថភាពទាំងនេះនឹងត្រូវបានលើកមកពិភាក្សាក្នុងជំពូកបន្ទាប់មកទៀតក្នុងសៀវភៅណែនាំនេះ ហើយនឹងរំលេច គោលការណ៍ និងលក្ខណៈទូទៅនៃកញ្ចប់សេវាសំខាន់ៗ (រូប ២)។

ការរៀបចំផែនការដែលផ្តល់ភាពជោគជ័យដល់ក្រុម រួមមានការកត់សម្គាល់ ការច្បាមយក ការវិភាគ និងការប្រើប្រាស់ទិន្នន័យចាំបាច់ដែលគិតគូរពីយេនឌ័រ និងបែងចែកតាមភេទដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការអនុវត្តការងាររបស់ក្រុមទាំងមូល និងការណែនាំដែលចាំបាច់។ ការប្រមូលទិន្នន័យក្នុងក្រុមគួរឆ្លុះបញ្ចាំងពីទំហំបទល្មើសពាក់ព័ន្ធនឹងយេនឌ័រ ដែលបានកើតឡើង ព្រោះវាជាសូចនាករដ៏សំខាន់ទាក់ទងនឹងសន្តិសុខរបស់ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី[48]។

វិធានការអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា អន្តរាគមន៍របស់នគរបាលចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីគិតគូរពីតម្រូវការរបស់ជនរងគ្រោះ។ ការនេះនឹងជួយដល់ជនរងគ្រោះក្នុងការរាយការណ៍ទៅនគរបាលនិងស្វែងរកដំណោះស្រាយផ្លូវតុលាការ រហូតដល់ការបញ្ចប់ករណី។ ក្រៅពីនេះ វិធានការអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រផ្តល់មូលដ្ឋានព័ត៌មានដល់អ្នកតាក់តែងគោលនយោបាយ និងសហគមន៍ស្តីពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្រសេវានគរបាល។

> "ការគិតគូរពីយេនឌ័រមានគោលបំណងស្វែងយល់ និងពិចារណាពីកត្តាសង្គម និងកត្តាវប្បធម៌ដែលពាក់ព័ន្ធក្នុងការផាត់ចេញ និងការរើសអើងផ្អែកលើយេនឌ័រ ក្នុងទិដ្ឋភាពចម្រុះបំផុតនៃជីវិតសាធារណៈនិងជីវិតឯកជន"។
>
> វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ

ក្នុងនាមជាអ្នកគ្រប់គ្រងក្នុងជួរនគរបាល ឬប្រធានក្រុម ការធ្វើប្រតិបត្តិការដោយជោគជ័យនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ផ្អែកលើកម្រិតដែលក្រុមរបស់អ្នកអាចកំណត់រកនិងច្បាមយកទិន្នន័យដែលគិតគូរពីយេនឌ័រនៅពេលបំពេញមុខងារប្រចាំថ្ងៃ។ ការមានកម្រងសូចនាករអនុវត្តន៍ការងារច្បាស់លាស់ដែលគិតគូរពីយេនឌ័រ[49] និងក្រុមដែលត្រៀមខ្លួនប្រមូលព័ត៌មានទាំងនោះ ជាជំហានដំបូងក្នុងការកំណត់ថាតើក្រុមរបស់អ្នកកំពុងឆ្លើយតបប្រកបដោយប្រសិទ្ធិភាព និងគ្រប់គ្រាន់ ឬទេ។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃសូចនាករអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រសម្រាប់សកម្មភាពរបស់នគរបាល ៖

- ការកើនឡើងនៃអត្រាជនរងគ្រោះដែលរាយការណ៍ពីអំពើហិង្សាលើស្ត្រី ទៅនគរបាល បែងចែកតាម

48. សូមមើលផងដែរ Megan Bastick "មគ្គុទេសក៏នៃស្វ័យវាយតម្លៃយេនឌ័រសម្រាប់នគរបាល កងកម្លាំងប្រដាប់អាវុធ និង វិស័យយុត្តិធម៌" (Geneva: DCAF, 2011) សម្រាប់ព័ត៌មានបន្ថែមស្តីពីការច្បាមយកការវិភាគ និងការប្រើប្រាស់ទិន្នន័យដែលគិតគូរពីយេនឌ័រ។
49. យេនឌ័រសំដៅលើតួនាទី និងទំនាក់ទំនង បុគ្គលិកលក្ខណៈ ឥរិយាបថ អាកប្បកិរិយា និងគុណតម្លៃដែលសង្គមកំណត់លើបុរស និងស្ត្រី។ ដូច្នេះ "យេនឌ័រ" សំដៅលើភាពខុសគ្នាដែលត្រូវបានសិក្សារៀនសូត្រដោយបុរស និងស្ត្រី ចំណែក "ភេទ" សំដៅលើភាពខុសគ្នាផ្អែកជីវសាស្ត្ររវាងមនុស្សប្រុស និងមនុស្សស្រី។ តួនាទីយេនឌ័រប្រែប្រួលក្នុង និងរវាងវប្បធម៌នានា និងអាចផ្លាស់ប្តូរតាមពេលវេលា។ យេនឌ័រមិនត្រឹមតែសំដៅលើស្ត្រី ឬបុរសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំដៅលើទំនាក់ទំនងរវាងស្ត្រី និងបុរសទៀតផង។ សូមមើល Megan Bastick, Kristin Valasek. (2008), 'Security Sector Reform Assessment, Monitoring and Evaluation and Gender' in the Gender and SSR Toolkit, Geneva Centre for Security Sector Governance.

អាយុ យេនឌ័រ និងអថេរសង្គមសេដ្ឋកិច្ចផ្សេងទៀត[50] ដូចជា ជាតិពន្ធុ និងពិការភាព។

- ភាគរយជនរងគ្រោះ ដែលធ្លាប់ប្រើប្រាស់សេវាឯកទេសសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអាចរាយការណ៍ពីការបញ្ចប់ទាំងស្រុងនៃការរំលោភបំពានគ្រប់ប្រភេទ បែងចែកតាមអាយុ ពិការភាព យេនឌ័រ និងអថេរសង្គមសេដ្ឋកិច្ចផ្សេងទៀត។
- ភាគរយជនរងគ្រោះដែលបង្ហាញការពេញចិត្តចំពោះការគាំទ្រ និងជំនួយដែលទទួលបានពីសេវាដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី បែងចែកតាមអាយុ ពិការភាព និងអថេរសង្គមសេដ្ឋកិច្ចផ្សេងទៀត។

ទោះជាយ៉ាងណា ការប្រមូលទិន្នន័យបទល្មើសដែលពាក់ព័ន្ធនឹងយេនឌ័រ ត្រូវការមូលដ្ឋានដូចរិបានការអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រសម្រាប់បង្កើនភាពមានវិជ្ជាជីវៈ និងទំនើបកម្មស្ថាប័ននគរបាលផងដែរ។ ជាធម្មតាការផ្តល់មូលដ្ឋានសម្រាប់ការប្រមូលទិន្នន័យទាំងនេះ គឺជាដំណើរការក្នុងស្ថាប័នដែលបន្សុីគ្នានឹងគោលដៅកម្រិតយុទ្ធសាស្ត្រ។នៅពេលមានមូលដ្ឋានទាំងនេះថ្នាក់ដឹកនាំនគរបាលអាចសន្មតកែប្រែតួនាទីរបស់ស្ថាប័ននិងបង្កើតមូលដ្ឋានសម្រាប់សកម្មភាពក្នុងក្រុមរបស់ខ្លួនដោយមានជំនួយពីអង្គភាពដែលមានតួនាទីប្រមូល និងវិភាគស្ថិតិ។

**ប្រអប់ ៥**

**តើអ្វីជាសូចនាករអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រ?**

សូចនាករអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រអាចជារង្វាស់រង្វាល់ លេខ ព័ត៌មានពិត ទស្សនៈ ឬការយល់ឃើញដែលបញ្ជាក់ពីលក្ខខណ្ឌឬស្ថានភាពជាក់លាក់ពាក់ព័ន្ធនឹងតួនាទី អាកប្បកិរិយា សកម្មភាព និងគុណលក្ខណៈដែលសង្គមមួយនៅពេលមួយយល់ថាសមស្របសម្រាប់បុរស និងស្ត្រី។ សូចនាករអនុវត្តន៍ការងារដែលគិតគូរពីយេនឌ័រ វាស់វែងការប្រែប្រួលលក្ខខណ្ឌ ឬស្ថានភាពទាំងនេះទៅតាមពេលវេលាដោយផ្តល់ព័ត៌មានស្តីពីទំនាក់ទំនងរវាងស្ត្រី និងទំនាក់ទំនងរវាងបុរស ដោយគូសបញ្ជាក់ពីក្តីរំពឹងទុករបស់សង្គមចំពោះពួកគេក្នុងដំណើរការនេះ។

50. គួរកត់សម្គាល់ថា ការកើនឡើងនៃការរាយការណ៍មិនមានន័យថាជាការកើនឡើងនៃឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រីឡើយ។

**សូមមើលជំពូកទី ១០ (ការកសាងស្ថាប័ន) សម្រាប់ការពិភាក្សាបន្ថែមទៀតស្តីពីការប្តេជ្ញាចិត្តរបស់ស្ថាប័នចំពោះការប្រមូលទិន្នន័យដែលគិតគូរពីយេនឌ័រក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

នគរបាលគួរមានការប្រុងប្រយ័ត្ននៅពេលបកស្រាយអត្រាបទល្មើសដែលបានរាយការណ៍ ដូចជា ករណីអំពើហិង្សាផ្លូវភេទ។ ឧ. នៅពេលជូនដំណឹងដល់សាធារណជនអំពីការកើនឡើង ឬការថយចុះនៃបទល្មើសដែលបានរាយការណ៍ សាធារណជនគួរបានដឹងថា ការថយចុះករណីដែលបានរាយការណ៍មិនមែនមានន័យថា កម្រិតនៃអំពើហិង្សាថយចុះនោះទេ។ នេះជាចំណុចសំខាន់ ព្រោះការផ្តោតសំខាន់លើបទល្មើសដែលបានរាយការណ៍ហាក់មើលរំលងបទល្មើសដែលមិនបានរាយការណ៍ (ដូចជាបទល្មើសអំពើហិង្សាទាក់ទងនឹងយេនឌ័រ)។

ផ្ទុយទៅវិញការកើនឡើងនៃការរាយការណ៍អាចឆ្លុះបញ្ចាំងការយល់ដឹងនិងទំនុកចិត្តកាន់តែច្រើនលើស្ថាប័នជាជាងការកើនឡើងនៃកម្រិតអំពើហិង្សា។ គួរឱ្យសោកស្តាយដែលគេលំបាកកំណត់ថានិន្នាការជាវិជ្ជមាននេះបណ្តាលមកពីនគរបាល នៅពេលដែលសេវាសំខាន់ៗផ្សេងទៀតនិងស្ថាប័នអនុវត្តន៍ច្បាប់អាចចូលរួមដោយស្មើភាពគ្នាទៅតាមសមត្ថភាពរបស់ពួកគេ។

វិទ្យាស្ថានជាតិយុត្តិធម៌សហរដ្ឋអាមេរិកលើកឡើងថាការផ្តោតលើការថយចុះនៃចំនួនរបាយការណ៍បទល្មើសធ្ងន់ធ្ងរ ដូចជា អំពើរំលោភសេពសន្ថវៈផ្តល់ចំណេះដឹងតិចតួចបំផុតស្តីពីមធ្យោបាយ ឬយុទ្ធសាស្ត្រដែលប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងបទល្មើសទាំងនេះដូចជាការជម្រុញការចូលរួមរបស់សហគមន៍ ឬអង្គការស្ត្រី។ ចំណុចនេះបង្កការលំបាកដល់ស្ថាប័ននគរបាលក្នុងការកំណត់ផលប៉ះពាល់នេះចេញពីសកម្មភាពផ្សព្វផ្សាយ និងសកម្មភាពកសាងភាពជាដៃគូរបស់នគរបាលដែលជាចំណុចស្នូលនៃសេវានគរបាលក្នុងសហគមន៍និងផ្អែកតាមចារកម្មលុះត្រាតែមានសូចនាករបែបគុណភាពដែលវាស់វែងកម្រិតនៃទំនុកចិត្ត ឬការយល់ឃើញចំពោះសេវានគរបាល។

ការផ្តោតសំខាន់លើការថយចុះចំនួនរបាយការណ៍បទល្មើសធ្ងន់ធ្ងរអាចដាក់សម្ពាធឥតឈប់ឈរលើការបន្ថយចំនួនបទល្មើសទាំងនោះប៉ុន្តែគ្មានការដាក់សម្ពាធលើការរក្សាសុចរិតភាពនៃប្រព័ន្ធកត់ត្រា និងប្រព័ន្ធរាយការណ៍[51]។ វិទ្យាស្ថានជាតិយុត្តិធម៌សហរដ្ឋអាមេរិកលើកឡើងថា ការដាក់សម្ពាធឱ្យសម្រេចបានចំណុចដៅសុវត្ថិភាពសាធារណៈ ជាពិសេសនៅពេលមានមហិច្ឆិតាធំហួសហេតុនាំឱ្យមានការចាត់ចែងស្ថិតិបទល្មើស( ការដាក់សម្ពាធលើរបាយការណ៍និងការធ្វើចំណាត់ថ្នាក់បទល្មើសមិនត្រឹមត្រូវ ) និងទម្រង់ផ្សេងទៀតនៃអំពើពុករលួយ[52]។

**ការវិភាគយេនឌ័រជាការពិនិត្យល្អិតល្អន់ថាតើតួនាទីយេនឌ័រ សកម្មភាព តម្រូវការ ឱកាស និងសិទ្ធិ/សិទ្ធិទទួលបាន បង្កផលប៉ះពាល់ដូចម្តេចលើបុរស ស្ត្រី ក្មេងស្រី និងក្មេងប្រុសក្នុងស្ថានភាព ឬបរិបទមួយជាក់លាក់។**

អ្នកជំនាញគូសបញ្ជាក់ថា ទង្វើខុសឆ្គងក្នុងស្ថាប័នលេចឡើងនៅពេលមានការផ្តោតកាន់តែខ្លាំងលើការសម្រេចបានលទ្ធផលចុងក្រោយ ជាជាងការរឹតត្បិតមធ្យោបាយ[53]។ ជាលទ្ធផលបទដ្ឋានដែលកំហិតមធ្យោបាយមិនសូវទទួលបានចំណាប់អារម្មណ៍និងហាក់បាត់បង់ផលប៉ះពាល់លើការកំហិតអាកប្បកិរិយា។

ឧ.គោលនយោបាយសន្តិសុខដែលរួមបញ្ចូលចំណុចដៅនៃការប្រយុទ្ធប្រឆាំងអំពើភេរវកម្មអាចជំរុញឱ្យនគរបាល "ផ្តល់សេវាច្រើនហួសហេតុ" ដល់សហគមន៍គោលដៅដែលអាចធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលក្នុងការផ្តល់សេវាដល់សហគមន៍កន្លងមក ដើម្បីទទួលបានទំនុកចិត្តពីសហគមន៍ រួមទាំងទំនុកចិត្តពីស្ត្រីនិងក្មេងស្រីដែលអាចមិនត្រូវបានអើពើ និង/ឬត្រូវបានមើលរំលងកាន់តែខ្លាំង និងងាយរងគ្រោះទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ក្នុងឧទាហរណ៍មួយផ្សេងទៀត គោលនយោបាយសន្តិសុខដែលខិតខំកាត់បន្ថយចំនួននៃការធ្វើទេសន្តរប្រវេសន៍ខុសច្បាប់ជាញឹកញាប់បង្ខំឱ្យជនចំណាកស្រុកខុសច្បាប់មិនរាយការណ៍ពីបទល្មើសដែលបានប្រព្រឹត្តលើពួកគេ ឬអ្នកដទៃ ដូចជា បទល្មើសដែលពាក់ព័ន្ធនឹងទាសភាពសម័យទំនើប ការជួញដូរមនុស្ស អំពើហិង្សាអន្តរបុគ្គល និងអំពើហិង្សាផ្លូវភេទ។ល។

តាមរយៈការវិភាគយេនឌ័រដែលផ្តោតលើកត្តាប្រទាក់ក្រឡា (សូមមើលខាងក្រោម) ក្នុងការប្រមូលទិន្នន័យស្តីពីបទល្មើសដែលពាក់ព័ន្ធនឹងយេនឌ័រ ថ្នាក់ដឹកនាំនគរបាលងាយស្រួលកំណត់រកផលប៉ះពាល់ផ្សេងៗនៃសកម្មភាពរបស់ខ្លួនលើសហគមន៍ដែលនគរបាលផ្តល់សេវាជូន និងការពារ។ ទាំងនេះជាព័ត៌មានដែលត្រូវផ្សព្វផ្សាយជូនសាធារណជន នៅពេលបង្ហាញអត្រានៃបទល្មើសដែលបានរាយការណ៍។

ក្រៅពីនេះ ការធានាថា ការរៀបចំផែនការរបស់ក្រុមអ្នករួមបញ្ចូលការវិភាគដែលគិតគូរពីយេនឌ័រ[54] ក្នុងសកម្មភាពរបស់ខ្លួននឹងជួយកាត់បន្ថយការពង្រឹងការរើសអើងកន្លងមករបស់មន្ត្រីនគរបាលដូចគ្នាឬដៃគូជិតស្និទ្ធផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌។ ចំណុចនេះនឹងជួយកាត់បន្ថយហានិភ័យដល់ក្រុមការងាររបស់អ្នកក្នុងពេលបំពេញភារកិច្ចពីករណីរំលោភសិទ្ធិមនុស្ស ។
សៀវភៅណែនាំនេះផ្តល់សូចនាករយោងផ្សេងៗជាច្រើនដល់នគរបាល ដោយផ្អែកលើលក្ខណៈទូទៅនៃសេវាសំខាន់ៗប្រកបដោយគុណភាពក្នុងកញ្ចប់សេវាសំខាន់ៗ ដើម្បីបំពេញបន្ថែមលើអត្រាបទល្មើសជាក់លាក់ ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យសហគមន៍ដែលគរបាលផ្តល់សេវាជូន មើលឃើញកិច្ចខិតខំប្រឹងប្រែងរបស់នគរបាល។

សូចនាករយោងដែលលើកឡើងមានបង្ហាញក្នុងជំពូកទី ៣ ដល់៩ នៃសៀវភៅណែនាំនេះដើម្បីជួយដល់ថ្នាក់ដឹកនាំនគរបាលក្នុងការកំណត់ប្រភពទិន្នន័យ ដែល

51. Malcolm K. Sparrow ( 2015 ), 'Measuring Performance in a Modern Police Organization' in 'New Perspectives in Policing'. ( National Institute of Justice ).

52. Ibid

53. D, Vaughan, 'Controlling Unlawful Organizational Behavior: Social Structure and Corporate Misconduct', Chicago, Illinois: University of Chicago Press, 1983 and R.K., Merton, 'Social Structure and Anomie,' in Social Theory and Social Structure, enlarged ed., New York: New York: The Free Press, 1968. See also n. 37.

54. ក្រៅពីនេះ ការវិភាគ យេនឌ័រគួរខិតខំធ្វើត្រីកោណវិធីលើសាវតារប្រជាសាស្ត្ររបស់ជនរងគ្រោះ ធៀបនឹងនិន្នាការនៃការធ្វើឱ្យរងគ្រោះ ការសិក្សាស្តីពីការយល់ឃើញរបស់ធារណជនចំពោះនគរបាល និងស្ថិតិបទល្មើសពីគ្រប់លំដាប់ថ្នាក់។

ពង្រឹងការឆ្លើយតបនៃក្រុមរបស់ខ្លួនទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ផ្អែកតាមម៉ូឌុលទី ៣ (យុត្តិធម៌ និងនគរបាល) នៃកញ្ចប់សេវាសំខាន់ៗ។ សូចនាករយោងទាំងនេះមិនមែនជាការបង្គាប់បញ្ជានោះទេ ប៉ុន្តែវានឹងបំផុសការដឹកនាំបែបប្រតិសកម្មឆ្ពោះទៅរកសកម្មភាពផ្អែកតាមភស្តុតាង។

"វាអាចជាការងាយស្រួលក្នុងការចាត់ប្រភេទជាសហគមន៍រង ដូចជា ស្ត្រីដែលងាយរងគ្រោះ។ ចំណុចនេះអាចបង្កើតឱ្យមានយល់ឃើញថា ក្រុមស្ត្រីទន់ខ្សោយជាងក្រុមបុរស ដែលធ្វើឱ្យសហគមន៍រងរបស់ស្ត្រីកាន់តែជួបការលំបាក។ ត្រូវអនុវត្តឥរិយាបថមួយដែលបង្កើនភាពអង់អាចដល់ស្ត្រីឱ្យកត់សម្គាល់ភាពខ្លាំងរបស់ខ្លួន។ ដូច្នេះ មន្ត្រីនគរបាលជាស្ត្រីដែលមាន តួនាទីកាន់អំណាចគឺជាបុគ្គលគំរូដ៏មានតម្លៃចំពោះស្ត្រី និងក្មេងស្រីនៅក្នុងសហគមន៍"។

អង្គការសហប្រជាជាតិ ឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល (២០១៥)

## ការកត់សម្គាល់កត្តាផ្សេងគ្នា និងកត្តាប្រទាក់ក្រឡាគ្នា

ស្ត្រី និងក្មេងស្រីមិនមែនជាក្រុមតែមួយនោះទេ។ ដូច្នេះ ដើម្បីឱ្យទិន្នន័យស្តីពីបទល្មើសឆ្លុះបញ្ចាំងពីតម្រូវការសន្តិសុខផ្សេងៗ និងតម្រូវការសន្តិសុខប្រទាក់ក្រឡារបស់ស្ត្រីនិងក្មេងស្រីចាំបាច់ត្រូវមានការប្រមូលព័ត៌មានលម្អិត និងគិតគូរពីយេនឌ័រស្តីពីសាវតារប្រជាសាស្ត្រ និងសាវតារសង្គមសេដ្ឋកិច្ចរបស់ជនរងគ្រោះ[55]។

ក្រៅពីនេះទិន្នន័យដែលប្រមូលបានគួរឆ្លងកាត់ការវិភាគដែលឆ្លើយតបនឹងយេនឌ័រដែលខិតខំកំណត់តម្រូវការ និងក្តីរំពឹងទុករបស់ស្ត្រីបុរសក្មេងស្រីនិងក្មេងប្រុសរបៀបដែលពួកគេខុសប្លែកពីគ្នា ថាតើអន្តរាគមន៍ដែលគ្រោងឡើង នឹងដោះស្រាយតម្រូវការផ្នែកយេនឌ័ររបស់ពួកគេឬទេ ហើយ ការរួមចំណែកក្នុងការបំពេញតម្រូវការរបស់ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីត្រូវបានពង្រឹងឬទេ។

"ប្រជាជនទូទាំងពិភពលោកប្រហែល ១៥% មានពិការភាពតាមបែបផ្សេងៗគ្នា"។

The Sphere Handbook (2018)

ក្នុងផ្នែកដ៏សំខាន់មួយនៃការវិភាគយេនឌ័រដែលគិតគូរពីយេនឌ័រ ថ្នាក់ដឹកនាំនគរបាលគួរប្តេជ្ញា អនុវត្តទស្សនៈប្រទាក់ក្រឡា ឬ "ភាពប្រទាក់ក្រឡា" ដែលកំណត់ថាតើស្ត្រីនិងក្មេងស្រីប្រឈមនឹងអំពើហិង្សាតាមរូបភាពខុសគ្នា និងរងគ្រោះដោយបទល្មើសដោយរបៀបណា។ ចំណុចនេះជួយឱ្យអ្នកយល់ពីបទពិសោធន៍របស់ស្ត្រីនិងក្មេងស្រីនៅចំណុចប្រទាក់ក្រឡាលើកត្តាគៀបសង្កត់ដំណាលគ្នាជាច្រើនដែលរួមមាន (ប៉ុន្តែមិនកំណត់ត្រឹម) ជាតិសាសន៍ ឋានៈ វណ្ណៈ យេនឌ័រ ជាតិពន្ធុ ផ្លូវភេទ ពិការភាព សញ្ជាតិ ស្ថានភាពទេសន្តរប្រវេសន៍ទីតាំងភូមិសាស្ត្រសាសនា[56]។ល។

អត្តសញ្ញាណសង្គមរបស់បុគ្គលម្នាក់ ដូចជា ជនមានពិការភាពឬជនមកពីក្រុមភាគតិច[57]ឬក្រុមដែលមានតំណាងតិចតួចអាចរួមផ្សំជាមួយនឹងកាលៈទេសៈតាមស្ថានភាព ដូចជា ជម្លោះប្រដាប់អាវុធ និង/ឬវិបត្តិសិទ្ធិមនុស្សដើម្បីបង្កើនកម្រិតហានិភ័យនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**សូមមើលជំពូកទី ១៣ (បញ្ហាដែលលេចឡើង) សម្រាប់ព័ត៌មានបន្ថែមស្តីពីរបៀបដែលកាលៈទេសៈតាមស្ថានភាពដែលពាក់ព័ន្ធនឹងជម្លោះ និងអត្តសញ្ញាណសង្គមរបស់បុគ្គលប្រទាក់ក្រឡាគ្នា ដើម្បីបង្កើនភាពងាយរងគ្រោះទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

55. យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ (សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឧបសម្ព័ន្ធ) អំពាវនាវឱ្យរដ្ឋសមាជិកបង្កើត និងពង្រឹងយន្តការសម្រាប់ការប្រមូលទិន្នន័យជាប្រព័ន្ធស្តីពីអំពើហិង្សាលើស្ត្រី ដើម្បីវាយតម្លៃវិសាលភាព និងប្រេវ៉ាឡង់នៃអំពើហិង្សានេះ និងតម្រឹមតម្រង់ការរៀបចំការអនុវត្ត និងការផ្តល់មូលនិធិដល់ការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព។

56. "គុណតម្លៃនៃភាពប្រសព្វគ្នាក្នុងការស្វែងយល់ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី" (Imkaan, UN Women and the European Union, July 2019).

57. ការធ្វើឱ្យក្លាយទៅជាក្រុមភាគតិច បង្កើត និងរក្សាលក្ខខណ្ឌសង្គម នយោបាយ សេដ្ឋកិច្ច និងលក្ខខណ្ឌផ្សេងទៀតដោយប្រសិទ្ធភាព ដែលនាំទៅរកក្រុមមនុស្សដែលត្រូវបានចាត់ទុក និងកំណត់ជាក្រុមជនជាតិភាគតិច ដូចជា "ជនជាតិភាគតិច" និង "ជាតិពន្ធុភាគតិច"។ ការធ្វើឱ្យក្លាយទៅជាក្រុមភាគតិចជាដំណើរការបន្តជាប់ និងរស់រវើកដែលធ្វើឱ្យក្រុមដាក់លាក់ជួបការលំបាក ដោយសារ "ជាតិសាសន៍" ជាតិពន្ធុ និងមូលហេតុផ្សេងទៀត។ សូមមើល 'ពីចំណុចសើៗឆ្ពោះទៅរកចំណុចស្នូល ៖ ការដោះស្រាយអំពើហិង្សាលើស្ត្រិ និងក្មេងស្រី ជម្រើសផ្សេងទៀត' (Imkaan, October 2018)។

ដោយសារតែនគរបាលមានភារកិច្ចផ្អែកតាមវជ្ជធម្មនុញ្ញ និងកាតព្វកិច្ចអន្តរជាតិក្នុងការការពារប្រជាជនមូលដ្ឋាន ពីអំពើហិង្សានិងបទល្មើសដោយគ្មានការរើសអើងរបៀប ដែលនគរបាលប្រមូលទិន្នន័យទាំងនេះឆ្លុះបញ្ចាំងពីការ ប្តេជ្ញាចិត្តបំពេញសេវា និងភារកិច្ចនេះ។

The Sphere Handbook (2018) ស្នើឱ្យបែងចែក ទិន្នន័យជាប្រភេទនិងធ្វើចំណាត់ថ្នាក់សមស្របទៅតាម បរិបទដើម្បីយល់ពីភាពខុសគ្នាផ្អែកតាមភេទ ឬយេនឌ័រ អាយុ ពិការភាព ភូមិសាស្ត្រ ជាតិពន្ធុ សាសនា វណ្ណៈ ឬ កត្តាផ្សេងទៀតដែលអាចរឹតត្បិតលទ្ធភាពទទួលបាន ជំនួយដោយយុត្តិធម៌[58]។

ការយល់ពីរបៀបដែលអត្តសញ្ញាណសង្គម និងកាលៈទេសៈ តាមស្ថានភាពអាចប្រទាក់ក្រឡាក្នុងការបង្កើន ឬកាត់ បន្ថយហានិភ័យ ឬគំរាមកំហែងដល់ស្ត្រី និងក្មេងស្រី នឹង នាំឱ្យមានការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវស្តីពី ការកំណត់អាទិភាពធនធានមនុស្ស និងធនធានសម្ភារ ទាំងក្នុងការទប់ស្កាត់និងការឆ្លើយតបទៅនឹងអំពើហិង្សា លើស្ត្រី និងក្មេងស្រី។ ដើម្បីឱ្យយល់ច្បាស់ពីអភិក្រម ប្រទាក់ក្រឡា[59] សម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី UNWomen (2018)[60] បានបង្ហាញពីបុគ្គលិកលក្ខណៈ និងស្ថានភាពនានាដែលជះឥទ្ធិពលលើភាពងាយរងគ្រោះ របស់ស្ត្រី និងក្មេងស្រីទៅនឹងអំពើហិង្សាដូចខាងក្រោម (រូប ៥)។

"បុគ្គលដែលកំណត់អត្តសញ្ញាណជាស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរ យេនឌ័រ អ្នកដែលមិនកំណត់ថាខ្លួនជាមនុស្សប្រុស ឬ មនុស្សស្រី ឬអ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរ ភេទ (LGBTQI) គឺជាញឹកញាប់ប្រឈមនឹងហានិភ័យ កាន់តែខ្ពស់នៃការរើសអើងការមាក់ងាយនិងអំពើហិង្សា ផ្លូវភេទ និងអំពើហិង្សាផ្លូវកាយ"។

The Sphere Handbook (2018)

58. 'The Sphere Handbook ៖ ធម្មនុញ្ញមនុស្សធម៌ និងស្តង់ដារអប្បបរមាក្នុងការឆ្លើយតប ផ្នែកមនុស្សធម៌' ការបោះពុម្ពលើកទី ៤ (The Sphere Association. Geneva, Switzerland, 2018)។
59. Crenshaw, K., 'Demarginalizing the Intersection of Race and Sex: A Black Feminist Critique of Antidiscrimination Doctrine, Feminist Theory and Antiracist Politics', University of Chicago Legal Forum Volume 1989, Issue 1 Article 8.
60. 'ឯកសារជំនួយស្មារតីរបស់អ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការ រៀបចំកម្មវិធីយុត្តិធម៌ (UN Women et al. 2018) https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-completetoolkit-en.pdf? la= en&vs=2654

### រូប ៥ ៖ បុគ្គលិកលក្ខណៈ និង ស្ថានភាពដែលជះឥទ្ធិពលលើភាពងាយរងគ្រោះ




## តើអ្វីជាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ

យោងតាម UNODC[61] នគរបាលអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនៅពេលពួកគេចាត់ទុកតម្រូវការរបស់ជនរងគ្រោះជាចំណុចស្នូលនៃកិច្ចអន្តរាគមន៍ ចាប់ពីគោលនយោបាយស្ថាប័ន រហូតដល់ប្រតិបត្តិការ និងវិធានការដាក់លាក់។ ចំណុចនេះពាក់ព័ន្ធនឹងការធានាការផ្តល់សេវាដែលការពារ ពង្រឹង និងគាំទ្រការបង្កើនភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រី ទន្ទឹមនឹងការផ្តោតអាទិភាពលើបញ្ហាសុវត្ថិភាពផ្លូវកាយ និងសុវត្ថិភាពផ្លូវចិត្ត។

សំខាន់បំផុតអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ មានគោលបំណងជួយដល់ជនរងគ្រោះ ក្នុងការស្វែងរកយុត្តិធម៌សម្រាប់បទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរបៀបដែលផ្តល់នូវសេមានចិត្ត និងការគោរព និងបន្ទុចបង្អាក់មិនឱ្យមន្ត្រីស្តីបន្ទោសជនរងគ្រោះដែលស្ទាក់ស្ទើរមិនហ៊ានសហការជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ដូច្នេះ នគរបាលត្រូវដឹង និងគិតគូរពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត[62] និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះជាពិសេសនៅពេលជនរងគ្រោះមិនសហការ ព្រោះពួកគេអាចរងការប៉ះទង្គិចជាក់ស្តែង និងភ័យខ្លាចជនបង្ក និង/ឬសម្ពាធជាប្រព័ន្ធ និងត្រូវការការគាំទ្រជាបន្ទាន់។

> នគរបាលដែលអាចការរក្សាការសម្ងាត់ដោយជោគជ័យ អាចនាំឱ្យមានការរាយការណ៍ពីបទល្មើសកាន់តែច្រើន និងបង្កើនទំនុកចិត្តលើនគរបាល។
>
> ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥

ដើម្បីអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ នគរបាលត្រូវប្រឆាំងនឹងឥរិយាបថអត់ឱនចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី បន្ទុចបង្អាក់ភាពអសកម្មក្នុងសង្គម និងការស្តីបន្ទោសជនរងគ្រោះ និង

61. 'ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី' (UNODC, 2014)។
62. ការគិតគូរពីបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តរបស់នរណាម្នាក់ ឬការផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត ផ្តោតលើបទពិសោធន៍ជាក់លាក់ដែលជះឥទ្ធិពលលើការប៉ះទង្គិចផ្លូវចិត្ត ការចងចាំ ប្រតិកម្ម និងឥរិយាបថរបស់ជនរងគ្រោះ និងរបៀបដែលការបកស្រាយ ឥរិយាបថនេះដោយមន្ត្រីនគរបាលជះឥទ្ធិពលលើការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាស។ សម្រាប់ព័ត៌មានបន្ថែមសូមមើល "វគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាសផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត" ពីសមាគមអន្តរជាតិនៃស្នងការនគរបាល (IACP) https://www.theiacp.org/projects/trauma-informed-sexual-assault-investigations។

ទទួលស្គាល់របៀបដែលបទល្មើសទាំងនេះបង្កគុណវិបត្តិយូរអង្វែងលើសង្គម និងសេដ្ឋកិច្ចក្នុងសង្គមទាំងអស់ ដោយមិនគិតតែពីផលប៉ះពាល់លើសុខភាពរាងកាយ និងសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះនិងកូនៗនិងសមាជិកគ្រួសារផ្សេងទៀតនោះទេ។

ចំណុចនេះក៏មានន័យផងដែរថាមន្ត្រីនគរបាលដែលមានទំនាក់ទំនងជាមួយជនរងគ្រោះ គួរធានាថា ពួកគេមិនបង្កការរងគ្រោះជាលើកទីពីរ។ ការរងគ្រោះជាលើកទីពីរមិនកើតចេញពីអំពើឧក្រិដ្ឋផ្ទាល់នោះទេប៉ុន្តែបណ្តាលមកពីកង្វះការឆ្លើយតបរបស់នគរបាល និងស្ថាប័ន និងបុគ្គលមានសមត្ថកិច្ចផ្សេងទៀតចំពោះជនរងគ្រោះ[63]។

នៅពេលមានភាពប្រតិសកម្ម និងវិជ្ជាជីវៈក្នុងការបំពេញកិច្ចការដែលបានចាត់តាំងមន្ត្រីឆ្លើយតបអាចកាត់បន្ថយហានិភ័យនៃការរងគ្រោះជាលើកទីពីរបានច្រើន។ ឧ. មន្ត្រីឆ្លើយតបច្រើនតែខ្វះខ្វែងផ្តល់របាយការណ៍នគរបាលដល់ជនរងគ្រោះ ដើម្បីជួយដល់ពួកគេក្នុងការទទួលបានដីកាការពារ ដំណោះស្រាយរដ្ឋប្បវេណី ញត្តិអន្តោប្រវេសន៍ អត្ថប្រយោជន៍ធានារ៉ាប់រង និងការទាមទារសំណងជំងឺចិត្ត។

ដើម្បីធានាថាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះការពារជនរងគ្រោះពីគ្រោះថ្នាក់បន្ថែមទៀត ជួយពួកគេគ្រប់គ្រងអារម្មណ៍ដែលទទួលការមាក់ងាយ និងបង្កើនភាពអង់អាចនៃការសម្រេចចិត្តរបស់ពួកគេដោយគ្មានសម្ពាធ និងការវិនិច្ឆ័យ UNPOL បានដាក់ស្នើគោលការណ៍ណែនាំ៤ចំណុចសម្រាប់ឱ្យនគរបាលយកទៅអនុវត្តប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងវិជ្ជាជីវៈ[64]។

១.សុវត្ថិភាពរាងកាយរបស់ជនរងគ្រោះ
២.ការរក្សាការសម្ងាត់របស់ជនរងគ្រោះ
៣.ការគោរពសិទ្ធិរបស់ជនរងគ្រោះ
៤.ការមិនរើសអើង។

ខាងក្រោមនេះជាខ្លឹមសារសង្ខេបនៃសកម្មភាពសំខាន់ៗ (រូប ៦) ដែលនគរបាលអាចយកទៅអនុវត្តពាក់ព័ន្ធនឹងគោលការណ៍ណែនាំរបស់UNPOLស្តីពីអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងធានាថាគ្មានគ្រោះថ្នាក់បន្ថែមទៀត។

**រូប ៦ ៖ អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ**

**ធានាសុវត្ថិភាពផ្លូវកាយរបស់ជនរងគ្រោះ**

- ធានាការដឹងលឺពីហានិភ័យសន្តិសុខដែលជនរងគ្រោះអាចប្រឈម
- រៀបចំកិច្ចសន្ទនា ការវាយតម្លៃ និងការសួរចម្លើយក្នុងមជ្ឈដ្ឋានដែលមានសុវត្ថិភាព
- ធានាថាជនរងគ្រោះមានកន្លែងសុវត្ថិភាពដែលត្រូវទៅ
- ផ្ទៀងផ្ទាត់ថាតើជនរងគ្រោះអាចប្រឈមមុខជាមួយនឹងជនល្មើស ឬទេ
- ដឹងពីប្រព័ន្ធគាំទ្រដែលមាន។

**រក្សាការសម្ងាត់របស់ជនរងគ្រោះ**

- ចែករំលែករឿងរ៉ាវរបស់ជនរងគ្រោះជាមួយអ្នកជំនាញប្រព័ន្ធគាំទ្រផ្សេងទៀត តែក្នុងករណីដែលជនរងគ្រោះយល់ពីអត្ថន័យ និងផ្តល់ការយល់ព្រមជាមុន
- រឹតត្បិតលទ្ធភាពទទួលបានព័ត៌មានវេជ្ជសាស្ត្រត្រឹមមន្ត្រីមានការអនុញ្ញាត និងអ្នកជំនាញវេជ្ជសាស្ត្រ
- ការពារសុវត្ថិភាពព័ត៌មានស៊ើបអង្កេតទាំងអស់ដើម្បីធានាសុវត្ថិភាពរបស់ជនរងគ្រោះនិងបញ្ចៀសមិនឱ្យជនរងគ្រោះទទួលរងការគំរាមកំហែង ឬបណ្តេញចេញពីសហគមន៍
- ធានាថា ជនរងគ្រោះមិនទទួលរងអំពើហិង្សាបន្ថែម

63. សូមមើល កំណត់សម្គាល់ទី ៤៧។
64. អង្គការសហប្រជាជាតិ ឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ - DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ, 2015)

### រូប ៦ ៖ អភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ (ត)

ទៀត អសន្តិសុខ ឬការរងគ្រោះឡើងវិញ ដោយសារការរាយការណ៍បទល្មើស
- អនុវត្តបានល្អតាមគោលការណ៍រក្សាការសម្ងាត់ប្រសិនបើមានមូលហេតុសមស្របដែលបញ្ជាក់ពីការរំលោភបំពានកុមារ ឬការមិនអើពើ ស្ថានភាពដែលគំរាមកំហែងអាយុជីវិត ការសង្ស័យពីទំនោរធ្វើអត្តឃាត ឬការគំរាមបង្កគ្រោះថ្នាក់លើអ្នកដទៃ។
- ស្វែងរកការណែនាំពីបុគ្គលិកថែទាំសុខភាព និងអ្នកផ្ដល់ប្រឹក្សា ក្នុងស្ថានភាពដែលត្រូវអនុវត្តផ្ទុយពីគោល ការណ៍រក្សាការសម្ងាត់។

#### គោរពសិទ្ធិរបស់ជនរងគ្រោះ

- គោរពការចង់បានសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ តាមរយៈការបង្ហាញឥរិយាបថគាំទ្រ
- ផ្ដោតការយកចិត្តទុកដាក់លើតម្រូវការទាំងអស់របស់ជនរងគ្រោះ រួមទាំងតម្រូវការផ្នែកវេជ្ជសាស្ត្រ ចិត្តវិទ្យាសង្គម និងច្បាប់
- ធានាផលប្រយោជន៍ល្អបំផុតរបស់កុមារដែលពាក់ព័ន្ធ រួមទាំងបង្កើនការប្រុងប្រយ័ត្ននៅពេលស្នើសុំការយល់ព្រមនិងនៅពេលពិគ្រោះជាមួយអាណាព្យាបាលស្របច្បាប់របស់កុមារ
- ធានាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មានតាមរយៈការផ្ដល់ព័ត៌មានបច្ចុប្បន្នភាពសមស្របស្ដីពីករណីរបស់ពួកគេដើម្បីអនុញ្ញាតឱ្យមានការសម្រេចចិត្តផ្អែកតាមព័ត៌មានគ្រប់គ្រាន់ និងការវាយតម្លៃហានិភ័យ។
- ធានាថា ជនរងគ្រោះពាក់ព័ន្ធក្នុងការធ្វើសេចក្ដីសម្រេចចិត្តដើម្បីឱ្យពួកគេទទួលបានភាពអង់អាច និងអាចគ្រប់គ្រងជីវិតរបស់ខ្លួនបាន
- កុំផ្ដល់ការណែនាំដល់ជនរងគ្រោះ ព្រោះជនរងគ្រោះអាចយកទៅប្រាប់នរណាម្នាក់ពីអ្វីដែលអ្នកយល់ថាពួកគេគួរធ្វើ និងរបៀបប្រព្រឹត្ត ដែលមានន័យស្មើនឹងការបញ្ចូលទស្សនៈផ្ទាល់ខ្លួនរបស់អ្នក
- គោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការដែលពួកគាត់មិនព្រមទទួលការព្យាបាលការពិនិត្យ ឬអន្តរាគមន៍ផ្សេងទៀត
- ជនរងគ្រោះមានសិទ្ធិស្នើការអមដំណើរដោយនគរបាល ឬទីប្រឹក្សាម្នាក់ក្នុងពេលស៊ើបអង្កេតប៉ុន្តែចំណុចនេះគួរសម្រេចដោយជនរងគ្រោះដូចជាអមដំណើរដោយនរណានៅពេលណាដែលពួកគេទទួលបានព័ត៌មានការត្រួតពិនិត្យ ឬទទួលសេវាផ្សេងទៀត។

#### មិនរើសអើង

- ធានាថា ជនរងគ្រោះទាំងអស់ត្រូវបានយកចិត្តទុកដាក់ស្មើៗគ្នា ដោយការគោរព និងសេចក្ដីថ្លៃថ្នូរ ដោយមិនគិតពីភេទ អាយុ សាវតារ ជាតិសាសន៍ ស្ថានភាពពិការភាព ជាតិពន្ធុ ទំនោរផ្លូវភេទ ឬកាលៈទេសៈនៃឧប្បត្តិហេតុ
- ដឹងពីភាពលម្អៀង និងការសន្មតរបស់អ្នក និងក្រុមរបស់អ្នកស្ដីពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងយេនឌ័រដើម្បីបញ្ចៀសការរើសអើងជនរងគ្រោះ
- ត្រួតពិនិត្យអាកប្បកិរិយារបស់អ្នក និងអាកប្បកិរិយារបស់ក្រុមអ្នកដោយមិនឱ្យជំនឿផ្ទាល់ខ្លួនរបស់អ្នកជះឥទ្ធិពលលើការងារជាសមូហភាពរបស់ក្រុម
- ដឹងពីភាសាភាសាកាយវិការនិងឥរិយាបថទូទៅរបស់អ្នកចំពោះជនរងគ្រោះ។

http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

ទោះបីជាមានបញ្ហាប្រឈមក្នុងស្ថាប័នក្តី អ្នកក្នុងនាមជាមន្ត្រីគ្រប់គ្រងក្នុងជួរនគរបាល នៅតែអាចដឹកនាំក្រុមរបស់អ្នកឱ្យបញ្ចប់ប្រតិបត្តិការដោយជោគជ័យនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរយៈការផ្តោតលើអភិក្រមដែលមានប្រសិទ្ធផលចំណាយ។ ចំណុចទាំងនេះទាមទារការប្តេជ្ញាចិត្តពីសំណាក់ថ្នាក់ដឹកនាំរបស់អ្នកក្នុងការធានាសមធម៌និងសមភាព ឥរិយាបថ បែបប្រតិសកម្មចំពោះអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងភាពឈ្លាសវៃក្នុងការជំរុញភាពជាដៃគូ។ ឧ. ក្នុងប្រអប់ ៦ UNPOL កំណត់របៀបដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចបង្កើនភាពអង់អាចរបស់មន្ត្រីនគរបាលជាស្ត្រីក្នុងការធ្វើជាភ្នាក់ងារផ្លាស់ប្តូរ និងជំរុញប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់នគរបាលសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ៦**

គន្លឹះសម្រាប់មេបញ្ជាការក្នុងការប្រើប្រាស់មន្ត្រីនគរបាលជាស្ត្រីប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៅពេលជម្រុញការចូលរួមរបស់សហគមន៍

១. ការធ្វើយ៉ាងណាឱ្យសាធារណជនងាយជួបជាមួយមន្ត្រីនគរបាលជាស្ត្រី ៖ មន្ត្រីនគរបាលជាស្ត្រីដែលចុះល្បាតនិងប្រចាំការក្នុងតំបន់ដែលមានប្រជាជនច្រើន បង្កើនភាពលេចធ្លោរ និងការបញ្ជាក់អះអាងចំពោះប្រជាជន ជាពិសេសស្ត្រី និងកុមារក្នុងតំបន់ទាំងនោះ។

២. ការចូលរួមរបស់មន្ត្រីនគរបាលជាស្ត្រីក្នុងប្រតិបត្តិការដែលផ្តល់លទ្ធផលកម្រិតខ្ពស់ ៖ មន្ត្រីនគរបាលជាស្ត្រីដែលចូលរួមក្នុងប្រតិបត្តិការផ្តល់លទ្ធផលកម្រិតខ្ពស់ ផ្តល់សារយ៉ាងសំខាន់ថា ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងនាមជាអ្នកផ្តល់សន្តិសុខ។ ក្រៅពីនេះមន្ត្រីនគរបាលជាស្ត្រីដែលធ្វើប្រតិបត្តិការចាប់ខ្លួនជាសាធារណៈ បង្ហាញថា ស្ត្រីរឹងមាំ និងមានសមត្ថភាព។ មន្ត្រីនគរបាលជាស្ត្រីដើរតួនាទីសំខាន់ណាស់ក្នុងការសួរចម្លើយជនរងគ្រោះសាក្សី និងជនសង្ស័យ ជាពិសេសស្ត្រី និងកុមារ។

៣. ចាត់តាំងមន្ត្រីនគរបាលជាស្ត្រីឱ្យបំពេញតួនាទីជួរមុខ ៖ មន្ត្រីនគរបាលជាស្ត្រីដែលពាក់ព័ន្ធក្នុងការឆ្លើយតបរហ័សទៅនឹងឧប្បត្តិហេតុបន្ទាន់ជាពិសេសភាពចលាចលអាចបង្ហាញពីតួនាទីដឹកនាំរបស់ស្ត្រីក្នុងអង្គភាពនគរបាល។

៤. អង្គភាពឯកទេសដែលមានមន្ត្រីនគរបាលជាស្ត្រី ៖ ការសំខាន់គឺត្រូវបង្កើតអង្គភាពនគរបាលសម្រាប់ដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលមានសមាសភាពមន្ត្រីនគរបាលជាស្ត្រី។ សមត្ថភាពរបស់ជនរងគ្រោះក្នុងការនិយាយជាមួយមនុស្សដែលមានយេនឌ័រដូចគ្នានឹងធានាការទទួលបានភស្តុតាងល្អបំផុត ហើយជនរងគ្រោះទទួលបានការគាំទ្រ។

៥. តួនាទីដឹកនាំ ៖ ក្នុងពេលជួបជាមួយជនរងគ្រោះក្រុមរងផលប៉ះពាល់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល ការសំខាន់ត្រូវបង្ហាញពីតួនាទីដឹកនាំរបស់ស្ត្រីក្នុងអង្គភាពនគរបាលដែលទទួលបន្ទុកដោះស្រាយបញ្ហា។ ចំណុចនេះនឹងគូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីក្នុងជួរនគរបាល។

៦. អ្នកគាំទ្រជាបុរស ៖ ការគាំទ្រយ៉ាងសកម្មរបស់មន្ត្រីជាបុរសចំពោះតួនាទីរបស់មន្ត្រីនគរបាលជាស្ត្រីគឺជាការសំខាន់។ ចំណុចនេះរួមបញ្ចូលការធ្វើការជាមួយមន្ត្រីនគរបាលរបស់រដ្ឋម្ចាស់ស្រុកដើម្បីលើកកម្ពស់តួនាទីរបស់ក្រុមដែលមានសមាជិកស្មើគ្នា ដែលសមាជិកគ្រប់រូបគាំទ្រយ៉ាងសកម្ម និងលើកទឹកចិត្តគ្នាទៅវិញទៅមក។

សៀវភៅណែនាំនេះ នឹងជួយដល់តួនាទីរបស់អ្នកក្នុងនាមជាអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដែលទទួលខុសត្រូវលើមន្ត្រីនគរបាលមួយក្រុម ឬច្រើនក្រុមក្នុងការផ្តល់សេវាដែលមានប្រសិទ្ធភាព និងឆ្លើយតបនឹងយេនឌ័រដល់សហគមន៍មូលដ្ឋានរបស់អ្នក។ មិនថាអ្នកទទួលបន្ទុកលើប៉ុស្តិ៍នគរបាល នាយកដ្ឋាន ឬស្រុកនោះទេ អ្នកប្រាកដជាប្រឈមនឹងបញ្ហាប្រចាំថ្ងៃជាច្រើន ជាពិសេសបញ្ហានៃការបន្សុីធនធានមានកម្រិតទៅនឹងការកើនឡើង និងការផ្លាស់ប្តូរបន្ទុកករណី។ នេះជាមូលហេតុដែលអ្នក និងបុគ្គលិករបស់អ្នកត្រូវកសាងទំនុកចិត្ត និង

ភាពជឿជាក់របស់សហគមន៍នៅមូលដ្ឋានលើសមត្ថភាពរបស់អ្នកក្នុងការផ្តល់សុវត្ថិភាព និងការការពារដល់ពួកគេ។ បើគ្មានជំនួយ និងការគាំទ្រពីសហគមន៍ដែលនគរបាលផ្តល់សេវាជូនទេ ការងាររបស់អ្នកនឹងកាន់តែលំបាកហើយសមត្ថភាពរបស់អ្នកក្នុងការសម្រេចបានលទ្ធផលវិជ្ជមានជម្រុញការអនុវត្តការងារផ្ទាល់ខ្លួន និងការអនុវត្តការងាររបស់ក្រុម និងបង្ហាញថ្នាក់ដឹកនាំជាន់ខ្ពស់របស់អ្នកពីសមត្ថភាពរបស់អ្នកក្នុងនាមជាអ្នកដឹកនាំ ក៏នឹងថយចុះយ៉ាងច្រើនផងដែរ។

ជំពូកខាងក្រោមមានគោលបំណងជួយដល់អ្នក និងបុគ្គលិករបស់អ្នក ហើយអ្នកគួរគប្បីអនុវត្តការណែនាំដែលផ្តល់ជូនទៅតាមបរិបទនៃបរិយាកាសការងារតាមមូលដ្ឋានរបស់អ្នក។

## កំណត់សម្គាល់ និងអំណានបន្ថែម


1. Domestic Abuse Strategy 2015-2020 The production of this document, and the contribution of resources to support the Strategy's development and ongoing maintenance, is sponsored by the States of Guernsey Home Department. https://www.gov.gg/CHttpHandler.ashx?id=98929&p=0

2. A Practitioner's Toolkit on Women's Access to Justice Programming (2018). UN Women https://www.unwomen.org/en/digital-library/publications/2018/5/a-practitioners-toolkit-on-womens-access-to-justice-programming

3. Everyone's business: Improving the police response to domestic abuse https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/2014/04/improving-the-police-response-to-domestic-abuse.pdf

4. Why do some men use violence against women and how can we prevent it? Partners for prevention (2013). A UNDP, UNFPA, UN Women and UNV regional joint programme for gender-based violence prevention in Asia and the Pacific Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific. http://www.partners4prevention.org/sites/default/files/resources/p4p-report.pdf

5. Gender Toolkit: Standardised Best Practices on Gender Mainstreaming in Peacekeeping Handbook (2015). United Nations Police http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Handbook.pdf?sequence=51&isAllowed=y

6. Justice Department Issues Guidance on Identifying and Preventing Gender Bias in Law Enforcement Response to Sexual Assault and Domestic Violence (2015). US Department of Justice, Office of Public Affairs. https://www.justice.gov/opa/pr/justice-department-issues-guidance-identifying-and-preventing-gender-bias-law-enforcement

7. OSCE-Led survey on violence against women: Main report (2019). Organization for Security and Co-operation in Europe. https://www.osce.org/secretariat/413237?download=true

8. National Outcome Standards for Perpetrator Interventions (NOSPI) Baseline Report 2015-2016. Australian Department for Social Sciences. https://plan4womenssafety.dss.gov.au/wp-content/uploads/2018/08/nationaloutcomestandardsreportweb.pdf

9. Welch, J. and F. Mason.,(2007), 'Rape and Sexual Assault' British Medical Journal 334, no. 7604: 1154–1158.

10. Progress of the World's Women in Pursuit of Justice (2011). UNWomen. https://www.unwomen.org/en/digital-library/publications/2011/7/progress-of-the-world-s-women-in-pursuit-of-justice

11. Crenshaw, K. 'Demarginalizing the Intersection of Race and Sex: A Black Feminist Critique of Antidiscrimination Doctrine, Feminist Theory and Antiracist Politics', University of Chicago Legal Forum Volume 1989, Issue 1 Article 8. https://chicagounbound.uchicago.edu/cgi/viewcontent.cgi?article=1052&context=uclf

12. Glossary of Terms and Concepts (2017). UNICEF Regional Office for South Asia. https://www.unicef.org/rosa/media/1761/file/Gender%20glossary%20of%20terms%20and%20concepts%20.pdf.

13. Sphere Association. The Sphere Handbook: Humanitarian Charter and Minimum Standards in Humanitarian Response (2015). fourth edition, Geneva, Switzerland. www.spherestandards.org/handbook

14. Security Sector Reform Assessment, Monitoring and Evaluation and Gender. Gender and SSR Toolkit (2008). Bastick, M., and Valasek, K., Geneva Centre for Security Sector Governance. https://www.dcaf.ch/gender-security-sector-reform-toolkit

15. Gender-based Violence Resource Pack. A Standardized Training Tool for Duty Bearers, Stakeholders, and Rights Holders (2019). UN Women https://www.genderinkenya.org/wp-content/uploads/2019/11/GBV-Resource-Pack-13-Sept-w-3mm-bleed.pdf

16. Case Study: Imkaan—Supporting Asian, Black, Minority, Ethnic, and Refugee Survivors (UK) http://www.endvawnow.org/uploads/browser/files/shelter_uk_case_study_imkaan.pdf

17. How the police are letting sexual assault victims down(2014) Bates, L., for *The Guardian* https://www.theguardian.com/lifeandstyle/womens-blog/2014/nov/21/police-letting-rape-victims-down-too

18. From the Margin to the Centre: Addressing Violence Against Women and Girls Alternative Bill October (2018). Imkaan https://829ef90d-0745-49b2-b404-cbea85f15fda.filesusr.com/ugd/2f475d_91a5eb3394374f24892ca1e1ebfeea2e.pdf

19. Tool 2: *Policing and Gender* (2019) in Gender and Security Toolkit. Geneva: DCAF, OSCE/ODIHR, UN Women. https://www.dcaf.ch/sites/default/files/publications/documents/GSToolkit_Tool-2%20EN%20FINAL.pdf

20. DCAF (2015) "The police", SSR Backgrounder Series, Geneva: DCAF http://ssrbackgrounders.org/fall.php?p=16&l=EN

21. Integrating gender into internal police oversight (2014). DCAF, OSCE, OSCE/ODIHR "https://www.dcaf.ch/integrating-gender-internal-police-oversight

22. Police as an Entry Point to End Violence Against Women and Girls. Lessons from Civil Society Organizations Funded by the UN Trust Fund to End Violence Against Women (2019). UN Trust Fund to End Violence against Women. New York, UN Women.

23. The Value of Intersectionality in Understanding Violence against Women and Girls (VAWG) 2019. Imkaan, UN Women and the European Union. https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339

24. Thematic study on the issue of violence against women and girls and disability, Report of the Office of the United Nations High Commissioner for Human Rights, 30 March 2012, A/HRC/20/5. https://www2.ohchr.org/english/issues/women/docs/A.HRC.20.5.pdf

25. The Trial of Rape. Understanding the Criminal Justice System Response to Sexual Violence in Thailand and Viet Nam (2017). UN Women, UNDP and UNODC. https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2019/08/ap-trial-of-rape_26aug2019_low-res-compressed.pdf?la=en&vs=1916

26. Intimate Partner Violence Response Policy and Training Content Guidelines 6 (2015). International Association of Chiefs of Police. https://www.theiacp.org/sites/default/files/all/i-jIACPIntimatePartnerViolenceResponsePolicyandTrainingGuidelines2017.pdf

27. Glossary of Common Terms in Gender Equality and Feminist Theory (2015). Šribar, R. in Gendering Science: Slovenian Surveys and Studies in the EU Paradigms, Vienna, Echoraum. M. Ule, R. Šribar and A. U. Venturini, eds.

28. Gender sensitivity. European Institute for Gender equality. https://eige.europa.eu/thesaurus/terms/1218?utm_source=newsletter&utm_medium=e-mail&utm_campaign=how_gender_equal_is_your_parliament&utm_term=2019-11-27

# 3

# ការទប់ស្កាត់

“ការទប់ស្កាត់ជាអាទិភាពដំបូងគេនៃយុត្តិធម៌”

អង្គការសហប្រជាជាតិ (S/2004/616 កថាខណ្ឌ ៤)

# គោលបំណងនៃជំពូកទី ៣

**បទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីត្រូវបានរារាំងដោយយុទ្ធសាស្ត្រទប់ស្កាត់របស់នគរបាលដែលទទួលបានធាតុចូលគ្រប់គ្រាន់ពីអ្នកពាក់ព័ន្ធ គាំទ្រដោយសហគមន៍ និងផ្អែកតាមអភិក្រមរបស់នគរបាលដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការស្វែងយល់ពីធម្មជាតិនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឫសគល់ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រីនិងក្មេងស្រីគឺជាចំណុចស្នូលនៃការទប់ស្កាត់អំពើហិង្សា។
- ការទប់ស្កាត់ចាប់ផ្តើមពីសមត្ថភាពកំណត់រក និងវិភាគឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីរិះរកដំណោះស្រាយ។
- ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ទាមទារអភិក្រមបែបសហការរវាងនគរបាល ស្ថាប័ន/អ្នកផ្តល់សេវាផ្សេងទៀត និងសហគមន៍មូលដ្ឋាន។
- ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីសំដៅលើការពិគ្រោះជាមួយជនដែលប្រឈមនឹងហានិភ័យគ្រោះថ្នាក់ខ្ពស់។
- ការកើនឡើងនៃទំនុកចិត្តនិងភាពជឿជាក់របស់សាធារណជនចំពោះនគរបាលជាសញ្ញាបង្ហាញថា យុទ្ធសាស្ត្រទប់ស្កាត់មានប្រសិទ្ធភាព។
- បុរសអាចនិងគួរបង្ហាញភាពជាអ្នកដឹកនាំតាមរយៈការប្រកាន់ជំហរវោហារស័ព្ទប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- អាទិភាពគួរតែជាសកម្មភាពដែលផ្តោតលើអន្តរាគមន៍បញ្ឈប់អំពើហិង្សា ទប់ស្កាត់អំពើហិង្សានាពេលអនាគតនិងលើកទឹកចិត្តឱ្យស្ត្រីនិងក្មេងស្រីរាយការណ៍ដើម្បីជានាសុវត្ថិភាពផ្ទាល់ខ្លួន។




## សេចក្តីផ្តើម

**ដើម្បីឱ្យការទប់ស្កាត់មានប្រសិទ្ធភាពក្នុងការកាត់បន្ថយបទល្មើស គ្រប់ទីកន្លែង និងការរាយការណ៍មិនគ្រប់ពីចំនួនករណី ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រី នគរបាលត្រូវទទួលបានការគាំទ្រពីសហគមន៍ដែលពួកគេផ្តល់សេវាជូន។ ការវិនិយោគលើកិច្ចខិតខំប្រឹងប្រែងពេលវេលា និងធនធានលើការទប់ស្កាត់បទល្មើសក្នុងសហគមន៍ មិនត្រឹមតែជាការវិនិយោគដ៏ល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសង្គ្រោះអាយុជីវិតទៀតផង។**

រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

ក្នុងការអនុវត្តអភិក្រមផ្អែកតាមភស្តុតាង[65]សម្រាប់សេវានគរបាល អាជ្ញាធរចក្រភពអង់គ្លេសយល់ថា បទល្មើសកើនឡើងនៅពេលមានឱកាសកាន់តែច្រើនក្នុងការប្រព្រឹត្តល្មើស និងថយចុះ នៅពេលឱកាសប្រព្រឹត្តបទល្មើសថយចុះ[66]។ ចំណុចនេះនាំឱ្យអាជ្ញាធរចក្រភពអង់គ្លេសសន្និដ្ឋានថា គេអាចទប់ស្កាត់បទល្មើសតាមរយៈការលុបបំបាត់ឱកាសប្រព្រឹត្តបទល្មើសដោយសហការជាមួយសហគមន៍រងផលប៉ះពាល់។

ជាញឹកញាប់ សហគមន៍មានលក្ខណៈចម្រុះ។ ដូច្នេះអភិក្រមសេវានគរបាលត្រូវគិតគូរ និងឆ្លើយតបទៅនឹងលក្ខណៈចម្រុះនេះ។ ចំណុចនេះរួមមានការយល់ថា ក្នុងសហគមន៍ជាច្រើន មានបុគ្គល និងក្រុមដែលត្រូវបានផាត់ចេញ និងមិនទទួលបានការយកចិត្តទុកដាក់តាមរបៀបចម្រុះ និងប្រទាក់ក្រឡាគ្នា។

ដើម្បីគាំទ្រ និងសហការជាមួយនគរបាល សហគមន៍រំពឹងថា សេវានគរបាលជាសេវាស្របច្បាប់ និងមានប្រសិទ្ធភាព។ យោងតាមមជ្ឈមណ្ឌលហ្សឺណែវ ដើម្បីអភិបាលកិច្ចវិស័យសន្តិសុខ (DCAF) ភាពស្របច្បាប់របស់នគរបាលជាផ្នែកដ៏សំខាន់មួយនៃសេវានគរបាលល្អប្រសើរ។ ភាពស្របច្បាប់នេះសំដៅលើកម្រិតនៃការគាំទ្ររបស់សាធារណជនចំពោះនគរបាល[67]។

**"យោងតាមស្តង់ដារអង្គការសហប្រជាជាតិ នគរបាលម្នាក់ៗ ឬស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀតគួរធ្វើជាតំណាង ឆ្លើយតប និងទទួលខុសត្រូវលើសហគមន៍ដែលពួកគេផ្តល់សេវាជូន"។**

សេចក្តីសម្រេចលេខ ៣៤/១៦៩ របស់មហាសន្និបាត ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩

65. សូមមើល Guerette, R.T. & Bowers, K.J. (2009), 'Assessing the Extent of Crime Displacement and Diffusion of Benefits: A Review of Situational Crime Prevention Evaluations', in Criminology, 47(4), in Modern Crime Prevention Strategy (Home Office UK, 2016).
66. យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសសម័យទំនើប (Home Office UK, 2016)។

ការគាំទ្ររបស់សាធារណជនចំពោះនគរបាល ទាមទារការឆ្លើយតបរបស់នគរបាលទៅនឹងតម្រូវការសន្តិសុខចម្រុះក្នុងសហគមន៍។ ការដាក់បញ្ចូលសំឡេងរបស់ស្ត្រី (មិនគិតសាវតាររបស់ស្ត្រី)តាមរយៈគំនិតផ្តួចផ្តើមគាំទ្រ និងស្ថាប័នដែលខិតខំបង្កើនការចូលរួមដោយស្មើភាព និងប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសនិងអំពើហិង្សា ជាវិធីដ៏មានប្រសិទ្ធភាពដែលអាចឱ្យនគរបាលទទួលបានភាពស្របច្បាប់ ការគាំទ្រ និងទំនុកចិត្ត។

### ប្រអប់ ១

**ការសម្របសម្រួលសំដៅលើការពិគ្រោះយោបល់**



រូបថតទទួលបានពី UNMINUSTAH/Logan Abassi (ប្រទេសហៃទី)

ដើម្បីយល់ពីបាតុភូតនៃបទល្មើស និងអំពើហិង្សាដែលបង្កផលប៉ះពាល់លើស្ត្រី និងក្មេងស្រី ចាំបាច់ត្រូវផ្តល់មូលដ្ឋានព័ត៌មានដល់កិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល តាមរយៈដំណើរការពិគ្រោះយោបល់។ ដំណើរការនេះត្រូវធានាការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី និងក្មេងស្រី ដើម្បីឱ្យមានអ្នកស្តាប់សំឡេងរបស់ពួកគេ និងរំលេចអាទិភាពរបស់ពួកគេក្នុងកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល។

វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័របានដាក់ស្នើ ៤ ជំហាន សម្រាប់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលអាចជួយដល់នគរបាលនៅពេលបង្កើតដៃគូសម្របសម្រួលនិងធានាការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេ។ ជំហានទាំងនោះរួមមាន ៖

- **ការរៀបចំផែនការ ៖** រួមមានការកំណត់គោលបំណងនៃការពិគ្រោះយោបល់ និងប្រធានបទពាក់ព័ន្ធ ការកំណត់អត្តសញ្ញាណអ្នកដែលត្រូវពិគ្រោះយោបល់ និងការយកចិត្តទុកដាក់ធានាតុល្យភាពយេនឌ័រ ក៏ដូចជាភាពជាតំណាងគ្រប់គ្រាន់ និងចម្រុះរបស់ស្ថាប័នដែលមានជំនាញយេនឌ័រ។ នៅដំណាក់កាលនេះ ការសំខាន់ត្រូវកំណត់អត្តសញ្ញាណក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត (ឧ. ស្ត្រីចំណាកស្រុក) និងប្រហែលជាត្រូវការការគាំទ្រទៅតាមតម្រូវការដើម្បីអាចចូលរួមបាន ព្រមទាំងការពិចារណាពីលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការចូលរួមដែលត្រូវបំពេញឱ្យបាន (ឧ. ការផ្តល់ការថែទាំកុមារ)។
- **ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ៖** ដំណើរការនេះគួរធ្វើឡើងឱ្យបានឆាប់រហ័សដើម្បីរកឱ្យឃើញបញ្ហាពិតប្រាកដសម្រាប់ធ្វើការសម្រេចចិត្តដែលត្រឹមត្រូវ សំរាប់ពួកគេធ្វើការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ

67. ឯកសារជំនួយស្មារតីស្តីពីសុចរិតភាពនគរបាល ( DCAF, 2012)

ជាមុន និងកែសម្រួលទៅតាមស្ថានភាពនៅមូលដ្ឋានដើម្បីរំលេចក្របខណ្ឌពេលវេលា បរិបទ និងភាសាក្នុងមូលដ្ឋាន។

- **ការដាក់បញ្ចូលយោបល់ត្រឡប់** ពីការពិគ្រោះយោបល់ក្នុងការរៀបចំផែនការ យុទ្ធសាស្ត្រនៃកិច្ចខិតខំប្រឹងប្រែងដោយមានការសម្របសម្រួល ដើម្បីឱ្យមានការឆ្លុះបញ្ចាំងគ្រប់គ្រាន់ពីទស្សនៈតម្រូវការ និងកង្វល់របស់អ្នកពាក់ព័ន្ធស្តីពីសមភាពយេនឌ័រក្នុងការសម្រេចចិត្ត/អន្តរាគមន៍ចុងក្រោយ។
- **ការចងក្រង** ដំណើរការពិគ្រោះយោបល់ និងលទ្ធផល និងការរាយការណ៍ទៅអ្នកពាក់ព័ន្ធ។ ចំណុចនេះរួមមានការជូនដំណឹងដល់អ្នកដែលត្រូវបានពិគ្រោះយោបល់ស្តីពីបញ្ហាសំខាន់ៗដែលត្រូវបានលើកឡើងជាជំហានដ៏សំខាន់មួយសម្រាប់រក្សាការចូលរួម។

ប្រភព ៖ ដកស្រង់ចេញពី "ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីយេនឌ័រ" (វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ)

តាមពិតការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍនិងការអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់មិនគួរកម្រិតត្រឹមអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងទម្រង់ផ្សេងទៀតនៃបទល្មើសអំពើហិង្សាទាក់ទងនឹងយេនឌ័រឡើយ ប៉ុន្តែគួររួមបញ្ចូលបទល្មើសគ្រប់ប្រភេទ និងគ្រប់កម្រិត។ ចំណុចនេះនឹងធានាការពិចារណាគ្រប់គ្រាន់ពីតម្រូវការសន្តិសុខជាក់លាក់ និងចម្រុះរបស់ស្ត្រីនិងក្មេងស្រីក៏ដូចជាការប្រើប្រាស់ទស្សនៈវិស័យនេះយ៉ាងមានប្រសិទ្ធផល និងប្រសិទ្ធភាពក្នុងការកាត់បន្ថយឱកាសប្រព្រឹត្តបទល្មើសជារួម។

ការដាក់បញ្ចូលសំឡេងរបស់ស្ត្រីក្នុងយុទ្ធសាស្ត្រទប់ស្កាត់បទល្មើស និងអំពើហិង្សា ត្រូវបន្សុីគ្នានឹងការកសាងការយល់ដឹងរបស់សាធារណជនតាមបែបប្រតិសកម្មស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីឫសគល់និងផលវិបាកនៃអំពើហិង្សាលើស្ត្រី ក្មេងស្រី ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ ក៏ដូចជាទណ្ឌកម្មដែលជនបង្កអាច និងគួរប្រឈម។

> ***"ភាពស្របច្បាប់របស់នគរបាលគឺការឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ តាមរយៈការបង្ហាញការវិនិច្ឆ័យដែលមិនលម្អៀង និងប្រកបដោយវិជ្ជាជីវៈ និងមានប្រសិទ្ធភាពក្នុងការធានាសន្តិសុខ"។***
>
> Amnesty International (2007)

អ្វីដែលសំខាន់ផងដែរគឺ ត្រូវផ្តល់ព័ត៌មានជាប្រចាំដល់សហគមន៍ស្តីពីការប្តេជ្ញាចិត្តរបស់នគរបាលក្នុងការអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះយុទ្ធសាស្ត្រស៊ើបអង្កេតដែលផ្តោតលើជនបង្កនិងដំណើរការផ្លាស់ប្តូរស្ថាប័នដែលមានគណនេយ្យភាពនិងប្រកបដោយបរិយាបន្ន។

ការធានាថាព័ត៌មានស្តីពីសេវានិងរបៀបដែលជនរងគ្រោះអាចទទួលបានព័ត៌មានទាំងនោះដោយគ្មានការរើសអើងជាវិធីមួយផ្សេងទៀតព្រោះវានឹងបង្ហាញដល់សាធារណជនថា ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីនឹងទទួលបានការការពារ និងការគាំទ្រ។

ការសំខាន់គឺការបង្កើតនិងលើកកម្ពស់វប្បធម៌ស្ថាប័នដែលខិតខំធានាលទ្ធភាពទទួលបានយុត្តិធម៌ដោយគ្មានការរើសអើង និងកំណត់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះជាអាទិភាពនឹងកាន់តែទទួលបានជោគជ័យសម្រាប់ការទប់ស្កាត់បទល្មើស ព្រោះវិធានការនេះនឹងផ្តល់ភាពស្របច្បាប់និងការគាំទ្រដល់សកម្មភាពរបស់នគរបាល ព្រមទាំងទំនុកចិត្តពីសហគមន៍ដែលនគរបាលចង់ផ្តល់សេវាជូន។

## ការណែនាំគ្នាទៅវិញទៅមក

ការប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនត្រឹមតែជាការទទួលខុសត្រូវរបស់នគរបាលនោះទេ។ តាមពិតការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាការទទួលខុសត្រូវរបស់សង្គមទាំងមូល។ ទោះជាយ៉ាងណាអ្នកដើរតួនាទីយ៉ាងសំខាន់។ មានផ្នែកសំខាន់ៗជាច្រើនក្នុងការទប់ស្កាត់បទល្មើស។ ផ្នែកមួយគឺការពង្រឹងការអនុវត្តច្បាប់ជាធរមានដើម្បីធានាការនាំខ្លួនជនបង្កទៅកាត់ទោស។

ការស៊ើបអង្កេតយ៉ាងល្អិតល្អន់ និងគត់មត់ ការកំណត់រក និងការរក្សាទុកភស្តុតាងតាមរបៀបដែលច្បាស់លាស់ និងលម្អិត នឹងធានាលទ្ធភាពខ្ពស់នៃការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មជនបង្ក។ ការផ្តន្ទាទោស និងការកាត់ទោសនឹងផ្តល់សារច្បាស់លាស់ដល់សង្គមថាអំពើហិង្សាលើស្ត្រី និងក្មេងស្រីនឹងមិនត្រូវបានអត់ឱនជាដាច់ខាត។ អ្នកមិនអាចគ្រប់គ្រងលើការកាត់ទោសបានទេ ប៉ុន្តែអ្នកអាចគ្រប់គ្រងលើគុណភាពនៃការស៊ើបអង្កេតដោយធានាការបង្ហាញករណីដែលមានមូលដ្ឋានច្បាស់លាស់ដល់អយ្យការដើម្បីបន្តទៅដំណើរការផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌។

ផ្នែកដ៏សំខាន់មួយទៀតនៃការទប់ស្កាត់គឺសមត្ថភាពវិភាគបញ្ហាដើម្បីរិះរកដំណោះស្រាយ និងអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់។ មានគំរូជាច្រើនដែលអ្នកអាចប្រើប្រាស់ដើម្បីជួយដល់អ្នកក្នុងដំណើរការនេះ។ សូមមើលឧទាហរណ៍មួយខាងក្រោម ៖

### ការដោះស្រាយបញ្ហា

**រូប ១ ៖ វដ្តនៃការដោះស្រាយបញ្ហា**



**១.ការកំណត់រកបញ្ហា ៖**
- តើមានភាពខុសគ្នាអ្វីខ្លះរវាងក្តីរំពឹងទុកនិងអ្វីដែលកំពុងកើតឡើង ?
- តើអ្វីជាបញ្ហា ?
- តើបញ្ហានេះមានសារៈសំខាន់កម្រិតណា ?

**២.ការវិភាគបញ្ហា ៖**
ហេតុអ្វីបញ្ហានេះកើតឡើង ?
ធាតុផ្សំសំខាន់ៗ ៤ នៃការវិភាគបញ្ហា ៖
១.សាវតាររបស់ជនរងគ្រោះ ?
២.សាវតាររបស់ជនល្មើស ?
៣.កន្លែងប្រព្រឹត្តបទល្មើស ?
៤.ធម្មជាតិនៃបទល្មើស ?

**៣. ការបង្កើតផែនការ ៖**
តើអ្វីជាគោលដៅ ? តើអ្វីជាផែនការអន្តរាគមន៍ដើម្បីសម្រេចបានគោលដៅនោះ ? តើវឌ្ឍនភាពត្រូវបានត្រួតពិនិត្យដោយរបៀបណា ?
( ឧ. ការចុះល្បាតដែលស្តែងចេញច្បាស់ ការពង្រាយមន្ត្រីនគរបាលជាស្ត្រីកាន់តែច្រើន ការអប់រំ យុទ្ធសាស្ត្រំខាន។ល។)

**៤.ការអនុវត្តផែនការ ៖**
យកផែនការទៅអនុវត្ត។ តើអាចធានាសុចរិតភាពនៃការអនុវត្តដោយរបៀបណា ?

**៥.ការវាយតម្លៃផែនការ៖**
តើផែនការអន្តរាគមន៍មានប្រសិទ្ធភាព ឬទេ ?

ជាញឹកញាប់អ្នកគ្រប់គ្រងក្នុងជួរនគរបាលជឿថាការកើនឡើងនៃការរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាការឆ្លុះបញ្ចាំងអវិជ្ជមានពីសមត្ថភាពនៃការឆ្លើយតបរបស់នគរបាលទៅនឹងបទល្មើសនេះដែលនៅដំណាក់កាលដំបូង វាគួរតែជាលទ្ធផលវិជ្ជមាន។

នៅពេលស្ត្រីមានទំនុកចិត្តនិងភាពជឿជាក់កាន់តែច្រើនលើនគរបាល ពួកគេងាយនឹងរាយការណ៍ពីបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការរាយការណ៍កាន់តែច្រើនផ្តល់ទិន្នន័យកាន់តែច្រើនដែលអាចឱ្យអ្នកកំណត់គោលនយោបាយ ... ដូច្នេះ អ្នកអាចតម្រែតម្រង់អន្តរាគមន៍ទប់ស្កាត់សមស្របដែលក្នុងរយៈពេលវែងនឹងចាប់ផ្តើមបង្ហាញការថយចុះជារួមនៃប្រភេទបទល្មើសនេះ។

ប្រសិនបើគ្មានការរាយការណ៍មានន័យថាគ្មានបទល្មើស និងគ្មានយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីអាចទទួលបានពីស្ថាប័នផ្សេងៗ។ ឧ. តើ របាយការណ៍អ្វីខ្លះដែលអ្នកផ្តល់សេវាផ្សេងទៀតទទួលបាននៅពេលជនរងគ្រោះមានអារម្មណ៍ភ័យខ្លាចពេក ឬក៏កង្វះទំនុកចិត្តរាំងពួកគេមិនឱ្យរាយការណ៍បទល្មើសនេះទៅនគរបាល? តើអ្នកអាចទទួលបានព័ត៌មានទាំងនេះដោយរបៀបណា? តើអ្នកបានកសាងទំនាក់ទំនងបែបសហការជាមួយស្ថាប័នផ្សេងទៀតដើម្បីផ្តល់លទ្ធភាពដល់ការចែករំលែកព័ត៌មានសម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយរបៀបណា?

ដើម្បីឱ្យការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីមានប្រសិទ្ធភាព ចាំបាច់ត្រូវមានកិច្ចសហការរវាងនគរបាល ស្ថាប័ន/អ្នកផ្តល់សេវាផ្សេងទៀត និងសហគមន៍មូលដ្ឋាន។

### រូប ២ ៖ ការស្វែងយល់ពីអំពើហិង្សាលើស្ត្រី[68]

ដើម្បីអាចឱ្យអ្នកវិភាគបញ្ហាដោយប្រសិទ្ធភាព អ្នកត្រូវការទិន្នន័យដែលថ្មីៗ និងសុក្រឹត។

ចារកម្មមានតម្លៃណាស់ក្នុងដំណើរការនេះ ហើយនៅពេលសហគមន៍មូលដ្ឋានរបស់អ្នក មានទំនុកចិត្តនិងភាពជឿជាក់កាន់តែខ្លាំងលើនគរបាល អ្នកនឹងកាន់តែងាយទទួលបានចារកម្មពាក់ព័ន្ធ។ខាងក្រោមនេះជាចំណុចមួយចំនួនដែលអ្នកត្រូវពិចារណា ៖

- តើអ្នកជានាក់កំណត់ត្រាសុក្រឹតអំពីបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាឧប្បត្តិហេតុដែលអាចមិនមានន័យស្មើនឹងបទល្មើសដោយរបៀបណា?
- តើអ្នកវិភាគបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីញឹកញាប់ប៉ុណ្ណាដើម្បីកំណត់គំរូនៃបទល្មើសដែលកើតមានទូទៅក្នុងដែនសមត្ថកិច្ចរបស់អ្នក?
- តើអ្នកអាចទប់ស្កាត់បទល្មើសនាពេលអនាគតដោយរបៀបណា ប្រសិនបើអ្នកមិនបានដឹងពីបញ្ហា និងមិនអាចដាក់ពង្រាយធនធានមានកម្រិតរបស់អ្នកដោយប្រសិទ្ធភាព?
- តើអ្វីជាកម្រិតនៃបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងតំបន់របស់អ្នក ធៀបនឹងទិន្នន័យថ្នាក់ជាតិ?
- តើលក្ខណៈចម្រុះនៃសហគមន៍ក្នុងមូលដ្ឋានរបស់អ្នកបង្កផលប៉ះពាល់ដូចម្តេចលើប្រភេទបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលបានប្រព្រឹត្ត និងកម្រិតនៃការរាយការណ៍?
- តើវប្បធម៌សហគមន៍របស់អ្នកត្រូវបានបង្កើតឡើងអ្វីខ្លះ?




**ឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី**

**វិសមភាពយេនឌ័រ និងការរើសអើងក្នុងបរិបទជាក់លាក់ដែលរងឥទ្ធិពលពី ៖**

- កត្តាសេដ្ឋកិច្ច នយោបាយ និងសង្គម ប្រព័ន្ធ និងបទដ្ឋាន រួមទាំងគោលនយោបាយនិងក្របខណ្ឌច្បាប់និងរចនាសម្ព័ន្ធ
- កត្តាប្រវត្តិសាស្ត្រ (ឧ. ការអនុវត្តចាក់ឫសក្នុងវប្បធម៌ សង្គ្រាម អាណានិគម)
- លក្ខណៈពិសេសផ្អែករចនាសម្ព័ន្ធ ផ្អែកតាមអាយុ ប្រាក់ចំណូល ទីតាំង ជាតិពន្ធ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ និងលក្ខណៈផ្សេងទៀត។

68. ក្របខណ្ឌគូសបញ្ជាក់សកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី (UN Women, 2015) ទំ. ២៣ https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework



រូបថតទទួលបានពី UNMIT/Bernardino Soares (ប្រទេសទីម័រខាងកើត)

តើមានបណ្ដាញសហការ ឬភាពជាដៃគូ/វេទិការសហគមន៍អ្វីខ្លះក្នុងតំបន់ប្រតិបត្តិការរបស់អ្នក? ប្រសិនគ្មានទេអ្នកត្រូវមានភាពប្រតិសកម្មក្នុងការជំរុញការចូលរួមរបស់ស្ថាប័ននិងអ្នកផ្ដល់សេវាផ្សេងទៀតរួមទាំងសង្គមស៊ីវិលដែលអាចជួយដល់អ្នកក្នុងការដោះស្រាយបញ្ហាបទល្មើសក្នុងតំបន់ទទួលខុសត្រូវរបស់អ្នក។ កត្តាសំខាន់បំផុតគឺអ្នកទាំងអស់គ្នាត្រូវប្ដេជ្ញាអនុវត្តសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អាចមានភាពជាដៃគូ ឬបណ្ដាញបែបសហការមានស្រាប់ដែលនគរបាលមិនត្រូវបានអញ្ជើញឱ្យចូលរួម។ ដូច្នេះ អ្នកត្រូវតែបើកទ្វារចំហរ និងចូលរួមធ្វើជាផ្នែកមួយនៃដំណោះស្រាយ។ ចំណុចនេះមិនត្រឹមតែជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកក្នុងការទប់ស្កាត់បទល្មើសទាំងនេះមិនឱ្យកើតឡើងតាំងពីដំបូងទៀតផង។

ទំនាក់ទំនងរវាងការជំរុញការចូលរួមរបស់សហគមន៍ និងការកើនឡើងនៃទំនុកចិត្តនិងភាពជឿជាក់លើនគរបាលគឺជាការសំខាន់ ព្រោះវាអាចសម្រួលដល់ការត្រៀមខ្លួនរបស់សាធារណជនក្នុងការសហការជាមួយនគរបាល និងបង្កើនការប្រមូលចារកម្ម និងនាំទៅរកការប្រមូលទិន្នន័យកាន់តែច្រើនសម្រាប់ការវិភាគបញ្ហា ដែលអាចជួយជំរុញការទប់ស្កាត់លើបទល្មើសទាំងអស់។

សូមមើលវដ្តទំនុកចិត្ត[69]របស់មហាវិទ្យាល័យសេវានគរបាលចក្រភពអអង់គ្លេស (រូប ៣) សម្រាប់ឧទាហរណ៍ស្ដីពីទំនាក់ទំនងរវាងការជំរុញការចូលរួមរបស់សហគមន៍ និងការកើនឡើងនៃទំនុកចិត្តនិងភាពជឿជាក់លើនគរបាលដែលជាដំណើរការវិលទៅមក។

សម្រាប់ព័ត៌មានបន្ថែមស្ដីពីការជំរុញការចូលរួម សូមមើលជំពូកទី ៧ (ការគាំទ្រ និងជំនួយ) និងជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌)។



រូបថតទទួលបានពី Graham Goulden ប្រធានក្រុមនគរបាលស៊ើបអង្កេតស្កុតឡែន (ចូលនិវត្តន៍)

---

69. "ការជំរុញការចូលរួម និងទំនាក់ទំនង ៖ ការអនុវត្តប្រកបដោយវិជ្ជាជីវៈដែលទទួលបានការអនុញ្ញាត" (មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស)

តើសារអ្វីខ្លះដែលអ្នកបង្ហាញថាអ្នកប្រព្រឹត្តអំពើហិង្សាគ្រប់ប្រភេទនឹងមិនត្រូវបានអត់ អោនជាដាច់ខាត រួមទាំងក្នុងចំណោមបុគ្គលិករបស់អ្នក? តើសារអ្វីខ្លះដែលអ្នកនឹងបង្ហាញដល់បុគ្គលិករបស់អ្នកនិងសហគមន៍ទាំងមូលថា បុរស និងក្មេងប្រុសដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី? ក្នុងនាមជាអ្នកដឹកនាំអ្នកត្រូវបង្ហាញសារច្បាស់លាស់ថាអំពើហិង្សាលើស្ត្រី និងក្មេងស្រី នឹងត្រូវបានពិចារណាយ៉ាងហ្មត់ចត់។ ហេតុអ្វីមិនពិចារណាកំណត់អត្តសញ្ញាណបុគ្គលិកជាបុរស និងបុរសក្នុងសហគមន៍ដែលអាចដើរតួនាទីជា"បុរសផ្ទើម" ដើម្បីអប់រំ និងជះឥទ្ធិពលលើបុរសដូចគ្នាស្តីពីមូលហេតុដែលត្រូវពិចារណាល្អិតល្អន់លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី?

ការជំរុញការចូលរួមរបស់បុរសនិងក្មេងប្រុសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាកិច្ចខិតខំប្រឹងប្រែងដ៏លំបាក និងមានតម្លៃ ដែលទាមទារការប្តេជ្ញាចិត្ត ផ្តល់ការដឹកនាំជាគំរូ និងការយល់ពីរបៀបដែលបទដ្ឋានសង្គម និងវប្បធម៌អាចជះឥទ្ធិពលលើការយល់ឃើញចំពោះអំពើហិង្សានេះ។

ក្នុងឧបសម្ព័ន្ធ ១ ស្តីពី "ការជំរុញការចូលរួមរបស់បុរស" Graham Goulden ប្រធានក្រុមនគរបាលស៊ើបអង្កេតស្កុតឡែន (ចូលនិវត្តន៍) ដែលមានបទពិសោធន៍ ៣០ ឆ្នាំ រួមទាំងបទពិសោធន៍ជាអ្នកស៊ើបអង្កេតឯកទេសលើបទល្មើសព្រហ្មទណ្ឌ ការស៊ើបអង្កេតគ្រឿងញៀន ការបណ្តុះបណ្តាល និងការទប់ស្កាត់បទល្មើស បានផ្តល់ការណែនាំស្តីពីសកម្មភាពដែលបុរសអាចធ្វើឡើងដើម្បីជួយទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**រូប ៧[70]៖ វដ្តនៃទំនុកចិត្ត (មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស)**




ចំណាំ ៖ NIM ជាគំរូចារកម្មថ្នាក់ជាតិ (ចក្រភពអង់គ្លេស) ដែលផ្តល់អភិក្រមមានរចនាសម្ព័ន្ធសម្រាប់ការប្រមូល វិភាគ និងប្រើប្រាស់ចារកម្មនៅ ៣ កម្រិត ៖ ១.បញ្ហាមូលដ្ឋាន ២.បញ្ហាឆ្លងដែន ៣.បញ្ហាជាតិ និងបញ្ហាអន្តរជាតិ (បទល្មើសធ្ងន់ធ្ងរ និងបទល្មើសដែលមានអង្គការចាត់តាំង)។
សូមមើលផងដែរ "ការជំរុញការចូលរួម និង
ទំនាក់ទំនង ៖ ការអនុវត្តប្រកបដោយវិជ្ជាជីវៈដែលមានការអនុញ្ញាត" (មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស)។

70. សូមមើល https://www.app.college.police.uk/app-content/engagement-and-communication/engaging-with-communities/

### ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីចាប់ផ្តើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

កង្វះយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើស និងអំពើហិង្សា នឹងផ្តល់ផលវិបាកយ៉ាងជ្រាលជ្រៅ។ ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ងាយប្រឈមនឹងបញ្ហាសុខភាពធ្ងន់ធ្ងរ និងយូរអង្វែង និងការបាត់បង់ជីវិត។ នៅកម្រិតសង្គម អំពើហិង្សាលើស្ត្រីនិងក្មេងស្រីអាចនាំទៅរកការមាក់ងាយក្នុងសង្គម ការបដិសេធ ការបែកបាក់គ្រួសារ ការគ្មានផ្ទះសម្បែង ការដកហូតទ្រព្យសម្បត្តិ និងភាពក្រខ្សត់[71]។ ក្រៅពីនេះ ការសិក្សាបង្ហាញថា កុមារដែលធំធាត់ក្នុងស្ថានភាពហិង្សា ងាយនឹងក្លាយជាជនរងគ្រោះ ឬជាជនបង្កបទល្មើស ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រីនាពេលអនាគត[72]។

**អត្តសញ្ញាណសង្គមរបស់បុគ្គលម្នាក់ ដូចជា ជនមានពិការភាព ឬជនមកពីក្រុមភាគតិច ឬក្រុមដែលមានតំណាងតិចតួច អាចរួមផ្សំជាមួយនឹងកាលៈទេសៈតាមស្ថានភាព ដូចជា ជម្លោះប្រដាប់អាវុធ និង/ឬវិបត្តិសិទ្ធិមនុស្សដើម្បីបង្កើនកម្រិតហានិភ័យនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

ការឆ្លើយតបដែលគ្មានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយនគរបាលឆ្លើយតប អាចបណ្តាលមកពីកង្វះការយល់ដឹងច្បាស់លាស់ស្តីពីធម្មជាតិនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឫសគល់ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ ចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមដែលជំរុញដោយភាពលម្អៀង និងផ្នត់គំនិត អាចបណ្តាលមកពីការយល់ដឹងពីផលប៉ះពាល់នៃអំពើហិង្សា និងបទល្មើសផ្អែកលើយេនឌ័រ លើស្ត្រី និងក្មេងស្រី ក៏ដូចជាសង្គមទាំងមូល។

ដូច្នេះ ថ្នាក់ដឹកនាំនគរបាលគ្រប់កម្រិតត្រូវយល់ពីមូលហេតុដែលការវិនិយោគលើយុទ្ធសាស្ត្រទប់ស្កាត់ជួយពង្រឹងសេវានគរបាលនិងផ្តល់អត្ថប្រយោជន៍ផ្នែកសង្គមសេដ្ឋកិច្ច។ ឧ. ផលវិបាកផ្នែកសេដ្ឋកិច្ចនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានទំហំធំធេង។ នៅ អេហ្ស៊ីប ការសិក្សាថ្នាក់ជាតិមួយសន្និដ្ឋានថាចំណាយសរុបទូទាំងប្រទេសលើការប្រឈមរបស់ស្ត្រីទៅនឹងអំពើហិង្សាគឺជាង ៧៨៥ លានផោនអេហ្ស៊ីបក្នុងមួយ ឆ្នាំនិងជាង ៣ ពាន់លានផោនអេហ្ស៊ីបក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ (២០០៧-២០១០)[73]។

ការសិក្សាស្រដៀងគ្នាមួយនៅប្រទេសកេនយ៉ាបង្ហាញថា ចំណាយផ្នែកវេជ្ជសាស្ត្រដោយបុគ្គលផ្ទាល់ (ប្រាក់ដែលជនរងគ្រោះ ឬក្រុមគ្រួសាររបស់ពួកគេ បង់ថ្លៃពេទ្យ) និងការបាត់បង់ផលិតភាពដោយសារការរងរបួស ត្រូវបានប៉ាន់ស្មានថាមានចំនួន ៤៦ ពាន់លាន KES ឬប្រហែល ១,១ ភាគរយនៃ ផសស កេនយ៉ា[74]។ ក្រៅពីនេះ ធនាគារពិភពលោករាយការណ៍ថាក្នុងប្រទេសមួយចំនួនការខាតបង់ដោយសារការប្រព្រឹត្តអំពើហិង្សាលើស្ត្រីត្រូវបានប៉ាន់ស្មានថាមានចំនួន ៣,៧% នៃ ផសស របស់ប្រទេសទាំងនោះ (បើធៀបនឹងចំណាយរបស់រដ្ឋាភិបាលភាគច្រើនលើវិស័យអប់រំគឺលើស ២ ដង)[75]។

នៅឆ្នាំ ២០១៨ UNFPA បានបង្កើតក្រាហ្វបង្ហាញក្នុងគោលការណ៍ណែនាំសម្រាប់ការប៉ាន់ស្មានការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារអំពើហិង្សាក្នុងគ្រួសារនៅតំបន់អារ៉ាប់ ដើម្បីជួយឱ្យ រដ្ឋាភិបាល និង ដៃគូ យល់ថាតើអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលជាបាតុភូតសង្គមមួយ បង្កផលវិបាកធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច និងសង្គមដោយរបៀបណា ។

71. "កញ្ចប់ធនធានស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ ៖ ឧបករណ៍បណ្តុះបណ្តាលស្តង់ដារសម្រាប់អ្នកមានភារកិច្ច អ្នកពាក់ព័ន្ធ និងអ្នកមានសិទ្ធិ" (UN Women, 2019)។
72. ការបញ្ឈប់អំពើហិង្សាលើស្ត្រី ៖ ពីពាក្យពេចន៍ឆ្ពោះទៅរកសកម្មភាព។ ការសិក្សារបស់អគ្គលេខាធិការ (ឯកសារចេញផ្សាយរបស់អង្គការសហប្រជាជាតិ សម្រាប់លក់ លេខE.06.IV.8)។
73. "ការសិក្សាសម្រាប់ការបង្កើតយន្តការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាលើស្ត្រីនៅអេហ្ស៊ីប" (UNODC, 2015)។
74. "កញ្ចប់ធនធានស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ ៖ ឧបករណ៍បណ្តុះបណ្តាលស្តង់ដារសម្រាប់អ្នកមានភារកិច្ច អ្នកពាក់ព័ន្ធ និងអ្នកមានសិទ្ធិ" (UN Women, 2019)។
75. អំពើហិង្សាផ្អែកតាមយេនឌ័រ (អំពើហិង្សាលើស្ត្រី និងក្មេងស្រី) (ធនាគារពិភពលោក ខែ មេសា ឆ្នាំ ២០១៩) https://www.worldbank.org/en/topic/socialsustainability/brief/violence-against-women-and-girls
76. 'គោលការណ៍ណែនាំសម្រាប់ការប៉ាន់ស្មានការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារអំពើហិង្សាក្នុងគ្រួសារនៅតំបន់អារ៉ាប់' (UNFPA, 2019) https://www.unescwa.org/sites/www.unescwa.org/files/publications/files/guidelines-estimate-economic-costdomesticviolence-arab-region-english_0.pdf។ សូមមើលផងដែរ "ការប៉ាន់ស្មានការខាតបង់ដោយសារអំពើហិង្សាក្នុងអាពាហ៍ពិពាហ៍នៅតំបន់អារ៉ាប់ ៖ គំរូប្រតិបត្តិការ" (UN Women E/ESCWA/ECW/2017/Technical Paper4, 18 July 2017)។

**រូប ៩ ៖ ការប៉ាន់ស្មានការខាតបង់ដោយសារអំពើហិង្សាក្នុងគ្រួសារនៅតំបន់អារ៉ាប់**[77]




Source: http://www.nuigalway.ie/media/researchcentres/womensstudies/womenstudies2020/Guidelines-to-estimate-the-economic-cost-of-domestic-violence-in-the-Arab-Region.pdf

ដ្យាក្រាមខាងលើដែលដកស្រង់ចេញពីគោលការណ៍ណែនាំឆ្នាំ ២០១៩ របស់ UNFPA បង្ហាញពីរបៀបដែលអំពើហិង្សាក្នុងគ្រួសារបង្កផលប៉ះពាល់ចម្រុះលើសុខភាព ការអប់រំ និង ឱកាសការងាររបស់ស្ត្រី[78]។

ឌ.ដ្យាក្រាមនេះគូសបញ្ជាក់ពីរបៀបដែលសមត្ថភាពរបស់ស្ត្រីក្នុងការទាញប្រយោជន៍ពីឱកាសការងារនិងការអនុវត្តការងាររបស់ស្ត្រី ត្រូវបានបង្អាក់ដោយសារការប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារ ដែលនាំទៅរកការខាតបង់ផលិតភាព និងប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ។

អំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាកត្តាយ៉ាងសំខាន់ដែលផាត់ ស្ត្រី និងក្មេងស្រីចេញពីជីវភាពនយោបាយ និងសេដ្ឋកិច្ច។ ចំណុចនេះបង្កផលប៉ះពាល់លើសហគមន៍ទាំងមូល។ ការសិក្សានានា ដូចជា ការសិក្សាដែលបានលើកឡើងក្នុងគោលការណ៍ណែនាំឆ្នាំ ២០១៩ របស់ UNFPA បង្ហាញថា ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការរួមបញ្ចូលស្ត្រីជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំងមូល។

ការសំខាន់ត្រូវគូសបញ្ជាក់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាអន្តរបុគ្គល អាចបង្កពិការភាពបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ (ទាំងផ្លូវកាយ និងផ្លូវចិត្ត)។ ចំណុចនេះអាចជះឥទ្ធិពលដោយផ្ទាល់និងដោយប្រយោលលើឱកាសរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានការអប់រំ ការងារ និងឱកាសផ្សេងទៀត រួមទាំងរយៈពេលជាច្រើនឆ្នាំក្រោយការរងគ្រោះដោយអំពើរំលោភបំពានដោយសារឧបសគ្គទាំងអស់ដែលពួកគាត់នឹងប្រឈម

77. See: https://www.nuigalway.ie/media/researchcentres/womensstudies/womenstudies2020/Guidelines-to-estimate-the-economic-cost-of-domestic-violence-in-the-Arab-Region.pdf

78. Ibid

79. សូមមើលបន្ថែមទៀត Humanity & Inclusion: https://www.hi-us.org/

ក្នុងនាមជាស្ត្រី និងក្មេងស្រី ដូចជា ការរើសអើង និងការមាក់ងាយ[79]។

អំពើហិង្សានេះបង្កផលប៉ះពាល់យូរអង្វែងលើសុខភាព និងការអប់រំរបស់កុមារ ដែលអាចរឹតត្បិតការចូលរួមក្នុងសេដ្ឋកិច្ចនាពេលអនាគត ដែលនៅពេលរួមផ្សំគ្នា នាំឱ្យមានការខាតបង់យ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចជាតិ។ ការវិនិយោគកាន់តែច្រើនលើការទប់ស្កាត់ ការការពារ ការផ្តន្ទាទោស និងការផ្តល់សំណងជំងឺចិត្ត នឹងជួយកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលបានយ៉ាងច្រើន។

ក្នុងការស្វែងយល់ពីផលប៉ះពាល់លើកុមារដោយសារផលប៉ះពាល់ផ្ទាល់ និងប្រយោលនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការសំខាន់ត្រូវពិនិត្យលទ្ធផលរកឃើញពីការសិក្សានៅ សហរដ្ឋអាមេរិកស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារ។ លទ្ធផលរកឃើញទាំងនេះ កំពុងត្រូវបានបង្កើតឡើង និងប្រើប្រាស់សម្រាប់ការបង្កើតគំនិតផ្តួចផ្តើមទប់ស្កាត់ក្នុងជួរកងកម្លាំងនគរបាលជាច្រើននៅទូទាំងចក្រភពអង់គ្លេស (សូមមើលប្រអប់ ៥)។

### ប្រអប់ ២

**តើអ្វីជាបទពិសោធន៍មិនល្អនៅវ័យកុមារ?**

បទពិសោធន៍មិនល្អនៅវ័យកុមារ បង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍខួរក្បាល របស់កុមារ និងនាំទៅរកការផ្លាស់ប្តូររបៀបដែលកុមារឆ្លើយតបទៅនឹងភាពតានតឹង។ បទពិសោធន៍នេះបំផ្លាញប្រព័ន្ធភាពស៊ាំរបស់កុមារយ៉ាងធ្ងន់ធ្ងរ ដែលបង្កផលប៉ះពាល់ ក្នុងរយៈពេលជាច្រើនទសវត្សរ៍ក្រោយមកទៀត។ការចងចាំអាចនឹងបាត់បង់ ប៉ុន្តែស្លាកស្នាមរាងកាយមិនអាចបំភ្លេចបានឡើយ។ បទពិសោធន៍មិនល្អនៅវ័យកុមារបណ្តាលឱ្យមានបន្ទុកធ្ងន់ធ្ងរនៃជំងឺរ៉ាំរ៉ៃ ជំងឺផ្លូវចិត្តភាគច្រើន និងជាឫសគល់នៃអំពើហិង្សាភាគច្រើនក្នុងសង្គម។




រូប ៥ ៖ រូបភាពនៃបទពិសោធន៍មិនល្អនៅវ័យកុមារ
charity WAVE Trust ៖ https://www.wavetrust.org/adverse-childhood-experiences

"បទពិសោធន៍មិនល្អនៅវ័យកុមារ"ត្រូវបានដកស្រង់ចេញពីមជ្ឈមណ្ឌលបង្ការនិងគ្រប់គ្រងជំងឺ(CDC)-ការសិក្សារបស់ Kaiser ស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារ។ នេះជាការសិក្សាសុខភាពដំបូងគេដែលរកឃើញថា ការប៉ះទង្គិចផ្លូវចិត្តនៅវ័យកុមារនាំទៅរកការកើតជំងឺរ៉ាំរ៉ៃការធ្លាក់ទឹកចិត្តនិងជំងឺផ្លូវចិត្តផ្សេងទៀតអំពើហិង្សានិងការក្លាយជាជនរងគ្រោះដោយសារអំពើហិង្សា ក៏ដូចជាបញ្ហាហិរញ្ញវត្ថុ និងបញ្ហាសង្គម នៅពេលពេញវ័យ។
អ្នកស្រាវជ្រាវ ១០ នាក់ស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារ បានវាស់វែង ៖

- ការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានជាពាក្យសម្តី
- ការមិនអើពើចំពោះរូបរាងកាយ និងផ្លូវចិត្ត
- សមាជិកគ្រួសារដែល ៖
  - ធ្លាក់ទឹកចិត្ត ឬមានជំងឺផ្លូវចិត្តផ្សេងទៀត
  - ញៀនគ្រឿងស្រវឹង ឬគ្រឿងញៀន
  - ជាប់ពន្ធនាគារ
- ការមើលឃើញម្តាយដែលរងការរំលោភបំពាន
- ការបាត់បង់ឪពុក/ម្តាយដោយសារការបែកផ្លូវគ្នា ការលែងលះ ឬហេតុផលផ្សេងទៀត។

បន្ទាប់ពីការសិក្សានេះការអង្កេតផ្សេងទៀតស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារបានពង្រីកប្រភេទបទពិសោធន៍នេះឱ្យរួមបញ្ចូលការរើសអើងជាតិសាសន៍ ការរើសអើងយេនឌ័រ ការមើលឃើញបងប្អូនបង្កើតដែលរងការរំលោភបំពាន ការមើលឃើញអំពើហិង្សានៅក្រៅផ្ទះ ការមើលឃើញឪពុករងការរំលោភបំពានដោយម្តាយ ការត្រូវបានមិត្តភក្តិ ឬមនុស្សពេញវ័យរករឿងរំខាន ការពាក់ព័ន្ធនឹងប្រព័ន្ធថែទាំដោយឪពុកម្តាយធម៌ ការរស់នៅក្នុងតំបន់សង្គ្រាម ការរស់នៅក្នុងសហគមន៍ដែលគ្មានសុវត្ថិភាព ការបាត់បង់សមាជិកគ្រួសារដោយសារការនិរទេស។ល។

ការរួមបញ្ចូលការក្លាយជាជនរងគ្រោះ ឬការមើលឃើញការរំលោភបំពាន បង្ហាញថា ការផ្តោតសំខាន់លើអំពើហិង្សាលើស្ត្រីអាចគាំទ្រដល់ការកាត់បន្ថយបទពិសោធន៍មិនល្អនៅវ័យកុមារក្នុងសង្គមនិងរួមចំណែកដល់ការកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍ទាំងអស់។ គួរពិភាក្សាជាប់ជានិច្ចអំពីការយល់ដឹងរបស់នគរបាលស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារ និងរបៀបកាត់បន្ថយបទពិសោធន៍ទាំងនោះក្នុងយុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សា។

ការដោះស្រាយបទពិសោធន៍មិនល្អនៅវ័យកុមារក្នុងសហគមន៍របស់អ្នក ទាមទារការសហការជាមួយស្ថាប័នជាច្រើន និងផ្តោតលើរបៀបកាត់បន្ថយ និងទប់ស្កាត់បទពិសោធន៍មិនល្អនៅវ័យកុមារ ដើម្បីទ្រទ្រង់សង្គមដែលកាន់តែធន់ សុវត្ថិភាព និងសុខដុម។ ក្នុងការប្រជុំពិភាក្សាស្តីពី "ចំណុចសកម្ម" របស់ខ្លួន អង្គការសុខភាពពិភពលោកស្នើឱ្យកំណត់យក "ទំនាក់ទំនងឪពុកម្តាយដែលផ្តល់សុវត្ថិភាព និងការគាំទ្រ" ជាគន្លឹះក្នុងការទប់ស្កាត់អំពើហិង្សា។

ខណៈដែលការចិញ្ចឹមកូនដែលផ្តល់ការគាំទ្រអាចមិនមែនជាតួនាទីក្នុងសេវានគរបាលការផ្តោតលើអំពើហិង្សាលើស្ត្រី និងក្មេងស្រីពាក់ព័ន្ធបំផុតនឹងសេវានគរបាល ហើយមន្ត្រីនគរបាលគួរដឹងពីការសិក្សាស្តីពីបទពិសោធន៍មិនល្អនៅវ័យកុមារ និងរបៀបដែលចំណុចផ្តោតសំខាន់នេះគាំទ្រដល់សេវានគរបាលទាំងមូល។

ប្រភព ៖ Graham Goulden for Cultivating Minds UK។ សូមមើលផងដែរ អង្គការសុខភាពពិភពលោក, ការទប់ស្កាត់អំពើហិង្សា ៖ ភស្តុតាង https://www.who.int/publications/i/item/violence-prevention-the-evidence and ACES too High News : https://acestoohigh.com/

ការពិនិត្យឡើងវិញនាពេលថ្មីៗនេះ (២០១៩) លើអក្សរសិល្ប៍ស្តីពីការសិក្សាអំពីបទពិសោធន៍មិនល្អនៅវ័យកុមារលើកឡើងថា ដើម្បីទប់ស្កាត់បទពិសោធន៍ទាំងនេះការសំខាន់គឺត្រូវមានការពិនិត្យតាមដានយ៉ាងទៀងទាត់ និងជាបន្តបន្ទាប់ដែលបន្សុីគ្នានឹងការងាររបស់សេវាសំខាន់ៗដើម្បីសម្រេចបានការយល់ដឹងកាន់តែទូលំទូលាយអំពីការប្រឈមនឹងបទពិសោធន៍មិនល្អនៅវ័យកុមារ ផលវិបាករបស់វា និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ដោយប្រសិទ្ធភាព។ អ្វីដែលសំខាន់ផងដែរនោះគឺនគរបាល និងសេវាសំខាន់ៗផ្សេងទៀត ត្រូវតាមដានវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់របស់ខ្លួន និងវាយតម្លៃផលប៉ះពាល់នៃកិច្ចខិតខំប្រឹងប្រែងទាំងនោះ[80]។

ចំណុចនេះមានន័យថា នគរបាលមិនត្រឹមតែត្រូវយកចិត្តទុកដាក់លើការស្វែងយល់ពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាកនៃអំពើហិង្សា (ដូចជាបទពិសោធន៍មិនល្អនៅវ័យកុមារ) និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវមានភាពប្រតិសកម្ម និងការខ្នះខ្នែងក្នុងការរាយការណ៍ទៅប្រព័ន្ធពិនិត្យតាមដានថ្នាក់ជាតិដែលតាមដានវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ទៀតផង។

មន្ត្រីឆ្លើយតបដែលមិនអាចកំណត់តួនាទីរបស់ខ្លួនក្នុងយុទ្ធសាស្ត្រទប់ស្កាត់ អាចធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរួមក្នុងការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ថ្នាក់ដឹកនាំនគរបាលគ្រប់កម្រិតដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា មន្ត្រីឆ្លើយតបរបស់ខ្លួនបានដឹងពីការរួមចំណែករបស់មន្ត្រីម្នាក់ៗដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ខាងក្រោមនេះចំណុចសំខាន់ៗមួយចំនួនដែលដកស្រង់ចេញពីការគូសផែនទីជាសកលស្តីពីការអនុវត្តល្អ និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ និងបុគ្គលិករបស់អង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចំណុចខ្វះខាតសមត្ថភាពដែលមានរៀបរាប់ខាងក្រោមបង្កអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលនៅគ្រប់ដំណាក់កាលនៃដំណើរការស៊ើបអង្កេត ប៉ុន្តែក្នុងករណីនេះចំណុចខ្វះខាតទាំងនេះកាត់បន្ថយប្រសិទ្ធភាពនៃយុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចទាំងនេះមានគោលបំណងជួយដល់ថ្នាក់ដឹកនាំនគរបាលដែលមានតួនាទីដាក់បទបញ្ជា ក្នុងការកំណត់រកយ៉ាងឆាប់រហ័សនូវចំណុចខ្វះខាតសមត្ថភាពនៅដំណាក់កាលដំបូង មុនការបង្កគ្រោះថ្នាក់ ឬគ្រោះថ្នាក់បន្ថែមទៀតលើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចំណងជើងរងនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាន និង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

## ភាពលម្អៀងយេនឌ័រ

- កង្វះការយល់ដឹងអំពីធម្មជាតិនៃអំពើហិង្សាឫសគល់ និងផលវិបាកនៃអំពើហិង្សានិងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី ជំរុញភាពលម្អៀងយេនឌ័រអវិជ្ជមាន និងផ្តត់គំនិត និងរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សា។
- ការខិតខំសហការគ្នាទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីពាក់ព័ន្ធតែនឹងនគរបាលមួយចំនួនតូចដែលប្រព្រឹត្តមិនសមស្រប និង/ឬបង្ហាញភាពលម្អៀងចំពោះជនរងគ្រោះជាស្ត្រី និងក្មេងស្រី ដែលធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់ដៃគូចំពោះនគរបាល ជាពិសេសសង្គមស៊ីវិល។

80. "ការទប់ស្កាត់បទពិសោធន៍មិនល្អនៅវ័យកុមារ ៖ ការទាញប្រយោជន៍ពីភស្តុតាងល្អបំផុត" (ផ្នែកទប់ស្កាត់អំពើហិង្សា មជ្ឈមណ្ឌលជាតិទប់ស្កាត់ និងគ្រប់គ្រងការរងរបួស មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ Atlanta, Georgia, 2019)។

• ជាញឹកញាប់ថ្នាក់ដឹកនាំនគរបាលគ្មានស្តង់ដារស្ថាប័ន ដែលផ្តល់ការណែនាំច្បាស់លាស់ និងស៊ីសង្វាក់គ្នា ដល់អ្នកគ្រប់គ្រងនៅពេលទប់ស្កាត់និងឆ្លើយតបទៅនឹងភាពលម្អៀងយេនឌ័រ និងផ្នត់គំនិតរបស់បុគ្គលិក។

## ការអនុវត្តខុសឆ្គង

• ជារឿយៗយុទ្ធសាស្ត្រដែលគ្មានលក្ខណៈជាការទប់ស្កាត់គឺគ្មានប្រសិទ្ធភាពសម្រាប់ការណែនាំផ្នែកប្រតិបត្តិការដល់នគរបាលឆ្លើយតបដំបូងនៅពេលប្រឈមនឹងប្រភេទមួយចំនួននៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីឡើយ (ដូចជា អាពាហ៍ពិពាហ៍កុមារ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី)។

• ការផ្តោតមិនសមស្របលើប្រតិកម្មតប ជាជាងយុទ្ធសាស្ត្រទប់ស្កាត់ ៖ ជាទូទៅ ចំណុចនេះបណ្តាលឱ្យមានហានិភ័យថ្មីៗនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ហើយមេបញ្ជាការនគរបាលមួយចំនួនមិនបានកត់សម្គាល់បទល្មើសពាក់ព័ន្ធឱ្យបានទាន់ពេលវេលា។ ក្នុងករណីជាច្រើនបញ្ហានេះបណ្តាលមកពីកង្វះការវាយការណ៍លម្អិតដោយមន្ត្រីក្រោមបង្គាប់ដែលមិនឱ្យតម្លៃ ឬមិនយល់ពីតម្រូវការទិន្នន័យសម្រាប់ការទប់ស្កាត់ដោយប្រសិទ្ធភាព។

• ជាទូទៅ គោលនយោបាយជាតិទប់ស្កាត់បទល្មើសមិនពិចារណាពីបទពិសោធន៍ដោយឡែកនិងចម្រុះរបស់ស្ត្រី និងក្មេងស្រីឡើយ រួមទាំងការរងគ្រោះ។ ដូច្នេះវាបានក្លាយជាបន្ទុករបស់មេបញ្ជាការនគរបាលដែលធ្វើប្រតិបត្តិការនៅកម្រិតមូលដ្ឋាន និងគ្មានធនធានគ្រប់គ្រាន់។

## ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ

• ជាទូទៅមន្ត្រីនគរបាលជាច្រើនមិនបានដឹងពីតួនាទីរបស់ខ្លួនក្នុងក្របខណ្ឌភាពជាដៃគូនៅពេលទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

• ទោះបីជាបានដឹងក៏ដោយ ក៏ថ្នាក់ដឹកនាំនគរបាលដែលគ្រប់គ្រងក្រុមប្រតិបត្តិការគ្មានការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងដើម្បីដោះស្រាយដោយប្រសិទ្ធភាពចំពោះការទទួលយកដែលមិនស្តែងចេញឱ្យឃើញច្បាស់ ឬស្តែងចេញឱ្យឃើញច្បាស់នូវបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ឧ. អំពើហិង្សាអន្តរបុគ្គល បទល្មើស "ដើម្បីរក្សាកិត្តិយស" និងការសម្លាប់ស្ត្រីដោយសារយេនឌ័រ) និងបង្កើនភាពអង់អាចរបស់សហគមន៍ក្នុងការទប់ស្កាត់បទល្មើសទាំងនេះឡើយ។

• កម្មវិធីបណ្តុះបណ្តាលនគរបាល មិនលើកឡើងគ្រប់គ្រាន់ពីឥរិយាបថរបស់ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសការត្រួតត្រាដោយបង្ខំដែលជាចំណុចដ៏សំខាន់សម្រាប់អភិក្រមទប់ស្កាត់។ ដូច្នេះ មន្ត្រីនគរបាលមានការលំបាកក្នុងការស្វែងយល់ថាតើការត្រួតត្រាបែបបង្ខំនេះបង្កផលប៉ះពាល់ដូចម្តេច លើសកម្មភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ឧ. ក្នុងករណីអំពើហិង្សាអន្តរបុគ្គល ៖
  - ការបន្តនៅជាមួយដៃគូ
  - ការមិនចង់គាំទ្រដល់សកម្មភាពរបស់នគរបាលឬ
  - ការដកខ្លួនចេញពីការគាំទ្រសំណុំរឿងព្រហ្មទណ្ឌ។

• កង្វះស្តង់ដារស្ថាប័ន ដែលផ្តល់ការណែនាំច្បាស់លាស់ និងស៊ីសង្វាក់គ្នាដល់ថ្នាក់ដឹកនាំនគរបាលនៅពេលទប់ស្កាត់ និងឆ្លើយតបនឹងភាពលម្អៀង និង ផ្នត់គំនិតក្នុងសេវានគរបាល ជាញឹកញាប់បង្ហាញថា អ្នកគ្រប់គ្រងប្រតិបត្តិការមិនទាន់អាចឆ្លើយតបនឹងបញ្ហានេះបានឡើយ។

## និយមន័យ និងក្របខណ្ឌ

ការណែនាំក្នុងក្របខណ្ឌកញ្ចប់សេវាសំខាន់ៗផ្តោតលើយុទ្ធសាស្ត្រគំរូស្តីពីការទប់ស្កាត់បទល្មើស ដែលសម្រេចដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងយុទ្ធសាស្ត្រគំរូនិងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើសនិងយុត្តិធម៌ព្រហ្មទណ្ឌ២០១០[81]និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ការទប់ស្កាត់បទល្មើស[82]។

81. A/RES/65/228 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១ ឧបសម្ព័ន្ធ។
82. សេចក្តីសម្រេចលេខ ២០០២/១៣ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០២ ឧបសម្ព័ន្ធ។

ឯកសារដែលសម្រេចយកជាអន្តរជាតិទាំងនេះពង្រឹងឱ្យគ្នាទៅវិញទៅមក និងគូសបញ្ជាក់ថា ការទប់ស្កាត់ក្នុងសេវានគរបាលពាក់ព័ន្ធនឹងសមាសធាតុ ដូចជា ការផ្អែកតាមសិទ្ធិមនុស្ស ការគ្រប់គ្រងហានិភ័យ និងការលើកកម្ពស់សុវត្ថិភាពនិងភាពអង់អាចរបស់ជនរងគ្រោះទន្ទឹមនឹងការធានាការទទួលខុសត្រូវរបស់ជនបង្ក។ កញ្ចប់សេវាសំខាន់ៗលើកឡើងទៀតថា វិធានការទប់ស្កាត់របស់នគរបាលគួរផ្តោតអាទិភាពលើសកម្មភាពនៃអន្តរាគមន៍បញ្ឈប់អំពើហិង្សា ទប់ស្កាត់អំពើហិង្សានាពេលអនាគត និងលើកទឹកចិត្តឱ្យស្ត្រី និងក្មេងស្រី រាយការណ៍ដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ[83]។

### ប្រអប់ ៣
### វិធានការទប់ស្កាត់*

| កម្រិតបឋម ៖ ទប់ស្កាត់មិនឱ្យអំពើហិង្សាកើតឡើង | កម្រិតទី ២ ៖ ការកំណត់រកកត្តាហានិភ័យ និងក្រុមប្រឈមនឹងហានិភ័យ ការផ្តល់ជំនួយ | កម្រិតទី ៣ ៖ វិធានការទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សានាពេលអនាគត |
|---|---|---|
| ការកសាងការយល់ដឹង យុទ្ធនាការ គំនិតផ្តួចផ្តើម សហគមន៍ ការអប់រំ ស្តីពីសិទ្ធិមនុស្ស កម្មវិធីអប់រំសម្រាប់កុមារ និងមនុស្សវ័យជំទង់ វិធានការទូទៅប្រឆាំងនឹងការរើសអើង និងគាំទ្រសមភាពជាក់ស្តែងរបស់ស្ត្រី ការបញ្ជ្រាបយេនឌ័រ។ | កម្មវិធីបង្កើនការយល់ដឹងក្នុងស្ថាប័នផ្សេងៗ ការបង្កើតខ្សែទូរស័ព្ទជំនួយសម្រាប់ស្ត្រី ការពិនិត្យសុខភាពបឋម វិធានការពង្រឹងភាពម្ចាស់ការរបស់ស្ត្រីនៅកម្រិតច្បាប់ សេដ្ឋកិច្ច និងសង្គម គំនិតផ្តួចផ្តើមដែលគាំទ្រស្ត្រីទេសន្តរប្រវេសន៍។ | ការជួយដល់ស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សា ការសង់ជម្រកសុវត្ថិភាពសម្រាប់ស្ត្រី ការអនុម័តច្បាប់ប្រឆាំងអំពើហិង្សា អន្តរាគមន៍នគរបាលដែលគិតពីអារម្មណ៍ និងមានប្រសិទ្ធភាព នីតិវិធីតុលាការព្រហ្មទណ្ឌដែលមានប្រសិទ្ធភាព។ |

*ប្រភព ៖ គំរូរបស់ប្រទេសអូទ្រីសសម្រាប់អន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ

នៅឆ្នាំ ២០០២ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិបានផ្តល់គោលការណ៍ណែនាំសម្រាប់ការទប់ស្កាត់បទល្មើសដោយផ្អែកលើការអនុវត្តល្អបំផុតរួមទាំងនិយមន័យដូចខាងក្រោម[84]៖

"ការទប់ស្កាត់បទល្មើសរួមបញ្ចូលយុទ្ធសាស្ត្រ និងវិធានការដែលខិតខំកាត់បន្ថយហានិភ័យបទល្មើសដែលកើតឡើង និងផលប៉ះពាល់អវិជ្ជមាននៃបទល្មើសទាំងនោះលើបុគ្គល និងសង្គម រួមទាំងការភ័យខ្លាចបទល្មើសតាមរយៈការធ្វើអន្តរាគមន៍ដើម្បីជះឥទ្ធិពលលើឫសគល់ចម្រុះនៃបទល្មើសទាំងនោះ"។

គោលការណ៍ណែនាំសម្រាប់ការទប់ស្កាត់បទល្មើស (សេចក្តីសម្រេចលេខ ២០០២ /១៣ របស់ ECOSOC ឧបសម្ព័ន្ធ)

ទន្ទឹមនឹងនេះ សហភាពអឺរ៉ុបបានដាក់ស្នើ[85] ជូនរដ្ឋសមាជិករបស់ខ្លួននូវច្បាប់អូទ្រីសស្តីពីអំពើហិង្សាក្នុងគ្រួសារ និងគំរូអន្តរាគមន៍សម្រាប់ដំណោះស្រាយបែបនវានុវត្តន៍ក្នុងការបង្កើតប្រព័ន្ធស្នូល និងមានការសម្របសម្រួល និងផ្តោតលើការទប់ស្កាត់ សម្រាប់ការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ (ហៅថាគំរូរបស់ប្រទេសអូទ្រីសសម្រាប់អន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ)[86]។ គំរូរបស់ប្រទេសអូទ្រីសបានទទួលពានរង្វាន់គោលនយោបាយអនាគត ឆ្នាំ ២០១៤ ក្នុងនាមជាគោលនយោបាយនៃការអនុវត្តល្អបំផុតសម្រាប់ការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី បន្ទាប់ពីទទួលបានយោបល់ត្រឡប់វិជ្ជមានពីជនរងគ្រោះដោយសារអំពើហិង្សា[87]។

83. ម៉ូឌុលទី ៣ ៖ យុត្តិធម៌ និងនគរបាល កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។

84. គោលការណ៍ណែនាំសម្រាប់ការទប់ស្កាត់បទល្មើសសេចក្តីសម្រេចលេខ២០០២/១៣របស់ ECOSOC ឧបសម្ព័ន្ធ។

85. "គំរូរបស់ប្រទេសអូទ្រីស" ត្រូវបានអនុម័ត/យកទៅអនុវត្តក្នុងបណ្តាប្រទេសជាច្រើននៅអឺរ៉ុប។ សូមមើល "ការប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រី ៖ ស្តង់ដារអប្បបរមាសម្រាប់សេវាគាំទ្រ" អគ្គនាយកដ្ឋានសិទ្ធិមនុស្ស និងកិច្ចការច្បាប់ (ក្រុមប្រឹក្សាអឺរ៉ុប Strasbourg ២០០៨)។ សូមមើលផងដែរ "ការសិក្សាបែបវិភាគស្តីពីលទ្ធផលនៃការពិនិត្យតាមដានជុំទី ៤ លើការអនុវត្តអនុសាសន៍ទី ៥ (២០០២) ស្តីពីការការពារស្ត្រីពីអំពើហិង្សា ក្នុងរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប (ក្រុមប្រឹក្សាអឺរ៉ុប ២០១៤) ៖ https://rm.coe.int/16805915e9។

86. សូមមើល Logar, Rosa, 'The Austrian model of intervention in cases of domestic violence', Paper presented at the UN Expert Group Meeting: Violence against Women: Good practice in Combating and Eliminating Violence against Women (Vienna, 17–20 May 2005).

87. សូមមើល "ការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ គោលនយោបាយដ៏ល្អបំផុតក្នុងពិភពលោក (ពានរង្វាន់គោលនយោបាយអនាគត ឆ្នាំ ២០១៤) ក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រីនៅតំបន់អាស៊ីប៉ាស៊ីហ្វិច ៖ វាជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា" (UNWomen ក្រុមប្រឹក្សាអនាគតពិភពលោក និងសហភាពអន្តរសភា)។

## ប្រអប់ ៤

### វិធានការកម្រិតបឋមរបស់ UN ECOSOC សម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី

| គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌស្នើឱ្យ ៖ | ឧទាហរណ៍នៃសកម្មភាពរបស់នគរបាល ៖ |
|---|---|
| ផ្លាស់ប្តូរឥរិយាបថ និងដេញដោលផ្នត់គំនិតក្នុងសង្គម និងជួយដល់សហគមន៍ដើម្បីបញ្ឈប់ការទទួលយកអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ | ដាក់ចេញការបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីភាពលម្អៀងយេនឌ័រ និងប្រព័ន្ធគុណសម្បត្តិពាក់ព័ន្ធនៅគ្រប់ជាន់ថ្នាក់ដែលផ្តោតសំខាន់និងបន្ទុចបង្អាក់ឥរិយាបថនិងផ្នត់គំនិតអវិជ្ជមានក្នុងស្ថាប័ននគរបាល។ |
| បង្កើនភាពអង់អាចដល់ស្ត្រីទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចដើម្បីជម្នះតួនាទីចាញ់ប្រៀបរបស់ស្ត្រីក្នុងសង្គម។ | ដាក់ចេញ និងពង្រឹងគោលនយោបាយ "មិនអត់ឱន" ចំពោះការបៀតបៀនផ្លូវភេទក្នុងស្ថាប័ននិងយន្តការបណ្តឹងដើម្បីជួយដល់មន្ត្រីនគរបាលជាស្ត្រីឱ្យសម្រេចសក្តានុពលរបស់ខ្លួនក្នុងស្ថាប័ននគរបាល និងធ្វើឱ្យអាជីពក្នុងសេវានគរបាលកាន់តែមានភាពទាក់ទាញសម្រាប់ស្ត្រីដែលចង់ក្លាយជានគរបាល។ |
| កែប្រែបរិយាកាសរូបវន្តដើម្បីលើកកម្ពស់ សុវត្ថិភាពរបស់ស្ត្រី។ | សហការជាមួយអ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាល មូលដ្ឋាន និងសង្គមស៊ីវិលដើម្បីពិគ្រោះយោបល់ទូលំទូលាយជាមួយក្រុមស្ត្រី និងក្មេងស្រីក្នុងសហគមន៍ទាំងអស់សំដៅកំណត់វិធីដែលមានប្រសិទ្ធភាពបំផុតក្នុងធ្វើឱ្យបរិយាកាសរូបវន្តកាន់តែមានសុវត្ថិភាពនិងសន្តិសុខសម្រាប់ពួកគេ។ |
| ផ្តល់កម្មវិធី ដើម្បីទប់ស្កាត់ ព្យាបាល និងស្តារនីតិសម្បទាការបំពានគ្រឿងស្រវឹងនិងគ្រឿងញៀនឱ្យបានគ្រប់ជ្រុងជ្រោយដល់អ្នកដែលប្រព្រឹត្តអំពើហិង្សានៅពេលដែលពួកគេប្រើប្រាស់សារធាតុញៀន ។ | ចូលរួមក្នុងគំនិតផ្តួចផ្តើមកសាងការយល់ដឹងដើម្បីលើកកម្ពស់ការយល់ដឹងទូទៅអំពីធម្មជាតិនៃអំពើហិង្សា ឫសគល់ និងផលវិបាកនៃអំពើហិង្សានិងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នានិងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ |

គំរូរបស់ប្រទេសអូទ្រីស ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញសារយ៉ាងច្បាស់ថាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមិនមែនជាបញ្ហាឯកជន ប៉ុន្តែជាបញ្ហាសាធារណៈ តាមរយៈផ្តល់អំណាចកាន់តែច្រើនដល់នគរបាលក្នុងការធ្វើអន្តរាគមន៍លើករណីអំពើហិង្សាដែលកើតឡើងក្នុងចំណោមវិធានការផ្សេងទៀត។ គំរូនេះត្រូវបានទទួលស្គាល់ជាគំរូដែលផ្តល់ឧទាហរណ៍ជាក់លាក់ ស្តីពីវិធានកាទប់ស្កាត់ដែលនាំទៅរកលទ្ធផល។ វិធានការត្រូវបានបែងចែកជា ៣ កម្រិត ៖ កម្រិតបឋម កម្រិតទី ២ និងកម្រិតទី ៣។

វិធានការទាំង ៣ កម្រិតនេះ (សូមមើលប្រអប់ ៦ ខាងក្រោម) អាចផ្តល់ឱកាសដល់នគរបាល ដើម្បីបង្កើនកិច្ចសហការ និងការសម្របសម្រួលក្នុងការទប់ស្កាត់ និងស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្រៅពីនេះ ការសំខាន់ត្រូវបញ្ជាក់ថា ក្រុមប្រឈមនឹងហានិភ័យមិនត្រូវបានកំណត់ត្រឹមស្ត្រី និងក្មេងស្រីទេសន្តរប្រវេសន៍។ ស្ត្រី និងក្មេងស្រីមានពិការភាពក៏ប្រឈមនឹងហានិភ័យខ្ពស់ដែរ។ ដូច្នេះ នគរបាលគួររួមបញ្ចូលវិធានការទប់ស្កាត់កម្រិតទី ៣ ដែលធានាថា ស្ត្រី និងក្មេងស្រីមានពិការភាពអាចទទួលបានសេវាយុត្តិធម៌ ការការពារ និងការបង្កើនភាពអង់អាចបន្ថែមទៀត ដើម្បីលុបបំបាត់វដ្តនៃការរងគ្រោះ[88]។

ផ្អែកតាមអភិក្រមវិធានការ ៣ កម្រិតនៃគំរូរបស់ប្រទេសអូទ្រីស គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិបានដាក់ស្នើវិធានការទប់ស្កាត់សំខាន់ៗ ៤ សម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[89]។ តារាងខាងក្រោម (ប្រអប់ ៧) ផ្តល់វិធានការទប់ស្កាត់សំខាន់ៗ ៤ ចំណុចដែលស្នើឡើងដោយគណៈកម្មការនេះដោយមានឧទាហរណ៍បង្ហាញពីសកម្មភាពដែលនគរបាលអាចធ្វើឡើងទៅតាមវិធានការទាំងនោះ។

88. "ស្ត្រី និងយុវជនមានពិការភាព ៖ គោលការណ៍ណែនាំសម្រាប់ការផ្តល់សេវាផ្អែកតាមសិទ្ធិ និងឆ្លើយតបនឹងយេនឌ័រ ដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ" (UNFPA-WEI ខែ វិច្ឆិកា ឆ្នាំ ២០១៨)។

89. ទិដ្ឋភាពនៃអំពើហិង្សាលើស្ត្រីដែលពាក់ព័ន្ធផ្ទាល់នឹងគណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ (កំណត់សម្គាល់របស់លេខាធិការដ្ឋាន E/CN.15/2008/CRP.1 (2008) និងការសិក្សារបស់អគ្គលេខាធិការស្តីពីអំពើហិង្សាលើស្ត្រី A/61/122/Add.1, para. 337)។

មូលដ្ឋានរួមនៃនិយមន័យនិងក្របខណ្ឌទាំងអស់ខាងលើគឺការផ្តោតសំខាន់លើភាពប្រតិសកម្មរបស់នគរបាលពាក់ព័ន្ធនឹងមធ្យោបាយនិងសមត្ថភាពរបស់ពួកគេក្នុងការកែប្រែលក្ខខណ្ឌនិងស្ថានភាពដែលអាចបង្កើនលទ្ធភាពប្រព្រឹត្តបទល្មើស ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ពោលគឺការកាត់បន្ថយឱកាសប្រព្រឹត្តបទល្មើស ដូចជា អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

"ការជំរុញការចូលរួមដោយប្រសិទ្ធភាពរបស់នគរបាលនឹងកំណត់អត្តសញ្ញាណក្រុមទាំងអស់ក្នុងសហគមន៍ ជាពិសេសស្ត្រីនិងកុមារនិងផ្តល់ឱកាសសម្រាប់ការផ្តល់យោបល់ត្រឡប់តាមរយៈភាពជាតំណាងក្នុងក្រុមផ្តល់ប្រឹក្សា ការអង្កេតសហគមន៍ វេទិការ និង កិច្ចប្រជុំ"។

ក្របខណ្ឌរំលេចសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី (UN Women, 2015)

ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ស្នើឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលប្រើប្រាស់គំរូ SARAជាឧបករណ៍ជួយដោះស្រាយបញ្ហាដែលរកឃើញជាមួយសហគមន៍[90]។ SARA ជាទម្រង់មួយនៃការវិភាគរកដំណោះស្រាយ។ គំរូ SARA មាន ៤ ជំហាន ៖

- ការពិនិត្យលម្អិត ៖ កំណត់បញ្ហា
- ការវិភាគ ៖ សិក្សាបញ្ហា
- ការឆ្លើយតប ៖ ចាត់វិធានការ
- ការប៉ាន់ប្រមាណៈវាយតម្លៃប្រសិទ្ធភាពនៃវិធានការ។

គំរូ SARA អាចប្រើប្រាស់ជាឧបករណ៍ជំរុញការចូលរួមដែលមានប្រសិទ្ធភាពជាមួយសហគមន៍ដើម្បីដោះស្រាយបញ្ហាតាមរយៈអភិក្រមបែបចូលរួម[91]។

ក្នុងជំពូកមុនការណែនាំស្តីពីការគ្រោងគោលដៅដែលដកស្រង់ចេញពីកញ្ចប់សេវាសំខាន់ៗគឺសម្រាប់ថ្នាក់ដឹកនាំនគរបាលដែលមានតួនាទីដាក់បទបញ្ជា (ឬអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល)។ សម្រាប់ជាយុទ្ធសាស្ត្រផ្លាស់ប្តូរលក្ខខណ្ឌ និងស្ថានភាពដែលអាចបង្កើនបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការណែនាំក្នុងជំពូកមុនគូសបញ្ជាក់ពីការផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់នគរបាលលើសសរស្តម្ភទាំង ៣ នៃការទប់ស្កាត់ ជាអាទិ៍ ១) ការរួបរួមក្នុងសហគមន៍សម្រាប់ដំណោះស្រាយតាមសហគមន៍ចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី ២) ការផ្សព្វផ្សាយពីការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ និងសង្គមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលប៉ះពាល់នៃការប្តេជ្ញាចិត្តទាំងនេះលើសមាជិកសហគមន៍ និងសង្គម និង ៣) តួអង្គក្នុងវិស័យយុត្តិធម៌ និងសន្តិសុខកំពុងសិក្សាស្វែងយល់ និងធ្វើកំណែទម្រង់ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការណែនាំខាងក្រោមដកស្រង់ចេញពីម៉ូឌុលទី ៣ នៃកញ្ចប់សេវាសំខាន់ៗ និងដាក់បញ្ចូលក្នុងសសរស្តម្ភយុទ្ធសាស្ត្រទាំង ៣ ខាងលើ។

ការណែនាំបន្ថែមនិងលម្អិតមានបង្ហាញក្នុងកម្រងឯកសារបោះពុម្ពផ្សាយរបស់ UNODC ស្តីពីការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបរបស់វិស័យយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី (២០១៤) និងឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល (UNPOL) ៖ ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព (២០១៥)។ ការណែនាំក្នុងឯកសារទាំងនេះផ្អែកតាមបទពិសោធន៍របស់ស្ថាប័ននគរបាលនៅជុំវិញពិភពលោក ដែលប្រកាន់ខ្ជាប់នីតិរដ្ឋក្នុងមជ្ឈដ្ឋានប្រឈម និងជាញឹកញាប់ប្រឈមនឹងកង្វះធនធាន។ គួរអានឯកសារទាំងនេះអមជាមួយនឹងការណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ "ក្របខណ្ឌរំលេចសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី" (UN Women et al. 2015)។ ការណែនាំនេះនឹងជួយពង្រឹងការយល់ដឹងរួមស្តីពីកត្តាដែលរួមចំណែកនិងការពារទល់នឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងតួនាទីរបស់វិស័យ និងផ្នែកផ្សេងៗក្នុងការទប់ស្កាត់អំពើហិង្សានេះ។

90. អង្គការសហប្រជាជាតិឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ - DPO/ DPET/សេវាបណ្តុះបណ្តាលចម្រុះ ២០១៥)។
91. សូមមើល ឧបករណ៍គម្រោងលេខ ១៣០ ៖ បញ្ជីត្រួតពិនិត្យដំណោះស្រាយបញ្ហាដោយប្រើគំរូ SARA ក្នុងឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ៖ ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព សេចក្តីសង្ខេបឧបករណ៍គម្រោង (២០១៥)។

## សមត្ថភាពគ្រប់គ្រងសំខាន់ៗ សម្រាប់អនុវត្តន៍យុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី

ខាងក្រោមនេះជាសមត្ថភាពផ្នែកឥរិយាបថសម្រាប់ថ្នាក់ដឹកនាំនគរបាល ដែលត្រូវបានដកស្រង់ពីយុទ្ធសាស្ត្រគំរូនិងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ២០១០ (សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត)[92]។

## មន្ត្រីនគរបាលជាន់ខ្ពស់ស្កុតឡែន គាំទ្រយុទ្ធនាការបូរពណ៌សដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ




រូបថតទទួលបានពីនគរបាលស្កុតឡែន/PA Wire

យុទ្ធសាស្ត្រនេះកំណត់ពីឥរិយាបថ និងគុណតម្លៃដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងពិពណ៌នាពីរបៀបបំពេញការងារដើម្បីឱ្យការទប់ស្កាត់បទល្មើសទទួលបានជោគជ័យ និងអាចឱ្យអ្នក និងក្រុមរបស់អ្នកអនុវត្តការងារនៅកម្រិតកាន់តែខ្ពស់និងបង្កើនការពេញចិត្តរបស់បុគ្គល/ក្រុមដែលអ្នកផ្តល់សេវាជូន។

នេះជាការសំអាងដែលធានាថា មានក្តីរំពឹងទុកច្បាស់លាស់លើស្តង់ដារអន្តរជាតិ[93] ក៏ដូចជាបំពេញបន្ថែមនិងពង្រឹងគោលនយោបាយជាតិរបស់ស្ថាប័ននគរបាលស្តីពីគុណតម្លៃ ក្រមសីលធម៌ និងសុចរិតភាព។

ទាំងនេះជាសមត្ថភាពអនុវត្តន៍ការងារសំខាន់ៗមួយចំនួនសម្រាប់ឱ្យអ្នកគ្រប់គ្រងក្នុងជួរនគរបាលដែលមានតួនាទីបញ្ជាប្រតិបត្តិការ យកមកអនុវត្ត និងពង្រឹង នៅពេលផ្តោតលើការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយផ្អែកតាមយុទ្ធសាស្ត្រទប់ស្កាត់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ពីអ្នកពាក់ព័ន្ធគាំទ្រដោយសហគមន៍ និងប្រើប្រាស់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ អ្នកគ្រប់គ្រងគួរធ្វើយ៉ាងណាឱ្យមន្ត្រីឆ្លើយតបជានាបាននូវចំណុចខាងក្រោម។

92. សូមមើលក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ (អនុម័តដោយសេចក្តីសម្រេចលេខ ៣៤/១៦៩ របស់មហាសន្និបាត ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩)។

93. Ibid

**ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា**

- លើកកម្ពស់សមភាព កិច្ចសហប្រតិបត្តិការ ការគោរពគ្នាទៅវិញទៅមកនិងការចែករំលែកការទទួលខុសត្រូវរវាងស្ត្រី និងបុរស។
- ផ្តល់ទិសដៅច្បាស់លាស់ និងបង្ហាញក្តីរំពឹងទុកជាក់លាក់លើការទទួលខុសត្រូវដែលបានកំណត់ច្បាស់សម្រាប់នគរបាលឯកទេស ទីភ្នាក់ងារមានសមត្ថកិច្ចស្ថាប័ននិងបុគ្គលិកដែលពាក់ព័ន្ធក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សាលើស្ត្រី និង ក្មេងស្រី។
- ផ្តល់ទិសដៅច្បាស់លាស់និងមានក្តីរំពឹងទុកជាក់លាក់ដែលជួយឱ្យមានការយល់ដឹងថាតើការងារទប់ស្កាត់របស់ពួកគេដំណើរការដូចម្តេចក្នុងបរិបទធំទូលាយ។
- ដឹកនាំក្រុមឆ្ពោះទៅរកការទប់ស្កាត់និងគ្រប់គ្រងកម្រិតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ការស៊ើបអង្កេត និងការពង្រឹងការអនុវត្តបានល្អ)។
- សហការជាមួយដៃគូដើម្បីជះឥទ្ធិពលលើបទដ្ឋានសង្គម ដែលរួមចំណែកបង្កឱ្យមានអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយសម្រាប់ជនល្មើស ឬជនដែលអាចជាជនល្មើសដើម្បីបំផុសដំណោះស្រាយទំនាស់បែបសន្តិវិធី ការគ្រប់គ្រងកំហឹង និងការកែប្រែឥរិយាបថជុំវិញតួនាទី និងទំនាក់ទំនងយេនឌ័រ។
- ដឹកនាំផ្នែកតាមអភិក្រមពហុវិស័យ និងគិតគូរពីយេនឌ័រជាមួយស្ថាប័នសាធារណៈនិងស្ថាប័នឯកជនតាមរយៈភាពជាដៃគូដើម្បីការពារស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី[94]។ ចំណុចនេះអាចរួមបញ្ចូលនគរបាលដែលរៀបចំផែនការយុទ្ធនាការបែបប្រតិសកម្មជាប្រចាំដោយផ្តោតសំខាន់លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី (សូមមើលប្រអប់ ៩ដែលមានរូបថតរបស់របស់អគ្គស្នងការរងនគរបាលស្កុតឡែន Iain Livingstone ដែលផ្តល់ការគាំទ្រដល់ការសច្ចានៃយុទ្ធនាការបូរពណ៌ស។ យុទ្ធនាការនេះជាផ្នែកមួយនៃយុទ្ធនាការជាសកលដើម្បីលើកទឹកចិត្តឱ្យបុរសមានភាពប្រតិសកម្ម ក្នុងការបញ្ឈប់បុរសមិនឱ្យប្រព្រឹត្តអំពើហិង្សាលើស្ត្រី)[95]។
- ចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយ និងត្រៀមខ្លួនផ្តល់ព័ត៌មានដល់ស្ត្រី រួមទាំងជនរងគ្រោះដោយសារអំពើហិង្សាសិទ្ធិមនុស្សរបស់ស្ត្រីនិងទិដ្ឋភាពនៃអំពើហិង្សាលើស្ត្រីដែលពាក់ព័ន្ធនឹងសង្គម សុខភាព ច្បាប់ និងសេដ្ឋកិច្ចដើម្បីបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងការការពារខ្លួនពីអំពើហិង្សាគ្រប់ទម្រង់។
- ជំរុញការចូលរួមរបស់យុវជនក្នុងគោលនយោបាយនិងដំណើរការទប់ស្កាត់បទល្មើសរួមទាំងការពឹងផ្អែកលើធនធានសហគមន៍ ក្រុមយុវជនជួយខ្លួនឯង និងការសងជំងឺចិត្តជនរងគ្រោះ និងកម្មវិធីជំនួយ។ ចំណុចនេះអាចរួមបញ្ចូលនគរបាលដែលចូលរួមក្នុងកម្មវិធីតាមសាលារៀន ដូចជា ការអប់រំ និងការបណ្តុះបណ្តាលស្តីពីការប្រឆាំងនឹងក្រុមជនពាល (G.R.E.A.T) ដែលស្នើឡើងដោយ WHO ដែលទទួលបានជោគជ័យនៅសហរដ្ឋអាមេរិកនិងអាមេរិកឡាទីន (សូមមើលប្រអប់ ១០)[96]។

---

**ប្រអប់ ៥**

**ការអប់រំ និងការបណ្តុះបណ្តាលស្តីពីការប្រឆាំងនឹងក្រុមជនពាល (G.R.E.A.T)**

G.R.E.A.T ជាកម្មវិធីសិក្សាក្នុងថ្នាក់រៀនដែលផ្តោតលើកុមារអាយុ ៨-១៣ ឆ្នាំដើម្បីទប់ស្កាត់ឥរិយាបថហិង្សា និងការចូលជាសមាជិកក្រុមជនពាល ក៏ដូចជាបង្កើតទំនាក់ទំនងវិជ្ជមានរវាងយុវជន និងនគរបាល។ មេរៀន ១៣ត្រូវបានបង្ហាត់បង្ហាញដោយមន្ត្រីនគរបាលដែលទទួលបានការបណ្តុះបណ្តាលស្តីពីការធ្វើការជាមួយយុវជន។ មេរៀនរួមមានការអភិវឌ្ឍជំនាញសង្គម និងជំនាញផ្លូវចិត្ត និងការសិក្សាអំពីបទល្មើស និងការចូលជាសមាជិកក្រុមជនពាល។ G.R.E.A.T ត្រូវបានបង្កើតឡើងនៅសហរដ្ឋអាមេរិក និងបានកាត់បន្ថយហានិភ័យនៃការចូលជាសមាជិកក្រុមជនពាល និងបង្កើនឥរិយាបថកាន់តែវិជ្ជមាន និងមានប្រយោជន៍ក្នុងចំណោមសិស្សអាយុ ១១-១៣ ឆ្នាំ។ បច្ចុប្បន្ន អភិក្រមនេះត្រូវបានពង្រីកទៅបណ្តាប្រទេសនៅអាមេរិកកណ្តាល ដូចជា បេលីហ្ស កូស្តារីកា និង អែលសាល់វ៉ាឌ័រ ជាទីដែលមន្ត្រីនគរបាលត្រូវបានបណ្តុះបណ្តាលស្តីពីការអនុវត្តគម្រោងនេះជាមួយសិស្សបឋមសិក្សា។

ប្រភព៖ Esbensen et al. (2012) at: https://www.great-online.org/GREAT-Home

---

### ភាពអាចសម្របតាមបាន

- បង្កើតទំនាក់ទំនងជាមួយក្រុមដែលតំណាងឱ្យផលប្រយោជន៍របស់ក្រុមស្ត្រីនិងក្មេងស្រីជាក់លាក់ ដូចជាជនមានពិការភាព សហគមន៍ភាគតិច ឬសហគមន៍មានតំណាងភាគតិចជនចំណាកស្រុកជនមានឧបសគ្គផ្នែកភាសា ឬស្ត្រីដែលមានទំនាស់ជាមួយច្បាប់។

### ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- កំណត់រកស្ថាប័ន/ក្រុមដែលអាចជាធនធានសម្រាប់ការទប់ស្កាត់បទល្មើស និងអំពើហិង្សា។
- បង្កើត និង/ឬអនុវត្តយន្តការសម្រាប់ការសម្របសម្រួលសមស្របលើកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់រវាងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល។

### ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន

- ធ្វើការវិភាគស៊ីជម្រៅលើបញ្ហានេះដោយប្រើព័ត៌មានដែលគិតគូរពីយេនឌ័រនិងបញ្ជីសារពើភណ្ឌប្រតិបត្តិការសេវា ហេដ្ឋារចនាសម្ព័ន្ធ និងធនធានដែលមាន។

---

**ប្រអប់ ៦**

**ការទប់ស្កាត់ចាប់ផ្តើមពីអ្នក!**

មជ្ឈមណ្ឌលហ្សឺណែវដើម្បីអភិបាលកិច្ចវិស័យសន្តិសុខ (DCAF) បានដាក់ស្នើក្នុងឯកសារជំនួយស្មារតីស្តីពីសុចរិតភាពរបស់នគរបាល(២០១២)នូវវិធានការគ្រប់គ្រង ៣ ចំណុចដើម្បីបង្ការកំហុសឆ្គង អំពើពុករលួយ ឬឥរិយាបថគ្មានក្រមសីលធម៌។ កំហុសឆ្គង ការអនុវត្ត និងឥរិយាបថទាំងនេះងាយធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់សហគមន៍លើនគរបាលដែលផ្តល់សេវាជូន និងបង្កើនការរាយការណ៍ពីចំនួនករណីក្រោមចំនួនករណីពិតប្រាកដនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលនាំទៅរកវប្បធម៌និទណ្ឌភាពកាន់តែខ្លាំង។ វិធានការគ្រប់គ្រងដែលស្នើឡើងទាំងនេះចាប់ផ្តើមពីអ្នកទាំងអស់គ្នាដែលជាមេបញ្ជាការនគរបាល និងប្រធានក្រុម។ វិធានការទាំងនេះមានគោលបំណងបញ្ចៀសព្រឹត្តិការណ៍ ឬផលវិបាកដោយចេតនា ឬដោយអចេតនា ដោយសារសកម្មភាពរបស់បុគ្គលក្នុងក្រុមរបស់អ្នក។ វិធានការទប់ស្កាត់ចែកជា ៣ ផ្នែក ១) ការត្រួតពិនិត្យ ២) គណនេយ្យភាពផ្ទៃក្នុង និង ៣) ការលុបចោលនីតិវិធីមានហានិភ័យខ្ពស់ដែលអាចជំរុញអំពើពុករលួយ ឬការប្រព្រឹត្តមិនត្រឹមត្រូវ។ វិធានការទាំងនេះត្រូវបានកែសម្រួលសម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ៖

**១. ការត្រួតពិនិត្យ៖** ធានាថា ក្រុមរបស់អ្នកយល់ច្បាស់ពីខ្សែសង្វាក់បញ្ជា និងយន្តការត្រួតពិនិត្យ។ មន្ត្រីគ្រប់រូបក្នុងក្រុមរបស់អ្នក រួមទាំងរូបអ្នកផ្ទាល់ គួរទទួលការបណ្តុះបណ្តាលស្តីពីសកម្មភាពគ្រប់គ្រង និងគួរត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីការអនុវត្តមិនល្អ។ ការស្គាល់បុគ្គលិករបស់អ្នកគឺសំខាន់ខ្លាំងណាស់។ ពេលគឺសំខាន់ជាងការមានលទ្ធភាពវាយតម្លៃការងាររបស់ក្រុមអ្នកទៅទៀត។ ការស្គាល់សមាជិកក្រុមច្បាស់សំដៅលើការមានលទ្ធភាពកំណត់រកភាពងាយរងគ្រោះទៅនឹងការអនុវត្តមិនល្អដោយសារតែបរិយាកាសផ្ទាល់ខ្លួនរបស់ពួកគេ និងទស្សនៈបែបអភិភាពលើបុគ្គល ឬក្រុម។

**២. គណនេយ្យភាព** ៖ ការទទួលខុសត្រូវ និងការផ្ទេរសិទ្ធិអំណាច ត្រូវតែមានសង្គតិភាព។ ថ្នាក់ដឹកនាំនគរបាលនៅ

---

94. ចំណុចនេះអាចរួមបញ្ចូលនគរបាលដែលរៀបចំផែនការយុទ្ធនាការបែបប្រតិសកម្មជាប្រចាំដោយផ្តោតសំខាន់លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
95. មន្ត្រីនគរបាលជាន់ខ្ពស់ស្កុតឡែនគាំទ្រយុទ្ធនាការបូរពណ៌សដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ Bussey, K. for the The Sunday Post. November 25, 2017. https://www.sundaypost.com/fp/senior-scots-police-officer-backs-white-ribbon-campaign-to-end-gender-based-violence/
96. "ការទប់ស្កាត់អំពើហិង្សាក្នុងសាលារៀន ៖ សៀវភៅណែនាំអនុវត្តន៍" ហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក។ សម្រាប់ការណែនាំបន្ថែមស្តីពីការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលពាក់ព័ន្ធនឹងសាលារៀន សូមមើល 'ការណែនាំជាសកលស្តីពីការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលពាក់ព័ន្ធនឹងសាលារៀន' (UN Women and UNESCO, 2016) at: https://www.unwomen.org/en/digital-library/publications/2016/12/global-guidance-on-addressing-school-related-gender-based-violence

កម្រិតនីមួយៗ ត្រូវជំរុញស្មារតីសមូហភាពនៃការដឹកនាំរបស់បុគ្គលម្នាក់ៗនៅពេលទប់ស្កាត់ការអនុវត្តមិនល្អ។ មានន័យថា ការអនុវត្តមិនល្អត្រូវបានកែតម្រូវភ្លាមៗដោយថ្នាក់លើផ្ទាល់ ឬដោយអ្នកដទៃដែលជាបុគ្គលផ្ទើម និងផ្តល់ការដឹកនាំគំរូនៅពេលធ្វើការងារប្រកបដោយសុចរិតភាពវិជ្ជាជីវៈក្នុងពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ តាមវិធីនេះ នឹងមានការបង្ហាញសារយ៉ាងច្បាស់ក្នុងជួរនគរបាលថា ថ្នាក់គ្រប់គ្រង និងបុគ្គលិកកំពុងសហការគ្នារក្សាការទទួលខុសត្រូវចំពោះវិធានក្នុងស្ថាប័នស្តីពីសុចរិតភាពនិងក្រមប្រតិបត្តិដែលរំលេចសេវានគរបាលដែលមានប្រសិទ្ធភាព និងស្របច្បាប់។

**៣. ការគ្រប់គ្រងហានិភ័យសម្រាប់នីតិវិធីដែលមានហានិភ័យខ្ពស់ ៖** ផ្នែកមួយចំនួននៃការងាររបស់នគរបាលងាយប្រឈមនឹងការអនុវត្តមិនល្អ។ ការងារទាំងនេះ ដូចជា ការគ្រប់គ្រងព្រំដែន ឬសន្តិសុខពន្ធនាគារ គួរត្រូវបានកំណត់ច្បាស់ថាមានហានិភ័យខ្ពស់។ ក្នុងករណីទាំងនេះ គេអាចបង្កើតទម្លាប់ និងនីតិវិធីគ្រប់គ្រងហានិភ័យ ដែលកាត់បន្ថយឱកាសប្រព្រឹត្តមិនសមស្រប ដូចជា ការណែនាំគ្នាទៅវិញទៅមក និងការចុះផ្តល់ការគាំទ្រផ្នែកចិត្តសង្គមដោយអ្នកជំនាញ ដល់នគរបាលក្នុងពន្ធនាគារដែលមានសន្តិសុខខ្ពស់ ឬចំណុចគ្រប់គ្រងព្រំដែនដាច់ដោយឡែក។

## សូចនាករយោងសម្រាប់នគរបាលដែលផ្តល់សេវាសំខាន់ៗ ៖ ការទប់ស្កាត់

ដូចការពិភាក្សាក្នុងជំពូកមុន កញ្ចប់សេវាសំខាន់ៗស្នើឡើងថា សេវាយុត្តិធម៌ និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះ ត្រូវមានលក្ខណៈទូទៅ និងសកម្មភាពរួមដើម្បីធានាផលប៉ះពាល់ជាអតិបរមា។

សូចនាករទាំងនេះ គឺអាចអនុវត្តបាន ដោយមិនគិតពី "វិស័យ" ជាក់លាក់ដែលអាចឆ្លើយតបទៅនឹងស្ត្រី និងក្មេងស្រីដែលទទួលរងអំពើហិង្សា។ ចំណុចខាងក្រោមដកស្រង់ចេញពីលក្ខណៈទូទៅ និងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗ និងផ្តល់ឧទាហរណ៍មួយចំនួននៃសូចនាករយោងសម្រាប់សកម្មភាពនគរបាលនៅពេលអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលផ្អែកតាមព័ត៌មានរបស់អ្នកពាក់ព័ន្ធ គាំទ្រដោយសហគមន៍ និងអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ ទាំងនេះជាសូចនាករសម្រាប់ឱ្យថ្នាក់ដឹកនាំនគរបាលដែលមានតួនាទីដាក់បទបញ្ជាយកជាសំអាងប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មានថ្នាក់គ្រប់គ្រងជាន់ខ្ពស់គួរបញ្ចូលសូចនាករទាំងនេះ។

**១. ភាពអាចរកបាន និងភាពអាចទទួលបាន ៖** ចំនួននៃការអង្កេតស្តីពីការពេញចិត្ត/ទំនុកចិត្តរបស់សហគមន៍លើសេវានគរបាលក្នុងមូលដ្ឋាន បែងចែកតាមភេទ ដែលរួមបញ្ចូលភាពខុសគ្នានៃទីកន្លែងរស់នៅ សញ្ជាតិ ជាតិពន្ធុ វណ្ណៈ ឋានៈ ស្ថានភាពជាជនចំណាកស្រុក ឬជនភៀសខ្លួន ស្ថានភាពជាជនជាតិដើមភាគតិច អាយុ សាសនា ភាសា និងកម្រិតអក្ខរភាព ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ពិការភាព ឬបុគ្គលិកលក្ខណៈផ្សេងទៀតដែលមិនត្រូវបានពិចារណា។

"យុទ្ធសាស្ត្រសម្រាប់ការលើកទឹកចិត្តឱ្យសាធារណជនសហការជាមួយនគរបាលក្នុងការទប់ស្កាត់និងគ្រប់គ្រងបទល្មើស ព្រមទាំងទិដ្ឋភាពផ្សេងទៀតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ ផ្អែកលើតម្រូវការរបស់សហគមន៍"។

UN Police Operation (2015)

**២. ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន ៖** ចំនួនគម្រោងរបស់នគរបាលដែលពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន និងក្រុមប្រឈមនឹងហានិភ័យជាក់លាក់ក្នុងសហគមន៍ទាំងនេះ ដូចជា យុវជន ក្រុម LGBTQI[97] និងស្ត្រី និងក្មេងស្រីមានពិការភាព។ គម្រោងនគរបាល-សហគមន៍ ដែលមានគោលបំណងកសាងបរិយាកាសដែលកាន់តែមានសុវត្ថិភាពតាមរយៈការធានាថា សហគមន៍ជួយដល់ពួកគេក្នុងការស្វែងយល់ពីនិន្នាការប្រែប្រួលនៃអំពើហិង្សា

លើស្ត្រី និងក្មេងស្រី និងការដោះស្រាយបញ្ហាដែលបង្កើតជាអំពើហិង្សា បទល្មើស ឬអសន្តិសុខ។

៣. **ភាពសមស្រប និងភាពអាចទទួលបាន** ៖ ចំនួនវេទិកាទប់ស្កាត់បទល្មើស ឬ សកម្មភាពរួមគាំទ្រដោយនគរបាល ដែលដឹកនាំដោយមានការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី ឬ អង្គការស្ត្រីក្នុងមូលដ្ឋាន ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាស្ត្រី ឬអង្គការស្ត្រីដែលផ្តោតសំខាន់លើការពង្រឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី[98]។ ក្នុងករណីខ្លះ ប្រហែលជាត្រូវមានការផ្សព្វផ្សាយដើម្បីអាចឱ្យស្ត្រី និងក្មេងស្រីកាន់តែច្រើនចូលរួមក្នុងព្រឹត្តិការណ៍នេះ។ កិច្ចពិភាក្សាដាច់ដោយឡែកជាមួយស្ត្រី អាចជាអ្វីដែលចាំបាច់ក្នុងការធានាថា ពួកគេអាចនិយាយដោយបើកចំហ។ ការទប់ស្កាត់បទល្មើសជារួម អាស្រ័យលើអ្វីដែលសាធារណជនធ្វើដើម្បីខ្លួនឯង តាមរយៈការបង្កើនភាពធន់របស់សហគមន៍ទៅនឹងការគំរាមកំហែងដោយបទល្មើស រួមទាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

"ការចូលរួមពីនគរបាលប្រកបដោយប្រសិទ្ធភាព នឹងកំណត់អត្តសញ្ញាណក្រុមទាំងអស់ក្នុងសហគមន៍ ជាពិសេសស្ត្រី និងកុមារ និងផ្តល់ឱកាសសម្រាប់ការផ្តល់យោបល់ត្រឡប់តាមរយៈភាពជាតំណាងក្នុងក្រុមផ្តល់ប្រឹក្សា ការអង្កេតសហគមន៍ វេទិកា និងកិច្ចប្រជុំ"។

ក្របខណ្ឌវិលេចសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី
(UN Women et al., 2015)

៤. **សុវត្ថិភាពជាចម្បង** ៖ ចំនួន និងគុណភាពនៃផលិតផលផ្សព្វផ្សាយរវាងនគរបាលនិងសហគមន៍ដែលផ្តល់មូលដ្ឋានព័ត៌មានដល់ស្ត្រី និងក្មេងស្រីស្តីពីរបៀបរាយការណ៍ពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីរួមទាំងការបៀតបៀនផ្លូវភេទ និងឬការឈ្លបចាប់តាមប្រព័ន្ធអ៊ីនធឺណិត (ឧ. ក្នុងបណ្តាញសង្គម) ស្វែងរកការការពារនិងការទ្រទ្រង់សុខភាពនៅពេលមានអំពើហិង្សា ក៏ដូចជាបញ្ជៀសតំបន់ដែលសំបូរបទល្មើស និង/ឬទម្រង់ផ្សេងទៀតនៃអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដែលផ្តោតសំខាន់លើស្ត្រី និងក្មេងស្រី។ ដូចគ្នានេះដែរផលិតផលផ្សព្វផ្សាយគួរផ្តោតគោលដៅលើបុរស និងក្មេងប្រុសក្នុងសហគមន៍តាមរបៀបដែលលើកទឹកចិត្តឱ្យពួកគេដើរតួនាទីបែបប្រតិសកម្មក្នុងការកសាងដំណោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

៥. **ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ និងភាពអាចទទួលបាន** ៖ ចំនួនកិច្ចប្រជុំទៀងទាត់ និងផ្លូវការជាមួយសហគមន៍មូលដ្ឋានដែលផ្តោតសំខាន់លើតម្រូវការសន្តិសុខជាក់លាក់របស់ស្ត្រី និងក្មេងស្រី។ កិច្ចប្រជុំទាំងនេះគួរមានគោលបំណងរួមបញ្ចូលអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ/ជនរស់រានមានជីវិតក្នុងយុទ្ធសាស្ត្ររួមរបស់នគរបាលសម្រាប់ការទប់ស្កាត់អំពើហិង្សា និងបទល្មើស។ ការរៀបចំព្រឹត្តិការណ៍សប្តាហ៍សំរាប់ភ្ញៀវប្រចាំប៉ុស្តិ៍នគរបាលជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍ចម្រុះ[99] អាចជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយដែលនគរបាលអាចត្រួតពិនិត្យមជ្ឈដ្ឋានរបស់ជនរងគ្រោះបាន។

"ចាំបាច់ត្រូវជំរុញការចូលរួមរបស់ប្រជាជន និងត្រូវបង្ហាញផលវិបាកច្បាស់លាស់ និងដាក់ស្លែងសម្រាប់អ្នកដែលបំពានច្បាប់។ ចំណុចនេះរួមមានការរក្សាការទទួលខុសត្រូវរបស់បុរស និងស្ត្រីដែលរំលោភបំពានស្ត្រី ចំពោះសកម្មភាពរបស់ពួកគេ"។

ក្របខណ្ឌវិលេចសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី
(UN Women et al., 2015)

97. ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកដែលមិនកំណត់ថាខ្លួនជាមនុស្សប្រុសឬមនុស្សស្រីនិងអ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរភេទ។

98. សេវានគរបាល ឬសេវាសំខាន់ៗផ្សេងទៀតគួរធានាថា អង្គការស្ត្រីដែលចូលរួមសហការ តំណាងឱ្យក្រុមស្ត្រីចម្រុះ និងចាត់វិធានការសមស្របដើម្បីធានាការដាក់បញ្ចូលស្ត្រីទាំងអស់ ឬយ៉ាងហោចណាស់ ធានាការដាក់បញ្ចូលក្រុមភាគតិចធំបំផុតក្នុងប្រទេសពាក់ព័ន្ធ។ គេអាចសម្រេចបានការដាក់បញ្ចូលនេះតាមរយៈការជំរុញការចូលរួមក្នុងសង្គម ការបង្កើនលទ្ធភាពទទួលបានសេវាគាំទ្រ នឹងការពិចារណាពីភាពងាយស្រួលផ្នែកភាសា។ សម្រាប់ការណែនាំបន្ថែម សូមមើល "ភាពប្រសព្វគ្នា និងអភិក្រមបរិយាបន្នសម្រាប់ការប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ" (២០១៨)។ ឯកសារគោលជំហរពី Women Against Violence Europe ( WAVE ) http://fileserver.wavenetwork.org/researchreports/WAVE%20_positionpaper_intersectionality2018.pdf

**៦. ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា៖** ចំនួន និងភាពញឹកញាប់នៃការផ្សព្វផ្សាយខាងក្រៅ (រួម) ដែលអាចឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មូលដ្ឋានយល់បាន រួមទាំងអ្នកដែលមានពិការភាពផ្សេងៗ ដែលលម្អិតពីការប្ដេជ្ញាចិត្តរបស់នគរបាលក្នុងការអនុវត្តអភិក្រមដែលផ្ដោតសំខាន់លើជនបង្កនិងអភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ/ជនរស់រានមានជីវិតនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចនេះគួររួមបញ្ចូលតាំងពីដំបូង អំពីខ្លឹមសារលម្អិតស្ដីពីយុទ្ធសាស្ត្រអន្តរាគមន៍ លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី ភាពជាដៃគូជាមួយអ្នកផ្ដល់សេវាផ្សេងទៀត និងសមាជិកសហគមន៍ដែលមានឥទ្ធិពល (ជាពិសេសសមាជិក សហគមន៍ជាស្ត្រី) និងគោលនយោបាយសមភាពយេនឌ័រផ្ទៃក្នុងរបស់នគរបាល ដូចជាគោលនយោបាយប្រឆាំងការបៀតបៀនផ្លូវភេទ។

**៧. ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន៖** ចំនួនការវាយតម្លៃឯករាជ្យលើយុទ្ធសាស្ត្ររបស់នគរបាលសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលត្រូវបានអនុវត្តនៅកម្រិតមូលដ្ឋានឬក្រុង។ការវាយតម្លៃទាំងនេះគួរផ្ដល់លទ្ធផលរកឃើញនៅកម្រិតលទ្ធផលចំណេះដឹងស្ដីពីឱកាសរៀនសូត្រនិងស្នើអនុសាសន៍សម្រាប់ការពង្រឹងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ការវាយតម្លៃគួរផ្សព្វផ្សាយជាសាធារណៈ ឬចែករំលែកជាមួយគណៈកម្មាធិការដឹកនាំរបស់អ្នកពាក់ព័ន្ធចម្រុះក្នុង សហគមន៍ និងអ្នកផ្ដល់សេវាសំខាន់ៗ។

ព្រឹត្តិការណ៍សប្ដាហ៍ សំរាប់ភ្ញៀវ ប្រចាំប៉ុស្ដិ៍នគរបាល (PSVW) ជាគំនិតផ្ដួចផ្ដើមជាសកលដែលបង្កើតឡើងដោយ Altus Global Aliance ដែលអញ្ជើញសមាជិកសហគមន៍ចុះទៅប៉ុស្ដិ៍នគរបាលតាមមូលដ្ឋានប្រាស្រ័យទាក់ទងជាមួយនគរបាលនិងវាយតម្លៃសេវានគរបាល។

(Altus Global Alliance, 2012)

**៨. ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល៖** ចំនួន និង គុណភាពនៃវគ្គបណ្ដុះបណ្ដាលរួមស្ដីពីយុទ្ធសាស្ត្រទប់ស្កាត់ និងបញ្ជូន ដែលត្រូវបានរៀបចំឡើង និង អនុវត្តដោយនគរបាល ជាមួយនឹងតួអង្គផ្ដល់សេវាសំខាន់ៗក្នុងមូលដ្ឋាន និងអង្គការស្ត្រី និងអង្គការកុមារក្នុងមូលដ្ឋាន។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់សេវា/ភាពជាដៃគូសម្រាប់ការផ្ដល់សេវាបញ្ជូនក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី នឹងផ្ដល់ប្រយោជន៍យ៉ាងច្រើនអនេក។

99. នៅពេលជំរុញការចូលរួមរបស់ថ្នាក់ដឹកនាំសហគមន៍ នគរបាលគួរផ្ដោតអាទិភាពលើការដាក់បញ្ចូលការដឹកនាំ និងឥទ្ធិពលរបស់ស្ត្រីក្នុងសហគមន៍គោលដៅ។

## ករណីសិក្សា
## ក្រុមប្រឹក្សាសន្តិសុខតាមមូលដ្ឋាន ៖ ប្រទេសកុងហ្គោ អេក្វាឌ័រ និង ម៉ិចស៊ិក[100]

រូបភាពទទួលបានពី COGINTA សម្រាប់កំណែទម្រង់នគរបាល និងសុវត្ថិភាពសហគមន៍[101]

យោងតាមគណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌនៃអង្គការសហប្រជាជាតិការចូលរួមយ៉ាងសកម្មរបស់សហគមន៍ និងផ្នែកផ្សេងទៀតនៃសង្គមស៊ីវិល គឺជាផ្នែកដ៏សំខាន់មួយនៃការទប់ស្កាត់បទល្មើសប្រកបដោយប្រសិទ្ធភាព។ សហគមន៍ដើរតួនាទីសំខាន់ក្នុងការកំណត់អាទិភាពទប់ស្កាត់បទល្មើស ការអនុវត្ត និងការវាយតម្លៃ និងការជួយកំណត់រកមូលដ្ឋានធនធានដែលមាននិរន្តរភាព[102]។




ការអនុវត្តល្អក្នុងការគៀងគរសហគមន៍ គឺពាក់ព័ន្ធនឹងដំណើរការបែបចូលរួមនិងការជំរុញការចូលរួមរបស់សង្គមគ្រប់កម្រិតរួមទាំងតំណាងរដ្ឋាភិបាលមូលដ្ឋាន អ្នកដឹកនាំសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមស្ត្រី[103]។

ទោះជាយ៉ាងណាការគៀងគរនេះទាមទារយន្តការអនុម័តដោយរដ្ឋាភិបាល ដើម្បីធានានិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែង និងភាពម្ចាស់ការរួមរបស់អ្នកមានភារកិច្ចក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន ជាឧទាហរណ៍មួយនៃយន្តការនេះ ដែលនគរបាល និងអ្នកផ្តល់សេវាក្នុងមូលដ្ឋានផ្សេងទៀតអាចបង្កើតឡើងរួមគ្នាជាមួយសង្គមស៊ីវិលក្នុងមូលដ្ឋានដើម្បីពិភាក្សានិងគ្រោងរៀបចំគម្រោងសន្តិសុខរួមនៅកម្រិតសហគមន៍រួមទាំងគម្រោងស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

យន្តការក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន មាននៅតាមទ្វីបនីមួយៗ។ នៅបារាំង និងសាធារណរដ្ឋហ្គីណេ យន្តការនេះមានឈ្មោះថា"ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានសម្រាប់ទប់ស្កាត់បទល្មើស" (CLSPD)។ នៅសាធារណរដ្ឋ



ប្រជាធិបតេយ្យកុងហ្គោ យន្តការនេះមានឈ្មោះថា "ក្រុមប្រឹក្សាសន្តិសុខសហគមន៍មូលដ្ឋាន" (CLSs)។ នៅអេក្វាឌ័រ យន្តការនេះមានឈ្មោះថា "ក្រុមប្រឹក្សាសន្តិសុខក្រុង" (CSM)។ អាស្រ័យលើគំរូនិងចំនួនប្រជាជនក្នុងក្រុង មន្ត្រីនគរបាលជាន់ខ្ពស់ក្នុងសហគមន៍ អាចជាតំណាងដ៏សំខាន់របស់នគរបាលក្នុងក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន។

ជាទូទៅ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានដើរតួនាទីជាយន្តការសម្របសម្រួលអ្នកពាក់ព័ន្ធផ្នែកសន្តិសុខទាំងនៅកម្រិតវិមជ្ឈការ និងកម្រិតសហព័ន្ធ។ ប្រសិនបើទទួលបានជំនួយមូលនិធិដែលមានលក្ខណៈបរិយាបន្ននិងនិរន្តរភាព ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានអាចអាចកំណត់រកនិងដោះស្រាយការគំរាមកំហែងលើក្រុមជាក់លាក់ និងភាពងាយរងគ្រោះផ្នែកសន្តិសុខរបស់ពួកគេតាមរយៈអភិក្រមដែលផ្តោតលើគោលដៅ និងអភិក្រមបែបសហការ។

100. ដកស្រង់ចេញពី Fernandez, M., Piaget, K., Hernandez, T., and Berthoud, S. (2017), 'Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR?' ISSAT HRBA Working Group Paper 3.
101. Coginta សម្រាប់កំណែទម្រង់នគរបាល និងសុវត្ថិភាពសហគមន៍ http://94.23.195.75/en។ សម្រាប់ព័ត៌មានបន្ថែម សូមមើល https://www.youtube.com/watch?v=7fGF0_nteGA&t=6s និង Guide Pratique Conseil Local de Sécurité et de Prévention de la Délinquance en République de Guinée (Coginta 2017)។
102. មាត្រា ១៦ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់បទល្មើស (សេចក្តីសម្រេចលេខ ២០០២/១៣ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឧបសម្ព័ន្ធ)។
103. "ផ្នែកនានានៃអំពើហិង្សាលើស្ត្រី ដែលពាក់ព័ន្ធផ្ទាល់នឹងគណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ" (គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ V.08-52191 (E) *0852191* Seventeenth session Vienna, 14-18 April 2008)។

ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានអាចដើរតួនាទីយ៉ាងសំខាន់ទាំងសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនិងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយសន្តិសុខ និងយុត្តិធម៌ថ្នាក់ជាតិ ដើម្បីជាប្រយោជន៍ដល់ប្រជាជនមូលដ្ឋាន។ ចំណុចនេះក៏គ្របដណ្តប់លើគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ។ សម្រាប់នគរបាល ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានអាចជាឧបករណ៍ដ៏សំខាន់សម្រាប់នគរបាលក្នុងការពង្រឹងភាពជាដៃគូលើអភិក្រមសេវានគរបាល ដែលផ្អែកតាមចារកម្ម និងការផ្សព្វផ្សាយជាយុទ្ធសាស្ត្រដល់មន្ត្រីរដ្ឋាភិបាលមូលដ្ឋាននិងអ្នកពាក់ព័ន្ធតាមសហគមន៍។

ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានជាវេទិកាកិច្ចសន្ទនាសម្រាប់ឱ្យស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនឹងផ្នែកសន្តិសុខពិគ្រោះគ្នា កំណត់រកបញ្ហា និងឯកភាពលើផែនការមូលដ្ឋានសម្រាប់ទប់ស្កាត់អសន្តិសុខ[104]។ ផ្អែកលើចំណុចនេះ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានមានសក្តានុពលក្នុងការគ្រប់គ្រងប្រកបដោយគុណភាព លើសកម្មភាពនានា ក្រោមការសម្របសម្រួល ដែលពាក់ព័ន្ធនឹងនគរបាល និងដៃគូក្នុងការបន្តផ្តល់យុត្តិធម៌ រួមទាំងនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ដោយសារតែជាទូទៅ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានរួមបញ្ចូលអាជ្ញាធរក្រុងស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋានមន្ត្រីយុត្តិធម៌ និងពេលខ្លះ តំណាងសង្គមស៊ីវិល បូករួមនឹងនគរបាល ពួកគេអាចបង្កើតជាតុចូលដ៏សំខាន់ក្នុងដំណើរការរៀនសូត្រស្តីពីការឆ្លើយតបដោយមានការសម្របសម្រួលទៅនឹងអំពើហិង្សាលើស្ត្រី និង ក្មេងស្រី[105]។ ឧ.ចំណុចនេះអាចរួមបញ្ចូលការពិនិត្យឡើងវិញ និងការវាយតម្លៃខាងក្រៅលើការឆ្លើយតបដោយមានការសម្របសម្រួលទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

104. "ការស្វែងយល់ពីក្រុមប្រឹក្សាសន្តិសុខតាមមូលដ្ឋាន ក្នុងរយៈពេល ២ នាទី" Conginta ដើម្បីកំណែទម្រង់នគរបាល at : https://www.youtube.com/watch?v=7fGF0_nteGA&t=6s។

105. សូមមើល Fernandez, M., Piaget, K., Hernandez, T., and Berthoud, S (2017)., 'Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR?' ISSAT HRBA Working Group Paper 3,and 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée' (Coginta for Police Reform, 2017)។

ក្រៅពីនេះ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានអាចនាំទៅរកគណនេយ្យភាពកាន់តែប្រសើរក្នុងចំណោមអ្នកផ្តល់សេវាយុត្តិធម៌ និងសន្តិសុខ ព្រោះពួកគេសហការជាមួយសហគមន៍ដែលពួកគេផ្តល់សេវាជូន។ តាមទ្រឹស្តី គំរូទាំងនេះនឹងក្លាយជាបុរេលក្ខខណ្ឌដ៏សំខាន់ក្នុងការកសាងទំនុកចិត្តរវាងអ្នកផ្តល់សេវាយុត្តិធម៌និងសន្តិសុខក្នុងនាមជាអ្នកមានភារៈកិច្ចផ្នែកសិទ្ធិមនុស្ស និងសហគមន៍ក្នុងនាមជាអ្នកមានសិទ្ធិ។ តាមវិធីនេះ ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានអាចនាំទៅរកអភិក្រមផ្អែកតាមសិទ្ធិមនុស្ស (HRBA)[106]ព្រោះការគំរាមកំហែងនិងតម្រូវការសន្តិសុខរបស់សហគមន៍ នឹងត្រូវបានកំណត់ចេញពីទស្សនៈផ្សេងៗ រួមទាំងទស្សនៈរបស់មនុស្ស/ក្រុមដែលគេចាត់ទុកថាងាយរងគ្រោះដោយសារការរើសអើង។

**សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ**

រដ្ឋាភិបាលកុងហ្គោបានកំណត់វិស័យសន្តិសុខជាវិស័យដ៏សំខាន់ជាងគេមួយដែលទទួលបានការយកចិត្តទុកដាក់ក្នុងបរិបទនៃការដោះស្រាយជម្លោះ ជាពិសេសនៅភាគខាងកើតនៃប្រទេស ដែលមានការចោទប្រកាន់ជាបន្តបន្ទាប់ពីការរំលោភសិទ្ធិមនុស្សពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងនគរបាល។

ក្រោមកិច្ចខិតខំប្រឹងប្រែងធ្វើវិមជ្ឈការដោយរដ្ឋាភិបាលកុងហ្គោ ក្រុមប្រឹក្សាសន្តិសុខ មូលដ្ឋានត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៣ ដើម្បីជួយទប់ស្កាត់អសន្តិសុខ និងផ្សារភ្ជាប់រដ្ឋមជ្ឈិមទៅនឹងអាជ្ញាធរមូលដ្ឋាន។ សមាសធាតុក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានរួមមាន ប្រធាន (អាចជាចៅហ្វាយក្រុង អ្នកគ្រប់គ្រងវិស័យ ឬប្រធានសហគមន៍អាស្រ័យលើស្ថាប័នតាមដែនដី)មន្ត្រីមួយរូបមកពីការិយាល័យអគ្គរដ្ឋអាជ្ញា ស្នងការប៉ុស្តិ៍នគរបាល និងតំណាង ២ រូបមកពីសង្គមស៊ីវិល។

106. អង្គការសហប្រជាជាតិកំណត់ HRBA ជា "ក្របខណ្ឌទស្សនាទានដែលផ្អែកលើស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងមានទិសដៅប្រតិបត្តិការដែលផ្តោតលើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស"។ HRBA កត់សម្គាល់ថា ស្ត្រី និងក្មេងស្រីមានសិទ្ធិមនុស្សស្មើនឹងបុរស និងក្មេងប្រុសដែរ ហើយអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាការរំលោភសិទ្ធិទាំងនេះ។ សូមមើល UN Women៖ គំនិតផ្តួចផ្តើមឈានមុខគេ។https://www.unwomen.org/en/how-we-work/flagship-programmes



តាមផ្លូវច្បាប់ ក្រុមប្រឹក្សានេះទទួលបានហិរញ្ញប្បទានពីមូលនិធិខេត្ត ទោះបីជាមិនដូច្នេះរហូតក៏ដោយ ចំណែក Forums de quartiera ដើរតួនាទីជាកិច្ចប្រជុំក្នុងមូលដ្ឋានដែលបើកទូលាយចំពោះសមាជិកសហគមន៍ទាំងអស់ជាទីដែលពួកគេអាចលើកឡើងពីកង្វល់អសន្តិសុខផ្ទាល់ខ្លួន។ ទោះជាយ៉ាងណា ការសំខាន់គឺក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានបានជំរុញឱ្យនគរបាលលើកកម្ពស់ការពិគ្រោះយោបល់យ៉ាងសកម្មជាមួយសង្គមស៊ីវិល និងសហគមន៍។ ដូច្នេះ នគរបាលបានរួមបញ្ចូលក្រុមស្ត្រី និងធានាការរាយការណ៍ពីគំរាមកំហែងសន្តិសុខដែលប្រមែប្រមូលបានពី forums de quartiers ហើយស្ថិតិត្រូវបានបែងចែកតាមយេនឌ័រជាតិពន្ធុនិងទំនោរផ្លូវភេទ។ល។

## Cuyabeno, Sucumbios ប្រទេសអេក្វាឌ័រ

នៅអេក្វាឌ័រការធ្វើវិមជ្ឈការការគ្រប់គ្រងសន្តិសុខត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ(២០០៨)។ ចំណុចនេះនាំទៅរកការបង្កើតក្របខណ្ឌគតិយុត្តិសម្រាប់ក្រុមប្រឹក្សាសន្តិសុខក្រុងទូទាំងប្រទេស រួមទាំងក្នុងក្រុង Cuyabeno ដែលស្ថិតនៅតំបន់ Amazon ជាប់ព្រំដែនប្រទេសកូឡុំប៊ី។

ទីតាំងនៃទីក្រុង Cuyabeno ដែលស្ថិតនៅជិតប្រទេសកូឡុំប៊ី និងភាពសម្បូរធនធានធម្មជាតិ ដូចជា ប្រេងកាតបានបង្កបញ្ហាសន្តិសុខជាច្រើនដែលធ្វើឱ្យយុវជន ស្ត្រី កុមារ និងក្រុមជនជាតិដើមភាគតិចងាយរងគ្រោះកាន់តែខ្លាំង។

ជាការឆ្លើយតប ក្របខណ្ឌគតិយុត្តិសម្រាប់ក្រុមប្រឹក្សាសន្តិសុខទីក្រុងCuyabeno(MSC)ត្រូវបានកែសម្រួលដើម្បីរួមបញ្ចូលការពិគ្រោះយោបល់ជាប្រចាំ ដែលចូលរួមដោយតំណាងមកពីរដ្ឋបាលក្រុង នគរបាល និងយោធា សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ Afro-Ecuadorian និងអង្គការស្ត្រី ក៏ដូចជាសេវាសុខាភិបាល និងស្ថាប័នសុខុមាលភាពកុមារ។

តំណាងម្នាក់មកពីក្រុមហ៊ុនអ៊ីដ្រូកាបូនដ៏មានឥទ្ធិពលជាងគេ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ។ ផ្អែកតាមទស្សនៈសិទ្ធិមនុស្សនេះជាចំណុចវិជ្ជមាននិងចម្រើនទៅមុខ ព្រោះវាផ្តល់ឱកាសឱ្យភាគីទីបីដែលមានកាតព្វកិច្ចសិទ្ធិមនុស្ស ដូចជា ក្រុមហ៊ុនប្រេង និងសន្តិសុខឯកជនរបស់ក្រុមហ៊ុនទាំងនោះ ចូលរួមក្នុងកិច្ចពិភាក្សាស្តីពីបញ្ហាសន្តិសុខដែលបង្កផលប៉ះពាល់លើតំបន់នោះក្រោមការត្រួតពិនិត្យមួយចំនួន។ ក្រុមប្រឹក្សាសន្តិសុខទីក្រុង Cuyabeno មានភាពម្ចាស់ការលើផ្នែកហិរញ្ញវត្ថុប៉ុន្តែមានសិទ្ធិទទួលបានធនធានរដ្ឋតាមរយៈថវិកានគរបាលជាតិសម្រាប់សេវានគរបាលក្នុងសហគមន៍។

## Juarez, Chihuahua ប្រទេសម៉ិចស៊ិក

នៅឆ្នាំ ២០១០ យុទ្ធសាស្ត្រផ្អែកតាមសហគមន៍ដើម្បីផ្តល់សន្តិសុខ និងយុត្តិធម៌ដល់ទីក្រុង Ciudad Juarez, Chihuahua ប្រទេសម៉ិចស៊ិក ចាប់ផ្តើមអនុវត្ត។ "Mesa de Seguridad de Cd. Juarez" (MSCJ) មានអាណត្តិដោះស្រាយផលប៉ះពាល់និងប្រភពនៃអំពើហិង្សា។ នេះជាស្ថាប័នឯករាជ្យក្នុងរដ្ឋាភិបាលមូលដ្ឋាន ហើយក្នុងនាមជាក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានដំបូងគេនៅម៉ិចស៊ិក ស្ថាប័ននេះបានជំរុញឱ្យមានការបង្កើត MSCJ ជាង ១៥ នៅទូទាំងប្រទេស។ ក្នុងនាមជាបណ្តាញមួយ Mesas ផ្សេងៗត្រូវបានសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល SOS ម៉ិចស៊ិក ដែលផ្តោតសំខាន់លើការចូលរួមរបស់ពលរដ្ឋក្នុងសន្តិសុខសាធារណៈ[107]។ MSCJ ត្រូវបានបង្កើតឡើងដោយមន្ត្រីរដ្ឋាភិបាល និងពលរដ្ឋ និងផ្តោតសំខាន់លើការរាយការណ៍ផ្អែកតាមលទ្ធផលស្តីពីបញ្ហា ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន។ ទោះ

ជាយ៉ាងណា MSCJs ត្រូវធានាផ្តល់ព័ត៌មានស្តីពីហិរញ្ញវត្ថុ សមាសធាតុស្ថាប័ន ឬបរិយាបន្នរបស់ខ្លួន ដើម្បីឱ្យវិស័យពាក់ព័ន្ធទាំងអស់ ចាត់ទុកជាយន្តការស្របច្បាប់។ កង្វះព័ត៌មានទាំងនេះធ្វើឱ្យប៉ះពាល់ដល់តម្លាភាព និងការផ្តល់សេវាដែល MSCJ មានគោលបំណងចង់សម្រេចឱ្យបាន។

ថ្វីបើជាធម្មតា សង្គមស៊ីវិលត្រូវបានកំណត់ជាវិស័យមួយក្តី ក៏តួអង្គក្នុង MSCJ ដូចជា នគរបាល ត្រូវធានាការផ្សព្វផ្សាយជាប្រចាំនូវទិន្នន័យបែងចែកតាមយេនឌ័រ និងកត្តានានាភាពផ្សេងទៀតរបស់សមាជិក ដូចជា ជាតិពន្ធុសម្ព័ន្ធភាព (ជនជាតិដើមភាគតិច) ពិការភាព និងអាយុ។

MSCJ មានសមត្ថភាពជំរុញការចូលរួមលើបញ្ហាយេនឌ័រ និងជួយពង្រឹងយុទ្ធសាស្ត្រជាតិដែលផ្តោតលើអំពើហិង្សាក្នុងគ្រួសារនិងអំពើហិង្សាផ្អែកលើយេនឌ័រ។សក្តានុពលរបស់ MSCJ ក្នុងនាមជាយន្តការសម្របសម្រួលដ៏មានប្រសិទ្ធភាពលើសេវាសំខាន់ៗ សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរផ្សារភ្ជាប់នឹងភាពទូលំទូលាយនៃភាពជាតំណាង និងសមត្ថភាពរបស់ខ្លួនក្នុងការធានាប្រសិទ្ធផលនៃអន្តរាគមន៍សុវត្ថិភាពសាធារណៈតាមមូលដ្ឋាន។

107. "SOS ម៉ិចស៊ិក" ត្រវបានបង្កើតឡើងនៅឆ្នាំ ២០០៨ ដោយ Alejandro Marti និងមានគោលបំណងបង្កើតនិងធានាប្រព័ន្ធសន្តិសុខនិងយុត្តិធម៌ដែលមានប្រសិទ្ធភាពនៅម៉ិចស៊ិក។ អង្គការនេះមានគោលបំណង ៣ ៖ ការពង្រឹងស្ថាប័ន កំណែទម្រង់ច្បាប់ និងការចូលរួមរបស់ពលរដ្ឋ។

## ឧបសម្ព័ន្ធ ១
## ការជំរុញការចូលរួមរបស់បុរសក្នុងការទប់ស្កាត់

**ប្រអប់ ៧**

"ឱ្យតែយើងយល់ថាទាំងនេះជាបញ្ហាដែលស្ត្រីខ្លួនឯងត្រូវដោះស្រាយយើងមិនអាចរំពឹងបានថាយើងអាចស្រោចស្រង់អត្រាខ្ពស់នៃឧប្បត្តិហេតុរំលោភសេពសន្ថវៈ ការរំលោភបំពានកុមារ និងអំពើហិង្សាក្នុងគ្រួសារបានឡើយ។ យើងដឹងច្បាស់ថា បុរសជាច្រើនមិនរំលោភបំពានស្ត្រី និងកុមារឡើយ និងតែងខិតខំរស់នៅដោយផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរ។ ប៉ុន្តែមកទល់សព្វថ្ងៃនេះ សំឡេងជាសមូហភាពរបស់បុរសទាំងនេះគ្មានអ្នកស្តាប់ឡើយ ដោយសារតែបញ្ហានេះមិនត្រូវបានចាត់ទុកជាបញ្ហាសម្រាប់ប្រជាជាតិទាំងមូល។ ចាប់ពីថ្ងៃនេះទៅ បុរសដែលប្រព្រឹត្តអំពើហិង្សាលើអ្នកដទៃនឹងដឹងថា ពួកគេកំពុងត្រូវបានកាត់ផ្តាច់ចេញ និងមិនអាចពឹងផ្អែកលើបុរសដទៃឱ្យជួយការពារពួកគេបានឡើយ។ ចាប់ពីពេលនេះទៅបុរសគ្រប់រូបនឹងស្តាប់លឺការអំពាវនាវឱ្យពួកគេទទួលខុសត្រូវលើការដោះស្រាយបញ្ហានេះ"។

Nelson Mandela National Men's March **ទីក្រុងប្រេតូរី ប្រទេសអាហ្វ្រិកខាងត្បូង ១៩៩៧**

នៅពេលយើងនិយាយពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី មនុស្សភាគច្រើននឹងចាត់ទុកថា វាជាបញ្ហារបស់ស្ត្រី។ ហេតុអ្វីមិនយល់ថាវាជាបញ្ហាទូទៅ? នៅពេលអ្នកនិយាយជាមួយក្មេងស្រីនិងស្ត្រីនៅជុំវិញពិភពលោកមនុស្សភាគច្រើនគិតពីការរំលោភបំពាន និងការបៀតបៀនរៀងរាល់ថ្ងៃ។ ស្ត្រី និងក្មេងស្រីមួយចំនួននៅតែរងគ្រោះដោយការបៀតបៀន និងការរំលោភបំពាន។ ស្ត្រី និងក្មេងស្រីជាច្រើននឹងក្លាយជាបុគ្គលដែលស្តារឡើងវិញក្រោយការឆ្លងកាត់អំពើហិង្សា នៅពេលពេញវ័យ ឬនៅវ័យកុមារ។ នៅគ្រប់ករណីទាំងអស់ ក្មេងស្រី និងស្ត្រីជាច្រើននៅតែរៀបចំផែនការសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនដើម្បីទប់ស្កាត់ ឬកាត់បន្ថយការគំរាមប្រព្រឹត្តអំពើហិង្សាដោយបុរស។

ការហៅទម្រង់នៃអំពើហិង្សានេះជាបញ្ហារបស់ស្ត្រី គឺមិនត្រឹមត្រូវទេ។ មិនថាយើងពិចារណាពីអំពើរំលោភសេពសន្ថវៈ ការប្រទូស្តកេរខ្មាស ឬអំពើហិង្សាក្នុងគ្រួសារ ឬយ៉ាងណានោះទេភាគច្រើនលើសលប់នៃបទល្មើសទាំងនេះពាក់ព័ន្ធនឹងជនបង្កជាបុរស និងក្មេងប្រុស។ តើការពិតនេះមិនគួរបញ្ជាក់ថាអំពើហិង្សារបស់បុរសគឺជាបញ្ហារបស់បុរស ទេឬ?

ដូច្នេះអំពើហិង្សាលើស្ត្រីនិងក្មេងស្រីគឺជា"បញ្ហារបស់បុរស" ព្រោះថាជាញឹកញាប់បុរសជាជនបង្កហើយការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ទាំងមូល រួមទាំងបុរសផង។

នៅពេលយើងនិយាយពីបុរសដែលជាជនបង្កយើងងាយនឹងពិពណ៌នាថា បុរសទាំងនោះជាបិសាច ឬសត្វតិរច្ឆានមិនមែនជាមនុស្សឡើយ។ ទោះជាយ៉ាងណា យើងត្រូវកំណត់បញ្ហាទាំងនេះថាជាបញ្ហារបស់បុរសដែលបុរសអាចជួយទប់ស្កាត់បាន។ ដូច្នេះ ចាំបាច់ត្រូវមានអភិក្រមផ្ទាល់ដើម្បីជួយទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងតាមវិធីជាច្រើន កាត់បន្ថយតម្រូវការសេវានគរបាលដែលបណ្តាលមកពីទម្រង់នៃអំពើហិង្សានេះ។ ខណៈដែលការដាក់ឱ្យជនបង្កទទួលខុសត្រូវ នៅតែជាអាទិភាព យើងត្រូវគិត "លើសពីនេះ" និងក្រឡេកមើល វប្បធម៌ដែលបង្កើតឱ្យមានបុរសហិង្សា និងប្រព្រឹត្តបំពានទាំងនេះ។ យើងត្រូវមានភាពស្វាហាប់ក្លាហាននិងពិចារណាពីការពិតដែលថាអំពើហិង្សា (និងជាពិសេសអំពើហិង្សាលើស្ត្រី និងក្មេងស្រី) គឺជាបញ្ហារបស់បុរសវិញ។ ខណៈដែលបុរសភាគច្រើនមិនបំពាន ឬប្រើប្រាស់អំពើហិង្សា ការគ្រាន់តែនិយាយថា "ខ្ញុំជាបុរសល្អ ខ្ញុំមិនធ្វើអញ្ចឹងទេ" គឺមិនទាន់គ្រប់គ្រាន់ឡើយ។ យើងត្រូវការឱ្យបុរសបង្ហាញភាពជាអ្នកដឹកនាំ និងប្រកាន់ជំហរប្រឆាំងនឹងឥរិយាបថប្រព្រឹត្តបំពានរបស់ "បុរសមួយចំនួន" ដែលប្រព្រឹត្តអំពើបំពាន។

តាមពិតបុរសបានធ្វើអ្វីៗជាច្រើនដើម្បីទប់ស្កាត់អំពើហិង្សា

របស់បុរសលើស្ត្រី។ ការស្វែងរកធន្ទៈជាសមូហភាពក្នុងភាពជាបុរសដើម្បីកំណត់យកជាអាទិភាព គឺជាគន្លឹះសំខាន់។ច្បាស់ណាស់ថាបុរសភាគច្រើនមិនទទួលយកឥរិយាបថបំពានរបស់បុរសផ្សេងទៀត ប៉ុន្តែពួកគេមិនពិចារណារកដំណោះស្រាយ ឬមិនទាន់មានភាពក្លាហានក្នុងការធ្វើសកម្មភាពដោយខ្លួនឯង។

ខាងក្រោមនេះជាចំណុចទាំង១០ដែលបុរសគ្រប់រូបអាចធ្វើបានដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

១ **មានភាពម្ចាស់ការលើបញ្ហា៖** ចំណាយពេលឆ្លុះបញ្ចាំងលើបញ្ហាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងមិនមានចរិកការពារខ្លួននៅពេលបុរសត្រូវបានចាត់ទុកជាជនបង្ក។ សូមចាំពាក្យសម្តីរបស់ Nelson Mandela។ គឺមានបុរសតែមួយចំនួនប៉ុណ្ណោះ។

២ **"សិក្សាស្វែងយល់"** ៖ ស្វែងយល់ពីប្រធានបទនេះ។ ការដែលអ្នកអានប្រធានបទនេះ មានន័យថា អ្នកមានចំណាប់អារម្មណ៍។

៣ **និយាយជាមួយអ្នកដទៃ** ៖ ប្រើប្រាស់ចំណេះដឹងថ្មីៗដែលអ្នកទទួលបានដើម្បីនិយាយជាមួយបុរសផ្សេងទៀតពីបញ្ហាទាំងនេះ។ ជួយពួកគេជម្នះចរិកការពារខ្លួន។

៤ **និយាយជាមួយស្ត្រីក្នុងជីវិតរបស់អ្នក៖** ស្តាប់បទពិសោធន៍នៃការរងគ្រោះដោយការបៀតបៀននិងការរំលោភបំពានរបស់នាង។រៀនសូត្រពីបទពិសោធន៍ទាំងនេះ។

៥ **មានភាពក្លាហានក្នុងការស្វែងយល់ពីខ្លួនឯង** ៖ ស្វ័យត្រួតពិនិត្យជួយពង្រឹងស្មារតី។ ជាញឹកញាប់ បុរសគ្រប់រូបពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលក្នុងការនិយាយប្រមាថស្ត្រី។ វាជាបញ្ហាជុំវិញជីវិតរស់នៅរបស់បុរស។ សូមកុំខ្មាសអៀន។ក្នុងទស្សនៈថ្មីនេះ សូមបង្ហាញការខឹងសម្បារនិងធ្វើអ្វីមួយដើម្បីបង្កើតភាពខុសប្លែក។

៦ **ធ្វើជាគំរូវិជ្ជមាន៖** បុរសគឺជាឪពុក។កូនប្រុសរបស់អ្នករងឥទ្ធិពលពីទង្វើរបស់អ្នក។ សូមធ្វើជាមនុស្សគំរូក្នុងជីវិតរបស់ពួកគេ។ សូមធ្វើជាបុរសដែលសុភាពនិងសប្បុរស។កូនប្រុសរបស់អ្នកនឹងយកគំរូតាមអ្នក។ កូនស្រីរបស់អ្នកនឹងរៀនសូត្រពីរបៀបដែលបុរសប្រព្រឹត្តចំពោះពួកគាត់។

៧ **មានសម្ព័ន្ធភាពជាមួយស្ត្រី៖** យកចំណេះដឹងថ្មីៗរបស់អ្នកទៅអនុវត្ត។ គាំទ្រដល់ស្ត្រី និងបុរសផ្សេងទៀតដែលមានជំហរប្រឆាំងនឹងការបៀតបៀន។

៨ **គាំទ្រអ្នកដទៃ** ៖ ក្នុងករណីដែលអ្នកសង្ស័យថា មិត្តភក្តិ ឬសាច់ញាតិណាម្នាក់គឺជាជនរងគ្រោះដោយសារការរំលោភបំពាន សូមជួយដល់ពួកគេ។ កុំធ្វើជាអ្នកមិនដឹងមិនលឺ ប៉ុន្តែធ្វើជាមិត្តភក្តិ។ ការងាររបស់អ្នកមិនមែនដើម្បីដោះស្រាយបញ្ហានោះទេ។ ការទទួលស្គាល់បទពិសោធន៍របស់ជនរងគ្រោះ នឹងផ្តល់ការគាំទ្រ។ ធានាថា អ្នកប្រាប់ពួកគេថា វាមិនមែនជាកំហុសរបស់ពួកគេទេ។

៩ **ដេញដោលអ្នកដទៃ៖** នៅពេលស្តាប់លឺអ្នកមានបទពិសោធន៍ និងវាយស្របាលគ្នា ឬអ្នកដទៃប្រព្រឹត្តបំពាន សូមនិយាយពាក្យពេចន៍ខ្លះ។ វាជាការលំបាកនិងត្រូវការភាពក្លាហាន។ សូមធ្វើជាអ្នកដឹកនាំ និងនិយាយអ្វីមួយដែលបង្ហាញថា ទង្វើរបស់ពួកគេគឺខុសឆ្គង។ ការពិត គឺបុរសផ្សេងទៀតនឹងគាំទ្រគោលជំហររបស់អ្នក។

១០ **ដេញដោលវប្បធម៌** ៖ ទន្ទឹមនឹងការដេញដោលអ្នកដទៃ សូមដេញដោលវប្បធម៌ក្នុងមជ្ឈដ្ឋានរស់នៅរបស់ក្មេងប្រុសនិងបុរស។មានតែការលើកឡើងពីវប្បធម៌នេះទេ ទើបយើងអាចកាត់បន្ថយកម្រិតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីបាន។



រូបថតទទួលបានពី Graham Goulden ប្រធានក្រុមនគរបាលស៊ើបអង្កេត (ចូលនិវត្តន៍) ស្កុតឡែន

# ៥

## កំណត់សម្គាល់ និងអំណានបន្ថែម


1. Code of Conduct for Law Enforcement Officials (adopted by General Assembly resolution 34/169 of 17 December 1979), see: https://www.ohchr.org/EN/ProfessionalInterest/Pages/LawEnforcementOfficials.aspx

2. 'Aspects of violence against women that pertain directly to the Commission on Crime Prevention and Criminal Justice, (Commission on Crime Prevention and Criminal Justice' V.08-52191 (E) *0852191* Seventeenth session Vienna, 2018).

3. Recommendations for Action against Gender-related Killing of Women and Girls (UNODC, 2015), see: https://www.unodc.org/documents/justice-and-prison-reform/15-08233_A4-GRK_eBook.pdf

4. Updated Model Strategies and Practical Measures on the Elimination of Violence against Women in the Field of Crime Prevention and Criminal Justice, adopted by General Assembly resolution 65/228 of 21 December 2010, see:. https://www.unodc.org/documents/justice-and-prison-reform/crimeprevention/Model_Strategies_and_Practical_Measures_on_the_Elimination_of_Violence_against_Women_in_the_Field_of_Crime_Prevention_and_Criminal_Justice.pdf

5. United Nations Guidelines for the Prevention of Crime (Economic and Social Council resolution 2002/13, annex), see: https://www.unodc.org/documents/justice-and-prison-reform/crimeprevention/resolution_2002-13.pdf

6. United Nations Standards and Norms in Crime Prevention At your Finger Tips (UNODC), at: https://www.unodc.org/pdf/criminal_justice/UN_standards_and_norms_in_crime_prevention_at_your_fingertips.pdf

7. Handbook on the Crime Prevention Guidelines: Making Them Work (UNODC, 2010), at: https://www.unodc.org/pdf/criminal_justice/Handbook_on_Crime_Prevention_Guidelines_-_Making_them_work.pdf

8. Guidelines on Police Operations in United Nations Peacekeeping Operations and Special Political Missions (DPKO-DFS, 2015), at: https://police.un.org/sites/default/files/sgf-guidelines_police_operations-2015.pdf

9. Global Report Police Station Visiting Week (2012): Advancing Human Rights Standards in Police Stations (Altus Global Alliance) at:. https://issat.dcaf.ch/download/29464/413964/Altus%20Global%20Report%202012%20(2).pdf

10. Secretary-General's In-depth study on all forms of violence against women (A/61/122/Add.1), at: https://documents-dds-ny.un.org/doc/UNDOC/GEN/N06/419/74/PDF/N0641974.pdf?OpenElement

11. 'A Framework to Underpin Action to Prevent Violence against Women' (UN Women et al., 2015), at: https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework

12. 'Reinforcing community and local security structures in Suzak, Kyrgyzstan' (Saferworld, 2015), at: https://www.saferworld.org.uk/en-stories-of-change/reinforcing-community-and-local-security-structures-in-suzak-kyrgyzstan).

13. Police Integrity Toolkit (The Geneva Centre for Security Sector Governance, 2012), at: https://www.dcaf.ch/sites/default/files/publications/documents/Toolkit_ENG_screen.pdf

14. Logar, R., 'The Austrian Model of Intervention in Cases of Domestic Violence', Paper presented at the UN Expert Group Meeting: Violence against Women: Good practice in Combating and Eliminating Violence against Women (Vienna, 17–20 May 2005), at: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/logar.dv.pdf

15. Ending Violence against Women and Girls: The world's best laws and policies' (Future Policy Award, 2014) (UN Women, World Future Council and Inter-Parliamentary Union), at: https://www.worldfuturecouncil.org/wp-content/uploads/2016/01/WFC_2014_Future_Policy_Award_En.pdf

16. 'Eliminating Violence Against Women in the Asia Pacific: It's all of our responsibility', (UN Women), at : https://www.aidsdatahub.org/sites/default/files/publication/UN_Women_2015_Eliminating_violence_against_women_in_the_Asia_Pacific.pdf

17. Ten Years of Austrian Anti-Violence Legislation: 2017 International Conference in the Context of the Council of Europe Campaign to Combat Violence Against Women, Including Domestic Violence

(Vienna and St. Pölten, Austria, 5 to 7 November 2007), at: https://www.interventionsstelle-wien.at/download/?id=406

18. 'A Study for Creating a Multidisciplinary Response Mechanism to Violence Against Women in Egypt' (UNODC, 2015).

19. 'Engagement and Communication Authorised Professional Practice' (College of Policing, UK), at: https://www.app.college.police.uk/app-content/engagement-and-communication/engaging-with-communities

20. Gender-Based Violence (Violence Against Women and Girls) (The World Bank, 2019), at: https://www.worldbank.org/en/topic/socialdevelopment/brief/violence-against-women-and-girls

21. Guidelines to Estimate the Economic Cost of Domestic Violence in the Arab Region (UNFPA, 2019), at: https://www.unescwa.org/sites/www.unescwa.org/files/publications/files/guidelines-estimate-economic-cost-domestic-violence-arab-region-english_0.pdf

22. 'Estimating Costs of Marital Violence in the Arab Region: Operational Model' (UN Women E/ESCWA/ECW/2017/Technical Paper 4, 18 July 2017), at: https://www.unescwa.org/file/66255/download?token=fGod_SpM

23. 'Understanding local security councils in two minutes', Coginta for Police Reforms, at: https://www.youtube.com/watch?v=7fGFo_nteGA

24. Qu'est ce qu'un CLSPD - CISPD ? Government of France, at: http://www.isere.gouv.fr/Politiques-publiques/Securites/Securite-publique/Prevention-de-la-delinquance2/Qu-est-ce-qu-un-CLSPD-CISPD

25. 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée (Coginta for Police Reform, 2017), at: http://www.coginta.org/uploads/documents/cedd246fbc7d133bcf29135bec8a66d561202ae4.pdf

26. Fernandez, M., Piaget, K., Hernandez, T., and Berthoud, S., (2017), 'Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR? ISSAT HRBA Working Group Paper 3, at: https://issat.dcaf.ch/download/111714/2027474/HRBA%20Working%20Group%20Paper%203.pdf

27. Intersectionality and the inclusive approach to dealing with gender-based violence: A Position Paper from Women Against Violence Europe (WAVE, 2018) at: http://fileserver.wave-network.org/researchreports/WAVE%20_positionpaper_intersectionality2018.pdf

28. World Health Organization, 'Violence Prevention: The Evidence', at: https://www.who.int/violence_injury_prevention/violence/the-evidence/en/

29. ACES too High News, see: https://acestoohigh.com/

30. Martinez Calvo. S, Adverse Childhood Experiences (ACEs), at: https://www.70-30.org.uk/18737-2/

31. 'Combating Violence against Women: Minimum Standards for Support Services' (Directorate General of Human Rights and Legal Affairs, Council of Europe, Strasbourg, 2008), at: https://www.coe.int/t/dg2/equality/domesticviolencecampaign/Source/EG-VAW-CONF(2007)Study%20rev.en.pdf

32. 'Analytical study of the results of the 4th round of monitoring the implementation of Recommendation Rec (2002) 5 on the protection of women against violence in Council of Europe member states' (Council of Europe, 2014), at: https://rm.coe.int/16805915e9

33. What Is G.R.E.A.T.? See: https://www.great-online.org/GREAT-Home

34. School-based Violence Prevention: A Practical Handbook (World Health Organization, Geneva, 2019), see: https://apps.who.int/iris/bitstream/handle/10665/324930/9789241515542-eng.pdf?sequence=1&isAllowed=y

35. 'Preventing Adverse Childhood Experiences (ACEs): Leveraging the Best Available Evidence', (Division of Violence Prevention National Center for Injury Prevention and Control Centers for Disease Control and Prevention Atlanta, Georgia, 2019), at: https://www.cdc.gov/violenceprevention/pdf/preventingACES-508.pdf

36. Project Tool 130: Checklist on problem resolution using the SARA model in UNPOL Gender Toolkit Standardised Best Practices on Gender Mainstreaming in Peacekeeping Compendium of Project Tools (2015), at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

4

# ទំនាក់ទំនងដំបូង

"ជំហានវិជ្ជមានមួយក្នុងការបង្កើនគណនេយ្យភាពគឺត្រូវធ្វើឱ្យអំពើរំលោភសេពសន្ថវៈក្លាយជាអំពើខុសច្បាប់ជាសកល។ បច្ចុប្បន្ន ប្រទេសជាង ៥០% នៅជុំវិញពិភពលោក មិនទាន់មានច្បាប់ដែលផ្តន្ទាទោសព្រហ្មទណ្ឌលើអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ឬផ្អែកលើគោលការណ៍នៃការយល់ព្រមនៅឡើយទេ។ទន្ទឹមនឹងការផ្តន្ទាទោសព្រហ្មទណ្ឌលើអំពើរំលោភសេពសន្ថវៈយើងត្រូវខិតខំដាក់ជនរងគ្រោះជាចំណុចស្នូលនៃការឆ្លើយតបនិងរក្សាការទទួលខុសត្រូវរបស់ជនបង្ក។ ពេលគឺការពង្រឹងសមត្ថភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់ក្នុងការស៊ើបអង្កេតបទល្មើសទាំងនេះ និងគាំទ្រដល់ជនរងគ្រោះតាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដោយផ្តល់លទ្ធភាពទទួលបានជំនួយផ្លូវច្បាប់សេវានគរបាល និងសេវាយុត្តិធម៌ ព្រមទាំងសេវាសុខាភិបាល និងសេវាសង្គម ជាពិសេសសម្រាប់ស្ត្រីដែលជួបការលំបាកបំផុត"។

Phumzile Mlambo-Ngcuka នាយកប្រតិបត្តិ UN Women

# គោលបំណងនៃជំពូកទី ៤

**នគរបាលបានជំរុញលើកទឹកចិត្ត និងសម្រួលដល់ស្ត្រី និងក្មេងស្រីដែលរាយការណ៍ពីបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរយៈការបង្ហាញដោយប្រសិទ្ធភាពនូវការប្តេជ្ញាចិត្តធានាសុខុមាលភាពរបស់ជនរងគ្រោះគាំទ្រដល់ស្ត្រី និងក្មេងស្រី និងធានាថា ពួកគាត់អាចទទួលបានយុត្តិធម៌ដោយគ្មានការរើសអើង ភាពលម្អៀង ឬបុរេនិច្ឆ័យ។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការកំណត់បរិបទនៃការណែនាំដល់ភ្នាក់ងារឆ្លើយតបបឋម នឹងជួយដល់មន្ត្រីក្នុងការបំពេញតម្រូវការចម្រុះរបស់ជនរងគ្រោះពាក់ព័ន្ធនឹងសន្តិសុខ និងជំនួយនានា។
- ការសំឡឹងមើលហួសពីសេណារីយ៉ូជំនួយបច្ចុប្បន្ន មិនត្រឹមតែផ្តល់ប្រយោជន៍ភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រយោជន៍រយៈពេលវែងទៀតផង។
- ការកាត់បន្ថយភាពលម្អៀងយេនឌ័រនិងការវិនិច្ឆ័យនឹងជួយបង្កើនភាពអង់អាចរបស់ជនរងគ្រោះក្នុងការសហការជាមួយក្រុមស៊ើបអង្កេត។
- ការយល់ថាតើការប៉ះទង្គិចផ្លូវចិត្តបង្កផលប៉ះពាល់ខុសគ្នាដូចម្តេចលើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានសារៈសំខាន់ណាស់នៅពេលជំរុញការចូលរួមរបស់ពួកគាត់។
- សម្រាប់ភ្នាក់ងារឆ្លើយតបបឋម អាទិភាពរបស់នគរបាលគ្រប់រូបគឺសុវត្ថិភាពរបស់ជនរងគ្រោះ។
- គុណភាពនៃសេវាដែលជនរងគ្រោះទទួលបានអាស្រ័យលើសមានចិត្តការយល់និងការប្តេជ្ញាចិត្តរបស់មន្ត្រីនគរបាលពាក់ព័ន្ធ។



## សេចក្ដីផ្ដើម

បទពិសោធន៍វិជ្ជមាននៃទំនាក់ទំនងដំបូងជាមួយប្រព័ន្ធយុត្តិធម៌ មានសារៈសំខាន់ណាស់សម្រាប់ជនរងគ្រោះ ដោយសារអំពើហិង្សា។ សេវាត្រូវផ្ដល់ជូន ហើយស្ត្រីគ្រប់រូបងាយស្រួលទទួលបានសេវាទាំងនោះ108។ យោងតាមកញ្ចប់សេវាសំខាន់ៗ សមាសធាតុសំខាន់ជាងគេនៃទំនាក់ទំនងដំបូងគឺសមត្ថភាពរបស់នគរបាលក្នុងការបង្ហាញដល់ជនរងគ្រោះថាប្រព័ន្ធយុត្តិធម៌ និងអ្នកផ្ដល់សេវាយុត្តិធម៌ក្នុងប្រព័ន្ធនេះប្ដេជ្ញាធានាសុខភាព និងសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រី ពិចារណាផិតដល់ពីបណ្ដឹងរបស់ពួកគាត់ ទុកលទ្ធភាពឱ្យពួកគាត់រៀបរាប់ដំណើររឿងនិងធានាបានថា ពួកគាត់ទទួលបានការគាំទ្រល្អប្រសើរនៅពេលប្រឡូកក្នុងប្រព័ន្ធយុត្តិធម៌[109]។

រូបថតទទួលបានពី UNMIT/Martine Perret (ប្រទេសទីម័រខាងកើត)

ថ្នាក់ដឹកនាំនគរបាលដែលមានតួនាទីដាក់បទបញ្ជា គួរធានាថាការរៀបចំពិធីសារស្ដាប័នសម្រាប់មន្ត្រីឆ្លើយតបបឋម ឬភ្នាក់ងារឆ្លើយតបបឋមក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីធានាការពារសុខុមាលភាពរបស់ជនរងគ្រោះ និងជាចំណុចចាប់ផ្ដើមសម្រាប់ការស៊ើបអង្កេតដែលមានប្រសិទ្ធភាព និងប្រកបដោយវិជ្ជាជីវៈ។

ក្នុងន័យនេះ ថ្នាក់ដឹកនាំនគរបាលដែលជាអ្នកគ្រប់គ្រងមន្ត្រីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរមានភាពម្ចាស់ការផ្នែកប្រតិបត្តិការក្នុងការកំណត់បរិបទនៃការណែនាំ នៅពេលបុគ្គលិក អនុវត្តពិធីសារស្ដីពីភ្នាក់ងារឆ្លើយតបដំបូង។ ចំណុចនេះ គឺដើម្បីធានាថា

> “ខណៈដែលស្ត្រីនិងក្មេងស្រីទូទាំងពិភពលោកទទួលរងទម្រង់មួយចំនួននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ វាបានក្លាយជាសោកនាដកម្មទ្វេដងសម្រាប់ស្ត្រី និងក្មេងស្រីជនជាតិដើម និងជនជាតិភាគតិច។ ក្នុងប្រទេសជាច្រើន មិនសូវមានការទទួលស្គាល់ផ្លូវច្បាប់ចំពោះអត្តសញ្ញាណរបស់ពួកគេក្នុងនាមជាសហគមន៍ពិសេសមួយដែលមានបែបផែនជីវិត វប្បធម៌ និងគន្លងជីវិត ដែលធ្វើឱ្យពួកគេមិនទទួលបានការយកចិត្តទុកដាក់ក្នុងស្ថិតិជាតិ និងសេវាសង្គម”។
>
> អង្គការក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ

បុគ្គលិកទាំងនោះអាចដោះស្រាយបញ្ហាសន្តិសុខចំពោះមុខនិងបំពេញតម្រូវការចម្រុះរបស់ជនរងគ្រោះបានគ្រប់គ្រាន់ដោយមិនគិតពីសាវតារ ស្ថានភាពផ្លូវច្បាប់ក៏ដូចជាសមត្ថភាពផ្លូវកាយ ឬ សមត្ថភាពផ្នែកបញ្ញាស្មារតីរបស់ពួកគេ។

108. សូមមើលម៉ូឌុលទី ៣ ៖ យុត្តិធម៌ និងនគរបាល កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្ដីពីសមាសធាតុស្នូល និងគុណភាព (២០១៥) ទំ. ៦-៧។
109. សម្រាប់សេវាសំខាន់ៗ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធនឹងជនរងគ្រោះជាក្មេងស្រី សូមមើលគោលការណ៍ណែនាំស្ដីពីយុត្តិធម៌ក្នុងបញ្ហាពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះ និងសាក្សីនៃបទល្មើស (សេចក្ដីសម្រេចលេខ ២០០៥/២០ របស់ ECOSOC)។

ក្នុងការកំណត់បរិបទនៃការណែនាំសម្រាប់ភ្នាក់ងារឆ្លើយតបបឋម ថ្នាក់ដឹកនាំនគរបាលគួរខិតខំពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងរបស់បុគ្គលដែលងាយរងគ្រោះ ដូចជា ជនជាតិភាគតិច[110] ឬអង្គការស្ត្រីដែលមានតំណាងភាគតិច[111]និងអ្នកដឹកនាំមកពីសហគមន៍ជនជាតិភាគតិច (ជាពិសេសអ្នកដឹកនាំជាស្ត្រី) ឬយ៉ាងហោចណាស់ស្នើសុំព័ត៌មានទាំងនេះពីនគរបាលដែលចូលរួមជាប្រចាំជាមួយសហគមន៍ក្នុងតំបន់សមត្ថកិច្ចរបស់ខ្លួន។

ដំណើរការពិគ្រោះយោបល់ជាការអនុវត្តល្អសម្រាប់បង្កើតទំនាក់ទំនងការងារជាមួយសហគមន៍មូលដ្ឋានដែលអាចជួយឱ្យនគរបាលកត់សម្គាល់ផលប៉ះពាល់នៃអំពើហិង្សាលើក្រុមស្ត្រី និងសហគមន៍ជារួម។ ការទទួលបានការគាំទ្រពីសហគមន៍ក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នឹងផ្តល់មូលដ្ឋានដល់ជនរងគ្រោះ ក្នុងការចាត់ទុកនគរបាលជាប្រភពនៃការការពារភ្លាមៗដែលស្របច្បាប់ និងបំផុសឱ្យជនរងគ្រោះបង្កើតទំនាក់ទំនងដំបូង។

## ការណែនាំគ្នាទៅវិញទៅមក

បុគ្គលិកទីមួយដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដើរតួនាទីយ៉ាងសំខាន់។ ពួកគេជា "មន្ត្រីជួរមុខ" សម្រាប់អ្នក និងស្ថាប័ននគរបាលរបស់អ្នក។ ការសំខាន់គឺពួកគេត្រូវយល់ពីគោលការណ៍ "ទំនាក់ទំនងនិមួយៗសុទ្ធតែបន្សល់ដាន" នៅពេលជំរុញការចូលរួមរបស់សហគមន៍។ ដូច្នេះ គុណភាពនៃទំនាក់ទំនងដំបូងគឺសំខាន់ណាស់។

ដើម្បីអាចឱ្យជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី រាយការណ៍បទល្មើសដល់អ្នក ឬបុគ្គលិករបស់អ្នកអ្នកត្រូវធានាការយល់ច្បាស់ពីយន្តការរាយការណ៍ និងផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះ។ ស្ត្រី និងក្មេងស្រីមិនសុទ្ធតែមានមធ្យោបាយធ្វើដំណើរទៅកាន់ប៉ុស្តិ៍នគរបាលឡើយ ហើយចំណុចនេះបណ្តាលមកពីកត្តាជាច្រើន។ ជនរងគ្រោះអាចមានការលំបាកក្នុងការចេញពីផ្ទះដោយសារគ្មានអ្នកអមដំណើរ។ ប៉ុស្តិ៍នគរបាលអាចនៅឆ្ងាយពេក។ ពួកគេប្រហែលជាគ្មានសាហ៊ុយធ្វើដំណើរ ឬក៏មធ្យោបាយធ្វើដំណើរគ្មានសុវត្ថិភាព ឬមិនអាចប្រើប្រាស់បាន។ ពួកគេប្រហែលជាត្រូវបំពេញកិច្ចការថែទាំនៅផ្ទះ និង/ឬកំពុងរស់នៅដោយការភ័យខ្លាចជនបង្កដែលរងការចោទប្រកាន់ សមាជិកគ្រួសារ ឬសហគមន៍ទាំងមូល។ ក្រៅពីនេះ ពួកគេប្រហែលជាមិនដឹងថានគរបាលអាចជួយដោះស្រាយបទល្មើសទាំងនេះបាន ព្រោះគេអាចចាត់ទុកវាជា "បញ្ហាឯកជន"។ ប្រសិនបើជនរងគ្រោះបានទៅកាន់ប៉ុស្តិ៍នគរបាលពួកគេអាចនៅតែប្រឈមនឹងឧបសគ្គមួយចំនួន ដូចជា ឥរិយាបថអវិជ្ជមានរបស់មន្ត្រី កង្វះហេដ្ឋារចនាសម្ព័ន្ធដែលគិតគូរពីជនរងគ្រោះឬក៏គ្មានហេដ្ឋារចនាសម្ព័ន្ធទាំងនោះឬមិនផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះដែលមានពិការភាពផ្សេងៗ។

ដូច្នេះ ដើម្បីធានាសិទ្ធិរបស់ជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌ អ្នកមានភារកិច្ចជួយដល់ពួកគេ។

110. "ការធ្វើឱ្យក្លាយជាក្រុមភាគតិច" បង្កើត និងរក្សាបានយ៉ាងមានប្រសិទ្ធភាពនូវលក្ខខណ្ឌសង្គម នយោបាយ សេដ្ឋកិច្ច និងលក្ខខណ្ឌផ្សេងទៀតដែលនាំឱ្យក្រុមមនុស្សមួយចំនួនត្រូវបានប្រព្រឹត្តចំពោះ និងកំណត់ជាជនជាតិភាគតិច ដូចជា "ជាតិពន្ធុភាគតិច" និង "ជនភាគតិច"។ វាជាដំណើរការយ៉ាងសកម្មនិងបន្តជាប់ដែលធ្វើឱ្យក្រុមមួយចំនួនជួបការលំបាក ដោយសារជាតិសាសន៍ ជាតិពន្ធុ និងមូលហេតុផ្សេងទៀត។
111. ក្នុងក្រុមជនជាតិភាគតិចមួយចំនួន អង្គការទាំងនេះអាចដឹកនាំដោយបុរស និង/ឬគ្រប់ដណ្តប់ដោយបុរស។ ជាយូរមកហើយ នេះជាការពិតសម្រាប់អង្គការជនពិការ។ ការសំខាន់គឺសំឡេងទាំងនេះនៅតែត្រូវបានដាក់បញ្ចូលជាគូសន្ទនា ប្រសិនបើគ្មានអង្គការដឹកនាំដោយស្ត្រីមានពិការភាព។

អ្នកត្រូវពិចារណាពីចំណុចខាងក្រោម ៖

- តើអ្នកមានមន្ត្រីជាស្ត្រីដែលទទួលការបណ្តុះបណ្តាលសមស្របស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងត្រូវបានដាក់ពង្រាយដើម្បីផ្តល់ភាពងាយស្រួលដល់ស្ត្រី និងក្មេងស្រីគ្រប់រូប ឬទេ ?
- តើអ្នកមានយន្តការរាយការណ៍សមស្រប និងផ្តល់ភាពងាយស្រួលសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ ?
- តើយន្តការទាំងនោះត្រូវបានបោះពុម្ពផ្សាយ និងផ្តល់ជូនយ៉ាងទូលំទូលាយជាភាសានិងក្នុងទម្រង់ផ្សេងៗ ឬទេ (អក្សរសម្រាប់ជនពិការភ្នែក តួអក្សរធំៗ ងាយស្រួលអាន) ?
- តើមានផ្នែកផ្តល់ជំនួយដល់ស្ត្រីឬកន្លែងរាយការណ៍ដោយឡែកផ្សេងទៀតដែលផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះក្នុងប៉ុស្តិ៍នគរបាលរបស់អ្នក ឬទេ ?
- ប្រសិនបើមានផ្នែកផ្តល់ជំនួយ តើវាស្ថិតនៅទីតាំងសមស្រប ឬទេ? ។. ជនរងគ្រោះមិនចាំបាច់ដើរកាត់ផ្នែកកណ្តាលដែលសាធារណជនចេញចូលរួមទាំងក្នុងប៉ុស្តិ៍នគរបាល ដើម្បីអាចរាយការណ៍ពីបទល្មើសដែលជាញឹកញាប់ធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ជាពិសេសដោយសារតែជារឿយៗជនរងគ្រោះភ័យខ្លាចផលវិបាកនៃការរាយការណ៍ទៅនគរបាល។តើអ្នកអាចរក្សាឯកជនភាព និងការរក្សាការសម្ងាត់បានដោយរបៀបណា ប្រសិនបើជនរងគ្រោះជាស្ត្រីត្រូវដើរកាត់ប៉ុស្តិ៍នគរបាលដ៏មមាញឹកដើរកាត់កន្លែងឃុំឃាំងដើម្បីចូលទៅដល់ផ្នែកផ្តល់ជំនួយ ? ប្រសិនបើអ្នកគ្មានហេដ្ឋារចនាសម្ព័ន្ធដែលគិតគូរពីជនរងគ្រោះ សូមពិចារណាស្នើសុំជំនួយពីសេវាសំខាន់ៗផ្សេងទៀត ដូចជា អ្នកផ្តល់សេវាសុខាភិបាល ដើម្បីឱ្យបុគ្គលិករបស់អ្នកអាចជួបជាមួយជនរងគ្រោះក្នុងទីតាំងមួយ ដែលនៅឆ្ងាយពីប៉ុស្តិ៍នគរបាល។

តួនាទីចម្បងគេរបស់នគរបាលគឺការធានាសុវត្ថិភាពចំពោះមុខ និងសុខភាពរបស់ជនរងគ្រោះ ក្រោយការរាយការណ៍ពីអំពើហិង្សាហើយអ្វីដែលសំខាន់បំផុតគឺការឆ្លើយតបទាន់ពេលវេលា។

សូម្បីតែក្នុងដំណាក់កាលឆ្លើយតបដំបូងក៏បុគ្គលិករបស់អ្នកត្រូវវាយតម្លៃពីអ្វីដែលអាចបង្កហានិភ័យចំពោះសុវត្ថិភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេផងដែរ ដើម្បីទប់ស្កាត់ឬកាត់បន្ថយការបំភិតបំភ័យការសងសឹក ឬការរងគ្រោះឡើងវិញ។ ទោះបីជាជនរងគ្រោះអាចនឹងស្ទាក់ស្ទើរក្តី (ជាញឹកញាប់ បណ្តាលមកពីការភ័យខ្លាចការពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ) ក៏អ្នកនិងបុគ្គលិករបស់អ្នកនៅតែមានភារកិច្ចការពារសុវត្ថិភាពរបស់ពួកគេ ឬសមាជិកគ្រួសារដែលអាចប្រឈមនឹងហានិភ័យ។ នេះជាការសំខាន់ប្រសិនបើកុមារប្រឈមនឹងហានិភ័យ រួមទាំងហានិភ័យនៃការប្រឈមនឹងគ្រោះថ្នាក់ផ្លូវកាយ និងផ្លូវចិត្ត។

អ្នកមានភារកិច្ចការពារ។ ដូច្នេះ សកម្មភាពវិជ្ជមានទោះក្នុងទម្រង់អ្វីក៏ដោយគឺត្រូវការជាចាំបាច់ហើយការមិនធ្វើអ្វីសោះមិនមែនជាជម្រើសនោះទេ។ សកម្មភាពវិជ្ជមានអាចជាការធានាសុវត្ថិភាពរបស់ជនរងគ្រោះ និងអ្នកផ្សេងទៀត តាមរយៈការបញ្ជូនពួកគេទៅកន្លែងសុវត្ថិភាព ឬជម្រកសុវត្ថិភាព ឬមជ្ឈមណ្ឌលផ្តល់សេវាចម្រុះ (ប្រសិនបើមាន) ឬការនាំខ្លួនជនបង្កដែលរងការចោទប្រកាន់ចេញពីកន្លែងនោះ។ អ្នកត្រូវធានាថា អ្នកប្រើប្រាស់អំណាចទាំងអស់របស់អ្នកប៉ុន្តែត្រូវចាំថាជនបង្កដែលរងការចោទប្រកាន់ក៏មានសិទ្ធិដែលត្រូវការពារផងដែរ។

ពេលទៅដល់កន្លែងកើតហេតុ ការសំខាន់ៗគឺនគរបាលឆ្លើយតបបឋមត្រូវយល់ពីទស្សនាទានថា អ្វីដែលពួកគេមើលឃើញនៅពេលទៅដល់អាចមិនមែនជាអ្វីដែលពួកគេរំពឹងទុក។ ។. ក្នុងករណីអំពើហិង្សាអន្តរបុគ្គលជនរងគ្រោះប្រហែលជាបានរៀបចំផ្ទះសម្ល្រែងក្រោយអំពើហិង្សា។

អ្នកត្រូវធានាថា បុគ្គលិករបស់អ្នកយល់ពីសារៈសំខាន់នៃការសំឡឹងមើលហួសពីទីតាំងនៅចំពោះមុខពួកគេ ហើយពួកគេទៅទីនោះដើម្បីផ្តល់ជំនួយភ្លាមៗ ក៏ដូចជាជំនួយរយៈពេលវែង។ គោលការណ៍មូលដ្ឋាន គឺត្រូវបំបែកជនរងគ្រោះចេញពីជនបង្ក ដែលរងការចោទប្រកាន់ ដើម្បីអាចឱ្យជនរងគ្រោះនិយាយរៀបរាប់ពីអ្វីដែលបានកើតឡើង។

ជាញឹកញាប់ ជនរងគ្រោះសម្រេចចិត្តប្រឈមមុខនឹងឧប្បត្តិហេតុដោយខ្លួនឯងព្រោះយល់ថាគ្រួសារនគរបាល និងសហគមន៍នឹងមិនជឿគាត់។ នេះអាចជាមូលហេតុទូទៅបំផុតមួយនៃការមិនទាក់ទងទៅនគរបាលឬអ្នកផ្តល់សេវាផ្សេងទៀត (ដូចករណីនៅសហភាពអឺរ៉ុប)។ នេះជាបញ្ហាចោទសម្រាប់ជនមានពិការភាពផ្សេងៗ។

**នៅពេលឆ្លើយតបនឹងកន្លែងប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ អ្នកត្រូវសំឡឹងមើលឫសពីទីតាំងនៅចំពោះមុខអ្នក។**

ការស្រាវជ្រាវបែបគុណភាពផ្តល់មូលហេតុបន្ថែមថា តើហេតុអ្វីស្ត្រីមិនទាក់ទងទៅនគរបាល(ឬសេវាផ្សេងទៀត)។ ឧ. អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ផ្តល់ចំណេះដឹងស្តីពីបញ្ហាប្រឈមទូទៅរបស់ស្ត្រី និងក្មេងស្រី និងមូលហេតុដែលស្ត្រី និងក្មេងស្រីចូលចិត្តប្រឈមមុខជាមួយឧប្បត្តិហេតុអំពើហិង្សាដោយខ្លួនឯង[112]៖

- **ភាពខ្មាសអៀន** រួមទាំងភាពខ្មាសអៀនដោយសារទម្រង់អំពើហិង្សាមួយចំនួន និងការលែងលះ
- **ហេតុផលហិរញ្ញវត្ថុ** រួមទាំងការបារម្ភថា ស្ត្រីមិនអាចរ៉ាប់រងចិញ្ចឹមខ្លួនឯង និងកូន និងមិនទទួលបានការគាំទ្រពីគ្រួសាររបស់គាត់។
- **កង្វះទំនុកចិត្តលើស្ថាប័ន**៖ ស្ត្រីមិនរំពឹងថានឹងទទួលបានការឆ្លើយតបដោយប្រសិទ្ធភាពពីនគរបាល និងការភ័យខ្លាចថា គ្មាននរណាជឿ។
- **កង្វះការយល់ដឹងអំពីសេវាឯកទេស** ៖ ស្ត្រីមិនដឹងពីកន្លែងដែលអាចទទួលបានជំនួយ។
- **ការភ័យខ្លាចទណ្ឌកម្មពីជនបង្កដែលរងការចោទប្រកាន់** ៖ ស្ត្រីភ័យខ្លាចថា អំពើហិង្សាអាចរីករាលដាលកាន់តែធំ។

បរិយាកាសនៃទំនាក់ទំនងដំបូងជាមួយជនរងគ្រោះគឺសំខាន់ខ្លាំងណាស់។ សូមចាំថា ជនរងគ្រោះអាចនឹងភ័យខ្លាចមិនហ៊ានមកជួបនគរបាល ហើយក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល នេះប្រហែលមិនមែនជាលើកដំបូងទេដែលគាត់ប្រឈមនឹងអំពើហិង្សាដែលប្រព្រឹត្តដោយជនបង្ក។ ដូច្នេះ អាទិភាពចម្បងរបស់អ្នកគឺត្រូវធ្វើឱ្យជនរងគ្រោះមានអារម្មណ៍ធូរស្រាល និងយល់ថាគាត់អាចនិយាយដោយបើកចំហក្នុងភាពឯកជន ហើយព័ត៌មានដែលគាត់ផ្តល់ឱ្យនឹងត្រូវរក្សាជាការសម្ងាត់។ អ្នកត្រូវធានាថាបុគ្គលិករបស់អ្នកយល់ពីសារៈសំខាន់នៃចំណុចនេះ ហើយពួកគេត្រូវកំណត់រកតម្រូវការជាក់លាក់របស់ជនរងគ្រោះ និងផ្តល់ការសម្របសម្រួលទៅតាមភាពចាំបាច់។

**នគរបាលត្រូវបានបញ្ជូនឱ្យទៅជួយ មិនមែនវិនិច្ឆ័យនោះទេ។**

ឧ. ចាស់ជរាអាចស្តាប់មិនសូវបាន ឬអន់ភ្នែក។ ក្នុងកាលៈទេសៈទាំងនេះ ការរកកន្លែងនិយាយដែលគ្មានសំឡេងរំខាន មានភ្លើងបំភ្លឺគ្រប់គ្រាន់ ឬមានធម្មជាតិល្អគឺជួយបានច្រើន។ ប្រសិនបើជនរងគ្រោះមានពិការភាពផ្នែកការស្តាប់ និង/ការនិយាយ នគរបាលត្រូវកំណត់ថាតើគាត់ចេះភាសាសញ្ញា ឬទេ និងផ្តល់អ្នកបកប្រែដើម្បីបន្តទំនាក់ទំនង។

ការល្អគឺត្រូវនិយាយជាមួយជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឆ្ងាយពីប៉ុស្តិ៍នគរបាល ប្រសិនបើអ្នកមានចន្លោះដែលគិតគូរពីជនរងគ្រោះដែលពួកគេអាចមានអារម្មណ៍ធូរស្រាល និងផ្តល់ភាពឯកជន និងការរក្សាការសម្ងាត់ដល់ពួកគេ។អាស្រ័យលើសាវតាររបស់ជនរងគ្រោះ ជាពិសេសប្រសិនបើជនរងគ្រោះមានសញ្ជាតិផ្សេង (ឧ. ជនភៀសខ្លួន ឬជនចំណាកស្រុក) ពួកគេអាចទាក់ទងទៅស្ថាប័ននគរបាល និងបុគ្គលិកសន្តិសុខស្លៀកឯកសណ្ឋានផ្សេងទៀតលើបញ្ហាអំពើហិង្សា។ ដូច្នេះ មន្ត្រីរបស់អ្នកត្រូវព្យាយាមយល់ពីកាលៈទេសៈរបស់ជនរងគ្រោះ។

112. ការអង្កេតដែលដឹកនាំដោយ OSCE ស្តីពីអំពើហិង្សាលើស្ត្រី ៖ របាយការណ៍គោល អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (ទីក្រុងវីយែន ២០១៩)។

### ប្រអប់ ១

**តើនរណាជាជនភៀសខ្លួន? តើនរណាជាជនចំណាកស្រុក?**

| ជនភៀសខ្លួន | ជនចំណាកស្រុក |
| --- | --- |
| បុគ្គលមានសញ្ជាតិផ្សេងដែលត្រូវការការពារពីអន្តរជាតិ ដោយសារតែការគំរាមកំហែងធ្ងន់ធ្ងរលើអាយុជីវិតបូរណភាពរាងកាយឬសេរីភាពក្នុងប្រទេសកំណើតដោយសារការធ្វើទុក្ខបុកម្នេញ ជម្លោះប្រដាប់អាវុធ អំពើហិង្សា ឬចលាចលសាធារណៈធ្ងន់ធ្ងរដែលអាថ្វាធរ ក្នុងប្រទេសកំណើត មិនអាច ឬមិនការពារពួកគេ[113]។ | ជនចំណាកស្រុកអន្តរជាតិសំដៅលើ "បុគ្គលដែលស្ថិតនៅក្រៅរដ្ឋមួយដែលពួកគេជាពលរដ្ឋ ឬមានសញ្ជាតិ ឬក្នុងករណីបុគ្គលដែលគ្មានរដ្ឋ រដ្ឋកំណើត ឬកន្លែងធ្លាប់រស់នៅពីមុន"[114]។ គ្មាននិយមន័យជាសកល និងស្របច្បាប់សម្រាប់ពាក្យ "ជនចំណាកស្រុក" ឡើយ [115]។ |

**សម្រាប់ព័ត៌មានបន្ថែមស្តីពីការផ្តល់ "កន្លែងសុវត្ថិភាព" ក្នុងការនិយាយជាមួយជនរងគ្រោះសូមមើលជំពូកទី៧(ការគាំទ្រ និងជំនួយ)។**

ដើម្បីផ្តល់ "អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ"អ្នកនិងបុគ្គលិករបស់អ្នកត្រូវយល់ពីទស្សនៈរបស់ជនរងគ្រោះ និងត្រូវពិចារណាល្អិតល្អន់លើទស្សនៈទាំងនោះ។ មិនត្រូវបង្ហាញភាពលម្អៀងរបស់អ្នក និងបុគ្គលិករបស់អ្នក (មិនថាលេចឡើងដោយដឹងខ្លួន ឬដោយមិនដឹងខ្លួននោះទេ)ឱ្យជនរងគ្រោះបានឃើញនោះឡើយ។ ឧ. របៀបស្លៀកពាក់របស់ជនរងគ្រោះ ថាតើនាងសេពគ្រឿងស្រវឹង ឬគ្រឿងញៀន ឬទេ ថាតើនាងចេញក្រៅតែម្នាក់ឯង ឬទេ ទីកន្លែងដែលនាងស្ថិតនៅ ឬពេលវេលាដែលនាងនៅទីនោះ ថាតើនាងពាក់ព័ន្ធនឹងសេវាផ្លូវភេទ ឬទេមិនមានន័យថា នាងជាអ្នកទទួលខុសត្រូវលើអំពើហិង្សាដែលប្រព្រឹត្តចំពោះរូបនាងនោះទេ។ កត្តាទាំងអស់នេះមិនអាចជាលេសសម្រាប់ទង្វើរបស់ជនបង្កបានឡើយ។សូមចាំថាអ្នក និងបុគ្គលិករបស់អ្នកមកទីនោះដើម្បី "ជួយ មិនមែនវិនិច្ឆ័យ" នោះទេ។

ជារឿយៗ ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានគេស្តីបន្ទោសចំពោះការធ្វើឱ្យខ្លួនឯងងាយរងគ្រោះ ដោយសារការប្រព្រឹត្ត ឬកន្លែងដែលពួកគាត់ទៅ ប៉ុន្តែសូមស្នើឱ្យបុគ្គលិករបស់អ្នកពិចារណាចំណុចនេះ។ ប្រសិនបើ ម្ចាស់ផ្ទះរាយការណ៍ពីករណីគាស់ផ្ទះ តើវាជាកំហុសរបស់គាត់ដែលមិនបានចាក់សោរទ្វារ ឬបិទបង្អួចទាំងអស់ឬ? ទេ។ ត្រូវទទួលរបាយការណ៍របស់គាត់ និងស៊ើបអង្កេតបទល្មើសនោះ។ គួរប្រព្រឹត្តដូចគ្នាចំពោះជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

### ភាពលម្អៀងយេនឌ័រ និងរបាយការណ៍មិនពិត

ភាពលម្អៀងយេនឌ័រ[116] មិនថាមិនស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយមិនដឹងខ្លួន)ឬស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយដឹងខ្លួន) នោះទេ រងឥទ្ធិពល និងផ្អែកតាមផ្នត់គំនិតយេនឌ័រ និងឥរិយាបថដែលកំណត់ចរិតលក្ខណៈ តួនាទី និងអាកប្បកិរិយាផ្សេងៗលើបុរស ធៀបនឹងស្ត្រី និងរួមបញ្ចូលតួនាទី និងអាកប្បកិរិយាផ្លូវភេទ។ យេនឌ័រប្រទាក់ក្រឡានឹងកត្តាផ្សេងទៀតដែលនាំឱ្យមានជំនឿស្តីពីក្រុមបុរស និងក្រុមស្ត្រីណាមួយ ដូចជា ការជឿថា ក្រុមស្ត្រីមួយចំនួនងាយប្រឡូកក្នុង "ផ្លូវភេទ" ដែលបង្កផលប៉ះពាល់អវិជ្ជមានលើភាពអាចជឿទុកចិត្តបានរបស់ពួកគាត់។

113. គោលការណ៍ និងសេចក្តីណែនាំ គាំទ្រដោយការណែនាំជាក់ស្តែង ស្តីពីការការពារសិទ្ធិមនុស្សរបស់ជនចំណាកស្រុកក្នុងស្ថានភាពងាយរងគ្រោះ (OHCHRនិងGlobal Migration Group)។
114. សូមមើល OHCHR "គោលការណ៍ និងសេចក្តីណែនាំជាអនុសាសន៍" ជំពូក ១ កថាខណ្ឌ ១០។ UNHCR ញែកដាច់ពីគ្នារវាងជនភៀសខ្លួន និងជនចំណាកស្រុក ដើម្បីឱ្យយល់ច្បាស់ពីឫសគល់ និងលក្ខណៈនៃចលនាជនភៀសខ្លួន និងសិទ្ធិទទួលបានរបស់ជនភៀសខ្លួនក្រោមច្បាប់អន្តរជាតិ។
115. សម្រាបការពន្យល់ពាក្យ "ជនចំណាកស្រុកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ" សូមមើល សញ្ញាណទូទៅនៃគោលការណ៍ និងសេចក្តីណែនាំ (n.6)។

ភាគច្រើនគឺយើងប្រកាន់ឥរិយាបថ និងគុណតម្លៃដែលគាំទ្រសមភាពយេនឌ័រ ក៏ដូចជា លទ្ធភាពស្មើភាព មិនលម្អៀង និងយុត្តិធម៌ក្នុងការទទួលបានយុត្តិធម៌ ប៉ុន្តែភាពលម្អៀងយេនឌ័រដោយប្រយោលនៅតែជះឥទ្ធិពលលើឥរិយាបថ និងគុណតម្លៃទាំងនេះ។ នោះគឺដោយសារតែភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់លេចឡើងដោយមិនដឹងខ្លួន។ បន្ទាប់មក ទើបយើងធ្វើការវិនិច្ឆ័យដោយមិនដឹងខ្លួន។តាមពិតភាពលម្អៀងទាំងនេះអាច និងជាញឹកញាប់ ដើរ បញ្ច្រាសជំនឿ និងគុណតម្លៃក្នុងខ្លួនរបស់យើង។

ភាពលម្អៀងយេនឌ័រអាចពន្យល់មួយផ្នែកពីជំនឿទូទៅដែលថា ជាញឹកញាប រឿងរ៉ាវនៃការប្រទូស្តកេរខ្មាសគឺមិនពិត។ការជឿដូច្នេះអាចធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបរបស់អ្នកជំនាញ ទាំងក្នុង និងក្រៅប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ អ្នកជំនាញដែលផ្តល់ការឆ្លើយតបនឹងធ្វើការកំណត់ដោយមិនដឹងខ្លួនជុំវិញសច្ចភាពនៃរឿងរ៉ាវមួយ ប៉ុន្តែប្រសិនបើការវិនិច្ឆ័យទាំងនេះគឺខុសឆ្គង ពួកគេអាចមិនបានចាត់វិធានការសមស្រប ឬអាចសន្និដ្ឋានមិនត្រឹមត្រូវ។ ភាពលម្អៀងយេនឌ័រ និងការវិនិច្ឆ័យងាយនឹងបង្ខំឱ្យជនរងគ្រោះ បិទមាត់ បដិសេធមិនផ្តល់ព័ត៌មាន ឬប្រានចោលដំណើររឿងរបស់ខ្លួន។ តើមានអ្វីកើតឡើង ប្រសិនបើមន្ត្រីអនុវត្តន៍ច្បាប់មិនជឿថា ដំណើររឿងរបស់ជនរងគ្រោះ អាចជឿទុកចិត្តបាន?

តើមានអ្វីកើតឡើងប្រសិនបើមន្ត្រីអនុវត្តន៍ច្បាប់មិនជឿថា ជនរងគ្រោះ អាចជាធនធានសម្រាប់នគរបាលក្នុងការបើកការស៊ើបអង្កេតផ្អែកតាមភស្តុតាងយ៉ាងល្អិតល្អន់?

បុគ្គលិករបស់អ្នកត្រូវចាប់ផ្តើមពីការយល់ថា តាមពិតការចោទប្រកាន់ក្លែងក្លាយលើករណីរំលោភសេពសន្ថវៈគឺមិនសូវមាននោះទេ។ ការព្រួយបារម្ភដ៏ធំ គឺបទល្មើសរំលោភសេពសន្ថវៈ ការប្រទូសកេរខ្មាស និងការបៀតបៀនផ្លូវភេទកុមារនៅទូទាំងសកលលោក មិនសូវត្រូវបានរាយការណ៍ ហើយពួកគេមានឱកាសផ្លាស់ប្តូរការយល់ដូច្នេះតាមរយៈការគោរពនិងផ្តល់សេចក្តីថ្លៃថ្នូរដល់ជនរងគ្រោះ។

ពេលខ្លះការគាំទ្រដ៏អស្ចារ្យសម្រាប់ជនរងគ្រោះ គឺការបង្ហាញថា គេជឿគាត់ ហើយអ្នកអាណិតអាសូរចំពោះបទពិសោធន៍ដ៏អាក្រក់របស់គាត់។ ការកសាងទំនុកចិត្តភាពជឿជាក់និងទំនាក់ទំនងល្អជាមួយជនរងគ្រោះគឺជាគន្លឹះក្នុងការធ្វើឱ្យពួកគេយល់ថាខ្លួនឯងអាចរ៉ាយរ៉ាប់អស់សេចក្តី ប៉ុន្តែចំណុចនេះអាចចំណាយពេលបន្តិច រហូតដល់រាប់ម៉ោង។

**រូប ១ ៖ ការចោទប្រកាន់ក្លែងក្លាយ** (Rape Crisis Scotland)

https://www.rapecrisisscotland.org.uk/files/false-allegations-bp-170913-1-1.pdf




**ការពិត**

ការចោទប្រកាន់ក្លែងក្លាយកើតឡើងញឹកញាប់ក្នុងករណីរំលោភសេពសន្ថវៈជាងបទល្មើសផ្សេងទៀត។ ការយល់ថា ពួកគេជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។

អ្នកត្រូវផ្តល់ពេលឱ្យបុគ្គលិករបស់អ្នកកសាងទំនាក់ទំនងជាមួយជនរងគ្រោះ។ មិនត្រូវប្រញាប់ពេកនោះទេ។ ប្រហែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបានទទួលរងការប៉ះទង្គិចផ្លូវចិត្តមួយចំនួន ហើយអាស្រ័យលើភាពធ្ងន់ធ្ងរនៃប្រតិកម្មរបស់ពួកគេវានឹងកំណត់រយៈពេលចាំបាច់ជាមួយជនរងគ្រោះ ដើម្បីផ្តល់ការធានាអះអាងឡើងវិញ និងលើកទឹកចិត្តឱ្យពួកគេពិពណ៌នាលម្អិតពីអ្វីដែលបានកើតឡើងចំពោះពួកគេ។

សម្រាប់ព័ត៌មានលម្អិតស្តីពីការនិយាយជាមួយជនរងគ្រោះនិងសាក្សី សូមមើលជំពូកទី ៩ (ទំនាក់ទំនង)។

អ្នកប្រហែលជាមិនអាចជួបជាមួយនគរបាលដែលទទួលបានការបណ្តុះបណ្តាលពិសេស និង/ឬនគរបាលជាស្ត្រីឡើយ។ដូច្នេះអ្នកត្រូវធានាថាបុគ្គលិករបស់អ្នកទាំងអស់យល់ពីស្តង់ដារអប្បបរមាខាងក្រោម ៖

- បរិយាកាស ៖ រក្សាឯកជនភាព។ ធានាថា ជនរងគ្រោះមានសុវត្ថិភាព សន្តិសុខ និងគ្មានការរំខាន។ យកល្អគឺស្ថិតក្នុងបន្ទប់ឬអគារដែលគិតគូរពីជនរងគ្រោះ និងកន្លែងដែលជនរងគ្រោះ មិនជួបជាមួយជនបង្ក

ដែលរងការចោទប្រកាន់។ ត្រូវផ្ដល់ការយកចិត្តទុកដាក់ និងការគោរពដល់ជនរងគ្រោះ។

**ប្រអប់ ២**

យុទ្ធនាការ "ចាប់ផ្ដើមពីការជឿជាក់" ៖ ការបង្កើនការឆ្លើយតប ការបង្ហាញម្ដងមួយរឿង *

យុទ្ធនាការ"ចាប់ផ្ដើមពីការជឿជាក់"ជាយុទ្ធនាការកសាងការយល់ដឹងដែលផ្ដោតសំខាន់លើការឆ្លើយតបរបស់សាធារណជនទៅនឹងការប្រទូស្ដកេរខ្មាសព្រោះបុគ្គលទីមួយដែលជនរងគ្រោះ ទុកចិត្តគឺមិត្តភក្តិ ឬសមាជិកគ្រួសារ។ ប្រតិកម្មរបស់ពួកគេកំណត់ភាគច្រើននូវអ្វីដែលកើតឡើងបន្ទាប់។ ប្រតិកម្មវិជ្ជមានអាចបង្កើនសុខុមាលភាពរបស់ជនរងគ្រោះ និងបង្កើនលទ្ធភាពដែលពួកគេនឹងរាយការណ៍ទៅមន្ត្រីអនុវត្តន៍ច្បាប់ និងស្វែងរកជំនួយពីប្រភពផ្សេងទៀត។ យុទ្ធនាការនេះ ក៏មានគោលបំណងបង្កើនការឆ្លើយតបប្រកបដោយវិជ្ជាជីវៈផង ដែរ។

ពលបាលត្រី Archambault លើកឡើងថា "បំណងប្រាថ្នាដំបូងនៃយុទ្ធនាការនេះគឺជាថ្មីម្ដងទៀត ខ្ញុំបានមើលឃើញការចាត់ទុកជនរងគ្រោះដោយសារការប្រទូស្ដកេរខ្មាសប្រៀបដូចជាពួកគេត្រូវបញ្ជាក់ថា ពួកគេជាជនរងគ្រោះស្របច្បាប់ មុននឹងទទួលបានការពិចារណាជិតដល់លើករណីរបស់ពួកគេ ៖ "អ្នកនិយាយថាអ្នកត្រូវបានគេរំលោភសេពសន្ថវៈ? សូមបញ្ជាក់ឱ្យបានច្បាស់!"

- **ចំនួនបុគ្គលិក៖** ការមានតែមន្ត្រីម្នាក់នៅពេលនិយាយជាមួយជនរងគ្រោះ គឺល្អបំផុត លុះត្រាតែមន្ត្រីស៊ើបអង្កេតមានយេនឌ័រខុសពីជនរងគ្រោះ ជាករណីដែលអាចត្រូវមានអ្នកអមដំណើរ។
- **ការរ៉ាយរ៉ាប់ដោយសេរី** ៖ អនុញ្ញាតឱ្យជនរងគ្រោះរំលឹកពីឧប្បត្តិហេតុដោយមិនកាត់សម្ដី។
- **ការស្ដាប់យ៉ាងយកចិត្តទុកដាក់** ៖ ប្រើទំនាក់ទំនងមិនមែនពាក្យសម្ដី (NVC) ឬភាសាកាយវិការបែបវិជ្ជមាន (ឧ. ក្រសែភ្នែក ឥរិយាបថ ទឹកមុខ ដូចជា ញញឹមញញែម ងក់ក្បាលដើម្បីបង្ហាញសមានចិត្ត)។
- **បញ្ចៀសភាសាកាយវិការអវិជ្ជមាន** ៖ ដូចជា មិនសូវសំឡឹងចំក្រសែភ្នែក អោបដៃ ងាកចេញ ឬសំឡឹងហួស/រំលងជនរងគ្រោះ គ្រវីក្បាល ទឹកមុខមិនល្អ (ឧ. ជ្រួញចិញ្ចើម)។
- **ការប្រើភាសា** ៖ ភាសាវិជ្ជមានពិពណ៌នាពីលទ្ធភាពជម្រើស ការជ្រើសរើស។ ភាសាអវិជ្ជមានពិពណ៌នាពីអ្វីដែលមិនអាចសម្រេចបាន។
- **កែសម្រួលរបៀបធ្វើទំនាក់ទំនង** ទៅតាមវ័យ និង/ឬសមត្ថភាពរបស់ជនរងគ្រោះ។ កុមារ ជាពិសេស ប្រសិនបើពួកគេនៅក្មេងមិនគួរចាត់ទុកជា "មនុស្សពេញវ័យមានមាឌតូច" ទេ។ ដូច្នេះ សូមនិយាយ និងប្រព្រឹត្តតាមរបៀបដែលពួកគេអាចយល់បាន។
- **វាយតម្លៃហានិភ័យ** ៖ ផ្ដោតសំខាន់លើជនរងគ្រោះ និងសមាជិកគ្រួសារងាយរងគ្រោះ ដូចជា កុមារ និងពិចារណាអ្វីដែលត្រូវដាក់បញ្ចូលក្នុងផែនការសុវត្ថិភាព។
- **កុំធ្វើការផ្សះផ្សាណាមួយ**[117] ព្រោះនេះមិនមែនជាតួនាទីរបស់នគរបាល។ ការទទួលខុសត្រូវរបស់នគរបាលគឺត្រូវប្រមែប្រមូលភស្តុតាងទាំងអស់តាមរយៈការស៊ើបអង្កេតល្អិតល្អន់ និងបង្ហាញអង្គហេតុសម្រាប់ការពិចារណាផ្ដន្ទាទោស។
- **ធានាសុវត្ថិភាព និងរក្សា**ទុកអ្វីដែលអាចជាភស្តុតាងឱ្យបានឆាប់បំផុត។ ចំណុចនេះរួមមានរបៀបនៃការទទួលបានភស្តុតាង ដូចជា ការកត់ត្រាចម្លើយរបស់ជនរងគ្រោះតាមរបៀបដែលបង្កើនឱកាសនៃការផ្ដន្ទាទោសដោយជោគជ័យដោយគ្មានសក្ខីកម្មរបស់ជនរងគ្រោះ។ ជាញឹកញាប់ ការថតវីដេអូការសួរចម្លើយទៅតាមលទ្ធភាពដែលមានអាចជាចំណុចសមស្រប ប៉ុន្តែមិនសុទ្ធតែអាចធ្វើទៅបាននោះទេ។

117. សេចក្ដីសន្និដ្ឋានដែលបានព្រមព្រៀងចំនួន ៥៧ ចំណុច (CSW ២០១៣) អំពាវនាវឱ្យរដ្ឋទាំងឡាយចាត់វិធានការផ្លូវច្បាប់និង/ឬវិធានការចាំបាច់ផ្សេងទៀតក្នុងការហាមឃាត់ដំណើរការដោះស្រាយវិវាទជាកាតព្វកិច្ច និងដោយបង្ខំ រួមទាំងការផ្សះផ្សារ និងការសម្រុះសម្រួលដោយបង្ខំ សម្រាប់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី (E/2013/27 – E/CN.6/2013/11, para (g)។

ខ្ញុំមិនធ្លាប់បានលឺមន្ត្រីណាម្នាក់ទាមទារឱ្យជនរងគ្រោះនៃករណីគាស់ផ្ទះ បញ្ជាក់ថា ពួកគេមានទូរទស្សន៍ មុនពេលធ្វើរបាយការណ៍បទល្មើសនោះទេ។ ប៉ុន្តែនេះជាអ្វីដែលយើងធ្វើជារៀងរាល់ថ្ងៃចំពោះជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស នៅទូទាំងប្រទេសនេះ និងជុំវិញពិភពលោក”។

ខណៈដែលសហគមន៍នីមួយៗមានលក្ខណៈខុសៗគ្នា សារនេះគឺដូចគ្នា៖ ”នៅពេលនរណាម្នាក់ប្រាប់ខ្ញុំថា ពួកគេត្រូវបានគេរំលោភសេពសន្ថវៈ ឬប្រទូស្តកេរខ្មាស ខ្ញុំចាប់ផ្តើមពីការជឿជាក់”។

យុទ្ធនាការនេះជាគោលជំហរបែបទស្សនវិជ្ជាដែលគួរជាត្រីវិស័យសម្រាប់ការឆ្លើយតបរបស់យើងទៅនឹងការប្រទូស្តកេរខ្មាស។ វា "ប្រែត្រឡប់ខ្លឹមសារ” ស្តីពីសារដែលជនរងគ្រោះធ្លាប់តែទទួលបានពីអ្នកជំនាញ និងគាំទ្រមនុស្ស ដែលលើកឡើងថា "តើខ្ញុំធ្វើម៉េចដឹងថា អ្នកមិននិយាយកុហក?”

ការអនុវត្តអភិក្រមយុទ្ធនាការនេះនឹងបង្កផលវិបាកយ៉ាងជ្រាលជ្រៅ សម្រាប់ទិដ្ឋភាពនីមួយៗនៃការឆ្លើយតបរបស់ស្ថាប័ន និងសហគមន៍។ ទស្សនៈវិជ្ជានេះគួរត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយ ការអនុវត្តប្រចាំថ្ងៃ និងពិធីសារពហុវិស័យ។ ទស្សនវិជ្ជានេះគួរជះឥទ្ធិពលលើភាសាដែលយើងប្រើប្រាស់ និងរបៀបបំពេញការងាររបស់យើង។ នេះជាយុទ្ធសាស្រ្តមួយប្រភេទដែលត្រូវការចាំបាច់ដើម្បីកាត់បន្ថយភាពលម្អៀងយេនឌ័រក្នុងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។ ជាថ្មីម្តងទៀត Joanne Archambault លើកឡើងដោយសង្ខេបថា ៖

> ជនរងគ្រោះដឹងថាពេលណាមានគេស្តាប់ និងពិចារណាពីរឿងរ៉ាវរបស់ខ្លួន ប៉ុន្តែវាមិនមែនដោយសារតែយើងមិនសូវនិយាយស្តីនោះទេ។ ពួកគេដឹងថា វាបណ្តាលមកពីសកម្មភាពរបស់យើង។ យុទ្ធនាការនេះផ្តោតលើការស្តាប់ជនរងគ្រោះ ជនសង្ស័យ និងសាក្សីយ៉ាងយកចិត្តទុកដាក់ និងការស៊ើបអង្កេតហ្មត់ចត់។ ដូច្នេះ ការសម្រេចត្រូវផ្អែកលើព័ត៌មាន និង ភស្តុតាងទាំងអស់។

*យុទ្ធនាការ "ចាប់ផ្តើមពីការជឿជាក់ (SBB) គឺជាទស្សនៈវិជ្ជាដែលបង្កើតឡើងនៅសហរដ្ឋអាមេរិក ដោយពលបាលត្រី Joanne Archambault នៃអង្គការអន្តរជាតិបញ្ឈប់អំពើហិង្សាលើស្ត្រីស្ត្រី (EVAWI) និងត្រូវបានអនុវត្តនៅឆ្នាំ ២០១១។ សូមមើលផងដែរ Tanner, H., `Start by Believing to Improve Responses to Sexual Assault and Prevent Gender Bias´ (2017)។

**យើងដឹងថា ជាញឹកញាប់ ជនរងគ្រោះស្តីបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។ការដែលមន្ត្រីម្នាក់និយាយថា “នេះមិនមែនជាកំហុសរបស់អ្នកទេ” ឬអ្វីដែលស្រដៀងគ្នាគឺជាវិធីដ៏ល្អក្នុងការជំរុញការចូលរួមរបស់ជនរងគ្រោះ ដែលបង្ហាញថា អ្នកយកចិត្តទុកដាក់ចំពោះពួកគេ។**

សូមចាំថា ដោយសារការប៉ះទង្គិចផ្លូវចិត្ត ជនរងគ្រោះអាចមិនប្រព្រឹត្តទៅតាមការរំពឹងទុក។ ឧ. គាត់អាចមិនបង្ហាញអារម្មណ៍ក្រៀមក្រំ ឬប្រាប់រឿងរ៉ាវតាមលំដាប់លំដោយ ស៊ីសង្វាក់គ្នា ឬខ្លី និងច្បាស់លាស់ ហើយបុគ្គលិករបស់អ្នកត្រូវយល់ថា ចំណុចនេះមិនមែនមានន័យថាគាត់មិនប្រាប់ការពិតនោះទេ។ ការឆ្លើយតបរបស់ជនរងគ្រោះក្នុងស្ថានភាពមួយចំនួនអាចមិនសមស្របនឹងគំនិតដែលសន្មតទុកអំពីអាកប្បកិរិយាសមស្រប។ឱកាសបង្កើតទំនុកចិត្ត និងភាពជឿជាក់ខ្លាំងបំផុតគឺនៅពេលអ្នកនិយាយជាមួយជនរងគ្រោះជាលើកដំបូង...។

ប្រសិនបើជនរងគ្រោះមិនទទួលបានការយកចិត្តទុកដាក់នៅដំណាក់កាលដំបូងនៃដំណើរការយុត្តិធម៌នោះគ្រួសារមិត្តភក្តិនិងសហគមន៍របស់គាត់ក៏នឹងមិនទទួលបានការយកចិត្តទុកដាក់ដែរ ហើយអ្នក និងបុគ្គលិករបស់អ្នកនឹងមានការលំបាកកាន់តែខ្លាំងក្នុងការបំពេញតួនាទី។

អ្នកទទួលខុសត្រូវលើការធានាថាបុគ្គលិករបស់អ្នកបង្ហាញសមានចិត្ត និងការយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដោយបញ្ជាក់ឡើងវិញថាអ្នកជឿនាងប៉ុន្តែមិនត្រូវអនុញ្ញាតឱ្យបុគ្គលិករបស់អ្នកសន្យាចោល ដូចជា ការនិយាយប្រាប់ជនរងគ្រោះថា ជនបង្កដែលរងការចោទប្រកាន់នឹងត្រូវបានបញ្ជូនទៅពន្ធនាគារ។ នោះមិនមែនជាការសន្យាដែលនគរបាលគួរធ្វើឡើងទេព្រោះតុលាការទើបជាអ្នកសម្រេចដាក់ទោស ប៉ុន្តែនគរបាលអាចសន្យាខិតខំធ្វើអ្វីគ្រប់បែបយ៉ាងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាការដាក់បញ្ជូនសំណុំរឿងដែលមានភស្តុតាងគ្រប់គ្រាន់ទៅអយ្យការ និង/ឬតុលាការ និងសន្យាថា ជនរងគ្រោះនឹងទទួលបានការគាំទ្រពីនគរបាលក្នុងដំណើរការនេះ។

ជារឿយៗផលប៉ះពាល់ជារួមនៃការប៉ះទង្គិចផ្លូវចិត្តមិនថាបណ្តាលមកពីព្រឹត្តិការណ៍មួយ ឬច្រើននោះទេ ធ្វើឱ្យជនរងគ្រោះ មិនអាចដោះស្រាយបាន។ មនុស្សមានប្រតិកម្មខុសៗគ្នាទៅនឹងការប៉ះទង្គិចផ្លូវចិត្តហើយអ្វីដែលអាចធ្វើឱ្យប៉ះពាល់ផ្លូវចិត្តរបស់មនុស្សម្នាក់អាចមិនធ្វើឱ្យប៉ះពាល់ផ្លូវចិត្តរបស់អ្នកផ្សេងទៀត។ នេះជាមូលហេតុដែលមន្ត្រីរបស់អ្នកមិនត្រូវវិនិច្ឆ័យជាមុនលើជនរងគ្រោះដោយផ្អែកលើជំនឿជាក់ និងបទពិសោធន៍ផ្ទាល់ខ្លួន ឬរបៀបដែលពួកគេសន្មតជាការឆ្លើយតបរបស់ជនរងគ្រោះ។ ជនរងគ្រោះម្នាក់ៗអាចមានការឆ្លើយតបដំបូងខុសៗគ្នាទៅនឹងការប៉ះទង្គិចផ្លូវចិត្ត។ ការឆ្លើយតប ដ៏គួរឱ្យកត់សម្គាល់ទាំងបី (ប្រយុទ្ធ គេចខ្លួន ឬនៅមួយកន្លែង) សុទ្ធតែជាការឆ្លើយតបដោយ "ស្វ័យប្រវត្តិ" ហើយជនរងគ្រោះនឹងមិនអាចគ្រប់គ្រងការឆ្លើយតបរបស់រាងកាយទៅនឹងព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តបានឡើយ។ នេះជាមូលហេតុដែលនៅពេលជនរងគ្រោះរាយការណ៍បទល្មើសមួយគាត់អាចមិនប្រព្រឹត្តដូចការរំពឹងទុកដោយមន្ត្រីរបស់អ្នក។ ដូច្នេះ មន្ត្រីរបស់អ្នកត្រូវយល់ថា ចំណុចនេះមិនមានន័យថាជនរងគ្រោះកំពុងនិយាយកុហកអំពីអ្វីដែលបានកើតឡើងឬផលប៉ះពាល់នៃបញ្ហានេះលើរូបគាត់ឡើយ។

ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តអាចធ្វើឱ្យជនរងគ្រោះមិនចាំអ្វីទាំងអស់ ឬមិនរៀបរាប់តាមលំដាប់លំដោយ។ នេះជាមូលហេតុមួយទៀតដែលមន្ត្រីរបស់អ្នកត្រូវចំណាយពេលកសាងទំនាក់ទំនងល្អជាមួយជនរងគ្រោះ ដើម្បីឱ្យគាត់អាចរៀបរាប់លម្អិតពីអ្វីដែលបានកើតឡើង ហើយមន្ត្រីរបស់អ្នកអាចកត់ត្រាអំណះអំណាងផ្លូវការ។

បុគ្គលិករបស់អ្នកត្រូវមានភាពអត់ធ្មត់ជាមួយជនរងគ្រោះ ហើយអ្នកត្រូវមានភាពអំណត់ជាមួយបុគ្គលិក នៅពេលពួកគេប្រឈមជាមួយជនរងគ្រោះ។ ការចំណាយពេលបញ្ជាក់ឡើងវិញជាមួយជនរងគ្រោះក្នុងដំណាក់កាលដំបូងៗទាំងនេះ នឹងបង្កើនលទ្ធភាពនៃការទទួលបានភស្តុតាងគ្រប់គ្រាន់ដើម្បីនាំយកជនបង្កដែលរងការចោទប្រកាន់ទៅកាត់ទោស។

**ប្រអប់ ៣**

**សញ្ញា និងរោគសញ្ញានៃការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ**[118]

| | |
|---|---|
| • ការប្រយ័ត្នប្រយែងហួសហេតុ<br>• ការមិនទុកចិត្តនរណា<br>• បែកអារម្មណ៍<br>• ឈឺចាប់/ឈឺក្បាលរ៉ាំរ៉ៃ<br>• បំពានគ្រឿងញៀន<br>• បញ្ហាពាក់ព័ន្ធនឹងការញ៉ាំអាហារ<br>• មានអារម្មណ៍ថាមិនពិត ឬក្រៅខ្លួន<br>• ឥរិយាបថបំផ្លាញខ្លួនឯង<br>• ការបាត់បង់ "អត្តសញ្ញាណ"<br>• ការបាត់បង់គំនិតអនាគត ៖ អស់សង្ឃឹម | • ថប់បារម្ភ/បារម្ភ<br>• ស្លឹកស្រពន់<br>• គ្មានចំណាប់អារម្មណ៍<br>• ការផ្តាច់ខ្លួនពីអ្នកដទៃ<br>• ធ្លាក់ទឹកចិត្ត<br>• គ្មានការចងចាំ ឬមិនសូវចងចាំ<br>• អារម្មណ៍តានតឹងលើសលប់<br>• សុបិន្តអាក្រក់ និងការនឹកឃើញរឿងអតីតកាល<br>• អាម៉ាស់ និងគ្មានតម្លៃ |

118. សៀវភៅណែនាំការបណ្តុះបណ្តាលស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់មន្ត្រីតុលាការនៅអ៊ិយហ្គង់ដា (UN Women មិនចេញផ្សាយ ២០១៩)។

**ប្រអប់ ៤**

**ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើជនរងគ្រោះ**

ឥរិយាបថទូទៅក្រោយការប៉ះទង្គិចផ្លូវចិត្តដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលនាំទៅរកការដកពាក្យបណ្ដឹង ឬការបដិសេធមិនសហការជាមួយដំណើរការយុត្តិធម៌ ៖

កង្វះភាពច្បាស់លាស់/លំដាប់លំដោយក្នុងបណ្ដឹងដំបូងរបស់ជនរងគ្រោះ → នគរបាលមិនសូវជឿជាក់លើជនរងគ្រោះ → ការរងគ្រោះដោយសារប្រព័ន្ធនេះ → ជនរងគ្រោះចាប់ផ្ដើមដកខ្លួនចេញពីកិច្ចសហការ → នគរបាលបញ្ឈប់ការស៊ើបអង្កេត ឬជនរងគ្រោះបដិសេធមិនផ្ដល់សក្ខីកម្មឬគាំទ្របណ្ដឹងពីដំបូង

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្ដើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

នៅទំនាក់ទំនងដំបូង ជាញឹកញាប់ ជនរងគ្រោះត្រូវបាននគរបាលធ្វើឱ្យយល់ខុសថាពួកគេទទួលខុសត្រូវលើការចោទប្រកាន់ ដាក់បណ្ដឹងផ្លូវការ ឬស្នើសុំការផ្ដន្ទាទោសក្នុងផ្លូវច្បាប់ ឬការអនុវត្តជាក់ស្ដែង។ ភាគច្រើនគឺចំណុចនេះបណ្ដាលមកពីការយល់ខុសចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី (សូមមើលប្រអប់ ៦ ស្ដីពី "ការយល់ខុសជុំវិញអំពើហិង្សាលើស្ត្រី និងក្មេងស្រី) ដែលប្រសិនបើបណ្ដោតបណ្ដោយដោយគ្មានការត្រួតពិនិត្យអាចជះផលប៉ះពាល់ខ្លាំងលើការស៊ើបអង្កេត និងការរាយការណ៍នាពេលអនាគតដោយស្ត្រី និងក្មេងស្រី។

ខាងក្រោមនេះជាចំណុចសំខាន់ៗមួយចំនួន ដែលដកស្រង់ចេញពីការគូសផែនទីជាសកលស្ដីពីការអនុវត្តល្អ និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[119]។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ និងបុគ្គលិករបស់អង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ចំណុចខ្វះខាតសមត្ថភាពដែលមានរៀបរាប់ខាងក្រោម បង្កផលប៉ះពាល់ខ្លាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលនៅគ្រប់ដំណាក់កាលនៃដំណើរការស៊ើបអង្កេត ប៉ុន្តែក្នុងករណីនេះ ចំណុចខ្វះខាតទាំងនេះកាត់បន្ថយប្រសិទ្ធភាពរបស់នគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលជាផ្នែកមួយនៃទំនាក់ទំនងដំបូងជាមួយជនរងគ្រោះ។

ចំណុចទាំងនេះមានគោលបំណងជួយដល់អ្នកគ្រប់គ្រងក្នុងជួរនគរបាល ក្នុងការកំណត់រកយ៉ាងឆាប់រហ័សនូវចំណុចខ្វះខាតសមត្ថភាពមុនការបង្កគ្រោះថ្នាក់ឬគ្រោះថ្នាក់បន្ថែមទៀតលើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណងជើងតាមផ្នែកនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណាចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាន និង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

### ភាពលម្អៀងយេនឌ័រ

- ជាញឹកញាប់ នគរបាលមិនយល់ថា ភាពលម្អៀងយេនឌ័រនិងផ្នត់គំនិតរបស់នគរបាលរួមចំណែកដល់ការមិនរាយការណ៍ពីករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីនិងការថយចុះនៃការរាយការណ៍ករណីឡើយ។

119. សូមមើលផងដែរ ម៉ូឌុលទី ៣ ៖ ការបញ្ឈប់អំពើហិង្សាលើស្ត្រី តារាង ៣.១ ស្ដីពីបញ្ហាប្រឈមសម្រាប់ស្ត្រីដែលជាជនរងគ្រោះនៃអំពើហិង្សា ក្នុងដំណើរការយុត្តិធម៌ ក្នុង "ឯកសារជំនួយស្មារតីអ្នកអនុវត្តន៍ស្ដីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌" (UN Women et al., 2018)។

## ការរងគ្រោះលើកទីពីរ

- ជាញឹកញាប់ នគរបាលធ្វើការទាមទារបែបបំពាន និងមិនសមស្របនូវទិន្នន័យផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ដោយមិនពិចារណាពីការប៉ះទង្គិចផ្លូវចិត្ត និងទុក្ខព្រួយបន្ថែមទៀតដែលកើតចេញពីចំណុចនេះ។

ប៉ុស្តិ៍នគរបាលក្នុងតំបន់មួយចំនួនគ្មានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដើម្បីធ្វើឱ្យស្ត្រីមានអារម្មណ៍កក់ក្តៅ តែបែរជាអាចដើរតួនាទីជាទីសំចតសម្រាប់បទល្មើសទៅវិញ។ ការបង្កភាពអាម៉ាស់និងការស្តីបន្ទោសជនរងគ្រោះក៏កើតឡើងនៅប៉ុស្តិ៍នគរបាលផងដែរជាពិសេសដោយសារការយល់ខុសជាបន្តចំពោះក្រុមមួយចំនួន។

## ការអនុវត្តខុសឆ្គង

- នគរបាលឆ្លើយតបដំបូង មិនបានពិចារណាថា ស្ត្រីអាចមិនសូវមានធនធានហិរញ្ញវត្ថុ ឬធនធានផ្សេងទៀតដើម្បីចូលរួមក្នុងប្រព័ន្ធនេះដោយប្រសិទ្ធភាព ដោយសារឥរិយាបថបង្ខិតបង្ខំនិងត្រួតត្រារបស់ជនបំពាន។
- នគរបាលឆ្លើយតបដំបូង មិនបានពិចារណាថាតើស្ត្រីដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន អាចប្រឈមនឹងហានិភ័យនៃអំពើហិង្សាផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃអំពើហិង្សាពីមន្ត្រីរដ្ឋដោយរបៀបណានោះទេ។
- ជាញឹកញាប់ គ្មានប្រព័ន្ធឬនីតិវិធីដើម្បីធានាការបន្តទំនាក់ទំនងដោយប្រសិទ្ធភាពជាមួយជនរងគ្រោះនោះទេ។
- ទិន្នន័យសម្រាប់ការគ្រប់គ្រងករណីហាក់មិនត្រូវបានបញ្ចូលឱ្យបានគ្រប់គ្រាន់មិនត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ និងជាធម្មតា មិនផ្តល់ភាពងាយស្រួលដល់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដែលទទួលខុសត្រូវលើការតាមដានបន្តជាមួយជនរងគ្រោះ ដោយសារច្បាប់ជាតិស្តីពីការការពារទិន្នន័យបុគ្គល។

## ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ

- នគរបាលឆ្លើយតបដំបូងអាចមិនបានដឹងថា ទម្រង់បែបបទនគរបាល ឬលិខិតទទួលស្គាល់ពាក្យបណ្តឹង គឺចាំបាច់សម្រាប់ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រដែលអាចប្រើប្រាស់ជាភស្តុតាងនៃបទល្មើសឡើយ។
- ការបណ្តុះបណ្តាលនិងពិធីសារពាក់ព័ន្ធមិនទាន់មានលក្ខណៈបរិយាបន្នគ្រប់គ្រាន់ដើម្បីគាំទ្រដល់មន្ត្រីឆ្លើយតបក្នុងករណីដែលជនរងគ្រោះឬជនបង្កមានពិការភាព។
- ជាទូទៅ មិនសូវមានចំណេះដឹងគ្រប់គ្រាន់ស្តីពីឫសគល់នៃអំពើហិង្សាក្នុងគ្រួសាររបៀបដែលអំពើហិង្សាក្នុងទំនាក់ទំនងកើតឡើងវិញដដែលៗ និងមូលហេតុដែលដៃគូមួយចំនួនមិនចាកចេញពីទំនាក់ទំនងបែបបំពាន។ ចំណេះដឹងនេះអាចគូសបញ្ជាក់ពីភាពចាំបាច់នៃការចាប់ខ្លួននិងភាពស្មុគស្មាញនៃមូលហេតុដែលការចាប់ខ្លួនអាចមិនមែនជាការឆ្លើយតបដែលមានប្រសិទ្ធភាពបំផុតរហូតនោះទេ។

### ប្រអប់ ៥

**ការយល់ខុសជុំវិញអំពើហិង្សាលើស្ត្រី និងក្មេងស្រី***

ការយល់ខុសទូទៅជុំវិញការរំលោភសេពសន្ថវៈ ៖

- ការរំលោភសេពសន្ថវៈពាក់ព័ន្ធនឹងជនមិនស្គាល់គ្នា ការប្រើកម្លាំង និងរបួសរាងកាយ។ ជាទូទៅ ការរំលោភសេពសន្ថវៈពាក់ព័ន្ធនឹងនរណាម្នាក់ដែលជនរងគ្រោះស្គាល់ និងមិនបន្សល់របួសស្នាម។
- ការរំលោភសេពសន្ថវៈជាបទល្មើសតណ្ហា ឬភាពងប់ងល់។ ការរំលោភសេពសន្ថវៈជាអំពើហិង្សា និងការឈ្លានពានដែលជនល្មើសប្រើប្រាស់សិចជាអាវុធ ដើម្បីមានអំណាច និងគ្រប់គ្រងលើជនរងគ្រោះ។

**ការយល់ខុសទូទៅជុំវិញអំពើហិង្សាក្នុងគ្រួសារ**

- ស្ត្រីមួយចំនួនជាអ្នកបំផុសឱ្យមានអំពើហិង្សាក្នុងគ្រួសារ ឬយល់ថា វាជាការបង្ហាញក្តីស្រឡាញ់ និងចូលចិត្តឱ្យគេបំពាន។ អ្នកស្រាវជ្រាវរកឃើញថា ស្ត្រីជាច្រើនដែលរងការបំពាន រស់នៅដោយស្ងៀមស្ងាត់ ប្រឈមនឹងការបំពានរាងកាយនិងបន្តទំនាក់ទំនងដោយសារមូលហេតុផ្សេងៗរួមទាំងមូលហេតុដែលពួកគេគ្មានកន្លែងត្រូវទៅ

រស់នៅដោយពឹងផ្អែកលើហិរញ្ញវត្ថុរបស់ដៃគូដែលប្រព្រឹត្តបំពានយល់ថាវាជាការល្អសម្រាប់កូននិងភ័យខ្លាចការមាក់ងាយក្នុងសង្គម។

- គ្រឿងស្រវឹង និងគ្រឿងញៀនជាឫសគល់ចម្បងដែលនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារ។ ទោះបីជាគ្រឿងស្រវឹងហាក់ពាក់ព័ន្ធក្នុងឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារប្រហែល ៥០% ក្តី ក៏ជាញឹកញាប់ ជនល្មើសបានប្រទូស្តរាយដៃគូរបស់ខ្លួននៅពេលមិនស្រវឹង។ ការសេពគ្រឿងស្រវឹងជាកត្តាហានិភ័យដែលរួមចំណែកដល់ការបំពានរបស់ប្តី/ប្រពន្ធ តាមរយៈការកាត់បន្ថយភាពស្វាងស្មារតី ប៉ុន្តែគ្រឿងស្រវឹង និងគ្រឿងញៀនមិនបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារឡើយ។
- ការរំលោភបំពានរាងកាយជាទម្រង់ធ្ងន់ធ្ងរបំផុតនៃអំពើហិង្សាក្នុងគ្រួសារៈ ការស្រាវជ្រាវគូសបញ្ជាក់ថាអំពើហិង្សាក្នុងគ្រួសារអាចមានលក្ខណៈផ្លូវកាយ ផ្លូវចិត្ត/ផ្លូវអារម្មណ៍ ផ្លូវសេដ្ឋកិច្ច និងផ្លូវភេទ។ ជនរងគ្រោះភាគច្រើនសារភាពថា ការរំលោភបំពានផ្លូវចិត្ត/ផ្លូវអារម្មណ៍ បង្កផលប៉ះពាល់ធ្ងន់ធ្ងរ និងជ្រាលជ្រៅលើពួកគេ ជាងការរំលោភបំពានផ្លូវកាយ។
- បុរសដែលរំលោភបំពានដៃគូរបស់ខ្លួន គឺជាទូទៅមានជំងឺផ្លូវចិត្ត។ ការសិក្សាគ្លីនិកស្តីពីបុរសដែលរំលោភបំពានដៃគូរបស់ខ្លួន មិនគាំទ្រការយល់ឃើញដូច្នេះឡើយ។ ភាគច្រើននៃជនរំលោភបំពានប្រពន្ធរបស់ខ្លួន មិនមានជំងឺផ្លូវចិត្តទេ។ ភាគច្រើនហាក់ជាបុរសធម្មតា។
- ជនបំពានភាគច្រើនជាបុរសមិនជោគជ័យដែលមានចរិតហិង្សាក្នុងទំនាក់ទំនងទាំងអស់របស់ខ្លួនជាមួយអ្នកដទៃ។ ការស្រាវជ្រាវគូសបញ្ជាក់ថា ដូចគ្នានឹងស្ត្រីដែលរងការរំលោភបំពានដែរ បុរសដែលប្រព្រឹត្តអំពើរំលោភបំពាន គឺជាមនុស្សដែលមកពីគ្រប់ស្រទាប់វណ្ណៈ។
- ការរំលោភបំពានគឺអាចទទួលយកបានក្នុងវប្បធម៌មួយចំនួន។ អំពើហិង្សាមិនមែនជាមធ្យោបាយដោះស្រាយជម្លោះដែលអាចទទួលយកបាននោះទេ។ ប្តី/ដៃគូគ្មានសិទ្ធិប្រទូស្តរាងកាយគ្នាទៅវិញទៅមកឡើយ ដោយមិនគិតពីការបង្ករឿង។
- ជម្លោះក្នុងគ្រួសារជាបញ្ហាឯកជន និងគួរដោះស្រាយដោយប្តីប្រពន្ធ ជាជាងពាក់ព័ន្ធនឹងនគរបាល អ្នកជំនាញសុខភាព ឬបុគ្គលិកសង្គមកិច្ច។ ជាញឹកញាប់ ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារទទួលរងអំពើហិង្សាផ្លូវកាយ ការរំលោភបំពានផ្លូវចិត្ត និងការប៉ះទង្គិចផ្លូវចិត្តកម្រិតខ្ពស់រយៈពេលជាច្រើនខែ ឬជាច្រើនឆ្នាំ មុននឹងស្វែងរកជំនួយ។ជនរងគ្រោះហាក់រាយការណ៍ពីការបំពានទៅនគរបាលអ្នកជំនាញសុខភាពឬបុគ្គលិកសង្គមកិច្ចបន្ទាប់ពីពួកគេបានព្យាយាមដោយអសារបង់ក្នុងការដោះស្រាយវិវាទជាលក្ខណៈឯកជន។
- ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ អាចចាកចេញពីទំនាក់ទំនងហិង្សា ប្រសិនបើពួកគេពិតជាចង់ធ្វើដូច្នេះមែន។ ដោយសារតែជំនឿក្នុងសាសនា និង/ឬជំនឿក្នុងវប្បធម៌ ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារអាចជឿថាការរំលោភបំពានជាផ្នែកមួយនៃជីវិតអាពាហ៍ពិពាហ៍។ប្រសិនបើជនរងគ្រោះបានធំធាត់ក្នុងបរិយាកាសដែលបណ្តែតបណ្តោយឱ្យមានអំពើហិង្សាក្នុងគ្រួសារ គាត់ងាយនឹងបន្តទំនាក់ទំនងបែបបំពាន។ ក្រៅពីនេះ ជាទូទៅ ស្ត្រីដែលរងការបំពានត្រូវបានរារាំងមិនឱ្យចាកចេញពីផ្ទះដោយសារកត្តាជាច្រើន ដូចជា ការភ័យខ្លាចការសងសឹក ការផ្តាច់ខ្លួនពីសង្គម ការពឹងផ្អែកផ្នែកហិរញ្ញវត្ថុ ការមាក់ងាយក្នុងសង្គម ការពឹងផ្អែកផ្លូវចិត្ត និងកង្វះតម្លៃផ្ទាល់ខ្លួន។
- ជាទូទៅ កុមារមិនរងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារឡើយ ហើយវាជាការល្អដែលមានឪពុកនៅផ្ទះ ទោះបីជាគាត់មានចរិតហិង្សាក៏ដោយ។កុមារដែលរស់នៅក្នុងគ្រួសារដែលមានការប្រព្រឹត្តបំពាន ច្រើនតែរងការរំលោភបំពាន ងាយមានរបួសក្នុងឧប្បត្តិហេតុហិង្សា និងងាយរងការប៉ះទង្គិចផ្លូវចិត្ត។ ការស្រាវជ្រាវបង្ហាញថាកុមារមកពីគ្រួសារហិង្សា ប្រឈមនឹងហានិភ័យខ្ពស់នៃការសេពគ្រឿងស្រវឹង និង/ឬគ្រឿងញៀន និងប្រព្រឹត្តបទល្មើសនៅវ័យអនីតិជន។ ក្រៅពីនេះ ពួកគេយល់ថា នៅពេលមនុស្សបំពានគ្នា ពួកគេមិនមានបញ្ហានោះទេ។

ប្រភព ៖ សៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី (UNODC, 2010) ទំ.១៨ និងសៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់អយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី (UNODC and UN Women, 2014) ទំ. ៣១។

## និយមន័យ និងក្របខណ្ឌ

នៅពេលគ្មាននិយមន័យជាសកលពាក់ព័ន្ធនឹងអ្វីដែលបង្កើតបានជាទំនាក់ទំនងដំបូងរវាងនគរបាល និងជនរងគ្រោះ ក្របខណ្ឌកញ្ចប់សេវាសំខាន់ៗផ្ដល់និយមន័យដូចខាងក្រោម ៖

ទំនាក់ទំនងដំបូងរួមបញ្ចូលការរាយការណ៍ទៅនគរបាល ការចងក្រងឯកសារ របាយការណ៍ ការចុះបញ្ជីករណីព្រហ្មទណ្ឌ សេវាប្រឹក្សារបស់មេធាវី ការចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណី ឬការអនុវត្តផ្នែករដ្ឋបាលដែលធ្វើឡើងដើម្បីបញ្ជាក់ពីគម្រោងផ្ដល់សំណង និងការដាក់ពាក្យសុំចែកផ្លូវគ្នា សិទ្ធិចិញ្ចឹមកូន និង/ឬវិធានការការពារបន្ទាន់ តាមរយៈតុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការគ្រួសារ ឬស្ថាប័ន/យន្តការរដ្ឋបាល[120]។

"មន្ត្រីឆ្លើយតប គួររក្សាសុវត្ថិភាពរបស់ជនរងគ្រោះ និងកូនៗរបស់ជនរងគ្រោះធ្វើឱ្យពួកគេមានទំនុកចិត្តលើការឆ្លើយតបរបស់នគរបាល វាយតម្លៃហានិភ័យនាពេលអនាគតដើម្បីឱ្យនគរបាលអាចរក្សាសុវត្ថិភាពរបស់ពួកគេបានយូរអង្វែង ស៊ើបអង្កេតឧប្បត្តិហេតុនេះ និងប្រមែប្រមូលភស្តុតាងសម្រាប់ការកាត់ទោស"។

កិច្ចការរបស់មនុស្សគ្រប់រូប ៖ ការបង្កើនការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ (HCIM, ២០១៤)

ការសំខាន់ត្រូវគូសបញ្ជាក់ថា នគរបាលមិនសុទ្ធតែជាអាជ្ញាធរផ្លូវការដំបូងដែលពាក់ព័ន្ធជាមួយជនរងគ្រោះនៅពេលជនរងគ្រោះស្វែងរកការការពារផ្នែកតុលាការពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនោះទេ។ ក្រៅពីនគរបាល ភ្នាក់ងារឆ្លើយតបដំបូងជាផ្លូវការ រួមមានក្រុមពន្លត់អគ្គីភ័យ យោធា អ្នកជំនាញក្នុងវិស័យសុខាភិបាល បុគ្គលិកមជ្ឈមណ្ឌលផ្ដល់សេវាចម្រុះ ការខ្សែទូរស័ព្ទជំនួយ និងអន្តរការីអ៊ីនធឺណិត។

ដោយមិនគិតថាតើនរណាជាភ្នាក់ងារឆ្លើយតបដំបូងអាទិភាពជារួមសម្រាប់នគរបាល គឺសុវត្ថិភាពរបស់ជនរងគ្រោះ។ ចំណុចនេះរួមមានការធានារក្សាការសម្ងាត់ និងការប៉ាន់ស្មាននិងដោះស្រាយផលវិបាកដោយអចេតនានៃវិធានការដែលធ្វើឡើង និង/ឬត្រូវធ្វើឡើង ដើម្បីទប់ស្កាត់គ្រោះថ្នាក់បន្ថែមទៀត។ ការខកខានមិនទប់ស្កាត់ ការពារ និងឆ្លើយតបសមស្របទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលនគរបាលបានដឹង ឬគួរតែបានដឹងអំពីសកម្មភាពរបស់ជនល្មើស ជាការទទួលខុសត្រូវរបស់រដ្ឋ[121]។

នគរបាលគួរដឹងច្បាស់ពីឱកាសរាយការណ៍ទាំងអស់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជានាការសម្របសម្រួលភ្នាក់ងារឆ្លើយតបដំបូង នៅពេលពួកគេមិនមែនជាមន្ត្រីនគរបាល ដើម្បីឱ្យមានការផ្ទេរព័ត៌មាន និងឯកសារភស្តុតាង ទៅតាមនីតិវិធីគ្រប់គ្រងភស្តុតាង។

នៅពេលជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី សម្រេចចិត្តប្រើប្រាស់ដំណើរការក្រៅផ្លូវការ ដូចជា ការផ្សះផ្សារ ឬប្រឈមនឹងដំណើរការក្រៅផ្លូវការ ការធានាសុវត្ថិភាពព័ត៌មាន និងឯកសារភស្តុតាងកាន់តែមានការលំបាក។ អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរធានាថា បុគ្គលិករបស់ខ្លួន និងដៃគូផ្ដល់សេវាសំខាន់ៗយល់ច្បាស់ពីហានិភ័យនិងបញ្ហាប្រឈមរបស់ជនរងគ្រោះនៅពេលការផ្សះផ្សារក្លាយជាបណ្ដាញសម្រាប់ការដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

អនុលោមតាមស្តង់ដារអន្តរជាតិពាក់ព័ន្ធ អង្គការសហប្រជាជាតិបានផ្ដល់ការណែនាំច្បាស់លាស់ស្ដីពីការបញ្ចៀសការផ្សះផ្សារក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី (សូមមើលប្រអប់ ៨)[122]។ កញ្ចប់សេវាសំខាន់ៗក្រើនរំលឹកថាការផ្សះផ្សារឬយុត្តិធម៌ស្តារឡើងវិញគួរអាចអនុញ្ញាត

120. ម៉ូឌុលទី ៣ ៖ យុត្តិធម៌ និងនគរបាល កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្ដីពីសមាសធាតុស្នូលនិងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្ដីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។

121. រដ្ឋមានកាតព្វកិច្ចសិទ្ធិមនុស្សក្នុងការធានាថា ទាំងភ្នាក់ងាររដ្ឋ និងភ្នាក់ងារមិនមែនរដ្ឋមិនត្រូវពាក់ព័ន្ធក្នុងអំពើរើសអើង ឬអំពើហិង្សាលើស្ត្រីឡើយ។ ក្នុងក្របខណ្ឌនេះ តួអង្គមិនមែនរដ្ឋរួមបញ្ចូលបុគ្គលឯកជន ដូចជា ក្រុមហ៊ុនឯកជន អនុលោមតាមមាត្រា ២ (ង) នៃអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ យោងតាមមាត្រា ៤ (គ) នៃសេចក្ដីប្រកាសស្ដីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី រដ្ឋគួរបំពេញការយកចិត្តទុកដាក់ខ្ពស់ក្នុងការទប់ស្កាត់ ស៊ើបអង្កេត និងដាក់ទណ្ឌកម្មការប្រព្រឹត្តអំពើហិង្សាលើស្ត្រី។

122. សូមមើល កញ្ចប់សេវាសំខាន់ៗ (ម៉ូឌុលទី ៣ សេវាសំខាន់ៗ ៤.៩) ការពង្រឹងការទប់ស្កាត់បទល្មើសនិងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី (UNODC, 2014) ទំ. ៧៧-៧៨។ ឯកសារជំនួយស្មារតីអ្នកអនុវត្តន៍ស្ដីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌ (UN Women et al., 2018) ps. 232-235។

ទៅបានតែក្នុងករណីដែលមាននីតិវិធីដើម្បីធានាថា គ្មានការបង្ខំសម្ពាធឬការបំភិតបំភ័យ និងកំណត់ពីលក្ខខណ្ឌតម្រូវអប្បបរមាមួយចំនួនដូចខាងក្រោម ៖

- ដំណើរការនេះត្រូវផ្ដល់វិធានការការពារដូចគ្នា ឬល្អជាងចំពោះសុវត្ថិភាពរបស់ជនរងគ្រោះដូចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ជនបង្កទទួលយកការទទួលខុសត្រូវ។
- អ្នកផ្ដល់សេវាយុត្តិធម៌ អនុម័ត។
- អ្នកផ្សះផ្សាទទួលការបណ្ដុះបណ្ដាល និងមានគុណវុឌ្ឍិ។
- ការវាយតម្លៃហានិភ័យដែលត្រូវបានផ្ដល់សុពលភាពកំណត់ថា ស្ត្រីមិនប្រឈមនឹងហានិភ័យខ្ពស់។
- ជនរងគ្រោះបានដឹងច្បាស់ពីដំណើរការនេះ និងយល់ព្រមទទួលយកការផ្សះផ្សា។
- ជនរងគ្រោះយល់ព្រមចូលរួម។

**ប្រអប់ ៦**

**គ្រោះថ្នាក់នៃការផ្សះផ្សាក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី**

ការផ្សះផ្សា (ពេលខ្លះ ហៅថា "ការសម្រុះសម្រួល") ត្រូវបានប្រើប្រាស់ទាំងក្នុងវិស័យយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ និងអាចបង្កបញ្ហា និងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាអន្តរបុគ្គលដោយសារមូលហេតុខាងក្រោម ៖

- ករណីអំពើហិង្សាលើស្ត្រីពាក់ព័ន្ធនឹងវិសមភាពនៃទំនាក់ទំនងអំណាចរវាងភាគីនានាដោយផ្អែកលើការប្រទូស្តរាយ ការបំភិតបំភ័យដោយហិង្សា និង/ឬឥរិយាបថត្រួតត្រា បំពាន ឬប្រមាថ។
- ការផ្សះផ្សាសន្មតថាភាគីចូលរួមក្នុងដំណើរការនេះដោយមានធនធាន និងអំណាចស្មើគ្នា ដែលជាញឹកញាប់គឺមិនដូច្នេះឡើយ។

ដោយសារការផ្សះផ្សាត្រូវបានប្រើប្រាស់ក្នុងប្រទេសជាច្រើន UNODC ស្នើឱ្យមានការផ្ដួចផ្ដើមកែទម្រង់ប្រព័ន្ធយុត្តិធម៌ដែលមានការផ្សះផ្សា អនុលោមតាមលក្ខណៈវិនិច្ឆ័យខាងក្រោម ៖

- អ្នកទាំងអស់ដែលពាក់ព័ន្ធក្នុងការសម្របសម្រួលការផ្សះផ្សា គួរទទួលបានការបណ្ដុះបណ្ដាលស្ដីពីឌីណាមិកនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាល។
- ការបណ្ដុះបណ្ដាលគួរផ្ដោតសំខាន់លើការវាយតម្លៃហានិភ័យ។
- ការបង្កើតនិងប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលត្រូវបានផ្ដល់សុពលភាពសម្រាប់ករណីរំលោភបំពានដោយប្ដី/ប្រពន្ធ។

ជារួម UNODC ស្នើឱ្យមានគោលការណ៍ណែនាំសមស្របសម្រាប់ការអនុវត្តការផ្សះផ្សានិងការអនុវត្តយុត្តិធម៌ស្ដារឡើងវិញផ្សេងទៀតក្នុងករណីអំពើហិង្សាលើស្ត្រី ដូចខាងក្រោម ៖

- ដំណើរការយុត្តិធម៌ស្ដារឡើងវិញត្រូវផ្ដល់វិធានការការពារដូចគ្នា ឬល្អជាង ចំពោះសុវត្ថិភាពរបស់ជនរងគ្រោះដូចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ការបញ្ជូនទៅដំណើរការយុត្តិធម៌ស្ដារឡើងវិញ ធ្វើឡើងបន្ទាប់ពីជនបង្កត្រូវបានចោទប្រកាន់បទល្មើស និងមានការអនុម័តពីអយ្យការ ឬចៅក្រមស៊ើបអង្កេត។
- ការកំណត់ដោយបុគ្គលិកដែលមានការបណ្ដុះបណ្ដាល ឬគុណវុឌ្ឍិថា ករណីនេះមិនមានហានិភ័យខ្ពស់។
- ជនរងគ្រោះបានដឹងច្បាស់ និងផ្ដល់ការយល់ព្រម។

ប្រភព ៖ "ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC, 2014) និង "ការសិក្សាមួយសម្រាប់ការបង្កើតយន្តការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាលើស្ត្រីនៅអេហ្ស៊ីប" (UNODC, 2015)

ជាធម្មតា មានពិធីសារជាតិ[123] ដែលលម្អិតពីនីតិវិធីទាំងនេះ និងភារកិច្ចពាក់ព័ន្ធរបស់មន្ត្រីឆ្លើយតបដំបូង ឬភ្នាក់ងារឆ្លើយតបដំបូងនៅកន្លែងកើតហេតុ ឬអ្នកមានតួនាទីដំបូងក្នុងការទទួលបានព័ត៌មានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ពីជនរងគ្រោះផ្ទាល់ ឬពីសាក្សី។

ពិធីសារថ្នាក់ជាតិសម្រាប់ភ្នាក់ងារឆ្លើយតបដំបូងគួរកំណត់ឱ្យនគរបាលផ្តោតសំខាន់លើការផ្តល់បរិយាកាសសុវត្ថិភាព និងស្ងៀមស្ងាត់ ដែលពួកគេស្តាប់ដោយផ្តល់ការគាំទ្រ បង្ហាញក្តីអាណិតអាសូរ និងមិនវិនិច្ឆ័យ ផ្តល់ការធានាឡើងវិញដោយមិនសន្យាចោល និងបង្កើនលទ្ធភាពការថែទាំវេជ្ជសាស្ត្រ និងការគាំទ្រផ្សេងទៀត។ សកម្មភាពទាំងនេះស៊ីសង្វាក់គ្នានឹង អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។

ក្នុងឯកសារណែនាំរបស់ខ្លួនដែលមានចំណងជើងថា "ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការណែនាំ និងការអនុវត្តពាក់ព័ន្ធនឹងការស៊ើបអង្កេតសិទ្ធិមនុស្ស" ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOHCHR) ដែលស៊ើបអង្កេតអំពើហិង្សាផ្អែកលើយេនឌ័រ ដូចជា អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលគោរពគោលការណ៍ "មិនបង្កគ្រោះថ្នាក់" តម្រូវឱ្យមានការវាយតម្លៃសមស្របលើឌីណាមិកយេនឌ័រ និងបទដ្ឋានវប្បធម៌ដែលអាចបណ្តាលឱ្យជនរងគ្រោះប្រឈមនឹងគ្រោះថ្នាក់បន្ថែមទៀតដូចជាការរងគ្រោះឡើងវិញការមាក់ងាយអំពើហិង្សានិងការជួបការលំបាកដោយសារជនបង្ក ឬគ្រួសារ និងសហគមន៍របស់ជនរងគ្រោះ[124]។




រូបថតទទួលបានពី UN/Martine Perret

123. ពិធីសារស្តីពីភ្នាក់ងារឆ្លើយតបដំបូងនឹងជួយដល់ការប្រមូល និងរក្សាទុកភស្តុតាងដោយអនុលោមតាមនីតិវិធីស៊ើបអង្កេតរបស់សេវានគរបាល ដែលគួររួមបញ្ចូលការកត់ត្រាលម្អិតពីសកម្មភាព និងការលើកឡើងរបស់ភាគីពាក់ព័ន្ធ និងរបាយការណ៍លម្អិតស្តីពីឧប្បត្តិហេតុ ដោយមិនគិតថាតើមានបទចោទ ឬមានការចោទប្រកាន់បទល្មើស ឬយ៉ាងណានោះទេ។ សូមមើល ៖ ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC, 2014)។

124. "ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការណែនាំ និងការអនុវត្តពាក់ព័ន្ធនឹងការស៊ើបអង្កេតសិទ្ធិមនុស្ស" (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ញូវយ៉ក និងហ្សឺណែវ ២០១៨) សូមមើល https://www.ohchr.org/sites/default/files/Documents/Issues/Women/Publications/GenderIntegrationintoHRInvestigations.pdf ។

ឯកសារណែនាំនេះស្នើឱ្យអ្នកសួរចម្លើយពិចារណាចំណុចខាងក្រោមមុននឹងរៀបចំការសួរចម្លើយជាមួយជនរងគ្រោះ ឬសាក្សីនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រជាពិសេសជាមួយជនរងគ្រោះដែលងាយរងគ្រោះ[125]៖

- ថាតើជនរងគ្រោះអាចប្រឈមនឹងការសងសឹកការមិនទទួលបានការយកចិត្តទុកដាក់ ការមាក់ងាយ និងអំពើហិង្សាដោយសារគ្រួសារ ឬសហគមន៍ ដែលបណ្តាលមកពីការទាក់ទង និង/ឬការផ្តល់ព័ត៌មានដល់ក្រុមស៊ើបអង្កេត។
- អង្គហេតុអ្វីខ្លះដែលសំខាន់សម្រាប់ករណីនេះ និងថាតើជនរងគ្រោះឬសាក្សីអាចផ្តល់ព័ត៌មានចាំបាច់បានដែរឬទេ។
- ថាតើជនរងគ្រោះ ឬសាក្សីបានផ្តល់សក្ខីកម្ម រួមទាំងសក្ខីកម្មដល់អាជ្ញាធរផ្សេងទៀតដើម្បីវាយតម្លៃថាតើចាំបាច់ត្រូវសុំឱ្យពួកគេរៀបរាប់ព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តឬទេ។
- ថាតើអ្នកស៊ើបអង្កេតដឹងពីរបៀបឆ្លើយតបសមស្របចំពោះជនរងគ្រោះ ឬសាក្សីប្រសិនបើគាត់មានទុក្ខព្រួយ ឬទេ។
- ថាតើអ្នកស៊ើបអង្កេតបានដឹងពីការបញ្ជូនទៅរកសេវាផ្តល់ប្រឹក្សា និងសេវាផ្សេងទៀត ឬទេ។

ទន្ទឹមនឹងនេះUNOHCHRគូសបញ្ជាក់ថាអ្នកស៊ើបអង្កេតគួរមានការប្រុងប្រយ័ត្នក្នុងការសន្មតអំពីតម្រូវការឬស្ថានភាពរបស់ជនរងគ្រោះ ដូចជា ការសន្មតថា ជនរងគ្រោះទាំងអស់ដោយសារអំពើហិង្សាផ្លូវភេទនឹងយល់ថា ដំណើរការរៀបរាប់ដំណើររឿងរបស់ខ្លួនធ្វើឱ្យប៉ះទង្គិចផ្លូវចិត្ត[126]។ ឯកសារណែនាំនេះលើកឡើងទៀតថានៅពេលសួរចម្លើយបានល្អិតល្អន់ ដំណើរការនេះអាចផ្តល់ការព្យាបាល និងការបង្កើនភាពអង់អាច[127]។

ក្រៅពីនេះ UNPOL បានផ្តល់ការណែនាំស្តីពីការសួរចម្លើយក្នុងឯកសារជំនួយស្មារតីយេនឌ័ររបស់ខ្លួនដោយមាននីតិវិធីប្រតិបត្តិស្តង់ដារគំរូ (SOP) ស្តីពីការស៊ើបអង្កេតរបស់នគរបាលលើបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសផ្លូវភេទ[128]។ នីតិវិធីនេះផ្តល់ទិសដៅគ្រប់ជ្រុងជ្រោយសម្រាប់ការស៊ើបអង្កេតបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសផ្លូវភេទ ចាប់ពីការរាយការណ៍ដំបូងរហូតដល់ការស៊ើបអង្កេតការត្រួតពិនិត្យនិងការបញ្ចប់ករណី។

## សមត្ថភាពគ្រប់គ្រងសំខាន់ៗសម្រាប់ទំនាក់ទំនងដំបូងដែលមានប្រសិទ្ធភាពនិងគ្រប់គ្រាន់ជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី

ការសំខាន់គឺមេបញ្ជាការ ឬអ្នកគ្រប់គ្រងក្នុងជួរនគរបាលត្រូវយល់ និងប្រាប់ក្រុមរបស់ខ្លួនថា ក្នុងទំនាក់ទំនងដំបូងជាមួយនគរបាល ជនរងគ្រោះទទួលបានបទពិសោធន៍ចម្រុះ។ អ្នកគ្រប់គ្រងក្នុងជួរនគរបាលត្រូវប្រុងប្រយ័ត្នចំពោះឥរិយាបថ សកម្មភាព និងអាកប្បកិរិយាអវិជ្ជមានរបស់បុគ្គលិក ព្រោះវាជះផលមិនល្អ។

នគរបាលប្រឈមនឹងបញ្ហាជាច្រើននៅពេលដោះស្រាយជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ក្នុងករណីជាច្រើន ហេដ្ឋារចនាសម្ព័ន្ធរបស់នគរបាលមិនផ្តល់ភាពងាយស្រួលដល់ស្ត្រីឬក្មេងស្រីដែលចង់រាយការណ៍ (ចាប់ពីការគ្មានមន្ត្រីជាស្ត្រី និង/ឬមន្ត្រីទទួលបានការបណ្តុះបណ្តាលស្តីពីការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី សម្រាប់ជួយដល់ជនរងគ្រោះ រហូតដល់កង្វះបរិក្ខារឆ្លើយតបក្នុងករណីអំពើរំលោភសេពសន្ថវៈឬកង្វះមធ្យោបាយធ្វើដំណើរប្រសិនបើជនរងគ្រោះត្រូវការវិធានការវេជ្ជសាស្ត្រភ្លាមៗ។ ក្នុងករណីជាច្រើនទំនាក់ទំនងដំបូងរបស់ជនរងគ្រោះធ្វើឡើងជាមួយតួអង្គក្នុងវិស័យយុត្តិធម៌ក្រៅផ្លូវការ ដូចជាអ្នកដឹកនាំបែបប្រពៃណី និងអ្នកដឹកនាំជំនឿ សមាជិកគ្រួសារ និងប្រធានសហគមន៍។ ប្រព័ន្ធយុត្តិធម៌ផ្លូវការអាចមិនផ្តល់ភាពងាយស្រួលដល់ប្រជាជនទាំងអស់។ ទោះជាយ៉ាងណា ដំណោះស្រាយនៅតែមាន ប៉ុន្តែទាមទារភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន អ្នកដឹកនាំសហគមន៍ ឬអាជ្ញាធរ និងក្នុងករណីមួយចំនួនក្រុមហ៊ុនឯកជន ដូចជា សេវាតាក់ស៊ី។

125. Ibid
126. Ibid
127. Ibid
128. សូមមើលឧបករណ៍គម្រោងលេខ ៩៧ ក្នុង "នីតិវិធីស្តីពីការស៊ើបអង្កេតរបស់នគរបាល" (ឯកសារជំនួយស្មារតីស្តីពីយេនឌ័ររបស់ UNPOL សេចក្តីសង្ខេបឧបករណ៍គម្រោង ២០១៥) ps. 272-291។

របាយការណ៍ឆ្នាំ ២០១៤ របស់នាយកដ្ឋានកិច្ចការផ្ទៃក្នុងចក្រភពអង់គ្លេសស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសាររកឃើញថាគុណភាពសេវាដែលជនរងគ្រោះទទួលបាន ផ្អែកលើសមានចិត្ត ការយល់ និងការប្តេជ្ញាចិត្តរបស់មន្ត្រីនគរបាលពាក់ព័ន្ធ[129]។

របាយការណ៍នេះគូសបញ្ជាក់ថា នៅពេលគ្មានការត្រួតពិនិត្យ និងការបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពនគរបាលនៅចក្រភពអង់គ្លេសស្ទើរតែបណ្តែតបណ្តោយទាំងស្រុងឱ្យមានបញ្ហាដែលពាក់ព័ន្ធនឹងសមត្ថភាព និងលទ្ធភាពរបស់មន្ត្រីឆ្លើយតប។ មានន័យថា សេវាដែលជនរងគ្រោះដែលងាយរងគ្រោះបំផុតមួយចំនួនទទួលបានពីនគរបាល គឺប្រៀបដូចការចាប់ឆ្នោត[130]។

ដើម្បីជួយធានាការជំរុញការចូលរួមរបស់ជនរងគ្រោះដែលស៊ីសង្វាក់គ្នា និងឆ្លើយតបនឹងយេនឌ័រក្នុងទំនាក់ទំនងដំបូង សូមអានការរៀបរាប់ពីសមត្ថភាពផ្នែកអាកប្បកិរិយាក្នុងផ្នែកខាងក្រោម។ ចំណុចទាំងនេះត្រូវបានដកស្រង់ចេញពី អង្គការសុខភាពពិភពលោក ៖ ការពង្រឹងការឆ្លើយតបផ្នែកវេជ្ជសាស្ត្រ-ច្បាប់ទៅនឹងអំពើហិង្សាផ្លូវភេទ (២០១៥)[131] ផែនការគោល ៖ ផែនការអនុវត្តន៍សម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី(មានបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយដែលមានចំណងជើងថា ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី (UNODC, 2014)។

"នៅពេលគ្មានការត្រួតពិនិត្យ និងការបណ្តុះបណ្តាលដែលមានប្រសិទ្ធភាព នគរបាលនៅចក្រភពអង់គ្លេសស្ទើរតែបណ្តែតបណ្តោយទាំងស្រុងឱ្យមានបញ្ហាពាក់ព័ន្ធនឹងសមត្ថភាពនិងលទ្ធភាពរបស់មន្ត្រីឆ្លើយតប(ទៅនឹងការទូរស័ព្ទចូលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ)"។

UK HMIC 2014 (បច្ចុប្បន្ន ហៅថា អធិការដ្ឋាននៃសេវាពន្លត់អគ្គីភ័យនិងសង្គ្រោះនៃនគរបាលមហាក្សត្រី)

ចំណុចទាំងនេះកំណត់ពីអាកប្បកិរិយា និងគុណតម្លៃដែលទទួលស្គាល់ជាអន្តរជាតិ និងពិពណ៌នាពីរបៀបដែលក្រុមរបស់អ្នកគួរឆ្លើយតបនឹងជនរងគ្រោះ ដោយសារបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងនាមជាភ្នាក់ងារឆ្លើយតបដំបូង និងផ្តល់ឧទាហរណ៍សំខាន់ៗនៃក្តីរំពឹងទុកក្នុងស្តង់ដារអន្តរជាតិ[132] ក៏ដូចជាបំពេញបន្ថែមនិងពង្រឹងឱ្យគោលនយោបាយក្នុងស្ថាប័ននគរបាលថ្នាក់ជាតិរបស់អ្នកស្តីពីគុណតម្លៃ ក្រមសីលធម៌ និងសុចរិតភាព។

សមត្ថភាពអនុវត្តន៍ការងារសំខាន់ៗមួយចំនួន ដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាគោល អនុវត្ត និងលើកកម្ពស់នៅពេលធានាថា មន្ត្រីឆ្លើយតបជំរុញលើកទឹកចិត្ត និងសម្របសម្រួលការរាយការណ៍របស់ស្ត្រី និងក្មេងស្រីស្តីពីបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការបង្ហាញការប្តេជ្ញាចិត្តដោយប្រសិទ្ធភាពចំពោះសុខុមាលភាពរបស់ជនរងគ្រោះ ការគាំទ្រជនរងគ្រោះ និងការបង្កើតទំនុកចិត្តថាការស្វែងរកយុត្តិធម៌នឹងគ្មានការរើសអើង ភាពលម្អៀង ឬបុរេនិច្ឆ័យ។ អ្នកគ្រប់គ្រងគួរធានាថា មន្ត្រីឆ្លើយតបអាចអនុវត្តចំណុចខាងក្រោម។

## ភាពអាចរកបាន និងភាពអាចទទួលបាន

- ធានាលទ្ធភាពទទួលបាននិងអាចប្រើប្រាស់ឧបករណ៍និងសម្ភារផ្គត់ផ្គង់សម្រាប់ការរាយការណ៍ពីទម្រង់ណាមួយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ( ឧ. ឧបករណ៍សម្រាប់ធ្វើកោសលវិច័យករណីមានបទល្មើសឧបករណ៍សម្រាប់ប្រមូលភស្តុតាងករណីប្រទូស្តកេរខ្មាស។ល។)
- ធានាថា ស្ត្រី និងក្មេងស្រីមានពិការភាព អាចចេញចូលប៉ុស្តិ៍នគរបាល និងផ្តល់រាល់ឧបករណ៍ទំនាក់ទំនងចាំបាច់ដល់ជនរងគ្រោះ ដែលខ្សោយក្នុងការស្តាប់/ការនិយាយ ដូចជា អ្នកបកប្រែភាសាសញ្ញា[133]។

129. "កិច្ចការរបស់មនុស្សគ្រប់រូប ៖ ការបង្កើនការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ" (HMIC, 2014)
130. Ibid
131. ការពង្រឹងការឆ្លើយតបផ្នែកវេជ្ជសាស្ត្រ-ច្បាប់ទៅនឹងអំពើហិង្សាផ្លូវភេទ (WHO and UNODC,២០១៥)
132. ក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់អនុម័តដោយសេចក្តីសម្រេចលេខ៣៤/១៦៩ របស់មហាសន្និបាត ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩។ សូមមើល https://www.ohchr.org/en/instruments-mechanisms/instruments/code-conduct-law-enforcement-officials

### ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា ៖

- ផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ជនរងគ្រោះដោយមិនស្នើសុំកម្រៃឬចំណាយដើម្បីឱ្យជនរងគ្រោះអាចសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវលើរបៀបចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយមិនវិនិច្ឆ័យ មិនធ្វើពាក់កំផែលនិងបង្ហាញសមានចិត្តដើម្បីធានាថាពួកគេផ្តល់ការរៀបរាប់ពេញលេញ។
- ធានាភាពអាចសម្របតាមបានក្នុងការប្រើប្រាស់បរិវេណអគារ និងធនធានរបស់នគរបាល ដូចជា យានជំនិះតាមរបៀបដែលផ្តោតលើតម្រូវការរបស់ជនរងគ្រោះដើម្បីធានាការរក្សាការសម្ងាត់បញ្ចៀសការមាក់ងាយនិងការរងគ្រោះលើកទីពីរ
- ផ្តល់ការណែនាំច្បាស់លាស់ស្តីពីការមិនចូលរួមក្នុងការផ្សះផ្សារក្រៅផ្លូវការក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយធានាថានគរបាលជួរមុខទទួលបានការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយស្តីពីពិធីសារសម្រាប់ភ្នាក់ងារឆ្លើយតបដំបូង។

### ភាពអាចសម្របតាមបាន

- អនុវត្តពិធីសារសម្រាប់ភ្នាក់ងារឆ្លើយតបដំបូងតាមរយៈអភិក្រមផ្អែកតាមបុគ្គល (តាមករណី) ដើម្បីកត់សម្គាល់តម្រូវការសន្តិសុខ និងតម្រូវការគាំទ្រផ្សេងៗរបស់ជនរងគ្រោះ។

### សុវត្ថិភាពជាចម្បង

- ផ្សារភ្ជាប់ចំណេះដឹងក្នុងមូលដ្ឋានទៅនឹងសាវតាររបស់ជនរងគ្រោះដើម្បីជួយកំណត់រកចំណុចខ្វះខាតក្នុងការការពារ។

### ភាពសមស្រប

- ប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះតាមរបៀបដែលកាត់បន្ថយការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្ត និងគ្រោះថ្នាក់បន្ថែមទៀតលើពួកគេ និងមន្ត្រីអន្តរាគមន៍
- ចុះឈ្មោះដាក់ពាក្យបណ្តឹងនិងផ្តល់ឱកាសឱ្យជនរងគ្រោះរ៉ាយរ៉ាប់ប្រាប់មន្ត្រីនគរបាលជាស្ត្រី (ទៅតាមការចង់បាន) មេធាវី (ប្រសិនបើអនុញ្ញាត) និងទទួលបានអ្នកបកប្រែឯករាជ្យ និងមានសមត្ថភាព (ក្នុងករណីចាំបាច់)។

### ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- ខិតខំរក្សាទុកកន្លែងកើតហេតុសូម្បីតែនៅពេលឧប្បត្តិហេតុកើតឡើងក្នុងដែនយុត្តាធិការមួយផ្សេងទៀតរបស់នគរបាល ដូចជាការបញ្ជូនទាន់ពេលវេលាទៅស្ថាប័ននគរបាលមានសមត្ថកិច្ច។
- កំណត់រកសមាសធាតុនៃសេវាសំខាន់ៗ ដូចជា អ្នកជំនាញផ្នែកចិត្តសង្គម និង/ឬអ្នកឯកទេសផ្នែកសុខភាពកុមារ និងរបៀបដែលពួកគេពាក់ព័ន្ធគ្នា។
- ខិតខំឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការវេជ្ជសាស្ត្រ និងតម្រូវការសន្តិសុខ រួមទាំងការឃុំខ្លួនជនប្រព្រឹត្តដែលរងការចោទប្រកាន់។
- គៀងគរអ្នកបកប្រែដែលទទួលការបណ្តុះបណ្តាលរួមទាំងអ្នកបកប្រែភាសាសញ្ញា (ក្នុងករណីចាំបាច់)។ ដើម្បីរក្សាការសម្ងាត់ មិនគួរឱ្យកុមារ ឬសមាជិកគ្រួសារផ្សេងទៀតធ្វើជាអ្នកបកប្រែឡើយ។ ទន្ទឹមនឹងនេះ នគរបាលមិនគួរប្រើប្រាស់អ្នកបកប្រែ (មាន ឬគ្មានការបណ្តុះបណ្តាល)ដែលមកពីសហគមន៍របស់ជនរងគ្រោះឡើយ ជាពិសេសសហគមន៍ជនជាតិដើមភាគតិច[134]។

> "ភាពទាន់ពេលវេលានៃរបាយការណ៍របស់ជនរងគ្រោះ (ឧ. ជាច្រើនថ្ងៃក្រោយឧប្បត្តិហេតុ) មិនសម្រាលភាពធ្ងន់ធ្ងរនៃឧប្បត្តិហេតុ និងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបរបស់នគរបាលនោះទេ។
>
> ការពង្រឹងការទប់ស្កាត់បទល្មើសនិងការឆ្លើយតបរបស់វិស័យយុត្តិធម៌ព្រហ្មទណ្ឌចំពោះអំពើហិង្សាលើស្ត្រី (UNODC, 2014)

133. ចំណុចនេះគួររួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងបែបប្រតិសកម្មក្នុងការលុបបំបាត់របាំងរូបវន្ត ឥរិយាបថ និងទំនាក់ទំនង ដែលស្ត្រី និងក្មេងស្រីមានពិការភាពតែងប្រឈម ហើយបញ្ហាទាំងនេះត្រូវបានដោះស្រាយតាមរយៈការការបណ្តុះបណ្តាលមន្ត្រី។

134. Sara Ferro Ribeiro and Danaé van der Straten Ponthoz, 'International Protocol on the Documentation and Investigation of Sexual Violence in Conflict - Best Practice on the Documentation of Sexual Violence as a Crime or Violation of International Law' (UK Foreign and Commonwealth Office, 2nd Edition, March 2017).

**ប្រអប់ ៧**

**មិនគួរឱ្យកុមារ ឬសមាជិកគ្រួសារធ្វើជាអ្នកបកប្រែឡើយ***

មិនគួរឱ្យកុមារធ្វើជាអ្នកបកប្រែព័ត៌មានដែលប៉ះពាល់អារម្មណ៍ឬច្រើនហួសប្រមាណពាក់ព័ន្ធនឹងតម្រូវការថែទាំសុខភាពនិងសង្គមដែលមិនសមស្របទៅតាមអាយុរបស់ពួកគេ ឬដែលសមាជិកគ្រួសារចង់រក្សាការសម្ងាត់។ ការប្រើកុមារធ្វើជាអ្នកបកប្រែសម្រាប់សមាជិកគ្រួសារណាម្នាក់ ងាយជះឥទ្ធិពលលើខ្លឹមសារនៃសារដែលពួកគេបកប្រែដែលអាចនាំឱ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់សមាជិកគ្រួសារ។ ក្រៅពីនេះ វាអាចធ្វើឱ្យកុមារថប់បារម្ភ ឬតានតឹងដោយសារបញ្ហាសុខភាពរបស់ឪពុកម្តាយ ក្រោយព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តនិង/ឬបង្កភាពទាល់ច្រកនិងភាពអាម៉ាស់ដល់កុមារនិងសមាជិកគ្រួសារ។ ការប្រើឱ្យកុមារធ្វើជាអ្នកបកប្រែ អាចដាក់បន្ទុកបន្ថែមទៀតលើពួកគេ ដូចជា ការទទួលខុសត្រូវលើការសម្រេចចិត្ត។ វាអាចបង្កើនភាពតានតឹងនិងការប្រែត្រឡប់តួនាទីក្នុងរចនាសម្ព័ន្ធគ្រួសារ ដែលអាចនាំឱ្យមានការរំលោភបំពានកុមារ ព្រោះមនុស្សពេញវ័យអាចអន់ចិត្ត ឬទាល់គំនិត នៅពេលសន្មតពីការបាត់បង់សិទ្ធិអំណាចក្នុងគ្រួសារ។

*ប្រភព ៖ The Children's Society UK

## ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន

- បន្តទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីច្បាប់ជាធរមាន និងគោលនយោបាយជាតិស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី រួមទាំងអ្វីដែលចាត់ទុកជាបទល្មើស និងអ្នកមានសមត្ថកិច្ចប្រមូលភស្តុតាង និង/ឬផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញឬឯកទេសក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា អំពើរំលោភសេពសន្ថវៈ។

## ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់

- ចែករំលែកព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដោយគោរពលក្ខខណ្ឌឯកជនភាព និងការរក្សាការសម្ងាត់។ជាទូទៅស្ថាប័ននានាអាចលាតត្រដាងព័ត៌មានទៅតាមគោលបំណងនៃការទទួលបាន ឬចងក្រងព័ត៌មានទាំងនោះឬសម្រាប់ការប្រើប្រាស់ទៅតាមគោលបំណងនោះ។ គួរពង្រឹងការផ្តល់ការយល់ព្រមត្រឹមត្រូវ តាមដែលអាចធ្វើទៅបាន។
- ទទួលបានការយល់ព្រមពីជនរងគ្រោះមុននឹងថតរូបស្នាមរបួសរបស់គាត់។

## សូចនាករយោងសម្រាប់នគរបាលដែលផ្តល់សេវាសំខាន់ៗ ៖ ទំនាក់ទំនងដំបូង

UNODC (២០១៤) បញ្ជាក់ថា ទំនាក់ទំនងដំបូងជាមួយនគរបាលគឺជាជំហានទីមួយក្នុងការធានាលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ទំនាក់ទំនងដំបូងជាឱកាសដ៏សំខាន់ក្នុងការទប់ស្កាត់គ្រោះថ្នាក់បន្ថែមទៀតនៅពេលចាត់វិធានការលើបញ្ហាដែលរកឃើញពីដំបូង។

ដោយសារតែក្នុងករណីជាច្រើន នគរបាលគឺជាភ្នាក់ងារឆ្លើយតបដំបូងទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នគរបាលដើរតួនាទីជាប្រភពដ៏សំខាន់នៃការប្រមូលទិន្នន័យសុក្រឹតស្តីពីឧប្បត្តិហេតុដែលបានរាយការណ៍។

ប្រសិនបើប្រមូលយ៉ាងសុក្រឹត ទិន្នន័យពីទំនាក់ទំនងដំបូងអាចផ្តល់ចំណេះដឹងសំខាន់ៗ ស្តីពីរបៀបដែលនគរបាលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជារួម និងថាតើអន្តរាគមន៍និងយុទ្ធសាស្ត្របែបប្រតិសកម្មរបស់នគរបាលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់និងកាត់បន្ថយអំពើហិង្សានេះឬទេ។ព័ត៌មានទាំងនេះជួយពង្រឹងគុណភាពប្រតិបត្តិការនៃសូចនាករជូនដំណឹងជាមុន ដែលមានប្រយោជន៍ដល់ការទប់ស្កាត់។

ទោះជាយ៉ាងណាសមត្ថភាពរបស់នគរបាលក្នុងការប្រមូលទិន្នន័យដែលមានគុណភាពអាស្រ័យលើសមត្ថភាពក្នុងការកំណត់រក និងផ្សារភ្ជាប់បទពិសោធន៍ចម្រុះរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទៅនឹងចំណុចបំផុសអំពើហិង្សា ដូចជា ឥរិយាបថបង្ខិតបង្ខំរបស់ជនប្រព្រឹត្ត។

ដូចការពិភាក្សាក្នុងជំពូកទី ២ កញ្ចប់សេវាសំខាន់ៗស្នើឱ្យសេវាយុត្តិធម៌និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះមានសកម្មភាពនិងលក្ខណៈទូទៅដូចគ្នាដើម្បីធានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈ និងសកម្មភាពទាំងនេះអាចអនុវត្តបានដោយមិនគិតពី "វិស័យ" ជាក់លាក់ដែលអាចឆ្លើយតបទៅនឹងស្ត្រីនិងក្មេងស្រីដែលកំពុងទទួលរងអំពើហិង្សា។

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅ និងសកម្មភាពដូចគ្នានៃកញ្ចប់សេវាសំខាន់ៗ និងផ្តល់ឧទាហរណ៍នៃសូចនាករយោងសម្រាប់សកម្មភាពរបស់នគរបាលនៅពេលខិតខំផ្តល់លទ្ធភាពឱ្យស្ត្រីនិងក្មេងស្រីរាយការណ៍បទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយទំនុកចិត្ត តាមរយៈការបង្ហាញការប្តេជ្ញាចិត្តចំពោះសុខុមាលភាពរបស់ជនរងគ្រោះ និងការគាំទ្រឱ្យទទួលបានយុត្តិធម៌ដោយគ្មានការរើសអើង ភាពលម្អៀង ឬបុរេនិច្ឆ័យ។ ទាំងនេះជាសូចនាករដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលយកជាសំអាងប្រសិនបើមានប៉ុន្តែប្រសិនបើគ្មានថ្នាក់គ្រប់គ្រងជាន់ខ្ពស់គួរបញ្ចូលសូចនាករទាំងនេះ។

- **ភាពអាចរកបាននិងភាពអាចទទួលបាន៖** ភាគរយប៉ុស្តិ៍នគរបាលមូលដ្ឋានដែលមានហេដ្ឋារចនាសម្ព័ន្ធដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ រួមបញ្ចូលពិការភាព និងមានលក្ខណៈកុមារមេត្រី[135] ដែលផ្តល់ការចូលរួមដោយមិនគិតថ្លៃរក្សាការសម្ងាត់ និងមានសុវត្ថិភាពជាមួយនគរបាល ២៤ ម៉ោងក្នុងមួយថ្ងៃ/៣៦៥ថ្ងៃក្នុងមួយឆ្នាំ និងជាភាសាឬសញ្ញាដែលជនរងគ្រោះអាចយល់បាន។ក្នុងករណីដែលភូមិសាស្ត្រពិបាកចូលដល់គួរមានយន្តការដែលអាចឱ្យជនរងគ្រោះទាក់ទងដោយសុវត្ថិភាពនិងទទួលបានសេវានគរបាលជាលក្ខណៈបុគ្គល និងដោយសម្ងាត់។ យន្តការទាំងនេះគួរផ្តល់ភាពអាចទទួលបានសម្រាប់ជនរងគ្រោះគ្រប់វ័យ និងមានពិការភាពចម្រុះ។
- **ភាពអាចសម្របតាមបាន៖** ផលធៀប (ក្នុងមនុស្សម្នាក់) នៃបុគ្គលិកដែលមានឯកទេស និងទទួលបានលិខិតបញ្ជាក់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹង យេនឌ័រក្នុងទីក្រុង។ គួរចាត់ទុកមន្ត្រីទាំងនេះជាគំរូ នៅពេលធានាទំនាក់ទំនងដំបូងជាមួយជនរងគ្រោះតាមរបៀបដែលគ្មានការវិនិច្ឆ័យបង្ហាញសមានចិត្ត គិតគូរពីអាយុ យេនឌ័រ និងពិការភាព និងផ្តល់ការគាំទ្រ។ អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរទទួលស្គាល់និងលើកទឹកចិត្តសកម្មភាពដែលពិចារណា និងទប់ស្កាត់ការរងគ្រោះជាលើកទីពីរនិងឆ្លើយតបទៅនឹងកង្វល់របស់ជនរងគ្រោះ។

"យុទ្ធសាស្ត្រដែលផ្លាស់ប្តូរឥរិយាបថរបស់សង្គម ជនរងគ្រោះនិងអ្នកជំនាញផ្នែកយុត្តិធម៌ព្រហ្មទណ្ឌរួមចំណែកដល់ការរកឃើញបទល្មើសទាំងនេះបានឆាប់រហ័ស"។

ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី (UNODC ២០១៤)

- **ភាពសមស្រប និងការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់៖** ភាគរយបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតផ្អែកតាមការប៉ះទង្គិចផ្លូវចិត្តរួមទាំងការបណ្តុះបណ្តាលស្តីពីការប៉ះទង្គិចផ្លូវចិត្តដោយអ្នកផ្តល់សេវាសំខាន់ៗ និងអ្នកជំនាញដែលផ្តល់ការគាំទ្រតាមមូលដ្ឋាន។ គួរចាត់ទុកមន្ត្រីទាំងនេះជាគំរូ នៅពេលធានាថាជនរងគ្រោះមានឱកាសរៀបរាប់ដំណើររឿងរបស់ខ្លួនមានអ្នកស្តាប់ និងកត់ត្រារឿងរ៉ាវរបស់គាត់យ៉ាងត្រឹមត្រូវ និងអាចប្រាប់ថាតើអំពើហិង្សានោះបង្កផលប៉ះពាល់ដូចម្តេចលើរូបគាត់។
- **សុវត្ថិភាពជាចម្បង** ៖ បរិមាណ និងគុណភាពនៃយោបល់ត្រឡប់ពីមន្ត្រីឆ្លើយតបស្តីពីភាពអាចអនុវត្តបាននៃឧបករណ៍វាយតម្លៃហានិភ័យនៅពេលទំនាក់ទំនងដំបូង។អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរខិតខំស្វែងរកព័ត៌មានទាំងនេះ ដើម្បីធានាការចងក្រងឯកសារដែលស៊ីសង្វាក់គ្នាអំពីឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនថាឧប្បត្តិហេតុនោះជាបទល្មើស ឬយ៉ាងណានោះទេ។
- **ទំនាក់ទំនងនិងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំអនុវត្ត និងវាយតម្លៃសេវា** ៖ ចំនួននៃការឆ្លើយតបដោយមានការសម្របសម្រួលជាមួយអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតធៀបនឹងចំនួនឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលត្រូវបានរាយការណ៍។ចំណុចនេះគួររួមបញ្ចូលតែករណីដែលបានបញ្ជូន ក្នុងករណីដែលអ្នកគ្រប់គ្រងផ្ទាល់បានអនុលោមតាមនិងពិនិត្យឡើងវិញលើពិធីសារស្តីពីការសម្របសម្រួល។

135. ចំណុចនេះអាចរួមបញ្ចូលលក្ខណៈសុវត្ថិភាពដែលអនុញ្ញាតឱ្យមានឯកជនភាពនិងការរក្សាការសម្ងាត់ (ឧ. បន្ទប់សុវត្ថិភាពសម្រាប់ការកត់ត្រាបណ្តឹង) ហេដ្ឋារចនាសម្ព័ន្ធរណបនៅទីតាំងសម្រាប់ការធ្វើដំណើរមកពីចម្ងាយ (ឧ. សម្រាប់ស្ត្រី និងក្មេងស្រីដែលរស់នៅទីជនបទ និងដាច់ស្រយាល) និងលទ្ធភាពប្រើប្រាស់ទូរស័ព្ទ ទូរសារ ឬអ៊ីនធឺណិតដើម្បីអាចឱ្យស្ត្រីរាយការណ៍ដោយសុវត្ថិភាព និងទទួលបានដីកាការពារ។

• **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន ៖** ភាគរយនៃឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលត្រូវបានរាយការណ៍ និងចាត់ប្រភេទត្រឹមត្រូវដោយនគរបាលឆ្លើយតប ទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងនៅប៉ុស្តិ៍នគរបាល។ ព័ត៌មានទាំងនេះនឹងអាចឱ្យអ្នកគ្រប់គ្រងជាន់ខ្ពស់កំណត់ថាតើបុគ្គលិកនៅកម្រិតប្រតិបត្តិការទាំងអស់មានការយល់ដឹងស៊ីសង្វាក់គ្នាស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ។ ទោះជាយ៉ាងណាសកម្មភាពនេះអាចប្រើប្រាស់ធនធានច្រើន ដោយសារត្រូវពិនិត្យផ្ទាល់ដៃលើការពិពណ៌នាអំពីឧប្បត្តិហេតុ។
• **ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល ៖** ភាគរយនៃយោបល់ត្រឡប់វិជ្ជមានពីដៃគូផ្តល់សេវាសំខាន់ៗ ស្តីពីគុណភាពនៃការឆ្លើយតបដំបូងរបស់នគរបាលធៀបនឹងចំនួននៃការបញ្ជូន។ ការអង្កេត ឬការពិភាក្សាលើការពេញចិត្តសេវា គួរសាកសួរពីភាពសមស្របនៃការចោទសួរ/ការសួរចម្លើយដាក់ស្តែងដោយមន្ត្រីឆ្លើយតបដំបូង។



## ករណីសិក្សាស្តីពីការអនុវត្តល្អ ៖ ការស៊ើបអង្កេតរបស់នគរបាលដែលផ្តោតលើការប៉ះទង្គិចផ្លូវចិត្ត

នៅឆ្នាំ ២០១៩ ក្រសួងយុត្តិធម៌កាណាដាបានចេញផ្សាយការសិក្សាមួយស្តីពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើមនុស្សពេញវ័យដែលជាជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស។ របាយការណ៍នេះគូសបញ្ជាក់ថា ការប៉ះទង្គិចផ្លូវចិត្តដែលពាក់ព័ន្ធការប្រទូស្តកេរខ្មាសច្រើនតែបង្កផលប៉ះពាល់លើសរសៃប្រសាទ។ ពោលគឺប៉ះពាល់ដល់ខួរក្បាល និងប្រព័ន្ធប្រសាទរបស់ជនរងគ្រោះ ហើយចំណុចនេះត្រូវបានឆ្លុះបញ្ចាំងក្នុងសក្ខីកម្មរបស់ជនរងគ្រោះ ក្នុងដំណើរការសួរចម្លើយស្តង់ដារ ជាពិសេសការសួរចម្លើយដោយនគរបាល[136]។

របាយការណ៍នេះលើកឡើងទៀតថា ដើម្បីដំណើរការករណីប្រទូស្តកេរខ្មាសឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបានភស្តុតាងក្នុងករណីទាំងនេះតាមរបៀបដែលកាន់តែមានយុត្តិធម៌ និងមិនលម្អៀង អ្នកជំនាញផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា នគរបាល ត្រូវមានការយល់ដឹងពីផលប៉ះពាល់ និងឥទ្ធពលនៃការប៉ះទង្គិចផ្លូវចិត្តលើជនរងគ្រោះ។

**លទ្ធផលរកឃើញសំខាន់ៗ មួយចំនួនពីរបាយការណ៍នេះ**

ការយល់ខុសដោយគ្មានមូលដ្ឋានជុំវិញស្ត្រី និងអំពើហិង្សាផ្លូវភេទ រួមចំណែកដល់ជំនឿខុសឆ្គងថា សក្ខីកម្មរបស់ជនរងគ្រោះ សាក្សី មិនសូវអាចជឿជាក់ ឬជឿទុកចិត្តបាន។ ឧទាហរណ៍មួយចំនួននៃការយល់ខុសដែលត្រូវបានដកស្រង់ក្នុងរបាយការណ៍នេះរួមមាន ៖

• ស្ត្រីដែល "មានដៃគូច្រើន" ឬ "មិនថ្លៃថ្នូរ" គឺមិនអាចជឿទុកចិត្តបាន និងច្រើនតែយល់ព្រមរួមភេទ។
• ស្ត្រីដែលមិនលាតត្រដាង ឬរាយការណ៍ភ្លាមៗពីការប្រទូស្តកេរខ្មាស កំពុងនិយាយកុហក ឬស្ត្រីដែលមិនចង់ប្រឡូកក្នុងផ្លូវភេទនឹងវាយតបតនិង/ឬប៉ុនប៉ងរត់គេចពីស្ថានភាពនេះដើម្បី "បញ្ជាក់" ថា ពួកគេពិតជាមិនយល់ព្រម។

ការយល់ខុសទាំងនេះរួមចំណែកដល់ការបង្កើតផ្នត់គំនិតមិនពិតអំពីជនរងគ្រោះពិតប្រាកដ ឬ "ល្អបំផុត" ហើយស្ត្រីដែលរងការប្រទូស្តកេរខ្មាស ត្រូវបានរំពឹងថានឹងធ្វើរឿងខាងក្រោម[137]៖

• ធ្វើការតបតដោយកម្លាំងបាយ និង/ឬពាក្យសម្តីចំពោះការរួមភេទដែលខ្លួនមិនចង់
• បង្ហាញច្បាស់នូវការមិនយល់ព្រមចំពោះទំនាក់ទំនងផ្លូវភេទដែលខ្លួនមិនចង់

136. Haskell, L. and Randell, M., 'The Impact of Trauma on Adult Sexual Assault Victims' (2019). Report submitted to: Justice Canada (2019).

137. See Randall, M (2010), 'Sexual Assault Law, Credibility, and "Ideal Victims": Consent, Resistance, and Victim Blaming', Canadian Journal of Women and the Law, 22(2), 397-43 in Haskell, L. and Randell, M., 'The Impact of Trauma on Adult Sexual Assault Victims' (2019). Report submitted to: Justice Canada (2019).

- ផ្តាច់ទំនាក់ទំនងជាមួយជនដែលប្រព្រឹត្តទង្វើផ្លូវភេទ "មិនសមស្រប" ឬប្រទូស្តរាយនាង
- បង្ហាញការរំលឹកឡើងវិញយ៉ាងល្អឥតខ្ចោះ ឬស្ទើរតែឥតខ្ចោះ រួមទាំងការពិពណ៌នាដែលស៊ីសង្វាក់គ្នា និងស្របគ្នាអំពី "អ្វីដែលបានកើតឡើង"។

របាយការណ៍នេះគូសបញ្ជាក់ថា បុគ្គលិកលក្ខណៈរបស់ជនរងគ្រោះ "ដែលល្អបំផុត" ទាំងនេះ មិនតំណាងឱ្យរបៀបដែលស្ត្រីភាគច្រើនដែលរងការប្រទូស្តកេរខ្មាសធ្វើការប្រឈម និងឆ្លើយតបជាក់ស្តែងនោះទេ។ មានន័យថា ការយល់ខុស ភាពលម្អៀង ការសន្មត និងក្តីរំពឹងទុកទាំងនេះជះឥទ្ធិពលអវិជ្ជមានលើរបៀបដែលជនរងគ្រោះផ្តល់សក្ខីកម្មក្នុងពេលដំណើរការករណីរបស់ពួកគេ និងរបៀបដែលតួអង្គ ដូចជា នគរបាលវាយតម្លៃភាពអាចជឿទុកចិត្តបានរបស់ពួកគេ។

របាយការណ៍នេះកំណត់ពីឥរិយាបថទូទៅផ្សេងទៀតរបស់ជនរងគ្រោះដោយសារបទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្តនិងសកម្មភាពរបស់នគរបាលដែលបង្កើនការប៉ះទង្គិចផ្លូវចិត្ត ដូចខាងក្រោម ៖

- ការប៉ះទង្គិចផ្លូវចិត្តដោយសារអំពើហិង្សាបង្កផលប៉ះពាល់លើសរសៃប្រសាទរបស់ជនរងគ្រោះ ដែលនាំឱ្យមានការចងចាំមិនពេញលេញអំពីការប្រទូស្តកេរខ្មាសនិងធ្វើឱ្យជនរងគ្រោះពិបាករំលឹកព័ត៌មានលម្អិតជាច្រើនដែលពាក់ព័ន្ធនឹងការប្រទូស្តកេរខ្មាសឱ្យបានគ្រប់ជ្រុងជ្រោយ និងស៊ីសង្វាក់គ្នា។
- នៅពេលសួរចម្លើយជនរងគ្រោះតាមរបៀបដែលបង្កភាពតានតឹងដូចជាប្រសិនបើមិនបង្ហាញសមានចិត្តចំពោះពួកគេ ប្រសិនបើមានការបង្អាក់សក្ខីកម្មរបស់ពួកគេ ប្រសិនបើសង្ស័យអ្វីដែលពួកគេរាយការណ៍ ជនរងគ្រោះនឹងមិនអាចរំលឹកព័ត៌មានសំខាន់ៗក្នុងខួរក្បាលរបស់ពួកគេបានឡើយ។
- ការរំពឹងថា ជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសនឹងរំលឹកព័ត៌មានទាំងអស់នៃបទពិសោធន៍ដែលបង្កការប៉ះទង្គិចផ្លូវចិត្តរបស់ខ្លួន ដោយផ្តល់ព័ត៌មានសុក្រឹតលម្អិតតាំងពីដើមដល់ចប់គឺគ្មានភាពជាក់ស្តែង ឬសនិទានភាពនោះទេ។ ខួរក្បាលឆ្លើយតបផ្ទុយពីការរំពឹងលើការរំលឹករឿងរ៉ាវយ៉ាងសុក្រឹតនេះដោយសារតែសរសៃប្រសាទឆ្លើយតបទៅនឹងការប៉ះទង្គិចផ្លូវចិត្ត។
- ការជឿថា ការលើកឡើងដែលមិនស៊ីសង្វាក់គ្នាមានន័យថា ជនរងគ្រោះកំពុងនិយាយកុហក នាំឱ្យមានការពឹងផ្អែកជ្រុលលើបច្ចេកទេស ដែលផ្តោតលើការកំណត់រកព័ត៌មានប្រឌិត។ អភិក្រមទាំងនេះបង្កភាពតានតឹងបន្ថែមទៀតលើជនរងគ្រោះ និងជាញឹកញាប់ រារាំងការរំលឹកឡើងវិញរបស់ជនរងគ្រោះ។
- កំហុសញឹកញាប់របស់នគរបាល ដោយសារការអនុវត្តរបៀបសួរចម្លើយបែបប្រពៃណី ឬស្តង់ដារ (ដើម្បីសួរចម្លើយជនល្មើស/ជនសង្ស័យ) ចំពោះជនរងគ្រោះនៃបទល្មើសធ្វើឱ្យនគរបាលមិនអាចទទួលបានព័ត៌មានចាំបាច់សម្រាប់ការស៊ើបអង្កេតការប្រទូស្តកេរខ្មាស។ ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃការសួរចម្លើយជនរងគ្រោះដោយមិនសមស្របដែលត្រូវបានដកស្រង់ក្នុងរបាយការណ៍នេះ ៖
  - ការសុំឱ្យជនរងគ្រោះដោយការប្រទូស្តកេរខ្មាសនិយាយដដែលៗចេញពីចំណុចសកម្មភាពផ្សេងៗតាមលំដាប់លំដោយដូចជា ការសុំឱ្យជនរងគ្រោះចាប់ផ្តើមរឿងរ៉ាវពីដើមដល់ចប់ រួចនិយាយត្រឡប់ពីក្រោយមកវិញ។
  - ការសួរសំណួរទៅជនរងគ្រោះដើម្បីបង្កការភាន់ច្រលំឬសាកល្បងការរៀបរាប់របស់ពួកគេ (ដើម្បីវាយតម្លៃសុពលភាពនៃការរៀបរាប់នោះ)។
- សំណួរក្នុងការសួរចម្លើយត្រូវបានចាត់ទុកថា មិនផ្តល់ប្រសិទ្ធភាពក្នុងរបាយការណ៍ ដោយសារការប្រើប្រាស់ភាសា/សំណួរ និងការសន្មតដែលស្តីបន្ទោសជនរងគ្រោះ (ឧ. ហេតុអ្វីអ្នក...?)
- ការសួរចម្លើយបែបប្រពៃណីមានការកាត់សម្តីច្រើនពេក នៅពេលជនរងគ្រោះកំពុងរៀបរាប់ពីការរងគ្រោះដោយការប្រទូស្តកេរខ្មាស។ ការកាត់សម្តីជាកំហុសដ៏ធំក្នុងអភិក្រមស៊ើបអង្កេត និងបង្អាក់ដល់ការរំលឹកការចងចាំ។

**ប្រអប់ ៨**

នៅពេលជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស យល់ថា ៖

១.នរណាម្នាក់កំពុងស្តាប់ការរៀបរាប់របស់គាត់
២.អ្នកស្តាប់អាចអត់ឱនអ្វីដែលពួកគេត្រូវនិយាយ
៣.អ្នកស្តាប់យល់ពីអ្វីដែលជនរងគ្រោះត្រូវនិយាយ
៤.អ្នកស្តាប់អាចស្រមៃថារឿងរ៉ាវរបស់ពួកគេគឺជាការពិត

ពួកគេនឹងមានអារម្មណ៍កាន់តែធូរស្រាលក្នុងការលាតត្រដាងបទពិសោធន៍និងយល់ថាមានភាពងាយស្រួលក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធ។

ការសិក្សាស្តីពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើមនុស្សពេញវ័យដែលជាជនរងគ្រោះដោយសារការ ប្រទូស្តកេរខ្មាស (ក្រសួងយុត្តិធម៌ កាណាដា ២០១៩)

## គន្លឹះឆ្ពោះទៅមុខ?

របាយការណ៍នេះកំណត់ពីសកម្មភាពវិជ្ជមានជាច្រើន និងបច្ចេកទេសដែលនគរបាលអាចយកទៅអនុវត្ត ដើម្បីឱ្យអភិក្រម កាន់តែផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត ៖

- បញ្ជ្រាបការបណ្តុះបណ្តាលក្នុងស្ថាប័នស្តីពីការស៊ើបអង្កេត ដែលផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត ដល់មន្ត្រីនគរបាលសម្រាប់ជាចំណុចស្នូលនៃការសួរចម្លើយ
- ការបណ្តុះបណ្តាលគួរលើកកម្ពស់សមត្ថភាពផ្លូវចិត្ត ដែលទាមទារការអភិវឌ្ឍជំនាញសង្គមសំខាន់ៗក្នុងការកត់សម្គាល់បកស្រាយនិងឆ្លើយតបបែបស្ថាបនាទៅនឹងអារម្មណ៍របស់អ្នក និងអ្នកដទៃ។ ពោលគឺការអភិវឌ្ឍសមត្ថភាពក្នុងការសួរចម្លើយជនរងគ្រោះតាមរបៀបដែលបង្កើនភាពអង់អាច និងរម្ងាប់អារម្មណ៍របស់ជនរងគ្រោះ ដើម្បីឱ្យពួកគេអាចផ្តល់ការរៀបរាប់ដែលកាន់តែសុក្រឹតមានសង្គតិភាព ស៊ីសង្វាក់គ្នា និងគួរឱ្យជឿបាន។

យោងតាមអ្នកជំនាញជាច្រើន ឥរិយាបថរបស់មន្ត្រីអនុវត្តន៍ច្បាប់គឺជា "កត្តាដ៏សំខាន់ជាងគេក្នុងការកំណត់ភាពជោគជ័យនៃការសួរចម្លើយជនរងគ្រោះ និងការស៊ើបអង្កេតទាំងមូល"។

ការសិក្សាស្តីពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើមនុស្សពេញវ័យដែលជាជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស (ក្រសួងយុត្តិធម៌ កាណាដា ២០១៩)

- ការសួរចម្លើយដំបូងជាមួយជនរងគ្រោះ ដែលរាយការណ៍ដំបូងអំពីការប្រទូស្តកេរខ្មាស គួរតែខ្លីល្មមរួចទើបធ្វើការសួរចម្លើយពេញលេញជាច្រើនថ្ងៃបន្ទាប់ពីជនរងគ្រោះមានពេលវេលាសម្រាក និងប្រមែប្រមូលការចងចាំរបស់ខ្លួនអំពីបទពិសោធន៍ដែលបង្កការប៉ះទង្គិចផ្លូវចិត្ត[138]។ ចំណុចនេះ អាចឱ្យមានការចងចាំកាន់តែច្រើនដែលងាយនឹងមានស្ថិរភាពកាន់តែអាចជឿជាក់បាន និងកាន់តែស៊ីសង្វាក់គ្នា និងកាន់តែមានប្រយោជន៍សម្រាប់ការរៀបរាប់លម្អិតរបស់ជនរងគ្រោះដែលនគរបាលកត់ត្រាទុក[139]។
- ក្នុងពេលដែលនគរបាលសួរចម្លើយជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសគួរផ្តោតសំខាន់លើការចងចាំដោយវិញ្ញាណ និងអារម្មណ៍ដែលជនរងគ្រោះបានកត់ចំណាំ និងចងចាំ ជាជាងរំពឹងឱ្យជនរងគ្រោះរៀបរាប់តាមលំដាប់លំដោយ។

- ការសំខាន់គឺមន្ត្រីនគរបាលត្រូវកត់សម្គាល់ថា ការបង្ហាញព័ត៌មានគឺជាដំណើរការមួយមិនមែនជាព្រឹត្តិការណ៍ដែលកើតឡើងតែម្តងនោះទេ។ ទន្ទឹមនឹងនេះ នគរបាលត្រូវទទួលស្គាល់ថាការបង្ហាញព័ត៌មានស្តីពីឧប្បត្តិហេតុនៃការប្រទូស្តកេរខ្មាសដែលជាញឹកញាប់ជនរងគ្រោះប្រឈមនឹងការប្រមាថ និងការមិនផ្តល់សិទ្ធិអំណាចគឺជាការលំបាកជាពិសេសក្នុងសង្គមដែលនៅតែមានការយល់ខុសជុំវិញការរំលោភសេពសន្ថវៈ។
- ផលប៉ះពាល់នៃឥរិយាបថរបស់នគរបាលស៊ើបអង្កេតចំពោះជនរងគ្រោះ ជាពិសេសជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសគឺជាអថេរយ៉ាងសំខាន់ក្នុងជំនួបដំបូង (និងជំនួបផ្សេងទៀត)។ ជាញឹកញាប់ជនរងគ្រោះយល់ថារងការបំភិតបំភ័យ ភាពអាម៉ាស់ ឬភ័យខ្លាច

138. សេវានគរបាលមួយចំនួននៅសហរដ្ឋអាមេរិក និងកាណាដា អនុញ្ញាតឱ្យមានការប្រមែប្រមូលការចងចាំបន្ទាប់ពីបានសម្រាកពេញភ្នែក២ដងមុននឹងសួរចម្លើយមន្ត្រីនគរបាលដែលពាក់ព័ន្ធក្នុងករណីបាញ់ប្រហារ។បច្ចេកទេសនេះអាចអនុវត្តក្នុងដំណើរការសួរចម្លើយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ See Haskell, L. and Randell, M., 'The Impact of Trauma on Adult Sexual Assault Victims' (2019).Report submitted to: Justice Canada (2019).

139. McGaugh, J. L. 'Memory consolidation and the amygdala: a systems perspective', Trends Neurosci. (2002) Sep;25(9):456.

នៅពេលដែលការឆ្លើយតបរបស់នគរបាលមិនស្ទើរ ខ្វាយខ្វល់ គ្រោតគ្រាត មិនជឿជាក់ ឬមានលក្ខណៈប្រានចោល។

- ជាញឹកញាប់ អភិក្រមបែបប្រពៃណីរបស់នគរបាលចំពោះការសួរចម្លើយជនរងគ្រោះក្នុងករណីប្រទូស្តកេរខ្មាសផ្តោតសំខាន់លើខ្លឹមសារមិនសូវសំខាន់ដែលមិនងាយរំលឹកឡើងវិញនិងអាចមិនពាក់ព័ន្ធ។ផ្ទុយទៅវិញ នគរបាលត្រូវផ្តោតលើខ្លឹមសារសំខាន់ៗ ដែលជនរងគ្រោះច្រើនតែ និងងាយរំលឹកឡើងវិញ។

## កំណត់សម្គាល់ និងអំណានបន្ថែម


1. Module 3: Justice and Policing Essential Services Package for Women and Girls Subject to Violence: Core Elements and Quality Guidelines (United Nations Joint Global Programme on Essential Services for Women and Girls Subject to Violence, 2015), see: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2015/essential-services-package-module-3-en.pdf?la=en&vs=3520

2. Guidelines on Justice in Matters Involving Child Victims and Witnesses of Crime (ECOSOC resolution 2005/20).

3. OSCE-led Survey on Violence against Women: Main report. (Organisation for the Security and Co-operation in Europe (Vienna, 2019), see: https://www.osce.org/secretariat/413237?download=true

4. Code of Conduct for Law Enforcement Official Adopted by General Assembly resolution 34/169 of 17 December 1979

5. Huhtanen, H., Lonsway, K.A., Archambault, J., 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 1. End Violence Against Women International (EVAWI, 2017)

6. Huhtanen, H., Lonsway, K.A., Archambault, J., 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 2. End Violence Against Women International (EVAWI, 2017).

7. Huhtanen, H., Lonsway, K.A., Archambault, J., 'Gender Bias in Sexual Assault Response and Investigation' Training Bulletin Series: Part 3. End Violence Against Women International (EVAWI, 2017).

8. Huhtanen, H., Lonsway, K.A., Archambault, J., 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 4. End Violence Against Women International (EVAWI, 2017).

9. 'Gender-Based Violence Training Manual for Judicial Officers in Uganda', (UN Women, 2019 unpublished).

10. Guerette, R.T. & Bowers, K.J. (2009), 'Assessing the Extent of Crime Displacement and Diffusion of Benefits: A Review of Situational Crime Prevention Evaluations' Criminology, 47(4), pp.1331-1368.

11. A Practitioner's Toolkit on Women's Access to Justice Programming. (UN Women et al., 2018), see:https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

12. Declaration on the Elimination of Violence against Women, 23 February 1994, see: https://undocs.org/en/A/RES/48/104

13. Strengthening Crime Prevention and Criminal Justice Response to Violence against Women (UNODC, 2014).

14. 'Integrating a Gender Perspective into Human Rights Investigations Guidance and Practice'. UN Office of the High Commission for Human Rights (New York and Geneva, 2018). https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegrationintoHRInvestigations.pdf

15. 'Everyone's business: Improving the Police Response to Domestic Abuse' (HCIM 2014). https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/2014/04/improving-the-police-response-to-domestic-abuse.pdf

16. Code of Conduct for Law Enforcement Officials, adopted by General Assembly resolution 34/169 of 17 December 1979, see: https://www.ohchr.org/EN/ProfessionalInterest/Pages/LawEnforcementOfficials.aspx

17. Haskell, L. and Randell, M., 'The Impact of Trauma on Adult Sexual Assault Victims (2019). Report Submitted to: Justice Canada (2019), see: https://www.justice.gc.ca/eng/rp-pr/jr/trauma/trauma_eng.pdf

18. Randall, M. (2010), 'Sexual Assault Law, Credibility, and "Ideal Victims": Consent, Resistance, and Victim Blaming', Canadian Journal of Women and the Law, 22(2), 397-43.

19. McGaugh, J. L. (2002), 'Memory consolidation and the amygdala: A Systems Perspective'. Trends Neurosci (2002) Sep;25(9):456.

20. Tanner, H., 'Start by Believing to Improve Responses to Sexual Assault and Prevent Gender Bias' (2017), see: https://www.evawintl.org/Library/DocumentLibraryHandler.ashx?id=919

21. Sara Ferro Ribeiro and Danaé van der Straten Ponthoz, 'International Protocol on the Documentation and Investigation of Sexual Violence in Conflict. Best Practice on the Documentation of Sexual Violence as a Crime or Violation of International Law' (UK Foreign & Commonwealth Office, 2nd Edition, March 2017), see: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

22. ‘Children and informal interpreting: Many children to take on an informal interpretation or translation role for their family’, (The Children’s Society UK), see: https://www.childrenssociety.org.uk/youngcarer/refugee-toolkit/children-and-informal-interpreting

23. ‘False Accusations’, (Rape Crisis Scotland), see: https://www.rapecrisisscotland.org.uk/false-allegations/

24. 2013 CSW 57 Agreed Conclusions call on States to take necessary legislative and/or other measures to prohibit compulsory and forced alternative dispute resolution processes, including forced mediation and conciliation, in relation to all forms of violence against women and girls (E/2013/27 – E/CN.6/2013/11, para (g).

25. Minority Rights Group International, see: https://minorityrights.org/2019/12/10/marginalized-and-violated-gbv/

26. *Principles and Guidelines*, supported by practical guidance, on the human rights protection of migrants in vulnerable situations (OHCHR and the Global Migration Group), see: https://www.ohchr.org/Documents/Issues/Migration/PrinciplesAndGuidelines.pdf

27. UNPOL *Gender Toolkit* Standardised Best Practices on Gender Mainstreaming in Peacekeeping: Compendium of Project Tools (2015), see: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

5

# ការស៊ើបអង្កេត

“នគរបាល និងអាជ្ញាធរផ្តន្ទាទោស ជាអ្នកទទួលខុសត្រូវបឋមលើការផ្តួចផ្តើមការស៊ើបអង្កេត និងការផ្តន្ទាទោស មិនមែនស្ត្រីដែលប្រឈមនឹងអំពើហិង្សាឡើយ (មិនគិតពីកម្រិត ឬទម្រង់នៃអំពើហិង្សា)”។

មហាសន្និបាតអង្គការសហប្រជាជាតិក្នុងយុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ២០១០
(២០១១ សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឧបសម្ព័ន្ធ)

# គោលបំណងនៃជំពូកទី ៥

**នគរបាលអាចបំពេញនូវលក្ខខណ្ឌតម្រូវនានាក្នុងការប្រមូលភស្តុតាង និងស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការបើកកិច្ចស៊ើបអង្កេតទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈហើយក្នុងដំណើរការនេះប្រើប្រាស់រាល់មធ្យោបាយដែលមានដើម្បីធានាការទទួលខុសត្រូវរបស់ជនបង្ក និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសឡើងវិញ។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- នគរបាល និងអាជ្ញាធរផ្តន្ទាទោសជាអ្នកទទួលខុសត្រូវចម្បងលើការផ្តួចផ្តើមការស៊ើបអង្កេតមិនមែនជនរងគ្រោះឡើយ។
- គ្មានឋានានុក្រមនៃអំពើហិង្សា នៅពេលកំណត់គុណភាពនៃការឆ្លើយតបរបស់នគរបាលឡើយ។
- ការស៊ើបអង្កេតដែលផ្តោតលើការបង្កើនភាពអង់អាចរបស់ជនរងគ្រោះតាមរយៈអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ បង្កើនការពេញចិត្ត និងទំនុកចិត្តរបស់ជនរងគ្រោះចំពោះនគរបាល។
- គោលការណ៍ "មិនបង្កគ្រោះថ្នាក់" ត្រូវតែជាចំណុចស្នូលនៃការសម្រេច ឬការធ្វើសកម្មភាពក្នុងពេលស៊ើបអង្កេត។
- សូចនាករនៃការស៊ើបអង្កេតប្រកបដោយវិជ្ជាជីវៈ និងឆ្លើយតបនឹងយេនឌ័រ គឺនៅពេលដែលនគរបាលរក្សាតុល្យភាពរវាងសុខុមាលភាពរបស់ជនរងគ្រោះនិងការបំពេញលក្ខខណ្ឌតម្រូវនៃការស៊ើបអង្កេត។
- កាប្រមូលភស្តុតាងកោសលវិច័យ/ភស្តុតាងវេជ្ជសាស្ត្រ-ច្បាប់ ត្រូវតែឆ្លើយតបនឹងយេនឌ័រ និងខិតខំអនុលោមតាមពិធីសារនានា។
- ត្រូវមានការយកចិត្តទុកដាក់ខ្ពស់ក្នុងករណីដែលជនរងគ្រោះជាចាស់ជរា នៅក្មេង ឬជាជនមានពិការភាព ព្រោះពួកគេអាចមានតម្រូវការជាក់លាក់។
- ការកត់សម្គាល់ដំណាក់កាលនៃឥរិយាបថបង្ខិតបង្ខំ និងត្រួតត្រាក្នុងអំពើហិង្សាអន្តរបុគ្គល អាចកំណត់លទ្ធផលនៃការស៊ើបអង្កេត។
- ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលពាក់ព័ន្ធនឹងអំពើហិង្សា/ការរំលោភបំពានដើម្បីកិត្តិយស និងការអនុវត្តមិនល្អ ទាមទារដំណោះស្រាយផ្អែកតាមសហគមន៍ និងអ្នកស៊ើបអង្កេតដែលគិតគូរពីបរិបទ។



## សេចក្ដីផ្ដើម

**ការស៊ើបអង្កេតនីមួយៗ គឺខុសៗគ្នា និងអាចទាមទារយុទ្ធសាស្ត្រ ឬអភិក្រមស៊ើបអង្កេតផ្សេងពីគ្នា។ ដោយមិនគិតពីយុទ្ធសាស្ត្រ/អភិក្រមដែលយកមកប្រើប្រាស់ បទដ្ឋានអន្តរជាតិដែលកំណត់ស្តង់ដារអប្បបរមា តម្រូវឱ្យនគរបាលខ្មុះខ្មែងឆ្លើយតបទាន់ពេលវេលា ដោយប្រើប្រាស់រាល់ធនធានដែលមាន និងគ្មានការរើសអើង។**

រូបថតទទួលបានពី UN/Martine Perret (ប្រទេសទីម័រខាងកើត)

ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី កញ្ចប់សេវាសំខាន់ៗលើកឡើងថាសូចនាករនៃការស៊ើបអង្កេតប្រកបដោយវិជ្ជាជីវៈ និងឆ្លើយតបនឹងយេនឌ័រ គឺនៅពេលដែលអ្នកស៊ើបអង្កេតមានភាពប៉ិនប្រសប់ក្នុងការរក្សាតុល្យភាពបានល្អរវាងការធានាសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះក្នុងដំណើរការនេះ និងការបំពេញលក្ខខណ្ឌតម្រូវផ្នែកភស្តុតាង និងការស៊ើបអង្កេតដើម្បីបញ្ជាក់ពីទោសព្រហ្មទណ្ឌ និង/ឬអំពើហិង្សា[1]។

គន្លឹះក្នុងការសម្រេចបានតុល្យភាពនេះគឺសមត្ថភាពរបស់អ្នកស៊ើបអង្កេតក្នុងការជំរុញលើកទឹកចិត្តឱ្យជនរងគ្រោះចូលរួមប្រកបដោយអត្ថន័យតាមរយៈការអនុវត្តអភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះការសហការជាមួយអ្នកផ្តល់សេវាសំខាន់ផ្សេងទៀត និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ ទាំងផ្លូវការ[140] និងក្រៅផ្លូវការ[141] និងការបំពេញការងារប្រកបដោយវិជ្ជាជីវៈដែលកាត់បន្ថយភាពលម្អៀងអវិជ្ជមាន និងការរងគ្រោះលើកទីពីរ។

សូមមើលជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រងនិងប្រធានក្រុម) សម្រាប់ព័ត៌មានបន្ថែមស្តីពីអភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ។

ដូចគ្នានេះដែរការស៊ើបអង្កេតដោយជោគជ័យលើករណីអំពើហិង្សាលើស្ត្រី ទាមទារការយល់ដឹងរបស់មន្ត្រីស៊ើបអង្កេតអំពីអ្វីដែលបង្កើតជាអំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងរបៀបដែលឥរិយាបថ និងភាពលម្អៀងមួយចំនួនជំរុញឱ្យមានអំពើហិង្សានេះ។ ចំណុចនេះ អាចឱ្យមន្ត្រីស៊ើបអង្កេតកំណត់រកគំរូនៃឥរិយាបថបំពានរបស់ជនបង្កដែលរងការចោទប្រកាន់ និងអថេរបរិយាកាសផ្សេងៗដែលជះឥទ្ធិពលលើឫសគល់នៃអំពើហិង្សាដែលជនរងគ្រោះទទួលរង ក៏ដូចជាឥរិយាបថ និងប្រតិកម្មរបស់ជនរងគ្រោះ។

ព័ត៌មានទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ការរៀបចំផែនការសុវត្ថិភាពនិងវិធានការការពារដើម្បីធានា

140. ឧ.គ្លីនិកវេជ្ជសាស្ត្រសហគមន៍ជម្រករបស់ជនរងគ្រោះដែលគាំទ្រដោយរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាលតាមមូលដ្ឋានដែលផ្តល់ជំនួយដល់ជនរងគ្រោះដែលប្រឡូកក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ។
141. ឧ.អ្នកដឹកនាំសហគមន៍ជាស្ត្រី ក្រុមប្រឹក្សាសាសនា ឬអាជ្ញាធរ ឬអ្នកអនុវត្តន៍យុត្តិធម៌បែបប្រពៃណី។

កុំឱ្យមានការប្រព្រឹត្តអំពើហិង្សាឡើងវិញ (សូមមើលជំពូកទី ៦ ៖ សុវត្ថិភាព និងការការពារ) ព្រោះវាជួយដល់ការដាក់បញ្ចូលឥរិយាបថបំពាន និងបង្ខិតបង្ខំរបស់ជនបង្កដែលរងការចោទប្រកាន់ក្នុងវដ្តនៃគំរូអំពើហិង្សា ដែលបង្កើតឡើងដោយអ្នកជំនាញក្នុងវិស័យនេះ។

សូមមើលជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) ស្តីពីការអនុវត្តវដ្តនៃគំរូអំពើហិង្សាក្នុងយុទ្ធសាស្ត្រឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ការដាក់បញ្ចូលគំរូឥរិយាបថបំពានរបស់ជនបង្កដែលរងការចោទប្រកាន់ក្នុងវដ្តនៃគំរូអំពើហិង្សានឹងផ្តល់ព័ត៌មានចាំបាច់សម្រាប់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពដែលផ្តោតលើជនបង្ក។ ការស៊ើបអង្កេតដូច្នេះនឹងជួយត្រួសត្រាយផ្លូវលើរបៀបបញ្ឈប់ និងដាក់ទណ្ឌកម្មលើឥរិយាបថបំពាន និងរបៀបទប់ស្កាត់មិនឱ្យជនបង្កប្រព្រឹត្តបទល្មើសជាថ្មីជាសេណារីយ៉ូមួយដែលជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាលើដៃគូស្និទ្ធស្នាលតែងប្រាថ្នាចង់បាន។

ផ្នែកខាងក្រោមនឹងពិភាក្សាពីបរិយាកាសអំណោយផលចាំបាច់ក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលមានប្រសិទ្ធភាពក្នុងការបំពេញលក្ខខណ្ឌតម្រូវផ្នែកភស្តុតាង ហើយក្នុងពេលតែមួយនឹងធានាការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ជនរងគ្រោះ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

ការណែនាំសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ផ្អែកលើការស្រាវជ្រាវ និងការអនុវត្តបច្ចុប្បន្នស្តីពីសេវានគរបាលដែលមិនលម្អៀង និងឆ្លើយតបនឹងយេនឌ័រនិងរបៀបដែលអភិក្រមនេះអាចគូសបញ្ជាក់ពីប្រសិទ្ធភាពនៃការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ជំពូកនេះនឹងអនុវត្តតាមក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ និងស្នើឱ្យអ្នកអានពិនិត្យមើលសេចក្តីណែនាំក្របខណ្ឌក្នុងម៉ូឌុលទី ៣ នៃកញ្ចប់សេវាសំខាន់ៗស្តីពីយុត្តិធម៌ និងនគរបាល សកម្មភាពសំខាន់ទី ៣ ស្តីពី "ការស៊ើបអង្កេត"។ ទន្ទឹមនឹងនេះ អ្នកអានគួរយោងតាមសេចក្តីណែនាំក្របខណ្ឌក្នុងម៉ូឌុលទី ២ នៃកញ្ចប់សេវាសំខាន់ៗ ស្តីពីសុខភាពជាពិសេសសកម្មភាពសំខាន់ទី ៦ ស្តីពី "ការចងក្រងឯកសារ (វេជ្ជសាស្ត្រ-ច្បាប់)"។

## ការណែនាំគ្នាទៅវិញទៅមក

ក្នុងនាមជាអ្នកដឹកនាំ អ្នកត្រូវធានាថា បុគ្គលិករបស់អ្នកផ្តល់សេវានគរបាលដែលមានប្រសិទ្ធភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ហើយខណៈដែលអ្នកកត់សម្គាល់ថា អ្នកនឹងប្រឈមនឹងតម្រូវការចំពោះមុខជាច្រើនលើសេវា និងធនធានដែលអ្នកមាន សារដែលអ្នកបង្ហាញដល់បុគ្គលិករបស់អ្នកនិងសហគមន៍មូលដ្ឋានគឺមានសារៈសំខាន់ណាស់។ ចាំបាច់ត្រូវបង្ហាញច្បាស់ថាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនឹងមិនត្រូវអត់ឱនឱ្យជាដាច់ខាត ថា អ្នក និងបុគ្គលិករបស់អ្នកនឹងអនុវត្តច្បាប់យ៉ាងតឹងរ៉ឹងហើយជនបង្កដែលរងការចោទប្រកាន់នឹងត្រូវបានដាក់ឱ្យស្ថិតក្រោមការស៊ើបអង្កេតយ៉ាងតឹងរ៉ឹងដើម្បីទទួលខុសត្រូវចំពោះមុខច្បាប់។ តើអ្នកបានបង្ហាញច្បាស់ដល់បុគ្គលិកទាំងអស់អំពីអ្វីដែលពួកគេគួរធ្វើឬទេ? តើអ្នកបានពិនិត្យតាមដាន និងរក្សាការទទួលខុសត្រូវរបស់ពួកគេលើការអនុវត្តការងារ ឬទេ?

ដើម្បីធានាថា បុគ្គលិករបស់អ្នកបំពេញស្តង់ដារដែលកំណត់ក្នុងស្ថាប័ន ពួកគេត្រូវដឹងពីខ្លឹមសារនៃគោលនយោបាយ ឬនីតិវិធីប្រតិបត្តិស្តង់ដារស្តីពីការប្រយុទ្ធប្រឆាំង/ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ប្រសិនបើគ្មានឯកសារទាំងនេះក្នុងស្ថាប័នរបស់អ្នក អ្នកអាចពិចារណាបង្កើតកម្រងគោលការណ៍ណែនាំសម្រាប់បុគ្គលិករបស់អ្នក។ ក្រៅពីនេះ អ្នកអាចទទូចឱ្យថ្នាក់លើរបស់អ្នកបញ្ចុះបញ្ចូលឱ្យមានការបង្កើតនីតិវិធីប្រតិបត្តិសម្រាប់ស្ថាប័នរបស់អ្នក (ផ្អែកលើធាតុចូល និងបទពិសោធន៍ពីក្រុម/អង្គភាពរបស់អ្នកផ្ទាល់)។

**អំពើហិង្សាលើស្ត្រី និងក្មេងស្រីជា “អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបង្កជា ឬនឹងបង្កជាគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី ដូចជា ការគំរាមកំហែង ប្រព្រឹត្ត ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានក្នុងជីវិតសាធារណៈ ឬជីវិតឯកជនឡើយ”។**

សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី សេចក្តីសម្រេចលេខ ៤៨/១០៤ របស់មហាសន្និបាត (១៩៩៣)

មិនថាមានឬគ្មានគោលនយោបាយ/នីតិវិធីប្រតិបត្តិស្តង់ដារក្នុងស្ថាប័ននោះទេ អ្នកត្រូវកំណត់រកបញ្ហាដែលអ្នក និងបុគ្គលិករបស់អ្នកប្រឈមក្នុងការដោះស្រាយឧប្បត្តិហេតុទាំងនេះ និងការខ្វះខាតធនធាន ឬចំណេះដឹងដែលត្រូវដោះស្រាយ ឬក៏អ្នកត្រូវការជំនួយពីសហគមន៍ អ្នកផ្តល់សេវាផ្សេងទៀតឬផ្នែកផ្សេងទៀតក្នុងស្ថាប័នរបស់អ្នក។

អ្នកនឹងត្រូវប្រាកដថាបុគ្គលិករបស់អ្នកបានដឹងនិងទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ពួកគេត្រូវដឹងពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួនក្នុងការអនុវត្តតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ អនុសញ្ញា ឬពិធីសារដែលរដ្ឋាភិបាលរបស់អ្នកជាហត្ថលេខី។

ឧទាហរណ៍ដ៏ល្អមួយគឺបទប្បញ្ញត្តិស្តីពីសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឬ សន្ធិសញ្ញាអន្តរជាតិដែលប្រទេសរបស់អ្នកបានផ្តល់សច្ចាប័នដែលអនុវត្តទាំងចំពោះជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់។ តើបុគ្គលិករបស់អ្នកបានដឹងពីការទទួលខុសត្រូវរបស់ពួកគេក្នុងការផ្តល់សុវត្ថិភាព និងការការពារដល់មនុស្សទាំងអស់ដែលស្ថិតនៅជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្នុងព្រំដែនប្រទេសរបស់អ្នកឬទេ? ពួកគេអាចជាជនភៀសខ្លួនអ្នកស្វែងរកសិទ្ធិជ្រកកោន និងជនចំណាកស្រុក មិនថាមានឬគ្មានឯកសារបញ្ជាក់នោះទេ។

ប្រសិនបើមានជំរំជនភៀសខ្លួនក្នុងតំបន់ដែនសមត្ថកិច្ចរបស់អ្នកតើបុគ្គលិករបស់អ្នកបានដឹងថាអ្នកដែលរស់នៅក្នុងជំរំទាំងនោះនៅតែមានសិទ្ធិរស់នៅទីនោះដោយសុវត្ថិភាព និងទទួលបានសេចក្តីថ្លៃថ្នូរ និងការគោរព ឬទេ?

សុវត្ថិភាព និងការការពាររបស់ពួកគេមិនមែនជាការទទួលខុសត្រូវទាំងស្រុងរបស់នគរបាលនោះទេ។ រាល់ស្ថាប័នដែលពាក់ព័ន្ធនៅក្នុង និងជុំវិញជំរំទាំងនោះសុទ្ធតែមានតួនាទី ប៉ុន្តែទន្ទឹមនឹងនេះ នគរបាលមិនអាចគេចវេសពីការទទួលខុសត្រូវដោយសារតែជំរំទាំងនោះគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR)[142] ឬ អង្គការអន្តរជាតិផ្សេងទៀតនោះទេ។

មានកំណត់យ៉ាងច្បាស់ពីតួនាទីរបស់នគរបាលក្នុងការទប់ស្កាត់ ស៊ើបអង្កេត គាំទ្រ និងជួយដល់សកម្មភាពនានាហើយដើម្បីជានាប្រសិទ្ធភាពត្រូវមានអភិក្រមបែបសហការ និងមានការសម្របសម្រួលរវាងនគរបាល និងស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការធ្វើការបែបសហការ សូមមើលជំពូកទី ៣ (ការទប់ស្កាត់ ) ជំពូកទី ៧ (ការគាំទ្រ និងជំនួយ) និងជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោម ស្ថាប័នយុត្តិធម៌)។

បន្ទាប់ពីបានកំណត់ថាមន្ត្រីរបស់អ្នកទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី អ្នកត្រូវមានទំនុកចិត្តថាពួកគេបានដឹងពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួនក្នុងការប្រយុទ្ធប្រឆាំងបទល្មើសទាំងនេះ។ បុគ្គលិកគ្រប់រូបត្រូវដឹងពីតួនាទីជាក់លាក់របស់ខ្លួនចាប់ពីអ្នកដែលមានទំនាក់ទំនងដំបូងជាមួយជនរងគ្រោះ ដូចជា អ្នកលើកទូរស័ព្ទ មន្ត្រីផ្តល់ព័ត៌មាន ឬមន្ត្រីចុះល្បាត (ភ្នាក់ងារឆ្លើយតបដំបូង) អ្នកត្រួតពិនិត្យកន្លែងកើតហេតុ ឬមន្ត្រីកោសលវិច័យ រហូតដល់អ្នកស៊ើបអង្កេតទូទៅ ឬអ្នកស៊ើបអង្កេតឯកទេស អ្នកគ្រប់គ្រងករណី អ្នកត្រួតពិនិត្យផ្ទាល់ និងអ្នកគ្រប់គ្រង។

142. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៥០ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ ស្ថាប័ននេះមានអាណត្តិដឹកនាំ និងសហការសម្របសម្រួលវិធានការអន្តរជាតិក្នុងការការពារជនភៀសខ្លួន និងដោះស្រាយបញ្ហារបស់ជនភៀសខ្លួននៅជុំវិញពិភពលោក។ សូមមើល https://www.un.org/youthenvoy/2013/09/office-of-the-united-nations-high-commissioner-for-refugees/

របៀបឆ្លើយតបដោយបុគ្គលដំបូងដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះនឹងបង្កផលប៉ះពាល់យ៉ាងខ្លាំងនិងយូរអង្វែងលើទំនុកចិត្ត និងភាពជឿជាក់របស់ជនរងគ្រោះចំពោះនគរបាល។ បន្ទាប់មក វានឹងបង្កើតជាទំនុកចិត្តនិងភាពជឿជាក់របស់គ្រួសារ មិត្តភក្តិ និងសហគមន៍របស់ជនរងគ្រោះចំពោះនគរបាល។

សម្រាប់ព័ត៌មានបន្ថែមស្ដីពីការប្រឈមជាមួយជនរងគ្រោះ សូមមើលជំពូកទី ៤ ( ទំនាក់ទំនងដំបូង ) និងជំពូកទី ៩ ( ទំនាក់ទំនង )។

ត្រូវឆ្លើយតបភ្លាមៗទៅនឹងឧប្បត្តិហេតុអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលបានរាយការណ៍ ដើម្បីបង្ហាញការប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងបទល្មើសទាំងនេះ និងផ្ញើសារយ៉ាងច្បាស់លាស់ថា ជនរងគ្រោះគ្រប់រូបសុទ្ធតែសំខាន់ ហើយនគរបាលពិចារណាយ៉ាងដិតដល់លើពួកគេ និងបណ្តឹងរបស់ពួកគេ។ ការឆ្លើយតបភ្លាមៗគឺសំខាន់ណាស់ក្នុងការធានាសុវត្ថិភាព និងការការពាររបស់ជនរងគ្រោះ ក៏ដូចជាក្រុមគ្រួសារ ឬអ្នកពាក់ព័ន្ធផ្សេងទៀតដែលអាចប្រឈមនឹងហានិភ័យ។ ជនរងគ្រោះអាចត្រូវការសេវាវេជ្ជសាស្ត្រសម្រាប់របួសរាងកាយឬរបួសផ្លូវចិត្តហើយការទទួលបានការព្យាបាលឱ្យបានឆាប់បំផុតមិនត្រឹមតែបំពេញតម្រូវការរបស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនលទ្ធភាពនៃការទទួលបានអ្វីដែលអាចជាភស្តុតាងពីជនរងគ្រោះផ្ទាល់ទៀតផង។

ទោះបីជាគ្មានអ្នកស៊ើបអង្កេត ឬមន្ត្រីដែលទទួលការបណ្តុះបណ្តាលពិសេសនៅពេលរាយការណ៍ក្តី ក៏មិនគួរទុកឱ្យជនរងគ្រោះរង់ចាំការឆ្លើយតបដែរ ហើយនេះជាមូលហេតុដែលយ៉ាងហោចណាស់ បុគ្គលិកគ្រប់រូបត្រូវមានការយល់ដឹងទូទៅស្តីពីរបៀបប្រឈមជាមួយនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងអ្នកដែលងាយរងគ្រោះបំផុត។បន្ទាប់ពីការរាយការណ៍ឧប្បត្តិហេតុ នគរបាលត្រូវយល់ពីគោលការណ៍ "មិនបង្កគ្រោះថ្នាក់"[143] ពាក់ព័ន្ធនឹងការសម្រេចចិត្ត ឬសកម្មភាពណាមួយ។

សំខាន់បំផុតគឺ ត្រូវធ្វើអ្វីគ្រប់យ៉ាងដើម្បីទប់ស្កាត់មិនឱ្យជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត ដោយសារការបំផុសដំណើរការ ឬនីតិវិធីរបស់នគរបាល ដែលអាចមានន័យស្មើនឹងការរងគ្រោះលើកទីពីរ។ ពួកគេត្រូវយល់ពីការលំបាករបស់ជនរងគ្រោះក្នុងការរាយការណ៍ទៅនគរបាលពីដំបូង និងហានិភ័យបន្ថែមទៀតដែលជនរងគ្រោះអាចប្រឈមពីក្រុមគ្រួសារ ឬ សហគមន៍ទាំងមូល ដោយសារការរាយការណ៍នេះ។

### ប្រអប់ ១

**តើអ្នកធានាការពិនិត្យតាមដានលើការអនុវត្តការងាររបស់ភ្នាក់ងារឆ្លើយតបដំបូងទៅនឹងបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ?**

ខាងក្រោមនេះ ជាចំណុចត្រួតពិនិត្យ សម្រាប់អ្នកត្រួតពិនិត្យផ្ទាល់លើភ្នាក់ងារឆ្លើយតបដំបូងដោយផ្អែកតាមការណែនាំពីមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស៖

១. ធ្វើឱ្យជនរងគ្រោះ យល់ថាមានសុវត្ថិភាព ៖ ភ្នាក់ងារឆ្លើយតបដំបូងបង្ហាញសមានចិត្ត
២. ភ្នាក់ងារឆ្លើយតបដំបូងមិនធ្វើការវិនិច្ឆ័យលើជម្រើសជីវិត ឬមានយន្តការដោះស្រាយឱ្យជនរងគ្រោះ
៣. អនុវត្តដំណើរការវាយតម្លៃហានិភ័យ
៤. ពិនិត្យនិងធានាលើសុខុមាលភាពរបស់កុមារ នៅកន្លែងកើតហេតុ
៥. រៀបចំផែនការសុវត្ថិភាពជាមួយជនរងគ្រោះនិងកុមារ
៦. ធានាឯកជនភាពនៅពេលបំបែកជនរងគ្រោះចេញពីជនបង្កដែលរងការចោទប្រកាន់
៧. ធ្វើការជូនដំណឹងដល់ជនរងគ្រោះថានគរបាលជឿពួកគេ ហើយពួកគេបានសម្រេចចិត្តត្រូវក្នុងការស្វែងរកជំនួយ
៨. បង្ហាញការយល់ពីមូលហេតុដែលជនរងគ្រោះមួយចំនួន មិនសហការជាមួយនគរបាល
៩. ធានាសុវត្ថិភាពទៅតាមតម្រូវការបុគ្គល
១០. អនុវត្តឱ្យបានសមស្របទៅតាមតម្រូវការរបស់ជនរងគ្រោះ ដែលមានសាវតារចម្រុះ
១១. ការកំណត់អត្តសញ្ញាណ ការការពារ និងការថែរក្សាកន្លែងកើតហេតុ

143. គោលការណ៍ "មិនបង្កគ្រោះថ្នាក់" សំដៅលើការធានាថា សកម្មភាព និងទំនាក់ទំនងមិនពង្រឹងដោយអចេតនានូវផ្នត់គំនិតអវិជ្ជមានស្តីពីបុរសនិងស្ត្រីដែលរួមចំណែកដល់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

១២. ការកំណត់អត្តសញ្ញាណការរក្សាទុកនិងក្នុងករណីសមស្រប ប្រមូលភស្តុតាង
១៣. ការចាត់វិធានការវិជ្ជមាន និងពន្យល់ដល់ជនរងគ្រោះ
១៤. ការដោះស្រាយការចោទប្រកាន់ប្រឆាំងតបវិញ។

យោងតាមសៀវភៅណែនាំរបស់ UNODC ស្ដីពី "ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី" (២០១០) ការស៊ើបអង្កេត ជាលំហាត់បែបវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងការកំណត់រកបទល្មើសតាមរយៈការពិនិត្យអង្គហេតុ ឬកាលៈទេសៈនៃឧប្បត្តិហេតុ និងការកំណត់រកជម្រើសអនុវត្តន៍ច្បាប់ដែលសមស្របនឹងអង្គហេតុឬកាលៈទេសៈទាំងនោះ។ ខណៈដែលភាពស្មុគស្មាញ និងធម្មជាតិនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានលក្ខណៈខុសប្លែកពីការស៊ើបអង្កេតផ្សេងទៀត គោលបំណង និងគោលការណ៍ណែនាំគឺប្រហាក់ប្រហែលគ្នា។

ខាងក្រោមនេះជាតារាងត្រួតពិនិត្យគោលបំណងនៃការស៊ើបអង្កេត និងអ្វីដែលនាំទៅរកការស៊ើបអង្កេតដែលមានប្រសិទ្ធភាព ដកស្រង់ចេញពីសៀវភៅណែនាំរបស់ UNODC។

**ប្រអប់ ២**

| **គោលបំណងនៃការស៊ើបអង្កេត ៖** | **ការស៊ើបអង្កេតដែលមានប្រសិទ្ធភាពគឺជាទូទៅ នៅពេលដែលអ្នកស៊ើបអង្កេត ៖** |
|---|---|
| • កំណត់ថាតើបទល្មើសមួយត្រូវបានប្រព្រឹត្តឬប្រានចោលការចោទប្រកាន់<br>• កំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ និងសាក្សី<br>• ប្រមែប្រមូល និងរក្សាទុកភស្តុតាងដែលអាចពាក់ព័ន្ធ<br>• ស្រាវជ្រាវរកឫសគល់ របៀបប្រព្រឹត្ត និងទីតាំងនៃបទល្មើស<br>• បញ្ជាក់អត្តសញ្ញាណរបស់ជនបង្កដែលរងការចោទប្រកាន់ ឬអ្នកទទួលខុសត្រូវ<br>• ក្នុងករណីសមស្រប បង្កើតមូលដ្ឋាននៃការចោទប្រកាន់<br>• ចងក្រងឯកសារស្ដីពីការស៊ើបអង្កេត និងភស្តុតាង និងត្រៀមបង្ហាញភស្តុតាងនៅពេលជំនុំជម្រះទោស<br>• ទប់ស្កាត់ការរងគ្រោះបន្ថែមទៀត (រួមបញ្ចូលទាំងជនរងគ្រោះ និងអ្នកផ្សេងទៀតដែលអាចរងផលប៉ះពាល់ដូចជា កុមារ) | • ធ្វើសកម្មភាពប្រកបដោយវិជ្ជាជីវៈមិនលម្អៀងបរិយាបន្ន និងសត្យានុម័ត<br>• ខ្នះខ្នែងប្រមូលវត្ថុតាង ឬភស្តុតាង និងអំណះអំណាង<br>• ផ្ដល់ការគោរព និងសេចក្ដីថ្លៃថ្នូរដល់ជនរងគ្រោះសាក្សី និងជនបង្កដែលរងការចោទប្រកាន់គ្រប់រូប<br>• ប្រសិនបើមានបទល្មើស ដែលនាំទៅរកការកំណត់អត្តសញ្ញាណជនបង្កដែលរងការចោទប្រកាន់ជានាថា ការប្រមូលភស្តុតាងដែលមានគុណភាពគ្រប់គ្រាន់ដើម្បីផ្ដល់លទ្ធភាពជាក់ស្ដែងដល់ការផ្ដន្ទាទោសនៅតុលាការ។<br>• ពិចារណាពីសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះសាក្សី និងជនបង្កដែលរងការចោទប្រកាន់ វាយតម្លៃហានិភ័យ អនុវត្តដំណើរការកំណត់រកហានិភ័យ និងគ្រប់គ្រងហានិភ័យ។ |

ក្រៅពីនេះអ្នកត្រូវមានទំនុកចិត្តថាគ្រប់របាយការណ៍ស្ដីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានកត់ត្រាយ៉ាងសុក្រឹតនិងមានព័ត៌មានលម្អិតគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេតល្អិតល្អន់។ ឧ. តើមានការកត់ត្រាពាក្យពេចន៍គ្រប់ម៉ាត់របស់ជនរងគ្រោះ ឬទេ? វាអាចធ្វើឱ្យប៉ះពាល់ដល់ករណីទាំងមូល ប្រសិនបើក្នុងតុលាការ ជនរងគ្រោះឬសាក្សីនិយាយដោយខ្លួនឯងអំពីអ្វីដែលបានកើតឡើងដែលមិនស៊ីសង្វាក់គ្នានឹងរបាយការណ៍ដំបូងរបស់នគរបាល ឬអំណះអំណាងដំបូងរបស់ជនរងគ្រោះ។

ការមិនកត់ត្រាខ្លឹមសារលម្អិតឱ្យច្បាស់ និងខ្លីអំពីអ្វីដែលបានធ្វើឬនិយាយអាចធ្វើឱ្យករណីមិនត្រូវបានបញ្ជូនទៅ

តុលាការ។ ប្រសិនបើអ្នកបានសង្ខេប ឬប្រើប្រាស់ពាក្យបច្ចេកទេសដែល "កាន់តែគួរសម" វាអាចសម្រាលភាពធ្ងន់ធ្ងរនៃបទល្មើសដែលបង្ហាញជូនអយ្យការ ឬអ្នកផ្តល់សេវាយុត្តិធម៌ផ្សេងទៀត។ការកត់ត្រាត្រឹមត្រូវពីឧប្បត្តិហេតុទាំងអស់(មិនថាត្រូវបានផ្តល់សុពលភាពជាបទល្មើសឬយ៉ាងណានោះទេ) មានសារៈសំខាន់ណាស់ចំពោះអ្នកក្នុងការបង្កើតទិន្នន័យស្តីពីប្រេវ៉ាឡង់និងប្រភេទនៃបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលអាចឱ្យអ្នកប្រើប្រាស់ធនធានបានល្អក្នុងការទប់ស្កាត់ឧប្បត្តិហេតុ ស្រដៀងគ្នា ឬដដែលៗ។

សូមមើល ជំពូកទី ៣ (ការទប់ស្កាត់) ជំពូកទី ៦ (សុវត្ថិភាពនិងការការពារ) ជំពូកទី ៧ (ការគាំទ្រ និងជំនួយ) និងជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) សម្រាប់ព័ត៌មានលម្អិតស្តីពីការច្បាប់យក និងការប្រើប្រាស់ទិន្នន័យ។

ចាំបាច់ត្រូវកំណត់តម្រូវការចំពោះមុខរបស់ជនរងគ្រោះតាំងពីដំបូង ដើម្បីឱ្យអ្នកអាចយល់ពីការ គាំទ្រ និងជំនួយបន្ថែមទៀតដែលជនរងគ្រោះត្រូវការ។ អ្នក និងបុគ្គលិករបស់អ្នកត្រូវការជំនួយពីអ្នកផ្តល់សេវាផ្សេងទៀត ដើម្បីគាំទ្រដល់ការស៊ើបអង្កេត។ ដូច្នេះ ចាំបាច់ត្រូវមានការសហការគ្នា។ក្នុងការសហការជាមួយអ្នកផ្តល់សេវាផ្សេងទៀតដើម្បីជួយដល់ជនរងគ្រោះ បុគ្គលិករបស់អ្នកអាចផ្តោតសំខាន់លើតួនាទីស្នូលរបស់ពួកគេក្នុងការប្រមូលភស្តុតាង ដើម្បីកំណត់អង្គហេតុនៃករណីនេះ និងបង្ហាញលទ្ធផលរកឃើញជូនអយ្យការ ឬតុលាការ។

សូមមើលជំពូកទី ៧ (ការគាំទ្រ និងជំនួយ) សម្រាប់ព័ត៌មានបន្ថែមនិងឧទាហរណ៍នៃការអនុវត្តល្អដូចជាមជ្ឈមណ្ឌលដោះស្រាយវិបត្តិជនរងគ្រោះ និងមជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស។

នៅដំណាក់កាលឆ្លើយតបភ្លាមៗ នៃការស៊ើបអង្កេតចាំបាច់ត្រូវដោះស្រាយដោយប្រសិទ្ធភាពជាមួយជនបង្កដែលមានវត្តមាន ឬអាចត្រូវបានកំណត់អត្តសញ្ញាណយ៉ាងឆាប់រហ័ស។ ការសំខាន់គឺបុគ្គលិករបស់អ្នកត្រូវធ្វើសកម្មភាពប្រកបដោយក្រមសីលធម៌និងវិជ្ជាជីវៈចំពោះជនបង្កដែលរងការចោទប្រកាន់ មិនចំពោះថាពួកគេមានការយល់ឃើញយ៉ាងណានោះទេ។

### ប្រអប់ ៣

យ៉ាងហោចណាស់ របាយការណ៍ទាំងអស់ស្តីពីឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរកត់ត្រាចំណុចខាងក្រោម ៖

- **អ្នកពាក់ព័ន្ធក្នុងការស៊ើបអង្កេត និងរបៀបទាក់ទងទៅពួកគេ?** លេខឯកសារនគរបាល/លេខឧប្បត្តិហេតុដើមបណ្តឹង/ជនរងគ្រោះ សាក្សី ជនបង្កដែលរងការចោទប្រកាន់ នគរបាលឆ្លើយតបដំបូង មន្ត្រីស៊ើបអង្កេត។
- អ្វីដែលបានកើតឡើង ? បទល្មើសដែលបានប្រព្រឹត្ត ទំនាក់ទំនងរវាងជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់ របួស (ជាក់ស្តែង ឬផ្លូវចិត្ត) ភស្តុតាងដែលមាន ស្ថានភាព និងទីតាំងនៃភស្តុតាង វិធានការដែលធ្វើឡើង និងវិធានការបន្ថែមដែលចាំបាច់ ភស្តុតាងសាក្សីដែលមាន និងការសាកសួរដើម្បីស្វែងរកសាក្សី។ ជំនួយវេជ្ជសាស្ត្រដែលផ្តល់ជូននិងដោយនរណាឬតើជនរងគ្រោះត្រូវបានបញ្ជូនទៅហេដ្ឋារចនាសម្ព័ន្ធវេជ្ជសាស្ត្រណាមួយ? (លម្អិតពីបុគ្គលិកវេជ្ជសាស្ត្រ និងព័ត៌មានទំនាក់ទំនង)។
- ពេលវេលាដែលព្រឹត្តិការណ៍នីមួយៗកើតឡើង ? ម៉ោង (ចាប់ផ្តើម/បញ្ចប់) កាលបរិច្ឆេទ/ថ្ងៃ កាលបរិច្ឆេទ/ម៉ោងដែលរាយការណ៍ ប្រសិនបើខុសគ្នា។
- កន្លែងដែលព្រឹត្តិការណ៍នីមួយៗកើតឡើង ? ការកំណត់អត្តសញ្ញាណកន្លែងកើតហេតុ ទីតាំងជាក់លាក់ ទីតាំងរបស់ដើមបណ្តឹង/ជនរងគ្រោះ ទីតាំងរបស់ជនបង្កដែលរងការចោទប្រកាន់និង ទីតាំងរបស់សាក្សី។ ពិពណ៌នាពីកន្លែងកើតហេតុ អាផាតមិន ផ្ទះ (បន្ទប់មួយណា ?) ហាង អគារសាធារណៈ សួនច្បារ ច្រកល្ហក ដងផ្លូវ ឬវិថី។ ពិពណ៌នាសកម្មភាពដែលបានធ្វើដើម្បីការពារ និងរក្សាកន្លែងកើតហេតុមិនឱ្យមានការប៉ះពាល់ឬមានការ

ប៉ះពាល់បន្ត។ ឧ. តើអ្នកបានទប់ស្កាត់មិនឱ្យមនុស្សចេញចូលកន្លែងកើតហេតុ និងបំផ្លាញភស្តុតាងរូបវន្ត និង/ឬភស្តុតាងកោសល្យវិច័យដោយរបៀបណា? ចងក្រងឯកសារស្តីពីការចេញចូល/ការគ្រប់គ្រង (ឧ.តើមានមន្ត្រីឯកទេស និងបុគ្គលិកណាខ្លះបានចូលកន្លែងកើតហេតុ និងមូលហេតុ? កាលបរិច្ឆេទ និងពេលវេលាដែលពួកគេចេញចូល។

- ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍នីមួយៗ? តើមានប្រើអាវុធ ឬទេ? ប្រសិនបើមាន តើបច្ចុប្បន្ន អាវុធទាំងនោះនៅឯណា? ហេតុអ្វីព្រឹត្តិការណ៍នេះកើតឡើង? ប្រវត្តិរបស់ជនបង្កដែលរងការចោទប្រកាន់ ប្រវត្តិដីកាតុលាការ និង/ឬដីកាហាមឃាត់បណ្តោះអាសន្នប្រវត្តិអំពើហិង្សាដែលពាក់ព័ន្ធនឹងជនបង្កដែលរងការចោទប្រកាន់/ជនរងគ្រោះ។
- សុវត្ថិភាពរបស់ជនរងគ្រោះ? សកម្មភាពដែលធ្វើឡើងដើម្បីធានាសុវត្ថិភាពនិងការពារដើមបណ្តឹង/ជនរងគ្រោះ សមាជិកគ្រួសារផ្សេងទៀត រួមទាំងកុមារ និងបុគ្គលងាយរងគ្រោះផ្សេងទៀត និងសាក្សី។

បន្ថែមលើការពិចារណាពីហានិភ័យដែលអាចបង្កឡើងលើជនរងគ្រោះ ដោយជនបង្កដែលរងការចោទប្រកាន់ អ្នកមាន "ភារកិច្ចយកចិត្តទុកដាក់ចំពោះ" ជនបង្កដែលរងការចោទប្រកាន់ ដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស រហូតដល់ត្រូវបានបញ្ជាក់ពិរុទ្ធភាពដោយតុលាការ។ មានន័យថាអ្នកក៏ត្រូវពិចារណាពីហានិភ័យចំពោះជនបង្កដែលរងការចោទប្រកាន់ផងដែរ ប្រសិនបើបានដឹងពីធម្មជាតិនៃអំពើដែលពួកគេត្រូវបានចោទប្រកាន់ និងអត្តសញ្ញាណរបស់ពួកគេ។ នេះជាផ្នែកមួយផ្សេងទៀតនៃឯកជនភាពនិងការរក្សាការសម្ងាត់ដែលអ្នកត្រូវគោរព ហើយសកម្មភាពរបស់នគរបាលដែលពាក់ព័ន្ធនឹងការផ្សាយព័ត៌មានជាសាធារណៈ ត្រូវអនុវត្តតាមដំណើរការស្របច្បាប់ដែលពាក់ព័ន្ធនឹងច្បាប់ជាតិ។

ឧ.ក្នុងប្រទេសមួយចំនួនអត្តសញ្ញាណរបស់ជនបង្កដែលរងការចោទប្រកាន់ត្រូវបានការពាររហូតដល់តុលាការធ្វើការការចោទប្រកាន់ជាផ្លូវការលើបទល្មើសមួយនៅកាលបរិច្ឆេទជាក់លាក់។ សូម្បីតែនៅពេលត្រូវបានចោទប្រកាន់ផ្លូវការនិងស្ថិតក្នុងដំណើរការយុត្តិធម៌ក្តីក៏ជនបង្កដែលរងការចោទប្រកាន់ និងក្រុមគ្រួសារ អាចនៅតែប្រឈមនឹងហានិភ័យនៃការសងសឹក ការបំភិតបំភ័យ ឬគ្រោះថ្នាក់រាងកាយដែលបង្កឡើងដោយអ្នកដទៃឬបង្កឡើងដោយខ្លួនឯង។ជាញឹកញាប់បញ្ហានេះកើតឡើងក្នុងករណីដែលជនបង្កដែលរងការចោទប្រកាន់ជាជនដែលទទួលបានការគោរពក្នុងសង្គម ដូចជា គ្រូបង្រៀន អ្នកដឹកនាំបែបប្រពៃណី ឬអ្នកដឹកនាំជំនឿ ឬ វេជ្ជបណ្ឌិត។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការពិចារណាក្រោយការចាប់ខ្លួន ពីការចោទប្រកាន់ និងការផ្តន្ទាទោស សូមមើលជំពូកទី ៦ (សុវត្ថិភាព និងការការពារ)។

អ្នកត្រូវធានាការអនុលោមតាមវិធានការដែលបានអនុវត្តក្នុងការការពារជនរងគ្រោះ ដូចជា ដីកាការពារ ហើយនគរបាលត្រូវឆ្លើយតបភ្លាមៗនៅពេលមានការរាយការណ៍ពីការរំលោភវិធានការទាំងនោះ។ចំណុចនេះមិនត្រឹមតែអនុវត្តបន្ទាប់ពីការចាប់ខ្លួនជនបង្កដែលរងការចោទប្រកាន់នោះទេព្រោះដីកាការពារនិងវិធានការផ្សេងទៀតអាចត្រូវបានចេញតាំងពីមុននេះ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលជំពូកទី ៦ (សុវត្ថិភាព និងការការពារ)។

ចំណុចដ៏សំខាន់មួយនៃការស៊ើបអង្កេតគឺភស្តុតាងដែលផ្តល់ដោយជនរងគ្រោះ ដែលត្រូវកត់ត្រាយ៉ាងលម្អិតអំពីឧប្បត្តិហេតុនេះ រួមទាំងព័ត៌មានដែលអាចជួយកំណត់សាវតារនៃអំពើហិង្សា។ត្រូវកត់ត្រាទាំងពាក្យពេចន៍គ្រប់ម៉ាត់ និងសកម្មភាពដែលប្រព្រឹត្តលើជនរងគ្រោះ ក៏ដូចជាព័ត៌មានទូទៅ ដូចជា រចនាសម្ព័ន្ធគ្រួសារ ប្រវត្តិប្រព្រឹត្តអំពើហិង្សា។ មូលហេតុនៃការមិនរាយការណ៍ពីមុន ដូចជាការភ័យខ្លាចរបស់ជនរងគ្រោះ ក៏គួរកត់ត្រាផងដែរ។

### ប្រអប់ ៤

**ត្រូវធានាសិទ្ធិមួយចំនួនរបស់ជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់**

- រួមមានសិទ្ធិទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរពីនគរបាល សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន/ឃុំខ្លួន សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានការការពារពីអំពើហិង្សាមិនសមស្របដែលបង្កឡើងដោយរដ្ឋ (ឧ. សកម្មភាពបំពានរបស់នគរបាល) សិទ្ធិមិនចោទប្រកាន់ខ្លួនឯង សិទ្ធិឯកជនភាព និងរក្សាការសម្ងាត់ សិទ្ធិទទួលបានមេធាវី សិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
- ការសំខាន់គឺមន្ត្រីត្រូវដឹងពីអ្វីដែលពួកគេមិនត្រូវពិចារណាក្នុងការកំណត់ថា តើគួរមានការចាប់ខ្លួន ឬទេ ៖
  - ស្ថានភាពអាពាហ៍ពិពាហ៍ សិទ្ធិកាន់កាប់ ឬសិទ្ធិជួលការធានាជាពាក្យសម្តីថា អំពើហិង្សានឹងត្រូវបញ្ឈប់ ស្ថានភាពផ្លូវចិត្តរបស់ជនរងគ្រោះ របួសជាក់ស្តែង ឬមើលមិនឃើញ ការបដិសេធអំពើហិង្សាក្នុងគ្រួសារដោយភាគីណាមួយ ការជឿថា ការចាប់ខ្លួនមិនអាចឈានដល់ការផ្តន្ទាទោស ផលវិបាកផ្នែកហិរញ្ញវត្ថុចំពោះភាគីណាមួយដោយសារការចាប់ខ្លួន ស្ថានភាពជាតិសាសន៍ វប្បធម៌ សង្គម នយោបាយ ឬវិជ្ជាជីវៈ ឬទំនោរផ្លូវភេទរបស់ជនរងគ្រោះ ឬជនបង្កដែលរងការចោទប្រកាន់ ការសេពគ្រឿងស្រវឹង ឬគ្រឿងញៀន ឬទាំងពីរ ដោយភាគីណាមួយ ឬទាំងពីរ ឬការយល់ឃើញចំពោះឆន្ទៈរបស់ភាគីណាមួយក្នុងការផ្តល់សក្ខីកម្ម ឬចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។
  - ការស្លៀកពាក់របស់ជនរងគ្រោះ ថាតើគាត់ប្រឡូកក្នុងរបររកស៊ីផ្លូវភេទ ឬឥរិយាបថផ្សេងទៀតដែលអាចវិនិច្ឆ័យថា "ប្រឈមនឹងហានិភ័យ" ដោយអ្នកផ្សេងទៀត ការចេញក្រៅតែម្នាក់ឯង ទីតាំងដែលគាត់ស្ថិតនៅ ឬពេលវេលា (ថ្ងៃ ឬយប់) ដែលគាត់ចេញក្រៅ។ល។

ដកស្រង់ចេញពី ៖ UNODC សៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី ២០២០

ការសួរចម្លើយជនរងគ្រោះ សាក្សី ឬជនសង្ស័យ គួរធ្វើឡើងដោយអ្នកស៊ើបអង្កេតជំនាញដែលទទួលការបណ្តុះបណ្តាលលើជំនាញសួរចម្លើយក្នុងការស៊ើបអង្កេត។ ក្នុងករណីដែលជនរងគ្រោះនិងសាក្សីឬកុមារត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសការសួរចម្លើយគួរធ្វើឡើងដោយអ្នកស៊ើបអង្កេតដែលទទួលបានការបណ្តុះបណ្តាលឯកទេសលើការសួរចម្លើយជនរងគ្រោះ និងសាក្សី/កុមារដែលងាយរងគ្រោះ (ទៅតាមភាពពាក់ព័ន្ធ)។ ការអនុវត្តមធ្យោបាយនេះនឹងអាចឱ្យអ្នកស៊ើបអង្កេតប្រមូលភស្តុតាងនិងចម្លើយដែលមានប្រយោជន៍បំផុត និងបញ្ចៀសការសួរចម្លើយដដែលៗក៏ដូចជាបង្ការការសួរចម្លើយដោយបង្ខំនិងការរងគ្រោះជាលើកទីពីរ[144]។ ការសួរចម្លើយរបៀបនេះ គួរគ្រោងឡើងដោយប្រុងប្រយ័ត្ននិងធ្វើឡើងក្នុងបរិយាកាសសមស្រប។

ការកត់ត្រាចម្លើយមានភាពពាក់ព័ន្ធបំផុតក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ព្រោះជនរងគ្រោះប្រហែលជាធ្លាប់រងគ្រោះដោយអំពើហិង្សានេះជាច្រើនលើក មុនពេលរាយការណ៍ឧប្បត្តិហេតុនេះទៅនគរបាល។ ក្នុងករណីនៃការត្រួតត្រាដោយបង្ខំ ប្រហែលជាជនបង្កបានចាប់ផ្តើមត្រួតត្រាជនរងគ្រោះបន្តិចម្តងៗរួចទៅហើយ។

ការកត់ត្រាចម្លើយរបស់ជនរងគ្រោះ ត្រូវស្វែងយល់ពីអារម្មណ៍របស់ជនរងគ្រោះ (ទាំងផ្លូវកាយ និងផ្លូវចិត្ត) ផលប៉ះពាល់នៃអំពើហិង្សា និងការរំលោភបំពានដែលពួកគេប្រឈម និងសមាជិកគ្រួសារផ្សេងទៀត ជាពិសេសកុមារ ដែលបានមើលឃើញហេតុការណ៍។ ចម្លើយរ៉ាយរ៉ាប់លម្អិតប្រហែលជាត្រូវចំណាយពេលយូរ។

ដោយសារតែការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ ឬការព្យាបាលវេជ្ជសាស្ត្រដែលពួកគេទាមទារនគរបាលប្រហែលជាមិនអាចទទួលបានចម្លើយទាំងអស់ពីការសួរចម្លើយតែ

144. សូមមើលឯកសារដែលនឹងចេញផ្សាយនាពេលឆាប់ៗនេះ "ពិធីសារស្តីពីការសួរចម្លើយដោយប្រសិទ្ធភាព ការប្រមូលព័ត៌មានដោយមានជំនាញបែបវិទ្យាសាស្ត្រ ការអនុវត្តផ្អែកតាមភស្តុតាងស្តង់ដារសិទ្ធិមនុស្សនិងក្រមសីលធម៌វិជ្ជាជីវៈ" (ពិធីសារMendez)។

មួយលើកទេ។ ភាពអំណត់ និងការគិតគូរពីអារម្មណ៍ជាជំនាញសំខាន់ៗដែលមន្ត្រីរបស់អ្នកត្រូវមាន ហើយនៅពេលពួកគេចំណាយពេលកាន់តែច្រើនជាមួយជនរងគ្រោះ ដើម្បីកសាងទំនុកចិត្តនិងទំនាក់ទំនងល្អពួកគេនឹងទទួលបានព័ត៌មានកាន់តែច្រើនពីជនរងគ្រោះ។

ការគិតគូរពីយេនឌ័រ ពិចារណាពីតម្រូវការដោយឡែក និងទស្សនៈរបស់ជនរងគ្រោះ គោរពសេចក្ដីថ្លៃថ្នូរ និងសុចរិតភាពរបស់ជនរងគ្រោះ និងកាត់បន្ថយការបំពានទន្ទឹមនឹងការគោរពតាមស្តង់ដារក្នុងការប្រមូលភស្តុតាងកោសលវិច័យ។

កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា(២០១៥)

យកល្អគឺបុគ្គលិករបស់អ្នកគួរចំណាយពេលច្បាមយកចម្លើយសុក្រឹតនិងលម្អិតពីជនរងគ្រោះក្នុងការសួរចម្លើយតែមួយលើកបានហើយជាជាងចំណាយពេលសួរចម្លើយឡើងវិញនៅពេលព័ត៌មានកាន់តែច្រើនលេចឡើង។ការធ្វើដូច្នេះនឹងបណ្តាលឱ្យជនរងគ្រោះប៉ះទង្គិចផ្លូវចិត្តកាន់តែខ្លាំង ព្រោះពួកគេនឹងនឹកឃើញឧប្បត្តិហេតុនោះគ្រប់ពេលវេលា តាមរយៈការរំលឹកឡើងវិញ។ នេះជាឧទាហរណ៍មួយនៃការបង្ក "ការរងគ្រោះជាលើកទីពីរ" ដោយសារនគរបាល។ប្រសិនបើត្រូវសួរចម្លើយម្តងទៀតត្រូវពន្យល់ជនរងគ្រោះដោយប្រុងប្រយ័ត្នអំពីមូលហេតុដែលត្រូវធ្វើដូច្នេះ។ ពុំនោះទេ ជនរងគ្រោះអាចយល់ថា គ្មានអ្នកជឿពួកគេ ដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តកាន់តែខ្លាំង។ ប្រសិនបើជនរងគ្រោះមានបញ្ហាផ្នែកទំនាក់ទំនងដែលអាចបណ្តាលមកពីពិការភាព ដូចជា គថ្លង់ ប្រហែលជាត្រូវចំណាយពេលបន្ថែមទៀតដើម្បីប្រមូលចម្លើយរបស់គាត់។

ប្រសិនបើជនរងគ្រោះគឺជាកុមារចាំបាច់ត្រូវកត់ត្រាពាក្យសម្តីគ្រប់ម៉ាត់របស់គាត់។ កុមារមិនសូវប្រើ ឬក្នុងករណីខ្លះមិនសូវយល់ពាក្យសម្តីមនុស្សពេញវ័យឬពាក្យបច្ចេកទេសច្បាប់ទេ។ ដូច្នេះ មន្ត្រីរបស់អ្នកមិនត្រូវប៉ុនប៉ងផ្លាស់ប្តូរអ្វីដែលពួកគេប្រាប់កុមារដោយប្រើប្រាស់ "ភាសាមនុស្សពេញវ័យ" នោះទេ។ ក្រៅពីនេះ ជនរងគ្រោះជាកុមារគួរសួរចម្លើយដោយអ្នកស៊ើបអង្កេតឯកទេស។

នៅពេលមន្ត្រីរបស់អ្នកធ្វើការជាមួយក្មេងស្រីដែលអាចជាជនរងគ្រោះ ការសំខាន់គឺពួកគេត្រូវកត់សម្គាល់ពីតម្រូវការជាក់លាក់របស់ក្មេងស្រី ទៅតាមអាយុរបស់ក្មេងស្រីនោះនិងកែសម្រួលការឆ្លើយតបទៅតាមភាពសមស្រប។ ពួកគេត្រូវធានាថាការនិយាយជាមួយក្មេងស្រីមានលក្ខណៈកុមារមេត្រី ហើយឳពុក/ម្តាយ អាណាព្យាបាល ឬអ្នកតំណាងអោយក្មេងស្រីដែលស្របច្បាប់ជាដើម ដែលមិនពាក់ព័ន្ធក្នុងឧប្បត្តិហេតុត្រូវមានវត្តមាននិងស្ថិតក្រោមការស៊ើបអង្កេត ហើយក៏ត្រូវចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះផងដែរ។ ក្រៅពីនេះ មន្ត្រីទាំងនោះត្រូវធានាថា កុមារទទួលបានការពិចារណាដូចជាមនុស្សពេញវ័យដែរពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ និងឯកជនភាព ហើយសេវាវេជ្ជសាស្ត្រ សេវាចិត្តសង្គម និងសេវា គាំទ្រជនរងគ្រោះក៏ត្រូវបានផ្តល់សមស្របតាមអាយុរបស់ពួកគេផងដែរ។

នៅពេលទទួលបានចម្លើយពីជនរងគ្រោះ ជាពិសេសប្រសិនបើពួកគេទទួលរងការប៉ះទង្គិចផ្លូវចិត្តខ្លាំង ដូចជាក្នុងអំឡុងនៃការប្រទូស្តកេរខ្មាសធ្ងន់ធ្ងរ គួរស្តាប់រឿងរ៉ាវរបស់ពួកគេជាមុនសិន ដោយធ្វើការកត់ត្រាខ្លីៗ ដើម្បីអាចចាប់ផ្តើមការស៊ើបអង្កេតឱ្យបានឆាប់បំផុត។សូមចាំថាការប៉ះទង្គិចផ្លូវចិត្តអាចបង្កផលប៉ះពាល់ខុសៗគ្នាលើជនរងគ្រោះហើយពីដំបូងជនរងគ្រោះអាចមិនចាំរឿងរ៉ាវទាំងអស់ដែលបានកើតឡើងចំពោះខ្លួន ឬមិនរៀបរាប់តាមលំដាប់លំដោយ។ មន្ត្រីរបស់អ្នកអាចយល់ថា ជនរងគ្រោះមិនប្រព្រឹត្តដោយសមហេតុផលក្នុងអំឡុងឧប្បត្តិហេតុនោះ ប៉ុន្តែចំណុចនេះមិនមានន័យថា ពួកគេកំពុងនិយាយកុហកនោះទេ។

## ប្រអប់ ៥

**ការណែនាំរបស់ WHO/UNODC ស្តីពីការប្រមូលសំណាកកោសលវិច័យ**



**សារៈតារ/សនិទានភាព ៖**

គួរទទួលបានការយល់ព្រមឱ្យប្រមូលសំណាកពីបុគ្គលគ្រប់រូប។ សំណាកអាចបរិយាយពីទំនាក់ទំនងរវាងបុគ្គល ឬរវាងបុគ្គលម្នាក់ និងទីតាំង។ ភស្តុតាងនៃការប៉ះពាល់លេចឡើងនៅពេលប្រព្រឹត្តបទល្មើស ប៉ុន្តែបាត់ទៅវិញយ៉ាងឆាប់រហ័ស។ មានតែភស្តុតាងដែលត្រូវបានប្រមូល រក្សាទុក និងវិភាគយ៉ាងត្រឹមត្រូវប៉ុណ្ណោះដែលគួរត្រូវបានប្រើប្រាស់ក្នុងការស៊ើបអង្កេត ឬកិច្ចដំណើរការនីតិវិធីតុលាការ។ ត្រូវបកស្រាយ លទ្ធផលនៃការវិភាគដោយប្រុងប្រយ័ត្ន សត្យានុម័ត និងក្នុងបរិបទនៃការស៊ើបអង្កេត។ ក្នុងករណីដ៏កម្រកិច្ចដំណើរការនីតិវិធីបន្តទៅមុខដោយផ្អែកតាមភស្តុតាងតែមួយ ដូចជា DNA ក្រយៅដៃ។

**ចំណុចសំខាន់ៗ ៖**

- គួរទទួលបានការយល់ព្រមពីជនរងគ្រោះឱ្យប្រមូល និងផ្តល់សំណាក (ដល់អ្នកស៊ើបអង្កេត)។ គួរពិចារណាយ៉ាងប្រុងប្រយ័ត្នលើផលប៉ះពាល់នៃការប្រមូលសំណាកលើជនរងគ្រោះ (ទាំងផ្លូវកាយ និងផ្លូវចិត្ត)។
- ការរៀបរាប់ដំណើររឿងដោយជនរងគ្រោះ (ឬសាក្សី) និងពេលវេលានៅចន្លោះការប្រទូស្តរាយ និងការត្រួតពិនិត្យនឹងគួសបញ្ជាក់ថាតើគួរធ្វើការប្រមូលសំណាក ឬទេ និងប្រភេទសំណាកដែលត្រូវបានប្រមូល។
- ប្រមូលសំណាកពីផ្នែកនៃរាងកាយដែលអាចមានវត្ថុជីវសាស្ត្រ ៖ ស្បែក សក់/រោម និងប្រហោងមាត់ រន្ធយោនី និងរន្ធគូថ។
- ផ្តោតការយកចិត្តទុកដាក់លើខ្លឹមសារលម្អិតក្នុងការដាក់ស្លាក និងការកត់ត្រាសំណាកដែលប្រមូលបាន។
- ទុកឱ្យសំណាកដែលសើម ស្ងួតសិន។ កុំប្រើបំពង់សម្រាប់បណ្តុះមេរោគដើម្បីដាក់សំណាកកោសលវិច័យ។
- ប្រមូលសំណាកឈាម និងទឹកនោមសម្រាប់ការវិភាគរកជាតិពុល ប្រសិនបើមានការចោទប្រកាន់ពីការប្រើប្រាស់គ្រឿងញៀនដោយសម្ងាត់ ឬដោយគ្មានការយល់ព្រម។
- ចងក្រងឯកសារអំពីការបញ្ជូនសំណាក (ខ្សែសង្វាក់នៃការគ្រប់គ្រងភស្តុតាង) ៖ អ្វី ទៅនរណា និងពេលបញ្ជូន ឬអាចធានាការរក្សាទុកសំណាកឱ្យបានសមស្រប។
- ប្រុងប្រយ័ត្នចំពោះការធ្វើឱ្យប្រឡាក់ប្រឡូក ៖ រឹតត្បិតលទ្ធភាពចេញចូលកន្លែងត្រួតពិនិត្យ ធានាថា កន្លែងត្រួតពិនិត្យត្រូវបានសម្អាតនៅចន្លោះករណីនីមួយៗ និងប្តូរស្រោមដៃឱ្យបានញឹកញាប់។

ប្រភព ៖ ឯកសារជំនួយស្មារតីស្តីពីការពង្រឹងការឆ្លើយតបផ្នែកវេជ្ជសាស្ត្រផ្លូវច្បាប់ទៅនឹងអំពើហិង្សាផ្លូវភេទ (WHO/UNODC ២០១៥)

ការរួមបញ្ចូលមូលហេតុនៃការប្រព្រឹត្ត ឬការមិនប្រព្រឹត្តតាមធម្មតានៅពេលប្រឈមនឹងអំពើហិង្សាក៏ជាភស្តុតាងដ៏មានប្រយោជន៍ក្នុងចម្លើយរបស់ជនរងគ្រោះផងដែរ។ ការទុកពេលឱ្យជនរងគ្រោះមិនមានន័យថាការច្បាមយកចម្លើយគួរពន្យារពេលដោយមិនសមស្របឡើយ។ ទោះជាយ៉ាងណាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ តម្រូវឱ្យបុគ្គលិករបស់អ្នកពិចារណាពីតម្រូវការរបស់ជនរងគ្រោះគ្រប់ពេលវេលា ដើម្បីជាត្រីវិស័យសម្រាប់ការស៊ើបអង្កេត ជាពិសេសនៅដំណាក់កាលដំបូងបំផុត។

សូមមើលជំពូកទី ៤ (ទំនាក់ទំនងដំបូង) សម្រាប់ព័ត៌មានលម្អិតស្តីពីការប៉ះទង្គិចផ្លូវចិត្ត និងជំពូកទី ៩ (ទំនាក់ទំនង) សម្រាប់ការណែនាំស្តីពីរបៀបកសាងទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយជនរងគ្រោះ។

ការពិនិត្យកោសលវិច័យ វេជ្ជសាស្ត្រ ត្រូវធ្វើឡើងភ្លាមៗ ដើម្បីធានាថាជនរងគ្រោះមិនប្រឈមនឹងការរងគ្រោះជាលើកទីពីរ ដែលធ្វើឱ្យគាត់ប៉ះទង្គិចផ្លូវចិត្តកាន់តែខ្លាំង។ ការគិតគូរពីយេនឌ័រ[145] គឺសំខាន់បំផុត ហើយជនរងគ្រោះជាស្ត្រីត្រូវមានអ្នកអមដំណើរតែក្នុងពេលត្រួតពិនិត្យដោយបុគ្គលិកជាស្ត្រីប៉ុណ្ណោះ។

ការសំខាន់គឺអ្នកត្រូវធានាថា មន្ត្រីរបស់អ្នកបានដឹងច្បាស់នូវរាល់លក្ខខណ្ឌតម្រូវផ្នែកភស្តុតាង និងរបៀបទុកដាក់ សម្គាល់និងរក្សាទុកវត្ថុតាងដែលអ្នកពិនិត្យផ្នែកវេជ្ជសាស្ត្រអាចប្រគល់ជូនពួកគេ។

ឯកសារជំនួយស្មារតីរបស់ WHO/UNODC ស្ដីពីការពង្រឹងការឆ្លើយតបផ្នែកវេជ្ជសាស្ត្រផ្លូវច្បាប់ទៅនឹងអំពើហិង្សាផ្លូវភេទ(២០១៥)ផ្ដល់ការណែនាំក្នុងការប្រមូលសំណាកពីបុគ្គលដែលចោទប្រកាន់ករណីអំពើហិង្សាផ្លូវភេទ និងអាចផ្ដល់ព័ត៌មានដល់អ្នកស៊ើបអង្កេត (និងតុលាការ) ដើម្បីគាំទ្រ ឬច្រានចោលបទចោទប្រកាន់ (សូមមើលប្រអប់៧)។ឯកសារជំនួយស្មារតីនេះគូសបញ្ជាក់ពីភាពចាំបាច់ដែលបុគ្គលគ្រប់រូបត្រូវផ្ដល់ការយល់ព្រមផ្អែកតាមព័ត៌មានគ្រប់គ្រាន់ នៅពេលប្រមូលសំណាក។

បញ្ហាទូទៅនៅប៉ុស្ដិ៍នគរបាល ជាពិសេសនៅទីជនបទ គឺកង្វះអ្នកស៊ើបអង្កេតឬបុគ្គលិកជាស្ត្រីដែលគ្មានការបណ្ដុះបណ្ដាលអំពីការច្បាមយកចម្លើយ ឬចាត់ចែងវត្ថុតាងក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ប៉ុន្តែមានតួនាទីត្រឹមតែជាអ្នកអមដំណើរ។ ប្រសិនបើ បញ្ហានេះកើតឡើងចំពោះស្ថាប័នអ្នកអ្នកត្រូវពិចារណាបណ្ដុះបណ្ដាលមន្ត្រីជាស្ត្រីទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អ្នក ស្ដីពីរបៀបច្បាមយកចម្លើយពីជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងជនរងគ្រោះដែលមានពិការភាព។

គួរផ្ដោតសំខាន់លើការច្បាមយកចម្លើយពីជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទនិងការយល់ដឹងស្ដីពីភស្តុតាងកោសលវិច័យ និងការចាត់ចែងវត្ថុតាង។ ចំណុចនេះនឹងធានាថាអ្នកអាចផ្ដល់ការឆ្លើយតបដែលគិតគូរពីអារម្មណ៍និងសមស្របបំផុតដល់ជនរងគ្រោះ(ជាអ្វីដែលគាត់ត្រូវការ) ផ្ដល់សេចក្ដីថ្លៃថ្នូរ និងការគោរពដល់ជនរងគ្រោះ ទន្ទឹមនឹងការច្បាមយកភស្តុតាងសំខាន់ៗដើម្បីឱ្យអ្នកស៊ើបអង្កេតជាស្ត្រីអាចបំពេញតួនាទីរបស់គាត់បាន។

ភ្នាក់ងារឆ្លើយតបដំបូង និងអ្នកផ្សេងទៀតដែលចេញចូលកន្លែងកើតហេតុ មិនត្រូវចូលទៅក្នុងតំបន់ ឬប៉ះពាល់អ្វីដែលមាននៅទីនោះដោយមិនចាំបាច់ឡើយ បន្ទាប់ពីបានដោះស្រាយ ហានិភ័យចំពោះអាយុជីវិត ដូចជា ការជួបជាមួយជនរងគ្រោះដែលមានរបួសធ្ងន់ធ្ងរ។

អ្នកត្រូវធានាថាមន្ត្រីរបស់អ្នកយល់ថាមិនគួរអនុញ្ញាតឱ្យនរណាម្នាក់ចេញចូលកន្លែងកើតហេតុឡើយ លុះត្រាតែពួកគេមានតួនាទីសំខាន់ក្នុងការស៊ើបអង្កេតឬកំពុងផ្ដល់ការព្យាបាលវេជ្ជសាស្ត្រដល់នរណាម្នាក់ដែលគេមិនអាចយកចេញពីកន្លែងកើតហេតុដោយសុវត្ថិភាពបាន។

តើភ្នាក់ងារឆ្លើយតបដំបូងរបស់អ្នកបានដឹងថាក្នុងករណីបទល្មើសធ្ងន់ធ្ងរ ដូចជា អំពើមនុស្សឃាត និងការរំលោភសេពសន្ថវៈ គួរធានាសុវត្ថិភាពនៅកន្លែងកើតហេតុ និងគួរកត់ត្រាពីបុគ្គលដែលប៉ុនប៉ងចេញចូល សូម្បីតែមន្ត្រីជាន់ខ្ពស់ ឬទេ?

ក្នុងពេលឆ្លើយតបដំបូង និងក្នុងពេលស៊ើបអង្កេត មន្ត្រីរបស់អ្នកត្រូវមានគំនិតបើកទូលាយ និងប្រើប្រាស់ភស្តុតាងជាត្រីវិស័យនៃការសម្រេចចិត្តរបស់ខ្លួន ជាជាងការវិនិច្ឆ័យជាមុនលើស្ថានភាព។

**គោលការណ៍សំខាន់ៗនៃការស៊ើបអង្កេត**

ការផ្ទេរ តែងកើតមានឡើង រវាងបុគ្គលម្នាក់ និងវត្ថុដែលពួកគេប៉ះពាល់។ ផ្អែកតាមគោលការណ៍ដោះដូររបស់ Locard "សកម្មភាពរបស់បុគ្គល និងជាពិសេសអំពើហិង្សាដែលបង្កើតបានជាបទល្មើសមួយ មិនអាចកើតឡើងដោយមិនបន្សល់ដាននោះទេ"។

"ការប្រឡាក់ប្រឡូក" អាចបង្កផលអន្តរាយលើការស៊ើបអង្កេតជាបន្តបន្ទាប់និងភាពអាចជឿទុកចិត្តបាននៃភស្តុតាងជាពិសេសភស្តុតាងកោសលវិច័យដែលបង្ហាញនៅចំពោះមុខតុលាការ។

JaneTownsleyអតីតស្នងការនគរបាលដឹកជញ្ជូនចក្រភពអង់គ្លេសនិងបច្ចុប្បន្នជានាយកប្រតិបត្តិសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (IAWP)

145. ការគិតគូរពីយេនឌ័រមានគោលបំណងស្វែងយល់និងពិចារណាពីកត្តាសង្គមនិងវប្បធម៌ដែលពាក់ព័ន្ធនឹងការផាត់ចេញ និងការរើសអើងផ្អែកតាមយេនឌ័រក្នុងមជ្ឈដ្ឋានចម្រុះបំផុតនៃជីវិតសាធារណៈនិងជីវិតឯកជន(វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ២០១៩) សូមមើល https://eige.europa.eu/thesaurus/terms/1211

ការការពារកន្លែងកើតហេតុគឺសំខាន់ណាស់ក្នុងការរក្សាអ្វីដែលអាចជាភស្តុតាងមិនឱ្យខូចខាត វងការបំផ្លាញ បាត់បង់ ផ្លាស់ប្តូរ តាមរបៀបណាមួយពីស្ថានភាពដើមរបស់វា។ ចំណុចនេះអាចឱ្យអ្នកស៊ើបអង្កេតកន្លែងកើតហេតុកត់ត្រាលម្អិតពីអ្វីៗទាំងអស់និងស្តារអ្វីដែលអាចជាភស្តុតាងឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

ការប្រមូលភស្តុតាងជាចំណុចគន្លឹះក្នុងការស៊ើបអង្កេតនីមួយៗ។ក្នុងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីភស្តុតាងនៃបទល្មើសប្រហែលជាមិនស្តែងឡើងរហូតនោះទេ។ ដូច្នេះ មន្ត្រីពាក់ព័ន្ធត្រូវពិចារណាពីឱកាសទាំងអស់នៅពេលពាក់ព័ន្ធនឹងឧប្បត្តិហេតុ។ ចំណុចនេះក៏គួរគិតគូរផងដែរក្នុងស្ថានភាពពេលអ្នកនិយាយជាមួយជនរងគ្រោះ សាក្សី និងក្នុងពេលសួរចម្លើយជនបង្កដែលរងការចោទប្រកាន់។អ្នកដឹកនាំបែបប្រពៃណីដែលមានជំនឿនិងអ្នកដឹកនាំសហគមន៍ក៏អាចផ្តល់ភស្តុតាងពាក់ព័ន្ធផងដែរជាពិសេសប្រសិនបើពួកគាត់ជាមនុស្សស្រី។

### ប្រអប់ ៦

**ឧទាហរណ៍នៃភស្តុតាងក្នុងអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាល**

- ការរៀបរាប់របស់ជនរងគ្រោះពីអ្វីដែលបានកើតឡើង និងជីវិតរស់នៅរបស់ពួកគេ
- កំណត់ត្រាទូរស័ព្ទ ជាពិសេសភស្តុតាង "ខ្សែទូរស័ព្ទចំហ" ដែលទាមទារដោយជនបង្ក
- សំណៅចម្លងសារជាអក្សរក្នុងអ៊ីមែល កំណត់សម្គាល់ដែលមានវិធាន ឬការទាមទារ
- ភស្តុតាងនៃការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត បច្ចេកវិទ្យាឌីជីថល និង បណ្តាញសង្គម
- ភស្តុតាងនៃការប្រទូស្តរាយ
- ធ្លាប់ត្រូវបាននគរបាលទូរស័ព្ទទាក់ទងទៅ
- ជនបង្កដែលរងការចោទប្រកាន់ ធ្លាប់ពាក់ព័ន្ធនឹងនគរបាល
- អំណះអំណាងរបស់មន្ត្រីដើម្បីដាក់បញ្ចូលការសង្កេតឃើញនៅពេលទៅដល់
- គ្រូពេទ្យវះកាត់អ្នករបួសសម្រាប់ការត្រួតពិនិត្យ ប្រសិនបើគ្មានចំណាត់ការភ្លាមៗផ្នែកវេជ្ជសាស្ត្រ
- ភស្តុតាងកោសលវិច័យក្នុងទីតាំង ៖ ស្នាមឈាម អាវុធដែលប្រើប្រាស់
- ភស្តុតាងកោសលវិច័យពីជនរងគ្រោះ និង/ឬជនបង្កដែលរងការចោទប្រកាន់ ៖ ស្នាមក្រញៅ/តម្បារ
- រូបថតស្នាមរបួស ដូចជា របួសលើកំភួនដៃដោយសារការការពារខ្លួន ស្នាមកញ្ចក់ដែលមើលឃើញលើដើមដៃ ស្នាមរលាត់ស្បែកក្បាល កញ្ចុំសក់/រោមដែលជ្រុះបាត់ សញ្ញានៃការច្របាច់/រឹតក
- សំលៀកបំពាក់
- ខ្សែអាត់សំឡេង ឬប្រតិចារិតលេខទូរស័ព្ទសង្គ្រោះបន្ទាន់
- កាមេរ៉ាសុវត្ថិភាព (CCTV) ក្នុងផ្ទះ/ទីសាធារណៈ/កន្លែងផ្សេងទៀត ដូចជា កន្លែងធ្វើការ ភោជនីយដ្ឋាន
- បែបផែនជីវិត និងគ្រួសារ រួមទាំងនៅភស្តុតាងរូបថតនៅកន្លែងកើតហេតុ
- កំណត់ត្រាទំនាក់ទំនងជាមួយសេវានានា ដូចជា សេវាគាំទ្រ (ទោះបីជាផ្នែកខ្លះនៃកំណត់ត្រាទាំងនោះពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើង មុនការប្រព្រឹត្តបទល្មើសថ្មីក៏ដោយ ក៏ក្នុងកាលៈទេសៈមួយចំនួន ខ្លឹមសាររបស់វានៅតែអាចយកជាមូលដ្ឋានក្នុងភស្តុតាងបាន)
- កំណត់ត្រាវេជ្ជសាស្ត្រ
- ឧ. សក្ខីកម្មរបស់សាក្សី គ្រួសារ និងមិត្តភក្តិរបស់ជនរងគ្រោះ អាចផ្តល់ភស្តុតាងស្តីពីផលប៉ះពាល់ និងឥទ្ធិពលនៃការផ្តាច់ជនរងគ្រោះចេញពីគ្រួសារ និង/ឬមិត្តភក្តិ
- ភស្តុតាងពីអ្នកធ្វើការជាមួយ
- ការសាកសួរក្នុងមូលដ្ឋាន ៖ អ្នកជិតខាង អ្នកដឹកជញ្ជូនឥវ៉ាន់ អ្នករត់សំបុត្រ អ្នកលក់ទឹកដោះគោ អ្នកសម្អាតបង្អួច។ល។

- កំណត់ត្រាធនាគារដើម្បីបង្ហាញពីការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ
- ការគំរាមកំហែងពីមុនៗមកលើកុមារ ឬសមាជិកគ្រួសារផ្សេងទៀត
- កំណត់ហេតុរបស់ជនរងគ្រោះ
- ភស្តុតាងនៃការផ្តាច់ខ្លួន ដូចជា កង្វះទំនាក់ទំនងរវាងគ្រួសារ និងមិត្តភក្តិ ជនរងគ្រោះដែលដកខ្លួនពីសកម្មភាពនានា និងថាតើផ្ទះរបស់ជនរងគ្រោះស្ថិតនៅដាច់ពីគេ ឬទេ។
- ទំនាក់ទំនងជាមួយស្ថាប័នផ្សេងទៀត ស្ថាប័នឯកទេស DA ទាំងផ្ទៃក្នុងជាមួយនគរបាល និងខាងក្រៅ
- ខ្សែអាត់/ប្រតិចារិតនៃការសួរចម្លើយ
- ការពិចារណាពីការសួរចម្លើយកុមារ
- DNA ពីជនបង្កដែលរងការចោទប្រកាន់
- ការរក្សាទុក/ការស្តារភស្តុតាងពីបណ្តាញឌីជីថល
- កំណត់ត្រាផ្ទះសម្បែងដើម្បីបញ្ជាក់ពីការកាន់កាប់។

នៅពេលកំណត់រកអ្វីដែលអាចជាភស្តុតាង ការសំខាន់គឺត្រូវពិនិត្យរកអ្វីដែលមើលមិនឃើញ មិនមែនពិនិត្យតែអ្វីដែលមើលឃើញច្បាស់នោះទេ។ ចំណុចនេះអាចមានប្រយោជន៍បំផុតក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលចំណុចសំខាន់គឺការត្រួតត្រាដោយបង្ខំ ដែលជាញឹកញាប់លេចឡើងជាឧប្បត្តិហេតុតូចៗ ដែលប្រព្រឹត្តដោយជនបង្កក្នុងរយៈពេលវែង។ បើពិចារណាដោយឡែកពីគ្នា វាអាចមិនសំខាន់ ប៉ុន្តែជារួមវាអាចផ្តល់ភស្តុតាងយ៉ាងសំខាន់ពាក់ព័ន្ធនឹងការត្រួតត្រាជនរងគ្រោះ។ សូមមើលប្រអប់ ៩ ស្តីពី "ឧទាហរណ៍នៃភស្តុតាងក្នុងអំពើហិង្សាផ្លូវភេទ/អំពើហិង្សាលើដៃគូស្និទ្ធស្នាល"។

ខណៈដែលមន្ត្រីមិនសុទ្ធតែកត់សម្គាល់សញ្ញានៃការរំលោភបំពាន គួរដឹងពីដំណាក់កាលទាំងនេះ និងអ្វីដែលអាចបង្ហាញឡើងដោយជនរងគ្រោះក្នុងពេលឆ្លើយតបនឹងការទូរស័ព្ទចូលរបស់អ្នក។ ខាងក្រោមនេះជាដំណាក់កាលដែលបានកត់សម្គាល់ពីឥរិយាបថបង្ខិតបង្ខំ និងត្រួតត្រាក្នុងទំនាក់ទំនង ដែលបង្កើតឡើងដោយ Graham Goulden នៅ Cultivating Minds UK ៖

- ការល្បួងតាមប្រព័ន្ធអ៊ីនធឺណិត
- ការគ្រប់គ្រងស្ថានភាព
- ការបំភ្លៃការយល់ឃើញ
- ការកំណត់និយមន័យនៃការរំលោភបំពាន
- ការវាយតម្លៃទំនាក់ទំនងឡើងវិញ
- ការបញ្ចប់ទំនាក់ទំនង
- ការបញ្ឈប់ការរំលោភបំពាន។

សូមអាន ឧបសម្ព័ន្ធ ១ សម្រាប់ខ្លឹមសារលម្អិតស្តីពី "ដំណាក់កាលដែលបានកត់សម្គាល់ពីឥរិយាបថបង្ខិតបង្ខំ និងត្រួតត្រាក្នុងទំនាក់ទំនង" របស់ Goulden។

អ្នកត្រូវពង្រឹងសាររបស់អ្នកចំពោះបុគ្គលិករបស់អ្នកថា នគរបាលមានតួនាទីប្រមូល និងវិភាគភស្តុតាងដើម្បីកំណត់អង្គហេតុនិងកំណត់ថាតើការចោទប្រកាន់អាចជឿទុកចិត្តបានឬទេ មិនមែនផ្តោតលើ "ភាពអាចជឿទុកចិត្តបាន" របស់ជនរងគ្រោះឡើយ។ នគរបាលមានតួនាទីជួយជ្រោមជ្រែង និងស៊ើបអង្កេត មិនមែនវិនិច្ឆ័យទេ។

បទល្មើសមួយចំនួនមានសូចនាករជាក់លាក់ដែលបញ្ជាក់ថា មន្ត្រីគួរធ្វើការពិនិត្យពិច័យរកអ្វីដែលបង្កើតបានជា "ភស្តុតាងល្អបំផុត" ក្នុងករណីជាក់លាក់ និងករណីស្មុគស្មាញ។ ការអនុវត្តក្នុងវប្បធម៌ និងការអនុវត្តបែបប្រពៃណីមួយចំនួនអាចមានន័យស្មើនឹងបទល្មើស មិនត្រឹមតែក្នុងប្រទេសមួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងសហគមន៍ដែលមានដើមកំណើតខុសៗគ្នាមកពីប្រទេសម្ចាស់ស្រុកផងដែរ។ ឧទាហរណ៍មួយចំនួននៃបទល្មើសទាំងនេះ រួមមានអំពើហិង្សា/ការរំលោភបំពានផ្អែកតាមកិត្តិយស និងការអនុវត្តដែលបង្កគ្រោះថ្នាក់ ដូចជា ការវះកាត់ប្រដាប់បន្ត

ពួជស្ត្រីនិងអាពាហ៍ពិពាហ៍កុមារនិងអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ។ ព័ត៌មានបន្ថែមស្តីពីបទល្មើសទាំងនេះ និងសូចនាករ មានបង្ហាញក្នុងឧបសម្ព័ន្ធ ២ ស្តីពី "អំពើហិង្សា/ការរំលោភបំពានផ្អែកលើកិត្តិយសនិងការអនុវត្តដែលបង្កគ្រោះថ្នាក់"។

សាក្សីអាចផ្តល់ភស្តុតាងដ៏មានតម្លៃហើយផ្អែកតាមភស្តុតាងទាំងនោះពួកគេអាចបរិយាយឬច្រានចោលការចោទប្រកាន់ណាមួយបាន។ បុគ្គលិករបស់អ្នកមានតួនាទីបង្ហាញភស្តុតាងទាំងអស់ដាក់ជូនតុលាការសម្រេចថាមានឬគ្មានពិរុទ្ធភាព។ ដូច្នេះ ការសំខាន់គឺត្រូវកំណត់អត្តសញ្ញាណអ្នកដែលអាចជាសាក្សីឱ្យបានឆាប់បំផុត ហើយភ្នាក់ងារឆ្លើយតបដំបូងទៅនឹងឧប្បត្តិហេតុ ឬកន្លែងកើតហេតុត្រូវខិតខំប្រមូលព័ត៌មានលម្អិតពីបុគ្គលដែលមានវត្តមានក្នុងឬនៅជិតកន្លែងកើតហេតុទោះបីជាពួកគេនិយាយថាពួកគេមិនបានឃើញអ្វីក៏ដោយ។

នៅពេលព័ត៌មានថ្មីៗលេចឡើងក្នុងពេលស៊ើបអង្កេតអ្នកប្រហែលជាត្រូវជួបបុគ្គលទាំងនេះជាថ្មី ប្រសិនបើជឿថាពួកគេអាចផ្តល់ភស្តុតាងពាក់ព័ន្ធនឹងអ្វីដែលលេចឡើងមិនច្បាស់។ ការច្បាមយកព័ត៌មានលម្អិតពីពួកគេ ត្រូវអនុវត្តដោយផ្តល់សេចក្តីថ្លៃថ្នូរ និងការគោរព និងក្នុងប៉ារ៉ាម៉ែត្រច្បាប់ ដើម្បីធានាការការពារសិទ្ធិរបស់ពួកគេ។ សាក្សីមួយចំនួនប្រហែលជាត្រូវការការគាំទ្រ និង/ឬការសម្របសម្រួលជាក់លាក់ដើម្បីធានាថា ពួកគេអាចផ្តល់ភស្តុតាងដ៏មានតម្លៃបាន។ នេះជាការពិតសម្រាប់សាក្សីដែលមានពិការភាពផ្សេងៗ ឬសាក្សីដែលចាស់ជរា ឬមានវ័យក្មេង។ ក្មេងស្រីមានតម្រូវការពិសេសទៅតាមអាយុរបស់ពួកគេ មិនថាក្នុងនាមជាជនរងគ្រោះ ឬសាក្សីនោះទេ។

---

**ប្រអប់ ៧**

**បញ្ជីត្រួតពិនិត្យស្តង់ដារអប្បបរមាសម្រាប់ការឆ្លើយតបដំបូង**

បំបែកជនរងគ្រោះភ្លាមៗចេញពីជនបង្កដែលរងការចោទប្រកាន់និងធានាសុវត្ថិភាពរបស់ជនរងគ្រោះ។ដោយសារជាញឹកញាប់វាជាស្ថានភាពអំណាច និងស្ថានភាពត្រូតត្រា មន្ត្រីមានតួនាទីធានាថា ភាគីពាក់ព័ន្ធត្រូវបានបំបែកចេញពីគ្នា និងមិនអាចស្តាប់លឺគ្នា ទន្ទឹមនឹងការផ្តោតសំខាន់លើការរក្សាសុវត្ថិភាពរបស់មន្ត្រី។

- កំណត់រក និងរក្សាទុកអាវុធដែលអាចមានក្នុងដៃ ដើម្បីការពារបុគ្គលមានវត្តមានទាំងអស់
- ប្រសិនបើមាន សូមបំបែកចេញ ស្រាវជ្រាវរក និងធានាសុវត្ថិភាពជនបង្កដែលរងការចោទប្រកាន់ ដោយយកគាត់ចេញពីកន្លែងកើតហេតុ
- រៀបចំការព្យាបាលវេជ្ជសាស្ត្រសម្រាប់អ្នកមានរបួស
- បញ្ជាក់អង្គហេតុដំបូងស្តីពីអ្វីដែលបានកើតឡើង និងកំណត់រកបទល្មើស
- ចាប់ផ្តើមកំណត់រក និងប្រមូលអ្វីដែលអាចជាភស្តុតាងនៃបទល្មើស
- ធ្វើការសួរចម្លើយដំបូងជាមួយជនរងគ្រោះ (ការសួរចម្លើយស៊ីជម្រៅអាចធ្វើឡើងនៅពេលក្រោយ រួមទាំងកំណត់ហេតុផ្លូវការនៃបទល្មើស )
- សួរចម្លើយសាក្សីទាំងអស់ និងប្រមូលចម្លើយជាលាយលក្ខណ៍អក្សរទៅតាមភាពចាំបាច់
- រៀបចំការតាមដានបន្ត ឬការស៊ើបអង្កេតបន្ទាប់បន្សំ (ឧ. កោសលវិច័យ ការពិនិត្យផ្នែកវេជ្ជសាស្ត្រ)
- ទាក់ទងទៅសេវាជនរងគ្រោះ (ប្រសិនបើមាន) ដើម្បីជួយដល់ការការថែទាំ និងការគាំទ្រជនរងគ្រោះ
- ចាប់ផ្តើមចងក្រងឯកសារស្តីពីការស៊ើបអង្កេត ភស្តុតាង និងចម្លើយ។

ប្រភព ៖ សៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី (UNODC ២០១០)

---

សូមមើលជំពូកទី ៤ (ទំនាក់ទំនងដំបូង) និងជំពូកទី ៩ (ទំនាក់ទំនង) សម្រាប់គន្លឹះនៃការនិយាយជាមួយកុមារ ចាស់ជរា ស្ត្រី និងក្មេងស្រីមានពិការភាព និងបុគ្គលផ្សេងទៀតដែលមានតម្រូវការជាក់លាក់។ សូមមើលផងដែរ ជំពូកទី ២ សម្រាប់និយមន័យនៃ "ភាពប្រទាក់ក្រឡាគ្នា"។

ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ខ្ពស់នៅពេលដែលជនរងគ្រោះ ឬសាក្សី ជាជនចាស់ជរា នៅក្មេង ឬមានពិការភាព ព្រោះពួកគាត់អាចមានតម្រូវការជាក់លាក់។ ឧ.ប្រសិនបើជនរងគ្រោះឬសាក្សីជាជនចាស់ជរា ពួកគាត់អាចខ្សោយក្នុងការស្តាប់។ ក្នុងករណីនេះ ត្រូវធានាថាបុគ្គលិករបស់អ្នកនិយាយជាមួយពួកគាត់នៅកន្លែងស្ងាត់ដែលមិនសូវមានសំឡេងរំខាន។ ប្រសិនបើពួកគាត់មើលមិនសូវច្បាស់ គួរនិយាយជាមួយពួកគាត់ក្នុងបន្ទប់ដែលមានពន្លឺគ្រប់គ្រាន់ (អាចនៅកន្លែងដែលមានពន្លឺបន្ថែម)។

ក្រៅពីនេះ ពួកគាត់អាចមានបញ្ហាចងចាំដោយសារវ័យ និងអាចរងផលប៉ះពាល់កាន់តែខ្លាំងដោយសារការប៉ះទង្គិចផ្លូវចិត្ត។ ដូច្នេះ បុគ្គលិករបស់អ្នកត្រូវមានភាពអំណត់ និងយល់ពីតម្រូវការបន្ថែមរបស់ពួកគាត់ និងធានាថា ពួកគាត់ពិចារណាពីពិការភាពរបស់ជនរងគ្រោះដើម្បីឱ្យមានការគិតគូរពីតម្រូវការជាក់លាក់របស់ជនរងគ្រោះម្នាក់ៗ និងត្រូវធ្វើការកែសម្រួលទៅតាមភាពជាក់ស្តែង។

ស្ត្រី និងក្មេងស្រីមានពិការភាពដែលប្រឈមនឹងអំពើហិង្សា និងការរើសអើង ក៏ប្រឈមនឹងឧបសគ្គក្នុងការទទួលបានយុត្តិធម៌ផងដែរដោយសារតែផ្នត់គំនិតអវិជ្ជមានឥរិយាបថរើសអើង និងកង្វះការសម្របសម្រួលផ្នែកនីតិវិធី និងសមហេតុផលដែលអាចនាំទៅរកមន្ទិលសង្ស័យលើភាពអាចជឿទុកចិត្តបាន និងការប្រមាថការចោទរបស់ពួកគាត់[147]។

សម្រាប់ការណែនាំល្អៗស្តីពីការសួរចម្លើយជនរងគ្រោះមានដែលពិការភាព ដែលរងការចោទប្រកាន់ សូមមើលឯកសាររបស់ UNDP "ការស៊ើបអង្កេត ការការពារ និងវិធានការគាំទ្រសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ - សៀវភៅធនធាន ៖ បទពិសោធន៍និងគោលការណ៍ណែនាំរបស់នគរបាលកូរ៉េ (២០១៩)"[148] ។ ពាក់ព័ន្ធនឹងការសួរចម្លើយជនមានពិការភាព(រួមទាំងកុមារ) សៀវភៅធនធាននេះផ្តល់ការណែនាំទូទៅស្តីពី១)ការរៀបចំការសួរចម្លើយ ២) ទំនាក់ទំនងជាពាក្យសម្តី និងមិនមែនពាក្យសម្តីនិង៣)លក្ខណៈនៃពិការភាពដើម្បីជួយឱ្យមន្ត្រីនគរបាលយល់ពីការពិចារណាចាំបាច់ក្នុងដំណើរការសួរចម្លើយ។



សៀវភៅ ធនធានរបស់ UNDP លើកឡើងថា ត្រូវប្រឈមជាមួយកុមារដោយផ្អែកតាមអាយុរបស់ពួកគេព្រោះកុមារមានការអភិវឌ្ឍនៅដំណាក់កាលផ្សេងៗ។ កុមារអាយុក្រោម ១០ ឆ្នាំងាយរងគ្រោះខ្លាំងជាងគេ។

ដូច្នេះ ត្រូវមានការសម្របសម្រួលសមស្រប និងការរៀបចំជាក់លាក់ផ្សេងទៀតនៅពេលគ្រប់គ្រងករណីដែលជនរងគ្រោះ ឬសាក្សីមានពិការភាព ដើម្បីដោះស្រាយឧបសគ្គប្រឈមរបស់ជនរងគ្រោះមានពិការភាព ក្នុងដំណើរការយុត្តិធម៌[149]។

ឧ. កម្មវិធី SAVE របស់ Cape Mental Health នៅអាហ្វ្រិកខាងត្បូង មានគោលបំណងគាំទ្រដល់ជនរងគ្រោះដែលមានពិការភាពផ្នែកបញ្ញាស្មារតី [150]។ សម្រាប់ការណែនាំបន្ថែម សូមមើលគោលការណ៍ណែនាំរបស់UNFPA និង Women Enabled International ស្តីពីការផ្តល់ការឆ្លើយតបទៅនឹងអំពើហិង្សាដែលផ្អែកតាមសិទ្ធិនិងឆ្លើយតបនឹងយេនឌ័រ សិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ[151]។

សម្រាប់ព័ត៌មានបន្ថែមស្តីពីរបៀបប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ និងសាក្សីជាកុមារ សូមមើលជំពូកទី ៩ (ទំនាក់ទំនង)។

147. Lisa Adams and Yumi Sera, 'Gender Guidelines'). Disability Rights Fund & Disability Rights Advocacy Fund (2018)

148. ការស៊ើបអង្កេត ការការពារ និងវិធានការគាំទ្រសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ-សៀវភៅធនធាន៖បទពិសោធន៍និងគោលការណ៍ណែនាំរបស់នគរបាលកូរ៉េ (មជ្ឈមណ្ឌលនគរបាលសេអ៊ូល UNDP ២០១៩)។

149. សារណាដាក់ជូនអ្នករាយការណ៍ពិសេសទទួលបន្ទុកជនមានពិការភាព ៖ ការអនុវត្តល្អសម្រាប់ការបង្កើតលទ្ធភាពដែលមានប្រសិទ្ធភាពក្នុងការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងក្មេងស្រីមានពិការភាព ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៩ Women Enabled International។

150. See https://www.westerncape.gov.za/facility/cape-mental-health

151. "ស្ត្រី និងយុវជនមានពិការភាព ៖ គោលការណ៍ណែនាំសម្រាប់ការផ្តល់សេវាផ្អែកតាមសិទ្ធិ និងឆ្លើយតបនឹងយេនឌ័រដើម្បីដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ" (UNFPA-WEI ២០១៨)។ សូមមើល https://www.womenenabled.org/wei-unfpa-guidelines.html។

ប្រអប់ ១១ ផ្ដល់ការលើកឡើងមួយចំនួន[152] ស្ដីពីថាតើបុគ្គលិករបស់អ្នកអាចបង្ហាញសេចក្ដីថ្លៃថ្នូរ និងសមានចិត្ត ចំពោះកុមារដែលជាជនរងគ្រោះ និងសាក្សីនៃបទល្មើសដោយរបៀបណា។

**ប្រអប់ ៤**

**ការបង្ហាញសេចក្ដីថ្លៃថ្នូរ និងសមានចិត្តចំពោះកុមារដែលជាជនរងគ្រោះ និងសាក្សីនៃបទល្មើស**

| | |
|---|---|
| **សន្តិសុខ** | ជ្រើសរើសកន្លែងដែលមានសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដើម្បីជួប និង/ឬសួរចម្លើយកុមារ។ ប្រសិនបើគ្មានកន្លែងដូច្នេះទេ សូមជ្រើសរើសទីតាំងដែលផ្ដល់ភាពងាយស្រួល និងគិតគូរពីកុមារតាមដែលអាចធ្វើទៅបាន។ |
| **មិនប្រឈមនឹងបញ្ហា** | បញ្ជាក់ដល់កុមារ ជាពិសេសប្រសិនបើគាត់នៅក្មេងថា គាត់មិនបានធ្វើអ្វីខុសទេ និងមិន "ប្រឈមនឹងបញ្ហា" ឡើយ។ ជាញឹកញាប់ កុមារតូចដែលជាជនរងគ្រោះ និងសាក្សីយល់ថា ពួកគេអាចត្រូវបានស្ដីបន្ទោសដោយសារបញ្ហាដែលកើតឡើង និង/ឬយល់ថា ជាអ្នកទទួលខុសត្រូវលើអ្វីដែលពួកគេរងគ្រោះ។ ពន្យល់ប្រាប់កុមារឱ្យបានច្បាស់ថា ជនដែលបង្កគ្រោះថ្នាក់លើពួកគេ ជាអ្នកបំពានច្បាប់។ កុមារមិនមែនជាអ្នកទទួលខុសត្រូវ ឬមិនគួរយល់ថា ខ្លួនឯងជាអ្នកទទួលខុសត្រូវលើឥរិយាបថ និងការប្រព្រឹត្តខុសរបស់អ្នកដទៃឡើយ។ |
| **ទំនុកចិត្ត និងទំនាក់ទំនងល្អ** | ចំណាយពេលកសាងទំនុកចិត្ត និងទំនាក់ទំនងល្អ មុននឹងពិភាក្សាលើចំណុចជាក់លាក់នៃករណី ឬឧប្បត្តិហេតុ ដោយស្ដាប់កុមារ និងទុកឱកាសឱ្យគាត់សួរសំណួរ និងបញ្ចេញគំនិតទៅតាមបំណង។ ជាទូទៅ កុមារដែលជាជនរងគ្រោះ និងសាក្សី មានសំណួរ កង្វល់ និងការភ័យខ្លាចជាច្រើន។ ពួកគេងាយនឹងសហការ និងមានអារម្មណ៍ធូរស្រាល ប្រសិនបើពួកគេយល់ថា មានអ្នកជំនាញស្ដាប់កង្វល់ និងគំនិតរបស់ពួកគេ។ |
| **សមានចិត្ត** | រក្សាឥរិយាបថមិនវិនិច្ឆ័យ និងបង្ហាញសមានចិត្តចំពោះកុមារ។ |
| **ការគោរព** | ដោយសារការរងគ្រោះ កុមារដែលជាជនរងគ្រោះ និងជាសាក្សី អាចងាយប៉ះពាល់អារម្មណ៍ដោយសារឥរិយាបថមិនគោរពណាមួយ។ គួរនិយាយស្ដីដោយប្រុងប្រយ័ត្ន។ |
| **ភាពលេចធ្លោ** | ប្រព្រឹត្តចំពោះកុមារក្នុងនាមជាបុគ្គលម្នាក់ដែលមានតម្រូវការបំណងប្រាថ្នាអារម្មណ៍និងកង្វល់ជាក់លាក់។ មិនត្រូវប្រៀបធៀបកុមារម្នាក់ជាមួយកុមារផ្សេងទៀតឡើយ មិនសូម្បីតែលើកឧទាហរណ៍។ |
| **គិតគូរពីអាយុ** | ដឹងថា ផ្លូវចិត្តរបស់កុមារដែលជាជនរងគ្រោះ និងជាសាក្សីងាយនឹងចុះខ្សោយក្នុងពេលតានតឹង។ ទង្វើរបស់ពួកគេ អាចនៅខ្ចីជាងវ័យ។ ឧ. ជនរងគ្រោះដែលមានអាយុ ៨ ឆ្នាំ អាចនៅជញ្ជក់មេដៃ។ |
| **ភាសាសមស្រប** | ប្រើភាសាដែលគិតគូរពីកុមារ និងសមស្របទៅតាមអាយុរបស់ពួកគេ។ កុំនិយាយ "ដូចក្មេង"។ |
| **ការលេងកំសាន្ត** | អនុញ្ញាតឱ្យជនរងគ្រោះ និងសាក្សីដែលមានវ័យក្មេង និងក្នុងករណីសមស្រប អនុញ្ញាតឱ្យកុមារធំលេងកំសាន្ត។ លើកទឹកចិត្តឱ្យពួកគេពន្យល់ពីអ្វីដែលបានកើតឡើងតាមរបៀបលេងកំសាន្ត ដោយប្រើតុក្កតា ឬសត្វញាត់សំឡី ឬគំនូរ ឬការផាត់ពណ៌។ |
| **ចំណាយពេលស្ដាប់** | ចំណាយពេលគ្រប់គ្រាន់ដើម្បីស្ដាប់កុមារនិងស្វែងយល់ពីអ្វីដែលបានកើតឡើងចំពោះគាត់។ប្រសិនបើកុមារអាចនិយាយអ្វីទៅតាមបំណងរបស់ខ្លួន គេអាចដោះស្រាយស្ថានភាពនោះបានកាន់តែល្អ។ |
| **ការពិចារណាពីទស្សនៈយល់ឃើញ** | ប្រសិនបើអាច សូមរួមបញ្ចូលកុមារក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការពិភាក្សាដោះស្រាយបញ្ហា។ កំណត់រក និងមានភាពអំណត់ក្នុងការឆ្លើយសំណួររបស់កុមារដើម្បីឱ្យគាត់អាចបង្ហាញទស្សនៈ និងកង្វល់ដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ។ |

152. កម្មវិធីបណ្ដុះបណ្ដាលស្ដីពីការប្រព្រឹត្តចំពោះកុមារដែលជាជនរងគ្រោះ និងសាក្សីនៃបទល្មើស" (UNODC ២០១៥)។ សូមមើល https://www.unodc.org/documents/justice-and-prison-reform/Training_Programme_on_the_Treatment_of_Child_Victims_and_Child_Witnesses_of_Crime_-_Law_Enforcement.pdf ទំ. ៤៤ ។

តួនាទីរបស់អ្នកក្នុងនាមជាអ្នកគ្រប់គ្រង ឬអ្នកដឹកនាំគឺត្រូវធានាថា ការស៊ើបអង្កេតឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើម និងនៅតែផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងទាមទារនូវការពិនិត្យពិច័យលើការស៊ើបអង្កេត និងដំណើរការគ្រប់គ្រងករណីតាមរយៈការធានាការត្រួតពិនិត្យដោយប្រសិទ្ធភាព និងសមស្រប។ ការត្រួតពិនិត្យជាអ្វីដែលចាំបាច់ក្នុងការធានាកិច្ចស៊ើបអង្កេតទៅតាមស្តង់ដារក្រមសីលធម៌ និងសុចរិតភាព។

ក្នុងនាមជាអ្នកដឹកនាំ អ្នកគួរលើកទឹកចិត្ត ផ្តល់ការគាំទ្រ និងងាយស្រួលទាក់ទងប៉ុន្តែនៅតែអាចរក្សាការទទួលខុសត្រូវរបស់បុគ្គល។

- តើអ្នកធានាបានថាបុគ្គលិករបស់អ្នកធ្វើការងារទៅតាមក្តីរំពឹងទុករបស់អ្នក និងក្តីរំពឹងទុករបស់ស្ថាប័នអ្នកដោយរបៀបណា?
- តើអ្នកធានាការរក្សាឯកជនភាពនិងការរក្សាការសម្ងាត់ដោយរបៀបណា?

សម្រាប់ព័ត៌មានបន្ថែមស្តីពីអ្វីបង្កើតបានជាអភិក្រម"ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ" សូមមើលជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម"។

សូមពិចារណាចំណុចខាងក្រោម ៖

- តើអ្នកធានាការត្រួតពិនិត្យសំណុំរឿងមុនបញ្ជូនទៅដំណាក់កាលបន្ទាប់នៃដំណើរការយុត្តិធម៌ដោយរបៀបណា?
- តើអ្នកបានដឹងពីអ្វីដែលជាភាពខ្វះចន្លោះក្នុងការស៊ើបអង្កេតដែលអាចនាំទៅរកការបញ្ឈប់ការផ្តន្ទាទោស ឬការសម្រេចឱ្យរួចពីការចោទប្រកាន់ ឬទេ?
- តើប៉ុស្តិ៍នគរបាលឬនាយកដ្ឋានរបស់អ្នកអនុវត្តការងារបានល្អកម្រិតណា ធៀបនឹងប៉ុស្តិ៍នគរបាល ឬនាយកដ្ឋានផ្សេងទៀត?
- តើអ្នក ឬបុគ្គលិករបស់អ្នកបានជួបជាប្រចាំជាមួយអយ្យការ ឬមន្ត្រីតុលាការ ដើម្បីពិភាក្សាពីតម្រូវការ និងក្តីរំពឹងទុករបស់អ្នកឬទេ? វាជាការល្អក្នុងការជំរុញការចូលរួមរបស់ស្ថាប័នយុត្តិធម៌ផ្សេងទៀតឱ្យបានឆាប់បំផុតក្នុងការរៀបចំសំណុំរឿង។ នៅប្រទេសមួយចំនួននគរបាលនិងអយ្យការដែលធ្វើការលើករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបំពេញការងារក្នុងទីតាំងជាមួយគ្នា ដើម្បីផ្តល់ឱកាសសម្រាប់កិច្ចសន្ទនាជាបន្តបន្ទាប់ទៅវិញទៅមក និងពង្រឹងជំនាញឯកទេសឆ្ពោះទៅរកការសម្រេចឱ្យរួចពីការចោទប្រកាន់តិចតួចបំផុត។ ក្រៅពីនេះគួរកាត់បន្ថយចំនួនដងនៃការសួរចម្លើយជនរងគ្រោះ ដើម្បីកាត់បន្ថយលទ្ធភាពនៃការរងគ្រោះជាលើកទីពីរ ក៏ដូចជាបង្កើនទំនុកចិត្តនិងភាពជឿជាក់របស់ជនរងគ្រោះលើប្រព័ន្ធយុត្តិធម៌។
- តើអ្នកធានាដូចម្តេចថាមាន "មេរៀន" ពីករណីដែលមិនបំពេញលក្ខណៈវិនិច្ឆ័យនៃការកាត់ទោស?
- តើមានករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីប៉ុន្មានភាគរយដែលពុំបានទៅដល់តុលាការ?
- តើអ្វីជាហេតុផលនៅពីក្រោយបញ្ហានេះ?

ដើម្បីឱ្យអ្នកអាចឆ្លើយសំណួរទាំងនេះបាន អ្នកត្រូវវិភាគទិន្នន័យដែលអ្នកស្នើសុំពីអយ្យការ ឬមន្ត្រីតុលាការ តាមរយៈការសម្របសម្រួល និងកិច្ចសហការ (សូមមើលជំពូកទី ៨ ៖ ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌)។

រហូតដល់ពេលវិភាគទិន្នន័យសំណុំរឿង តើអ្នកមានទំនុកចិត្តកម្រិតណាថា ការស៊ើបអង្កេតរបស់នគរបាលផ្តល់ភស្តុតាងពេញលេញ? អ្នកអាចមានការផ្លាស់ប្តូរមួយចំនួន ដូចជា ការចេញសេចក្តីណែនាំថ្មីដល់បុគ្គលិករបស់អ្នក។ ប៉ុន្តែប្រសិនបើអ្នកមិនបានពិនិត្យទិន្នន័យទាំងនោះទេអ្នកប្រហែលជាមិនអាចកត់សម្គាល់បញ្ហាបានឡើយ។

ដើម្បីធានាការបន្តអភិវឌ្ឍវិជ្ជាជីវៈ អ្នកត្រូវដឹងពីចំណុចខ្សោយក្នុងការទទួលខុសត្រូវរបស់អ្នកហើយការទទួលនិងដោះស្រាយបណ្តឹងសាធារណៈគឺជាយន្តការមួយសម្រាប់ការទទួលបានព័ត៌មាន។ នៅពេលយល់ពីបញ្ហាទាំងនេះ អ្នកមានលទ្ធភាពកាន់តែច្រើនក្នុងការផ្តល់ការណែនាំច្បាស់លាស់ដល់បុគ្គលិករបស់អ្នកនិងធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីកសាងទំនុកចិត្ត និងភាពជឿជាក់ក្នុងសហគមន៍មូលដ្ឋានរបស់អ្នក។

- តើអ្នកមាននីតិវិធីអ្វីខ្លះដើម្បីអាចឱ្យជនរងគ្រោះ ដាក់បណ្តឹងផ្លូវការចំពោះភាពសកម្ម ឬភាពអសកម្មរបស់នគរបាល ពាក់ព័ន្ធនឹងរបាយការណ៍របស់ពួកគេ?
- តើដំណើរការនេះផ្តល់ភាពងាយស្រួលកម្រិតណា?

តើអ្នកបានផ្សព្វផ្សាយពីដំណើរការនេះក្នុងសហគមន៍របស់អ្នក ឬទេ ?

ការគ្រប់គ្រងនិងត្រួតពិនិត្យការស៊ើបអង្កេតមិនផ្ដោតលើការគ្រប់គ្រងសកម្មភាពបុគ្គលិករបស់អ្នកនោះទេប៉ុន្តែអ្នកទទួលខុសត្រូវលើលទ្ធផលចំពោះមុខថ្នាក់គ្រប់គ្រងជាន់ខ្ពស់ក៏ដូចជាសហគមន៍មូលដ្ឋាន។អ្នកត្រូវបង្ហាញភាពជាអ្នកដឹកនាំ ដោយបង្កើនភាពអង់អាច និងផ្ដល់លទ្ធភាពដល់មន្ត្រីរបស់អ្នក តាមរយៈការបង្វឹកបង្ហាត់ ការណែនាំ និងក្នុងករណីចាំបាច់រក្សាការទទួលខុសត្រូវលើសកម្មភាព ឬការធ្វេសប្រហែសរបស់ពួកគេ។ ធ្វើដូច្នេះទើបអ្នកអាចបញ្ជូនសារច្បាស់លាស់ពាក់ព័ន្ធនឹងក្ដីរំពឹងទុករបស់អ្នក ហើយពួកគេនឹងយល់ពីអ្វីដែលពួកគេត្រូវធ្វើ។

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្ដើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីការគូសផែនទីជាសកលស្ដីពីការអនុវត្តល្អនិងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលឆ្លើយតបនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ និងបុគ្គលិករបស់អង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាលនិងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និង ក្មេងស្រី។ ចំណងជើងរងនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាន និង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

### ឥរិយាបថ

- ការយល់ឃើញជាទូទៅថាការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈគឺលំបាកណាស់និងថាវាជាកិច្ចការឯកទេស[153]។
- ជាញឹកញាប់ ជនមានពិការភាពត្រូវបានពិពណ៌នាថាប្រៀបដូចទារក ពឹងផ្អែក និងមិនអាចសម្រេចចិត្តដោយខ្លួនឯងបាន។ ការយល់ដូច្នេះច្បាស់បង្កើនការមាក់ងាយ និងភាពភ័យខ្លាច។

### ភាពលម្អៀងយេនឌ័រ

- ជំនឿលើការយល់ខុសជុំវិញអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា ជំនឿថា មន្ត្រីបញ្ជាការបានដឹងពីការចោទប្រកាន់អំពើហិង្សាផ្លូវភេទដែលបង្កឡើងដោយនគរបាល ប៉ុន្តែគ្មានការដោះស្រាយ (សូមមើលចំណុចខាងក្រោម ស្ដីពីលទ្ធផលទូទៅនៃភាពលម្អៀងយេនឌ័ររបស់កងកម្លាំងនគរបាលដែលរកឃើញដោយក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក)
- ការយល់ខុសពាក់ព័ន្ធនឹង "ឥរិយាបថល្អរបស់ជនរងគ្រោះជាពិសេសក្នុងបទល្មើសអំពើហិង្សាផ្លូវភេទលើស្ត្រី និងក្មេងស្រី ដែលអាចមានផលប៉ះពាល់" ដល់គុណភាពនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាល
- មន្ត្រីនគរបាលអាចនឹងស្ដីបន្ទោសជនរងគ្រោះ ព្រោះជឿថា ជនរងគ្រោះជាអ្នកបំផុសឱ្យមានការវាយប្រហារតាមរយៈការស្លៀកពាក់ ឬការប្រព្រឹត្តរបស់គាត់។

### ការរងគ្រោះលើកទីពីរ

- ជនរងគ្រោះត្រូវបានសួរចម្លើយជាច្រើនដងដោយមន្ត្រីនគរបាលជាបុរស និងមិនទទួលបានការគោរពនៅពេលផ្ដល់ចម្លើយ។

### ការអនុវត្តខុសឆ្គង

- ជាញឹកញាប់នគរបាលស៊ើបអង្កេតដាក់បន្ទុកភស្តុតាងលើជនរងគ្រោះ ដើម្បីបញ្ជាក់ថា ជនរងគ្រោះរងការគំរាមកំហែង ឬប្រឈមនឹងអំពើហិង្សា (ឧ. មិនផ្ដល់ការយល់ព្រម) ក្នុងករណីប្រទូស្តកេរខ្មាស ជាជាងផ្ដោតលើសកម្មភាពរបស់ជនបង្កដែលរងការចោទប្រកាន់ដើម្បីបញ្ជាក់ថាគាត់ទទួលបានការយល់ព្រមពីជនរងគ្រោះ។
- ការធ្វើចំណាត់ថ្នាក់មិនត្រឹមត្រូវ ឬការរាយការណ៍ពីចំនួនករណីប្រទូស្តកេរខ្មាស ឬអំពើហិង្សាក្នុងគ្រួសារក្រោមចំនួនករណីពិតប្រាកដ ឬការសន្និដ្ឋានមិនសម

153. Erin Gallagher, 'SGBV Investigation Planning', Institute for International Criminal Investigations (IICI) and the Justice Rapid Response (2015).

ស្របថាករណីប្រទូស្តកេរខ្មាសគ្មានមូលដ្ឋានបញ្ជាក់។ ឧ. ក្នុងករណីរាយការណ៍ពីការបាត់ខ្លួនស្ត្រី ឬក្មេងស្រី ជំទង់ជាញឹកញាប់នគរបាលរង់ចាំការបញ្ជាក់ថាពិតជាមានការប្រព្រឹត្តបទល្មើសមួយមុននឹងផ្តល់ការឆ្លើយតប។

- ធនធានមិនគ្រប់គ្រាន់ ដូចជា មធ្យោបាយដឹកជញ្ជូនជនរងគ្រោះទៅគោលដៅត្រឹមត្រូវនាំឱ្យនគរបាលទារប្រាក់ពីជនរងគ្រោះជាថ្នូរនឹងការបំពេញតួនាទីទប់ស្កាត់ និងស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ប្រព័ន្ធគ្រប់គ្រងករណីមិនត្រូវបានដាក់បញ្ចូលឱ្យបានគ្រប់គ្រាន់ ធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំ និងផ្តល់ភាពងាយស្រួលដល់ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដែលទទួលខុសត្រូវលើការតាមដានជនរងគ្រោះ។
- មន្ត្រីអាចផ្តោតសំខាន់លើការស៊ើបអង្កេត ជាជាងសុខុមាលភាពរបស់ជនរងគ្រោះតាមរយៈការប្រើប្រាស់ជនរងគ្រោះជាប្រភពព័ត៌មាន ឬភស្តុតាង[154]។
- ពិធីសារសម្រាប់ការចែករំលែកព័ត៌មាន ជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតដើម្បីធានាការចែករំលែកព័ត៌មានពាក់ព័ន្ធទាន់ពេលវេលា គឺជាទូទៅគ្មានការពិនិត្យរកភាពអនុលោមតាម និងការរៀនសូត្រ។

## ការរើសអើង

- ជនរងគ្រោះដែលមានពិការភាព ឬមិនចេះអក្សរ គឺជាញឹកញាប់មិនទទួលបានការគាំទ្រគ្រប់គ្រាន់នៅពេលរាយការណ៍ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសនៅពេលចុះហត្ថលេខាលើអំណះអំណាងដែលមានផលវិបាកធ្ងន់ធ្ងរក្នុងផ្លូវច្បាប់[155]។

## ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ

- នគរបាលមិនសូវមានចំណេះដឹងស្តីពីរបៀបគាំទ្រដល់ជនរងគ្រោះ ដោយសារអំពើរំលោភសេពសន្ថវៈក្នុងរយៈពេលឆ្លើយតប ៧២ ម៉ោង (ឧ. បង្ការមេរោគអេដស៍ ការមានផ្ទៃពោះ) ដែលជាសេវាដែលផ្តល់ដោយមន្ទីរពេទ្យ។
- ការបណ្តុះបណ្តាលស្តីពីអន្តរាគមន៍ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត គឺជាញឹកញាប់មិនត្រូវបានដាក់បញ្ចូលក្នុងការបណ្តុះបណ្តាល និងការអប់រំមន្ត្រីគ្រប់រូបដែលអាចពាក់ព័ន្ធជាមួយនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីនោះទេ។
- កង្វះការយល់ដឹងទូទៅស្តីពីច្បាប់ជាតិដែលពាក់ព័ន្ធនឹងការការពារទិន្នន័យបុគ្គលដោយមន្ត្រី។

### ប្រអប់ ៩

**លទ្ធផលទូទៅពីភាពលម្អៀងយេនឌ័ររបស់កងកម្លាំងនគរបាល***

- មិនសូវផ្តល់ការការពារដល់ជនរងគ្រោះមួយចំនួនដោយសារយេនឌ័រ
- មិនឆ្លើយតបនឹងបទល្មើសដែលបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់មនុស្ស ដែលមានយេនឌ័រជាក់លាក់
- មន្ត្រីផ្តល់សេវាតិចតួច ឬមិនជាប់លាប់ ដោយសារផ្នត់គំនិតយេនឌ័រ
- ការធ្វើចំណាត់ថ្នាក់មិនត្រឹមត្រូវ ឬការរាយការណ៍ពីចំនួនករណីប្រទូស្តកេរខ្មាស ឬអំពើហិង្សាក្នុងគ្រួសារក្រោមចំនួនករណីពិតប្រាកដ
- សន្និដ្ឋានដោយមិនសមស្របថាករណីប្រទូស្តកេរខ្មាសគ្មានមូលដ្ឋានបញ្ជាក់
- មិនបានធ្វើតេស្តលើឃីត សម្រាប់ស្រាវជ្រាវករណីប្រទូស្តកេរខ្មាស
- សួរចម្លើយ ជាជាងសម្ភាសជនរងគ្រោះ និងសាក្សី
- ចាត់ទុកអំពើហិង្សាក្នុងគ្រួសារជាបញ្ហាគ្រួសារជាជាងបទល្មើស
- ខកខានមិនពង្រឹងដីកាការពារ
- ខកខានមិនចាត់ទុកអំពើហិង្សាក្នុងគ្រួសាររវាងមនុស្សមានភេទដូចគ្នា ជាបទល្មើស
- រារាំងសមត្ថភាពក្នុងការបញ្ជាក់អង្គហេតុកំណត់ថាតើឧប្បត្តិហេតុមួយគឺជាបទល្មើស ឬទេ និងបង្កើតករណីដែលគាំទ្រដល់ការផ្តន្ទាទោសដោយប្រសិទ្ធភាព និងរក្សាការទទួលខុសត្រូវរបស់ជនបង្ក។

ប្រភព ៖ ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ២០១៥

154. Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police–victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research, 18:1, 75-86, DOI: 10.1080/15614263.2016.1230061.
155. "ឯកសារជំនួយស្មារតីអ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌" (UN Women et al., 2018)

## និយមន័យ និងគ្របខណ្ឌ

កញ្ចប់សេវាសំខាន់ៗ ពិពណ៌នាដំណើរការនៃការស៊ើបអង្កេតរបស់នគរបាលលើឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលរួមបញ្ចូលសកម្មភាពដូចខាងក្រោម ៖

- ការវាយតម្លៃករណី និងការស៊ើបអង្កេត ដែលជាទូទៅធ្វើឡើងក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ
- ការគ្រប់គ្រងកន្លែងកើតហេតុ
- ការរៀបចំផែនការស៊ើបអង្កេត
- ការសួរចម្លើយជនរងគ្រោះ និងសាក្សី
- ការកំណត់រក ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ
- ការប្រមូល ដំណើរការ និងវិភាគភស្តុតាង
- ការពិនិត្យកោសល្យវិច័យ
- ចារកម្មពាក់ព័ន្ធនឹងជនបង្កដែលរងការចោទប្រកាន់ និងទីតាំងដដែលៗ
- ការកំណត់អត្តសញ្ញាណជនបង្កដែលរងការចោទប្រកាន់ ការសួរចម្លើយការចាប់ខ្លួននិងដំណើរការសំណុំរឿងនិង
- ការចងក្រងឯកសារស្តីពីលទ្ធផលរកឃើញនិងសកម្មភាពដែលបានធ្វើឡើង។

ចំណុចសំខាន់ក្នុងដំណើរការនេះគឺការញែកឱ្យដាច់រវាងបុគ្គលដែលជាជនបង្ក និងអ្នកដែលជាជនរងគ្រោះ និងផ្តល់ទំនាក់ទំនងផ្សេងពីគ្នា[156]។ ការធ្វើដូច្នេះនឹងអាចឱ្យមន្ត្រីស៊ើបអង្កេតកំណត់រកវិសាលភាពផ្សេងៗនៃការរងគ្រោះរបស់ជនរងគ្រោះ និងការការពារដែលផ្តល់ជូនដែលជាជំហានដ៏សំខាន់មួយនៅពេលផ្តួចផ្តើមអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ[157]។ ក្រៅពីនេះ វាជួយឱ្យអ្នកស៊ើបអង្កេតកំណត់រកគំរូនៃឥរិយាបថបំពានលើជនរងគ្រោះនិងអថេរបរិយាកាសដែលជះឥទ្ធិពលលើឫសគល់នៃអំពើហិង្សា។

---

**ប្រអប់ ១០**

Virtual Knowledge Centre to End Violence against Women and Girls

**ឧទាហរណ៍នៃការមិនបង្កគ្រោះថ្នាក់***

នគរបាលគួរពិចារណាថាតើសកម្មភាពនិងទំនាក់ទំនងរបស់ខ្លួនជួយពង្រឹងដោយអចេតនានូវផ្នត់គំនិតមិនល្អក្នុងប្រពៃណីស្តីពីបុរស និងស្ត្រីដែលរួមចំណែកដល់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ។

ក្រៅពីនេះ នគរបាលគួរគិតគូរពីការស្តែងចេញដោយអចេតនានូវឥរិយាបថរើសអើងយេនឌ័រផ្សេងទៀត (ដូចជាបុរសដែលយល់ថាពួកគេត្រូវ "ការពារ" ស្ត្រី តាមរយៈការរឹតត្បិតចល័តភាព សេរីភាព ឬឯកជនភាពរបស់នាង) ឬទស្សនៈប្រឆាំងសមភាព (ដូចជា ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា) ដែលលេចឡើងនៅពេលខ្លះ។
របៀបបញ្ចៀសការបង្កគ្រោះថ្នាក់ ៖

- ធានាថាអន្តរាគមន៍ផ្តោតលើការការពារសុវត្ថិភាពនិងសុខុមាលភាពរបស់ជនរងគ្រោះដោយផ្អែកតាមបទពិសោធន៍ចម្រុះរបស់ស្ត្រី និងក្មេងស្រីក្នុងសហគមន៍ និងអ្នកជំនាញក្នុងវិស័យអំពើហិង្សាលើស្ត្រី និងក្មេងស្រី
- ធានាថា អភិក្រម និងសកម្មភាព មានភាពសមស្របទៅតាមវប្បធម៌ តាមរយៈការជំរុញការចូលរួមរបស់អង្គការ និងបុគ្គលក្នុងមូលដ្ឋាន (ទាំងពីរភេទ) ដែលមានចំណេះដឹងអំពីបរិបទ និងលទ្ធផលនៃអន្តរាគមន៍កន្លងមក។
- ជំរុញការចូលរួមរបស់បុរសនិងក្មេងប្រុសក្នុងការបង្កើតសារយុទ្ធនាការឯកសារ/សម្ភារផ្សព្វផ្សាយនិងផលិតផល ឬអន្តរាគមន៍សំខាន់ៗផ្សេងទៀត
- ធ្វើការសាកល្បងតាមមូលដ្ឋាននូវរាល់ឯកសារ/សម្ភារផ្សព្វផ្សាយ ជាមួយក្រុមគោលដៅជាក់លាក់ (ឧ. បែងចែកតាមអនុក្រុមអាយុ ក្រុមភាសា ក្រុមជាតិពន្ធ ឬលក្ខណៈក្រុមសំខាន់ៗផ្សេងទៀត)
- បន្តពិនិត្យតាមដាន និងវាយតម្លៃអន្តរាគមន៍
- រួមបញ្ចូលយោបល់ត្រឡប់របស់ស្ត្រីក្នុងអន្តរាគមន៍ (ឧ. ក្នុងការបរិយាយពីការលើកឡើងដោយបុរសអំពីការផ្លាស់ប្តូរឥរិយាបថ ឬអាកប្បកិរិយា)។

ដកស្រង់ចេញពី ៖ "ការមិនបង្កគ្រោះថ្នាក់" UN Women (២០១០)

បន្ទាប់ពីទទួលបានព័ត៌មានទាំងនេះនគរបាលអាចកំណត់ភាពសមាមាត្រនៃការឆ្លើយតបរបស់ខ្លួនដើម្បីធានាតុល្យភាពត្រឹមត្រូវរវាងការធានាសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះក្នុងដំណើរការនេះនិងការបំពេញលក្ខខណ្ឌតម្រូវផ្នែកភស្តុតាង និងការស៊ើបអង្កេត ដើម្បីបញ្ជាក់ពីបទល្មើស និង/ឬអំពើហិង្សា។ គន្លឹះសំខាន់គឺត្រូវអនុវត្ត "គោលការណ៍មិនបង្កគ្រោះថ្នាក់" ។ ខាងក្រោមនេះជាឧទាហរណ៍នៃរបៀបដែលនគរបាល"មិនបង្កគ្រោះថ្នាក់" នៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ការឆ្លើយតបរបស់នគរបាលដោយមានការយកចិត្តទុកដាក់និងការឃ្លាំមើលដែលខិតខំបំពេញការងារផ្អែកតាមគោលការណ៍ "មិនបង្កគ្រោះថ្នាក់" សត្យានុម័តភាព និងគ្មានការរើសអើង គឺជាគន្លឹះក្នុងការអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ក្នុងការស៊ើបអង្កេតដែលផ្តោតលើជនបង្ក។

ការស៊ើបអង្កេតដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្តោតលើជនបង្ក មានសកម្មភាពសំខាន់ៗ ៤ ៖

១. ចាប់ផ្តើមពីការជឿលើជនរងគ្រោះ (ស៊ើបអង្កេតទៅតាមស្ថានភាពបុគ្គល)
២. ធានាថាគ្មានគ្រោះថ្នាក់បន្ថែមទៀតចំពោះជនរងគ្រោះ និងសមាជិកគ្រួសារផ្សេងទៀតក៏ដូចជាលទ្ធភាពបង្កគ្រោះថ្នាក់ (ឬការបង្កគ្រោះថ្នាក់លើខ្លួនឯង) ចំពោះជនបង្កដែលរងការចោទប្រកាន់
៣. ពឹងផ្អែកលើការប្រមូលភស្តុតាងសំខាន់ៗ[158]និងភស្តុតាងជីវសាស្ត្រ/ភស្តុតាងកោសលវិច័យ ដើម្បីកំណត់សមាសធាតុឬអង្គហេតុនៃករណីដោយប្រើប្រាស់មធ្យោបាយដែលមាន និងទាន់ពេលវេលា[159]
៤. ខិតខំកសាងករណីរឹងមាំដែលមិនដាក់បន្ទុកទាំងស្រុងលើជនរងគ្រោះជាប្រភពផ្តល់ភស្តុតាងឬផ្អែកភស្តុតាងលើសក្ខីកម្មដែលធ្វើឡើងក្រោមការបង្ខិតបង្ខំ រួមទាំងសក្ខីកម្មរបស់ជនបង្កដែលរងការចោទប្រកាន់ ឬសាក្សី។
៥. ក្នុងករណីអំពើហិង្សាផ្លូវភេទលើស្ត្រី និងក្មេងស្រី ការស៊ើបអង្កេតដែលផ្តោតលើជនបង្ក ផ្តោតការយកចិត្តទុកដាក់លើជនបង្កដែលរងការចោទប្រកាន់ ដើម្បីធ្វើការកំណត់បែបសត្យានុម័តថាតើមានការយល់ព្រមពីជនរងគ្រោះ ផ្ទុយពីការដាក់បន្ទុកភស្តុតាងលើជនរងគ្រោះដើម្បីបញ្ជាក់ថា គាត់រងការគំរាម ឬប្រឈមនឹងអំពើហិង្សា (៥. មិនយល់ព្រម)។

ក្នុងករណីនេះ ការកំណត់ពីគំរូឥរិយាបថបំពានរបស់ជនបង្កដែលរងការចោទប្រកាន់ ស៊ីសង្វាក់គ្នានឹងគំរូវដ្តអំពើហិង្សាដែលបង្កើតឡើងដោយអ្នកជំនាញ នឹងស៊ីសង្វាក់គ្នានឹងអភិក្រមស៊ើបអង្កេតដោយមិនលម្អៀង និងបែបសត្យានុម័តដែលជាផ្នែកមួយនៃការអនុវត្តល្អបំផុតជាអន្តរជាតិ។

**ការយល់ព្រម** គឺនៅពេលដែលបុគ្គលម្នាក់បង្កើតជម្រើសផ្អែកតាមព័ត៌មានត្រឹមត្រូវដើម្បីធ្វើអ្វីមួយដោយសេរី និងដោយស្ម័គ្រចិត្ត។ គេមិនចាត់ទុកជាការយល់ព្រមទេ ប្រសិនបើការយល់ព្រមនេះទទួលបានតាមរយៈការគំរាមកំហែង កម្លាំង ការបង្ខិតបង្ខំ ការក្លែងបន្លំ ការបោកបញ្ឆោត ឬភាពជាតំណាងមិនត្រឹមត្រូវ[160]។

ផ្អែកតាមនិយមន័យនេះ នគរបាលត្រូវចងចាំជាក់នៅពេលកំណត់អង្គហេតុជុំវិញការយល់ព្រមក្នុងករណីអំពើហិង្សាផ្លូវភេទថាតើនៅពេលមានអំពើនេះជនរងគ្រោះដែលរងការចោទប្រកាន់ ទទួលរងបញ្ហាផ្លូវចិត្ត ឬផ្លូវកាយដែលជះឥទ្ធិពលលើសមត្ថភាពផ្តល់ការយល់ព្រម ឬទេ។

156. សៀវភៅណែនាំនេះកត់សម្គាល់ថាជនបង្កអំពើហិង្សាជាច្រើនក៏ជាជនរងគ្រោះដោយសារអំពើហិង្សាដែរ។

157. យោងតាមក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ តម្កល់សិទ្ធិ តម្រូវការ និងបំណងប្រាថ្នារបស់ស្ត្រី និងក្មេងស្រីជាចំណុចស្នូលនៃការផ្តល់សេវា។ចំណុចនេះទាមទារការពិចារណាពីតម្រូវការចម្រុះរបស់ជនរងគ្រោះ ហានិភ័យនិងភាពងាយរងគ្រោះផ្សេងៗផលប៉ះពាល់នៃការសម្រេចចិត្តនិងសកម្មភាពដែលធ្វើឡើង និងធានាថា សេវាត្រូវបានកែសម្រួលទៅតាមលក្ខខណ្ឌតម្រូវរបស់ស្ត្រី និងក្មេងស្រីម្នាក់ៗ។ ការផ្តល់សេវាគួរបំពេញតម្រូវការរបស់ជនរងគ្រោះ។

158. ភស្តុតាងសំខាន់ៗមិនគួររឹតត្បិតត្រឹមភស្តុតាងរូបវន្តនោះទេ ប៉ុន្តែក៏រួមបញ្ចូលផលប៉ះពាល់នៃអំពើហិង្សានិងការប៉ះទង្គិចផ្លូវចិត្តលើជនរងគ្រោះនិងឥរិយាបថរបស់នាងផងដែរ ដូចជា ការបន្តទំនាក់ទំនងជាមួយជនបង្កអំពើហិង្សាលើដៃគូស្និទ្ធស្នាល។

159. See: Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police-victim engagement in building a victim empowerment approach to intimate partner violence cases,' Police Practice and Research, 18:1, 75-86, DOI:10.1080/15614263.2016.1230061 and Ellison, L. (2002), 'Prosecuting domestic violence without victim participation', Modern Law Review, 65, 834–858.

"ការទទួលខុសត្រូវរបស់ជនបង្ក ទាមទារនូវសេវាសំខាន់ៗដែលរក្សាឱ្យជនបង្កទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពទន្ទឹមនឹងការធានានូវភាពសក្តិសមនៃការឆ្លើយតបក្នុងប្រព័ន្ធយុត្តិធម៌។ សេវាសំខាន់ៗត្រូវគាំទ្រ និងសម្របសម្រួលការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការយុត្តិធម៌ បង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការធ្វើសកម្មភាពឬប្រើប្រាស់ទីភ្នាក់ងាររបស់ខ្លួនទន្ទឹមនឹងការធានាថាស្ត្រីមិនទទួលរងបន្ទុក ឬកាតព្វកិច្ចនៃការស្វែងរកយុត្តិធម៌។ វាជា ភារកិច្ចរបស់រដ្ឋ"។

កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា(២០១៥)

ក្រៅពីនេះ ការយល់ព្រមមិនគួរចាត់ទុកជាកត្តាមួយឡើយ នៅពេលដែលអាយុរបស់ជនរងគ្រោះទាបជាងអាយុអប្បបរមាក្នុងច្បាប់ជាតិដែលបុគ្គលនោះត្រូវបានចាត់ទុកក្នុងផ្លូវច្បាប់ថាមានអាយុច្រើនល្មមអាចផ្តល់ការយល់ព្រមលើការចូលរួមក្នុងសកម្មភាពផ្លូវភេទបាន។

យោងតាម UNICEF ស្តង់ដារអន្តរជាតិមិនបញ្ជាក់ពីអាយុអប្បបរមាក្នុងការការយល់ព្រមរួមភេទឡើយ [161]។ ទោះជាយ៉ាងណា គណៈកម្មាធិការសិទ្ធិកុមារ (CRC) ចាត់ទុកថា អាយុ ១៣ ឆ្នាំគឺ "ទាបណាស់)។

ក្រៅពីនេះ គណៈកម្មាធិការសិទ្ធិកុមារស្នើឱ្យរដ្ឋសមាជិកគោរពការវិវត្តសមត្ថភាពរបស់កុមារនិងកុំឱ្យកំណត់អាយុអប្បបរមានេះខ្ពស់ពេក។ សម្រាប់ជាលក្ខណៈវិនិច្ឆ័យមួយ រដ្ឋគួរពិចារណាភាពខុសគ្នានៃអាយុរវាងដៃគូពាក់ព័ន្ធ ដើម្បីគូសបញ្ជាក់ពីតុល្យភាពអំណាចរវាងពួកគេនិងលើកឡើងពីករណីដែលពាក់ព័ន្ធនឹងមនុស្សវ័យជំទង់ពីរនាក់ដែលមិនទាន់គ្រប់អាយុ"[162]។

សូមមើលជំពូកទី ៩ (ទំនាក់ទំនង) សម្រាប់ឧទាហរណ៍ស្តីពីអ្វីដែលបង្កើត និងមិនបង្កើតបានជាការយល់ព្រម។

ការប្រមូលភស្តុតាងបែបប្រតិសកម្ម គឺសំខាន់ណាស់ក្នុងការធានាកិច្ចសហការពីសំណាក់ជនរងគ្រោះជាមួយនគរបាល ព្រោះវាជួយសម្រួលបន្ទុកដល់ជនរងគ្រោះតាមរយៈភស្តុតាងគាំទ្រនានា ដែលទាក់ទងនឹងអំពើហិង្សាដែលជនរងគ្រោះបានប្រឈមហើយក៏ធានាថានគរបាលធ្វើការស៊ើបអង្កេតករណីនោះ ដោយមានលទ្ធភាពជាក់ស្តែងតាំងពីដំបូង[163]។ ខាងក្រោមនេះជាក្រាហ្វបង្ហាញពីលំដាប់លំដោយនៃអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ រហូតដល់ការស៊ើបអង្កេតដែលផ្តោតលើជនបង្កក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

"គោលបំណងនៃការកំណត់អាយុអប្បបរមានៃក្នុងការយល់ព្រមរួមភេទ គឺដើម្បីការពារមនុស្សវ័យជំទង់ពីការរំលោភបំពានផ្លូវភេទ និងផលវិបាកនៃការធ្លាប់ប្រទ្បូកក្នុងសកម្មភាពផ្លូវភេទ និងការពារសិទ្ធិ និងការអភិវឌ្ឍរបស់ពួកគេ។"

អាយុអប្បបរមាក្នុងការយល់ព្រមរួមភេទ (UNICEF)

គួរឱ្យសោកស្តាយដែលការសិក្សានានា គូសបញ្ជាក់ពីភាពលម្អៀងរបស់មន្ត្រីនគរបាលដែលស្តែងចេញឱ្យឃើញច្បាស់ និងមិនស្តែងចេញឱ្យឃើញច្បាស់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ហើយភាពលម្អៀងទាំងនេះជះឥទ្ធិពលយ៉ាងខ្លាំងលើការកំណត់របៀបដែលនគរបាលគ្រប់គ្រងករណី[164]។ មន្ត្រីនគរបាលមួយចំនួន និងតួអង្គផ្សេងទៀតក្នុងវិស័យយុត្តិធម៌មិនត្រឹមតែមានទស្សនៈរើសអើងប៉ុណ្ណោះទេ ពួកគេក៏អាចជាអ្នកប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬអាចជាអ្នកគាំទ្រទង្វើបែបនេះទៀតផង។

160. កញ្ចប់ឯកសារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ៖ ឧបករណ៍បណ្តុះបណ្តាលស្តង់ដារសម្រាប់អ្នកមានភារកិច្ច អ្នកពាក់ព័ន្ធ និងអ្នកមានសិទ្ធិ" (UN Women, 2019)
161. អាយុអប្បបរមាស្របច្បាប់ និងការទទួលបានសិទ្ធិរបស់មនុស្សវ័យជំទង់" (UNICEF) ៖ https://www.unicef.org/lac/media/2806/file
62. សូមមើល មតិយោបល់រួមលេខ ៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC/GC/2003/4 of 2003) និងមតិយោបល់រួមលេខ ២១ របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងស្ត្រី (CEDAW/C/GC/21 of 1994)។
163. See Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police-victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research, 18: 1, 75-86, DOI: 10.1080/15614263.2016.1230061
164. Huhtanen, H., Lonsway, K.A., Archambault, J. (2017), 'Gender Bias in Sexual Assault Response and Investigation'; Training Bulletin Series: Part 1-4. End Violence Against Women International (EVAWI).

**រូប ១៖**

**អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះសម្រាប់ការស៊ើបអង្កេតដែលផ្តោតលើជនបង្ក**




ក្នុងករណីមួយចំនួនភាពលម្អៀងយេនឌ័រ ជាពិសេសភាពលម្អៀដែលពាក់ព័ន្ធនឹងផ្នត់គំនិតជុំវិញតួនាទីយេនឌ័រ ការប្រទូស្តកេរខ្មាស និងអំពើហិង្សាក្នុងគ្រួសារសុទ្ធតែធ្វើឱ្យនគរបាលមានភាពស្រពិចស្រពិល ឬផ្លាស់ប្តូរការធ្វើចំណាត់ថ្នាក់ឬស្ថានភាពរបស់ជនរងគ្រោះ/ជនបង្ក។

ក្នុងករណីទាំងនេះ មន្ត្រីឆ្លើយតបអាចចាប់ផ្តើមដេញដោលភាពអាចជឿទុកចិត្តបានរបស់ជនរងគ្រោះ ឬអាចស្តីបន្ទោសជនរងគ្រោះចំពោះអំពើហិង្សានៅពេលពួកគេយល់ថាមានការផ្តល់ព័ត៌មានមិនត្រឹមត្រូវឬមិនស៊ីសង្វាក់គ្នា។ ជាលទ្ធផល មន្ត្រីនគរបាលស៊ើបអង្កេតដែលទទួលភារកិច្ច ហាក់លែងផ្តោតលើការស៊ើបអង្កេតឥរិយាបថ និងសកម្មភាពរបស់ជនបង្កដែលរងការចោទប្រកាន់ ប៉ុន្តែងាកទៅផ្តោតលើឥរិយាបថរបស់ជនរងគ្រោះ និងលែងសួរផ្តោតលើការទទួលខុសត្រូវរបស់ជនបង្ក និងទោសព្រហ្មទណ្ឌសម្រាប់អំពើហិង្សាដែលរងការចោទប្រកាន់។

ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាននៃភាពលម្អៀងយេនឌ័រលើសេវានគរបាល ស្ថាប័ននគរបាលត្រូវធ្វើការប្តេជ្ញាចិត្តផ្នែកស្ថាប័នដែលគាំទ្រដោយគោលនយោបាយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងយន្តការគណនេយ្យភាពដែលជំរុញការផ្លាស់ប្តូរការគិតនិងឥរិយាបថចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការផ្លាស់ប្តូរការគិត និងឥរិយាបថទាំងនេះត្រូវផ្អែកលើការទទួលស្គាល់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជា ១) ការរំលោភសិទ្ធិមនុស្ស និង ២) បញ្ហាប្រឈមជាប្រព័ន្ធដែលកាត់ផ្តាច់និងធ្វើឱ្យក្រុមមួយចំនួនក្នុងសង្គមជួបការលំបាកនិងរាំងស្ទះដល់សិទិទ្ធពលក្នុងសង្គម សមាហរណកម្ម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព[165]។

យុទ្ធសាស្រ្តគំរូបច្ចុប្បន្នភាព ២០១០ ស្នើឱ្យបង្កើតស្តង់ដារនៃការអនុវត្ត និងឥរិយាបថ និងក្រមប្រតិបត្តិដែលអាចអនុវត្តបានដើម្បីធានាថា មន្ត្រីនគរបាលទទួលខុសត្រូវលើការរំលោភស្តង់ដារនិងក្រមប្រតិបត្តិទាំងនេះតាមរយៈយន្តការត្រួតពិនិត្យ និងគណនេយ្យភាពសមស្រប[166]។

សូមមើលជំពូកទី ១០ (ការកសាងស្ថាប័នដើម្បីធានាការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និង

165. "ការស៊ើបអង្កេត ការការពារ និងវិធានការគាំទ្រសម្រាប់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ" សៀវភៅធនធាន ៖ បទពិសោធន៍ និងគោលការណ៍ណែនាំរបស់នគរបាលកូរ៉េ (មជ្ឈមណ្ឌលគោលនយោបាយសេអ៊ូល UNDP ២០១៩)។
166. "យុទ្ធសាស្រ្តគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ" (សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឆ្នាំ ២០១១ ឧបសម្ព័ន្ធ)

ក្មេងស្រីប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ) និងជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ការណែនាំស្តីពីការបង្កើត និងពង្រឹងគោលនយោបាយ និងយន្តការដើម្បីធានាសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

សម្រាប់ករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល មានការចោទប្រកាន់ប្រឆាំងតបលើបុគ្គលដែលដាក់បណ្តឹងដំបូងទៅនគរបាល។ត្រូវដោះស្រាយស្ថានភាពទាំងនេះដោយប្រុងប្រយ័ត្ន និងមិនត្រូវជាប់ផុងក្នុងការជឿថា បុគ្គលទាំងពីរនាក់នោះ គឺ "អាក្រក់ដូចគ្នា" និងប្រានចោលបណ្តឹងរបស់ពួកគេនោះទេ។

ក្នុងស្ថានភាពនៃ "ការចោទប្រកាន់គ្នាទៅវិញទៅមក" មន្ត្រីអាចខិតខំកំណត់ថាតើនរណាជាជនរងគ្រោះ និងនរណាជាជនបង្កដែលរងការចោទប្រកាន់ ដើម្បីកំណត់ឌីណាមិកអំណាចនៃការរំលោភបំពានក្នុងគ្រួសារ។ខាងក្រោមនេះជាឧទាហរណ៍នៃការបញ្ជាក់ពីឥរិយាបថរបស់ជនរងគ្រោះ ៖

- **ការភ័យខ្លាច**៖ជនរងគ្រោះច្រើនតែភ័យខ្លាចដៃគូរបស់ខ្លួន ឬផលវិបាកនៃការលូកដៃរបស់នគរបាល ដែលស្តែងឡើងជាពាក្យសម្តី ឬទំនាក់ទំនងមិនមែនពាក្យសម្តីហើយនេះជាអ្វីដែលនគរបាលត្រូវកត់សម្គាល់។
- **ការទទួលខុសត្រូវ**៖ជាញឹកញាប់ជនរងគ្រោះផ្តល់សំអាងហេតុលើឥរិយាបថហិង្សា ឬបំពានរបស់ដៃគូខ្លួន ឬទទួលខុសត្រូវលើការបង្កើតស្ថានភាពប្រឈមមុខដាក់គ្នា ឬមិនធ្វើទៅតាមការរំពឹងទុកលើពួកគេ។ ជនបង្កដែលរងការចោទប្រកាន់ អាចទទួលយកឥរិយាបថហិង្សា ឬបំពាន និងផ្តល់សំអាងហេតុ។
- **ខ្លឹមសារពិស្តារនៃឧប្បត្តិហេតុ**៖ ជនបង្កដែលរងការចោទប្រកាន់ ច្រើនតែមិនរៀបរាប់លម្អិតឱ្យបានច្បាស់អំពីអ្វីដែលបានកើតឡើង ចំណែកជនរងគ្រោះងាយនឹងរៀបរាប់លម្អិតពីអ្វីដែលបានកើតឡើងឱ្យតែជនរងគ្រោះនោះមិនប៉ះទង្គិចផ្លូវចិត្តខ្លាំងពេក ។

នៅពេលពិចារណាពីសូចនាករសាមញ្ញៗទាំងនេះអ្នកគ្រប់គ្រងប្រតិបត្តិការគួរវាយតម្លៃល្អិតល្អន់លើសាវតារអំណះអំណាងកន្លែងកើតហេតុរបួសនិងយន្តការដើម្បីកំណត់រក "ជនប្រព្រឹត្ត"។ សំណួរដែលថា "នរណាជាជនប្រព្រឹត្ត?" គួរប្រើប្រាស់ក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលអាចមានចម្លើយមិនច្បាស់លាស់ពាក់ព័ន្ធនឹងឃ្លា "គាត់/នាងនិយាយថា..." និងមានរបួសទាំងពីរភាគី។

អ្នកគ្រប់គ្រងក្នុងជួរនគរបាល និងក្រុម គួរធ្វើអន្តរាគមន៍ភ្លាមៗក្នុងករណីមានអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយយល់ថា នគរបាល និងអាជ្ញាធរផ្តន្ទាទោស (មិនមែនជនរងគ្រោះ) ជាអ្នកទទួលខុសត្រូវចម្បងលើការផ្តួចផ្តើមការស៊ើបអង្កេតនិងការកាត់ទោសហើយគ្មានការកំណត់ឋានានុក្រមនៃអំពើហិង្សាឡើយ នៅពេលកំណត់គុណភាពនៃការឆ្លើយតប[167]។

ផ្ទុយទៅវិញ នគរបាលគួរចាត់ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាបាតុភូតវិលទៅវិលមកដែលឥរិយាបថមួយចំនួនជំរុញដំណាក់កាលនីមួយៗ។ តាមរយៈការធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពនៅកៀកនឹង "ការចាប់ផ្តើម" នៃវដ្តនេះនៅចំណុចដែលបញ្ជាក់ពីទម្រង់មិនសូវធ្ងន់ធ្ងរនៃអំពើហិង្សា នគរបាលអាចទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សាបន្ថែមទៀត។

នេះជាវិធីដែលកាន់តែមានប្រសិទ្ធផលសម្រាប់នគរបាលក្នុងការស៊ើបអង្កេតពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ប៉ុន្តែទាមទារការយល់ដឹងអំពីវដ្តនៃអំពើហិង្សា និងឥរិយាបថរបស់ជនបង្ក ដែលពាក់ព័ន្ធនឹងដំណាក់កាលនីមួយៗនៃវដ្តនៃអំពើហិង្សា។

ការប្រើប្រាស់គំរូវដ្តនៃអំពើហិង្សាក្នុងការស៊ើបអង្កេតពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាយុទ្ធសាស្ត្រស្នូលដែលគាំទ្រការស៊ើបអង្កេតដែលផ្តោតលើជនបង្ក។ ដ្យាក្រាមខាងក្រោមបង្ហាញថាតើជាតុផ្សំទាំងនេះរួមបញ្ចូលគ្នាដូចម្តេចដើម្បីផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកប្រកបដោយ

167. តាមពិត អំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចមិនបណ្តាលឱ្យមានគ្រោះថ្នាក់រាងកាយ និងមិនបន្សល់កស្តុតាងរូបវន្ត ប៉ុន្តែនៅតែជាទម្រង់មួយនៃអំពើហិង្សា និងគួរដោះស្រាយដោយប្រសិទ្ធភាព។

ប្រសិទ្ធភាព និងប្រសិទ្ធផល លើការស៊ើបអង្កេត ដែលផ្តោតលើជនបង្ក ដែលរងការចោទប្រកាន់ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី (គំរូ "៤ ចំណុច" របស់ Fernandez-Townsley)។

**រូប ២ ៖ "គំរូ ៤ ចំណុច" របស់** Fernandez-Townsley




"គំរូ ៤ ចំណុច" របស់ Fernandez-Townsley អាចអនុវត្តចំពោះការស៊ើបអង្កេតលើគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ពីអំពើហិង្សាក្នុងគ្រួសាររហូតដល់ការបៀតបៀនតាមប្រព័ន្ធបច្ចេកវិទ្យា និងការជួញដូរមនុស្ស និងពាក់ព័ន្ធនឹងបរិបទមានជម្លោះ និងបរិបទគ្មានជម្លោះ។ គួរចាត់ទុកគំរូនេះ ជាការបង្ហាញសមាសធាតុសំខាន់ៗសម្រាប់អភិក្រម ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ដើម្បីបង្កផលប៉ះពាល់លើការអនុវត្តពិធីសារស្ថាប័ននិងការស៊ើបអង្កេតរបស់នគរបាលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

យុទ្ធសាស្ត្រ ឬអភិក្រមស៊ើបអង្កេត មិនថាបែបប្រតិកម្ម ឬប្រតិសកម្មនោះទេ[168] នឹងអាស្រ័យលើបទល្មើសផ្ទាល់ និងធាតុផ្សំចាំបាច់សម្រាប់ការផ្តន្ទាទោស។ ក្នុងន័យនេះ យុទ្ធសាស្ត្រគំរូបច្ចុប្បន្នភាព ឆ្នាំ ២០១០ ស្នើឱ្យបង្កើតបច្ចេកទេសស៊ើបអង្កេតដែលមិនបន្ទាបតម្លៃស្ត្រីដែលប្រឈមនឹងអំពើហិង្សា និងកាត់បន្ថយការរំលោភបំពានទន្ទឹមនឹងការរក្សាស្តង់ដារសម្រាប់ការប្រមូលភស្តុតាងល្អបំផុត[169]។ សម្រាប់ការណែនាំបន្ថែមផ្នែកនីតិវិធី សៀវភៅណែនាំនេះ បានដាក់ស្នើសម្រាប់ជាធនធានគាំទ្រដល់ពិធីសារ និងនីតិវិធីជាតិ នូវឯកសារអន្តរជាតិស្តីពីស្តង់ដារនៃការស៊ើបអង្កេតរបស់នគរបាលសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងឧបសម្ព័ន្ធ ២ (សន្ធិសញ្ញានៃពិធីសារអន្តរជាតិ)។

ការសំខាន់ត្រូវគូសបញ្ជាក់ថា ការយល់ពីឥរិយាបថរបស់ជនបង្ក និងវដ្តនៃអំពើហិង្សា (មិនថាបណ្តាលឱ្យមានអំពើហិង្សាផ្លូវកាយ ឬយ៉ាងណានោះទេ) នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់គ្រោះថ្នាក់លើជនរងគ្រោះសាច់ញាតិឬមិត្តភក្តិជិតស្និទ្ធនិងអាចជួយបង្ការមិនឱ្យជនបង្កដែលរងការចោទប្រកាន់ធ្វើបាបខ្លួនឯង។ ការដែល

168. យោងតាមមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេសការផ្តួចផ្តើមការស៊ើបអង្កេតរបស់នគរបាលអាចបែងចែកជាអភិក្រម ២ ៖ ១) អភិក្រមបែបប្រតិកម្ម ដែលព័ត៌មានត្រូវបានប្រមូលពីរបាយការណ៍របស់សាធារណជនការបញ្ជូនដោយស្ថាប័នផ្សេងទៀត ចារកម្មពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀត (ព័ត៌មានពាក់ព័ន្ធគ្នា) ការស៊ើបអង្កេតឡើងវិញដោយសារទទួលបានព័ត៌មានថ្មីឬដោយសារសកម្មភាពផ្សេងទៀតរបស់នគរបាល ឬ ២) អភិក្រមបែបប្រតិសកម្ម ដែលជាទូទៅកើតចេញពីប្រភពចារកម្ម ដូចជា ការវិភាគគំរូបទល្មើស ការវិភាគបណ្តាញ ការវាយតម្លៃចារកម្មប្រតិបត្តិការ សារតាបញ្ហា ឬការវាយតម្លៃបែបកលយុទ្ធ។ល។ សូមមើល "ដំណើរការស៊ើបអង្កេត" មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស។

169. "យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ" (សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឆ្នាំ ២០១១ ឧបសម្ព័ន្ធ)

នគរបាលធ្វើអន្តរាគមន៍បានឆាប់រហ័សដោយផ្អែកតាមព័ត៌មានពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្ត នឹងជួយទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបទល្មើសដែលពាក់ព័ន្ធ។

សូមមើលជំពូកទី ១១ (បញ្ញាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ការណែនាំលើការយល់ដឹងស្តីពីវដ្តនៃអំណាច និងការគ្រប់គ្រង/ការត្រួតត្រា។

## សមត្ថភាពគ្រប់គ្រងសំខាន់ៗសម្រាប់ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលផ្តោតសំខាន់លើជនបង្ក

ដោយសារភាពលម្អៀងយេនឌ័រ ដែលស្តែងចេញឱ្យឃើញច្បាស់ និងដែលមិនស្តែងចេញឱ្យឃើញច្បាស់ ត្រូវបានបង្កប់ក្នុងវប្បធម៌របស់យើង អ្នកគ្រប់គ្រងក្នុងជួរនគរបាលមានការលំបាកក្នុងការកាត់បន្ថយការសន្មត និងផ្នត់គំនិតអវិជ្ជមាន និងគ្មានបានការ លើជនរងគ្រោះដែលស្វែងរកយុត្តិធម៌ដោយសារការរងគ្រោះដោយអំពើហិង្សា។

ដូច្នេះ មន្ត្រីនគរបាលត្រូវមានឆន្ទៈប្រឈមមុខនឹងទំនោរដោយមិនដឹងខ្លួនក្នុងការរំពឹងថា ជនរងគ្រោះប្រព្រឹត្តទៅតាមអ្វីដែលនគរបាលសន្មតថា "ជនរងគ្រោះដ៏ល្អ" រួមទាំងមានចរិត "ថ្លៃថ្នូរ" និងអាចផ្តល់ភស្តុតាងជាក់ស្តែង និងសមហេតុផល ដែលងាយលើកមកបង្ហាញសម្រាប់ការផ្តន្ទាទោស។

ការដោះស្រាយភាពលម្អៀងយេនឌ័រ ទាមទារការយល់ដឹងច្រើនអំពីការសិក្សាបច្ចុប្បន្នក្នុងផ្នែកវិទ្យាសាស្ត្រនគរបាលដែលបង្ហាញថា ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី មធ្យោបាយស៊ើបអង្កេតធម្មតា ជាពិសេសការសួរចម្លើយគឺជាទូទៅមិនល្អឥតខ្ចោះនោះទេ បើនិយាយពីគោលការណ៍ភស្តុតាង និងមិនផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។

សូមមើលជំពូកទី ៤ (ទំនាក់ទំនងដំបូង) សម្រាប់ព័ត៌មានស្តីពីការស៊ើបអង្កេតផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត។

ក្នុងករណីជាច្រើន ភាពលម្អៀងយេនឌ័រដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងស្តែងចេញឱ្យឃើញច្បាស់ អាចរារាំងមិនឱ្យអ្នកស៊ើបអង្កេតប្រកាន់ខ្ជាប់ការអនុវត្តល្អ ឬផ្តួចផ្តើមការស៊ើបអង្កេត។

ដើម្បីជម្នះភាពលម្អៀងយេនឌ័រ អ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចដាក់ចេញ និងលើកកម្ពស់គោលការណ៍ស៊ើបអង្កេតសម្រាប់វាយតម្លៃសមាជិកក្រុម។ឧ.រដ្ឋាភិបាលខេត្ត British Columbia ប្រទេសកាណាដា បានចេញកម្រងគោលការណ៍ណែនាំស្តីពីសេវានគរបាលដែលមិនលម្អៀង ដោយផ្អែកលើដំណើរការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធនិងអង្គការសហគមន៍បន្ទាប់ពីមានការចោទប្រកាន់ជាបន្តបន្ទាប់លើឥរិយាបថលម្អៀងរបស់នគរបាល ជាពិសេសភាពលម្អៀងចំពោះសហគមន៍ជនជាតិដើមភាគតិច ឬសមាជិកសហគមន៍ជនជាតិដើម។

ការចោទប្រកាន់ពីភាពលម្អៀងរបស់កងកម្លាំងនគរបាលខេត្ត British Columbia គឺដោយសារតែនគរបាលមិនបើកការស៊ើបអង្កេតគ្រប់គ្រាន់លើរបាយការណ៍ស្តីពីស្ត្រីដែលបាត់ខ្លួនក្នុងខេត្តនេះ ដែលភាគច្រើនជាជនជាតិដើម[170]។ ប្រអប់ខាងក្រោមបង្ហាញគោលការណ៍ដែលជាមូលដ្ឋានស្តង់ដារពីកងកម្លាំងនគរបាលខេត្ត British Columbia ស្តីពីសេវានគរបាលដែលមិនលម្អៀង[171]។

170. ចាប់ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០២ ស្ត្រី ៦៧ នាក់បានបាត់ខ្លួនពីតំបន់ទីក្រុង Vancouver ខេត្ត British Columbia ប្រទេសកាណាដា។ ភាគច្រើននៃស្ត្រីទាំងនេះត្រូវបានគេធ្វើឃាត ខណៈដែលស្ត្រីផ្សេងទៀតនៅតែបាត់ខ្លួន។ ស្ត្រីដែលបាត់ខ្លួនទាំងនោះពាក់ព័ន្ធនឹងក្រុមស្ត្រីជួបការលំបាក និងងាយរងគ្រោះបំផុតនៅ British Columbia។ គណៈកម្មការស្រាវជ្រាវរកស្ត្រីដែលបាត់ខ្លួន (MWCI) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១០ ដើម្បីត្រួតពិនិត្យការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ទៅនឹងស្ត្រីដែលត្រូវបានរាយការណ៍ថាបាត់ខ្លួនក្នុងអំឡុងពេលនេះ។ គណៈកម្មការនេះ រកឃើញថាផ្នែកនានានៃការសម្រេចចិត្តនិងយុទ្ធសាស្ត្ររបស់សេវានគរបាលឆ្លុះបញ្ចាំងពីផ្នត់គំនិតទូលំទូលាយក្នុងសហគមន៍នេះពាក់ព័ន្ធនឹងស្ត្រីងាយរងគ្រោះ និងជួបការលំបាក។ របាយការណ៍ចុងក្រោយដែលចេញផ្សាយនៅឆ្នាំ ២០១២ ផ្តល់អនុសាសន៍ជាច្រើនដើម្បីដោះស្រាយបញ្ហាទាំងនេះ។ សូមមើល "សេវានគរបាលដែលមិនលម្អៀងពីរដ្ឋាភិបាលខេត្ត British Columbia" សម្រាប់ព័ត៌មានបន្ថែម ៖ https://engage.gov.bc.ca/govtogetherbc/impact/promoting-unbiased-policing-results/ ។

171. សូមមើលបន្ថែមទៀត ៖ https://engage.gov.bc.ca/govtogetherbc/impact/promoting-unbiased-policing-results/ ។

**ប្រអប់ ១១**

**គោលការណ៍សេវានគរបាលដែលមិនលម្អៀង**

នៅ British Columbia ប្រទេសកាណាដា រដ្ឋាភិបាលខេត្ត បានដាក់ចេញគោលការណ៍ណែនាំពាក់ព័ន្ធនឹងសេវានគរបាលដែលមិនលម្អៀង។ គោលការណ៍នេះអនុវត្តតាមដំណើរការជំរុញការចូលរួមជាសាធារណៈ ដែលមន្ត្រីរដ្ឋាភិបាលជួបជាមួយអ្នកពាក់ព័ន្ធ និងអង្គការតាមសហគមន៍នៅចំពោះមុខការចោទប្រកាន់លើភាពលម្អៀងនៃសេវានគរបាល។អនុសាសន៍*ពីការសាកសួរនគរបាលត្រូវបានប្រែក្លាយទៅជាគោលការណ៍និងប្រើប្រាស់សម្រាប់លើកកម្ពស់ស្តង់ដារសេវានគរបាលដែលមិនលម្អៀងក្នុងខេត្តនេះ។ សូមអានអនុសាសន៍ខាងក្រោម ៖

- ការទទួលស្គាល់ភាពលម្អៀង ជាជំហានដ៏សំខាន់ក្នុងការដោះស្រាយផលប៉ះពាល់អវិជ្ជមានរបស់វា។
- សាធារណជនត្រូវមានទំនុកចិត្តថា សេវានគរបាលមានប្រសិទ្ធភាព យុត្តិធម៌ និងសុវត្ថិភាព។
- ប្រជាជនបង្កើនទំនុកចិត្តលើនគរបាល នៅពេលប្រជាជនជឿជាក់ថា សេវានគរបាលមានភាពយុត្តិធម៌ និងមិនលម្អៀង។
- សេវានគរបាលដែលផ្អែកលើផ្នត់គំនិត ឬការរើសអើង គឺគ្មានប្រសិទ្ធភាព មិនយុត្តិធម៌ និងគ្មានសុវត្ថិភាព។
- គោលនយោបាយ និងការអនុវត្តគួរផ្អែកតាមការយល់ដឹងពីប្រវត្តិ និងស្ថានភាពបច្ចុប្បន្ននៃទំនាក់ទំនងរវាងនគរបាល និងសហគមន៍ និងមូលហេតុនៃភាពរងគ្រោះ។
- ក្រុមមួយចំនួនប្រឈមនឹងហានិភ័យកាន់តែខ្លាំងនៃការរងផលប៉ះពាល់ ដោយសារអំពើហិង្សា និងមិនសូវរាយការណ៍ពីករណីនេះ។
- នគរបាលមានភារកិច្ចធានាសមភាពក្នុងការផ្តល់សេវា និងលទ្ធភាពទទួលបានយុត្តិធម៌។
- ការធានាសមភាព រួមមានការអនុវត្តជាជំហានដើម្បីការពារមិនឱ្យមានភាពលម្អៀង និងការកែសម្រួលដំណើរការទៅតាមភាពចាំបាច់ដើម្បីជម្នះឧបសគ្គ។

ប្រភព ៖ សេវានគរបាលដែលមិនលម្អៀង រដ្ឋាភិបាលខេត្ត British Columbia https://engage.gov.bc.ca/unbiasedpolicing/work-to-date/

ទោះជាយ៉ាងណាអ្នកគ្រប់គ្រងក្នុងជួរនគរបាលត្រូវដឹងពីសមត្ថភាពសំខាន់ៗ (ដូចជា សមត្ថភាព ជំនាញ ចំណេះដឹង កម្លាំងចិត្តឬបុគ្គលិកលក្ខណៈដែលអាចកត់សម្គាល់) ដែលត្រូវការជាចាំបាច់សម្រាប់ការធានាការគោរពគោលការណ៍ទាំងនេះហើយការស៊ើបអង្កេតធ្វើឡើងទាន់ពេលវេលា និងប្រកបដោយសត្យានុម័ត។

ឧ. ការយល់ដឹងផ្នែកបច្ចេកទេសអំពីករណីអំពើហិង្សាផ្លូវភេទ ដូចជា រយៈពេលសម្រាប់ឱ្យជនរងគ្រោះទទួលបានការព្យាបាលវេជ្ជសាស្ត្រ ការនិយាយជាមួយនគរបាល ការផ្លាស់សំលៀកបំពាក់ក្នុងពេលរក្សាភស្តុតាងនិងការទទួលបានការគាំទ្រផ្លូវចិត្តដែលអាចធ្វើឱ្យមានភាពខុសប្លែកជាវិជ្ជមានសម្រាប់ជនរងគ្រោះ និងការស៊ើបអង្កេត គឺមានសំខាន់ខ្លាំងណាស់។

អ្នកជំនាញផ្នែកឧក្រិដ្ឋកម្ម វិទ្យាសាស្ត្រនគរបាល និងវិទ្យាសាស្ត្រឥរិយាបថ បានបង្ហាញថា នៅពេលទស្សនៈវិជ្ជានៃសេវានគរបាលសម្រាប់ឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ផ្តោតសំខាន់លើការបង្កើនភាពអង់អាចរបស់ជនរងគ្រោះ តាមរយៈការចូលរួមប្រកបដោយអត្ថន័យក្នុងអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ[172] វានឹងបង្កើនការពេញចិត្ត និងទំនុកចិត្តរបស់ជនរងគ្រោះ។ ចំណុចនេះនឹងលើកទឹកចិត្តឱ្យជនរងគ្រោះសហការជាមួយនគរបាល[173]។ អ្នកជំនាញទាំងនេះក៏គូសបញ្ជាក់ផងដែរថា ការបង្កើនភាពអង់អាចរបស់ជនរងគ្រោះជំរុញការបង្កើតបណ្តាញគាំទ្រដែលមានប្រសិទ្ធភាព[174] ព្រោះជនរងគ្រោះងាយនឹងយល់ថា នគរបាលមានភាពស្របច្បាប់ និងអាចជឿទុកចិត្តបានកាន់តែខ្លាំង[175] ។

172. Wilson, S., & Jasinski, J. (2004), 'Public satisfaction with the police in domestic violence cases: The importance of arrest, expectations, and involuntary contact' American Journal of Criminal Justice, 28, 235–254
173. Nathan Birdsall, Stuart Kirby & Michelle McManus (2017,) Police-victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research, 18:1, 75-86, DOI: 10.1080/15614263.2016.123006
174. Hohl, K., Bradford, B., & Stanko, E. (2010), 'Influencing trust and confidence in the London metropolitan police: Results from an experiment testing the effect of leaflet drops on public opinion', British Journal of Criminology, 50, 491–513
175. Tyler, T. (2004), 'Enhancing police legitimacy', The Annals of the American Academy of Political and Social Science, 593, 84–99.

Birdsall et al. (២០១៧) បន្ថែមទៀតថា បទពិសោធន៍នេះផ្ទុយគ្នាស្រឡះនឹងបទពិសោធន៍របស់ជនរងគ្រោះផ្សេងទៀតដែលការចោទប្រកាន់បទព្រហ្មទណ្ឌត្រូវបានទម្លាក់ដោយសារកង្វះភស្តុតាងឬនៅពេលដែលប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកំពុងឈានទៅរកការផ្តន្ទាទោសជនបង្កដែលរងការចោទប្រកាន់ និងកំពុងខិតខំបំពេញការងារផ្ទុយពីបំណងប្រាថ្នារបស់ជនរងគ្រោះ[176] ។

ខាងក្រោមនេះជាសមត្ថភាពអនុវត្តន៍ការងារសំខាន់ៗមួយចំនួនដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង និងលើកកម្ពស់ការអនុវត្តការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អ្នកគ្រប់គ្រងគួរជានាថា មន្ត្រីឆ្លើយតបអាចអនុវត្តចំណុចខាងក្រោម។

## ភាពអាចរកបាន និងភាពអាចទទួលបាន

- បង្ហាញការគិតជាយុទ្ធសាស្ត្រយូរអង្វែងលើការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីការគិតហួសពីគោលដៅបុគ្គលនិងការពិចារណាថាតើភាពជោគជ័យនៃការស៊ើបអង្កេត បង្កផលប៉ះពាល់ដូចម្តេចលើបរិយាកាសសង្គមនិងសេដ្ឋកិច្ចជារួម។
- យល់ពីរបៀបចូលរួមរបស់មន្ត្រីជាមួយជនរងគ្រោះចូលរួមចំណែកដល់សេវានគរបាលជារួម។
- បង្កើតវិធានការដែលអនុញ្ញាតឱ្យមន្ត្រីផ្សេងទៀតទទួលខុសត្រូវដោយប្រសិទ្ធភាពនៅពេលផ្ទេរការធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជាជួយដល់ថ្នាក់ក្រោមក្នុងការបង្កើនការអនុវត្តការងាររបស់ពួកគេ។
- លើកទឹកចិត្តនិងគាំទ្រការរៀនសូត្រពីការស៊ើបអង្កេតក្នុងក្រុម និងក្នុងចំណោមសហការី។

## ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា ៖

- យល់និងបង្ហាញពីភាពខុសគ្នារវាងការទប់ស្កាត់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងករណីដែលកំពុងត្រូវបានដោះស្រាយ
- បង្ហាញពីរបៀបដែលទស្សនៈវិស័យរួមផ្សារភ្ជាប់នឹងផែនការដាក់លាក់និងគោលបំណងនៃការស៊ើបអង្កេតដើម្បីឱ្យមន្ត្រីចូលរួម មានកម្លាំងចិត្ត និងយល់ច្បាស់ពីគោលដៅនៃការស៊ើបអង្កេតដែលផ្តោតលើជនបង្ក។
- ផ្តល់ភាពប្រាកដប្រជាអំពីដំណើរការ រួមទាំងក្តីរំពឹងទុកច្បាស់លាស់ អ្វីដែលជាក្តីរំពឹងទុកក្នុងដំណើរការនេះ ដោយផ្តល់ភាពប្រាកដប្រជាកាន់តែច្រើន និងតាមរបៀបដែលអាចឱ្យជនរងគ្រោះយល់បាន[177]។
- កត់សម្គាល់គំរូនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីប្រធានបទ និងទំនាក់ទំនងរវាងប្រភពព័ត៌មានចម្រុះជាច្រើននិងភស្តុតាងល្អបំផុតដែលអាចរកបាន។

## ភាពអាចសម្រេបតាមបាន

- កត់សម្គាល់របៀបដែលភាពលម្អៀងដោយសារយេនឌ័រនិងពិការភាព ដូចជា ការសន្មត និងផ្នត់គំនិតអំពីជនរងគ្រោះ និងរបៀបដែលចំណុចទាំងនេះបង្កផលប៉ះពាល់លើការធ្វើសេចក្តីសម្រេចចិត្តប្រចាំថ្ងៃ។

## ភាពសមស្រប

- លុបបំបាត់ការយល់ខុស និង ការភាន់ច្រលំដែលបណ្តាលមកពីភាពលម្អៀងយេនឌ័រជុំវិញជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសការយល់ថារបាយការណ៍ភាគច្រើនជាការចោទប្រកាន់មិនពិត។
- កំណត់រកមូលហេតុសំខាន់ៗកត្តាជំរុញឬឧប្បត្តិហេតុនៅពីក្រោយអំពើហិង្សា ដូចជា ចំណេះដឹងអំពីគំរូវដ្តនៃអំពើហិង្សា ឌីណាមិកអំណាច និងឥរិយាបថទូទៅដែលពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលពាក់ព័ន្ធនឹងជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់។
- យល់ពីអត្ថន័យនៃ "ការគិតគូរពីកុមារ" និង "សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ និងសមានចិត្ត" ជាពិសេសជាមួយនឹងជនរងគ្រោះ និងសាក្សីជាកុមារ ។

176. Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police-victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research, 18:1, 75-86, DOI: 10.1080/15614263.2016.1230061. Also, see Harris-Short, S., & Miles, J. (2011), Family LAW (2nd ed.), Oxford: Oxford University Press; and Payne, D., & Wermeling, L. (2009), 'Domestic violence and the female victim: The real reason women stay!', Journal of Multicultural, Gender and Minority Studies, 3, 1–6.

177. កម្មវិធីបណ្តុះបណ្តាលស្តីពីការប្រព្រឹត្តចំពោះកុមារជាជនរងគ្រោះ និងកុមារជាសាក្សីនៃបទល្មើស សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ (UNODC, 2015)។

178. Ibid

**ប្រអប់ ១២**

**ការស៊ើបអង្កេតរបស់នគរបាលដែលពិតគួរពីកុមារ***

ខាងក្រោមនេះជាកត្តាជាក់លាក់ដែលមន្ត្រីអនុវត្តន៍ច្បាប់ គួរពិចារណានៅពេលប្រឈមនឹងជនរងគ្រោះ/សាក្សីជាកុមារ ព្រោះពួកគេងាយប៉ះពាល់អារម្មណ៍ (ឬហៅថា "ការប្រព្រឹត្តផ្សេងៗគ្នា") ៖

- កត្តាដែលពាក់ព័ន្ធនឹងកាលៈទេសៈផ្ទាល់ខ្លួនរបស់កុមារ ៖ អាយុ បំណងប្រាថ្នា ការយល់ឃើញ យេនឌ័រទំនោរផ្លូវភេទ។
- កត្តាដែលពាក់ព័ន្ធនឹងតម្រូវការពិសេសរបស់កុមារ ៖ សុខភាព សមត្ថភាព លទ្ធភាព តម្រូវការពិសេសផ្សេងទៀត។
- កត្តាដែលពាក់ព័ន្ធនឹងបរិយាសសង្គមរបស់កុមារ ៖ សាវតារជាតិពន្ធ និងវប្បធម៌ សាវតារសាសនា សាវតារភាសា និងសង្គម វណ្ណៈ។
- កត្តាដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមសេដ្ឋកិច្ចរបស់គ្រួសារកុមារ ៖ លក្ខខណ្ឌសង្គមសេដ្ឋកិច្ច ស្ថានភាពទេសន្តរប្រវេសន៍ ស្ថានភាពជាជនភៀសខ្លួន។

*ប្រភព ៖ កម្មវិធីបណ្តុះបណ្តាលស្តីពីការប្រព្រឹត្តចំពោះជនរងគ្រោះជាកុមារ និងសាក្សីជាកុមារ សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ (UNODC ២០១៥)

## ផ្តោតអាទិភាពលើការវាយតម្លៃហានិភ័យ សុវត្ថិភាព និងការរៀបចំផែនការសុវត្ថិភាព

- ស្វែងរក និងផ្សារភ្ជាប់ព័ត៌មានអំពីលក្ខណៈសាវតាររបស់ជនរងគ្រោះ ដូចជា យេនឌ័រ ផ្លូវភេទ ពិការភាព ជាតិពន្ធ សាសនា និងអាយុ ទៅនឹងវដ្តនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងគំរូឥរិយាបថរបស់ជនបង្ក។
- បន្ទាប់ពីទទួលបានព័ត៌មានពីជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី អនុវត្តគោលការណ៍មិនលម្អៀង និងសមាមាត្រ ដើម្បីធានាការឆ្លើយតបភ្លាមៗ និងគ្រប់គ្រាន់ទៅនឹងតម្រូវការការពារ[179] ។
- ធានាការប្រើប្រាស់ធនធានដោយប្រសិទ្ធផល ដើម្បីផ្តល់ការការពារគ្រប់គ្រាន់ និងកិច្ចសហប្រតិបត្តិការពីជនរងគ្រោះ[180] ។

## ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- កែសម្រួលវិធីសាស្ត្រស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា ការសួរចម្លើយជនរងគ្រោះនិងការផ្តល់ការគាំទ្រដល់ជនរងគ្រោះ ដើម្បីសម្រួលដល់បទពិសោធណ៍ដែលប៉ះទង្គិចផ្លូវចិត្ត និងធានាថាជនរងគ្រោះចូលរួមប្រកបដោយអត្ថន័យក្នុងការស៊ើបអង្កេត។

## ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន

- អនុវត្តដោយសត្យានុម័ត មិនលម្អៀង និងល្អិតល្អន់ និងផ្អែកតាមពិធីសារនៅពេលបំពេញឯកសាររបាយការណ៍ករណី រួមទាំងការធ្វើចំណាត់ថ្នាក់អំពើហិង្សាឱ្យបានសមស្រប។
- ធានាតម្លាភាពនៃនីតិវិធីរាយការណ៍ រួមទាំងនីតិវិធីក្នុងការទទួលរបាយការណ៍ ការទទួលយកដំបូង និងការឆ្លើយតបទៅនឹងរបាយការណ៍[181] ។
- ទទួលខុសត្រូវលើការត្រួតពិនិត្យការស៊ើបអង្កេតរហូតដល់ការបិទបញ្ចប់គួរជាទីគាប់ចិត្ត និងការកែខៃបញ្ហាយ៉ាងឆាប់រហ័ស និងដោយបើកចំហ។

## ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់

- កំណត់រកចំណុចចាប់ផ្តើមរួមនៃការរងគ្រោះលើកទីពីរក្នុងពេលស៊ើបអង្កេត។
- តំណាងឱ្យទស្សនៈយល់ឃើញរបស់ជនរងគ្រោះយ៉ាងត្រឹមត្រូវ និងស៊ីសង្វាក់គ្នា។ ពេលគឺមានដំណើរការគ្រប់គ្រាន់ក្នុងការប្រមូលទស្សនៈរបស់ជនរងគ្រោះ

179. ក្នុងករណីមានការរាយការណ៍ពីស្ត្រី និងក្មេងស្រីដែលបាត់ខ្លួន នគរបាលមិនគួររង់ចាំការបញ្ជាក់ថា បទល្មើសមួយពិតជាបានកើតឡើងមុននឹងធ្វើការឆ្លើយតបឡើយ។
180. "លើសពីផ្លូវជម្រាល ៖ មគ្គុទេសក៍សម្រាប់ជនភៀសខ្លួនជាស្ត្រីក្នុងការបង្កើតផែនការសកម្មភាពនៃច្បាប់ស្តីពីការរើសអើងពិការភាព" អង្គការស្ត្រីមានពិការភាពអូស្ត្រាលី (WWDA) (២០០៧)។
181. គួរបោះពុម្ពផ្សាយ និងចែកចាយនីតិវិធីទាំងនេះដល់សាធារណជន វិស័យទាំងអស់ក្នុងរដ្ឋាភិបាល និងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀត។សម្រាប់អនុសាសន៍បន្ថែមស្តីពីការគ្រប់គ្រងករណី សូមអាន "ការពង្រឹងការទប់ស្កាត់បទល្មើសនិងការឆ្លើយតបផ្នែកយុត្តិធម៌ ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC ២០១៤)

សូម្បីតែនៅពេលដែលជនរងគ្រោះមានការលំបាកក្នុងទំនាក់ទំនង ឬមិនសូវមានសមត្ថភាពផ្លូវច្បាប់។

នៅឆ្នាំ ២០១៥ សមាគមអន្តរជាតិនៃស្នងការនគរបាល (IACP) បានបង្កើតគោលការណ៍ណែនាំសម្រាប់គោលនយោបាយស្តីពីការឆ្លើយតបនឹងការប្រទូស្តកេរខ្មាស និងខ្លឹមសារវគ្គបណ្តុះបណ្តាល ដែលមានគោលបំណងផ្តល់ចំណុចប្រយោល នីតិវិធី និងអនុសាសន៍សម្រាប់ឱ្យមន្ត្រីអនុវត្តន៍ច្បាប់យកទៅពិចារណានៅពេលតាក់តែងគោលនយោបាយដែលពាក់ព័ន្ធនឹងការប្រទូស្តកេរខ្មាស ក៏ដូចជាខ្លឹមសារវគ្គបណ្តុះបណ្តាលដែលអមមកជាមួយគោលនយោបាយនោះ[182] ។

ក្នុងគោលការណ៍ណែនាំនេះ IACP បានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់នៃការត្រួតពិនិត្យដែលមានប្រសិទ្ធភាពក្នុងការធានាការឆ្លើយតបគ្រប់ជ្រុងជ្រោយនិងការស៊ើបអង្កេតបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា ការប្រទូស្តកេរខ្មាស។ IACP ស្នើឱ្យមន្ត្រីត្រួតពិនិត្យជួរមុខមានការយល់ដឹងគត់មត់អំពីបញ្ហារបស់ជនរងគ្រោះ និងការឆ្លើយតបសមស្របពីថ្នាក់ក្រោម[183]។ ដើម្បីពង្រឹងអនុសាសន៍ទាំងនេះ IACP បានផ្តល់កម្រងសកម្មភាពសំខាន់ៗដល់មន្ត្រីត្រួតពិនិត្យសម្រាប់ការប្រឈមនឹងករណីករណីអំពើហិង្សាផ្លូវភេទ ដែលអាចអនុវត្តចំពោះគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ១៣**

**តួនាទីរបស់មន្ត្រីត្រួតពិនិត្យក្នុងករណីអំពើហិង្សាផ្លូវភេទ***

- ប្រសិនបើមានការស្នើសុំពីមន្ត្រីឬនៅពេលចាត់ទុកថាចាំបាច់សូមឆ្លើយតបដើម្បីជួយដល់មន្ត្រីដែលស៊ើបអង្កេតឧប្បត្តិហេតុការប្រទេស្តកេរខ្មាស
- មន្ត្រីត្រូវឆ្លើយតបដោយសត្យានុម័ត វិជ្ជាជីវៈ និងមិនវិនិច្ឆ័យ។ មន្ត្រីត្រួតពិនិត្យត្រូវធានាថា មន្ត្រីជួរមុខបានដឹងពីក្តីរំពឹងទុកទាំងនេះ។
- ជួយកំណត់រកធនធានស្ថាប័ន និងធនធានសហគមន៍ដើម្បីស៊ើបអង្កេតដោយប្រសិទ្ធភាពលើការប្រទូស្តរាយដែលកើតឡើង។
- ជំរុញភាពជាដៃគូនៃការដោះស្រាយបញ្ហារវាងនាយកដ្ឋាននគរបាលនិងអង្គការតាមសហគមន៍ដូចជាមជ្ឈមណ្ឌលដោះស្រាយវិបត្តិដោយសារអំពើរំលោភសេពសន្ថវៈនិងកម្មវិធីពិនិត្យកោសលវិច័យដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងផ្តល់ការគាំទ្រល្អប្រសើរដល់ជនរងគ្រោះ។
- ពិនិត្យឡើងវិញលើរបាយការណ៍ទាំងអស់របស់នគរបាលស្តីពីការប្រទូស្តកេរខ្មាស ដើម្បីធានាសុក្រឹតភាព ភាពស៊ីសង្វាក់គ្នា និងការឆ្លើយតបដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។
- លើកទឹកចិត្តឱ្យមន្ត្រីស្វែងរកបទល្មើសដែលកើតឡើងដំណាលគ្នា និងប្រទាក់ក្រឡាគ្នា នៅពេលឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស។
- ធានាថា មន្ត្រី និងអ្នកស៊ើបអង្កេតយល់ពីការដាក់លេខកូដករណី និងដាក់លេខកូដករណីប្រទូស្តកេរខ្មាសបានសមស្រប។
- ធ្វើការពិនិត្យឡើងវិញក្រោយការអនុវត្ត និងសវនកម្មករណីប្រទូស្តកេរខ្មាសដើម្បីធានាថា មន្ត្រី និងអ្នកស៊ើបអង្កេតធ្វើការស៊ើបអង្កេតដែលគ្រប់ជ្រុងជ្រោយ ផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងការស៊ើបអង្កេតដែលផ្តោតលើជនបង្ក។
- បង្កើតឱកាសបណ្តុះបណ្តាលជាប់ជាប្រចាំសម្រាប់មន្ត្រីក្នុងនាយកដ្ឋានដើម្បីបង្កើនជំនាញចាំបាច់ក្នុងការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាសឱ្យបានសមស្រប។ ខិតខំបង្កើនទំនាក់ទំនងរវាងមន្ត្រីអនុវត្តន៍ច្បាប់ និងអយ្យការដើម្បីសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនេះចាប់ពីការស៊ើបអង្កេតរហូតដល់ការផ្តន្ទាទោស។

182. សូមមើលបន្ថែមទៀត https://www.theiacp.org/resources/sexual-assault-response-policy-and-training-content-guidelines

183. Ibid

- ដាក់បញ្ចូលបញ្ហាសេវាសំរាប់របស់ជនរងគ្រោះ និងការឆ្លើយតបនឹងជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស ក្នុងការវាយតម្លៃការអនុវត្តការងារ និងការស្នើផ្តល់រង្វាន់ និងដំឡើងតំណែងដល់មន្ត្រីក្នុងនាយកដ្ឋាន។
- រក្សាការទទួលខុសត្រូវរបស់មន្ត្រី នៅពេលពួកគេប្រព្រឹត្តមិនស៊ីសង្វាក់គ្នានឹងគុណតម្លៃ និងបេសកកម្មរបស់នាយកដ្ឋាន ពាក់ព័ន្ធនឹងការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាស។
- ផ្តល់ឱ្យជនរងគ្រោះនូវព័ត៌មានជាប្រចាំអំពីសេវានានា នៅពេលចុះវត្តមាន និងប្រជុំពិភាក្សាបុគ្គលិកមុនពេលចាប់ផ្តើមសកម្មភាព។ ការអប់រំ និងការបណ្តុះបណ្តាលគួរធ្វើឡើងជាប្រចាំ និងអាចអនុវត្តតាមមូលដ្ឋានជាមួយមន្ត្រី នៅពេលមិនឆ្លើយតបនឹងការអំពាវនាវរកសេវា។
- ទទួលស្គាល់និងផ្តល់រង្វាន់ដល់មន្ត្រីដែលផ្តល់សេវាយ៉ាងមានប្រសិទ្ធភាពដល់ជនរងគ្រោះ។

*ប្រភព ៖ សមាគមអន្តរជាតិនៃស្នងការនគរបាល គោលការណ៍ណែនាំសម្រាប់គោលនយោបាយស្តីពីការឆ្លើយតបនឹងការប្រទូស្តកេរខ្មាស និងខ្លឹមសារវគ្គបណ្តុះបណ្តាល (២០១៥)

## សូចនាករយោងសម្រាប់នគរបាលដែលផ្តល់សេវាសំខាន់ៗ ៖ ការស៊ើបអង្កេត

ដូចការពិភាក្សាក្នុងជំពូកទី ២ ដែរ កញ្ចប់សេវាសំខាន់ៗ ស្នើឱ្យមានសេវាយុត្តិធម៌និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះ មានលក្ខណៈទូទៅ និងសកម្មភាពរួមដើម្បីជានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈទូទៅ និងសកម្មភាពរួមទាំងនេះអាចអនុវត្តបាន ដោយមិនគិតពី "វិស័យ" ជាក់លាក់ ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងក្មេងស្រីដែលកំពុងរងគ្រោះដោយអំពើហិង្សា។

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅ និងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗ និងផ្តល់ឧទាហរណ៍នៃសូចនាករយោងសម្រាប់សកម្មភាពរបស់នគរបាល ក្នុងគោលបំណងបំពេញលក្ខខណ្ឌតម្រូវផ្នែកកស្តុតាងនិងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនៅពេលឆ្លើយតបនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចនេះរួមមានការបើកការស៊ើបអង្កេតទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈ និងក្នុងដំណើរការនេះ ប្រើប្រាស់រាល់មធ្យោបាយដែលមានដើម្បីធានាការទទួលខុសត្រូវរបស់ជនបង្ក និងទប់ស្កាត់ការប្រព្រឹត្តល្មើសជាថ្មី។ ទាំងនេះជាសូចនាករដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង ប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មាន ថ្នាក់លើគួរបញ្ចូលសូចនាករទាំងនេះ។

១. **ភាពអាចរកបាន និងភាពអាចទទួលបាន** ៖ ភាគរយឬសមាមាត្រយោបល់ត្រឡប់វិជ្ជមានពីជនរងគ្រោះនិង/ឬតំណាងរបស់ពួកគេពាក់ព័ន្ធនឹងភាពអាចទទួលបាននូវសេវានគរបាលទាំងគុណភាពនិងបរិមាណ។ យោបល់ត្រឡប់គួរមានគោលបំណងរួមបញ្ចូលរបៀបដែលនគរបាលជូនដំណឹងដល់ជនរងគ្រោះអំពីស្ថានភាពនៃការស៊ើបអង្កេត ក្នុងដំណើរការនេះ។ ផ្អែកតាមយោបល់ត្រឡប់ទាំងនេះអ្នកគ្រប់គ្រងអាចវាយតម្លៃកម្រិតដែលបុគ្គលិករបស់ខ្លួនប្រមូល និងគ្រប់គ្រងព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះបានសមស្រប។

២. **ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន** ៖ ភាគរយឬសមាមាត្រនៃរបាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលដាក់បញ្ចូលការវិភាគឥរិយាបថរបស់ជនបង្ក អនុលោមតាមគំរូវដ្តនៃអំពើហិង្សា។ ការវិភាគនេះគួរផ្តល់មូលដ្ឋានព័ត៌មានដល់ការស៊ើបអង្កេតដែលផ្តោតលើជនបង្ក ក៏ដូចជាតម្រូវការការពាររបស់ជនរងគ្រោះ។

៣. **ភាពសមស្រប និងភាពអាចទទួលបាន** ៖ ភាគរយ ឬសមាមាត្រនៃសមាជិកក្រុមដែលត្រូវទទួលការបណ្តុះបណ្តាលស្តីពីការឆ្លើយតបទៅនឹងកុមារដែលជាជនរងគ្រោះដោយសារអំពើហិង្សា។ ចំណុចនេះគួររួមបញ្ចូលទាំងការបណ្តុះបណ្តាលឯកទេសសម្រាប់ក្រុមជាក់លាក់និងការបណ្តុះបណ្តាលទូទៅជាប្រចាំសម្រាប់មន្ត្រីទាំងអស់។ ការបណ្តុះបណ្តាលគួរផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីអាសយដ្ឋានទំនាក់ទំនងសម្រាប់ការបញ្ជូនជនរងគ្រោះ ច្បាប់ថ្មីៗរួមទាំងច្បាប់ស្តីពីអំពើហិង្សា និងបទល្មើសបច្ចេកវិទ្យា អំពើហិង្សា

ដែលពាក់ព័ន្ធនឹងសាលារៀននិងតួនាទីរបស់បណ្ដាញសង្គម និងសកម្មភាពរបស់ជនល្មើសដែលបង្កផលប៉ះពាល់លើក្រុមងាយរងគ្រោះដូចជាជនចំណាកស្រុក។

៤. **សុវត្ថិភាពជាចម្បង** ៖ ភាគរយ ឬសមាមាត្រនៃដីកាការពារ ដែលស្នើឡើង និង អនុវត្តដោយនគរបាលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលគេស្គាល់អត្តសញ្ញាណជនបង្កដែលរងការចោទប្រកាន់។ អ្វីដែលសំខាន់ផងដែរនោះគឺភាគរយ ឬសមាមាត្រនៃករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលគ្មាន និង/ឬមានការផ្ដល់ដីកាការពារ ប៉ុន្តែមិនត្រូវបានអនុវត្ត។ គួរពិចារណាពីសូចនាករនេះធៀបនឹងចំនួននៃការចាប់ខ្លួនក្នុងករណីទាំងនេះ។

> "គុណភាពនៃការស៊ើបអង្កេត និងរបៀបចងក្រងជាឯកសារ បូករួមនឹងការសម្រេចចិត្តរបស់អ្នកស៊ើបអង្កេតសុទ្ធតែជាកត្តាសំខាន់ៗដែលនាំទៅរកលទ្ធផលផ្លែផ្កា។ ២.ការគ្រប់គ្រងខ្សែសង្វាក់បញ្ជូនភស្តុតាង ជាពិសេសដោយសារតែវាពាក់ព័ន្ធនឹងភស្តុតាងកោសលវិច័យគឺមានសារៈសំខាន់បំផុត និងជាផ្នែកដំបូងបង្អស់ដែលត្រូវដេញដោលក្នុងប្រព័ន្ធយុត្តិធម៌"។
>
> Gerry Campbell អតីតប្រធានផ្នែកស៊ើបអង្កេត Scotland Yard

៥. **ការផ្ដល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ និងភាពអាចទទួលបាន** ៖ ភាគរយ ឬសមាមាត្រមន្ត្រីដែលបានទទួលការបណ្ដុះបណ្ដាលស្ដីពីអភិក្រមនៃសេវានគរបាលដែលផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត។ ការបណ្ដុះបណ្ដាលគួររួមបញ្ចូលការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃ និងគួរមានការបណ្ដុះបណ្ដាលឯកទេសសម្រាប់ក្រុមជាក់លាក់ក៏ដូចជាការបណ្ដុះបណ្ដាលទូទៅជាប្រចាំសម្រាប់មន្ត្រីគ្រប់រូប។

៦. **ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំអនុវត្ត និងវាយតម្លៃសេវា** ៖ ចំនួនជនរងគ្រោះដែលបាននិយាយជាមួយនិងផ្ដល់ចម្លើយ។ទោះបីជាសូចនាករនេះមិនផ្ដល់ព័ត៌មានស្ដីពីគុណភាពនៃទំនាក់ទំនងរវាងមន្ត្រីនគរបាល និងជនរងគ្រោះឬសាក្សីក្ដី ប៉ុន្តែវាជួយបំពេញបន្ថែមលើយោបល់ត្រឡប់បែបគុណភាពរបស់ជនរងគ្រោះ។

៧. **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន** ៖ ភាគរយ ឬសមាមាត្រនៃករណីដែលត្រូវបានកត់ត្រានិងរក្សាទុកសមស្រប ដោយផ្អែកតាមពិធីសារ ឬនីតិវិធីគ្រប់គ្រងសំណុំរឿង។ការកត់ត្រាព័ត៌មានទាំងនេះបង្ហាញពីគណនេយ្យភាព និងសុចរិតភាពនៃដំណើរការស៊ើបអង្កេត។ ចំណុចនេះរួមមានកំណត់ត្រាដែលបញ្ជាក់ថា បន្ទាប់ពីការរាយការណ៍បទល្មើស ជនរងគ្រោះបានទទួលការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីនគរបាលថា បានទទួលបណ្ដឹងរបស់ពួកគេ ដោយបញ្ជាក់ពីធាតុផ្សំសំខាន់ៗនៃបទល្មើសដូចជាប្រភេទបទល្មើស ពេលវេលា ទីកន្លែង និងការខូចខាតដែលបណ្ដាលមកពីបទល្មើសនោះ។ ការទទួលស្គាល់នេះគួររួមបញ្ចូលលេខសំណុំរឿង កាលបរិច្ឆេទ ប៉ុស្តិ៍នគរបាល និងឈ្មោះមន្ត្រីដែលធ្វើរបាយការណ៍។ ព័ត៌មានទាំងនេះជាភស្តុតាងបញ្ជាក់ថាមានការរាយការណ៍ពីបទល្មើស (២. ពាក់ព័ន្ធនឹងការទាមទារសំណងជំងឺចិត្ត)[184]។

៨. **ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល** ៖ ភាគរយ ឬសមាមាត្រនៃករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលត្រូវបានបញ្ជូនទៅស្ថាប័ន និងដៃគូខាងក្រៅ។ ការសំខាន់គឺត្រូវចងក្រងឯកសារស្ដីពីភាគរយ ឬសមាមាត្រនៃករណីដែលជនរងគ្រោះបដិសេធមិនទទួលយកជំនួយជាការបញ្ជូន។

**ប្រអប់ ១៤**

**ការដឹកនាំនគរបាលប្រកបដោយប្រសិទ្ធភាព ៖ អំពើហិង្សាក្នុងគ្រួសារ**

យោងតាមនាយកដ្ឋានកិច្ចការផ្ទៃក្នុងចក្រភពអង់គ្លេសការដឹកនាំដែលមានប្រសិទ្ធភាពសម្រាប់ការប្រយុទ្ធប្រឆាំងអំពើហិង្សាក្នុងគ្រួសារឬអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងផ្នែកនេះ សំដៅលើ * ៖

184. សម្រាប់អនុសាសន៍បន្ថែមស្ដីពីការគ្រប់គ្រងករណី សូមយោងតាម "ការពង្រឹងការទប់ស្កាត់បទល្មើសនិងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC, ២០១៤)។

- ការផ្តោតអាទិភាពលើការរំលោភបំពានក្នុងគ្រួសារដែលមន្ត្រីយល់ពីអត្ថន័យនៃបញ្ហានេះ។
- ការយល់ច្បាស់ថាការរំលោភបំពានក្នុងគ្រួសារជាកិច្ចការរបស់មនុស្សគ្រប់រូបមិនត្រឹមតែជាបញ្ហាសម្រាប់អង្គភាពឯកទេសនោះទេ។
- ការពង្រឹងវប្បធម៌ និងឥរិយាបថវិជ្ជមាន
- ការផ្តល់រង្វាន់ និងការទទួលស្គាល់បុគ្គលដែលគាំទ្រដល់ជនរងគ្រោះដោយសារការរំលោភបំពានក្នុងគ្រួសារដោយផ្តល់ការលើកទឹកចិត្តចាប់ពីការកោតសរសើររហូតដល់ការដំឡើងតំណែង។ យើងមាន "ពានរង្វាន់សំរាប់នគរបាលក្លាហាន"។ តើគួរមាន "ពានរង្វាន់សម្រាប់ការយកចិត្តទុកដាក់លើជនរងគ្រោះ"ដែរឬទេ?
- ការផ្តោតសំខាន់លើការគ្រប់គ្រងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ក្នុងផ្នែកនេះ និង
- ការធានាថា មានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដើម្បីពង្រឹងអភិក្រមដែលមានវិជ្ជាជីវៈនិងសមត្ថកិច្ច។

*ប្រភព៖ "កិច្ចការរបស់មនុស្សគ្រប់រូប៖ ការកែលម្អការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ" (អធិការដ្ឋាននគរបាលមហាក្សត្រី HMIC, 2014)។

## ឧបសម្ព័ន្ធ ១
## ដំណាក់កាលគួរឱ្យកត់សម្គាល់នៃអំពើហិង្សាក្នុងទំនាក់ទំនង

ដោយ Graham Goulden ប្រធានផ្នែកស៊ើបអង្កេត (ចូលនិវត្តន៍) Scotland Yard

ខណៈដែលមន្ត្រីមិនសុទ្ធតែកត់សម្គាល់សញ្ញានៃការរំលោភបំពាន គួរដឹងពីដំណាក់កាលទាំងនេះ និងអ្វីដែលជនរងគ្រោះអាចបង្ហាញឡើងនៅពេលឆ្លើយតបទៅនឹងការទូរស័ព្ទចូល។

**ការល្បួងតាមប្រព័ន្ធអ៊ីនធឺណិត៖**ជនបំពានជាច្រើននឹងមានសម្រស់ស្រស់ស្អាតនៅដំណាក់កាលដំបូងនៃទំនាក់ទំនង។ ពួកគេអាចជា "ដៃគូល្អឥតខ្ចោះ"។ ជាញឹកញាប់ចំណុចនេះត្រូវបានមើលឃើញដោយមិត្តភក្តិ និងគ្រួសាររបស់ជនរងគ្រោះ។

នៅដំណាក់កាលដំបូងៗទាំងនេះកលវិធីរបស់ជនបង្កគឺការផ្តាច់ខ្លួនជនរងគ្រោះចេញពីគ្រួសារ និង មិត្តភក្តិ។ ចំណុចនេះអាចត្រូវបានចាត់ទុកជាការយកចិត្តទុកដាក់ និងក្តីស្រឡាញ់។

ដំណើរការនៃការល្បួងជនរងគ្រោះគឺជាញឹកញាប់ធ្វើឡើងដោយសន្សឹមៗនិងផ្តល់គោលជំហរកាន់តែល្អដល់ជនបង្កក្នុងការអនុវត្តការបំពាន និងអំពើហិង្សាផ្លូវកាយដែលធ្ងន់ធ្ងរជាងមុន។

មន្ត្រីនគរបាលអាចទទួលបានការទូរស័ព្ទទាក់ទងពីសមាជិកគ្រួសារ ឬមិត្តភក្តិដែលព្រួយបារម្ភពីបុគ្គលណាម្នាក់។

**សញ្ញានៃភស្តុតាង ៖ ចំណុចត្រូវប្រុងប្រយ័ត្ន**
- ការផ្តាច់ខ្លួនចេញពីគ្រួសារ និងមិត្តភក្តិ
- ការចាប់ពឹងផ្អែកផ្នែកហិរញ្ញវត្ថុ ៖ ការខ្ចីប្រាក់ដោយប្រើឈ្មោះរបស់ជនរងគ្រោះ
- ការចាប់មានផ្ទៃពោះ
- ការចាប់រស់នៅជាមួយគ្នា
- មិត្តភក្តិអាចពិពណ៌នាជនបង្កជាដៃគូល្អឥតខ្ចោះ។

គួរកត់សម្គាល់ថា មិនមែនរាល់ចំណុចត្រូវប្រុងប្រយ័ត្នខាងលើសុទ្ធតែជាឧទាហរណ៍នៃការល្បួងនោះទេ។ នៅពេលស៊ើបអង្កេតការរំលោភបំពានក្នុងគ្រួសារ មន្ត្រីគួរពិចារណាសាកសួរអំពីដំណាក់កាលដំបូងៗ នៃទំនាក់ទំនងនេះ។

**ការគ្រប់គ្រងស្ថានការណ៍ ៖** នៅពេលជនបំពានចាប់ផ្តើមប្រព្រឹត្តបំពាន និង/ឬអំពើហិង្សាផ្លូវកាយកាន់តែញឹកញាប់ ជនរងគ្រោះមួយចំនួនអាចចាកចេញពីទំនាក់ទំនងប៉ុន្តែ ជនរងគ្រោះជាច្រើនមិនបញ្ចប់ទំនាក់ទំនងនោះទេ ដោយសារកម្រិតនៃការគ្រប់គ្រងដែលបង្កើតឡើងនៅដំណាក់កាលល្បួង។ ជនរងគ្រោះ ច្រើនតែព្យាយាមស្វែងរកការពន្យល់លើការបំពានដើម្បីអាចស្រោចស្រង់ស្ថានការណ៍បាន។

ជនរងគ្រោះនឹងបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងជនបង្ក និងស្ថានការណ៍ជាក់លាក់ជាញឹកញាប់គឺតាមរយៈការផ្លាស់

ប្តូរឥរិយាបថរបស់ខ្លួន។ តាមវិធីនេះ ជនបង្កកំណត់ស្តង់ដារលើទំនាក់ទំនង ហើយការបំពានក្លាយជាផ្នែកមួយនៃទំនាក់ទំនង។

ប្រសិនបើមានការទូរស័ព្ទប្តឹងនគរបាល វាអាចជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងការបំពានក្នុងទំនាក់ទំនង។ ប្រសិនបើជនរងគ្រោះមិនចង់ពាក់ព័ន្ធនៅចំណុចនេះ មិនមានន័យថា ពួកគេមានចេតនារារាំង ឬមិនសហការនោះទេ។ ពួកគេគ្រាន់តែគ្រប់គ្រងស្ថានការណ៍តាមរបៀបដែលពួកគេយល់ថា ធ្វើឱ្យពួកគេមានសុវត្ថិភាពបំផុត។

ការសំខាន់នៅដំណាក់កាលនេះគឺ មន្ត្រីត្រូវសួរសំណួរដែលអាចឱ្យជនរងគ្រោះយល់ពីរបៀបដែលពួកគេកំពុងកែប្រែនិងកម្រិតឥរិយាបថរបស់ខ្លួនឱ្យស៊ីគ្នានឹងឥរិយាបថរបស់ជនបង្ក។

**សញ្ញានៃភស្តុតាង ៖ ចំណុចត្រូវប្រុងប្រយ័ត្ន**

- ការផ្តាច់ខ្លួនចេញពីគ្រួសារ និងមិត្តភក្តិ
- ជនរងគ្រោះស្តីបន្ទោសខ្លួនឯង
- ការសុំច្បាប់ឈប់សម្រាកពីការងារដោយសាររបួស
- វិធានតឹងរឹងដែលតម្រូវដោយជនបង្ក ( ឧ.អាហារពេលល្ងាច ការសម្អាត អនាម័យរបស់ជនរងគ្រោះ សំលៀកបំពាក់ដែលត្រូវស្លៀក។ល។ )
- ជនបង្កត្រួតពិនិត្យការដើរហើររបស់ជនរងគ្រោះ។ មន្ត្រីគួរពិចារណាថា ជនបង្កអាចប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើតការគ្រប់គ្រង។
- ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។

**ការបំភាន់ការយល់ឃើញ/តថភាព** ៖ ឥរិយាបថត្រួតត្រាដោយបង្ខំ ពាក់ព័ន្ធនឹងកលវិធីផ្សេងៗ និងត្រួតគ្នាជាច្រើន។ នៅពេលអនុវត្តរួមគ្នា កលវិធីទាំងនេះធ្វើឱ្យជនរងគ្រោះរស់នៅដោយភាពភ័យខ្លាច។ពួកគេច្រើនតែថប់បារម្ភនិងខ្លាចអា។

ជនបង្កនឹងព្យាយាមបង្វែរការស្តីបន្ទោស និងការទទួលខុសត្រូវលើការបំពានទៅលើជនរងគ្រោះ។ ជនរងគ្រោះមួយចំនួននឹងវាយតបត និងតដៃ។ ជាញឹកញាប់ គ្រឿងស្រវឹងនិងគ្រឿងញៀនផ្សេងទៀតត្រូវបានប្រើប្រាស់ជាយន្តការដោះស្រាយ និងអាចប៉ះពាល់ដល់ការពិចារណា និងហាក់បង្ហាញថា ជនរងគ្រោះមិនជួយជ្រោមជ្រែង ឬការយល់ថា "ទាំងជនរងគ្រោះ និងជនបង្កគឺមិនល្អដូចគ្នា"។

ការឆ្លើយតបសំខាន់ៗរបស់នគរបាលនៅដំណាក់កាលនេះគឺត្រូវព្យាយាមដេញដោលបញ្ហានៃការស្តីបន្ទោសដោយគួសបញ្ជាក់ថាជនរងគ្រោះមិនមែនជាអ្នកដែលត្រូវស្តីបន្ទោស និងខិតខំធ្វើឱ្យពួកគេយល់ពីរបៀបដែលពួកគេផ្លាស់ប្តូរឥរិយាបថដើម្បីសាកល្បង និងសម្រួលដល់ជនបង្ក។

**សញ្ញានៃភស្តុតាង ៖ ចំណុចត្រូវប្រុងប្រយ័ត្ន**

មន្ត្រីគួរពិចារណាសួរពីអារម្មណ៍របស់ជនរងគ្រោះចំពោះទំនាក់ទំនងនេះជាជាងគ្រាន់តែសួរថា "មានអ្វីកើតឡើង ?"

នៅពេលលើកទូរស័ព្ទមន្ត្រីគួរនិយាយជាមួយជនរងគ្រោះដោយផ្ទាល់និងដឹងថាឥរិយាបថត្រួតត្រាអាចលេចឡើងក្នុងពេលទូរស័ព្ទចូលនេះ។

- ការភ័យខ្លាចជាប់ជាប្រចាំក្នុងទំនាក់ទំនងដោយសារឥរិយាបថត្រួតត្រា
- ការស្តីបន្ទោសខ្លួនឯង
- ការសេពគ្រឿងស្រវឹង ឬគ្រឿងញៀន
- ការលើកឡើងដោយមិត្តភក្តិ/គ្រួសារ/និយោជក
- ការប្រមាថជាសាធារណៈ
- ជនបង្កវិលត្រឡប់ទៅរកដំណាក់កាលល្បួង ព្រោះពួកគេខ្លាចថា ជនរងគ្រោះអាចនឹងបញ្ចប់ទំនាក់ទំនង
- ជនបង្កនៅជាប់ជាមួយជនរងគ្រោះក្នុងពេលប្រឹក្សាវេជ្ជសាស្ត្រ និងការណាត់ជួបផ្សេងទៀត
- កន្លែងកើតហេតុមិនដូចអ្វីដែលអ្នករំពឹងទុក។

នៅពេលលើកទូរស័ព្ទមន្ត្រីគួរស្វែងរកសញ្ញាបង្កប់នៃឥរិយាបថត្រួតត្រា ដូចជា ៖

- ការប្រើដៃជាសញ្ញាដើម្បីបំបិទមាត់ជនរងគ្រោះ
- ជនបង្កស្តីបន្ទោសជនរងគ្រោះ
- ជនបង្កអះអាងពីស្ថានភាពរបស់ជនរងគ្រោះ។

ករណីមួយដែលត្រូវបានរាយការណ៍នៅសហរដ្ឋអាមេរិក

កត់សម្គាល់ពីរបៀបដែលជនរងគ្រោះលែងនិយាយ នៅពេលជនបង្កដែលរងការចោទប្រកាន់ចូលទៅក្នុងបន្ទប់។ នៅក្រោយមកទៀតទើបមន្ត្រីដឹងថា ចំណុចនេះកើតឡើងនៅពេលដែលជនបង្កដែលរងការចោទប្រកាន់ដើរចូលក្នុងបន្ទប់ដោយមានកាន់កន្សែងពោះគោពណ៌ស។ បន្ទាប់ការសួរចម្លើយ ជនរងគ្រោះនិយាយថា កន្សែងនេះត្រូវបានជនបង្កប្រើប្រាស់ជាញឹកញាប់សម្រាប់ខ្ទប់ដង្ហើមគាត់។

**ការកំណត់ការបំពាន៖** ជាញឹកញាប់ គឺក្រោយអំឡុងពេលមួយដែលជនរងគ្រោះកំណត់អ្វីដែលបានកើតឡើងថាជាការបំពាន ជាពិសេសប្រសិនបើមិនសូវមានការប្រព្រឹត្តអំពើហិង្សាផ្លូវកាយឬប្រសិនបើអំពើហិង្សាមាន"កម្រិតទាប" ប៉ុន្តែជាការបង្ខិតបង្ខំ។

នេះអាចជាដំណាក់កាលលំបាកសម្រាប់ជនរងគ្រោះ ព្រោះពួកគេនឹងត្រូវទទួលស្គាល់ស្ថានភាពរបស់ខ្លួនជាជនរងគ្រោះ ហើយបុគ្គលដែលពួកគេស្រឡាញ់ជាជនបំពាន។ យ៉ាងហោចណាស់ ដំណាក់កាលនេះនឹងពាក់ព័ន្ធការទទួលស្គាល់ថា ការបំពានកើតឡើងជាប្រចាំ មិនមែនឧប្បត្តិហេតុដែល "កើតឡើងតែម្តង"។

ជាការល្អ ភ្នាក់ងារឆ្លើយតបគួរជួយដល់ជនរងគ្រោះឱ្យដេញដោលផ្នត់គំនិតអំពី "ជនរងគ្រោះ" និង "ជនបង្ក" ដែលរងការចោទប្រកាន់។ដូច្នេះមន្ត្រីត្រូវផ្តល់សុពលភាពលើបទពិសោធន៍របស់ជនរងគ្រោះ និងមិនត្រូវស្តីបន្ទោសពួកគេឡើយ។ ការនិយាយថា "នេះមិនមែនជាកំហុសរបស់អ្នក" ទៅកាន់ជនរងគ្រោះអាចជួយផ្តល់កម្លាំងចិត្តដល់ពួកគេ។

**សញ្ញានៃភស្តុតាង ៖ ចំណុចត្រូវប្រុងប្រយ័ត្ន**
- ការលើកឡើងលម្អិតដោយជនរងគ្រោះដោយមានការបង្ហាញការបំពាន
- ការទទួលស្គាល់ស្ថានភាពជាជនរងគ្រោះ
- ការទទួលស្គាល់ថា ដៃគូគឺជាជនបង្ក
- ជនរងគ្រោះទូរស័ព្ទប្តឹងពីការបំពាននេះ។

**ការវាយតម្លៃទំនាក់ទំនងឡើងវិញ ៖** នៅពេលជនរងគ្រោះទទួលស្គាល់ថាអ្វីដែលកើតឡើងចំពោះគាត់គឺជាការបំពាន គាត់អាចចាប់ផ្តើមវាយតម្លៃទំនាក់ទំនងទាំងស្រុងឡើងវិញ។

ជនរងគ្រោះអាចបន្តប្រើប្រាស់យុទ្ធសាស្ត្រគ្រប់គ្រងការបំពាន។ ការចាកចេញ (បណ្តោះអាសន្ន ឬជារៀងរហូត) ហើយការសុំជំនួយពីប្រព័ន្ធគាំទ្រផ្លូវការ នឹងលេចឡើងកាន់តែច្បាស់។

អន្តរាគមន៍នៅដំណាក់កាលនេះ អាចជាការស្វែងយល់ពីឧបសគ្គជាក់ស្តែងដែលរារាំងការចាកចេញពីទំនាក់ទំនងនេះ។

ជាថ្មីម្តងទៀតមន្ត្រីគួរខិតខំផ្តល់សុពលភាពលើបទពិសោធន៍របស់ជនរងគ្រោះ។

**សញ្ញានៃភស្តុតាង ៖ ចំណុចត្រូវប្រុងប្រយ័ត្ន**
- ស្វ័យឆ្លុះបញ្ចាំងដោយជនរងគ្រោះ
- ការរៀបចំផែនការសុវត្ថិភាព
- ការប្រាស្រ័យទាក់ទងជាមួយសេវាជនរងគ្រោះ
- ការបន្តនៅជាមួយជនបង្ករហូតដល់មានសុវត្ថិភាពអាចចាកចេញបាន
- ការនិយាយជាមួយមិត្តភក្តិ/គ្រួសារ/នគរបាលអំពីការចាកចេញពីទំនាក់ទំនង។

**ការបញ្ចប់ទំនាក់ទំនង ៖** ការសំខាន់ត្រូវចងចាំថា ជនរងគ្រោះជាច្រើនប៉ុនប៉ងចាកចេញពីដៃគូបំពានជាច្រើនលើកច្រើនសា មុននឹងអាចសម្រេចបានជោគជ័យ។

ជាញឹកញាប់ មូលហេតុនៃការមិនបញ្ចប់ទំនាក់ទំនងនឹងមានភាពជាក់ស្តែង និងរួមបញ្ចូលឥរិយាបថគ្រួតត្រា និងកលវិធីចម្រុះ និងការសន្យាកែប្រែ លំនៅដ្ឋាន ការគាំទ្រផ្នែកសេដ្ឋកិច្ច និងកូន សម្ពាធពីគ្រួសារ និងការខ្លាចថាពួកគេមិនអាចធានាសុវត្ថិភាពផ្ទាល់ខ្លួនបាន។

ភ្នាក់ងារឆ្លើយតបដំបូងត្រូវដឹងពីលក្ខខណ្ឌចាំបាច់ក្នុងការរៀបចំផែនការសុវត្ថិភាពចំពោះមុខ និងធានាការបញ្ជូនជនរងគ្រោះទៅរកសេវាគាំទ្រឯកទេសដែលអាចជួយដល់ពួកគេក្នុងការសម្រេចចិត្តដ៏លំបាកអំពីអនាគត។

ការបង្កើត "ចន្លោះសម្រាប់សកម្មភាព" ជាការសំខាន់ ហើយ ភ្នាក់ងារឆ្លើយតបអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតចន្លោះនោះតាមរយៈការបំបែកជនបង្កចេញពីជនរងគ្រោះ និងចាប់ខ្លួន ប្រសិនបើមានមូលដ្ឋានគ្រប់គ្រាន់។

**សញ្ញានៃភស្តុតាង**

- ផែនការសុវត្ថិភាព
- ការពិភាក្សាជាមួយសេវាជនរងគ្រោះ
- ការបន្តរស់នៅជាមួយជនបង្ករហូតដល់មានសុវត្ថិភាពអាចចាកចេញបាន។

**ការបញ្ឈប់ការបំពាន** ៖ ការសំខាន់ត្រូវកត់សម្គាល់ថា ការបញ្ឈប់ទំនាក់ទំនងមិនសុទ្ធតែមានន័យថាជាការបញ្ឈប់អំពើហិង្សា និងការបំពាននោះទេ។ អំឡុងពេលក្រោយការបែកផ្លូវគ្នាអាចជាដំណាក់កាលគ្រោះថ្នាក់បំផុត។ ជនរងគ្រោះជាច្រើនរងគ្រោះដោយការបំពានបន្ទាប់ពីការបែកផ្លូវគ្នានេះ ហើយភ្នាក់ងារឆ្លើយតបត្រូវកត់សម្គាល់ពីគ្រោះថ្នាក់កាន់តែច្រើន។ ទំនាក់ទំនងជាមួយកូនអាចជាបញ្ហាដ៏ធំក្រោយការបែកផ្លូវគ្នា។ ជនប្រព្រឹត្តអំពើរំលោភបំពានជាច្រើនបន្តសាកល្បង និងគ្រប់គ្រងលើទំនាក់ទំនងជាមួយកូន ហើយជនរងគ្រោះ និងកូនត្រូវបានបំពាន និងសម្លាប់ នៅពេលដែលជនបង្កទៅលេងកូនពេលមានការអនុញ្ញាតពីតុលាការ។

**សញ្ញានៃភស្តុតាង**

- ការបន្តទំនាក់ទំនងជាមួយជនបង្កដែលពាក់ព័ន្ធនឹងកូន
- ទំនាក់ទំនងរបស់ជនបង្កតាមទូរស័ព្ទចល័តនៅកន្លែងធ្វើការ ឬតាមរយៈមិត្តភក្តិ និងគ្រួសារ។

## ឧបសម្ព័ន្ធ ២
## អំពើហិង្សា/ការបំពានដើម្បីកិត្តិយស និងការអនុវត្តដែលបង្កគ្រោះថ្នាក់ដូចជាអាពាហ៍ពិពាហ៍កុមារ អាពាហ៍ពិពាហ៍វ័យក្មេង ដោយការបង្ខិតបង្ខំ និងការកាត់ប្រដាប់បន្តពូជស្ត្រី

ដោយ Gerry Campbell MBE FCMI AFHEA ប្រធានផ្នែកស៊ើបអង្កេត (ចូលនិវត្តន៍) Scotland Yard

### តើអ្វីជាអំពើហិង្សា/ការបំពានដើម្បីកិត្តិយស?

ដើម្បីកំណត់និយមន័យនៃការបំពានដើម្បីកិត្តិយស ការសំខាន់ត្រូវយល់ពីអត្ថន័យនៃពាក្យ "កិត្តិយស" ជាមុនសិន។ អាចមានការលើកឡើងថាវប្បធម៌ទាំងអស់នៅជុំវិញពិភពលោកប្រកាន់យក ក្រមកិត្តិយសជាធំ។

ជានិច្ចជាកាល វាជាការផ្តោតសំខាន់លើវិធានដែលបានកំណត់ក្នុងសង្គមរបស់យើងនូវឥរិយាបថដែលអាចទទួលយកបាន និងមិនអាចទទួលយកបាន "ប្រការគួរ និងមិនគួរ"។ ក្នុងវប្បធម៌មួយចំនួន ក្រមកិត្តិយសគឺជាបែបផែននៃជីវិត។



Gerry Campbell
MBE FCMI AFHEA
ប្រធានផ្នែកស៊ើបអង្កេត
(ចូលនិវត្តន៍)
Scotland Yard

កិត្តិយសសំដៅលើការគោរព ឬការផ្តល់តម្លៃខ្ពស់ និងជាចរិតលក្ខណៈវិជ្ជមានដែលពាក់ព័ន្ធនឹងសុចរិតភាព និងសីលធម៌ល្អ។ បុគ្គលដែលមានគុណសម្បត្តិទាំងនេះ ត្រូវបានពិពណ៌នាជាបុគ្គលមាន "កិត្តិយស"[185] ដែលរួមបញ្ចូលគុណសម្បត្តិវិជ្ជមានផ្សេងទៀត ដូចជាទំនុកចិត្ត និងការ

185. Vandello, J. A. & Cohen, D. (2003), 'Male honor and female fidelity: Implicit cultural scripts that perpetuate domestic violence', Journal of Personality and Social Psychology, 84, at p 997.

គោរព និងពាក់ព័ន្ធទៅនឹងស្ថានភាព និងកេរ្តិ៍ឈ្មោះផងដែរ។កិត្តិយសជាអ្វីដែលសំខាន់បំផុតក្នុងក្រសែភ្នែករបស់បុគ្គលនោះផ្ទាល់ ក៏ដូចជាសង្គមទាំងមូល។

ផ្នែកដ៏សំខាន់មួយនៃវប្បធម៌កិត្តិយសនេះពាក់ព័ន្ធគ្នានឹងកេរ្តិ៍ឈ្មោះ និងស្ថានភាពរបស់បុគ្គលម្នាក់ក្នុងសហគមន៍។

អាចមានផលប៉ះពាល់យ៉ាងខ្លាំងនៅពេលមានការសន្មតពីការរំលោភកិត្តិយស ដែលអាចឈានទៅរកការដាក់ "ទណ្ឌកម្មហិង្សា" ដើម្បីការពារកិត្តិយសរបស់បុគ្គល ឬគ្រួសារ។ ទណ្ឌកម្មហិង្សាទាំងនេះអាចធ្វើឡើងយ៉ាងឆាប់រហ័ស និងអាចជាការប្រើប្រាស់កម្លាំងដែលនឹកស្មានមិនដល់រហូតឈានដល់ការបាត់បង់អាយុជីវិត។

**ករណីសិក្សា ៖ ការសម្លាប់លោកស្រី** Banaz MAHMOD (២០០៦)

"នេះជាបទល្មើសយ៉ាងសាហាវព្រៃផ្សៃ និងគ្មានក្តីមេត្តា...។ ដើម្បីស្តារកិត្តិយសរបស់គ្រួសារ ឪពុក និងពូរបស់នាងសម្រេចថា នាងគួរតែស្លាប់ និងគួរលុបការចងចាំរបស់នាង" (ចៅក្រម Brian Barker)។
លោកស្រី Banaz Mahmod កើតនៅតំបន់ Kurdistan ប្រទេសអ៊ីរ៉ាក់ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៨៥។ នៅអាយុ ១០ ឆ្នាំ Banaz បានផ្លាស់ទៅរស់នៅចក្រភពអង់គ្លេសជាមួយគ្រួសារ ជាទីដែលពួកគេទទួលបានសិទ្ធិជ្រកកោន។ នៅអាយុ ១៧ ឆ្នាំ Banaz ត្រូវគេរៀបការផ្សំផ្គុំជាមួយបុរសម្នាក់ដែលមានអាយុបងនាង ១០ ឆ្នាំ។ ពីរឆ្នាំក្រោយមក និងបន្ទាប់ពីរងគ្រោះដោយការបំពានផ្លូវភេទ និងផ្លូវកាយ Banaz បានចាកចេញពីស្វាមី និងត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយនៅ Mitcham ទីក្រុងឡុងដ៍ ដោយមានការយល់ព្រមពីពួកគាត់។ ក្រោយការចែកផ្លូវគ្នា Banaz បានបង្កើតទំនាក់ទំនងថ្មីជាមួយបុរសម្នាក់ទៀត ដែលបុរសជាសមាជិកគ្រួសាររបស់នាងយល់ថា "មិនសក្តិសម" នឹងនាង។ Banaz និងមិត្តប្រុសរបស់នាងស្ថិតក្រោមការតាមដាន និងឃ្លាំមើលដោយសមាជិកសហគមន៍ និងត្រូវបានគេឃើញអោបថើបគ្នានៅក្រៅស្ថានីយ៍រថភ្លើងក្រោមដីទីក្រុងឡុងដ៍។
នៅខែ ធ្នូ ឆ្នាំ ២០០៥ ពូខាងឪពុករបស់ Banaz បានរៀបចំជំនួបគ្រួសារ ឬក្រុមប្រឹក្សានៅផ្ទះល្វែងមួយក្នុងទីក្រុងឡុងដ៍ ដែលបញ្ចប់ដោយឃាតវាសនារបស់ Banaz ព្រោះនាងត្រូវបានគេចាត់ទុកថាជាអ្នកបង្កភាពអាម៉ាស់ដល់ក្រុមគ្រួសារ។
នៅអំឡុងខែ កញ្ញា ឆ្នាំ ២០០៥ និងខែ មករា ឆ្នាំ ២០០៦ Banaz បានទូរស័ព្ទទៅនគរបាលក្រុងឡុងដ៍ និងមន្ត្រីនគរបាលតំបន់ West Midland (Birmingham ចក្រភពអង់គ្លេស) ចំនួន ៥ ដង ពីបទចោទប្រកាន់ធ្ងន់ធ្ងរ រួមទាំងការប្រទូស្តកេរខ្មាស និងការគំរាមសម្លាប់។ គណៈកម្មការបណ្តឹង ឯករាជ្យនៃនគរបាល (បច្ចុប្បន្នហៅថាការិយាល័យស៊ើបអង្កេតបណ្តឹងសាធារណៈដោយឯករាជ្យ) ក្រោយមករកឃើញថា មន្ត្រីនគរបាលមួយចំនួនមិនបានធ្វើការស៊ើបអង្កេតបទចោទប្រកាន់ទាំងនេះឱ្យបានគ្រប់គ្រាន់ (IPCC ខែ វិច្ឆិកា ឆ្នាំ ២០០៨)។
វេលាមួយនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៥ អ្នកជិតខាងម្នាក់របស់ជីដូន Banaz បានប្តឹងនគរបាលអំពីការបែកកញ្ចក់ទ្វារផ្ទះរបស់ Banaz។ Banaz បានវាយបំបែកកញ្ចក់នោះដើម្បីគេចខ្លួនចេញពីឪពុករបស់នាងដែលបានឱ្យនាងញ៉ាំស្រា Brandy យ៉ាងដោតជាំ។ Banaz បានរត់ទៅហាងកាហ្វេនៅជិតនោះ ហើយបុគ្គលិក និងអតិថិជននៅទីនោះមើលឃើញថា នាងមានទុក្ខព្រួយ ហើយដៃរបស់នាងហូរឈាម។ Banaz ប្រាប់ពួកគេថា នាងត្រូវបានគេបង្ខំឱ្យញ៉ាំស្រា មានគេ "តាមដាននាង" ដូច្នេះ នាងត្រូវវាយបំបែកបង្អួចដើម្បីរត់ចេញ។ បន្ទាប់មក រថយន្តសង្គ្រោះ និងនគរបាលបានទៅដល់កន្លែងកើតហេតុ។ Banaz បានប្រាប់បុគ្គលិករថយន្តសង្គ្រោះថា នាងបានវាយបំបែកបង្អួច និងថា ឪពុករបស់នាងបង្ខំឱ្យនាងញ៉ាំគ្រឿងស្រវឹង និងព្យាយាមសម្លាប់នាង។ នាងនិយាយទៀតថា "ពួកគេ" នឹងសម្លាប់មិត្តប្រុសរបស់នាង (លោក Rahmat Suleimani)។
Rahmat និយាយថា Banaz បានប្រាប់មន្ត្រីនគរបាលថា នាងជឿថា ឪពុក និងពូរបស់នាងចង់សម្លាប់នាង។
នៅល្ងាចថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៦ បុរស ៤ នាក់បានស្ទាក់ផ្លូវមិត្តប្រុសរបស់ Banaz និងសុំឱ្យគាត់ទៅ

ជាមួយពួកគេ ហើយនៅពេលគាត់បដិសេធ បុរសទាំងនោះបានគំរាមសម្លាប់គាត់ និង Banaz។ គាត់បានរាយការណ៍ករណីនេះទៅនគរបាល។ នៅថ្ងៃទី ២៣ ខែ មករា Banaz បានទៅកាន់ប៉ុស្តិ៍នគរបាលដើម្បីរាយការណ៍ពីការគំរាមកំហែងនេះ។ នាងបានប្រាប់មន្ត្រីនគរបាលពីឈ្មោះរបស់បុរសដែលបានគំរាមមិត្តប្រុសរបស់នាង។ មិនយូរប៉ុន្មាន Banaz បានបាត់ខ្លួន។ នាងត្រូវបានគេរំលោភសេពសន្ថវៈ ប្របាច់កឱ្យស្លាប់ រួចញាត់ចូលក្នុងវ៉ាលី។ នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៦ Banaz ត្រូវបាន Rahmat (មិនមែនសមាជិកគ្រួសាររបស់នាង) រាយការណ៍ថាបានបាត់ខ្លួន។នគរបាលក្រុងឡុងដ៍ចាប់ផ្តើមធ្វើការស្រាវជ្រាវរកបុគ្គលបាត់ខ្លួនដែលមានហានិភ័យខ្ពស់រយៈពេល ៣ ខែ។ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៦។ សាកសពស្អុយរលួយរបស់ Banaz ត្រូវបានរកឃើញក្នុងវ៉ាលីកប់ក្រោមសួនច្បារនៅជិត Birmingham ចម្ងាយ ២០០ ម៉ាយពីផ្ទះរបស់គ្រួសារនាងនៅទីក្រុងឡុងដ៍។
នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៧ ឪពុករបស់ Banaz ឈ្មោះ Mahmod Mahmod ពូខាងឪពុករបស់នាងឈ្មោះ Ari Mahmod និងសាច់ញាតិម្នាក់ទៀតឈ្មោះ Mohammed Hama ត្រូវបានផ្តន្ទាទោសពីបទមនុស្សឃាត និងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ សមាជិកសហគមន៍ Kurdistani អ៊ីរ៉ាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសពីបទល្មើសដែលពាក់ព័ន្ធនឹងការសម្លាប់ Banaz ក៏ដូចជា ការកុហកតុលាការ និងការរារាំងការបញ្ចុះសព Banaz តាមផ្លូវច្បាប់ និងឱ្យបានសមរម្យ។
នៅខែ មីនា ឆ្នាំ ២០១៦ Rahmat Suleimani ដែលស្ថិតក្រោមការការពារដោយនគរបាលអស់រយៈពេល ១០ឆ្នាំមកហើយបានស្លាប់ក្នុងមន្ទីរពេទ្យដោយបានបញ្ចប់ជីវិតខ្លួនឯង។សេចក្តីរាយការណ៍បង្ហាញថា គាត់ធ្លាប់ព្យាយាមធ្វើអត្តឃាតពីរដងរួចមកហើយ។
Rahmat ត្រូវបានគេដកស្រង់សម្តីថា "ជីវិតរបស់ខ្ញុំពឹងផ្អែកលើនាង។ នាងជាបច្ចុប្បន្នភាព អនាគត និងក្តីសង្ឃឹមរបស់ខ្ញុំ។ នាងជាវត្ថុដ៏ល្អបំផុតក្នុងជីវិតរបស់ខ្ញុំ។ ជីវិតរបស់ខ្ញុំបានរសាត់នៅតាមការស្លាប់របស់នាង។ ពេលនេះជីវិតខ្ញុំគឺទទេ។ អ្វីដែលបន្តជីវិតរបស់ខ្ញុំគឺការរង់ចាំយុត្តិធម៌សម្រាប់ Banaz"។ Rahmat គឺជាជនរងគ្រោះម្នាក់ទៀតដោយសារការសម្លាប់ Banaz ដើម្បីរក្សាកិត្តិយស។

ក្រៅពីនេះ បញ្ញាកិត្តិយស និងកេរ្តិ៍ឈ្មោះ [Izzart (កិត្តិយស) និង "Sharam" (ភាពអាម៉ាស់)] ក្នុងសហគមន៍នៅអាស៊ីខាងត្បូងក៏ដូចជាភាសាជាច្រើនផ្សេងទៀតសម្រាប់ពាក្យពីរម៉ាត់នេះ ក៏ជះឥទ្ធិពលគួរឱ្យកត់សម្គាល់លើគំនិតកិត្តិយសផងដែរ។កិត្តិយសនិងភាពអាម៉ាស់ជាអារម្មណ៍ដ៏មានឥទ្ធិពលដែលអាចកំណត់ដោយខ្លួនឯងឬកំណត់ដោយអ្នកដទៃ និងជះឥទ្ធិពលយ៉ាងខ្លាំងលើសកម្មភាពរបស់បុគ្គល។ ខណៈដែលការរំលោភបំពានផ្អែកលើកិត្តិយសជាប្រតិកម្មមិនល្អទៅនឹងការបង្កភាពអាម៉ាស់ ឬការយល់ថារងភាពអាម៉ាស់ វាក៏ត្រូវបានប្រព្រឹត្តដើម្បីទប់ស្កាត់ ឬបញ្ចៀសការទទួលរងភាពអាម៉ាស់ផងដែរ។ ខណៈដែលស្ត្រី កុមារ និងបុរសសុទ្ធតែជាជនរងគ្រោះដោយសារអំពើហិង្សា និងការរំលោភបំពានផ្អែកលើកិត្តិយសភាគច្រើនគឺស្ត្រីនិងក្មេងស្រីទេដែលជាជនរងគ្រោះដែលធ្វើឱ្យបទល្មើសនេះក្លាយជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ពាក់ព័ន្ធនឹងគ្រោះថ្នាក់ការបំពានវប្បធម៌ឬក្រមកិត្តិយសរបស់សហគមន៍អាចពាក់ព័ន្ធនឹងបទល្មើសចម្រុះដូចជាមនុស្សឃាតការចាប់ជំរិតការដាក់ពន្ធនាគារមិនត្រឹមត្រូវការរំលោភសេពសន្ថវៈការវាយប្រហារយ៉ាងធ្ងន់ធ្ងរលើរាងកាយ (រួមទាំងការវាយប្រហារដោយទឹកអាស៊ីត ការប្រើប្រាស់អាវុធ) ការគំរាមសម្លាប់ ការបៀតបៀន ការឈ្លបចាប់ ការបំភិតបំភ័យ និងបទល្មើសជាច្រើនផ្សេងទៀត។ អង្គការសហប្រជាជាតិប៉ាន់ស្មានថា ជារៀងរាល់ឆ្នាំស្ត្រីចំនួន ៥.០០០ នាក់ ត្រូវបានសម្លាប់ដើម្បីរក្សាកិត្តិយស[188]។ តថភាពគឺស្ត្រីកាន់តែច្រើនបានបាត់ខ្លួនហើយគ្មានការរាយការណ៍ពីករណីទាំងនេះ និង/ឬមិនត្រូវបានស្តារ ឬកត់ត្រាដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ[189]។ ក្រៅពីនេះមានជនរងគ្រោះដែលបានស្លាប់ដោយសារ "ការបង្ខំ

188. ព័ត៌មានរបស់អង្គការសហប្រជាជាតិ (ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១០) https://news.un.org/en/story/2010/03/331422
189. ការសិក្សាជាសកលស្តីពីអំពើមនុស្សឃាត ការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ (UNODC ២០១៨)។

ឱ្យធ្វើអត្តឃាត” ស្លាប់ដោយសារការធ្វើពលីកម្ម របួសដោយសារកាំបិត និងមូលហេតុផ្សេងទៀត។

ការសិក្សាឆ្នាំ ២០១៨ ដោយ UNODC រកឃើញថា នៅឆ្នាំ ២០១៧ ស្ត្រីចំនួន ៨៧.០០០ នាក់នៅជុំវិញពិភពលោកត្រូវបានសម្លាប់ដោយចេតនា[190]។ ជនរងគ្រោះជាងពាក់កណ្តាល (៥៨%) ឬស្មើនឹង ៥០.០០០ នាក់ ត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល ឬសមាជិកគ្រួសារ។ មានន័យថា ស្ត្រីចំនួន ១៣៧ នាក់នៅជុំវិញពិភពលោកត្រូវបានសម្លាប់ដោយសមាជិកគ្រួសារណាម្នាក់ជារៀងរាល់ថ្ងៃ។ ស្ត្រីជាង ១ ភាគ ៣ (៣០.០០០) ត្រូវបានសម្លាប់ដោយចេតនានៅឆ្នាំ ២០១៧ ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬពីអតីត។ ចំណុចនេះស៊ីសង្វាក់គ្នានឹងការសិក្សាប្រេវ៉ាឡង់នៅឆ្នាំ ២០១៨ ដោយអង្គការសុខភាពពិភពលោក។ ការសិក្សានេះបានកត់សម្គាល់ពីការសម្លាប់ដើម្បីរក្សាកិត្តិយសនិងការសម្លាប់ដែលពាក់ព័ន្ធនឹងបណ្ណាការរបស់ស្ត្រី ក៏ដូចជាការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងអំពើអាបធ្មប់[191]ដែលជាទម្រង់មួយផ្សេងទៀតនៃការអនុវត្តដែលបង្កគ្រោះថ្នាក់។

## ការអនុវត្តដែលបង្កគ្រោះថ្នាក់

អំពើហិង្សា និងការរំលោភបំពានលើស្ត្រី មានលក្ខណៈចម្រុះនិងលេចឡើងជាមួយគ្នាក្នុងប្រធានបទពហុវិស័យ ប្រទាក់ក្រឡាគ្នា និងលាយឡំគ្នា ក្នុងបរិបទសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយផ្សេងៗ[192]។ អំពើហិង្សាលើស្ត្រីគឺជាឫសគល់ និងជាផលវិបាកនៃវិសមភាពយេនឌ័រ និងការរើសអើង[193] ហើយក៏ជាឧបសគ្គដ៏ធំមួយដែលរារាំងការសម្រេចបានសមភាពយេនឌ័រ[194]។

ប្រពៃណី ជាគំរូសកម្មភាព ឬឥរិយាបថដែលត្រូវបានបង្កើតឡើងជាយូរមកហើយ និងជាញឹកញាប់ត្រូវបានផ្ទេរបន្តក្នុងគ្រួសារ និងសហគមន៍ជាច្រើនជំនាន់។ ទំនៀមទម្លាប់ទាំងនេះផ្អែកលើជំនឿ និងគុណតម្លៃជាក់លាក់។ ជាញឹកញាប់ ប្រពៃណីត្រូវបានការពារដោយតំណម ដែលជាការហាមឃាត់ដ៏តឹងរ៉ឹងក្នុងសង្គម (ឬការហាមប្រាម) ដែលពាក់ព័ន្ធនឹងសកម្មភាពមនុស្ស ឬទំនៀមទម្លាប់សង្គម ដោយផ្អែកលើការវិនិច្ឆ័យប្រកបដោយសីលធម៌និងជំនឿសាសនា។ មានន័យថា ប្រពៃណីមិនងាយនឹងផ្លាស់ប្តូរ ព្រោះមនុស្សប្រកាន់ខ្ជាប់គំរូឥរិយាបថទាំងនេះដោយជឿថា នោះជារឿងត្រឹមត្រូវដែលត្រូវធ្វើ។

ប្រពៃណីជះឥទ្ធិពលវិជ្ជមានលើបុគ្គល គ្រួសារ និងសហគមន៍។ ទោះជាយ៉ាងណា ប្រពៃណីក៏អាចបង្កគ្រោះថ្នាក់ផងដែរ។ អង្គការសហប្រជាជាតិបានកំណត់ការរំលោភសិទ្ធិមនុស្សខាងក្រោមជាការអនុវត្តដែលបង្កគ្រោះថ្នាក់ ដែលបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងអន្តរាយដល់សុខភាព សុខុមាលភាព និងសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី មានដូចជា៖ ការវះកាត់ប្រដាប់បន្តពូជស្ត្រី ការផ្តល់អាហារដល់ស្ត្រីដោយបង្ខំ អាពាហ៍ពិពាហ៍កុមារ អាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ ការចង់បានកូនប្រុស ការសម្លាប់ទារិកា ការមានផ្ទៃពោះវ័យក្មេង និងថ្លៃបណ្ណាការ[195]។ ការអនុវត្តដែលបង្កគ្រោះថ្នាក់ផ្សេងទៀត រួមមាន បទល្មើសដើម្បីរក្សាកិត្តិយស ថ្លៃបណ្ណាការកូនក្រមុំ ការចាប់ជំរិតកូនក្រមុំ ជម្លោះសាច់សាលោហិត "ការអ៊ុត/បូម និងទុកសម្លាក” លើដើមទ្រូង។

ស្ត្រី និងក្មេងស្រីមានពិការភាពក៏ប្រឈមនឹងការអនុវត្តដែលបង្កគ្រោះថ្នាក់ ដូចស្ត្រី និងក្មេងស្រីដែលគ្មានពិការភាពដែរ ហើយពេលខ្លះ ផលវិបាកបង្កើនបន្ទុកលើពិការភាពមានស្រាប់បង្កើតឱ្យមានពិការភាពថ្មីឬបង្កើនភាពងាយរងគ្រោះដែលមានស្រាប់ និងការផាត់ចេញក្នុងសង្គម[196]។

## អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ

អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំជាអាពាហ៍ពិពាហ៍ដែល

190. Ibid
191. Ibid
192. Ibid
193. ការសិក្សាស៊ីជម្រៅរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី (A/61/122/Add.1 (2006), para 65, p.27).
194. ការសិក្សាស៊ីជម្រៅរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី (A/61/122/Add.1 (2006), para 1, p.9).
195. ឯកសារលេខ ២៣ របស់អង្គការសហប្រជាជាតិស្តីពីការអនុវត្តដែលបង្កគ្រោះថ្នាក់ក្នុងប្រពៃណីដែលជះឥទ្ធិពលលើសុខភាពរបស់ស្ត្រីនិងកុមារ៖ https://www.ohchr.org/sites/default/files/Documents/Publications/FactSheet23en.pdf
196. សារណាដែលគូសបញ្ជាក់ពីការអនុវត្តដែលបង្កគ្រោះថ្នាក់លើជនមានពិការភាព និងជាពិសេសស្ត្រី និងក្មេងស្រីមានពិការភាព (សម្ព័ន្ធជនពិការអន្តរជាតិ ២០១៧)។

ប្ដី/ប្រពន្ធ ឬទាំងប្ដី និងប្រពន្ធមិនផ្ដល់ការយល់ព្រមត្រឹមត្រូវចំពោះអាពាហ៍ពិពាហ៍នោះ ប៉ុន្តែត្រូវបានប្រទូស្តរាយគំរាមកំហែង បោកបញ្ឆោត ឬបង្ខំឱ្យរៀបការ។ ការបង្ខំឱ្យនរណាម្នាក់រៀបការ អាចមានទម្រង់ជាច្រើន និងអាចរួមមានការដាក់សម្ពាធលើផ្លូវកាយ ផ្លូវចិត្ត ហិរញ្ញវត្ថុ ផ្លូវភេទ និងផ្លូវអារម្មណ៍[197] ។

អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំដែលជាទម្រង់មួយផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាទម្រង់មួយនៃការរំលោភបំពានកុមារ និងមនុស្សពេញវ័យ ជាការរំលោភជាសារវន្តលើសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី និងជាបទល្មើសព្រហ្មទណ្ឌក្នុងប្រទេសនិងយុត្តាធិការជាច្រើន។

ខណៈដែលមានការទទួលស្គាល់ថាស្ត្រីនិងបុរសសុទ្ធតែត្រូវបានបង្ខំឱ្យរៀបការ ភាគច្រើនលើសលប់គឺស្ត្រី និងក្មេងស្រីទេដែលជាជនរងគ្រោះឬងាយរងគ្រោះដោយសារការអនុវត្តដែលបង្កគ្រោះថ្នាក់នេះ។បន្ទាប់ពីត្រូវបានបង្ខំឱ្យរៀបការ ជនរងគ្រោះប្រឈម និងរងគ្រោះដោយបទល្មើសធ្ងន់ធ្ងរផ្សេងទៀតយ៉ាងច្រើនអនេកមានដូចជាអំពើហិង្សាផ្លូវកាយ និងផ្លូវភេទ ការរំលោភបំពានផ្លូវចិត្ត និងផ្លូវអារម្មណ៍និងការធ្វើជាបាវបម្រើដាច់ថ្លៃក្នុងផ្ទះពេញមួយជីវិតដែលបង្កផលវិបាកដល់សុខភាពយ៉ាងធំធេង។

## ប្រអប់ ១៥

### អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ៖ ការពិត

- ស្ត្រីចំនួន ៧០០ លាននាក់ដែលមានជីវិតមកដល់បច្ចុប្បន្ននេះ បានរៀបការមុនអាយុ ១៨ ឆ្នាំ។ ក្នុងនោះ ស្ត្រី ២៥០ នាក់បានរៀបការនៅអាយុ ១៥ ឆ្នាំ។
- នៅឆ្នាំ ២០១៩ ក្នុងចំណោមស្ត្រី ៥ នាក់ (២០-២៤ ឆ្នាំ) មានម្នាក់បានរៀបការមុនអាយុ ១៨ ឆ្នាំ[198]។
- ប្រសិនបើគ្មានការកាត់បន្ថយអាពាហ៍ពិពាហ៍កុមារ ការឆាប់រៀបការ និងអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំទេនោះ គិតត្រឹមឆ្នាំ ២០៣០ ស្ត្រី និងក្មេងស្រីចំនួន ៩៥០ លាននាក់នឹងរៀបការមុនអាយុ ១៨ ឆ្នាំ។ តួលេខនេះនឹងកើនជិត ១,២ ពាន់លាននាក់នៅឆ្នាំ ២០៥០[199]។
- នៅទូទាំងពិភពលោកក្នុងចំណោមក្មេងស្រីជំទង់ (១៥-១៩ ឆ្នាំ) ៣ នាក់ មានជិតម្នាក់ (៨៤ លាននាក់) ក្លាយជាជនរងគ្រោះដោយសារអំពើហិង្សាផ្លូវចិត្តអំពើហិង្សាផ្លូវកាយនិង/ឬអំពើហិង្សាផ្លូវភេទដែលបង្កឡើងដោយប្ដី ឬដៃគូរបស់ខ្លួន[200]។
- ក្នុងប្រទេសដែលមានប្រាក់ចំណូលទាបនិងមធ្យម[201] ផលវិបាកដោយសារការមានផ្ទៃពោះនិងការសម្រាលកូនជាឬសគល់ធំៗដែលបណ្ដាលឱ្យក្មេងស្រីអាយុ ១៥-១៩ ឆ្នាំ បាត់បង់ជីវិត។
- បុរសចំនួន ១១៥ លាននាក់បានរៀបការមុនអាយុ ១៨ ឆ្នាំ។ ក្នុងនោះ ២៣ លាននាក់រៀបការមុនអាយុ ១៥ ឆ្នាំ[4]។

អាពាហ៍ពិពាហ៍កុមារ ដែលជាការរៀបការមុនអាយុ ១៨ ឆ្នាំលេចឡើងក្នុងប្រទេសជាច្រើននៅជុំវិញពិភពលោក រួមទាំងនៅសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។

មានកត្តាជំរុញខុសៗគ្នាជាច្រើន និងការប្រែប្រួលតាមតំបន់ ពាក់ព័ន្ធនឹងមូលហេតុនៃអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ដូចជា ការរក្សា និង/ឬការធានាទ្រព្យសម្បត្តិ និងស្ថានភាព ភាពក្រីក្រ សន្តិសុខ ការទប់ស្កាត់ការផ្ដាច់ខ្លួនពីសហគមន៍ការធានាថាមានអ្នកថែទាំកុមារដែលឈឺ និងការផ្សារភ្ជាប់នឹងទម្រង់ផ្សេងទៀតនៃការអនុវត្តដែលបង្កគ្រោះថ្នាក់ ដូចជា ការចាប់ជំរិតកូនក្រមុំ។

197. រដ្ឋាភិបាលរបស់មហាក្សត្រី សេចក្ដីណែនាំការអនុវត្តពហុស្ថាប័ន ការគ្រប់គ្រងករណីអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ (ខែ មិថុនា ឆ្នាំ ២០១៤)។
198. អង្គការសហប្រជាជាតិនាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គមកិច្ចផ្នែកស្ថិតិ(២០២០)៖ សម្រេចបានសមភាពយេនឌ័រ និងបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីគ្រប់រូប។
199. GirlsNotBrides https://www.girlsnotbrides.org/articles/700-million-women-married-children-reveals-new-unicef-data/
200. អង្គការសុខភាពពិភពលោកមនុស្សវ័យជំទង់៖ហានិភ័យសុខភាព និងដំណោះស្រាយ (ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨) https://www.who.int/news-room/fact-sheets/detail/adolescents-health-risks-and-solutions
201. Ibid

## អាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ

ប្រពៃណីនៃអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំត្រូវបានអនុវត្ត នៅទូទាំងពិភពលោក ដែលសមាជិកគ្រួសារ ជាពិសេស ឪពុកម្តាយ ជាអ្នកដឹកនាំការរៀបចំអាពាហ៍ពិពាហ៍។ ទោះ ជាយ៉ាងណា ការសំខាន់ត្រូវញែកភាពខុសគ្នារវាងអាពាហ៍ ពិពាហ៍តាមការផ្សំផ្គុំ និងអាពាហ៍ពិពាហ៍ដោយការបង្ខិត បង្ខំ។ ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយពិតជាអាពាហ៍ពិពាហ៍ តាមការផ្សំផ្គុំ អាពាហ៍ពិពាហ៍នោះត្រូវផ្អែកលើភាពសក្តិ សមគ្នា ជម្រើស និងការផ្តល់ការយល់ព្រមត្រឹមត្រូវពី សំណាក់ភាគីទាំងសងខាង។

អ្នកចូលរួមប្រារព្ធអាពាហ៍ពិពាហ៍ នគរបាល អ្នកជំនាញ អនុវត្តន៍ច្បាប់ផ្សេងទៀត សមាជិកគ្រួសារសាច់ឆ្ងាយ និង សមាជិកសហគមន៍ត្រូវដឹងថា អាពាហ៍ពិពាហ៍ដោយការ បង្ខិតបង្ខំអាច "មានលក្ខណៈ" ដូចអាពាហ៍ពិពាហ៍តាមការ ផ្សំផ្គុំដោយមានការព្រមព្រៀងដែរ។ ដូច្នេះ ការសំខាន់គឺ ទោះបីជាសហគមន៍គាំទ្រការអនុវត្តដែលបង្កគ្រោះថ្នាក់ ដែលរំលោភសិទ្ធិមនុស្សនិងច្បាប់ជាតិនិងច្បាប់អន្តរជាតិ ក្តី ក៏រដ្ឋសមាជិក និងរដ្ឋាភិបាលតំបន់ ស្ថាប័នត្រួតពិនិត្យ និង ស្ថាប័នអនុវត្តន៍ច្បាប់ ត្រូវផ្តោតការយកចិត្តទុកដាក់ ខ្ពស់លើការការពារកុមារពីការរើសអើងគ្រប់ទម្រង់។

**ប្រអប់ ១៦**

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ៥ មាត្រា ២ ចែងថា ៖**

១.រដ្ឋភាគីត្រូវគោរពនិងធានាសិទ្ធិដែលចែងក្នុងអនុសញ្ញា នេះដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជ សាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬ មតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើត ជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមាររបស់ឪពុកម្តាយកុមារ ឬអ្នកដែលជាអាណាព្យាបាលស្របច្បាប់របស់កុមារ។

២.រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បី ធានាឱ្យកុមារបានទទួលនូវការការពារប្រឆាំងនឹង រាល់ទម្រង់នៃការរើសអើងឬទណ្ឌកម្មដែលផ្អែកលើ មូលដ្ឋានស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬ ជំនឿរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកគ្រួសាររបស់កុមារ។

ក្នុងឆាកអន្តរជាតិ ស្ថាប័ននគរបាល និងស្ថាប័នអនុវត្តន៍ ច្បាប់ និងមន្ត្រីរបស់ស្ថាប័នទាំងនេះមានគោលបំណង ស្នូលក្នុងការការពារអាយុជីវិត ទប់ស្កាត់ និងស្រាវជ្រាវ បទល្មើស និងរក្សា សណ្តាប់ធ្នាប់ និងសន្តិសុខ។

ក្នុងសេចក្តីណែនាំពហុស្ថាប័នស្តីពីអាពាហ៍ពិពាហ៍ដោយការ បង្ខិតបង្ខំ រដ្ឋាភិបាលចក្រភពអង់គ្លេសគាំទ្រគោលគំនិត "វិធានមានឱកាសតែមួយលើក" ដល់មន្ត្រីនគរបាល និង អ្នកជំនាញផ្សេងទៀតក្នុងការគ្រប់គ្រងករណីអាពាហ៍ ពិពាហ៍ដោយការបង្ខិតបង្ខំ[69]។ គោលគំនិតនេះគូសបញ្ជាក់ ថាអ្នកជំនាញមាន "ឱកាសតែម្តង" ប៉ុណ្ណោះក្នុងការធានា សុវត្ថិភាព ការពារ និងសង្គ្រោះបុគ្គលពីការរងគ្រោះ ឬការ រងគ្រោះបន្ថែមទៀត។ គោលគំនិតនេះផ្តោតលើការលើ កទឹកចិត្តឱ្យអ្នកជំនាញចាត់វិធានការវិជ្ជមានក្នុងការធានា សុវត្ថិភាពនិងការពារជនរងគ្រោះនិងអ្នកដែលអាចក្លាយ ជាជនរងគ្រោះ ពីគ្រោះថ្នាក់។

**ប្រអប់ ១៧**

**Bea* អាយុ ១៤ ឆ្នាំ**

Bea ជាក្មេងស្រីអាយុ ១៤ ឆ្នាំ មកពីប្រទេសកេនយ៉ា ដែលត្រូវបានបង្ខំឱ្យរៀបការនៅពេលសាលាវាំកង។ គាត់ ត្រូវរៀបការជាមួយបុរសអាយុ ៦៧ ឆ្នាំ បន្ទាប់ពីឪពុកម្តាយ បានលក់នាងជាថ្នូរនឹងស្លឹកតែ ២ គីឡូក្រាម និងស្ករ ១០ គីឡូក្រាម (ថ្លៃបណ្ណាការ)។

ជារឿងធម្មតាទេដែលនៅថ្ងៃដែលអនាគតស្វាមីរបស់ នាងមកទទួលយកនាង Bea ប្រកែកថាមិនរៀបការ ជាមួយគាត់។ បុរសនោះបានចាកចេញទៅវិញ បន្ទាប់ពី បានប្រាប់ឪពុករបស់នាងថា គាត់នឹងត្រឡប់មកម្តងទៀត នៅពេលនាងស្ងប់អារម្មណ៍។ នៅពេលបុរសនោះចេញ ផុតពីផ្ទះរបស់នាង ឪពុកនាងមានអារម្មណ៍ខ្មាសអៀន និងខឹងសម្បារយ៉ាងខ្លាំង ដែល Bea ធ្វើឱ្យគាត់បាត់បង់ កិត្តិយស ដោយសារតែនាងមិនស្តាប់តាមគាត់ និង បដិសេធមិនរៀបការ។

ដូច្នេះBeaត្រូវទទួលទណ្ឌកម្មដោយបងប្អូនប្រុសរបស់ នាងសង្កត់នាងផ្ទប់ទៅនឹងដី ហើយឪពុករបស់នាងយក កូនកាំបិតមកកាត់ទងត្រចៀករបស់នាង។

69. 69 Ibid

បន្ទាប់ពីរបួសសះស្បើយ Bea ត្រូវបានបញ្ជូនឱ្យទៅរៀបការជាមួយបុរសអាយុ៦៧ឆ្នាំនោះ។បន្ទាប់មកBea ត្រូវបានសង្គ្រោះ និងកំពុងរស់នៅដោយសុវត្ថិភាពក្នុងមណ្ឌលសង្គ្រោះមួយជាមួយក្មេងស្រីជាច្រើននាក់ផ្សេងទៀតដែលត្រូវបានសង្គ្រោះចេញពីអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំដែលនឹងរៀបចំឡើង ឬមានជោគវាសនាស្រដៀងគ្នា។

*មិនមែនជាឈ្មោះពិតរបស់ជនរងគ្រោះ។

វិធាននេះត្រូវបានបង្កើតឡើងសម្រាប់អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ប៉ុន្តែគេអាចផ្លាស់ប្តូរវិធាន "មានឱកាសតែមួយលើក" ក្នុងផ្នែកយ៉ាងទូលំទូលាយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

## ការវះកាត់ប្រដាប់បន្តពូជស្ត្រី

ការវះកាត់ប្រដាប់បន្តពូជស្ត្រី នៅតែជាបញ្ហាប្រឈមដ៏គួរឱ្យកត់សម្គាល់សម្រាប់នគរបាលស៊ើបអង្កេត និងអយ្យការក្នុងយុត្តាធិការជាច្រើននៅជុំវិញពិភពលោកដែលបញ្ហានេះត្រូវបានកំណត់ជាបទល្មើស[67]។

អង្គការសុខភាពពិភពលោក បានកំណត់ការវះកាត់ប្រដាប់បន្តពូជស្ត្រីថា រួមបញ្ចូលរាល់នីតិវិធីដែលពាក់ព័ន្ធនឹងការកាត់ចេញប្រដាប់ភេទខាងក្រៅរបស់ស្ត្រីមួយផ្នែក ឬទាំងស្រុង ឬរបួសផ្សេងទៀតលើសរីរាង្គភេទរបស់ស្ត្រីដោយសារមូលហេតុមិនមែនវេជ្ជសាស្ត្រ[68]។

ការវះកាត់ប្រដាប់បន្តពូជស្ត្រីជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើសុខភាព និងសុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី និងអាច បណ្តាលឱ្យបាត់បង់អាយុជីវិត[69]។

ដូច្នេះ មន្ត្រីនគរបាល និងថ្នាក់ដឹកនាំត្រូវទទួលស្គាល់ថា ការវះកាត់ប្រដាប់បន្តពូជស្ត្រីបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើរូបរាងកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ។ របួសរាងកាយទាំងនេះគឺស្រដៀងគ្នានឹងរបួសដោយសារការចាក់ ឬកាប់នឹងកាំបិត។

### ប្រអប់ ១៨
**ការវះកាត់ប្រដាប់បន្តពូជស្ត្រី ៖ ការពិត** [202]

- ការវះកាត់ប្រដាប់បន្តពូជស្ត្រី រួមបញ្ចូលនីតិវិធីដែលមានចេតនាកែប្រែ ឬបង្ករបួសលើសរីរាង្គភេទរបស់ស្ត្រី ដោយសារមូលហេតុមិនមែនវេជ្ជសាស្ត្រ។
- នីតិវិធីទាំងនោះមិនផ្តល់អត្ថប្រយោជន៍សុខភាពដល់ក្មេងស្រី និងស្ត្រីទេ។
- នីតិវិធីអាចបណ្តាលឱ្យហូរឈាមច្រើន ឬមានបញ្ហាក្នុងការបត់ជើងតូច និងគីស ជំងឺឆ្លង ក៏ដូចជាផលវិបាកក្នុងពេលសម្រាលកូន និងហានិភ័យកាន់តែខ្ពស់នៃមរណភាពទារក។
- ក្មេងស្រី និងស្ត្រីជាង ២០០ លាននាក់ដែលមានជីវិតមកទល់បច្ចុប្បន្ននេះ ត្រូវបានវះកាត់ប្រដាប់បន្តពូជក្នុង ៣០ ប្រទេសនៅអាហ្វ្រិក មជ្ឈិមបូព៌ា ជាទីសំបូរដោយករណីវះកាត់ប្រដាប់បន្តពូជ។
- ការវះកាត់ប្រដាប់បន្តពូជស្ត្រីភាគច្រើនអនុវត្តលើក្មេងស្រី (ទារកភាព-អាយុ ១៥ ឆ្នាំ)។
- ការវះកាត់ប្រដាប់បន្តពូជស្ត្រីជាការរំលោភសិទ្ធិមនុស្សរបស់ក្មេងស្រី និងស្ត្រី។
- ការវះកាត់ប្រដាប់បន្តពូជស្ត្រីចែកចេញជា ៤ ប្រភេទ (សូមមើលខាងក្រោម)។

នៅឆ្នាំ ១៩៩៧ អង្គការសុខភាពពិភពលោកបានបែងចែកការវះកាត់ប្រដាប់បន្តពូជស្ត្រីជា ៤ ប្រភេទធំៗ ដូចខាងក្រោម ៖

- **ប្រភេទទី ១** ៖ ជាញឹកញាប់ សំដៅលើការកាត់សិរ មួយផ្នែក ឬទាំងស្រុង (ផ្នែកតូចមួយ ងាយរំញោច និងអាចបះរឹង នៃយោនីស្ត្រី) និងក្នុងករណីកម្របំផុត កាត់តែស្បែកប្រដាប់ភេទ (ផ្នត់ស្បែកជុំវិញសិរ)។

202. Ibid

- **ប្រភេទទី ២៖** ជាញឹកញាប់ សំដៅលើការកាត់សិរ និង បបូរទ្វារមាសខាងក្នុងមួយផ្នែកឬទាំងស្រុង(ផ្នត់ស្បែកខាងក្នុងនៃយោនី) ដោយមាន ឬគ្មានការកាត់ចេញបបូរទ្វារមាសខាងក្រៅ(ផ្នត់ស្បែកខាងក្រៅនៃយោនី)។
- **ប្រភេទទី ៣៖** ជាញឹកញាប់សំដៅលើការដេរភ្ជិតយោនីតាមរយៈការដាក់សន្ទះបិទ។ សន្ទះនេះបង្កើតឡើងដោយការកាត់ និងប្តូរទីតាំងបបូរទ្វារមាសខាងក្នុង ឬបបូរទ្វារមាសខាងក្រៅ ដែលពេលខ្លះតាមរយៈការដេរភ្ជិត ដោយគ្មាន ឬមានការកាត់សិរចេញ។
- **ប្រភេទទី ៤៖** រួមបញ្ចូលរាល់នីតិវិធីដែលបង្កគ្រោះថ្នាក់ផ្សេងទៀតលើប្រដាប់ភេទស្ត្រី សម្រាប់គោលបំណងមិនមែនវេជ្ជសាស្ត្រ ដូចជា ការចាក់ ការបោះទម្លុះ ការកាត់ចេញការកោសនិងការអុជបរិវេណប្រដាប់ភេទ។

ការស្រាយការដេរភ្ជិតសំដៅលើការកាត់បើកសន្ទះយោនីដែលបានបិទភ្ជិតលើស្ត្រីដែលត្រូវបានដេរភ្ជិតយោនីដែលជាញឹកញាប់គឺចាំបាច់សម្រាប់ការបង្កើនសុខភាព និង សុខុមាលភាព ក៏ដូចជាអនុញ្ញាតឱ្យរួមសង្វាស ឬសម្រួលដល់ការសម្រាលកូន[203]។

មានមូលហេតុនិងកត្តាជំរុញជាច្រើនដែលនាំឱ្យមានការវះកាត់ប្រដាប់បន្តពូជស្ត្រីដោយគ្រួសារ និងសហគមន៍ ដូចជាការគ្រប់គ្រងស្វ័យភាពផ្លូវភេទរបស់ស្ត្រីនិង"ជាញឹកញាប់ត្រូវបានជំរុញដោយជំនឿជុំវិញអ្វីដែលចាត់ទុកជាឥរិយាបថផ្លូវភេទដែលអាចទទួលយកបាន"[204] ។

ការស៊ើបអង្កេត និង/ឬការផ្តន្ទាទោសការវះកាត់ប្រដាប់បន្តពូជកាន់តែមានការលំបាក ដោយសារកត្តាចម្រុះដូចខាងក្រោម[205]៖

- ការកំណត់ពេលនៃការវះកាត់ប្រដាប់បន្តពូជស្ត្រី (០-១៥ឆ្នាំ)។ជនរងគ្រោះមិនចងចាំថាតើមានការវះកាត់ប្រដាប់បន្តពូជស្ត្រី ឬទេ ឬពេលណា និងមានបញ្ហាបន្ថែមទៀតលើការកំណត់ពេលសះរបួស។
- ពេលខ្លះការពាក់ព័ន្ធរបស់ម្តាយ និងស្ត្រីជាសាច់ញាតិផ្សេងទៀតបង្កផលប៉ះពាល់លើការសម្រេចចិត្តរបស់ជនរងគ្រោះទាក់ទិននឹងនគរបាល អយ្យការ និង អាជ្ញាធរផ្សេងទៀតជាមួយគ្រួសារ។
- សម្រាប់ជនរងគ្រោះ ដែលមានភាពសកម្មជាមួយនគរបាល ឬអាជ្ញាធរផ្សេងទៀត ចំណុចនេះអាចនាំទៅរកការផ្តាច់ចេញពីសង្គម និងសហគមន៍។
- ជនរងគ្រោះ មិនចង់ដាក់ទោសព្រហ្មទណ្ឌ ឬធ្វើឱ្យមានការប៉ះពាល់ដល់សាសនារបស់ខ្លួន។ទោះបីជាគ្មានអត្ថបទសាសនាដែលកំណត់ពីការអនុវត្តនេះក្តី ក៏ជាញឹកញាប់ អ្នកអនុវត្តជឿថា ការអនុវត្តដូច្នេះមានមូលដ្ឋានខាង  សាសនា។
- រចនាសម្ព័ន្ធអំណាច និងសមត្ថកិច្ចក្នុងមូលដ្ឋាន ដូចជាអ្នកដឹកនាំសហគមន៍ អ្នកដឹកនាំបែបប្រពៃណី និងមេដឹកនាំសាសនា អ្នកកាត់ស្បែកអង្គជាតិ និងសូម្បីតែបុគ្គលិកវេជ្ជសាស្ត្រមួយចំនួនអាចរួមចំណែកដល់ការប្រកាន់ខ្ជាប់ការអនុវត្តនេះដែលដាក់សម្ពាធបន្ថែមលើជនរងគ្រោះ។

កត្តាខាងលើគូសបញ្ជាក់ពីសារៈសំខាន់របស់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល និងអ្នកផ្សេងទៀតដែលសហការ និងបង្កើតកិច្ចព្រមព្រៀងភាពជាដៃគូជាមួយសមាជិក សហគមន៍ អ្នកដឹកនាំសហគមន៍ មេធាវី អ្នកដឹកនាំបែបប្រពៃណី និងមេដឹកនាំសាសនា អយ្យការ អ្នកជំនាញសុខភាព និងសង្គមកិច្ច។ ទំនាក់ទំនង និងការជំរុញការចូលរួមរបស់សហគមន៍ដែលរងផលប៉ះពាល់ និងអ្នកជំនាញផ្សេងទៀតមានសារៈសំខាន់ក្នុងការកសាងការយល់ដឹង និងបង្កើតទំនុកចិត្ត និងភាពជឿជាក់ក្នុងការចាត់វិធានការវិជ្ជមានដើម្បីរាយការណ៍ករណីវះកាត់ប្រដាប់បន្តពូជស្ត្រី និងទប់ស្កាត់មិនឱ្យករណីនេះកើតឡើងតាំងពីដំបូង។

203. Ibid
204. Ibid
205. Ibid



Gerry Campbell MBE FCMI AFHEA-
ប្រធានផ្នែកស៊ើបអង្កេត (ចូលនិវត្តន៍)
Scotland Yard

អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលមានតួនាទី៖

- ចរចា និងជះឥទ្ធិពលជាមួយស្ថាប័ន និងដៃគូផ្សេងទៀតក្នុងការបង្កើតពិធីសារ ដូចជា ការស៊ើបអង្កេត និងការផ្តន្ទាទោសកិច្ចព្រមព្រៀងស្តីពីការចែករំលែកព័ត៌មាន។ល។
- ជូនដំណឹងដល់ថ្នាក់ដឹកនាំរបស់ស្ថាប័នទាំងនោះអំពីការរៀបចំនានា។
- ផ្សព្វផ្សាយ និងកសាងការយល់ដឹងពីពិធីសារ និងការរៀបចំចម្រុះជាមួយមន្ត្រី និងបុគ្គលិករបស់ខ្លួន។
- ផ្តល់ធនធានសម្រាប់ការអនុវត្តពិធីសារ និងកិច្ចព្រមព្រៀងស្តីពីការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព
- ដើម្បីធានាការអនុវត្តពិធីសារ និងកិច្ចព្រមព្រៀងទាំងនោះដោយប្រសិទ្ធភាព។

## ការអនុវត្តល្អក្នុងការសហការលើការស៊ើបអង្កេត និងការផ្តន្ទាទោសការអនុវត្តដែលបង្កគ្រោះថ្នាក់

ឧទាហរណ៍សំខាន់ៗនៃកិច្ចព្រមព្រៀងភាពជាដៃគូក្នុងការស៊ើបអង្កេតការរំលោភបំពានផ្អែកលើកិត្តិយស អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រីដែលត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល មានបង្ហាញក្នុងសេចក្តីណែនាំរបស់ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាលចក្រភពអង់គ្លេស (NPCC)[206] និងសេវាអយ្យការ Crown (CPS)(អង់គ្លេស និងវ៉េល)[207]ដែលរួមបញ្ចូលពិធីសារដូចខាងក្រោមសម្រាប់ការស៊ើបអង្កេត និងការកាត់ទោស ៖

**១. ពិធីសារសម្រាប់ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាលចក្រភពអង់គ្លេស និងសេវាអយ្យការ Crown សម្រាប់ការស៊ើបអង្កេត និងកាត់ទោសករណីវះកាត់ប្រដាប់បន្តពូជស្ត្រី**

- ពិធីសារស្តីពីការគ្រប់គ្រងបទល្មើសនៃការវះកាត់ប្រដាប់បន្តពូជស្ត្រី រវាងក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល និងសេវាអយ្យការ Crown ។

**២. ពិធីសារសម្រាប់ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាលចក្រភពអង់គ្លេស និងសេវាអយ្យការ Crown សម្រាប់ការស៊ើបអង្កេត និងកាត់ទោសការរំលោភបំពានផ្អែកលើកិត្តិយស និងអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ**

- ពិធីសារស្តីពីការគ្រប់គ្រងបទល្មើសអំពើហិង្សា/ការរំលោភបំពានផ្អែកលើកិត្តិយសនិងអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ រវាងក្រុមប្រឹក្សាជាតិនៃស្នងការនគរបាលចក្រភពអង់គ្លេស និងសេវាអយ្យកាCrown[209]
- ការរំលោភបំពានផ្អែកលើកិត្តិយស អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំនិងការវះកាត់ប្រដាប់បន្តពូជស្ត្រី។ យុទ្ធសាស្ត្រគោលនយោបាយសម្រាប់ប្រទេសអង់គ្លេស វ៉េល និងអៀកឡង់ខាងជើង ៖ ការលុបបំបាត់ការរំលោភបំពានផ្អែកលើកិត្តិយស អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី[210]។

## ការអនុវត្តល្អក្នុងការស៊ើបអង្កេតជាលក្ខណៈបុគ្គលលើការអនុវត្តដែលបង្កគ្រោះថ្នាក់

ខាងក្រោមនេះជា "ប្រការគួរ និងមិនគួរ" មួយចំនួនក្នុងការស៊ើបអង្កេតការអនុវត្តដែលបង្កគ្រោះថ្នាក់សម្រាប់ឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលអនុវត្ត ផ្សព្វផ្សាយ និងពង្រឹងជាមួយភ្នាក់ងារឆ្លើយតបជួរមុខ និងអ្នកស៊ើបអង្កេត។ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីការអនុវត្តល្អ។

206. ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (ចក្រភពអង់គ្លេស) https://www.npcc.police.uk/
207. សេវាអយ្យការ Crown (ចក្រភពអង់គ្លេស) https://www.cps.gov.uk/
208. ពិធីសារស្តីពីការគ្រប់គ្រងបទល្មើសវះកាត់ប្រដាប់បន្តពូជស្ត្រី រវាងក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល និងសេវាអយ្យការ Crown (២០១៦) ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (ចក្រភពអង់គ្លេស)។
209. Ibid
210. ការរំលោភបំពានផ្អែកលើកិត្តិយសអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី យុទ្ធសាស្ត្រគោលនយោបាយសម្រាប់ប្រទេសអង់គ្លេស វ៉េល និងអៀកឡង់ខាងជើង ៖ ការលុបបំបាត់ការរំលោភបំពានផ្អែកលើកិត្តិយស អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (ចក្រភពអង់គ្លេស)។

## ប្រអប់ ១៩

| ប្រការគួរ | ប្រការមិនគួរ |
|---|---|
| ការពារជនរងគ្រោះ និងទប់ស្កាត់មិនឱ្យមានបទល្មើសបន្ថែមទៀត។ | ធ្វើការវិនិច្ឆ័យបែបបរានុម័តលើជនរងគ្រោះ បែបផែនជីវិត វប្បធម៌ ឬសាសនា/ជំនឿរបស់ពួកគេ។ល។ |
| បញ្ជាក់ឡើងវិញនិងបង្ហាញសមានចិត្តជាមួយជនរងគ្រោះ | សួរចម្លើយជនរងគ្រោះដោយមានវត្តមានជនបង្ក និងសាក្សី។ នៅកន្លែងកើតហេតុ សូមបំបែកភាគីពាក់ព័ន្ធ៖ ជនរងគ្រោះ ជនបង្ក និងសាក្សី។ |
| ការពាររក្សានិងធានាសុវត្ថិភាពកន្លែងកើតហេតុនិងភស្តុតាងរបស់សាក្សីដើម្បីបង្កើនការស្តារភស្តុតាងជាអតិបរមា | មិនធ្វើអ្វីទាំងអស់ |
| គ្រប់គ្រងករណីប្រកបដោយវិជ្ជាជីវៈ យកចិត្តទុកដាក់ និងរក្សាការសម្ងាត់ | ចូលដល់គ្រួសាររបស់ជនរងគ្រោះឬខិតខំពាក់ព័ន្ធក្នុងទម្រង់ណាមួយនៃការផ្សះផ្សារ(ព្រោះវាអាចបង្កើនហានិភ័យ)។ |
| ពិនិត្យឡើងវិញលើការវាយតម្លៃនិងគ្រប់គ្រងហានិភ័យដែលប៉ះពាល់ដល់ជនរងគ្រោះ និងអ្នកផ្សេងទៀត ដូចជាកុមារ មនុស្សពេញវ័យដែលងាយរងគ្រោះ និងអ្នកដែលគាំទ្រជនរងគ្រោះ។ បង្កើនផែនការគ្រប់គ្រងហានិភ័យ ឬផែនការសុវត្ថិភាព ដែលរួមបញ្ចូលផែនការគេចខ្លួន និងមធ្យោបាយទាក់ទងដែលមានសុវត្ថិភាព។ | បង្ហាញព័ត៌មានលម្អិតនៃសំណុំរឿងនេះទៅនរណាម្នាក់នៅក្រៅក្រុមស៊ើបអង្កេត ឬ "ក្រុមមនុស្សដែលទុកចិត្ត" ។ "ក្រុមមនុស្សដែលទុកចិត្ត"រួមមានIDVA[211]អ្នកឯកទេសគ្រប់គ្រងករណី មិនមែនសមាជិកក្រុមប្រឹក្សានៅមូលដ្ឋាន ចៅហ្វាយក្រុងអ្នកដឹកនាំសហគមន៍អ្នកនយោបាយដែលត្រូវបានជ្រើសតាំងឬបុគ្គលផ្សេងទៀតក្នុងជីវិតសាធារណៈ និង/ឬតួនាទីមានសមត្ថកិច្ច។ |
| គ្រប់គ្រងរក្សាទុកនិងផ្ទេរព័ត៌មានលម្អិតរបស់ជនរងគ្រោះដោយប្រុងប្រយ័ត្ន និងរក្សាការសម្ងាត់ | ធ្លាប់លើកឡើងថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនមែនជាការងារក្នុងសេវានគរបាល |
| គ្រប់គ្រងករណីផ្អែកតាមគោលការណ៍"ត្រូវដឹងជាចាំបាច់" | ធ្លាប់ប្រើសមាជិកគ្រួសារណាម្នាក់ (ជាពិសេសកុមារ) សមាជិកសហគមន៍ មិត្តភក្តិ ឬបុគ្គលគ្មានសមត្ថកិច្ចផ្សេងទៀតឱ្យជួយបកស្រាយ/បកប្រែ |
| បញ្ជាក់ឡើងវិញ និងគាំទ្រដល់ជនរងគ្រោះ ទន្ទឹមនឹងការធានាផ្តល់ព័ត៌មានបច្ចុប្បន្នភាពទាន់ពេលវេលា និងជាប្រចាំដោយប្រើមធ្យោបាយទំនាក់ទំនងដែលជនរងគ្រោះចង់បាន | ធ្វើទំនាក់ទំនងផ្ទាល់ជាមួយស្ថាប័នអនុវត្តន៍ច្បាប់បរទេស ឬមន្ត្រីរដ្ឋាភិបាលនៅពេលបទល្មើសកើតឡើងក្នុងដែនសមត្ថកិច្ចបរទេស។ អនុវត្តដូច្នេះ តែតាមរយៈការប្រើប្រាស់ប្រភពគួរឱ្យទុកចិត្ត និងដំណើរការដែលត្រូវបានអនុញ្ញាត។ |
| ស្មោះត្រង់ បើកចំហ និងមានតម្លាភាពជាមួយជនរងគ្រោះ | ដាក់បន្ទុកលើជនរងគ្រោះឱ្យការពារខ្លួន ឬកូនដោយគ្មានការគាំទ្រពីនគរបាល ស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត ឬអង្គការគាំទ្រឯកទេស។ |
| ធានាភាពអាចទទួលបានសេវារបស់អ្នកនិងជំរុញការអនុវត្តបែបបរិយាបន្នក្នុងការគ្រប់គ្រងករណី | |
| ធានាថាអ្នកគ្រប់គ្រងត្រូវបានប្រជុំពិភាក្សាពន្យល់អំពីការផ្តល់ដំបូន្មាន ការណែនាំ និងការគាំទ្រជាធនធាន ដូចជា | |

211. ទីប្រឹក្សាឯករាជ្យផ្នែកអំពើហិង្សាក្នុងគ្រួសារ

| | |
|---|---|
| ទីប្រឹក្សាកលយុទ្ធមន្ត្រីទំនាក់ទំនងគ្រួសារទីប្រឹក្សាផ្នែកសួរចម្លើយអ្នកគ្រប់គ្រងកោសលវិច័យ(អាស្រ័យលើភាពធ្ងន់ធ្ងរនិងភាពស្មុគស្មាញនៃបទល្មើស) | |
| ពិនិត្យឡើងវិញលើសកម្មភាពរបស់ភ្នាក់ងារឆ្លើយតបបឋម។ ប្រសិនបើមានហេដ្ឋារចនាសម្ព័ន្ធសមស្រប សូមផ្តិតក្រយៅដៃ DNA និងរូបថតដោយមានការផ្តល់ការយល់ព្រមត្រឹមត្រូវពីជនរងគ្រោះនិងបង្កើតដើមឈើគ្រួសារ។ | |
| បញ្ជូនជនរងគ្រោះទៅអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានទំនុកចិត្តផ្នែកតាមវប្បធម៌ | |
| បញ្ជូនសំណុំរឿងទៅអង្គភាពនគរបាលស៊ើបអង្កេតឯកទេស និង/ឬអយ្យការឯកទេស | |
| ពិចារណាប្រើប្រាស់អ្នកជំនាញផ្នែកវប្បធម៌ឬអ្នកជំនាញផ្សេងទៀតដើម្បីផ្តល់ការណែនាំក្នុងពេលស៊ើបអង្កេត។ ត្រូវយកចិត្តទុកដាក់ខ្ពស់ជានិច្ចលើការពិនិត្យគុណវុឌ្ឍិរបស់អ្នកជំនាញ និងអ្នកបកប្រែដែលបានជួល។<br>▪ ធានាថាអ្នកប្រើប្រាស់អ្នកជំនាញត្រឹមត្រូវដោយមានមូលហេតុសមស្រប) | |
| បង្កើតក្រុមទីប្រឹក្សានគរបាលឯកទេសដើម្បីផ្តល់ការណែនាំលើយុទ្ធសាស្ត្រនិង/ឬអភិក្រមប្រតិបត្តិការក្នុងការដោះស្រាយការរំលោភបំពានផ្អែកលើយេនឌ័រ។ | |
| ដឹកនាំនិងរៀបចំវគ្គបណ្តុះបណ្តាលរួមជាមួយនគរបាលឆ្លើយតបដំបូង និង/ឬអ្នកស៊ើបអង្កេតដំបូង អ្នកស៊ើបអង្កេតឯកទេស និងមន្ត្រីត្រួតពិនិត្យពាក់ព័ន្ធ ដើម្បីឱ្យគ្រប់គ្នាបានដឹងពីរបៀបដាក់បញ្ចូលពួកគេក្នុងគំរូនៃការឆ្លើយតប និងការស៊ើបអង្កេត។<br>ពង្រីកវគ្គបណ្តុះបណ្តាលទាំងនេះទៅដៃគូពហុស្ថាប័ន។ | |

៥

# កំណត់សម្គាល់ និងអំណានបន្ថែម


1. Investigation Process (College of Policing), see: https://www.app.college.police.uk/app-content/investigations/investigation-process/

2. Huhtanen, H., Lonsway, K.A., Archambault, J. (2017), 'Gender Bias in Sexual Assault Response and Investigation. Training Bulletin Series: Part 1', End Violence Against Women International (EVAWI).

3. Unbiased Policing (Provincial Government of British Columbia), see: https://engage.gov.bc.ca/unbiasedpolicing/work-to-date/

4. Malcolm K. Sparrow (2015), 'Measuring Performance in a Modern Police Organization in New Perspectives in Policing' (National Institute of Justice), see: https://www.ncjrs.gov/pdffiles1/nij/248476.pdf

5. Erin Gallagher, SGBV Investigation Planning (2015), Institute for International Criminal Investigations (IICI) and the Justice Rapid Response.

6. Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police-victim engagement in building a victim empowerment approach to intimate partner violence cases', *Police Practice and Research*, 18:1, 75-86, DOI: 10.1080/15614263.2016.1230061

7. Training Programme on the Treatment of Child Victim/survivors and Child Witnesses of Crime for Law Enforcement Officials (UNODC, 2015), see: https://www.unodc.org/documents/justice-and-prison-re-form/Training_Programme_on_the_Treatment_of_Child_Victim/survivors_and_Child_Witnesses_of_Crime_-_Law_Enforcement.pdf

8. United Nations Police *Gender Toolkit* (UN. Department of Peace Operations - DPO/ DPET/Integrated Training Service, 2015).

9. 'A Handbook for Police Responding to Domestic Violence: Promoting Safer Communities by Integrating Research & Practice', see: file:///C:/Users/User/Documents/UNWomenGVA/Resources/Secondary/2004%20RCMP%20Handbook%20for%20Police%20Responding%20to%20Domestic%20Violence.pdf

10. Training Programme on the Treatment of Child Victim/survivors and Child Witnesses of Crime (UNODC, 2015), see: file:///C:/Users/User/Documents/UNWomenGVA/Resources/Secondary/2015%20UNODC%20UNICEF%20Training%20Programme%20Treatment%20of%20Child%20Victim/survivors%20and%20Child%20Witnesses.pdf

11. Training Manual for Police Officers Strengthening Program for the Security of Vulnerable Groups, (UNODC in partnership with the Government of Mexico, 2017), see: http://www.policia-mas.org/man-uales/Manual_Policias_INGLES_PREVIO_090817.pdf

12. WHO Guidelines for Medico-Legal Care for Victim/Survivors of Sexual Violence (2003), see: https://www.who.int/violence_injury_prevention/publications/violence/med_leg_guidelines/en/

13. Roberts, Campbell and Lloyd, '*Honor-Based Violence: Policing and Prevention'* CRC Press (Taylor and Francis Group), 2013

14. Sexual Assault Response Policy and Training Content Guidelines. International Association of Chiefs of Police (2015), National Law Enforcement Leadership Initiative on Violence Against Women https://www.theiacp.org/resources/sexual-assault-response-poli-cy-and-training-content-guidelines

15. Guidelines for Medico-legal Care for Victim/Survivors of Sexual Violence (World Health Organisation (2003), see: https://www.who.int/violence_injury_prevention/publications/violence/med_leg_guidelines/en/

16. Training Programme on the Treatment of Child Victim/survivors and Child Witnesses of Crime for Law Enforcement Officials (UNODC, 2015), see: https://www.unodc.org/documents/justice-and-prison-re-form/Training_Programme_on_the_Treatment_of_Child_Victim/survivors_and_Child_Witnesses_of_Crime_-_Law_Enforcement.pdf

17. 'Do No Harm' (UN Women, 2010), see: https://end-vawnow.org/en/articles/200-do-no-harm.html

18. 'Gender-based Violence Resource Pack - A Standardized Training Tool for Duty Bearers, Stakeholders, and Rights Holders (UN Women, 2019), see: https://www.genderinkenya.org/wp-content/uploads/2019/11/GBV-Resource-Pack-13-Sept-w-3mm-bleed.pdf

19. Lisa Adams and Yumi Sera, 'Gender Guidelines' (2018), Disability Rights Fund & Disability Rights Advocacy Fund, see: http://disabilityrightsfund.org/wp-content/uploads/DRF-DRAF-Gender-Guidelines-Print.pdf

20. 'More than just a ramp: A guide for Women's Refuges to develop Disability Discrimination Act Action Plans' (2007), Women with Disabilities Australia (WWDA), see: http://wwda.org.au/wp-content/up-loads/2013/12/More_Than_Just_A_Ramp.pdf

21. UN, Fact Sheet No.23, on Harmful Traditional Practices Affecting the Health of Women and Children, accessed via https://www.ohchr.org/Documents/Publications/FactSheet23en.pdf

22. A Submission Highlighting the Harmful Practices Targeted at Persons with Disabilities, and in Particular Women and Girls with Disabilities, International Disability Alliance (2017), see: http://www.internationaldisabilityalliance.org/resources/submission-highlighting-harmful-practices-targeted-persons-disabilities-and-particular

23. Nathan Birdsall, Stuart Kirby & Michelle McManus (2017), 'Police–victim engagement in building a victim empowerment approach to intimate partner violence cases', *Police Practice and Research*, 18:1, 75-86, DOI: 10.1080/15614263.2016.1230061.

24. Ellison, L. (2002), 'Prosecuting domestic violence without victim participation', *Modern Law Review*, 65, 834–858

25. Vandello, J. A. & Cohen, D., 'Male honor and female fidelity: Implicit cultural scripts that perpetuate domestic violence', [2003] *Journal of Personality and Social Psychology* 84 at p. 997.

26. Julian Pitt-Rivers, "Honor and Social Status," in *Honour and Shame: The Values of Mediterranean Society* (ed. J. G. Peristiany, Weidenfeld and Nicolson, 1965), p 21.

27. UN News (4 March 2010) access via https://news.un.org/en/story/2010/03/331422

28. Global Study on Homicide, Gender related killing of women and girls (UNODC, 2018), accessed via https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf p.31.

29. UN Secretary General's In-depth study of all forms of violence against women, A/61/122/Add.1 (2006), para 65, p27.

30. UN Secretary General's In-depth study of all forms of violence against women, A/61/122/Add.1 (2006), para 1, p9.

31. UN Fact Sheet No.23 on Harmful Traditional Practices Affecting the Health of Women and Children, accessed via https://www.ohchr.org/Documents/Publications/FactSheet23en.pdf

32. A Submission Highlighting the Harmful Practices Targeted at Persons with Disabilities, and in Particular Women and Girls with Disabilities (International Disability Alliance, 2017).

33. HM Government Multi-agency practice guidelines, *Handling cases of Forced Marriage* (June 2014)

34. GirlsNotBrides, accessed via https://www.girlsnotbrides.org/700-million-women-married-children-reveals-new-unicef-data/

35. World Health Organisation (WHO), Adolescents: health risks and solutions, 13 December 2018 accessed via https://www.who.int/en/news-room/fact-sheets/detail/adolescents-health-risks-and-solutions

36. 115 million boys and men around the world married as children - UNICEF United Kingdom, accessed via https://www.unicef.org.uk/press-releases/115-million-boys-and-men-around-the-world-married-as-children-unicef/

37. The United Nations Convention on the Rights of the Child, accessed via https://downloads.unicef.org.uk/wp-content/uploads/2010/05/UNCRC_PRESS200910web.pdf?_ga=2.16687990.170076905.1577836147-1551955756.1577836147

38. HM Government, Multi-agency practice guidelines: Handling cases of Forced Marriage, p.16, June 2014, accessed via https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/322307/HMG_MULTI_AGENCY_PRACTICE_GUIDELINES_v1_180614_FINAL.pdf

39. Thomson Reuters Foundation and 28TooMany, 'The Law and FGM, An Overview of 28 African Countries' (September 2018) accessed via https://www.28toomany.org/static/media/uploads/Law%20Reports/the_law_and_fgm_v1_(september_2018).pdf

40. World Health Organisation (WHO), Factsheet on Female genital mutilation, 31 January 2018, accessed via https://www.who.int/news-room/fact-sheets/detail/female-genital-mutilation

41. National Police Chiefs Council (UK), see: https://www.npcc.police.uk

42. The Crown Prosecution Service (UK), see: https://www.cps.gov.uk

43. Protocol on the handling of Female Genital Mutilation (FGM) offences between the National Police Chiefs' Council and the Crown Prosecution Service (National Police Chiefs Council UK), see: https://www.cps.gov.uk/sites/default/files/documents/legal_guidance/hbv_and_fm_protocol_nov_16.pdf

44. 'Honour-based Abuse, Forced Marriage and Female Genital Mutilation: A Policing Strategy for England, Wales & Northern Ireland - Eradicating Honour Based Abuse, Forced Marriage and Female Genital Mutilation Together' (National Police Chiefs Council UK), see: https://www.npcc.police.uk/Publication/Final%20NPCC%20HBA%20strategy%202015%202018December%202015.pdf

6

# សុវត្ថិភាព និងការការពារ

"អំពើហិង្សាលើដៃគូស្និទ្ធស្នាលជាទម្រង់ទូទៅបំផុតនៃអំពើហិង្សាលើស្ត្រីនៅជុំវិញពិភពលោក ដែលបង្កផលវិបាកសុខភាពធ្ងន់ធ្ងរលើស្ត្រី និងការខាតបង់យ៉ាងច្រើនដល់សង្គម និងសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងរដ្ឋាភិបាល"។

មហាសន្និបាតអង្គការសហប្រជាជាតិ ២០០៦

# គោលបំណងនៃជំពូកទី ៦

**នគរបាលបានបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងការទទួលបានយុត្តិធម៌ តាមរយៈការផ្តល់វិធានការការពារផ្អែកតាមព័ត៌មានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព និងមិនពាក់ព័ន្ធនឹងការផ្តួចផ្តើមករណីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ឬករណីច្បាប់គ្រួសារ និងផ្តល់លទ្ធភាពឱ្យពួកគេបន្តចូលរួមដោយសុវត្ថិភាពក្នុងដំណើរការយុត្តិធម៌។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- អំពើហិង្សាលើដៃគូស្និទ្ធស្នាលតំណាងឱ្យសមាសធាតុស្នូលមួយនៃការងាររបស់នគរបាល។ហេតុដូច្នេះមន្ត្រីឆ្លើយតបទាំងអស់គួរមានសមត្ថភាពក្នុងការអនុវត្តគោលការណ៍ "មិនបង្កគ្រោះថ្នាក់"។
- សុវត្ថិភាព និងការការពារជនរងគ្រោះ ត្រូវតែជាចំណុចស្នូលនៃការធ្វើសេចក្តីសម្រេចចិត្ត។
- ការវាយតម្លៃហានិភ័យ ការរៀបចំផែនការសុវត្ថិភាព និងការពិនិត្យឡើងវិញត្រូវបន្តជាប់ជាប្រចាំចាប់ពីពេលដែលជនរងគ្រោះចូលរួមក្នុងដំណើរការយុត្តិធម៌។
- ផែនការសុវត្ថិភាពជាឧបករណ៍ទប់ស្កាត់ មិនមែនជាឧបករណ៍ព្យាករណ៍ឡើយ ហើយដែលគួរបង្កើតឡើងរួមគ្នាជាមួយនឹងជនរងគ្រោះ ដោយផ្អែកទៅតាមកាលៈទេសៈ។
- វិធានការការពារគួរត្រូវបានត្រួតពិនិត្យ និងពង្រឹងឱ្យសមាមាត្រទៅនឹងការគំរាមកំហែង និងដើម្បីធានាភាពអង់អាចរបស់ជនរងគ្រោះ។
- ការពិនិត្យឡើងវិញឬការវាយតម្លៃឧបករណ៍ប៉ាន់ប្រមាណហានិភ័យដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់រកការអនុវត្តការងារមិនបានល្អនិងលើកកម្ពស់ភាពមានវិជ្ជាជីវៈ។
- ជំនាញទន់និងសមត្ថភាពដែលឆ្លុះបញ្ចាំងពីការស្តាប់យ៉ាងយកចិត្តទុកដាក់ការប្រព្រឹត្តដោយមិនវិនិច្ឆ័យ និងការគោរពសេចក្តីថ្លៃថ្នូរបស់អ្នកដទៃ រួមចំណែកដល់ការផ្តល់សេវានគរបាលដោយជោគជ័យ។
- ការផ្សារភ្ជាប់ឫសគល់នៃការប្រព្រឹត្តអំពើហិង្សានិងការរើសអើងដែលមិនសមាមាត្រទៅនឹងបរិបទ ជាចំណុចស្នូលក្នុងការពង្រឹងវិធានការការពារ។



**សេចក្ដីផ្ដើម**

**យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាព ស្ដីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ឆ្នាំ ២០១០ ទាមទារឱ្យមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា នគរបាល និងមេធាវីរបស់ជនរងគ្រោះ ធ្វើការវាយតម្លៃហានិភ័យដែលគូសបញ្ជាក់ពីកម្រិតឬទំហំនៃគ្រោះថ្នាក់ដែលជនរងគ្រោះអាចប្រឈមដោយផ្អែកលើគោលធំបរនៃភាពងាយរងគ្រោះរបស់ពួកគេ ការគំរាមកំហែងលើពួកគេ វត្តមានអាវុធ និងកត្តាកំណត់ផ្សេងទៀត។**

រូបថតទទួលបានពី UN Women/Jashim Salam (ប្រទេសបង់ក្លាដេស)

ក្នុងន័យនេះ គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌនៃអង្គការសហប្រជាជាតិគូសបញ្ជាក់ពីកត្តាហានិភ័យជាច្រើនដែលអាចពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ[212]។

ចំណុចទាំងនេះ រួមបញ្ចូលអនក្ខរភាព វិសមភាពផ្នែកសេដ្ឋកិច្ច បទដ្ឋានវប្បធម៌ និងការអនុវត្តក្នុងសង្គម-ទំនៀមទម្លាប់កង្វះលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផ្ទះដែលផ្ដល់សុវត្ថិភាព និងអាចលៃលកបាន និងការផ្ដាច់កេរមរតក កង្វះ ឬអប្រសិទ្ធភាពនៃសេវា និងធនធានសម្រាប់ស្ត្រី និង គោលនយោបាយសមភាពយេនឌ័រ បទដ្ឋានសង្គមដែលគាំទ្រអំពើហិង្សា វិសមភាពយេនឌ័រ និងសិទ្ធិបុរស កង្វះក្នុងការដាក់ទណ្ឌកម្មរបស់សហគមន៍ប្រឆាំងនឹងអំពើហិង្សាប្រព័ន្ធយុត្តិធម៌ដែលគ្មានប្រសិទ្ធភាព ហេដ្ឋារចនាសម្ព័ន្ធទីក្រុងមិនសូវល្អ និងការបំពានគ្រឿងស្រវឹង និងគ្រឿងញៀន[213] ។

---

212. ឧទាហរណ៍នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមមាន អំពើហិង្សាផ្លូវភេទ រួមទាំងការកេងប្រវ័ញ្ច/ការរំលោភបំពានផ្លូវភេទ និងពេស្យាចារដោយបង្ខំ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងក្មេងស្រី ការអនុវត្តដែលបង្កគ្រោះថ្នាក់ ដូចជា ការវះកាត់ប្រដាប់បន្តពូជស្ត្រី ការសម្លាប់ដើម្បីរក្សាកិត្តិយស និងអាពាហ៍ពិពាហ៍កុមារ និងអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ។
213. សូមមើល UN-HABITAT និងគណៈកម្មការ Huairou "ការវាយតម្លៃជាសកលស្ដីពីសុវត្ថិភាពរបស់ស្ត្រី ៖ លទ្ធផលបឋមពីការអង្កេត" ពង្រាងឯកសារស្រាវជ្រាវ ខែ កញ្ញា ឆ្នាំ ២០០៧ ទំ. ៨ ក្នុងទិដ្ឋភាពនៃអំពើហិង្សាលើស្ត្រីដែលពាក់ព័ន្ធផ្ទាល់នឹង គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ (គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ V.08-52191 (E) *0852191* កិច្ចប្រជុំលើកទី ១៧) ទីក្រុងវីយែន ថ្ងៃទី ១៤-១៨ ខែ មេសា ឆ្នាំ ២០០៨។

> **“អំពើហិង្សាទាក់ទងនឹងយេនឌ័រជាពាក្យទូលំទូលាយដែលគ្របដណ្តប់លើការបង្កគ្រោះថ្នាក់ដែលប្រព្រឹត្តផ្ទុយនឹងឆន្ទៈរបស់បុគ្គលណាម្នាក់ និងផ្អែកលើភាពខុសគ្នាដែលកំណត់ដោយសង្គម (យេនឌ័រ) រវាងមនុស្សស្រី និងមនុស្សប្រុស។ ឫសគល់ និងប្រភេទជាក់លាក់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រែប្រួលតាមវប្បធម៌ ប្រទេស និងតំបន់”។**
>
> ប្រភព ៖ UNICEF, UNFPA, UNDP, UN WOMEN

កត្តាផ្សេងទៀតរួមមានទម្រង់នៃការរើសអើងក្នុងស្ថាប័ន និង/ឬត្រូវបានទទួលយកក្នុងសង្គម ដោយផ្អែកលើជាតិពន្ធុ ទំនោរផ្លូវភេទ ដើមកំណើតជាតិ និង/ឬពិការភាព ដែលធ្វើឱ្យស្ត្រីនិងក្មេងស្រីកាន់តែប្រឈមនឹងភាពងាយរងគ្រោះ។

ជំពូកខាងក្រោមនឹងផ្តោតសំខាន់លើធាតុផ្សំសំខាន់ៗនៃវិធានការការពារ ដែលចាំបាច់សម្រាប់អន្តរាគមន៍គ្រប់គ្រាន់និងមានប្រសិទ្ធភាពរបស់នគរបាលលើអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅពេលដែលជនរងគ្រោះ និង/ឬនគរបាលស្គាល់អត្តសញ្ញាណជនបង្កដែលរងការចោទប្រកាន់។

អាស្រ័យលើក្របខណ្ឌច្បាប់ជាតិ នគរបាលនឹងមានឧបករណ៍និងនីតិវិធីផ្សេងៗដែលអាចយកទៅប្រើប្រាស់នៅពេលធ្វើអន្តរាគមន៍ការពារករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា សមត្ថភាពចេញដីកាអន្តរាគមន៍ ឬដីកាការពារតាងនាមឱ្យជនរងគ្រោះ។ ការប្រើប្រាស់ឧបករណ៍និងអនុវត្តនីតិវិធីទាំងនេះតាមបែបប្រតិសកម្ម អាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងសម្រាប់ស្ត្រី និងក្មេងស្រីដែលស្វែងរកការការពារ។

ការពិនិត្យឡើងវិញជាថ្នាក់ជាតិដោយក្រសួងសេវាសង្គមនៃរដ្ឋាភិបាលអូស្ត្រាលី ស្តីពីរបៀបដែលសេវាសំខាន់ៗរក្សាការទទួលខុសត្រូវរបស់ជនបង្កក្នុងប្រព័ន្ធទាំងអស់ គូសបញ្ជាក់ថា សមត្ថភាពរបស់នគរបាលក្នុងការចេញដីកាអន្តរាគមន៍ជំនួសមុខឱ្យជនរងគ្រោះពិតជាសំខាន់ខ្លាំងណាស់។ ការពិនិត្យឡើងវិញនេះកត់សម្គាល់ពីភាពចាំបាច់ក្នុងការការពារស្ត្រី និងកូន ពីគ្រោះថ្នាក់បន្ថែមទៀតដែលបណ្តាលមកពីការអនុវត្តដីកាអន្តរាគមន៍ទាំងនោះ ដូចជា ការសងសឹកដោយជនបង្ក និងដើម្បីកាត់បន្ថយបន្ទុក និងការទទួលខុសត្រូវរបស់ជនរងគ្រោះក្នុងការការពារខ្លួន[214]។ ដូច្នេះ របាយការណ៍នេះបានកំណត់ស្តង់ដារដូចខាងក្រោមសម្រាប់វិធានការការពារ និងវិធានការសុវត្ថិភាពដែលអនុវត្តដោយអ្នកផ្តល់សេវាសំខាន់ៗ[214]៖

- សុវត្ថិភាពរបស់ស្ត្រី និងកូន គួរតែជាចំណុចស្នូលនៃអន្តរាគមន៍លើជនបង្ក។
- ជនបង្កទទួលបានអន្តរាគមន៍ត្រឹមត្រូវក្នុងពេលវេលាសមស្រប។
- ជនបង្កប្រឈមនឹងផលវិបាកផ្នែកយុត្តិធម៌ និងផលវិបាកផ្លូវច្បាប់ នៅពេលពួកគេប្រព្រឹត្តអំពើហិង្សា។
- ជនបង្កចូលរួមក្នុងកម្មវិធីនិងសេវាដែលផ្តល់លទ្ធភាពឱ្យពួកគេផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថហិង្សារបស់ខ្លួន។
- អន្តរាគមន៍លើជនបង្កត្រូវបានជំរុញដោយភស្តុតាងដែលអាចជឿទុកចិត្តបានដើម្បីធ្វើការកែលម្អជាប្រចាំ។
- អ្នកការក្នុងប្រព័ន្ធអន្តរាគមន៍លើជនបង្កមានភាពស្ទាត់ជំនាញក្នុងការឆ្លើយតបទៅនឹងឌីណាមិក និងផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ។

ជំពូកនេះផ្តោតសំខាន់លើការលើកកម្ពស់ស្តង់ដារទាំងនេះ ដែលទទួលបានពីការពិនិត្យឡើងវិញក្រោមការគាំទ្រដោយរដ្ឋាភិបាល បូករួមនឹងគោលការណ៍គន្លឹះក្នុងវិធានការការពាររបស់នគរបាលដូចការគូសបញ្ជាក់ក្នុងកញ្ចប់សេវាសំខាន់ៗ ដើម្បីអាចបង្កើតវិធានការទៅតាមជនរងគ្រោះម្នាក់ៗ និងមានភាពម្ចាស់ការលើដំណើរការនេះ។

## នគរបាលគួរធានា នូវភាពស្មើគ្នានៃវិធានការការពារសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាដែលសម្រេចចិត្តមិនចូលរួមក្នុងប្រព័ន្ធយុត្តិធម៌។

214. សូមមើល ស្តង់ដារលទ្ធផលថ្នាក់ជាតិសម្រាប់អន្តរាគមន៍លើជនបង្ក ឬរបាយការណ៍ដើមគ្រា NOSPI (២០១៥-២០១៦) (ក្រសួងសេវាសង្គមអូស្ត្រាលី២០១៧) ៖ https://plan4womenssafety.dss.gov.au/wp-content/uploads/2015/04/nospi_coag_paper.pdf

215. Ibid

ក្រៅពីជំពូកនេះ នគរបាលគួរអានផ្នែកទី ៨ (សុវត្ថិភាព និងការការពារ) នៃម៉ូឌុលទី ៣ (យុត្តិធម៌ និងនគរបាល) ក្នុងកញ្ចប់សេវាសំខាន់ៗ។

ជំពូកទី ៨ (សុវត្ថិភាព និងការការពារ) មានភាពខុសប្លែកពីជំពូកផ្សេងទៀត ព្រោះជំពូកនេះផ្តោតសំខាន់លើករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល[216] ដែលក្នុងករណីភាគច្រើនលើសលប់ ជនរងគ្រោះបានស្គាល់រួចទៅហើយ ឬចាប់ផ្តើមស្គាល់ជនបង្កអំពើហិង្សាដែលរងការចោទប្រកាន់។ កញ្ចប់សេវាសំខាន់ៗ កំណត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល ជា ៖

> "ទម្រង់ទូទៅបំផុតនៃអំពើហិង្សាដែលប្រព្រឹត្តលើស្ត្រីទូទាំងពិភពលោក... និងរួមបញ្ចូលការបង្ខិតបង្ខំផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទលើស្ត្រីពេញវ័យ និងស្ត្រីជំទង់ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬពីអតីតដោយគ្មានការយល់ព្រមពីស្ត្រី។អំពើហិង្សាផ្លូវកាយរួមមានការប្រើប្រាស់កម្លាំងកាយ ឬអាវុធដើម្បីបង្ករបួស ឬគ្រោះថ្នាក់ដល់ស្ត្រី។ អំពើហិង្សាផ្លូវភេទរួមមានការប្រទូស្តកេរភេទការធ្វើឱ្យស្ត្រីពាក់ព័ន្ធក្នុងផ្លូវភេទដោយគ្មានការយល់ព្រមពីស្ត្រី និងការប៉ុនប៉ងរំលោភផ្លូវភេទ ឬការរំលោភផ្លូវភេទបានសម្រេចជាមួយស្ត្រីដែលមានជំងឺ ពិការ និងទទួលរងសម្ពាធ ឬស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀនផ្សេងៗ។ អំពើហិង្សាផ្លូវចិត្តរួមបញ្ចូលការគ្រប់គ្រងឬការដាក់ឱ្យស្ត្រីឯកោរ និងការប្រមាថ ឬបង្កក្តីអាម៉ាស់ដល់ស្ត្រី។អំពើហិង្សាផ្នែកសេដ្ឋកិច្ចរួមមានការបដិសេធមិនឱ្យស្ត្រីទទួលបាន និងគ្រប់គ្រងធនធានសំខាន់ៗ"[217](របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិឆ្នាំ ២០០៦)។

អំពើហិង្សាលើដៃគូស្និទ្ធស្នាលតំណាងឱ្យសមាសធាតុស្នូលនៃការងាររបស់មន្ត្រីឆ្លើយតប។ ហេតុដូច្នេះ នគរបាលឆ្លើយតបគ្រប់រូបគួរមានសមត្ថភាពក្នុងការអនុវត្តគោលការណ៍មិនបង្កគ្រោះថ្នាក់ ដែលចាប់ផ្តើមពីការគោរពសិទ្ធិរបស់ជនរងគ្រោះ រួមទាំងឯកជនភាព និងតម្រូវការរក្សាការសម្ងាត់របស់ជនរងគ្រោះ[218]។ "ការមិនបង្កគ្រោះថ្នាក់" អាចមានន័យថា អន្តរាគមន៍មិនត្រូវពង្រីកស្ថានភាព ឬបញ្ហាដែលស្ថិតក្រោមការពិនិត្យឡើងវិញ និងមិនត្រូវបង្កគ្រោះថ្នាក់ដល់គ្រួសារ និងសហគមន៍ពាក់ព័ន្ធ[219]។ ការរៀបចំកិច្ចសន្ទនា ការវាយតម្លៃ និងការសួរចម្លើយជនរងគ្រោះក្នុងមជ្ឈដ្ឋានដែលមានសុវត្ថិភាពជាឧទាហរណ៍នៃការអនុលោមតាមគោលការណ៍មិនបង្កគ្រោះថ្នាក់។

ត្រីកោណសុវត្ថិភាព ការយល់ព្រម និងការរក្សាការសម្ងាត់ (ខាងក្រោម) របស់ UN Women ជាការបង្ហាញដ៏ល្អដែលត្រូវពិចារណានៅពេលខិតខំផ្តល់សុវត្ថិភាពនិងការការពារដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ត្រីកោណនេះ លើកកម្ពស់អាជ្ញាធរក្នុងនាមជាតួអង្គសំខាន់ដែលការពារស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សានៅផ្ទះ ដោយគូសបញ្ជាក់ពីសារៈសំខាន់នៃការស្វែងរកការយល់ព្រមរបស់ពួកគេមុននឹងចាត់វិធានការ និងរក្សាអត្តសញ្ញាណ និងបទពិសោធន៍របស់ពួកគេទុកជាសម្ងាត់។ ការសំខាន់គឺអាជ្ញាធរទាំងនេះត្រូវទទួលបានការអនុញ្ញាតពីពួកគេមុននឹងចាត់វិធានការលុះត្រាដែលជីវិតរបស់ពួកគេស្ថិតក្នុងគ្រោះថ្នាក់។




216. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ អ្នកនិពន្ធប្រើពាក្យ "អំពើហិង្សាលើដៃគូស្និទ្ធស្នាល" ជាជាង "អំពើហិង្សាក្នុងគ្រួសារ" ឬ "អំពើហិង្សាអន្តរគ្រួសារ" និងផ្តោតអាទិភាពលើពាក្យ "អំពើហិង្សាលើដៃគូស្និទ្ធស្នាល" លុះត្រាតែពាក្យ "អំពើហិង្សាក្នុងគ្រួសារ" ត្រូវបានប្រើប្រាស់ក្នុងឯកសារដើម។
217. របាយការណ៍របស់អគ្គលេខាធិការ ការសិក្សាស៊ីជម្រៅស្តីពីទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី អង្គការសហប្រជាជាតិ A/61/122/Add.1, (6 July 2006) paras. 111- 112.
218. អាចមានករណីលើកលែងក្នុងគោលការណ៍រក្សាការសម្ងាត់។ ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ផ្តល់ឧទាហរណ៍ ដូចជា ការសង្ស័យការរំលោភបំពាន ឬការមិនអើពើចំពោះកុមារស្ថានភាពដែលគំរាមកំហែងអាយុជីវិតការសង្ស័យពីគំនិតធ្វើអត្តឃាត ឬការគំរាមយ៉ាងធ្ងន់ធ្ងរក្នុងការបង្កគ្រោះថ្នាក់លើអ្នកដទៃ។ យោងតាម UNPOL ក្នុងករណីទាំងនេះ នគរបាលអាចធ្វើហាក់ដូចជាមានមូលដ្ឋានសមហេតុផលក្នុងការបញ្ជាក់ស្ថានភាពទាំងនេះ និងស្វែងរកការណែនាំពីបុគ្គលិកថែទាំសុខភាព និងមេធាវី។ សូមមើល ៖ អង្គការសហប្រជាជាតិ ឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ-DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ ២០១៥)។
219. ឯកសារជំនួយស្មារតីអ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌ (UN WOMEN et al., 2018)

## ការណែនាំគ្នាទៅវិញទៅមក

នគរបាលជាដៃគូដ៏សំខាន់ក្នុងប្រព័ន្ធយុត្តិធម៌នៅពេលផ្តោតលើការធានាសុវត្ថិភាព និងការការពារជនរងគ្រោះពីដំបូង និងជាបន្តបន្ទាប់។ ដូច្នេះ អ្នកមានតួនាទីយ៉ាងសំខាន់ក្នុងការសហការជាមួយស្ថាប័ន និងអ្នកផ្តល់សេវាផ្សេងទៀត។
តាមរយៈការសហការជាមួយដៃគូផ្សេងទៀតតួនាទីរបស់អ្នកក្នុងការស៊ើបអង្កេតបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីនឹងត្រូវបានពង្រឹង និងគាំទ្រខណៈដែលជនរងគ្រោះទទួលបានសុវត្ថិភាព និងការការពារទៅតាមតម្រូវការជាក់លាក់របស់ពួកគេ។ ដើម្បីកំណត់រកតម្រូវការ សុវត្ថិភាព និងការការពាររបស់ជនរងគ្រោះ ដំបូងអ្នកត្រូវកំណត់រកហានិភ័យជាក់លាក់របស់គាត់។ ការវាយតម្លៃហានិភ័យនេះមានភាពជាក់លាក់ទៅតាមជនរងគ្រោះម្នាក់ៗ អាស្រ័យលើកាលៈទេសៈរបស់ជនរងគ្រោះ ហើយជនរងគ្រោះត្រូវតែជាចំណុចស្នូលនៃដំណើរការវាយតម្លៃហានិភ័យ។

**ឧបសម្ព័ន្ធ ១** ៖ ការវាយតម្លៃស្តង់ដារលើហានិភ័យ និងគ្រោះថ្នាក់ ៖ ការវាយតម្លៃហានិភ័យដែលអាចបណ្តាលឱ្យស្លាប់ និងហានិភ័យនៃការប្រព្រឹត្តអំពើហិង្សាជាច្រើនលើកច្រើនសាផ្តល់នូវតារាងត្រួតពិនិត្យកត្តាហានិភ័យដ៏មានប្រយោជន៍ដែលដកស្រង់ពីសៀវភៅណែនាំរបស់ UNODC និង UN Women ស្តីពី "ការឆ្លើយតបដោយប្រសិទ្ធភាពនៃសេវាអយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី"។ ការសំខាន់ត្រូវយល់ថា ហានិភ័យដែលលេចឡើងអាចគួសបញ្ជាក់ពីហានិភ័យខ្ពស់នៃរបួសធ្ងន់ធ្ងរ ឬការបាត់បង់ជីវិត។ ទន្ទឹមនឹងនេះ ការគ្មានកត្តាទាំងនេះមិនមានន័យថាគ្មានហានិភ័យនៃការបាត់បង់ជីវិតនោះទេ។

លទ្ធផលពីការវាយតម្លៃហានិភ័យគួរតែជាផែនការសុវត្ថិភាពដែលបង្កើតឡើងរួមគ្នាដោយអ្នក មន្ត្រីរបស់អ្នក និងជនរងគ្រោះ។ អ្នកមានតួនាទីសម្របសម្រួលការបង្កើតផែនការនេះ ហើយខណៈដែលផែនការសុវត្ថិភាពនឹងមិនព្យាករណ៍ពីពេលដែលអំពើហិង្សាអាចកើតឡើងផែនការនេះគឺដើម្បីជាការទប់ស្កាត់តាមរយៈការកាត់បន្ថយគ្រោះថ្នាក់ និងការបង្កើនសុវត្ថិភាពដល់ជនរងគ្រោះ។

ផែនការសុវត្ថិភាពគួរផ្តោតសំខាន់លើការកាត់បន្ថយហានិភ័យដែលរកឃើញ និងអាចសម្រេចបានតាមរយៈភាពជាដៃគូជាមួយអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតដែលជាញឹកញាប់ អាចផ្តល់សេវាគាំទ្របន្ថែមដែលអ្នកមិនមាន។ ពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យនេះ ផែនការសុវត្ថិភាពនឹងមានភាពជាក់លាក់ទៅតាមជនរងគ្រោះម្នាក់ៗ ព្រោះកាលៈទេសៈរបស់ជនរងគ្រោះម្នាក់ៗមានភាពស្មុគស្មាញខុសៗ គ្នា។ប្រអប់២ ខាងក្រោមបង្ហាញឧទាហរណ៍នៃវិធានការកាត់បន្ថយហានិភ័យក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ១**

តើអ្នក និងបុគ្គលិករបស់អ្នកអាចធ្វើអ្វីបានខ្លះដើម្បីកាត់បន្ថយហានិភ័យលើជនរងគ្រោះ និងអ្នកពាក់ព័ន្ធនឹងជនរងគ្រោះ?

វិធានការ ៖

- ការស្វែងរកដីកាការពារពីតុលាការ មិនមែនដីកាទំនាក់ទំនង។ល។
- ការសហការជាមួយជនរងគ្រោះដើម្បីកំណត់កត្តាហានិភ័យ និងបង្កើតផែនការសុវត្ថិភាពទៅតាមបទពិសោធន៍ជនរងគ្រោះ
- ការបញ្ជូនឬអមដំណើរស្ត្រីទៅកាន់ទីជម្រកសុវត្ថិភាព
- ការអនុម័តគោលនយោបាយចាប់ខ្លួនជាកាតព្វកិច្ចនៅគ្រប់ករណីអំពើហិង្សាក្នុងគ្រួសារដែលរងការចោទប្រកាន់ ឬសង្ស័យ
- ការស្នើសុំទៅតាមភាពចាំបាច់នូវលក្ខខណ្ឌដោះលែងយ៉ាងតឹងរ៉ឹងសម្រាប់ជនល្មើស រួមទាំងបំរាមគោចរ ដីកាហាមឃាត់ទំនាក់ទំនង ការតមគ្រឿងស្រវឹង ការហាមឃាត់មិនឱ្យប្រើអាវុធ និងការស្វែងរក និងការចូលរួមក្នុងការពិគ្រោះយោបល់
- ការពិនិត្យតាមដាននិងពង្រឹងលក្ខខណ្ឌបង់ប្រាក់នៅក្រៅឃុំ/ដោះលែង និងលក្ខខណ្ឌដោះលែងក្រោយការជំនុំជម្រះ ការជូនដំណឹងដល់ជនរងគ្រោះ មុនពេល

ដោះលែងជនល្មើស

- ការវាយតម្លៃហានិភ័យ និងការអនុវត្តផែនការគ្រប់គ្រងការគំរាមកំហែងដើម្បីកាត់បន្ថយហានិភ័យនៃការវាយប្រហារនាពេលអនាគត។

ប្រភព ៖ សៀវភៅណែនាំស្តីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី (UNODC, 2010)

ពាក់ព័ន្ធនឹងទិដ្ឋភាពទាំងអស់នៃការឆ្លើយតបនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ខ្លឹមសារនៃការវាយតម្លៃហានិភ័យ និងផែនការសុវត្ថិភាពជាបន្តបន្ទាប់ត្រូវរក្សាឯកជនភាព និងការសម្ងាត់ ដោយមានតែអ្នកពាក់ព័ន្ធក្នុងការការពារជនរងគ្រោះក្នុងចំណោមអ្នកផ្តល់សេវាផ្សេងៗប៉ុណ្ណោះដែលអាចចូលមើលខ្លឹមសារទាំងនោះបាន។

## ក្របខណ្ឌលំហូរនៃការវាយតម្លៃហានិភ័យ (PROTECT II, 2012)

| | |
|---|---|
| ១ មជ្ឈដ្ឋានដែលមានសុវត្ថិភាព | ជូនដំណឹងដល់ជនរងគ្រោះអំពីគោលបំណងនៃការវាយតម្លៃនេះ និងរៀបរាប់ពីកិច្ចព្រមព្រៀងរក្សាការសម្ងាត់ក្នុងស្ថាប័ន។<br>សួរសំណួរដែលផ្តល់ការគោរពនិងគិតពីអារម្មណ៍ដែលបង្ហាញពីចំណេះដឹងនិងសមត្ថភាពជុំវិញអំពើហិង្សាក្នុងគ្រួសារ។ (តើមាននរណាម្នាក់ធ្វើឱ្យអ្នកឈឺចាប់ ឬទេ? ឬ តើអ្នកត្រូវបានគេបន្លាច ឬទេ? តើអ្នកយល់ថាមានសុវត្ថិភាពនៅផ្ទះ ឬទេ?<br>ផ្តល់បរិយាកាសសុវត្ថិភាព និងឯកជនភាព ដែលស្ត្រីអាចនិយាយដោយសេរី។ ពិចារណានិងគោរពលក្ខណៈចម្រុះ។ |
| ២ អនុវត្តអភិក្រមជាប្រព័ន្ធ | ការវាយតម្លៃហានិភ័យគួរផ្អែកតាមគោលនយោបាយ និងនិតិវិធីស្ថាប័នច្បាស់លាស់ និងការត្រួតពិនិត្យការគ្រប់គ្រងបែបគាំទ្រ។<br>ការវាយតម្លៃហានិភ័យគួរធ្វើឡើងជាមួយជនរងគ្រោះគ្រប់រូប ទៅតាមគោលនយោបាយរបស់ស្ថាប័ន (ការវាយតម្លៃហានិភ័យជាមូលដ្ឋានក្នុងសេវាទូទៅ ការវាយតម្លៃហានិភ័យស៊ីជម្រៅក្នុងសេវាឯកទេសគាំទ្រស្ត្រី)។ |
| ៣ ប្រមូលព័ត៌មានដែលមានប្រសិទ្ធភាព | ការវាយតម្លៃហានិភ័យគួរប្រើប្រាស់តារាងត្រួតពិនិត្យជាមួយស្ត្រីនិងយោងតាមកត្តាហានិភ័យដែលបានដឹងក្នុងករណីអំពើហិង្សាលើស្ត្រីក្នុងគ្រួសារ។ចំណុចនេះគួរពាក់ព័ន្ធនឹងការប្រមូលព័ត៌មានសមស្របពីប្រភពជាច្រើន។ ស្ត្រីមានការយល់ដឹងលម្អិតពីស្ថានភាពរបស់ខ្លួន និងជម្រើសនៃការគ្រប់គ្រងសុវត្ថិភាពដែលសមស្របបំផុតទៅនឹងកាលៈទេសៈផ្ទាល់ខ្លួន។ គួរជឿជាក់ និងផ្តល់សុពលភាពដល់ស្ត្រី។ |
| ៤ ទស្សនៈជំនាញរបស់អ្នកអនុវត្តន៍ | ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈកើតចេញពីបទពិសោធន៍ការងារជាមួយជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។ ដូច្នេះ សេវាទូទៅគួរពាក់ព័ន្ធនឹងអ្នកជំនាញឯកទេស។<br>ប្រសិនបើផ្អែកទស្សនៈជំនាញរបស់អ្នកតែលើវិចារណញាណរបស់អ្នក អ្នកគួរដឹងថា នេះជាទស្សនៈបែបបរានុម័ត (subjective)។ មានភស្តុតាងតិចតួចដែលបង្ហាញថា អ្នកជំនាញតែងធ្វើការសម្រេចចិត្តផ្អែកតាមវិចារណញាណ (Hart, ២០០៨)។<br>ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈគួររួមបញ្ចូលការពិចារណាពីឫសគល់ និងភាពធ្ងន់ធ្ងរនៃឧប្បត្តិហេតុដែលកើតឡើងចុងក្រោយ របួសនានាដែលអាចបណ្តាលមកពីឧប្បត្តិហេតុនោះ បរិបទ និងស្ថានភាពផ្ទាល់ខ្លួនរបស់ស្ត្រី។ |

**៥**
**ការរៀបចំផែនការសុវត្ថិភាព**

ក្រោយការវាយតម្លៃហានិភ័យ ត្រូវអនុវត្តសកម្មភាពគ្រប់គ្រងសុវត្ថិភាពដែលកាត់បន្ថយហានិភ័យលើស្ត្រី ហើយបង្កើនសុវត្ថិភាពដល់ស្ត្រី។ អ្នកធ្វើការវាយតម្លៃហានិភ័យត្រូវដឹងពីអ្វីដែលត្រូវធ្វើបន្ទាប់ និងស្ថាប័នដែលអាចជួយដល់ស្ត្រីប្រកបដោយប្រសិទ្ធភាពបំផុត។ ក្នុងករណីដែលស្នើឱ្យមានការឆ្លើយតបទៅនឹងការរំលោភបំពានក្នុងគ្រួសារ ពីពហុស្ថាប័ន តារាងត្រួតពិនិត្យដើម្បីកំណត់ហានិភ័យអាចផ្តល់ជាមូលដ្ឋានក្នុងការបញ្ជូន។

ខាងលើនេះជាដ្យាក្រាមលំហូរនៃការវាយតម្លៃហានិភ័យ ដកស្រង់ចេញពី PROTECT II "ការកសាងសមត្ថភាពក្នុងការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងសុវត្ថិភាពដើម្បីការពារជនរងគ្រោះដែលមានហានិភ័យខ្ពស់៖ ធនធានរៀនសូត្រ" (ទីក្រុងវីយែន ២០១២) ទំ. ១០៥។

**ពាក់ព័ន្ធនឹងសកម្មភាពជាក់លាក់របស់នគរបាល ៖**

- តើអ្នកធានាដូចម្តេចថា សុវត្ថិភាពរបស់ជនរងគ្រោះជាចំណុចស្នូលនៃការធ្វើសេចក្តីសម្រេចចិត្តរបស់អ្នក?
- តើអ្នកធានាដូចម្តេចថា អ្នកធ្វើសេចក្តីសម្រេចចិត្ត (មិនថានរណានោះទេ) ដូចជា បុគ្គលិកមន្ទីរឃុំឃាំង ទទួលបានព័ត៌មានដែលមានទាំងអស់ដើម្បីធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវលើការចាប់ខ្លួន ការដោះលែង ឬការបន្តឃុំខ្លួនជនបង្កដែលរងការចោទប្រកាន់?
- តើអ្នកធានាដូចម្តេចថា ការវាយតម្លៃហានិភ័យត្រូវបានពិនិត្យឡើងវិញក្នុងករណីមានការចេញដីកាការពារ ឬធានាថា អ្នកត្រូវបានជូនដំណឹងពីការរំលោភដីកាការពារជាធរមាន និងក្នុងករណីពាក់ព័ន្ធ ធានាដូចម្តេចថា ផែនការសុវត្ថិភាពត្រូវបានធ្វើបច្ចុប្បន្នភាព?
- តើអ្វីជាយន្តការពិនិត្យឡើងវិញរបស់អ្នក?
- តើអ្នកពិនិត្យតាមដានផែនការសុវត្ថិភាព និងការអនុលោមតាមដីកាតុលាការដោយរបៀបណា?

រាល់ការប្រែប្រួលស្ថានការណ៍របស់ជនរងគ្រោះឬជនបង្កដែលរងការចោទប្រកាន់ត្រូវតែជាផ្នែកមួយនៃដំណើរការវាយតម្លៃហានិភ័យជាបន្តបន្ទាប់និងទាមទារការពិនិត្យតាមដានជាប់ជាប្រចាំលើផែនការសុវត្ថិភាព។ ប្រអប់ ៣ ខាងក្រោមជាឧទាហរណ៍នៃដំណើរការវាយតម្លៃហានិភ័យពីគំរូនៃការរំលោភបំពានក្នុងគ្រួសារ ការឈ្លបចាប់ និងការបៀតបៀន (DASH)។ គំរូនៃការវាយតម្លៃហានិភ័យទូទៅ ដូចជា DASH[220] (ចក្រភពអង់គ្លេស) និង B-SAFER[221] (កាណាដា) មានគោលបំណងផ្តល់ក្របខណ្ឌដ៏មានប្រយោជន៍ ជាប្រព័ន្ធ និងស្តង់ដារសម្រាប់ការប្រមូល និងពិចារណាព័ត៌មាននៅពេលធ្វើការសម្រេចចិត្តអំពីហានិភ័យនៃអំពើហិង្សា។ ក្របខណ្ឌទាំងនេះអាចជាតារាងត្រួតពិនិត្យឬមគ្គុទេសក៍សម្រាប់ជួយឱ្យនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗក្នុងការឆ្លើយតបដំបូងផ្សេងទៀត វាយតម្លៃហានិភ័យ និងកំណត់រកអំពើហិង្សាលើដៃគូស្និទ្ធស្នាល ទាំងក្នុងយុត្តិធម៌ព្រហ្មទណ្ឌ និងយុត្តិធម៌រដ្ឋប្បវេណី។

គំរូ និងក្របខណ្ឌទាំងនេះផ្អែកតាមឯកសារពាក់ព័ន្ធផ្នែកវិទ្យាសាស្ត្រ និងវិជ្ជាជីវៈស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ការវាយតម្លៃហានិភ័យ និងការរៀបចំផែនការសុវត្ថិភាពរបស់ជនរងគ្រោះ[222] និងត្រូវបានមន្ត្រីនគរបាលចាត់ទុកថាមានប្រយោជន៍។ ឧ. មិនយូរប៉ុន្មានបន្ទាប់ពីការអនុវត្តស្តង់ដារនៅឆ្នាំ ២០១៤ នគរបាលរដ្ឋ Maryland សហរដ្ឋអាមេរិក បានរាយការណ៍ពីការថយចុះការស្លាប់ដោយសារអំពើហិង្សាលើដៃគូស្និទ្ធស្នាលចំនួន៣០%[223]។

គួរកត់សម្គាល់ថា គំរូ DASH កំពុងស្ថិតក្រោមការជួយពិនិត្យ ដោយមានការចែករំលែកលទ្ធផលតាមប្រព័ន្ធអ៊ីនធឺណិត។ ដោយសារតែគ្មានគំរូដែលល្អឥតខ្ចោះដំណើរការពិនិត្យឡើងវិញទាំងនេះគឺសំខាន់ខ្លាំងណាស់ក្នុងការកំណត់រកចំណុចខ្វះខាតនៃគំរូនេះ និងការលើកកម្ពស់ភាពមាន

220. ការរំលោភបំពានក្នុងគ្រួសារ ការឈ្លបចាប់ និង "អំពើហិង្សាដើម្បីកិត្តិយស" (DASH, 2009) គំរូនៃការកំណត់រក ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ៖ https://www.dashriskchecklist.co.uk/។
221. ទម្រង់សង្ខេបនៃការប្រទូស្តរាយប្តី/ប្រពន្ធសម្រាប់ការវាយតម្លៃហានិភ័យ (B-SAFER) ៖ https://www.justice.gc.ca/eng/rp-pr/fl-lf/famil/rr05_fv1-rr05_vf1/index.html។
222. សូមមើល ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ-DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ ២០១៥)
223. សូមមើល ១៦ សំណួរដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារការរំលោភបំពានក្នុងគ្រួសារ ដែលងាយនឹងត្រូវបានសម្លាប់ ៖ https://www.cbsnews.com/news/16-questions-used-to-id-domestic-abuse-victims-likely-to-be-killed/។

**ប្រអប់ ២**

**ការរំលោភបំពានក្នុងគ្រួសារ ការឈ្លបចាប់ និង "អំពើហិង្សាដើម្បីកិត្តិយស" (DASH) ៖ គំរូនៃការកំណត់រក ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ**

នៅខែ មីនា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាសមាគមស្នងការនគរបាល (ACPO) បានទទួលស្គាល់គំរូ DASH ដែលត្រូវអនុវត្តក្នុងសេវានគរបាលទាំងអស់នៅចក្រភពអង់គ្លេស។ តារាងត្រួតពិនិត្យនៃគំរូ DASH ផ្តល់ឧបករណ៍អនុវត្តន៍ដល់មន្ត្រី និងបុគ្គលិកដើម្បីជួយដល់ការកំណត់រកហានិភ័យពីដំបូង។ តារាងត្រួតពិនិត្យនេះមាន ២៧ សំណួរ។ នៅពេលមានការបណ្តុះបណ្តាលសមស្រប ការប្រើប្រាស់តារាងត្រួតពិនិត្យនៃគំរូ DASH អាចឱ្យមន្ត្រី និងបុគ្គលិកកំណត់រកករណីដែលមានហានិភ័យខ្ពស់និងកំណត់អត្តសញ្ញាណជនបង្កដែលគ្រោះថ្នាក់និងប្រព្រឹត្តបទល្មើសលើជនរងគ្រោះជាច្រើននាក់។ បន្ទាប់ពីការកំណត់រក និងការវាយតម្លៃហានិភ័យដំបូង ករណីនឹងត្រូវបានបែងចែកជា ៣ កម្រិតនៃហានិភ័យ៖

- **កម្រិតស្តង់ដារ៖** ភស្តុតាងបច្ចុប្បន្នមិនគួសបញ្ជាក់ពីលទ្ធភាពនៃការបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ។
- **កម្រិតមធ្យម៖** មានសូចនាករដែលអាចកំណត់រកបាននៃហានិភ័យគ្រោះថ្នាក់ធ្ងន់ធ្ងរ។ ជនល្មើសអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែហាក់មិនធ្វើដូច្នោះ លុះត្រាតែមានការប្រែប្រួលស្ថានការណ៍ ដូចជា ការមិនបានលេបថ្នាំ ការបាត់បង់កន្លែងស្នាក់នៅ ការកាត់ផ្តាច់ទំនាក់ទំនង និងការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹងមិនបានត្រឹមត្រូវ។
- **កម្រិតខ្ពស់៖** មានសូចនាករដែលអាចកំណត់រកបានពីហានិភ័យគ្រោះថ្នាក់ធ្ងន់ធ្ងរ។ ព្រឹត្តិការណ៍នានាអាចកើតឡើងគ្រប់ពេល និងអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរ។

ហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវបានកំណត់ជា"ហានិភ័យដែលគំរាមកំហែងដល់អាយុជីវិតនិង/ឬប៉ះទង្គិចផ្លូវចិត្ត ហើយការស្តារឡើងវិញផ្នែកផ្លូវកាយ ឬផ្លូវចិត្ត អាចជាការលំបាក ឬមិនអាចទៅរួច" (ប្រភព ៖ នាយកដ្ឋានកិច្ចការផ្ទៃក្នុង ២០០២ និងប្រព័ន្ធវាយតម្លៃ ជនល្មើស ២០០៦)។

វិជ្ជាជីវៈរបស់អ្នកប្រើប្រាស់គំរូនេះ។ ក្រៅពីនេះ ការដែលលទ្ធផលពីការពិនិត្យឡើងវិញទាំងនេះ (ក្នុងករណីនេះសំដៅលើគំរូ DASH) ត្រូវបានចែករំលែកតាមប្រព័ន្ធអ៊ីនធឺណិតបង្ហាញពីការប្តេជ្ញាចិត្តក្នុងការធានានូវតម្លាភាព និងគណនេយ្យភាព[224]។

ដើម្បីធានាថាមន្ត្រីរបស់អ្នកធានាសុវត្ថិភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព អ្នកត្រូវពិចារណាពីចំណុចខាងក្រោម ៖

- តើអ្នក (នគរបាល) មានតួនាទីអ្វីក្នុងដីកាការពារករណីរដ្ឋប្បវេណី និង/ឬករណីព្រហ្មទណ្ឌ ប្រសិនបើមានដីកាទាំងនេះ?
- តើអ្នកអាចទទួលបានដីកាការពារធាប់ហ័សកម្រិតណា?
- តើអ្នក ឬបុគ្គលិករបស់អ្នកប្រឈមនឹងបញ្ហាអ្វីខ្លះក្នុងដំណើរការអនុវត្តដីកាការពារទាំងនេះមិនថាការអនុវត្តធ្វើឡើងដោយស្ថាប័នមួយផ្សេងទៀតឬយ៉ាងណានោះ?
- តើអ្វីជាកត្តាចាំបាច់ក្នុងការដោះស្រាយនិងកំណត់រកបញ្ហា?
- តើអ្នកមានអំណាចអ្វីខ្លះក្នុងការបញ្ចុះបញ្ចូលឱ្យមានដីកាការពារបន្ទាន់? តើត្រូវបំពេញលក្ខខណ្ឌតម្រូវអ្វីខ្លះ?តើអ្នកនិងបុគ្គលិករបស់អ្នកបានដឹងពីលក្ខខណ្ឌតម្រូវទាំងនោះ ឬទេ?

ប្រសិនបើអ្នក ឬបុគ្គលិករបស់អ្នកមិនអាចឆ្លើយសំណួរខាងលើបាន តើអ្នកអាចផ្តល់ព័ត៌មានលម្អិត និងសុក្រឹតដោយរបៀបណាដល់ជនរងគ្រោះដើម្បីគ្រប់គ្រងក្តីរំពឹងទុករបស់ពួកគេនិងផ្អែកតាមអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះអនុញ្ញាតឱ្យពួកគេសម្រេចចិត្តដោយផ្អែកតាមព័ត៌មានត្រឹមត្រូវអំពីថាតើអ្វីជាយុត្តិធម៌

224. សូមមើលផងដែរ Emily Turner, Juanjo Medina, Gavin Brown, 'Dashing Hopes? The Predictive Accuracy of Domestic Abuse Risk Assessment by Police,' The British Journal of Criminology, Volume 59, Issue 5, September 2019, Pages 1013–1034.

ចំពោះពួកគេ? ប្រសិនបើជនរងគ្រោះប្រឈមនឹងហានិភ័យ ឬមានការភ័យខ្លាច អ្នកត្រូវធានាសុវត្ថិភាពរបស់ពួកគេ មុនពេលពួកគេមានឆន្ទៈដាក់បណ្តឹងប្រឆាំងនឹងជនបង្កដែលរងការចោទប្រកាន់ជាពិសេសក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាលើដៃគូស្និទ្ធស្នាល។

ឧទាហរណ៍នៃការអនុវត្តល្អក្នុងការធ្វើការជាមួយអ្នកផ្តល់សេវាផ្សេងទៀត ដើម្បីកាត់បន្ថយហានិភ័យលើជនរងគ្រោះ និងគ្រួសាររបស់ពួកគេមានបង្ហាញនៅចក្រភពអង់គ្លេស ជាទីដែលតែងមានការរៀបចំសន្និសីទវាយតម្លៃហានិភ័យពហុស្ថាប័ន (MARAC)[225]។ សន្និសីទវាយតម្លៃហានិភ័យពហុស្ថាប័នស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ជាកិច្ចប្រជុំដែលស្ថាប័ននានាពិភាក្សាពីហានិភ័យនៃគ្រោះថ្នាក់នាពេលអនាគតលើអ្នកដែលកំពុងរងគ្រោះដោយអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងក្នុងករណីចាំបាច់ កូនៗរបស់ពួកគេ ដោយមានការបង្កើតផែនការសុវត្ថិភាពដើម្បីជួយគ្រប់គ្រងហានិភ័យ[226]។ ប្រអប់ ៤ ខាងក្រោមបង្ហាញឧទាហរណ៍នៃកត្តាដែលត្រូវពិចារណានៅពេលបង្កើតផែនការសុវត្ថិភាពក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ៣**

**ការបង្កើតផែនការសុវត្ថិភាពផ្ទាល់ខ្លួន**

ក្នុងការបង្កើតផែនការសុវត្ថិភាពផ្ទាល់ខ្លួន សូមពិចារណាពីកត្តាគាំទ្រសុវត្ថិភាពដូចខាងក្រោម ៖

- កម្រិតនៃការគាំទ្រផ្ទាល់ខ្លួន ដែលផ្តល់ជូនជនរងគ្រោះ
- ស្ថានភាពរស់នៅរបស់ពួកគេ
- កម្រិតនៃការភ័យខ្លាច
- ឧបសគ្គក្នុងការទទួលបានសុវត្ថិភាពដោយសារឥរិយាបថ និងជំនឿផ្ទាល់ខ្លួន និងឥរិយាបថ និងជំនឿរបស់គ្រួសារសាច់ឆ្ងាយ សហគមន៍ ឬវប្បធម៌
- ផលប៉ះពាល់លើសុខភាពដោយសារការរំលោភបំពាននោះ
- ស្ថានភាពការងារ ឬបញ្ហាហិរញ្ញវត្ថុ
- ការព្រួយបារម្ភពាក់ព័ន្ធនឹងកូន
- ការបំពាន/ប្រើប្រាស់គ្រឿងញៀន (គ្រឿងស្រវឹង និង/ឬថ្នាំញៀន ទាំងស្របច្បាប់ និងខុសច្បាប់)
- លទ្ធភាពទទួលបាន និងភាពអាចរកបានសេវាក្នុងមូលដ្ឋាន និងការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ
- ភាពអាចទទួលបាន និងភាពអាចរកបានព័ត៌មានដែលចាំបាច់
- ការសម្របសម្រួលសេវាគាំទ្រ។

ប្រភព ៖ សៀវភៅណែនាំស្តីពីការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី ប្រកបដោយប្រសិទ្ធភាព (UNODC, 2010)

សម្រាប់ព័ត៌មានបន្ថែមស្តីពីអភិក្រម ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ សូមមើលជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម)។

គួរផ្តល់ដំណឹងដល់នគរបាលនៅពេលមានការចេញដីកាការពារ ទាំងក្នុងតំបន់រស់នៅរបស់ជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់ ប្រសិនបើពួកគេស្ថិតក្នុងតំបន់នគរបាលផ្សេងគ្នា។

- តើអ្នកទទួលបានព័ត៌មានទាំងនោះដោយរបៀបណា?
- តើអ្នកអាចទទួលបានព័ត៌មានទាំងនោះនៅទីណា? តើព័ត៌មានទាំងនោះត្រូវបានពិនិត្យរកអនុលោមភាពញឹកញាប់ប៉ុណ្ណា? ឧ. ប្រសិនបើជនល្មើសត្រូវរស់នៅអាសយដ្ឋានដែលបានកំណត់តើបុគ្គលិករបស់អ្នកបាន

225. សម្រាប់ការជួយពិនិត្យលើ MARAC សូមមើល Rachel Robbins, Hugh McLaughlin, Concetta Banks, Claire Bellamy, Debbie Thackray (2014),´Domestic violence and multiagency risk assessment conferences (MARACs): A Scoping Review´, The Journal of Adult Protection, Vol. 16 Iss 6 pp. 389 – 398n.
226. សញ្ញាណដ៏មានប្រយោជន៍ស្តីពីតួនាទីរបស់ MARAC ត្រូវបានផលិតឡើងដោយ SafeLives និងអាចរកបានតាមគេហទំព័រ https://safelives.org.uk/sites/default/files/resources/MARAC%20FAQs%20General%20FINAL.pdf។

ត្រួតពិនិត្យទីតាំងនោះញឹកញាប់ដើម្បីធានាអនុលោមភាព ឬទេ?

- តើអ្នកធានាដូចម្តេចថាជនរងគ្រោះទទួលបានព័ត៌មានជាប្រចាំ? សូមចាំថាចាំបាច់ត្រូវរក្សាទំនាក់ទំនងជាមួយជនរងគ្រោះក្នុងដំណើរការយុត្តិធម៌នេះ។
- តើខ្លឹមសារលម្អិតនៃដីកាការពារត្រូវបានផ្សព្វផ្សាយទូលំទូលាយកម្រិតណា ដល់បុគ្គលិករបស់អ្នក ដើម្បីអាចកំណត់រកការរំលោភបំពានបានទាន់ពេលវេលា? ជាការល្អគួរធានាថា បុគ្គលិកផ្នែកឃុំឃាំងបានដឹងពីព័ត៌មានលម្អិត ប្រសិនបើជនបង្កដែលរងការចោទប្រកាន់ត្រូវបានឃុំឃាំងជាថ្មីដោយសារឧប្បត្តិហេតុពាក់ព័ន្ធគ្នា ឬមិនពាក់ព័ន្ធគ្នា។

អ្នកគួរមានភាពប្រតិសកម្មក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងវិធានការការពារ ឬដីកាការពារ ដែលចេញដោយតុលាការ ឬស្ថាប័នយុត្តិធម៌ផ្សេងទៀតតាមរយៈការសហការ និង សម្របសម្រួលជាមួយដៃគូប្រព័ន្ធយុត្តិធម៌របស់អ្នក។

តើអ្នកធានាថាបុគ្គលិករបស់អ្នកឆ្លើយតបទាន់ពេលវេលាទៅនឹងការរាយការណ៍ពីការរំលោភដីកាការពារ និងធានាថា ពួកគេចាត់វិធានការវិជ្ជមានក្នុងការធានាសុវត្ថិភាពជនរងគ្រោះដោយរបៀបណា? អ្នកត្រូវផ្តល់ការណែនាំច្បាស់លាស់ស្តីពីក្តីរំពឹងទុករបស់អ្នកចំពោះបុគ្គលិកពាក់ព័ន្ធនឹងរបាយការណ៍ទាំងនោះ។ ការចែករំលែកចារកម្ម និងព័ត៌មានក្នុងចំណោមអ្នកផ្តល់សេវាជាធាតុផ្សំដ៏សំខាន់មួយនៃការធានាសុវត្ថិភាព និងការការពារជនរងគ្រោះ។ ទិដ្ឋភាពធំទូលាយនៃករណីមួយអាចលេចឡើង ប្រសិនបើអ្នកផ្តល់សេវាម្នាក់ៗចែករំលែកព័ត៌មានស្តីពីទំនាក់ទំនងជាមួយជនរងគ្រោះឬជនបង្ក។ ឧ.សេវាសុខាភិបាល សេវាអប់រំ និងសេវាសង្គម អាចមានព័ត៌មានសំខាន់ៗ និងចារកម្មដែលអាចជួយដល់ការស៊ើបអង្កេតក៏ដូចជាការធានាសុវត្ថិភាព និងការការពារជនរងគ្រោះ។ តើអ្នកមានពិធីសារអ្វីខ្លះស្តីពីការចែករំលែកព័ត៌មាន និង/ឬចារកម្មជាមួយអ្នកផ្តល់សេវាផ្សេងទៀត? ប្រសិនបើគ្មានពិធីសារទេ អ្នកត្រូវបង្កើតវាឡើង។

**សម្រាប់ព័ត៌មានបន្ថែម សូមមើលជំពូកទី ៩ (ទំនាក់ទំនង) និងជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌)។**

ដើម្បីបំពេញបន្ថែមលើដំណើរការ MARAC និងក្របខណ្ឌវាយតម្លៃហានិភ័យ DASH សេវានគរបាលក្រុងឡុងដ៍បានអនុវត្តក្នុងផ្នែកនៃគំរូវាយតម្លៃហានិភ័យអំពើហិង្សាក្នុងគ្រួសាររបស់ខ្លួន (ចក្រភពអង់គ្លេស) នូវទំនោរប្រថុយប្រថាន និងឥរិយាបថចង់ប្រថុយប្រថាន[227] ឬអនុវត្តគំរូគ្រប់គ្រងហានិភ័យRARAជាជម្រើសស្តីពីរបៀបគ្រប់គ្រងហានិភ័យ។

ប្រអប់ទី ៥ ខាងក្រោមដកស្រង់ចេញពី Richard,L. 2003 "គំរូវាយតម្លៃហានិភ័យអំពើហិង្សាក្នុងគ្រួសារនៃសេវានគរបាលក្រុងឡុងដ៍" ដែលនគរបាលក្រុងឡុងដ៍រៀបរាប់ពីជម្រើសហានិភ័យសំខាន់ៗ និងវិធានការឆ្លើយតប។

227. សូមមើល Richards, L. (2003), MPS Domestic Violence Risk Assessment Model (Metropolitan Police Service, London).

**ប្រអប់ ៤**

**គំរូគ្រប់គ្រងហានិភ័យ RARA**

| ជម្រើសហានិភ័យ | វិធានការឆ្លើយតប |
|---|---|
| ការកំចាត់ហានិភ័យ | ការចាប់ខ្លួនជនបង្កដែលរងការចោទប្រកាន់ និងបញ្ជូនទៅមន្ទីរឃុំឃាំង |
| ការបញ្ចៀសហានិភ័យ | ការប្តូរទីលំនៅរបស់ជនរងគ្រោះ ឬសាក្សីសំខាន់ៗ ឬការដាក់ក្នុងជម្រក/កន្លែងស្នាក់សុវត្ថិភាពនៅទីតាំងដែលជនបង្កមិនស្គាល់ |
| ការកាត់បន្ថយហានិភ័យ | ការធ្វើអន្តរាគមន៍រួម ឬការរៀបចំផែនការសុវត្ថិភាពជនរងគ្រោះ ការពង្រឹងគោលដៅ និងការប្រើប្រាស់ច្បាប់ការពារ |
| ការទទួលយកហានិភ័យ | ការសំអាងជាប្រចាំលើការវាយតម្លៃហានិភ័យ ការរៀបចំផែនការអន្តរាគមន៍ពហុស្ថាប័នជាបន្តបន្ទាប់ការគាំទ្រនិងការយល់ព្រមរបស់ជនរងគ្រោះនិងការកំណត់យកជនល្មើសជាគោលដៅ |

## ការដោះស្រាយបញ្ហាក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

យោងតាម Logar (២០០៥) ក្នុងរបាយការណ៍របស់គាត់ដាក់ជូនផ្នែកពន្លឿនវឌ្ឍនភាពស្ត្រីនៃអង្គការសហប្រជាជាតិ កំហុសដ៏ធំមួយនៃអន្តរាគមន៍ក្នុងវិស័យអំពើហិង្សាលើស្ត្រី គឺការមើលស្រាលគ្រោះថ្នាក់ពាក់ព័ន្ធ[228]។

"កំហុសដ៏ធំមួយនៃអន្តរាគមន៍ផ្នែកអំពើហិង្សាលើស្ត្រី គឺការមើលស្រាលគ្រោះថ្នាក់ពាក់ព័ន្ធ"។

បទពិសោធន៍ពីគំរូអន្តរាគមន៍របស់ប្រទេសអូទ្រីសក្នុងករណីអំពើហិង្សាលើស្ត្រី

ក្នុងរបាយការណ៍ដូចគ្នានេះ Logar លើកឡើងទៀតថា ទោះបីជានគរបាលប្រើប្រាស់ឧបករណ៍ជាច្រើនសម្រាប់វាយតម្លៃគ្រោះថ្នាក់ក្តី ក៏ឧបករណ៍ដ៏សំខាន់បំផុតគឺត្រូវស្តាប់ជនរងគ្រោះ ជឿលើពួកគេ និងពិចារណាឱ្យហ្មត់ចត់[229]។

Logarកត់សម្គាល់ថាគន្លឹះក្នុងការបញ្ចៀសការមើលស្រាលហានិភ័យរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីចាប់ផ្តើមពីការអនុវត្តមូលដ្ឋានគ្រឹះក្នុងទំនាក់ទំនងអន្តរបុគ្គល នៅពេលពាក់ព័ន្ធជាមួយជនរងគ្រោះ៖ ការគោរព និងការស្តាប់ប្រកបដោយ ប្រសិទ្ធភាព។

គួរឱ្យសោកស្តាយដែលគុណសម្បត្តិអន្តរបុគ្គលទាំងនេះត្រូវបានដកស្រង់ញឹកញាប់ថា មិនសូវមានក្នុងជួរនគរបាល ឬមិនត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៅពេលពាក់ព័ន្ធជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ថ្នាក់ដឹកនាំនគរបាលគួរធ្វើយ៉ាងណាឱ្យក្រុមរបស់ខ្លួនបានដឹងពីសារៈសំខាន់នៃជំនាញទន់ ដូចជា ការស្តាប់យ៉ាងយកចិត្តទុកដាក់ ការវិនិច្ឆ័យ និងការគោរពសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ ក្នុងការរួមចំណែកដល់ការអនុវត្តសេវានគរបាលដោយជោគជ័យ។

**សូមមើលជំពូកទី ៩ (ទំនាក់ទំនង)។**

**សេវាសំខាន់ៗ ដែលសមស្របសម្រាប់ស្ត្រី និងក្មេងស្រីជាសេវាដែលផ្តល់ជូនតាមរបៀបដែលគាត់យល់ស្របៈ គោរពសេចក្តីថ្លៃថ្នូររបស់គាត់ ធានាការសម្ងាត់ពិតពិតម្រវការ និងទស្សនៈរបស់គាត់ និងកាត់បន្ថយការរងគ្រោះលើកទីពីរ។ និងទស្សនៈរបស់គាត់ និងកាត់បន្ថយការរងគ្រោះលើកទីពីរ។**

227. Loger, Rosa., 'Violence against women: Good practices in combating and eliminating violence against women': Austrian Model of Intervention in Domestic Violence Cases. Report to the Expert Group Meeting at the UN Division for the Advancement of Women in collaboration with UN Office on Drugs and Crime (Vienna, Austria, 2005).
229. Loger (2005) based on Gondolf's (1999) long-term investigation of programs for violent men. See: Golding JM., 'Intimate Partner Violence as a R Factor for Mental Disorders: A Meta-Analysis.' Journal of Family Violence, 1999; 14:99–132

ក្រៅពីនេះ និងជាពិសេសពាក់ព័ន្ធនឹងស្ត្រី និងក្មេងស្រីមានពិការភាព ការអនុវត្តជំនាញទន់គឺជាការសំខាន់នៅពេលស្វែងយល់ពីតម្រូវការជាក់លាក់ពាក់ព័ន្ធនឹងការសម្របសម្រួលគ្រប់គ្រាន់ (សុវត្ថិភាព) និងសមស្រប។ ប្រសិនបើគ្មានសមត្ថភាពពេញលេញក្នុងការធ្វើទំនាក់ទំនងឱ្យបានសមស្របជាមួយមន្ត្រីឆ្លើយតបទេនោះ ក្រុមឆ្លើយតបនឹងមិនអាចវាយតម្លៃគ្រោះថ្នាក់ និងចាត់វិធានការឆ្លើយតបបានឡើយ។

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីការគូសផែនទីការអនុវត្តល្អជាសកល និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលផ្តល់វិធានការការពារ និងវិធានការសុវត្ថិភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ និងបុគ្គលិករបស់អង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាលនិងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ចំណងជើងរងនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាត ទាក់ទងនឹងសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាននិង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

## ការអនុវត្តខុសឆ្គង

- ការបកស្រាយ និងការកត់ត្រាដោយមន្ត្រីឆ្លើយតបអំពីឧប្បត្តិហេតុមួយ មិនសុទ្ធតែស៊ីសង្វាក់គ្នានឹងច្បាប់ជាតិនោះទេ។ ចំណុចនេះរួមមានការបញ្ចប់ការវាយតម្លៃហានិភ័យដោយ មិនបានដឹងពីជនរងគ្រោះ[230] ។
- មន្ត្រីនគរបាល និងមន្ត្រីដទៃទៀត ហាក់ផ្តោតលើភស្តុតាងរូបវន្ត និងរបួសដើម្បីកំណត់រកបទល្មើសព្រហ្មទណ្ឌ ទាំងនៅដំណាក់កាលដំបូង និងដំណាក់កាលបន្ទាប់នៃការវាយតម្លៃហានិភ័យ។
- ឧបករណ៍វាយតម្លៃហានិភ័យដើម្បីគាំទ្រដល់មន្ត្រីជួរមុខមិនសូវផ្តោតសំខាន់លើគំរូនៃឥរិយាបថបំពានទេ។
- នគរបាលច្រើនតែចងក្រងឯកសារស្តីពីអំពើហិង្សាផ្លូវកាយ ហើយអ្វីដែលបានកើតឡើងមិនមែនជាទម្រង់នៃអំពើហិង្សាដែលមិនពាក់ព័ន្ធនឹងផ្លូវកាយនោះទេ (ឧ. ការបង្ខិតបង្ខំ និងការត្រួតត្រាដែលជំរុញឱ្យមានអំពើហិង្សា)។ជាទូទៅការវាយតម្លៃដំបូងដ៏តូចចង្អៀតនេះជះឥទ្ធិពលអវិជ្ជមានលើការវាយតម្លៃហានិភ័យជាបន្តបន្ទាប់។
- នគរបាលហាក់បញ្ចប់ឧបករណ៍វាយតម្លៃហានិភ័យក្នុងរយៈពេលជាច្រើនម៉ោងបន្ទាប់ពីពួកគេបានចាកចេញពីឧប្បត្តិហេតុអំពើហិង្សាលើដៃគូស្និទ្ធស្នាល ជាជាងស្ថិតនៅកន្លែងកើតហេតុ ហើយការធ្វើដូច្នេះអាចបង្កផលប៉ះពាល់លើគុណភាពព័ត៌មាន ព្រោះវាបង្កើនលទ្ធភាពនៃការមិនពិគ្រោះជាមួយជនរងគ្រោះ[231]។
- ក្នុងករណីដែលពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរដូចជាការជួញដូរស្ត្រីសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទដែលពាក់ព័ន្ធនឹងក្រុមជនល្មើស នគរបាលមានការលំបាកក្នុងការធានាការផ្តល់ដីកាការពារដល់សមាជិកគ្រួសាររបស់ជនរងគ្រោះដែលអាចប្រឈមនឹងការសងសឹក។
- ជាញឹកញាប់ នគរបាលបានត្រឹមតែស៊ើបអង្កេតព្រឹត្តិការណ៍នីមួយៗប៉ុន្តែមិនពិចារណាពីទំនាក់ទំនងបែបបំពានទាំងស្រុងឡើយ។

## ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ

- ការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាពិសេសអំពើហិង្សាលើដៃគូស្និទ្ធស្នាល គឺផ្អែកតាមដំណើរការ។ ជាញឹកញាប់ មន្ត្រីឆ្លើយតបមិនយល់ពីសនិទានភាពសម្រាប់ការកំណត់រក និងការវាយតម្លៃហានិភ័យ[232]។ ដូច្នេះ ពួកគេមិនអាចកំណត់រកសូចនាករហានិភ័យ និង/ឬកត់ត្រាព័ត៌មានយ៉ាងសុក្រឹត និងស៊ីសង្វាក់គ្នាបានឡើយ។
- ជាទូទៅ នគរបាលឆ្លើយតបមិនសូវយល់ដឹងពីការត្រួតត្រាដោយបង្ខំ ឬយល់ដែរ ប៉ុន្តែមិនបង្កប់ចំណុចនេះក្នុងអភិក្រមផ្អែកតាមហានិភ័យឱ្យមានប្រសិទ្ធភាពគ្រប់គ្រាន់[233]។

230. ដកស្រង់ចេញពី Kropp, R.P, Hart, S.D., (2004) 'The Development of the Brief Spousal Assault Form for the Evaluation of Risk (BSAFER): A Tool for Criminal Justice Professionals', Family Violence Initiative Research and Statistics Division, Department of Justice, Canada.
231. Dowling, C., Morgan, A., Boyd, C., Voce, I., (2018) 'Policing Domestic Violence: A Review of the Evidence', Australian Institute of Criminology, Research Report 13.

- មន្ត្រីឆ្លើយតបមិនបានប្រើប្រាស់ទម្រង់វាយតម្លៃហានិភ័យ ព្រោះពួកគេយល់ថា ដំណើរការនេះតម្រូវឱ្យពួកគេធ្វើការ "វិនិច្ឆ័យ និងសន្មត" លើជនល្មើស និងជនរងគ្រោះដែលលើសពីតួនាទីរបស់មន្ត្រីនគរបាល[234]។

"ផែនការសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រីចំណាកស្រុកដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរពិចារណាថាភាសាកំណើតរបស់ពួកគាត់ខុសពីភាសាក្នុងប្រទេសដែលពួកគាត់កំពុងរស់នៅឬក្លាយជាជនរងគ្រោះ។ពួកគាត់អាចមានស្ថានភាពទេសន្តប្រវេសន៍មិនទៀងទាត់ និងមកពីសហគមន៍ជនជាតិភាគតិច"។

Gerry Campbell អតីតប្រធានផ្នែកស៊ើបអង្កេត Scotland Yard

- នគរបាលមានការលំបាកជាខ្លាំងនៅពេលស្វែងយល់ពីហានិភ័យរបស់ស្ត្រីទេសន្តប្រវេសន៍ ដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ក្នុងករណីជាច្រើន ស្ត្រីចំណាកស្រុកមានការពឹងផ្អែកផ្នែកសង្គមនិងសេដ្ឋកិច្ចលើដៃគូស្និទ្ធស្នាលរបស់គាត់។ ដូច្នេះផែនការសុវត្ថិភាពរបស់នគរបាលត្រូវពិចារណាពីលិខិតអនុញ្ញាតឱ្យរស់នៅ និងលិខិតអនុញ្ញាតការងារដែលមិនពាក់ព័ន្ធនឹងដៃគូស្និទ្ធស្នាលរបស់គាត់ដើម្បីអាចឱ្យជនរងគ្រោះចាកចេញពីទំនាក់ទំនងបែបបំពាននេះ។
- ជាញឹកញាប់កម្មវិធីបណ្តុះបណ្តាលសម្រាប់នគរបាលមិនគ្របដណ្តប់លើហានិភ័យ និងតម្រូវការជាក់លាក់របស់ស្ត្រីមានពិការភាព និងស្ត្រីផ្សេងទៀតមកពីក្រុមមានហានិភ័យ ដែលជាជនរងគ្រោះដោយសារអំពើហិង្សា។ ចំណុចនេះរួមមានភាពចាំបាច់ក្នុងការទទួលបានការផ្តល់ការយល់ព្រមត្រឹមត្រូវ ការរក្សាការសម្ងាត់

232. ក្នុងស្ថានភាពជាច្រើនមន្ត្រីនគរបាលមិនសូវមានចំណេះដឹងស្តីពីប្រភេទហានិភ័យមួយចំនួនដូចជា ហានិភ័យនៃជំងឺផ្លូវចិត្ត។ សូមមើល សេវានគរបាលដែលផ្អែកតាមហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ និងគំរូហានិភ័យ DASH មហាវិទ្យាល័យសេវានគរបាល (ចក្រភពអង់គ្លេស) https://www.college.police.uk/News/College-news/Documents/Riskled_policing_of_domestic_abuse_and_the_DASH_risk_model.pdf ។
233. យោងតាម Robinson et al. (2016) កង្វះការយល់ដឹងពីគំរូបែបបង្ខិតបង្ខំ និងត្រួតត្រានៃឥរិយាបថបំពាន អាចបង្កផលវិបាកលើអ្វីដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាការរំលោភបំពានក្នុងគ្រួសារ និងជាកម្មវត្ថុនៃការវាយតម្លៃហានិភ័យ។
234. ដកស្រង់ចេញពី Kropp, R.P, Hart, S.D (2004), 'The Development of the Brief Spousal Assault Form for the Evaluation of Risk (B-SAFER): A Tool for Criminal Justice Professionals', Family Violence Initiative Research and Statistics Division, Department of Justice Canada.

នៅពេលដែលទំនាក់ទំនងផ្អែកលើសាច់ញាតិនិងតួនាទីបែបបង្ខិតបង្ខំរបស់អ្នកថែទាំ ដែលពេលខ្លះគឺជាជនបង្កតែម្តង។ ជាញឹកញាប់ នគរបាលមើលរំលងរបៀបដែលស្ត្រីមានពិការភាពពឹងផ្អែកលើសាច់ញាតិឬអ្នកថែទាំរបស់ខ្លួនហើយចំណុចនេះធ្វើឱ្យពួកគាត់ប្រឈមនឹងហានិភ័យ។ កត្តានេះរារាំងមិនឱ្យពួកគេរាយការណ៍ និងបង្កអន្តរាយដល់ការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសង្គម។

រដ្ឋគួរផ្តន្ទាទោសអំពើហិង្សាលើស្ត្រី និងមិនគួរបំផុសឱ្យមានការពិចារណាក្នុងទំនៀមទម្លាប់ប្រពៃណីឬសាសនាដើម្បីបញ្ចៀសកាតព្វកិច្ចរបស់ខ្លួនក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រីឡើយ។រដ្ឋគួរប្រើប្រាស់គ្រប់មធ្យោបាយសមស្របទាំងអស់ និងដោយមិនបង្អែបង្អង់ក្នុងការអនុម័តគោលនយោបាយស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីហើយក្នុងន័យនេះគួរ ៖
គ. ខិតខំទប់ស្កាត់ ស៊ើបអង្កេត និងអនុលោមតាមច្បាប់ជាតិ ដាក់ទណ្ឌកម្មលើអំពើហិង្សាប្រឆាំងនឹងស្ត្រី មិនថាអំពើទាំងនោះបង្កឡើងដោយរដ្ឋ ឬបុគ្គលឯកជននោះទេ។

មាត្រា ៤ ៖ សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (១៩៩៣)

## និយមន័យ និងក្របខណ្ឌ

កញ្ចប់សេវាសំខាន់ៗលើកឡើងថាវិធានការការពារ សម្រាប់ស្ត្រីនិងក្មេងស្រីដែលឆ្លងកាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ឈប់អំពើហិង្សា និងការទប់ស្កាត់ការកើតឡើងវិញ ការរីករាលដាល និងការគំរាមប្រព្រឹត្តអំពើហិង្សានាពេលអនាគត។

មានន័យថាដោយមិនគិតពីបរិបទឬប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត នគរបាលត្រូវធ្វើអន្តរាគមន៍ភ្លាមៗ និងដោយសមាមាត្រ (ទៅតាមការគំរាមកំហែង) ដើម្បីធានាការការពារនិងសុវត្ថិភាពរបស់ជនរងគ្រោះ។លើសពីនេះត្រូវផ្តល់វិធានការការពារដាច់ដោយឡែក ពីការផ្តួចផ្តើមករណីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ឬច្បាប់គ្រួសារ។

កញ្ចប់សេវាសំខាន់ៗបញ្ជាក់ថា វិធានការការពារគួរត្រូវ

បានរៀបចំឡើងសម្រាប់បង្កើនភាពអង់អាចរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ និងផ្តល់លទ្ធភាពឱ្យពួកគេចូលរួមដោយសុវត្ថិភាពក្នុងដំណើរការយុត្តិធម៌[235]។

នៅពេលមានអន្តរាគមន៍ដំបូង និងភ្លាមៗ នគរបាលនឹងមានឧបករណ៍ជាច្រើន ដូចជា ទម្រង់វាយតម្លៃហានិភ័យសម្រាប់ភ្នាក់ងារឆ្លើយតបដំបូង[236] និងប្រសិនបើមានព័ត៌មានស្តីពីឥរិយាបថបំពានពីមុន ដើម្បីជួយដល់ការកំណត់ភាពសមាមាត្រនៃវិធានការការពារដែលចាំបាច់(អាសន្នឬបន្ទាន់)។

យោងតាមកញ្ចប់សេវាសំខាន់ៗ ៖

- ***វិធានការអាសន្ន*** សំដៅលើវិធានការដែលអាចទទួលបានដោយគ្មានការជូនដំណឹងទៅជនបង្កដែលរងការចោទប្រកាន់ដោយមិនតម្រូវឱ្យប្រមូលភស្តុតាងពេញលេញនិងសម្រេចទៅតាមគុណភាពនៃលទ្ធភាពដែលអាចកើតឡើង។ ជាទូទៅវិធានការទាំងនេះគឺសម្រាប់ការការពារ រយៈពេលខ្លី។
- ***វិធានការបន្ទាន់*** សំដៅលើវិធានការដែលត្រូវបញ្ជូនទៅតុលាការដោយឥតបង្អែបង្អង់ ដូចជា តាមរយៈនីតិវិធីរហ័ស ប៉ុន្តែការសម្រេចគឺផ្អែកលើសវនាការភស្តុតាងពេញលេញ។ជាទូទៅវិធានការការពារបន្ទាន់គឺសម្រាប់រយៈពេលវែង[237] ។

ដោយមិនគិតពីចំណាត់ថ្នាក់នៃវិធានការការពារ និងថាតើវិធានការនោះស្ថិតក្រោមច្បាប់រដ្ឋប្បវេណី ឬច្បាប់ព្រហ្មទណ្ឌនោះទេ ជាតុផ្សំដ៏សំខាន់នៃវិធានការការពារដែលមានប្រសិទ្ធភាព និងគ្រប់គ្រាន់គឺការដឹងពីជាតុផ្សំដែលផ្តល់មូលដ្ឋានព័ត៌មានដល់ភាពសមាមាត្រ និងប្រសិទ្ធភាពនៃវិធានការការពារដើម្បីធានាថា វិធានការទាំងនោះបញ្ឈប់ភ្លាមៗនូវអំពើហិង្សា ដែលស្ត្រីប្រឈម

235. សូមមើលម៉ូឌុលទី ៣ ស្តីពីយុត្តិធម៌ និងនគរបាល កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព(កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥) ៖ https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence p. 28.។
236. សម្រាប់ឧទាហរណ៍នៃទម្រង់វាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាល សូមមើលផ្នែកស្តីពីគន្លឹះសម្រាប់ការណែនាំគ្នាទៅវិញទៅមកស្តីពីសេវានគរបាលផ្អែកតាមហានិភ័យ និងការប្រើប្រាស់គំរូហានិភ័យ DASH របស់ចក្រភពអង់គ្លេស។
237. សូមមើល n.24។

ហើយទន្ទឹមនឹងនេះអនុញ្ញាតឱ្យជនរងគ្រោះទាមទារសិទ្ធិរបស់ខ្លួន និងផ្តួចផ្តើមដោយអនុលោមតាមច្បាប់នូវកិច្ចស៊ើបអង្កេតពេញលេញនិងមិនលម្អៀងលើអំពើហិង្សានោះ។

ដើម្បីធានាថា អន្តរាគមន៍ការពារមានប្រសិទ្ធភាព និងស៊ីគ្នានឹងស្តង់ដារអន្តរជាតិនៃការយកចិត្តទុកដាក់ខ្ពស់[238] ការពិចារណាពីភាពសមាមាត្រ[239] ដោយនគរបាលសម្រាប់ការដាក់អនុសាសន៍ និងការពង្រឹងវិធានការការពារ ត្រូវមានភាពទូលំទូលាយលើសពីការផ្អែកតាមកាលៈទេសៈចំពោះមុខ (រួមទាំងអំពើហិង្សាផ្លូវចិត្ត ការបង្កភាពតក់ស្លុត ឬការឈ្លបចាប់) ដែលស្តែងចេញពីអំពើហិង្សាដែលកំពុងស៊ើបអង្កេត។

បទដ្ឋានអន្តរជាតិទាមទារអន្តរាគមន៍របស់នគរបាល ជាពិសេសវិធានការការពារសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវផ្អែកតាមបរិបទ[240]។ ចំណុចនេះមានន័យថានគរបាលត្រូវយល់និងពិចារណាពីវប្បធម៌នៃអំពើហិង្សា និងការរើសអើងដែលប្រឈមដោយស្ត្រីនិងក្មេងស្រីបូករួមនឹងឥរិយាបថបែបបង្ខិតបង្ខំ និងបំពានរបស់ជនបង្កដែលរងការចោទប្រកាន់នៅពេលនគរបាលវាយតម្លៃហានិភ័យសុវត្ថិភាពចំពោះជនរងគ្រោះក្នុងពេលស៊ើបអង្កេត។

238. គោលគំនិតនៃការយកចិត្តទុកដាក់ខ្ពស់អាចពិពណ៌នាជាយន្តការដែលកំណត់ស្តង់ដារនៃភារកិច្ចយកចិត្តទុកដាក់ ឬស្តង់ដារនៃការយកចិត្តទុកដាក់ដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់ថាតើរដ្ឋបានអនុលោមដោយប្រសិទ្ធភាពតាមកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ ឬទេ។ រដ្ឋមានតួនាទីទប់ស្កាត់គ្រោះថ្នាក់លើអ្នកដទៃ និងផ្តល់ដំណោះស្រាយដែលមានប្រសិទ្ធភាពអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្នុងសន្ធិសញ្ញា នៅពេលមានការបង្កគ្រោះថ្នាក់។ សូមមើល R. Higgins, Problems and Process, (Clarendon Press, Oxford, 1994.), pp. 153-54, at, p. 153។ រដ្ឋត្រូវលុបបំបាត់ឧបសគ្គដែលរារាំងលទ្ធភាពប្រកបដោយប្រសិទ្ធភាពរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ ចាត់វិធានការដែលមានគោលបំណងជួយឱ្យជនរងគ្រោះទាមទារសិទ្ធិរបស់ខ្លួន និងវាយតម្លៃផលប៉ះពាល់នៃការអនុវត្តសកម្មភាពទាំងនេះជំនួសមុខឱ្យជនរងគ្រោះ។ សូមមើលផងដែរ ៖ សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលការពង្រឹងកម្មវិធីសម្រាប់ធានាសន្តិសុខរបស់ក្រុមងាយរងគ្រោះ(UNODC ក្រោមភាពជាដៃគូជាមួយរដ្ឋាភិបាលម៉ិចស៊ិក ២០១៧)។
239. សូមមើលគោលការណ៍នៃភាពចាំបាច់ និងភាពសមាមាត្រ គោលការណ៍ទី ៥ ៖ គោលការណ៍គ្រឹះស្តីពីការប្រើប្រាស់កងកម្លាំងនិងកាំភ្លើងដោយមន្ត្រីអនុវត្តន៍ច្បាប់(១៩៩០) ដែលត្រូវបានអនុម័តដោយសមាជលើកទី ៨ របស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តលើជនល្មើស ទីក្រុងហាវ៉ាណា ប្រទេសគុយបា (ថ្ងៃទី ២៧ ខែ សីហា-ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០)។
240. សូមមើល រឿងក្តី Maria da Penha ទល់នឹង ប្រេស៊ីល គណៈកម្មការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស (២០០០)។ រឿងក្តី Gonzalez និងអ្នកផ្សេងទៀត (ចម្ការកប្បាស) ទល់នឹង ម៉ិចស៊ិក តុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស (២០០៩)។ រឿងក្តី Opuz ទល់នឹង ទួរគី តុលាការសិទ្ធិមនុស្សអឺរ៉ុប (២០០៩)។ រឿងក្តី A.T. ទល់នឹង ហុងគ្រី គណៈកម្មាធិការអនុសញ្ញា CEDAW (២០០៣)។ រឿងក្តី Osman ទល់នឹង ចក្រភពអង់គ្លេស តុលាការសិទ្ធិមនុស្សអឺរ៉ុប (១៩៩៨)។ រឿងក្តី Jessica Lenahan ទល់នឹង សហរដ្ឋអាមេរិក (២០១១) គណៈកម្មការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស។រឿងក្តី Fatima Yildirim ទល់នឹង អូទ្រីស គណៈកម្មាធិការអនុសញ្ញា CEDAW (២០០៧)។ល។

**សូមមើលឧបសម្ព័ន្ធ ១ ក្នុងជំពូកទី ៥ (ការស៊ើបអង្កេត) សម្រាប់ឧទាហរណ៍លម្អិតនៃឥរិយាបថត្រួតត្រាដោយបង្ខំ។**

ព័ត៌មានបរិបទបូករួមនឹងព្រឹត្តិការណ៍ដែលបំផុសឱ្យមានអន្តរាគមន៍របស់នគរបាល គួររួមបញ្ចូលទាំងសុវត្ថិភាពរបស់ក្រុមគ្រួសារជនរងគ្រោះដើម្បីការពារពួកគេពីការបំភិតបំភ័យ និងការសងសឹក។

ព័ត៌មានទាំងអស់នេះគួរផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ក្នុងប្រព័ន្ធយុត្តិធម៌ ដូចជា ចៅក្រម អយ្យការ នគរបាលនិងស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀតដើម្បីធានាថា ហានិភ័យដែលបង្កផលប៉ះពាល់លើសុវត្ថិភាពរបស់ជនរងគ្រោះ ត្រូវបានលើកមកពិចារណាក្នុងការសម្រេចពាក់ព័ន្ធនឹងការដោះលែងជនបង្កនិងធានាថាមានវិធានការគ្រប់គ្រាន់ដើម្បីសម្របសម្រួលការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ វិធានការអាចជាការចុះញ៉ើកញ្ញាប់ទៅទីលំនៅរបស់ជនរងគ្រោះដោយនគរបាលល្បាតក្នុងមូលដ្ឋានការត្រួតពិនិត្យការទៅលេងកូនពីសំណាក់ជនបង្ក ឬបទប្បញ្ញត្តិតឹងរ៉ឹងក្នុងដីកាហាមឃាត់បណ្តោះអាសន្ន។ល។

តាមរយៈការអនុលោមតាមស្តង់ដារនៃការយកចិត្តទុកដាក់ខ្ពស់ នគរបាលនឹងផ្តល់ការឆ្លើយតបទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សជាវិជ្ជមាន នៅពេលធ្វើសកម្មភាព "ទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស" និងនៅពេល "ខិតខំសម្រេចបានគោលបំណងស្របច្បាប់"[241]។

វិសមភាពយេនឌ័រសម្រួលដល់ការប្រព្រឹត្តអំពើហិង្សា និងការរើសអើងធ្ងន់ធ្ងរលើស្ត្រីនិងក្មេងស្រីក្នុងសង្គម(សូមមើលសេចក្តីផ្តើម)។ មជ្ឈដ្ឋានបរិបទនីមួយៗក្នុងសង្គមនឹងរំលេចអំពើហិង្សា និងការរើសអើងលើស្ត្រី និងក្មេងស្រីដែលស្រដៀងគ្នាផង ខុសគ្នាផង។ សូមមើលបរិបទក្នុងប្រអប់ ៩-១១ សម្រាប់ឧទាហរណ៍នៃទម្រង់អំពើហិង្សា និងការរើសអើងធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ៩**

**បរិបទទី ១**

ជាទូទៅ ពហុពន្ធភាព និងអាពាហ៍ពិពាហ៍កុមារជាកត្តាពីរដែលបំផុសឱ្យមានឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារ។ ក្មេងស្រីដែលរៀបការវ័យក្មេងច្រើនតែក្លាយជាជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារព្រោះពួកគេគ្មានអំណាចដោយសារពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើប្តី មានកម្រិតអប់រំទាបដែលមិនអាចឱ្យពួកគេធ្វើការបាន មានគំនិតក្មេងខ្ចីទាក់ទងនឹងការប្រឈមនឹងការរំលោភបំពាន និងមានភាពក្មេងខ្ចីក្នុងវ័យបន្តពូជ។

លទ្ធផលរកឃើញពី "ការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ស្រុក ប្រទេស នេប៉ាល់" (របាយការណ៍វាយតម្លៃនៅពេលបញ្ចប់គម្រោង ២០០៩)

សមត្ថភាពរបស់មន្ត្រីនគរបាលក្នុងការផ្សារភ្ជាប់លក្ខណៈមិនសមាមាត្រនៃអំពើហិង្សា និងការរើសអើងក្នុងបរិបទមិនមែនលេចឡើងដោយឯកឯងនោះទេ។

ដូច្នេះការកសាងការយល់ដឹងពីបរិបទរបស់មន្ត្រីនគរបាលត្រូវផ្អែកតាម ភស្តុតាង និងឆ្លុះបញ្ចាំងពីទិន្នន័យដែលប្រមូលបាន និងស្ថិតិផ្លូវការរបស់អ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតដែលបង្ហាញពីប្រេវ៉ាឡង់សម្រាប់ទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងគំរូឥរិយាបថរបស់ជនបង្ក។

ចំណុចនេះនឹងដើរតួនាទីសំខាន់ក្នុងការការទប់ស្កាត់បទល្មើសជារួមក៏ដូចជាផ្តល់មូលដ្ឋានព័ត៌មានដល់សកម្មភាពដែលបានដៅទុកដូចជាការរៀបចំនិងការអនុវត្តវិធានការការពារដើម្បីអាចបំពេញគ្រប់គ្រាន់នូវតម្រូវការសុវត្ថិភាពរបស់ជនរងគ្រោះ និងកាត់បន្ថយការប្រព្រឹត្តអំពើហិង្សាបន្ថែមទៀតលើពួកគេ។

241. គោលការណ៍ទី៥នៃគោលការណ៍គ្រឹះស្តីពីការប្រើប្រាស់កងកម្លាំងនិងកាំភ្លើងដោយមន្ត្រីអនុវត្តន៍ច្បាប់ (១៩៩០) ដែលត្រូវបានអនុម័តដោយសមាជលើកទី ៨ របស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តលើជនល្មើស ទីក្រុងហាវ៉ាណា ប្រទេសគុយបា (ថ្ងៃទី ២៧ ខែ សីហា-ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០)។

**ប្រអប់ ៦**

**បរិបទទី ២**

ជាញឹកញាប់ការអនុវត្តដែលបង្កគ្រោះថ្នាក់ដូចជាអាពាហ៍ពិពាហ៍កុមារការឆាប់រៀបការនិងអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី មិនទទួលបានការយកចិត្តទុកដាក់។ នគរបាលមិនគួរមើលស្រាលអំពើហិង្សាផ្លូវកាយ និងអំពើហិង្សាផ្លូវចិត្តដែលពាក់ព័ន្ធនឹងការអនុវត្តទាំងនេះឡើយ។ UNICEF ប៉ាន់ស្មានថាក្មេងស្រី និងស្ត្រី ៧៥០ លាននាក់នៅជុំវិញពិភពលោកបានរៀបការតាំងពីក្មេង ហើយក្មេងស្រី និងស្ត្រីជាង ២០០ លាននាក់ត្រូវបានវះកាត់ប្រដាប់បន្តពូជ។

UNICEF

សេណារីយ៉ូដ៏លំបាកមួយទៀតសម្រាប់នគរបាល គឺការផ្តល់វិធានការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យា ដូចជា ការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ឬការល្បួងតាមប្រព័ន្ធអ៊ីនធឺណិតដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។

ដំបូង ជនបង្កស្ថិត ពីចំងាយពីជនរងគ្រោះ ប៉ុន្តែពួកគេមានគោលបំណងចង់ទាក់ទងក្នុងទម្រង់មួយផ្ទាល់ខ្លួន។

ឥរិយាបថបែបបង្ខិតបង្ខំ និងបង្កហិង្សាលើផ្លូវចិត្ត ជាគំរូទូទៅដែលស្តែងឡើងដោយជនបង្ក។ ទម្រង់នៃអំពើហិង្សាមិនមែនផ្លូវកាយទាំងនេះក៏អាចកត់សម្គាល់ក្នុងវដ្តអំពើហិង្សាផងដែរ និងជួយដល់នគរបាលក្នុងការកាត់បន្ថយអំពើហិង្សាបន្ថែមទៀត និងធានាវិធានការការពារគ្រប់គ្រាន់។

**សូមមើលជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ព័ត៌មានបន្ថែមស្តីពីគំរូវដ្តអំពើហិង្សាក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

ម៉ូឌុលទី ១២ របស់ UNODC ដែលមានចំណងជើងថា "ការអប់រំស្តីពីយុត្តិធម៌ក្នុងបទល្មើសអន្តរបុគ្គលតាមប្រព័ន្ធបច្ចេកវិទ្យា"[242] ផ្តល់ការយល់ដឹងអំពីកម្រិតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាផលប៉ះពាល់ និងផលវិបាកធ្ងន់ធ្ងរនៃអំពើហិង្សានេះលើស្ត្រី និងក្មេងស្រី។

"ស្ត្រីប្រឈមធ្ងន់ធ្ងរទៅនឹងទម្រង់ផ្សេងៗនៃការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតនៅជុំវិញពិភពលោកជាពិសេសស្ត្រីដែលកាន់សាសនាជាក់លាក់ មកពីក្រុមជាតិពន្ធុ ឬក្រុមជាតិសាសន៍ជាក់លាក់ មានទំនោរផ្លូវភេទ និងស្ថានភាពសេដ្ឋកិច្ចជាក់លាក់ និងស្ត្រីមានពិការភាព។ ការស្ទង់មតិដោយអង្គការលើកលែងទោសអន្តរជាតិ (២០១៧) បង្ហាញថា ប្រហែល ១/៤ នៃស្ត្រីទាំង ៤.០០០ នាក់ដែលចូលរួមក្នុងការអង្កេតនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ដាណឺម៉ាក ស៊ុយអែត អេស្ប៉ាញ អ៊ីតាលី និងប៉ូឡូញ បានឆ្លងកាត់ទម្រង់មួយចំនួននៃការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត (ឧ. ការបៀតបៀនតាមប្រព័ន្ធបច្ចេកវិទ្យា) យ៉ាងតិចម្តង។ ក្រៅពីនេះ ៤១% នៃស្ត្រីដែលឆ្លងកាត់ការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតទាំងនេះ ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនដោយសារការរំលោភបំពាន និងការបៀតបៀន (អង្គការលើកលែងទោសអន្តរជាតិ ២០១៧)។ ស្ត្រីបានទទួលសារគំរាម ការគំរាមប្រព្រឹត្តអំពើហិង្សា និងសារ អ៊ីមែល រូបភាព និងវីដេអូបែបផ្លូវភេទតាមរយៈការណាត់ជួបគ្នា បណ្តាញសង្គម និងវេទិកាអនឡាញផ្សេងទៀត ក៏ដូចជាក្នុងកម្មវិធី Chat និងសេវាសារខ្លីៗ"។

ក្រៅពីនេះ នគរបាលមានការលំបាកក្នុងការផ្តល់ការការពារសម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ជាពិសេសអំពើហិង្សាផ្លូវភេទ។ ក្នុងបរិបទនេះជាញឹកញាប់នគរបាលនិងកងកម្លាំងសន្តិសុខរដ្ឋផ្សេងទៀតគ្មានសមត្ថភាពធានាការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះ និង/ឬសាក្សីនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីឡើយ ឬពួកគេពេញចិត្ត ឬសមគំនិតក្នុងករណី

242. បទល្មើសអន្តរបុគ្គលតាមប្រព័ន្ធបច្ចេកវិទ្យាផ្អែកលើយេនឌ័រ (UNODC) សូមមើល https://www.unodc.org/e4j/en/cybercrime/module-12/key-issues/gender-based-interpersonal-cybercrime.html។ សូមមើលផងដែរ បាយការណ៍ឆ្នាំ ២០១៨ របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រី ឫសគល់ និងផលវិបាកនៃអំពើហិង្សានេះចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតផ្អែកតាមទស្សនៈសិទ្ធិមនុស្ស (A/HRC/38/47) និង "អង្គការលើកលែងទោសអន្តរជាតិបង្ហាញផលប៉ះពាល់គួរឱ្យព្រួយបារម្ភនៃការរំលោភបំពានស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត" (២០១៧) https://www.amnesty.org/en/latest/news/2017/11/amnesty-reveals-alarming-impact-of-online-abuse-against-women/។

អំពើហិង្សាដែលរងការចោទប្រកាន់។ ដូច្នេះ ត្រូវផ្ដោតការយកចិត្តទុកដាក់លើការសាយភាយអាវុធធុនតូចនិងធុនស្រាលដែលមិនត្រឹមតែបង្កហានិភ័យកាន់តែខ្លាំងលើស្ត្រី និងក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កហានិភ័យលើមន្ត្រីនគរបាលឆ្លើយតបផងដែរ។

**ប្រអប់ ៧**

**បរិបទទី ៣**

អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការមានអាវុធធុនតូច និងធុនស្រាលនៅផ្ទះ ៖ ការមានអាវុធធុនតូច និងធុនស្រាលនៅផ្ទះផ្តល់ជាឧបករណ៍ចុងក្រោយសម្រាប់ឱ្យជនបំពានធ្វើការគ្រប់គ្រងទាំងស្រុង និងរក្សាអំណាចលើដៃគូស្និទ្ធស្នាល ដែលជាគោលដៅនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ទោះបីជាមិនត្រូវបានប្រើប្រាស់ក្តីក៏វត្តមានអាវុធទាំងនោះអាចកាត់បន្ថយឱកាសរបស់ស្ត្រីក្នុងការរាយការណ៍ពីអំពើហិង្សា និងកាត់បន្ថយលទ្ធភាពរបស់គាត់ក្នុងការប្រឆាំងតប។ ក្រៅពីនេះ ការសិក្សាបានគូសបញ្ជាក់ពីទំនាក់ទំនងវិជ្ជមានរវាងការមានអាវុធធុនតូចនិងធុនស្រាលនៅផ្ទះនិងការសម្លាប់មនុស្សស្រី។យោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ និងបូព៌ា(SEESAC)អំពើមនុស្សឃាតដែលប្រព្រឹត្តដោយសមាជិកគ្រួសារម្នាក់ គឺជាទម្រង់ទូទៅបំផុតនៃការសម្លាប់មនុស្សស្រីនៅអឺរ៉ុបភាគអាគ្នេយ៍ ដែលជាញឹកញាប់កាំភ្លើងត្រូវបានប្រើប្រាស់ជាអាវុធ។ SEESAC រាយការណ៍ថាក្នុងតំបន់នេះ ស្ត្រីចំនួន ៦១% ដែលត្រូវបានសម្លាប់ គឺត្រូវបានសម្លាប់ដោយសមាជិកគ្រួសារម្នាក់ធៀបនឹងបុរសចំនួន ១២,៤% ដែលត្រូវបានសម្លាប់ដោយសមាជិកគ្រួសារម្នាក់។ មានភាពខុសគ្នាកាន់តែខ្លាំង សម្រាប់អំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (៣៨,៦% នៃស្ត្រីទាំងអស់ដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាលធៀបនឹង ១,២% នៃបុរសទាំងអស់ដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល)។

ស្ថិតិទាំងនេះអាចងាយនឹងកើនឡើងដោយសារការសាយភាយ (prefoliation) នៃអាវុធធុនតូច និងធុនស្រាលដែលបណ្តាលមកពីជម្លោះប្រដាប់អាវុធក្នុងប្រទេសនោះ ឬប្រទេសជិតខាង។

ប្រភព ៖ Bozanic, D, 'The Hidden Pandemic: Firearms and Intimate Partner Violence Killing Women' (UNDP SEESAC, 2020)

ក្រៅពីនេះការហូរចូលយ៉ាងច្រើនលើសលប់នៃជនភៀសខ្លួនដែលស្វែងរកការការពារពីជម្លោះប្រដាប់អាវុធឬទម្រង់ផ្សេងទៀតនៃវិបត្តិធំៗក្នុងប្រទេសជិតខាង ក៏បង្កការលំបាកធ្ងន់ធ្ងរដល់នគរបាលនិងដៃគូសេវាសំខាន់ៗរបស់ពួកគេផងដែរ ដោយសារបំលាស់ទីប្រជាជនដែលគ្មានលិខិតស្នាម រួមទាំងបំលាស់ទីរបស់ជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់បានរឹតត្បិតផលប៉ះពាល់នៃវិធានការការពាររបស់នគរបាល។ ការការពារ និងសុវត្ថិភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះនឹងលើកមកពិភាក្សាក្នុងជំពូកទី១៣ (បញ្ហាដែលលេចឡើងក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី)។

## សមត្ថភាពគ្រប់គ្រងសំខាន់ៗសម្រាប់ការអនុវត្តយុទ្ធសាស្ត្រសុវត្ថិភាព និងការការពារ ដែលពាក់ព័ន្ធនឹងបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី

ពាក់ព័ន្ធនឹងការការពារ និងសុវត្ថិភាព និងក្រោយពីការវាយតម្លៃហានិភ័យដំបូង នគរបាលគួរពិចារណាឱ្យបានទូលំទូលាយនៅពេលផ្តល់ព័ត៌មានត្រឹមត្រូវ ស្តីពីជម្រើសដំណោះស្រាយដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ត្រង់ចំណុចនេះ នគរបាលអាចពិចារណាពីចំណុចបំផុសទូទៅដែលនាំឱ្យមានអំពើហិង្សា និង/ឬបទល្មើសបន្ថែមទៀតលើជនរងគ្រោះ ក្រោយការរាយការណ៍ពីអំពើហិង្សា និង/ឬបទល្មើស ដូចខាងក្រោម (ប៉ុន្តែមិនកំណត់ត្រឹម)៖

- ការសងសឹកដោយជនបង្កពីមុន ដែលអាចមានមកលើផ្លូវកាយ ផ្លូវចិត្ត (ដូចជា ការគំរាមកុមារ ឬការពង្រត់កុមារ) ផ្នែកហិរញ្ញវត្ថុ ផ្នែកសង្គម និងវប្បធម៌ តាមរយៈការផាត់ចេញពីសហគមន៍ឬបណ្តាញសង្គម។
- ការប្រព្រឹត្តអំពើហិង្សាជាបន្តបន្ទាប់ដោយជនបង្ក ចម្រុះ និងភាគីដែលមានប្រយោជន៍ចម្រុះក្នុងតំបន់រងផលប៉ះពាល់ដោយសារជម្លោះ។
- អំពើហិង្សាដែលប្រព្រឹត្តដោយជនបំពានថ្មីដោយសារភាពងាយរងគ្រោះទៅនឹងអំពើហិង្សាពីមុន រួមទាំងអំពើហិង្សាដែលប្រព្រឹត្តដោយនគរបាលផ្ទាល់។
- គ្រោះថ្នាក់ដែលបង្កឡើងដោយជនរងគ្រោះ ដោយសារអំពើហិង្សាពីមុន។

ក្នុងករណីជាច្រើននគរបាលឬអង្គភាពឯកទេសត្រូវបានស្នើឱ្យផ្តល់ការគាំទ្រ និងគ្រប់គ្រងលើករណី ឬឧប្បត្តិហេតុទាំងនេះ។ ជាធម្មតា មន្ត្រីឯកទេសទាំងនេះទទួលបានការបណ្តុះបណ្តាលល្អប្រសើរស្តីពីការវាយតម្លៃប្រព័ន្ធបណ្តាញបញ្ជូនជនរងគ្រោះ និងមានទំនាក់ទំនងល្អទៅនឹងជំនាញរបស់ដៃគូផ្តល់សេវាសំខាន់ៗ។ អង្គភាពឯកទេសទាំងនេះហាក់មានសមាសធាតុនគរបាលជាស្ត្រីច្រើនជាងអង្គភាពផ្សេងទៀត ដែលសម្រាប់ជនរងគ្រោះ វាអាចជួយកសាងទំនាក់ទំនងល្អពីដំបូងជាមួយនគរបាល។

ទោះជាយ៉ាងណា ដូចការលើកឡើងក្នុងជំពូកមុនៗ មិនសុទ្ធតែមានអង្គភាពឯកទេសឬប្រសិនបើមានមានធនធានគ្រប់គ្រាន់ក្នុងការគ្រប់គ្រងករណីទាំងអស់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនោះទេ។ដូច្នេះការយល់ពីអត្ថន័យនៃការបង្កើនភាពអង់អាចដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដើម្បីចូលរួមប្រកបដោយអត្ថន័យក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងសុវត្ថិភាពនិងការការពារជនរងគ្រោះ គួរតែជាសមត្ថភាពដ៏សំខាន់មួយរបស់មន្ត្រីគ្រប់ជាន់ថ្នាក់។

> "ជនមានពិការភាពដែលមិនអាចប្រាប់ពីរឿងរ៉ាវរបស់ខ្លួនបាន ក៏អាចប្រឈមនឹងហានិភ័យខ្ពស់ផងដែរ។ នេះជាការពិតជាពិសេសសម្រាប់ជនមានពិការភាពផ្នែកបញ្ញាស្មារតី ឬចិត្តសង្គម និងជនដែលមានការលំបាកក្នុងការធ្វើទំនាក់ទំនង"។
>
> គោលការណ៍ណែនាំស្តីពីការដាក់បញ្ចូលជនមានពិការភាពក្នុងសកម្មភាពមនុស្សធម៌ (២០១៩)

ការប្រើប្រាស់គំរូវាយតម្លៃហានិភ័យ (ដូចការលើកឡើងខាងលើ) និងក្របខណ្ឌសម្រាប់មន្ត្រីនគរបាលនៅពេលកំណត់តម្រូវការសុវត្ថិភាព និងការការពាររបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី កាន់តែមានភាពទូលំទូលាយ ព្រោះជាទូទៅមន្ត្រីនគរបាលឆ្លើយតបចេះប្រើប្រាស់គំរូទាំងនេះ។

ទោះជាយ៉ាងណា ដូចការគូសបញ្ជាក់ដោយ UNPOL ក្នុងឯកសារជំនួយស្មារតីយេនឌ័ររបស់ខ្លួន (២០១៥) ឧបករណ៍ទាំងនេះមិនជំនួសឱ្យឆន្ទានុសិទ្ធិវិជ្ជាជីវៈឡើយ។ នេះជាអំណះអំណាងដ៏សំខាន់របស់ UNPOL ព្រោះវាគូសបញ្ជាក់ពីភាពចាំបាច់ដែលមន្ត្រីនគរបាលត្រូវមានសមត្ថភាពសមស្របនៅពេលវាយតម្លៃហានិភ័យនិងផ្តល់ការសង្កេតដែលមានប្រសិទ្ធភាព ដោយមិនលម្អៀង និងទាន់ពេលវេលាដល់អ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតក្នុងការបន្តផ្តល់យុត្តិធម៌។ ការពិនិត្យឡើងវិញលើឧបករណ៍ DASH ដែលលើកមកពិភាក្សាក្នុងជំពូកនេះក៏គាំទ្រដល់ការសង្កេតរបស់ UNPOL ផងដែរ។

ដូច្នេះ ថ្នាក់ដឹកនាំនគរបាល រួមទាំងអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដើរតួនាទីដ៏សំខាន់ក្នុងការធានាថាមន្ត្រីឆ្លើយតបមានសមត្ថភាពសមស្របនិងជំនាញទន់ក្នុងការវាយតម្លៃហានិភ័យប្រកបដោយប្រសិទ្ធភាព និងផ្តល់ការសង្កេតដោយមិនលម្អៀង និងទាន់ពេលវេលា។

ដើម្បីជួយធានាថា អន្តរាគមន៍ផ្អែកតាមហានិភ័យរបស់នគរបាលបន្ស៊ីគ្នានឹងការអនុវត្តល្អបំផុតដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងឆ្លើយតបនឹងយេនឌ័រ និងរួមបញ្ចូលការពិចារណាពីកត្តាប្រទាក់ក្រឡាគ្នាដូចជា ជាតិពន្ធុ អនក្ខរភាព ពិការភាព និងទំនោរផ្លូវភេទ ។ល។ ផ្នែកនេះនឹងផ្តល់កម្រងសមត្ថភាពផ្នែកឥរិយាបថដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង នៅពេលណែនាំ និងត្រួតពិនិត្យបុគ្គលិករបស់ខ្លួនដែលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាពិសេសឧប្បត្តិហេតុអំពើហិង្សាលើដៃគូស្និទ្ធស្នាល។

**ប្រអប់ ៩**

**បរិបទទី ៩**

ការបាត់បង់ទីលំនៅក្នុងស្រុកបង្កើនហានិភ័យដល់ស្ត្រីនិងក្មេងស្រីក្នុងការប្រឈមនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ មជ្ឈមណ្ឌលត្រួតពិនិត្យការបាត់បង់ទីលំនៅក្នុងស្រុក* រាយការណ៍ថា ការសិក្សាជាច្រើននៅក្នុងប្រទេស គួសបញ្ជាក់ថា អំពើហិង្សាលើដៃគូស្និទ្ធស្នាលកើនឡើងក្រោយការបាត់បង់ទីលំនៅ។ ឧ. នៅប្រទេសកូឡុំប៊ី ស្ត្រីបាត់បង់ទីលំនៅជាង ៥០% រងគ្រោះដោយទម្រង់មួយចំនួននៃអំពើហិង្សាពីដៃគូស្និទ្ធស្នាល ធៀបនឹងស្ត្រីដែលមិនបាត់បង់ទីលំនៅចំនួន ៤១%។ នៅអាហ្វហ្គានីស្ថាន ២/៣ នៃស្ត្រីដែលបាត់បង់ទីលំនៅលើកឡើងពីអំពើហិង្សាក្នុងគ្រួសារ។ ស្ត្រីជាង ១២% និយាយថា អំពើហិង្សានេះកើតឡើងញឹកញាប់ ជាងមុនពេលបាត់បង់ទីលំនៅ។

*ប្រភព ៖ ឯកសារពន្យល់ពិភាក្សា ៖ "បញ្ហាភេទ-ទស្សនៈយេនឌ័រស្តីពីការបាត់បង់ទីលំនៅក្នុងស្រុក" (មជ្ឈមណ្ឌលត្រួតពិនិត្យការបាត់បង់ទីលំនៅក្នុងស្រុក២០១៩)

ដូចជំពូកមុនៗដែរ សមត្ថភាពដែលស្នើឡើងទាំងនេះផ្អែកតាមឯកសារផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ដូចជា UNODC ផែនការគោល ៖ ផែនការអនុវត្តន៍សម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី (មានក្នុងឯកសារបោះពុម្ពផ្សាយដែលមានចំណងជើងថា ការពង្រឹងការទប់ស្កាត់បទល្មើសនិងការឆ្លើយតបរបស់វិស័យយុត្តិធម៌ព្រហ្មទណ្ឌចំពោះអំពើហិង្សាលើស្ត្រី ២០១៥) និង UNPOL ឯកសារជំនួយស្មារតីយេនឌ័រ (២០១៥)។ល។ សមត្ថភាពទាំងនេះ (មិនទាន់រៀបរាប់អស់សេចក្តី) មានគោលបំណងផ្តល់ឧទាហរណ៍សំខាន់ៗពីក្តីរំពឹងទុកពីស្តង់ដារអន្តរជាតិ[243] ក៏ដូចជាបំពេញបន្ថែម និងពង្រឹងស្ថាប័ននគរបាលជាតិរបស់អ្នកស្តីពីគុណតម្លៃ ក្រមសីលធម៌ និងសុចរិតភាពរបស់នគរបាល។ អ្នកគ្រប់គ្រងគួរធានាថា មន្ត្រីឆ្លើយតបផ្តោតអាទិភាពលើការវាយតម្លៃហានិភ័យ និងការរៀបចំផែនការសុវត្ថិភាពតាមរយៈការបង្ហាញថា ពួកគេអាចអនុវត្តចំណុចខាងក្រោម។

### ភាពអាចរកបាន ៖

- ស្វែងរក និងពង្រឹងវិធានការការពារដែលមាន ដោយមិនគិតពីសមត្ថភាព ឬឆន្ទៈចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ប្រមែប្រមូលរាល់ភស្តុតាងចាំបាច់ដើម្បីគាំទ្រដល់វិធានការការពារ ដែលចេញដោយតុលាការ ដោយមិនគិតពីការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីករណីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីប្រឆាំងនឹងជនបង្ក។
- អនុវត្តឧបករណ៍វាយតម្លៃហានិភ័យ ទៅតាមពិធីសារទន្ទឹមនឹងការទទួលបានព័ត៌មានច្រើនបំផុតពាក់ព័ន្ធនឹងស្ថានភាព និងបុគ្គលពាក់ព័ន្ធ។

### ទំនាក់ទំនងនិងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា ៖

- ផ្តល់ការពិចារណាជាក់លាក់នៅដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដើម្បីធានាសុវត្ថិភាព និងការការពារជនរងគ្រោះ។ ចំណុចនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមការពិនិត្យតាមដាននិងពង្រឹងលក្ខខណ្ឌបង់ប្រាក់នៅក្រៅឃុំ/ដោះលែង និងលក្ខខណ្ឌនៃការដោះលែងក្រោយការជំនុំជម្រះនិងការជូនដំណឹងដល់ជនរងគ្រោះមុននឹងដោះលែងជនល្មើស។

243. សូមមើល "ក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់" ដែលអនុម័តដោយសេចក្តីសម្រេចលេខ ៣៤/១៦៩ របស់មហាសន្និបាត ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩។
244. ដកស្រង់ចេញពី "ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC ២០១៤)

- កត់សម្គាល់ទិដ្ឋភាពឆ្លងដែន នៃតម្រូវការការការពារ និងក្រើនរំលឹកពីភាពចាំបាច់ក្នុងការបង្កើតយន្តការ និងដំណើរការសមស្របដើម្បីធានាការទទួលស្គាល់និងការពង្រឹងដីកាការពារ និងធានាការបន្សុីគ្នានៃការអនុវត្តរបស់នគរបាលក្នុងដែនយុត្តាធិការនានាក៏ដូចជាព្រំដែនតំបន់ ព្រំដែនជាតិ និងព្រំដែនអន្តរជាតិ។
- អនុវត្តបច្ចេកទេសស៊ើបអង្កេតដែលមិនប្រមាថស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា និងកាត់បន្ថយការឈ្លានពានក្នុងជីវិតរបស់ពួកគេទន្ទឹមនឹងការរក្សាស្តង់ដារសម្រាប់ការប្រមូលភស្តុតាងល្អបំផុត[244]។ ចំណុចនេះរួមបញ្ចូលសមត្ថភាពច្បាមយកចម្លើយពីជនរងគ្រោះដែលត្រូវបានកត់ត្រាគ្រប់ម៉ាត់និងការធ្វើទំនាក់ទំនងទៅអ្នកផ្តល់សេវាដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុអំពើហិង្សាពីមុនមក។
- បន្ទាប់មក ប្រធានត្រួតពិនិត្យរៀបចំខ្លឹមសារសង្ខេបភស្តុតាង និងបញ្ជូនសំណុំរឿងទៅអយ្យការ រួចបន្ថែមចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី និងចម្លើយរបស់ជនបង្កដែលរងការចោទប្រកាន់។

## ភាពអាចសម្របតាមបាន ៖

- កំណត់រកភាពងាយរងគ្រោះរបស់ជនរងគ្រោះនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផ្សារភ្ជាប់ភាពងាយរងគ្រោះទាំងនោះទៅនឹងហានិភ័យ និងការសម្រេចចិត្តរបស់ថ្នាក់គ្រប់គ្រង ដែលនាំទៅរកការបែងចែក និងការសម្របសម្រួលធនធានទៅតាមតម្រូវការរបស់ជនរងគ្រោះ។ ចំណុចនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមដីកាការពារចេញដោយតុលាការ ដីកាហាមឃាត់ទំនាក់ទំនង លក្ខខណ្ឌដោះលែងយ៉ាងតឹងរ៉ឹងសម្រាប់ជនល្មើសរួមទាំងបំរាមគោចរ ដីកាហាមឃាត់ទំនាក់ទំនង ការតមគ្រឿងស្រវឹង ការហាមឃាត់មិនឱ្យប្រើអាវុធការស្វែងរកនិងការចូលរួមក្នុងការពិគ្រោះយោបល់។
- មានការយល់ដឹងច្បាស់អំពីក្រុមស្ត្រីដែលអាចងាយរងគ្រោះកាន់តែខ្លាំង ឬប្រឈមនឹងហានិភ័យនៃអំពើហិង្សាក្នុងទម្រង់មួយចំនួន និងកត្តាបង្កភាពងាយរងគ្រោះដែលអាចបង្កផលប៉ះពាល់លើសុវត្ថិភាពនិងគុណភាពជីវិតរបស់ស្ត្រីទាំងនេះ។ ឧ. ពិចារណាថាតើការសម្លុតគំរាមផ្លូវភេទ និងការបៀតបៀនផ្លូវភេទ ដូចជា "ការផ្ញើរូបភាព ឬសារបង្កប់ន័យផ្លូវភេទ" ឬហានិភ័យខ្ពស់នៃការរងរបួស ឬស្លាប់ចំពោះអ្នកប្រកបរបរផ្លូវភេទ ជាបញ្ហាដែលកើតឡើងក្នុងប្រទេសរបស់អ្នក ឬទេ[245]។
- អនុវត្ត និង/ឬពង្រឹងវិធានការដែលអាចធ្វើឡើងក្នុងពេលចាំបាច់ដើម្បីធានាសុវត្ថិភាពរបស់គ្រួសារជនរងគ្រោះ និងការពារពួកគេពីការបំភិតបំភ័យ។
- អនុវត្ត និង/ឬពង្រឹងវិធានការនានាដើម្បីធានាការផ្តល់ការគាំទ្រ និងការការពារពេញលេញដល់ស្ត្រី និងក្មេងស្រីងាយរងគ្រោះបំផុតដូចជាស្ត្រីនិងក្មេងស្រីដែលមិនចេះអក្សរ មានពិការភាព ឬខ្វះខាត។ល។
- ធានាថាផែនការសុវត្ថិភាពបំពេញបន្ថែមលើដីកាតុលាការ (ដូចជា ដីកាហាមឃាត់ទំនាក់ទំនង) ក្នុងករណីព្រហ្មទណ្ឌ ឬករណីរដ្ឋប្បវេណី ដែលផ្អែកតាមបទពិសោធន៍ជនរងគ្រោះដែលគាំទ្រដោយសហគមន៍មានភាពជាក់ស្តែង និង ទូលំទូលាយ។

## ភាពសមស្រប ៖

- ឆ្លើយតបទាន់ពេលវេលាដោយមានការយកចិត្តទុកដាក់ខ្ពស់ នៅពេលមានការរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងចាត់វិធានការភ្លាមៗ ដើម្បីធានាសុវត្ថិភាព និងសុខភាពរបស់ជនរងគ្រោះ និងសមាជិកគ្រួសាររបស់គាត់ ប្រសិនបើចាំបាច់។

## ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល ៖

- សម្របសម្រួលជាមួយអ្នកផ្តល់សេវាសំខាន់ៗ លើការពិនិត្យតាមដានការប្រែប្រួលបរិយាកាសខាងក្រៅ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានលើសុវត្ថិភាពរបស់ជនរងគ្រោះដែលស្ថិតក្រោមវិធានការការពារ។
- ជំរុញការចូលរួមរបស់ក្រុមជួយជនរងគ្រោះ ឬមេធាវីរបស់ពួកគេនៅពេលបង្កើតផែនការសុវត្ថិភាព ឬធ្វើការបញ្ជូនសមស្របទៅក្រុមទាំងនេះ ដើម្បីជួយដល់ជនរងគ្រោះក្នុងការរៀបចំផែនការសុវត្ថិភាព។ចំណុចនេះគួររួមបញ្ចូលសេវាឯកទេសសម្រាប់ស្ត្រីដែលដឹកនាំដោយអ្នកមានជំនាញនិងសេវាឯកទេសក្នុងការដោះស្រាយទម្រង់ជាក់លាក់ណាមួយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលផ្តល់ជាប្រយោជន៍ដល់ក្រុមជួបការលំបាក និងស្ត្រី និងក្មេងស្រីដែលមានពិការភាព។

## ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន ៖

- កំណត់រក និងរាយការណ៍នៅពេលដែលឧបករណ៍

245. Ibid

ហានិភ័យ និងតថភាពជាក់ស្តែងនៃសេវានគរបាលជួរមុខមិនស៊ីសង្វាក់គ្នា ដើម្បីធ្វើការកែសម្រួល និង បណ្តុះបណ្តាលបុគ្គលិកបន្ថែមទៀត បង្កើនប្រសិទ្ធភាព និង ធ្វើឱ្យឧបករណ៍ទាំងនោះកាន់តែងាយស្រួលប្រើប្រាស់។

- អនុវត្តឧបករណ៍វាយតម្លៃហានិភ័យ ទៅតាមពិធីសារ ទន្ទឹមនឹងការទទួលបានព័ត៌មានច្រើនបំផុតពាក់ព័ន្ធនឹងស្ថានភាពនេះ និងបុគ្គលពាក់ព័ន្ធ។

ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ ៖

- ផ្តល់ស្មារតីម្ចាស់ការដល់ជនរងគ្រោះលើដំណើរការនេះ តាមរយៈការផ្តល់ព័ត៌មានច្រើនបំផុតដល់ពួកគេ និងអនុញ្ញាតឱ្យពួកគេគ្រប់គ្រងសកម្មភាពរបស់ខ្លួនក្នុងកិច្ចដំណើរការនីតិវិធីនេះ។
- បង្កើតផែនការសុវត្ថិភាពជាមួយជនរងគ្រោះដើម្បីកំណត់រកជម្រើស និងធនធានដែលមានសម្រាប់បំពាក់បំប៉ន និងផ្តល់លទ្ធភាពឱ្យជនរងគ្រោះការពារខ្លួន កូននិងសមាជិកគ្រួសារផ្សេងទៀត ក្នុងមជ្ឈដ្ឋាន និងកាលៈទេសៈចម្រុះ[246]។

## សូចនាករយោងសម្រាប់នគរបាលដែលផ្តល់សេវាសំខាន់ៗ ៖ សុវត្ថិភាព និងការការពារ

ដូចក្នុងករណីមានការប្រមូលទិន្នន័យទូទៅសម្រាប់ស្ថិតិបទល្មើស និងការអនុវត្តការងាររបស់នគរបាលដែរព័ត៌មានរបស់នគរបាលស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីមានប្រយោជន៍ដូចព័ត៌មានដែលបានច្បាមយកក្នុងប្រព័ន្ធនានាដោយនគរបាលឆ្លើយតប និងសេវាសំខាន់ៗផ្សេងទៀតដែរ។

នៅពេលនគរបាលឆ្លើយតបច្បាមយកព័ត៌មានបានយ៉ាងត្រឹមត្រូវ ប្រកបដោយសត្យានុម័ត និងប៉ិនប្រសប់ ព័ត៌មានទាំងនោះអាចផ្តល់មូលដ្ឋានសម្រាប់ប្រតិបត្តិការ និង យុទ្ធសាស្ត្រ ក៏ដូចជាអាចជួយលុបបំបាត់ការយល់ខុសផ្អែកតាមយេនឌ័រ ជុំវិញករណីអំពើហិង្សាលើស្ត្រី និង ក្មេងស្រីរួមទាំងការយល់ខុសដែលពាក់ព័ន្ធនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលបានលើកឡើងក្នុងជំពូកមុនៗផងដែរ។

ព័ត៌មានប្រកបដោយគុណភាពដែលនគរបាលប្រមូលបានអាចផ្តល់ចំណេះដឹងអំពីផលប៉ះពាល់វិជ្ជមានដល់ជនរងគ្រោះដែលត្រូវបានគេបង្កើនភាពអង់អាចនៅពេលទទួលបានការគាំទ្រពីមន្ត្រីឆ្លើយតប។ ឧ. ការតាមដានចំនួនទម្រង់វាយតម្លៃហានិភ័យដែលឆ្លងកាត់ការពិគ្រោះយោបល់ និងបំពេញបានល្អ និងត្រូវបាននគរបាលប្រើប្រាស់ក្នុងអន្តរាគមន៍អំពើហិង្សាលើដៃគូស្និទ្ធស្នាល អាចឆ្លុះបញ្ចាំងពីទំនាក់ទំនងដែលមានប្រសិទ្ធភាពរវាងមន្ត្រីឆ្លើយតប និងជនរងគ្រោះ។
ព័ត៌មានទាំងនេះដែលត្រូវបានពិនិត្យធៀបនឹងការអង្កេតលើការផ្តល់សេវារបស់នគរបាល ក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល(នៅពេលមានការយល់ឃើញជាវិជ្ជមានកាន់តែច្រើន)អាចគូសបញ្ជាក់ពីអត្រាកាន់តែខ្ពស់នៃការរាយការណ៍ករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាលដោយសារតែស្ត្រីនិងក្មេងស្រីមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការទាក់ទងជាមួយនគរបាល ជាជាងការកើនឡើងនៃប្រេវ៉ាឡង់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

តាមទ្រឹស្តី ទម្រង់វាយតម្លៃហានិភ័យដែលបំពេញបានត្រឹមត្រូវ នឹងជួយកាត់បន្ថយចំនួនដងដែលជនរងគ្រោះត្រូវប្រាប់រឿងរ៉ាវរបស់ខ្លួន ក៏ដូចជាចំនួន ឬមនុស្សដែលគាត់ត្រូវប្រឈមជាមួយ និងធានាថា គាត់ទទួលបានការគាំទ្រពីអ្នកជំនាញសមស្រប។ ក្រៅពីនេះ វិធានការនេះអាចផ្តល់ការយល់ដឹងអំពីសកម្មភាពរបស់នគរបាលក្នុងការបញ្ជូនជនរងគ្រោះទៅរកការផ្សះផ្សារ ដែលផ្ទុយពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផ្លូវការ ដោយយកត់សម្គាល់ថាមន្ត្រីនគរបាលមិនគួរដើរតួនាទីជាអ្នកផ្សះផ្សារឡើយ។

វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ (EIGE) ផ្តល់អនុសាសន៍ល្អៗសម្រាប់ការកែលម្អអភិក្រមផ្អែកតាមភស្តុតាងក្នុងការគ្រប់គ្រងហានិភ័យ (សូមមើលប្រអប់ ១៤ ខាងក្រោម)។
នៅពេលមានការវាយតម្លៃកាន់តែខ្ពស់លើហានិភ័យរបស់ជនរងគ្រោះ មន្ត្រីឆ្លើយតប ងាយនឹងប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ផ្លូវការ ដើម្បីសម្រាលគ្រោះថ្នាក់ និងស្វែងរកទណ្ឌកម្មដែលសមាមាត្រទៅនឹងអំពើហិង្សានោះ។

246. Ibid

**ប្រអប់ ៩**

**អនុសាសន៍សម្រាប់ការកែលម្អអភិក្រមផ្អែកតាមភស្តុតាងក្នុងការគ្រប់គ្រងហានិភ័យ**



ក្នុងមគ្គុទេសក៍សម្រាប់នគរបាលស្តីពីការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលប្រឆាំងនឹងស្ត្រី (២០១៩) វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រស្នើឱ្យការពិនិត្យការគ្រប់គ្រងហានិភ័យរួមបញ្ចូលនូវទិន្នន័យពីប្រភពរដ្ឋបាល និងបែងចែកទិន្នន័យជាប្រភេទ អនុលោមទៅតាមក្របខណ្ឌច្បាប់អឺរ៉ុប ដូចខាងក្រោម ៖

- ចំនួន និងប្រភេទបទល្មើសដែលបានរាយការណ៍
- ចំនួន អាយុ និងយេនឌ័ររបស់ជនរងគ្រោះ
- ចំនួនករណីដែលបានស៊ើបអង្កេត
- ចំនួនជនដែលត្រូវបានកាត់ទោស
- ចំនួនជនដែលត្រូវបានផ្តន្ទាទោស។

ក្រៅពីនេះ ការត្រួតពិនិត្យការគ្រប់គ្រងហានិភ័យគួរ រួមបញ្ចូលយ៉ាងហោចណាស់ ការបែងចែកទិន្នន័យជាប្រភេទដូចខាងក្រោម ៖

- ភេទរបស់ជនរងគ្រោះ និងជនបង្ក
- អាយុរបស់ជនរងគ្រោះ និងជនបង្ក
- ប្រភេទនៃអំពើហិង្សា
- ទំនាក់ទំនងរវាងជនបង្ក និងជនរងគ្រោះ
- ទីតាំងភូមិសាស្ត្រ
- កត្តាពាក់ព័ន្ធផ្សេងទៀត ដូចជា ជាតិសាសន៍ ពិការភាព និងបុគ្គលិកលក្ខណៈផ្សេងទៀត។

Rollings and Taylor (2008) បានផ្តល់ឧទាហរណ៍មួយផ្សេងទៀតនៃព័ត៌មានយោងល្អៗ ដោយលើកឡើងថា ការថយចុះចំនួនជនល្មើសដែលបន្តប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារឬអំពើហិង្សាលើដៃគូស្និទ្ធស្នាលបន្ទាប់ពីនគរបាលត្រូវបានទទួលស្គាល់ឱ្យធ្វើអន្តរាគមន៍ជាសូចនាការបង្ហាញថា អន្តរាគមន៍នគរបាលកន្លងមក មានផលប៉ះពាល់លើឥរិយាបថប្រព្រឹត្តល្មើសបន្ថែមទៀត[248]។

ដូចការពិភាក្សាក្នុងជំពូកមុនៗកញ្ចប់សេវាសំខាន់ៗស្នើឱ្យសេវាយុត្តិធម៌ និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះត្រូវមានលក្ខណៈទូទៅរួមទាំងសកម្មភាពរួមនានា ដើម្បីធានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈទូទៅ និងសកម្មភាពរួមទាំងនេះអាចអនុវត្តបានដោយមិនគិតពី "វិស័យ" ជាក់លាក់ដែលអាចឆ្លើយតបទៅនឹងស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា។ ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅនិងសកម្មភាពរួមក្នុងកញ្ចប់សេវាសំខាន់ៗ ដោយផ្តល់ឧទាហរណ៍មួយចំនួនពីសូចនាករយោងសម្រាប់វិធានការការពារ និងវិធានការសុវត្ថិភាពដែលមានប្រសិទ្ធភាពរបស់នគរបាលដែលពួកគាត់បានបង្កើននូវភាពអង់អាចដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងការទទួលបានយុត្តិធម៌ និងអាចឱ្យពួកគេបន្តចូលរួមដោយសុវត្ថិភាពក្នុងដំណើរការយុត្តិធម៌។

ទាំងនេះជាសូចនាករដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាងប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មាន ថ្នាក់លើគួរបញ្ចូលសូចនាករទាំងនេះ។

247. សូមមើល "ការវាយតម្លៃហានិភ័យនិងការគ្រប់គ្រងហានិភ័យដោយនគរបាល" (វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ) ៖ https://eige.europa.eu/gender-based-vilence/risk-assessment-risk-management/principle-3-establishing-evidence-based-approach។

248. Kiah Rollings and Natalie Taylor, 'Measuring police performance in domestic and family violence" for Trends & issues in Crime and Criminal Justice No. 367 December 2008 (Australian Government/Australian Institute of Criminology, 2008)

“ផ្អែកតាមការសង្កេតរបស់យើង ការបណ្តុះបណ្តាលស្តីពីការកសាងការយល់ដឹងនឹងកាន់តែមានប្រសិទ្ធភាពថែមទៀត ប្រសិនបើវាត្រូវបានរៀបចំឡើងដោយបុគ្គលមកពីក្រុមដែលមានតំណាងតិចតួច ដែលនិយាយពីបទពិសោធន៍ជីវិតផ្ទាល់ខ្លួនរបស់ពួកគេ”។



Elena Ratoi ប្រធានកម្មវិធី (UN Women, Moldova)

១. **ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន** ៖ ចំនួនវគ្គបណ្តុះបណ្តាលឬការពិគ្រោះយោបល់ផ្លូវការជាមួយសហគមន៍ចម្រុះក្នុងមូលដ្ឋាន។ ចំណុចនេះ គួររួមបញ្ចូលក្រុមដែលតំណាងឱ្យជនមានពិការភាព ជនបាត់បង់ទីលំនៅក្នុងប្រទេស និងសហគមន៍ជនជាតិភាគតិច ដើម្បីទទួលបានធាតុចូលស្តីពីកត្តាបរិបទ និងកត្តាវប្បធម៌ដែលនគរបាលគួរពិចារណាក្នុងការវាយតម្លៃហានិភ័យ។ គួរខិតខំធានាថា ការបណ្តុះបណ្តាលសម្រាប់សមាជិកក្រុមឆ្លុះបញ្ចាំងពីភាពខុសគ្នាផ្នែកវប្បធម៌ក្នុងតំបន់ និងតម្រូវការសន្តិសុខរបស់ពួកគេ។

២. **ភាពសមស្រប និងភាពអាចទទួលបាន** ៖ ផលធៀបនៃទម្រង់វាយតម្លៃហានិភ័យដែលត្រូវបានបំពេញបានត្រឹមត្រូវដោយមន្ត្រីធៀបនឹងចំនួនអន្តរាគមន៍អំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលធ្វើឡើងដោយសមាជិកក្រុម (ជាពិសេសក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល)។ សូចនាករនេះ គួរផ្តល់ការយល់ដឹងអំពីកម្រិតដែលនគរបាលធ្វើទំនាក់ទំនងជាភាសាដែលជនរងគ្រោះអាចយល់បាន។ ការបែងចែកចំនួនទម្រង់វាយតម្លៃហានិភ័យទៅតាមភេទរបស់មន្ត្រីឆ្លើយតបឋានន្តរសក្តិ និងអង្គភាព នឹងផ្តល់ព័ត៌មានស្តីពីអថេរផ្សេងទៀតដែលជះឥទ្ធិពលលើគុណភាពនៃទំនាក់ទំនងរវាងនគរបាល និងជនរងគ្រោះ។

៣. **សុវត្ថិភាពជាចម្បង** ៖ ផលធៀបនៃវិធានការការពារ និងផែនការសុវត្ថិភាពដែលត្រូវបានអនុវត្ត និងពង្រឹងរហូតដល់ការបញ្ចប់ករណី ទៅតាមការស្នើឡើងដោយអ្នកផ្តល់សេវាសំខាន់ៗ (សង្គម សុខភាព និងយុត្តិធម៌) និងក្រោមការពិគ្រោះជាមួយជនរងគ្រោះ ធៀបនឹងវិធានការការពារដែលលើកឡើងនិង/ឬស្នើឱ្យអនុវត្ត។ សូចនាករនេះនឹងផ្តល់ការយល់ដឹងអំពីសកម្មភាពរបស់នគរបាលក្នុងការវាយតម្លៃជាប្រចាំ និងជាបន្តបន្ទាប់លើសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រី។

៤. **ការផ្តល់ការយល់ព្រមត្រឹមត្រូវ ការរក្សាការសម្ងាត់ និងភាពអាចទទួលបាន** ៖ ភាគរយនៃវិធានការការពារ និងផែនការសុវត្ថិភាពដែលអនុវត្តដោយមន្ត្រី ធៀបនឹងចំនួនករណីនៃការប្រព្រឹត្តខុសជាថ្មី/ការប្រព្រឹត្តល្មើសដដែលៗ ឬការរំលោភវិធានការទាំងនេះដោយជនប្រព្រឹត្ត[249] ។ ឬអាចជាផលធៀបនៃវិធានការការពារដែលត្រូវបានពង្រឹងរហូតដល់ការសម្រេចបញ្ចប់ករណីជាមួយជនរងគ្រោះ ធៀបនឹងចំនួនករណីនៃការប្រព្រឹត្តខុសជាថ្មី/ការប្រព្រឹត្តល្មើសដដែលៗដោយជនប្រព្រឹត្ត និង/ឬការចាប់ខ្លួន។ សូចនាករនេះនឹងផ្តល់ការយល់ដឹងអំពីផលប៉ះពាល់នៃវិធានការការពារនៅពេលត្រូវបានអនុវត្តទាំងស្រុង ដោយផ្នែកឬមិនត្រូវបានអនុវត្ត។ សូចនាករនេះសន្មតថាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការរៀបចំផែនការសុវត្ថិភាព និងការការពាររបស់ពួកគេនឹងបង្កើន លទ្ធភាពនគរបាលក្នុងការពង្រឹងវិធានការការពាររហូតដល់ បញ្ចប់ករណី។

៥. **ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា** ៖ ការអង្កេតលើការផ្តល់សេវាដោយនគរបាលនៅមូលដ្ឋានជាមួយមន្ត្រី និងអ្នករស់នៅក្នុងជម្រកសុវត្ថិភាព ពាក់ព័ន្ធនឹងការពេញចិត្តរបស់ជនរងគ្រោះចំពោះការឆ្លើយតបរបស់នគរបាល។ ការអង្កេតទាំងនេះអាចត្រូវបានផ្តួចផ្តើមនៅកម្រិតប៉ុស្តិ៍នគរបាល និងគួរខិតខំធ្វើយ៉ាងណាឱ្យមធ្យោបាយសហការបន្ស៊ីគ្នាដើម្បីឱ្យមធ្យោបាយទាំងនោះឆ្លុះបញ្ចាំងពីគោលដៅទប់ស្កាត់អំពើហិង្សា

249. Rollings and Taylor (2008) ស្នើឡើងថា នគរបាលគួរប្រើសូចនាករមួយស្តីពីការថយចុះចំនួនដងនៃការចុះទៅអាស័យដ្ឋាន ដដែលៗ សម្រាប់ជាជម្រើសមួយ ព្រោះអន្តរាគមន៍នគរបាលកន្លងមកបានបង្កផលប៉ះពាល់វិជ្ជមាននៅទីនោះ។ អ្នកនិពន្ធបន្ថែមទៀតថា រង្វាស់ការអនុវត្តការងារនេះត្រូវមានការពិនិត្យតាមដាន ដើម្បីឱ្យដឹងថាតើភាគរយគ្រួសារដែលមានការចុះជួបជាច្រើនលើកច្រើនសា មានការថយចុះ និងអាចវាស់វែងដោយប្រើទិន្នន័យស្ថិតិមានស្រាប់របស់នគរបាលបានដែរ ឬទេ។ សូមមើល “ការវាស់វែងការអនុវត្តការងាររបស់នគរបាលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ” (២០០៨)។

លើស្ត្រី និងក្មេងស្រីនៅថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន។ សូចនាករនេះនឹងផ្ដល់ការយល់ដឹងអំពីឥរិយាបថ និងអាកប្បកិរិយារបស់នគរបាល ព្រោះវាផ្តល់មូលដ្ឋានព័ត៌មានដល់ជនរងគ្រោះស្តីពីជម្រើសការពារនិងជំរុញការចូលរួមរបស់ដៃគូក្នុងការផ្តល់ជម្រកសុវត្ថិភាព។ការអង្កេតទាំងនេះគួរស្វែងរកព័ត៌មានស្តីពីកម្រិតដែលនគរបាលបង្ហាញការយកចិត្តទុកដាក់ ដើម្បីអាចផ្តល់ព័ត៌មានសុក្រឹតស្តីពីអ្វីដែលកើតឡើងចំពោះកុមារ នៅពេលម្តាយរស់នៅក្នុងជម្រកសុវត្ថិភាពក៏ដូចជាអ្វីដែលជាផលនៃវិធានការការពារប្រចាំថ្ងៃសម្រាប់កុមារដែលត្រូវស្នាក់នៅជាមួយសាច់ញាតិនិងត្រូវទៅរៀនជាប្រចាំ។

៦. **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន** ៖ ចំនួននៃការចាប់ខ្លួនពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីធៀបនឹងចំនួនជនរងគ្រោះដែលបានពិគ្រោះយោបល់លើការយល់ឃើញចំពោះហានិភ័យផ្ទាល់ខ្លួន និងការបញ្ជូនទៅស្ថាប័ន ខាងក្រៅដើម្បីទទួលបានវិធានការការពារ។ យ៉ាងហោចណាស់គួរពិចារណាពីព័ត៌មានទាំងនេះធៀបនឹងការប្រមូលទិន្នន័យ និងគួរធ្វើឡើងនៅកម្រិតប៉ុស្តិ៍នគរបាលដើម្បីដាក់បញ្ចូលក្នុងប្រព័ន្ធប្រមូលទិន្នន័យថ្នាក់ជាតិ។

៧. **ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល** ៖ កំណើនប្រចាំឆ្នាំនៃការយល់ឃើញបែបវិជ្ជមាន ចំពោះការអនុវត្តវិធានការការពារដោយនគរបាល ផ្អែកតាមការអង្កេតជាមួយអ្នកផ្តល់សេវាសំខាន់ៗនៅមូលដ្ឋាន ឬដៃគូផ្សេងទៀត។ សូចនាករនេះនឹងផ្តល់ការយល់ដឹងពីប្រភពខាងក្រៅពាក់ព័ន្ធនឹងសមត្ថភាពរបស់នគរបាលក្នុងការគោរពនិងអនុលោមតាមពិធីសារស្តីពីការសម្របសម្រួលការបញ្ជូន និងការអនុវត្តល្អបំផុត។ Dowling et al. (2018) លើកឡើងថា ជាទូទៅ ការពេញចិត្តរបស់ជនរងគ្រោះចំពោះការវាយតម្លៃហានិភ័យមិនសូវទទួលបានចំណាប់អារម្មណ៍ឡើយ។ ទោះជាយ៉ាងណា មានការសិក្សាតិចតួចដែលគូសបញ្ជាក់ថា ជនរងគ្រោះហាក់មិនសូវយល់ពីឧបករណ៍វាយតម្លៃហានិភ័យទាំងនេះ ដែលពួកគេយល់ថាសំបូរដោយសំណួរមិនពាក់ព័ន្ធហើយនគរបាលចោទសួរពួកគេតាមរបៀបដែលមិនផ្តល់ចំណាប់អារម្មណ៍ និងច្រំដែល ជាពិសេសនៅពេលពួកគេទាក់ទងទៅនគរបាលញឹកញាប់[250] ។ Dowling et al. លើកឡើងទៀតថាការដែលជនរងគ្រោះ មិនយល់ពីឧបករណ៍ទាំងនេះអាចបណ្តាលមកពីកង្វះការយល់ដឹងអំពីសារៈសំខាន់នៃឧបករណ៍ទាំងនោះ ក្នុងការធានាសុវត្ថិភាពរបស់ពួកគេ។ ដូច្នេះ នគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត ត្រូវធានាថាជនរងគ្រោះយល់ និងគាំទ្រដំណើរការនេះ[251] ។

250. Dowling, C., Morgan, A., Boyd, C., Voce, I., 'Policing Domestic Violence: A Review of the Evidence', Australian Institute of Criminology, Research Report 13 (2018).
251. Ibid

## ករណីសិក្សា
## ការពិនិត្យឡើងវិញលើឧបករណ៍វាយតម្លៃហានិភ័យ DASH របស់ចក្រភពអង់គ្លេស



ជាញឹកញាប់ កងកម្លាំងនគរបាលមានការលំបាកក្នុងការធានាថា មន្ត្រីគ្រប់រូបដែលឆ្លើយតបទៅនឹងបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានសមត្ថភាពសមស្របក្នុងការវាយតម្លៃ ហានិភ័យដែលបន្សុីគ្នានឹងស្តង់ដារ និងពិធីសារ ដើម្បីធានាការប្រើប្រាស់ឧបករណ៍ដល់សក្តានុពល ដូចជា B-SAFER និង DASH ។

តាមពិតការពិនិត្យឡើងវិញលើគំរូDASH (២០១៦)[252] ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយនគរបាលនៅចក្រភពអង់គ្លេស រកឃើញបញ្ហាប្រឈមជាច្រើនរបស់នគរបាលឆ្លើយតបជួរមុខក្នុងពេលធ្វើអន្តរាគមន៍លើឧប្បត្តិហេតុអំពើហិង្សាលើដៃគូស្និទ្ធស្នាល នៅពេលព្យាយាមអនុវត្តគំរូនេះ។ បញ្ហាប្រឈមរួមមានដូចខាងក្រោម[253]៖

- ទោះបីជាមានការគាំទ្រយ៉ាងទូលំទូលាយលើការវាយតម្លៃហានិភ័យពីសំណាក់នគរបាល និងដៃគូក្តី ក៏ឧបករណ៍ហានិភ័យ DASH មិនត្រូវបានអនុវត្តស៊ីសង្វាក់គ្នានៅជួរមុខដែរ។
- ពេលខ្លះមន្ត្រីប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនដាក់ទម្រង់។ សំណួរមួយចំនួនត្រូវបានកែប្រែ ឬលុបចោលហើយជួនកាលព័ត៌មានត្រូវបានកត់ត្រាមិនពេញលេញ ឬមិនស៊ីសង្វាក់គ្នា។
- មិនចាំបាច់ស្នើសុំរាល់ព័ត៌មានដែលមានក្នុងឧបករណ៍ DASH ដែលមាន ២៧ ចំណុចនៅពេលឆ្លើយតបដំបូងឡើយ។ ក្នុងទម្រង់បច្ចុប្បន្ន DASH មិនត្រូវបានប្រើប្រាស់ពេញលេញក្នុងការអនុវត្តឡើយ និងផ្តល់ទិន្នន័យមិនស៊ីសង្វាក់គ្នាដល់អ្នកវាយតម្លៃហានិភ័យបន្ទាប់បន្សំ។
- មន្ត្រីនគរបាល និងបុគ្គលិក ហាក់ផ្តោតអាទិភាពលើបទល្មើសព្រហ្មទណ្ឌ និងជាពិសេសអំពើហិង្សាផ្លូវកាយ និងរបួសដែលបណ្តាលមកពីឧប្បត្តិហេតុនេះ ទាំងនៅដំណាក់កាលដំបូង និងដំណាក់កាលបន្ទាប់បន្សំនៃការវាយតម្លៃហានិភ័យ។

ផ្អែកលើការអង្កេតទាំងនេះការពិនិត្យឡើងវិញបានផ្តល់ភាពពាក់ព័ន្ធមួយចំនួនសម្រាប់ការធ្វើបច្ចុប្បន្នភាព DASH នាពេលអនាគតដែលអាចអនុវត្តចំពោះគំរូវាយតម្លៃហានិភ័យ និងក្របខណ្ឌភាគច្រើន។ ខាងក្រោមនេះជាអនុសាសន៍សម្រាប់ការវាយតម្លៃហានិភ័យក្នុងសេវានគរបាលជាពិសេសភាពពាក់ព័ន្ធសម្រាប់ការប្រើប្រាស់ DASH នាពេលអនាគត ដែលដកស្រង់ចេញពីការពិនិត្យឡើងវិញលើ DASH[254] ៖

- អភិក្រមផ្អែកតាមភស្តុតាងក្នុងសេវានគរបាលដែលផ្អែកតាមហានិភ័យ ពិតជាចាំបាច់ណាស់ ៖ ត្រូវគាំទ្រដោយការបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងការវាយតម្លៃ ការកំណត់រក និងការគ្រប់គ្រងហានិភ័យ។ កងកម្លាំងនគរបាលគួរព្យាយាមកាត់បន្ថយការរៀនសូត្រក្រៅផ្លូវការក្នុងពេលបម្រើការ ដែលហាក់ធ្វើឡើងដោយគ្មានការបណ្តុះបណ្តាល។ ចាំបាច់ត្រូវមានការត្រួតពិនិត្យនិងការផ្តល់យោបល់ត្រឡប់ដែលអាចពង្រឹងការរៀនសូត្របន្ថែមទៀត។
- ចាំបាច់ត្រូវដាក់បញ្ចូលការយល់ដឹងពីការត្រួតត្រាដោយបង្ខំក្នុងអភិក្រមផ្អែកតាមហានិភ័យ៖មន្ត្រីឆ្លើយតបដែលពាក់ព័ន្ធនឹងឧប្បត្តិហេតុ ត្រូវកត់សម្គាល់ទិដ្ឋភាពនៃការរំលោភបំពានក្នុងគ្រួសារឱ្យបានច្បាស់។ ទោះបីជាការស្រាវជ្រាវគូសបញ្ជាក់ថា ការត្រួតត្រាដោយបង្ខំជាកត្តាហានិភ័យដ៏សំខាន់មួយសម្រាប់អំពើមនុស្សឃាតក្នុងគ្រួសារក្តី ក៏ជាញឹកញាប់ នគរបាលមិនបានកត់សម្គាល់ពេញលេញនូវសារៈសំខាន់នៃការត្រួតត្រាដោយបង្ខំនៅពេលវាយតម្លៃហានិភ័យឡើយ។

252. ការរំលោភបំពានក្នុងគ្រួសារ ការឈ្លបចាប់ និង អំពើហិង្សាផ្អែកលើកិត្តិយស (DASH ២០០៩) គំរូនៃការកំណត់រកការវាយតម្លៃនិងការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តក្នុងសេវានគរបាលទាំងអស់នៅចក្រភពអង់គ្លេសចាប់ពីខែ មីនា ឆ្នាំ ២០០៩ និងត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សា ACPO ដែលបច្ចុប្បន្នហៅថា ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (NPCC)។ សូមមើល គំរូ ហានិភ័យ https://www.dashriskchecklist.co.uk/។

253. សេវានគរបាលផ្អែកតាមហានិភ័យសម្រាប់ការរំលោភបំពានក្នុងគ្រួសារនិងគំរូហានិភ័យ DASH។ Amanda L. Robinson, Andy Myhill, Julia Wire, Jo Roberts and Nick Tilley for the College of Policing (2016) https://pdf4pro.com/amp/view/risk-led-policing-of-domestic-abuse-and-the-dash-risk-model-480cf9.html

254. Ibid

- ឧបករណ៍ហានិភ័យដែលត្រូវបានកែសម្រួលសម្រាប់មន្ត្រីជួរមុខគួរផ្តោតសំខាន់លើគំរូនៃឥរិយាបថរំលោភបំពាន ៖ ឧបករណ៍ដែលកាន់តែផ្តោតលើមន្ត្រីជួរមុខអាចធ្វើឱ្យមន្ត្រីបង្វែរផ្នត់គំនិតដែលផ្តោតលើឧប្បត្តិហេតុឆ្ពោះទៅរកគំរូនៃឥរិយាបថរំលោភបំពាន រួមទាំងការត្រួតត្រាដោយបង្ខំ។
- ការវាយតម្លៃហានិភ័យ/តម្រូវការកាន់តែល្អិតល្អន់ គួរធ្វើឡើងដោយអ្នកដែលមានការបណ្តុះបណ្តាលជាមួយអ្នកមានឯកទេស ៖ ចាំបាច់ត្រូវមានអ្នកឯកទេសអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីកំណត់កត្តាមានហានិភ័យខ្ពស់ (ដូចជា ការបំបែកចេញពីជនបង្ក) ក្នុងបរិបទដែលជនបង្កមានឥរិយាបថត្រួតត្រាខ្លាំង។ គួរមានអ្នកឯកទេសទាំងនេះសម្រាប់ធ្វើការវាយតម្លៃហានិភ័យ/តម្រូវការកាន់តែល្អិតល្អន់ ដើម្បីអាចកំណត់សកម្មភាពតាមដានបន្តក្នុងករណីដែលមានការរំលោភបំពានជាបន្តបន្ទាប់។ តួនាទី និងរចនាសម្ព័ន្ធរបស់នគរបាលត្រូវគាំទ្រទាន់ពេលវេលា និងរឹងមាំដល់ការពិនិត្យឡើងវិញលើការវាយតម្លៃហានិភ័យដំបូង និងការបញ្ជូនទាន់ពេលវេលាទៅរកសេវាគាំទ្រឯកទេស។

ស្រដៀងគ្នានឹងការលើកឡើងរបស់ UNPOL ស្តីពីសារៈសំខាន់នៃធនធានុសិទ្ធិវិជ្ជាជីវៈក្នុងការវាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាល DASH ពិនិត្យឡើងវិញលើអនុសាសន៍ដែលពង្រឹងសារៈសំខាន់របស់មន្ត្រីនគរបាលដែលមានសមត្ថភាពចាំបាច់សម្រាប់ការវាយតម្លៃហានិភ័យក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ក៏ដូចជាស្នើឱ្យមានការបណ្តុះបណ្តាល និងការពិនិត្យតាមដានគ្រប់គ្រាន់ដើម្បីកុំឱ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងដែលជះផលមិនល្អលើសុវត្ថិភាពរបស់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ។

ក្រៅពីនេះ ការបណ្តុះបណ្តាល និងការពិនិត្យតាមដានគួរគ្របដណ្តប់លើការប្រើប្រាស់ និងការសាយភាយកាំភ្លើង (ទាំងខុសច្បាប់ និងស្របច្បាប់) ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ខណៈដែលអាចមិនសូវមានការប្រើប្រាស់អាវុធធុនស្រាល និងធុនតូចខុសគោលការណ៍នៅចក្រភពអង់គ្លេស ក្នុងបណ្តាប្រទេសជាច្រើន និងតំបន់ផ្សេងទៀត ជនល្មើសប្រើប្រាស់កាំភ្លើងយ៉ាងគឃ្លើនដើម្បីបង្ហាញអំណាច និងការត្រួតត្រាលើជនរងគ្រោះហើយចំណុចនេះទាមទារការឆ្លើយតបជាក់លាក់ពីស្ថាប័ន។



ការយល់ដឹងកាន់តែច្រើនផ្អែកតាមបរិបទស្តីពីទំនាក់ទំនងរវាងអាវុធធុនស្រាល និងអាវុធធុនតូច គួរតែជាផ្នែកមួយនៃការយល់ដឹងផ្អែកតាមព័ត៌មានត្រឹមត្រូវក្នុងស្ថាប័ននគរបាល អំពីឫសគល់នៃអំពើហិង្សា និងផលវិបាកនៃអំពើហិង្សានិងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ វត្តមានកាំភ្លើងក្នុងបរិបទអំពើហិង្សាលើដៃគូស្និទ្ធស្នាលនឹងបង្កើនហានិភ័យនៃការសម្លាប់ជនរងគ្រោះ។

ក្នុងន័យនេះ មជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ និងបូព៌ា (SEESAC) បានផ្តល់ការណែនាំថ្នាក់តំបន់ក្នុងឯកសារបោះពុម្ពផ្សាយរបស់ខ្លួនស្តីពីការប្រើប្រាស់កាំភ្លើងខុសគោលការណ៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារនៅអឺរ៉ុបអាគ្នេយ៍៖ ព័ត៌មានពិតរហ័ស (២០១៩) ដែលគាំទ្រដោយសហភាពអឺរ៉ុបតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុប (CFSP) លេខ ២០១៦/២៣៥៦ ដើម្បីគាំទ្រដល់សកម្មភាពដកហូត និងគ្រប់គ្រងអាវុធរបស់ SEESAC នៅអឺរ៉ុបភាគអាគ្នេយ៍[255]។

255. ការប្រើប្រាស់កាំភ្លើងខុសគោលការណ៍ក្នុងអំពើហិង្សាក្នុងគ្រួសារនៅអឺរ៉ុបភាគអាគ្នេយ៍៖ ព័ត៌មានពិតរហ័ស (២០១៩) មជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ និងបូព៌ា (SEESAC)។ សូមមើល https://www.seesac.org/f/docs/News-SALW/Misuse-of-firearms-in-SEE_ENG_WEB_FINAL.pdf។

## ឧបសម្ព័ន្ធ ១

**UNODC (២០១៩) ស្តង់ដារនៃការវាយតម្លៃហានិភ័យ និងគ្រោះថ្នាក់ ការវាយតម្លៃហានិភ័យនៃការបាត់បង់ជីវិត និងហានិភ័យនៃការប្រព្រឹត្តអំពើហិង្សាជាច្រើនលើកច្រើនសា**[256]

| | |
|---|---|
| ការរងគ្រោះពីមុនមក | • ប្រភេទ ភាពធ្ងន់ធ្ងរ និងភាពញឹកញាប់នៃការប្រទូស្តរាយ<br>• កាលបរិច្ឆេទនៃការប្រទូស្តរាយដែលទើបនឹងកើតឡើង<br>• របួសធ្ងន់ធ្ងរក្នុងការប្រទូស្តរាយពីមុន<br>• ប្រវត្តិ និងធម្មជាតិនៃអំពើហិង្សាកន្លងមកចំពោះជនរងគ្រោះនេះ<br>• តើមានគំរូនៃការបំភិតបំភ័យ ការបង្ខិតបង្ខំ និងអំពើហិង្សាជាបន្តបន្ទាប់ ឬទេ?<br>• តើនរណាជាអ្នកបង្កឱ្យមានគំរូមួយ និងលើនរណា?<br>• តើអំពើហិង្សានោះមានភាពធ្ងន់ធ្ងរកម្រិតណា?<br>• តើនរណារងរបួស និងដោយរបៀបណា?<br>• តើនរណាភ័យខ្លាច និងដោយរបៀបណា?<br>• តើជនរងគ្រោះត្រូវបានប្រទូស្តរាយក្នុងពេលមានផ្ទៃពោះឬភ្លាមៗក្រោយការសម្រាលកូន ឬទេ?<br>• ដីកាការពារបច្ចុប្បន្ន ឬពីមុនមក<br>• ប្រវត្តិប្រានចោលបទចោទអំពើហិង្សាក្នុងគ្រួសារ ប្រវត្តិទាក់ទងទៅនគរបាល ឬការិយាល័យអយ្យការលើករណីអំពើហិង្សាក្នុងគ្រួសារ។ |
| ជនបង្កមានបញ្ហាគ្រឿងស្រវឹង និងគ្រឿងញៀន | • ការបំពានគ្រឿងស្រវឹង ឬគ្រឿងញៀន |
| ឥរិយាបថគិតមមៃ/ត្រួតត្រា និងការប្រចណ្ឌហួសហេតុ | • ឥរិយាបថប្រចណ្ឌ ឬត្រួតត្រារបស់ជនបង្ក<br>• ការបំភិតបំភ័យជនរងគ្រោះ ប្រសិនបើនាងស្វែងរកជំនួយ<br>• ធម្មជាតិនៃឥរិយាបថត្រួតត្រា៖ ការគំរាមបង្ករបួស ឬសម្លាប់ (បើការគំរាមកាន់តែជាក់លាក់ ហានិភ័យគឺកាន់តែធំ) ការគំរាមប្រើប្រាស់អាវុធ ការគំរាមចាប់ពង្រត់កូន ឬការបដិសេធសិទ្ធិទៅលេង ការគំរាមដោយចំហ និងនៅចំពោះមុខគេឯង។<br>• តើមានការគំរាមកំហែង ឬការបង្ខិតបង្ខំអ្វីខ្លះដែលបង្អាក់មិនឱ្យជនរងគ្រោះចូលរួមក្នុងការកាត់ទោស?<br>• តើនរណាដែលងាយរងគ្រោះបំផុតទៅនឹងការគំរាមកំហែង និងការបង្ខិតបង្ខំជាបន្តបន្ទាប់? |
| ប្រវត្តិសុខភាពផ្លូវចិត្តរបស់ជនបង្ក (ឧ. គំនិត ផែនការ ការគំរាម និងធ្លាប់ប៉ុនប៉ងធ្វើអត្តឃាត) | • ជនបង្កគំរាមធ្វើមនុស្សឃាត ឬសម្លាប់ខ្លួន<br>• ភស្តុតាងបង្ហាញថា ជនបង្កធ្លាក់ទឹកចិត្ត<br>• ភស្តុតាងបង្ហាញថា ជនបង្កមានគំនិតឆ្កួតលីលា<br>• ជនបង្កមានប្រវត្តិសុខភាពផ្លូវចិត្ត ឬបញ្ហាខួរក្បាល។ |
| ជនបង្កគំរាមសម្លាប់ជនរងគ្រោះ ឬកូនៗរបស់នាង | • ការគំរាមបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬកូនៗរបស់នាង<br>• តើជនបង្កបានបង្កគ្រោះថ្នាក់លើកូនៗរបស់នាង ឬទេ? ប្រសិនបើមែន ដោយរបៀបណា? |

| | |
|---|---|
| | • តើជនបង្កបានគំរាមបង្គ្រោះថ្នាក់លើកូនៗរបស់នាងឬទេ? ដោយរបៀបណា?<br>• តើជនរងគ្រោះភ័យខ្លាចថាជនប្រព្រឹត្តបំពាននឹងចាប់ពង្រត់កូនៗរបស់នាងដើម្បីជាការសងសឹក ដែលនាងសហការជាមួយអយ្យការ ឬទេ?<br>• តើកូនៗរបស់នាងមើលឃើញបទល្មើសឬអំពើហិង្សាឬការគំរាមកំហែងផ្សេងទៀតឬទេ? |
| ជនបង្កប្រព្រឹត្តអំពើហិង្សានៅក្រៅផ្ទះ | • ប្រវត្តិប្រព្រឹត្តទោសព្រហ្មទណ្ឌពីមុនរបស់ជនបង្កនិងថាតើបច្ចុប្បន្នមានបទចោទផ្សេងទៀតលើជនបង្ក ឬទេ?<br>• ប្រវត្តិ និងធម្មជាតិនៃអំពើហិង្សាពីមុនលើអ្នកដទៃ (ឧ. ប្រវត្តិប្រព្រឹត្តអំពើហិង្សាក្នុងទំនាក់ទំនងពីមុន)។ |
| ភស្តុតាងបង្ហាញពីការរីករាលដាលនៃអំពើហិង្សា ឬការបំភិតបំភ័យ | • ឥរិយាបថឈ្លបចាប់ ការប្រើអាវុធ ការរំលោភបំពានផ្លូវភេទ ការប្រព្រឹត្តបំពានលើសត្វ ការបំផ្លាញទ្រព្យសម្បត្តិ ឬការគំរាមបំផ្លាញទ្រព្យសម្បត្តិនាពេលអនាគត ការចាប់ដាច់ចំណាប់ខ្នាំងជនរងគ្រោះកាន់តែងាយរងគ្រោះដោយសារអាយុពិការភាព ការមានផ្ទៃពោះ។ |
| ជនបង្កកាន់កាប់ អាចទទួលបាន ស្គាល់ និងចូលចិត្តកាំភ្លើង | • លទ្ធភាពទទួលបានអាវុធថ្មី/ការរកបានអាវុធ |
| ទំនោររបស់ជនបង្កក្នុងការគោរពតាមវិធានរបស់តុលាការ | • កំណត់ត្រានៃការរំលោភដីកាតុលាការ<br>• កំណត់ត្រានៃការមិនអនុវត្តតាមវិធានដោះលែង ឬដាក់ឱ្យនៅក្រៅឃុំមុនពេលជំនុំជម្រះ<br>• ធ្លាប់ចូលរួមក្នុងកម្មវិធីព្យាបាលអ្នកវាយដំ (battery treatment programme) |
| ស្ថានភាពទំនាក់ទំនង | • តើជនរងគ្រោះ និងជនបង្កកំពុង ឬបានបែកផ្លូវគ្នា បំបែកចេញពីគ្នា ឬទេ?<br>• តើជនរងគ្រោះ កំពុងរត់គេចខ្លួន ឬទេ?<br>• តើអ្វីជាស្ថានភាពករណីតុលាការគ្រួសារ ឬករណីតុលាការផ្សេងទៀត?<br>• ការជិតឈានដល់ការលែងលះចែកផ្លូវឬផ្ដាច់ទំនាក់ទំនងដែលផ្ដួចផ្ដើមដោយជនបង្ក ការជិតឈានទៅរកការផ្លាស់ប្ដូរការគ្រប់គ្រងកូន និង/ឬការជិតឈានទៅរកការផ្លាស់ប្ដូរទីលំនៅរបស់ជនរងគ្រោះ។ |

256. សៀវភៅណែនាំស្ដីពីការឆ្លើយតបដោយប្រសិទ្ធភាពរបស់អយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី (UNODC and UN Women, 2014) សូមមើល ៖ https://www.unodc.org/documents/justice-and-prison-reform/Handbook_on_effective_prosecution_responses_to_violence_against_women_and_girls.pdf p.54.។

8

# កំណត់សម្គាល់ និងអំណានបន្ថែម


1 Report of the Secretary-General, 'In-depth study on all forms of violence against women', United Nations, A/61/122/Add.1, (6 July 2006) paras. 111- 112

2 National Outcome Standards for Perpetrator Interventions (NOSPI) Baseline Report 2015-2016; Australian Department for Social Sciences, see: https://plan4womenssafety.dss.gov.au/wp-content/uploads/2018/08/nationaloutcomestandardsreport-web.pdf

3 Haskell, L. and Randell, M., 'The Impact of Trauma on Adult Sexual Assault Victims', Report Submitted to: Justice Canada (2019), see: https://www.justice.gc.ca/eng/rp-pr/jr/trauma/trauma_eng.pdf

4 'Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific' Partners For Prevention (2013), see:, https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/womens_empowerment/RBAP-Gender-2013-P4P-VAW-Report.pdf Partners for Prevention is an UNDP, UNFPA, UN Women and UNV regional joint programme for Gender-based Violence Prevention in Asia and the Pacific.

5 Ellsberg, M., H. A. F. M. Jansen, L. Heise, C. H. Watts and C. García Moreno (2008), 'Intimate partner violence and women's physical and mental health in the WHO multi-country study on women's health and domestic violence: An observational study' The Lancet, vol. 371, pp. 1165-1172.

6 Ethical and Safety Recommendations for Interviewing Trafficked Women (WHO, 2003), see: https://www.who.int/mip/2003/other_documents/en/Ethical_Safety-GWH.pdf

7 Guidelines on the Protection of Child Victims of Trafficking (UNICEF, 2006) https://www.unicef.org/protection/Unicef_Victims_Guidelines_en.pdf

8 R. Higgins., 'Problems and Process' (Clarendon Press, Oxford, 1994.), pp. 153-54, at, p. 153.

9 Basic Principles on the Use of Force and Firearms by Law Enforcement Officials (1990), adopted by the Eighth United Nations Congress on the Prevention of Crime and the Treatment of Offenders, Havana, Cuba, 27 August - 7 September 1990, see: https://www.ohchr.org/en/professionalinterest/pages/useofforceandfirearms.aspx

10 United Nations Police Gender Toolkit (UN Department of Peace Operations - DPO/ DPET/Integrated Training Service, 2015)

11 A Practitioner's Toolkit on Women's Access to Justice Programming (UN Women et al., 2018). https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

12 'Multi-Sectoral Gender Based Violence Response at the District Level in Nepal', End of Project Evaluation Report (August 2009 August – July 2013) supported by The UN Trust Fund to Eliminate Violence against Women, see: https://www2.unwomen.org/-/media/field%20office%20untf/publications/2018/evaluation%20digital%20library/3%20onpluntfecompressed.pdf?la=en&vs=832

13 Briefing Paper: 'Sex matters - A gender perspective on internal displacement' (2019), The Internal Displacement Monitoring Centre, see: http://www.internal-displacement.org/sites/default/files/publications/documents/201902-gender-dimension.pdf

14 Quintero and Culler, 'IDP health in Colombia: Needs and Challenges," Forced Migration Review (2009).

15 Bozanic, D., 'The Hidden Pandemic: Firearms and Intimate Partner Violence Killing Women (UNDP SEESAC, 2020), see: https://www.eurasia.undp.org/content/rbec/en/home/blog/2020/hidden-pandemic-firearms-killing-women.html

16 Challenges of IDP Protection - Research study on the protection of internally displaced persons in Afghanistan' (Joint IDP Profiling Service, November 2012).

17 Kiah Rollings and Natalie Taylor, 'Measuring Police Performance in Domestic and Family Violence', Trends and Issues in Crime and Criminal Justice, No. 367 December 2008, (Australian Government/Australian Institute of Criminology), see: https://aic.gov.au/publications/tandi/tandi367

17 Loger, Rosa, 'Violence against women: Good practices in combating and eliminating violence against women: Austrian Model of Intervention in Domestic Violence Cases. Report to the Expert Group Meeting at the UN Division for the Advancement of Women, in collaboration with UN Office on Drugs and Crime, Vienna, Austria, 2005).

18 Golding JM., 'Intimate partner violence as a risk factor for mental disorders: a meta-analysis' Journal of Family Violence, 1999;14:99–132.

19 Dowling, C., Morgan, A., Boyd, C., Voce, I., 'Policing Domestic Violence: A Review of the Evidence (Research Report 13). Australian Institute of Criminology, 2018), see:https://aic.gov.au/file/6650/download?token=CgV__eGo

20 Training Manual for Police Officers Strengthening Program for the Security of Vulnerable Groups (UNODC in partnership with the Government of Mexico 2017), see: http://www.policia-mas.org/manuales/Manual_Policias_INGLES_PREVIO_090817.pdf

21 Guidelines on Inclusion of Persons with Disabilities in Humanitarian Action (The Inter-Agency Standing Committee (IASC) Task Team on Inclusion of Persons with Disabilities in Humanitarian Action. Inter-Agency Standing Committee, 2019), see:. https://interagencystandingcommittee.org/iasc-task-team-inclusion-persons-disabilities-humanitarian-action/documents/iasc-guidelines

22 'Everyone's business: Improving the police response to domestic abuse (2014). Her Majesty's Inspectorate of Constabulary (HMIC). https://www.gov.uk/government/news/major-review-of-police-response-to-domestic-violence

23 'Handbook on effective prosecution responses to violence against women and girls' (UNODC in partnership with UN Women 2014), see: https://www.unodc.org/documents/justice-and-prison-reform/14-02565_Ebook_new.pdf

24 'Capacity Building in Risk Assessment and Safety Management to Protect High Risk Victims' – A Learning Resource, (PROTECT II, Vienna 2012)

25 Frequently asked questions in Multi-Agency Risk Assessment Conferences (MARAC) Save Lives, see: http://www.safelives.org.uk/sites/default/files/resources/MARAC%20FAQs%20General%20FINAL.pdf

26 DASH Risk Model, at: https://www.dashriskchecklist.co.uk/

27 A Guide to Risk Assessment and Risk Management of Intimate Partner Violence against Women for Police (European Institute for Gender Equality, 2019), see:. https://eige.europa.eu/sites/default/files/documents/20191701_mh0119277enn_pdf.pdf

28 2018 Report of the Special Rapporteur on violence against women, its causes and consequences on online violence against women and girls from a human rights perspective(A/HRC/38/47), at: http://ap.ohchr.org/documents/dpage_e.aspx?si=A/HRC/38/47

29 Rachel Robbins Hugh McLaughlin Concetta Banks Claire Bellamy Debbie Thackray, (2014), 'Domestic violence and multiagency risk assessment conferences (MARACs): A Scoping Review", The Journal of Adult Protection, Vol. 16 Iss 6 pp. 389 – 398n accessed at: https://www.researchgate.net/publication/280194675_Domestic_violence_and_multi-agency_risk_assessment_conferences_MARACs_A_scoping_review

30 Emily Turner, Juanjo Medina, Gavin Brown, 'Dashing Hopes? ThePredictive Accuracy of Domestic Abuse Risk Assessment by Police', *The British Journal of Criminology*, Volume 59, Issue 5, September 2019, Pages 1013–1034, accessed at: https://doi.org/10.1093/bjc/azy074

31 Risk assessment and Risk Management by Police (European Institute for Gender Equality),at: https://eige.europa.eu/gender-based-violence/risk-assessment-risk-management/principle-3-establishing-evidence-based-approach

32 Amnesty reveals alarming impact of online abuse against women (2017), see:. https://www.amnesty.org/en/latest/news/2017/11/amnesty-reveals-alarming-impact-of-online-abuse-against-women/

33 'Misuse of Firearms in Domestic Violence in South East Europe: Fast Facts', South Eastern and Eastern Europe Clearinghouse for the Control of Small Arms and Light Weapons (SEESAC) (2019), see: https://www.seesac.org/f/docs/News-SALW/Misuse-of-firearms-in-SEE_ENG_WEB_FINAL.pdf

34 Domestic Abuse Stalking and Harassment and 'Honour'-Based Violence (DASH) (2011). Coordinated Action against Domestic Violence or 'CAADA' UK (now SafeLives UK)

35 Hart, S. D. (2008) 'Preventing violence: The role of risk assessment and management' in. A. C. Baldry & F. W. Winkel (Eds.), Intimate partner violence prevention and intervention: The risk assessment and management approach (pp. 7-18). Hauppauge, NY: Nova Science Publishers.

7

# ការគាំទ្រ និងជំនួយ

ប្រសិនបើយើងទទួលយកថាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបណ្តាលមកពី"វិសមភាពដែលបង្កប់ក្នុងសង្គមរបស់យើង និងបន្តលេចឡើងទូទាំងសកលលោក យើងក៏គួរពិចារណាថា គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីគឺតាមពិតជា "ការអនុវត្តដែលបង្កគ្រោះថ្នាក់" ផងដែរ។ ប្រសិនបើយើងផ្សារភ្ជាប់ការអនុវត្តដែលបង្កគ្រោះថ្នាក់ទាំងនេះទៅនឹងប្រពៃណី ដំបូងយើងត្រូវសួរខ្លួនឯងថា "តើអ្វីដែលអាចជាវិសមភាព "បែបប្រពៃណី" ជាជាងវិសមភាពទូលំទូលាយ និងបង្កប់?"

Marai Larasi ៖ អ្នកតស៊ូមតិឱ្យមានការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជាសកម្មជន ទីប្រឹក្សា និងអ្នកអប់រំ

# គោលបំណងនៃជំពូកទី ៧

**នគរបាលអាចបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ និងតាមរយៈការផ្តល់ព័ត៌មានដល់ពួកគេអំពីសិទ្ធិរបស់ពួកគេ និងជម្រើសយុត្តិធម៌តាមរបៀបដែលជាក់ស្តែង សុក្រឹត អាចទទួលបាន និង ទូលំទូលាយ។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- នគរបាលគួរពន្យល់ពីដំណើរការស៊ើបអង្កេតឱ្យជនរងគ្រោះបានយល់ និងបន្តឱ្យពួកគេទទួលបានព័ត៌មាននៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌។
- កិច្ចសហការជាមួយអ្នកផ្តល់សេវាផ្សេងទៀតជាគន្លឹះក្នុងការផ្តល់ការគាំទ្រ និងជំនួយដែលមានប្រសិទ្ធភាពដល់ជនរងគ្រោះ ក៏ដូចជាធានាថា នគរបាលអាចផ្តោតសំខាន់លើតួនាទីស៊ើបអង្កេតរបស់ខ្លួន។ អាទិភាពនៃកិច្ចសហការគឺត្រូវបំពេញតម្រូវការរបស់ជនរងគ្រោះ។
- តួនាទីរបស់នគរបាលមិនមែនវិនិច្ឆ័យលើជនរងគ្រោះនោះទេ។ ដូច្នេះ មន្ត្រីឆ្លើយតបមិនត្រូវរងឥទ្ធិពលដោយភាពលម្អៀង ឬផ្នត់គំនិតឡើយ។
- នៅពេលនគរបាលពិចារណាទូលំទូលាយពីសេវាជំនួយនិងសេវាគាំទ្រវានឹងបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីឱ្យសហការ។
- ការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងដំណើរការនេះ មានន័យស្មើនឹងការកសាងទំនុកចិត្តជាមួយសហគមន៍។
- នគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតគួរចាត់ទុកជនរងគ្រោះជាដៃគូដែលត្រូវបង្កើនភាពអង់អាច ជាជាងចាត់ទុកភាពងាយរងគ្រោះរបស់ពួកគេថាដូចគ្នានឹងភាពទន់ខ្សោយផ្លូវកាយ ឬផ្លូវចិត្ត។
- នគរបាលត្រូវទទួលបានព័ត៌មានផ្អែកតាមបរិបទនៅពេលស្វែងយល់ពីតម្រូវការជំនួយ និងការគាំទ្ររបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ការគោរពនិងសេចក្តីថ្លៃថ្នូរគួរផ្តល់ដល់ជនបង្កដែលរងការចោទប្រកាន់ជាពិសេសស្ត្រី និងក្មេងស្រីដែលត្រូវបានរងគ្រោះ ក្នុងក្របខណ្ឌច្បាប់។



## សេចក្តីផ្តើម

**ការផ្តល់ជំនួយ និងការគាំទ្ររបស់នគរបាលដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាចំណុចស្នូលនៃដំណើរការស៊ើបអង្កេត និងចាប់ផ្តើមឡើងនៅពេលមានការជូនដំណឹងដំបូងពី ឧប្បត្តិហេតុនេះ និងបន្តជាប់ក្នុងដំណើរការយុត្តិធម៌។ នៅដំណាក់កាលដំបូងនេះហើយដែលនគរបាលត្រូវរៀបចំផែនការយ៉ាងសកម្មដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ ក្នុងការស៊ើបអង្កេត។ នៅពេលមន្ត្រីនគរបាលផ្តល់ព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលាដល់ជនរងគ្រោះស្តីពីសិទ្ធិ និងជម្រើសស្របច្បាប់របស់ពួកគេតាមរបៀបដែលគ្រប់ជ្រុងជ្រោយអាចទទួលបាន និងផ្តល់ការគោរព ការសិក្សា257 បង្ហាញថា ជនរងគ្រោះងាយនឹងស្វែងរកដំណោះស្រាយផ្លូវការក្នុងការទប់ស្កាត់អំពើហិង្សា និងដាក់ទណ្ឌកម្មលើជនប្រព្រឹត្ត។**

រូបថតទទួលបានពី UNMIT/Bernardino Soares (ប្រទេសទីម័រខាងកើត)

ជំពូកខាងក្រោមផ្តោតលើការផ្តល់ការណែនាំដល់អ្នកគ្រប់គ្រងនគរបាល ដែលចង់ពង្រឹងសមត្ថភាពក្រុមរបស់ខ្លួនលើការធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេតលើការចោទប្រកាន់ក៏ដូចជាទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សាបន្ថែមទៀតលើជនរងគ្រោះ និងអ្នកផ្សេងទៀតដែលជិតស្និទ្ធនឹងជនរងគ្រោះ គ្រួសាររបស់នាង និងសាក្សី។

ការណែនាំទាំងនោះ នឹងផ្តោតសំខាន់លើអត្ថន័យនៃការចូលរួមប្រកបដោយអត្ថន័យចំពោះជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងរបៀបដែលការបង្កើនភាពអង់អាចរបស់ជនរងគ្រោះក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការគាំទ្រ និងជំនួយដែលជនរងគ្រោះទទួលបានអាចប្រែក្លាយទៅជាលទ្ធផលកាន់តែប្រសើរសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។ ដូចជំពូកផ្សេងទៀតដែរ អ្នកអានគួរអានជំពូកនេះអមជាមួយនឹងសេវាសំខាន់ទី ៩ ស្តីពី "ការគាំទ្រ និងជំនួយ" ក្នុងម៉ូឌុលទី ៣ (យុត្តិធម៌ និងនគរបាល) នៃកញ្ចប់សេវាសំខាន់ៗ។

257. ឧ. សូមមើលតួនាទីរបស់មន្ត្រីនគរបាលជាស្ត្រីនៅនេប៉ាល់ដែលឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងរបាយការណ៍វាយតម្លៃនៅពេលបញ្ចប់គម្រោង "ការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ស្រុកក្នុងប្រទេសនេប៉ាល់" ថិរវេលាគម្រោង ៖ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ខែ កក្កដា ឆ្នាំ ២០១៣។ គម្រោងនេះគាំទ្រដោយ Trust Fund សម្រាប់ការលុបបំបាត់អំពើហិង្សាលើស្ត្រី។ សូមមើលផងដែរ Wilson, S., & Jasinski, J. (2004). Public satisfaction with the police in domestic violence cases: The importance of arrest, expectations, and involuntary contact. American Journal of Criminal Justice, 28, 235–254, Nathan Birdsall, Stuart Kirby & Michelle McManus (2017) Police–victim engagement in building a victim empowerment approach to intimate partner violence cases, Police Practice and Research, 18:1, 75-86., Hohl, K., Bradford, B., & Stanko, E. (2010). Influencing trust and confidence in the London metropolitan police: Results from an experiment testing the effect of leaflet drops on public opinion. British Journal of Criminology, 50, 491–513 and Tyler, T. (2004). Enhancing police legitimacy. The Annals of the American Academy of Political and Social Science, 593, 84–99។

## ការណែនាំគ្នាទៅវិញទៅមក

អ្នក និងបុគ្គលិករបស់អ្នកត្រូវពិចារណាពីការគាំទ្រ និងជំនួយដែលអ្នកអាចផ្តល់ជូនដើម្បីបំពេញតម្រូវការរបស់ជនរងគ្រោះម្នាក់ៗ នៅពេលដែលអ្នកត្រូវបានជូនដំណឹងអំពីឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះតម្រូវឱ្យមានការផ្តល់ព័ត៌មានជាប្រចាំដល់ជនរងគ្រោះអំពីវឌ្ឍនភាពនៃការស៊ើបអង្កេត។ដូច្នេះគួរចាត់តាំងមន្ត្រីម្នាក់ឱ្យបំពេញ តួនាទីនេះដើម្បីធានាការផ្តល់ព័ត៌មានឥតដាច់ និងបន្តកសាងទំនុកចិត្តរវាងជនរងគ្រោះ និងនគរបាល។ នៅពេលបង្កើតបានទំនាក់ទំនងហើយ មន្ត្រីរូបនោះអាចប្រមែប្រមូលព័ត៌មាន និង ចារកម្មដើម្បីគាំទ្រដល់ជនរងគ្រោះ សម្រាប់ជាប្រយោជន៍ដល់មន្ត្រីស៊ើបអង្កេត។ នៅចក្រភពអង់គ្លេស នេះជាតួនាទីរបស់មន្ត្រីទំនាក់ទំនងគ្រួសារ (FLO) ដែលទទួលបានការបណ្តុះបណ្តាលពិសេស និងត្រូវបានទទួលស្គាល់ជាការអនុវត្តល្អជាអន្តរជាតិ (សូមមើលប្រអប់ ១)។

### ប្រអប់ ១

**មន្ត្រីទំនាក់ទំនងគ្រួសារ (FLO) សម្រាប់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ(ចក្រភពអង់គ្លេស)**

មន្ត្រីទំនាក់ទំនងគ្រួសារដើរតួនាទីស្នូលក្នុងក្រុមស៊ើបអង្កេតដោយគាំទ្រដល់គ្រួសារជនរងគ្រោះក្នុងដំណើរការស៊ើបអង្កេតរហូតដល់បិទបញ្ចប់ដំណើរការតុលាការ។ មន្ត្រីនេះមានតួនាទីគាំទ្រដល់មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ (SIO) និងរក្សាឱ្យគ្រួសារជនរងគ្រោះទទួលបានព័ត៌មានអំពីវឌ្ឍនភាពនៃការស៊ើបអង្កេត។

ដំបូងឡើយតួនាទីនេះត្រូវបានបង្កើតឡើងដោយសារមិនសូវមានទំនាក់ទំនងជាមួយគ្រួសារជនរងគ្រោះ ដែលនាំទៅរកការស៊ើបអង្កេតមិនពេញលេញនិងផ្តល់របាយការណ៍អវិជ្ជមានក្នុងបណ្តាញផ្សព្វផ្សាយ ក៏ដូចជាព័ត៌មានសំខាន់ៗដែលពេលខ្លះនៅតែជាកម្មវត្ថុនៃការពិចារណារបស់តុលាការដែលត្រូវផ្តល់ជូនបណ្តាញផ្សព្វផ្សាយជាជាងនគរបាល។

មន្ត្រីទំនាក់ទំនងគ្រួសារដែលល្អត្រូវមានសមត្ថភាពស្តាប់ និងបង្ហាញសមានចិត្ត ប៉ុន្តែអាចផ្តាច់ខ្លួនបានសមស្របដើម្បីសង្កេតមើលប៉ារ៉ាម៉ែត្រនៃតួនាទី ដូចជា ការមានយុទ្ធសាស្ត្រចាកចេញច្បាស់លាស់ និងត្រូវពន្យល់ពីចំណុចនេះតាំងពីដំបូង។ មន្ត្រីរូបនេះត្រូវបង្ហាញភាពស្មោះត្រង់ និងសុចរិតភាពអំពីតួនាទីរបស់ខ្លួន ដែលជាផ្នែកមួយនៃការស៊ើបអង្កេត។ ឧ. ជំនួសឱ្យការនិយាយថា "ខ្ញុំមិនដឹង" ទៅកាន់គ្រួសារជនរងគ្រោះ មន្ត្រីរូបនេះគួរនិយាយថា "ក្នុងពេលនេះ ខ្ញុំគ្មានតួនាទីផ្តល់ព័ត៌មានទាំងនោះទេ"។ វានឹងបង្ហាញតាំងពីដំបូងឱ្យគ្រួសាររបស់ជនរងគ្រោះបានដឹងថា ទោះបីជាមន្ត្រីទំនាក់ទំនងគ្រួសារនៅចាំផ្តល់ការគាំទ្រក្តីក៏ពួកគេនៅតែជាមន្ត្រីនគរបាលនិងជាផ្នែកនៃក្រុមស៊ើបអង្កេត។

មន្ត្រីទំនាក់ទំនងគ្រួសារត្រូវចូលរួមការប្រជុំពិភាក្សាមុនចាប់ផ្តើមសកម្មភាពពាក់ព័ន្ធនឹងការស៊ើបអង្កេត និងត្រូវប្រុងប្រយ័ត្នមិននិយាយអ្វីទៅកាន់ជនរងគ្រោះដែលអាចប៉ះពាល់ដល់ករណីនេះ។ ប្រសិនបើចាំបាច់ មន្ត្រីរូបនោះមិនគួរចូលរួមក្នុងការប្រជុំពិភាក្សាមុនចាប់ផ្តើមសកម្មភាពនោះទេ ព្រោះពេលខ្លះពួកគេមិនគួរដឹងព័ត៌មានលម្អិតមួយចំនួនឡើយដើម្បីរក្សាកម្រិតសុចរិតភាពជាមួយគ្រួសារជនរងគ្រោះ។ទោះជាយ៉ាងណាមន្ត្រីទំនាក់ទំនងគ្រួសារគួរប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ ជាពិសេសប្រសិនបើគ្រួសាររបស់ជនរងគ្រោះគឺជាជនសង្ស័យ។
មន្ត្រីទំនាក់ទំនងគ្រួសារមិនមែនជាទីប្រឹក្សាឡើយហើយពួកគេត្រូវបញ្ជូនគ្រួសាររបស់ជនរងគ្រោះទៅរកស្ថាប័នគាំទ្រផ្សេងទៀតនៅពេលសមស្រប។ ពួកគេនឹងផ្តល់ការណែនាំ និងការគាំទ្រដល់គ្រួសារ តាមរយៈការប្រកាសព័ត៌មានតាមបណ្តាញផ្សព្វផ្សាយ និងបទសម្ភាសន៍។

ផ្អែកតាមទំនាក់ទំនងជាមួយគ្រួសារជនរងគ្រោះ មន្ត្រីទំនាក់ទំនងគ្រួសារមានតួនាទី ផ្តល់ព័ត៌មានសំខាន់ៗស្តី

ពីគ្រួសារជនរងគ្រោះដល់ក្រុមស្រាវជ្រាវ ដើម្បីជួយដល់ការស៊ើបអង្កេត។ ពួកគេមានតួនាទីសំខាន់ក្នុងការផ្តល់បណ្តាញទំនាក់ទំនងទ្វេទិសដ៏សំខាន់រវាងមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ អ្នកស៊ើបអង្កេត និងគ្រួសារជនរងគ្រោះ។

មន្ត្រីទំនាក់ទំនងគ្រួសារដែលល្អអាចបង្កើតទំនុកចិត្ត និងរក្សាទំនាក់ទំនងល្អជាមួយគ្រួសារជនរងគ្រោះ ដែលនឹងបង្កផលប៉ះពាល់វិជ្ជមានលើសមាជិកសហគមន៍ផ្សេងទៀតនៅមូលដ្ឋាន។

យោងតាមមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស គោលបំណងបឋមរបស់មន្ត្រីទំនាក់ទំនងគ្រួសារគឺជាគោលបំណងបឋមរបស់អ្នកស៊ើបអង្កេត។ ពួកគេមានតួនាទីប្រមូលភស្តុតាងនិងព័ត៌មានពីគ្រួសារជនរងគ្រោះ ដើម្បីរួមចំណែកដល់ការស៊ើបអង្កេត និងរក្សាសុចរិតភាពនៃការស៊ើបអង្កេត។ ក្រៅពីនេះ មន្ត្រីទំនាក់ទំនងគ្រួសារផ្តល់ការគាំទ្រនិងព័ត៌មានតាមរបៀបដែលគិតគូរពីអារម្មណ៍ និងមានក្តីមេត្តា ដែលធានាទំនុកចិត្ត និងភាពជឿជាក់របស់គ្រួសារជនរងគ្រោះ។

ប្រភព៖ មន្ត្រីទំនាក់ទំនងគ្រួសារ (មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស៖ https://profdev.college.police.uk/professional-profile/family-liaison-officer-flo/#role-purpose)

**សម្រាប់ព័ត៌មានបន្ថែមស្តីពីអ្វីដែលបង្កើតបានជាអភិក្រម "ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ" សូមមើលជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម)។**

ដើម្បីឱ្យបុគ្គលិករបស់អ្នកយល់ច្បាស់ អ្នកត្រូវពិចារណារួចបង្ហាញសំណួរខាងក្រោមដល់ពួកគេ៖

- តើអ្នករំពឹងថាបុគ្គលិករបស់អ្នកនឹងចែករំលែកព័ត៌មានអ្វីខ្លះជាមួយជនរងគ្រោះ? តើពួកគេធានាដូចម្តេចថាជនរងគ្រោះនឹងទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីការស៊ើបអង្កេត?
- តើបុគ្គលិករបស់អ្នកធានាទំនាក់ទំនងជាមួយជនរងគ្រោះដែលងាយរងគ្រោះបំផុតដោយរបៀបណា?

អ្នកត្រូវធានាថាស្ត្រី និងកុមារដែលត្រូវបានចោទប្រកាន់ពីបទល្មើស ដែលប្រឈមនឹងអំពើហិង្សា ក៏ត្រូវបានចាត់ទុកថាជាជនរងគ្រោះដែរ។ ឧ. ស្ត្រី និងក្មេងស្រីដែលត្រូវបានជួញដូរ ស្ត្រី និងក្មេងស្រីដែលត្រូវបានអ្នកដទៃកេងប្រវ័ញ្ច និងស្ត្រី និងក្មេងស្រីដែលអាចនឹងបានប្រព្រឹត្តអំពើហិង្សាព្រោះចំណុចនេះអាចបណ្តាលឱ្យមានការប៉ះទង្គិចផ្លូវចិត្តយូរអង្វែងដោយសារការទទួលរងការបំពានជាច្រើនឆ្នាំ។

អ្នក និងបុគ្គលិករបស់អ្នកមានតួនាទីជួយ មិនមែនវិនិច្ឆ័យនោះទេ។ ដូច្នេះ ការសំខាន់គឺមិនត្រូវប្រែក្លាយភាពលម្អៀងផ្នត់គំនិត និងគំនិត ឬជំនឿផ្សេងទៀតរបស់អ្នក ឬបុគ្គលិករបស់អ្នកទៅជាពាក្យពេចន៍ ឬអាកប្បកិរិយាចំពោះជនរងគ្រោះនោះទេ។

មានការកត់សម្គាល់ថា នគរបាលប្រហែលជាមិនមានធនធានគ្រប់បែបយ៉ាងដើម្បីបំពេញតម្រូវការរបស់ជនរងគ្រោះម្នាក់ៗនោះទេ ដូចជា ការគាំទ្រផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ការសម្របសម្រួលដល់ជនមានពិការភាពផ្សេងៗ (ឧ.ការបកប្រែភាសាសញ្ញា) ការផ្តល់សេវាសុខាភិបាល វេជ្ជសាស្ត្រ និងសុខុមាលភាពសង្គម ជម្រកសុវត្ថិភាព។ល។ ដូច្នេះ កិច្ចសហការរបស់អ្នកជាមួយអ្នក ផ្តល់សេវាគាំទ្រផ្សេងទៀតក្នុងតំបន់របស់អ្នកនឹងផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះ និងជួយដល់ការពង្រាយបុគ្គលិករបស់អ្នកប្រកបដោយប្រសិទ្ធភាព។ ការណ៍នេះនឹងអាចឱ្យអ្នកផ្តោតសំខាន់លើតួនាទីស៊ើបអង្កេតរបស់នគរបាលដើម្បីធានាការរៀបចំករណីឱ្យបានរឹងមាំសម្រាប់ដំណាក់កាលបន្ទាប់នៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

**រូប ១ ៖ ដំណើរនៃភាពជាដៃគូ** (Protect II 2012 )[258]




ដើម្បីទាញប្រយោជន៍ពីការផ្តល់ការគាំទ្រ និងជំនួយដោយស្ថាប័នដល់ជនរងគ្រោះ ដំបូងអ្នកត្រូវ ៖

- កំណត់រកសេវាគាំទ្រដែលមានក្នុងតំបន់សមត្ថកិច្ចរបស់អ្នក
- តើសេវាទាំងនោះអាចជួយឱ្យអ្នកបំពេញតម្រូវការរបស់ជនរងគ្រោះបានដោយរបៀបណា ?
- តើអ្នកមានទំនាក់ទំនងអ្វីខ្លះជាមួយជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណ ?

ប្រសិនបើមិនទាន់មានទំនាក់ទំនងគ្នា អ្នកត្រូវមានភាពប្រតិសកម្មក្នុងការបណ្តុះ/អភិវឌ្ឍ ទំនាក់ទំនងការងារល្អ។ ការបង្កើតការផ្តល់សេវាពហុស្ថាប័នមិនចាំបាច់ទាល់តែជាការលះបង់ច្រើននោះទេ។ ចំណុចសំខាន់គឺបុគ្គលពាក់ព័ន្ធគ្រប់រូបកំពុងឆ្ពោះទៅរកគោលដៅរួមនៃការគាំទ្រជនរងគ្រោះ។

ឧបករណ៍ដ៏ល្អ (គំរូទិន្នន័យ) ដើម្បីជួយដល់អ្នកក្នុងការគូសផែនទីសេវាដែលមានក្នុងតំបន់របស់អ្នក មានបង្ហាញក្នុងទំព័រទី ១៥ នៃឯកសារ "ការគូសផែនទីសេវាគាំទ្រសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីអនុលោមតាមស្តង់ដារអនុសញ្ញាទីក្រុងអ៊ីស្តង់ប៊ុលៈ វិធីសាស្ត្រ និងឧបករណ៍"[259] ។

នៅចក្រភពអង់គ្លេស គោលគំនិតនៃមជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូសកេរខ្មាស (SARCs) ត្រូវបានបង្កើតឡើងដោយសេវាសុខាភិបាលជាតិ(NHS) និងនគរបាល ដើម្បីប្រមូលផ្តុំសេវាសំខាន់ៗសម្រាប់ជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស។ យោងតាម NHS England [260] "SARCs រួមចំណែកដល់ការសម្រេចបានអាទិភាព និង គោលនយោបាយចម្រុះនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីបង្កើនសុខភាព និងសុខុមាលភាព ដោះស្រាយអំពើហិង្សា និងការរំលោភបំពានកាត់បន្ថយវិសមភាពនិងដោះស្រាយការរើសអើង"។

ក្របខណ្ឌគំរូសម្រាប់ SARCs[261] ផ្តែកលើកិច្ចសហការរវាងស្ថាប័នដៃគូក្នុងការផ្តល់ការថែទាំដែលមានសុវត្ថិភាព និងប្រសិទ្ធភាព។ ខាងក្រោមនេះមិនមែនជាបញ្ជីរាយនាមដៃគូពាក់ព័ន្ធដែលត្រូវបានបញ្ចូលនៅចក្រភពអង់គ្លេស ៖

- សេវានគរបាល
- ស្នងការនគរបាល និងបទល្មើស
- ប្រធានផ្នែកសុខាភិបាល
- អាជ្ញាធរមូលដ្ឋាន
- NHS England ក្រុមបេសកកម្មគ្លីនិក
- វិស័យសុខភាពសាធារណៈអង់គ្លេស
- សេវាកុមារក្នុងមូលដ្ឋាន
- សេវាសុខាភិបាលផ្លូវចិត្តកុមារ និងមនុស្សវ័យជំទង់
- សេវាសុខាភិបាលផ្លូវចិត្តមនុស្សពេញវ័យ
- សេវាអយ្យការ Crown
- អ្នកផ្តល់សេវាវិទ្យាសាស្ត្រកោសលវិច័យ
- អង្គការទទួលបន្ទុកវិស័យទីបីរួមមានអង្គការគាំទ្រជនមានពិការភាព
- សេវាសុខភាពផ្លូវភេទ
- ស្ថាប័នគាំពារសង្គម
- អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា ក្រសួងយុត្តិធម៌ និង

258. ដំណើរនៃភាពជាដៃគូ ៖ Protect II ៖ ការកសាងសមត្ថភាពក្នុងការវាយតម្លៃហានិភ័យ និងការរៀបចំផែនការសុវត្ថិភាពដើម្បីការពារជនរងគ្រោះដែលមានហានិភ័យខ្ពស់ (វីយែន ២០១២) http://fileserver.wave-network.org/trainingmanuals/PROTECTII_Risk_Assessment_and_Safety_2012_English.pdf p.47 ។

259. Kelly, L., Chair, R., (2018), 'Mapping Support Services for Victims of Violence against Women In Line with the Istanbul Convention Standards Methodology and Tools, (London Metropolitan University). The Handbook also recommends the document 'Combating violence against women: minimum standards for support services' By Kelly, L., Chair, R., and Dubois, L. (London Metropolitan University, 2008) for the Directorate General of Human Rights and Legal Affairs Council of Europe Strasbourg, at: https://www.coe.int/t/dg2/equality/domesticviolencecampaign/Source/EG-VAWCONF(2007)Study%20rev.en.pdf

នាយកដ្ឋានកិច្ចការផ្ទៃក្នុង ដែលផ្តល់ជំនួយឥតសំណង ដើម្បីគាំទ្រដល់ SARCs និងការគាំទ្រដល់ការព្យាបាលក្នុងវិស័យទីបី។

ទោះបីជាអ្នកពាក់ព័ន្ធ និងការពឹងផ្អែកគ្នាទៅវិញទៅមកអាចខុសពីអ្វីដែលត្រូវបានកំណត់ក្នុងផ្នែកខាងលើនៅតាមបណ្តាប្រទេសផ្សេងទៀតក្តី ក៏ SARCs កំពុងត្រូវបានបង្កើតឡើងក្នុងប្រទេសជាច្រើនជាពិសេសនៅអឺរ៉ុប និងអាមេរិកខាងត្បូង។

សូមមើលករណីសិក្សាទី ១ ស្តីពីការបង្កើត SARCs នៅប្រទេសប៊ុលហ្គារី។

SARC មានគោលបំណងផ្តល់ជូនអតិថិជននូវ ៖

១. ការគាំទ្រ និងការថែទាំសុខភាពស្រួចស្រាវក្នុងមជ្ឈដ្ឋានសមស្របតាមវ័យ
២. ការពិនិត្យវេជ្ជសាស្ត្រកោសលវិច័យគ្រប់ជ្រុងជ្រោយ
៣. សេវាតាមដានបន្តដែលបំពេញតម្រូវការវេជ្ជសាស្ត្រ តម្រូវការចិត្តសង្គម និងតម្រូវការជាប្រចាំ
៤. លទ្ធភាពទទួលបានឬការបញ្ជូនដោយផ្ទាល់ទៅទីប្រឹក្សាឯករាជ្យផ្នែកការ ប្រទូស្តកេរខ្មាស។

ប្រសិនបើ គ្មានមជ្ឈមណ្ឌលសង្គ្រោះជនរងគ្រោះ ឬមជ្ឈមណ្ឌលដោះស្រាយវិបត្តិចម្រុះក្នុងតំបន់របស់អ្នកទេ ហេតុអ្វីមិនបង្កើតឱ្យមាន? ការណ៍នេះនឹងបង្ហាញភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តរបស់អ្នកក្នុងការផ្តល់ការឆ្លើយតបដែលមានគុណភាពទៅនឹងជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជាគំរូដល់មន្ត្រីដូចគ្នា និងអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អ្នក។

សូមមើលករណីសិក្សាទី២នៅចុងបញ្ចប់នៃជំពូកនេះស្តីពីការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាចម្រុះដល់ជនរងគ្រោះនៅទីក្រុងដាកា ប្រទេសបង់ក្លាដេស។

ខណៈដែលអ្នកប្រហែលជាមិនអាចបង្កើតមជ្ឈមណ្ឌលផ្តល់សេវាចម្រុះ ដែលផ្តល់សេវាពេញលេញនៅពេលដំបូង សូមពិចារណាពីចំណុចសំខាន់ៗក្នុងការបង្កើតមជ្ឈមណ្ឌលនេះ ដើម្បីអាចផ្តល់សេវាមូលដ្ឋាន និងក្រោយមក អាចអភិវឌ្ឍ និងបន្ថែមដៃគូ ក៏ដូចជាបង្កើតភាពជាដៃគូ។ អាចមានអង្គការមិនមែនរដ្ឋាភិបាល និង/ឬអង្គការសង្គមស៊ីវិលដែលអាចជួយដល់អ្នកក្នុងការសម្របសម្រួលការបង្កើតភាពជាដៃគូជាមួយអ្នកផ្តល់សេវាផ្សេងទៀតក្នុងទម្រង់ជាគម្រោង ដោយមានបទប្បញ្ញត្តិសមស្របសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃដើម្បីកំណត់រកចំណុចល្អបំផុតសម្រាប់យកទៅអនុវត្តបន្ត។

ខណៈដែលអ្នកប្រហែលជាត្រូវខិតខំប្រឹងប្រែងក្នុងរយៈពេលខ្លី រយៈពេលមធ្យម អត្ថប្រយោជន៍រយៈពេលវែងគឺធំធេងណាស់។ សម្រាប់ជនរងគ្រោះ វាអាចផ្តល់សេវាចាំបាច់មួយចំនួនដើម្បីបំពេញតម្រូវការរបស់ពួកគេតាមរយៈការផ្តល់ការគាំទ្រ និងជំនួយពាក់ព័ន្ធដើម្បីជួយឱ្យពួកគេឆ្លងផុតការប៉ះទង្គិចផ្លូវចិត្ត និងផលប៉ះពាល់នៃអំពើហិង្សា។

សម្រាប់អ្នក និងបុគ្គលិករបស់អ្នក វាអាចគាំទ្រដល់ការស៊ើបអង្កេត ប្រសិនបើជនរងគ្រោះអាចទទួលបានសេវាដែលអ្នកមិនអាចផ្តល់ឱ្យបានប៉ុន្តែអាចគាំទ្រដល់ផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះក្នុងដំណើរការស៊ើបអង្កេត ដើម្បីទប់ស្កាត់ការរងគ្រោះលើកទីពីរដោយសារនគរបាលដែលបណ្តាលមកពីកង្វះធនធាន។ ឧ. ការសហការជាមួយអង្គការជនពិការនឹងជួយឱ្យអ្នកធានាថាជនរងគ្រោះដែលមានពិការភាពផ្សេងៗទទួលបានការគាំទ្រទាំងអស់ទៅតាមតម្រូវការដើម្បីសម្រេចបានយុត្តិធម៌[262]។ ដោយធានាថា ជនរងគ្រោះ ទទួលបានការគាំទ្រ និងជំនួយជាប្រចាំ តាមរយៈកិច្ចសហការជាមួយអ្នកផ្តល់សេវាផ្សេងទៀត មន្ត្រីរបស់អ្នកអាចរក្សាការផ្តោតសំខាន់លើការប្រមូលភស្តុតាងដើម្បីកសាងករណីរឹងមាំប្រឆាំងនឹងជនបង្កដែលរងការចោទប្រកាន់និងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ក្រៅពីនេះ វាអាចកសាងទំនុក

260. ការអនុវត្តក្របខណ្ឌសម្រាប់សេវានៅមជ្ឈមណ្ឌលបញ្ជូនមនុស្សពេញវ័យ និងកុមារដែលជាជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស (NHS England ២០១៥)។
261. បច្ចុប្បន្ន វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពចក្រភពអង់គ្លេស (NIHR) កំពុងវិនិយោគទឹកប្រាក់ចំនួន១,៣លានផោនលើការវាយតម្លៃការងាររបស់មជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសនៅអង់គ្លេស។ ការវាយតម្លៃនេះ ដឹកនាំដោយសាកលវិទ្យាល័យ Conventry ក្រោមការសហការជាមួយសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសជាច្រើនផ្សេងទៀត។
262. សូមមើលមាត្រា ១៣ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានយុត្តិធម៌ ៖ https://www.un.org/development/desa/disabilities/convention-on-the-rights-of-persons-with-disabilities/article-13-access-tojustice.html. ។

ចិត្ត និងភាពជឿជាក់របស់ជនរងគ្រោះ និងគ្រួសារ និងមិត្តភក្តិរបស់ពួកគេលើនគរបាល ដោយផ្តល់លទ្ធផលវិជ្ជមានដែលជនរងគ្រោះកាន់តែច្រើនមានទំនុកចិត្តក្នុងការរាយការណ៍ពីបទល្មើសទាំងនេះ។

ស្ត្រី និងក្មេងស្រី មានពិការភាពជាច្រើនហាក់មិនរាយការណ៍អំពើហិង្សាឡើយព្រោះពួកគេបានដឹងពីកង្វះការគាំទ្រដែលផ្តល់ភាពងាយស្រួលនៅប៉ុស្តិ៍នគរបាល។ ការផ្តល់ការគាំទ្រដែលផ្តល់ភាពងាយស្រួលនឹងបង្កើនទំនុកចិត្តរបស់ស្ត្រី និងក្មេងស្រីមានពិការភាពចំពោះនគរបាល។ នគរបាលអាចទទួលបានព័ត៌មាន និងចារកម្មកាន់តែច្រើនពីសហគមន៍ដែលអាចឱ្យអ្នកនិងបុគ្គលិករបស់អ្នកវិភាគបទល្មើសទាំងនេះនិងកំណត់រកអន្តរាគមន៍ទប់ស្កាត់ដោយសហការជាមួយស្ថាប័នផ្សេងទៀត ក៏ដូចជាសហគមន៍ផ្ទាល់។

សម្រាប់ព័ត៌មានបន្ថែមស្តីពីវិធានការទប់ស្កាត់សូមមើលជំពូកទី ៣ (ការទប់ស្កាត់)។

ក្នុងពេលបង្កើត SARC/មជ្ឈមណ្ឌលគាំពារជនរងគ្រោះ (VCC) អ្នកត្រូវបង្កើតពិធីសារផ្សេងៗរវាងស្ថាប័ន/អ្នកផ្តល់សេវា ដែលអាចមានលក្ខណៈផ្លូវការ ឬក្រៅផ្លូវការអាស្រ័យលើកម្រិតនៃកិច្ចសហការ។ ពិធីសារផ្លូវការគឺចាំបាច់ណាស់សម្រាប់ការចែករំលែកទិន្នន័យ និងចារកម្ម/ព័ត៌មានរវាងដៃគូនិងត្រូវមានកិច្ចព្រមព្រៀងដើម្បីកំណត់សេវា ឬធនធានដែលដៃគូនីមួយៗអាចផ្តល់ជូនបាន។

អ្នកប្រហែលជាត្រូវធានាថា ថ្នាក់លើរបស់អ្នកផ្តល់សិទ្ធិអំណាចដល់អ្នកក្នុងការផ្តល់ធនធានរបស់នគរបាលដល់គម្រោងនេះ។ ដូច្នេះ អ្នកត្រូវផ្តល់ឧទាហរណ៍ដល់ថ្នាក់លើរបស់អ្នកអំពីអត្ថប្រយោជន៍យូរអង្វែងសម្រាប់សេវានគរបាលក្នុងមូលដ្ឋានរបស់អ្នក និងនគរបាលជាតិក្នុងការផ្តល់សុវត្ថិភាព និងសន្តិសុខដល់ប្រជាពលរដ្ឋទូទាំងប្រទេស។



រូបថតទទួលបានពី UNMIT/Bernardino Soares (ប្រទេសទីម័រខាងកើត)

ក្រៅពីនេះ អ្នកត្រូវសម្រេចជាមួយអ្នកផ្តល់សេវាផ្សេងទៀត អំពីយន្តការបញ្ជូនដែលមាន ឬនឹងមានសម្រាប់ជនរងគ្រោះ របៀបផ្សព្វផ្សាយពីយន្តការនេះ និងក្នុងករណីសមស្រប ចំណាយពាក់ព័ន្ធនានា។ អ្នកប្រហែលជាត្រូវកសាងទំនុកចិត្ត និងភាពជឿជាក់ជាមួយ និងរវាងអ្នកផ្តល់សេវាផ្សេងទៀត ដើម្បីធានាថា អ្នកអាចយោងតាមយុទ្ធសាស្ត្រជាតិណាមួយស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេស គោលនយោបាយដែលពិពណ៌នាពីយន្តការបញ្ជូន និងយន្តការសម្របសម្រួល។

ប្រសិនបើពួកគេមិនសូវយល់ដឹងពីតួនាទីរបស់នគរបាល អំណាចដែលអ្នកមាន និងបញ្ហាប្រឈមរបស់អ្នក ពួកគេអាចនឹងស្ទាក់ស្ទើរមិនហ៊ានលើកទឹកចិត្តឱ្យជនរងគ្រោះរាយការណ៍ទៅអ្នកឱ្យបានឆាប់រហ័សនោះទេ។

តើអ្នកអាចលើកទឹកចិត្តឱ្យមានការរាយការណ៍ឆាប់រហ័សទៅនគរបាល និងបញ្ចៀសលទ្ធភាពនៃការបាត់បង់ភស្តុតាងដែលទទួលបានពីជនរងគ្រោះ សាក្សី កន្លែងកើតហេតុ និងជនបង្កដែលរងការចោទប្រកាន់ដោយរបៀបណា? អ្នកត្រូវពិចារណាពីជំហានជាក់ស្តែងដើម្បីធានានិងរក្សាភស្តុតាងឱ្យបានឆាប់រហ័សបំផុត ទោះបីជាជនរងគ្រោះមិនចង់ដាក់បណ្តឹងទៅនគរបាលក៏ដោយ។ ដូច្នេះ ប្រសិនបើនាងសម្រេចចិត្តដាក់របាយការណ៍នៅពេលក្រោយនោះភស្តុតាងសំខាន់ៗគឺនៅតែមាន។ វិធីសាមញ្ញមួយគឺការកសាងការយល់ដឹងរបស់ស្ថាប័ន/អ្នកផ្តល់សេវាផ្សេងទៀតអំពី ៖

- ប្រភេទនៃភស្តុតាង
- ការកំណត់រក និងការការពារអ្វីដែលអាចជាភស្តុតាង
- អ្វីដែលកើតឡើងនៅកន្លែងកើតហេតុ
- សារៈសំខាន់នៃការការពារនិងការរក្សាកន្លែងកើតហេតុ
- របៀបរក្សាភស្តុតាងជាពិសេសភស្តុតាងកោសលវិច័យរួមទាំងសារធាតុរាវក្នុងរាងកាយ។

ខណៈដែលអ្នកចង់ឱ្យនគរបាលគ្រប់គ្រងផ្នែកសំខាន់ៗទាំងនេះក្នុងការស៊ើបអង្កេតការយល់ដឹងច្រើនអំពីអ្វីដែលអ្នកចង់បានពីអ្នកផ្តល់សេវាផ្សេងទៀតនឹងអាចជួយដល់អ្នកក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ។

គួរចងចាំថាការពិចារណាដ៏សំខាន់លើអភិក្រមរួមគឺការបំពេញតម្រូវការរបស់ជនរងគ្រោះ។

ឧ.ការមានមជ្ឈមណ្ឌលដោះស្រាយវិបត្តិចម្រុះនៅមន្ទីរពេទ្យគឺគ្មានប្រយោជន៍ទេ ប្រសិនបើភ្នាក់ងារឆ្លើយតបដំបូងមិនដឹងថាមានមជ្ឈមណ្ឌលនេះ ឬមិនដឹងថា ពួកគេអាចជួយដល់ជនរងគ្រោះឱ្យទទួលបានសេវាទាំងនោះ។ ដូច្នេះ សូមពិចារណាចំណុចខាងក្រោម ៖

- ក្នុងករណីមានសេវាគាំទ្រ តើវាផ្តល់ភាពងាយស្រួល[263] និងភាពសមស្រប[264] កម្រិតណាដល់ស្ត្រីនិងក្មេងស្រី?
- តើសេវាទាំងនោះ អាចគាំទ្រដល់កុមារ និងមនុស្សពេញវ័យ ឬទេ?
- តើបុគ្គលិករបស់អ្នកទាំងអស់បានដឹងពីសេវាផ្សេងទៀតដែលមាន និងកន្លែងដែលមាន ឬអាចរកបានសេវាទាំងនោះ ឬទេ[265]?

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីការគូសផែនទីការអនុវត្តល្អជាសកល និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលផ្តល់វិធានការការពារ និងវិធានការ សុវត្ថិភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុង

263. ភាពអាចទទួលបានមានន័យថាសេវាត្រូវតែអាចទទួលបានជាក់ស្តែង(មានសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រីគ្រប់រូប) អាចទទួលបានផ្នែកសេដ្ឋកិច្ច (តម្លៃសមស្រប) និងអាចទទួលបានផ្នែកភាសា(ព័ត៌មានត្រូវបានផ្តល់ក្នុងក្នុងទម្រង់ផ្សេងៗ)។"កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា៖គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូលនិងគុណភាព"(កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)៖ https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-toviolence.

264. ភាពសមស្រប មានន័យថា សេវាសំខាន់ៗទាំងអស់ត្រូវគោរពសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ រក្សាការសម្ងាត់ គិតគូរពីតម្រូវការ និងទស្សនវិស័យរបស់ពួកគេ និងកាត់បន្ថយការរងគ្រោះលើកទីពីរ។។ សូមមើល កញ្ចប់សេវាសំខាន់ៗ (n.7)។

265. សូមមើលសៀវភៅណែនាំការបណ្តុះបណ្តាលនៃឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល អង្គការសហប្រជាជាតិ ៖ ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព-ម៉ូឌុលទី ៣ ៖ ការកសាងសមត្ថភាពរបស់នគរបាលក្នុងរដ្ឋម្ចាស់ស្រុកក្នុងការទប់ស្កាត់ និងស៊ើបអង្កេតអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ មេរៀនទី ៤ ៖ ការអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ការបង្កើតបណ្តាញបញ្ជូនជនរងគ្រោះ ៖ http://repository.un.org/handle/11176/387374 ។

បម្រើការ និងចូលនិវត្តន៍ និងបុគ្គលិករបស់អង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចំណុចខ្វះខាតសមត្ថភាពដែលលើកឡើងខាងក្រោមបង្កអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលនៅគ្រប់ចំណុចនៃដំណើរការស៊ើបអង្កេតប៉ុន្តែក្នុងករណីនេះ ចំណុចខ្វះខាតទាំងនេះ បន្ទុចបង្អាក់យុទ្ធសាស្ត្ររបស់នគរបាលក្នុងការផ្តល់ជំនួយ និងការគាំទ្រដល់ជនរងគ្រោះ។

ចំណុចខាងក្រោមមានគោលបំណងជួយឱ្យអ្នកគ្រប់គ្រងក្នុងជួរនគរបាល កំណត់រក និងកែតម្រូវអាកប្បកិរិយាសកម្មភាព និងឥរិយាបថដែលដាក់កំហិតលើលទ្ធភាពរបស់នគរបាលក្នុងការបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ តាមរយៈការផ្តល់ព័ត៌មានស្តីពីសិទ្ធិរបស់ពួកគេ និងជម្រើសយុត្តិធម៌ តាមរបៀបដែលជាក់ស្តែង សុក្រឹត អាចទទួលបាន និងគ្រប់ជ្រុងជ្រោយ។ ចំណាងជើងរងនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាននិង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

### ភាពលម្អៀងយេនឌ័រ

- នគរបាលនឹងបញ្ជូនទៅរកការផ្សះផ្សារ នៅពេលមានការបង្វែរពីយុត្តិធម៌ផ្លូវការ ជាញឹកញាប់ដោយសារតែនគរបាលជឿថា វាជាដំណោះស្រាយល្អសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។

### ការរងគ្រោះលើកទីពីរ

- ការខកខានមិនចែករំលែកព័ត៌មាន ឬការចែករំលែកព័ត៌មានមិនសមស្របអាចធ្វើឱ្យជនរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្និទ្ធស្នាល និងកូនរបស់ពួកគេ ប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ។ អភិក្រមស៊ីសង្វាក់គ្នាក្នុងការចែករំលែកព័ត៌មានបុគ្គលដោយស្ថាប័នទាំងអស់ជួយបង្កើនគុណភាពនៃសេវាសំខាន់ៗសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្និទ្ធស្នាលពាក់ព័ន្ធនឹងការទប់ស្កាត់ប្រវត្តិករណីបង្កទុក្ខព្រួយច្រំដែលចំពោះអ្នកជំនាញផ្សេងៗ និងកាត់បន្ថយពេលវេលាបានច្រើន។ គោលការណ៍រួមគឺត្រូវបង្កើតឱ្យមានសុវត្ថិភាព និងការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ[266]។
- ការកសាងទំនុកចិត្តដោយនគរបាលនៅពេលផ្តល់ការគាំទ្រ និងជំនួយ ងាយនឹងអាក់ខាន នៅពេលដែលជនរងគ្រោះយល់ថា ពួកគេត្រូវបានសួរចម្លើយក្នុងពេលសម្ភាសន៍។

### ការអនុវត្តខុសឆ្គង

- នគរបាលខិតខំធ្វើយ៉ាងណាឱ្យជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបានដឹងពីស្ថានភាពនៃករណីរបស់ពួកគេ រួមទាំងស្ថានភាពរបស់ជនបង្កដែលរងការចោទប្រកាន់។
- ជាញឹកញាប់នគរបាលមើលរំលងការសម្របសម្រួលដែលមានទំនាស់ជាមួយច្បាប់ ជាមួយក្រុមជនជាតិភាគតិច ក្រុមមានពិការភាព ក្រុមយុវជន ឬស្ត្រី ក្នុងការបង្កើនគុណភាពនៃសេវាសំខាន់ៗ។
- នគរបាលជំនាញមិនចូលរួមក្នុងការកាត់ទោសជាបន្តបន្ទាប់សូម្បីតែក្នុងករណីដែលពួកគេមានកាតព្វកិច្ច។
- នគរបាលខិតខំតាមដានបន្តលើការវាយតម្លៃហានិភ័យដំបូង ជាពិសេសនៅពេលដែលពាក់ព័ន្ធនឹងជនបង្កដែលរងការចោទប្រកាន់។ ជាទូទៅ មានភាពមិនស៊ីសង្វាក់គ្នាលើការដែលនគរបាលស្នើឱ្យដោះលែងក្រោមលក្ខខណ្ឌតឹងរ៉ឹង (ឧ. ការបង់ប្រាក់ធានានៅក្រៅឃុំ) ដែលតម្រូវឱ្យជនល្មើសនៅឆ្ងាយពីជនរងគ្រោះ និងសាក្សី រួមទាំងផ្ទះសម្ងែង កន្លែងធ្វើការ និងគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះ ព្រមទាំងលក្ខខណ្ឌត្រួតពិនិត្យយ៉ាងជិតដល់[267]។
- កង្វះភាពម្ចាស់ការលើបញ្ហាពីសំណាក់អ្នកគ្រប់គ្រងក្នុងជួរនគរបាលនាំទៅរកភាពមិនស៊ីសង្វាក់គ្នានៃការបែងចែកការគ្រប់គ្រងពេលវេលាចាំបាច់សម្រាប់អ្នកស៊ើបអង្កេត ក្នុងការបំពេញការងាររបស់ខ្លួនឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធភាព។ ជាលទ្ធផល "ភាពជិនណាយរបស់អ្នកស៊ើបអង្កេត" កើនឡើងដែលបង្កផល

---

266. ដកស្រង់ចេញពី "ទិដ្ឋភាពនៃអំពើហិង្សាលើស្ត្រីដែលពាក់ព័ន្ធផ្ទាល់នឹងគណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ" (គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ V.08-52191 (E) *0852191* កិច្ចប្រជុំលើកទី ១៧ ទីក្រុងវីយែន ថ្ងៃទី ១៤-១៨ ខែ មេសា ឆ្នាំ ២០០៨)។
267. ដកស្រង់ចេញពី "ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (UNODC ២០១៤)។

ប៉ះពាល់លើគុណភាពជារួមនៃការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី[268]។

**ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ**

- នគរបាលត្រូវមានការប្រុងប្រយ័ត្នខ្ពស់លើរបៀបប្រមូល និងរក្សាភស្តុតាង ដូចជា ការដកហូតទូរស័ព្ទចល័តរបស់ជនរងគ្រោះ។
- ជាញឹកញាប់នគរបាលយល់ថាពួកគេគ្មានពេលវេលាជំនាញ ឬឆន្ទៈក្នុងការប្រឈមជាមួយនឹងតម្រូវការការគាំទ្ររបស់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ[269]។

## និយមន័យ និងក្របខណ្ឌ

កញ្ចប់សេវាសំខាន់ៗកំណត់ថាការរងគ្រោះលើកទីពីរ មិនមែនកើតឡើងដោយសារទង្វើនេះទេប៉ុន្តែបណ្តាលមកពីកង្វះការឆ្លើយតបរបស់ស្ថាប័ន និងបុគ្គលទៅនឹងជនរងគ្រោះ[270]។ ការរងគ្រោះជាលើកទីពីរអាចកើតឡើងក្នុងដំណើរការយុត្តិធម៌។

នគរបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រី តាមរយៈការអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវដោយផ្អែកលើការយល់ដឹងពីសិទ្ធិរបស់ពួកគេ និងជម្រើសយុត្តិធម៌។

> "អ្នកស៊ើបអង្កេតត្រូវសហការជាមួយជនរងគ្រោះក្នុងដំណើរការស៊ើបអង្កេត និងគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការស្នើមិនឱ្យអនុវត្តជំហានស៊ើបអង្កេតមួយចំនួន។ ការស៊ើបអង្កេតបទព្រហ្មទណ្ឌគួរធ្វើឡើងទៅតាមល្បឿនដែលកំណត់ដោយជនរងគ្រោះ មិនមែនមន្ត្រីអនុវត្តន៍ច្បាប់នោះទេ"។
>
> គោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាសនិងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គបណ្តុះបណ្តាល(២០១៥) សមាគមអន្តរជាតិនៃស្នងការនគរបាល

ចំណុចនេះ អាចចាប់ផ្តើមពីការដែលនគរបាលបញ្ជាក់ឡើងវិញចំពោះជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីថា ផ្អែកតាមស្តង់ដារអន្តរជាតិ[271] ការទទួលខុសត្រូវលើការចោទប្រកាន់និងផ្តន្ទាទោសជនបង្កដែលរងការចោទប្រកាន់មិនត្រឹមតែជាបន្ទុករបស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាបន្ទុករបស់នគរបាល និងស្ថាប័នអយ្យការផងដែរ។

បន្ទាប់ពីនេះគឺការផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីសេវា និងដំណោះស្រាយផ្លូវច្បាប់ ដែលមាន ដោយមិនគិតពីស្ថានភាព (ជនចំណាកស្រុក ជនភៀសខ្លួន ជនគ្មានរដ្ឋ ឬជនត្រូវបានគេជួញដូរ)និងសាវតាររបស់ពួកគេ(យេនឌ័រ ជាតិពន្ធុ ទំនោរផ្លូវភេទ ដើមកំណើតជាតិ និង/ឬពិការភាព) ដោយមិនគិតថ្លៃ និងជាភាសាដែលជនរងគ្រោះអាចយល់បាន។

យោងតាមកញ្ចប់សេវាសំខាន់ៗធាតុផ្សំដ៏សំខាន់មួយក្នុងការធានាលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះទាំងអស់ដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រី គឺការផ្តល់សេវា គាំទ្រ និងសេវាជំនួយដែលមានភាពជាក់ស្តែងសុក្រឹត អាចទទួលបាន និងគ្រប់ជ្រុងជ្រោយ[272]។ កញ្ចប់សេវាសំខាន់ៗ ក៏បានបន្ថែមទៀតថា តួអង្គយុត្តិធម៌ មានដូចជា នគរបាល គួរចាត់ទុកសេវាជំនួយ និងគាំទ្រប្រៀបដូចជាអ្នកឯកទេសក្នុងការផ្តល់សេវាសុខាភិបាលជម្រកសុវត្ថិភាព សេវាសង្គម និងសេវាពិគ្រោះ យោបល់។ល។

អភិក្រមគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួលសម្រាប់ការគាំទ្រ និងជំនួយ នឹងជួយបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឱ្យចូលរួមប្រកបដោយអត្ថន័យក្នុងសម្រេចចិត្តយ៉ាងស្មុគស្មាញដែលជះឥទ្ធិពលលើសិទ្ធិ និងជម្រើសយុត្តិធម៌របស់ពួកគេ រួមទាំងកម្រិតនៃការការពារ និង

268. ដកស្រង់ចេញពី The Honourable Wally T. Oppal, 'FORSAKEN. The Report of the Missing Women Commission of Inquiry VOLUME IIB Nobodies: How and Why We Failed the Missing and Murdered Women Part 3, 4 and 5' (2012).
269. Gemma Hamilton, Lisa Harris & Anastasia Powell (2019): 'Policing repeat and high-risk family violence: police and servicesector perceptions of a coordinated model', Police Practice and Research, DOI: 10.1080/15614263.2019.1697267
270. សូមមើលផងដែរ យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ២០១០ (២០១១ សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឧបសម្ព័ន្ធ)។
271. សូមមើល យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ២០១០ (២០១១ សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឧបសម្ព័ន្ធ)។
272. សូមមើលបន្ថែមទៀត កញ្ចប់សេវាសំខាន់ៗ។

សុវត្ថិភាពដែលជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេចង់បានពីនគរបាល។ តាមរយៈការធានាថា ជនរងគ្រោះទទួលបានព័ត៌មានគ្រប់គ្រាន់នគរបាលមិនត្រឹមតែបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ ក្នុងដំណើរការស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងទំនុកចិត្តជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងសហគមន៍គាំទ្ររបស់ពួកគេដែលជាគន្លឹះនៃកិច្ចសហការប្រកបដោយប្រសិទ្ធភាពនិងលទ្ធផលវិជ្ជមានទៀតផង។ ពេលគឺការធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានន័យស្មើនឹងការកសាងទំនុកចិត្តជាមួយសហគមន៍ជារួម។ ក្នុងការបង្កើតយុទ្ធសាស្ត្រ ឬអភិក្រមស៊ើបអង្កេត ការចូលរួមប្រកបដោយ អត្ថន័យគួរចាត់ទុកជាគោលបំណង និងមធ្យោបាយនៅពេលធានាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ[273]។

ផ្អែកតាមអង្គការសុខភាពពិភពលោក (WHO)[274] ការចូលរួមប្រកបដោយអត្ថន័យទាមទារឱ្យបុគ្គលម្នាក់ៗមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលផ្ទាល់លើពួកគេ រួមទាំងការសម្រេចចិត្តក្នុងការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដានអន្តរាគមន៍។ ឧ. ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានសិទ្ធិបង្ហាញអំណះអំណាងស្របច្បាប់ពាក់ព័ន្ធនឹងឧប្បត្តិហេតុដែលត្រូវពិចារណាក្នុងដំណើរការនេះ និងធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវដែលជះឥទ្ធិពលលើសិទ្ធិរបស់ពួកគេ។

ចំណុចនេះអាចរួមបញ្ចូលការសម្រេចចិត្តរបស់ជនរងគ្រោះក្នុងការទទួលយក (ឬមិនទទួលយក) ដំណោះស្រាយជម្លោះជាជម្រើស ឬប្រព័ន្ធក្រៅផ្លូវការ ការសម្រេចចិត្តរបស់គាត់ក្នុងការទទួលយកដំណោះស្រាយជាក់លាក់មួយជាជាងដំណោះស្រាយផ្សេងទៀត[275]។ ក្រៅពីនេះ ការចូលរួមប្រកបដោយអត្ថន័យអាចមានទម្រង់ផ្សេងៗជាច្រើន ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមការទទួលបានព័ត៌មានគ្រប់គ្រាន់ប្រកបដោយគុណភាព ងាយស្រួលទទួលបាន និងសត្យានុម័ត ដើម្បីរក្សាការគ្រប់គ្រងយ៉ាងជិតស្និទ្ធលើការសម្រេចចិត្តសំខាន់ៗដែលជះឥទ្ធិពលលើសុខុមាលភាព និងការពិគ្រោះយោបល់លើដំណើរការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការបង្កើតជម្រើសនិងការរិះរកដំណោះស្រាយ[276] ។

ការសំខាន់គឺការចូលរួមប្រកបដោយអត្ថន័យ សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងដំណើរការស៊ើបអង្កេត នឹងជួយបង្កើនភាពអង់អាចនៅពេលដែលជន រងគ្រោះអាចធ្វើសកម្មភាពសម្រាប់និងជំនួសមុខឱ្យខ្លួនឯងក្នុងការទាមទារសិទ្ធិរបស់ខ្លួន។ ការិយាល័យសិទ្ធិមនុស្ស និងសិទ្ធិស្របច្បាប់របស់ស្ត្រី (WLB) និង UN Women លើកឡើងពីវិធី ៣ ក្នុងការវាស់វែងការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងដំណើរការស្វែងរកយុត្តិធម៌[277] ៖

១. ថាតើជនរងគ្រោះបានដឹងពីសិទ្ធិរបស់ខ្លួនក្រោមច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ ឬទេ
២. ថាតើប្រព័ន្ធច្បាប់ និងអ្នកមានកាតព្វកិច្ច[278]អនុញ្ញាតឱ្យមានការចូលរួមយ៉ាងសកម្មប្រកបដោយអត្ថន័យ និងលេចធ្លោររបស់ជនរងគ្រោះក្នុងករណីរបស់គាត់ ឬទេ។
៣. ថាតើដំណើរការនេះទាំងមូល ជំរុញការចូលរួមរបស់ជនរងគ្រោះក្នុងប្រព័ន្ធនេះ ឬទេ?

273. អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះមានគោលបំណងបង្កើតបរិយាកាសគាំទ្រដែលមានការគោរពសិទ្ធិរបស់ជនរងគ្រោះ និងផ្តល់សេចក្តីថ្លៃថ្នូរ និងការគោរពដល់ពួកគេ។ អភិក្រមនេះជួយលើកកម្ពស់ការស្តារឡើងវិញ និងសមត្ថភាពរបស់ជនរងគ្រោះក្នុងការកំណត់ និងបង្ហាញពីតម្រូវការ និងបំណងប្រាថ្នារបស់ពួកគេ ក៏ដូចជាពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអន្តរាគមន៍នានា។ សូមមើល "កម្មវិធីគាំពារសហគមន៍ ៖ ការផ្លាស់ប្តូរជីវិតរស់នៅ និងការទប់ស្កាត់អំពើហិង្សា" (UNICEF, New York, 2014) ៖https://www.unicef.org/documents/communities-care ។
274. ការចូលរួម ៖ យេនឌ័រ សមធម៌ និងសិទ្ធិមនុស្ស។ អង្គការសុខភាពពិភពលោក ៖https://www.euro.who.int/en/publications/abstracts/participation-as-a-driver-of-health-equity-2019។
275. "ការគូសផែនទី និងការវិភាគដំណោះស្រាយស្របច្បាប់ក្នុងស្រុកលើបញ្ហាអំពើហិង្សាលើស្ត្រី (ការិយាល័យសិទ្ធិមនុស្ស និងសិទ្ធិស្របច្បាប់របស់ស្ត្រី និង UN Women ២០១០)។
276. សូមមើល "ការចូលរួម ៖ យេនឌ័រ សមធម៌ និងសិទ្ធិមនុស្ស។ អង្គការសុខភាពពិភពលោក ៖ https://www.euro.who.int/en/publications/abstracts/participation-as-a-driver-of-health-equity-2019។
277. "ការគូសផែនទី និងការវិភាគដំណោះស្រាយស្របច្បាប់ក្នុងស្រុកលើបញ្ហាអំពើហិង្សាលើស្ត្រី (ការិយាល័យសិទ្ធិមនុស្ស និងសិទ្ធិស្របច្បាប់របស់ស្ត្រី និង UN Women ២០១០)។
278. ជាទូទៅអ្នកមានកាតព្វកិច្ចជាតួអង្គរដ្ឋ (ដូចជា នគរបាល) ឬតួអង្គដែលចាត់វិធានការជំនួសមុខឱ្យរដ្ឋដែលមានកាតព្វកិច្ច ឬការទទួលខុសត្រូវលើការគោរព លើកកម្ពស់ និងសម្រេចបានសិទ្ធិមនុស្ស និងមិនរំលោភសិទ្ធិមនុស្ស។ អាស្រ័យលើបរិបទ កងកម្លាំងប្រដាប់អាវុធ ឯកជន បុគ្គល (ឧ. ឪពុកម្តាយ) អង្គការក្នុងមូលដ្ឋាន ក្រុមហ៊ុនឯកជន ម្ចាស់ជំនួយ និងស្ថាប័នអន្តរជាតិក៏អាចជាអ្នកមានកាតព្វកិច្ចផងដែរ។ សូមមើល សទ្ទានុក្រមវាក្យស័ព្ទ និងគោលគំនិត ការិយាល័យ UNICEF ប្រចាំនៅអាស៊ីទក្សិណខែវិច្ឆិកា ឆ្នាំ ២០១៧៖ https://www.unicef.org/rosa/media/1761/file/Gender%20glossary%20of%20terms%20and%20concepts%20.pdf%20.

ការរៀបចំផែនការរបស់នគរបាល សម្រាប់ការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរពិចារណាពីកត្តាប្រទាក់ក្រឡាគ្នា និងត្រួតគ្នាផ្សេងៗ[279] នៃសាវតាររបស់ជនរងគ្រោះនិងថាតើអត្តសញ្ញាណសង្គម និងកាលៈទេសៈតាមស្ថានភាពអាចប្រទាក់ក្រឡាគ្នាដោយរបៀបណាដើម្បីជះឥទ្ធិពលលើការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ ដូចការពិពណ៌នាក្នុងចំណុចទាំងបីខាងលើ។

ចំណុចនេះអាចរួមបញ្ចូលអំពើហិង្សាដែលជាបទល្មើស "ដើម្បីកិត្តិយស"[280] ដែលបណ្តាលមកពីវិសមភាពយេនឌ័រ ដែលពាក់ព័ន្ធនឹងជំនឿ ឬការបកស្រាយក្នុងសាសនា។ ឧទាហរណ៍ផ្សេងទៀតនៃកត្តាប្រទាក់ក្រឡាគ្នារួមមានពិការភាព ដែលរួមបញ្ចូលពិការភាពផ្នែកផ្លូវចិត្ត និងចិត្តសង្គម ការញៀនគ្រឿងញៀន ការមានទំនាស់ជាមួយច្បាប់ និង/ឬការក្លាយជាផ្នែកមួយនៃក្រុមភាគតិច[281]។

នៅពេលកំណត់ អំពើហិង្សាណាមួយ ជាអំពើហិង្សា "ដើម្បីកិត្តិយស" ការសំខាន់ត្រូវកត់សម្គាល់ថា ពាក្យនេះអាចត្រូវបានប្រឆាំងតវ៉ាព្រោះពាក្យនេះកំណត់គោលដៅមិនសមាមាត្រលើសហគមន៍ជាក់លាក់ដែលអាចនាំឱ្យមានការឃ្លាំមើល និងសេវានគរបាលកាន់តែច្រើនក្នុងសហគមន៍ទាំងនោះព្រោះពាក្យនេះផ្សារភ្ជាប់សហគមន៍ទៅនឹងរបៀបវារៈដែលមិនពាក់ព័ន្ធនឹងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[282]។ គួរកត់សម្គាល់ថានៅពេលនគរបាលឆ្លើយតបនឹងអំពើហិង្សា "ដើម្បីកិត្តិយស" ពួកគេគួរមានភាពប្រុងប្រយ័ត្នក្នុងការកំណត់ផ្នត់គំនិតនិងការចាត់ប្រភេទបែបរើសអើងផ្សេងទៀតដែលផ្តោតគោលដៅលើបុគ្គល និងសហគមន៍នានា[283]។

279. គោលគំនិតនៃភាពប្រសព្វគ្នាត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨៩ ដោយសកម្មជនស្ត្រីនិយមជនជាតិស្បែកខ្មៅ និងសាស្ត្រាចារ្យ Kimberlie Crenshaw។ ចាប់តាំងពីពេលនោះមក គោលគំនិតនោះត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់ពីបទពិសោធន៍របស់ស្ត្រី ធៀបនឹងភាពប្រទាក់ក្រឡាគ្នានៃការគៀបសង្កត់ក្នុងពេលតែមួយជាច្រើន ដែលរួមបញ្ចូល (ប៉ុន្តែមិនកំណត់ត្រឹម) ជាតិសាសន៍ ឋានៈ វណ្ណៈ យេនឌ័រ ជាតិពន្ធុ ផ្លូវភេទ ពិការភាព សញ្ជាតិ ស្ថានភាពទេសន្តរប្រវេសន៍ ទីតាំងភូមិសាស្ត្រ និងសាសនា។ សូមមើល Hill Collins, P., 'Black Feminist Thought: Knowledge, Consciousness, and the Politics of Empowerment' (Routledge, New York, 1990); cited in Imkaan and UN Women (2019), 'The Value of Intersectionality in Understanding Violence against Women and Girls' at: https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339

កត្តាប្រទាក់ក្រឡាគ្នា និងត្រួតគ្នាផ្សេងៗ នឹងជះឥទ្ធិពលយ៉ាងខ្លាំងលើភាពងាយរងគ្រោះរបស់បុគ្គល ឬក្រុមណាមួយទៅនឹងអំពើហិង្សាជាពិសេសប្រសិនបើពួកគេតំណាងឱ្យក្រុមភាគតិចក្នុងសង្គមមួយ។

សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ អ្នកនិពន្ធកំណត់និយមន័យ[284]នៃក្រុមងាយរងគ្រោះដូចខាងក្រោម៖

> "ជនងាយរងគ្រោះសំដៅលើអ្នកដែលមានការលំបាកក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន នៅចំពោះមុខប្រព័ន្ធយុត្តិធម៌ដែលត្រូវបានច្បាប់ទទួលស្គាល់ ដោយសារអាយុយេនឌ័រស្ថានភាពផ្លូវកាយឬផ្លូវចិត្តឬដោយសារកាលៈទេសៈសង្គម សេដ្ឋកិច្ច ជាតិពន្ធុ និង/ឬ វប្បធម៌។ ចំណុចដូចតទៅនេះអាចបង្កជាភាពងាយរងគ្រោះ ៖ អាយុ ពិការភាព ភាពជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ឬជនជាតិភាគតិច ការធ្វើឱ្យរងគ្រោះ ការធ្វើចំណាកស្រុក និងការបាត់បង់ទីលំនៅក្នុងប្រទេស ភាពក្រីក្រ យេនឌ័រ និងការដកហូតសេរីភាព។ និយមន័យជាក់លាក់នៃក្រុមងាយរងគ្រោះក្នុងប្រទេសនីមួយៗនឹងអាស្រ័យលើលក្ខណៈជាក់លាក់ក៏ដូចជាកម្រិតនៃការអភិវឌ្ឍសង្គម ឬសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ"។

យោងតាមអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការ (OSCE) កត្តាទូទៅមួយដែលកំណត់ក្រុមងាយរងគ្រោះទាំងអស់គឺភាគច្រើនពួកគេប្រឈមនឹងបទល្មើសដោយផ្អែកលើ "អត្ត-សញ្ញាណ" របស់ពួកគេ"[285]។

280. ជាទូទៅអំពើហិង្សាលើស្ត្រី និងក្មេងស្រី "ផ្អែកលើកិត្តិយស" រំលេចធាតុផ្សំសំខាន់ៗ៣៖ ការគ្រប់គ្រង ឬបំណងចង់ត្រួតត្រាអាកប្បកិរិយារបស់ស្ត្រី ២) អារម្មណ៍អៀនខ្មាសរបស់មនុស្សប្រុសចំពោះការបាត់បង់ការត្រួតត្រារបស់ខ្លួនឬការបាត់បង់ការគ្រប់គ្រងតាមការសន្មតលើអាកប្បកិរិយារបស់ជនរងគ្រោះនិង៣) ការចូលរួមរបស់សហគមន៍ឬគ្រួសារក្នុងការបង្កើននិងដោះស្រាយភាពអាម៉ាស់នេះ។ សូមមើល 'Barker, N., Gregware., P.R., Cassidy, M.A. (1999), 'Family Killing Fields: Honor Rationales in the Murder of Women'.

281. Imkaan ដែលជាអង្គការស្ត្រីមានមូលដ្ឋាននៅចក្រភពអង់គ្លេស ប្តេជ្ញាដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីជនជាតិស្បែកខ្មៅ និងជាជនជាតិភាគតិច ពិពណ៌នា "ការធ្វើឱ្យក្លាយទៅជាក្រុមភាគតិច" ថាជាដំណើរការដែលបង្កើត និងរក្សាស្ថានភាពសង្គម នយោបាយ សេដ្ឋកិច្ច និងស្ថានភាពផ្សេងទៀតដែលនាំឱ្យក្រុមមនុស្សរងការប្រព្រឹត្តចំពោះ និងត្រូវបានកំណត់ជាជនជាតិភាគតិច ដូចជា "ជ នជាតិភាគតិច" និង "ក្រុមភាគតិច"។ ក្រៅពីនេះ ការធ្វើឱ្យក្លាយទៅជាក្រុមភាគតិច គឺជាដំណើរការបន្តជាប់ និងយ៉ាងរស់រវើក ដែលធ្វើឱ្យក្រុមមួយចំនួនជួបការលំបាកដោយសារ "ជាតិសាសន៍" ជាតិពន្ធុ និងមូលហេតុផ្សេងទៀត។ សូមមើល "ចាប់ពីការរស់រានរហូតដល់និរន្តរភាព ៖ បញ្ហាសំខាន់ៗសម្រាប់អ្នកឯកទេសជនជាតិស្បែកខ្មៅ និង "ជនជាតិភាគតិច" ក្នុងវិស័យបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅចក្រភពអង់គ្លេស" (Imkaan, 2018)។

282. Ibid

283. Ibid

284. សូមមើល "បទប្បញ្ញត្តិប្រេស៊ីលពាក់ព័ន្ធនឹងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ជនងាយរងគ្រោះ"។ សូមមើល ៖ at: https://www.icj.org/wpcontent/uploads/2018/11/Brasilia-rules-vulnerable-groups.pdf ដែលត្រូវបានដកស្រង់ក្នុងឯកសារស្តីពី "ការបំពានគោលជំហរនៃភាពងាយរងគ្រោះ និង "មធ្យោបាយ" ផ្សេងទៀតក្នុងនិយមន័យនៃការជួញដូរ (UNODC, 2013) ៖ https://www.unodc.org/documents/human-trafficking/2012/UNODC_2012_Issue_Paper_-_Abuse_of_a_Position_of_Vulnerability.pdf

OSCEលើកឡើងទៀតថាក្រុមជាក់លាក់រងគ្រោះដោយសារតែចំណង់ចំណូលចិត្តផ្លូវភេទ ឬពណ៌សម្បុររបស់ពួកគេ ឬដោយសារតែពួកគេមិនអាចការពារខ្លួនឯង មិនអាចស្វែងយល់ដោយខ្លួនឯង ឬមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបាន។ ដូច្នេះ បទល្មើសទាំងនេះមិនត្រឹមតែពាក់ព័ន្ធនឹងបទល្មើសលើបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតបានជាបទល្មើសប្រឆាំងនឹងសារតារ វប្បធម៌ បេតិកភណ្ឌ និងអត្តសញ្ញាណ (បទល្មើសនៃការស្អប់ខ្ពើម) របស់បុគ្គលថែមទៀតផង[286] ។



រូបថតទទួលបានពី UNMIL Photo/Christopher Herwig (ប្រទេសលីបេរីយ៉ា)

ទោះជាយ៉ាងណា ការសំខាន់គឺនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត មិនត្រូវចាត់ទុកពិការភាពថាដូចគ្នានឹងកម្សោយរាងកាយ ឬកម្សោយផ្លូវចិត្តឡើយ។

ជាញឹកញាប់ ស្ត្រី និងក្មេងស្រីត្រូវបានលាបពណ៌ជាក្រុម "ងាយរងគ្រោះ" ទៅនឹងបទល្មើសមួយចំនួន ដូចជា ការកេងប្រវ័ញ្ចផ្លូវភេទដោយបង្ខំ។ នេះក៏ដោយសារតែសមាសធាតុយ៉ាងច្រើនរបស់ស្ត្រី និងក្មេងស្រីក្នុងនាមជាជនរងគ្រោះដោយសារបទល្មើសនេះ និងអំពើហិង្សាធៀបនឹងបុរស និងក្មេងប្រុស។ ជាញឹកញាប់ ស្ត្រី និងក្មេងស្រីត្រូវបានដាក់ក្នុងស្ថានភាពនៃភាពងាយរងគ្រោះដោយសារការរើសអើងចេញពីវិសមភាពយេនឌ័រ។

ឧ. ក្នុងប្រទេសមួយចំនួន ការដែលស្ត្រីផ្ទេរកេរមត៌កដីធ្លីដោយផ្ទាល់គឺជាអំពើខុសច្បាប់ ដែលធ្វើឱ្យស្ត្រីមានការពិបាកក្នុងការធ្វើឱ្យខ្លួនឯងឯករាជ្យ និងចាកចេញពីទំនាក់ទំនងស្និទ្ធស្នាលបែបបំពាន។ ក្នុងឧទាហរណ៍មួយទៀត ការងារដែលគេចាត់ទុកជាការងារមនុស្សស្រី ដូចជា កិច្ចការផ្ទះសម្បែង ឬការមើលថែកូន គឺជាញឹកញាប់ទទួលបានប្រាក់ឈ្នួលតិចមានរយៈពេលច្រើនម៉ោងនិងស្ថិតនៅឆ្ងាយពីទីក្រុង។ ជាញឹកញាប់ ការធ្វើការងារយូរម៉ោង បូករួមនឹងការធ្វើដំណើរផ្លូវឆ្ងាយ ធ្វើឱ្យស្ត្រី និងក្មេងស្រីត្រូវជិះមធ្យោបាយធ្វើដំណើរសាធារណៈនៅពេលមេឃងងឹត (ឧ. ព្រឹកព្រលឹម ឬយប់ជ្រៅ)។ ដូច្នេះ ពួកគាត់កាន់តែងាយរងគ្រោះដោយសារការប្រឈមនឹងបទល្មើសទាំងឡាយ រួមទាំងអំពើហិង្សាផ្លូវភេទ។

នៅពេលពិចារណាពីតម្រូវការរបស់ក្រុមងាយរងគ្រោះឬក្រុមភាគតិចក្នុងការផ្តល់ជំនួយ និងការគាំទ្រ នគរបាលគួរចំណាយធនធានលើការស្វែងយល់អំពីរបៀបដែលអត្តសញ្ញាណសង្គម និងកាលៈទេសៈតាមស្ថានភាព (ឆ្លុះបញ្ចាំងពីរបៀបដែលមនុស្សឆ្លើយតបនឹងមជ្ឈដ្ឋានផ្សេងៗគ្នា) ក្នុងបរិបទមួយ អាចធ្វើឱ្យស្ត្រី និងក្មេងស្រីងាយរងគ្រោះ ជាជាងការផ្អែកលើវិធានការស្តីពីការប្រមូលព័ត៌មានដែលផ្តោតលើទង្វើ និង/ឬអាកប្បកិរិយាដែលគេសន្មតលើស្ត្រី និងក្មេងស្រី។ សូមមើលប្រអប់ ៣ ខាងក្រោម សម្រាប់គន្លឹះស្តីពីការធ្វើការជាមួយក្រុមងាយរងគ្រោះ។

285. Lindgren, M and Nikolić-Ristanović, V, Crime Victims: International and Serbian Perspective. Organization for Security and Cooperation in Europe, Mission to Serbia, Law Enforcement Department (2011).
286. Ibid

ប្រអប់ ២

**គន្លឹះសម្រាប់ការធ្វើការជាមួយក្រុមងាយរងគ្រោះ**

ក្នុងគោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស និងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គបណ្តុះបណ្តាល (២០១៥)* សមាគមអន្តរជាតិនៃស្នងការនគរបាល (IACP) ផ្តល់គន្លឹះមួយចំនួនសម្រាប់ការធ្វើការជាមួយសមាជិកក្រុមងាយរងគ្រោះក្នុងករណីអំពើហិង្សាផ្លូវភេទ ៖

- មិនមែនពិការភាពទាំងអស់សុទ្ធតែស្តែងឡើងនោះទេ ៖ ជនរងគ្រោះអាចមានពិការភាពផ្នែករាងកាយ វិញ្ញាណ ឬផ្លូវចិត្ត ឬពិការភាពចម្រុះ។
- ឥរិយាបថផ្សេងៗចំពោះ "ការប្រទូស្តកេរខ្មាស" និងការយល់ឃើញចំពោះការអនុវត្តច្បាប់ ៖ ត្រូវដឹងថាជំនឿជុំវិញយេនឌ័រ ផ្លូវភេទ ទំនោរផ្លូវភេទ ជាតិសាសន៍ សាសនា អាចខុសគ្នាខ្លាំងទៅតាមវប្បធម៌។
- សំណួរស្តីពីការប្រទូស្តកេរខ្មាសធ្វើឱ្យរំជួលអារម្មណ៍ និងអាចពិបាកលើកមកពិភាក្សា។ របួសផ្ទាល់ខ្លួននេះអាចបង្កើតជាអារម្មណ៍អៀនខ្មាស និងអាម៉ាស់។ អារម្មណ៍ទាំងនេះអាចកើនឡើងក្នុងវប្បធម៌មួយចំនួនរួមទាំងអារម្មណ៍យល់ថា ការបាត់បង់ព្រហ្មចារីមុនពេលរៀបការ អាចបង្កអន្តរាយយ៉ាងធំធេងក្នុងសង្គម។
- សហគមន៍មួយចំនួនអាចមានច្បាប់ពាក់ព័ន្ធនឹងការប្រទូស្តកេរខ្មាសបន្ថែមលើឬជំនួសឱ្យច្បាប់រដ្ឋឬច្បាប់សហព័ន្ធ។
- ប្រសិនបើជនរងគ្រោះមិននិយាយភាសារបស់អ្នក សូមផ្តល់ការបកប្រែដែលមិនលម្អៀង និងឯករាជ្យ។ កុំពឹងឱ្យសមាជិកគ្រួសារ កុមារ ជនសង្ស័យ ឬភាគីពាក់ព័ន្ធផ្សេងទៀត ធ្វើឱ្យជាអ្នកបកប្រែ។
- ក្រុម LGBTQI អាចមានតម្រូវការឯកជនភាពជាក់លាក់ អាស្រ័យលើទំនោរផ្លូវភេទរបស់បុគ្គលនោះដែលបុគ្គលផ្សេងទៀតក្នុងជីវិតរបស់គាត់បានដឹង។ ពោលគឺការយកចិត្តទុកដាក់ និងការដឹងពីបញ្ហាដូចគ្នា។

*ប្រភព ៖ គោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស និងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គបណ្តុះបណ្តាល (សមាគមអន្តរជាតិនៃស្នងការនគរបាល ២០១៥)

ដូច្នេះសមត្ថភាពក្នុងការបន្តទទួលបានព័ត៌មានផ្អែកតាមបរិបទ[287] និងធ្វើការវិភាគពាក់ព័ន្ធលើអន្តរាគមន៍ ដូចជាការវិភាគហានិភ័យ និងការវាយតម្លៃតម្រូវការ គឺជាសមត្ថភាពដ៏សំខាន់របស់នគរបាលនៅពេលខិតខំផ្តល់ការឆ្លើយតបដែលមានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការឆ្លើយតបសមស្របរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី សូមមើលជំពូកទី ៦ (សុវត្ថិភាព និងការការពារ)។ សម្រាប់ឧទាហរណ៍ជាក់លាក់នៃឥរិយាបថរបស់នគរបាលដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់អនុវត្តតាមគោលការណ៍សមាមាត្រភាព សូមមើលជំពូកទី ៥ (ការស៊ើបអង្កេត)។

សៀវភៅណែនាំនេះលើកទឹកចិត្តឱ្យនគរបាល និងដៃគូផ្តល់សេវាសំខាន់ៗ ផ្អែកតាមសេចក្តី ប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច នៅពេលពាក់ព័ន្ធជាមួយជនរងគ្រោះ។

គោលការណ៍គ្រឹះទាំងនេះក៏គ្របដណ្តប់លើជនបង្កដែលរងការចោទប្រកាន់ផងដែរជាពិសេសក្នុងករណីដែលពួកគេផ្ទាល់ក្លាយជាជនរងគ្រោះ។ ដូចគ្នានឹងជនរងគ្រោះដែលមានទំនាស់ជាមួយច្បាប់ ដូចជា ជនរងគ្រោះដែលត្រូវបានបង្ខំឱ្យក្លាយជាទាសករផ្លូវភេទសម្រាប់ការជួញដូរក្រុមងាយរងគ្រោះក៏រួមបញ្ចូលជនចំណាកស្រុកគ្មានលិខិតស្នាមបញ្ជាក់ ដែលត្រូវបានជួញដូរ និងបុគ្គលដែលបានប្រព្រឹត្តអំពើប្រទូស្តរាយធ្ងន់ធ្ងរ ឬអំពើមនុស្សឃាតដោយសារទទួលរងការរំលោភបំពានជាច្រើនឆ្នាំ។

ចំណុចនេះ រួមមានសិទ្ធិទទួលបានការប្រព្រឹត្តចំពោះដោយការគោរព និងសេចក្តីថ្លៃថ្នូរពីសំណាក់នគរបាល សិទ្ធិទទួលបានព័ត៌មានស្តីពីមូលហេតុនៃការចាប់ខ្លួន/ឃុំខ្លួនសិទ្ធិត្រូវបានសន្មតជាមុនថាគ្មានទោសសិទ្ធិទទួលបានការការពារពីអំពើហិង្សាមិនសមស្របដែលបង្កឡើងដោយតួអង្គរដ្ឋ (ឧ.សកម្មភាពបំពានរបស់នគរបាល) ឬតួអង្គមិនមែនរដ្ឋសិទ្ធិមិនចោទប្រកាន់ខ្លួនឯងសិទ្ធិទទួលបានឯកជនភាព និងការរក្សាការសម្ងាត់ សិទ្ធិទទួលបាន

មេធាវីស្របច្បាប់ និងសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួន និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[288]។ ចំណុចនេះគួររួមបញ្ចូលស្ត្រី និងក្មេងស្រីដែលត្រូវបានឃុំខ្លួន/ស្ថិតក្រោមវិធានការរដ្ឋបាល ដូចជា ស្ត្រីធ្វើចំណាកស្រុកដោយខុសច្បាប់ដែលត្រូវបានឃុំខ្លួន និងរង់ចាំការនិរទេស ស្ត្រីដែលត្រូវបានឃុំខ្លួនក្នុងកន្លែងព្យាបាលគ្រឿងញៀនជាកាតព្វកិច្ច ឬកន្លែងព្យាបាលសុខភាពផ្លូវចិត្ត[289] ។

**សេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច**

អនុម័តដោយសេចក្តីសម្រេចលេខ ៤០/៣៤ របស់មហាសន្និបាត ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥

“ជនរងគ្រោះជាបុគ្គលដែលទទួលរងគ្រោះថ្នាក់ជាលក្ខណៈបុគ្គល ឬជាសមូហភាព រួមទាំងរបួសផ្លូវកាយ ឬរបួសផ្លូវចិត្តការរងគ្រោះផ្លូវចិត្តការខាតបង់ផ្នែកសេដ្ឋកិច្ចឬការថយចុះយ៉ាងខ្លាំងនៃសិទ្ធិជាសារវន្តរបស់ខ្លួនដោយសារអំពើឬភាពអកម្មដែលរំលោភច្បាប់ព្រហ្មទណ្ឌដែលមានចែងក្នុងរដ្ឋសមាជិក រួមទាំងច្បាប់ដែលបដិសេធការបំពានអំណាចប្រព្រឹត្តដោយជនល្មើស”។

ទន្ទឹមនឹងគោលការណ៍គ្រឹះសម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច ថ្នាក់ដឹកនាំនគរបាលគួរធានាថា មន្ត្រីឆ្លើយតបអនុលោមតាមគោលការណ៍ដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងដូចមានចែងក្នុងច្បាប់ជាតិ ពិធីសារស្តាប័ន និងស្តង់ដារអន្តរជាតិ ដូចជាគោលការណ៍គ្រឹះស្តីពីការប្រើប្រាស់កម្លាំង និងកាំភ្លើងដោយមន្ត្រីអនុវត្តន៍ច្បាប់[290] នៅពេលពាក់ព័ន្ធជាមួយជនបង្កដែលរងការចោទប្រកាន់។

ឧ. គោលការណ៍គ្រឹះស្តីពីការប្រើប្រាស់កម្លាំង និងកាំភ្លើងដោយមន្ត្រីអនុវត្តន៍ច្បាប់កំណត់ថាចំណុចខាងក្រោមជាគោលការណ៍គន្លឹះដែលគាំទ្រដល់ការប្រើប្រាស់កម្លាំង ៖

- សមាមាត្រភាព
- ភាពស្របច្បាប់
- គណនេយ្យភាព
- ភាពចាំបាច់។

គួរផ្តោតការយកចិត្តទុកដាក់លើការធានាការប្រើប្រាស់យន្តការគ្រប់គ្រងកម្លាំង ដោយប្រសិទ្ធភាពដើម្បីឱ្យការប្រមូលភស្តុតាងដោយមន្ត្រីឆ្លើយតប (ឬភ្នាក់ងារឆ្លើយតបដំបូងផ្សេងទៀត ដូចជា យោធា) មិនរួមបញ្ចូលសក្ខីភាព ឬចម្លើយសារភាពរបស់ជនបង្កដែលរងការចោទប្រកាន់ ឬជនសង្ស័យ ដែលបានមកពីការបង្ខិតបង្ខំ។

ការផ្តល់ការគោរពនិងសេចក្តីថ្លៃថ្នូរដល់ជនដែលត្រូវបានស៊ើបអង្កេតបង្កើនឱកាសទទួលបានកិច្ចសហការចំណែកព័ត៌មានដែលទទួលបានតាមមធ្យោបាយបង្ខិតបង្ខំជះផលអវិជ្ជមានលើការទប់ស្កាត់បទល្មើស មិនអាចជឿទុកចិត្តបាន និងរំលោភសិទ្ធិមនុស្សជាសារវន្តក្នុងពេលមានសន្តិភាព និងក្នុងពេលសង្គ្រាម ដូចការកំណត់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ[291] និងច្បាប់មនុស្សធម៌អន្តរជាតិ[292]។

យោងតាមសមាគមទប់ស្កាត់ការធ្វើទារុណកម្ម (ATP) ដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវ ការស្រាវជ្រាវបង្ហាញថាក្រោមទារុណកម្មឬការគំរាមធ្វើទារុណកម្មបុគ្គលម្នាក់នឹងនិយាយឬធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីបញ្ចៀសការឈឺចាប់។ដូច្នេះគ្មានវិធីដឹងថាតើចម្លើយដែលទទួលបានគឺជាចម្លើយពិតប្រាកដ ឬយ៉ាងណានោះទេ[293]។

ដើម្បីទប់ស្កាត់ការប្រើប្រាស់កម្លាំងមិនសមស្របដោយមន្ត្រីឆ្លើយតប ក្នុងការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីសមាគមនេះស្នើឱ្យថ្នាក់ដឹកនាំនគរបាលលុបបំបាត់ការលើកទឹកចិត្តដែលអាចនាំឱ្យមន្ត្រីឆ្លើយតបប្រើប្រាស់កម្លាំងមិនសមស្រប។ខាងក្រោមនេះជាវិធានការជាក់ស្តែងផ្សេងទៀត ដែលលើកឡើងដោយសមាគមនេះ[294]៖

287. អង្គការសង្គមស៊ីវិលតាមមូលដ្ឋានជាធនធានដ៏មានតម្លៃសម្រាប់ពង្រឹងការយល់ដឹងរបស់នគរបាលស្តីពីបរិបទមូលដ្ឋាននិងរបៀបដែលកាលៈទេសៈតាមស្ថានភាពមួយចំនួនជានិន្នាការបន្តជាប់។
288. “ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតប ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី (UNODC, 2014)។
289. Ibid
290. “គោលការណ៍គ្រឹះស្តីពីការប្រើប្រាស់កម្លាំងនិងកាំភ្លើងដោយមន្ត្រីអនុវត្តន៍ច្បាប់”(អនុម័តដោយសមាជលើកទី៨នៃអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់បទល្មើសនិងការប្រព្រឹត្តចំពោះជនល្មើស Havana ប្រទេសគុយបា ថ្ងៃទី ២៧ ខែ សីហា-ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០)
291. ឧ.សូមមើលអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងការប្រព្រឹត្តលើខ្លួនឬទណ្ឌកម្មដទៃទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក (ត្រូវបានអនុម័ត នឹងដាក់ឱ្យចុះហត្ថលេខាផ្តល់សច្ចាប័ន និងទទួលយកដោយសេចក្តីសម្រេចលេខ ៣៩/៤៦ របស់មហាសន្និបាត ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧ អនុលោមតាមមាត្រា ២៧.១)។
292. សូមមើលមាត្រា ៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ។
293. ការផាត់ចេញភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម សមាគមទប់ស្កាត់ការធ្វើទារុណកម្ម៖ https://cti2024.org/wp-content/uploads/2021/01/CTI-Exclusionary_Rule_Tool_8-2020_FINAL_.pdf។
294. Ibid

- ផាត់ចេញរាល់ចម្លើយសារភាពរបស់អ្នកដែលមិនមែនជាមន្ត្រីតុលាការ ឬដោយគ្មានវត្តមានមេធាវីរបស់ជនជាប់ឃុំ
- ផាត់ចេញភស្តុតាងពីការសួរចម្លើយដែលមិនត្រូវបានកត់ត្រា ឬថតវីដេអូ
- ហាមឃាត់ការគ្របមុខ ឬការយកក្រណាត់ចងបិទភ្នែកក្នុងពេលសួរចម្លើយ
- ធានាសិទ្ធិប្រឆាំងនឹងការចោទប្រកាន់ខ្លួនឯង និងធានាថា ជនជាប់ចោទបានដឹងពីសិទ្ធិរបស់ខ្លួន
- កំណត់នីតិវិធីច្បាស់លាស់ដើម្បីធ្វើតេស្តចម្លើយសារភាពរកសញ្ញានៃការធ្វើទារុណកម្ម។

ក្នុងករណីអំពើហិង្សាដោយដៃគូស្និទ្ធស្នាល ជនរងគ្រោះអាចមានចំណងផ្លូវចិត្តជាមួយជនបង្កដែលរងការចោទប្រកាន់ ជាលក្ខណៈបុគ្គល ឬបណ្តាលមកពីតួនាទីជាឪពុក/ម្តាយ ឬ អាណាព្យាបាលរបស់កុមារ។ ក្នុងករណីទាំងនេះការប្រព្រឹត្តមិនសមស្របលើជនបង្កដែលរងការចោទប្រកាន់ដោយនគរបាលឆ្លើយតបអាចធ្វើឱ្យជនរងគ្រោះលែងនិយាយស្តី និងមិនសហការជាមួយនគរបាលឬស្វែងរកការការពារខ្លួនក្នុងករណីដែលជនបង្កប្រព្រឹត្តបទល្មើសជាថ្មី។

## សមត្ថភាពគ្រប់គ្រងសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រផ្តល់ការគាំទ្រ និងជំនួយសម្រាប់បទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី

បទពិសោធន៍ពីគំរូរបស់ប្រទេសអូទ្រីស សម្រាប់អន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ[295] បង្ហាញថា ការពឹងផ្អែកលើច្បាប់តែម្យ៉ាងមិនទាន់អាចផ្តល់ការគាំទ្រនិងជំនួយដល់ស្ត្រីប្រកបដោយប្រសិទ្ធភាពបានឡើយ។ អ្នកជំនាញគូសបញ្ជាក់ថាជាញឹកញាប់លទ្ធភាពទទួលបានវិធានការច្បាប់គឺជាការលំបាកសម្រាប់ជនរងគ្រោះជាច្រើនហើយចាំបាច់ត្រូវមានការគាំទ្រយ៉ាងច្រើនដើម្បីឱ្យពួកគេអាចប្រឆាំងតបនឹងដៃគូហិង្សា ឬផ្តាច់ទំនាក់ទំនងពីជនបង្កដែលរងការចោទប្រកាន់។

ការពឹងផ្អែកផ្នែកសេដ្ឋកិច្ចគឺជាកត្តាប្រឈមក្នុងករណីជាច្រើន ព្រោះស្ត្រីដែលមានការពឹងផ្អែកផ្នែកសេដ្ឋកិច្ចលើជនបំពាន ឬជនបង្ក ដើម្បីទទួលបានលំនៅដ្ឋាន ជម្រកសុវត្ថិភាពប្រាក់កាក់។ល។សម្រាប់ខ្លួនឯងនិងកូនៗនៅតែប្រឈមនឹងការរំលោភបំពាន។

"ការស្តាប់យ៉ាងយកចិត្តទុកដាក់ គឺជាវិធីនៃការស្តាប់ និងការឆ្លើយតបនឹងបុគ្គលម្នាក់ដែលបង្កើនការយល់ពីគ្នាទៅវិញទៅមក។ វាជាជំហានដំបូងដ៏សំខាន់ក្នុងការសម្រាលស្ថានការ និងស្វែងរកដំណោះស្រាយបញ្ហា។"

តើអ្វីជាការស្តាប់យ៉ាងយកចិត្តទុកដាក់? (វិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក)

ក្នុងកាលៈទេសៈទាំងនេះ នគរបាលគួរមានសមត្ថភាពកំណត់រកភាពស្មុគស្មាញ និងកែសម្រួលការឆ្លើយតបរបស់ខ្លួនឱ្យសមស្របទៅនឹងស្ថានការណ៍ និងក្រោមការសម្របសម្រួលជាមួយសេវាសង្គម។ សមត្ថភាពដ៏សំខាន់មួយក្នុងការផ្តល់ជំនួយដោយនគរបាលដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺសមត្ថភាពស្តាប់យ៉ាងយកចិត្តទុកដាក់ក្នុងគោលបំណងផ្តល់សេវាក្រោមកិច្ចសហការជាមួយស្ថាប័នផ្សេងទៀត និងផ្អែកតាមតម្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះ។

ករណីនីមួយៗគឺខុសគ្នា។ មិនមែនស្ត្រី និងក្មេងស្រីគ្រប់រូបសុទ្ធតែមានការយល់ឃើញដូចគ្នាចំពោះនគរបាលនោះទេ ហើយក៏មិនមែនស្ត្រី និងក្មេងស្រីគ្រប់រូបឆ្លងកាត់ភាពងាយរងគ្រោះតាមរបៀបដូចគ្នាដែរ។ ម្យ៉ាងវិញទៀតមិនមែនស្ត្រី និងក្មេងស្រីគ្រប់រូបមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការជួបជាមួយ និងទុកចិត្តនគរបាលនោះទេ។

នៅប្រទេសនេប៉ាល់ UN Women សង្កេតឃើញថាជាទូទៅជនរងគ្រោះចង់ទទួលបានការគាំទ្រដំបូង និងដំបូន្មានលើការដោះស្រាយឧប្បត្តិហេតុអំពើហិង្សាដែលប្រព្រឹត្តលើពួកគេពីគ្រួសារ និង/ឬសមាជិកសហគមន៍[296] ។ ក្នុង

295. សូមមើល ឯកសារអ្នកជំនាញរបស់ Rosa Logar ដែលបង្ហាញក្នុងកិច្ចប្រជុំក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិ ៖ "អំពើហិង្សាលើស្ត្រី ៖ ការអនុវត្តល្អក្នុងការប្រយុទ្ធប្រឆាំង និងលុបបំបាត់អំពើហិង្សាលើស្ត្រី ទីក្រុងវីយែន ថ្ងៃទី ១៧-២០ ខែ ឧសភា ឆ្នាំ ២០០៥។
296. របាយការណ៍វាយតម្លៃនៅពេលបញ្ចប់គម្រោង "ការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ស្រុកក្នុងប្រទេសនេប៉ាល់" (ខែ សីហា ឆ្នាំ ២០០៩-ខែ កក្កដា ឆ្នាំ ២០១៣) គាំទ្រដោយ Trust Fund របស់អង្គការសហប្រជាជាតិដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី។
297. Ibid

ករណីទាំងនេះ ជាទូទៅគឺសមាជិកសហគមន៍ប្រមូលផ្តុំគ្នា និងព្យាយាមដោះស្រាយបញ្ហាដោយខ្លួនឯង មុននឹងដាក់ឱ្យអាជ្ញាធរមូលដ្ឋានជួយដោះស្រាយ។

យោងតាមUNWomenប្រចាំនៅនេប៉ាល់ ទាល់តែបញ្ហានេះទាមទារការគិតគូរហ្មត់ចត់ទើបសមាជិកសហគមន៍ផ្តល់យោបល់ និងជួយដល់ជនរងគ្រោះក្នុងការស្វែងរកដំណោះស្រាយផ្លូវការ។ នៅពេលជនរងគ្រោះយល់ថាគាត់មិនទទួលបានដំណោះស្រាយគ្រប់គ្រាន់ពីក្រុមក្រៅផ្លូវការទាំងនេះ គាត់នឹងទៅជួបនគរបាលដោយផ្ទាល់[297]។

នៅពេលរៀបចំផ្តល់ជំនួយក្នុងសេណារីយ៉ូមួយនគរបាលគួរពិចារណាយ៉ាងប្រុងប្រយ័ត្នពីរបៀបដែលសហគមន៍របស់ជនរងគ្រោះនឹងឆ្លើយតបចំពោះជនរងគ្រោះ នៅពេលដែលពួកគេស្វែងរកជម្រើសផ្សេងៗ។ ដូចគ្នានេះដែរនគរបាលគួរពិចារណាពីតួនាទីវិជ្ជមានយូរអង្វែងរបស់សហគមន៍ជនរងគ្រោះនៅពេលរៀបចំវិធានការគាំទ្រ និងផ្តល់ជំនួយ (ដោយពិចារណាពីហានិភ័យគ្រោះថ្នាក់ចំពោះពួកគេក្នុងដំណើរការនេះ)។

**ភាពងាយរងគ្រោះរបស់ជនរងគ្រោះអាចរួមផ្សំដោយបញ្ហានានា ដូចជា អនក្ខរភាព ពិការភាពមួយ ឬច្រើនស្ថានភាពជាជនចំណាកស្រុក(ស្របច្បាប់ ឬខុសច្បាប់) និងឧបសគ្គផ្នែកភាសា ជរាភាព ឬកុមារភាព។**

គន្លឹះក្នុងការដាក់បញ្ចូលតួនាទីរបស់សហគមន៍ក្នុងការគាំទ្រនិងជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរសម្រេចដោយជនរងគ្រោះផ្ទាល់ តាមរយៈការចូលរួមរបស់គាត់ក្នុងដំណើរការស៊ើបអង្កេតប្រកបដោយអត្ថន័យពិតប្រាកដ។

ដើម្បីជួយដល់នគរបាលក្នុងការគាំទ្រ និងជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ខាងក្រោមនេះជាកម្រងសមត្ថភាពផ្នែកឥរិយាបថដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាងនៅពេលបង្កើតក្រុមដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ ក្នុងដំណើរការស៊ើបអង្កេត។

> "ការត្រួតពិនិត្យដោយប្រសិទ្ធភាពដើរតួនាទីសំខាន់ក្នុងការធានាការឆ្លើយតបគ្រប់ ជ្រុងជ្រោយ និងការស៊ើបអង្កេតការប្រទូស្តកេរខ្មាស"។
>
> សមាគមអន្តរជាតិនៃស្នងការនគរបាល (២០១៥)

មិនខុសពីជំពូកមុនៗនោះទេ សមត្ថភាពមួយចំនួនខាងក្រោមត្រូវបានដកស្រង់ចេញពី ស្តង់ដារ និងបទដ្ឋានពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ដូចជា យុទ្ធសាស្ត្រគំរូបច្ចុប្បន្នភាព (២០១០) និង សេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច (១៩៨៥)។ សមត្ថភាពខាងក្រោមបំពេញបន្ថែម និងពង្រឹងគោលនយោបាយរបស់ស្ថាប័ននគរបាលជាតិស្តីពីគុណតម្លៃក្រមសីលធម៌ និងសុចរិតភាព។ អ្នកគ្រប់គ្រងគួរធានាថាមន្ត្រីឆ្លើយតបអាចអនុវត្តចំណុចខាងក្រោម។

### ភាពអាចរកបាន

- ធានាថាជនរងគ្រោះទទួលបានរបាយការណ៍ដែលអាចជួយឱ្យពួកគេទទួលបានដីកាការពារ ដំណោះស្រាយរដ្ឋប្បវេណី ញត្តិអន្តោរប្រវេសន៍ អត្ថប្រយោជន៍ធានារ៉ាប់រង និងការទាមទារសំណងជំងឺចិត្ត។

### ទំនាក់ទំនងនិងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា

- លើកទឹកចិត្តនិងជួយដល់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ក្នុងការរៀបចំ និងដាក់បណ្តឹងផ្លូវការតាមរយៈការផ្តល់ការការពារនិងការណែនាំដល់ពួកគេថាការទទួលខុសត្រូវលើការស្វែងរកបទចោទប្រកាន់និងផ្តន្ទាទោសជនបង្ក ជាបន្ទុករបស់នគរបាល និងស្ថាប័នអយ្យការ។
- ផ្តល់ព័ត៌មានពាក់ព័ន្ធដល់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សាស្តីពីសិទ្ធិដំណោះស្រាយ និងសេវាគាំទ្រជនរងគ្រោះនិងរបៀបទទួលបានសេវាទាំងនោះ ក្រៅពីព័ត៌មានស្តីពីតួនាទី និងឱកាសរបស់ពួកគេក្នុងការចូលរួមក្នុងកិច្ចដំណើរការ នីតិវិធីព្រហ្មទណ្ឌ និងការកំណត់រយៈពេល វឌ្ឍនភាព និងការអនុវត្តកិច្ចដំណើរ

ការនីតិវិធី ក៏ដូចជា ដីកាប្រឆាំងនឹងជនល្មើស។

- ផ្សព្វផ្សាយ និងពង្រឹងបទដ្ឋានដែលកំណត់ថា មន្ត្រី និង/ឬអ្នកស៊ើបអង្កេតនឹងមិនតម្រូវឱ្យជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស ប្រើប្រាស់តេស្តប៉ូលីក្រាហ្វ ឬឧបករណ៍ប្រាប់ការពិតផ្សេងទៀតឡើយ។

## ភាពអាចសម្របតាមបាន

- ទទួលស្គាល់ថាកុមារដែលជាសាក្សីនៃអំពើហិង្សាលើឪពុក/ម្តាយឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយកុមារនោះ ក៏ជាជនរងគ្រោះដោយសារអំពើហិង្សា និងត្រូវការការការពារ ការយកចិត្តទុកដាក់ និងការគាំទ្រផងដែរ។
- បញ្ចៀសនិងបន្ធូបង្អាក់មិនឱ្យអ្នកដទៃដាក់ទោសជនរងគ្រោះដែលត្រូវបានជួញដូរ សម្រាប់ការចូលមកក្នុងប្រទេសមួយដោយខុសច្បាប់ ឬសម្រាប់ការពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់ដែលពួកគេត្រូវបានបង្ខំឱ្យធ្វើ។
- ពិចារណាពីសិទ្ធិរបស់ជនដែលត្រូវបានចោទប្រកាន់ពីបទអំពើហិង្សា និងតម្រូវការគាំទ្ររបស់ពួកគេ ដោយយល់ថា វិធានការការពារជនរងគ្រោះនឹងមានប្រសិទ្ធភាពខ្ពស់ ប្រសិនបើមានការពិចារណាដូច្នេះ[298]។

ការណែនាំប្រកបដោយប្រសិទ្ធភាពដើរតួនាទីយ៉ាងសំខាន់ក្នុងធានានូវការឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងការស៊ើបអង្កេតលើការបំពានផ្លូវភេទ។

## ភាពសមស្រប

- ចាត់វិធានការសមស្របដើម្បីទប់ស្កាត់ការលំបាកក្នុងពេលកំណត់រកមុខសញ្ញា ស៊ើបអង្កេត និងក្នុងដំណើរការកាត់ទោសសំដៅធានាថាជនរងគោះទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរ ដោយមិនគិតថាតើពួកគេចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬយ៉ាងណានោះទេ។

- កំណត់រកពេលដែលស្ត្រីឬក្មេងស្រីអាចមិនដឹងច្បាស់ពីសិទ្ធិស្របច្បាប់របស់ពួកគេ និងផ្តល់ជំនួយតាមរយៈការសម្រួលលទ្ធភាពទទួលបានសេវាជំនួយផ្លូវច្បាប់ដែលអាចជួយបង្កើនសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេជាពិសេសនៅពេលជនរងគ្រោះត្រូវការជំនួយក្នុងការស្វែងរក និងទទួលបានដីកាតុលាការដើម្បីទប់ស្កាត់ជនបង្ក។
- ដឹងពីទំនៀមទម្លាប់ជាក់លាក់របស់សហគមន៍មូលដ្ឋាន។ ផ្តោតអាទិភាពលើការវាយតម្លៃហានិភ័យសុវត្ថិភាព និងការរៀបចំផែនការសុវត្ថិភាព
- ធានាថា វិធានការទប់ស្កាត់ជនបង្កដែលរងការចោទប្រកាន់និងយកពួកគេចេញពីផ្ទះមានការរៀបចំបន្ថែមទៀតដើម្បីធានាថា ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនត្រូវបានទុកចោលដោយគ្មានជម្រកឬជំនួយ។

## ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- មានលទ្ធភាពទទួលបានសេវា និងវិធានការបន្ថែម ដូចជាជម្រក និងកន្លែងស្នាក់នៅដែលមានសុវត្ថិភាព រួមទាំងជម្រកនិងកន្លែងស្នាក់នៅដែលផ្តល់/គ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល អង្គការជនពិការ អង្គការស្ត្រីឬអង្គការសាសនានិងតួអង្គសង្គមស៊ីវិលផ្សេងទៀត។

## ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់

- បន្តធ្វើការដោយរក្សាព័ត៌មានដែលទទួលបានជាការសម្ងាត់ (ឧ. កំណត់ត្រាឌីជីថល រូបថត និងរបាយការណ៍ដែលពាក់ព័ន្ធនឹងជនរងគ្រោះ សាក្សី និងជនល្មើសទាំងអស់) លុះត្រាតែជាលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹងក្នុងការបំពេញភារកិច្ច ឬតម្រូវការយុត្តិធម៌។
- ផ្តល់វិធានការការពារឯកជនភាព និងការរក្សាការសម្ងាត់សម្រាប់ជនរងគ្រោះ និងសាក្សីគ្រប់រូប រួមទាំងកុមារ និងស្ត្រី និងក្មេងស្រីមានពិការភាព ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តនិងទប់ស្កាត់ការរងគ្រោះបន្ថែមទៀត។

298. អនុសាសន៍ជាក់លាក់ពីគោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស និងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គ បណ្តុះបណ្តាល(សមាគមអន្តរជាតិនៃស្នងការនគរបាល ២០១៥) ៖ https://www.theiacp.org/resources/sexual-assault-response-policy-and-training-content-guidelines។

ប្រអប់ ៣

**នៅពេលអ្វីៗចំណើរការល្អ ៖**

**រាល់សកម្មភាពដែលនគរបាលលើកឡើង សុទ្ធតែមានប្រសិទ្ធភាព**

ក្នុងការអង្កេតដែលឧបត្ថម្ភដោយការិយាល័យសេវានគរបាលដែលផ្តោតការយកចិត្តទុកដាក់លើសហគមន៍នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (២០០៦) *ដែលមានគោលបំណងប្រមូលទិន្នន័យបែបពណ៌នាពីនាយកដ្ឋាននគរបាលនៅជុំវិញសហរដ្ឋអាមេរិក ដែលបានសហការជាមួយសហគមន៍ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ធាតុផ្សំសំខាន់ៗនៃការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាក្នុងគ្រួសារត្រូវបានកត់សម្គាល់ដូចខាងក្រោម ៖

- ចាត់ទុកអំពើហិង្សាក្នុងគ្រួសារជាបទល្មើសដូចជាឆ្លើយតបយ៉ាងហ្មត់ចត់ក្នុងការស៊ើបអង្កេត (ការអនុវត្តល្អក្នុងការប្រមូលភស្តុតាង) និងធ្វើការចាប់ខ្លួន
- មានឆន្ទៈសហការជាមួយសហគមន៍ក្នុងការដោះស្រាយបញ្ហាជាមួយគ្នា។ ភាពជាដៃគូទាំងនេះអាចរួមបញ្ចូលការខិតខំធ្វើអន្តរាគមន៍តាំងពីដំបូងជាមួយសាលារៀន អ្នកផ្តល់ជម្រកសុវត្ថិភាព និងស្ថាប័នពិគ្រោះយោបល់។ ភាពជាដៃគូជាមួយស្ថាប័នសហគមន៍ និងអ្នកស្ម័គ្រចិត្តគឺត្រូវការជាចាំបាច់ ព្រោះស្ថាប័នអនុវត្តន៍ច្បាប់មិនអាចដោះស្រាយបញ្ហានេះតែម្នាក់បានឡើយ។ ភាពជាដៃគូជាមួយការិយាល័យរដ្ឋអាជ្ញាថ្នាក់ស្រុក និងតុលាការក៏សំខាន់ផងដែរ។
- ផ្តោតលើ និងគិតគូរពីជនរងគ្រោះ និងស្ថានភាពរបស់ពួកគេ។ មន្ត្រីត្រូវយកចិត្តទុកដាក់លើស្ថានភាពនេះ និងបង្ហាញសមានចិត្ត និងក្តីមេត្តាចំពោះជនរងគ្រោះ។ ការផ្តោតសំខាន់លើជនរងគ្រោះក៏រួមបញ្ចូលការផ្តោតលើសុវត្ថិភាពរបស់ពួកគេផងដែរ។
- អភិវឌ្ឍចំណេះដឹងគ្រប់គ្រាន់ស្តីពីឫសគល់នៃអំពើហិង្សាក្នុងគ្រួសាររបៀបដែលអំពើហិង្សាក្នុងទំនាក់ទំនងកើតឡើងដដែលៗ និងមូលហេតុដែលដៃគូមួយចំនួនមិនងាយចាកចេញពីទំនាក់ទំនងបែបបំពាននេះ។ ចំណេះដឹងនេះអាចគូសបញ្ជាក់ពីភាពចាំបាច់នៃការចាប់ខ្លួនក៏ដូចជាភាពស្មុគស្មាញនៃមូលហេតុដែលការចាប់ខ្លួនអាចមិនមែនជាការឆ្លើយតបដែលមានប្រសិទ្ធភាពបំផុតរហូតនោះទេ។
- ផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការបង្ហាញជម្រើសនានាដល់ជនរងគ្រោះ។ នេះជាចំណុចសំខាន់ ព្រោះវាអាចឱ្យជនរងគ្រោះដឹងថាមានការចាត់វិធានការ និងដឹងថា គាត់មានជម្រើស។
- ផ្តោតសំខាន់លើការបញ្ចុះបញ្ចូលមន្ត្រីអំពីគុណតម្លៃនៃគោលនយោបាយ និងនីតិវិធីដែលពួកគេប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ។

*ប្រភព ៖ Reuland, M., Schaefer-Morabito, M., Preston, C., Cheney, J. 'Police-Community Partnerships to Address Domestic Violence' (US State Department of Justice Office of Community-Orientated Policing Services, 2006)

## សូចនាករយោងសម្រាប់នគរបាលដែលផ្ដល់សេវាសំខាន់ៗ ៖ ការគាំទ្រ និងជំនួយ

ដូចការពិភាក្សាក្នុងជំពូកមុនៗដែរ កញ្ចប់សេវាសំខាន់ៗស្មើឱ្យសេវាយុត្តិធម៌ និងសេវា គាំទ្រទាំងអស់សម្រាប់ជនរងគ្រោះ មានលក្ខណៈទូទៅ និងមានសកម្មភាពរួមដើម្បីជានាលទ្ធផលបាន ជាអតិបរមា។ លក្ខណៈទូទៅនិងសកម្មភាពរួមទាំងនេះអាចអនុវត្តបានដោយមិនគិតពី"វិស័យ"ជាក់លាក់ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីនិងក្មេងស្រីដែលកំពុងរងគ្រោះដោយអំពើហិង្សា។ ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅ និងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗ និងផ្ដល់ឧទាហរណ៍នៃសូចនាករយោងសម្រាប់នគរបាល នៅពេលនគរបាលខិតខំបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីឱ្យធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ តាមរយៈការផ្ដល់ព័ត៌មានដល់ពួកគេស្ដីពីសិទ្ធិនិងជម្រើសយុត្តិធម៌តាមរបៀបដែលជាក់ស្ដែង សុក្រឹតអាចទទួលបាន និងគ្រប់ជ្រុងជ្រោយ។ ទាំងនេះជាសូចនាករដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង ប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មានអ្នកគ្រប់គ្រងជាន់ខ្ពស់អាចពិចារណាបញ្ចូលសូចនាករទាំងនេះ។

១. **ភាពអាចរកបាន និងភាពអាចទទួលបាន** ៖ ការអង្កេតមន្ត្រីនគរបាលស្ដីពី ចំណេះដឹងរបស់ពួកគេពាក់ព័ន្ធនឹងប្រព័ន្ធគាំទ្រសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងប៉ុស្តិ៍ប្រចាំការរបស់ពួកគេ។ ការអង្កេតគួរធ្វើឡើងពីរដងក្នុងមួយឆ្នាំដោយក្រុមពហុវិស័យ ដូចជា ធនធានមនុស្ស ការបណ្ដុះបណ្ដាល និងអប់រំ និងមន្ត្រីអធិការកិច្ច។

២. **ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន** ៖ ចំនួនកិច្ចសហការរួមជាមួយស្ថាប័ននៅមូលដ្ឋាន និង/ឬអង្គការមិនមែនរដ្ឋាភិបាលតាមមូលដ្ឋានដែលផ្ដល់ការគាំទ្រ និងជំនួយដល់ស្ត្រី និងក្មេងស្រីដែលមានទំនាស់ជាមួយច្បាប់។ចំណុចនេះគួររួមបញ្ចូលស្ថាប័នដែលធ្វើការលើបញ្ហានៃការជួញដូរមនុស្សការកេងប្រវ័ញ្ចផ្លូវភេទ ការរត់ពន្ធមនុស្ស និងសេវាពន្ធនាគារ និងការព្យួរទោសដោយមានលក្ខខណ្ឌ។ សូចនាករនេះមានគោលបំណងផ្ដល់ព័ត៌មានស្ដីពីចំនួនឱកាសសម្រាប់នគរបាលក្នុងការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវនៅពេលកែសម្រួលការគាំទ្រ និងជំនួយទៅតាមតម្រូវការរបស់ជនរងគ្រោះក្នុងស្ថានភាពដែលអាចមានហានិភ័យខ្ពស់។

៣. **ភាពសមស្រប និងទំនាក់ទំនង និងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា** ៖ ទិន្នន័យដែលគូសបញ្ជាក់ពីចំនួនមធ្យមនៃការស្ទួរចម្លើយ (រួមទាំងចម្លើយ) ឬសំណើសុំព័ត៌មានពីជនរងគ្រោះទាំងទិន្នន័យផ្ទាល់ខ្លួននិងការរៀបរាប់ឧប្បត្តិហេតុដោយសមាជិកនៃអង្គភាពនគរបាលឬប៉ុស្តិ៍នគរបាលតែមួយ សម្រាប់ករណីនីមួយៗនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលត្រូវបានរាយការណ៍។ ព័ត៌មានទាំងនេះគួរបែងចែកតាមភេទ សម្រាប់ទាំងជនរងគ្រោះ និងមន្ត្រីនគរបាលអន្តរាគមន៍។ ព័ត៌មានទាំងនេះគួរផ្ដល់ចំណេះដឹងស្ដីពីប្រសិទ្ធភាពនៃសកម្មភាពស្ទួរចម្លើយរបស់នគរបាល រួមទាំង ហានិភ័យនៃការរងគ្រោះលើកទីពីរ ជាពិសេសនៅពេលចាត់ទុកអត្តសញ្ញាណរបស់ជនរងគ្រោះជាអថេរមួយ[299]។

៤. **ផ្ដោតអាទិភាពលើសុវត្ថិភាព** ៖ ភាគរយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងករណីដែលត្រូវបានរាយការណ៍ទៅនគរបាលប៉ុស្តិ៍ដែលបានទទួលការចុះជួបបន្ថែមឬស្ថិតក្នុងទំនាក់ទំនងតាមដានបន្តផ្ទាល់ជាមួយនគរបាលដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពសុវត្ថិភាពរបស់ពួកគេ។ ព័ត៌មានទាំងនេះ គួររួមបញ្ចូលវិធានការសុវត្ថិភាពទៅតាមការវាយតម្លៃហានិភ័យដោយនគរបាលអន្តរាគមន៍ ក្នុងទំនាក់ទំនងផ្សេងៗជាមួយជនរងគ្រោះ។ សម្រាប់សូចនាករយោងនេះ ការសំខាន់គឺត្រូវកត់សម្គាល់ឱកាសដែលនគរបាលផ្ដល់ព័ត៌មានគ្រប់គ្រាន់ដល់ជនរងគ្រោះស្ដីពីស្ថានភាពជាក់ស្ដែងនៃករណីរបស់គាត់ និងស្ថានភាពរបស់ជនបង្កដែលរងការចោទប្រកាន់។

៥. **ការផ្ដល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់** ៖ ភាគរយឬផលធៀបករណីដែលអ្នកស៊ើបអង្កេតនៅប៉ុស្តិ៍នគរបាល ស្វែងរកការគាំទ្ររបស់សហគមន៍ ដូចជាអ្នកដឹកនាំសាសនា អង្គការស្ត្រី និងអង្គការជនពិការដើម្បីជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទទៅតាមសំណើរបស់ពួកគេ។ គួរពិចារណាពីចំនួននេះធៀបនឹងចំនួនករណីអំពើហិង្សាផ្លូវភេទលើស្ត្រី និង

ក្មេងស្រីដែលត្រូវបានរាយការណ៍ ដែលសំណើនេះត្រូវបានដាក់ជូនប៉ុន្តែត្រូវបានបដិសេធដោយជនរងគ្រោះ។ ការបញ្ជូនសារថា ពួកគេជាសមាជិក និងត្រូវបានទទួលយកក្នុងសហគមន៍អាចជាជំហានដ៏សំខាន់មួយក្នុងការព្យាបាលជនរងគ្រោះ និងចាប់ផ្តើមនិយាយ និងលាតត្រដាងអ្វីដែលពួកគេបានស៊ូទ្រាំ[300]។ សូចនាករនេះផ្តល់ចំណេះដឹងអំពីតួនាទីរបស់នគរបាល(ដោយសហការជាមួយសហគមន៍និងជាពិសេសជាមួយស្ត្រីដែលជាអ្នកដឹកនាំសហគមន៍) ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

៦. **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន ៖** ការពិនិត្យឡើងវិញប្រចាំឆ្នាំលើការគ្រប់គ្រងសំណុំរឿងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនៅកម្រិតប៉ុស្តិ៍នគរបាល។ ការពិនិត្យឡើងវិញនេះផ្តោតលើគុណភាពនិងបរិមាណនៃព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងការរក្សាការសម្ងាត់។ការពិនិត្យឡើងវិញនេះគួររួមបញ្ចូលការសម្របសម្រួលការប្រមូលភស្តុតាងការសាកសួរជនរងគ្រោះ និងសាក្សី ការតាមដានបន្ត ការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនបង្ក។ ការពិនិត្យឡើងវិញនេះគួរផ្តល់ការយល់ដឹងស្តីពីបញ្ហាជាក់ស្តែង ដែលលើកឡើងពីបញ្ហាគ្រប់គ្រងពេលវេលា ដូចជា "ភាពជិនណាយរបស់អ្នកស៊ើបអង្កេត"សង្គតិភាពនៃការវាយតម្លៃរបស់អ្នកគ្រប់គ្រង និងភាពប្រជុំប្រសងគ្នាទៅនឹងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត។



**ប្រអប់ ៤**

**គន្លឹះសម្រាប់អ្នកគ្រប់គ្រងក្នុងជួរនគរបាលដែលត្រួតពិនិត្យការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី**

ក្នុងគោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាសនិងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គបណ្តុះបណ្តាល(២០១៥)*សមាគមអន្តរជាតិនៃស្នងការនគរបាលផ្តល់ការណែនាំសម្រាប់ធានាការអនុលោមតាមគោលនយោបាយរបស់នាយកដ្ឋាន និងការទទួលខុសត្រូវចំពោះបញ្ហារបស់ជនបង្ក និងការឆ្លើយតបសមស្របពីសំណាក់មន្ត្រីថ្នាក់ក្រោម។ មន្ត្រីត្រួតពិនិត្យគួរ ៖

- ប្រសិនបើមានការស្នើសុំដោយមន្ត្រី ឬនៅពេលចាត់ទុកថាចាំបាច់ ឆ្លើយតបដើម្បីជួយដល់មន្ត្រីដែលស៊ើបអង្កេតឧប្បត្តិហេតុប្រទូស្តកេរខ្មាស
- មន្ត្រីត្រូវឆ្លើយតបប្រកបដោយសត្យានុម័ត វិជ្ជាជីវៈ និងគ្មានការវិនិច្ឆ័យ។ មន្ត្រីត្រួតពិនិត្យត្រូវធានាថា មន្ត្រីថ្នាក់ក្រោមបានដឹងពីក្តីរំពឹងទុកទាំងនេះ។
- ជួយកំណត់រកទាំងធនធានស្ថាប័ននិងធនធានសហគមន៍ដើម្បីធ្វើការស៊ើបអង្កេតដោយប្រសិទ្ធភាពលើករណីប្រទូស្តរាយដែលបានកើតឡើង។
- លើកទឹកចិត្តឱ្យមានភាពជាដៃគូក្នុងការដោះស្រាយបញ្ហារវាងនាយកដ្ឋាន(នគរបាល)និងអង្គការក្នុងសហគមន៍ ដូចជា មជ្ឈមណ្ឌលដោះស្រាយវិបត្តិដោយសារការរំលោភសេពសន្ថវៈ និងកម្មវិធីត្រួតពិនិត្យកោសលវិច័យ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងផ្តល់ការគាំទ្រល្អប្រសើរដល់ជនរងគ្រោះ។
- ពិនិត្យឡើងវិញលើរបាយការណ៍ទាំងអស់របស់នគរបាលស្តីពីការប្រទូស្តកេរខ្មាស ដើម្បីធានាសុក្រឹតភាព ភាពស៊ីសង្វាក់គ្នា និងការឆ្លើយតបដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ
- លើកទឹកចិត្តឱ្យមន្ត្រីស្វែងរកបទល្មើសដែលកើតឡើងជាមួយគ្នា និងពាក់ព័ន្ធគ្នា នៅពេលឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស

299. ដូចការកត់សម្គាល់ក្នុងជំពូកទី ៤ (ទំនាក់ទំនងដំបូង) ការវិភាគទិន្នន័យដែលប្រមូលបានពីអន្តរាគមន៍របស់នគរបាលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនគួរសន្មតថា ការសួរចម្លើយជនរងគ្រោះឡើងវិញគឺជាការរងគ្រោះលើកទីពីរនោះទេ។ UNHCHR (២០១៨) កត់សម្គាល់ថានៅពេលសួរចម្លើយយ៉ាងរលូនដំណើរការនេះអាចផ្តល់ការព្យាបាលនិងបង្កើនភាពអង់អាច។ សូមមើលបន្ថែមទៀត "ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត"(ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ទីក្រុងញូវយ៉ក និងហ្សឺណែវ ២០១៨)។

300. យោងតាម UNHCHR (២០១៨) ក្នុងករណីខ្លះ អ្នកដឹកនាំបែបប្រពៃណី និងអ្នកដឹកនាំជំនឿអាចគាំទ្រជនរងគ្រោះជាស្ត្រីដែលមិនបានរៀបការនៅពេលមានបទល្មើសដែលរងការចោទប្រកាន់ តាមរយៈការផ្តល់ឱកាសដែលពួកគេនៅតែអាចរៀបការទៅតាមបំណង ហើយសម្រាប់ស្ត្រីដែលរៀបការហើយ នៅពេលប្រឈមនឹងអំពើហិង្សា ពួកគេច្រើនតែត្រូវបានទទួលយក និងគាំទ្រដោយស្វាមី និងគ្រួសារពន្លាតរបស់ពួកគេ។ សូមមើលឧទាហរណ៍ស្តីពីផលប៉ះពាល់នៃការជំរុញការចូលរួមរបស់សហគមន៍ក្នុងដំណើរការផ្តល់ការគាំទ្រ និងជំនួយក្នុង "ពួកគេមកដើម្បីបំផ្លាញ" ៖ បទល្មើសរបស់ ISIS ប្រឆាំងនឹង Yazidis។ របៀបវារៈនៃកិច្ចប្រជុំលើកទី ៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ចំណុចទី ៤ ស្ថានភាពសិទ្ធិមនុស្ស (A/HRC/32/CRP.2 Advance Version Distribution, 2016)។

- ជានាថា មន្ត្រី និងអ្នកស៊ើបអង្កេតយល់ពីការដាក់កូដករណី និងអាចដាក់កូដករណីប្រទូស្តកេរខ្មាសបានសមស្រប
- ពិនិត្យឡើងវិញក្រោយការបញ្ចប់សកម្មភាព និងធ្វើសវនកម្មករណីប្រទូស្តកេរខ្មាសដើម្បីធានាថា មន្ត្រី និងអ្នកស៊ើបអង្កេតអនុវត្តការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះនិងផ្តោតលើជនបង្ក
- បង្កើតឱកាសបណ្តុះបណ្តាលជាបន្តបន្ទាប់សម្រាប់សមាជិកនាយកដ្ឋាន ដើម្បីបង្កើនជំនាញចាំបាច់ក្នុងការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាសឱ្យបានសមស្រប
- ខិតខំបង្កើនទំនាក់ទំនងរវាងមន្ត្រីអនុវត្តន៍ច្បាប់ និងអយ្យការដើម្បីសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ ចាប់ពីដំណាក់កាលស៊ើបអង្កេតរហូតដល់ដំណាក់កាលកាត់ទោស
- ដាក់បញ្ចូលបញ្ហាសេវារបស់ជនរងគ្រោះ និងការឆ្លើយតបទៅនឹងជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសក្នុងការវាយតម្លៃការអនុវត្តការងារ និងផ្តល់រង្វាន់ និងដំឡើងតំណែងរបស់សមាជិកនាយកដ្ឋាន
- រក្សាការទទួលខុសត្រូវរបស់សមាជិកនៅពេលពួកគេប្រព្រឹត្ត តាមរបៀបដែលមិនស៊ីសង្វាក់គ្នានឹងគុណតម្លៃ និងបេសកកម្មរបស់នាយកដ្ឋានពាក់ព័ន្ធនឹងការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាស
- ផ្តល់ឱ្យជនរងគ្រោះនូវព័ត៌មានជាប្រចាំអំពីសេវានានា នៅពេលចុះវត្តមាន និងប្រជុំពិភាក្សាជាមួយបុគ្គលិកមុនពេលចាប់ផ្តើមសកម្មភាព។ ការអប់រំ និងបណ្តុះបណ្តាលនេះគួរធ្វើឡើងជាប្រចាំ និងអាចធ្វើឡើងតាមមូលដ្ឋានជាមួយមន្ត្រីដែលមិនឆ្លើយតបនឹងការអំពាវនាវរកសេវា
- ទទួលស្គាល់ និងលើកទឹកចិត្តមន្ត្រីដែលផ្តល់សេវាមានប្រសិទ្ធភាពដល់ជនរងគ្រោះ។

*ប្រភព ៖ គោលនយោបាយស្តីពីការឆ្លើយតបទៅនឹងការប្រទូស្តកេរខ្មាស និងគោលការណ៍ណែនាំស្តីពីខ្លឹមសារវគ្គបណ្តុះបណ្តាល (សមាគមអន្តរជាតិនៃស្នងការនគរបាល ២០១៥)

៧. **ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល៖**ចំនួនក្នុងមួយឆ្នាំៗនៃករណីដែលមានសកម្មភាពសម្របសម្រួលជាមួយស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងៗ និងអ្នកផ្តល់សេវាសំខាន់ៗដែលពាក់ព័ន្ធក្នុងកម្មវិធីការពារសាក្សីដែលទាក់ទិននឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំនួននេះគួរតែត្រូវគ្នានឹងចំនួនករណីដែលនគរបាលឆ្លើយតប និង/ឬអ្នកផ្តល់សេវាសំខាន់ៗ ចាត់ទុកថាមានហានិភ័យខ្ពស់នៃការបង្កអំពើហិង្សាបន្ថែមទៀត។ ការពិនិត្យឡើងវិញ បែបគុណភាពលើករណីទាំងនេះគួរខិតខំផ្ទៀងផ្ទាត់ថាតើជំនាញផ្នែកសុខុមាលភាពកុមារ លំនៅដ្ឋានសង្គម សេវាពន្ធនាគារ និងការគ្រប់គ្រងព្រំដែន។ល។ ត្រូវបាននគរបាលយកមកប្រើប្រាស់នៅពេលវេលាសមស្រប ឬទេ។

## ករណីសិក្សាទី ១ ៖ ការគាំទ្រ និងជំនួយ មជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស (SARC) ទីក្រុង Burgas ប្រទេសប៊ុលហ្គារី

ដោយ Alison Eaton[301] (អធិការស៊ើបអង្កេត DCI បច្ចុប្បន្ន ជាមន្ត្រីចូលនិវត្តន៍)



សិក្ខាសាលា SARC នៅប៊ុលហ្គារី រូបថតទទួលបានពី Alison Eaton



រូបថតទទួលបានពី Alison Eaton ដំណាក់កាលដំបូងនៃ SARC នៅប្រទេសប៊ុលហ្គារី

ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅទីក្រុង Sofia ប្រទេសប៊ុលហ្គារី បានសហការជាមួយសមាគមអង្គការមិនមែនរដ្ឋាភិបាល Demetra និងទទួលបានការគាំទ្រពីសាលាក្រុង Burgas នគរបាលតំបន់ Burgas រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងតំបន់ និងមន្ទីរពេទ្យរដ្ឋនៅ Burgas ដើម្បីបង្កើតSARCដែលយកលំនាំតាមចក្រភពអង់គ្លេសដែលចាប់តាំងពីពេលនោះមកបានរួមចំណែកយ៉ាងច្រើនដល់ការគាំទ្រនិងការផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ និងការប្រទូស្តកេរខ្មាសក្នុងដែនដីនេះ។

គម្រោងនេះត្រូវបានផ្តួចផ្តើមឡើងនៅឆ្នាំ ២០១៣ ក្នុងគោលបំណងអភិវឌ្ឍ SARC ឱ្យផ្តល់ជំនួយវេជ្ជសាស្ត្រ ការគាំទ្រ និងជំនួយនៅពេលមានវិបត្តិដល់ជនរងគ្រោះ ក្នុងពេលស៊ើបអង្កេតនិងកាត់ទោសករណីអំពើហិង្សាផ្លូវភេទ។ គំនិតផ្តួចផ្តើមនេះចាប់ផ្តើមពីសិក្ខាសាលារវាងស្ថានទូតចក្រភពអង់គ្លេសនិងនគរបាលប៊ុលហ្គារីស្តីពី"ការធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស"។ សិក្ខាសាលានេះរួមមានបទបង្ហាញស្តីពីគំរូ SARC របស់ចក្រភពអង់គ្លេស ដោយអធិការស៊ើបអង្កេត Alison Eaton ដែលជាអ្នកជំនាញ និងទីប្រឹក្សាលើប្រធានបទស្តីពីនគរបាលចក្រភពអង់គ្លេស។ នគរបាលប៊ុលហ្គារី និង Demetra បានចូលរួមក្នុងសន្និសីទ និងចាប់អារម្មណ៍លើការរៀបចំសិក្ខាសាលាមួយសម្រាប់បុគ្គលិកគាំទ្រសេវាសំខាន់ៗនៅប៊ុលហ្គារី ដើម្បីកសាងការយល់ដឹងអំពីគំរូនេះ។

នៅឆ្នាំ ២០១៤ ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅប៊ុលហ្គារី ដែលគាំទ្រដោយ Alison Eaton បានរៀបចំការដំណើរទស្សនៈរបស់មន្ត្រីក្រសួងមហាផ្ទៃពីនាក់ទៅកាន់មជ្ឈមណ្ឌល Saturn, SARC នៅSussex ចក្រភពអង់គ្លេស។ នៅឆ្នាំ ២០១៥ សិក្ខាសាលមួយស្តីពី SARC ត្រូវបានរៀបចំឡើងនៅប៊ុលហ្គារី ពាក់ព័ន្ធនឹងសេវាសំខាន់ៗក្នុងគោលបំណងបង្កើត SARC ជាលើកដំបូងនៅ Burgas ប្រទេសប៊ុលហ្គារី។ Vslena SARC ត្រូវបានបើកជាផ្លូវការនៅខែ កក្កដា ឆ្នាំ ២០១៦។

ចាប់តាំងពីការបើក SARC ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅប៊ុលហ្គារី បានបន្តផ្តល់ការគាំទ្រដល់នគរបាលនិងដៃគូតាមមូលដ្ឋានដោយរៀបចំសិក្ខាសាលានិងកម្មវិធីបណ្តុះបណ្តាលជាច្រើនសម្រាប់នគរបាល អយ្យការ និងស្ថាប័នដៃគូផ្សេងទៀត។បទពិសោធន៍នេះបានបង្ហាញពីរបៀបដែលនគរបាលនិងដៃគូសហការគ្នាដោយជោគជ័យ។ គណៈគ្រប់គ្រង SARC ក៏ត្រូវបានបង្កើតឡើងផងដែរ។

---

301. Alison Eaton ជាអតីតអធិការស៊ើបអង្កេតដែលបំពេញតួនាទីក្នុងកងកម្លាំងនគរបាល Sussex អស់រយៈពេល ៣០ ឆ្នាំមកហើយ។ លោកស្រីមានតួនាទីជាមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ (SIO) ដែលមានឯកទេសក្នុងការធានាសុវត្ថិភាព និងស៊ើបអង្កេតអំពើហិង្សា និងការរំលោភបំពានក្នុងគ្រួសារការរំលោភបំពានកុមារនិងអំពើរំលោភសេពសន្ថវៈ/អំពើហិង្សាផ្លូវភេទ។ ក្រៅពីនេះ លោកស្រីធ្លាប់ធ្វើការជាមួយនាយកដ្ឋានកិច្ចការផ្ទៃក្នុង (ចក្រភពអង់គ្លេស) ដើម្បីផ្តល់ការណែនាំដល់ស្ថាប័នចម្រុះនៅថ្នាក់ជាតិសម្រាប់ដំណើរការពិនិត្យឡើងវិញលើករណីមនុស្សឃាតក្នុងស្រុក (DHR)។ លោកស្រីបន្តធ្វើការជាមួយស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅប៊ុលហ្គារី ដើម្បីពង្រីកការផ្តល់ SARC និងកំពុងគាំទ្រដល់ប្រទេសរូម៉ានី អ៊ុយហ្គង់ដា និងប៉េរូក្នុងគម្រោងស្រដៀងគ្នា។

SARC “Vselena” មានវត្តមានក្នុងមន្ទីរពេទ្យធំជាងគេនៅ Burgas។

‘Vselena’ SARC ជាកន្លែងសុវត្ថិភាពដែលជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសអាចចូលមក និងនិយាយប្រកបដោយទំនុកចិត្តអំពីបទពិសោធន៍របស់ខ្លួននិងទទួលបានការថែទាំចាំបាច់បំផុត ការគាំទ្រ និងការយល់ដឹងពីអ្នកជំនាញ ដើម្បីជួយដល់ការស្តារឡើងវិញ ក៏ដូចបង្កើនការស៊ើបអង្កេត និងការកាត់ទោសបទល្មើសទាំងនេះ។ សេវានេះគាំទ្រដល់ជនរងគ្រោះនៅប៊ុលហ្គារីផ្ទាល់និងមកពីប្រទេសផ្សេងទៀត។

ក្រោយការបើក Vselena SARC ដៃគូកាន់តែច្រើនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភិវឌ្ឍន៍ SARC បន្ថែមទៀត។ ដៃគូរួមមានការិយាល័យអយ្យការថ្នាក់ស្រុកនៅ Burgas សាលាក្រុង Sozoplo សាលាក្រុង Karnobat សាលាក្រុងPomorieសាលាក្រុងNessebarនិងសាលាក្រុង Primorsko។

## និរន្តរភាព ភាពម្ចាស់ការក្នុងមូលដ្ឋាន និងការត្រួតពិនិត្យ

ភាពជោគជ័យនៃ‘Vselena’SARCបានទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅទូទាំងប្រទេសប៊ុលហ្គារី និងត្រូវបានពង្រីកដល់ប្រទេសរូម៉ានី។ សន្និសីទប្រកបដោយផ្លែផ្កាចំនួនពីរត្រូវបានរៀបចំឡើងនៅខែ តុលា ឆ្នាំ ២០១៨ នៅ Burgas និង Plovidiv ដោយផ្តោតសំខាន់លើការទប់ស្កាត់ ការការពារ និងការជំនុំជម្រះករណីអំពើហិង្សផ្លូវភេទ ដើម្បីបង្កើនការផ្តល់ SARC នៅទូទាំងប្រទេសទាំងពីរ។

ពាក់ព័ន្ធនឹងការផ្តល់មូលនិធិ ដំបូងឡើយ តំបន់ Burgas បានផ្តល់ហិរញ្ញប្បទានដល់ SARC។ ទោះជាយ៉ាងណាដៃគូកាន់តែច្រើនបានចូលរួមសហការ ចាប់ពីការិយាល័យអយ្យការថ្នាក់ស្រុក រហូតដល់សាលាក្រុងផ្សេងៗ។

SARC នៅ Burgas បានឆ្លងកាត់ការត្រួតពិនិត្យការធានាគុណភាព ៣លើក ដែលដឹកនាំដោយ Alison Eaton ដោយប្រើប្រាស់ឧបករណ៍សវនកម្ម SARC ចក្រភពអង់គ្លេស។ គណៈគ្រប់គ្រង SARC បានធ្វើការពិនិត្យឡើងវិញប្រចាំឆ្នាំលើ SARC។



ដំណាក់កាលដំបូងនៃ SARC នៅប្រទេសប៊ុលហ្គារី ៖ រូបថតទទួលបានពី Alison Eaton

## ដំបូន្មាន និងការណែនាំស្តីពីការបង្កើត SARC

### ទីតាំង

ការសំខាន់គឺត្រូវចាត់ទុក SARC ជាគោលគំនិត ជាជាងអគារមួយ។

- SARCផ្តល់អត្ថប្រយោជន៍នៅពេលស្ថិតក្នុងមន្ទីរពេទ្យ និងអគារសុខាភិបាលផ្សេងទៀត (ឧ. ដាក់បញ្ចូលក្នុងសេវាសុខភាពផ្លូវភេទ)។

### ការចេញចូល SARC

- សញ្ញាខាងក្រៅ និងខាងក្នុងគួរបង្ហាញឱ្យបានច្បាស់ (ពិចារណាពីភាសាផ្សេងៗ)
- គួរមានផែនទី SARC ក្នុងបណ្តាញអ៊ីនធឺណិត និងសម្រាប់ការតាមផ្ញើអ៊ីមែល
- ចំណតសម្រាប់នគរបាល បុគ្គលិក និងជនរងគ្រោះគួរនៅជិត មានសញ្ញាសម្គាល់ និងបើក ២៤ ម៉ោង/៧ ថ្ងៃ
- កន្លែងចេញចូលគួរមានអនាម័យនិងភ្លើងបំភ្លឺគ្រប់គ្រាន់
- កណ្តឹងនៅច្រកចូលដែលភ្ជាប់ជាមួយនឹងប្រព័ន្ធវីដេអូ/កាមេរ៉ាសុវត្ថិភាពនឹងសម្រួលលទ្ធភាពចេញចូលរបស់ជនរងគ្រោះ ក៏ដូចជា ធានាសន្តិសុខរបស់បុគ្គលិកនៅពេលយប់។

### បរិវេណអគារ

- ច្រកចូល SARC គួរត្រូវបានរឹតត្បិត ដូចជាមានផ្ទាំងចុច ឬកាតអូស
- SARC គួរមានបន្ទប់យ៉ាងតិចមួយ ឬច្រើនសម្រាប់ការពិនិត្យកោសលវិច្ច័យ និងអាចមានកន្លែងតាមដានបន្ត
- បង្កើនឯកជនភាពដោយផ្តល់លទ្ធភាពចេញចូលផ្ទាល់ក្នុងSARCជាជាងត្រូវឆ្លងកាត់បរិវេណអគារផ្សេងទៀត

- សន្តិសុខក្នុងបរិវេណអគារ និងបុគ្គលិកសន្តិសុខជាផ្នែកដ៏សំខាន់នៃការរៀបចំផែនការ SARC ដូចជាប្រព័ន្ធប្រកាសអាសន្ន។

### ហេដ្ឋារចនាសម្ព័ន្ធ SARC គួររួមបញ្ចូល ៖

- កន្លែងទទួលភ្ញៀវ
- បន្ទប់រង់ចាំការធ្វើកោសលវិច័យ
- បន្ទប់ពិនិត្យវេជ្ជសាស្ត្រកោសលវិច័យ
- បង្គន់អនាម័យ និងបន្ទប់ទឹក
- បន្ទប់សម្ភាសន៍សម្រាប់នគរបាល។

### កន្លែងតាមដានបន្ត

- អាចធ្វើការណាត់ជួបនៅពេលពិនិត្យកោសលវិច័យ
- ច្រកចូលមួយដោយឡែកទៅកាន់បន្ទប់តាមដានបន្ត ដើម្បីចៀសវាងនូវការនឹកឃើញបទពិសោធន៍ពីមុនៗ ពាក់ព័ន្ធនឹងការពិនិត្យកោសលវិច័យ។
- កន្លែងតាមដានបន្តគួរមាន ៖
  - កន្លែងទទួលភ្ញៀវ
  - កន្លែងរង់ចាំដែលមានកៅអីអង្គុយផ្តល់ផាសុកភាព
  - បន្ទប់ពិគ្រោះយោបល់
  - បន្ទប់ពិនិត្យ
  - បង្គន់អនាម័យ និងបន្ទប់ទឹក
  - បន្ទប់សម្ភាសន៍សម្រាប់ឱ្យនគរបាល/អ្នកចិត្តវិទ្យា។

### កន្លែងធ្វើកោសលវិច័យ/បូរណភាព

- បន្ទប់រង់ចាំការធ្វើកោសលវិច័យ (កៅអី និងផ្ទៃកម្រាលដែលអាចជូតសម្អាតបាន)
- បន្ទប់ទាំងអស់គួរមានបិទស្លាកសម្គាល់ច្បាស់ពាក់ព័ន្ធនឹងការប្រើប្រាស់ ដូចជា ការពិនិត្យ វេជ្ជសាស្ត្រ បន្ទប់រង់ចាំ បន្ទប់ទឹក
- បន្ទប់កោសលវិច័យគួរមានទ្វារដែលអាចចាក់សោរបាន និងចាក់សោរនៅពេលគ្មានការប្រើប្រាស់ដើម្បីរក្សាបូរណភាពនៃនីតិវិធីសម្អាត
- គួរបិទផ្សាយការជូនដំណឹងដែលមានផ្ទៃការពារ និងអាចដាក់បញ្ញាសបាននៅខាងក្រៅទ្វារបន្ទប់ធ្វើកោសលវិច័យទាំងអស់
- សម្រេចថាតើត្រូវមានទូភ្លាសេក្នុងបន្ទប់វេជ្ជសាស្ត្រដើម្បីរក្សាទុកសំណាក ឬទេ

- ពិធីសារស្តីពីការសម្អាតសម្រាប់ផ្នែកធ្វើកោសលវិច័យ។

### ការកត់ត្រាព័ត៌មានលម្អិតរបស់ជនរងគ្រោះម្នាក់ៗដែលចូលមក SARC

- ត្រូវមានសៀវភៅបញ្ជីទូទៅសម្រាប់ការកត់ត្រាខាងក្រោមនិងបំពេញគ្រប់ពេលដែលទៅកាន់ SARC ៖
  - ចំនួនអ្នកចូលមកម្តងៗ
  - កាលបរិច្ឆេទ និងម៉ោងដែលចូលមកដល់
  - ឈ្មោះ
  - ការសម្ភាសន៍ដោយនគរបាល ដែលបានធ្វើឡើង
  - ការពិនិត្យវេជ្ជសាស្ត្រកោសលវិច័យដែលបានធ្វើឡើង
  - សំណើសុំការសម្អាត
  - ការសម្អាតដែលធ្វើឡើង(ម៉ោងកាលបរិច្ឆេទឈ្មោះ)
  - ស្តុកបន្ថែមដែលត្រូវបានស្នើសុំ
  - ស្តុកដែលត្រូវបានបន្ថែម(ម៉ោងកាលបរិច្ឆេទឈ្មោះ)
- សំណុំឯកសារគោលដែលមានគោលការណ៍ណែនាំស្តីពីពិធីសារសម្អាតការយកក្រណាត់លីនិនដែលប្រឡាក់ចេញពីបន្ទប់ទឹក ការណែនាំអំពីការបោះចោលម្សុល
- ខ្លឹមសារលម្អិតផ្នែកលទ្ធកម្មពាក់ព័ន្ធនឹងការបំពេញស្តុកបន្ទប់វេជ្ជសាស្ត្រ និងសម្ភារបន្ទប់ទឹកឡើងវិញ។

### ការយកចិត្តទុកដាក់លើជនរងគ្រោះ

- ផ្តល់គ្រឿងសំអិតសំអាងខ្លួនដែលប្រើបានតែម្តងដល់ជនរងគ្រោះម្នាក់ៗ ដូចជា ដែលងូតទឹក ថ្នាំដុសធ្មេញ ច្រាសដុះធ្មេញ និងក្រាសសិតសក់
- សម្លៀកបំពាក់ខោអាវក្នុង ស្បែកជើងមួយចំនួនដែលមិនអាចប្រគល់ជូនវិញ ដើម្បីជំនួសឱ្យសម្លៀកបំពាក់ចាស់ដែលត្រូវផ្លាស់ចេញ
- ខិតប័ណ្ណដែលផ្តល់ការណែនាំដល់ជនរងគ្រោះដែលរងគ្រោះដោយការប្រទូស្តកេរខ្មាសដើម្បីបញ្ចូលខ្លឹមសារលម្អិតនៃអង្គការគាំទ្រពាក់ព័ន្ធ។
- ផ្តល់ព័ត៌មានទំនាក់ទំនងរបស់ SARC រួមទាំងឈ្មោះបុគ្គលិកដែលពាក់ព័ន្ធជាមួយជនរងគ្រោះ និងឱសថដែលផ្តល់ជូន
- ផ្តល់ខិតប័ណ្ណស្តីពីមធ្យោបាយពន្យារកំណើតបន្ទាន់ដល់ជនរងគ្រោះ។

**ការរៀបចំបុគ្គលិក**

- ប៉ាន់ប្រមាណចំនួនជនរងគ្រោះដែលត្រូវជួបនៅ SARC ដើម្បីកំណត់ចំនួនបុគ្គលិកដែលត្រូវការចាំបាច់។

**តួនាទីសំខាន់ៗ ៖**

- ប្រធានគ្រប់គ្រង SARC ៖ ពេញម៉ោង
- បុគ្គលិករដ្ឋបាល SARC ៖ ពេញម៉ោង
- បុគ្គលិក/អ្នកចិត្តវិទ្យា/គិលានុបដ្ឋាកសម្រាប់គាំទ្រដល់ជនមានវិបត្តិ ៖ ពេញម៉ោង
- នាយកគ្លីនិក ៖ ពីរថ្ងៃ/សប្តាហ៍
- អ្នកពិនិត្យកោសលវិច័យ (ការស្រាវជ្រាវពីចក្រភពអង់គ្លេសបង្ហាញថា ភាគច្រើននៃជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ ចង់ទទួលការពិនិត្យកោសលវិច័យពីស្ត្រីដូចគ្នា)
- នគរបាល ៖ ទទួលការបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសផ្លូវភេទ
- គណៈគ្រប់គ្រង។

**សមត្ថភាពសំខាន់ៗសម្រាប់បុគ្គលិកគាំទ្រជនមានវិបត្តិ**

- គិលានុបដ្ឋាកដែលមានគុណវុឌ្ឍិ ឬទីប្រឹក្សាសុខភាពដែលមានបទពិសោធន៍ ឬអ្នក ផ្តល់ប្រឹក្សាដែលមានបទពិសោធន៍/គុណវុឌ្ឍិ
- ការយល់ពីតម្រូវការរបស់បុគ្គលម្នាក់ៗដែលរងគ្រោះដោយការប្រទូស្តកេរខ្មាស
- ជំនាញទំនាក់ទំនងល្អ (ផ្ទាល់មាត់ និងសំណេរ)
- សមត្ថភាពធ្វើការក្នុងក្រុមអ្នកជំនាញចម្រុះ។

**តម្រូវការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលស្តីពីបទល្មើសផ្លូវភេទ
- ការបណ្តុះបណ្តាលស្តីពីតុលាការ
- ការបណ្តុះបណ្តាលស្តីពីភស្តុតាងដំបូង
- ការឆ្លើយតបដំបូង
- **នគរបាលនឹងត្រូវការព័ត៌មានច្បាស់លាស់/ការបណ្តុះបណ្តាលស្តីពីការធ្វើការជាមួយ SARC។**

**ទំនាក់ទំនង**

- ទំនាក់ទំនងដែលមានប្រសិទ្ធភាពជាធាតុផ្សំដ៏សំខាន់នៃការដំណើរការ SARC ដោយជោគជ័យ ៖
  - ចាត់តាំងមន្ត្រីទំនាក់ទំនងនគរបាល ដែលអាចដើរតួនាទីជាមន្ត្រីបង្គោលក្នុងទំនាក់ទំនងជាមួយនគរបាល
  - ចាត់តាំងមន្ត្រីទំនាក់ទំនងផ្នែកសុខភាពដែលអាចដើរតួនាទីជាមន្ត្រីបង្គោលក្នុងទំនាក់ទំនងជាមួយអាជ្ញាធរសុខភាព
  - បង្កើតគណៈគ្រប់គ្រងដោយមានសមាជិកពាក់ព័ន្ធមកពីស្ថាប័នចម្រុះ
  - កំណត់ពិធីសារសម្រាប់ការចែករំលែកព័ត៌មាន
  - ត្រូវបង្កើត និងកំណត់គោលនយោបាយប្រតិបត្តិការ និងនីតិវិធីជាក់លាក់។

**សវនកម្ម និងគុណភាព**

- ជានាការធ្វើសវនកម្ម និងផ្ទៀងផ្ទាត់ស្ថិតិធៀបនឹងទិដ្ឋភាពផ្សេងទៀតនៃការផ្តល់សេវានៅ SARC ដូចជា ៖
  - ភាពអាចរកបាននៃការពិនិត្យកោសលវិច័យ
  - ការអង្កេតអំពីការពេញចិត្តរបស់អ្នកប្រើប្រាស់
  - ព័ត៌មានស្តីពីការគ្រប់គ្រង។
- ចំណុចទាំងនេះនឹងផ្តល់ភស្តុតាងស្តីពីប្រសិទ្ធភាពរបស់ SARC និងជួយឱ្យមជ្ឈមណ្ឌលនេះទទួលបានជំនួយមូលនិធិរយៈពេលវែង។

## ករណីសិក្សាទី ២
## មជ្ឈមណ្ឌលគាំពារជនរងគ្រោះ ៖ មាគ៌ាឆ្ពោះទៅរកយុត្តិធម៌នៅប្រទេសបង់ក្លាដេស

ដោយ Shamima Begum PPM, Addl. DIG[302] នគរបាលបង់ក្លាដេស



មជ្ឈមណ្ឌលគាំពារជនរងគ្រោះ រូបថតទទួលបានពីទំព័រ Facebook របស់នគរបាលបង់ក្លាដេស



មជ្ឈមណ្ឌលគាំពារជនរងគ្រោះ ៖ រូបថតទទួលបានពីទំព័រ Facebook របស់នគរបាលបង់ក្លាដេស

អំពើហិង្សាលើស្ត្រីនិងកុមារជាអំពើដែលបង្កអន្តរាយដល់សង្គម។ នៅបង់ក្លាដេស នគរបាលបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបជារួមទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈមជ្ឈមណ្ឌលគាំពារជនរងគ្រោះ (VSC)។ មជ្ឈមណ្ឌលគាំពារជនរងគ្រោះទីមួយត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩ ក្រោមគម្រោងកែទម្រង់នគរបាលរបស់ UNDP និងបានក្លាយជាគំនិតផ្តួចផ្តើមដ៏ថ្មីស្រឡាងសម្រាប់នគរបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅបង់ក្លាដេស។

### ដោយរបៀបណា ?

មជ្ឈមណ្ឌលនេះផ្តោតសំខាន់លើការផ្តល់ការឆ្លើយតបរហ័ស និងការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៍ឡើងវិញ។ មជ្ឈមណ្ឌលនេះមានបុគ្គលិក និងទទួលបានការគាំទ្រទាំងស្រុងពីអ្នកជំនាញជាស្ត្រីដូចជា នគរបាល មេធាវី អ្នកផ្តល់ប្រឹក្សា និងវេជ្ជបណ្ឌិត ក្នុងការផ្តល់ការគាំទ្រចម្រុះ រួមទាំងជម្រកសុវត្ថិភាព ការពិគ្រោះយោបល់ ជំនួយផ្លូវច្បាប់ ការព្យាបាលបន្ទាន់ និងឱសថ។ ក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូចំនួន ១០ មជ្ឈមណ្ឌលនេះផ្តល់ការថែទាំ ២៤ ម៉ោង /ថ្ងៃដល់ស្ត្រី និងកុមារដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

មជ្ឈមណ្ឌលនេះមានមូលដ្ឋានទិន្នន័យដើម្បីការពារស្ត្រី និងកុមារពីការរងគ្រោះឡើងវិញ និងផ្តល់ខ្សែទូរស័ព្ទជំនួយ តំណភ្ជាប់ Facebook ដល់នគរបាលក្រុងដាកា និងគេហទំព័រ www.dmpwsid.gov.bd ដើម្បីគាំទ្រដល់នគរបាលក្នុងការឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពទៅនឹងជនរងគ្រោះ។

ខាងក្រោមនេះជាសកម្មភាពរួមផ្សេងទៀតដែលពាក់ព័ន្ធនឹងនគរបាល និងមជ្ឈមណ្ឌលគាំពារជនរងគ្រោះ ៖

- យុទ្ធនាការក្នុងគ្រឹះស្ថានអប់រំ ដែលលើកទឹកចិត្តឱ្យមានការអភិវឌ្ឍកម្មវិធីយល់ដឹងពីការបៀតបៀនផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីសម្រាប់សិស្ស
- ថ្ងៃបើកឱ្យចូលទស្សនាដោយសេរីនៅប៉ុស្តិ៍នគរបាល
- ការរៀបចំតូបក្នុងពិពណ៌នៅមូលដ្ឋានសម្រាប់ការកសាងការយល់ដឹងជាមួយសហគមន៍
- ការចែកខិតប័ណ្ណ និងកូនសៀវភៅផ្តល់ព័ត៌មាន។

នៅអំឡុងឆ្នាំ ២០០៩-២០១៤ មជ្ឈមណ្ឌលគាំពារជនរងគ្រោះនៃនគរបាលក្រុងដាកា បានផ្តល់ការគាំទ្រដល់ជនរងគ្រោះជាង ៣.០០០ នាក់។

301. Addl DIG ជាស្នងការរងទទួលបន្ទុកការស៊ើបអង្កេតម្នាក់ទៀត។ បច្ចុប្បន្ន Shamima Begum គឺជាអនុប្រធានបណ្តាញនគរបាលជាស្ត្រីបង់ក្លាដេស (BPWN) និងជាអ្នកសម្របសម្រួលតំបន់ ២២ នៃសមាគមនគរបាលជាស្ត្រីអន្តរជាតិ (IAWP)។

## តើសេវាអ្វីខ្លះដែលធ្វើឱ្យមានភាពខុសប្លែក?

មជ្ឈមណ្ឌលនេះទទួលយកស្ត្រីនិងកុមារនិងផ្តល់សេចក្តីថ្លៃថ្នូរនិងការគោរពដល់ពួកគេតាមរយៈការផ្តល់បរិយាកាសសមស្របដែលនគរបាលចុះឈ្មោះរាយការណ៍ពីបណ្តឹងហើយឆ្លើយតបទៅនឹងតម្រូវការបន្ទាន់របស់ពួកគេ។ សំខាន់បំផុតគឺមជ្ឈមណ្ឌលនេះ ៖

- ជួយដល់ "របាយការណ៍ព័ត៌មានបឋម" ដោយផ្តល់ព័ត៌មានដល់ជនរងគ្រោះពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌ ជំនួយវេជ្ជសាស្ត្របន្ទាន់និងក្នុងកាលៈទេសៈសមស្រប សម្របសម្រួលការមកទទួលការព្យាបាលនៅមជ្ឈមណ្ឌលវេជ្ជសាស្ត្រ
- ជួយដល់ដំណើរការស៊ើបអង្កេត ជូនដំណឹងដល់ជនរងគ្រោះអំពីដំណើរការនេះ ដូចជា ផ្តល់ព័ត៌មានតាមទូរស័ព្ទ (ប្រសិនបើចាំបាច់) និងការពិគ្រោះយោបល់ផ្នែកចិត្តសង្គម
- ផ្តល់ការបញ្ជូនទៅអង្គការរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលបានជំនួយរយៈពេលវែង ដូចជា ការស្តារនីតិសម្បទា ជំនួយផ្លូវច្បាប់ ការគាំទ្របន្ថែមផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងគ្រួសារ ដើម្បីបង្ការមិនឱ្យជនរងគ្រោះ រងគ្រោះម្តងហើយម្តងទៀត។

**"ចំណុចដែលមានប្រសិទ្ធភាព" ៖ ជំហានប្រតិសកម្មរបស់ថ្នាក់ដឹកនាំនគរបាលនៃមជ្ឈមណ្ឌលគាំពារជនរងគ្រោះ**

**ការធានាស្ថិរភាពហិរញ្ញវត្ថុ** ៖ អ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងជួរនគរបាលនៃមជ្ឈមណ្ឌលនេះបានបញ្ចុះបញ្ចូលរដ្ឋាភិបាល និងរៀបចំសំណើសុំហិរញ្ញប្បទានដែលត្រូវបានដាក់តាមរយៈបញ្ជាការដ្ឋាននគរបាលក្រុង ដាកា ជូនក្រសួងហិរញ្ញវត្ថុ ដែលនាំឱ្យមានការផ្តល់ជំនួយមូលនិធិពីកញ្ចប់ថវិកាផ្សេងៗរបស់រដ្ឋាភិបាលនិងអាចឱ្យមជ្ឈមណ្ឌលនេះផ្តល់ការព្យាបាលវេជ្ជសាស្ត្រ អាហារ និងសម្លៀកបំពាក់ និងរ៉ាប់រងចំណាយផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងករណី។ជំនួយមូលនិធិបានគាំទ្រដល់ការជ្រើសរើសមន្ត្រីនគរបាលជាស្ត្រីបន្ថែម ដែលបច្ចុប្បន្នពាក់ព័ន្ធក្នុងដំណើរការស៊ើបអង្កេតករណី និងការគ្រប់គ្រងជនរងគ្រោះ។

**បង្កើតយុទ្ធសាស្ត្រច្បាស់លាស់**៖ យុទ្ធសាស្ត្រមួយដែលដាក់ចេញដោយនគរបាលក្រុងដាកាគឺការបង្កើតក្រុមឆ្លើយតបរហ័ស ដែលអាចឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងឧប្បត្តិហេតុ និងផ្តល់ជំនួយ។ ក្រុមនេះមានអធិការរង ជាប្រធានក្រុម និងអធិការរងជំនួយការ និងនគរបាលពីរនាក់សមាជិកក្រុម។ សមាជិកក្រុមទាំងអស់សុទ្ធសឹងជាមន្ត្រីនគរបាលជាស្ត្រី។



មជ្ឈមណ្ឌលគាំពារជនរងគ្រោះ ៖ រូបថតទទួលបានពីទំព័រ Facebook នគរបាលបង់ក្លាដេស

**ធានាការចូលរួមដោយអង្គភាពនគរបាលដែលមានសមត្ថកិច្ច** ៖ ថ្នាក់គ្រប់គ្រងនគរបាលនៃមជ្ឈមណ្ឌលគាំពារជនរងគ្រោះប្រមូលផ្តុំដោយបុគ្គលិកដែលមានជំនាញនិងវិជ្ជាជីវៈសមស្របមកពីអង្គភាពគាំពារជនរងគ្រោះ អង្គភាពស៊ើបអង្កេត និងក្រុមឆ្លើយតបរហ័សដើម្បីជានាការផ្តល់បណ្តុំជំនាញ និងការគាំទ្រចម្រុះដល់ជនរងគ្រោះ។

**ផលប៉ះពាល់របស់មជ្ឈមណ្ឌលគាំពារជនរងគ្រោះ ចាប់តាំងពីឆ្នាំ ២០០៩**

មជ្ឈមណ្ឌលនេះជាគំនិតផ្តួចផ្តើមដ៏ថ្មីស្រឡាងនៅបង់ក្លាដេសក៏ដូចជាតំបន់អាស៊ី ទក្សិណ និងបច្ចុប្បន្នត្រូវបានចាត់ទុកជាការត្រួសត្រាយផ្លូវសម្រាប់ការលើកកម្ពស់លទ្ធភាពការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សា។ ចាប់តាំងពីពេលដែលមជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដំបូងដោយនគរបាលក្រុងដាកា មជ្ឈមណ្ឌលគាំពារចំនួន ៨ ទៀតត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះក្នុងប្រទេសបង់ក្លាដេស។

# ៨

## កំណត់សម្គាល់ និងអំណានបន្ថែម


1 'Participation: Gender, Equity and Human Rights (WHO) at: https://www.who.int/gender-equity-rights/understanding/participation-definition/en/

2 'Good Practices in Supporting Victims of Terrorism within the Criminal Justice Framework' (UNODC, 2015) at: https://www.unodc.org/documents/terrorism/Publications/Good%20practices%20on%20victims/good_practices_victims_E.pdf

3 Updated Model Strategies and Practical Measures on the Elimination of Violence against Women in the Field of Crime Prevention and Criminal Justice (2011, General Assembly resolution 65/228, annex)

4 Essential services Package for Women and Girls subject to Violence: Core Elements and Quality Guidelines (United Nations Joint Global Programme on Essential Services for Women and Girls Subject to Violence, 2015) at: https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

5 Mapping and Analysis of Domestic Legal Remedies to issues of Violence against Women (VAW), (Women's Legal and Human Rights Bureau and UN Women, 2010).

6 Hill Collins, P., 1990. Black Feminist Thought: Knowledge, Consciousness, and the Politics of Empowerment. Routledge, New York; cited in Imkaan and UN Women (2019), the Value of Intersectionality in Understanding Violence against Women and Girls, at: https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339

7 'Abuse of a position of vulnerability and other "means" within the definition of trafficking in persons', Issue Paper (UNODC, 2013), at: https://www.unodc.org/documents/human-trafficking/2012/UNODC_2012_Issue_Paper_-_Abuse_of_a_Position_of_Vulnerability.pdf

8 Declaration of Basic Principles of Justice for Victims of Crime and Abuse of Power (adopted by General Assembly resolution 40/34 of 29 November 1985)

9 Strengthening Crime Prevention and Criminal Justice Response to Violence against Women, (UNODC, 2014).

10 Dowling, C., Morgan, A., Boyd, C., Voce, I., 'Policing Domestic Violence: A Review of the Evidence' (Australian Institute of Criminology, Research Report 13, 2018) at: https://aic.gov.au/file/6650/download?token=CgV__eGo

11 Sexual Assault Response Policy and Training Content Guidelines (The International Association of Chiefs of Police 2015) at: https://www.theiacp.org/sites/default/files/all/i-j/IACP%20Sexual%20Assault%20Response%20Policy%20and%20Training%20Content%20Guidelines.2017.3.23.pdf

12 Lindgren, M and Nikolić-Ristanović, V., (2015), 'Crime Victims: International and Serbian Perspective' (Organization for Security and Cooperation in Europe, Mission to Serbia, Law Enforcement Department), at: https://www.osce.org/serbia/85268?download=true

13 Logar, Rosa, 'The Austrian Model of Intervention in Cases of Domestic Violence', Paper presented at the UN Expert Group Meeting on Violence against women: Good practice in Combating and Eliminating Violence against Women (Vienna, 17–20 May 2005).

14 Reuland, M., Schaefer-Morabito, M., Preston, C., Cheney, J., 2006) 'Police-Community Partnerships to Address Domestic Violence', U.S. Department of Justice Office of Community Oriented Policing Services, at: https://cops.usdoj.gov/RIC/Publications/cops-p091-pub.pdf

15 'The Partnership Wheel - Protect II – Capacity Building in Risk Assessment and Safety Planning to Protect High Risk Victims', (Vienna, 2012), at: http://fileserver.wave-network.org/trainingmanuals/PROTECTII_Risk_Assessment_and_Safety_2012_English.pdf

16 'Research will review support offered to sexual assault victims' (University of Birmingham, 2018) at: https://www.birmingham.ac.uk/university/colleges/mds/news/2018/08/Research-sex-assault-victims-support.aspx

17 Barker, N., Gregware., P.R., Cassidy, M.A., (1999), 'Family Killing Fields: Honor Rationales in the Murder of Women.'

18 'From the Margin to the Centre: Addressing Violence Against Women and Girls: Alternative Bill (Imkaan, October,2018),at: https://829ef90d-0745-49b2-b404-cbea85f15fda.filesusr.com/ugd/2f475d_91a5eb-3394374f24892ca1e1ebfeea2e.pdf

19 The Family Liaison Officer (College of Policing, UK), at: https://profdev.college.police.uk/professional-profile/family-liaison-officer-flo/#role-purpose

20 What is Active Listening? (The United States Institute of Peace) at: https://www.usip.org/public-education/educators/what-active-listening

21 'Basic Principles on the Use of Force and Firearms by Law Enforcement Officials' (adopted by the Eighth UN Congress on the Prevention of Crime and the Treatment of Offenders, Havana, Cuba, 27 August to 7 September 1990).

22 Exclusion of Evidence Obtained through Torture (Association for the Prevention of Torture), at: https://apt.ch/en/evidence-obtained-through-torture/

# ការសម្របសម្រួល ក្នុងចំណោមស្ថាប័នយុត្តិធម៌

“ការសម្របសម្រួលជាគន្លឹះឆ្ពោះទៅរកដំណោះស្រាយលើបញ្ហានេះ ប្រសិនបើការសម្របសម្រួលនេះកៀរគរអង្គការតាមមូលដ្ឋាន អ្នកតស៊ូមតិដើម្បីសិទ្ធិជនរងគ្រោះ អ្នកផ្តល់សេវា និងភ្នាក់ងារនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងវេទិការួមមួយ”។

ទិដ្ឋភាពរួមនៃការអនុវត្តល្អបំផុតជុំវិញពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ (សភាអឺរ៉ុប ២០១៣)។

# គោលបំណងនៃជំពូកទី ៨

**បច្ចុប្បន្ននគរបាលបានផ្តល់សេវាសំខាន់ៗដែលមានគុណភាពប្រកបដោយប្រសិទ្ធភាព ដែលអាចផ្តល់លទ្ធផលល្អបំផុតដល់ជនរងគ្រោះ តាមរយៈការបំពេញស្តង់ដារ និងក្តីរំពឹងទុករបស់ស្ថាប័នយុត្តិធម៌ និងអ្នកផ្តល់សេវាផ្សេងៗតាមបែបប្រតិសកម្ម ក្រោមការឆ្លើយតបដោយមានការសម្របសម្រួល ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងឆ្លើយតបនឹងយេនឌ័រ ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការដាក់បញ្ចូលអ្នកពាក់ព័ន្ធខាងក្រៅក្នុងការត្រួតពិនិត្យកិច្ចសហការលើសេវាសំខាន់ៗ ធានាតម្លាភាព និងភាពស្របច្បាប់។
- ការសម្របសម្រួលអាចជួយបញ្ចៀសភាពត្រួតគ្នាឬការដើរបញ្ច្រាស់គ្នានៃស្ថាប័នយុត្តិធម៌ផ្សេងៗ ឬរាំងស្ទះដល់ស្ថាប័នយុត្តិធម៌ផ្សេងទៀត ក៏ដូចជាកាត់បន្ថយហានិភ័យនៃការរងគ្រោះលើកទីពីរ។
- ព័ត៌មានដែលផ្តល់ជូនជនរងគ្រោះ ត្រូវតែស៊ីសង្វាក់គ្នានៅគ្រប់ស្ថាប័នយុត្តិធម៌ទាំងអស់ ដើម្បីអាចគ្រប់គ្រងក្តីរំពឹងទុករបស់ពួកគេបានដោយប្រសិទ្ធភាព។
- ការរក្សាតុល្យភាពនៃការត្រួតពិនិត្យរបស់អ្នកពាក់ព័ន្ធខាងក្រៅ ក្នុងដំណើរការសម្របសម្រួលការស៊ើបអង្កេតអំពើហិង្សាលើស្ត្រីនិងក្មេងស្រីធៀបនឹងការរក្សាសុចរិតភាពនៃការស៊ើបអង្កេត គឺមានសារៈសំខាន់ណាស់។
- អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត និង/ឬពង្រឹងក្របខណ្ឌត្រួតពិនិត្យសម្រាប់យន្តការសម្របសម្រួល។
- គោលការណ៍ "មិនបង្កគ្រោះថ្នាក់" គួរអនុវត្តក្នុងដំណើរការជ្រើសរើសដៃគូឆ្លើយតបនឹងបទល្មើសព្រោះវាអាចជួយក្នុងការកំណត់ស្ថានភាពរបស់ក្រុម ហើយនិង បដិសេធក្នុងករណីដៃគូក្នុងក្រុមមិនសូវត្រូវបានគេទទួលស្គាល់។



## សេចក្តីផ្តើម

**តាមរយៈភារកិច្ចសំខាន់ៗ និងវត្តមានក្នុងមូលដ្ឋាន នគរបាល និងមន្ត្រីអនុវត្តន៍ច្បាប់ផ្សេងទៀតគឺជាយុត្តិធម៌ជួរមុខសម្រាប់ជនរងគ្រោះដោយសារបទល្មើស និងអំពើហិង្សា។ ទោះបីពួកគេជាតួអង្គលេចធ្លោរក្នុងប្រព័ន្ធយុត្តិធម៌ក្តី ក៏ស្ថាប័ននគរបាលមិនមែន និងមិនគួរជាសេវាតែមួយគត់ដែលជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីអាចយកជាបង្អែកនៅពេលស្វែងរកយុត្តិធម៌នោះទេ។**

រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

ការរក្សាសណ្តាប់ធ្នាប់ និងយុត្តិធម៌ក្នុងមូលដ្ឋានមួយ ដែលនគរបាលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ជាការទទួលខុសត្រូវរបស់រដ្ឋនិងស្ថាប័នផ្សេងៗដែលតំណាងឱ្យវិស័យយុត្តិធម៌ វិស័យសុខាភិបាល និងសុខុមាលភាពសង្គម។ ដូច្នេះស្ថាប័ននគរបាលនិងស្ថាប័នយុត្តិធម៌គួរមានឱកាសដែលផ្តល់កិច្ចសហការនិងយន្តការសម្របសម្រួលជាច្រើនដើម្បីពង្រឹងក្របខណ្ឌទ្រឹស្តីរួមស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលខិតខំដើម្បីផ្តល់លទ្ធផលល្អបំផុតដល់ជនរងគ្រោះ។

ឱកាសនិងយន្តការសម្របសម្រួលទាំងនេះស្តែងឡើងក្នុងរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់តំបន់[303] និងថ្នាក់ក្រុង និងជាធម្មតាផ្អែកតាមក្របខណ្ឌអភិក្រមពហុវិស័យទូលំទូលាយជាមួយតួអង្គនីមួយៗ រួមទាំងនគរបាល ដែលដើរតួនាទីក្រោមការសម្របសម្រួលទៅតាមដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការបន្តផ្តល់យុត្តិធម៌។

តាមធម្មតា ស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត មានពិធីសារឬអនុស្សារណៈយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន និងជួបជាប្រចាំជាមួយស្ថាប័នសន្តិសុខ និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ដើម្បីឱ្យមានភាពបន្សីគ្នាជាយុទ្ធសាស្ត្រតាមរយៈក្រុមប្រឹក្សាឬគណៈកម្មាធិការសន្តិសុខនៅថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់ក្រុង។

ក្នុងនាមជាអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ជាទូទៅឱកាសជានាការរួមចំណែកដល់ការឆ្លើយតបចម្រុះ និងក្រោមការសម្របសម្រួលដែលឆ្លើយតបនឹងយេនឌ័រទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ស្តែងឡើងនៅថ្នាក់ក្រុង និងថ្នាក់សហគមន៍។ វេទិកាដឹកនាំដោយសេវានគរបាលក្នុងសហគមន៍និង/ឬក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន (ក្រុង) ផ្តល់ចំណុចចាប់ផ្តើមជាច្រើននៅកម្រិតនេះ ហើយភាពជោគជ័យរបស់ពួកគេអាស្រ័យលើថាតើ

303. អាស្រ័យលើប្រទេសនីមួយៗ ថ្នាក់ក្រោមជាតិនេះអាចសំដៅលើស្រុក នាយកដ្ឋាន ដែនដីមណ្ឌល ឬខេត្ត។



រូបថតទទួលបានពី UNMIT/Martine Perret (ប្រទេសទីម័រខាងកើត)

នគរបាលមូលដ្ឋានដៃគូនគរបាលក្នុងប្រព័ន្ធ(ការបន្តផ្តល់) យុត្តិធម៌ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន មានការយល់ដឹងជារួមល្អកម្រិតណាអំពីអ្វីដែលជាធាតុផ្សំ និងសកម្មភាពយុទ្ធសាស្ត្រក្នុងការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

តាមរយៈវេទិកាឬក្រុមប្រឹក្សាទាំងនេះហើយដែលនគរបាល និងដៃគូនគរបាលក្នុងប្រព័ន្ធយុត្តិធម៌ អាចស្វែងរកភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធខាងក្រៅដើម្បីពង្រឹងប្រព័ន្ធគាំទ្រតាមបែបប្រតិសកម្ម។ ភាពជាដៃគូទាំងនេះអាចផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀនសូត្រជាសមូហភាពសម្រាប់កិច្ចសហការកាន់តែមានប្រសិទ្ធភាពរវាងអ្នកផ្តល់សេវាសំខាន់ៗ រួមទាំងកិច្ចសហការរវាងនគរបាល និងស្ថាប័នយុត្តិធម៌ផ្សេងទៀត។

តាមរយៈការដាក់បញ្ចូលអ្នកពាក់ព័ន្ធខាងក្រៅក្នុងមូលដ្ឋាន និងអ្នកពាក់ព័ន្ធដែលមានសមត្ថភាពក្នុងការត្រួតពិនិត្យការសម្របសម្រួលសេវាសំខាន់ៗ នគរបាល និងដៃគូក្នុងការបន្តផ្តល់យុត្តិធម៌នឹងផ្តល់តម្លាភាព និងភាពស្របច្បាប់ដ៏ចាំបាច់ដល់ដំណើរការស្មុគស្មាញ និងមាលក្ខណៈបច្ចេកទេសខ្ពស់ដែលជាញឹកញាប់ មិនសូវមានការពិនិត្យឡើងវិញ ការពិនិត្យតាមដាន និងការវាយតម្លៃជាប្រចាំ។

ជំពូកខាងក្រោមមានគោលបំណងផ្តល់ការណែនាំដល់អ្នកគ្រប់គ្រងក្នុងជួរនគរបាលដែលមានតួនាទីសម្របសម្រួលនៅកម្រិតមូលដ្ឋានជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀត ដោយទទួលបានធាតុចូលពីអ្នកពាក់ព័ន្ធក្នុងសហគមន៍ ដើម្បីធានាការផ្តល់សេវាសំខាន់ៗ ដែលឆ្លើយតបនឹងយេនឌ័រប្រកបដោយប្រសិទ្ធភាព។ ការណែនាំនេះនឹងតម្រែតម្រង់ឱ្យអ្នកអានឆ្ពោះទៅរកការអនុវត្តល្អបំផុត ក្នុងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលដែលគ្រប់គ្រងដោយនគរបាលដែលខិតខំសម្រេចបានលទ្ធផលល្អបំផុតសម្រាប់ជនរងគ្រោះ និងបំពេញស្តង់ដារ និងក្តីរំពឹងទុករបស់ស្ថាប័នយុត្តិធម៌ និងអ្នកផ្តល់សេវាផ្សេងៗនៅពេលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ជំពូកនេះនឹងបង្ហាញពីសមត្ថភាព និងជំនាញសំខាន់ៗរបស់នគរបាលក្នុងការចូលរួមនិងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយស្ថាប័នយុត្តិធម៌ និងអ្នកពាក់ព័ន្ធ (ទាំងក្នុង និងក្រៅការបន្តផ្តល់យុត្តិធម៌) ដើម្បីធានាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ជំពូកនេះផ្តោតសំខាន់លើអ្វីដែលនគរបាលអាច និងគួរគ្រប់គ្រងក្នុងការសម្របសម្រួល។ ដូច្នេះ នឹងគ្មានការលើកឡើងពីតួនាទីសម្របសម្រួលរបស់ តួអង្គយុត្តិធម៌ផ្សេងទៀតឡើយប៉ុន្តែតួនាទីនេះនឹងត្រូវបានលើកមកពិភាក្សាលម្អិតក្នុងជំពូកទី ១២ (ការបន្តផ្តល់យុត្តិធម៌)។

ជំពូកនេះនឹងផ្អែកតាមការសន្មតថាមានយន្តការសម្រាប់អភិក្រមដែលមានការសម្របសម្រួលសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី រវាងស្ថាប័នយុត្តិធម៌ក្នុងប្រទេសមួយនៅកម្រិតអភិបាលកិច្ចផ្សេងៗ ដែលស្ថាប័ននីមួយៗមានពិធីសារ និងនីតិវិធីរួចជាស្រេច។

ជំពូកនេះមានផ្នែកស្តីពីការណែនាំឱ្យគ្នាទៅវិញទៅមក ដែលបំពេញបន្ថែមលើឧបករណ៍ថ្នាក់ជាតិ តាមរយៈការពង្រឹងលក្ខណៈទូទៅ និងគោលការណ៍នៃកញ្ចប់សេវាសំខាន់ៗស្តីពីការសម្របសម្រួលក្នុងចំណោមតួអង្គក្នុងវិស័យយុត្តិធម៌។

មិនខុសពីជំពូកមុនៗនោះទេ អ្នកអានគួរអានជំពូកនេះអមជាមួយនឹងផ្នែកទី១១(ការសម្របសម្រួលក្នុងចំណោមតួអង្គក្នុងវិស័យយុត្តិធម៌) នៃម៉ូឌុលទី ៣ ក្នុងកញ្ចប់សេវា

សំខាន់ៗស្តីពីយុត្តិធម៌ និងនគរបាល និងម៉ូឌុលទី ៥ ក្នុងកញ្ចប់សេវាសំខាន់ៗស្តីពីការសម្របសម្រួលនិងការគ្រប់គ្រងការងារសម្របសម្រួល។ ក្រៅពីនេះ អ្នកអានគួរអានជំពូកនេះគួបផ្សំនឹងផែនការគោលរបស់ UNODC ២០១៤៖ ផែនការអនុវត្តន៍សម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី (មានបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយដែលមានចំណងជើងថា ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី)។ គោលការណ៍ណែនាំស្តីពីការដាក់បញ្ចូលអន្តរាគមន៍សម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសកម្មភាពមនុស្សធម៌ (២០១៥) ពីគណៈកម្មាធិការអចិន្ត្រៃយ៍អន្តរស្ថាប័ន[304]ដែលលើកឡើងច្បាស់ពីអភិក្រមផ្អែកតាមសហគមន៍។ ការសិក្សារបស់ UNODC ២០១៥ សម្រាប់ការបង្កើតយន្តការឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាលើស្ត្រីនៅអេហ្ស៊ីប សម្រាប់បទពិសោធន៍ជាសកលក្នុងការរិះរកដំណោះស្រាយដែលមានការសម្របសម្រួលចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី និង UNHCHR ការសិក្សាតាមប្រធានបទស្តីពីបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងពិការភាពសម្រាប់ការណែនាំស្តីពីទិដ្ឋភាពទាំងអស់ ដែលពាក់ព័ន្ធនឹងយុត្តិធម៌សម្រាប់ស្ត្រីមានពិការភាព[305]។

## ការណែនាំគ្នាទៅវិញទៅមក

ការស៊ើបអង្កេតដែលមានប្រសិទ្ធភាពត្រូវមានការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌ដើម្បីបញ្ចៀសកិច្ចខិតខំប្រឹងប្រែងត្រួតគ្នា ឬការធ្វើសកម្មភាពដែលអាចបញ្ច្រាសគ្នា ឬរាំងស្ទះដល់ស្ថាប័នយុត្តិធម៌ផ្សេងទៀត។ ក្រៅពីនេះ ការសម្របសម្រួលជួយជានាអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះក្នុងការស៊ើបអង្កេត ការជំនុំជម្រះ និងការកាត់ទោសបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាកាត់បន្ថយហានិភ័យនៃការរងគ្រោះលើកទីពីរដោយបង្កើនសក្តានុពលនៃការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ។

ប្រសិនបើគ្មានការសម្របសម្រួលរវាងស្ថាប័នយុត្តិធម៌ឬគ្មានការសម្របសម្រួលរឹងមាំក្នុងតំបន់សមត្ថកិច្ចរបស់អ្នកទេនោះអ្នកត្រូវដឹកនាំបង្កើតឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ ការធានាយុត្តិធម៌ជាកិច្ចខិតខំប្រឹងប្រែងជាក្រុម និងគ្មានស្ថាប័នយុត្តិធម៌ណាអាចសម្រេចបានគោលដៅចុងក្រោយនៃការប្រកាន់ខ្ជាប់ច្បាប់និងការផ្តល់យុត្តិធម៌ដែលអាចទទួលបាន មានប្រសិទ្ធភាព និងមិនលម្អៀងដល់ជនរងគ្រោះបានឡើយ ប្រសិនបើស្ថាប័ននីមួយៗមិនខិតខំបំពេញកិច្ចការយ៉ាងយកចិត្តទុកដាក់ មានក្រមសីលធម៌ ផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរ និងសហការគ្នាជាដៃគូ។

ដើម្បីជាការចាប់ផ្តើម អ្នកត្រូវកំណត់អ្នកដែលជាដៃគូស្ថាប័នយុត្តិធម៌របស់អ្នក (អ្នកពាក់ព័ន្ធ) ដូចជា អ្នកតស៊ូមតិផ្លូវច្បាប់ មេធាវី អយ្យការ តុលាការី ចៅក្រម និងក្នុងករណីពាក់ព័ន្ធ ចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ និងអ្នកប្រកាន់ខ្ជាប់ច្បាប់ ឬជំនឿនៅមូលដ្ឋាន។ បន្ទាប់ពីបានកំណត់ អត្តសញ្ញាណអ្នកពាក់ព័ន្ធ អ្នកត្រូវកំណត់ថាតើអ្នកពាក់ព័ន្ធម្នាក់ៗនឹងរួមចំណែកដូចម្តេចដល់ដំណើរការយុត្តិធម៌ អ្វីជាលក្ខខណ្ឌតម្រូវ និងក្តីរំពឹងទុករបស់ពួកគេចំពោះនគរបាល និងអ្វីដែលជាលក្ខខណ្ឌតម្រូវនិងក្តីរំពឹងទុករបស់អ្នកចំពោះពួកគេ។ ជាការល្អគួរប្រមូលផ្តុំតំណាងមកពីស្ថាប័ននីមួយៗឱ្យពិភាក្សាគ្នាពីតួនាទីរបស់

304. "គោលការណ៍ណែនាំស្តីពីការដាក់បញ្ចូលអន្តរាគមន៍សម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសកម្មភាពមនុស្សធម៌ ៖ ការកាត់បន្ថយហានិភ័យ ការលើកកម្ពស់ភាពធន់ និងការជួយដល់ការស្តារឡើងវិញ" (គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរស្ថាប័ន ២០១៥)។

305. "ការសិក្សាតាមប្រធានបទស្តីពីបញ្ហាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងពិការភាពរបាយការណ៍របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ"(A/HRC/20/5 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២)។

ដៃគូនីមួយៗ និងបង្ហាញពីតម្រូវការ ក្តីរំពឹងទុក និងបញ្ហាប្រឈមរបស់ពួកគេ។ ធ្វើដូច្នេះទើបអ្នកអាចបង្កើនកម្រិតយល់ដឹងក្នុងចំណោមស្ថាប័នទាំងនោះ និងផ្តល់វេទិកាសម្រាប់ការកសាងទំនាក់ទំនងបែបសហការ។

៤. ប្រសិនបើអ្នក និងបុគ្គលិករបស់អ្នកយល់ច្បាស់ពីលក្ខខណ្ឌតម្រូវរបស់អយ្យការដើម្បីអាចបង្ហាញករណីដែលមានមូលដ្ឋានគ្រប់គ្រាន់ដល់តុលាការអ្នកប្រហែលជាកាត់បន្ថយចំនួនករណី "ដែលទម្លាក់ចោល" ដោយអយ្យការមុនពេលដែលករណីទាំងនោះត្រូវបានបញ្ជូនទៅតុលាការ។ ដូចគ្នានេះដែរ អយ្យការត្រូវយល់ពីលក្ខខណ្ឌតម្រូវរបស់តុលាការ ដើម្បីទទួលបានការផ្តន្ទាទោសដោយជោគជ័យហើយព័ត៌មានទាំងនេះអាច "បញ្ជូនបន្ត" ទៅអ្នកដើម្បីឱ្យអ្នកអាចប្រជុំពិភាក្សាជាមួយមន្ត្រីរបស់អ្នកបាន។

នៅពេលមានការយល់ដឹងច្រើនអំពីអ្វីជាលក្ខខណ្ឌតម្រូវដើម្បីឈានទៅរកការផ្តន្ទាទោសដោយជោគជ័យនៅតុលាការ មន្ត្រីរបស់អ្នកនឹងអាចកំណត់រក និងទទួលបានភស្តុតាងដ៏ល្អបំផុតយ៉ាងឆាប់រហ័ស។

ដើម្បីយល់ពីក្តីរំពឹងទុករវាងនគរបាល និងសេវាអយ្យការ UN Women បានផ្តល់គន្លឹះល្អៗ និងច្បាស់លាស់ដូចខាងក្រោម។



រូបថតទទួលបានពី UNMIT/Martine Perret (ប្រទេសទីម័រខាងកើត)

**ប្រអប់ ១**

**គន្លឹះខ្លីៗ ៖ ក្តីរំពឹងទុករបស់នគរបាល និងអយ្យការ** [306]

| តួអង្គ | ក្តីរំពឹងទុក |
|---|---|
| នគរបាលរំពឹងថា ការិយាល័យប្រធានអយ្យការសាធារណៈ ៖ | • ផ្តល់ការណែនាំអំពីថាតើមានការព្រាងទម្រង់ចោទប្រកាន់បានសមស្រប ឬទេ<br>• ផ្តល់ការណែនាំអំពីថាតើត្រូវកត់ត្រាអំណះអំណាងបន្ថែម ឬទេ<br>• ផ្តល់ការណែនាំអំពីថាតើត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀត ឬទេ<br>• បង្ហាញកំណត់ត្រាជនបង្ក ជូនតុលាការ<br>• ក្នុងករណីចាំបាច់ជំទាស់ទៅនឹងការដោះលែងជនបង្កដោយបង់ប្រាក់ធានានៅក្រៅឃុំ/បង់ប្រាក់ធានា និងផ្តោតអាទិភាពលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាពិសេសនៅពេលដែលជនរងគ្រោះមានវត្តមាននៅតុលាការ<br>• ត្រួតពិនិត្យសាក្សីក្នុងតុលាការ<br>• សម្រួលដល់ការផ្សារភ្ជាប់ជាមួយស្ថាប័នការពារសាក្សី។ |
| ការិយាល័យប្រធានអយ្យការសាធារណៈរំពឹងថានគរបាលនឹង ៖ | • ធ្វើការស៊ើបអង្កេតសមស្របលើឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី<br>• ចាប់ខ្លួនជនសង្ស័យ<br>• កត់ត្រាចម្លើយគ្រប់ជ្រុងជ្រោយពីជនរងគ្រោះ សាក្សី និងជនសង្ស័យ<br>• អមដំណើរជនរងគ្រោះ និងជនសង្ស័យទៅមន្ទីរពេទ្យ នៅពេលមានការពិនិត្យវេជ្ជសាស្ត្រ<br>• ព្រាងទម្រង់ចោទប្រកាន់ ដោយមានអំណះអំណាង សមស្របស្តីពីបទល្មើស និងខ្លឹមសារពិស្តារនៃបទចោទ<br>• រក្សាការគ្រប់គ្រងវត្ថុតាងឱ្យបានសមស្រប<br>• ប្រមូល និងរក្សាទុកវត្ថុតាងឱ្យបានសមស្រប<br>• បង្ហាញជនសង្ស័យជូនតុលាការ ក្នុងរយៈពេល ២៤ ម៉ោង<br>• បង្ហាញ និងផ្តល់វត្ថុតាងក្នុងតុលាការ<br>• ចងកាតព្វកិច្ច និងបញ្ជូនសាក្សីឱ្យចូលរួមក្នុងសវនាការ<br>• ធ្វើការស៊ើបអង្កេតបន្ថែមក្នុងករណីចាំបាច់<br>• ផ្តល់ការណែនាំលើការកត់ត្រាអំណះអំណាងបន្ថែម<br>• តាមដានជនសង្ស័យ និង/ឬការធានា ក្នុងករណីចាំបាច់<br>• សង្គ្រោះជនរងគ្រោះដែលងាយរងគ្រោះ។ បង្ហាញកំណត់ត្រាពីមុនរបស់ជនសង្ស័យ<br>• បង្ហាញសំណុំរឿងរបស់នគរបាលទៅអយ្យការយ៉ាងតិច ៣ ថ្ងៃមុនថ្ងៃសវនាការ<br>• ផ្តល់សក្ខីកម្មក្នុងតុលាការ<br>• ផ្តល់លិខិតបញ្ជាក់សម្រាប់ប្រើប្រាស់ក្នុងការជំទាស់នឹងពាក្យសុំបង់ប្រាក់ធានានៅក្រៅឃុំ/បង់ប្រាក់ធានា។ |

306. "កញ្ចប់ធនធានស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ៖ ឧបករណ៍បណ្តុះបណ្តាលស្តង់ដារសម្រាប់អ្នកមានភារកិច្ច អ្នកពាក់ព័ន្ធ និងអ្នកមានសិទ្ធិ" (UN Women, ២០១៩) ទំ. ៩២-៩៣។

ការសម្របសម្រួលរវាងស្ថាប័នយុត្តិធម៌ អាចកាត់បន្ថយសក្តានុពលនៃការរងគ្រោះជាលើកទីពីរ តាមរយៈការ

កាត់បន្ថយចំនួនដងដែលជនរងគ្រោះត្រូវប្រាប់រឿងរ៉ាវរបស់គាត់។ ល្អបំផុត ជនរងគ្រោះគួរប្រាប់រឿងរ៉ាវរបស់ខ្លួនតែម្តងបានហើយ។ ការសម្របសម្រួលនឹងកសាងទំនុកចិត្ត និងភាពជឿជាក់របស់ និងរវាងស្ថាប័នយុត្តិធម៌ ដែលនាំទៅរកការចែករំលែកព័ត៌មាន និងចារកម្មកាន់តែច្រើន។ចំណុចនេះអាចឱ្យមានការច្បាមយកទិន្នន័យកាន់តែសុក្រឹត និងផ្តល់ឱកាសទប់ស្កាត់កាន់តែច្រើន។

ដំណើរការវាយតម្លៃហានិភ័យគួរឆ្លងកាត់ការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ។ ប្រសិនបើស្ថាប័ននីមួយៗធ្វើការវាយតម្លៃហានិភ័យរៀងៗខ្លួន នឹងមានលទ្ធភាពកាន់តែច្រើននៃការបាត់ព័ត៌មានសំខាន់ៗ ហើយផែនការសុវត្ថិភាពអាចមានចំណុចខ្វះខាតក្នុងវិធានការកាត់បន្ថយហានិភ័យ។

ការសម្របសម្រួលដោយប្រសិទ្ធភាពអាស្រ័យលើក្របខណ្ឌនៃការអនុវត្តការងារ ដែលត្រូវបានកំណត់យ៉ាងច្បាស់ និងមានតម្លាភាព ដោយមានការទទួលខុសត្រូវរួម និងវិធានការអនុវត្តន៍ការងាររួមដែលត្រូវបានបង្កើតឡើងក្រោមកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់។ ការបំពេញការងារក្រោមការសម្របសម្រួលដូច្នេះតម្រូវឱ្យមានការបង្កើតពិធីសារដែលរៀបរាប់ពីការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗនិងចំណុចប្រសព្វនៃគណនេយ្យភាពរបស់ស្ថាប័ននីមួយៗ និងអ្នកពាក់ព័ន្ធ។
ផ្នែកដ៏សំខាន់មួយនៃរចនាសម្ព័ន្ធ និងដំណើរការសម្របសម្រួល គឺការបំពេញលក្ខខណ្ឌតម្រូវផ្លូវច្បាប់ពាក់ព័ន្ធនឹងឯកជនភាព និងការរក្សាការសម្ងាត់ និងជារួមការធានាថា តម្រូវការរបស់ជនរងគ្រោះនៅតែជាចំណុចស្នូលនៃសូចនាករអនុវត្តន៍ការងារ។ គោលដៅរួម គឺត្រូវសម្រេចបានលទ្ធផលល្អបំផុតសម្រាប់ជនរងគ្រោះមិនថាក្នុងទម្រង់យ៉ាងណានោះទេ។
ក្រោមការសម្របសម្រួលដោយប្រសិទ្ធភាពក្នុងស្ថាប័នយុត្តិធម៌ ព័ត៌មានដែលផ្តល់ជូនជនរងគ្រោះគួរតែស៊ីសង្វាក់គ្នា ដើម្បីកុំឱ្យមានសារលាយឡំគ្នាដែលធ្វើឱ្យភាន់ច្រលំ។ ការគ្រប់គ្រងក្តីរំពឹងទុករបស់ជនរងគ្រោះនិងអ្នកទាំងអស់ដែលពាក់ព័ន្ធក្នុងដំណើរការយុត្តិធម៌នឹងកាន់តែងាយស្រួលនៅពេលមានការសម្របសម្រួលដោយប្រសិទ្ធភាព។

**ការរងគ្រោះលើកទីពីរកើតឡើងមិនមែនដោយសារលទ្ធផលផ្ទាល់នៃពីអំពើហិង្សានោះទេ ប៉ុន្តែតាមរយៈការឆ្លើយតបមិនគ្រប់គ្រាន់របស់ស្ថាប័ន និងបុគ្គលចំពោះជនរងគ្រោះ។**

ការសម្របសម្រួលរវាងស្ថាប័នយុត្តិធម៌ អាចរួមបញ្ចូលបញ្ហាឆ្លងដែនសមត្ថកិច្ចរវាងស្ថាប័ននគរបាល។ ប្រសិនបើជនរងគ្រោះមកជួបអ្នក ឬបុគ្គលិករបស់អ្នកដើម្បីរាយការណ៍ពីឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី ប៉ុន្តែឧប្បត្តិហេតុនោះបានកើតឡើងនៅប៉ុស្តិ៍នគរបាល ស្រុក ឬតំបន់ទទួលខុសត្រូវមួយផ្សេងទៀត អ្នក និងបុគ្គលិករបស់អ្នកគួរតែជាអ្នកជួយជនរងគ្រោះ ហាក់ដូចជាឧប្បត្តិហេតុនោះកើតឡើងក្នុងតំបន់សមត្ថកិច្ចរបស់អ្នកដូច្នោះដែរ។ ការផ្ទេរទិន្នន័យបទល្មើស ឬការស៊ើបអង្កេតគួរតែជាផ្នែកមួយនៃដំណើរការរដ្ឋបាលប៉ុណ្ណោះ ហើយមិនគួរបញ្ជូនជនរងគ្រោះទៅប៉ុស្តិ៍នគរបាល ឬតំបន់មួយផ្សេងទៀតឡើយ ព្រោះវានឹងបន្ថែមការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀតលើជនរងគ្រោះ។ ចំណុចនេះមានន័យស្មើនឹងការរងគ្រោះជាលើកទីពីរ និងមិនបំពេញលក្ខណៈវិនិច្ឆ័យនៃអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ឬ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើមពីការកំណត់គេចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

ជនល្មើសមិនគោរពយុត្តាធិការដែនដីរបស់ស្ថាប័ននគរបាលនីមួយៗឡើយ។ ផ្ទុយទៅវិញ ពួកគេអាចមានចេតនាគេចវេសពីការកំណត់មុខសញ្ញា ដោយធ្វើសកម្មភាពឆ្លងដែន និងទាញប្រយោជន៍ពីចំណុចខ្វះខាតក្នុងដំណើរការស៊ើបអង្កេតនៃការអនុវត្តច្បាប់បែបប្រពៃណី។ ការស៊ើបអង្កេតក្នុងដែនយុត្តាធិការចម្រុះអាចមិនរលូនសូម្បីតែនៅពេលដែលស្ថាប័ននគរបាលមានកិច្ចសហប្រតិបត្តិការរួម និងបណ្តាញទំនាក់ទំនងទូទៅក៏ដោយ ។

ការចែករំលែកព័ត៌មានក្នុងការស៊ើបអង្កេតអំពើហិង្សាក្នុងគ្រួសារ មានមុខងារសំខាន់ៗ ២ ៖

១. ដើម្បីអាចឱ្យមានការពិនិត្យតាមដានដោយប្រសិទ្ធភាពលើឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានដល់ការឆ្លើយតបផ្នែកសេវា និងការបែងចែកធនធាន។

២. ដំណោះស្រាយដែលមានប្រសិទ្ធភាពលើករណីអំពើហិង្សាក្នុងគ្រួសារមួយចំនួន ដែលត្រូវការការឆ្លើយតបបន្ទាន់ពីស្ថាប័នចម្រុះ។

គណៈកម្មការទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌនៃអង្គការសហប្រជាជាតិ(២០០៨)

ដូចការពិពណ៌នាខាងលើ គុណវិបត្តិនៃកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួលដោយអ្នកផ្តល់សេវាសំខាន់ៗ គឺជាប្រភពរួមនៃការរងគ្រោះលើកទីពីរសម្រាប់ជនរងគ្រោះ ព្រោះគេពិបាកប៉ាន់ស្មាន និងគួសបញ្ជាក់ពីការទទួលខុសត្រូវលើភាពបរាជ័យ។

ការសម្របសម្រួលការចែករំលែកព័ត៌មានរវាងនគរបាល និងស្ថាប័នអនុវត្តន៍ច្បាប់ និងស្ថាប័នយុត្តិធម៌ផ្សេងទៀតជាដំណើរការយុទ្ធសាស្ត្រដែលអាចនឹងលំបាកអនុវត្តដោយសារបញ្ហាការិយាល័យធិបតេយ្យ។

បញ្ហាប្រឈមមួយគឺយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់នគរបាលហាក់មើលរំលងដំណើរការសម្របសម្រួលខាងក្រៅ ដោយសារភាពស្មុគស្មាញផ្នែកបច្ចេកទេសក្នុងការសម្របសម្រួលប្រព័ន្ធនានានិងការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងករណី។

ដូច្នេះ អ្នកដែលខាតបង់ខ្លាំងបំផុតដោយសារចំណុចខ្វះខាតក្នុងការសម្របសម្រួលរវាងស្ថាប័ន អនុវត្តន៍ច្បាប់ គឺជនរងគ្រោះដោយសារបទល្មើស និងអំពើហិង្សា ព្រោះពួកគេមិនអាចគ្រប់គ្រងដំណើរការនេះបានហើយការស្តីបន្ទោសត្រូវបានបង្វែរទៅស្ថាប័នមានសមត្ថកិច្ចផ្សេងៗជាជាងការទទួលយកកំហុសជាសមូហភាព។

របៀបដែលនគរបាលសម្របសម្រួលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាមួយតួអង្គវិស័យយុត្តិធម៌ រួមទាំងស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត អាស្រ័យលើក្របខណ្ឌអភិបាលកិច្ចរបស់ប្រទេសមួយ។ នេះក៏ជាការពិតសម្រាប់របៀបគ្រប់គ្រងដំណើរការសម្របសម្រួលនេះដើម្បីកែលម្អគុណភាព និងការអនុវត្តការងារផងដែរ។

ឧ. ក្នុងស្ថាប័ននគរបាល ដូចជា នៅប្រទេសហុងឌូរ៉ាស និងរុស្ស៊ី ដែលមានស្ថាប័ននគរបាលជាន់ខ្ពស់មួយ ការគ្រប់គ្រងគុណភាពនៃការអនុវត្តការងារ រួមទាំងការសម្របសម្រួលជាមួយតួអង្គវិស័យយុត្តិធម៌ខាងក្រៅ ជាបន្ទុករបស់អ្នកគ្រប់គ្រងផ្ទាល់ ដែលជាធម្មតាគ្មានការចែករំលែកហានិភ័យរវាងស្ថាប័នដៃគូដែលមានសមត្ថកិច្ចប្រហាក់ប្រហែលគ្នា[308]។ ដូច្នេះ អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលពឹងផ្អែកលើការគាំទ្រពីសហការី និងថ្នាក់លើដើម្បីធានាការសម្របសម្រួលដោយប្រសិទ្ធផល និងប្រសិទ្ធភាពរវាងអង្គភាពនគរបាល ស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀតអ្នកជំនាញផ្នែកព្រហ្មទណ្ឌស៊ីវិលឬវេជ្ជសាស្ត្រ-ច្បាប់ និងតួអង្គវិស័យយុត្តិធម៌ផ្សេងទៀត។

307. The Honourable Wally T. Oppal,.'FORSAKEN The Report of the Missing Women Commission of Inquiry: VOLUME IIB "Nobodies": How and Why We Failed the Missing and Murdered Women, Parts 3, 4 and 5' (2012).

308. Osse, Anneke, 'Understanding Policing: A Resource for Human Rights Activists', for Amnesty International (2006) at: https://www.amnesty.nl/content/uploads/2017/01/book_1_0.pdf?x30221

ពោលគឺ ប្រសិនបើ គ្មានយន្តការគ្រប់គ្រងគុណភាពសម្រាប់ជាមូលដ្ឋាននៃការសម្របសម្រួល ឬក៏យន្តការទាំងនោះមិនត្រូវបានពិនិត្យឡើងវិញដោយល្អិតល្អន់ និងជាដំណាក់កាលដោយថ្នាក់គ្រប់គ្រងនគរបាលជាន់ខ្ពស់ ទេនោះប្រសិទ្ធផលនិងប្រសិទ្ធភាពនៃការសម្របសម្រួលព័ត៌មាន ឬការឆ្លើយតបជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀតនឹងផ្អែកតាមបុគ្គល ជាជាងផ្អែកតាមស្ថាប័ន។ ចំណុចនេះនាំទៅរកភាពបរាជ័យ ឬចំណុចខ្វះខាតក្នុងការការពារដែលនឹងបង្កអន្តរាយដល់ជនរងគ្រោះដោយសារបទល្មើសនិងអំពើហិង្សាគ្រប់រូបមិនមែនត្រឹមតែជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីនោះទេ។

ក្នុងគំរូសេវានគរបាលបែបវិមជ្ឈការ មានក្តីរំពឹងទុកកាន់តែច្រើនលើនគរបាលក្នុងការបង្កើតទំនាក់ទំនងការងារជាមួយរដ្ឋបាលមូលដ្ឋាន សហគមន៍ និងអ្នកពាក់ព័ន្ធនៅកម្រិតសហគមន៍ផ្សេងទៀតដែលដើរតួនាទីសំខាន់[309] ក្នុងការពង្រឹងការបន្តផ្តល់យុត្តិធម៌ ព្រោះពួកគេខិតខំទប់ស្កាត់ និងស៊ើបអង្កេតបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ តាមទ្រឹស្តី ចំណុចនេះមានន័យថា របៀបសម្របសម្រួលរបស់នគរបាលរួមទាំងការសម្របសម្រួលរវាងស្ថាប័នយុត្តិធម៌ផ្សេងទៀត គួរឆ្លងកាត់ការពិនិត្យពិច័យទូលំទូលាយ។

ដូច្នេះ ការគ្រប់គ្រងគុណភាពនៃប្រព័ន្ធសម្របសម្រួលរបស់នគរបាលអាចផ្អែកតាមប្រភពជាច្រើនអាស្រ័យលើទំនាក់ទំនងរបស់នគរបាលជាមួយអ្នកពាក់ព័ន្ធនៅមូលដ្ឋានដែលជាញឹកញាប់ពាក់ព័ន្ធនឹងអ្នកផ្តល់សេវាសំខាន់ៗ។

ប្រសិនបើនគរបាលមិនបានកសាងទំនាក់ទំនងចាំបាច់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដូចការប្រមាលមើលជារួមក្នុងគំរូសេវានគរបាលបែបវិមជ្ឈការ (ឧ. យុទ្ធសាស្ត្រសេវានគរបាលក្នុងសហគមន៍)ចំណុចខ្វះខាតជាប្រព័ន្ធដែលរាំងស្ទះដល់ការសម្របសម្រួលដោយប្រសិទ្ធផលនិងប្រសិទ្ធភាពជាមួយតួអង្គវិស័យយុត្តិធម៌ផ្សេងទៀតនឹងក្លាយជាការអនុវត្តទូទៅជាជាងការអនុវត្តដាច់ដោយឡែក។

309. អ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋានដែលដើរតួនាទីសំខាន់អាចរួមបញ្ចូលក្រុមហ៊ុនសន្តិសុខឯកជនដែលធ្វើប្រតិបត្តិការក្នុងតំបន់ដែលមិនសូវមានវត្តមានរដ្ឋឬសហគ្រាសអាជីវកម្មឯកជនធំៗដែលជះឥទ្ធិពលយ៉ាងខ្លាំងលើសហគមន៍ ដូចជា ក្រុមហ៊ុនរុករករ៉ែខ្នាតធំ។



រូបថតទទួលបានពី Force International (ប្រទេសបង់ក្លាដេស)

ការរក្សាតុល្យភាពត្រឹមត្រូវរវាងការពង្រីកវិសាលភាពនៃអ្នកពាក់ព័ន្ធនៅមូលដ្ឋាន(រួមទាំងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត)ដែលគួរពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាពនៃដំណើរការសម្របសម្រួលការស៊ើបអង្កេតឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទន្ទឹមនឹងការរក្សាសុចរិតភាពនៃការស៊ើបអង្កេត គឺជាការលំបាក ប៉ុន្តែមានសារៈសំខាន់ណាស់។

នៅពេលរក្សាបានតុល្យភាពនេះ អ្នកគ្រប់គ្រងក្នុងជួរនគរបាលនឹងអាចកាត់បន្ថយហានិភ័យនៃការរងគ្រោះជាលើកទីពីរ នៅពេលជនរងគ្រោះប្រឡូកក្នុងការបន្តផ្តល់យុត្តិធម៌ ក៏ដូចជាបង្កើនភាពលេចធ្លោររបស់នគរបាលក្នុងនាមជាស្ថាប័នអនុវត្តន៍ច្បាប់ស្របច្បាប់។

ខាងក្រោមនេះជាការរៀបរាប់អំពីបរាជ័យក្នុងការសម្របសម្រួលរវាងនគរបាលនិងស្ថាប័នយុត្តិធម៌ផ្សេងទៀតនៅពេលឆ្លើយតបនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចទាំងនេះត្រូវបានដកស្រង់ចេញពី"អ្នកដែលត្រូវបានគេបោះបង់ចោល៖ របាយការណ៍របស់គណៈកម្មការស្រាវជ្រាវរកស្ត្រីដែលបាត់ខ្លួន" ដោយរដ្ឋាភិបាលខេត្ត British Columbia ប្រទេសកាណាដា ដែលពិនិត្យពិច័យលើការឆ្លើយតបក្រោមការសម្របសម្រួលដោយកងកម្លាំងនគរបាល British Columbia ក្នុងករណីស្ត្រីបាត់ខ្លួនដែលជនរងគ្រោះភាគច្រើនជាស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច[310]។

310. The Honourable Wally T. Oppal., 'FORSAKEN: The Report of the Missing Women Commission of Inquiry VOLUME IIB Nobodies: How and Why We Failed the Missing and Murdered Women, Parts 3, 4 and 5' (2012).

ចំណុចខាងក្រោមបំពេញបន្ថែមដោយយោបល់ត្រឡប់ពីការគូសផែនទីជាសកល ស្ដីពីការអនុវត្តល្អ និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលដែលសម្របសម្រួលការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ សង្គមស៊ីវិល និងបុគ្គលិកអង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិ ដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចំណុចខាងក្រោមមានគោលបំណងជួយឱ្យអ្នកគ្រប់គ្រងក្នុងជួរនគរបាលកំណត់រកចំណុចខ្វះខាតសមត្ថភាពឱ្យបានឆាប់រហ័សបំផុត មុនការបង្កគ្រោះថ្នាក់បន្ថែមទៀតលើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចជើងរងនីមួយៗ ជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាននិង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

### ឥរិយាបថ

- ការគ្រប់គ្រងយន្តការសម្របសម្រួលគឺជាបញ្ហាប្រឈមសម្រាប់អ្នកផ្ដល់សេវាសំខាន់ៗព្រោះស្ថាប័ននានាហាក់គេចវេសពីការប្រឈមមុខគ្នាក្នុងករណីមានភាពបរាជ័យ។

### ការរងគ្រោះលើកទីពីរ

- នគរបាលខិតខំធានាថាជនរងគ្រោះនៅតែជាចំណុចស្នូលនៃដំណើរការនេះក្នុងពេលប្រឈមនឹងសម្ពាធដ៏ចម្រូងចម្រាស់ពីដំណើរការការិយាល័យធិបតេយ្យផ្ទៃក្នុង និងលក្ខខណ្ឌតម្រូវរបស់ស្ថាប័នយុត្តិធម៌ផ្សេងទៀត។

### ការអនុវត្តខុសឆ្គង

- កិច្ចខិតខំប្រឹងប្រែងក្រោមការសម្របសម្រួលដោយអ្នកផ្ដល់សេវាសំខាន់ៗ គឺជាញឹកញាប់ផ្ដោតខ្លាំងពេកលើការដាក់ទោសព្រហ្មទណ្ឌដែលនាំឱ្យលែងមានការផ្ដោតលើផលប្រយោជន៍របស់ជនរងគ្រោះ។
- ចំណុចខ្វះខាតក្នុងការសម្របសម្រួលរវាងអយ្យការ និងនគរបាលបង្កផលប៉ះពាល់លើគុណភាពនៃការគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ក្នុងករណីបទល្មើសធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ដូចជា អ្នកបាត់ខ្លួន) ជាទូទៅក្រុមស៊ើបអង្កេតត្រូវបានបង្កើតចេញពីផ្នែកផ្សេងៗនៃស្ថាប័ននគរបាល និងអាចស្ថិតនៅក្រៅបណ្ដាញរាយការណ៍ធម្មតា។ ភាពចាំបាច់នៃការធ្វើរបាយការណ៍ច្បាស់លាស់ និងទំនាក់ទំនងបែបត្រួតពិនិត្យ មានសារៈសំខាន់ណាស់ក្នុងការស៊ើបអង្កេតក្រោមដែនយុត្តាធិការចម្រុះ[311]។
- កង្វះកិច្ចសហប្រតិបត្តិការក្នុងស្ថាប័ននាំទៅរកការភ្លាំងភ្លាត់ក្នុងការគ្រប់គ្រងកំណត់ត្រា កង្វះការពិនិត្យពិច័យលើសំណុំឯកសារសម្រាប់ការតាមដានបន្តលើប្រព័ន្ធវាយតម្លៃហានិភ័យ/រាយការណ៍ ជំហាននៃការស៊ើបអង្កេតដែលមិនត្រូវបានចងក្រងឯកសារដោយស៊ីសង្វាក់គ្នាក្នុងទម្រង់ស្តង់ដារ ដែលបង្កការលំបាកក្នុងដំណើរការពិនិត្យឡើងវិញនិងកង្វះភាពបន្តជាប់គ្នានៃការស៊ើបអង្កេតឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ជាញឹកញាប់ មន្ត្រីសម្របសម្រួល គ្មានរចនាសម្ព័ន្ធរាយការណ៍ និងរបៀបធ្វើទំនាក់ទំនងសមស្រប ដែលបង្កផលអន្តរាយដល់ការស៊ើបអង្កេត។
- អសមត្ថភាពរបស់ស្ថាប័ននគរបាលក្នុងការដោះស្រាយពេញលេញចំពោះបញ្ហាឆ្លងដែន សមត្ថកិច្ច អាចជាបរាជ័យដ៏ធំរបស់នគរបាល ដែលដាក់កំហិតយ៉ាងខ្លាំងលើប្រសិទ្ធភាពនៃការស៊ើបអង្កេត។ជារឿយៗនគរបាលមិនសូវមានលិខិតកិច្ចព្រមព្រៀងជាក់លាក់រវាងកងកម្លាំង ដែលអាចយកមកអនុវត្តបានភ្លាមៗ ប៉ុន្តែច្រើនតែខ្ជះខ្ជាយពេលវេលាស៊ើបអង្កេតលើការសម្រួលការរៀបចំលម្អិតផ្នែករដ្ឋបាលរវាងកងកម្លាំងនានា[312]។
- ទំនាក់ទំនងត្រូវបានកាត់ផ្ដាច់ នៅពេលមានការខ្វែងគំនិតគ្នារវាងអ្នកស៊ើបអង្កេតលើភាពអាចជឿជាក់បានរបស់អ្នកផ្ដល់ព័ត៌មាន[313]។ការចែករំលែកព័ត៌មានច្រើនពេកអាចធ្វើឱ្យជនរងគ្រោះ/សាក្សីប្រឈមនឹងហានិភ័យ។

311. Ibid
312. Ibid
313. Ibid

“ភាគច្រើន ការទទួលខុសត្រូវជាបន្ទុករបស់មេបញ្ជាការក្រុមដែលជាអ្នកមានសមត្ថកិច្ចទទួលខុសត្រូវ (លើក្រុមស៊ើបអង្កេត) ធនធាន (ធនធានមនុស្ស និងធនធានរូបវន្ត) និងអាណត្តិ។ មេបញ្ជាការក្រុមត្រូវផ្តាច់ខ្លួនចេញពីការទទួលខុសត្រូវសំខាន់ៗលើការស៊ើបអង្កេត ដើម្បីអាចគ្រប់គ្រងគំនិតផ្តួចផ្តើមជារួម។ តាមធម្មតា នេះមិនមែនជាបញ្ហាចោទនោះទេហើយជាញឹកញាប់មេបញ្ជាការក្រុមត្រូវពិចារណាពីអាទិភាពចម្រូងចម្រាស់ជាច្រើនផ្សេងទៀតដែលធ្វើឱ្យការគ្រប់គ្រងគុណភាពនៃការសម្របសម្រួលរបស់នគរបាលប្រឈមនឹងហានិភ័យ”។

The Honourable Wally T. Oppal, in ‘FORSAKEN The Report of the Missing Women Commission of Inquiry’ (2012)

## និយមន័យ និងក្របខណ្ឌ

កញ្ចប់សេវាសំខាន់ៗចាត់ទុកការសម្របសម្រួលជាធាតុផ្សំដ៏សំខាន់នៃការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ មានការសម្របសម្រួល ៣ កម្រិតដែលត្រូវបន្សីគ្នានៅពេលជានាការផ្តល់សេវាសំខាន់ៗប្រកបដោយគុណភាព និងប្រសិទ្ធភាព ដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ការសម្របសម្រួលទាំង ៣ កម្រិតនេះលេចឡើងនៅរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់តំបន់/នាយកដ្ឋាន និងថ្នាក់ក្រុង។ កម្រិតនីមួយៗ បង្ហាញពីអាណត្តិខុសៗគ្នានៃស្ថាប័នយុត្តិធម៌នីមួយៗ រួមទាំងសមត្ថភាពត្រួតត្រារបស់ស្ថាប័នអនុវត្តន៍ច្បាប់ (អាស្រ័យលើអំពើហិង្សា និងបទល្មើសដែលបានកំណត់) និងតួនាទីកាន់តែច្រើនរបស់អ្នកពាក់ព័ន្ធដែលអាចជះឥទ្ធិពលលើការឆ្លើយតបដែលមានការសម្របសម្រួល ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

នៅថ្នាក់ជាតិ នគរបាលប្រតិបត្តិការ និងនគរបាលជាន់ខ្ពស់ធ្វើការជាមួយអ្នកពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការឆ្លើយតប ដោយមានការសម្របសម្រួលសេវាសំខាន់ៗសម្រាប់ជនរងគ្រោះ[314] ។ គឺនៅកម្រិតនេះហើយដែលមានការខិតខំស្វែងរកការយល់ដឹងរួមនិងបង្កើតក្របខណ្ឌចិត្តវិទ្យាស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងចំណោមអ្នកផ្តល់សេវាសំខាន់ៗជាលើកដំបូង។

ផ្អែកលើចំណុចនេះ កិច្ចព្រមព្រៀងស្តីពីការចែករំលែកព័ត៌មានត្រូវបានបង្កើតឡើង និង/ឬធ្វើបច្ចុប្បន្នភាពរវាង

**រូប ១ ៖ កម្រិតនៃការសម្របសម្រួលរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ**

| កម្រិតនៃការសម្របសម្រួលរបស់រដ្ឋាភិបាល | ឧទាហរណ៍អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី |
|---|---|
| ថ្នាក់ជាតិ (យុទ្ធសាស្ត្រ) | ក្រសួង/នគរបាល តំណាងគណៈកម្មាធិការ សន្តិសុខជាតិ ជំនួយអន្តររដ្ឋាភិបាល ជំនួយអន្តរជាតិ ស្ថាប័នសិក្សាស្រាវជ្រាវបណ្តាញផ្សព្វផ្សាយ និងការត្រួតពិនិត្យថ្នាក់ជាតិ |
| ថ្នាក់នាយកដ្ឋាន ដែនដី និងតំបន់ (យុទ្ធសាស្ត្រ) | អភិបាលក្រុង ឬចៅហ្វាយខេត្ត ក្រសួង/នគរបាល តំណាងគណៈកម្មាធិការសន្តិសុខតំបន់បណ្តាញផ្សព្វផ្សាយស្ថាប័នរដ្ឋាភិបាលសង្គមស៊ីវិលក្នុងតំបន់ និងសហគ្រាសឯកជនធំៗ |
| ថ្នាក់ក្រុង (យុទ្ធសាស្ត្រ និងប្រតិបត្តិការ) | អភិបាលក្រុង ស្ថាប័នរដ្ឋាភិបាល ក្រុមប្រឹក្សា សន្តិសុខមូលដ្ឋាន សង្គមស៊ីវិល នគរបាលក្រុង (សហគមន៍) តុលាការ អ្នកជំនាញក្នុងមូលដ្ឋានមន្ទីរពេទ្យ/គ្លីនិកមេដឹកនាំសហគមន៍អ្នករៀបចំផែនការទីក្រុងបណ្តាញផ្សព្វផ្សាយ និងអាជីវកម្មនៅមូលដ្ឋាន |

អ្នកផ្តល់សេវាសំខាន់ៗនៅកម្រិតខ្ពស់ រួមទាំងកិច្ចព្រមព្រៀងរវាងតួអង្គអនុវត្តន៍ច្បាប់ក្នុងអង្គនីតិប្រតិបត្តិ ដែលមានសមត្ថភាពខុសៗគ្នា ប៉ុន្តែបំពេញឱ្យគ្នា។ ផលិតផលសំខាន់ៗពីកិច្ចព្រមព្រៀងទាំងនេះរួមមានអនុស្សារណៈយោគយល់គ្នារវាងតួអង្គនានា គោលការណ៍ណែនាំស្តីពីការគ្រប់គ្រង គុណភាព[315] និងការបង្ហាញការប្តេជ្ញាចិត្តរួមចំពោះការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ផលិតផលនៃការចែករំលែកព័ត៌មានទាំងនេះ ក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដែលធ្វើការជាមួយក្រុមប្រតិបត្តិការនៅជួរមុខ។

អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ដែលមានបុគ្គលិកធ្វើការងារជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និង/ឬពាក់ព័ន្ធក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើរតួនាទីសំខាន់ក្នុងការធានាប្រសិទ្ធភាពនៃគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគុណភាព។អាស្រ័យលើឋានន្តរសក្តិនិងគំរូសេវានគរបាល អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត និង/ឬពង្រឹងក្របខណ្ឌត្រួតពិនិត្យយន្តការសម្របសម្រួល។

"អ្នកពាក់ព័ន្ធសំខាន់ៗសំដៅលើរដ្ឋាភិបាលអង្គការសង្គមស៊ីវិលនិងស្ថាប័នដែលមានតួនាទីឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិតរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល"។

អង្គការសហប្រជាជាតិ កញ្ចប់សេវាសំខាន់ៗ

នៅពេលបង្កើតយន្តការដើម្បីធានាការឆ្លើយតបដោយមានការសម្របសម្រួល ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងក្របខណ្ឌគ្រប់គ្រងគុណភាព កញ្ចប់សេវាសំខាន់ៗស្នើឱ្យនគរបាលខិតខំជំរុញការចូលរួមរបស់ក្រុមពហុវិស័យ។ កញ្ចប់សេវាសំខាន់ៗលើកឡើងទៀតថាក្រុមពហុវិស័យនេះគួរចូលរួមដោយអ្នកពាក់ព័ន្ធចម្រុះដែលធ្លាប់ចុះកិច្ចព្រមព្រៀងការងារ ឬមានឥទ្ធិពលវិជ្ជមាននៅពេលធានាករណីឆ្លើយតបក្រោមការសម្របសម្រួលដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាមួយនគរបាល និងតួអង្គវិស័យយុត្តិធម៌ផ្សេងទៀត។ សូមមើលប្រអប់ ១០ ស្តីពីគំនិតផ្តួចផ្តើមល្អៗសម្រាប់ការសម្របសម្រួលនៅ Illinois និង Oromina សម្រាប់ឧទាហរណ៍នៃក្រុមពហុវិស័យដែលចូលរួមដោយអ្នកពាក់ព័ន្ធចម្រុះ។

កញ្ចប់សេវាសំខាន់ៗលើកឡើងថា អ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលសេវាសំខាន់ៗរួមមានជនរងគ្រោះ និងតំណាង សេវាសង្គម វិស័យថែទាំសុខភាព អ្នកផ្តល់ជំនួយផ្នែកច្បាប់ នគរបាល អយ្យការ ចៅក្រម ទីភ្នាក់ងារការពារកុមារ និងវិស័យអប់រំ [316]។ល។ ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិល ដើម្បីកៀរគរជំនាញក្នុងការគ្រប់គ្រងករណីដែលជនរងគ្រោះជាសមាជិកក្រុមប្រឈមនឹងហានិភ័យ ដូចជា ស្ត្រី និងក្មេងស្រីមានពិការភាព នឹងធានាគុណភាពនៃសេវាដែលផ្តល់ជូន និងជំរុញលទ្ធភាពទទួលបានយុត្តិធម៌[317]។

314. សហភាពអឺរ៉ុបគូសបញ្ជាក់ថាផែនការសកម្មភាពជាតិស្តីពីការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងយន្តការសម្របសម្រួលពាក់ព័ន្ធ ត្រូវបានចាត់ទុកជាធាតុផ្សំសំខាន់ៗក្នុងការអនុវត្តច្បាប់និងគោលនយោបាយ។ក្រៅពីនេះសៀវភៅណែនាំរបស់អង្គការសហប្រជាជាតិ (២០១០) ស្តីពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ចាត់ទុកផែនការសកម្មភាពជាតិជាគន្លឹះនៃការធានាអភិក្រមគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួលក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធ។ សូមមើល "ទិដ្ឋភាពរួមនៃការអនុវត្តល្អទូទាំងពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈនិងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ"(អគ្គនាយកដ្ឋានគោលនយោបាយផ្ទៃក្នុង នាយកដ្ឋានគោលនយោបាយ ៖ សិទ្ធិពលរដ្ឋ និងកិច្ចការរដ្ឋធម្មនុញ្ញ សមភាពយេនឌ័រ សភាអឺរ៉ុប ២០១៣)។

315. យោងតាមកញ្ចប់សេវាសំខាន់ៗ គោលការណ៍ណែនាំស្តីពីគុណភាព គាំទ្រការផ្តល់ និងការអនុវត្តធាតុផ្សំសំខាន់ៗនៃសេវាសំខាន់ៗដើម្បីធានាថា សេវាទាំងនោះមានសុវត្ថិភាព និងមានគុណភាពគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការរបស់ស្ត្រី និងក្មេងស្រី។ គោលការណ៍ណែនាំទាំងនេះផ្តល់ "វិធី" នៃការផ្តល់សេវាក្នុងអភិក្រមដែលផ្អែកតាមសិទ្ធិមនុស្ស គិតពីវប្បធម៌ និងបង្កើនភាពអង់អាចរបស់ស្ត្រី។ គោលការណ៍ណែនាំទាំងនេះផ្អែកលើ និងបំពេញបន្ថែមឱ្យស្តង់ដារអន្តរជាតិ និងឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុតក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

316. កញ្ចប់សេវាសំខាន់ៗលើកឡើងថា អ្នកពាក់ព័ន្ធទាំងនេះអាច និងគួរមានតំណាងក្នុងស្ថាប័នសម្របសម្រួលទាំងអស់នៅគ្រប់កម្រិតនៃរដ្ឋាភិបាល ដើម្បីធានាការប្រកាន់ខ្ជាប់ អនុវត្ត និង/ឬអនុលោមតាមច្បាប់ជាតិ យុទ្ធសាស្ត្រ ពិធីសារ និងកិច្ចព្រមព្រៀងសម្រាប់ការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ សូមមើលម៉ូឌុលទី ៥ (ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល) កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។

317. ឧទាហរណ៍ Cape Mental Health អនុវត្តកម្មវិធី SAVE ដើម្បីផ្តល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះដែលមានពិការភាពផ្នែកបញ្ញាស្មារតីដើម្បីផ្តល់សក្ខីកម្មក្នុងតុលាការ ៖ https://www.westerncape.gov.za/facility/cape-mental-health។

"ស្ត្រីមិនមែនជាក្រុមតែមួយនោះទេ។ ដើម្បីធានាសកម្មភាពដែលមានប្រសិទ្ធភាពប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាំបាច់ត្រូវពិចារណាពីតម្រូវការជាក់លាក់របស់ក្រុមមួយចំនួន។ ស្ត្រី និងក្មេងស្រីមានពិការភាពដែលប្រឈមនឹងអំពើហិង្សា និងការរើសអើង ប្រឈមនឹងឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ដោយសារផ្នត់គំនិតដែលបង្កគ្រោះថ្នាក់ ឥរិយាបថរើសអើង និងកង្វះការសម្របសម្រួលផ្នែកនីតិវិធី និងសមហេតុផល ដែលអាចនាំឱ្យមានមន្ទិលលើភាពអាចជឿទុកចិត្តបានរបស់ជនរងគ្រោះនិងការច្រានចោលការចោទប្រកាន់។ឧបសគ្គរារាំងការរាយការណ៍បទល្មើស និង/ឬករណីរើសអើងចាប់ផ្តើមក្នុងសហគមន៍ដែលឥរិយាបថរបស់សមាជិកគ្រួសារ តំណាងសហគមន៍ និងតុលាការនៅមូលដ្ឋាន អាចបំភិតបំភ័យជនរងគ្រោះ ឬបន្ទុចបង្អាក់ពួកគេមិនឱ្យស្វែងរកយុត្តិធម៌"។

គោលការណ៍ណែនាំស្តីពីយេនឌ័រ (មូលនិធិសិទ្ធិជនពិការ និងមូលនិធិតស៊ូមតិសិទ្ធិជនពិការ ២០១៨)

សម្រាប់ជាមធ្យោបាយបង្កើតក្របខណ្ឌគ្រប់គ្រងគុណភាព ដើម្បីជួយធានាការឆ្លើយតបដោយមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀត និងអ្នកពាក់ព័ន្ធ អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលអាចទាញប្រយោជន៍ពីយន្តការអភិបាលកិច្ចតាមមូលដ្ឋាន ដូចជា ក្រុមប្រឹក្សាសន្តិសុខនៅថ្នាក់ក្រុង។

ក្រុមប្រឹក្សានេះជាវេទិកាកិច្ចសន្ទនាសម្រាប់ឱ្យស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនឹងសន្តិសុខសាធារណៈ ពិគ្រោះយោបល់គ្នា កំណត់រកបញ្ហា និងសម្រេចយកផែនការតាមមូលដ្ឋានសម្រាប់ការទប់ស្កាត់អសន្តិសុខ[318]។ ដូច្នេះ ក្រុមប្រឹក្សានេះអាចធានាគុណភាពនៃការគ្រប់គ្រងសកម្មភាពដោយមានការសម្របសម្រួលដែលពាក់ព័ន្ធនឹងនគរបាល និងដៃគូក្នុងការបន្តផ្តល់យុត្តិធម៌រួមទាំងនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ជាធម្មតា ក្រុមប្រឹក្សានេះរួមបញ្ចូលអាជ្ញាធរក្រុង ស្ថាប័នរដ្ឋាភិបាលនៅមូលដ្ឋានមន្ត្រីយុត្តិធម៌និងពេលខ្លះតំណាងរបស់សង្គមស៊ីវិល បូករួមនឹងនគរបាល។ ដូច្នេះ ពួកគេអាចបង្កើតជាតុចូលដ៏សំខាន់សម្រាប់ដំណើរការរៀនសូត្រពីការឆ្លើយតបដោយមានការសម្របសម្រួលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[319]។ ចំណុចនេះអាចរួមបញ្ចូលការពិនិត្យឡើងវិញ និងការវាយតម្លៃខាងក្រៅលើការឆ្លើយតបដោយមានការសម្របសម្រួលក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ២**

លក្ខណៈវិនិច្ឆ័យរបស់សហភាពអឺរ៉ុបសម្រាប់ការអនុវត្តល្អបំផុតក្នុងការសម្របសម្រួលក្នុងការសិក្សាស្តីពីការអនុវត្តល្អបំផុតជុំវិញពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ សហភាពអឺរ៉ុបបានកំណត់លក្ខណៈវិនិច្ឆ័យសំខាន់ៗ ៥ នៃការសម្របសម្រួលសេវាដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ ដូចខាងក្រោម ៖

- ការរួមបញ្ចូលស្ថាប័នពាក់ព័ន្ធតួអង្គយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកតស៊ូមតិឱ្យមានសិទ្ធិស្ត្រី និងសិទ្ធិជនរងគ្រោះ
- ការយល់ដឹងច្បាស់និងជារួមអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងអំពើរំលោភសេពសន្ថវៈ
- ការសហការគ្នាឆ្ពោះទៅរកការបង្កើតគោលនយោបាយ គោលការណ៍ណែនាំយន្តការបញ្ជូន និងយន្តការប្រមូលទិន្នន័យ
- ផ្អែកតាមអ្នកជំនាញយេនឌ័រ និងបទពិសោធន៍របស់ជនរងគ្រោះ
- យន្តការគណនេយ្យភាពនិងភាពម្ចាស់ការមួយចំនួន (មិនពាក់ព័ន្ធនឹងរដ្ឋ)។

ប្រភព ៖ ទិដ្ឋភាពរួមនៃការអនុវត្តល្អបំផុតជុំវិញពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ (សភាអឺរ៉ុប ២០១៣)

318. "ការស្វែងយល់ពីក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានក្នុងរយៈពេល ២ នាទី" Coginta សម្រាប់កំណែទម្រង់នគរបាល ៖ https://www.youtube.com/watch?v=7fGF0_nteGA។
319. យន្តការក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន មាននៅគ្រប់ទ្វីបទាំងអស់។ នៅបារាំង និងសាធារណរដ្ឋហ្គីណេ ក្រុមប្រឹក្សានេះមានឈ្មោះថា ក្រុមប្រឹក្សាសន្តិសុខមូលដ្ឋានសម្រាប់ការទប់ស្កាត់បទល្មើស (CLSPD)។ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្រុមប្រឹក្សានេះមានឈ្មោះថា ក្រុមប្រឹក្សាសន្តិសុខសហគមន៍មូលដ្ឋាន (CLSPs) ។ នៅអេក្វាឌ័រ ក្រុមប្រឹក្សានេះមានឈ្មោះថា ក្រុមប្រឹក្សា សន្តិសុខក្រុង (CSM)។ អាស្រ័យលើគំរូ និងចំនួនប្រជាជនក្នុងក្រុង មន្ត្រីនគរបាលជាន់ខ្ពស់ក្នុងសហគមន៍អាចជាតំណាងនគរបាលដ៏សំខាន់ក្នុងក្រុមប្រឹក្សានេះ។ សូមមើល៖ Fernandez, M., Piaget, K., Hernandez, T., and Berthoud, S., 'Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR?', ISSAT HRBA Working Group Paper 3 (2017) and 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée' (Cognita for Police Reform, 2017).

ដំណើរការពិគ្រោះយោបល់ដោយបើកចំហ និងមានតម្លាភាពសម្រាប់ការគ្រប់គ្រងគុណភាពដែលពាក់ព័ន្ធនឹងអាណត្តិរបស់នគរបាលនេះរួមចំណែកយ៉ាងច្រើនដល់ភាពស្របច្បាប់របស់នគរបាលក្នុងក្រសែភ្នែកប្រជាជនដែលពួកគេផ្តល់សេវាជូន និងការពារ។

**សម្រាប់ព័ត៌មានលម្អិតស្តីពីក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន សូមអានករណីសិក្សាស្តីពីក្រុមប្រឹក្សាសន្តិសុខមូលដ្ឋាន (ប្រទេសកុងហ្គោ អេក្វាឌ័រ និងម៉ិចស៊ិក) ក្នុងជំពូកទី ៣ (ការទប់ស្កាត់)។**

## សមត្ថភាពគ្រប់គ្រងសំខាន់ៗ សម្រាប់ការសម្របសម្រួលជាមួយស្ថាប័នយុត្តិធម៌ ដើម្បីធានាការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

គេអាចធានាផលប្រយោជន៍សាធារណៈបានល្អបំផុតនៅពេលដែលសាធារណជនចែករំលែកព័ត៌មាន និងសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកផ្តល់សេវាសំខាន់ៗ ដើម្បីកំណត់រកនិងសម្រេចបានគោលបំណងរួមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

បទដ្ឋានអន្តរជាតិតម្រូវឱ្យមានការសម្របសម្រួលរវាងនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗរួមទាំងដៃគូក្នុងស្ថាប័នយុត្តិធម៌ យ៉ាងទូលំទូលាយ ជាពហុជំនាញ ប្រកបដោយការសម្របសម្រួលជាប្រព័ន្ធ និងមាននិរន្តរភាព[320]។

ដំណើរការយុត្តិធម៌អាចមានលក្ខណៈស្មុគស្មាញ និងការិយាល័យធិបតេយ្យ។ បើគ្មានការសម្របសម្រួលដោយមានប្រសិទ្ធភាពរវាងដំណើរការស្មុគស្មាញទាំងនេះទេ ជនរងគ្រោះអាចជួបនឹងបញ្ហា និងប្រឈមនឹងការរងគ្រោះលើកទីពីរ។

ជនរងគ្រោះដែលមានតម្រូវការជាក់លាក់ គួរទទួលបានការយកចិត្តទុកចិត្តខ្ពស់ ហើយដើម្បីកុំឱ្យមានការផាត់ពួកគេចេញពីការសម្របសម្រួលយុត្តិធម៌គួរដោះស្រាយបញ្ហាប្រឈមរបស់ជនរងគ្រោះដែលមានពិការភាពក្នុងកិច្ចដំណើរការនីតិវិធីតុលាការ[321] ។

ការរងគ្រោះលើកទីពីរលេចឡើងក្នុងការបន្តផ្តល់យុត្តិធម៌។ តារាងខាងក្រោម (ប្រអប់ ៧) បង្ហាញពីចំណុចខ្វះខាតក្នុងការសម្របសម្រួល និងឧទាហរណ៍នៃផលប៉ះពាល់របស់វាលើការរងគ្រោះលើកទីពីរ។

**ប្រអប់ ៣**

| ចំណុចខ្វះខាតក្នុងការសម្របសម្រួល | ផលប៉ះពាល់លើការរងគ្រោះលើកទីពីរ |
|---|---|
| ជារឿយៗនគរបាលផ្តោតខ្លាំងពេកលើការចោទប្រកាន់បទព្រហ្មទណ្ឌមិនមែនផលប្រយោជន៍របស់ជនរងគ្រោះឡើយ។ | ជនរងគ្រោះលែងសហការ ដោយសារខ្លាចបាត់បង់ប្រាក់ចំណូលពីឪពុករបស់កូន ឬការសហការគ្នាចិញ្ចឹមកូនដោយសារការចោទប្រកាន់បទព្រហ្មទណ្ឌ។ជនរងគ្រោះតម្កល់សុខុមាលភាពរបស់កូន ធំជាងសុខុមាលភាពផ្ទាល់ខ្លួន។ |
| វេជ្ជបណ្ឌិត ចៅក្រម និងនគរបាលដែលមិនទទួលបានការបណ្តុះបណ្តាលក្នុងការចាត់ចែងករណីទាំងនេះចូលធ្វើអន្តរាគមន៍។ | ការសម្ភាសន៍ឡើងវិញដដែលៗ ដែលជះផលអវិជ្ជមាន ឬកាតព្វកិច្ចផ្តល់សក្ខីកម្មដែលធ្វើឱ្យជនរងគ្រោះ ប៉ះទង្គិចផ្លូវចិត្តឡើងវិញ និងប៉ះពាល់ដល់សមត្ថភាពរបស់ជនរងគ្រោះ ក្នុងការរំលឹកព្រឹត្តិការណ៍តាមលំដាប់លំដោយ ទៅតាមការរំពឹងទុក ឬនាំឱ្យជនរងគ្រោះប្រានចោលបទពិសោធន៍របស់ខ្លួនដើម្បីគេចវេសពីការចូលរួមបន្ថែមទៀតដែលបង្ក |

320. សូមមើល ម៉ូឌុលទី ១ ៖ សេចក្តីផ្តើម "កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា" "កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។ សូមមើលផងដែរ ផ្នែកស្តីពីកិច្ចសហការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័ន និងសេវាពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រគំរូបច្ចុប្បន្នភាព (២០១០)។

321. សារណាដាក់ជូនអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិជនមានពិការភាព ៖ ការអនុវត្តល្អសម្រាប់ការបង្កើនលទ្ធភាពដែលមានប្រសិទ្ធភាពរបស់ស្ត្រីនិងក្មេងស្រីមានពិការភាពក្នុងការទទួលបានយុត្តិធម៌ (Women Enabled International ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៩)

| ចំណុចខ្វះខាតក្នុងការសម្របសម្រួល | ផលប៉ះពាល់លើការរងគ្រោះលើកទីពីរ |
|---|---|
| | គ្រោះថ្នាក់ ជាមួយអ្នកផ្តល់សេវាសំខាន់ៗដែលគ្មានការបណ្តុះបណ្តាល។ |
| កង្វះកិច្ចសហការក្នុងស្ថាប័ន នាំទៅរកការភ្លាំងភ្លាត់ក្នុងការគ្រប់គ្រងកំណត់ត្រា កង្វះការពិនិត្យពិច័យសំណុំឯកសារសម្រាប់ការតាមដានបន្តលើប្រព័ន្ធវាយតម្លៃហានិភ័យ ឬការរាយការណ៍។ | កង្វះការតាមដានបន្តដោយនគរបាលនិងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតជាមួយជនរងគ្រោះ នាំឱ្យមានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពរបស់សមាជិកគ្រួសារ។ |
| ការគ្រប់គ្រងយន្តការសម្របសម្រួលជាបញ្ហាប្រឈមសម្រាប់អ្នកផ្តល់សេវាសំខាន់ៗ ព្រោះស្ថាប័ននានាហាក់មិនចង់ប្រឈមមុខគ្នា ក្នុងពេលបរាជ័យ។ | ចៅក្រមទាមទារភស្តុតាងបន្ថែមដែលពិបាកនឹងរកបាន ជាហេតុនាំឱ្យនគរបាលដាក់សម្ពាធលើជនរងគ្រោះឱ្យផ្តល់ព័ត៌មាន ឬការដាក់សម្ពាធឱ្យនគរបាលធ្វើការផ្សះផ្សារដើម្បីព្យាយាមបញ្ចុះបញ្ចូលឱ្យជនរងគ្រោះប្រានចោល ឬដកបណ្តឹងរបស់ខ្លួន។ |
| នគរបាលខិតខំធានាថាជនរងគ្រោះនៅតែជាចំណុចស្នូលនៃដំណើរការនេះនៅចំពោះមុខសម្ពាធដ៏ចម្រូងចម្រាស់ពីដំណើរការការិយាល័យធិបតេយ្យផ្ទៃក្នុងនិងលក្ខខណ្ឌតម្រូវរបស់ស្ថាប័នយុត្តិធម៌ផ្សេងទៀត។ | ជនរងគ្រោះ ត្រូវបានតម្រូវឱ្យបង់ថ្លៃសេវាវេជ្ជសាស្ត្រ សេវាច្បាប់ សេវានគរបាលដើម្បីអាចជំនុំជម្រះករណីរបស់គាត់ ឬត្រូវបានតម្រូវឱ្យស្នាក់នៅកន្លែង "សុវត្ថិភាព" ដែលមិនបំពេញតម្រូវការគ្រប់គ្រាន់[322]។ |

ក្រៅពីនេះគួរផ្តោតការយកចិត្តទុកដាក់លើគោលការណ៍មិនបង្កគ្រោះថ្នាក់ក្នុងដំណើរការជ្រើសរើសដៃគូនៅពេលសម្របសម្រួលការឆ្លើយតបទៅនឹងបទល្មើសនិងអំពើហិង្សាព្រោះវាអាចជួយក្នុងការកំណត់ស្ថានភាពរបស់ក្រុមហើយនិងបដិសេធ ក្នុងករណីដៃគូក្នុងក្រុមមិនសូវត្រូវបានគេទទួលស្គាល់[323]។ នាយកដ្ឋានប្រតិបត្តិការ សន្តិភាព (UN DPO) កត់សម្គាល់ថា ការធ្វើការជាមួយសហគមន៍ ឬការសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិលដែលតំណាងឱ្យសហគមន៍ អាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនអនេកដល់នគរបាល។ ទោះជាយ៉ាងណា នគរបាលត្រូវយកចិត្តទុកដាក់ចំពោះផលប៉ះពាល់នៃវិសាលភាពការងាររបស់ខ្លួនលើសហគមន៍។

ក្នុងសៀវភៅណែនាំស្តីពីសេវានគរបាលដែលផ្តោតលើសហគមន៍ UN DPO ស្នើឱ្យនគរបាលជំរុញការចូលរួមពីគ្រប់ផ្នែកក្នុងសហគមន៍។ ពុំនោះទេ ក្រុមមួយ ឬច្រើនអាចចោទប្រកាន់នគរបាលថាមានការរើសអើងនិងមានទំនាក់ទំនងជិតស្និទ្ធជ្រុលជាមួយផ្នែកផ្សេងទៀតនៃសហគមន៍នោះ[324]។ តារាងត្រួតពិនិត្យរបស់ UNPOL គួរអនុវត្តផងដែរចំពោះអង្គការសង្គមស៊ីវិលដែលតំណាងឱ្យសហគមន៍ នៅពេលនគរបាលស្វែងរកដៃគូសម្របសម្រួលការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្នុងន័យនេះ UNDPO ផ្តល់តារាងត្រួតពិនិត្យដ៏ល្អសម្រាប់ជំរុញការចូលរួមរបស់ដៃគូ និងអ្នកពាក់ព័ន្ធក្នុងសហគមន៍[325] (សូមមើលប្រអប់ ៨ ខាងក្រោម)។

កញ្ចប់សេវាសំខាន់ៗលើកឡើងថា ការឆ្លើយតបដោយមានការសម្របសម្រួលរវាងស្ថាប័នយុត្តិធម៌មានសារៈសំខាន់ព្រោះវាកាន់តែមានប្រសិទ្ធភាពក្នុងការរក្សាសុវត្ថិភាពរបស់ជនរងគ្រោះពីអំពើហិង្សានិងការរក្សាការទទួលខុសត្រូវរបស់ជនល្មើសនៅពេលដែលវិស័យផ្សេងៗក្នុងសង្គមបំពេញការងារដាច់ដោយឡែកពីគ្នាដើម្បីដោះស្រាយបញ្ហានេះ[326]។

322. សំខាន់បំផុតត្រូវគូសបញ្ជាក់ថា ថ្លៃឱកាសនឹងកាន់តែខ្ពស់ នៅពេលដែលស្ត្រីជាអ្នកផ្គត់ផ្គង់គ្រួសារតែម្នាក់ឯង ហើយការចូលរួមក្នុងតុលាការបង្កការលំបាក។ ដូច្នេះ ស្ត្រីអាចសម្រេចមិនគាំទ្រការជំនុំជម្រះករណីរបស់ខ្លួន។
323. សេវានគរបាលដែលផ្តោតលើសហគមន៍ក្នុងសៀវភៅណែនាំប្រតិបត្តិការសន្តិភាពរបស់អង្គការសហប្រជាជាតិ (នាយកដ្ឋានប្រតិបត្តិការសន្តិភាព អង្គការសហប្រជាជាតិ ២០១៨)។
324. Ibid

## ប្រអប់ ៩

**តារាងត្រួតពិនិត្យរបស់ UNPOL**
**សម្រាប់ជំរុញការចូលរួមរបស់ដៃគូ និងអ្នកពាក់ព័ន្ធក្នុងសហគមន៍**

- តើយើងបានកំណត់រកដៃគូ និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ (និងវិធីល្អបំផុតដែលពួកគេអាចរួមចំណែកដល់សកម្មភាពគម្រោង) ទៅតាមធនធានរបស់ពួកគេ ឬទេ?
- តើយើងបានបង្ហាញច្បាស់ និងឯកភាពលើការជំរុញការចូលរួមរបស់ដៃគូ និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ តួនាទីរបស់ពួកគេ និងរបៀបគ្រប់គ្រងក្ដីរំពឹងទុក ឬទេ?
- តើយើងបានបង្កើតប្រព័ន្ធសម្របសម្រួល និងផ្ដល់យោបល់ត្រឡប់ ដូចជា កិច្ចប្រជុំជាប្រចាំ និងរបាយការណ៍សកម្មភាព ឬទេ?
- តើយើងបានបង្កើតប្រព័ន្ធផ្សព្វផ្សាយដែលមានប្រសិទ្ធភាពដើម្បីផ្ដល់មូលដ្ឋានព័ត៌មានដល់ដៃគូអ្នកពាក់ព័ន្ធអ្នកធ្វើសេចក្ដីសម្រេចចិត្ត ម្ចាស់ជំនួយ និងអ្នកផ្សេងទៀតក្នុងសហគមន៍ស្ដីពីវឌ្ឍនភាពនៃសកម្មភាពគម្រោង បញ្ហាប្រឈម និងភាពជោគជ័យ ឬទេ?

### ប្រព័ន្ធយុត្តិធម៌ជាមូលដ្ឋាននៃការសម្របសម្រួលសនិទ្ធភាព និងភាពពាក់ព័ន្ធរវាងជនរងគ្រោះ និងស្ថាប័នយុត្តិធម៌ទាំងអស់។

សូចនាករួមមួយនៃការសម្របសម្រួលដែលមានប្រសិទ្ធភាពក្នុងចំណោមស្ថាប័នយុត្តិធម៌ គឺការចែករំលែកហានិភ័យជាប្រព័ន្ធ និងក្របខណ្ឌជាធរមានសម្រាប់ជានាការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពលើគុណភាព និងប្រសិទ្ធភាពនៃសេវាសំខាន់ៗ។

នៅចក្រភពអង់គ្លេសសកម្មភាពខាងក្រោមត្រូវបានដាក់ចេញដើម្បីបង្កើនការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌ដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[327] ៖

- រដ្ឋាភិបាលរបស់មហាក្សត្រីបានបង្កើតឯកសារណែនាំយុទ្ធសាស្ត្រជាច្រើនក្នុងគោលបំណងបង្កើនអភិក្រមពហុស្ថាប័នលើប្រធានបទ ដូចជា អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ការវះកាត់ប្រដាប់បន្តពូជស្ត្រី និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ។ ឯកសារទាំងនេះផ្ដល់ព័ត៌មានយ៉ាងមានតម្លៃដល់អ្នកអនុវត្តន៍ជួរមុខស្ដីពី "ប្រការគួរ និងប្រការមិនគួរ" ពាក់ព័ន្ធនឹង "សញ្ញា និងរោគសញ្ញា" ដើម្បីអាចឱ្យអ្នកអនុវត្តន៍កំណត់អត្តសញ្ញាណជនរងគ្រោះបាន។
- ដើម្បីសម្រេចគោលដៅខាងលើ សេវាអយ្យការ Crown ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល និងកងកម្លាំងនគរបាលបានរៀបចំវគ្គបណ្ដុះបណ្ដាលរួមនិងបង្កើតពិធីសារួមដែលផ្ដោតជាពិសេសលើការស៊ើបអង្កេត និងការផ្ដន្ទាទោសករណីរំលោភសេពសន្ថវៈការរំលោភបំពានដើម្បីកិត្តិយស អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី។

ដើម្បីជួយដល់នគរបាលក្នុងការផ្ដល់សេវាសំខាន់ៗតាមរបៀបដែលអាចផ្ដល់លទ្ធផលល្អបំផុតដល់ជនរងគ្រោះ ផ្នែកនេះនឹងផ្ដល់កម្រងសមត្ថភាពផ្នែកឥរិយាបថដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង នៅពេលខិតខំសម្របសម្រួលការឆ្លើយតបដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្ដោតសំខាន់លើជនបង្កទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀត។ សមត្ថភាពទាំងនេះអាចផ្ទេរតាមរយៈភាពជាដៃគូរវាងនគរបាល និងសាធារណជន រួមទាំងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីរិះរកដំណោះស្រាយដែលមានការសម្របសម្រួលក្នុងសហគមន៍សម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

---

325. អង្គការសហប្រជាជាតិ ឯកសារជំនួយស្មារតីយេនឌ័រសម្រាប់នគរបាល ៖ ស្តង់ដារនៃការអនុវត្តល្អបំផុតស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាពសេចក្ដីសង្ខេបឧបករណ៍គម្រោង (២០១៥)។
326. ម៉ូឌុលទី ៥ ៖ ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា៖គោលការណ៍ណែនាំស្ដីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្ដីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។
327. សៀវភៅណែនាំស្ដីពីច្បាប់ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ប្រទេសអង់គ្លេស និងប្រទេសវ៉ែលក្រិច អៀកឡង់ អ៊ីតាលី អៀកឡង់ខាងជើង ប៉ូឡូញ និងអេស្ប៉ាញ (មូលនិធិមេជារីអឺរ៉ុប ២០១៨)។

មិនខុសពីជំពូកមុនៗដែរ សមត្ថភាពទាំងនេះត្រូវបានដកស្រង់ចេញពីឯកសាររបស់ អង្គការសហប្រជាជាតិដូចជា យុទ្ធសាស្ត្រគំរូបច្ចុប្បន្នភាព (២០១០) ការអនុវត្តល្អក្នុងការកសាងភាពជាដៃគូរវាងនគរបាលនិងសាធារណជន (អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប -OSCE) និងក្របខណ្ឌការណែនាំជាយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព (SGF)[328] ។ល។ ចំណុចមួយចំនួនខាងក្រោមមានគោលបំណងបំពេញបន្ថែម និងពង្រឹងគោលនយោបាយ និងពិធីសារជាតិសម្រាប់ស្ថាប័ននគរបាលស្តីពីការសម្របសម្រួលជាមួយស្ថាប័នផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌។ អ្នកគ្រប់គ្រងគួរជានាថា មន្ត្រីនគរបាលមានតួនាទីសម្របសម្រួល អាចអនុវត្តចំណុចខាងក្រោម។

### ភាពអាចរកបាន និងភាពអាចទទួលបាន (ផ្អែកតាមទស្សនៈវិស័យនៃអភិបាលកិច្ច ការត្រួតពិនិត្យ និងគណនេយ្យភាព)

- ដើរតួនាទីក្នុងការសម្របសម្រួលទំនាក់ទំនងរវាងតួអង្គវិស័យយុត្តិធម៌និងអ្នកតស៊ូមតិក្នុងសហគមន៍។ អ្នកតស៊ូមតិបំពេញបន្ថែមលើការងាររបស់មន្ត្រីនគរបាលផ្តល់យោបល់ត្រឡប់ និងផ្តល់ការបណ្តុះបណ្តាល។ តាមរយៈការកសាងភាពជាដៃគូជាមួយអ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្ស[329] សិទ្ធិស្ត្រី និងសិទ្ធិជនពិការ នគរបាលអាចពង្រឹងភាពអាចជឿទុកចិត្តបានរបស់ពួកគេជាមួយសហគមន៍។

### ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា

- លើកទឹកចិត្តនិងជួយដល់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា ក្នុងការរៀបចំនិងដាក់បណ្តឹងផ្លូវការតាមរយៈការផ្តល់ការការពារដល់ជនរងគ្រោះ និងការណែនាំពួកគេថាការទទួលខុសត្រូវលើការនាំទៅរកការចោទប្រកាន់ និងផ្តន្ទាទោសជនល្មើសជាបន្ទុករបស់សេវានគរបាល និងសេវាអយ្យការ។ ផ្តល់ការគាំទ្រសមស្របដល់ស្ត្រីនិងក្មេងស្រីដែលមានតម្រូវការជាក់លាក់។

### ភាពអាចសម្របតាមបាន

- លើកកម្ពស់ និងតស៊ូមតិឱ្យមានបទប្បញ្ញត្តិ និងគោលនយោបាយតឹងរ៉ឹង និងច្បាស់លាស់ក្នុងផ្នែកសម្របសម្រួល ដើម្បីប្រឈមមុខនឹងទ្វេគ្រោះផ្នែកក្រមសីលធម៌ដែលអាចកើតឡើង ឬផលប៉ះពាល់អវិជ្ជមាននៃទំនាក់ទំនងជិតស្និទ្ធរវាងនគរបាល និងសហគមន៍ដែលអាចរារាំងមិនឱ្យជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីរាយការណ៍ឬសហការជាមួយនគរបាល និងស្ថាប័នយុត្តិធម៌ផ្សេងទៀត។
- ស្វែងរកឱកាសចែករំលែកសមិទ្ធផលជារួម កំណត់រកគុណវិបត្តិ និងបង្កើត និងអនុវត្តយុទ្ធសាស្ត្រដើម្បីបង្កើនវិសាលភាព និងការឆ្លើយតប។

### ភាពសមស្រប

- ដឹកនាំកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលដើម្បីឱ្យជានាការតម្កល់ផលប្រយោជន៍របស់ស្ត្រី និងក្មេងស្រី ជាចំណុចស្នូលនៃអន្តរាគមន៍លើអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើរំលោភសេពសន្ថវៈ[330] ។

"គោលដៅបឋមនៃការសម្របសម្រួលគួរតែជាការបង្កើនសុវត្ថិភាពរបស់ជន រងគ្រោះ។ ការឆ្លើយតបដោយមានការសម្របសម្រួល ដែលមិនផ្តោតសំខាន់លើសុវត្ថិភាពជនរងគ្រោះ អាចបង្កអន្តរាយដល់ពួកគេទៅវិញ"។

អត្ថប្រយោជន៍នៃការសម្របសម្រួល ៖ បញ្ឈប់អំពើហិង្សាលើស្ត្រី ៖ គម្រោងរបស់អ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្ស

### ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- ធ្វើការជាមួយស្ថាប័នយុត្តិធម៌ និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ដើម្បីសម្រេចជាឯកច្ឆន្ទនិងកំណត់ការប្តេជ្ញាចិត្តចំពោះការទទួលខុសត្រូវរបស់ពួកគេ និងភាព

328. ក្របខណ្ឌការណែនាំជាយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព (SGF) មានគោលបំណងបង្កើនប្រសិទ្ធភាពរបស់នគរបាលអង្គការសហប្រជាជាតិដែលរក្សាសន្តិភាពតាមរយៈអភិក្រមដែលកាន់តែស៊ីសង្វាក់គ្នានិងបន្សីគ្នាសម្រាប់ការផ្តល់សុវត្ថិភាពសាធារណៈកំណែទម្រង់នគរបាលនិងការគាំទ្រដល់សេវានគរបាលក្នុងរដ្ឋម្ចាស់ស្រុក៖https://police.un.org/en/sgf។
329. រួមបញ្ចូល អ្នកតស៊ូមតិឱ្យជនមានពិការភាព និងអថេរបុគ្គលផ្សេងទៀតដែលធ្វើឱ្យមនុស្សងាយរងគ្រោះ។
330. "ទិដ្ឋភាពរួមនៃការអនុវត្តល្អទូទាំងពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ" (អគ្គនាយកដ្ឋានគោលនយោបាយផ្ទៃក្នុង នាយកដ្ឋានគោលនយោបាយ៖ សិទ្ធិពលរដ្ឋនិងកិច្ចការរដ្ឋធម្មនុញ្ញ សមភាពយេនឌ័រ សភាអឺរ៉ុប ២០១៣)។

ចាំបាច់នៃកិច្ចសហប្រតិបត្តិជិតស្និទ្ធ។

- អនុវត្តអភិក្រមដោះស្រាយបញ្ហានៅពេលសហការជាមួយអ្នកពាក់ព័ន្ធដើម្បីធានាថា ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី យល់ថា ពួកគេអាចចូលរួមប្រកបដោយអត្ថន័យក្នុងផ្នែកទាំងអស់នៃការស៊ើបអង្កេត។ ឧ. សហការជាមួយតួអង្គវិស័យយុត្តិធម៌ផ្សេងទៀតដើម្បីបង្កើតដំណើរការជំរុញការចូលរួមបែបសហការជាមួយអ្នកដឹកនាំសហគមន៍ និងបណ្ដាញផ្សព្វផ្សាយនៅមូលដ្ឋាន ក្នុងផ្នែកនៃកិច្ចខិតខំប្រឹងប្រែងលុបបំបាត់ការមាក់ងាយ ឬបង្កការលំបាកក្នុងសង្គមដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងផ្សព្វផ្សាយការប្ដេជ្ញាចិត្តនេះជាសាធារណៈ។
- សម្របសម្រួលការពិនិត្យតាមដានអន្តរាគមន៍អំពើហិង្សាក្នុងគ្រួសារឬការពិនិត្យឡើងវិញលើអភិក្រមជាក់លាក់ (ការប្រមូលទិន្នន័យ) និងឧបករណ៍ពាក់ព័ន្ធជាមួយតួអង្គវិស័យយុត្តិធម៌ផ្សេងទៀត និងអ្នកពាក់ព័ន្ធក្នុងសហគមន៍។ រួមគ្នាកំណត់រកចំណុចខ្វះខាតក្នុងសេវា រួមទាំងការកសាងការយល់ដឹង។ ការខិតខំសហការគ្នាកែលម្អសេវាគួរតែជាគោលបំណងមួយនៃការសម្របសម្រួលរបស់នគរបាល[331]។

## ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន

- សម្របសម្រួលជាមួយស្ថាប័នយុត្តិធម៌ ស្ដីពីការចែករំលែកព័ត៌មានស៊ើបប្រកបដោយក្រមសីលធម៌សម្រាប់យុទ្ធសាស្ត្រទប់ស្កាត់ជាមួយអ្នកពាក់ព័ន្ធចម្រុះក្នុងសហគមន៍ ដូចជា សេវាសន្តិសុខឯកជន សម្រាប់ការពិនិត្យសាវតាររបស់ជនល្មើស ជាពិសេសក្នុងករណីបទល្មើសផ្លូវភេទ[332]។

## ការផ្ដល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់

- បង្កើត និងរក្សាទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធចម្រុះឆ្ពោះទៅរកលទ្ធផលនៃការស៊ើបអង្កេត ទន្ទឹមនឹងមានភាពប្រុងប្រយ័ត្នក្នុងការវិនិច្ឆ័យដើម្បីរក្សាតុល្យភាពនៃសុចរិតភាពក្នុងការស៊ើបអង្កេត រួមទាំងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការប្រព្រឹត្តចំពោះដោយសេចក្ដីថ្លៃថ្នូរ និងរក្សាការសម្ងាត់។
- ធានាថាបានកំណត់ និងផ្សព្វផ្សាយច្បាស់អំពីដំណើរការស្វែងរកការផ្ដល់ការយល់ព្រមត្រឹមត្រូវ ដោយអ្នកពាក់ព័ន្ធក្នុងដំណើរការតុលាការជាពិសេសក្នុងករណីដែលស្ត្រីត្រូវបានបដិសេធលទ្ធភាពផ្លូវច្បាប់ក្នុងការសម្រេចចិត្តដោយខ្លួនឯង។

## សូចនាករយោងសម្រាប់នគរបាលដែលផ្ដល់សេវាសំខាន់ៗ៖ ការសម្របសម្រួល ក្នុងចំណោមស្ថាប័នយុត្តិធម៌

ការសម្របសម្រួលមានទម្រង់ចម្រុះដែលការសម្របសម្រួលខ្លះមានលក្ខណៈកាន់តែផ្លូវការនិងមានភាពពាក់ព័ន្ធកាន់តែច្រើនសម្រាប់ការតាក់តែងគោលនយោបាយ ចំណែកការសម្របសម្រួលខ្លះទៀតគឺមិនសូវផ្លូវការនិងផ្ដោតលើការជំរុញការចូលរួមរបស់ជនរងគ្រោះម្នាក់ៗប្រកបដោយប្រសិទ្ធភាព។ការឆ្លើយតបដោយមានការសម្របសម្រួលមានសារៈសំខាន់ ព្រោះវាមានប្រសិទ្ធភាពក្នុងការរក្សាសុវត្ថិភាពរបស់ជនរងគ្រោះពីអំពើហិង្សានិងរក្សាការទទួលខុសត្រូវរបស់ជនល្មើសជាងនៅពេលដែលវិស័យផ្សេងៗក្នុងសង្គមបំពេញការងារដាច់ដោយឡែកពីគ្នាដើម្បីដោះស្រាយបញ្ហានេះ។ ការសម្របសម្រួលផ្ដល់អត្ថប្រយោជន៍ដល់ជនរងគ្រោះ ក៏ដូចជាទីភ្នាក់ងារ និងស្ថាប័នដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងសហគមន៍របស់ពួកគេ[333]។

ដូចការពិភាក្សាក្នុងជំពូកទី ២ កញ្ចប់សេវាសំខាន់ៗស្នើឱ្យសេវាយុត្តិធម៌និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះមានលក្ខណៈទូទៅនិងសកម្មភាពរួមដើម្បីធានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈទូទៅ និងសកម្មភាពរួមទាំងនេះអាចអនុវត្តបាន ដោយមិនគិតពី "វិស័យ" ជាក់លាក់ ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងក្មេងស្រីដែលកំពុងរងគ្រោះដោយអំពើហិង្សា។

331. Logar, Rosa, 'The Austrian model of intervention in cases of domestic violence', Paper presented at the UN Expert Group Meeting: Violence against women: Good practice in combating and eliminating violence against women' (Vienna, 17–20 May 2005).
332. គោលការណ៍ណែនាំសម្រាប់អ្នកផ្ដល់សេវាសន្តិសុខឯកជនស្ដីពីការទប់ស្កាត់ និងដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (សមាគមក្រមប្រតិបត្តិអន្តរជាតិសម្រាប់អ្នកផ្ដល់សេវាសន្តិសុខឯកជន ២០១៩)។
333. សូមមើលម៉ូឌុលទី ៥ ៖ ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល កញ្ចប់សេវាសំខាន់ៗ (២០១៥)។

ចំណុចខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅនិងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗនិងផ្តល់ឧទាហរណ៍នៃសូចនាករយោងសម្រាប់សកម្មភាពរបស់នគរបាលនៅពេលខិតខំផ្តល់សេវាសំខាន់ៗក្នុងការឆ្លើយតបដោយមានការសម្របសម្រួល ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងគិតគូរពីយេនឌ័រ ទៅនឹងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ទាំងនេះជាសូចនាករដែលអ្នកគ្រប់គ្រងនគរបាលអាចយកជាសំអាង ប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មាន ថ្នាក់លើគួរបញ្ចូលសូចនាករទាំងនេះ។

១. **ភាពអាចរកបាន និងភាពអាចទទួលបាន** ៖ ភាគរយនគរបាលតាមប៉ុស្តិ៍ដែលចូលរួមជាប្រចាំ ឬបានចូលរួមក្នុងដំណើរការសម្របសម្រួលផ្លូវការនិង/ឬក្រៅផ្លូវការជាមួយស្ថាប័នយុត្តិធម៌ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ សូចនាករនេះគួរបែងចែកនគរបាលទៅតាមយេនឌ័រ ឋានន្តរសក្តិ អង្គភាព និងផ្ទៀងផ្ទាត់ថាតើពួកគេទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ក្នុងការចូលរួមជាមួយអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត រួមទាំងស្ថាប័នយុត្តិធម៌ ឬទេ។ សូចនាករនេះនឹងផ្តល់ព័ត៌មានស្តីពីកម្រិតដែលនគរបាលតាមប៉ុស្តិ៍យល់ថា ពួកគេមានតួនាទីជាភ្នាក់ងារឆ្លើយតបដំបូងក្នុងឧប្បត្តិហេតុអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

២. **ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន** ៖ ភាគរយនៃដំណើរការសម្របសម្រួលដែលពាក់ព័ន្ធនឹងក្រុមនគរបាលនៅមូលដ្ឋាន ដែលពឹងផ្អែកលើការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការសង្គមស៊ីវិលដូចជាអង្គការសិទ្ធិស្ត្រី។ យន្តការទាំងនេះគួរខិតខំរួមបញ្ចូលអង្គការស្ត្រីដោយមិនគិតពីជាតិពន្ធុ អាយុ[334] សាសនា ពិការភាព ភាសា និងទំនោរផ្លូវភេទ ព្រោះលក្ខណៈចម្រុះនៃភាពជាតំណាង អាចផ្តល់ការពិពណ៌នាកាន់តែសុក្រឹតអំពីបញ្ហាទាំងនេះ។ ភាគរយទាបនៃការចូលរួមប្រកបដោយអត្ថន័យរបស់អង្គការសង្គមស៊ីវិលអាចបង្ហាញពីកង្វះទំនុកចិត្តឬកង្វះការរៀបចំផែនការភស្តុភារ ឬទាំងពីរ។

៣. **ភាពសមស្រប និងភាពអាចទទួលបាន** ៖ ភាគរយនៃដំណើរការសម្របសម្រួលដែលពាក់ព័ន្ធនឹងក្រុមនគរបាលនៅមូលដ្ឋានដែលពឹងផ្អែកលើអ្នកជំនាញយេនឌ័រ។ អ្នកជំនាញយេនឌ័រគួរដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់បរិបទអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាមួយអ្នកផ្តល់សេវាសំខាន់ៗ ដូចជា នគរបាល និងជួយឱ្យពួកគេជានាថា ពួកគេ និងសហគមន៍យល់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អ្នកជំនាញយេនឌ័រអាចជួយធានាក្របខណ្ឌទស្សនៈវិជ្ជារួមនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី រវាងអ្នកផ្តល់សេវាសំខាន់ៗ។

៤. **សុវត្ថិភាពជាចម្បង** ៖ ភាគរយនៃដំណើរការសម្របសម្រួលដែលពាក់ព័ន្ធនឹងក្រុមនគរបាលនៅមូលដ្ឋានដែលបានបង្កើតឱ្យមានមន្ត្រីទំនាក់ទំនង ឬមន្ត្រីបង្គោលដែលត្រួតពិនិត្យពិធីសារស្តីពីសុវត្ថិភាព និងការការពារជនរងគ្រោះ (សូមមើលប្រអប់ ១០ ស្តីពីតួនាទីត្រួតពិនិត្យរបស់ IFVCCs)។ តួនាទីរបស់មន្ត្រីទំនាក់ទំនង ឬមន្ត្រីបង្គោល គួរត្រូវបានផ្លាស់ប្តូរក្នុងចំណោមអ្នកផ្តល់សេវាឯកទេសសំខាន់ៗដើម្បីធានាលំហូរព័ត៌មានជាពិសេសព័ត៌មានស្តីពីការវាយតម្លៃហានិភ័យ និងការសម្របសម្រួលវិធានការសុវត្ថិភាព និងវិធានការការពារតាមរយៈការស៊ើបអង្កេតផ្សេងៗ។ តួនាទីនេះគួររួមបញ្ចូលការយល់ដឹងរួមពីតួនាទីរបស់តួអង្គផ្សេងៗ និងព័ត៌មានបច្ចុប្បន្នភាពស្តីពីចំណុចខ្វះខាតក្នុងប្រព័ន្ធនេះ[335] ។

៥. **ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ និងភាពអាចទទួលបាន** ៖ ភាគរយនៃដំណើរការសម្របសម្រួលពាក់ព័ន្ធនឹងក្រុមនគរបាលនៅមូលដ្ឋានដែលពិនិត្យឡើងវិញលើគោលនយោបាយ នីតិវិធី និងពិធីសារស្តង់ដារសម្រាប់អន្តរាគមន៍អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ គួរផ្តោតសំខាន់លើការអនុលោមតាមក្រមសីលធម៌ស្តីពីការយល់ព្រម និងការរក្សាការសម្ងាត់ដោយនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗ ផ្សេងទៀត សម្រាប់ស្ត្រី និងក្មេងស្រីគ្រប់រូប រួមទាំងស្ត្រី និងក្មេងស្រីដែលមានពិការភាពផ្នែកបញ្ញាស្មារតី ការលំបាកក្នុងការរៀនសូត្រ ឬពិការភាពផ្នែកវិញ្ញាណ។

334. យន្តការសម្របសម្រួលគួរធានាថាមានអ្នកស្តាប់សំឡេងរបស់ស្ត្រីវ័យក្មេង និងក្មេងស្រី ដោយផ្តោតការយកចិត្តទុកដាក់លើភាពងាយរងគ្រោះរបស់ពួកគេ។ ដូចគ្នានេះដែរ យន្តការសម្របសម្រួលគួរធានាការដោះស្រាយតម្រូវការជាក់លាក់ និងបញ្ហាប្រឈមរបស់ស្ត្រី និងក្មេងស្រីមានពិការភាពនៅពេលស្វែងរកយុត្តិធម៌។

335. ដកស្រង់ចេញពី "ទិដ្ឋភាពរួមនៃការអនុវត្តល្អទូទាំងពិភពលោកសម្រាប់ការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងជួយដល់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ" (អគ្គនាយកដ្ឋានគោលនយោបាយផ្ទៃក្នុង នាយកដ្ឋានគោលនយោបាយ ៖ សិទ្ធិពលរដ្ឋ និងកិច្ចការរដ្ឋធម្មនុញ្ញ សមភាពយេនឌ័រ សភាអឺរ៉ុប ២០១៣)។

៦. **ទំនាក់ទំនង និងការចូលរួមដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា** ៖ ចំនួនក្នុងមួយឆ្នាំៗនៃការបណ្តុះបណ្តាលស្តាប័នរួមស្តីពីដំណើរការសម្របសម្រួលដែលពាក់ព័ន្ធនឹងនគរបាលនៅប៉ុស្តិ៍។ ចំណុចនេះ គួររួមបញ្ចូលការពង្រឹងការយល់ដឹងរួមអំពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និយមន័យទូទៅការបញ្ជាក់ឡើងវិញពីក្តីរំពឹងទុក និងការអនុវត្តល្អបំផុត និងរបៀបដែលអន្តរាគមន៍ពីវិស័យនីមួយៗរួមចំណែកដល់ការបង្កើនសុវត្ថិភាពរបស់ជនរងគ្រោះ។

៧. **ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន** ៖ ភាគរយនៃក្រុមនគរបាលដែលបានធ្វើការសិក្សាដើមគ្រាដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំផែនការប្រតិបត្តិការនិងកំណត់ឧបសគ្គរាំងការសម្របសម្រួលដោយជោគជ័យ។ ការពិនិត្យតាមដាន និងវាយតម្លៃផ្តល់ឱកាសស្វែងយល់ និងរៀនសូត្រថាតើប្រព័ន្ធដែលមានការសម្របសម្រួលបំពេញមុខងារដោយរបៀបណា។ ការចែករំលែកលទ្ធផលរកឃើញពីការពិនិត្យតាមដាន និងវាយតម្លៃ ជួយដល់ការកែលម្អការឆ្លើយតបដែលមានការសម្របសម្រួល ហើយអ្នកពាក់ព័ន្ធអាចចូលរួម និងធ្វើសេចក្តីសម្រេចចិត្តលើការកែលម្អ។

៨. **ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការសម្របសម្រួល** ៖ ចំនួននៃការវាយតម្លៃ ឬការពិនិត្យឡើងវិញដោយឯករាជ្យ (ប៉ុន្តែរក្សាការសម្ងាត់) លើភាពជាដៃគូរបស់នគរបាលដែលពាក់ព័ន្ធនឹងក្រុមនគរបាលនៅមូលដ្ឋានដែលកំណត់យកយុទ្ធសាស្រ្តឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាចំណុចដៅ។ ការវាយតម្លៃ ឬការពិនិត្យឡើងវិញទាំងនេះអាចបង្ហាញប្រសិទ្ធភាពនៃការសម្របសម្រួលរវាងស្ថាប័ន ឬអភិក្រមសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការវាយតម្លៃអាចធ្វើឡើងតាមរយៈ ៖

- ការអង្កេតការយល់ឃើញជាសាធារណៈ និងការសម្ភាសន៍ក្រុមគោលដៅស្តីពីការអនុវត្តការងាររបស់នគរបាល និងស្ថានភាពសុវត្ថិភាព និងសន្តិសុខក្នុងសហគមន៍
- ការធ្វើរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងជាសាធារណៈស្តីពីនគរបាល ការវិភាគរបាយការណ៍បណ្តាញផ្សព្វផ្សាយ
- ការកត់ត្រាពីសកម្មភាពរបស់នគរបាល-សហគមន៍
- ការវិភាគនិន្នភាពនៃវេទិកាសាធារណៈផ្លូវការនិងក្រៅផ្លូវការ[336]។ល។

**ប្រអប់ ៥**

**គំនិតផ្តួចផ្តើមជាវិជ្ជមានសម្រាប់ការសម្របសម្រួលនៅ Illinois និង Oromina**
**ក្រុមប្រឹក្សាសម្របសម្រួលអំពើហិង្សាក្នុងគ្រួសារ (IFVCC) Illinois សហរដ្ឋអាមេរិក***

ក្រុមប្រឹក្សាសម្របសម្រួលអំពើហិង្សាក្នុងគ្រួសារ (IFVCC) ត្រូវបានផ្តួចផ្តើមឡើងដោយតុលាការកំពូល Illinois នៅឆ្នាំ ១៩៩០ ទាំងសម្រាប់កម្រិតរដ្ឋ និងកម្រិតមូលដ្ឋាន/តំបន់។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើង និងធ្វើជាប្រធានដោយប្រធានចៅក្រម និងចៅក្រមតំបន់ និងមានសមាសភាពអ្នកធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតគោលនយោបាយដែលតំណាងឱ្យស្ថាប័ន និងសេវាអន្តរាគមន៍ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។ ក្រុមប្រឹក្សានេះពាក់ព័ន្ធនឹងនគរបាល ស្ថាប័នយុត្តិធម៌ និងអង្គការសង្គមស៊ីវិល។ ក្រុមប្រឹក្សានេះផ្តល់វេទិកាសម្រាប់ការកែលម្អការឆ្លើយតបរបស់ស្ថាប័ន អ្នកជំនាញ និងសហគមន៍ទៅនឹងអំពើហិង្សាក្នុងគ្រួសារ។ ពួកគេផ្តល់ការអប់រំវិជ្ជាជីវៈ និងការទប់ស្កាត់សម្របសម្រួលអន្តរាគមន៍ និងសេវាសម្រាប់ជនរងគ្រោះ និងជនបង្ក ព្រមទាំងរួមចំណែកដល់ការកែលម្អប្រព័ន្ធច្បាប់ និងការគ្រប់គ្រងយុត្តិធម៌។

ដើម្បីជាជំនួយដល់ការសម្របសម្រួល គណៈកម្មាធិការដឹកនាំបានរៀបចំកិច្ចប្រជុំជាប្រចាំដែលចូលរួមដោយតុលាការ និងអយ្យការ នគរបាលរដ្ឋ នាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល។

336. សូមមើល "ការអនុវត្តល្អក្នុងការកសាងភាពជាដៃគូរវាងនគរបាល និងសាធារណជន ដោយទីប្រឹក្សានគរបាលជាន់ខ្ពស់ ជាក់ជូនអគ្គលេខា OSCE (អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប ២០០៨)។

ក្រុមការងារដែលមានសមាសធាតុសមាជិកគណៈកម្មាធិការផ្តល់ប្រឹក្សា បុគ្គលិក IFVCC នៅ Illinois អ្នកសម្របសម្រួលក្រុមប្រឹក្សានៅមូលដ្ឋាន និងសមាជិកក្រុមប្រឹក្សាសម្របសម្រួលអំពើហិង្សានៅមូលដ្ឋាន ពិនិត្យឡើងវិញលើពិធីសារ ធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈ និងបង្កើតធនធានថ្មីៗសម្រាប់ពិធីសារស្តីពីការសម្របសម្រួល និងការឆ្លើយតប។ល។ ឧ. នៅឆ្នាំ ២០១៨ IFVCC បានចូលរួមក្នុងការពិនិត្យឡើងវិញលើពិធីសាររបស់អយ្យការសម្រាប់ការឆ្លើយតបទៅនឹងជនរងគ្រោះដែលមានពិការភាព និងមនុស្សពេញវ័យដែលរងគ្រោះដោយការប្រទូស្តកេរខ្មាស អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬការកេងប្រវ័ញ្ច។

ប្រភព ៖ ក្រុមប្រឹក្សាសម្របសម្រួលអំពើហិង្សាក្នុងគ្រួសារ (IFVCC) និងពិធីសាររបស់អយ្យការសម្រាប់ការឆ្លើយតបទៅនឹងជនរងគ្រោះដែលមានពិការភាព និងមនុស្សពេញវ័យដែលរងគ្រោះដោយការប្រទូស្តកេរខ្មាស អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬការកេងប្រវ័ញ្ច (រដ្ឋ Illinois អាជ្ញាធរព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ Illinois)។

## មណ្ឌលផ្តល់សេវាចម្រុះ ប្រទេសអេត្យូពី

មណ្ឌលផ្តល់សេវាចម្រុះនៅតំបន់ Oromia ត្រូវបានរដ្ឋាភិបាលអេត្យូពីបង្កើតឡើងដំបូងនៅក្រុង Adama ក្នុងឆ្នាំ ២០១៣ ដោយមានការគាំទ្រពី UNICEF។ មជ្ឈមណ្ឌលនេះផ្តល់សេវាវេជ្ជសាស្ត្រ-ច្បាប់ (កោសលវិច័យ) និងសេវាចិត្តសង្គមដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទដែលអាចទទួលបានសេវាទាំងអស់ក្រោមការសម្របសម្រួលពីនគរបាល និងអយ្យការនៅនឹងកន្លែង។

ក្រោយមក មណ្ឌលពីរផ្សេងទៀតត្រូវបានបង្កើតឡើងនៅក្រុង Shashamane និងក្រុង Jimma។ ចាប់ពីពេលនោះមក រដ្ឋាភិបាលបានធ្វើឱ្យមណ្ឌលទាំងនេះមានស្តង់ដារតាមរយៈការបង្កើតនីតិវិធីប្រតិបត្តិស្តង់ដារ និងយុទ្ធសាស្ត្រ។ នៅក្រុង Adama ក្នុងតំបន់ Oromia * បុគ្គលិកមជ្ឈមណ្ឌលផ្តល់សេវាចម្រុះ គឺជាបុគ្គលិកសង្គមកិច្ចដែលត្រូវបានបណ្តុះបណ្តាល និងមានការប្តេជ្ញាចិត្ត អយ្យការ មន្ត្រីនគរបាល គិលានុបដ្ឋាក ស្មៀន វេជ្ជបណ្ឌិត និងពេទ្យជំនាញវិកលចរិក ។ មណ្ឌលនេះផ្សារភ្ជាប់ជាមួយនឹងការិយាល័យកិច្ចការនារី កុមារ និងយុវជន ការិយាល័យអគ្គរដ្ឋអាជ្ញានគរបាល តុលាការជាន់ខ្ពស់ពិសេស និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន1។

ការិយាល័យអគ្គរដ្ឋអាជ្ញាធ្វើការត្រួតពិនិត្យតាមរយៈគណៈកម្មាធិការដឹកនាំពហុវិស័យ។ គណៈកម្មាធិការនេះគ្រប់គ្រង និងសម្របសម្រួលការផ្តល់សេវាសំខាន់ៗ ដូចជា ការស៊ើបអង្កេតដោយនគរបាល ការពិគ្រោះយោបល់ការព្យាបាលវេជ្ជសាស្ត្រ និងជំនួយផ្លូវច្បាប់ដោយមិនគិតថ្លៃ។

មណ្ឌលផ្តល់សេវាចម្រុះ ជះឥទ្ធិពលលើស្ថាប័នសម្របសម្រួលថ្នាក់ជាតិដែលទទួលបន្ទុកលើការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលដឹកនាំដោយអគ្គរដ្ឋអាជ្ញាសហព័ន្ធ។ ស្ថាប័ននេះគាំទ្រដោយឧបករណ៍ប្រតិបត្តិការ ដូចជា យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ៥ ឆ្នាំ។ បច្ចុប្បន្ន ដោយមានការគាំទ្រពី UN Women គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលបានកៀរគរវិស័យតុលាការទាំង ៣ (នគរបាល អយ្យការសាធារណៈ និងចៅក្រម) សម្រាប់ការបណ្តុះបណ្តាលស្តង់ដារស្តីពីរបៀបសម្របសម្រួល និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។គំនិតផ្តួចផ្តើមនេះបានចាប់ផ្តើមឡើងនៅឆ្នាំ២០១៦ក្នុងរដ្ឋតំបន់មួយដើម្បីពង្រឹងការសម្របសម្រួល និងបង្កើតអត្រាកាត់ទោសករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងតំបន់នោះ។

*ប្រភព ៖ Kefetew, K. 'Providing a coordinated response to survivors of sexual violence in the Oromia Region, Ethiopia' (UNICEF, 2019)

៨

# កំណត់សម្គាល់ និងអំណានបន្ថែម

1 Good Practices in Building Police-Public Partnerships by the Senior Police Adviser to the OSCE Secretary General (The Organization for Security and Co-operation in Europe, 2008), see: https://www.osce.org/secretariat/32547?download=true

2 Anneke Osse, Understanding Policing: A Resource for Human Rights Activists (Amnesty International, 2006)

3 Community-Oriented Policing in United Nations Peace Operations Manual (UN DPO, 2018), see: https://police.un.org/sites/default/files/manual-community-oriented-poliicing.pdf

4 Guidelines for Integrating Gender-Based Violence Interventions in Humanitarian Action: Reducing risk, promoting resilience and aiding recovery (Inter-Agency Standing Committee, 2015), see: https://gbvguidelines.org/wp/wp-content/uploads/2015/09/2015-IASC-Gender-based-Violence-Guidelines_lo-res.pdf

5 Module 5: Coordination and Governance of Coordination, Essential Services Package for Women and Girls subject to Violence: Core Elements and Quality Guidelines (United Nations Joint Global Programme on Essential Services for Women and Girls Subject to Violence, 2015), see: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2015/essential-services-package-module-5-en.pdf?la=en&vs=3759

6 Good Practices in Building Police-Public Partnerships by the Senior Police Adviser to the OSCE Secretary General (The Organization for Security and Co-operation in Europe, 2008).

7 'Understanding local security councils in two minutes' Coginta for Police Reforms, see: https://www.youtube.com/watch?v=7fGFo_nteGA

8 Qu'est ce qu'un CLSPD - CISPD? (Government of France), see: http://www.isere.gouv.fr/Politiques-publiques/Securites/Securite-publique/Prevention-de-la-delinquance2/Qu-est-ce-qu-un-CLSPD-CISPD

9 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée' (Coginta for Police Reform, 2017), see : http://www.coginta.org/uploads/documents/cedd246fbc7d133bcf29135bec8a66d561202ae4.pdf

10 Fernandez, M., Piaget, K., Hernandez, T., and Berthoud, S., "Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR?' ISSAT HRBA Working Group Paper 3 (2017), see: https://issat.dcaf.ch/download/111714/2027474/HRBA%20Working%20Group%20Paper%203.pdf

11 'Aspects of violence against women that pertain directly to the Commission on Crime Prevention and Criminal Justice', Commission on Crime Prevention and Criminal Justice V.08-52191 (E) *0852191* (Seventeenth session, Vienna, 14-18 April 2008).

12 UN Women: Flagship Programme Initiatives, see: https://www.unwomen.org/en/how-we-work/flagship-programmes

13 Benefits of Coordination. Stop Violence against Women: A Project of The Advocates for Human Rights, see: http://www.stopvaw.org/Benefits_of_Coordination.html

14 A Study for Creating a Multidisciplinary Response Mechanism to Violence Against Women in Egypt (UNODC, 2015).

15 Manual on the law relating to violence against women, England and Wales, Greece, Ireland, Italy, Northern Ireland, Poland, Spain (European Lawyers Foundation, 2018), see: https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

16 Thematic study on the issue of violence against women and girls and disability, Report of the Office of the United Nations High Commissioner for Human Rights, 30 March 2012, (A/HRC/20/5) at: https://www2.ohchr.org/english/issues/women/docs/A.HRC.20.5.pdf

17 Submission to the Special Rapporteur on the Rights of Persons with Disabilities: Good Practices for Increasing Effective Access to Justice for Women and Girls with Disabilities, (Women Enabled International, August 9, 2019) at: https://www.womenenabled.org/pdfs/WEI%20Access%20to%20Justice%20Good%20Practices%20Submission%20to%20UN%20Special%20Rapporteur%20on%20Persons%20with%20Disabilities,%20Aug%209,%202019.pdf

18 Manual on Community-Oriented Policing in United Nations Peace Operations (UN DPO, 2018), see: https://police.un.org/en/manual-community-oriented-policing-in-peace-operations

19 UN Police Gender Toolkit: Standardised Best Practices on Gender Mainstreaming in Peacekeeping: Compendium of Project Tools (2015), see: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20

Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

20 Prosecutor Protocol for Responding to Victims with Disabilities and Older Adults who Experience Sexual Assault, Domestic Violence, Abuse, Neglect or Exploitation (State of Illinois, Illinois Criminal Justice Information Authority), at: http://www.icjia.state.il.us/assets/ifvcc/Model%20Protocols/PWD_OA_Prosecutor_Protocol_113018.pdf

21 Family Violence Coordinating Councils (IFVCC), Illinois, see: http://www.icjia.state.il.us/ifvcc

22 Prosecutor Protocol for Responding to Victims with Disabilities and Older Adults who Experience Sexual Assault, Domestic Violence, Abuse, Neglect or Exploitation, (State of Illinois, Illinois Criminal Justice Information Authority), at: http://www.icjia.state.il.us/assets/ifvcc/Model%20Protocols/PWD_OA_Prosecutor_Protocol_113018.pdf

23 Kefetew, K., Providing a coordinated response to survivors of sexual violence in the Oromia Region, Ethiopia (UNIFEF, 2019), see: https://www.unicef.org/ethiopia/stories/providing-coordinated-response-survivors-sexual-violence-oromia-region

9

# ទំនាក់ទំនង

“ទំនាក់ទំនងជាគន្លឹះក្នុងការកសាងទំនុកចិត្ត និងសម្រេចបានគោលដៅប្រកបដោយ ប្រសិទ្ធភាព”។

ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥

# គោលបំណងនៃជំពូកទី ៩

**នគរបាលអាចបង្កើនភាពអង់អាចរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងប្រព័ន្ធយុត្តិធម៌បាន តាមរយៈការប្រាស្រ័យទាក់ទង និងការស្ដាប់ដែលធានាបាននូវអារម្មណ៍កក់ក្ដៅ ដើម្បីអាចចាប់បាននូវតម្រូវការផ្នែកយុត្តិធម៌របស់ជនរងគ្រោះនិងជំរុញទំនាក់ទំនងដោយផ្អែកលើការរក្សាការសម្ងាត់ និងឯកជនភាព។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការកំណត់រក និងដោះស្រាយភាពលម្អៀងយេនឌ័រ និងភាពលម្អៀងអវិជ្ជមានប្រទាក់ក្រឡាគ្នាផ្សេងទៀត ដែលបង្ហាញឡើងដោយបុគ្គលិក គឺជាផ្នែកមួយនៃការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង/ប្រធានក្រុម។
- ការប្រើប្រាស់ជំនាញស្ដាប់ "យ៉ាងយកចិត្តទុកដាក់" គឺជាផ្នែកដ៏សំខាន់មួយនៃការធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ ដើម្បីធានាថាពួកគេមិនត្រូវបានវិនិច្ឆ័យដោយ "អ្នកស្ដាប់" នៅពេលរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួន។
- កសាងទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយជនរងគ្រោះ ដើម្បីធ្វើយ៉ាងណាឱ្យគាត់មានទំនុកចិត្តលើរឿងរ៉ាវរបស់គាត់ ផ្ដល់សុពលភាពដល់គាត់ និងបញ្ជាក់អះអាងជាថ្មីថា គាត់មិនត្រូវបានស្ដីបន្ទោសឡើយ។
- ពន្យល់ពេញលេញអំពីការស៊ើបអង្កេត និងដំណើរការយុត្តិធម៌ និងរក្សាទំនាក់ទំនងដើម្បីផ្ដល់ព័ត៌មានបច្ចុប្បន្នភាពដែលមានការសម្របសម្រួល។
- កង្វះជំនាញទំនាក់ទំនងជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កការប៉ះទង្គិចផ្លូវចិត្តយូរអង្វែង និងនាំឱ្យមានការរាយការណ៍ពីចំនួនករណីក្រោមចំនួនករណីពិតប្រាកដ។
- ភាពលម្អៀងយេនឌ័រកើតឡើងពីកង្វះការយល់ដឹងអំពីការរើសអើង ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី។
- កង្វះការយល់ព្រមគឺជាប្រជ្ញទូលនៃអំពើហិង្សាផ្លូវភេទ និងបទល្មើសផ្អែកតាមភេទ។



**សេចក្តីផ្តើម**

**ក្រោយពីការចូលរួមជារៀងរាល់ថ្ងៃជាមួយសហគមន៍ និងជនរងគ្រោះដោយសារអំពើហិង្សា និងបទល្មើស នគរបាលត្រូវចូលរួមជាមួយស្ថាប័នយុត្តិធម៌ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានដើម្បីធានាការផ្តល់សេវាសំខាន់ៗ។ ដូច្នេះ នគរបាលប្រហែលជាត្រូវមានជំនាញអន្តរបុគ្គលដើម្បីអាចធ្វើទំនាក់ទំនងដោយប្រសិទ្ធភាព។**

រូបថតទទួលបានពី UNIFIL/Pasqual Gorriz (ប្រទេសលីបង់)

នៅខាងក្រៅនគរបាលជួរមុខចូលរួមជាមួយជនរងគ្រោះ និងពលរដ្ឋពាក់ព័ន្ធមកពីគ្រប់សាវតារ។ ចំណុចនេះទាមទារឱ្យមានការបង្ហាញសមានចិត្ត ក្តីមេត្តា ទំនាក់ទំនងមិនមែនពាក្យសម្តី និងការស្តាប់យ៉ាងយកចិត្តទុកដាក់ បូករួមនឹងសមត្ថភាពកែសម្រួលរបៀបទំនាក់ទំនងទៅតាមតម្រូវការរបស់គូសន្ទនាដោយផ្អែកតាមអាយុកម្រិតអប់រំ សមត្ថភាពស្តាប់ និង/ឬយល់។

នៅកម្រិតបុគ្គល ជំនាញទាំងនេះជាគន្លឹះក្នុងការធានាការអះអាងចំពោះជនរងគ្រោះសម្រួលអារម្មណ៍របស់ពួកគេ កាត់បន្ថយកម្រិតនៃអំពើហិង្សាជានាភាពច្បាស់លាស់នៅពេលផ្តល់ព័ត៌មានអំពីតួនាទី និងដំណើរការនានា(កែសម្រួលទៅតាមអ្នកដែលត្រូវធ្វើទំនាក់ទំនងជាមួយ) និងបង្កើតទំនាក់ទំនងការងារ ឬទំនាក់ទំនងបែបសហការដើម្បីដោះស្រាយបញ្ហាសន្តិសុខសាធារណៈ។

នៅកម្រិតស្ថាប័នមន្ត្រីនគរបាលគ្រប់រូប(មិនគិតឋានន្តរសក្តិ) ត្រូវត្រៀមខ្លួនចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយតំណាងសហគមន៍ សង្គមស៊ីវិល តំណាងស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងៗ និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត។ ក្នុងពេលចូលរួម ទំនាក់ទំនងរបស់នគរបាលគួរមានតម្លាភាព បង្ហាញច្បាស់ពីក្តីរំពឹងទុក និងតួនាទី ស៊ីសង្វាក់គ្នាមានភាពផ្អែកតាមដំណោះស្រាយប្រកបដោយបរិយាបន្ន និងមានភាពសហការគ្នា។

> “ទំនាក់ទំនងពាក់ព័ន្ធនឹងការធ្វើអន្តរកម្មជាមួយសហគមន៍ ការស្តាប់ទស្សនៈនិងមតិរបស់ពួកគេនិងការធ្វើសកម្មតាមរបៀបដែលបង្កើនការអនុវត្តការងាររបស់នគរបាល និងការផ្តល់សេវា”។
>
> មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស

ក្នុងស្ថាប័នរបស់ខ្លួនទំនាក់ទំនងអន្តរបុគ្គលរបស់នគរបាលត្រូវប្រកាន់ខ្ជាប់ក្រមប្រតិបត្តិ ក្របខណ្ឌសុចរិតភាព (ផ្អែកតាមទ្រឹស្តី) និងមានក្តីរំពឹងទុកជាក់លាក់ពីថ្នាក់ដឹកនាំពាក់ព័ន្ធនឹងការទទួលខុសត្រូវលើការដាក់បទបញ្ជា។ អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរពង្រឹងក្រមក្របខណ្ឌ និងក្តីរំពឹងទុកទាំងនេះជាប្រចាំថ្ងៃ និងបញ្ចុះបញ្ចូលបុគ្គលិករបស់ខ្លួនដើម្បីធានាថាវិន័យ និងសុចរិតភាពគាំទ្រដល់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រតិបត្តិការ។

ចំណុចនេះគួររួមបញ្ចូលការបញ្ជាក់ឱ្យច្បាស់ នៅពេលមន្រ្តីនគរបាលដូចគ្នា ឬក្រុមមន្រ្តីនគរបាលមិនយល់ ឬមានសំនួរទាក់ទងនឹងគោលនយោបាយជាតិ ឬសេចក្តីសម្រេចរបស់ស្ថាប័ន។ការដោះស្រាយអំពើហិង្សាលើស្រ្តី និងក្មេងស្រី និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រជាប្រធានបទដែលបំផុសឱ្យមានភាពលម្អៀងអវិជ្ជមានជាច្រើនដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងស្តែងចេញឱ្យឃើញច្បាស់ព្រោះវាពាក់ព័ន្ធនឹងបទដ្ឋានសង្គមនិងវប្បធម៌តាមការសន្មតដែលមានលក្ខណៈបិតាធិបតេយ្យ និងរើសអើង។

**ភាពលម្អៀងយេនឌ័រជាទំនោរឆ្ពោះទៅរក ឬបុរេនិច្ឆ័យលើយេនឌ័រមួយធៀបនឹងយេនឌ័រផ្សេងទៀត។ ភាពលម្អៀងយេនឌ័រ មិនថាមិនស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយមិនដឹងខ្លួន) ឬស្តែងចេញឱ្យឃើញច្បាស់ (កើតឡើងដោយដឹងខ្លួន) ត្រូវបានកំណត់និងផ្អែកតាមផ្នត់គំនិត និងឥរិយាបថផ្អែកលើយេនឌ័រដែលកំណត់នូវចរិតលក្ខណៈ តួនាទីនិងអាកប្បកិរិយាផ្សេងៗរបស់បុរស ធៀបនឹងស្រ្តី ហើយមានរួមបញ្ចូលនូវតួនាទី និងអាកប្បកិរិយាផ្លូវភេទផងដែរ។**

ដោយសារតែមន្រ្តីនគរបាលជាច្រើនអាចមិនមានការយល់ដឹងគ្រប់គ្រាន់ អំពីគ្រោះថ្នាក់នៃភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងភាពលម្អៀងដែលស្តែងចេញឱ្យឃើញច្បាស់លើសេវានគរបាល ជាទូទៅជារឿងធម្មតាដែលពួកគេដេញដោលអំពីភាពពាក់ព័ន្ធ និង/ឬភាពអាចអនុវត្តបាននៃគោលនយោបាយនិងយុទ្ធសាស្រ្តដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ដែលទាមទារឱ្យពួកគេធ្វើការផ្លាស់ប្តូរឥរិយាបថ។

អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរដឹកនាំធ្វើជាគំរូនិងត្រៀមខ្លួនកំណត់រកភាពលម្អៀងយេនឌ័រ និងភាពលម្អៀងអវិជ្ជមានប្រទាក់ក្រឡាគ្នាផ្សេងទៀត[337] និងដោះស្រាយការដេញដោលឬឥរិយាបថខ្លាចរអានៅពេលភាពលម្អៀងទាំងនេះលេចឡើងដោយបង្ហាញច្បាស់ពីគោលបំណងនៃក្របខណ្ឌ គោលនយោបាយ ឬក្រមប្រតិបត្តិចំពោះសុវត្ថិភាពសាធារណៈអត្ថប្រយោជន៍សម្រាប់សហគមន៍ និងសេវានគរបាលជារួមក៏ដូចជាផលវិបាកនៅពេលមិនអនុលោមតាម។

ការសំខាន់គឺកម្មវិធីបណ្តុះបណ្តាលមន្រ្តី និងប្រព័ន្ធគាំទ្រស្ថាប័ន (ដូចជា គម្រោងផ្តល់ការណែនាំ) ផ្តល់ជំនាញទំនាក់ទំនងអន្តរបុគ្គល និងឧបករណ៍ពាក់ព័ន្ធនៅពេលត្រៀមខ្លួនមន្រ្តីនគរបាលសម្រាប់តួនាទីដាក់បទបញ្ជា ដើម្បីឱ្យពួកគេមានគោលជំហររឹងមាំក្នុងការកាត់បន្ថយផលប៉ះពាល់នៃភាពលម្អៀងអវិជ្ជមានដែលរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលក្នុងការស៊ើបអង្កេត និងទប់ស្កាត់អំពើហិង្សាលើស្រ្តី និងក្មេងស្រី។

ការបណ្តុះបណ្តាលនិងប្រព័ន្ធគាំទ្រទាំងនេះទាមទារគោលនយោបាយ និងយុទ្ធសាស្រ្តស្ថាប័ន និងត្រូវពង្រឹងដោយថ្នាក់ដឹកនាំជាន់ខ្ពស់ដែលមានការប្តេជ្ញាចិត្ត និងត្រៀមខ្លួនផ្តោតអាទិភាពលើជំនាញទំនាក់ទំនងដែលគិតគូរពីយេនឌ័រ ដែលជាសមត្ថភាពគន្លឹះសម្រាប់ការផ្តល់សេវានគរបាលប្រចាំថ្ងៃ។ចំណុចនេះគឺសំខាន់ខ្លាំងណាស់ដោយសារតែចំនួនឧប្បត្តិហេតុពាក់ព័ន្ធនឹងអំពើហិង្សាលើស្រ្តី

337. ភាពលម្អៀងដែលជះឥទ្ធិពលលើឥរិយាបថនិងអាកប្បកិរិយាពាក់ព័ន្ធនឹងកត្តាប្រសព្វគ្នាផ្សេងៗ ដូចជា យេនឌ័រ អាយុ ពិការភាព ជាតិពន្ធុ ទំនោរផ្លូវភេទ និងសាវតាសង្គមសេដ្ឋកិច្ច។ល។

និងក្មេងស្រីដែលនគរបាលឆ្លើយតបប្រចាំថ្ងៃនិងការដែលអំពើហិង្សាលើដៃគូស្និទ្ធស្នាលមិនមែនជាព្រឹត្តិការណ៍តែមួយក្នុងអំឡុងពេលមួយ។ ដូច្នេះ ជារឿយៗ នគរបាលនឹងចូលរួមជាថ្មីជាមួយជនរងគ្រោះ និងជនបង្កដដែលៗ។

**ការគិតគូរពីយេនឌ័រ ពិចារណាពីតម្រូវការ និងទស្សនៈរបស់ជនរងគ្រោះ ដោយគោរពសេចក្ដីថ្លៃថ្នូរ និងសុចរិតភាពរបស់ជនរងគ្រោះ និងកាត់បន្ថយការរំលោភបំពាន ទន្ទឹមនឹងការគោរពតាមស្តង់ដារនៃការប្រមូលភស្តុតាងកោសលវិច័យ។**

ចំណុចនេះគួបផ្សំនឹងតម្រូវការនគរបាលជួរមុខប្រចាំថ្ងៃដើម្បីធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយមនុស្សដែលមានសាវតារចម្រុះក្រោមលក្ខខណ្ឌប្រែប្រួល និងជាញឹកញាប់មិនអាចព្យាករណ៍បាន។

គោលនយោបាយនិងយុទ្ធសាស្ត្រទាំងនេះត្រូវមានលក្ខណៈផ្លាស់ប្តូរ និងមានគោលដៅច្បាស់លាស់ក្នុងការបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នដើម្បីឱ្យនគរបាលកាន់តែអាចឆ្លើយតបទៅនឹងយេនឌ័រ[338] ក្នុងនាមជាស្ថាប័នសាធារណៈនិងអ្នកមានភារកិច្ច។ ការបង្កប់សមត្ថភាពដែលឆ្លើយតបនឹងយេនឌ័រ និងកម្រងជំនាញ ដូចជា ជំនាញទំនាក់ទំនងដែលគិតគូរពីយេនឌ័រ គឺជាចំណុចស្នូលនៃដំណើរការផ្លាស់ប្តូរ។

ដូច្នេះ គោលនយោបាយ និងយុទ្ធសាស្ត្រផ្លាស់ប្តូរ ត្រូវរំលេចក្នុងការបង្កើតបេសកកម្ម និងទស្សនៈវិស័យរបស់ស្ថាប័ននគរបាល និងក្នុងគោលបំណងជាយុទ្ធសាស្ត្ររបស់ស្ថាប័ននេះនៅកម្រិតខ្ពស់បំផុត ដើម្បីផ្តល់ជាមូលដ្ឋានដល់អ្នកគ្រប់គ្រងថ្នាក់កណ្ដាលក្នុងជួរនគរបាល រួមចំណែកជះឥទ្ធិពលលើការផ្លាស់ប្តូរដែលចង់បាន តាមរយៈការលើកកម្ពស់ជំនាញទំនាក់ទំនងដែលគិតគូរពីយេនឌ័រក្នុងដំណើរការនេះ។ សូមមើលជំពូកទី ១០ (ការកសាងស្ថាប័នដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី) និងជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ការពិភាក្សាបន្ថែមទៀតស្តីពីការផ្លាស់ប្តូរក្នុងស្ថាប័នដើម្បីឱ្យមានការផ្លាស់ប្តូរក្នុងជួរនគរបាល។



រូបថតទទួលបានពី UNMIT/Martine Perret (ប្រទេសទីម័រខាងកើត)

338. យុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រ មានន័យថា ច្បាប់ ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងលទ្ធផលនៃយុត្តិធម៌ព្រហ្មទណ្ឌ មិនរើសអើងនរណាម្នាក់ដោយសារយេនឌ័រ។ សូមមើល Skinnider, Eileen, 'Towards Gender-Responsive Criminal Justice: Good Practices from Southeast Asia in responding to violence against women (Thailand Institute of Justice, 2018)។

ជំពូកខាងក្រោមមានគោលបំណងផ្តល់ការណែនាំដល់អ្នកគ្រប់គ្រងក្នុងជួរនគរបាល នៅពេលធ្វើទំនាក់ទំនងតាមរបៀបដែលគិតគូរពីយេនឌ័រជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីឱ្យពួកគេយល់ថាទទួលបានភាពអង់អាច ដើម្បីចូលរួមក្នុងការស៊ើបអង្កេតរបស់នគរបាលប្រកបដោយអត្ថន័យ។

ការណែនាំនេះនឹងដោះស្រាយបញ្ហាប្រឈមរបស់អ្នកគ្រប់គ្រងក្នុងជួរនគរបាល នៅពេលខិតខំលើកកម្ពស់ជំនាញទំនាក់ទំនងដែលគិតគូរពីយេនឌ័រសម្រាប់ជំរុញការចូលរួមរបស់ជនរងគ្រោះ និងសហគមន៍ឬអ្នកតស៊ូមតិរបស់ពួកគេ។

> "នគរបាលត្រូវធានាថា ស្ត្រីទទួលបានព័ត៌មានដែលពាក់ព័ន្ធ បានទាន់ពេលវេលា អាចជឿទុកចិត្តបាន និងមានភាពស្មោះត្រង់។ ព័ត៌មានដែលផ្តល់ជូនតាមរបៀបនេះអាចជួយកាត់បន្ថយបទល្មើស។ផ្ទុយទៅវិញប្រសិនបើសហគមន៍ ឬនគរបាលមិនចែករំលែកព័ត៌មាន វាអាចជះឥទ្ធិពលអវិជ្ជមានលើការកាត់បន្ថយបទល្មើស"។
>
> ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥

ជំពូកនេះនឹងមិនលើកឡើងពីទំនាក់ទំនងជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀតឡើយព្រោះចំណុចនេះត្រូវបានពិភាក្សាលម្អិតក្នុងជំពូកទី៨( ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌ ) និងជំពូកទី១២ ( ការបន្តផ្តល់យុត្តិធម៌ )។ មុនខុសពីជំពូកមុនៗនោះទេ អ្នកអានគួរអានជំពូកនេះអមជាមួយនឹងសេវាសំខាន់ៗទី ១០ ( ទំនាក់ទំនង ) ក្នុងម៉ូឌុលទី ៣ (យុត្តិធម៌ និងនគរបាល) នៃកញ្ចប់សេវាសំខាន់ៗ។

ក្រៅពីនេះ អ្នកអានគួរអានជំពូកនេះអមជាមួយនឹងសៀវភៅណែនាំស្តីពីប្រតិបត្តិការសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្របខណ្ឌណែនាំយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព និងឯកសាររបស់ UNODC (ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបរបស់វិស័យយុត្តិធម៌ព្រហ្មទណ្ឌចំពោះអំពើហិង្សាលើស្ត្រី២០១៤)។

## ការណែនាំគ្នាទៅវិញទៅមក

ទំនាក់ទំនងដែលមានប្រសិទ្ធភាពប្រហែលជាទិដ្ឋភាពដ៏សំខាន់ជាងគេមួយ នៅពេលមានការប្រឈមជាមួយជនរងគ្រោះនិងសាក្សីនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ភាសាកាយវិការ (ទំនាក់ទំនងមិនមែនពាក្យសម្តី) ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សារវិជ្ជមាន ឬអវិជ្ជមានដល់ជនរងគ្រោះ ហើយការស្តាប់ "យ៉ាងយកចិត្តទុកដាក់" ជាជំនាញដ៏ចាំបាច់សម្រាប់អ្នកទាំងឡាយណាដែលធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ និងសាក្សីនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ការផ្តល់សារប្រកបដោយប្រសិទ្ធភាព អាស្រ័យលើពាក្យពេចន៍ ទឹកដមសម្តី និងភាសាកាយវិការ។ ការស្រាវជ្រាវបង្ហាញថា ទំនាក់ទំនងនេះជាផលធៀបនៃការបង្ហាញធាតុផ្សំទាំងបីនេះដែលបង្កផលប៉ះពាល់ខ្លាំងបំផុតលើអ្វីដែលអ្នកស្តាប់ទទួលបានពីសារនោះ។

ផលធៀបនេះអាចធ្វើឱ្យអ្នកភ្ញាក់ផ្អើល ព្រោះសារដែលជោគជ័យគឺ ៧% ជាពាក្យសម្តី, ៣៨% ជាទឹកដមសម្តី និង ៥៥% ជាភាសាកាយវិការ។ ចំណុចនេះមានផលវិបាកសម្រាប់អ្នក និងបុគ្គលិករបស់អ្នក ប្រសិនបើអ្នកមិនចាប់ភ្លឹកភាសាកាយវិការផ្ទាល់ខ្លួន ឬប្រសិនបើអ្នកមិនបង្ហាញការយកចិត្តទុកដាក់ឬក្តីមេត្តាតាមរយៈទឹកដមសម្តីរបស់អ្នក។

ក្នុងការផ្តល់ទំនុកចិត្តនិងទំនាក់ទំនងល្អជាមួយជនរងគ្រោះដើម្បីឱ្យគាត់ប្រាប់ពីរឿងរ៉ាវទាំងស្រុង របៀបធ្វើទំនាក់ទំនងជាមួយជនរងគ្រោះគឺសំខាន់ខ្លាំងណាស់។ សូមចាំថា ជនរងគ្រោះអាចមានអារម្មណ៍ភិតភ័យ ព្រោះភ័យខ្លាចផលវិបាកនៃការរាយការណ៍ទៅនគរបាល ការរងគ្រោះដោយសារការប៉ះទង្គិចផ្លូវចិត្ត ឬមានភាពងាយរងគ្រោះ ឬតម្រូវការជាក់លាក់។ ការប្រើប្រាស់ភាសាក៏សំខាន់ណាស់ដែរព្រោះភាសាវិជ្ជមានបង្ហាញពីលទ្ធភាពជម្រើស និងឱកាស ចំណែកភាសាអវិជ្ជមានបង្ហាញពីអ្វីដែលមិន

អាចសម្រេចបាន។

ការស្តាប់យ៉ាងយកចិត្តទុកដាក់ជាជំនាញដ៏មានតម្លៃ និងគាំទ្រដោយការប្រើប្រាស់ភាសាកាយវិការវិជ្ជមាន ដូចជាក្រសែភ្នែកការងក់ក្បាលការបង្ហាញឥរិយាបថវិជ្ជមានដែលអាចធ្វើទំនាក់ទំនងបានជាមួយជនរងគ្រោះ។

ត្រូវគ្រប់គ្រងទំនាក់ទំនងដោយប្រុងប្រយ័ត្នក្នុងបរិបទវប្បធម៌មួយចំនួន ហើយប្រសិនបើជនរងគ្រោះមិនអាចរក្សាក្រសែភ្នែក ដោយសារបទដ្ឋានវប្បធម៌ និង/ឬការប៉ះទង្គិចផ្លូវចិត្តដែលគាត់ធ្លាប់រងគ្រោះ ឬកំពុងប្រឈម ចំណុចនេះមិនមានន័យថា គាត់ចង់លាក់បាំងការពិតនោះទេ។

> "កុមារមិនមែនជាមនុស្សពេញវ័យដែលមានមាឌតូចនោះទេ។ ពួកគេធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍ គិត និយាយ និងប្រព្រឹត្តដោយមិនខ្វល់ពីនរណា តាមរបៀបដែលឆ្លុះបញ្ចាំងពីអាយុ និងការវិវត្តសមត្ថភាពរបស់ខ្លួន។ ប្រសិនបើយើងចង់ឱ្យកុមារអាចចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការយុត្តិធម៌និងទទួលបានការការពារពីគ្រោះថ្នាក់បន្ថែមទៀតយើងត្រូវកែសម្រួលភាសានិងឥរិយាបថរបស់យើងនៅពេលធ្វើទំនាក់ទំនងជាមួយកុមារ"។
>
> សៀវភៅណែនាំស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី (UNODC ២០១៥)

ឱ្យមន្ត្រីរបស់អ្នកគិតពីស្ថានភាពរបស់ជនរងគ្រោះ។ តើជនរងគ្រោះមានអារម្មណ៍បែបណានៅពេលពួកគេព្យាយាមប្រាប់នរណាម្នាក់ពីអ្វីដែលសំខាន់ចំពោះពួកគេហើយអ្នកដទៃហាក់មិនសូវចង់ស្តាប់? ឧ. ពួកគេអាចមិនសំឡឹងមើលជនរងគ្រោះឬអាចបែកអារម្មណ៍ដោយសារសំឡេងទូរស័ព្ទពេទី ឬសារវិទ្យុទាក់ទង។

**សូមមើលជំពូកទី ៤ (ទំនាក់ទំនងដំបូង) សម្រាប់ព័ត៌មានបន្ថែមស្តីពីការនិយាយជាមួយជនរងគ្រោះ។**

បុគ្គលិករបស់អ្នកត្រូវមានគំនិតបើកទូលាយទទួលយកអ្វីដែលជនរងគ្រោះនិយាយប្រាប់ពួកគេនិងធានាថាពួកគេមិនបង្ហាញបុរេនិច្ឆ័យ ការគិតទុកជាមុន ឬការវិនិច្ឆ័យផ្ទាល់ខ្លួនឱ្យជនរងគ្រោះបានឃើញទោះតាមរបៀបណាក៏ដោយ។ ចូរចាំថា ពួកគេគ្មានតួនាទីវិនិច្ឆ័យជនរងគ្រោះឡើយ ហើយការអនុញ្ញាតឱ្យជនរងគ្រោះនិយាយ និងកសាងទំនុកចិត្តរបស់គាត់។ ការកសាងទំនុកចិត្ត និងទំនាក់ទំនងល្អជាមួយជនរងគ្រោះត្រូវចំណាយពេលបន្តិចអាស្រ័យលើកត្តានានា ដូចជា កម្រិតនៃការប៉ះទង្គិចផ្លូវចិត្តដែលពួកគេរងគ្រោះ ឬការភ័យខ្លាចរបស់ពួកគេ។

ការសំខាន់គឺបុគ្គលិករបស់អ្នកត្រូវផ្តល់សុពលភាពលើអ្វីដែលជនរងគ្រោះបានឆ្លងកាត់ ព្រោះយើងដឹងថា ជាញឹកញាប់ ជនរងគ្រោះស្តីបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។ ការប្រើប្រាស់ការរៀបរាប់ដំណើររឿងដើម្បីកុំឱ្យមានការស្តីបន្ទោសជនរងគ្រោះ មានន័យថា អ្នកកំពុងជួយកសាងទំនុកចិត្ត។ ពាក្យសម្តីដ៏មានអនុភាពបំផុតដែលបុគ្គលិករបស់អ្នកអាចនិយាយទៅកាន់ជនរងគ្រោះគឺ "អ្នកមិនត្រូវបានស្តីបន្ទោសសម្រាប់អ្វីដែលបានកើតឡើងនោះទេ"។

បុគ្គលិករបស់អ្នកត្រូវទទួលយកអ្វីដែលជនរងគ្រោះនិយាយរួចប្រមូលភស្តុតាង ដូចការអនុវត្តក្នុងបទល្មើសផ្សេងទៀតដែរ ដោយចងចាំថា ការរាយការណ៍មិនពិតគឺជាករណីកម្រ។ ផ្ទុយទៅវិញ អ្នកគួរផ្តោតសំខាន់លើការពិតជាសកលថា ការរាយការណ៍ពីចំនួនករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីគឺមានក្រោមចំនួនករណីពិតប្រាកដ។

អ្នកត្រូវធានាថា បុគ្គលិករបស់អ្នកបំពេញស្តង់ដារមូលដ្ឋានដូចខាងក្រោម ៖

- ជ្រើសរើសទីតាំងសមស្របដើម្បីនិយាយជាមួយជនរងគ្រោះ ដែលធានាឯកជនភាព និងការរក្សាការសម្ងាត់របស់ពួកគេនិងមិនបង្កើនអារម្មណ៍ភ័យខ្លាចឬការប៉ះទង្គិចដល់ផ្លូវចិត្តបច្ចុប្បន្នរបស់ជនរងគ្រោះ។
- ណែនាំខ្លួន និងពន្យល់ពីដំណើរការដែលអាចលេចឡើង ដូចជា សុវត្ថិភាពរបស់ជនរងគ្រោះ ការរក្សាការសម្ងាត់ សេវាគាំទ្រ (ប្រសិនបើមាន) ការពិនិត្យកោសលវិច័យ /វេជ្ជសាស្ត្រ។ល។
- អនុញ្ញាតឱ្យពួកគេ "រៀបរាប់ដំណើររឿងដោយសេរី" (មិនកាត់សម្តី)។
- សួរសំណួរបើក (នរណា អ្វី ពេលណា ទីណា និង ដោយរបៀបណា?) ដើម្បីលើកទឹកចិត្តឱ្យជនរងគ្រោះ

ផ្តល់ព័ត៌មានបន្ថែមបន្ទាប់ពី"ការរៀបរាប់ដំណើររឿងដោយសេរី"។ សួរសំណួរ "ហេតុអ្វី?" ដោយប្រុងប្រយ័ត្ន ព្រោះជនរងគ្រោះដែលប៉ះទង្គិចផ្លូវចិត្តងាយនឹងសួរសំណួរនេះទៅខ្លួនឯងជាច្រើនលើកច្រើនសា ហើយអ្នកអាចបន្ថែមការប៉ះទង្គិចផ្លូវចិត្ត ឬអារម្មណ៍ស្តីបន្ទោសខ្លួនឯងលើជនរងគ្រោះ។

- ផ្តួចផ្តើមដំណើរការវាយតម្លៃហានិភ័យ និងពិចារណាពីធាតុផ្សំពីដំបូងនៃផែនការសុវត្ថិភាពជាមួយជនរងគ្រោះ។

### ប្រអប់ ១

**គន្លឹះសម្រាប់ការនិយាយជាមួយកុមារ***

ការអនុវត្តល្អកំណត់ថា មន្ត្រីនគរបាល/អ្នកស៊ើបអង្កេត មិនគួរទៅយក ឬធ្វើទំនាក់ទំនងផ្ទាល់ជាមួយកុមារដែលត្រូវបានប្រទូស្តរាយឡើយ។ ក្នុងនាមជាមនុស្សប្លែកមុខ អ្នកអាចបន្ថែមការប៉ះទង្គិចផ្លូវចិត្ត និងអាចត្រូវបានទិតៀនក្នុងតុលាការដោយសារការប្រើប្រាស់ឥទ្ធិពលមិនសមស្រប។ យកល្អគួរប្រើបន្ទប់ដែលមិនសូវធ្វើឱ្យបែកអារម្មណ៍ ( ឧ.ប្រដាប់ប្រដារក្មេងលេង និងសំឡេងរំខាន ) បញ្ចៀសការប្រើទឹកអប់ឬដែលកោរពុកមាត់ដែលមានក្លិនធួល និងពិចារណាប្រើកូនតុក្កតាដែលមានសរីរៈសមស្របដើម្បីជួយដល់ការបង្ហាញ និងការយល់ដឹង។

ដោយសារតែនៅពេលនិយាយជាមួយអ្នក កុមារគឺតូចទាបជាងអ្នក អ្នកគួរអង្គុយស្មើនឹងកុមារ និងបាញ់ក្រសែភ្នែកតាមខ្សែផ្តេក ( ឧ. អង្គុយចុះ ឬលុតជង្គង់ )។

ធានាថា អ្នកចេះភាសារបស់កុមារ ( សួរឪពុកម្តាយ ) និងជំរុញការចូលរួមរបស់កុមារតាមវិធីនេះ ដោយមិនត្រូវប្រើភាសាមនុស្សធំឡើយ ជាពិសេសភាសាដែលពាក់ព័ន្ធនឹងប្រដាប់បន្តពូជរបស់មនុស្សប្រុស និងមនុស្សស្រី។ កំណត់ថាតើកុមារដឹងខុសដឹងត្រូវ ឬទេ។ តើកុមារដឹងថា ពួកគេមិនគួរនិយាយកុហកទេ? តើកុមារនឹងសន្យាប្រាប់ការពិត ឬទេ? តើអ្វីធ្វើឱ្យពួកគេសប្បាយចិត្ត? តើអ្វីធ្វើឱ្យពួកគេក្រៀមក្រំ? ចំណុចនេះលើកឡើងពីការអះអាងថា វាគ្រាន់តែជាការលេងកំសាន្ត ហើយកុមារជាអ្នកញុះញង់ឱ្យមានសកម្មភាពទាំងនោះ។

| **កុំប្រើ** | **សូមប្រើ** |
|---|---|
| ប្រយោគវែងអន្លាយ | ប្រយោគខ្លីៗ |
| ប្រយោគស្មុគស្មាញ | ប្រយោគធម្មតា |
| សំឡេងបែបខ្ជិលច្រអូស ឬក្តៅក្រហាយ | សំឡេងនឹងធឹង និងរស់រវើក |
| ប្រយោគបដិសេធ ( តើប្អូនមិនប្រាប់នរណាទេ មែនទេ? ) | ប្រយោគស្រប ( តើប្អូនមានប្រាប់នរណាទេ? ) |
| សំណួរដែលមានន័យច្រើន ( តើប្អូនមានអារម្មណ៍បែបណាដែរ? ) | សំណួរដែលមានន័យតែមួយ ( តើប្អូនខឹងទេ? ) |
| ទឹកមុខ ឬភាសាកាយវិការអវិជ្ជមាន | ទឹកមុខ ឬភាសាកាយវិការវិជ្ជមាន |

ដកស្រង់ចេញពី ៖ សៀវភៅណែនាំស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ( UNODC ២០១០ )

សម្រាប់ព័ត៌មានបន្ថែមស្តីពីការនិយាយជាមួយកុមារ សូមមើលជំពូកទី ៥ ( ការស៊ើបអង្កេត )។

នៅពេលជនរងគ្រោះប្រឡូកក្នុងដំណើរការយុត្តិធម៌តាមរយៈការដាក់បណ្តឹងទៅនគរបាល ការសំខាន់គឺត្រូវរក្សាទំនាក់ទំនងជាមួយជនរងគ្រោះ។ ត្រូវផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ជនរងគ្រោះនៅពេលករណីមានដំណើរការទៅមុខរួមទាំងការឃុំខ្លួនជនបង្កដែលរងការចោទប្រកាន់និងលក្ខខណ្ឌដោះលែង ឬការរំលោភលក្ខខណ្ឌណាមួយ។

ជនរងគ្រោះត្រូវតែដឹងពីអ្វីដែលត្រូវធ្វើនិងរបៀបទាក់ទងទៅនគរបាលប្រសិនបើគាត់បារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន។ ត្រូវរក្សាទំនាក់ទំនងជាមួយជនរងគ្រោះដើម្បីធ្វើការពិនិត្យ

ឡើងវិញជាប្រចាំលើការវាយតម្លៃហានិភ័យនិងផែនការសុវត្ថិភាព។

សូមមើលជំពូកទី ៧ (ការគាំទ្រ និងជំនួយ) សម្រាប់ឧទាហរណ៍នៃការអនុវត្តល្អក្នុងការរក្សា ទំនាក់ទំនងជាមួយជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ (មន្ត្រីទំនាក់ទំនងគ្រួសារ)។

ទំនាក់ទំនងជាប្រចាំជាមួយជនរងគ្រោះ គួរឆ្លងកាត់ការសម្របសម្រួលជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀតដើម្បីធានាការផ្តល់សារដែលស៊ីសង្វាក់គ្នា។ ទំនាក់ទំនងរវាងស្ថាប័នយុត្តិធម៌ច្រើនតែតម្រូវឱ្យមានពិធីសារ ព្រោះអាចមានការចែករំលែកព័ត៌មានរសើប ឬឯកជនដែលពាក់ព័ន្ធនឹងជនរងគ្រោះ។

**ការផ្សះផ្សាអាចចោទជាបញ្ហាខ្លាំងនិងបង្កគ្រោះថ្នាក់ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយសារមូលហេតុខាងក្រោម ៖**

- **ករណីអំពើហិង្សាលើស្ត្រីពាក់ព័ន្ធនឹងវិសមភាពនៃទំនាក់ទំនងអំណាចរវាងគូភាគីដោយផ្អែកលើការប្រទូស្តរាយការបំភិតបំភ័យបែបហិង្សា និង/ឬឥរិយាបថត្រួតត្រាបំពាន ឬប្រមាថ។**
- **ការផ្សះផ្សាសន្មតថា គូភាគីប្រឡូកក្នុងដំណើរការនេះដោយមានឆន្ទៈ និងអំណាចស្មើគ្នា ដែលជាញឹកញាប់មិនលេចឡើងក្នុងស្ថានភាពទាំងនេះឡើយ។**

ពិធីសារដែលបានព្រមព្រៀងរួចហើយ នឹងធានានូវការរក្សាការសម្ងាត់ ពោលគឺមានតែអ្នកដែលពាក់ព័ន្ធផ្ទាល់នឹងករណីប៉ុណ្ណោះទើបអាចចូលមើលបាន។ មុននឹងចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងជនរងគ្រោះអ្នកត្រូវធានាថាបុគ្គលិករបស់អ្នកបានទទួលការយល់ព្រមពីជនរងគ្រោះ។ ជនរងគ្រោះត្រូវការការបញ្ជាក់ឡើងវិញពីមូលហេតុនៃការចែករំលែកព័ត៌មានទាំងនេះជាមួយដៃគូយុត្តិធម៌ និងថាតើព័ត៌មានទាំងនោះត្រូវបានការពារ និងរក្សាទុកដោយរបៀបណា។ អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះកំណត់ថាជនរងគ្រោះត្រូវទទួលបានព័ត៌មានពេញលេញហើយត្រូវពិចារណាពីទស្សនៈរបស់ជនរងគ្រោះនៅពេលចេញសេចក្តីសម្រេចលើករណីរបស់គាត់។

តើអ្នកមានពិធីសារស្តីពីការចែករំលែកទិន្នន័យ ឬព័ត៌មានរវាងដៃគូវិស័យយុត្តិធម៌ ឬទេ? ប្រសិនបើគ្មានទេ សូមពិចារណាស្នើឱ្យមានពិធីសារទាំងនោះ ដើម្បីធានាឱ្យដំណើរការយុត្តិធម៌ក្នុងតំបន់របស់អ្នកកាន់តែមានប្រសិទ្ធភាព។ ទិន្នន័យ ព័ត៌មាន ឬចារកម្មពីស្ថាប័នយុត្តិធម៌ផ្សេងទៀតអាចជួយឱ្យមន្ត្រីរបស់អ្នកធានាបាននូវការស៊ើបអង្កេតល្អិតល្អន់និងពេញលេញដែលបង្កើនលទ្ធភាពទទួលបានលទ្ធផលជោគជ័យសម្រាប់ជនរងគ្រោះ និងនាំឱ្យមានទំនុកចិត្ត និងភាពជឿជាក់កាន់តែខ្លាំងពីសហគមន៍មូលដ្ឋានទៅលើនគរបាល។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការសម្របសម្រួល និងពិធីសារ សូមមើលជំពូកទី ៧ (ការ គាំទ្រ និងជំនួយ) ជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) និងជំពូកទី ១២ (ការបន្តផ្តល់យុត្តិធម៌)។

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្តើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

ដូចការពិភាក្សាក្នុងជំពូកទី ២ ភាពលម្អៀងដែលស្តែងចេញឱ្យឃើញច្បាស់ និងមិនស្តែងចេញឱ្យឃើញច្បាស់ត្រូវបានបង្កប់ក្នុងវប្បធម៌របស់យើង ប៉ុន្តែពាក់ព័ន្ធនឹងសេវានគរបាលយេនឌ័រនិងភាពលម្អៀងអវិជ្ជមានប្រទាក់ក្រឡាគ្នាផ្សេងទៀតមានទម្រង់នៃការរើសអើងដែលងាយធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃសេវាសំខាន់ៗដែលផ្តល់ជូនជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងនាំទៅរកការរងគ្រោះលើកទីពីរ[339]។ ជាធម្មតា ចំណុចនេះចាប់ផ្តើមពីទំនាក់ទំនងមិនល្អរវាងនគរបាលឆ្លើយតប និងជនរងគ្រោះក្នុងទំនាក់ទំនងដំបូង និងអាចបន្តក្នុងទំនាក់ទំនងរបស់ជនរងគ្រោះជាមួយនគរបាលនិងតួអង្គវិស័យយុត្តិធម៌ផ្សេងទៀត។

339. ការរងគ្រោះលើកទីពីរត្រូវបានកំណត់និយមន័យក្នុងយុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពរបស់អង្គការសហប្រជាជាតិថាជាការរងគ្រោះដែលកើតឡើងមិនមែនដោយសារលទ្ធផលផ្ទាល់នៃអំពើហិង្សានោះទេ ប៉ុន្តែតាមរយៈការឆ្លើយតបមិនគ្រប់គ្រាន់របស់ស្ថាប័ននិងបុគ្គលចំពោះជនរងគ្រោះ។

ចលករដែលជំរុញឱ្យមានភាពលម្អៀងអវិជ្ជមានដែលស្តែងចេញឱ្យឃើញច្បាស់ និងមិនស្តែងចេញឱ្យឃើញច្បាស់ ប្រែប្រួលទៅតាមបុគ្គល ប៉ុន្តែវាសុទ្ធតែអាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ៦.មន្ត្រីម្នាក់ដែលធ្វើអន្តរាគមន៍និងផ្សះផ្សារ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាជាអន្តរគ្រួសារ ដោយមិនដាក់របាយការណ៍ផ្លូវការអាចជឿថាពួកគេផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ(និងកូនៗរបស់ជនរងគ្រោះ) ជាជំក្នុងរយៈពេលវែង។ ទោះជាយ៉ាងណា ចំណុចនេះផ្តល់សារមិនត្រឹមត្រូវថាមានការអត់ឱនចំពោះបទល្មើសទាំងនេះដែលផ្តល់ឱកាសឱ្យដៃគូស្និទ្ធស្នាលរបស់ជនរងគ្រោះប្រព្រឹត្តល្មើសម្តងទៀត។

ក្នុងករណីធ្ងន់ធ្ងរផ្សេងទៀត ភាពលម្អៀងអវិជ្ជមានរបស់នគរបាលឆ្លើយតបអាចស្តែងឡើងកាន់តែច្បាស់ ដែលបង្កភាពអាម៉ាស់ ការស្តីបន្ទោស និងការប្រមាថ ឬការចោទប្រកាន់ជនរងគ្រោះថារាយការណ៍មិនពិត ឬប្រឆាំងនឹងបទដ្ឋានវប្បធម៌ ឬសង្គម។ កង្វះជំនាញទំនាក់ទំនងជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កការប៉ះទង្គិចផ្លូវចិត្តយូរអង្វែង និងនាំឱ្យមានការរាយការណ៍ពីចំនួនករណីក្រោមចំនួនពិតប្រាកដ។
ការរាយការណ៍ពីចំនួនករណីក្រោមចំនួនពិតប្រាកដ ធ្វើឱ្យខកឱកាសក្នុងការ ៖

- កំណត់អត្តសញ្ញាណនិងផ្តល់ការគាំទ្រឯកទេសដល់ជនរងគ្រោះដដែលៗនិងក្រុមគ្រួសាររបស់ពួកគេ។
- កំណត់អត្តសញ្ញាណជនបង្កដដែលៗដែលបង្កគ្រោះថ្នាក់ និងប្រព្រឹត្តហិង្សា។
- កំណត់អត្តសញ្ញាណទីកន្លែង និងទីតាំងដដែលៗដែលមានគ្រោះថ្នាក់។

**ភាពប្រទាក់ក្រឡាគ្នាធ្វើឱ្យយើងកត់សម្គាល់ថាអត្តសញ្ញាណ និងតួនាទីក្នុងសង្គមរបស់ស្ត្រី និងក្មេងស្រីរងឥទ្ធិពលពីកត្តាជាច្រើនក្នុងពេលតែមួយ ដែលបង្កើតនូវបទពិសោធន៍ និងទស្សនៈវិស័យដោយឡែកៗពីគ្នា។**

ក្រៅពីនេះ ភាពលម្អៀងយេនឌ័រដែលមិនស្តែងចេញឱ្យឃើញច្បាស់ និងស្តែងចេញឱ្យឃើញច្បាស់ ក៏ស្តែងឡើងរវាងនគរបាលជាស្ត្រីនិងនគរបាលជាបុរសផងដែរដែលជារឿយៗធ្វើឱ្យនគរបាលជាស្ត្រីផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន (ដូចជាការបញ្ចៀសការធ្វើការក្នុងអង្គភាពមួយចំនួន) ដើម្បីកុំឱ្យប្រឈមនឹងភាសារបស់អ្នកប្រកាន់ភេទនិងអ្នកស្អប់ស្ត្រី។ ការប្រើប្រាស់ដោយសេរីនូវភាសាបែបលម្អៀងនិងភាសារបស់អ្នកប្រកាន់ភេទ បន្ទុចបង្អាក់មិនឱ្យមន្ត្រីនគរបាលជាស្ត្រីសម្រេចសក្តានុពលវិជ្ជាជីវៈរបស់ខ្លួន និងជះឥទ្ធិពលអវិជ្ជមានលើរបៀបដែលនគរបាលធ្វើទំនាក់ទំនងជាមួយស្ត្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សា និងបទល្មើស។

សូមមើលជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម" និងជំពូកទី ៥ (ការស៊ើបអង្កេត) សម្រាប់ព័ត៌មានលម្អិតស្តីពីភាពលម្អៀងយេនឌ័រ។

ក្នុងករណីជាច្រើន ភាពលម្អៀងអវិជ្ជមាន ដូចជា ភាពលម្អៀងយេនឌ័រ ដែលបណ្តាលពីកង្វះការយល់ដឹងពីបញ្ហាដែលជះឥទ្ធិពលធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី។ ចំណុចនេះអាចបណ្តាលឱ្យមន្ត្រីនគរបាលចោទសួរឬដេញដោលជាចំហលើច្បាប់ គោលនយោបាយ និង/ឬ យុទ្ធសាស្ត្រមួយចំនួនដែលមានគោលបំណងបង្កើតការការពារដល់ស្ត្រី និងក្មេងស្រី នៅពេលពួកគេក្លាយជាគោលដៅនៃអំពើហិង្សា ឬបទល្មើស ដោយសារតែសង្គម "កំណត់យេនឌ័រ"របស់ពួកគេក្នុងស្ថានភាពងាយរងគ្រោះ។អំពើហិង្សាដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រីរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមការសម្លាប់ស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ (ហៅថា ការសម្លាប់ទារិកាក្នុងផ្ទៃ)ដូចជាការសម្លាប់ដោយដៃគូស្និទ្ធស្នាលឬដោយសារមូលហេតុ "ដើម្បីរក្សាកិត្តិយស"[340]។ យោងតាមការសិក្សាឆ្នាំ ២០១៩ របស់ UNODC ស្តីពីអំពើមនុស្សឃាត ការប្រព្រឹត្តអំពើមនុស្សឃាតដោយដៃគូស្និទ្ធស្នាល គឺជាទម្រង់ទូទៅបំផុតនៃការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ[341] ។

340. មានការលើកឡើងថា នៅពេលនគរបាលឆ្លើយតបទៅនឹង "អំពើហិង្សាដើម្បីកិត្តិយស" ពួកគេគួរមានភាពប្រុងប្រយ័ត្នចំពោះការពឹងផ្អែកលើការកំណត់ផ្នត់គំនិត និងការចាត់ប្រភេទបែបរើសអើងផ្សេងទៀត ដែលកំណត់យកបុគ្គល និងសហគមន៍ជាគោលដៅ។
341. សូមមើល ការសិក្សាជាសកលស្តីពីអំពើមនុស្សឃាត (UNODC, 2019)។

មន្ត្រីនគរបាលជាច្រើនអាចនឹងយល់ថា ច្បាប់ គោលនយោបាយ និង/ឬយុទ្ធសាស្ត្រទាំងនេះផ្តោតសំខាន់លើតម្រូវការសន្តិសុខរបស់ស្ត្រី និងក្មេងស្រី ដែលធ្វើឱ្យមានការរើសអើងលើបុរសដែលពួកគេយល់ថាជាក្រុមដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារបទល្មើស និងអំពើហិង្សាជារួម ជាពិសេសអំពើមនុស្សឃាត[342]។

**ការកើនឡើងនៃការសម្លាប់ស្ត្រីដោយដៃគូស្និទ្ធស្នាលឬសមាជិកគ្រួសារ**

"ស្ត្រី និងក្មេងស្រីចំនួន ៨៧.០០០ នាក់ត្រូវបានសម្លាប់ដោយចេតនានៅឆ្នាំ ២០១៧។ នេះជាចំនួនថយចុះធៀបនឹងឆ្នាំ ២០១២។ ទោះជាយ៉ាងណា ចំនួនស្ត្រីដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល ឬសមាជិកគ្រួសារផ្សេងទៀត កើនពី ៤៧% នៃចំនួនស្ត្រីជាជនរងគ្រោះដោយសារអំពើមនុស្សឃាតទាំងអស់នៅឆ្នាំ ២០១២ រហូតដល់ ៥៨% នៅឆ្នាំ ២០១៧ ហើយចំនួនស្ត្រីដែលបានស្លាប់ដោយសារអំពើមនុស្សឃាតនេះកើនពី ៤៨.០០០ នាក់នៅឆ្នាំ ២០១២ រហូតដល់ ៥០.០០០ នាក់នៅឆ្នាំ ២០១៧។ ផ្ទះសម្បែងនៅតែជាកន្លែងគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី ដែលបន្តប្រឈមនឹងបន្ទុកធ្ងន់ធ្ងរបំផុតនៃការរងគ្រោះដែលអាចបណ្តាលឱ្យស្លាប់ដោយសារវិសមភាព និងផ្នត់គំនិតយេនឌ័រ។

ការសិក្សាឆ្នាំ ២០១៩ របស់ UNODC ស្តីពីអំពើមនុស្សឃាត

នៅពេលដែលភាពលម្អៀងយេនឌ័រក្នុងស្ថាប័ននគរបាលធ្វើឱ្យជនរងគ្រោះមានការយល់ឃើញ ពីទម្រង់បញ្ច្រាស់នៃការរើសអើង ហើយបញ្ហានេះមិនត្រូវបានដោះស្រាយ ឬជូនដំណឹងដោយថ្នាក់លើរបស់ពួកគេ ឥរិយាបថ និងអាកប្បកិរិយាអវិជ្ជមាននឹងបង្កផលប៉ះពាល់ដល់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការងាររបស់នគរបាល ជាពិសេសនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

តាមពិត ការសិក្សាមួយដោយ Harvard Business Review (២០១៦) ស្តីពីមូលហេតុដែលបុរសអាមេរិកកាន់តែច្រើនយល់ថាពួកគេទទួលរងការរើសអើងសន្និដ្ឋានថាថ្វីបើជាទូទៅបុរសទទួលបានបុព្វសិទ្ធិក្នុងក្នុងសង្គមក្តីក៏ការជឿថាពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតការប្រឆាំងតប ធ្វើឱ្យពួកគេបង្កើនការកំណត់អត្តសញ្ញាណក្រុមយេនឌ័របស់ពួកគេ ប្រឈមនឹងតម្លៃផ្ទាល់ខ្លួនទាបខឹងសម្បារ និងអាចជះកំហឹងលើក្រុមដែលពួកគេយល់ថាកំពុងគៀបសង្កត់មកលើពួកគេ[434] ។

ការមានយុទ្ធសាស្ត្រទំនាក់ទំនងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងថ្នាក់ដឹកនាំនគរបាលគ្រប់ជាន់ថ្នាក់និងខិតខំដោះស្រាយជាមុនលើការយល់ឃើញអវិជ្ជមានចំពោះច្បាប់ គោលនយោបាយ និង/ឬយុទ្ធសាស្ត្រដែលលើកកម្ពស់សមភាពយេនឌ័រ គឺជាចំណុចចាប់ផ្តើមដ៏ល្អ។ តាមទ្រឹស្តីយុទ្ធសាស្ត្រទំនាក់ទំនងគួរផ្តោតសំខាន់លើឋានានុក្រមស្ថាប័នគ្រប់ជាន់ថ្នាក់រួមទាំងថ្នាក់ទាបដើម្បីឱ្យមានឯកសណ្ឋានភាពក្នុងការអនុវត្តក៏ដូចជាគណនេយ្យភាព។សំខាន់ផងដែរគឺកម្មវិធី បណ្តុះបណ្តាល និងអប់រំនគរបាលគួរឆ្លុះបញ្ចាំង និងពង្រឹងយុទ្ធសាស្ត្រទំនាក់ទំនងផ្ទៃក្នុងដើម្បីធានានិរន្តរភាព។

ក្នុងករណីដែលគ្មានយុទ្ធសាស្ត្រទំនាក់ទំនងខាងលើក្នុងស្ថាប័ននគរបាល ប្រធានក្រុម/ អង្គភាព ឬអ្នកគ្រប់គ្រងអាចអនុវត្តអភិក្រមនៅកម្រិតក្រុម ដើម្បីបកស្រាយសំណួរចម្ងល់ ឬការសង្ស័យទាំងឡាយ ជាពិសេសនៅពេលស្តែងចេញនូវអាកប្បកិរិយា ដូចជា អាកប្បកិរិយាដែលលើកឡើងក្នុងអត្ថបទរបស់ Harvard Business Review។

ការអនុវត្តប្រព័ន្ធទំនាក់ទំនងរបៀបនេះ មិនថាជំរុញដោយស្ថាប័ន ឬជាផ្នែកមួយនៃអភិក្រមនៅកម្រិតក្រុមនោះទេ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងការមិនអត់ឱនចំពោះការប្រទូស្តកេរខ្មាស និងឥរិយាបថរបស់អ្នកប្រកាន់ភេទក្នុងក្រុមនេះ។

342. ប្រតិកម្មតបក្នុងសមភាពយេនឌ័រ និងសិទ្ធិស្ត្រី និងក្មេងស្រី។ សិទ្ធិស្ត្រី និងសមភាពយេនឌ័រ។ នាយកដ្ឋាននគរបាលដើម្បីសិទ្ធិពលរដ្ឋ និងកិច្ចការរដ្ឋធម្មនុញ្ញ អគ្គនាយកដ្ឋានគោលនយោបាយផ្ទៃក្នុងរបស់សហភាពអឺរ៉ុប PE 604.955 ខែ មិថុនា ឆ្នាំ ២០១៨។

343. Cassino, D., 'Why More American Men Feel Discriminated Against', Harvard Business Review, September 29, 2016, at:https://hbr.org/2016/09/why-more-american-men-feel-discriminated-against

**ប្រអប់ ២**



"ការសំខាន់គឺក្នុងនាមជាអ្នកគ្រប់គ្រងក្នុងជួរនគរបាល អ្នកត្រូវតែអាចបង្ហាញដោយប្រសិទ្ធភាពនូវការគាំទ្រផ្ទាល់ខ្លួន ចំពោះការទប់ស្កាត់ និងដោះស្រាយអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់ រួមទាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ អ្នកត្រូវបង្ហាញការដឹកនាំដ៏លេចធ្លោរ តាមរយៈពាក្យពេចន៍ដែលអ្នកប្រើប្រាស់ក្នុងការដោះស្រាយអំពើហិង្សា និងការរំលោភបំពាន និងត្រូវបំពេញបន្ថែមដោយសកម្មភាព និងអាកប្បកិរិយារបស់អ្នក។ ប្រសិនបើអ្នកមិន "អនុវត្តតាមពាក្យសម្ដីរបស់អ្នកទេ" បុគ្គលិករបស់អ្នកដែលងាយនឹងបាត់ទំនុកចិត្តលើរូបអ្នក"។

Jane Townsley អតីតស្នងការនគរបាលដឹកជញ្ជូនចក្រភពអង់គ្លេស
បច្ចុប្បន្នជានាយកប្រតិបត្តិសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (IAWP)

ខាងក្រោមនេះជាគុណវិបត្តិមួយចំនួនរបស់នគរបាលនៅពេលធ្វើទំនាក់ទំនងជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចទាំងនេះមានគោលបំណងផ្តល់ជាឧទាហរណ៍ ដែលដកស្រង់ចេញពីការគូសផែនទីជាសកលស្តីពីការអនុវត្តល្អ និងចំណុចខ្វះខាតសមត្ថភាពរបស់ស្ថាប័ននគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការគូសផែនទីនេះពាក់ព័ន្ធនឹងការពិភាក្សាជាមួយមន្ត្រីនគរបាលជាច្រើននាក់ដែលកំពុងបម្រើការ និងចូលនិវត្តន៍ សង្គមស៊ីវិល និងបុគ្គលិកអង្គការសហប្រជាជាតិដែលមានបទពិសោធន៍ការងារជាមួយស្ថាប័ននគរបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានឯកទេសក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ចំណុចទាំងនេះមានគោលបំណងកសាងការយល់ដឹងអំពីចំណុចខ្វះខាតលើទំនាក់ទំនងក្នុង និងក្រៅសេវានគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ចំណងជើងរងនីមួយៗជួយឱ្យអ្នកអានផ្សារភ្ជាប់ទៅនឹងចំណុចដ៏សំខាន់មួយនៃចំណុចខ្វះខាតសមត្ថភាពដែលបានរកឃើញ។ ទោះជាយ៉ាងណា ចំណុចទាំងនេះសុទ្ធតែអាចអនុវត្តបាន និង/ឬបំពេញឱ្យគ្នាទៅវិញទៅមក។

## ឥរិយាបថ

- ជាញឹកញាប់ នគរបាលដែលមិនមែនជាផ្នែកមួយនៃអង្គភាពឯកទេស មិនសូវមានសមានចិត្ត ឬក្តីមេត្តាចំពោះជនរងគ្រោះឡើយ។ ឧ. ពួកគេមិនទទួលស្គាល់ផ្នែកដ៏លំបាកបំផុតនៃរឿងរ៉ាវរបស់ជនរងគ្រោះ ឬមិនពន្យល់ពីមូលហេតុដែលពួកគេត្រូវការព័ត៌មានលម្អិតទាំងនេះ ប្រសិនបើពិតជាត្រូវការមែន។ អ្នកគ្រប់គ្រងក្នុងជួរនគរបាលគួរពិចារណាដាក់បញ្ចូលមន្ត្រី ឯកទេសដើម្បីជួយបង្កើនចំណេះដឹងក្នុងក្រុម។

- ការបៀតបៀនផ្លូវភេទជាពាក្យសម្តីមិនត្រូវបានពិចារណាដិតដល់នោះទេ។
- សមភាពយេនឌ័រត្រូវបានកំណត់ជាចំណុចអវិជ្ជមានឬប្រានចោលឬត្រូវបានកំណត់ជារបៀបវារៈនយោបាយដែលមានគោលបំណងរើសអើងផ្តាច់ចេញឬបង្កគ្រោះថ្នាក់ដល់បុរស។

## ភាពលម្អៀងយេនឌ័រ

- ជនរងគ្រោះទទួលរងសម្ពាធមិនឱ្យដាក់បណ្តឹងផ្លូវការស្តីពីអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ (អ្នកនឹងបំផ្លាញជីវិតរបស់បុរសដ៏កំសត់នេះ។ នេះមិនមែនជារឿងធំដុំទេ។ សូមគិតពីកូនៗរបស់អ្នក)។
- នគរបាលជឿថា តាមរយៈការផ្តល់ការណែនាំដល់ជនរងគ្រោះ វាអាចជួយដល់ពួកគេនៅពេលដែលពួកគេពិតជាបញ្ចូលទស្សនៈផ្ទាល់ខ្លួនតាមរយៈការប្រាប់ជនរងគ្រោះពីអ្វីដែលពួកគេគួរធ្វើ និងរបៀបដែលពួកគេគួរធ្វើ[344]។

> “ការសិក្សាថ្នាក់ជាតិមួយចំនួនបង្ហាញថា ស្ត្រីរហូតដល់ ៧០% រងគ្រោះដោយអំពើហិង្សាផ្លូវកាយ និង/ឬ អំពើហិង្សាផ្លូវភេទបង្កដោយដៃគូស្និទ្ធស្នាលក្នុងជីវិតរបស់ខ្លួន”។
>
> ព័ត៌មានពិត និងតួលេខរបស់ UN Women ៖ ការបញ្ឈប់អំពើហិង្សាលើស្ត្រី

- សនិទានភាពដែលចោទជាបញ្ហាបំផុត ដោយសារតែមន្ត្រីនគរបាលមិនធ្វើការព្រមានលើជនប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងសហគមន៍មូលដ្ឋានគឺវានឹងមិនអាចផ្លាស់ប្តូរអាកប្បកិរិយារបស់ស្ត្រីបានឡើយ[345]។

## ការរងគ្រោះជាលើកទីពីរ

- ក្នុងពេលសម្ភាសន៍ជាមួយនគរបាល ជាញឹកញាប់ជនរងគ្រោះអាចត្រូវបានកាត់សម្តី និង/ឬសំឡក់ មានការសន្មតពីអ្វីដែលជនរងគ្រោះចង់និយាយ ការពិភាក្សាមានភាពប្រញាប់ប្រញាល់ឬក៏ជនរងគ្រោះត្រូវបានតម្រូវឱ្យថាឡើងវិញនូវរឿងរ៉ាវនៃការបំពានប្រាប់អ្នកផ្សេង។
- ជាញឹកញាប់ គ្មានការគោរពទស្សនៈ ជំនឿ គំនិត និងអារម្មណ៍របស់ជនរងគ្រោះ (ជនរងគ្រោះត្រូវបានគេប្រាប់ឱ្យឈប់យំ ឬរម្ងាប់អារម្មណ៍)។
- គ្មានឱកាសគ្រប់គ្រាន់ ដូចជា មិនផ្តល់ចន្លោះរូបវន្តសម្រាប់ឱ្យជនរងគ្រោះប្រាប់រឿងរ៉ាវរបស់គាត់បានពេញលេញ មានអ្នកស្តាប់ និងមានគេកត់ត្រារឿងរ៉ាវរបស់ពួកគេបានត្រឹមត្រូវ និងអាចបង្ហាញពីតម្រូវការ និងការព្រួយបារម្ភទៅតាមលទ្ធភាព អាយុ ភាពឆ្លាតវៃ និងសមត្ថភាពរបស់ពួកគេ[346]។

## ការអនុវត្តខុសឆ្គង

- ព័ត៌មានស៊ើបអង្កេតដែលកំណត់រកនិន្នាការបទល្មើសធ្ងន់ធ្ងរនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីគឺជាញឹកញាប់មិនត្រូវបានចែករំលែកជាមួយមន្ត្រីនៅកម្រិតសហគមន៍ដែលពាក់ព័ន្ធជាមួយស្ត្រីនិងក្មេងស្រីនៅមូលដ្ឋាននោះទេ[347] ។ សូមពិចារណាស្នើឱ្យអ្នកវិភាគ/អ្នកឯកទេសនៅមូលដ្ឋានចែករំលែកព័ត៌មានស្តីពីនិន្នាការនៃបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ក្នុងករណីនៃស្ត្រី និងក្មេងស្រីដែលបាត់ខ្លួន បរាជ័យនៃទំនាក់ទំនងផ្ទៃក្នុងធ្វើឱ្យអាក់ខានដល់ការវាយតម្លៃសមស្របលើទំនាក់ទំនងរវាងករណីទាំងនេះ។ ការមិនដឹងពីទំនាក់ទំនងទាំងនេះកើតមានជាទូទៅក្នុងករណីមានយុត្តាធិការចម្រុះ[348]។

## ការរើសអើង

- ជាញឹកញាប់ ភាសារបស់អ្នកប្រកាន់ភេទត្រូវបានអត់អោននៅពេលបំពេញភារកិច្ចឬត្រូវបានជំរុញលើកទឹកចិត្តនៅពេលមានវត្តមានរបស់ស្ត្រី និងក្មេងស្រី។

## ចំណុចខ្វះខាតក្នុងការបណ្តុះបណ្តាល និងការអប់រំ

- ជាញឹកញាប់ នគរបាលដែលមិនមែនជាផ្នែកនៃក្រុមឯកទេសមិនសូវមានសមានចិត្តនោះទេ។ ឧ. ពួកគេមិនដឹងពីពេលដែលត្រូវបញ្ឈប់ការសួរសំណួរមួយចំនួនឬប្តូរប្រធានបទ។
- នគរបាលមិនសូវផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងមិនមែនពាក្យសម្តីរបស់ខ្លួន ឬទំនាក់ទំនងមិនមែនពាក្យសម្តីរបស់ជនរងគ្រោះ។
- ក្នុងពេលសម្ភាសន៍ គ្មានការប្រើប្រាស់ភាសាធម្មតា និងច្បាស់លាស់ឱ្យបានគ្រប់គ្រាន់ និងមិនបញ្ជាក់ពីពាក្យពេចន៍ប្លែកៗ។
- នគរបាលមិនសូវយកចិត្តទុកដាក់ ឬមិនត្រូវបានបណ្តុះបណ្តាលឱ្យកំណត់រក និងដោះស្រាយបញ្ហាប្រឈម/ឧបសគ្គរបស់ជនរងគ្រោះ ក្នុងការយល់ពីការណែនាំ/សំណួររបស់បុគ្គលិក និងឆ្លើយសំណួរទាំងនោះ ហើយបុគ្គលិកទាំងនោះត្រូវកែសម្រួលទៅតាមតម្រូវការទំនាក់ទំនងរបស់ជនរងគ្រោះ។
- នគរបាលមិនសូវនិយាយត្រង់ទៅតាមការរំពឹងទុកនៅ

344. នគរបាលមិនអាចដឹងថាតើទស្សនៈផ្ទាល់ខ្លួនគឺត្រឹមត្រូវសម្រាប់ជនរងគ្រោះឬយ៉ាងណានោះទេ។ ដូច្នេះ គួរផ្តល់ព័ត៌មានដែលពួកគេត្រូវការសម្រាប់ការសម្រេចចិត្តដោយខ្លួនឯង។ ចំណុចនេះក៏បង្ហាញផងដែរថាអ្នកគោរពនិងទុកចិត្តទស្សនៈនិងការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់ជនរងគ្រោះ។ សូមមើល ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ -DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ ២០១៥)។

345. ដកស្រង់ចេញពី The Honourable Wally T. Oppal, ‘FORSAKEN. The Report of the Missing Women Commission of Inquiry VOLUME IIB Nobodies: How and Why We Failed the Missing and Murdered Women Part 3, 4 and 5 (2012)’ at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/about-bc-justice-system/inquiries/forsaken-vol_2b.pdf។

346. ស្ត្រី និងក្មេងស្រីត្រូវមានឱកាសប្រាប់ពីរឿងរ៉ាវរបស់ខ្លួន មានអ្នកស្តាប់ និងមានគេកត់ត្រារឿងរ៉ាវរបស់ពួកគេបានត្រឹមត្រូវ និងអាចបង្ហាញពីតម្រូវការ និងការព្រួយបារម្ភទៅតាមលទ្ធភាព អាយុ ភាពវៃឆ្លាត និងសមត្ថភាពរបស់ពួកគេ។

347. សូមមើល n.9.

348. Ibid

ពេលពួកគេត្រូវចែករំលែកព័ត៌មានជាមួយស្ត្រី និងសមាជិកសហគមន៍ផ្សេងទៀតស្តីពីការស៊ើបអង្កេតបទល្មើសធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ទោះជាយ៉ាងណា អ្នកស៊ើបអង្កេតត្រូវរក្សាទុកព័ត៌មានមួយចំនួនដើម្បីពន្លឿនការស៊ើបអង្កេតប៉ុន្តែត្រូវពិចារណាពីតុល្យភាពសមស្របរវាងគោលដៅទាំងពីរនៃការចាប់ខ្លួនជនបង្ក និងការទប់ស្កាត់មិនឱ្យស្ត្រីម្នាក់ផ្សេងទៀតក្លាយជាជនរងគ្រោះដោយសារបទល្មើសធ្ងន់ធ្ងរ[349] ។

"ការទទួលខុសត្រូវរួមទូទាំងនាយកដ្ឋាន និងការបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋាន និងរវាងមន្ត្រីជួរមុខនិងមន្ត្រីត្រួតពិនិត្យរបស់ពួកគេនាំទៅរកការកែលម្អបរិយាកាសការងារក្នុងស្ថាប័ននគរបាល"។

អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE)

ក្នុងនាមជាអតីតយុទ្ធជនដែលមានបទពិសោធន៍បម្រើការជាង ៣០ ឆ្នាំក្នុងជួរនគរបាល ស្កុតឡែន អធិការ Graham Goulden (ចូលនិវត្តន៍) សង្កេតឃើញថា វប្បធម៌របស់បុរស រួមទាំងសហការី គឺមិននិយាយស្តី នៅពេលពួកគេសង្កេតឃើញការប្រព្រឹត្តមិនសមស្របចំពោះស្ត្រី ឬក្មេងស្រី។ ជាញឹកញាប់ នៅពេលសម្ភាសន៍បុគ្គលដែលជាសាក្សីនៃការរំលោភបំពាន និងអំពើហិង្សា Graham លឺពាក្យថា "ខ្ញុំដឹងថា នឹងមានអ្វីមួយកើតឡើង"។ ដូច្នេះ លោក Graham Goulden បានរៀបចំគំនិតផ្តួចផ្តើមសម្រាប់ការបង្កើតអភិក្រម ដូចជា "អភិក្រមអ្នកនៅជិតកន្លែងកើតហេតុ (bystander approach)[350]" ព្រមទាំងកម្មវិធីដែលជួយបង្កើតលក្ខខណ្ឌដែលមនុស្សល្អអាចចាត់វិធានការវិជ្ជមាននៅពេលពើបប្រទះស្ថានភាពប្រឈម។ សូមមើលប្រអប់ ៩ ខាងក្រោម សម្រាប់ព័ត៌មានស្តីពីអភិក្រមអ្នកនៅជិតកន្លែងកើតហេតុ របស់អធិការចូលនិវត្តន៍ Graham Goulden។

### ប្រអប់ ៣

**តើអ្វីជាអភិក្រមអ្នកនៅជិតកន្លែងកើតហេតុសម្រាប់ការទប់ស្កាត់អំពើហិង្សា?**




តាមធម្មតា អភិក្រមនៃអំពើហិង្សា និងការរំលោភបំពាន ផ្តោតលើអំពើរបស់ជនបង្ក និងជនរងគ្រោះ។ ដំបូង អភិក្រមអ្នកនៅជិតកន្លែងកើតហេតុ លុបបំបាត់អភិក្រមទ្វេទិស (binary approach) នេះដោយកំណត់អត្តសញ្ញាណបុគ្គលពាក់ព័ន្ធជាមិត្តភក្តិ មិត្តរួមថ្នាក់ អ្នកជិតខាង សមាជិកក្រុម សហសេវិក ឬសមាជិកគ្រួសារដែលមានតួនាទីក្នុងការទប់ស្កាត់ការរំលោភបំពានដែលប្រព្រឹត្តលើ ឬដោយអ្នកដទៃ។

ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី អភិក្រមសម្រាប់ការទប់ស្កាត់អំពើហិង្សា ផ្តោតលើបុរស និងក្មេងប្រុស មិនមែនក្នុងនាមជាជនបង្ក ឬអ្នកដែលអាចជាជនបង្កនោះទេ ប៉ុន្តែក្នុងនាមជាអ្នកនៅជិតកន្លែងកើតហេតុដែលមានសិទ្ធិអំណាចអាចប្រឈមជាមួយមនុស្សក្នុងជំនាន់ជាមួយគ្នា ដែលប្រព្រឹត្តបំពាន និងគាំទ្រអ្នកដែលរងការបំពាន។ ដូចគ្នានេះដែរ គំរូនេះ ផ្តោតលើក្មេងស្រី និងស្ត្រីមិនមែនក្នុងនាមជាជនរងគ្រោះ ឬអ្នកដែលអាចជាចំណុចដៅនៃការបៀតបៀន អំពើរំលោភសេពសន្ថវៈ និងការរំលោភបំពាននោះទេ ប៉ុន្តែក្នុងនាមជាអ្នកនៅជិតកន្លែងកើតហេតុដែលមានសិទ្ធិអំណាចអាចគាំទ្រដល់មនុស្សជំនាន់ជាមួយគ្នាដែលរងការបំពាននិងប្រឈមជាមួយអ្នកដែលប្រព្រឹត្តបំពាន។ដោយគ្មានការវិនិច្ឆ័យវត្តទាំងឡាយនឹងបង្ខំឱ្យមានទម្រង់ "ស្វ័យត្រួតពិនិត្យ" ដែលជួយឱ្យបុគ្គលឆ្លុះបញ្ចាំងលើអាកប្បកិរិយារបស់ខ្លួន។

អភិក្រមនេះមានគោលដៅបង្រៀនមនុស្សពីរបៀបធ្វើអន្តរាគមន៍នៅកន្លែងប្រទូស្តរាយ។ វាជាយុទ្ធសាស្ត្រផ្លាស់ប្តូរបទដ្ឋានសង្គម ក្នុងវប្បធម៌មនុស្សក្នុងជំនាន់ជាមួយគ្នានៅគ្រប់កម្រិត។ ដូច្នេះអភិក្រមនេះលើកទឹកចិត្តឱ្យមនុស្សហ៊ាននិយាយនៅចំពោះមុខឥរិយាបថបំពាន នៅមុនពេល ក្នុងពេល ឬបន្ទាប់ពីឧប្បត្តិហេតុ។ ចំណុចនេះជួយបង្កើតវប្បធម៌

349.Ibid

350. សម្រាប់ព័ត៌មានស្តីពី "អភិក្រមអ្នកនៅជិតកន្លែងកើតហេតុ" របស់អធិការចូលនិវត្តន៍ Graham Goulden និងបច្ចុប្បន្នជានាយកមជ្ឈមណ្ឌល Cultivating Minds UK សូមមើល www.grahamgoulden.com ។

មនុស្សក្នុងជំនាន់ជាមួយគ្នា ដែលការរំលោភបំពាន និងឥរិយាបថបំពានផ្សេងទៀតរបស់អ្នកប្រកាន់ភេទ ត្រូវបានចាត់ទុកជាទង្វើខុសឆ្គង និងមិនអាចទទួលយកបាន។ សម្រាប់ក្មេងប្រុស និងបុរស ការរំលោភបំពាននេះលេចឡើងជាការប្រព្រឹត្តផ្ទើន ជាជាងការអនុវត្តបទដ្ឋានសង្គមដែលពាក់ព័ន្ធនឹងភាពជាបុរស។

ទស្សនៈវិជ្ជាអប់រំក្នុងអភិក្រមនេះមានប្រភពចេញពីយុត្តិធម៌សង្គមដ៏សំខាន់ ដែលបង្រៀនថា មនុស្សគ្រប់រូបសុទ្ធតែមានតួនាទីដេញដោល និងផ្លាស់ប្តូរបទដ្ឋានសង្គម ដែលរួមចំណែកឱ្យមានឥរិយាបថបំពាន ជាពិសេសសមាជិករបស់ក្រុមគ្របដណ្តប់ឬក្រុមដែលមានឯកសិទ្ធិ។ទស្សនៈវិជ្ជានេះក៏កត់សម្គាល់ពីសិទ្ធិដែលបុគ្គលគួរទទួលបានក្នុងសង្គមផងដែរ។

អភិក្រមនេះគាំទ្រការពិភាក្សាជុំវិញបទដ្ឋានល្អៗក្នុងសង្គមរបស់យើង។ ការផ្តល់ឱកាសពិភាក្សានឹងអាចឱ្យបុគ្គលកំណត់អត្តសញ្ញាណអ្នកដទៃក្នុងបណ្តាញមនុស្សក្នុងជំនាន់ជាមួយគ្នាញឹកញាប់ ជាជាងមិនចែករំលែកឥរិយាបថ និងទស្សនៈល្អៗរបស់ខ្លួន។ ការទប់ស្កាត់ការរំលោភបំពានជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា។

អភិក្រមនេះជួយដល់ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងការទប់ស្កាត់អំពើហិង្សាតាមរយៈការផ្តល់ការពិភាក្សាដែលមានការរៀបចំដែលទទួលបានការអនុញ្ញាតពីបុរសផ្សេងទៀតក្នុងការធ្វើសកម្មភាព។ក្មេងប្រុសនិងបុរសមានឱកាសហាត់សមនិងអនុវត្តអន្តរាគមន៍ក្នុងបរិយាកាសដែលពួកគេទទួលបានការគាំទ្រពីមនុស្សក្នុងជំនាន់ជាមួយគ្នា និងការលើកទឹកចិត្តពីបុរសផ្សេងទៀត។

គោលដៅមួយទៀតគឺដើម្បីជួយឱ្យមនុស្សលែងធ្វើជាអ្នកនៅជិតកន្លែងកើតហេតុដែលអសកម្មនិងផ្លាស់ប្តូរទៅជាអ្នកនៅជិតកន្លែងកើតហេតុដែលមានសិទ្ធិអំណាច និងសកម្ម និងរួមចំណែកដល់ការផ្លាស់ប្តូរភាពអាចទទួលយកបាននៃការបៀតបៀន ការរំលោភបំពាន ឬអំពើហិង្សាក្នុងសង្គម។

សូមមើល ៖ www.mvpstrat.com សម្រាប់តំណភ្ជាប់គេហទំព័ររបស់បណ្ឌិត Jackson Katz។ កម្មវិធីអ្នកណែនាំការទប់ស្កាត់អំពើហិង្សា (MVP) ជាកម្មវិធីពិភពលោកសម្រាប់ប្រមូលភស្តុតាងពីអ្នកនៅជិតកន្លែងកើតហេតុ ដែលអនុវត្តតាមការពិពណ៌នាកម្មវិធីខាងលើ។កម្មវិធីនេះត្រូវបានអនុវត្តដោយជោគជ័យនៅសហរដ្ឋអាមេរិកចក្រភពអង់គ្លេសនិងស៊ុយអែត។

កម្មវិធីនេះត្រូវបានអនុវត្តក្នុងសាលារៀន និងសាកលវិទ្យាល័យ ដើម្បីជួយទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាទម្រង់ផ្សេងទៀតនៃអំពើហិង្សាក្នុងមជ្ឈដ្ឋានទាំងនេះ និងមជ្ឈដ្ឋានផ្សេងទៀត។

## និយមន័យ និងក្របខណ្ឌ

ទំនាក់ទំនង ជាប្រធានបទគន្លឹះក្នុងការបន្តការផ្តល់យុត្តិធម៌។ កញ្ចប់សេវាសំខាន់ៗលើកឡើងថា ការផ្តល់សេវាសំខាន់ៗដល់ជនរងគ្រោះ ចាប់ផ្តើមពីការស្តាប់ជនរងគ្រោះ និងយល់ពីតម្រូវការយុត្តិធម៌របស់ពួកគេ ដើម្បីអាចបំពេញតម្រូវការទាំងនោះប្រកបដោយប្រសិទ្ធភាព។

**ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព កសាងទំនុកចិត្ត បង្កើតតម្លាភាព និងពង្រឹងបរិយាកាសដែលពោរពេញដោយការគោរពនិងសមានចិត្តចំពោះគ្នាទៅវិញទៅមក មិនថាក្នុងការិយាល័យ តាមផ្លូវ ឬក្នុងបន្ទប់សវនាការនោះទេ។**

ការផ្តល់ព័ត៌មានច្បាស់លាស់ និងអាចទទួលបាន តាមរបៀបដែលបង្ហាញសមានចិត្ត មិនលម្អៀង និងប្រកបដោយបរិយាបន្នអាចបង្កើនភាពអង់អាចរបស់ជនរងគ្រោះឱ្យសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវទាក់ទងនឹងការពាក់ព័ន្ធរបស់ពួកគាត់ក្នុងប្រព័ន្ធយុត្តិធម៌។ ចំណុចនេះរួមមានការបញ្ជាក់ជាមួយជនរងគ្រោះថា អាទិភាពគឺការរក្សាការសម្ងាត់ និងឯកជនភាពរបស់ពួកគាត់ នៅពេលចែករំលែកព័ត៌មាននិងធ្វើទំនាក់ទំនងជាមួយស្ថាប័នផ្តល់សេវាយុត្តិធម៌ផ្សេងៗ និងវិស័យមិនមែនយុត្តិធម៌។

វប្បធម៌ទំនាក់ទំនងផ្អែកតាមគោលការណ៍ ការផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ រវាងជនរងគ្រោះ និងនគរបាលអាចរួមចំណែកដល់ការកាត់បន្ថយហានិភ័យរបស់ជនរងគ្រោះនៅពេលស្វែងរកយុត្តិធម៌[351]។

351. កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥)។

ដើម្បីជួយដល់ស្ថាប័ននគរបាលឱ្យធ្វើទំនាក់ទំនងកាន់តែល្អ ជាមួយជនរងគ្រោះដោយសារបទល្មើស និងអំពើហិង្សា អង្គការសហប្រជាជាតិស្នើឱ្យស្ថាប័នអនុវត្តន៍ច្បាប់លើកកម្ពស់ និងគោរពគោលការណ៍ដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច (១៩៨៥)។

ដើម្បីជួយដល់ដំណើរការនេះ UNODC បានផ្តល់ឧបករណ៍ជាច្រើនដល់ស្ថាប័ននគរបាលដែលខិតខំធ្វើទំនាក់ទំនងជាមួយជនរងគ្រោះតាមរបៀបដែលគិតគូរពីយេនឌ័រ។ ឧ. សម្រាប់ទំនាក់ទំនងជាមួយជនរងគ្រោះក្នុងពេលសម្ភាសន៍សូមមើលសៀវភៅណែនាំ(២០១០) ស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី[352] និងសៀវភៅណែនាំ (២០១៤) ស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់អយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[353]។

ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយកុមារដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី សៀវភៅណែនាំរបស់ UNODC-UNICEF សម្រាប់កម្មវិធីបណ្តុះបណ្តាលស្តីពីការប្រព្រឹត្តចំពោះកុមារដែលជាជនរងគ្រោះ និងកុមារដែលជាសាក្សីនៃបទល្មើសសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ (២០១៥)[354] ផ្តល់ការណែនាំច្បាស់លាស់ដល់ស្ថាប័នអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តសេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច នៅពេលពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះដោយសារបទល្មើស និងអំពើហិង្សា។ សៀវភៅណែនាំនេះក៏បានផ្តល់ការយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីយុត្តិធម៌ក្នុងបញ្ហាដែលពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះ និងជាសាក្សីនៃបទល្មើសផងដែរ[355] ។

សៀវភៅណែនាំនិងកម្រងគោលការណ៍ណែនាំទាំងនេះមានប្រយោជន៍ណាស់ព្រោះវាផ្តល់ និយមន័យច្បាស់លាស់នៃជនរងគ្រោះ និងជនរងគ្រោះជាកុមារ ទៅតាមស្តង់ដារអន្តរជាតិ (សូមមើលតារាង១ ខាងក្រោម)។ ភាពច្បាស់លាស់នេះអាចឱ្យស្ថាប័នអនុវត្តន៍ច្បាប់និងស្ថាប័ននគរបាលយល់ពីបុគ្គលដែលពួកគេធ្វើទំនាក់ទំនងជាមួយ និងរបៀបដែលស្ថាប័នទាំងនេះគួររៀបចំទំនាក់ទំនងជាមួយពួកគេ។

ឧ.ប្រសិនបើក្មេងស្រីម្នាក់ត្រូវបានគេជឿថាជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ ជាទូទៅគឺពួកគេត្រូវឆ្លងកាត់ការសម្ភាសន៍កោសលវិច័យជាមួយអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលឯកទេសលើការសម្ភាសន៍កុមារ។

សារទូទៅក្នុងឯកសារទាំងពីរនេះដែលអនុម័តដោយអង្គការសហប្រជាជាតិ គឺគួរប្រព្រឹត្តចំពោះជនរងគ្រោះប្រកបដោយសមានចិត្ត និងគោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបានយន្តការយុត្តិធម៌ និងដំណោះស្រាយឆាប់រហ័ស ដូចមានចែងក្នុងច្បាប់ជាតិ សម្រាប់គ្រោះថ្នាក់ដែលពួកគេទទួលរង[356]។

352. សូមមើលផ្នែកស្តីពីការសម្ភាសន៍ជនរងគ្រោះនិងអំណះអំណាងក្នុង"សៀវភៅណែនាំស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី"(UNODC,2010)។
353. សូមមើលផ្នែកស្តីពីការណែនាំបច្ចុប្បន្នភាពស្តីពីការសម្ភាសន៍ជនរងគ្រោះក្នុង"សៀវភៅណែនាំ (២០១៤) ស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់អយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី" (UNODC, UN Women, 2014)។
354. កម្មវិធីបណ្តុះបណ្តាលរបស់ UNODC ស្តីពីការប្រព្រឹត្តចំពោះកុមារដែលជាជនរងគ្រោះ និងកុមារដែលជាសាក្សីនៃបទល្មើសសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ (២០១៥)។
355. ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសន្តិសុខនៃអង្គការសហប្រជាជាតិបានអនុម័តគោលការណ៍ណែនាំស្តីពីយុត្តិធម៌ក្នុងបញ្ហាដែលពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះនិងជាសាក្សីនៃបទល្មើសក្នុងសេចក្តីសម្រេចលេខ ២០០៥/២០ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៥។
356. សូមមើល n.18.

**តារាង ១ ៖**

**និយមន័យនៃជនរងគ្រោះ ផ្អែកតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ**

| **និយមន័យនៃជនរងគ្រោះ[357]** | |
|---|---|
| យោងតាមសេចក្ដីប្រកាសស្ដីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការបំពានអំណាច (១៩៨៥) "ជនរងគ្រោះ" គឺជា ៖ | យោងតាមគោលការណ៍ណែនាំស្ដីពីយុត្តិធម៌ ក្នុងបញ្ហាដែលពាក់ព័ន្ធនឹងកុមារដែលជាជនរងគ្រោះនិងជាសាក្សីនៃបទល្មើស "កុមារដែលជាជនរងគ្រោះ និងជាសាក្សី" គឺជា ៖ |
| បុគ្គលដែលទទួលរងគ្រោះថ្នាក់ជាលក្ខណៈបុគ្គល ឬជាសមូហភាព រួមទាំងរបួសផ្លូវកាយ ឬរបួសផ្លូវចិត្ត ការរងគ្រោះផ្លូវចិត្ត ការខាតបង់ផ្នែកសេដ្ឋកិច្ច ឬការថយចុះយ៉ាងខ្លាំងនៃសិទ្ធិជាសារវន្តរបស់ខ្លួនដោយសារអំពើ ឬភាពអកម្មដែលរំលោភច្បាប់ព្រហ្មទណ្ឌដែលមានចែងក្នុងរដ្ឋសមាជិក រួមទាំងច្បាប់ដែលបដិសេធការបំពានអំណាចប្រព្រឹត្តដោយជនល្មើស។<br><br>បុគ្គលម្នាក់អាចចាត់ទុកជាជនរងគ្រោះក្រោមសេចក្ដីប្រកាសនេះ ដោយមិនគិតថាតើជនបង្កត្រូវបានកំណត់អត្តសញ្ញាណ ចាប់ខ្លួន ជំនុំជម្រះ ឬផ្ដន្ទាទោស និងមិនគិតពីទំនាក់ទំនងគ្រួសាររវាងជនបង្កនិងជនរងគ្រោះឡើយ។<br><br>ក្នុងករណីសមស្រប ពាក្យ "ជនរងគ្រោះ" ក៏រួមបញ្ចូលគ្រួសាររបស់ជនរងគ្រោះឬមនុស្សក្នុងបន្ទុករបស់ជនរងគ្រោះនិងអ្នកដែលរងគ្រោះថ្នាក់ក្នុងអន្តរាគមន៍ជួយដល់ជនរងគ្រោះដែលមានទុក្ខព្រួយ ឬទប់ស្កាត់ការរងគ្រោះផងដែរ។ | មនុស្សមានអាយុក្រោម ១៨ ឆ្នាំ ដែលជាជនរងគ្រោះដោយសារបទល្មើសឬជាសាក្សីនៃបទល្មើសដោយមិនគិតពីតួនាទីរបស់ពួកគេក្នុងបទល្មើសនោះ ឬក្នុងការផ្ដន្ទាទោសជនល្មើស ឬក្រុមជនល្មើសដែលរងការចោទប្រកាន់។ |

**ការយល់ព្រម កើតឡើងនៅពេលដែលបុគ្គលម្នាក់បង្កើតជម្រើសផ្អែកតាមព័ត៌មានត្រឹមត្រូវដើម្បីធ្វើអ្វីមួយដោយសេរី និងដោយស្ម័គ្រចិត្ត។ គេមិនចាត់ទុកជាការយល់ព្រមទេ ប្រសិនបើការយល់ព្រមនេះទទួលបានតាមរយៈការគំរាមកំហែង កម្លាំង ការបង្ខិតបង្ខំ ការក្លែងបន្លំ ការបោកបញ្ឆោត ឬមានភាពជាតំណាងមិនត្រឹមត្រូវ។**

ធាតុផ្សំដ៏សំខាន់មួយក្នុងការធានាសមានចិត្ត និងការគោរពសេចក្ដីថ្លៃថ្នូរដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺត្រូវបង្ហាញពីរបៀបដែលការចាត់ទុកជនរងគ្រោះជាចំណុចស្នូលនៃដំណើរការនេះ នឹងបង្កើនការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តដោយស៊ីសង្វាក់គ្នាក្នុងការស្វែងរកការយល់ព្រមពីជនរងគ្រោះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការដាក់បញ្ចូលជនរងគ្រោះជាចំណុចស្នូលនៃការស៊ើបអង្កេត និងធ្វើឱ្យជនរងគ្រោះយល់ថាពួកគាត់ទទួលបានការគោរព និងចូលរួមប្រកបដោយអត្ថន័យ។

357. Ibid

ការសំខាន់គឺនគរបាលដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវយល់ថា ការដកហូតអំណាចរបស់ជនរងគ្រោះក្នុងការផ្ដល់ការយល់ព្រម ធ្វើឱ្យជនរងគ្រោះប្រឈមនឹងការរងគ្រោះលើកទីពីរ។គួរកត់សម្គាល់ផងដែរថា ការដកហូតអំណាចរបស់ជនរងគ្រោះក្នុងការផ្ដល់ការយល់ព្រមអាចជាកត្តាដ៏សំខាន់ដែលញ៉ាំងឱ្យមានអំពើហិង្សាដែលគាត់ប្រឈមពីដំបូង។

"ជនរងគ្រោះមានសិទ្ធិទទួលបានព័ត៌មាន។ ជនរងគ្រោះគួរទទួលបានព័ត៌មាននិងព័ត៌មានបច្ចុប្បន្នភាពសមស្របស្ដីពីករណីរបស់ខ្លួន ដើម្បីអាចសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ និងធ្វើការវាយតម្លៃហានិភ័យ។ នៅពេលជំរុញឱ្យជនរងគ្រោះចូលរួមក្នុងការសម្រេចចិត្ត ពួកគេនឹងមានភាពអង់អាច និងមានភាពម្ចាស់ការលើជីវិតរបស់ខ្លួន"។

ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥

ការយល់ពីរបៀបនៃការធានាការយល់ព្រម ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញការគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្ស បរិយាបន្ន និងតម្លាភាព ហើយមានសារៈសំខាន់ខ្លាំងណាស់ក្នុងសេវានគរបាល[358]។

អ្វីដែលសំខាន់ផងដែរនោះ គឺនគរបាលត្រូវមានភាពច្បាស់លាស់ជាច់ខាតនៅពេលដែលកង្វះការយល់ព្រមគឺជាប្រច្ចូលនៃអំពើហិង្សាផ្លូវភេទ និងបទល្មើសផ្អែកតាមភេទ។ អំពើហិង្សាផ្លូវភេទជាសកម្មភាពផ្លូវភេទដែលគ្មានការយល់ព្រមដោយសេរី។ និយមន័យនេះគួរអនុវត្តនៅគ្រប់កាលៈទេសៈរួមទាំងរវាងគូស្វាមីភរិយាដែលរៀបការរួច។ ទំនាក់ទំនងផ្លូវភេទដោយមានការយល់ព្រម កើតឡើងនៅពេលដែលគូភាគីយល់ស្របទៅនឹងអ្វីដែលកំពុងកើតឡើងដោយផ្អែកតាមជម្រើស និងការមានសេរីភាព និងសមត្ថភាពធ្វើការជ្រើសរើស[359]។ UN Women ផ្ដល់កម្រងគោលការណ៍ណែនាំដ៏មានប្រយោជន៍(ប្រអប់១១) សម្រាប់ការស្វែងយល់ថាតើអ្វីជាការយល់ព្រមក្នុងទំនាក់ទំនងផ្លូវភេទ។

**ប្រអប់ ៩**

**UN Women ៖ នៅពេលមានការយល់ព្រម គឺមិនត្រូវមានភាពមិនច្បាស់លាស់ឡើយ[360]**

| | |
|---|---|
| រំភើបសាទរ | • ការយល់ព្រមកើតចេញពីក្ដីរំភើបសាទរ។ ដោយមិនស្វែងរកចម្លើយ "ទេ" ត្រូវធានាថាមានចម្លើយ "អូខេ"។<br>• ប្រសិនបើដៃគូរបស់អ្នកយល់ស្រប ប៉ុន្តែហាក់ព្រួយបារម្ភ ឬមិនប្រាកដក្នុងចិត្ត មានន័យថាពួកគេមិនយល់ព្រមទេ។<br>• "ទេ" ឬ "ខ្ញុំមិនដឹង" និងភាពស្ងៀមស្ងាត់ មិនមែនជាការយល់ព្រមទេ។ |
| ធ្វើឡើងដោយសេរី | • ការយល់ព្រមត្រូវធ្វើឡើងដោយគ្មានសម្ពាធ។ មិនគួរមានការបោកបញ្ឆោត ការបង្ខិតបង្ខំ ឬការគំរាមនរណាម្នាក់ឱ្យឆ្លើយ "អូខេ" នោះទេ។<br>• អ្នកមិនអាចផ្ដល់ការយល់ព្រមបានឡើយ ប្រសិនបើអ្នកមិនដឹងខ្លួន ឬមានអារម្មណ៍មិននឹងនរ ដូចជា ស្រវឹង ឬវិជ្ជលអារម្មណ៍ខ្លាំង។ |
| ផ្អែកតាមព័ត៌មានត្រឹមត្រូវ | • អ្នកអាចយល់ព្រមទៅនឹងអ្វីមួយ ប្រសិនបើអ្នកក្ដាប់ព័ត៌មានពិតទាំងអស់។ ឧ. ប្រសិនបើដៃគូម្នាក់និយាយថា ពួកគេនឹងប្រើស្រោមអនាម័យក្នុងពេលរួមភេទ ប៉ុន្តែពួកគេបែរជាមិនប្រើ វាមិនមែនជាការរួមភេទដោយមានការយល់ព្រមនោះទេ។ |

358. សូមមើល "សេវានគរបាលដែលផ្ដោតសំខាន់លើសហគមន៍ ក្នុងសៀវភៅណែនាំប្រតិបត្តិការសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ក្របខណ្ឌណែនាំជាយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព" (នាយកដ្ឋានប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ នាយកដ្ឋានគាំទ្រតាមមូលដ្ឋាន ២០១៨)។

359. "តើអ្វីជាអំពើរំលោភសេពសន្ថវៈ និងការប្រទូស្តកេរខ្មាស?" នគរបាលក្រុងឡុងដ៍ ចក្រភពអង់គ្លេស៖https://www.met.police.uk/advice/adviceandinformation/rsa/rape-and-sexual-assault/what-is-rape-and-sexual-assault/។

360. "ពាក់ព័ន្ធនឹងការយល់ព្រមត្រូវតែមានភាពច្បាស់លាស់" UN Women ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ https://www.unwomen.org/en/news/stories/2019/11/feature-consent-no-blurred-lines។

| | |
|---|---|
| ផ្អែកតាមព័ត៌មានត្រឹមត្រូវ | • ការយល់ព្រមមិនអាចមានលក្ខណៈសេរី និងពេញលេញនោះទេ ប្រសិនបើភាគីពាក់ព័ន្ធណាម្នាក់គឺជាអនីតិជន។ ដូច្នេះ អាពាហ៍ពិពាហ៍កុមារគឺជាអំពើដែលគ្មានការយល់ព្រម។ |
| ជាក់លាក់ | • ការយល់ព្រមផ្តល់ភាពជាក់លាក់។<br>• អ្នកមានសិទ្ធិយល់ព្រមទៅនឹងចំណុចមួយ មិនមែនចំណុចមួយផ្សេងទៀតនោះទេ។ អ្នកអាចយល់ព្រមឱ្យថើប ឬប៉ះពាល់នៅថ្ងៃណាមួយ ប៉ុន្តែមិនមែនថ្ងៃបន្ទាប់ពីនេះឡើយ។ អ្វីដែលអ្នកយល់ស្របគឺអាស្រ័យលើខ្លួនអ្នក និងអាចប្រែប្រួល។ |
| អាចដកហូតវិញបាន | • ការយល់ព្រមអាចដកហូតវិញបាន។អ្នកអាចផ្លាស់ប្តូរគំនិតបានគ្រប់ពេលហើយការយល់ព្រមគឺសំខាន់ណាស់សូម្បីតែក្នុងចំណោមស្វាមីភរិយា ដែលធ្លាប់រួមភេទពីមុនមក។ |

តាមរយៈការយល់ច្បាស់ពីអ្វីដែលបង្កើត និងមិនបង្កើតបានជាការយល់ព្រមក្នុងទំនាក់ទំនងផ្លូវភេទ នគរបាលនឹងមានគោលជំហរឹងមាំក្នុងការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទដែលរងការចោទប្រកាន់។ សំខាន់ជាងនេះគឺ វានឹងជួយឱ្យនគរបាលមានការយកចិត្តទុកដាក់ក្នុងការកំណត់រកលទ្ធភាពនៃការប្រព្រឹត្តអំពើផ្លូវភេទដែលគ្មានការយល់ព្រមពីមនុស្សម្នាក់ដោយមិនចាំបាច់មានភាពបំពានហួសហេតុក្នុងពេលសម្ភាសន៍។ ចំណុចនេះនឹងជួយកាត់បន្ថយបទពិសោធន៍អវិជ្ជមានរបស់ជនរងគ្រោះ(ការរងគ្រោះលើកទីពីរ) នៅពេលដាក់បណ្តឹងផ្លូវការ។

ពិធីសារអន្តរជាតិស្តីពីការចងក្រងឯកសារ និងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទក្នុង ស្ថានភាពមានជម្លោះ ៖ ការអនុវត្តល្អបំផុតក្នុងការកំណត់អំពើហិង្សាផ្លូវភេទជាបទល្មើសឬជាការរំលោភច្បាប់អន្តរជាតិ (២០១៧) ផ្តល់ឧទាហរណ៍បន្ថែមទៀតអំពីការអនុវត្តល្អដែលពាក់ព័ន្ធនឹងទំនាក់ទំនងដែលយកចិត្តទុកដាក់លើជនរងគ្រោះ (សូមមើលប្រអប់ ១២)។

**ប្រអប់ ៩**

**ប្រការគួរ និងមិនគួរក្នុងទំនាក់ទំនង**[361]

| ប្រការគួរ | ប្រការមិនគួរ |
|---|---|
| • ផ្តោតការយកចិត្តទុកដាក់ពេញលេញលើអ្នកតបសម្ភាសន៍ និងបង្ហាញតាមរយៈឥរិយាបថស្តាប់យ៉ាងយកចិត្តទុកដាក់៖រក្សាក្រសែភ្នែកដែលពោរពេញដោយការគោរព ងក់ក្បាលនិយាយថា "អ៊ឹម,ហ៊ឹម" ដើម្បីរក្សាទំនាក់ទំនងល្អនិងលើកទឹកចិត្តឱ្យជនរងគ្រោះ/សាក្សីនិយាយបន្ត។<br>• អនុញ្ញាតឱ្យជនរងគ្រោះ/សាក្សីនិយាយដោយគ្មានការកាត់សម្តី។<br>• ទប់អារម្មណ៍ និងមិនត្រូវបណ្តោយឱ្យអារម្មណ៍ផ្ទាល់ខ្លួនប៉ះពាល់ដល់ដំណើរការសម្ភាសន៍ឡើយ។អនុញ្ញាតឱ្យជនរងគ្រោះគ្រប់គ្រងល្បឿននៃការបង្ហាញព័ត៌មាន និងកម្រិតនៃការបង្ហាញ។<br>• ផ្តល់ការលួងលោម ការគាំទ្រ និងការបញ្ជាក់អះអាងឡើងវិញ។ | • កាត់សម្តីជនរងគ្រោះ/សាក្សី។<br>• ដាក់សម្ពាធ និងសួរសំណួរដដែលៗ។<br>• ឱ្យជនរងគ្រោះ/សាក្សីនិយាយដដែលៗពីរឿងរ៉ាវនៃការរំលោភបំពានរបស់ខ្លួនប្រាប់អ្នកដទៃ។<br>• ខឹងសម្បារ ឬបង្ខំឱ្យជនរងគ្រោះ/សាក្សីនិយាយ។<br>• សំឡុកជនរងគ្រោះ/សាក្សី។<br>• បង្ហាញការមិនជឿការខ្ចើមរអើមការបន្ទោសភាពក្រេវក្រោធ ឬភាពតក់ស្លុត ។<br>• សន្មតថាអ្នកដឹងអ្វីដែលជនរងគ្រោះ/សាក្សីចង់និយាយ។<br>• ប្រញាប់បញ្ចប់ការសម្ភាសន៍ ឬបញ្ចប់ជំហាននៃការសម្ភាសន៍។ |

- សួរសំណួរបើកដែលច្បាស់លាស់ និងសាមញ្ញ ហើយសួរសំណួរម្តងមួយៗ។
- ប្រើភាសាសាមញ្ញ និងច្បាស់លាស់ និងខិតខំបញ្ជាក់រាល់ពាក្យពេចន៍ប្លែកៗ។
- ទទួលស្គាល់ផ្នែកដ៏លំបាកបំផុតនៃការរៀបរាប់ដំណើររឿង និងពន្យល់ថាហេតុអ្វីព័ត៌មានលម្អិតទាំងនេះគឺត្រូវការជាចាំបាច់ (ប្រសិនបើចាំបាច់មែន)។
- ផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងមិនមែនពាក្យសម្តី។ដឹងថាពេលណាត្រូវឈប់សួរសំណួរមួយចំនួន ឬប្តូរប្រធានបទ។
- គោរពទស្សនៈ ជំនឿ គំនិត និងអារម្មណ៍របស់ជនរងគ្រោះ/សាក្សី។ កុំប្រាប់គាត់ឱ្យឈប់យំ ឬទប់អារម្មណ៍។




## សមត្ថភាពគ្រប់គ្រងសំខាន់ៗសម្រាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

ដូចការពិភាក្សាខាងលើជំនាញអន្តរបុគ្គលពិតជាចាំបាច់ណាស់សម្រាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយជនរងគ្រោះ មន្ត្រីដូចគ្នា ថ្នាក់ក្រោម ថ្នាក់លើ សមាជិកសហគមន៍ នាយកដ្ឋាន និងយុត្តាធិការផ្សេងទៀត ហើយប្រព័ន្ធតុលាការដើរតួនាទីយ៉ាងសំខាន់សម្រាប់ការធានាសេវានគរបាលដែលមានប្រសិទ្ធភាព។ យោងតាមមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស ទំនាក់ទំនងពាក់ព័ន្ធនឹងអន្តរកម្មជាមួយសហគមន៍ ការស្តាប់ទស្សនៈ និងគំនិតរបស់ពួកគេ និងការធ្វើសកម្មភាពតាមរបៀបដែលបង្កើនការអនុវត្តការងាររបស់នគរបាល និងការផ្តល់សេវា[362]។

"ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ជួយដល់ការផ្តល់សេវាដែលផ្តោតសំខាន់លើតម្រូវការរបស់សាធារណជន។របៀបធ្វើទំនាក់ទំនងរបស់នគរបាលគួរសមាមាត្រទៅតាមតម្រូវការ និងលក្ខខណ្ឌតម្រូវរបស់សហគមន៍ដែលនគរបាលផ្តល់សេវាជូន"។

មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស

មិនខុសពីជំពូកមុនៗទេសមត្ថភាពទាំងនេះត្រូវបានដកស្រង់ចេញពីឯកសារអង្គការសហប្រជាជាតិ ដូចជាឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL (២០១៥) ឯកសាររបស់ អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ស្តីពីការអនុវត្តល្អក្នុងការកសាងភាពជាដៃគូរវាងនគរបាល និងសាធារណជន ក្របខណ្ឌណែនាំជាយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព (SGF)[363]និងគោលការណ៍ណែនាំសម្រាប់ការដាក់បញ្ចូលអន្តរាគមន៍អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសកម្មភាពមនុស្សធម៌ (២០១៥)[364]។

ខាងក្រោមនេះជាចំណុចមួយចំនួននៃសមត្ថភាពអនុវត្តន៍ការងារសំខាន់ៗដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាងបាននៅពេលខិតខំធានាថាមន្ត្រីឆ្លើយតបរបស់ខ្លួនបង្កើនភាពអង់អាចដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមរយៈការធ្វើទំនាក់ទំនង

361. សូមមើលប្រអប់ ១ ក្នុងជំពូកទី ១១ (ការសម្ភាសន៍) នៃពិធីសារអន្តរជាតិស្តីពីការចងក្រងឯកសារ និងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទក្នុងស្ថានភាពមានជម្លោះ ៖ ការអនុវត្តល្អបំផុតក្នុងការកំណត់អំពើហិង្សាផ្លូវភេទជាបទល្មើស ឬជាការរំលោភច្បាប់អន្តរជាតិ 2nd Edition ៖ Sara Ferro Ribeiro and Danaé van der Straten Ponthoz on behalf of the UK Foreign & Commonwealth Office, March 2017។
362. ទំនាក់ទំនង ៖ ការជំរុញការចូលរួម និងទំនាក់ទំនង មហាវិទ្យាល័យសេវានគរបាល ៖ https://www.app.college.police.uk/appcontent/engagement-and-communication/communications/។
363. ក្របខណ្ឌណែនាំជាយុទ្ធសាស្ត្រសម្រាប់នគរបាលអន្តរជាតិដែលរក្សាសន្តិភាព (SGF) មានគោលបំណងបង្កើនប្រសិទ្ធភាពនៃការរក្សាសន្តិភាពដោយនគរបាលអង្គការសហប្រជាជាតិតាមរយៈអភិក្រមដែលកាន់តែស៊ីសង្វាក់គ្នា និងបន្សីគ្នាក្នុងការផ្តល់សុវត្ថិភាពសាធារណៈ កំណែទម្រង់នគរបាល និងការគាំទ្រដល់សេវានគរបាលរបស់រដ្ឋម្ចាស់ស្រុក។
364. គោលការណ៍ណែនាំសម្រាប់ការដាក់បញ្ចូលអន្តរាគមន៍អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសកម្មភាពមនុស្សធម៌ ៖ ការកាត់បន្ថយ ហានិភ័យ ការលើកកម្ពស់ភាពធន់ និងការជួយដល់ការស្តារឡើងវិញ (គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរស្ថាប័ន ២០១៥)។

និងការស្តាប់ដែលផ្តល់ភាពកក់ក្តៅ ច្បាមយកតម្រូវការយុត្តិធម៌របស់ជនរងគ្រោះ បំផុសទំនាក់ទំនងដោយផ្អែកលើការរក្សាការសម្ងាត់ និងឯកជនភាព។ អ្នកគ្រប់គ្រងគួរធានាថាមន្ត្រីឆ្លើយតបអាចអនុវត្តបាននូវចំណុចខាងក្រោម៖

> "យុទ្ធសាស្ត្រទំនាក់ទំនងទាំងអស់ត្រូវអនុលោមតាមស្តង់ដារនៃការរក្សាការសម្ងាត់ និងការការពារទិន្នន័យ នៅពេលប្រើប្រាស់រឿងរ៉ាវរូបភាពឬរូបថតរបស់ជនរងគ្រោះ ក្នុងគោលបំណងធ្វើការតស៊ូមតិ"។
>
> ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥

### ភាពអាចរកបាន និងទទួលបាន (ផ្អែកតាមអភិបាលកិច្ចការត្រួតពិនិត្យ និងគណនេយ្យភាព)

- ធានាការរាយការណ៍ជាប្រចាំអំពីទំនាក់ទំនង និងរបាយការណ៍ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទៅអ្នកពាក់ព័ន្ធនៅមូលដ្ឋានរួមទាំងអ្នកដែលទទួលបានការគាំទ្រក្នុងស្ថានភាពមនុស្សធម៌ ដោយប្រើទម្រង់ និងភាសាចម្រុះដើម្បីធានាភាពអាចទទួលបាន (ឧ. អក្សរសម្រាប់ជនពិការភ្នែក តួអក្សរធំៗ ភាសាសញ្ញា ភាសាដែលងាយស្រួលអានការផ្តល់សារបែបសាមញ្ញ ដូចជា អក្សររូប និងរូបភាព។ល។)។

### ទំនាក់ទំនងនិងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា

- ធានាទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយក្រុមស្ត្រី និងកុមារដើម្បីកសាង និងរក្សាទំនុកចិត្ត។ ចំណុចនេះគួររួមបញ្ចូលការចំណាយពេលជាមួយក្រុមទាំងនេះ និងសហគមន៍របស់ពួកគេ ការដើរល្បាតជាប្រចាំ ជំនួបជាជាប់លាប់ ការស្វែងរកយោបល់ត្រឡប់ ការធ្វើការអង្កេត ការរៀបចំវេទិកាសហគមន៍ ការទទួលបានការគាំទ្រពីថ្នាក់លើ និងការកែសម្រួលការឆ្លើយតបទៅតាមតម្រូវការ។

- កំណត់រក និងឆ្លើយតបទៅនឹងតួនាទីរបស់អ្នកក្នុងយុទ្ធនាការផ្សព្វផ្សាយដើម្បីផ្តល់មូលដ្ឋានព័ត៌មានស្តីពីនិន្នាការ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដល់ប្រជាជនដែលរងផលប៉ះពាល់ ។

### ភាពអាចរកបាន

- យល់និងផ្តោតការយកចិត្តទុកដាក់លើភាសាកាយវិការបញ្ចៀសការបែកអារម្មណ៍ ដូចជា សំឡេងរំខាន ញែកឱ្យដាច់នូវបុរេនិច្ច័យនិងការវិនិច្ឆ័យផ្ទាល់ខ្លួនលើបញ្ហានេះសួរសំណួរតែក្នុងគោលបំណងដើម្បីបញ្ជាក់ព័ត៌មានបន្ទាប់ពីជនរងគ្រោះបានរៀបរាប់ពីដំណើររឿងរបស់ពួកគេទាំងស្រុង និងនិយាយតាមនូវឃ្លាប្រយោគឡើងវិញ ដើម្បីបញ្ជាក់ពីការយល់របស់អ្នកអំពីព័ត៌មានដែលបានទទួល[365] ។
- យល់ និង សម្របតាមបាន ព្រោះសមាជិកសហគមន៍ឆ្លើយតបខុសៗគ្នាទៅនឹងមន្ត្រីនគរបាលដែលជាស្ត្រី និងមន្ត្រីនគរបាលដែលជាបុរស ជាពិសេសអាស្រ័យលើប្រភេទបទល្មើសដែលពួកគេប្រឈម។
- យល់ និងសម្រួលនូវឌីណាមិកទំនាក់ទំនង (communication dynamics) ក្នុងវេទិកាសហគមន៍ ឬវេទិកាស្រដៀងគ្នា ដើម្បីធានាថា សំឡេងទាំងអស់ត្រូវបានស្តាប់។ ចំណុចនេះរួមបញ្ចូលទាំងការដឹងថា ក្នុងការជួបជុំគ្នាទ្រង់ទ្រាយធំមានតែអ្នកមកពីក្រុមមួយចំនួនប៉ុណ្ណោះដែលអាចនិយាយ ចំណែកអ្នកផ្សេងទៀតជាពិសេសក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងកុមារប្រហែលជាមិននិយាយនោះទេ។ ដូច្នេះ ប្រហែលជាត្រូវមានអភិក្រមផ្សេងៗទៅតាមបរិយាកាសជាក់ស្តែង[366]។

### ភាពសមស្រប

- ស្តាប់យ៉ាងយកចិត្តទុកដាក់។ ពោលគឺត្រូវផ្តោតសំខាន់លើអ្នកនិយាយ និងព្យាយាមយល់ពីបទពិសោធន៍មុននឹងបកស្រាយ និងវាយតម្លៃពាក្យសម្តីរបស់គាត់[367] ។ ការបកស្រាយពាក្យសម្តីរបស់មនុស្សជាជាងការស្តាប់ និងយល់ អាចជះផលមិនល្អទៅវិញ ព្រោះវាហាក់ដូចជាអ្នកស្តាប់ នឹងធ្វើការ "បកស្រាយ" ដោយផ្អែកទៅតាមបុរេនិច្ច័យ/បទពិសោធន៍ផ្ទាល់ខ្លួន។
- ចែករំលែកព័ត៌មានជាមួយកុមារតាមរបៀបដែលអាចឱ្យពួកគេយល់បាន ជាពិសេសរបៀបបញ្ជូន ឬព័ត៌មានសំខាន់ៗផ្សេងទៀតដែលមានលក្ខណៈកុមារមេត្រី។

---

365. ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥ នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ ៖ http://repository.un.org/handle/11176/387374។
366. Ibid
367. Ibid

- ជំរុញការចូលរួម (ដាច់ដោយឡែក ក្នុងករណីចាំបាច់) របស់ស្ត្រី ក្មេងស្រី បុរស និងក្មេងប្រុសនៅមូលដ្ឋាន ក្នុងការបង្កើតសារនិងក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយសារទាំងនោះឱ្យសមស្របទៅតាមអាយុយេនឌ័រនិងវប្បធម៌។
- បង្ហាញសមានចិត្តចំពោះជនរងគ្រោះ និងសមាជិកសហគមន៍ ជាពិសេសអ្នកដែលច្រើនតែជួបការលំបាកក្នុងសង្គម។ ក្នុងករណីជនរងគ្រោះ ការប្រព្រឹត្តប្រកបដោយសមានចិត្ត នឹងផ្តល់អារម្មណ៍ធូរស្រាលដល់ពួកគេ និងអាចឱ្យអ្នកស៊ើបអង្កេតកំណត់ឡើងវិញនូវស្ថានភាពឡើងវិញដែលនាំទៅរកព្រឹត្តិការណ៍បង្កការប៉ះទង្គិចផ្លូវចិត្ត។

"នៅពេលនគរបាលផ្តល់ការណែនាំដល់ស្ត្រីស្តីពីការរក្សាសុវត្ថិភាព ចាំបាច់ត្រូវធានាថា ការណែនាំនោះមិនបង្ហាញថា ស្ត្រីជាអ្នកដែលត្រូវបានគេស្តីបន្ទោសនោះទេ"។

របាយការណ៍វាយតម្លៃបទល្មើសនៃការស្អប់ស្ត្រី ដែលទទួលបានជំនួយមូលនិធិពីការិយាល័យនគរបាល និងស្នងការបទល្មើស Nottinghhamshire (២០១៨)

**ប្រអប់ ៦**

**ប្រការគួរ និងមិនគួរក្នុងការជំរុញការចូលរួមរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីមានពិការភាព**[368]

| ប្រការមិនគួរ | ប្រការគួរ |
|---|---|
| កុំនិយាយជាមួយអ្នកបកប្រែ ឬតាមរយៈបុគ្គលិកគាំទ្ររបស់ពួកគេ អ្នកថែទាំផ្សេងទៀត ឬសមាជិកគ្រួសារ។ | និយាយផ្ទាល់ជាមួយជនរងគ្រោះដោយសំឡឹងមើលមុខគាត់ ទោះបីជាគាត់មានកម្សោយតំហើញក៏ដោយ។ |
| កុំប៉ះពាល់បរិក្ខារចល័តភាពរបស់ជនរងគ្រោះ ដោយគ្មានការអនុញ្ញាតជាមុន។ | រាល់ពេលនិយាយជាមួយជនមានកម្សោយគំហើញ សូមណែនាំខ្លួនជាមុនសិន (ឧ. មន្ត្រី "X" កំពុងនិយាយ)។ |
| កុំមើលស្រាលជំនាញទំនាក់ទំនងរបស់ជនមានពិការភាព។ អ្នកដែលមានកម្សោយក្នុងការស្តាប់ក៏អាចធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដោយប្រើប៊ិច/ខ្មៅដៃ និងក្រដាសបានផងដែរ។ | នៅពេលធ្វើទំនាក់ទំនងជាមួយអ្នកមានកម្សោយក្នុងការស្តាប់ និងទំនាក់ទំនង សួរថាតើគាត់មានអ្នកបកប្រែភាសាសញ្ញាដែលគាត់ទុកចិត្ត និងចង់ឱ្យចូលរួមឬទេ។ |
| ចាត់ទុកជនរងគ្រោះថា "មានពិការភាព"។ កុំប្រើឃ្លា "មនុស្សដូចជាអ្នក" ឬឃ្លាផ្សេងទៀតដែលអាចបង្ហាញថាអ្នកចាត់ប្រភេទជនរងគ្រោះជាក្រុមមួយផ្សេងទៀត។ | ហៅឈ្មោះជនរងគ្រោះ។ |
| បង្ហាញភាពមិនអត់ធ្មត់។ | យល់ពីតម្រូវការរបស់អ្នកដទៃ។ |
| សួរសំណួរអវិជ្ជមាន ដូចជា "តើអ្នកមានបញ្ហាអ្វី?" ឬ "តើអ្នកគឺអញ្ចឹងរហូត ឬ?" | សួរសំណួរវិជ្ជមាន ដូចជា "តើអ្នកប្រឈមនឹងការលំបាកក្នុងការធ្វើសកម្មភាពផ្សេងៗ ឬទេ?" ឬ "តើអ្នកត្រូវការការសម្របសម្រួលដើម្បីអាចចូលរួមបានពេញលេញឬទេ?" |
| សន្មតថាជនមានពិការភាពគ្រប់រូបមិនអាចចាប់រលាក់ដៃបាន។ | ហុចដៃទៅចាប់រលាក់ដៃជាមួយជនរងគ្រោះ។ អ្នកអាចសួរថាតើអ្នកអាចចាប់រលាក់ដៃបានដែរឬទេឬប្រាប់នរណាម្នាក់ដែលមានកម្សោយគំហើញដែលមើលមិនឃើញដៃរបស់អ្នក |
| សន្មតថា ជនមានពិការភាពគ្រប់រូបត្រូវការជំនួយ ហើយអ្នកដឹងពីរបៀបជួយ។ | សួរថាតើគាត់ចង់បានជំនួយណាមួយឬទេ និងរបៀបដែលអ្នកអាចជួយបាន។ |

368. ដកស្រង់ចេញពី Elena Ratoi, UN Women Programme Manager in Moldova and Humanity and Inclusion https://www.hi-us.org/

### ផ្ដោតអាទិភាពលើការវាយតម្លៃហានិភ័យសុវត្ថិភាពនិងការរៀបចំផែនការសុវត្ថិភាព

- កសាងការយល់ដឹងក្នុងសហគមន៍ផ្សេងៗស្ដីពីសុវត្ថិភាពទូទៅ និងការកាត់បន្ថយហានិភ័យអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- បង្កើត និងរក្សាបណ្ដាញទំនាក់ទំនងផ្សេងៗជាមួយជនរងគ្រោះរហូតដល់បិទបញ្ចប់ករណី និងធានាសុខុមាលភាពរបស់ជនរងគ្រោះ។

### ការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល

- ដាក់បញ្ចូលសារសំខាន់ៗស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងសកម្មភាពផ្សព្វផ្សាយ និងកសាងចំណេះដឹងតាមវិស័យក្នុងសហគមន៍។
- ធានាថា ការកសាងការយល់ដឹងមានព័ត៌មានស្ដីពីការទប់ស្កាត់ សិទ្ធិរបស់ជនរងគ្រោះ (ដូចជា ការរក្សាការសម្ងាត់នៅកម្រិតផ្ដល់សេវា និងកម្រិតសហគមន៍) កន្លែងរាយការណ៍ពីហានិភ័យ និងរបៀបទទួលបានការថែទាំសម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- លើកទឹកចិត្តឱ្យបុរស និងក្មេងប្រុសក្នុងមូលដ្ឋាន ចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាអំពីការនិយាយប្រឆាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

### ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន

- ស្វែងរក និងបញ្ចូលយោបល់ត្រឡប់របស់មន្ត្រីនគរបាលជាស្ត្រីនិងស្ត្រីក្នុងសហគមន៍ប្រសិនបើសកម្មភាពរបស់នគរបាលដែលស្នើឡើងសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាអ្វីដែលនគរបាលគួរធ្វើ។
- ប្រមូល និងរក្សាព័ត៌មានបច្ចុប្បន្នភាពស្ដីពីសមត្ថភាពឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងមូលដ្ឋាននិងវិធីបញ្ជូននិងចែករំលែកព័ត៌មានទាំងនេះតាមបែបប្រតិសកម្មជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីឱ្យពួកគេអាចបញ្ជូនជនរងគ្រោះ ទៅបណ្ដាញគាំទ្រ/ឆ្លើយតបសមស្រប។

### ការផ្ដល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់

- ពង្រឹងស្តង់ដារនៃការចែករំលែកព័ត៌មានដែលលើកកម្ពស់ការរក្សាការសម្ងាត់ និងធានាអនាមិកភាពរបស់ជនរងគ្រោះ។ ចំណុចនេះរួមបញ្ចូលដំណាក់កាលដំបូងនៃគ្រោះអាសន្ន ដែលសេវានៅមានកម្រិត។

## សូចនាករយោងសម្រាប់នគរបាលដែលផ្ដល់សេវាសំខាន់ៗ៖ ទំនាក់ទំនង

កញ្ចប់សេវាសំខាន់ៗស្នើឱ្យសមាសធាតុស្នូលនៃការផ្សព្វផ្សាយព័ត៌មានស្ដីពីយុត្តិធម៌ និងសេវានគរបាល មានលក្ខណៈសាមញ្ញ និងងាយស្រួលទទួលបាន។ ក្នុងន័យនេះទំនាក់ទំនងគួរមានគោលបំណងលើកកម្ពស់សេចក្ដីថ្លៃថ្នូរ និងការគោរពជនរងគ្រោះ។ ចំណុចនេះគួររួមបញ្ចូលទំនាក់ទំនងជាបន្តបន្ទាប់របស់នគរបាលជាមួយជនរងគ្រោះក៏ដូចជាទំនាក់ទំនងជាប្រចាំ និងមានប្រសិទ្ធភាពជាមួយដៃគូរបស់ពួកគេក្នុងការបន្តផ្ដល់យុត្តិធម៌។

ដើម្បីគូសបញ្ជាក់ពីសមាសធាតុសំខាន់ៗទាំងនេះកញ្ចប់សេវាសំខាន់ៗស្នើឱ្យសេវាយុត្តិធម៌ និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះ មានលក្ខណៈទូទៅ និងសកម្មភាពរួមដើម្បីធានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈទូទៅ និងសកម្មភាពរួមទាំងនេះមានរៀបរាប់ក្នុងជំពូកទី ២ (ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាអ្នកគ្រប់គ្រង និងប្រធានក្រុម)។



រូបថតទទួលបានពី UN Photo/Martine Perret (ប្រទេសទីម័រខាងកើត)

ដើម្បីជួយឱ្យយល់ពីរបៀបដាក់បញ្ចូលលក្ខណៈទូទៅ និងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗក្នុងយុទ្ធសាស្ត្រទំនាក់ទំនងនៅមូលដ្ឋានសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីសំដៅបង្កើនភាពអង់អាច



រូបថតទទួលបានពី UNAMID/Albert Gonzalez Farran (តំបន់ដាហ្វ៊ួរ ប្រទេសស៊ូដង់)

ដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងប្រព័ន្ធយុត្តិធម៌ សៀវភៅណែនាំនេះផ្តល់ឧទាហរណ៍នៃសូចនាករដែលអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចយកជាសំអាង ប្រសិនបើមាន ប៉ុន្តែប្រសិនបើគ្មាន ថ្នាក់លើគួរបញ្ចូលសូចនាករទាំងនេះ។

- **ភាពអាចរកបាន និងភាពអាចទទួលបាន** ៖ ភាគរយនៃប្រជាជននៅមូលដ្ឋានដែលពេញចិត្តនឹងព័ត៌មានដែលផ្តល់ដោយនគរបាលស្តីពីតួនាទីរបស់នគរបាលក្នុងការផ្តល់សេវាសំខាន់ៗដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការអង្កេតគួរខិតខំដាក់បញ្ចូលក្រុមជួបការលំបាកឬក្រុមប្រឈមនឹងហានិភ័យខ្ពស់ពីអំពើហិង្សាដើម្បីធានាការផ្តល់ព័ត៌មានដែលគ្រប់ជ្រុងជ្រោយ និងប្រកបដោយបរិយាបន្នដល់ពួកគេ។ ប្រភពព័ត៌មានដ៏សំខាន់ដែលត្រូវពិចារណាក្នុងសូចនាករនេះគឺបណ្តឹងប្រជាពលរដ្ឋលើទំនាក់ទំនងអន្តរបុគ្គលរបស់នគរបាល។
- **ភាពអាចសម្របតាមបាន និងភាពអាចទទួលបាន** ៖ ភាគរយនៃនគរបាលឆ្លើយតបនៅមូលដ្ឋានដែលពេញចិត្តនឹងភាពពាក់ព័ន្ធ និងភាពទាន់ពេលវេលានៃព័ត៌មានដែលបានផ្តល់ដល់ពួកគេមុនពេលចូលមកដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារឬអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ដើម្បីឱ្យនគរបាលឆ្លើយតបសមស្របទៅនឹងឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារ ការសំខាន់គឺមន្ត្រីឆ្លើយតបត្រូវដឹងពីបញ្ហាវប្បធម៌ តម្រូវការដាក់លាក់ ឬមានការចូលរួមពី សំណាក់នគរបាលមុនៗក្នុងទីតាំងនោះ ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ និងថាតើជនល្មើសអាចបង្កហិង្សា ឬទេ[369]។ ពាក់ព័ន្ធនឹងការវាស់វែងការអនុវត្តការងារគឺចាំបាច់ណាស់ក្នុងការពិនិត្យតាមដាន

369. ទំនាក់ទំនងផ្ទៃក្នុងរបស់នគរបាលត្រូវកំណត់រក និងផ្តល់ព័ត៌មានសំខាន់ៗដល់មន្ត្រីចុះល្បាតឱ្យបានឆាប់រហ័ស និងសុក្រឹត។ ការបង្កើនការអនុវត្តការងារលើផ្នែកនេះ នឹងបង្កើនសុវត្ថិភាពជាក់ស្តែង និងសុវត្ថិភាពតាមការសន្មតរបស់មន្ត្រីដែលប្រទះក្នុងស្ថានភាពអំពើហិង្សាក្នុងគ្រួសារ និងត្រៀមខ្លួនពួកគេបានយ៉ាងល្អក្នុងករណីមានពិការភាពផ្នែកបញ្ញាស្មារតីឬពិការភាពរាងកាយ ឬតម្រូវការពិសេសផ្សេងទៀត។ សូមមើល "ការវាស់វែងការអនុវត្តការងាររបស់នគរបាលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ (២០០៨)" Kiah Rollings and Natalie Taylor for Trends & issues in Crime and Criminal Justice No. 367 December 2008., Australian Institute of Criminology។

ជាប្រចាំលើភាពគ្រប់គ្រាន់នៃព័ត៌មានដែលផ្តល់ជូនមន្ត្រីចុះល្បាតនិងការបែងចែកព័ត៌មានតាមតំបន់ផ្សព្វផ្សាយ។ ការប្រមូលទិន្នន័យស្តីពីការអនុវត្តការងាររបស់មន្ត្រីឆ្លើយតបគួរធ្វើឡើងជាប្រចាំដោយប្រធានអង្គភាព ឬអ្នកគ្រប់គ្រងតាមផ្នែកដោយមានការសម្របសម្រួលជាមួយអ្នកគ្រប់គ្រងករណីស៊ើបអង្កេតនិងអាចបញ្ចូលជា "កំណត់សម្គាល់"ឬអនុសាសន៍ក្នុងរបាយការណ៍សំណុំរឿង។បន្ទាប់មក គួរដាក់បញ្ចូលព័ត៌មានទាំងនេះក្នុងការគ្រប់គ្រងគុណភាពនៃការអនុវត្តការងារនៃយន្តការសម្របសម្រួល និងគន្លងសកម្មភាព (ទាំងផ្ទៃក្នុង និងខាងក្រៅ) ជាមួយអ្នកផ្តល់សេវាសំខាន់ៗផ្សេងៗ រួមទាំងស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត។

**ហៅឈ្មោះជាតិពន្ធទៅតាមអ្វីដែលប្រជាជនហៅ (ឧ. ក្នុងករណីជនជាតិ Roma ក្នុងភាសាមួយចំនួន មានពាក្យផ្សេងសម្រាប់ក្រុមជាតិពន្ធនេះ ដូចជា gypsy និង tsygan ដែលជនជាតិ Roma យល់ថាជាការរើសអើង និងមិនគួរហៅដូច្នេះឡើយ)។**

**៣.ភាពសមស្រប៖** ចំនួនបណ្តឹងប្រឆាំងនឹងមន្ត្រីនគរបាលឆ្លើយតបដែលប្រព្រឹត្តខុសឆ្គងក្នុងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីអត្រានៃការទុកបណ្តឹងចោលភាគរយមន្ត្រីដែលមានតួនាទីពាក់ព័ន្ធនឹងបណ្តឹងទាំងនោះ។ ការបង្កើតមូលដ្ឋាន ភស្តុតាងជាចំណុចចាប់ផ្តើមនៃការខិតខំកែលម្អការផ្តល់សេវាដែលជនរងគ្រោះចង់បាន។ តាមរយៈការបង្ហាញដែលផ្អែកតាមពិសោធន៍នូវចំណុចដែលនគរបាលត្រូវកែលម្អនិងកសាងនូវការអនុវត្តល្អៗទាក់ទងនឹងទំនាក់ទំនងជាអន្តរបុគ្គលប្រកបដោយប្រសិទ្ធភាពជាមួយនឹងស្ត្រីអ្នកគ្រប់គ្រងក្នុងជួរនគរបាលអាចជួយណែនាំឱ្យបុគ្គលិកឆ្លើយតបរបស់ខ្លួន ផ្តោតលើការបង្កើនភាពអង់អាចដល់ជនរងគ្រោះ ជាជាងធ្វើឱ្យពួកគេរងគ្រោះជាលើកទីពីរ។

**៤. សុវត្ថិភាពជាចម្បង៖** ភាគរយ ឬផលធៀបនៃសំណុំរឿងអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលពីរសប្តាហ៍កន្លងមក) ធៀបនឹងករណីដែលអាស្រ័យលើព័ត៌មានបន្ថែម(រយៈពេលលើស២សប្តាហ៍)។ ការមានព័ត៌មានទាំងនេះ អាចឱ្យអ្នកគ្រប់គ្រងកំណត់ចំនួននៃករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលមិនត្រូវបានផ្សព្វផ្សាយជាប់ជាប្រចាំដល់ជនរងគ្រោះ។ ការពិនិត្យល្អិតល្អន់ជាងមុនលើករណីទាំងនេះដែលត្រូវបានចាត់ទុកថាគ្មានបច្ចុប្បន្នភាព គួរជួយកំណត់កម្រិតដែលជនរងគ្រោះប្រឈមនឹងហានិភ័យខ្ពស់ពីការប្រព្រឹត្តអំពើហិង្សាបន្តទៀតដោយជនបង្កជួយផ្តល់ជាព័ត៌មានថាតើជនសង្ស័យក្នុងករណីនេះត្រូវបានចាប់ខ្លួន គេចខ្លួន ស្ថិតក្រោមការសម្រេចដោះលែង ឬត្រូវបានដោះលែង និងបង់ប្រាក់ធានានៅក្រៅឃុំឬត្រូវបានដោះលែងមុនកាលកំណត់ និងថាតើជនរងគ្រោះមានមធ្យោបាយទំនាក់ទំនង ឬសមត្ថភាពទទួលបានសេវាគាំទ្រចាំបាច់ឬទេ។ទិន្នន័យគួរតម្រូវឱ្យមានជា ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ដើម្បីអាចធ្វើការប្រៀបធៀបបាន។

**ក្នុងករណីដែលអ្នកពាក់ព័ន្ធមិននិយាយភាសាទូទៅ សូមសួរមុននិងចាត់តាំងអ្នកបកប្រែ។**

**៥.ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ និងភាពអាចទទួលបាន៖**ភាគរយនៃប៉ុស្តិ៍នគរបាលដែលមានដំណើរការក្នុងការផ្តល់របាយការណ៍របស់នគរបាលដល់ជនរងគ្រោះ និង/ឬក្រុមច្បាប់ ដើម្បីសម្រួលដល់បញ្ហាផ្លូវច្បាប់។ ដំណើរការទាំងនេះគួរមានក្រមសីលធម៌សម្រាប់ជាមូលដ្ឋានក្នុងការផ្លាស់ប្តូរព័ត៌មាន(យោងតាមច្បាប់ជាធរមាន) រួមទាំងប្រភេទព័ត៌មានដែលអាចចែករំលែកបាន របៀបចែករំលែក របៀបរក្សាទុកព័ត៌មានដោយសុវត្ថិភាពនិងអ្នកណាខ្លះដែលអាចចែករំលែកព័ត៌មានជាមួយបាន។ គួរផ្តោតសំខាន់លើសារៈសំខាន់នៃការអនុលោមតាមការយល់ព្រមនិងការរក្សាការសម្ងាត់ដោយនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត។

**៦.ទំនាក់ទំនង និងការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃសេវា និងការផ្សារភ្ជាប់ទៅនឹងវិស័យនិងស្ថាប័នសំខាន់ៗតាមរយៈការសម្របសម្រួល៖** ចំនួនក្នុងមួយឆ្នាំៗនៃវគ្គបណ្តុះបណ្តាលរួមសម្រាប់ដំណើរការសម្របសម្រួលពហុស្ថាប័នដែលពាក់ព័ន្ធនឹងនគរបាលនៅមូលដ្ឋានស្តីពីការចែករំលែក

ព័ត៌មានប្រកបដោយប្រសិទ្ធភាពក្នុងចំណោមអ្នកផ្តល់សេវាយុត្តិធម៌។នគរបាលគួរទទួលបានការបណ្តុះបណ្តាលស្តីពីការចែករំលែកព័ត៌មានឱ្យបានសមស្របទៅតាមលក្ខខណ្ឌឯកជនភាព និងការរក្សាការសម្ងាត់ ជានាការផ្តល់ការយល់ព្រមត្រឹមត្រូវសម្រាប់ការបង្ហាញព័ត៌មានពីសំណាក់ជនរងគ្រោះនិង/ឬឪពុកម្តាយ/អាណាព្យាបាល និងតំណាងផ្លូវច្បាប់ (ឱ្យតែអាចធ្វើទៅបាន) និងត្រូវគោរពពិធីសារនិងដំណើរការ/របៀបបញ្ជូនដែលបង្កើនលំហូរព័ត៌មានទាន់ពេលវេលា និងមានប្រសិទ្ធផលក្នុងចំណោមអ្នកផ្តល់សេវាយុត្តិធម៌។

**៧.ការប្រមូលទិន្នន័យ និងគ្រប់គ្រងព័ត៌មាន៖** ការអង្កេតការយល់ឃើញរបស់សាធារណជនដែលជាលក្ខខណ្ឌតម្រូវនៃដំណើរការគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ បទពិសោធន៍ពីសេវានគរបាលចក្រភពអង់គ្លេសបង្ហាញថានគរបាលត្រូវស្វះស្វែងរកយោបល់ត្រឡប់ពីជនរងគ្រោះដោយសារការរំលោភបំពានក្នុងគ្រួសារ។ យោងតាមការសិក្សាមួយដែលគាំទ្រដោយរដ្ឋាភិបាលស្តីពីការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាក្នុងគ្រួសារនៅចក្រភពអង់គ្លេស ប្រសិនបើកងកម្លាំង (នគរបាល) យល់ពីមូលហេតុដែលជនរងគ្រោះមួយចំនួនមិនហ៊ានចូលរួមជាមួយនគរបាល នគរបាលត្រូវស្វះស្វែងរកយោបល់ត្រឡប់ពីជនរងគ្រោះដើម្បីអាចបំពេញតម្រូវការរបស់ជនរងគ្រោះ និងអាចគូសបញ្ជាក់ពីចំណុចដែលត្រូវកែលម្អ[370]។

### ករណីសិក្សា

## នគរបាល Nottinghamshire ៖ ការចាត់ទុកអំពើហិង្សាលើស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម

NOTTINGHAMSHIRE POLICE PROUD TO SERVE

នៅឆ្នាំ ២០១៦ នគរបាល Nottinghamshire បានក្លាយជាកងកម្លាំងនគរបាលដំបូងគេនៅចក្រភពអង់គ្លេសដែលអនុញ្ញាតឱ្យស្ត្រីនិងក្មេងស្រីរាយការណ៍ករណីនៃការស្អប់ស្ត្រី ផ្តល់ការគាំទ្រដល់ជនរងគ្រោះ និងស៊ើបអង្កេតជនបង្កដែលរងការចោទប្រកាន់។ នគរបាល Nottinghamshireចាត់ទុកការស្អប់ស្ត្រីនិងក្មេងស្រីជាបទល្មើសនៃការស្អប់ខ្ពើម ដោយមានការវាយតម្លៃខាងក្រៅស្តីពីវឌ្ឍនភាពដែលចេញផ្សាយនៅឆ្នាំ ២០១៨។

"អ្វីដែលស្ត្រីប្រឈមប្រចាំថ្ងៃ គឺមិនអាចទទួលយកបានឡើយ និងអាចបង្កទុក្ខព្រួយយ៉ាងខ្លាំង។ នេះជាបញ្ហាដ៏សំខាន់មួយក្នុងការងារពាក់ព័ន្ធនឹងបទល្មើសនៃការស្អប់ខ្ពើម ហើយនេះការដោះស្រាយបញ្ហានេះនឹងធ្វើឱ្យ Nottinghamshire ក្លាយជាកន្លែងដែលកាន់តែមានសុវត្ថិភាពសម្រាប់ស្ត្រីគ្រប់រូប"។

អធិការនគរបាល Nottinghamshire លោកស្រី Sue Fish (ចូលនិវត្តន៍)

យោងតាមគោលនយោបាយនេះ បទល្មើសនៃការស្អប់ស្ត្រី សំដៅលើ "ឧប្បត្តិហេតុប្រឆាំងនឹងស្ត្រីដែលជំរុញដោយឥរិយាបថរបស់បុរសចំពោះស្ត្រី និងរួមបញ្ចូលអាកប្បកិរិយារបស់បុរសចំពោះស្ត្រីដោយសារតែពួកគេជាស្ត្រី"[371]។

ក្នុងច្បាប់ចក្រភពអង់គ្លេសបទល្មើសនៃការស្អប់ខ្ពើមជាឥរិយាបថឧក្រិដ្ឋដែលជនបង្កត្រូវបានជំរុញដោយអរិភាព ឬបង្ហាញអរិភាពចំពោះជនរងគ្រោះដោយសារពិការភាព ជាតិសាសន៍ សាសនា ទំនោរផ្លូវភេទ ឬអត្តសញ្ញាណប្តូរយេនឌ័រ[372]។ សេវាអយ្យការ Crown ចក្រភពអង់គ្លេសលើកឡើងថាបទល្មើសនៃការស្អប់ខ្ពើមអាចរួមបញ្ចូលការរំលោភបំពានជាពាក្យសម្តី ការបំភិតបំភ័យ ការគំរាមកំហែង ការបៀតបៀន ការប្រទូស្តរាយ និងការរករឿងរំខានក៏ដូចជាការបំផ្លាញទ្រព្យសម្បត្តិ។លើសពីនេះជនបង្កអាចជាមិត្តភក្តិ អ្នកថែទាំ ឬមនុស្សស្គាល់គ្នាដែលកេងប្រវ័ញ្ចលើទំនាក់ទំនងជាមួយជនរងគ្រោះដើម្បីទទួលបានប្រយោជន៍ហិរញ្ញវត្ថុ ឬគោលបំណងឧក្រិដ្ឋផ្សេងទៀត[373]។

370. ការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ ៖ របាយការណ៍បច្ចុប្បន្នភាព អធិការដ្ឋាននៃសេវាពន្លត់អគ្គិភ័យ និងសង្គ្រោះនៃនគរបាលមហាក្សត្រី (HMICFRS) ខែ កុម្ភៈ ឆ្នាំ ២០១៩។

371. នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។ BBC https://www.bbc.com/news/uk-england-nottinghamshire-36775398។

កងកម្លាំងនគរបាលនៅអង់គ្លេសវែលនិងអៀកឡង់ខាងជើង បានធ្វើការពិនិត្យតាមដានប្រចាំឆ្នាំលើកត្តាទាំង ៥ ដែលនាំឱ្យមានបទល្មើសនៃការស្អប់ខ្ពើមដូចជាពិការភាព អត្តសញ្ញាណយេនឌ័រ ជាតិសាសន៍ ជាតិពន្ធុ ឬសញ្ជាតិ សាសនា ឬជំនឿ និងទំនោរផ្លូវភេទ[374]។ យោងតាម នគរបាលក្រុងឡុងដ៍ ភស្តុតាងដែលបង្ហាញពីធាតុផ្សំនៃការស្អប់ខ្ពើម មិនមែនជាលក្ខខណ្ឌតម្រូវឡើយ។ ជនរងគ្រោះមិនចាំបាច់សន្មតឧប្បត្តិហេតុនេះជាការស្អប់ខ្ពើមឡើយ ព្រោះឱ្យតែអ្នកផ្សេងទៀត សាក្សី ឬមន្ត្រីនគរបាលយល់ថា ឧប្បត្តិហេតុនោះជាការស្អប់ខ្ពើម គឺគ្រប់គ្រាន់ហើយ[375]។

ការសំខាន់ត្រូវកត់សម្គាល់ថា គោលនយោបាយរបស់នគរបាល Nottinghamshire ស្តីពីបទល្មើសនៃការស្អប់ស្ត្រី មិនកែប្រែ ឬមិនបន្ថែមលើច្បាប់ជាធរមានឡើយ ព្រោះគោលនយោបាយនេះបន្សុីគ្នានឹងនិយមន័យបទល្មើសនៃការស្អប់ខ្ពើមដែលត្រូវបានកំណត់ជាស្រេចក្រោមច្បាប់ចក្រភពអង់គ្លេស[376]។

ចំណុចបន្ថែម ក្នុងគោលនយោបាយរបស់នគរបាល Nottinghamshire គឺជនរងគ្រោះដោយសារបទល្មើសនៃការស្អប់ស្ត្រីអាចរាយការណ៍ឧប្បត្តិហេតុដែលអាចមិនត្រូវបានចាត់ទុកជាបទល្មើសក្រោមច្បាប់ចក្រភពអង់គ្លេស ហើយនគរបាលនឹងស៊ើបអង្កេត។ នគរបាល Nottinghamshire ត្រូវពិនិត្យថាតើជនរងគ្រោះអាចទទួលបានការគាំទ្រ ឬទេ ឬថាតើអាចធ្វើអ្វីមួយដើម្បីទប់ស្កាត់មិនឱ្យពួកគេក្លាយជាគោលដៅជាថ្មី ឬទេ និងដោយរបៀបណា[377]។

**ប្រអប់ ៧**

**អាកប្បកិរិយាដែលជាបទល្មើសនៃការស្អប់ស្ត្រី**

ក្នុងផ្នែកមួយនៃគោលនយោបាយនេះអាកប្បកិរិយាដែលនគរបាល Nottinghamshire កំណត់ជាបទល្មើសនៃការស្អប់ស្ត្រី រួមមាន ៖

- ការហួចដាក់
- ការលួចមើលកន្ទុយភ្នែក
- ការស្ទាបអង្អែល
- ការប្រទូស្តកេរខ្មាស
- ការតាមដល់ផ្ទះ
- ការថតរូបតាមទូរស័ព្ទចល័ត ដែលគេមិនចង់ឱ្យថត
- ការលួចថតក្រោមសំពត់មនុស្សស្រី *
- ភាសាបង្កប់ន័យផ្លូវភេទ
- អាកប្បកិរិយាគំរាម/គឃ្លើន/បំភិតបំភ័យ
- ការបង្ហាញដោយមិនសមរម្យ
- កាយវិការផ្លូវភេទដោយមិនចង់
- ការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត។

*ក្នុងច្បាប់ចក្រភពអង់គ្លេស “ការលួចថតក្រោមសំពត់មនុស្សស្រី” ពាក់ព័ន្ធនឹងជនល្មើសដែលថតរូបក្រោមសំពត់មនុស្សស្រី ដោយមិនឱ្យស្ត្រីដឹង ដើម្បីមើលប្រដាប់ភេទ ឬគូទរបស់ស្ត្រី។

នេះជាចំណុចសំខាន់សម្រាប់ការអភិវឌ្ឍការយល់ដឹងនិងលើកទឹកចិត្តឱ្យស្ត្រី និងក្មេងស្រីរាយការណ៍ពីអាកប្បកិរិយាគឃ្លើនដែលពួកគេមិនសុទ្ធតែយល់ថាជាបទល្មើសដូចជា ការបៀតបៀន (ផ្នែកទី ៤ ឬ ៥ នៃច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ ការប្រទូស្តរាយមិនសមរម្យ)។ ជាទូទៅ ស្ត្រីជាច្រើនរាយការណ៍ចំនួនករណីបទល្មើសក្រោមចំនួនករណីបទល្មើសពិតប្រាកដ (ជាពិសេសបទល្មើសហិង្សា និងបទល្មើសផ្លូវភេទ)។ អ្វីដែលត្រូវធ្វើគឺត្រូវបង្កើនទំនុកចិត្តរបស់ស្ត្រីលើសេវានគរបាលដើម្បីបង្កើនអត្រានៃការរាយការណ៍ករណីបទល្មើស។

ការផ្លាស់ប្តូរយុទ្ធសាស្ត្រដោះស្រាយអំពើស្អប់ស្ត្រី ដោយនគរបាល Nottinghamshire នឹងបង្កផលប៉ះពាល់លើ

372. និយមន័យរួមនេះត្រូវបានសម្រេចយកនៅឆ្នាំ ២០០៧ ដោយនគរបាល សេវាអយ្យការ Crown សេវាពន្ធនាគារ (បច្ចុប្បន្នជាសេវាជាតិគ្រប់គ្រងជនល្មើស) និងស្ថាប័នផ្សេងទៀតដែលបង្កើតបានជាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ សូមមើល បទឧក្រិដ្ឋនៃការស្អប់ខ្ពើម ប្រទេសអង់គ្លេស និងវែល ព្រឹត្តិប័ត្រស្ថិតិលេខ ២០១៧/១៨ ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៨។ នាយកដ្ឋានកិច្ចការផ្ទៃក្នុង ស្ថិតិបទល្មើស និងសេវានគរបាល។
373. បទល្មើសនៃការស្អប់ខ្ពើម សេវាអយ្យការ Crown ចក្រភពអង់គ្លេស https://www.cps.gov.uk/hate-crime ។
374. នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។ BBC https://www.bbc.com/news/uk-england-nottinghamshire-36775398 ។
375. តើអ្វីជាបទល្មើសនៃការស្អប់ខ្ពើម? នគរបាលក្រុងឡុងដ៍ ចក្រភពអង់គ្លេស ៖ https://www.met.police.uk/advice/advice-andinformation/ hco/hate-crime/what-is-hate-crime/ ។
376. ៦ ចំណុចដែលយើងបានដឹងអំពីការស្អប់ស្ត្រីដែលជាបទល្មើសនៃការស្អប់ខ្ពើម (២០១៦) Bates, L. for The Guardian, at: https://www.theguardian.com/lifeandstyle/womens-blog/2016/sep/22/six-things-weve-learned-about-misogyny-as-a-hate ។
377. នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។ BBC https://www.bbc.com/news/uk-england-nottinghamshire-36775398 ។

ការយល់ឃើញរបស់ស្ត្រីចំពោះអ្វីដែលពួកគេអាចរាយការណ៍បាន។ នៅចក្រភពអង់គ្លេស កងកម្លាំងនគរបាលអាចបញ្ចូលនិយមន័យផ្ទាល់ខ្លួនសម្រាប់និយមន័យបទល្មើសនៃការស្អប់ខ្ពើម ដោយបច្ចុប្បន្នមានការបន្ថែមផ្នែករងជាច្រើន[378]។

ដូច្នេះ ការកំណត់ការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម នឹងផ្តល់ទិដ្ឋភាពលម្អិតដល់នគរបាលស្តីពីភាពញឹកញាប់ ពេលវេលា និងកន្លែងដែលបទល្មើសនេះកើតឡើង ក៏ដូចជាផ្តល់សារយ៉ាងច្បាស់ថា នគរបាលនឹងពិចារណាយ៉ាងដិតដល់លើករណីស្អប់ស្ត្រី ដែលនឹងធ្វើឱ្យស្ត្រី និងក្មេងស្រីមានទំនុកចិត្តក្នុងការមកស្វែងរកជំនួយ និងរាយការណ៍បទល្មើស។អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺការរំលោភបំពានក្នុងគ្រួសារមិនត្រូវបានកំណត់ជាបទល្មើសនៃការស្អប់ស្ត្រី ក្រោមសេវានគរបាលនេះឡើយ ព្រោះករណីនេះមានពិធីសារផ្សេងទៀត[379]។

ផ្អែកលើបទពិសោធន៍នៅNottinghamshireនគរបាលដែលមិនសូវមានការយល់ដឹងផ្ទាល់ខ្លួនអំពីបទល្មើសនេះ មានការយល់ដឹងយ៉ាងច្រើនអំពីបទពិសោធន៍របស់ស្ត្រី និងក្មេងស្រី ដែលប្រឈមនឹងអាកប្បកិរិយារបស់អ្នកស្អប់ស្ត្រី។ ជាលទ្ធផល នគរបាលហាក់មានសមានចិត្ត និងក្តីមេត្តាកាន់តែច្រើនចំពោះជនរងគ្រោះដោយសារបទល្មើសនៃការស្អប់ខ្ពើមគ្រប់ប្រភេទហើយភ្លាមៗបន្ទាប់ពីបានបញ្ចប់កម្មវិធីបណ្តុះបណ្តាល ជនរងគ្រោះដោយសារបទល្មើសនៃការស្អប់ខ្ពើម មានការពេញចិត្តខ្លាំងជាងមុន ជាពិសេសពាក់ព័ន្ធនឹងសមានចិត្តរបស់នគរបាល និងការជឿរឿងរ៉ាវរបស់ពួកគេ[380]។

### ការអនុវត្តល្អ ៖ ការវាយតម្លៃថាសាធារណៈលើគោលនយោបាយរបស់នគរបាលដែលចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម

នៅឆ្នាំ ២០១៨ ការវាយតម្លៃមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលស្ត្រី Nottingham និងក្រោមជំនួយមូលនិធិរបស់ការិយាល័យនគរបាល និងស្នងការបទល្មើស Nottinghamshire បង្ហាញថា សាធារណជនមានទស្សនៈយល់ឃើញជាច្រើនចំពោះគោលនយោបាយនេះ។ ការវាយតម្លៃនេះលើកឡើងថាអ្នកចូលរួមក្នុងការអង្កេតជាង ៨៧% យល់ថា គួរកែប្រែគោលនយោបាយនេះ[381]។

ទោះបីជាសាធារណជនផ្តល់យោបល់ត្រឡប់វិជ្ជមានលើគោលនយោបាយនេះក្តី ក៏មជ្ឈមណ្ឌលស្ត្រី Nottingham និងដៃគូមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលពាក់ព័ន្ធក្នុងការអនុវត្តសាកល្បងនេះ ប្រឈមនឹងការរំលោភបំពានតាមបណ្តាញផ្សព្វផ្សាយសង្គមអនឡាញ( ទាំងក្នុងប្រទេស និងក្រៅប្រទេស) ដែលមានចាប់ពីការមិនយល់ស្រប និងការប្រមាថបែបគំរាមលើការស្អប់ស្ត្រី។

ចាប់តាំងពីការអនុវត្តសាកល្បងនេះមកកងកម្លាំងនគរបាលជាច្រើនផ្សេងទៀតនៅចក្រភពអង់គ្លេសបានដាក់ចេញគោលនយោបាយស្រដៀងគ្នា។ ទោះជាយ៉ាងណា ស្នងការនគរបាល Nottinghamshire ណែនាំថា ការងារស្រដៀងគ្នានាពេលអនាគតគួររួមបញ្ចូលយុទ្ធសាស្ត្រមានស្រាប់តាំងពីដំបូង ដើម្បីផ្តល់ការគាំទ្រដល់ការប្រឈមនឹងការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត ដូចជា ការរំលោភបំពានដែលផ្តោតលើសមាជិកនៃមជ្ឈមណ្ឌលស្ត្រី Nottingham។
អនុសាសន៍បន្ថែមសម្រាប់ការអនុវត្តគោលនយោបាយស្តីពីបទល្មើសនៃការស្អប់ស្ត្រី មានបង្ហាញក្នុងការវាយតម្លៃខាងក្រៅ[382] លើការអនុវត្តគោលនយោបាយនេះ ក្រោមជំនួយមូលនិធិរបស់ការិយាល័យនគរបាល និងស្នងការបទល្មើស Nottinghamshire។

យើងប្រមូលយករបាយការណ៍ទាំងអស់ដែលពាក់ព័ន្ធនឹងបទល្មើសរើសអើង យ៉ាងយកចិត្តទុកដាក់បំផុត។ ហើយយើងសប្បាយចិត្តដែលឮថា ការផ្តោតយកចិត្តទុកដាក់លើបទល្មើសរើសអើងតាំងពីឆ្នាំ២០១៦ ដោយកងកម្លាំងនិងដៃគូ បានផ្តល់ទំនុកចិត្តឱ្យស្ត្រីក្នុងការរាយការណ៍ពីឧប្បត្តិហេតុដែលកើតឡើង។ គោលបំណងរបស់យើងគឺមិនមែនដើម្បីដាក់ទោស ឬបង្កើនការផ្តន្ទាទោសនោះទេ ប៉ុន្តែដើម្បីបញ្ជាក់ឱ្យច្បាស់ថា

378. នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។ BBC https://www.bbc.com/news/uk-england-nottinghamshire-36775398 ។
379. ក្រោមការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាអ្នកពាក់ព័ន្ធនៅមូលដ្ឋានដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារនិងការសម្រេចចិត្តដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។សូមមើលផងដែរ នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។ BBC https://www.bbc.com/news/uk-england-nottinghamshire-36775398 ។
380. ការសង្កេតផ្ទាល់របស់លោកស្រី Susannah Fish ស្នងការនគរបាល Nottinghamshire (២០២០)
381. ការគាំទ្រយ៉ាងច្រើនលើសលប់របស់សាធារណជនលើគោលនយោបាយស្តីពីបទល្មើសនៃការស្អប់ស្ត្រី (២០១៨) សាកលវិទ្យាល័យ Nottingham។

រាល់អាកប្បកិរិយាដែលបំភិតបំភ័យគំរាមកំហែងបំបាក់មុខឬដៅមុខសញ្ញាលើស្ត្រីគឺមិនអាចទទួលយកបានទេ។ទោះជាយ៉ាងណាក៏ដោយយើងនឹងនឹងផ្តន្ទាទោសក្នុងករណីជាក់លាក់ណាមួយ។ដូចដែលរបាយការណ៍បានបង្ហាញបុរសភាគច្រើនមានភាពតក់ស្លុតចំពោះការដាក់ទោសទណ្ឌហើយវាជាការល្អដែលយើងអាចផ្តល់ឱកាសដល់ជនរងគ្រោះក្នុងការបញ្ចេញមតិ និង ទស្សនៈដើម្បីអប់រំ និងបញ្ឈប់បទល្មើសរើសអើងលើស្ត្រី ។

## អនុសាសន៍សម្រាប់ការបង្កើនប្រសិទ្ធភាពរបស់នគរបាល

អនុសាសន៍ទាំងនេះផ្តោតសំខាន់លើវគ្គបណ្តុះបណ្តាលនាពេលអនាគតសម្រាប់នគរបាលស្តីពីបទល្មើសនៃការស្អប់ស្ត្រី ដោយអនុសាសន៍ជាច្រើនផ្តោតលើវិធីល្អបំផុតក្នុងការផ្សព្វផ្សាយគោលនយោបាយនេះក្នុងស្ថាប័ននគរបាលដើម្បីឱ្យមានការទទួលយកដោយមន្ត្រីតាំងពីដំបូងក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការជំទាស់ដែលអាចលេចឡើង។ អនុសាសន៍រួមមាន ៖

- ការបណ្តុះបណ្តាលក្នុងទម្រង់ជាសិក្ខាសាលាដោយមានមតិយោបល់ពីជនរងគ្រោះ និងស្ថាប័នខាងក្រៅ។ ក្នុងការអង្កេតវាយតម្លៃជាមួយនគរបាល មន្ត្រីនគរបាលមិនពេញចិត្តនឹងវគ្គបណ្តុះបណ្តាលស្តីពីបទល្មើសនៃការស្អប់ខ្ពើម (ជារួម) និងជាញឹកញាប់រិះគន់ខ្លឹមសារនិងទម្រង់នៃវគ្គបណ្តុះបណ្តាល ជាពិសេសការបណ្តុះបណ្តាលអនឡាញ។ នគរបាលដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើកឡើងថាពួកគេចង់បានមតិយោបល់ពីជនរងគ្រោះ និងស្ថាប័នខាងក្រៅ[383]។

"យើងពិចារណាជិតដល់លើរាល់របាយការណ៍ស្តីពីបទល្មើសនៃការស្អប់ខ្ពើម។ យើងសប្បាយចិត្តនៅពេលបានដឹងថា ការដែលកងកម្លាំងនគរបាលនិងដៃគូផ្តោតសំខាន់លើបទល្មើសនេះតាំងពីឆ្នាំ ២០១៦ បានបង្កើនទំនុកចិត្តរបស់ស្ត្រីក្នុងការរាយការណ៍ឧប្បត្តិហេតុ។គោលដៅរបស់យើងគឺមិនមែនដាក់ទោសព្រហ្មទណ្ឌលើមនុស្សឬបង្កើនការកាត់ទោសនោះទេប៉ុន្តែយើងផ្តោតលើការបង្ហាញយ៉ាងច្បាស់ថា អាកប្បកិរិយាដែលបំភិតបំភ័យ គំរាមកំហែង ប្រមាថ ឬកំណត់ស្ត្រីជាគោលដៅ គឺមិនអាចទទួលយកបានឡើយ។ ទោះជាយ៉ាងណា យើងនឹងជានាឱ្យមានការកាត់ទោសក្នុងករណីសមស្រប។របាយការណ៍នេះបង្ហាញថាបុរសភាគច្រើនលើសលប់ភ័យញាប់ញ័រដោយសារឥរិយាបថនេះ។ចំណុចសំខាន់គឺយើងអាចផ្តល់ទស្សនៈយល់ឃើញរបស់ជនរងគ្រោះដើម្បីអប់រំនិងបញ្ឈប់មិនឱ្យស្ត្រីប្រឈមនឹងបទល្មើសនៃការស្អប់ខ្ពើមដោយសារយេនឌ័ររបស់ពួកគេ"។

Rachel Barber អធិការរងនៃនគរបាល Nottinghamshire និងជាអ្នកដឹកនាំយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសនៃការស្អប់ខ្ពើម

- ចាំបាច់ត្រូវពន្យល់ពីឥរិយាបថដែលលើកឡើងក្នុងគោលនយោបាយនេះថា មិនមែនជាអ្វីដែលថ្មីនោះទេ ប៉ុន្តែត្រូវបានលើកឡើងក្នុងបទល្មើសព្រហ្មទណ្ឌរួចទៅហើយ។ គោលនយោបាយនេះមានគោលបំណងបង្កើនការកត់ត្រា និងការឆ្លើយតបទៅនឹងបទល្មើស និងឧប្បត្តិហេតុដែលមិនត្រូវបានរាយការណ៍នាពេលបច្ចុប្បន្ន។
- ពន្យល់ច្បាស់ថា គោលនយោបាយនេះមានគោលបំណងកត់ត្រាឧប្បត្តិហេតុមួយចំនួនដើម្បីបញ្ជាក់អះអាងឡើងវិញដល់សាធារណជន គាំទ្រជនរងគ្រោះ និងបង្កើនការប្រមូលចារកម្ម។
- ជាទូទៅ គួរមានវគ្គបំប៉នស្តីពីបទល្មើសនៃការស្អប់ខ្ពើមដោយគូសបញ្ជាក់ថា បទល្មើសនេះមានទំហំធំធេងជាងការស្អប់ខ្ពើមនិងផ្តោតលើការកំណត់ជាគោលដៅបែបលម្អៀងដោយផ្អែកលើអត្តចរិតផ្ទាល់ខ្លួនដែលជាញឹកញាប់ពាក់ព័ន្ធនឹងការអះអាងពីអំណាច។
- មានការគូសបញ្ជាក់ថា បទល្មើសនៃការស្អប់ខ្ពើមរួមបញ្ចូលនូវការកត់ត្រាពីឧប្បត្តិហេតុ ហើយគោលនយោបាយស្តីពីការស្អប់ស្ត្រីនេះ ត្រូវអនុវត្តតាមបែបបទនេះ។មន្ត្រីផ្តោតខ្លាំងពេកលើគោលនយោបាយស្តីពីការស្អប់ស្ត្រី (misogyny policy) មិនមែនលើបទល្មើសនៃការស្អប់ខ្ពើមឡើយ។ ដូច្នេះហើយបានជាគេយល់ថាជាការសំខាន់ ដែលផ្តោតលើមូលហេតុដែល

382. របាយការណ៍វាយតម្លៃបទល្មើសនៃការស្អប់ស្ត្រីសម្រាប់មជ្ឈមណ្ឌលស្ត្រី Nottingham ដែលទទួលបានជំនួយមូលនិធិពីការិយាល័យនគរបាល និងស្នងការបទល្មើស Nottinghamshire៖ នគរបាល Nottinghamshire ចាត់ទុកការស្អប់ស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម។https://www.nottingham.ac.uk/lipp/documents/misogyny-evaluation-report.pdf ។
383. វគ្គបណ្តុះបណ្តាលសម្រាប់នគរបាល Nottinghamshire គោរពតាមការអនុវត្តល្អបំផុតដោយមានការបណ្តុះបណ្តាលតទល់និងរួមបញ្ចូលការប្រើប្រាស់វីដេអូនិងស្ត្រីដែលបង្ហាញសក្ខីកម្មផ្ទាល់ ដើម្បីអាចឱ្យមានការជជែកដេញដោល និងចំណេះដឹងកាន់តែច្រើនលើបញ្ហាដែលមានភាពស្មុគស្មាញ ឬទាមទារការយកចិត្តទុកដាក់ខ្ពស់។

ឥរិយាបថទាំងនេះ បញ្ជាក់ពីការមើលងាយស្ត្រី និង អាចមានភាពពាក់ព័ន្ធនឹងការបង្ហាញអរិភាព ។

ភស្តុតាងពីជនរងគ្រោះនិងអ្នកដែលមិនបានរាយការណ៍ បង្ហាញថា មន្ត្រីត្រូវជានាផ្តល់ការឆ្លើយតបប្រកបដោយ សមានចិត្ត និងក្តីមេត្តាចំពោះជនរងគ្រោះជាស្ត្រី និង ពិចារណាករណីឱ្យបានដិតដល់។ ទោះបីជាមិនអាចរក ឃើញជនបង្កក៏ដោយ ក៏នេះជាចំណុចសំខាន់សម្រាប់ សាធារណជន។ ការពិចារណាដិតដល់ជាគន្លឹះសំខាន់ ហើយជាញឹកញាប់ពួកគេនឹងដឹងថាអត្រាផ្តន្ទាទោសនឹង មានកម្រិតទាប ព្រោះឧប្បត្តិហេតុភាគច្រើនកើតឡើង លឿនពេករហូតមិនអាចផ្តល់ការពិពណ៌នាបាន។ល។

របាយការណ៍វាយតម្លៃបទល្មើសនៃការស្អប់ស្ត្រី ដែលទទួលបានជំនួយមូលនិធិ ពីការិយាល័យនគរបាល និងស្នងការបទល្មើស Nottinghamshire (២០១៨)

- បណ្តុះបណ្តាលនគរបាលឱ្យមើលឃើញពីសារៈសំខាន់ នៃគោលនយោបាយនេះ សម្រាប់ស្ត្រីក្នុងសង្គម ទាំងមូល របៀបដែលបទល្មើសនេះបង្កផលប៉ះពាល់ អវិជ្ជមានលើស្ត្រីនិងរំលោភសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី រួមទាំងសុខភាព និងសុខុមាលភាពប្រចាំថ្ងៃរបស់ស្ត្រី និងមិនគ្រាន់តែពិចារណាបទល្មើសនេះដោយផ្អែកលើ សេវានគរបាលនោះឡើយ (ពាក់ព័ន្ធនឹងអត្ថន័យរបស់វា សម្រាប់បន្ទុកការងារ។ល។)
- ត្រូវពិពណ៌នា និងចាត់ទុកគោលនយោបាយនេះជា បទពិសោធន៍ចម្រុះផ្អែកតាមយេនឌ័រដែលមាន លក្ខណៈប្រសព្វគ្នាដោយគូសបញ្ជាក់ពីបទពិសោធន៍ ផ្សេងៗសម្រាប់ក្រុមផ្សេងៗ។ចំណុចនេះអាចសម្រេច បានតាមរយៈមធ្យោបាយបណ្តុះបណ្តាលចម្រុះ (ឧ. ភាពយន្ត វីដេអូ បណ្តាញសង្គម។ល។)
- បញ្ចៀសការផ្តោតលើបទពិសោធន៍របស់បុគ្គលម្នាក់ៗ ដើម្បីងាកចេញពីការចោទប្រកាន់លើ "ការទាមទារ" ផ្ទាល់ខ្លួន និងផ្ទុយទៅវិញ ផ្តោតលើបទពិសោធន៍ ចម្រុះរបស់ក្រុមស្ត្រី និងក្មេងស្រីផ្សេងៗ។
- ចាំបាច់ត្រូវជំរុញឱ្យមានការជជែកដេញដោលយ៉ាង ទូលំទូលាយ ស្តីពីការរងគ្រោះផ្អែកតាមយេនឌ័រសម្រាប់ ស្ត្រី និងបុរសក្នុងសង្គម ដោយផ្តល់សារសំខាន់ៗស្តីពី សកម្មភាពរបស់នគរបាលដែលជាផ្នែកមួយនៃទិដ្ឋភាព សង្គមទូលំទូលាយ ដែលយើងទាំងអស់គ្នាសុទ្ធតែ មានតួនាទីរួមចំណែក។

# ៩

## កំណត់សម្គាល់ និងឯកសារបន្ថែម


1 Cassino, D. Why More American Men Feel Discriminated Against. Harvard Business Review. September 29, 2016, at: https://hbr.org/2016/09/why-more-american-men-feel-discriminated-against

2 The Honourable Wally T. Oppal., The Report of the Missing Women Commission of Inquiry VOLUME IIB Nobodies: How and Why We Failed the Missing and Murdered Women Part 3, 4 and 5 (2012). at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/about-bc-justice-system/inquiries/forsaken-vol_2b.pdf

3 Global Study on Homicide (UNODC, 2019), at: https://www.unodc.org/documents/data-and-analysis/gsh/Booklet1.pdf

4 Global Study on Homicide: Gender-related killing of women and girls (UNODC, 2018) at:https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf

5 Backlash in Gender Equality and Women's and Girls' Rights. Women's Rights & Gender Equality. Policy Department for Citizens' Rights and Constitutional Affairs Directorate General for Internal Policies of the Union PE 604.955– June 2018, at: http://www.europarl.europa.eu/RegData/etudes/STUD/2018/604955/IPOL_STU(2018)604955_EN.pdf

6 Communication: Engagement and communication. UK College of Policing, at: https://www.app.college.police.uk/app-content/engagement-and-communication/communications/

7 Kehn, A, and Ruthig, J.C. Perceptions of Gender Discrimination across Six Decades: The Moderating Roles of Gender and Age. 16 June 2013 # Springer Science+Business Medi New York 2013

8 United Nations Police Gender Toolkit,(UN Department of Peace Operations - DPO/ DPET/Integrated Training Service, 2015).

9 See United Nations Police Gender Toolkit Standardised Best Practices on Gender Mainstreaming in Peacekeeping Compendium of Project Tools (2015), at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

10 International Protocol on the Documentation and Investigation of Sexual Violence in Conflict. Best Practice on the Documentation of Sexual Violence as a Crime or Violation of International Law 2nd Edition: Sara Ferro Ribeiro and Danaé van der Straten Ponthoz on behalf of the UK Foreign and Commonwealth Office, March 2017, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

11 Lee P. (1989), Community Policing: A Practical Guide for Police Officials (U.S. Department of Justice, Office of Justice Programs, Washington, DC 1989), at: https://www.ncjrs.gov/pdffiles1/nij/118001.pdf

12 Good Practices in Building Police-Public Partnerships by the Senior Police Adviser to the OSCE Secretary General (The Organization for Security and Co-operation in Europe, 2008), at: https://www.osce.org/secretariat/32547?download=true

13 What is rape and sexual assault? Metropolitan Police UK, at: https://www.met.police.uk/advice/advice-and-information/rsa/rape-and-sexual-assault/what-is-rape-and-sexual-assault/

14 'When it comes to consent, there are no blurred lines' UN Women, November 18, 2019, at: https://www.unwomen.org/en/news/stories/2019/11/feature-consent-no-blurred-lines

15 'Measuring police performance in domestic and family violence', Kiah Rollings and Natalie Taylor for *Trends and Issues in Crime and Criminal Justice* No. 367 December 2008, Australian Institute of Criminology, at: https://aic.gov.au/publications/tandi/tandi367

16 The Police Response to Domestic abuse: An Update Report, Her Majesty's Inspectorate of Constabulary and Fire & Rescue Services (HMICFRS). February 2019 https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/the-police-response-to-domestic-abuse-an-update-report.pdf

17 'Nottinghamshire Police records misogyny as a hate crime' at: https://www.bbc.com/news/uk-england-nottinghamshire-36775398

18 Mullany, L. and Trickett, L. (June 2018): 'Misogyny Hate Crime Evaluation Report for Nottingham Women's Centre', funded by the Office of Nottinghamshire Police and Crime Commissioner, at: http://www.nottinghamwomenscentre.com/wp-content/uploads/2018/07/Misogyny-Hate-Crime-Evaluation-Report-June-2018.pdf

19 'Six things we've learned about misogyny as a hate crime', Bates, L (2016), for *The Guardian*. https://www.theguardian.com/

lifeandstyle/womens-blog/2016/sep/22/six-things-weve-learned-about-misogyny-as-a-hate

20 Overwhelming public support for Misogyny Hate Crime Policy (2018). University of Nottingham https://www.nottingham.ac.uk/news/pressreleases/2018/july/overwhelming-public-support-for-misogyny-hate-crime-policy.aspx

21 Hate Crime. The Crown Prosecution Service (CPS) United Kingdom, at: https://www.cps.gov.uk/hate-crime

22 Hate Crime, England and Wales, 2017/18 Statistical Bulletin 20/18 16 October 2018. Home Office Crime and Policing Statistics, at:. https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/748598/hate-crime-1718-hosb2018.pdf

23 What is hate crime? Metropolitan Police United , at: https://www.met.police.uk/advice/advice-and-information/hco/hate-crime/what-is-hate-crime/

24 'Upskirting' now a specific crime as bill receives Royal Assent (Ministry of Justice, UK, 2019), at: https://www.gov.uk/government/news/upskirting-now-a-specific-crime-after-bill-receives-royal-assent

25 Handbook on Effective Police Responses to Violence against Women (UNODC, 2010) at: https://www.unodc.org/documents/justice-and-prison-reform/Handbook_on_Effective_police_responses_to_violence_against_women_English.pdf

26 Handbook on Effective Prosecution Responses to Violence against Women and Girls (UNODC, UN Women, 2014), at: https://www.unodc.org/documents/justice-and-prison-reform/14-02565_Ebook_new.pdf

27 Skinnider, Eileen. 'Towards Gender-Responsive Criminal Justice: Good Practices from Southeast Asia in responding to violence against women' (2018: Thailand Institute of Justice).

10

# ការកសាងស្ថាប័នដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

“ការមានស្ត្រីកាន់តែច្រើនក្នុងកងកម្លាំងនគរបាល និងការបណ្តុះបណ្តាលស្ត្រីទាំងនោះឱ្យបានជិតដល់គឺជាជំហានបឋមដ៏សំខាន់ក្នុងការធានាថា ជនរងគ្រោះចាប់ផ្តើមមានទំនុកចិត្តឡើងវិញ និងយល់ថាមានការពិចារណាយ៉ាងល្អិតល្អន់លើបណ្តឹងរបស់ពួកគេនៅដំណាក់កាលនីមួយៗនៃដំណើរការដ៏ស្មុគស្មាញមួយ។ ដើម្បីសម្រេចវឌ្ឍនភាព យើងត្រូវដោះស្រាយដោយជោគជ័យនូវឧបសគ្គផ្នែកស្ថាប័ន និងឧបសគ្គផ្នែករចនាសម្ព័ន្ធជាច្រើន ប្រព័ន្ធបិតាធិបតេយ្យ និងផ្នត់គំនិតអវិជ្ជមានជុំវិញយេនឌ័រដែលលេចឡើងក្នុងស្ថាប័នសន្តិសុខ ស្ថាប័ននគរបាល និងស្ថាប័នតុលាការ ដូចអ្វីដែលបានអនុវត្តក្នុងស្ថាប័នផ្សេងទៀតដែរ”។

សេចក្តីថ្លែងការណ៍ក្នុងទិវាអន្តរជាតលុបបំបាត់អំពើហិង្សាលើស្ត្រី (ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩) របស់ Phumzile Mlambo-Ngcuka អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និងជានាយកប្រតិបត្តិអង្គការ UN Women

# គោលបំណងនៃជំពូកទី ១០

១. ផ្តល់ការណែនាំដល់ថ្នាក់ដឹកនាំនគរបាលដែលខិតខំបង្កើតបរិយាកាសអំណោយផលសម្រាប់ក្រុមរបស់ខ្លួនក្នុងការបន្តផ្តល់ការឆ្លើយតបដែលកាន់តែមានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

២. ផ្តល់ការណែនាំដល់ថ្នាក់ដឹកនាំនគរបាលស្តីពីការពង្រឹងវប្បធម៌នៃការឆ្លុះបញ្ចាំង និងការរៀនសូត្រក្នុងស្ថាប័ន ដោយសហការជាមួយអ្នកពាក់ព័ន្ធខាងក្រៅ ដើម្បីផ្តល់សេវានគរបាលប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព។



## សេចក្ដីផ្ដើម

**យោងតាមស្តង់ដាររបស់អង្គការសហប្រជាជាតិ ស្ថាប័ននគរបាលនីមួយៗ ឬស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀតគួរធ្វើជាតំណាងឆ្លើយតប និងទទួលខុសត្រូវចំពោះសហគមន៍ដែលពួកគេផ្តល់សេវាជូន384។ ទាំងនេះសុទ្ធសឹងជាសមាសធាតុសំខាន់ៗដើម្បីសន្មតថាជាអ្នកផ្តល់សេវាយុត្តិធម៌ដ៏សំខាន់ និងស្របច្បាប់។**

រូបថតទទួលបានពី UNIFIL/Pasqual Gorriz (ប្រទេសលីបង់)

ភាពឆ្លើយតបនឹងយេនឌ័រ ជួយកំណត់ការសន្មតលើស្ថាប័ននគរបាលក្នុងនាមជាស្ថាប័នដែលទទួលបានការទុកចិត្ត និងស្របច្បាប់ ជាពិសេសនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័រ។ ទោះជាយ៉ាងណា ចំណុចនេះទាមទារឱ្យស្ថាប័ននគរបាល "មានភាពម្ចាស់ការលើបញ្ហានេះ" ជាមុនសិន។ មានន័យថា ការឆ្លើយតប[385] ទៅនឹងការកើតមានអំពើហិង្សានេះគឺជាការទទួលខុសត្រូវចម្បងរបស់នគរបាល។

ជារួម ការទទួលខុសត្រូវលើបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានន័យថា នគរបាលត្រូវបានដាក់បញ្ចូលក្នុងចំណោមអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុត និងព្រួយបារម្ភចំពោះការកើតមានបញ្ហានេះ។ សំខាន់បំផុត ការសន្មតពីភាពម្ចាស់ការលើអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានន័យថា ស្ថាប័ននគរបាលប្តេជ្ញាប្រែក្លាយទៅជាចលករនៃដំណោះស្រាយ ដើម្បីទទួលបានលទ្ធផលវិជ្ជមានសម្រាប់ជនរងគ្រោះ។

ការផ្លាស់ប្តូរទាមទារឱ្យថ្នាក់ដឹកនាំជាន់ខ្ពស់របស់នគរបាលឆ្លុះបញ្ចាំងពីមូលហេតុដែលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរតាំងពីដំបូង។ ឧ. ត្រូវច្បាមយកការរៀនសូត្រអ្វីខ្លះ និងតើត្រូវមានបរិយាកាសអំណោយផលអ្វីខ្លះសម្រាប់ការផ្លាស់ប្តូរមន្ត្រីនគរបាលឱ្យឆ្លើយតបនឹងយេនឌ័រនិងជំរុញដំណោះស្រាយឆ្ពោះទៅរកការកាត់បន្ថយប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី?

384. សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៣៤/១៦៩ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩
385. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី សំដៅលើការទប់ស្កាត់ និងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបដោយនគរបាល។

ជំពូកនេះមានគោលបំណងផ្តល់ការណែនាំដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់នគរបាលនិងអ្នកគ្រប់គ្រងថ្នាក់កណ្តាលរបស់ពួកគេដែលខិតខំបង្កើតបរិយាកាសអំណោយផលសម្រាប់ឱ្យមន្ត្រីឆ្លើយតបរួមចំណែកដល់ការបង្កើតស្ថាប័ននគរបាលដែលកាន់តែឆ្លើយតបនឹងយេនឌ័រ និងមានប្រសិទ្ធភាពជាមុន។

ជំពូកនេះនឹងលើកកម្ពស់វប្បធម៌នៃការឆ្លុះបញ្ចាំង និងការរៀនសូត្រក្នុងស្ថាប័នតាមរយៈគោលនយោបាយដែលគិតគូរពីយេនឌ័រនិងការបង្កើនសមត្ថភាពសំខាន់ៗរបស់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលដើម្បីអាចជំរុញការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ដូចជា ការគូសបញ្ជាក់ពីតួនាទីសំខាន់ៗនៃវិធានការគណនេយ្យភាព ក្នុងការគាំទ្រដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាលតាមរយៈការផ្លាស់ប្តូរនិងរបៀបដែលទំនាក់ទំនងប្រកបដោយតម្លាភាពជាមួយអ្នកពាក់ព័ន្ធខាងក្រៅ [386] មិនត្រឹមតែជួយបង្កើនភាពធន់ និងភាពសមស្របដល់ដំណើរការនេះប៉ុណ្ណោះទេប៉ុន្តែថែមទាំងពង្រឹងភាពរីកចម្រើនផ្នែកវិជ្ជាជីវៈ និងការធ្វើទំនើបកម្មស្ថាប័ននគរបាលទៀតផង។



រូបថតទទួលបាន MINUSTAH/Logan Abassi (ប្រទេសហៃទី)

បរិយាកាសអំណោយផលសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល ត្រូវមានទម្រង់ជាគោលនយោបាយប្រកបដោយការផ្លាស់ប្តូរ រចនាសម្ព័ន្ធដែលសម្រួលដល់លក្ខណៈចម្រុះ និងការអនុវត្តបែបបរិយាបន្នដែលជំរុញលើកទឹកចិត្តឱ្យមានការយល់ដឹងសំខាន់ៗអំពីតួនាទីនិងបទដ្ឋានយេនឌ័រ។ ចំណុចនេះរួមមានការលើកឡើងពីវិធីផ្លាស់ប្តូរបទដ្ឋានយេនឌ័រអវិជ្ជមានដើម្បីជំរុញឱ្យមានទំនាក់ទំនងអំណាចដែលកាន់តែមានសមធម៌រវាងបុរសនិងស្ត្រី និងរវាងស្ត្រី និងអ្នកផ្សេងទៀតក្នុងសហគមន៍។

ការណែនាំស្តីពីបរិយាកាសអំណោយផលដែលថ្នាក់ដឹកនាំនគរបាលគួរយកមកពិចារណាដើម្បីជានាការឆ្លើយតបកាន់តែច្រើននិងកាន់តែមានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចែកចេញជាផ្នែកដូចខាងក្រោម ៖

១. ការកសាងការយល់ដឹងរួមស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី
២. គោលនយោបាយ និងយុទ្ធសាស្ត្រដែលជំរុញសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ
៣. ការកសាងភាពជាដៃគូយុទ្ធសាស្ត្រ
៤. ការបណ្តុះបណ្តាលការអប់រំនិងការអភិវឌ្ឍវិជ្ជាជីវៈ
៥. ធនធានមនុស្ស
៦. ការប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ
៧. ការពិនិត្យតាមដាននិងវាយតម្លៃលើសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រប្រកបដោយប្រសិទ្ធភាព។

អ្នកប្រើប្រាស់សៀវភៅណែនាំនេះ គួរអានជំពូកនេះអមជាមួយនឹងការណែនាំថ្មីៗពីឯកសារជំនួយស្មារតីដែលត្រូវបានកែសម្រួលស្តីពីយេនឌ័រ និងសន្តិសុខ, ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រ (២០១៩)[387] ដែលផលិតឡើងដោយមជ្ឈមណ្ឌលអភិបាលកិច្ចវិស័យ សន្តិសុខហ្សឺណែវ (DCAF) ក្រោមភាពជាដៃគូជាមួយអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE)/ការិយាល័យស្ថាប័នប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស (ODIHR) និង UN Women។ យោងតាម ODCAF ឧបករណ៍នេះផ្តោតសំខាន់លើកម្រិតគោលនយោបាយជាជាងកម្រិតប្រតិបត្តិការនិងពាក់ព័ន្ធនឹងនគរបាលជាន់ខ្ពស់ អង្គភាពយេនឌ័រ និងអ្នកដែលចាប់អារម្មណ៍លើការបង្កើនប្រសិទ្ធភាពរបស់នគរបាលតាមរយៈការដាក់បញ្ចូលទស្សនៈយេនឌ័រ។

386. អ្នកពាក់ព័ន្ធសំដៅលើរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនិងស្ថាប័នទាំងអស់ដែលមានតួនាទីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិតនៃរដ្ឋាភិបាល និងសង្គមស៊ីវិល។ អ្នកពាក់ព័ន្ធសំខាន់ៗរួមមានជនរងគ្រោះ និងតំណាង សេវាសង្គម វិស័យថែទាំសុខភាព និងអ្នកផ្តល់ជំនួយផ្នែកច្បាប់នគរបាលអយ្យការចៅក្រមទីភ្នាក់ងារការពារកុមារនិងវិស័យអប់រំ។ល។
387. ឯកសារជំនួយស្មារតី ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (Geneva: DCAF, OSCE/ODIHR, UN Women, 2019)

## ការបង្កើតការយល់ដឹងរួមស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី

### ចាប់ផ្តើមពីការយល់ដឹងរួមអំពីបញ្ហានេះ

ស្ត្រីនិងក្មេងស្រីនៅគ្រប់ទីកន្លែងត្រូវមានសិទ្ធិនិងឱកាសស្មើភាព និងអាចរស់នៅដោយគ្មានអំពើហិង្សា និងការរើសអើង។ សមភាពយេនឌ័រទាមទារឱ្យមានសកម្មភាពទូទាំងរដ្ឋាភិបាល និងរួមបញ្ចូលនគរបាល ដើម្បីលុបបំបាត់ឫសគល់ជាច្រើននៃការរើសអើងដែលនៅតែបន្តរឹតត្បិតសិទ្ធិរបស់ស្ត្រីក្នុងជីវិតឯកជននិងជីវិតសាធារណៈ។ វិសមភាពយេនឌ័រគឺជាការរើសអើង។

ដើម្បីផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ថ្នាក់ដឹកនាំនគរបាលត្រូវបង្កើតការយល់ដឹងផ្អែកតាមព័ត៌មានត្រឹមត្រូវថាតើឫសគល់នៃអំពើហិង្សា និងផលវិបាកនៃអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រីនិងក្មេងស្រីក្នុងស្ថាប័ននេះ។ ប្រសិនបើផ្អែកតាមព័ត៌មានត្រឹមត្រូវ ពីអ្នកដែលរងផលប៉ះពាល់ និងងាយរងគ្រោះខ្លាំងបំផុត ការយល់ដូច្នេះនឹងជួយឱ្យថ្នាក់ដឹកនាំនគរបាលកំណត់រកចំណុចខ្វះខាតក្នុងស្ថាប័ន។ ចំណុចខ្វះខាតទាំងនោះច្រើនតែមានទម្រង់ជាគោលនយោបាយ និងយុទ្ធសាស្ត្រមិនគ្រប់ជ្រុងជ្រោយដែលមានវិសាលភាពតូច និងវិធានការគណនេយ្យភាពទន់ខ្សោយដែលធ្វើឱ្យនគរបាលប្រព្រឹត្ត និងមានឥរិយាបថលម្អៀង និងឈានទៅរកការរើសអើងស្ត្រី និងក្មេងស្រី។

សូមមើល "សេចក្តីផ្តើម" សម្រាប់សាវតារស្តីពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលប៉ះពាល់នៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី និង ជំពូក ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់បញ្ហាប្រឈមទូទៅរបស់ស្ថាប័ន។

> ពាក្យ "ទស្សនៈយេនឌ័រ" ជាវិធីមួយក្នុងការយល់ឃើញ ឬការវិភាគដែលផ្តោតលើផលប៉ះពាល់នៃយេនឌ័រលើឱកាសតួនាទីក្នុងសង្គម និងទំនាក់ទំនងរបស់មនុស្ស។
> (UN Women)

នៅពេលរកឃើញចំណុចខ្វះខាតក្នុងស្ថាប័នទាំងនេះអ្នកគ្រប់គ្រងប្រតិបត្តិក្នុងជួរនគរបាលនឹងអាចដាក់ចេញគោលនយោបាយនិងយុទ្ធសាស្ត្ររួមទាំងគោលនយោបាយ និង យុទ្ធសាស្ត្រពង្រឹងសុចរិតភាព និងគណនេយ្យភាពរបស់នគរបាល ដើម្បីបញ្ឈប់ការអនុវត្តបែបរើសអើងនិងផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

ស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រគឺជាស្ថាប័នដែលប្តេជ្ញាបញ្ជ្រាបគោលការណ៍សមភាពយេនឌ័រ និងការមិនរើសអើងក្នុងគោលនយោបាយ និងការអនុវត្តរបស់ខ្លួនដែលរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមការអនុវត្តទស្សនៈយេនឌ័រក្នុងការរៀនសូត្រ និងការអភិវឌ្ឍន៍វិជ្ជាជីវៈក្នុងស្ថាប័ន។

ការអនុវត្តទស្សនៈយេនឌ័រ នឹងអាចឱ្យនគរបាលកំណត់កាន់តែច្បាស់នូវភាពខុសគ្នានៃជីវិតរស់នៅរបស់បុរស និងស្ត្រី និងរបៀបដែលការសម្រេចចិត្ត និងកាលៈទេសៈនានាដែលជះឥទ្ធិពលខុសគ្នាលើបុរស និងស្ត្រី។ ការវិភាគនឹងផ្តល់ការយល់ដឹងសមស្របស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា អំពើហិង្សាលើដៃគូស្និទ្ធស្នាល) ដោយមានការពិចារណាពីប្រវត្តិ បរិបទ អត្ថន័យ ផលប៉ះពាល់ និងផលវិបាកនៃអំពើហិង្សានេះ។ ការពិចារណាពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងបរិបទយេនឌ័រ នឹងជួយឱ្យនគរបាលយល់ពីបរិបទ ធម្មជាតិ វិសាលភាព

---

388. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ "ផ្អែកតាមព័ត៌មានត្រឹមត្រូវ" មានន័យថា វាពាក់ព័ន្ធនឹងបរិបទនិងមានការផ្តល់ធាតុចូលជាប្រចាំ (ទិន្នន័យបែបបរិមាណនិងទិន្នន័យបែបគុណភាព) ពីនគរបាលជំនាញ និងអ្នកពាក់ព័ន្ធខាងក្រៅ ដូចជា អ្នកផ្តល់សេវាសំខាន់ៗ និង/ឬអង្គការសង្គមស៊ីវិល។
389. គួរមានការពិចារណាជាពិសេសចំពោះស្ថានភាពនៃជម្លោះប្រដាប់អាវុធ ឬវិបត្តិមនុស្សធម៌។
390. "ផ្អែកតាមព័ត៌មានត្រឹមត្រូវ" មានន័យថា វាពាក់ព័ន្ធនឹងបរិបទ និងមានការផ្តល់ធាតុចូលជាប្រចាំ (ទិន្នន័យបែបបរិមាណនិងទិន្នន័យបែបគុណភាព) ពីអ្នកពាក់ព័ន្ធក្នុងនិងក្រៅស្ថាប័ន។

និងផលវិបាកនៃអំពើហិង្សានេះ ដើម្បីផ្តល់ការឆ្លើយតបកាន់តែប្រសើរ។

ការយល់ដោយផ្អែកតាមព័ត៌មានត្រឹមត្រូវអំពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឫសគល់ ផលវិបាក និងផលប៉ះពាល់មិនសមាមាត្រនៃអំពើហិង្សានេះ នឹងផ្តល់មូលដ្ឋានសម្រាប់ឱ្យនគរបាលសហការជាមួយសេវាសំខាន់ៗផ្សេងទៀតក្នុងការបន្តផ្តល់យុត្តិធម៌ និងកសាងភាពជាដៃគូសមស្របជាមួយអ្នកពាក់ព័ន្ធខាងក្រៅក្នុងដំណើរការនេះ។

ប្រអប់ ១ បង្ហាញពីតួនាទីរបស់ថ្នាក់ដឹកនាំនគរបាលក្នុងការទទួលខុសត្រូវចំពោះបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ១ ៖**

**ការទទួលខុសត្រូវលើបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី តួនាទីរបស់ថ្នាក់ដឹកនាំនគរបាល**

| បង្កើតក្នុងស្ថាប័ននូវ ៖ | ផ្តល់បរិយាកាសអំណោយផលសម្រាប់ឱ្យមន្ត្រីឆ្លើយតប៖ | ធានាការទទួលខុសត្រូវលើ ៖ |
|---|---|---|
| ការយល់ដឹងដោយផ្អែកតាមព័ត៌មានត្រឹមត្រូវស្តីពីធម្មជាតិនៃអំពើហិង្សា ឫសគល់ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី | សហការ និងសម្របសម្រួលបែបប្រតិសកម្មជាមួយអ្នកពាក់ព័ន្ធដូចជា អង្គការសិទ្ធិស្ត្រី ដើម្បីស្វែងយល់ពីបញ្ហាទាំងនេះ ផ្សព្វផ្សាយពីភាពមិនអាចទទួលយកបាននៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបង្ហាញការប្តេជ្ញាចិត្តចាត់វិធានការលើករណីជាក់ស្តែង | ការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ គឺជាការអនុវត្តទូទៅនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី |
| | ប្តេជ្ញាអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងផ្តោតលើជនបង្ក សម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាមួយអ្នកផ្តល់សេវាសំខាន់ៗ | |
| | អនុវត្តការរៀនសូត្រផ្អែកតាមព័ត៌មានត្រឹមត្រូវនិងឆ្លងកាត់ការពិគ្រោះយោបល់ទូលំទូលាយ ឆ្ពោះទៅរកការទប់ស្កាត់ និងស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីឱ្យការរៀនសូត្រទាំងនោះឆ្លុះបញ្ចាំងពីសិទ្ធិ គិតគូរពីយេនឌ័រ និងផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត | |

**ការឆ្លុះបញ្ចាំង ការរៀនសូត្រ ការផ្លាស់ប្តូរ និងការធ្វើទំនើបកម្ម**

## ការកសាងការយល់ដឹង និងការអប់រំស្តីពីគន្លឹះឆ្ពោះទៅមុខ

ការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័របង្ហាញថាការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីគឺជាអាទិភាពមួយរបស់ស្ថាប័ន ហើយការឆ្លើយតបទៅនឹងករណីអំពើហិង្សានេះតាមរយៈការស៊ើបអង្កេត អនុលោមតាមស្តង់ដារអន្តរជាតិដែលតម្កល់សុខុមាលភាពរបស់ជនរងគ្រោះជាអាទិភាព និងរក្សាការទទួលខុសត្រូវរបស់ជនបង្ក។

ក្រៅពីនេះ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រលើកកម្ពស់ការចាត់វិធានការនិងការធ្វើសកម្មភាពដោយមន្ត្រី និង/ឬក្រុមពាក់ព័ន្ធដែលឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលា ដោយយល់ឃើញថា គ្មានការផ្តន្ទាទោសករណីអំពើហិង្សាលើស្ត្រីភាគច្រើនដែលត្រូវបានរាយការណ៍នោះទេ។

ថ្នាក់ដឹកនាំប្រតិបត្តិក្នុងជួរនគរបាលត្រូវតែកំណត់ និងផ្សព្វផ្សាយអាទិភាពទាំងនេះជាចំណុចចាប់ផ្តើមនៃការជំរុញឱ្យមានដំណោះស្រាយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការអនុវត្តដោយមន្ត្រីបញ្ជាការទាំងអស់។

គន្លឹះនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រក្នុងការធានាការចូលរួមប្រកបដោយអត្ថន័យ[391] របស់ជនរងគ្រោះក្នុងការស៊ើបអង្កេតព្រោះការចូលរួមនេះនឹងបង្កផលប៉ះពាល់លើដំណើរការស៊ើបអង្កេត។ ការចូលរួមនឹងធ្វើសារសម្រាប់ការទប់ស្កាត់អំពើហិង្សានាពេលអនាគត ព្រោះនគរបាលនឹងប្តេជ្ញារក្សាសុវត្ថិភាព និងការពារជនរងគ្រោះ ហើយបញ្ហារបស់ពួកគេទទួលបានការពិចារណាជិតដល់។

"ការខិតខំសម្រេចបានសមភាពយេនឌ័រគឺជាកាតព្វកិច្ចក្នុងច្បាប់អន្តរជាតិផងនិងជាចំណុចចាំបាច់ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ"។

ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រ (២០១៩) ក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ

ការប្តេជ្ញាចិត្តរបស់នគរបាលក្នុងការធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះដើម្បីធានាការឆ្លើយតបផ្អែកតាមព័ត៌មានត្រឹមត្រូវ គួរអនុវត្តចំពោះករណីរដ្ឋប្បវេណីដូចក្នុងដំណើរការយុត្តធម៌ព្រហ្មទណ្ឌដែរ។ ជនរងគ្រោះអាចស្វែងរកដំណោះស្រាយផ្លូវច្បាប់ (ទម្រង់មួយចំនួន) តែក្នុងតុលាការរដ្ឋប្បវេណីប៉ុណ្ណោះ។ក្រៅពីនេះនគរបាលគួរឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងគ្រប់គ្រាន់ទៅនឹងដីកាការពារក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ឬអនុវត្តដីកាបញ្ឈប់ និងដីកាដកបណ្តឹង (Cease and Desist Orders) ដែលខិតខំទប់ស្កាត់ការចេញផ្សាយ និងការចែកចាយបន្តនូវរូបភាពបុគ្គលតាមប្រព័ន្ធអ៊ីនធឺណិត។



រូបថតទទួលបានពីនាយកដ្ឋានទំនាក់ទំនងសាធារណៈនៃកងកម្លាំងនគរបាលនីហ្សេរីយ៉ា

ដោយសារតែជាញឹកញាប់នគរបាលជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គមជាក់ស្តែង ការផ្តល់សារក្នុងស្ថាប័នស្តីពីការប្តេជ្ញាចិត្តធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះគួរលេចឡើងច្បាស់ក្នុងការកត់សម្គាល់ថា ជនរងគ្រោះ និងជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏អាចជាសមាជិកក្នុងស្ថាប័ននគរបាលផងដែរ។ ទិន្នន័យអន្តរជាតិបង្ហាញថា ក្នុងចំណោមស្ត្រី ៣នាក់ មានម្នាក់[392]នឹងប្រឈមនឹងទម្រង់មួយនៃអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាផ្លូវភេទក្នុងជីវិតរបស់ពួកគេ។មានន័យថានគរបាលក៏អាចជាជនបង្ក និងជាជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រផងដែរ។

ការស្រាវជ្រាវ និងការអនុវត្តបង្ហាញថា របៀបអនុវត្តច្បាប់ដោយនគរបាលបង្កផលប៉ះពាល់យ៉ាងខ្លាំងលើប្រសិទ្ធិភាពនៃច្បាប់ទាំងនោះ[393]។ដូច្នេះការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេតគួរត្រូវបានពិចារណា និងផ្សព្វផ្សាយជាមធ្យោបាយមួយនិងជាគោលដៅមួយក្នុងការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយមន្ត្រីនគរបាលទាំងអស់។ ការអនុវត្តវិធីសាស្ត្រផ្អែកតាមសិទ្ធិនិងគោលការណ៍ "មិនបង្កគ្រោះថ្នាក់" ក្នុងការជំរុញការចូលរួមរបស់ជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាវិធីជាក់លាក់មួយក្នុងការធានា

ការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេក្នុងការស៊ើបអង្កេត។

រូប ១ ៖ ដំណើរការនៃការផ្លាស់ប្តូរ




ការកសាងការយល់ដឹង និងការអប់រំអំពីដំណោះស្រាយសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួររំលេចពីសារៈសំខាន់នៃការប្តេជ្ញាអនុវត្តវិធីសាស្ត្រផ្អែកតាមសិទ្ធិសម្រាប់ការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេត។ ការផ្តល់សារច្បាស់លាស់ដោយមន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំប្រតិបត្តិក្នុងជួរនគរបាលពិតជាសំខាន់ណាស់សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល នៅពេលផ្តល់ការណែនាំដល់មន្ត្រីឆ្លើយតបឆ្ពោះទៅរកការអនុលោមតាមស្តង់ដារអន្តរជាតិ និងជានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការស៊ើបអង្កេត ក៏ដូចជាកាត់បន្ថយហានិភ័យនៃការអនុវត្តខុសឆ្គង ដូចជា ការចូលរួមក្នុងដំណើរការផ្សះផ្សារក្រៅផ្លូវការ។

ដោយសារតែការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះអាចបង្កផលប៉ះពាល់វិជ្ជមានលើការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ស្ថាប័ននគរបាលត្រូវខិតខំធានាគុណភាពនៃការស៊ើបអង្កេត ជាពិសេសនៅពេលមន្ត្រីឆ្លើយតបមិនអនុលោមតាមគោលនយោបាយ និងស្តង់ដារ។ ការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំនគរបាលចំពោះការរៀនសូត្រក្នុងស្ថាប័ន ក្នុងទម្រង់ជាការពិនិត្យឡើងវិញ ការវាយតម្លៃ និងការពិនិត្យតាមដានកិច្ចខិតខំប្រឹងប្រែងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី គឺជាទម្រង់មួយនៃគណនេយ្យភាពស្ថាប័នដែលនឹងជួយកាត់បន្ថយកំហុស ឬការអនុវត្តខុសឆ្គង និងកែលម្អឧបករណ៍ វិធីសាស្ត្រ និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់។

ការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលសម័យទំនើបដែលឆ្លើយតបនឹងយេនឌ័រ មិនអាចសម្រេចបានដោយគ្មានស្វ័យឆ្លុះបញ្ចាំងក្នុងស្ថាប័ន និងការរៀនសូត្របានឡើយ ជាពិសេសការរៀនសូត្រអំពីអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារវិធានការរបស់នគរបាល(សូមមើលរូប១)។

ស្ថាប័ននគរបាលសម័យទំនើប ត្រូវតែអាចពឹងផ្អែកលើថ្នាក់ដឹកនាំរបស់ខ្លួននៅកម្រិតផ្សេងៗដើម្បីជំរុញលើកទឹកចិត្តឱ្យមានការពិនិត្យការអនុវត្តការងារក្នុងស្ថាប័នដោយទទួលបានមតិយោបល់ពីសហគមន៍និងក្រុមចម្រុះ ជាពិសេសក្រុមដែលងាយរងគ្រោះ។

ដើម្បីសម្រេចគោលដៅនេះមន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំត្រូវកសាងការយល់ដឹង និងផ្តល់ការអប់រំអំពីថាតើការរៀនសូត្រតាមរយៈការពិនិត្យឡើងវិញលើការអនុវត្តការងារអាចផ្តល់ប្រយោជន៍ដល់ការអនុវត្តច្បាប់ដោយរបៀបណាជាពិសេសក្នុងករណីដែលពួកគេទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធខាងក្រៅ និងអ្នកពាក់ព័ន្ធដែលមានសមត្ថកិច្ច។ កិច្ចការនេះ ត្រូវតែមានការគូសបញ្ជាក់ពីសារៈសំខាន់នៃការកសាង និងការរក្សាភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធចម្រុះដែលមានសមត្ថភាពដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ មន្ត្រីជាន់ខ្ពស់ និងថ្នាក់ដឹកនាំប្រតិបត្តិគួរពិចារណាវិនិយោគលើការបណ្តុះបណ្តាល ឬការអភិវឌ្ឍវិជ្ជាជីវៈក្នុងការកសាងភាពជាដៃគូសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលដើម្បីជាកត្តាអំណោយផលដ៏សំខាន់មួយ។

391. “ការចូលរួមប្រកបដោយអត្ថន័យ” ទាមទារលក្ខខណ្ឌដែលបុគ្គលមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលបង្កផលប៉ះពាល់ផ្ទាល់លើពួកគេរួមទាំងការចូលរួមក្នុងការបង្កើត ការអនុវត្ត និងការពិនិត្យតាមដានអន្តរាគមន៍នានា។ ការចូលរួមនេះអាចមានទម្រង់ផ្សេងៗជាច្រើនដូចជា ការបង្ហាញដល់ជនរងគ្រោះនូវព័ត៌មានដែលមានតុល្យភាព និងសត្យានុម័ត ដើម្បីឱ្យពួកគេអាចគ្រប់គ្រងយ៉ាងល្អលើការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗដែលជះឥទ្ធិពលលើសុខុមាលភាពរបស់ពួកគេក៏ដូចជាការពិគ្រោះយោបល់ជាមួយពួកគេដើម្បីទទួលបានមតិយោបល់ស្តីពីដំណើរការធ្វើសេចក្តីសម្រេចចិត្តរួមទាំងការបង្កើតជម្រើសនិងការរិះរកដំណោះស្រាយ។

392. គួរកត់សម្គាល់ថា ក្នុងចំណោមស្ត្រី ៣ នាក់ មានម្នាក់ប្រឈមនឹងការរំលោភបំពានរាងកាយ និងផ្លូវភេទ។ ព័ត៌មានរបស់អង្គការសហប្រជាជាតិ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩។ https://news.un.org/en/story/2019/11/1052041

393. កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា, ២០១៥)

អ្នកពាក់ព័ន្ធសំដៅលើរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនិងស្ថាប័នទាំងអស់ដែលមានតួនាទីឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិតរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល។ អ្នកពាក់ព័ន្ធសំខាន់រួមមានជនរងគ្រោះ និងតំណាងសេវាសង្គម វិស័យថែទាំសុខភាព និងអ្នកផ្តល់ជំនួយផ្នែកច្បាប់ នគរបាល អយ្យការ ចៅក្រម ទីភ្នាក់ងារការពារកុមារ និងវិស័យអប់រំ។ល។

ពាក់ព័ន្ធនឹងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ថ្នាក់ដឹកនាំនគរបាលមានជម្រើសជាច្រើនក្នុងការជំរុញការរៀនសូត្រដោយទទួលបានមតិយោបល់ពីអ្នកពាក់ព័ន្ធដែលមានសមត្ថកិច្ច។ ជម្រើសអាចរួមមានការបង្កើតស្តង់ដារសេវានគរបាលដោយមានការពិនិត្យឡើងវិញម្តងម្កាលក្នុងស្ថាប័ន ដោយអង្គភាពស្តង់ដារសេវានគរបាល ដូចជាប្រព័ន្ធស្តង់ដារសេវានគរបាលដែលប្រើប្រាស់ដោយក្រសួងសុវត្ថិភាពសាធារណៈនិងអគ្គមេធាវីនៃរដ្ឋាភិបាលខេត្ត British Columbia ប្រទេសកាណាដា[394]។

១. នៅឆ្នាំ ២០២០ រដ្ឋាភិបាលខេត្ត British Columbia បានដាក់ចេញស្តង់ដារសេវានគរបាលសម្រាប់ការលើកកម្ពស់សេវានគរបាលដោយមិនលម្អៀង ដែលខិតខំកាត់បន្ថយហានិភ័យនៃការត្រួតពិនិត្យតាមដងផ្លូវបែបលម្អៀងដោយនគរបាល ដែលអង្គការសង្គមស៊ីវិលនៅមូលដ្ឋានលើកឡើងថា ផ្តោតតែលើជនជាតិដើម និងជនជាតិភាគតិចតាមរបៀបដែលគ្មានសមាមាត្រ[395]។

ជម្រើសផ្សេងទៀតរួមមានការកំណត់ស្តង់ដារ សម្រាប់ការពិនិត្យឡើងវិញម្តងម្កាលលើការអនុវត្តប្រតិបត្តិការដូចជាមធ្យោបាយសួរចម្លើយរបស់មន្ត្រីឆ្លើយតបភាពអាចអនុវត្តបាន និង/ឬប្រសិទ្ធភាពនៃឧបករណ៍វាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងយុទ្ធសាស្ត្រអន្តរាគមន៍ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត។

ការកសាងការយល់ដឹង និងការអប់រំសម្រាប់ការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ គួរពង្រឹងភាពជាបុរសវិជ្ជមានក្នុងសង្គម។ ដូច្នេះ នគរបាលត្រូវបានចាត់ទុកជាបុគ្គលគំរូសម្រាប់បុរសនិងក្មេងប្រុសដែលមានទំនុកចិត្ត មានភាពមាំមួន និងអាចទទួលយកបាននូវភាពចម្រុះគ្នា។ ភាពជាបុរសបែបវិជ្ជមានអាចពិពណ៌នាជាការ ការយកចិត្តទុកដាក់ មានសមានចិត្ត និងមានការគោរពដល់មនុស្សស្រីលើលក្ខណៈសម្បត្តិដ៏មានតម្លៃដែលមនុស្សគ្រប់រូបមាន។ ទន្ទឹមនឹងនេះ ការលើកកម្ពស់ភាពជាបុរសបែបវិជ្ជមានពាក់ព័ន្ធនឹងការមិនត្រាប់តាមគំនិតដែលយល់ថា បុរសមានចរិតឃ្លើនរឹងមាំ ឬត្រួតត្រាពីកំណើត។ ភាពជាបុរសវិជ្ជមានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណោះស្រាយកាត់បន្ថយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្នុងន័យនេះ UNPOL ផ្តល់ការអនុវត្តល្អមួយចំនួនសម្រាប់ជំរុញការចូលរួមរបស់មន្ត្រីជាបុរស[396]៖

- ការគូសបញ្ជាក់ពីអត្ថប្រយោជន៍នៃគោលនយោបាយសមភាពយេនឌ័រ និង គោលនយោបាយមេត្រីភាពគ្រួសារទាំងចំពោះបុរស និងស្ត្រី
- ការស្នើឱ្យមន្ត្រីនគរបាលប្រកាន់ខ្ជាប់យុត្តិធម៌
- ការផ្តល់អ្នកណែនាំនគរបាលជាស្ត្រីក្នុងជួរមន្ត្រី
- ការផ្សារភ្ជាប់នឹងមន្ត្រីបញ្ជាការដែលសម្រេចបានសមភាពយេនឌ័រ
- ការអញ្ជើញឱ្យមន្ត្រីចូលរួមកិច្ចពិភាក្សាដែលបែងចែកជាក្រុមនគរបាលជាបុរសនិងក្រុមនគរបាលទាំងពីរភេទ
- ការស្វែងរកជើងឯកសមភាពយេនឌ័រដែលអាចជាបុគ្គលគំរូសម្រាប់មន្ត្រីផ្សេងទៀត (សូមមើលប្រអប់ ៥)
- ការរៀបចំសិក្ខាសាលាបង្កើន និងកសាងការយល់ដឹង។

394. ច្បាប់ស្តីពីនគរបាលឆ្នាំ ១៩៩៦ អនុញ្ញាតឱ្យរដ្ឋាភិបាលថ្នាក់ខេត្តបង្កើតស្តង់ដារចងកាតព្វកិច្ចនគរបាល និងវាយតម្លៃការអនុលោមរបស់នគរបាលតាមស្តង់ដារទាំងនោះ។ សូមមើលស្តង់ដារសេវានគរបាលថ្នាក់ខេត្តរដ្ឋាភិបាលខេត្ត British Columbia ៖ https://www2.gov.bc.ca/gov/content/justice/criminal-justice/policing-in-bc/policing-standards
395. Foreword BCPPS 6.2 Police Stops. Provincial Policing Standards. Provincial Government of British Columbia at:https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminal-justice/police/standards/6-2-foreword-police-stops.pdf
396. ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL (នាយកដ្ឋានប្រតិបត្តិការសន្តិភាពនៃអង្គការសហប្រជាជាតិ DPO/DPET/សេវាបណ្តុះបណ្តាលចម្រុះ ២០១៥)

## ប្រអប់ ២ ៖ នគរបាលសម្រាប់ចលនា HeForShe

ចលនាសាមគ្គី HeForShe ដែលបង្កើតឡើងដោយ UN Women ផ្តល់វិធីសាស្ត្រជាប្រព័ន្ធ និងវេទិកាជាក់លាក់ដែលបុរស និងក្មេងប្រុសអាចចូលរួម និងក្លាយជាភ្នាក់ងារផ្លាស់ប្តូរឆ្ពោះទៅរកការសម្រេចបានសមភាពយេនឌ័រ។

HeForSheជាការអញ្ជើញឱ្យបុរសនិងមនុស្សគ្រប់យេនឌ័រសាមគ្គីជាមួយស្ត្រីដើម្បីបង្កើតកម្លាំងដ៏អង់អាច លេចធ្លោ និងពេញជាឆ្លង់មួយដើម្បីសមភាពយេនឌ័រ។ ចលនានេះផ្សព្វផ្សាយថា បុរសមិនគួរជាអ្នកអោបដៃឈរមើលបញ្ហាសិទ្ធិមនុស្ស ដូចជា សមភាពយេនឌ័រ នោះទេ។ សមាជិកនៃចលនានេះចាត់វិធានការបង្កើតការផ្លាស់ប្តូរប្រកបដោយអត្ថន័យក្នុងសហគមន៍ ឬប្រទេសរបស់ពួកគេ។

សមាជិករួមមានជើងឯកIMPACTដែលជាបុរសមានតួនាទីដឹកនាំជាន់ខ្ពស់ក្នុងប្រទេសនិងកំណត់យកសមភាពយេនឌ័រជាអាទិភាពក្នុងស្ថាប័នតាមរយៈការអនុវត្តការប្តេជ្ញាចិត្តសំខាន់ៗ៣ក្នុងការពង្រឹងនិងសម្រេចបានសមភាពយេនឌ័រ។ ពួកគេជាថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងជួរនគរបាលជាន់ខ្ពស់ ដូចជា ទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិ Luis Carrilho (សូមមើលរូបថត)។

ក្នុងនាមជាអ្នកតស៊ូមតិឱ្យចលនា HeForShe លោក Carrilho ប្តេជ្ញាពង្រឹងកិច្ច សហការលើសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ រវាងស្ថាប័នអង្គការសហប្រជាជាតិ ដើម្បីធានាថា ស្ត្រី និងក្មេងស្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាជាពិសេសស្ត្រីនិងក្មេងស្រីដែលជួបការលំបាកបំផុតអាចទទួលបានកងកម្លាំងនគរបាលដែលមានគុណភាពខ្ពស់ និងការឆ្លើយតបផ្នែកយុត្តិធម៌ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់អង្គការសហប្រជាជាតិ។

"ការមាននគរបាលជាស្ត្រីកាន់តែច្រើនក្នុងកិច្ចការរក្សាសន្តិភាព ធ្វើឱ្យការរក្សាសន្តិភាពកាន់តែមានប្រសិទ្ធភាព។តាងនាមឱ្យមន្ត្រីនគរបាលចំនួន១១.០០០នាក់ដែលជេកក្រោម ទង់ជាតិអង្គការសហប្រជាជាតិ ខ្ញុំមានមោទនភាពណាស់ដែលបានធ្វើជាអ្នកតស៊ូមតិឱ្យចលនា HeForShe" ... "ដោយទទួលបានកិត្តិយសដ៏ធំធេងនេះ ខ្ញុំមានតួនាទីយ៉ាងច្រើនក្នុងការពង្រឹងការប្តេជ្ញាចិត្តរបស់យើងក្នុងការបង្កើនភាពអាចជឿទុកចិត្តបានរបស់អង្គការសហប្រជាជាតិនៅតាមបណ្តាប្រទេសដែលយើងធ្វើប្រតិបត្តិការ និងបង្កផលប៉ះពាល់វិជ្ជមានកាន់តែខ្លាំងលើជីវិតរស់នៅរបស់ប្រជាជន ក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត"។



ប្រភព ៖ សេចក្តីប្រកាសព័ត៌មាន ៖ UN Women ប្រកាសថា លោក Luis Carrilho ទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិ ជាអ្នកតស៊ូមតិឱ្យចលនា HeForShe ដើម្បីសមភាaaពយេនឌ័រ។ HeForShe

ដើម្បីជួយឱ្យមន្ត្រីឆ្លើយតបមានឥរិយាបថឆ្លើយតបនឹងយេនឌ័រ ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងជួរនគរបាលគួរធានាថា អ្នកគ្រប់គ្រងថ្នាក់កណ្តាលអាចពឹងផ្អែកលើការយល់ដឹងក្នុងស្ថាប័នអំពីចំណុចខាងក្រោម ៖

- ឫសគល់នៃអំពើហិង្សា និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។
- សារៈសំខាន់ផ្នែកប្រតិបត្តិការនៃវិធីសាស្ត្រផ្អែកតាមសិទ្ធិក្នុងការធានាការចូលរួម ប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- សារៈសំខាន់ផ្នែកប្រតិបត្តិការនៃទស្សនាទាន"មិនបង្កគ្រោះថ្នាក់"។
- ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ដើម្បីបញ្ជាក់អះអាងនិងជួយកសាងទំនុកចិត្តនិងភាពជឿជាក់លើនគរបាលក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាចំណុចអាទិភាព។

- សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទាមទារឱ្យថ្នាក់ដឹកនាំនគរបាល លើកកម្ពស់គោលការណ៍ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះក្នុងស្ថាប័នដោយធានាថាយ៉ាងហោចណាស់មានការបណ្តុះបណ្តាលដល់មន្ត្រីគ្រប់រូប។
- សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទាមទារឱ្យមានស្វ័យឆ្លុះបញ្ចាំងនិងការរៀនសូត្រជាប់ជាប្រចាំមានតម្លាភាពនិងផ្អែកតាមការពិគ្រោះយោបល់ទូលំទូលាយ។
- នៅពេលនគរបាលអនុលោមតាមស្តង់ដារនិងបទដ្ឋានអន្តរជាតិ នឹងមានការសន្មតថា នគរបាលជាអ្នកផ្តល់សេវាសំខាន់ដែលស្របច្បាប់ និងគួរឱ្យជឿទុកចិត្ត។

## ការកសាងការយល់ដឹងនៅក្រៅស្ថាប័ន

នគរបាលដែលខិតខំផ្លាស់ប្តូរស្ថាប័នឱ្យឆ្លើយតបនឹងយេនឌ័រត្រូវប្តេជ្ញាអនុវត្តដំណើរការជំរុញការចូលរួមពីខាងក្រៅដែលមានតម្លាភាពនិងបរិយាបន្ន។ការផ្តល់សារខាងក្រៅដល់សហគមន៍ដែលតំណាងឱ្យក្រុមប្រជាជនចម្រុះក្នុងមូលដ្ឋាន មានសារៈសំខាន់ដូចការផ្តល់សារក្នុងស្ថាប័នដែរ។ មិនថាថ្នាក់ដឹកនាំនគរបាលផ្សព្វផ្សាយដោយផ្ទាល់មាត់ តាមប្រព័ន្ធឌីជីថល ឬតាមរូបភាព ឬយ៉ាងណានោះទេ ភាពជាតំណាងរបស់នគរបាលក្នុងទំនាក់ទំនងផ្លូវការ ដូចជា យុទ្ធនាការជ្រើសរើសនគរបាល គួររំលេចនូវទស្សនៈវិស័យផ្លាស់ប្តូរ និងជំហានដែលនគរបាលកំពុងអនុវត្តដើម្បីទទួលខុសត្រូវលើបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

> **ការយល់ និង "ការទទួលខុសត្រូវ" លើបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានន័យថា អ្នក និងក្រុមរបស់អ្នកបានកត់សម្គាល់ និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុត។ ដូច្នេះ អ្នកប្តេជ្ញាធ្វើជាផ្នែកមួយនៃដំណោះស្រាយ និងការផ្លាស់ប្តូរទៅរកភាពល្អប្រសើរ។**

ការផ្សព្វផ្សាយក្រៅស្ថាប័នដោយថ្នាក់ដឹកនាំនគរបាលស្តីពីដំណើរការផ្លាស់ប្តូរ ត្រូវបង្ហាញពីការប្តេជ្ញាចិត្តសម្រេចឱ្យបានតម្លាភាព។ចំណុចនេះអាចរួមមានការបង្ហោះតាមប្រព័ន្ធអ៊ីនធឺណិតនូវការពិនិត្យឡើងវិញក្នុងស្ថាប័នលើគោលនយោបាយ យុទ្ធសាស្ត្រ វិធីសាស្ត្រ និងឧបករណ៍



រូបថតទទួលបានពីសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (ប្រទេសបង់ក្លាដេស)

របស់នគរបាលសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ការពិនិត្យឡើងវិញទាំងនេះប្រាកដជារំលេចនូវចំណុចខ្វះខាតសមត្ថភាព ប៉ុន្តែគួរលម្អិតពីការរៀនសូត្រ និងគន្លឹះឆ្ពោះទៅមុខ។ ចំណុចនេះនឹងពង្រឹងភាពស្របច្បាប់នៃការប្តេជ្ញាចិត្តរបស់នគរបាលចំពោះការផ្លាស់ប្តូរ ដែលនឹងជួយបំផុសកិច្ចសហការពីសំណាក់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាសហគមន៍របស់ពួកគេ។

ជាទូទៅ ការកសាងការយល់ដឹង (ក្នុង ឬក្រៅស្ថាប័ន) គួរលើកកម្ពស់សមភាពយេនឌ័រដែលជាដំណោះស្រាយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងឫសគល់ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ មានន័យថា ថ្នាក់ដឹកនាំនគរបាលត្រូវបន្តពង្រឹងសារនេះក្នុងជួរនគរបាល ៖ តម្រូវការ និងផលប្រយោជន៍របស់សហគមន៍ទាំងអស់ជាចំណុចស្នូលនៃសេវានគរបាលសម័យទំនើប។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការផ្សព្វផ្សាយក្រៅស្ថាប័នដែលបន្ស៊ីគ្នានឹងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ សូមមើលជំពូកទី ៩ (ទំនាក់ទំនង)។

## គោលនយោបាយ និងយុទ្ធសាស្ត្រជំរុញសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

អ្នកគ្រប់គ្រងថ្នាក់កណ្ដាល ដើរតួនាទីសំខាន់ក្នុងដំណើរការផ្លាស់ប្ដូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រប៉ុន្តែមន្ត្រីជាន់ខ្ពស់និងថ្នាក់ដឹកនាំប្រតិបត្តិការក្នុងជួរនគរបាលត្រូវផ្ដល់បរិយាកាសអំណោយផលសមស្របដល់ពួកគេក្នុងការទទួលខុសត្រូវចំពោះបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ បរិយាកាសអំណោយផលរួមមានគោលនយោបាយ និងយុទ្ធសាស្ត្រស្ថាប័នដែលជាគោលការណ៍ ផ្អែកតាមបទដ្ឋាន មានធនធានគ្រប់គ្រាន់ និងរួមបញ្ចូលយន្តការរក្សាការទទួលខុសត្រូវរបស់ប្រជាជន។

"គោលនយោបាយ និងនីតិវិធីប្រតិបត្តិស្តង់ដារមិនមែនគ្រាន់តែជា "ទ្រឹស្តី" នោះទេ ប៉ុន្តែត្រូវតែយកទៅអនុវត្ត ដើម្បីសម្រេចគោលបំណង។ អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល/ថ្នាក់ដឹកនាំនគរបាលមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការអនុវត្តការប្រតិបត្តិនិងការសម្រេចបានគោលនយោបាយទាំងនេះ"។

Gerry Campbell MBE FCMI AFHEA-ប្រធានផ្នែកស៊ើបអង្កេត (ចូលនិវត្តន៍) Scotland Yard

មន្ត្រីគ្រប់រូបគួរគោរពគោលនយោបាយផ្អែកតាមបទដ្ឋានដែលបានបង្កើតឡើង ទុកជាគោលការណ៍ និងគួរមានពិធីសារ ឬនីតិវិធីប្រតិបត្តិស្តង់ដារភ្ជាប់មកជាមួយនឹងគោលនយោបាយទាំងនោះ រួមទាំងគោលនយោបាយសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រដែរ។

យោងតាម UNPOL គោលនយោបាយ និងនីតិវិធីប្រតិបត្តិស្តង់ដារស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានសារៈសំខាន់ណាស់ ព្រោះឯកសារណែនាំទាំងនេះរៀបរាប់ពីបញ្ហាដែលមានសារៈសំខាន់ចំពោះស្ថាប័ននគរបាល និងច្បាមយកការយល់ដឹងផ្ទត់គំនិតនិងការយល់ឃើញរបស់បុគ្គលស្តីពីបញ្ហាទាំងនេះដោយគាំទ្រដល់ស្តង់ដារស្ថាប័ន។ ឯកសារទាំងនេះក៏បានផ្តល់គណនេយ្យភាពសម្រាប់មន្ត្រីពាក់ព័ន្ធ និងថ្នាក់លើរបស់ពួកគេផងដែរ[397]។

ការវិនិយោគលើការបង្កើតពិធីសារស្តង់ដារសេវានគរបាល ឬនីតិវិធីប្រតិបត្តិស្តង់ដារផ្អែកតាមព័ត៌មានត្រឹមត្រូវ នឹងអាចឱ្យមន្ត្រីឆ្លើយតបយល់ពីការទទួលខុសត្រូវរបស់ខ្លួន និងផ្តល់ជំហានសំខាន់ៗសម្រាប់ការអនុវត្តអភិក្រមប្រទាក់ក្រឡាគ្នានិងផ្អែកតាមសិទ្ធិក្នុងការស៊ើបអង្កេតដោយធានាថា គ្មានការយល់ដឹងខុសគ្នាលើជំហានទាំងនេះ។

សូមមើលឧបសម្ព័ន្ធ ២ នៃជំពូកទី ៥ (ការស៊ើបអង្កេត) និងជំពូកទី ១២ (ការបន្តផ្តល់យុត្តិធម៌) សម្រាប់ការអនុវត្តល្អក្នុងពិធីសាររបស់នគរបាលសម្រាប់ការសហការជាមួយស្ថាប័នផ្សេងទៀតលើការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

"ក្នុងករណីដែលមន្ត្រីអាចអនុវត្តបានល្អជាងស្តង់ដារទាំងនេះ គួរផ្តល់រង្វាន់លើកទឹកចិត្តដល់ពួកគេ ហើយប្រសិនបើពួកគេអនុវត្តមិនបានពេញលេញ ពួកគេត្រូវទទួលខុសត្រូវ និងប្រឈមនឹងវិធានការវិន័យ (ប្រសិនបើសមស្រប)។ លុះត្រាតែមានថ្នាក់ដឹកនាំតឹងរ៉ឹងដែលរក្សាការទទួលខុសត្រូវរបស់មន្ត្រី និងបុគ្គលិក ទើបយើងអាចសម្រេចបាននូវវឌ្ឍនភាពសម្រាប់សាធារណជន"។

ឯកសារជំនួយស្មារតីរបស់អ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌ (UN Women et al., 2018)

ការដាក់ចេញគោលនយោបាយនិងពិធីសារពាក់ព័ន្ធថ្មីៗ ឬនីតិវិធីប្រតិបត្តិស្តង់ដារទាមទារការកែសម្រួលសារដែលផ្សព្វផ្សាយដល់មន្ត្រីគ្រប់ជាន់ថ្នាក់។ ថ្នាក់ដឹកនាំនគរបាលមិនគួរពឹងផ្អែកទាំងស្រុងលើការបណ្តុះបណ្តាលដើម្បីធានាការយល់ដឹងអំពីគោលនយោបាយផ្អែកតាមបទដ្ឋាន និងក្រមប្រតិបត្តិទាំងនោះឡើយ។ ភស្តុតាងបង្ហាញថា បុគ្គលគំរូនិង/ឬអ្នកមានតួនាទីណែនាំផ្តល់ផលប៉ះពាល់ធំធេងលើឥរិយាបថរបស់មន្ត្រីនគរបាលផ្សេងទៀតនិងអ្នកក្រោមបង្គាប់ជាងការបណ្តុះបណ្តាលជាក់ស្តែងជាពិសេសប្រសិនបើការបណ្តុះបណ្តាលនោះ ផ្តោតសំខាន់លើការផ្លាស់ប្តូរឥរិយាបថ[398]។

397. ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព សេចក្តីសង្ខេបឧបករណ៍គម្រោង (២០១៥)។

ឱ. នៅពេលបំពាក់បំប៉នវប្បធម៌ "មិនអត់អោន"ក្នុងស្ថាប័នដែលពាក់ព័ន្ធនឹងការរើសអើងផ្អែកលើយេនឌ័រ និងការរើសអើងផ្លូវភេទ ការបៀតបៀន ការរករឿងរ៉ៅខាន និងការរំលោភបំពានក្នុងស្ថាប័ននគរបាលថ្នាក់ដឹកនាំនគរបាលត្រូវអំពាវនាវឱ្យផ្តោតការយកចិត្តទុកដាក់លើឥរិយាបថទាំងនោះ នៅពេលមានការរាយការណ៍ និងការមើលឃើញជាក់ស្តែង និងត្រូវដំណើរការការគ្រប់គ្រងផ្ទៃក្នុង និងស្ថាប័នត្រួតពិនិត្យឱ្យបានឆាប់រហ័សនិងប្រកបដោយតម្លាភាព និងធានានូវបរិយាកាសអំណោយផលដែលមានសុវត្ថិភាព និងរក្សាការសម្ងាត់សម្រាប់សាក្សី និង/ឬដើមបណ្តឹង។ ឥរិយាបថរបស់ថ្នាក់ដឹកនាំនគរបាលដូចការលើកឡើងខាងលើ ផ្តល់ភាពសមស្របច្បាប់យ៉ាងសំខាន់ និងចាំបាច់ដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងការបង្កើត បង្កើនសិទ្ធិអំណាច និងផ្តល់រង្វាន់លើកទឹកចិត្តដល់សមត្ថភាពចាំបាច់ក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងកុមារ។




Human Rights Watch បានផ្តល់ការណែនាំល្អៗសម្រាប់អនុវត្តវិធានការសុវត្ថិភាពក្នុងស្ថាប័នប្រឆាំងនឹងការបៀតបៀនផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាក្នុងកន្លែងធ្វើការ។ ឯកសាររបស់ Human Rights Watch ដែលមានចំណងជើងថា "សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរនៅកន្លែងធ្វើការ ៖ មគ្គុទេសក៏សម្រាប់អនុសញ្ញាលេខ ១៩០ (២០១៩) របស់ ILO ស្តីពីអំពើហិង្សា និងការបៀតបៀន"[399] ផ្តល់និយមន័យ និងវិធានការច្បាស់លាស់រួមទាំងយន្តការបណ្តឹង និងការពិនិត្យតាមដាន ដែលស្ថាប័នសាធារណៈ ដូចជា ស្ថាប័ននគរបាលអាចយកទៅអនុវត្តក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សានេះ[400]។

ជារួមគោលនយោបាយផ្អែកតាមបទដ្ឋានគួរបង្កើតអនុវត្ត និង/ឬពង្រឹងចំណុចខាងក្រោម[401]៖

**ពិធីសារ**

- នីតិវិធីប្រតិបត្តិស្តង់ដារ និងក្រមប្រតិបត្តិច្បាស់លាស់ដែលឆ្លុះបញ្ចាំងពីគោលនយោបាយរបស់ស្ថាប័នសម្រាប់បុគ្គលិកដែលជាជនរងគ្រោះ ឬជាជនបង្កអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ វិធានការទាំងនេះជាផ្នែកដ៏សំខាន់មួយនៃការទទួលខុសត្រូវលើបញ្ហានេះ និងការពិចារណាហ្មត់ចត់លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រោះវិធានការទាំងនោះគាំទ្រដល់បុគ្គលិកកំណត់ស្តង់ដារ និងជួយរក្សាការទទួលខុសត្រូវរបស់ស្ថាប័ន[402]។
- ការកំណត់ស្តង់ដារនគរបាលឱ្យបន្សុីគ្នានឹងក្របខណ្ឌវាយតម្លៃម្តងម្កាលលើភាពអនុលោមតាម។
- ប្រព័ន្ធពិនិត្យតាមដានដែលវាស់វែងការអនុវត្តពិធីសារ/នីតិវិធីប្រតិបត្តិស្តង់ដារជាប្រចាំ ដោយមានធាតុចូលពីស្ថាប័នជំនាញដើម្បីធានាថាពិធីសារ/នីតិវិធីប្រតិបត្តិស្តង់ដារទាំងនោះមានលក្ខណៈបរិយាបន្ន(ដូចជាស្ថាប័នដែលតំណាងឱ្យតម្រូវការរបស់ជនមានពិការភាព)។
- ពិធីសារ និងគោលការណ៍ណែនាំគ្រប់ជ្រុងជ្រោយដែលលើកកម្ពស់អភិក្រមឆ្លើយតបនឹងយេនឌ័រដែល

---

398. សូមមើល Jenni Cross, '3 Myths of Behaviour Change and Other Challenges for Sustainability' (2014), Center for Energy and Behavior Institute for the Built Environment, Colorado State University and; Bohent, I, 'What Works: Gender Equality by Design' (Harvard University Press, 2016)។ សូមមើលផងដែរផ្នែកស្តីពី 'ទ្រឹស្តីចិត្តវិទ្យា និងសង្គមវិទ្យា ក្នុង Flanagan', A.E., and Tanner, J.C., 'A Framework for Evaluating Behavior Change in International Development Operations', Independent Evaluation Group Working Paper 2016/No.2 (World Bank, 2018)។
399. នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ សមាជិកនៃអង្គការអន្តរជាតិខាងការងារ (ILO) រួមមានរដ្ឋាភិបាលសហជីពនិងសមាគមនិយោជកបានបោះឆ្នោតយ៉ាងច្រើនលើសលប់ឱ្យមានការអនុម័តអនុសញ្ញារបស់ ILO ស្តីពីអំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ (អនុសញ្ញាលេខ ១៩០ ស្តីពីអំពើហិង្សា និងការបៀតបៀន)។
400. សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរនៅកន្លែងធ្វើការ ៖ មគ្គុទេសក៏នៃអនុសញ្ញាលេខ ១៩០ របស់ ILO ស្តីពីអំពើហិង្សា និងការបៀតបៀន ២០១៩ (Human Right Watch ២០២០) https://www.hrw.org/sites/default/files/media_2020/06/ILO_advocacy_brochure_0620.pdf
401. "ការកាត់ទោសករណីរំលោភសេពសន្ថវៈ ៖ ការស្វែងយល់ពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាផ្លូវភេទនៅប្រទេសថៃ និងវៀតណាម (UNWomen, UNDP and UNODC, 2017)។
402. ឱ.សេវានគរបាលក្រុងឡុងដ៍(MPS)ដែលជាកងកម្លាំងនគរបាលដែនដីទទួលខុសត្រូវលើការអនុវត្តច្បាប់ក្នុង Metropolitan Police District នៃទីក្រុងឡុងដ៍ ផ្តល់បញ្ជីត្រួតពិនិត្យតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់វិធានការជាកាតព្វកិច្ចនៅពេលដែលមន្ត្រីឬបុគ្គលិកត្រូវបានសង្ស័យថាបានប្រព្រឹត្តការរំលោភបំពានក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ ឬបទល្មើសផ្លូវភេទធ្ងន់ធ្ងរផ្សេងទៀត ៖ https://www.met.police.uk/SysSiteAssets/foi-media/metropolitan-police/policies/strategy--governance---mps-employee-domestic-abuse-policy

ស៊ីសង្វាក់គ្នានិងមានឯកសណ្ឋានភាពក្នុងការគ្រប់គ្រង និងស៊ើបអង្កេតឧប្បត្តិហេតុអំពើហិង្សាផ្លូវភេទ។ ចំណុចនេះគួររួមបញ្ចូលការណែនាំដែលតម្រូវឱ្យមន្ត្រីនគរបាលពន្យល់ដល់ជនរងគ្រោះអំពីដំណើរការយុត្តិធម៌ សិទ្ធិរបស់គាត់ និងសេវាដែលមាន[403]។ ល្អបំផុត ពិធីសារគួរគូសបញ្ជាក់ថា ស្ត្រីគួរតែអាចជ្រើសរើសមន្ត្រីនគរបាល (ស្រី/ប្រុស) ដែលពួកគេត្រូវរាយការណ៍ជូន/ធ្វើការជាមួយ។

- កិច្ចព្រមព្រៀងការងាររួមនៅកម្រិតយុទ្ធសាស្ត្រជាមួយអយ្យការ និងស្ថាប័នផ្សេងទៀត ដូចជា អ្នកផ្ដល់សេវា (ឧ. សង្គម សុខភាព អប់រំ។ល។)។

## ការលើកទឹកចិត្តផ្នែកវិជ្ជាជីវៈ

- ភាពជោគជ័យរបស់ក្រុមគួរកំណត់ចេញពីកិច្ចខិតខំប្រឹងប្រែងរួម ឆ្ពោះទៅរកការកាត់បន្ថយប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលពាក់ព័ន្ធនឹងការកើនឡើងនៃការរាយការណ៍ទៅនគរបាល។ ថ្នាក់ដឹកនាំនគរបាលមិនគួរកំណត់ចំណុចដៅនៃការកាត់បន្ថយបទល្មើសអំពើហិង្សាលើស្ត្រី និងកុមារដែលបានកត់ត្រានោះទេព្រោះស្ថាប័ននគរបាលជាច្រើនទទួលស្គាល់ថាការរាយការណ៍ពីចំនួនករណីទាំងនោះគឺទាបជាងចំនួនករណីពិតប្រាកដ[404]។



លោក Altin Qato (ប្រធានផ្នែកសន្តិសុខសាធារណៈ) និងលោក Haki Cako (ស្នងការនគរបាលរដ្ឋអាល់បានី) ជាបុគ្គលគំរូនៃចលនា HeForShe។ រូបថតទទួលបានពី UN Women ប្រចាំនៅអាល់បានី/Besnik Baka

- លើកទឹកចិត្តក្នុងការទទួលស្គាល់វិជ្ជាជីវៈដល់មន្ត្រីនគរបាលដែលមានសមត្ថភាពឆ្លើយតបនឹងយេនឌ័រក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ការបង្កើតការលើកទឹកចិត្ត និងឱកាសសម្រាប់ការអភិវឌ្ឍអាជីព នឹងបង្កើនការប្ដេជ្ញាចិត្តរបស់មន្ត្រីនគរបាលទាំងពីរភេទឆ្ពោះទៅរកការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងការចូលរួមប្រកបដោយអត្ថន័យពីជនរងគ្រោះក្នុងការស៊ើបអង្កេត។ គ្រឿងលើកទឹកចិត្តទាំងនេះនឹងពង្រឹងសមភាពយេនឌ័រនិងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

- អ្នកគ្រប់គ្រងថ្នាក់កណ្ដាលរហូតដល់មន្ត្រីជាន់ខ្ពស់ ត្រូវចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការសាធារណៈដែលលើកឡើងពីបទដ្ឋានយេនឌ័រ/សង្គម និងផ្នត់គំនិត ដូចជាយុទ្ធនាការ HeForShe។



នៅឆ្នាំ ២០២០ នគរបាលចក្រភពអង់គ្លេសបានសហការបោះពុម្ពផ្សាយរបាយការណ៍ដំបូងរបស់ខ្លួនដែលមានចំណងជើងថា "សមភាពយេនឌ័រក្នុងរបាយការណ៍ប្រចាំឆ្នាំទីមួយស្ដីពីសេវានគរបាលចក្រភពអង់គ្លេស" ដែលជាផ្នែកមួយនៃយុទ្ធនាការ HeForShe នៅថ្នាក់ជាតិ។ របាយការណ៍នេះគូសបញ្ជាក់ពីការប្ដេជ្ញាចិត្ត និងវឌ្ឍនភាពសំខាន់ៗរបស់នគរបាលចក្រភពអង់គ្លេសគ្រប់ជាន់ថ្នាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័ននគរបាលរបស់ខ្លួនរួមទាំងតួនាទីសម្រេចចិត្តរបស់មន្ត្រីជាន់ខ្ពស់ភាគច្រើនដែលជាបុរសនៅពេលប្ដេជ្ញាដោះស្រាយវិសមភាពយេនឌ័រដែលជាបញ្ហាគន្លឹះក្នុងសេវានគរបាល[405]។

- លើកទឹកចិត្តដល់អ្នកគ្រប់គ្រងថ្នាក់កណ្ដាលជាពិសេសនៅកម្រិតប៉ុស្តិ៍នគរបាល ដើម្បីបង្កើតគំនិតផ្ដួចផ្ដើម/ភាពជាដៃគូជាមួយស្ថាប័នផ្សេងទៀត សហគមន៍ ក៏ដូចជាគំនិតផ្ដួចផ្ដើមសាធារណៈ និង/ឬឯកជន ដូចជាសកម្មភាពសប្បុរសធម៌ដែលគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

403. "នគរបាលក្នុងនាមជាចំណុចផ្ដើមនៃការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ មេរៀនពីអង្គការសង្គមស៊ីវិល ក្រោមជំនួយពីមូលនិធិ Trust Fund របស់អង្គការសហប្រជាជាតិដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី។ មូលនិធិ Trust Fund របស់អង្គការ-សហប្រជាជាតិដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី ទីក្រុងញូវយ៉ក ឆ្នាំ ២០១៩។

404. សូមមើល "កិច្ចការរបស់មនុស្សគ្រប់រូប ៖ ការបង្កើនការឆ្លើយតបរបស់នគរបាលទៅនឹងការបៀតបៀនក្នុងគ្រួសារ" (អធិការដ្ឋាននៃនគរបាលមហាក្សត្រី២០១៤) សម្រាប់បទពិសោធន៍របស់ស្ថាប័ននគរបាលចក្រភពអង់គ្លេសដែលមិនកំណត់ចំណុចដៅនៃការកាត់បន្ថយបទល្មើសអំពើហិង្សាក្នុងគ្រួសារដែលបានកត់ត្រា។

405. សមភាពយេនឌ័រក្នុងរបាយការណ៍ប្រចាំឆ្នាំទីមួយស្ដីពីសេវានគរបាលចក្រភពអង់គ្លេស(២០២០) ការផ្សព្វផ្សាយផ្នែកសាជីវកម្មរបស់នគរបាល Sussex ២០១៩ ដើម្បីគាំទ្រចលនាសាមគ្គីដើម្បីសមភាពយេនឌ័រ HeForShe របស់ UN Women https://www.sussex.police.uk/SysSiteAssets/media/downloads/sussex/about-us/governance-and-processes/equality-anddiversity/heforshe-annual-report-2019.pdf



Fred Yiga ស្នងការនគរបាល UNMISS ចូលរួមក្នុងយុទ្ធនាការ HeForShe។
រូបថត ៖ UNMISS (ប្រទេសស៊ូដង់)

- បង្កើនស្ថានភាពរបស់ភ្នាក់ងារឆ្លើយតបបឋមដើម្បីឱ្យពួកគេយល់ពីតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការកសាងទំនុកចិត្ត និងភាពជឿជាក់របស់សហគមន៍មូលដ្ឋានលើនគរបាល។

### អង្គភាពឯកទេស

- អង្គភាពឯកទេសដែលមានសមាសធាតុអ្នកជំនាញពហុវិស័យ ដូចជាអ្នកជំនាញកោសលវិច័យ បុគ្គលិកថែទាំសុខភាព បុគ្គលិកសង្គមកិច្ច ទីប្រឹក្សា។ល។ ក្នុងប្រទេសមួយចំនួន ដូចជា ឥណ្ឌា និងតង់ហ្សានី អង្គភាពនគរបាលពិសេសដឹកនាំដោយស្ត្រីនិងអាចមានសមាសភាពស្ត្រី ១០០%។ អង្គភាពពិសេសនេះ មានតួនាទីជួយកសាងទំនុកចិត្តរបស់សហគមន៍ក្នុងការរាយការណ៍ករណីនានា។ ឧ. "She Teams" ដែលត្រូវបានបង្កើតឡើងនៅ Hyderabad ប្រទេសឥណ្ឌា មានតួនាទីដោះស្រាយការចំអក និងការបៀតបៀនក្នុងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- មន្ត្រីឆ្លើយតបដែលទទួលការបណ្តុះបណ្តាលឯកទេសដើម្បីចូលរួមក្នុង "មជ្ឈមណ្ឌលផ្តល់សេវាចម្រុះ" ដូចជាមជ្ឈមណ្ឌល Sunflower នៅប្រទេសកូរ៉េ (សូមមើលប្រអប់ ៩) មជ្ឈមណ្ឌលគាំពារជនរងគ្រោះក្នុងប្រទេសបង់ក្លាដេស ឬមជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសក្នុងប្រទេសប៊ុលហ្គារី (សូមមើលករណីសិក្សាក្នុងជំពូកទី ៧ ៖ "ការគាំទ្រ និងជំនួយ")[406]។
- អង្គភាពការពារពិសេស និងផ្នែកយេនឌ័រក្នុងប៉ុស្តិ៍នគរបាលដែលមានតួនាទីធានាថា នីតិវិធីដែលគិតគូរពីយេនឌ័រ ជួយបញ្ចៀសការរងគ្រោះលើកទីពីរ និងការមាក់ងាយ។
- ក្រុមចម្រុះដែលទទួលខុសត្រូវលើការរាយការណ៍ពីចំណុចបញ្ជូនករណីផ្សេងៗ ក្នុងរយៈពេល ២៤ម៉ោង/ថ្ងៃ ៣៦៥ ថ្ងៃ/ឆ្នាំ ដូចជា តាមប្រព័ន្ធអ៊ីនធឺណិត សារខ្លីៗ ខ្សែទូរស័ព្ទជំនួយ ដើម្បីផ្តល់ភាពងាយស្រួល និងការរក្សាការសម្ងាត់ប្រសើរជាងមុន។

**ប្រអប់ ៣ ៖**

**មជ្ឈមណ្ឌលផ្តល់សេវាចម្រុះ Sunflower ប្រទេសកូរ៉េ**

មជ្ឈមណ្ឌល Sunflower ត្រូវបានបង្កើតឡើងជាលើកដំបូងនៅឆ្នាំ ២០០៤។ នៅឆ្នាំ ២០១៩ មានមជ្ឈមណ្ឌល Sunflower ចំនួន ៣៩ នៅទូទាំងប្រទេស។ នេះជាមជ្ឈមណ្ឌលផ្តល់សេវាចម្រុះក្នុងមន្ទីរពេទ្យ សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រ ការប្រឹក្សាយោបល់ ការស៊ើបអង្កេត និងជំនួយផ្លូវច្បាប់ក្នុងទីតាំងតែមួយ។

មជ្ឈមណ្ឌល Sunflower ផ្តល់សេវាចម្រុះតាមរយៈភាពជាដៃគូផ្លូវការជាមួយក្រសួងសមភាពយេនឌ័រ និងគ្រួសារ រដ្ឋាភិបាលមូលដ្ឋាន នគរបាល និងមន្ទីរពេទ្យ។

ពាក់ព័ន្ធនឹងការគាំទ្ររបស់នគរបាល មន្ត្រីនគរបាលជាស្ត្រីដែលទទួលការបណ្តុះបណ្តាលឯកទេសស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ និងបច្ចេកទេសសួរចម្លើយជនរងគ្រោះ បានចូលរួម និងត្រូវបានដាក់ពង្រាយក្នុងមជ្ឈមណ្ឌលនេះ រយៈពេល ២៤ ម៉ោង/ថ្ងៃ និង ៧ ថ្ងៃ/សប្តាហ៍។

មន្ត្រីនគរបាលទាំងនោះមានតួនាទីសួរចម្លើយជនរងគ្រោះ ក្នុងបរិយាកាសដែលផ្តល់ភាពកក់ក្តៅដល់ពួកគេ។ លទ្ធផលនៃការសួរចម្លើយ (ឧ. របាយការណ៍ដែលត្រូវបានផ្ទៀងផ្ទាត់) បូករួមនឹងភស្តុតាងកោសលវិច័យដែល

406. សម្រាប់ឧទាហរណ៍បន្ថែមទៀតពីមជ្ឈមណ្ឌលផ្តល់សេវាចម្រុះ សូមមើល South Africa (Thuthuzela Care Centres) and of Women's police station (Delegacias Especiais de Atendimento à Mulher – DEAM) in Brazil, in Progress of the World's Women 2011–2012: Families in a Changing World (UN Women, 2011).

ប្រមូលដោយក្រុមវេជ្ជសាស្ត្រ ត្រូវបានបញ្ជូនទៅប៉ុស្តិ៍នគរបាលសម្រាប់ធ្វើការស៊ើបអង្កេតបន្ថែម។ មជ្ឈមណ្ឌល Sunflower ក៏ផ្តល់ការគាំទ្រឯកទេសដល់កុមារ និងជនមានពិការភាពផងដែរ។ មជ្ឈមណ្ឌលនេះតម្រូវឱ្យមានការថតវីដេអូជនរងគ្រោះដែលមានអាយុក្រោម ១៩ ឆ្នាំ ដើម្បីបង្ការកុំឱ្យជនរងគ្រោះ ត្រូវផ្តល់សក្ខីកម្មដដែលៗ។

ចំណុចសំខាន់ៗដែលត្រូវចងចាំពីបទពិសោធន៍របស់មជ្ឈមណ្ឌល Sunflower ក្នុងប្រទេសកូរ៉េ ៖

- ការសម្របសម្រួល និងកិច្ចព្រមព្រៀងផ្លូវការក្នុងចំណោមអ្នកពាក់ព័ន្ធ ជាដំណើរការនយោបាយ និងចំណាយពេលយូរ។ ការកៀងគរការគាំទ្រផ្នែកគោលនយោបាយនៅកម្រិតខ្ពស់ ជាការសំខាន់ និងគួរជំរុញការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ និងអ្នកធ្វើសេចក្តីសម្រេចចិត្តតាំងពីដំបូង។
- ការសម្របសម្រួលជាមួយយន្តការគាំទ្រមានស្រាប់ ៖ ការជំរុញការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាចម្រុះ ជាការសំខាន់។

## គណៈកម្មាធិការត្រួតពិនិត្យ

- ការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់និងថ្នាក់ដឹកនាំប្រតិបត្តិក្នុងការផ្តល់សេវាដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ ឧ. មន្ត្រីជាន់ខ្ពស់ត្រូវចូលរួមក្នុងគណៈកម្មាធិការកម្រិត មូលដ្ឋានដែលដោះស្រាយអំពើហិង្សទាក់ទងនឹងយេនឌ័រ រួមទាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[407]។

## ការផ្សព្វផ្សាយ

- ធានាទំនាក់ទំនងជាយុទ្ធសាស្ត្ររវាងនគរបាល និងសហគមន៍ និងជំរុញការចូលរួមនៅគ្រប់កម្រិតនៃស្ថាប័ននគរបាល។
- ផ្តល់ទិសដៅច្បាស់លាស់ដល់បុគ្គលិកទាំងអស់ស្តីពីក្តីរំពឹងទុកក្នុងពេលដែលនគរបាលធ្វើការឆ្លើយតបទៅតាមតួនាទីផ្សេងៗ។
- ចែកសៀវភៅផ្តល់ព័ត៌មានក្បោះក្បាយដល់សហគមន៍ដើម្បីលុបបំបាត់ការយល់ខុស និងបុរេនិច្ឆ័យខុសឆ្គងជុំវិញអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលអាចលេចឡើងក្នុងផ្នត់គំនិតរបស់សាធារណជន។




គោលនយោបាយផ្អែកតាមបទដ្ឋានដែលកំណត់ឡើងយ៉ាងច្បាស់ និងលើកកម្ពស់ សមភាពយេនឌ័រ នឹងរំលេចសេវានគរបាលបែបប្រជាធិបតេយ្យ និងការអនុវត្តល្អបំផុតក្នុងការជ្រើសរើស និងការដាក់ពង្រាយការផ្ទេរការបណ្តុះបណ្តាល និងសុខុមាលភាពរបស់មន្ត្រី។ ការអនុវត្តវិធានការទាំងនេះនឹងអាចឱ្យស្ត្រីចូលរួមនិងទទួលបានអត្ថប្រយោជន៍ដោយស្មើភាពពីការផ្លាស់ប្តូរនិងការកែសម្រួលសេវានគរបាល។

សម្រាប់ឧទាហរណ៍បន្ថែមទៀតស្តីពីគោលនយោបាយផ្អែកតាមបទដ្ឋានដែលលើកកម្ពស់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រសូមអានឯកសារជំនួយស្មារតីរបស់DCAF, ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រ (២០១៩) ក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និង សន្តិសុខ។ សម្រាប់សេចក្តីណែនាំ សូមមើល "សៀវភៅណែនាំរបស់អង្គការសហប្រជាជាតិស្តីពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្ត្រី" (២០១២) និងផែនការគោលរបស់ UNODC ៖ ផែនការអនុវត្តន៍សម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី (ក្នុងឯកសារចេញផ្សាយដែលមានចំណងជើងថា "ការពង្រឹងការទប់ស្កាត់បទល្មើស និងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាលើស្ត្រី" (២០១៤)។

## គោលនយោបាយដែលជំរុញបរិយាបន្ននិងគុណតម្លៃចម្រុះ

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ទាមទារនូវគោលនយោបាយប្រកបដោយការផ្លាស់ប្តូរដែលខិតខំពង្រឹងការទទួលខុសត្រូវរបស់នគរបាលក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រាន់ទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក៏ដូចជាធានាថាវិធានការរបស់នគរបាលរួមចំណែកដល់យុទ្ធសាស្ត្រទប់ស្កាត់ដែលរារាំងការប្រព្រឹត្ត

407. ក្នុងប្រទេសមួយចំនួនតូច ដូចជា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការអំពើហិង្សាផ្អែកលើយេនឌ័រដែលចូលរួមដោយរដ្ឋាភិបាលអង្គការសង្គមស៊ីវិលអ្នកដឹកនាំសហគមន៍ និងដៃគូអភិវឌ្ឍន៍។ គណៈកម្មាធិការនេះមានតួនាទីត្រួតពិនិត្យ និងដាក់ចេញវិធានការកែតម្រូវសម្រាប់ការកែលម្អប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។



រូបថតទទួលបានពី MINUSTAH/Marco Dormino (ប្រទេសហៃទី)

អំពើហិង្សាបន្ថែមទៀតដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើស្ត្រី និងក្មេងស្រី។ គោលនយោបាយទាំងនេះ ត្រូវផ្លាស់ប្តូរទំនាក់ទំនងអំណាចមិនស្មើភាពក្នុងស្ថាប័ននគរបាល ដើម្បីលើកកម្ពស់ការបែងចែកអំណាចបែបបរិយាបន្ន និងលក្ខណៈចម្រុះក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជាគាំទ្រដល់ការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងស្ថាប័ននគរបាល។

ឱ. ចាប់ផ្តើមពីការជំនួស ឬកែសម្រួលគោលនយោបាយ និងរចនាសម្ព័ន្ធមានស្រាប់ដែលកំពុងលើកកម្ពស់ភាពលម្អៀងអវិជ្ជមាននិងការអនុវត្តបែបរើសអើងក្នុងស្ថាប័ននគរបាលហើយជំនួសដោយគោលនយោបាយដែលលើកកម្ពស់ និងជំរុញលើកទឹកចិត្តប្រកបដោយបរិយាបន្ន និងមានលក្ខណៈចម្រុះ។ ឱ. គោលនយោបាយច្បាស់លាស់ប្រឆាំងនឹងការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទក្នុងកន្លែងធ្វើការអាចជំរុញឱ្យស្ថាប័ននគរបាលបំពេញការទទួលខុសត្រូវរបស់ខ្លួន ឆ្ពោះទៅរកការផ្តល់ឱកាសស្មើភាពដល់មន្ត្រីនគរបាលទាំងពីរភេទ។

ក្នុងឯកសារជំនួយស្មារតីយេនឌ័រ (២០១៩) មជ្ឈមណ្ឌលហ្សឺណែវសម្រាប់អភិបាលកិច្ចវិស័យសន្តិសុខ (DCAF) លើកឡើងថា ដើម្បីផ្លាស់ប្តូរវប្បធម៌ក្នុងស្ថាប័នរបស់នគរបាលឆ្ពោះទៅរកគោលនយោបាយ និងសេចក្តីណែនាំពាក់ព័ន្ធដែលផ្តោតលើបរិយាបន្ន លក្ខណៈចម្រុះ ភាពអត់អោន និងការគោរព គួរបង្កើតបរិយាកាសការងារប្រកបដោយវិជ្ជាជីវៈដែលផ្តល់តម្លៃដល់បុគ្គលិកគ្រប់រូប[408]។




រូបថតទទួលបានពីសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (Abu Dhabi)

ខាងក្រោមនេះជាចំណុចពាក់ព័ន្ធមួយចំនួនក្នុងឯកសារជំនួយស្មារតីយេនឌ័ររបស់ DCAF ដើម្បីឱ្យគោលនយោបាយរបស់ស្ថាប័ននគរបាលឆ្លើយតបនឹងយេនឌ័រ។

- គោលនយោបាយ "មិនអត់អោនដាច់ខាត" ចំពោះការរើសអើង ការបៀតបៀន ការរករឿងរំខាន និងការរំលោភបំពាន។

408. ឯកសារជំនួយស្មារតី, ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (Geneva: DCAF, OSCE/ODIHR, UN Women, 2019).

- ការបណ្តុះបណ្តាលជាកាតព្វកិច្ចរបស់បុគ្គលិកគ្រប់រូបក្នុងការធានាការយល់ដឹងអំពីគោលនយោបាយប្រឆាំងការបៀតបៀន និងការរើសអើង។
- គួរមានសំណៅចម្លងគោលនយោបាយទាំងនេះនៅគ្រប់ប៉ុស្តិ៍នគរបាល ដោយមានចែកឯកសារផ្សព្វផ្សាយផងដែរ។
- ជំរុញការចូលរួមជាប្រចាំ(ពិតប្រាកដនិងបើកទូលាយ) ពីសំណាក់សមាគមនគរបាល និងអង្គការសង្គមស៊ីវិលដែលតំណាងឱ្យស្ត្រីនិងក្រុមភាគតិចដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេស្តីពីចំណុចសកម្ម និងអសកម្មក្នុងការបង្កើតបរិយាកាសវិជ្ជមាននៅកន្លែងធ្វើការ។
- ដើម្បីឱ្យថ្នាក់ដឹកនាំនគរបាលថ្លែងជាសាធារណៈ និងស៊ីសង្វាក់គ្នាអំពីគុណតម្លៃនៃកម្លាំងពលកម្មចម្រុះ និងការបដិសេធការរើសអើង ការផាត់ចេញ ការរករឿងរំខាន និងការបៀតបៀន ឬឥរិយាបថដែលបណ្តុះឱ្យមានការអនុវត្តទាំងនេះ។
- យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជំនាញត្រិះរិះ និងការគ្រប់គ្រងភាពតានតឹងរបស់នគរបាលប្រតិបត្តិការគ្រប់រូប។

បុគ្គលិកដែលយល់ថាត្រូវបានគេឱ្យតម្លៃ ជាពិសេសការឱ្យតម្លៃលើសុចរិតភាពរបស់ពួកគេ ងាយនឹងផ្តល់បទពិសោធន៍វិជ្ជមានពីការចូលរួមជាមួយអ្នកដទៃ។ក្នុងករណីនេះ អ្នកគ្រប់គ្រងថ្នាក់កណ្តាលដែលយល់ថាត្រូវបានគេឱ្យតម្លៃក្នុងស្ថាប័ននគរបាល ច្រើនតែអនុលោមតាមគោលការណ៍បទដ្ឋាន និងស្តង់ដារសេវានគរបាលរួមទាំងគោលការណ៍បទដ្ឋាននិងស្តង់ដារដែលពាក់ព័ន្ធនឹងការមិនរើសអើង និងការទទួលខុសត្រូវ។ គឺអ្នកគ្រប់គ្រងទាំងនេះហើយដែលផ្តល់គំរូល្អក្នុងការដឹកនាំ និងបំផុសឱ្យមានទីភ្ជាក់ងារនៃការផ្លាស់ប្តូរក្នុងក្រុមរបស់ពួកគេ។

ថ្នាក់ដឹកនាំនគរបាលអាចដើរតួនាទីដ៏សំខាន់ក្នុងការដេញដោលផ្នត់គំនិតមិនល្អ និងភាពលម្អៀងអវិជ្ជមាន ដែលរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនាពេលកន្លងមក។

ការដឹកនាំផ្អែកតាមបទដ្ឋានមានសារៈសំខាន់សម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ ផ្ទុយទៅវិញនៅពេលថ្នាក់ដឹកនាំនគរបាលមិនធ្វើជាគំរូ ឬមិនប្រកាន់ខ្ជាប់ស្តង់ដារ ភាពមានវិជ្ជាជីវៈ សមត្ថភាព និងឥរិយាបថសំខាន់ៗ ដែលនាំទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ នឹងកាត់ផ្តាច់អ្នកគ្រប់គ្រងប្រតិបត្តិ (ថ្នាក់កណ្តាល) ឬប្រធានក្រុម ដែលមើលឃើញតម្លៃក្នុងក្រុមបរិយាបន្ននិងចម្រុះក្នុងការការឆ្លើយតបទៅនឹងបទល្មើសនិងអំពើហិង្សាជារួម។

យោងតាម DCAF ការរើសអើង និងការបៀតបៀនច្រើនតែលេចឡើងក្នុងស្ថាប័នដែលក្រុមភាគតិច គ្មានតំណាងគ្រប់គ្រាន់ឬក្នុងស្ថាប័នដែលពួកគេមានតំណាងតិចតួចក្នុងតួនាទីគ្រប់គ្រង ឬឯកទេសជាច្រើន[409]។ ដូច្នេះចាំបាច់ត្រូវបង្កប់និរន្តភាពនៃការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រក្នុងការបង្កើតបរិយាកាសការងារប្រកបដោយវិជ្ជាជីវៈ ដែលបុគ្គលិកគ្រប់រូបត្រូវបានគេឱ្យតម្លៃនិងមិនមានការបន្ទុចបង្អាក់យ៉ាងផុសផុល និងជាបន្តបន្ទាប់មិនឱ្យមានភាពលម្អៀងអវិជ្ជមានចំពោះក្រុមភាគតិច។

នគរបាលដែលយល់ថាត្រូវបានគេឱ្យតម្លៃលើសុចរិតភាពរបស់ពួកគេ និងការអនុលោមតាមស្តង់ដារ គួរទទួលបានការពិចារណាដោយស្មើភាពលើសុខភាពនិងសុខុមាលភាពរបស់ពួកគេ ពីសំណាក់មេបញ្ជាការជាន់ខ្ពស់។ មន្ត្រីនគរបាលដែលដោះស្រាយករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាច្រើនឆ្នាំមានភាពនឿយណាយយ៉ាងខ្លាំងចំពោះការងាររបស់ខ្លួនព្រោះគ្មានការលើកទឹកចិត្តឬការដំឡើងឋានៈ។

ប្រអប់ ១០ ផ្តល់ឧទាហរណ៍ល្អៗស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការសន្តិសុខជាតិប្រទេសម៉ិចស៊ិក និង UNODCក្នុងការដោះស្រាយភាពតានតឹងក្នុងវិជ្ជាជីវៈដែលអាចនាំទៅរកការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃ។

409. ឯកសារជំនួយស្មារតី ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (Geneva: DCAF, OSCE/ODIHR, UN Women, 2019)។

## ប្រអប់ ៩ ៖
### កិច្ចខិតខំប្រឹងប្រែងរួមរវាង UNODC និងប្រទេសម៉ិចស៊ិកក្នុងការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ




នៅឆ្នាំ ២០១០ UNODC បានសហការជាមួយប្រទេសម៉ិចស៊ិកក្នុងការបង្កើតកម្មវិធីមួយដែលមានចំណងជើងថា "ការពង្រឹងសន្តិសុខសម្រាប់ក្រុមងាយរងគ្រោះ" ដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ។

ក្រោមការអនុវត្តរបស់ការិយាល័យUNODCប្រចាំនៅម៉ិចស៊ិកនិងគណៈកម្មការសន្តិសុខជាតិម៉ិចស៊ិក កម្មវិធីនេះមានគោលបំណងបណ្ដុះបណ្ដាលមន្ត្រីនគរបាលចំនួន ៨.០០០ នាក់ និងអ្នកបម្រើសេវាទូរស័ព្ទសង្គ្រោះបន្ទាន់ចំនួន១.០០០នាក់ក្នុងរដ្ឋសហព័ន្ធចំនួន១៩ដើម្បីកំណត់អត្តសញ្ញាណ និងផ្ដល់ជំនួយដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ។

ក្រៅពីនេះUNODCបានផលិតសៀវភៅណែនាំស្ដីពីការគ្រប់គ្រងភាពតានតឹងនិងសមត្ថភាពត្រិះរិះសម្រាប់មន្ត្រីរាជការដែលប្រឈមនឹងករណីអំពើហិង្សាយ៉ាងច្រើន។ ដូចគ្នានេះដែរ ឯកសារផ្ដល់ព័ត៌មានផ្សេងទៀត ដូចជាសៀវភៅព័ត៌មាន វីដេអូ និងផ្ទាំងបដា ត្រូវបាន ផលិតឡើងសម្រាប់ការបណ្ដុះបណ្ដាលដើម្បីផ្ដល់បទពិសោធន៍រៀនសូត្រកាន់តែប្រសើរ។

ក្រៅពីវគ្គបណ្ដុះបណ្ដាល ឯកសារផ្ដល់ព័ត៌មានបានជួយឱ្យសិក្ខាកាមទាញប្រយោជន៍ពីជំនាញចាំបាច់ក្នុងការកំណត់អត្តសញ្ញាណ និងដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រក្នុងប្រទេសម៉ិចស៊ិក។

ប្រភព ៖ កិច្ចសហការរវាង UNODC និងប្រទេសម៉ិចស៊ិកដើម្បីលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ

ការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃសំដៅលើប្រតិកម្មអវិជ្ជមានដែលអាចកើតឡើងនៅពេលស្ដាប់លឺបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តរបស់នរណាម្នាក់។ ការប្រឈមនឹងអារម្មណ៍ រឿងរ៉ាវ និងរូបភាពរបស់នរណាម្នាក់ដែលរងការប៉ះទង្គិចផ្លូវចិត្តអាចបង្កឱ្យមានប្រតិកម្មលើអ្នកផ្ដល់សេវាសំខាន់ៗដែលស្រដៀងគ្នានឹងជំងឺបាក់ស្បាត[410]។

ការដែលនគរបាលប្រឈមយ៉ាងខ្លាំងទៅនឹងការប៉ះទង្គិចផ្លូវចិត្ត ដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃ គឺជាតថភាពដែលត្រូវមានការផ្ដោតការយកចិត្តទុកដាក់ក្នុងស្ថាប័ននគរបាល។ ការអភិវឌ្ឍសមត្ថភាពដែលគាំទ្រដល់ស្វ័យយល់ដឹង ដើម្បីកត់សម្គាល់ និងគ្រប់គ្រងអារម្មណ៍តានតឹង និងអារម្មណ៍ប្រឈម ដែលនគរបាលលើកឡើងជាញឹកញាប់នៅពេលឆ្លើយតបទៅនឹងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីគឺជាជំហានដ៏ត្រឹមត្រូវមួយ។ គោលនយោបាយនិងសេចក្ដីណែនាំពាក់ព័ន្ធដែលផ្ដោតសំខាន់លើការគ្រប់គ្រងភាពតានតឹង និងសុខុមាលភាពរបស់មន្ត្រី អាចពង្រឹងសមានចិត្តរបស់មន្ត្រីនគរបាលពាក់ព័ន្ធនឹងបទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្ត ដើម្បីឱ្យមន្ត្រីរូបនោះអាចប្រឈមមុខនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានប្រសើរជាងមុន។

នៅឆ្នាំ ២០១៩ ការវាយតម្លៃដោយឯករាជ្យលើកម្មវិធី "ពង្រឹងសន្តិសុខសម្រាប់ក្រុមងាយរងគ្រោះ" នៅប្រទេសម៉ិចស៊ិក (ប្រអប់ ១០) បង្ហាញថា នគរបាលចាត់ទុកឯកសារបណ្ដុះបណ្ដាលស្ដីពីជំនាញត្រិះរិះ និងការគ្រប់គ្រងភាពតានតឹង មានភាពពាក់ព័ន្ធបំផុតក្នុងការអនុវត្តជាក់ស្ដែង[411]។ ពោលគឺ នគរបាលម៉ិចស៊ិកដែលឆ្លងកាត់ការពិគ្រោះយោបល់ មើលឃើញតម្លៃបន្ថែមក្នុងការផ្សារភ្ជាប់ជំនាញត្រិះរិះ និងការគ្រប់គ្រងភាពតានតឹង ទៅនឹងការឆ្លើយតបដែលកាន់តែមានប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបទល្មើសផ្អែកលើយេនឌ័រផ្សេងទៀត។

### បើគ្មានវិធានការគណនេយ្យភាពទេ គោលនយោបាយនឹងមិនធ្វើឱ្យមានការផ្លាស់ប្ដូរឡើយ

ស្ថាប័ននគរបាល ដែលសាធារណជនយល់ថាស្របច្បាប់

410. សូមមើលជំពូក ១២ ៖"ការប៉ះទង្គិចផ្លូវចិត្ត និងស្ទ័យថៃទាំក្នុងសៀវភៅណែនាំស្ដីពីការត្រួតពិនិត្យសិទ្ធិមនុស្ស" (OHCHR, 2011)។

411. Evaluación independiente de proyecto/evaluación en profundidad de: `Fortalecimiento para la Seguridad de Grupos ensituación de vulnerabilidad´ CÓDIGO: MEXZ93-2018-005 México, abril 2019.

ជាស្ថាប័នដែលប្រកាន់ខ្ជាប់គោលការណ៍គណនេយ្យភាពដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការរក្សាតុល្យភាពផ្ទៃក្នុង និងខាងក្រៅ ដើម្បីធានាថា នគរបាលបំពេញមុខងារដែលរំពឹងទុកប្រកបដោយស្តង់ដារខ្ពស់ និងត្រូវទទួលខុសត្រូវ ប្រសិនបើនគរបាលបំពេញមុខងារមិនបានល្អ[412]។ ក្នុងន័យនេះ UNODC[413] កំណត់ថា គណនេយ្យភាពដែលមានប្រសិទ្ធភាពចែកជា ៤ ផ្នែក ៖

១. ការណែនាំដល់នគរបាលស្តីពីអ្វីដែលត្រូវធ្វើ និងរបៀបអនុវត្ត (មុនពេលអនុវត្ត)។
២. ការត្រួតពិនិត្យនគរបាល និងការយល់ដឹងពីតម្រូវការគណនេយ្យភាព (ក្នុងពេ អនុវត្ត)។
៣. ការកែតម្រូវសកម្មភាពមិនសមស្រប និងភាពអសកម្មរបស់នគរបាល (ក្រោយពេលអនុវត្ត)
៤. យោបល់ត្រឡប់ និង ឱកាសឆ្លុះបញ្ចាំងលើបទពិសោធន៍ (ក្រោយពេលអនុវត្ត)។

វិធានការគណនេយ្យភាពទាំងនេះអាចអនុវត្តបានដូចគ្នាចំពោះក្របខណ្ឌប្រតិបត្តិនិងសុចរិតភាពរបស់នគរបាលដែលរួមមានគោលនយោបាយនិងសេចក្តីណែនាំពាក់ព័ន្ធដែលលើកកម្ពស់សមភាពយេនឌ័រនិងដាក់ទណ្ឌកម្មលើការប្រព្រឹត្តមិនសមរម្យដែលមានលក្ខណៈរើសអើង។

សំខាន់បំផុត ការផ្លាស់ប្តូរទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ទាមទារឱ្យមន្ត្រីនគរបាលគ្រប់រូបហ៊ានចាត់វិធានការវិន័យលើការរើសអើង ការបៀតបៀន ការរករឿងរំខាន ឬការរំលោភបំពាន[414]។ DCAF ព្រមានថា ការនិយាយលេង អំពើរប៉ិលរប៉ូច ភាសាបរិហារកេរ្តិ៍ សកម្មភាពនានាដែលបង្កទុក្ខបុកម្នេញ ឬការអនុវត្តផ្សេងទៀត ដែលគេចាត់ទុកថាជារឿងកំប៉ិចកំប៉ុក ឬមិនសំខាន់ អាចបង្កើតនូវការយល់ថាការរើសអើងនិងការផាត់ចេញត្រូវបានអត់អោន[415]។

សម្រាប់ជាត្រីវិស័យដល់បណ្តារដ្ឋទាំងឡាយ យុទ្ធសាស្ត្រគំរូបច្ចុប្បន្នភាព (២០១០)[416] ផ្តល់អនុសាសន៍សម្រាប់វិធានការគណនេយ្យភាពក្នុងស្ថាប័ននគរបាល ដូចខាងក្រោម ៖

- បង្កើតស្តង់ដារអនុវត្តន៍ និងការប្រព្រឹត្ត និង/ឬក្រមប្រតិបត្តិដែលអាចអនុវត្តបាន ដើម្បីបញ្ចៀស និងដោះស្រាយភាពលម្អៀងដែលស្តែងចេញឱ្យឃើញច្បាស់ និងភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់ក្នុងចំណោមមន្ត្រីនគរបាល ដែលពាក់ព័ន្ធក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ពិនិត្យតាមដានការអនុវត្តស្តង់ដារ និងក្រមប្រតិបត្តិទាំងនោះ។
- រក្សាការទទួលខុសត្រូវរបស់មន្ត្រីចំពោះការរំលោភស្តង់ដារ និងក្រមប្រតិបត្តិទាំងនោះតាមរយៈយន្តការត្រួតពិនិត្យ និងយន្តការគណនេយ្យភាពដែលបានបង្កើតឡើង។

### វិធានការសមស្របផ្សេងទៀតរួមមាន ៖

- ការបង្កើតនិងអនុវត្តគោលការណ៍ណែនាំច្បាស់លាស់សម្រាប់អនុវត្តការផ្សះផ្សារ និងយុត្តិធម៌ស្តារឡើងវិញនានាក្នុងករណីមានអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយអនុលោមតាមស្តង់ដារ និងអនុសាសន៍អន្តរជាតិរបស់ស្ថាប័នអង្គការសហប្រជាជាតិ ដូចមានរៀបរាប់ក្នុងសៀវភៅណែនាំនេះ។
- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីត្រួតពិនិត្យទាំងអស់ស្តីពីរបៀបកត់សម្គាល់ និងដោះស្រាយភាពលម្អៀងអវិជ្ជមានក្នុងក្រុមរបស់ខ្លួន។គួរចាត់វិធានការវិន័យលើភាពលម្អៀងដែលស្តែងចេញឱ្យឃើញច្បាស់និងភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់និងគួរពិភាក្សាពីករណីនៃភាពលម្អៀងដែលមិនស្តែងចេញឱ្យឃើញច្បាស់ជាមួយមន្ត្រីដើម្បីបញ្ចៀសការប្រព្រឹត្តដដែលៗ[417]។

វិធានការទាំងនេះ នឹងពង្រឹងសុចរិតភាពនគរបាលដែលជាកត្តាចាំបាច់ក្នុងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ និងការធ្វើទំនើបកម្មស្ថាប័ននគរបាល។

412. សៀវភៅណែនាំស្តីពីការទទួលខុសត្រូវ ការត្រួតពិនិត្យ និងសុចរិតភាពរបស់នគរបាល (UNODC, 2011), see: https://www.unodc.org/documents/justiceand-prison-reform/crimeprevention/PoliceAccountability_Oversight_and_Integrity_1057991_Ebook .pdf
413. Ibid
414. Ibid
415. ឯកសារជំនួយស្មារតី ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រ (២០១៩) ក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ។ Geneva: DCAF, OSCE/ODIHR, UN Women
416. យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ (២០១១ សេចក្តីសម្រេចលេខ ៦៥/២២៨ របស់មហាសន្និបាត ឧបសម្ព័ន្ធ)
417. បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី https://gnwp.org/

សម្រាប់ព័ត៌មានបន្ថែមស្តីពីវិធានការគណនេយ្យភាពសម្រាប់នគរបាល សៀវភៅណែនាំនេះសូមបង្ហាញឧបករណ៍ខាងក្រោមដែលផលិតដោយ DCAF ក្រោមកិច្ចសហការជាមួយ OSCE និងការិយាល័យស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODHIR)៖

- ការដាក់បញ្ចូលយេនឌ័រក្នុងការត្រួតពិនិត្យនគរបាលក្នុងស្ថាប័ន (២០១៤)[418]។
- ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការត្រួតពិនិត្យក្នុងស្ថាប័នកងកម្លាំងប្រដាប់អាវុធ (២០១៤)[419]។





## អំពើពុករលួយ និងផលប៉ះពាល់នៃអំពើពុករលួយលើសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

មិនខុសពីវិធានការដែលលើកកម្ពស់ក្រមប្រតិបត្តិសម្រាប់សុចរិតភាពរបស់នគរបាលនោះទេវិធានការគ្រប់គ្រងគុណភាពសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រងាយប្រឈមនឹងអំពើពុករលួយ។យោងតាមបណ្តាញសកលនៃអ្នកកសាងសន្តិភាពសកលជាស្ត្រី (GNWP) អំពើពុករលួយបានបង្កផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សរួមទាំងសិទ្ធិមនុស្សរបស់ស្ត្រី។ ក្រៅពីនេះ អំពើពុករលួយក៏ជាកង្វល់សន្តិសុខផងដែរ ព្រោះវាអាចបង្កទំនាស់ និងបង្កើនអសន្តិសុខជាពិសេសអសន្តិសុខសម្រាប់ក្រុមដែលគេចាត់ទុកថាងាយរងគ្រោះដោយសារការរើសអើងក្នុងសង្គម ដូចជាស្ត្រី និងក្មេងស្រី[420]។

ចំណុចសំខាន់គឺ អំពើពុករលួយរឹតត្បិតសមត្ថភាពរបស់ស្ត្រីនិងក្មេងស្រីមិនឱ្យចូលរួមប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្តរួមទាំងការសម្រេចចិត្តក្នុងការស៊ើបអង្កេតរបស់នគរបាល។ អំពើពុករលួយជារបាំងរារាំងមិនឱ្យជនរងគ្រោះរាយការណ៍ពីបទល្មើសអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាពិសេសប្រសិនបើជនបង្កជាបុគ្គលសាធារណៈដ៏មានឥទ្ធិពល មន្ត្រីនគរបាល ឬសមាជិកនៃកងកម្លាំងសន្តិសុខ។ ក្រៅពីនេះ អំពើពុករលួយរារាំងមិនឱ្យសាក្សីចូលផ្តល់សក្ខីកម្ម ដោយសារភ័យខ្លាចការបង្ហាញអត្តសញ្ញាណហើយពួកគេនិង/ឬក្រុមគ្រួសាររបស់ពួកគេក្លាយជាគោលដៅរបស់មន្ត្រីពុករលួយ។ ដូចគ្នានេះដែរ អំពើពុករលួយបានបង្ហាញអត្តសញ្ញាណរបស់ជនរងគ្រោះដែលកំពុងរស់នៅក្នុងជម្រកសុវត្ថិភាពក៏ដូចជាអ្នកដែលស្ថិតក្នុងគម្រោងការពារសាក្សី។

បណ្តាញស្ត្រីអ្នកកសាងសន្តិភាពសកល(GNWP)បានចងក្រងករណីជាច្រើនដែលនគរបាល និងបុគ្គលិកវេជ្ជសាស្ត្រទាមទារឱ្យបង់ប្រាក់លើសេវាដែលផ្តល់ជូនជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទទាក់ទងនឹងយេនឌ័រ(SGBV)សូម្បីតែក្នុងករណីដែលពួកគេគួរទទួលបានសេវាទាំងនោះដោយមិនគិតថ្លៃក្តី។ ក្នុងករណីផ្សេងទៀត នៅពេលអំពើហិង្សាផ្លូវភេទទាក់ទងនឹងយេនឌ័របង្កឡើងដោយបុគ្គលដ៏មានឥទ្ធិពលក្នុងសហគមន៍ នគរបាលមិនអើពើនឹងករណីទាំងនោះទេ ហើយជនបង្កមិនត្រូវបានកាត់ទោសឡើយ។ ក្នុងករណីទាំងនេះដែលនគរបាលរងឥទ្ធិពលពីបុគ្គលមានអំណាចផ្ទត់គំនិតរបស់កងកម្លាំងនគរបាលនិងតុលាការដែលមានចំពោះស្ត្រីច្រើនតែមានអភិភាព និងមិនគួរឱ្យទុកចិត្ត[421]។




បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រីគូសបញ្ជាក់ថា ទោះបីជាអំពើពុករលួយលេចឡើងយ៉ាងច្រើនក្នុងកងកម្លាំងសន្តិសុខក្តី ក៏ស្ត្រីជាពិសេសសង្គមស៊ីវិលដែលដឹកនាំដោយស្ត្រីអាចជាតួអង្គសំខាន់ក្នុងការទប់ស្កាត់និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ការដោះស្រាយអំពើពុករលួយមិនស្ថិតក្នុងវិសាលភាពនៃសៀវភៅណែនាំនេះទេ ប៉ុន្តែសូមអាន "ឯកសារជំនួយ

418. Bastick, M., Integrating Gender into Internal Police Oversight (DCAF, OSCE, OSCE/ODIHR, 2014).
419. Ibid
420. បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី https://gnwp.org/

ស្មារតីស្ដីពីសុចរិតភាពនគរបាល"របស់DCAD(២០១៩)[422] ដែលផ្ដោតសំខាន់លើអំពើពុករលួយរបស់នគរបាល និងផ្ដល់ការណែនាំដល់នគរបាលមានសមត្ថកិច្ច និងអ្នកធ្វើសេចក្ដីសម្រេចចិត្តផ្នែកនយោបាយស្ដីពីការឆ្លើយតបគ្រប់គ្រាន់ នៅពេលអំពើពុករលួយរបស់នគរបាលលេចឡើងក្នុងវិស័យរបស់ពួកគេ។

## ការកសាងភាពជាដៃគូយុទ្ធសាស្ត្រ

ការអនុវត្តច្បាប់ដែលឆ្លើយតបនឹងយេនឌ័រ ទាមទារនូវវិធីសាស្ត្ររស់រវើក និងក្ដោបរួម និងគួររួមបញ្ចូលធាតុចូលពីក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងសន្តិសុខជាតិ និងក្រសួងយុត្តិធម៌។ ពួកគេត្រូវសហការគ្នាក្នុងនាមជាអ្នកផ្ដល់សេវាសំខាន់ឬអ្នកមានភារកិច្ច[423] ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ និងបំពេញតម្រូវការរបស់ជនរងគ្រោះតាមរបៀបដែលឆ្លុះបញ្ចាំងពីកាតព្វកិច្ចរបស់ពួកគេឆ្ពោះទៅរកបទដ្ឋាន និងស្ដង់ដារសិទ្ធិមនុស្សជាសារវន្ត។ ក្រោមកាតព្វកិច្ចទាំងនេះហើយដែលនគរបាល (ដូចស្ថាប័នរដ្ឋផ្សេងទៀតដែរ)មានសមត្ថភាពជាក់លាក់និងការទទួលខុសត្រូវរួមដែលនៅពេលបូកបញ្ចូលគ្នា នឹងផ្ដល់ការឆ្លើយតបជារួមទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ប្រសិទ្ធភាពនៃការឆ្លើយតបជារួមទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាស្រ័យលើថាតើអ្នកមានភារកិច្ចអាចសម្របសម្រួលសមត្ថភាពរបស់ខ្លួនបានល្អកម្រិតណាក្នុងការផ្ដល់លទ្ធផលល្អបំផុតដល់ជនរងគ្រោះនិងជានាការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្តអំពើហិង្សា និងបទល្មើស។ កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្ដីពីសមាសធាតុស្នូល និងគុណភាព ផ្ដល់ក្របខណ្ឌសម្រាប់ការសម្របសម្រួលនិងអន្តរាគមន៍រួមសម្រាប់អ្នកមានភារកិច្ចដោយផ្អែកតាមគោលការណ៍ និងលក្ខណៈរួមដែលផ្អែកតាមសិទ្ធិ។ តួនាទីជាក់លាក់របស់នគរបាលក្នុងការកំណត់ការឆ្លើយតបគ្រប់ជ្រុងជ្រោយនេះ ត្រូវបានលើកមកពិភាក្សាលម្អិតក្នុងជំពូកទី ២-៩ នៃសៀវភៅណែនាំនេះ។

**ជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌)ផ្ដល់ការណែនាំសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្ដាលស្ដីពីការកំណត់ចំណុចចាប់ផ្ដើមនៃភាពជាដៃគូជាមួយអ្នកផ្ដល់សេវាសំខាន់ៗនិងអ្នកពាក់ព័ន្ធសំខាន់ៗដែលតំណាងឱ្យផលប្រយោជន៍របស់អ្នកមានសិទ្ធិ។**

ដើម្បីឱ្យការឆ្លើយតបជារួមទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្អែកតាមសិទ្ធិ ចាំបាច់ត្រូវកសាង និងរក្សាភាពជាដៃគូទ្វេភាគីជាយុទ្ធសាស្ត្រជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដែលតំណាងឱ្យផលប្រយោជន៍របស់អ្នកមានសិទ្ធិ[424] ដែលក្នុងករណីនេះសំដៅលើស្ត្រី និងក្មេងស្រី។

ដូចការគូសបញ្ជាក់ក្នុងសៀវភៅណែនាំនេះ ស្ត្រីនិងក្មេងស្រីប្រឈមនឹងអំពើហិង្សានិងបទល្មើសតាមរបៀបខុសៗគ្នា និងប្រទាក់ក្រឡាគ្នា។ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ត្រូវតែមានភាពប្រទាក់ក្រឡាគ្នា ពោលគឺសេវានគរបាលខិតខំស្វែងយល់ពីបទពិសោធន៍របស់ស្ត្រីនិងក្មេងស្រីនៅចំណុចប្រទាក់ក្រឡារវាងកត្តាគៀបសង្កត់ក្នុងពេលដំណាលគ្នាជាច្រើន ដែលរួមបញ្ចូល (ប៉ុន្តែមិនកំណត់ត្រឹម) ជាតិសាសន៍ វណ្ណៈ ឋានៈ យេនឌ័រ ជាតិពន្ធុ និន្នាការផ្លូវភេទ ពិការភាព សញ្ជាតិ ស្ថានភាពអន្តោប្រវេសន៍ទីតាំងភូមិសាស្ត្រសាសនា[425]។ល។របៀបដែលស្ថាប័ននគរបាលកសាងភាពជាដៃគូយុទ្ធសាស្ត្រជាមួយអ្នកផ្ដល់សេវាសំខាន់ៗ និងអ្នកពាក់ព័ន្ធសំខាន់ៗ ត្រូវរំលេចនូវអភិក្រមនៃភាពប្រទាក់ក្រឡាគ្នានេះដើម្បីស្វែងយល់ថាតើធម្មជាតិនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីឫសគល់ និងផលវិបាកនៃអំពើហិង្សានេះបង្កផលប៉ះពាល់ដូចម្ដេចលើស្ត្រី និងក្មេងស្រី។

នគរបាលមានកាតព្វកិច្ចនៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រាន់ទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ដូច្នេះនគរបាលត្រូវបង្កើតនិងផ្ដួចផ្ដើមវិធានការដើម្បីចូលដល់អ្នកពាក់ព័ន្ធ

421. បណ្ដាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី https://gnwp.org/
422. ឯកសារជំនួយស្មារតីស្ដីពីសុចរិតភាពនគរបាល" (មជ្ឈមណ្ឌលហ្សឺណែវសម្រាប់អភិបាលកិច្ចវិស័យសន្តិសុខ ២០១៩)
423. រដ្ឋត្រូវទទួលខុសត្រូវលើការគោរព ការការពារ និងការសម្រេចបានសិទ្ធិមនុស្ស។
424. អ្នកមានសិទ្ធិសំដៅលើមនុស្សគ្រប់រូប។
425. គុណតម្លៃនៃភាពប្រទាក់ក្រឡាគ្នាក្នុងការស្វែងយល់ពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី(VAWG) (Imkaan, UN Women and the European Union, July 2019).

ជាពិសេសអ្នកដែលងាយរងគ្រោះនិង/ឬអ្នកដែលមិនសូវទុកចិត្តនគរបាល។ ការចូលដល់អ្នកពាក់ព័ន្ធ ត្រូវចាប់ផ្ដើមពីកម្រិតមន្ត្រីជាន់ខ្ពស់ដែលថ្នាក់ដឹកនាំនគរបាលជួយបង្កើតគោលដៅ និងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តការប្ដេជ្ញាចិត្តរួម រួមទាំងយន្តការគ្រប់គ្រងគុណភាព ដើម្បីត្រួសត្រាយផ្លូវឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្ដាល កសាង និងរក្សាភាពជាដៃគូដែលចាំបាច់សម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

ខាងក្រោមនេះជាឧទាហរណ៍នៃគោលបំណងកសាងភាពជាដៃគូ ដែលនឹងជួយឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្ដាល និងក្រុមរបស់ពួកគេឆ្លើយតបកាន់តែប្រសើរទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅពេលដែលថ្នាក់ដឹកនាំប្រតិបត្តិ/ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងជួរនគរបាលសម្រេចបានគោលបំណងទាំងនោះ។

## ភាពជាដៃគូយុទ្ធសាស្ត្រជាមួយអ្នកផ្ដល់សេវាសំខាន់ៗផ្សេងទៀត

- ពិធីសារជាយុទ្ធសាស្ត្រស្ដីពីការចែករំលែកទិន្នន័យ/ព័ត៌មានជាមួយដៃគូ ក្នុងការបន្ត ផ្ដល់យុត្តិធម៌។
- ពិធីសារជាយុទ្ធសាស្ត្រស្ដីពីការចែករំលែកព័ត៌មានជាមួយអ្នកផ្ដល់សេវាសំខាន់ៗ។
- ការកៀរគរធនធាន រួមទាំងបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជានាការប្រព្រឹត្តសមស្របចំពោះជនរងគ្រោះ។ ចំណុចនេះរួមមានការបង្កើនភាពអាចរកបាន លទ្ធភាពទទួលបាន និងគុណភាពនៃផ្ទះសុវត្ថិភាព។
- ការត្រួតពិនិត្យរួមលើដំណើរការស៊ើបអង្កេត ត្រូវបានបង្កើតឡើង និងមានគណនេយ្យភាព។ ចំណុចនេះរួមមានការប្រជុំពិភាក្សាក្រោយពេលចប់សកម្មភាព និងការចែករំលែកមេរៀន។
- យន្តការបណ្ដឹងរួមដែលមានមូលដ្ឋានរឹងមាំអាចទទួលបាន និងផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ។
- ទំនាក់ទំនងកម្រិតយុទ្ធសាស្ត្ររវាងដៃគូស្ថាប័នយុត្តិធម៌ទាំងអស់ រួមទាំងស្ថាបអនុវត្តន៍ច្បាប់ផ្សេងទៀត។

## ភាពជាដៃគូយុទ្ធសាស្ត្រជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ

- ទំនាក់ទំនងជាមួយមេធាវីជនរងគ្រោះដើម្បីពង្រឹងការផ្សារភ្ជាប់រវាងសហគមន៍និងស្ថាប័ននគរបាល។ មេធាវីបំពេញបន្ថែមលើការងាររបស់មន្ត្រីនគរបាលផ្ដល់យោបល់ត្រឡប់និងការបណ្ដុះបណ្ដាល[426]។ នគរបាលគួរមើលឃើញឱកាសក្នុងការកសាងភាពជាដៃគូជាមួយអ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្ស និងសិទ្ធិស្ត្រីដើម្បីពង្រឹងទំនុកចិត្តរបស់សហគមន៍ចំពោះពួកគេ។
- ការបង្កើតភាពជាដៃគូការងារជាមួយស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ និងផ្ដល់យោបល់ និងស្ថាប័នផ្អែកលើចំណេះដឹងផ្សេងទៀត អាចជួយផ្ដល់ព័ត៌មាន និងពង្រឹងការយល់ដឹងរួមស្ដីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីឫសគល់និងផលវិបាកនៃអំពើហិង្សានិងថាតើអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នានិងមិនសមាមាត្រគ្នាដូចម្ដេចដល់ស្ត្រី និងក្មេងស្រី។ ចំណុចនេះអាចរួមបញ្ចូលស្ថាប័នអនុវត្តន៍ច្បាប់ដែលចុះអនុស្សារណៈយោគយល់គ្នាជាមួយស្ថាប័នដែលផ្អែកលើចំណេះដឹង ដែលអាចផ្ដល់ព័ត៌មានបរិបទដល់នគរបាលស្ដីពីការសាយភាយអាវុធធុនតូចនិងធុនស្រាល ឥរិយាបថរបស់ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជនរងគ្រោះក្នុងអំឡុងវិបត្តិសុខភាពសាធារណៈ ដូចជាជំងឺរាតត្បាតកូវីដ ១៩ និងការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃដល់មន្ត្រីនគរបាល រួមទាំងភាពពាក់ព័ន្ធរវាងតួអង្គទាំងនេះ។ ស្ថាប័នដែលផ្អែកលើចំណេះដឹងទាំងនេះអាចជាដៃគូខាងក្រៅដ៏សំខាន់នៅពេលពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយយុទ្ធសាស្ត្រនិងសកម្មភាពរបស់នគរបាល។
- ការបង្កើតឱ្យមានមន្ត្រីទំនាក់ទំនងសហគមន៍សម្រាប់សម្របសម្រួលការឆ្លើយតបសេវាសំខាន់ៗនិងដែលមានសមត្ថភាពលេចធ្លោក្នុងការកសាងភាពជាដៃគូ និងទំនាក់ទំនងអន្តរបុគ្គល។
- អ្នកគ្រប់គ្រងករណីស៊ើបអង្កេត ដែលបានទទួលការបណ្ដុះបណ្ដាលគ្រប់គ្រាន់ក្នុងការជំរុញទំនាក់ទំនងជាមួយគ្រួសារដែលទទួលខុសត្រូវលើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។

---

426. ដើម្បីជានាការដាក់បញ្ចូលវគ្គបណ្ដុះបណ្ដាលដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីការស៊ើបអង្កេតកម្រិតមូលដ្ឋាន និងការស៊ើបអង្កេតឯកទេសទាំងអស់។

### ប្រអប់ ៥ ៖

**នគរបាលសហការជាមួយអង្គការជនពិការក្នុងប្រទេសម៉ាឡាវី**[427]

នៅឆ្នាំ២០១៧នគរបាលម៉ាឡាវី(ដែនដីកណ្តាល)បានចុះអនុស្សារណៈយោគយល់គ្នាជាមួយអង្គការស្ត្រីមានពិការភាពនៅអាហ្វ្រិក (DIWA) ដើម្បីកែលម្អវិធីដែលនគរបាល និងប្រព័ន្ធច្បាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជនរងគ្រោះដែលមានពិការភាព។ ក្រោមអនុស្សារណៈខាងលើ អង្គការនេះបានប្តេជ្ញារាយការណ៍ពីករណីអំពើហិង្សា និងបណ្តុះបណ្តាលនគរបាល ចំណែកនគរបាលប្តេជ្ញាឆ្លើយតបកាន់តែឆាប់រហ័សទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងស្ត្រី និងក្មេងស្រីមានពិការភាព។

អនុស្សារណៈនេះកើតចេញពីការអង្កេតដើមគ្រាដោយអង្គការនេះនៅឆ្នាំ ២០១៤ ហើយលទ្ធផលនៃការអង្កេតបញ្ជាក់ថា ស្ត្រី និងក្មេងស្រីមានពិការភាពជាច្រើននាក់ ដែលរងគ្រោះដោយអំពើហិង្សា និងបទល្មើស មិនបានរាយការណ៍ដោយសារមូលហេតុធម្មតា ដូចជា ការមិនដឹងកន្លែងរាយការណ៍។

> "មុនការបណ្តុះបណ្តាលដោយអង្គការនេះ យើងមិនសូវចង់ដោះស្រាយករណីរបស់ជនពិការនោះទេ ៖ យើងដឹងពីពិការភាពរាងកាយ ប៉ុន្តែយើងមិនដឹងពីរបៀបដោះស្រាយជាមួយអ្នកដែលមានពិការភាពផ្នែកបញ្ញាស្មារតី និង/ឬពិការភាពដែលមើលមិនឃើញនោះទេ។

Jane Mkangala អធិការក្នុងអង្គភាពគាំពារជនរងគ្រោះ និងសេវានគរបាលក្នុងសហគមន៍ នៃកងកម្លាំងនគរបាលម៉ាឡាវី
ប្រភព ៖ អង្គការស្ត្រីមានពិការភាពនៅអាហ្វ្រិក (DIWA)

### ប្រអប់ ៦ ៖

**ការកសាងទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការរវាងនគរបាល និងសហគមន៍នៅ British Columbia (BC) ប្រទេសកាណាដា** [428]

កងរាជអាវុធហត្ថកាណាដា (RCMP) មានផ្នែកសេវានគរបាលជាតិសម្រាប់ជនជាតិដើមភាគតិច (NAPS) នៅ British Columbia ដែលសហការយ៉ាងជិតស្និទ្ធជាមួយក្រុមជនជាតិដើមភាគតិចដើម្បីបង្កើតអភិក្រមថ្មីក្នុងសេវានគរបាល ដែលបំពេញតម្រូវជាក់លាក់របស់ជនជាតិដើមភាគតិច។

ការបង្កើត ពង្រឹង និងពង្រីកទំនាក់ទំនងទាំងនេះជាមួយស្ត្រីនៅថ្នាក់មូលដ្ឋាន ផ្តល់សក្តានុពលក្នុងការកំណត់ និងលើកឡើងពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាយុត្តិធម៌ចាប់ពីការបង្កើនការយល់ដឹងអំពីសេវានានារហូតដល់ការផ្តល់វគ្គបណ្តុះបណ្តាលដែលត្រូវបានកែសម្រួលទៅតាមតម្រូវការយេនឌ័រ និងគិតគូរពីវប្បធម៌ ការបង្កើតបណ្តាញបញ្ជូន និងបណ្តាញគាំទ្រក្នុងមូលដ្ឋាន និងការជានាការឆ្លើយតប និងការស៊ើបអង្កេតដែលគិតគូរពីយេនឌ័រ ដើម្បីបង្កើនទំនុកចិត្ត និងភាពជឿជាក់រវាងស្ត្រី និងបុរសក្នុងសហគមន៍ទាំងនេះ និងនគរបាល។

ប្រភព ៖ "ការផ្តល់សេវាជូនជនជាតិដើមភាគតិចនៅកាណាដា" (កងរាជអាវុធហត្ថកាណាដា) : https://www.rcmp-grc.gc.ca/en/indigenous-policing

427. "អង្គការស្ត្រីមានពិការភាពនៅអាហ្វ្រិកដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានពិការភាព"។ សូមមើល http://www.diwaafrica.org/ និង "ការលើកកម្ពស់បរិយាកាសដែលកាន់តែមានសុវត្ថិភាព និងគ្មានអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់ស្ត្រី និងក្មេងស្រីមានពិការភាព" ក្នុង Lilongwe ប្រទេសម៉ាឡាវី អង្គការស្ត្រីមានពិការភាពនៅអាហ្វ្រិក។

428. ដកស្រង់ចេញពី "គម្រោងបង្កើនលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងខេត្ត British Columbia ៖ ការពិនិត្យឡើងវិញលើការអនុវត្តពីប្រទេសកាណាដានិងប្រទេសផ្សេងទៀតដើម្បីកែលម្អការឆ្លើយតបរបស់យើង" (មជ្ឈមណ្ឌលអន្តរជាតិដើម្បីកំណែទម្រង់ច្បាប់ព្រហ្មទណ្ឌនិងគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ" (ICCLR)

## ការបណ្ដុះបណ្ដាល ការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

ការអនុវត្តច្បាប់ដែលឆ្លើយតបនឹងយេនឌ័រ សំដៅលើការអនុវត្តចំណេះដឹង ជំនាញ និងឥរិយាបថ ដែលយល់ និងពិចារណាពីចលករក្នុងសង្គមនិងវប្បធម៌ដែលនាំឱ្យមានការផាត់ចេញ និងការរើសអើងផ្អែកលើយេនឌ័រ ដែលកើតឡើងនៅគ្រប់ទិដ្ឋភាពនៃជីវិតសាធារណៈ និងជីវិតឯកជន។ បើរួមបញ្ចូលគ្នា ចំណុចទាំងនេះបង្កើតបានជាសមត្ថភាពដែលគិតគូរពីយេនឌ័រ។ សមត្ថភាពដែលគិតគូរពីយេនឌ័រជាគន្លឹះក្នុងការជំរុញការចូលរួមប្រកបដោយប្រសិទ្ធភាពពីសំណាក់ជនរងគ្រោះដោយសារអំពើហិង្សា និងការកសាងទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធចម្រុះ ដែលអាចជះឥទ្ធិពលលើសេវាសំខាន់ៗដែលផ្ដល់ជូន។

"ការស៊ើបអង្កេតករណីប្រទូស្តកេរខ្មាសប្រកបដោយប្រសិទ្ធភាព ទាមទារនូវអ្នកស៊ើបអង្កេតដែលមិនលម្អៀង មានជំនាញមានសមានចិត្តទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ និងមានបទពិសោធន៍។ អ្នកស៊ើបអង្កេតនោះត្រូវចងក្រងរាល់ខ្លឹមសារលម្អិតនៃបទល្មើសយ៉ាងយកចិត្តទុកដាក់ និងប្រមូលរាល់ភស្តុតាងដែលមានឱ្យបានត្រឹមត្រូវ"។

សមាគមអន្តរជាតិនៃស្នងការនគរបាល (២០០៥)

ការបំពាក់បំប៉ន និង/ឬការពង្រឹងសមត្ថភាពដែលគិតគូរពីយេនឌ័រក្នុងការបណ្ដុះបណ្ដាល ការអប់រំ និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈនគរបាល ចាប់ផ្ដើមពីស្វ័យឆ្លុះបញ្ចាំង។ ស្វ័យឆ្លុះបញ្ចាំងត្រូវផ្អែកតាមការយល់ច្បាស់ថាតើឫសគល់នៃអំពើហិង្សា និងផលវិបាករបស់វា បង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្ដេចដល់ស្ត្រី និងក្មេងស្រី។ ការយល់ដឹងជារួមនេះ ដែលបង្កប់ក្នុងការ អនុវត្តរបស់មន្ត្រីនគរបាលជាន់ខ្ពស់និងថ្នាក់ដឹកនាំប្រតិបត្តិការក្នុងជួរនគរបាល គួររំលេចក្នុងការបណ្ដុះបណ្ដាលអំពីការស៊ើបអង្កេតជំនាញ និងការស៊ើបអង្កេតកម្រិតមូលដ្ឋានទាំងអស់ និងក្នុងការអប់រំមន្ត្រីជាន់ខ្ពស់ និងកម្មវិធីសិក្សាវិទ្យាសាស្ត្រសម្រាប់នគរបាល ឬកម្មវិធីស្រដៀងគ្នា។



រូបថតទទួលបានពី Force International (ប្រទេសបង់ក្លាដេស)

ដើម្បីឱ្យការយល់ដឹងទូទៅនេះក្លាយជាមូលដ្ឋានសម្រាប់ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍវិជ្ជាជីវៈ ចាំបាច់ត្រូវមានការផ្ដល់ព័ត៌មានជាប់ជាប្រចាំ។ កិច្ចសន្ទនា និងការផ្ដល់ធាតុចូលដោយជនរងគ្រោះ ក្រុមងាយរងគ្រោះ សហគមន៍ និងអ្នកជំនាញ (អ្នកសិក្សាស្រាវជ្រាវ ឬអ្នកអនុវត្តន៍) ដែលអាចផ្ដល់ការយល់ឃើញផ្សេងៗជុំវិញការផ្ដល់សេវា គឺជាវិធីមួយក្នុងការធ្វើឱ្យកម្មវិធីបណ្ដុះបណ្ដាល និងអប់រំនគរបាលអាចបំពេញតម្រូវការប្រតិបត្តិការសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

គណៈកម្មាធិការផ្ទៃក្នុងនិងគណៈកម្មាធិការខាងក្រៅអាចជួយដល់ការប្រមូលព័ត៌មានទាំងនេះ។ ឧ. គណកម្មការអន្តរស្ថាប័នឬក្រុមការងារទទួលបន្ទុកបទល្មើសផ្អែកលើយេនឌ័រ ជាប្រភពផ្ដល់ព័ត៌មានដ៏សំខាន់សម្រាប់ការកំណត់រកចំណុចខ្វះខាត មេរៀន និងការអនុវត្តល្អ ដែលគួរលើកមកចែករំលែក។

វិធីមួយទៀតក្នុងការរក្សាឱ្យការបណ្ដុះបណ្ដាល ការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈនគរបាល នៅតែមានភាពពាក់ព័ន្ធ គឺថ្នាក់ដឹកនាំនគរបាលត្រូវវិនិយោគនិងជំរុញលើកទឹកចិត្តឱ្យមានវដ្តនៃការរៀនសូត្រក្នុងស្ថាប័នដើម្បីពិនិត្យឡើងវិញនិងវាយតម្លៃឧបករណ៍និងអភិក្រមបច្ចុប្បន្ននៅពេលធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ភាពអាចប្រើប្រាស់បាន និងភាពអាចអនុវត្តបាននៃឧបករណ៍អន្តរាគមន៍ក្នុងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដូចជាទម្រង់វាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាល

ឬប្រព័ន្ធគ្រប់គ្រងករណី អាចទាញប្រយោជន៍យ៉ាងច្រើនពីការវិនិយោគលើវដ្តនៃការរៀនសូត្រទាំងនេះព្រោះវាផ្តល់ចំណុចចាប់ផ្តើមសម្រាប់ឱ្យមន្ត្រីឆ្លើយតប និងប្រធានក្រុមរបស់ពួកគេ ផ្តល់មតិ ឬយោបល់ត្រឡប់។ ការជានាការផ្តល់មតិលើការរៀនសូត្រដោយអ្នកពាក់ព័ន្ធដែលរងផលប៉ះពាល់ និងនគរបាលឆ្លើយតប នឹងបំពេញបន្ថែម និងពង្រឹងឱ្យគ្នាទៅវិញទៅមក។

ប្រភពនៃការរៀនសូត្រមួយផ្សេងទៀត ដែលជួយជំរុញដំណើរការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ គឺយន្តការបណ្តឹងផ្ទៃក្នុង និងយន្តការបណ្តឹងខាងក្រៅ ឬស្ថាប័នត្រួតពិនិត្យ ដូចជា ស្ថាប័នជាតិសិទ្ធិមនុស្ស។ ជាញឹកញាប់ ស្ថាប័នត្រួតពិនិត្យដូចជាស្ថាប័នជាតិសិទ្ធិមនុស្ស អាចជួយកំណត់រកដៃគូដែលអាចជួយដល់ការបណ្តុះបណ្តាល ការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

អ្វីដែលសំខាន់ផងដែរគឺការតាមដានប្រសិទ្ធភាពនៃវដ្តរៀនសូត្រ។ វិធីមួយក្នុងការត្រួតពិនិត្យប្រសិទ្ធភាពនៃវដ្តរៀនសូត្រ គឺចំនួន/ភាគរយអនុសាសន៍ដែលត្រូវបានដាក់បញ្ចូលក្នុងការបណ្តុះបណ្តាលនគរបាលដែលទទួលបានពីការពិនិត្យឡើងវិញ ឬការវាយតម្លៃហានិភ័យ[429] និងឧបករណ៍រៀបចំផែនការសុវត្ថិភាពដែលប្រើប្រាស់ដោយនគរបាលឆ្លើយតបដំបូងនិង/ឬក្នុងពេលធ្វើទំនាក់ទំនងដំបូង។

## ការកសាងភាពធន់នៃឥរិយាបថជំរុញការផ្លាស់ប្តូរ

ស្វ័យឆ្លុះបញ្ចាំងជាចំណុចចាប់ផ្តើមនៃដំណើរការផ្លាស់ប្តូរ។ ដូច្នេះស្វ័យឆ្លុះបញ្ចាំងទាមទារកិច្ចសន្ទនាបើកចំហដើម្បីដោះស្រាយបញ្ហាឫសគល់ក្នុងសង្គម។ ក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ កិច្ចពិភាក្សាដោយបើកទូលាយនិងប្រកបដោយតម្លាភាពស្តីពីភាពលម្អៀងអវិជ្ជមានក្នុងវប្បធម៌របស់ស្ថាប័ននគរបាលពិតជាចាំបាច់ណាស់។ ក្នុងករណីទាំងនេះ ការបណ្តុះបណ្តាល និងការអប់រំដោយផ្ទាល់គឺល្អបំផុត។ នេះជាអ្វីដែលលើកឡើងដោយស្ថាប័ននគរបាលដែលទទួលបានការបណ្តុះបណ្តាលស្តីពីទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងការអង្កេតមួយ[430]។ ដើម្បីឱ្យមានការរៀនសូត្រប្រកបដោយការផ្លាស់ប្តូរ UNPOL បានលើកឡើងនូវសកម្មភាពដែលជំរុញឱ្យមានការគិតបែបច្នៃប្រឌិត និងសេណារីយ៉ូជាក់ស្តែងដែលបំផុសការរៀនសូត្ររបស់សិក្ខាកាម[431]។



រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

429. ជាទូទៅ អភិក្រមរួមដើម្បីផ្តល់សុពលភាពឧបករណ៍វាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាល ពាក់ព័ន្ធនឹងការប្រើប្រាស់រូបមន្តស្ថិតិដែលប៉ាន់ប្រមាណលទ្ធភាពដែលឧបករណ៍នោះនឹងផលិតប្រូបាបព្យាករណ៍កម្រិតខ្ពស់នៃការប្រព្រឹត្តបទល្មើសឡើងវិញ ឬការប្រព្រឹត្តខុសម្តងទៀតសម្រាប់ជនបង្កដែលនៅតែបន្តប្រព្រឹត្តបទល្មើសបន្ថែមទៀតធៀបនឹងជនបង្កដែលលែងប្រព្រឹត្តបទល្មើស។ សូមមើល Dowling, C., Morgan, A., Boyd, C., Voce, I., 'Policing Domestic Violence: A Review of the Evidence', Australian Institute of Criminology, Research Report 13 (2018).

430. សូមមើលករណីសិក្សារបស់នគរបាល Nottinghamshire "ការចាត់ទុកឥរិយាបថហិង្សាចំពោះស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម" ក្នុងជំពូកទី ៩ (ទំនាក់ទំនង) សម្រាប់ឧទាហរណ៍នៃការឆ្លើយតបរបស់នគរបាលក្នុងការអង្កេតពាក់ព័ន្ធនឹងការបណ្តុះបណ្តាលស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

431. ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ៖ ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាពសេចក្តីសង្ខេបឧបករណ៍គម្រោង (២០១៥)។

ដើម្បីធានាការពិភាក្សាផ្អែកតាមព័ត៌មានត្រឹមត្រូវនគរបាលគួររួមបញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជួយសម្របសម្រួល និងរៀបចំម៉ូឌុលបណ្តុះបណ្តាល ហើយមតិយោបល់ស្តីពីកម្មវិធីសិក្សាអប់រំដើម្បីធានាការយល់ដឹងរួមស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានបញ្ជ្រាបបានយ៉ាងល្អសម្រាប់អ្នកដែលចង់ក្លាយជាសិស្សនាយនគរបាល និងមន្ត្រីនគរបាលគ្រប់កម្រិត។



រូបថតទទួលបានពី MINUSMA/Marco Dormino (ប្រទេសម៉ាលី)

ការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ សំដៅលើការផ្លាស់ប្តូរអាកប្បកិរិយា គំនិតផ្តួចផ្តើមក្នុងការបណ្តុះបណ្តាលនិងការអប់រំ។ដូច្នេះនគរបាលគួរស្វែងរកការណែនាំពីឯកសារវិទ្យាសាស្ត្រឥរិយាបថដែលអាចផ្តល់គំនិតល្អៗ។ ចំណេះដឹងពីផ្នែកចិត្តវិទ្យា សង្គមវិទ្យា និងសេដ្ឋកិច្ចឥរិយាបថ អាចជួយផ្តល់និរន្តរភាព និងភាពធន់ដល់ការផ្លាស់ប្តូរនេះក្នុងទម្រង់ជាមេរៀននិងការអនុវត្តល្អជាសមូហភាព។ឧ.អ្នកជំនាញផ្នែកវិទ្យាសាស្ត្រឥរិយាបថ អាចរួមចំណែកដល់ការរៀនសូត្រផ្អែកតាមភស្តុតាងដើម្បីជួយកែសម្រួលការបណ្តុះបណ្តាលនិងការអប់រំទៅតាមការផ្លាស់ប្តូរអាកប្បកិរិយាដែលអាចវាស់វែងនិងអាចសម្រេចបាន[432]។

ពាក់ព័ន្ធនឹងការផ្លាស់ប្តូរអាកប្បកិរិយាដែលអាចវាស់វែងនិងអាចសម្រេចបានរបាយការណ៍នគរបាលនៃគណៈកម្មការអឺរ៉ុបដែលមានចំណងជើងថា"ចំណេះដឹងពីវិទ្យាសាស្ត្រឥរិយាបថដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រី" (២០១៦)[433] លើកឡើងថា អ្នកផ្តល់សេវាសំខាន់ៗជាពិសេសនគរបាលគួរខិតខំផ្តោតសំខាន់លើការផ្លាស់ប្តូរអាកប្បកិរិយាតាមរយៈអ្នកជំនាញរបស់ពួកគេដើម្បីឱ្យជនរងគ្រោះអនុវត្តជំហានសម្រាប់ការរាយការណ៍ពីការប្រឈមនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដូចខាងក្រោម ៖

១. រក្សាឥរិយាបថវិជ្ជមានចំពោះការរាយការណ៍ពីអំពើហិង្សា។
២. ជឿថា អ្នកដទៃនឹងទទួលយកអាកប្បកិរិយារបស់គាត់ (ឧ. បទដ្ឋាន)។
៣. គិតថា គាត់ពិតជាអាចធ្វើបាន (ប្រសិទ្ធផលផ្ទាល់ខ្លួន)។
៤. ដឹងច្បាស់ពីអាកប្បកិរិយានោះ និងមិនត្រូវរាំងស្ទះដោយស្ថានភាពជុំវិញខ្លួនរបស់គាត់ (ឧ. ឧបសគ្គផ្នែកជំនាញ ចំណេះដឹង និងបរិស្ថាន)។

ប្រអប់ ១៤ ផ្តល់គន្លឹះមួយចំនួនពីវិទ្យាសាស្ត្រឥរិយាបថស្តីពីការបង្កើតឱ្យមានការផ្លាស់ប្តូរឥរិយាបថ។

ជាទូទៅដំណើរការផ្លាស់ប្តូរក្នុងស្ថាប័ននគរបាលប្រឈមនឹងការប្រឆាំង ឬការបដិសេធ និងការរារាំងពីមន្ត្រីនគរបាល រួមទាំងមន្ត្រីក្នុងជួរថ្នាក់ដឹកនាំ។ ក្រៅពីក្រមប្រតិបត្តិនិងគណនេយ្យភាពឬវិធានការពង្រឹងការអនុវត្តភាពធន់ទៅនឹងការប្រឆាំងឬការរារាំងការបណ្តុះបណ្តាលការអប់រំនិងការអភិវឌ្ឍវិជ្ជាជីវៈស្តីពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ត្រូវការយន្តការគាំទ្រជាចាំបាច់។ ឧទាហរណ៍មួយនៃយន្តការគាំទ្រគឺកម្មវិធីណែនាំនគរបាលនិងកម្មវិធីមិត្តជួយមិត្ត។

UNPOL ពិពណ៌នាការណែនាំជាទំនាក់ទំនងគ្រប់ជ្រុងជ្រោយ យូរអង្វែង និងតទល់ និងពាក់ព័ន្ធនឹងការជំរុញលើកទឹកចិត្តឱ្យមានភាពរីកចម្រើនក្នុងវិជ្ជាជីវៈដែលបុគ្គលម្នាក់ចំណាយពេលវេលា ថាមពល និងចំណេះធ្វើផ្ទាល់ខ្លួនដើម្បីជួយដល់ភាពរីកចម្រើន និងសមត្ថភាពរបស់បុគ្គលម្នាក់ទៀត។ UNPOL បន្ថែមទៀតថា ទំនាក់ទំនងយូរអង្វែងដែលផ្តោតសំខាន់លើការអភិវឌ្ឍវិជ្ជាជីវៈរបស់សិក្ខាកាមតាមរយៈការបង្ហាត់បង្រៀន ការហ្វឹកហ្វឺន ការណែនាំ និងជំរុញលើកទឹកចិត្ត[434]។

432. Sara Rafael Almeida, Joana Sousa Lourenço, François J. Dessart and Emanuele Ciriolo, 'Insights from behavioural sciences to prevent and combat violence against women', EUR 28235 EN, doi:10.2788/412325
433. Ibid
434. ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ស្តង់ដារនៃការអនុវត្តល្អបំផុតស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការរក្សាសន្តិភាព សេចក្តីសង្ខេបឧបករណ៍គម្រោង (២០១៥)

**ប្រអប់ ៧ ៖**

**គន្លឹះសម្រាប់ការបណ្ដុះបណ្ដាល និងការអប់រំឆ្ពោះទៅរកការផ្លាស់ប្ដូរអាកប្បកិរិយា**

- ជះឥទ្ធិពលលើគុណវិបត្តិ និងគុណសម្បត្តិ ៖ ធានាថា សិក្ខាកាមនគរបាល និងសិស្សនាយនគរបាលយល់ពីសារៈសំខាន់នៃការទប់ស្កាត់អំពើហិង្សា ធៀបនឹងការខាតបង់ក្នុងសង្គម និងរបៀបដែលពួកគេទទួលរងផលប៉ះពាល់ផ្ទាល់ពីការខាតបង់ ដែលបណ្ដាលមកពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- អាកប្បកិរិយាអាចកំណត់ឥរិយាបថ ប៉ុន្តែឥរិយាបថមិនកំណត់អាកប្បកិរិយាឡើយ ៖ រៀបចំការបណ្ដុះបណ្ដាល ការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈដែលផ្ដោតសំខាន់លើអាកប្បកិរិយារំពឹងទុក មិនមែនអាកប្បកិរិយាមានស្រាប់។ នៅពេលបុគ្គលអាចសម្រេចបានអាកប្បកិរិយារំពឹងទុក ការផ្លាស់ប្ដូរឥរិយាបថនឹងកើតឡើងតាមក្រោយ។
- ធ្វើឱ្យព័ត៌មានមានលក្ខណៈរូបី និងផ្អែកតាមបទពិសោធន៍ផ្ទាល់ខ្លួន ៖ បង្ហាញឧទាហរណ៍នៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ដែលផ្ដល់លទ្ធផលជាក់លាក់ដើម្បីឱ្យសិក្ខាកាមអាចផ្សារភ្ជាប់ទៅនឹងបទពិសោធន៍របស់សិក្ខាកាមដូចគ្នាក្នុងបរិស្ថានប្រឈមស្រដៀងគ្នា។
- លើកកម្ពស់ការប្ដេជ្ញាចិត្ត និងពិពណ៌នាអត្ថន័យនៃការប្ដេជ្ញាចិត្តនោះ ៖ កំណត់ច្បាស់ពីអាកប្បកិរិយារំពឹងទុកសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ និងថាតើអនុលោមភាពត្រូវបានផ្ដល់តម្លៃ និងលើកទឹកចិត្តដូចម្ដេចក្នុងស្ថាប័ន។ សូមអានឧបសម្ព័ន្ធ ១ (ការជំរុញការចូលរួមរបស់បុរសក្នុងការទប់ស្កាត់អំពើហិង្សា) ក្នុងជំពូក ៣ (ការទប់ស្កាត់) សម្រាប់ឧទាហរណ៍នៃសកម្មភាព ដែលឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តក្នុងការសម្រេចបានសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។
- ផ្សារភ្ជាប់នឹងគុណតម្លៃ ៖ បង្ហាញច្បាស់ពីទំនាក់ទំនងរវាងអាកប្បកិរិយារំពឹងទុកដែលបានកំណត់ក្នុងក្រមប្រតិបត្តិសុចរិតភាពនគរបាល និងការអនុវត្តល្អបំផុតក្នុងសេវានគរបាល ព្រមទាំងគោលដៅនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។
- កំណត់រក និងប្រើប្រាស់បុគ្គលគំរូដែលជំរុញលើកទឹកចិត្ត ៖ រួមបញ្ចូលបុគ្គលគំរូ ឬបទពិសោធន៍របស់ពួកគេក្នុងកម្មវិធីបណ្ដុះបណ្ដាល និងកម្មវិធីអប់រំសម្រាប់ជាឧទាហរណ៍។ មន្ត្រីនគរបាលមិនខុសពីអ្នកជំនាញផ្សេងទៀតនោះទេ ព្រោះពួកគេនឹងមានកម្លាំងចិត្តកាន់តែខ្លាំងនៅពេលមើលឃើញបុគ្គលដែលមានឥទ្ធិពលបង្ហាញច្បាស់ពីការផ្លាស់ប្ដូរអាកប្បកិរិយាដែលចង់បាន។

ប្រភព ៖ Jenni Cross., '3 Myths of Behavior Change & Other Challenges for Sustainability', Center for Energy and Behavior Institute for the Built Environment, Colorado State University, at: https://sustain.uccs.edu/sites/g/files/kjihxj1306/files/inline-files/Myths%20of%20Behaivor%20Change_UCCS2015_1.pdf

ការបង្កើតសមាគម/បណ្ដាញនគរបាលជាស្ត្រីក្នុងស្ថាប័ននគរបាលអាចជួយបង្កើតភាពស៊ាំទៅនឹងការបណ្ដុះបណ្ដាល និងការអប់រំស្ដីពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ សមាគម/បណ្ដាញទាំងនេះអាចជះឥទ្ធិពលលើការកែប្រែគោលនយោបាយ ហើយនៅពេលពិចារណាពីភាពចាំបាច់នៃយេនឌ័រ ជនជាតិភាគតិច និងសិទ្ធិមនុស្ស សេវានគរបាលនឹងអាចតំណាងឱ្យសហគមន៍ដែលពួកគេផ្ដល់សេវាជូន បានកាន់តែប្រសើរ។

សមាគម/បណ្ដាញនគរបាលជាស្ត្រី ក៏ជួយធានាផងដែរថា ស្ត្រីមានសំឡេង និងត្រូវបានទទួលស្គាល់ចំពោះការរួមចំណែករបស់ពួកគេ។ស្ត្រីអាចដើរតួនាទីជាមូលដ្ឋានក្នុងការពិគ្រោះយោបល់សម្រាប់ឆ្លើយតបទៅនឹងបទល្មើសយេនឌ័រនិងបញ្ហាប្រឈមជាបន្តបន្ទាប់របស់ជនរងគ្រោះជាស្ត្រី។ សមាគម/បណ្ដាញស្ត្រីជះឥទ្ធិពលលើការផ្លាស់ប្ដូរ និងជួយឱ្យស្ថាប័ននគរបាលសម្រេចបានការកែលម្អជាបន្តបន្ទាប់ដើម្បីពង្រឹងការផ្ដល់សេវាដល់សហគមន៍។

សមាគម/បណ្ដាញស្ត្រីអាចជាដៃគូដ៏សំខាន់របស់រដ្ឋាភិបាលក្នុងការបំពេញការប្ដេជ្ញាចិត្តជាអន្តរជាតិ



រូបថតទទួលបានពីសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (កិច្ចប្រជុំកំពូលស្តីពីការបញ្ឈប់អំពើហិង្សាផ្លូវភេទក្នុងស្ថានភាពមានជម្លោះ ទីក្រុងឡុងដ៍ ឆ្នាំ ២០១៤)

ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ដូចខាងក្រោម ៖

- អនុសញ្ញា CEDAW៖ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)។
- សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។
- សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់បទល្មើស និងវិធានការយុត្តិធម៌ព្រហ្មទណ្ឌដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី (១៩៩៨)។
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទី ៥ (សមភាពយេនឌ័រ) និងគោលដៅទី១៦ (សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ)។

សូមមើលករណីសិក្សានៅចុងបញ្ចប់នៃជំពូកនេះ ស្តីពីរបៀបដែលសមាគម/បណ្តាញនគរបាលជាស្ត្រីអាចគាំទ្រដល់សេវានគរបាលដែលគិតគូរពីយេនឌ័រ និងឆ្លើយតបនឹងយេនឌ័រ។

ខាងក្រោមនេះជាអនុសាសន៍មួយចំនួនសម្រាប់ពង្រឹងការបណ្តុះបណ្តាលការអប់រំនិងការអភិវឌ្ឍវិជ្ជាជីវៈនគរបាលក្នុងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ៖

### ក្របខណ្ឌបណ្តុះបណ្តាល

- កែសម្រួលកម្មវិធីសិក្សា និងប្លង់នៃវគ្គបណ្តុះបណ្តាល និងការអប់រំដែលផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការងារនាពេលអនាគតរបស់មន្ត្រីនគរបាលថ្មី និងនគរបាលដែលកំពុងបម្រើការ។ វគ្គបណ្តុះបណ្តាល និងការអប់រំគួរផ្តោតសំខាន់លើសមានចិត្តនិងគោលការណ៍សីលធម៌ដោយប្រើអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ ចំណុចនេះនឹងជួយបង្កើនសិទ្ធិអំណាចរបស់ស្ថាប័ននគរបាល ដែលមានសមត្ថភាពបំពេញភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពដោយគ្មានភាពលម្អៀងនិងការរើសអើង។
- ដាក់បញ្ចូលការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលផ្តោតសំខាន់លើជនបង្ក និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ក្នុងម៉ូឌុលបណ្តុះបណ្តាល និងកម្មវិធីសិក្សា ដើម្បីឱ្យមន្ត្រីគ្រប់រូបដែលបានចូលរៀននៅសាលាបណ្តុះបណ្តាលនគរបាលមានចំណេះដឹងមូលដ្ឋានលើប្រធានបទនេះ។
- រៀបចំការបណ្តុះបណ្តាលអន្តរវិស័យ (ប្រសិនបើអាច) និងបង្កើតការបណ្តុះបណ្តាលក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់សេវាសំខាន់ៗនិងក្រុមសិទ្ធិស្ត្រី និងសង្គមស៊ីវិល។
- អញ្ជើញឱ្យអ្នកជំនាញតាមប្រធានបទ ចូលរួមជាប្រចាំដើម្បីឱ្យការបណ្តុះបណ្តាលប្រព្រឹត្តទៅ និងដំណើរការបានរលូនដូចជាអ្នកជំនាញផ្នែកកោសលវិច័យមជ្ឈមណ្ឌលបញ្ជូនជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស ក្រុមតស៊ូមតិស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីអ្នកអប់រំការស្រាវជ្រាវស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអ្នកស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យា។
- កំហិតការពឹងផ្អែកលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការបណ្តុះបណ្តាលមន្ត្រី និងបុគ្គលិកស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អាចរៀបចំការប្រជុំពិភាក្សាផ្ទាល់ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយគ្មានការវិនិយោគច្រើនបន្ថែមទៀត ឬការដកមន្ត្រីចេញពីភារកិច្ចជួរមុខ។ វគ្គបណ្តុះបណ្តាលខ្លីៗក្នុងដំណើរការប្រជុំពិភាក្សាប្រចាំថ្ងៃជាជម្រើសដ៏ល្អ។
- រៀបចំករណីសិក្សា និងសេណារីយ៉ូដាក់ស្តែងពីបទពិសោធន៍ក្នុងមូលដ្ឋានដែលបង្ហាញមន្ត្រីនូវលទ្ធផលនៃសកម្មភាពរបស់ពួកគេក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- មិនបង្កគ្រោះថ្នាក់ ៖ អំពើហិង្សាលើស្ត្រី និងក្មេងស្រីកើតឡើងលើមនុស្សមិនរើសមុខហើយមន្ត្រីនគរបាលក៏មិនអាចគេចរួចពីបញ្ហានេះដែរ។ការបណ្តុះបណ្តាលនិងការអប់រំស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវ

កំណត់ថានគរបាលក៏អាចក្លាយជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជាជនបង្កផងដែរ។ គួរជំរុញឱ្យមានការគិតគូរពីអារម្មណ៍ក្នុងពេលបណ្តុះបណ្តាល។

- ដាក់បញ្ចូលការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំនគរបាលក្នុងវគ្គបណ្តុះបណ្តាលដូចជាការបង្ហាញសារពីចម្ងាយ ឬការបង្ហាញសារផ្ទាល់ពីមន្ត្រីជាន់ខ្ពស់ នៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល ឬតាមរយៈការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាមួយមន្ត្រីផ្សេងទៀត។
- បង្កើតវគ្គឯកទេស/វគ្គផ្សព្វផ្សាយ/វគ្គរយៈពេលខ្លី និងវគ្គរយៈពេលវែងស្តីពីបទល្មើសប្រឆាំងនឹងស្ត្រី និងក្មេងស្រី រួមទាំងបទល្មើសបច្ចេកវិទ្យា និងទម្រង់នៃការរំលោភបំពានដែលគ្មានការប៉ះពាល់រាងកាយ។
- ពិចារណារៀបចំការបណ្តុះបណ្តាលបំប៉នចល័តដែលផ្តោតសំខាន់លើតំបន់ប្រមូលផ្តុំដោយស្ត្រី និងក្មេងស្រីងាយរងគ្រោះនិងក្រុមស្រីនិងក្មេងស្រីភាគតិច។
- ធានាថា មន្ត្រីស៊ើបអង្កេតគ្រប់រូបឆ្លងកាត់វគ្គណែនាំគ្រប់ជ្រុងជ្រោយ។
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអប់រំដើម្បីឱ្យមានជំនួបរវាងថ្នាក់ដឹកនាំនគរបាលជួរមុខ និងមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់និងអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងជួរនគរបាល/ថ្នាក់ដឹកនាំនគរបាលផ្សេងទៀត។

### សមត្ថភាព (ចំណេះដឹង ជំនាញ និងឥរិយាបថ)

- ផ្តោតអាទិភាពលើគុណលក្ខណៈអន្តរបុគ្គលដែលគិតគូរពីយេនឌ័រ អាចជឿទុកចិត្តបាន មានការប្តេជ្ញាចិត្ត ជំរុញលើកទឹកចិត្ត ផ្សព្វផ្សាយ ឆ្លើយតប បំផុសមានយុត្តិធម៌ មិនលម្អៀង និងគ្មានការវិនិច្ឆ័យ។
- ផ្តោតសំខាន់លើការគោរពការសម្ងាត់ និងសុខុមាលភាពរបស់ជនរងគ្រោះ។ ជនរងគ្រោះគួរតែជាចំណុចស្នូលនៃការបណ្តុះបណ្តាល។ឧ.ការបណ្តុះបណ្តាលអំពីការស៊ើបអង្កេតគួរផ្តោតសំខាន់លើការគ្រប់គ្រងជនរងគ្រោះ ជាជាងការគ្រប់គ្រងវត្ថុតាង។
- ផ្តោតសំខាន់លើអាកប្បកិរិយាបង្ខិតបង្ខំនិងត្រួតត្រារបស់ជនបង្ក។ ជាញឹកញាប់ មន្ត្រីឆ្លើយតបពិបាកកំណត់រកទម្រង់នៃការរំលោភបំពាននេះ ព្រោះការរំលោភបំពាននេះច្រើនតែកើតឡើងដោយគ្មានការប៉ះពាល់រាងកាយនិងជាពាក្យសំដី។ជាទូទៅការមិនយល់ពីអាកប្បកិរិយាបង្ខិតបង្ខំ និងត្រួតត្រាដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនាំទៅរកការបង្កើតផ្នត់គំនិតនិងការស្តីបន្ទោសជនរងគ្រោះ។
- លើកទឹកចិត្តឱ្យមានការពិភាក្សាបើកចំហតាមរយៈការដេញដោលពីឥរិយាបថ និងភាពលម្អៀងរបស់មន្ត្រី។ ការប្រើប្រាស់សេណារីយ៉ូជាក់ស្តែង ដោយមានការពិភាក្សាពីសេចក្តីសម្រេចចិត្ត នឹងសម្រួលដល់ស្វ័យឆ្លុះបញ្ចាំង។
- បង្កើតយុទ្ធសាស្ត្របង្កើនការយល់ដឹងសម្រាប់មន្ត្រី "ដែលមិនសូវមានការយល់ដឹង"។ ធម្មជាតិនៃអំពើហិង្សា ឫសគល់ និងផលវិបាកនៃអំពើហិង្សា បង្កផលប៉ះពាល់ខុសៗគ្នា និងមិនសមាមាត្រគ្នាលើស្ត្រី និងក្មេងស្រី និងជាញឹកញាប់ អាចដោះស្រាយបានល្អបំផុតតាមរយៈការស្តាប់មតិរបស់ជនរងគ្រោះផ្ទាល់។
- ធានាថា ការបណ្តុះបណ្តាល និងការអប់រំរួមបញ្ចូលរបៀបកំណត់រកឧបសគ្គទំនាក់ទំនង ឧបសគ្គរូបវន្ត និងឧបសគ្គឥរិយាបថសម្រាប់ស្ត្រីនិងក្មេងស្រីដែលមានពិការភាពផ្សេងៗ។
- សម្របសម្រួលកិច្ចសន្ទនាដែលដេញដោលទស្សនាទានស្តីពីជនរងគ្រោះដែលល្អបំផុត ដោយមានឧទាហរណ៍ផ្សេងៗ រួមទាំងករណីល្អបំផុត។
- ធានាថា មន្ត្រីនគរបាលមានចំណេះដឹង និងយល់ពីចំណុចខ្វះខាតក្នុងច្បាប់ និងបទដ្ឋានសង្គម ដើម្បីបង្កើនការយល់ដឹងអំពីធម្មជាតិនៃអំពើហិង្សា ឫសគល់ និងផលវិបាកនៃអំពើហិង្សា និងថាតើអំពើហិង្សាបង្កផលប៉ះពាល់ខុសៗគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។

> "សមត្ថភាពផ្នែកផ្លូវចិត្ត ទាមទារការអភិវឌ្ឍជំនាញសង្គមសំខាន់ៗក្នុងការកត់សម្គាល់ បកស្រាយ និងឆ្លើយតបបែបស្ថាបនាទៅនឹងផ្លូវចិត្តរបស់ខ្លួនអ្នកផ្ទាល់និងអ្នកដទៃ។ ពោលគឺការអភិវឌ្ឍសមត្ថភាពក្នុងការស្ទួចម្លើយជនរងគ្រោះតាមរបៀបដែលបង្កើនសិទ្ធិអំណាច និងរម្ងាប់អារម្មណ៍របស់ពួកគេ ដើម្បីឱ្យពួកគេអាចផ្តល់ការរៀបរាប់ដំណើររឿងកាន់តែសុក្រឹត ពាក់ព័ន្ធគ្នា ស៊ីសង្វាក់គ្នា និងអាចជឿជាក់បាន។
>
> ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស បង្កឡើងដោយមនុស្សពេញវ័យ
> (Justice Canada 2019)

## ធនធានមនុស្ស
## សក្ដានុពលរបស់មន្ត្រីជាស្ត្រី

> សេវានគរបាលដែលតំណាងឱ្យសហគមន៍ចម្រុះដែលនគរបាលផ្ដល់សេវាជូនរួមទាំងពាក់ព័ន្ធនឹងយេនឌ័រងាយស្រួលធ្វើទំនាក់ទំនង និងទទួលបានទំនុកចិត្តពីសហគមន៍នោះ។
>
> ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្ដីពីយេនឌ័រ និងសន្តិសុខ
>
> ( DCAF, OSCE/ODIHR, UN Women, 2019 )

ដើម្បីឱ្យសេវានគរបាលឆ្លើយតបនឹងយេនឌ័រ ចាំបាច់ត្រូវមានភាពជាតំណាង និងប្រកបដោយបរិយាបន្នក្នុងស្ថាប័ននគរបាល។ស្ត្រីរួមចំណែកដល់ការបង្កើតស្ថាប័ននគរបាលដែលកាន់តែគិតគូរពីយេនឌ័រ ហើយសមាសជាតុមន្ត្រីនគរបាលជាស្ត្រីនឹងពង្រឹងប្រសិទ្ធភាពនៃការឆ្លើយតប។ ចំណុចទាំងពីរនេះមានសារៈសំខាន់ណាស់ក្នុងការកែលម្អកិច្ចការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ទោះជាយ៉ាងណា ការមានសមាសជាតុស្ត្រីកាន់តែច្រើនក្នុងស្ថាប័ននគរបាល មិននាំទៅរកការថយចុះករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីឡើយ ជាពិសេសប្រសិនបើមន្ត្រីជាស្ត្រីទាំងនោះមិនតំណាងឱ្យសហគមន៍ដែលពួកគេផ្ដល់សេវាជូន និងការពារ។

### ប្រអប់ ៩ ៖

**ប្រទេសអាល់បានី ៖ ផលប៉ះពាល់របស់ស្ត្រីដែលកាន់មុខតំណែងដឹកនាំជាន់ខ្ពស់ក្នុងជួរនគរបាល៖**

នៅឆ្នាំ ២០១៦ Force International បានធ្វើការវិភាគគំនិតផ្ដួចផ្ដើមសកម្មភាពវិជ្ជមានដើម្បីដាក់បញ្ចូលមន្ត្រីជាស្ត្រីក្នុងមុខតំណែងបញ្ជាការប្រតិបត្តិការក្នុងកងកម្លាំងនគរបាល រដ្ឋអាល់បានី (ASP)។ គំនិតផ្ដួចផ្ដើមនេះត្រូវបានគាំទ្រដោយ ICITAP ស្ថានទូតអាមេរិក និងដៃគូយុទ្ធសាស្ត្រផ្សេងទៀតក្នុងប្រទេសអាល់បានី។ ការពិនិត្យឡើងវិញនេះមានគោលបំណងកំណត់ការរៀនសូត្រវិជ្ជមានក្នុងការរៀបចំផែនការនិងការគ្រប់គ្រងការរៀបចំកម្មវិធីសកម្មភាពវិជ្ជមានទាំងនេះនាពេលអនាគត។ ក្នុងពេលពិនិត្យឡើងវិញ មានការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ជនបទអាល់បានី ( ស្ត្រី ) ស្ដីពីផលប៉ះពាល់របស់ស្ត្រីដំបូងគេដែលកាន់តំណែងជាមេបញ្ជាការនគរបាលថ្នាក់ស្រុក។ កិច្ចពិភាក្សាក្រុមគោលដៅបានធ្វើឡើង បន្ទាប់ពីមេបញ្ជាការស្រីរូបនោះចូលកាន់តំណែងបាន ៣ ខែ។

មតិយោបល់របស់ស្ត្រីក្នុងសហគមន៍នេះ ផ្ដោតសំខាន់លើការជំរុញការចូលរួមរបស់សហគមន៍ និងផលប៉ះពាល់របស់មន្ត្រីជាស្ត្រីដែលកាន់មុខតំណែងថ្នាក់ដឹកនាំជាន់ខ្ពស់លើពួកគេនិងអារម្មណ៍កក់ក្ដៅរបស់ពួកគេ។ការពិគ្រោះយោបល់កត់សម្គាល់ថា សម្រាប់ស្ត្រីក្នុងសហគមន៍នេះ ការមើលឃើញអ្នកកាន់មុខតំណែងណាម្នាក់ដែលមានលក្ខណៈសម្បត្តិដូចពួកគេ បានបង្កើនទំនុកចិត្ត និងការជឿជាក់របស់ពួកគេលើនគរបាល និងពង្រឹងទឡ្ហីករណ៍នៃការបង្កើនភាពលេចធ្លោររបស់ស្ត្រីក្នុងសេវានគរបាល។ខាងក្រោមជាមតិយោបល់មួយចំនួនរបស់ស្ត្រីក្នុងសហគមន៍ក្នុងដំណើរការពិគ្រោះយោបល់នេះ ៖

- "បច្ចុប្បន្ន ស្ត្រី និងក្មេងស្រីក្នុងសហគមន៍នេះមានទំនាក់ទំនងកាន់តែច្រើនជាមួយនគរបាល".
- "ការមានស្ត្រីក្នុងតួនាទីដឹកនាំ និងតួនាទីដាក់បទបញ្ជា ធ្វើឱ្យមានភាពខុសប្លែកសម្រាប់ស្ត្រី និងក្មេងស្រីក្នុងសហគមន៍ ពោលគឺពួកគេផ្លាស់ប្ដូរការយល់ឃើញចំពោះតម្លៃផ្ទាល់ខ្លួន"។
- "ការមានស្ត្រីកាន់មុខតំណែងនឹងបង្កើនទំនុកចិត្ត និងភាពជឿជាក់ ព្រោះការមើលឃើញនរណាម្នាក់ដែលមានលក្ខណៈសម្បត្តិដូចពួកយើងកាន់តែមុខតំណែង ជះឥទ្ធិពលលើពួកយើង"។
- "ការមានស្ត្រីកាន់តួនាទីដឹកនាំ និងតួនាទីដាក់បទបញ្ជា ធ្វើឱ្យមានភាពខុសប្លែកសម្រាប់ស្ត្រី និងក្មេងស្រីក្នុងសហគមន៍ ព្រោះពួកគេផ្លាស់ប្ដូរការយល់ឃើញចំពោះតម្លៃផ្ទាល់ខ្លួន។ វាបង្កផលប៉ះពាល់លើយើងទាំងអស់គ្នា។ ស្នងការដ្ឋានដែល ពោរពេញដោយស្ត្រី គឺជាការល្អ"។

ប្រភព ៖ Anon as cited in Townsley, J. ( 2016:40 ) Initiative for Mid-Ranking Women Officers to take on Operational Command Roles within the Albanian State Police: Review, Castleford: Force International Ltd. ( Document not in public domain )

ការជ្រើសរើស និងការរក្សាទុកស្ត្រីក្នុងស្ថាប័ននគរបាលនឹងក្លាយជាផ្នែកដ៏សំខាន់នៃការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ យោងតាម DCAF ក្រៅពីការបន្ថែមគំនិត ជំនាញ និងបទពិសោធន៍ទូលំទូលាយដល់ស្ថាប័ននគរបាល មន្ត្រីនគរបាលជាស្ត្រីហាក់ផ្តល់គុណសម្បត្តិមួយចំនួន ដូចជា ការផ្សារភ្ជាប់នឹងការមិនសូវប្រើកម្លាំងបាយ ពលរដ្ឋដាក់បណ្តឹងតិច (ធៀបនឹងមន្ត្រីជាបុរស)ច្រើនតែមានជំនាញទំនាក់ទំនងល្អប្រសើរហើយអ្នកដាក់បណ្តឹងចាត់ទុកថាមន្ត្រីនគរបាលជាស្ត្រីមានចិត្តមេត្តាជាងមន្ត្រីនគរបាលជាបុរស[435]។ នៅសហរដ្ឋអាមេរិក ការវិភាគផ្អែកលើយេនឌ័រស្តីពីការចោទប្រកាន់និងករណីនៃការប្រើកម្លាំងជ្រុលដោយនគរបាលបង្ហាញថាមានពលរដ្ឋតែ ៥% ប៉ុណ្ណោះដែលបានដាក់បណ្តឹងលើការប្រើកម្លាំងជ្រុល ហើយ ២% នៃការចោទប្រកាន់លើការប្រើកម្លាំងជ្រុលក្នុងស្ថាប័ននគរបាលធំៗពាក់ព័ន្ធនឹងមន្ត្រីជាស្ត្រី[436]។

ក្រៅពីនេះ ស្ត្រី និងក្មេងស្រី (និងសូម្បីតែបុរសដែលជាជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ) លើកឡើងថា ពួកគេចង់រាយការណ៍ទៅមន្ត្រីជាស្ត្រី[437]។ នេះជារឿងធម្មតា ព្រោះថា ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺភាគច្រើនជាបុរស និងក្មេងប្រុស ហើយកន្លងមកវប្បធម៌របស់នគរបាលក្នុងស្ថាប័នមិនសូវឱ្យតម្លៃនគរបាលដែលខិតខំអនុវត្តការងារបែបឆ្លើយតបនឹងយេនឌ័រឡើយ។

នៅឆ្នាំ ២០១១ UN Women បានបូកសរុបទិន្នន័យស្តីពីភាពជាតំណាងរបស់នគរបាលពី ៣៩ ប្រទេស ដែលប្រមូលដោយ UNODC (២០០៩) បូករួមនឹងការរាយការណ៍ករណី ប្រទូស្តកេរខ្មាស ដែលគណនាដោយការអង្កេតស្តីពីជនរងគ្រោះដោយសារបទល្មើសអន្តរជាតិ (ICVS) ដើម្បីបង្ហាញថា វត្តមានរបស់មន្ត្រីនគរបាលជាស្ត្រីមានទំនាក់ទំនងវិជ្ជមានទៅនឹងការរាយការណ៍ករណីប្រទូស្តកេរខ្មាស[438]។ ការវិភាគនេះពង្រឹងការយល់ឃើញថា ការជ្រើសរើស និងការរក្សាទុកស្ត្រីក្នុងស្ថាប័ននគរបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីប្រកបដោយប្រសិទ្ធភាព(សូមមើលរូប២)។

**រូប ២ ៖**

**ទំនាក់ទំនងរវាងវត្តមានរបស់មន្ត្រីនគរបាលជាស្ត្រី និងការរាយការណ៍ករណីប្រទូស្តកេរខ្មាស**




435. ឯកសារជំនួយស្មារតី ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (Geneva: DCAF, OSCE/ODIHR, UN Women, 2019)
436. បុរស ស្ត្រី និងការប្រើកម្លាំងជ្រុលដោយនគរបាល ៖ "រឿងរ៉ាវរបស់យេនឌ័រ ២ ៖ ការវិភាគខ្លឹមសារនៃករណីបទល្មើសរដ្ឋប្បវេណីការចោទប្រកាន់ជាប្រចាំនិងបណ្តឹងរបស់ពលរដ្ឋ"(មជ្ឈមណ្ឌលជាតិដើម្បីស្ត្រី និងសេវានគរបាល ២០០២)។
437 Welch, J and Mason, F., 'Rape and Sexual Assault', British Medical Journal 2007;334;1154-1158
438. វឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោក២០១១-២០១២៖គ្រួសារក្នុងពិភពដែលពោរពេញដោយការប្រែប្រួល (UN Women, 2011)

ស្ត្រីក្នុងកងកម្លាំងនគរបាល និងការរាយការណ៍ករណីប្រទូស្តកេរខ្មាស (ទំ. ៥៩) ក្នុងឯកសារវឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោក ២០១១។



រូបថត ៖ MINUSTAH (ប្រទេសហៃទី)

EUROPOL ផ្តោតសំខាន់លើការសិក្សាស្រដៀងគ្នានៅពេលខិតខំអភិវឌ្ឍស្ថាប័ន។ ឧ. EUROPOL យល់ថាក្រុមថ្នាក់ដឹកនាំដែលមានតុល្យភាពយេនឌ័រនឹងបង្កើនគុណភាពនៃការធ្វើសេចក្តីសម្រេចចិត្តហើយកន្លែងធ្វើការដែលមានតុល្យភាពយេនឌ័រ នឹងអនុវត្តការងារបានកាន់តែប្រសើរ[439]។ ដូច្នេះ EUROPOL បានខិតខំស្វែងយល់បន្ថែមទៀតថាតើកន្លែងធ្វើការដែលមានយេនឌ័រចម្រុះ និងតុល្យភាពយេនឌ័របង្កើនការអនុវត្តការងារនិងលទ្ធផលរបស់ពួកគេដូចម្តេចតាមរយៈការអនុវត្តគម្រោងតុល្យភាពយេនឌ័រ(២០១២)ដើម្បីស្វែងយល់ពីមូលហេតុដែលនាំឱ្យមានអតុល្យភាពក្នុងសមាសធាតុបុគ្គលិក ជាពិសេសនៅកម្រិតគ្រប់គ្រង[440]។ គម្រោងនេះ មានគោលបំណងកែលម្អអតុល្យភាពយេនឌ័រ កសាងការយល់ដឹងអំពីសមភាពយេនឌ័រ និងបង្កើតអភិក្រមមួយដើម្បីធានាថាសមភាពយេនឌ័រក្លាយជាចំណុចស្នូលនៃបរិយាកាសការងាររបស់ EUROPOL[441]។

## ការជ្រើសរើស និងការរក្សាទុកបុគ្គលិកដើម្បីធានានូវស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ

ទោះបីជាមន្ត្រីនគរបាលជាស្ត្រីមានសមាសធាតុតិចក្នុងស្ថាប័ននគរបាលក្តី ប៉ុន្តែពួកគេអាចរួមចំណែកយ៉ាងច្រើនដល់ការធ្វើឱ្យសាធារណជនយល់ថា នគរបាលជាស្ថាប័នស្របច្បាប់និងគួរឱ្យជឿទុកចិត្ត។ការសន្មតជាស្ថាប័នស្របច្បាប់ និងគួរឱ្យជឿទុកចិត្ត ជាធាតុផ្សំដ៏សំខាន់នៃស្ថាប័ននគរបាលសម័យទំនើប។

ដូច្នេះ ការជ្រើសរើស និងការរក្សាទុកស្ត្រីក្នុងស្ថាប័ននគរបាល ជាធាតុផ្សំដ៏សំខាន់មួយនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ ទោះជាយ៉ាងណាចំណុចនេះជាអ្វីដែលមិនងាយនឹងសម្រេចបាននោះទេ។ បទពិសោធន៍បង្ហាញថា ការធានាផ្តល់ធនធានសមស្របដល់ការផ្តល់សេវាសំខាន់ៗ និងការធានា ឱ្យមន្ត្រីទទួលបានការបណ្តុះបណ្តាលនិងការជំរុញលើកទឹកចិត្តគ្រប់គ្រាន់មានសារៈសំខាន់ដូចការបង្កើននិងការរក្សាសមាសធាតុមន្ត្រីជាស្ត្រីដែរ[442]។

> "ស្ត្រីមានជំនាញគួរឱ្យកោតសរសើរក្នុងការគ្រប់គ្រង និងការដឹកនាំ...។ ស្ត្រីមានជំនាញល្អក្នុងការស្តាប់ និងប្រតិភូកម្មការយល់ច្បាស់ពីតថភាព និង ជាទូទៅមានរបៀបរៀបរយ។ ស្ត្រីអាចរក្សាតុល្យភាពរវាងយុទ្ធសាស្ត្រសំខាន់ៗទន្ទឹមនឹងការផ្តោតការយកចិត្តទុកដាក់ពិសេសលើខ្លឹមសារលម្អិត និងមានការទទួលខុសត្រូវខ្ពស់។
>
> Ignacio Cosidó Gutiérrez មេបញ្ជាការនគរបាលជាតិអាស្ប៉ាញ (២០១៣)

យុទ្ធសាស្ត្រគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីក្នុងផ្នែកទប់ស្កាត់បទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ទទូចឱ្យរដ្ឋទាំងឡាយ ៖

- ធានាភាពជាតំណាងដែលមានសមធម៌យេនឌ័រក្នុងកងកម្លាំងនគរបាល និងស្ថាប័នផ្សេងទៀតនៃប្រព័ន្ធយុត្តិធម៌ ជាពិសេសនៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត និងកម្រិតគ្រប់គ្រង។
- ប្រសិនបើអាច ផ្តល់សិទ្ធិឱ្យជនរងគ្រោះដោយសារអំពើហិង្សានិយាយជាមួយមន្ត្រីជាស្ត្រីមិនថាជានគរបាល ឬមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតនោះទេ[443]។

439. Wittenberg-Cox, A, 'How Women Mean Business: A Step by Step Guide to Profiting from Gender Balanced Business (2010)', in 'The Female Factor Gender Balance in Law Enforcement (EUROPOL, 2013), see: https://www.europol.europa.eu/publicationsdocuments/female-factor-gender-balance-in-law-enforcement
440. កត្តាមនុស្សស្រី តុល្យភាពយេនឌ័រក្នុងការអនុវត្តច្បាប់ (EUROPOL, 2013) https://www.europol.europa.eu/publicationsdocuments/female-factor-gender-balance-in-law-enforcement
441. Ibid
442. វឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោក ២០១១-២០១២ ៖ គ្រួសារក្នុងពិភពដែលពោរពេញដោយការប្រែប្រួល (UN Women, 2011)។

ទោះជាយ៉ាងណាគួរមានការប្រុងប្រយ័ត្ននៅពេលគោលដៅចម្បងត្រឹមតែជាការបង្កើនភាពជាតំណាងក្នុងសេវានគរបាល ព្រោះស្ថាប័ននគរបាលអាចបំផុសឱ្យមានផ្នត់គំនិតថាមានតែមន្ត្រីជាស្ត្រីប៉ុណ្ណោះដែលគួរគិតគូរពីយេនឌ័រ និងទទួលខុសត្រូវលើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី[444]។

ជំនួសឱ្យការជ្រើសរើសការរក្សាទុកនិងការដំឡើងតំណែងមន្ត្រីនគរបាលគ្រប់រូបគួរផ្តោតអាទិភាព និងលើកស្ទួយបេក្ខជនដែលមានសមត្ថភាពឆ្លុះបញ្ចាំងពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រដោយប្រើអភិក្រមប្រទាក់ក្រឡាគ្នា និងផ្អែកតាមសិទ្ធិ។

ក្រៅពីនេះការអនុវត្តគោលនយោបាយជ្រើសរើសបេក្ខជនដែលគិតគូរពីយេនឌ័រគួរស៊ីសង្វាក់គ្នានឹងការបណ្តុះបណ្តាលបុគ្គលិកស្តីពីសិទ្ធិមនុស្ស និងបញ្ហាយេនឌ័រ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដើម្បីកាត់បន្ថយហានិភ័យចំពោះស្ត្រី និងមនុស្សដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ និងដំណើរការសម្រាប់ការពារ និងឆ្លើយតបនឹងការរើសអើង[445]។ ឯកសារជំនួយស្មារតីយេនឌ័ររបស់ DCAF (២០១៩) ផ្តល់ឧទាហរណ៍ស្តីពីសមត្ថភាពរបស់មន្ត្រីនគរបាល និងការពិពណ៌នាការងារ ដែលបន្ស៊ីគ្នានឹងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ (ប្រអប់ ១៩)។

**ប្រអប់ ៩៖**

**សមត្ថភាពរបស់មន្ត្រីនគរបាល នៅក្នុងការពិពណ៌នាការងារ**

- ជំនាញទំនាក់ទំនងអន្តរវប្បធម៌ល្អប្រសើរជាមួយក្រុមប្រជាជនចម្រុះ (បុរស ស្ត្រី ក្មេងស្រី ក្មេងប្រុស ជនមានទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះ អាយុចម្រុះ ជាតិពន្ធុ សាសនា។ល។)។
- មានសមានចិត្ត និងមានជំនាញល្អផ្នែកស្តាប់។
- សមត្ថភាពបន្ធូរបន្ថយស្ថានភាពងាយប្រែប្រួល និងផ្សះផ្សាទំនាស់។
- សមត្ថភាពបង្កើតការមូលមតិគ្នាក្នុងចំណោមអ្នកដែលមានចំណាប់អារម្មណ៍ចម្រុះ។
- សមត្ថភាពធ្វើកិច្ចការចម្រុះ និងកំណត់អាទិភាពលើតម្រូវការចម្រុះ។
- សមត្ថភាពសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងក្នុងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- មានភាពប្រតិសកម្មក្នុងការបង្កើតអភិក្រមទប់ស្កាត់បទល្មើស និងបញ្ហាសង្គម។
- ចេះគោរព និងគួរសម។
- ឱ្យតម្លៃការពិគ្រោះយោបល់ និងការកសាងទំនាក់ទំនង។
- ស្មោះត្រង់ និងប្តេជ្ញាចិត្តអនុវត្តតាមដំណើរការសមស្រប។។

ប្រភព៖ ឯកសារជំនួយស្មារតី ឧបករណ៍ទី ២ ៖ សេវានគរបាល និងយេនឌ័រក្នុងឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (Geneva: DCAF, OSCE/ODIHR, UN Women, 2019)

ក្រៅពីនេះ ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL (២០១៥)[446] ផ្តល់ការណែនាំបន្ថែមទៀតសម្រាប់ដំណើរការជ្រើសរើស និងរក្សាទុកនគរបាល ដែលបំពេញបន្ថែម និងពង្រឹង សេចក្តីណែនាំ (ខាងលើ) របស់ DCAF ស្តីពីការជ្រើសរើសបេក្ខជនដើម្បីធានានូវសេវានគរបាលចម្រុះ។ ទោះជាយ៉ាងណា រាល់សេចក្តីណែនាំដែលផ្តល់ជូន និងលើកឡើងក្នុងសៀវភៅណែនាំនេះ នឹងគ្មានប្រសិទ្ធភាពឡើយ ប្រសិនបើគ្មានវិធានការគណនេយ្យភាព និងគោលនយោបាយដែលលុបបំបាត់រាំងបែបរើសអើង។

ឱ.ស្ត្រីក្នុងជួរនគរបាលប្រឈមនឹងឧបសគ្គដែលនគរបាលជាបុរសមិនប្រឈមដូចជាផលប៉ះពាល់នៃការលាបពណ៌ និងការបៀតបៀនផ្លូវភេទ។ លើសពីនេះ ទិន្នន័យបង្ហាញថា

443. A/Res/65/228 ឧបសម្ព័ន្ធ កថាខណ្ឌ ១៦ (k-l)។ សូមមើលផងដែរ UNODC ការអប់រំដើម្បីយុត្តិធម៌៖ ម៉ូឌុលស្តីពីយេនឌ័រក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រធានបទទី ៤ ៖ នានាភាពយេនឌ័រក្នុងជួរមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ។

444. Ibid

445. Gordon, E., McHugh, C., and Townsley, J., 'Risks versus Transformational Opportunities in Gender-Responsive Security Sector Reform', Journal of Global Security Studies, 0(0), 2020, 1–16 doi: 10.1093/jogss/ogaa028

មន្ត្រីនគរបាលជាស្ត្រីសម្រេចចិត្តមិនអភិវឌ្ឍអាជីពរបស់ខ្លួនដោយសារតែក្តីពឹងទុក និងបទដ្ឋានគ្រួសារ[447]។ ដូច្នេះគោលនយោបាយដែលតម្រូវឱ្យមានការពិនិត្យឡើងវិញលើនីតិវិធីជ្រើសរើសនគរបាលផ្អែកតាមទស្សនៈយេនឌ័រ មានសារៈសំខាន់ណាស់ក្នុងការកំណត់ថាតើនីតិវិធីទាំងនោះមានលក្ខណៈរើសអើងស្ត្រី ឬទេ។ ក្នុងន័យនេះ UN Women ស្នើឱ្យគោលនយោបាយនៃការជ្រើសរើសនគរបាល ជានាថា[448] ៖

១. ស្ត្រីមានគន្លងអាជីពច្បាស់លាស់ដើម្បីប្រឡូកក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត។
២. ផែនការធនធានមនុស្សគាំទ្រភាពរីកចម្រើនប្រកបដោយនិរន្តរភាពរបស់មន្ត្រីនគរបាលជាស្ត្រី។
៣. មានលក្ខខណ្ឌ និងគ្រឿងលើកទឹកចិត្តសម្រាប់រក្សាទុកនគរបាលជាស្ត្រី។

ការបង្កើតគណៈកម្មាធិការផ្ទៃក្នុងឬក្រុមការងារដែលមានតួនាទីកំណត់រកឧបសគ្គដែលនាំឱ្យមានការរើសអើងស្ត្រី និងក្រុមភាគតិច ក៏ជាសកម្មភាពវិជ្ជមានមួយផងដែរ។ ទោះជាយ៉ាងណា គណៈកម្មាធិការ ឬក្រុមការងារទាំងនេះគួរឆ្លុះបញ្ចាំងពីគោលការណ៍សមភាព និងសមធម៌យេនឌ័រក្នុងចំណោមសមាជិកក៏ដូចជាទទួលបានធនធាន និងការគាំទ្រគ្រប់គ្រាន់ពីមន្ត្រីនគរបាលជាន់ខ្ពស់ និងថ្នាក់ដឹកនាំប្រតិបត្តិក្នុងជួរនគរបាល ដើម្បីសម្រេចផលប៉ះពាល់ដែលចង់បាន។ ប្រអប់ ២០ បង្ហាញឧទាហរណ៍ពីប្រទេសលីបេរីយ៉ាស្តីពីរបៀបដែលនគរបាលលីបេរីយ៉ាជះឥទ្ធិពលលើការឡើងដំណែងរបស់មន្ត្រីនគរបាលជាស្ត្រី។

**ប្រអប់ ១០ ៖**
**នគរបាលជាស្ត្រីក្នុងប្រទេសលីបេរីយ៉ា តស៊ូមតិឱ្យមានស្ត្រីកាន់តួនាទីដឹកនាំកាន់តែច្រើន**

ក្រោមការគាំទ្រពី UN Women សមាគមស្ត្រីអ្នកអនុវត្តន៍ច្បាប់លីបេរីយ៉ា បានរៀបចំសន្និសីទមួយដែលកៀរគរអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យសន្តិសុខ រួមទាំងអ្នកគ្រប់គ្រងជាន់ខ្ពស់។ ចំណុចសំខាន់ៗដែលលើកឡើងរួមមានការពិភាក្សា ពាក់ព័ន្ធនឹងបញ្ហាប្រឈមរបស់ស្ត្រីក្នុងស្ថាប័នសន្តិសុខ។

ឧ. ក្នុងកងកម្លាំងនគរបាលជាតិលីបេរីយ៉ា គ្មានស្ត្រីក្នុងមុខតំណែងប្រតិបត្តិឡើយ និងមានស្ត្រីតែ ១៦ នាក់ប៉ុណ្ណោះ (ធៀបនឹងនគរបាលប្រុស ១២៦ នាក់) ដែលកាន់តួនាទីត្រួតពិនិត្យ។ ក្រៅពីនេះ មាននិស្សិតស្រីតែ ៧៨ នាក់ប៉ុណ្ណោះដែលបញ្ចប់ការសិក្សា និងប្រឡូកក្នុងកងកម្លាំងនគរបាលទាំងមូល។

សមាគមនេះទទួលបានជោគជ័យក្នុងការបញ្ចុះបញ្ចូលឱ្យមានការតែងតាំងមន្ត្រីជាស្ត្រី ២ នាក់ជាមន្ត្រីជាន់ខ្ពស់ក្នុងជួរនគរបាលជាតិលីបេរីយ៉ា និង Executive Mansion Protection Services រួមទាំងនគរបាលជាស្ត្រីម្នាក់ដែលកំពុងកាន់តំណែងថ្នាក់ទី ៣ ក្នុងជួរនគរបាលជាតិលីបេរីយ៉ា។

ប្រភព ៖ "ការវិភាគរបាយការណ៍ប្រចាំឆ្នាំថ្នាក់ប្រទេស" (UN Women 2016) (មិនបានបោះពុម្ពផ្សាយ)

**ប្រអប់ ១១ ៖**
**បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៅតំបន់អឺរ៉ុបអាគ្នេយ៍ (WPON)**



ឧទាហរណ៍វិជ្ជមានមួយទៀតគឺបណ្តាញមន្ត្រីនគរបាលជាស្ត្រីនៅតំបន់អឺរ៉ុបអាគ្នេយ៍ (WPON) ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ២០១៣។ បណ្តាញនេះបានបង្កើតស្ថាប័ន និងបណ្តាញផ្តល់ប្រឹក្សាដ៏មានឥទ្ធិពលសម្រាប់សេវានគរបាលក្នុងតំបន់នេះលើបញ្ហាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសេវានគរបាល។ ពាក់ព័ន្ធនឹងប្រធានបទនេះ WPON បានបង្កើត "គោលការណ៍ណែនាំសម្រាប់សេវានគរបាលដែលគិតគូរពីយេនឌ័រដោយផ្តោតសំខាន់លើការជ្រើសរើសការជ្រើសតាំងនិងការអភិវឌ្ឍវិជ្ជាជីវៈរបស់ស្ត្រីក្នុងសេវានគរបាល" (២០១២)។

គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងជាសៀវភៅណែនាំសម្រាប់អ្នកគ្រប់គ្រងក្នុងជួរនគរបាលគ្រប់

446. សូមមើល ផ្នែកទី ១ ៖ "ការជួយដល់នគរបាលក្នុងរដ្ឋម្ចាស់ស្រុក ក្នុងការជ្រើសរើសមន្ត្រីនគរបាលជាស្ត្រី" (ឯកសារជំនួយស្មារតីយេនឌ័ររបស់ UNPOL ២០១៥)
447. Graue T.M., Hildie, R.E., and Weatherby, G.A, 'Women in Modern Policing'. Department of Sociology and Criminal Justice, Gonzaga University, Spokane, WA, USA, Journal of Social Sciences and Humanities Vol. 2, No. 3, 2016, pp. 51-62 ISSN: 2381-7763 (Print); ISSN: 2381-7771.
448. "ឯកសារជំនួយស្មារតីរបស់អ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌" (UN Women et al, 2018)

កម្រិត ជាពិសេសនគរបាលដែលធ្វើការក្នុងនាយកដ្ឋានអប់រំ ធនធានមនុស្ស និងទំនាក់ទំនងសាធារណៈ ឬមន្ត្រីផ្សេងទៀតក្នុងក្រសួងមហាផ្ទៃ និងនគរបាលដែលចាត់ចែងការជ្រើសរើស ការទទួលយក ការជ្រើសតាំង និងការអភិវឌ្ឍវិជ្ជាជីវៈ។ ពួកគេបានដាក់ស្នើកម្រងវិធានការធម្មតា និងចំណាយតិច ដែលជួយឱ្យសេវានគរបាលទាក់ទាញ និងរក្សាទុកស្ត្រីដែលមានលក្ខណៈសម្បត្តិ និងពង្រឹងសមភាពយេនឌ័រ។

ប្រភព ៖ គោលការណ៍ណែនាំសម្រាប់សេវានគរបាលដែលគិតគូរពីយេនឌ័រ ដោយផ្តោតសំខាន់លើការជ្រើសរើស ការជ្រើសតាំង និងការអភិវឌ្ឍវិជ្ជាជីវៈរបស់ស្ត្រីក្នុងសេវានគរបាល” បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៅតំបន់អឺរ៉ុប អាគ្នេយ៍ (WPON) ៖ មជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ និងបូព៌ា (SEESAC, 2012) សូមមើល ៖ https://www.seesac.org/f/tmp/files/publication/812.pdf

## ការវាយតម្លៃយេនឌ័រក្នុងស្ថាប័ន

យោងតាម DCAF ការវាយតម្លៃក្នុងស្ថាប័នអំពីឧបសគ្គ និងចំណុចចាប់ផ្តើមសម្រាប់សមភាពយេនឌ័រ គួរតែជាជំហានដំបូងក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ ការវាយតម្លៃយេនឌ័រក្នុងស្ថាប័នអាចជួយ ៖

- កំណត់រកធនធានស្ថាប័នដែលអ្នកមានដើម្បីដោះស្រាយបញ្ហាយេនឌ័រពាក់ព័ន្ធនឹងជំនាញ ចំណេះដឹង អាណត្តិ គោលនយោបាយ និងនីតិវិធី។
- កំណត់ចំណុចសកម្មនិងចំណុចអសកម្មក្នុងការបំពេញតម្រូវការរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសក្នុងសហគមន៍ដែលពួកគេផ្តល់សេវាជូន។
- កំណត់តម្រូវការបណ្តុះបណ្តាលនិងតម្រូវការសម្ភារ។
- ទទួលបានទិន្នន័យដើមគ្រាសម្រាប់ពិនិត្យ និងវាយតម្លៃវឌ្ឍនភាព។
- បង្ហាញដល់បុគ្គលិកនូវការប្តេជ្ញាចិត្តរបស់អ្នកក្នុងការសម្រេចបានលក្ខខណ្ឌការងារល្អប្រសើរ និងឱកាសស្មើភាព។
- យល់ពីមូលហេតុដែលបុគ្គលិកជាស្ត្រី និងបុគ្គលិកជាបុរស លាឈប់ពីមុខតំណែង។
- កំណត់រកការអនុវត្តល្អមានស្រាប់ដើម្បីគាំទ្រដល់ការជ្រើសរើស ការរក្សាទុក និងការដំឡើងតំណែងបុគ្គលិកទាំងពីរភេទបុរស ឈរលើមូលដ្ឋានស្មើភាព។
- បង្ហាញដល់សហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតនូវការប្តេជ្ញាចិត្តរបស់អ្នកក្នុងការសម្រេចបានសិទ្ធិមនុស្ស និងសមភាពយេនឌ័រ។
- ពង្រឹងភាពជាដៃគូជាមួយសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាបន្ទាប់បន្សំ។
- បង្កើតគោលដៅជាក់ស្តែង និងយុទ្ធសាស្ត្រអនុវត្តន៍ដែលកាន់តែឆ្លើយតបនឹងយេនឌ័រ។




សៀវភៅណែនាំនេះលើកឡើងពីឯកសារ “មគ្គុទេសក៍ស្តីពីស្វ័យវាយតម្លៃយេនឌ័រសម្រាប់នគរបាល កងកម្លាំងប្រដាប់អាវុធ និងវិស័យយុត្តិធម៌”របស់ DCAF (២០១១) នៅពេលពិចារណាពីការវាយតម្លៃក្នុងស្ថាប័នលើឧបសគ្គនិងចំណុចចាប់ផ្តើមសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

## ការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

### សូចនាករនៃទំនុកចិត្តរបស់សាធារណជនសម្រាប់ការអនុវត្តច្បាប់ដែលឆ្លើយតបនឹងយេនឌ័រ

ក្រោយបញ្ចប់ការវាយតម្លៃយេនឌ័រក្នុងស្ថាប័ននគរបាលអាចបង្កើតទិន្នន័យគោលដើម្បីវាស់វែងថាតើពួកគេកំពុងធ្វើរឿងត្រឹមត្រូវ ឬទេ និងផលប៉ះពាល់របស់វាលើប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ទំនុកចិត្តរបស់សាធារណជននឹងដើរតួនាទីយ៉ាងសំខាន់លើកម្រិតប្រសិទ្ធភាពរបស់នគរបាលក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រោះនេះជា សូចនាករដ៏ល្អដែលបង្ហាញពីឆន្ទៈរបស់សាធារណជនក្នុងការចូលរួមជាមួយនគរបាលដើម្បីរាយការណ៍ពីបទល្មើស និងអំពើហិង្សា។ ដូច្នេះ នគរបាលគួររៀបចំទិន្នន័យគោល និងវិធីសាស្ត្រប្រមូលទិន្នន័យ ដើម្បីឱ្យដឹងថាតើពួកគេកំពុងផ្តល់ការឆ្លើយតបដែលមានប្រសិទ្ធភាពទៅនឹងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ។

**ការវិភាគយេនឌ័រជាការពិនិត្យល្អិតល្អន់លើថាតើភាពខុសគ្នានៃតួនាទីយេនឌ័រសកម្មភាពតម្រូវការ ឱកាស និងសិទ្ធិ/សិទ្ធិទទួលបាន បង្កផលប៉ះពាល់ដូចម្តេចលើបុរស ស្ត្រី ក្មេងស្រីនិងក្មេងប្រុសក្នុងស្ថានភាព ឬបរិបទជាក់លាក់។**

មានគំរូយ៉ាងច្រើនសម្រាប់វាស់វែងទំនុកចិត្តរបស់សាធារណជនលើស្ថាប័ននគរបាល។ ឧ. Stanko and Bradford ស្នើឱ្យប្រព័ន្ធនគរបាលច្បាមយកទិន្នន័យដែលឆ្លើយតបទៅនឹងសូចនាករបែបគុណភាពដូចតទៅ ក) ការយល់ឃើញចំពោះប្រសិទ្ធភាពរបស់នគរបាល ខ) ភាពយុត្តិធម៌នៃការប្រព្រឹត្តរបស់នគរបាលចំពោះពួកគេ គ) កម្រិតនៃការចូលរួមរបស់នគរបាលក្នុងសហគមន៍ និង ឃ) ការព្រួយបារម្ភរបស់ប្រជាជនមូលដ្ឋានស្តីពីភាពអសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន ព្រោះការព្រួយបារម្ភទាំងនោះបង្កផលប៉ះពាល់យ៉ាងខ្លាំងលើទំនុកចិត្ត "ជារួម" ចំពោះនគរបាល [449]។

ទោះជាយ៉ាងណាសម្រាប់គោលបំណងនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ សូចនាករបែបគុណភាពដែលស្នើឡើងដោយ Stanko and Bradford នឹងតម្រូវឱ្យមានការបែងចែកជាប្រភេទបន្ថែមទៀតដើម្បីធានាការវិភាគដែលគិតគូរពីយេនឌ័រលើកត្តាប្រទាក់ក្រឡាគ្នាដែលបង្កផលប៉ះពាល់លើតម្រូវការសន្តិសុខរបស់ស្ត្រី និងក្មេងស្រី។

ប្រអប់ ១២ ខាងក្រោមបង្ហាញឧទាហរណ៍ស្តីពីរបៀបបែងចែកជាប្រភេទបន្ថែមទៀតនូវរង្វាស់ទាំង៤របស់Stanko and Bradford (២០០៩) សម្រាប់វាស់វែងទំនុកចិត្តរបស់សាធារណជនចំពោះស្ថាប័ននគរបាល ដើម្បីធានាការវិភាគដែលកាន់តែគិតគូរពីយេនឌ័រសំដៅពិនិត្យតាមដានការអនុវត្តការងាររបស់នគរបាលក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ១២ ៖**

| ទំនុកចិត្តរបស់សាធារណជនចំពោះនគរបាល[450] | ការយល់ឃើញចំពោះប្រសិទ្ធភាពរបស់នគរបាល | ភាពយុត្តិធម៌នៃការប្រព្រឹត្តរបស់នគរបាលចំពោះពួកគេ | ការព្រួយបារម្ភរបស់ប្រជាជនមូលដ្ឋានស្តីពីភាព អសណ្តាប់-ធ្នាប់ក្នុងមូលដ្ឋាន | កម្រិតនៃការចូលរួមរបស់នគរបាលក្នុងសហគមន៍ |
|---|---|---|---|---|
| សូចនាករបែបគុណភាព បែងចែកតាមអាយុ និងអថេរសេដ្ឋកិច្ច-សង្គមផ្សេងទៀត (ប្រសិនបើអាច) | ការកើនឡើងនៃកម្រិតទំនុកចិត្តរបស់ស្ត្រី និងក្មេងស្រីចំពោះសេវានគរបាលការកើនឡើងនៃការយល់ឃើញរបស់ដៃគូផ្តល់សេវាសំខាន់ៗចំពោះប្រសិទ្ធភាពនៃការបញ្ជូនដោយនគរបាល | ជនរងគ្រោះ និង/ឬក្រុមគ្រួសាររាយការណ៍ថាមិនសូវប្រឈមនឹងការរងគ្រោះលើកទីពីរ[451]ការថយចុះបណ្តឹងលើនគរបាលក្នុងពេលឆ្លើយតបដំបូង ពេលមានករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី | ការកើនឡើងនៃការពេញចិត្តរបស់ជនរងគ្រោះ និង/ឬក្រុមគ្រួសារដែលយល់ថា ការចូលរួមរបស់ពួកគេមានអត្ថន័យ និងយល់ថាមានសុវត្ថិភាពជាងមុន | ការកើនឡើងនៃកម្រិតទំនុកចិត្តរបស់អង្គការសង្គមស៊ីវិលចំពោះសេវាសំខាន់ៗរបស់នគរបាល |

449. Stanko, E.A., and Bradford, B. (2009), "Beyond Measuring 'How Good a Job' Police Are Doing: The MPS Model of Confidence in Policing", Policing, Volume 3, Number 4, pp. 322–330. Oxford University Press.

450. As per Stanko, E.A., and Bradford, B (2009).

451. ការរងគ្រោះជាលើកទីពីរត្រូវបានកំណត់និយមន័យក្នុងយុទ្ធសាស្ត្រគំរូនិងវិធានការអនុវត្តន៍បច្ចុប្បន្នភាពថាមិនមែនកើតចេញពីទង្វើនោះទេប៉ុន្តែបណ្តាលមកពីកង្វះការឆ្លើយតបរបស់ស្ថាប័ន និងបុគ្គលចំពោះជនរងគ្រោះ។

| | | | | |
|---|---|---|---|---|
| សូចនាករបែប គុណភាព បែងចែក តាមអាយុ និងអថេរ សេដ្ឋកិច្ច -សង្គមផ្សេងទៀត (ប្រសិនបើអាច) | ការកើនឡើងនៃចំនួនករណីបញ្ជូនទៅអ្នកផ្តល់សេវាសំខាន់ៗ<br><br>% ជនរងគ្រោះដែលត្រូវប្រើប្រាស់សេវាអ្នកឯកទេសអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអាចរាយការណ៍ពីការបញ្ចប់ទាំងស្រុងនូវការរំលោភបំពានគ្រប់ប្រភេទ | ការថយចុះនៃអត្រាអាទ្រីត (attrition rate) បែងចែកតាមដំណាក់កាលនៃការបន្តផ្តល់យុត្តិធម៌ (ទំនាក់ទំនងដំបូង ការស៊ើបអង្កេត មុនពេលជំនុំជម្រះ ។ល។) | ការកើនឡើងនៃអត្រាជនរងគ្រោះដែលរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីទៅនគរបាល<br><br>ភាគរយនៃការថយចុះចំនួនបទល្មើសដដែលដែលប្រព្រឹត្តដោយជនបង្កម្នាក់ៗ | ចំនួនអង្គការសហគមន៍ដែលសហការជាមួយនគរបាលដើម្បីផ្តល់ព័ត៌មានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី<br><br>ចំនួនយុវជនដែលបានទទួលការយល់ដឹងពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីពីនគរបាលក្នុងសាលារៀន គ្រឹះស្ថានអប់រំផ្សេងទៀត និងសហគមន៍ |

គួរកត់សម្គាល់ថា ការវាស់វែងការអនុវត្តការងាររបស់នគរបាលមានភាពស្មុគស្មាញ និងពហុវិស័យ។ ដូច្នេះ មិនគួរចាត់ទុកសូចនាករដែលលើកឡើងក្នុងសៀវភៅណែនាំនេះថារៀបរាប់អស់សេចក្តីនោះទេ និងគួរពិចារណាពីសូចនាករមួយធៀបនឹងសូចនាករមួយទៀត ជាជាងពិចារណាពីសូចនាករដាច់ដោយឡែកពីគ្នា។

ក្រៅពីការតម្រូវឱ្យមានព័ត៌មានដើមគ្រាសម្រាប់វាស់វែងការអនុវត្តការងារ ប្រព័ន្ធប្រមូលទិន្នន័យរបស់នគរបាលត្រូវមានកត្តាកំណត់អត្តសញ្ញាណជនរងគ្រោះដោយឡែកមួយដើម្បីតាមដានបន្តលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី[452]។

**ទិន្នន័យដែលមិនត្រូវបានបែងចែកតាមភេទ និងកត្តាប្រជាសាស្ត្រផ្សេងទៀត មិនអាចផ្តល់ព័ត៌មានតំណាងបានឡើយ។**

ក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ប្រព័ន្ធប្រមូលទិន្នន័យរបស់នគរបាលដែលមានកត្តាកំណត់អត្តសញ្ញាណជនរងគ្រោះដោយឡែកមួយអាចពិនិត្យផលប៉ះពាល់នៃវិធានការការពារដែលកំពុងអនុវត្តដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក៏ដូចជាប្រេវ៉ាឡង់នៃការប្រព្រឹត្តបទល្មើសដដែលៗ។ ក្នុងន័យនេះ Rollings and Taylor (2008) ជឿថាការកត់សម្គាល់ជនល្មើសជាបន្តបន្ទាប់នឹងអាចឱ្យមានការវាស់វែងការប្រព្រឹត្តបទល្មើសដដែលៗបានសមស្របនិងការប្រៀបធៀបនឹងទិន្នន័យផ្សេងទៀត ដូចជា អត្រាអាទ្រីត (attrition rates) ឬការយល់ឃើញរបស់ស្ត្រី និងក្មេងស្រីចំពោះសេវានគរបាល[453]។

ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ នគរបាលសម្រាប់ការពិនិត្យតាមដានឥរិយាបថរបស់ជនបង្ក បទពិសោធន៍ថ្មីៗពីចក្រភពអង់គ្លេសស្នើឱ្យនគរបាលផ្តោតសំខាន់លើសូចនាករខាងក្រោម[454] ៖

- ការថយចុះនៃចំនួនជនបង្កអំពើហិង្សាលើដៃគូស្និទ្ធស្នាលជាច្រើននាក់។

452. ការវាស់វែងការអនុវត្តការងាររបស់នគរបាលក្នុងករណីអំពើហិង្សាក្នុងគ្រួសារ (២០០៨)។ Rollings, K. and Taylor, N. for Trends & issues in crime and criminal justice No. 367 December 2008. Australian Government. Australian Institute of Criminology.
453. Ibid
454. ដកស្រង់ចេញពី "គម្រោងវាយតម្លៃកត្តាជំរុញ ៖ ការអនុវត្តសាកល្បង ៣ ឆ្នាំដើម្បីលើកឡើងពីជនបង្កការរំលោភបំពានក្នុងគ្រួសារដែលមានហានិភ័យខ្ពស់ និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ" (មជ្ឈមណ្ឌលស្រាវជ្រាវយេនឌ័រ និងអំពើហិង្សា University of Bristol, 2019)

• ការថយចុះនៃចំនួនជនរងគ្រោះដដែលៗ និងជនរងគ្រោះថ្មី។
• ការថយចុះនៃកម្រិតគ្រោះថ្នាក់ចំពោះជនរងគ្រោះនិងកុមារ។
• ពេលវេលាឆ្លើយតបកាន់តែឆាប់រហ័សដើម្បីការពារសុវត្ថិភាពរបស់គ្រួសារដែលប្រឈមនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលមានហានិភ័យខ្ពស់ និងគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ប្រអប់ ២៣ (ខាងក្រោម) បង្ហាញការសិក្សាដើមគ្រាដ៏គួរឱ្យចាប់អារម្មណ៍មួយដែលធ្វើឡើងដោយរដ្ឋាភិបាល (ក្រសួងវិទ្យាសាស្ត្រសង្គម ប្រទេសអូស្ត្រាលី) ដែលផ្តោតលើឥរិយាបថរបស់ជនបង្កអំពើហិង្សាក្នុងគ្រួសារ។ ការសិក្សាដើមគ្រានេះបានផលិតកម្រងសូចនាករសម្រាប់ឱ្យនគរបាលប្រើប្រាស់ក្នុងការតាមដានឥរិយាបថរបស់ជនបង្ក។ទិន្នន័យដែលប្រមូលបាននឹងជួយដល់ការស៊ើបអង្កេតដែលផ្តោតលើជនបង្ក ដែលជាធាតុផ្សំដ៏សំខាន់មួយនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

**ប្រអប់ ១៣ ៖**

**ការប្រមូលព័ត៌មានសម្រាប់ជួយដល់ការស៊ើបអង្កេតដែលផ្តោតលើជនបង្ក**

ក្នុងប្រទេសអូស្ត្រាលីក្រសួងវិទ្យាសាស្ត្រសង្គមបានចេញផ្សាយរបាយការណ៍ដើមគ្រាសម្រាប់ឆ្នាំ២០១៥-២០១៦ ដែលមានចំណងជើងថា "ស្តង់ដារលទ្ធផលថ្នាក់ជាតិសម្រាប់អន្តរាគមន៍លើជនបង្ក (NOSPI)" សម្រាប់ពិនិត្យតាមដាន និងវាស់វែងលទ្ធផលនៃអន្តរាគមន៍ថ្នាក់ជាតិដែលផ្តោតសំខាន់លើឥរិយាបថ និងផ្លាស់ប្តូរអាកប្បកិរិយារបស់ជនបង្កអំពើហិង្សាក្នុងគ្រួសារ។

របាយការណ៍នេះផ្អែកលើការប្រមូលទិន្នន័យទូទាំងប្រទេស ស្តីពីការអនុវត្តការងារនៃប្រព័ន្ធតាមដានជនបង្ក ដែលរួមបញ្ចូលចំណុចសំខាន់នៃការទប់ស្កាត់តាមរយៈការរក្សាការទទួលខុសត្រូវរបស់ជនបង្ក និងការធានាថាពួកគេទទួលផលវិបាកពីអំពើហិង្សារបស់ខ្លួន ក៏ដូចជាការផ្តល់សេវាដល់ពួកគេដើម្បីផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ពួកគេ។ NOSPI បានប្រើប្រាស់ និងដាក់ស្នើកម្រងសូចនាករដែលនគរបាលអាចយកទៅប្រើប្រាស់ដើម្បីធានាថា ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីផ្អែកតាមព័ត៌មានត្រឹមត្រូវ។ សូចនាករទាំងនោះរួមមាន ៖

• %នៃឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍ដែលមានការវាយតម្លៃហានិភ័យរបស់ជនរងគ្រោះ។
• %នៃនគរបាលដែលរាយការណ៍ពីឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារដែលជនរងគ្រោះត្រូវបានបញ្ជូនទៅសេវា ឬកម្មវិធីសមស្របសម្រាប់ការវាយតម្លៃ។
• %នៃឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារដែលនគរបាលបានចេញដីកាអន្តរាគមន៍ករណីអំពើហិង្សាក្នុងគ្រួសារជំនួសមុខឱ្យជនរងគ្រោះ។
• % នៃជនរងគ្រោះដែលបានរាយការណ៍ពីការប្រទូស្តកេរខ្មាស ដែលត្រូវបានបញ្ជូនទៅសេវាអ្នកឯកទេសការប្រទូស្តកេរខ្មាស។
• % នៃការជូនដំណឹងអំពីការការពារកុមារដែលកត់ត្រាអំពើហិង្សាក្នុងគ្រួសារ ក្នុងការជូនដំណឹងនោះ។
• % នៃស្ត្រី (និងកូនៗ) ដែលយល់ថាមានសុវត្ថិភាពជាងមុន ក) នៅមុនពេល និង ខ) នៅពេល ឬនៅក្រោយពេលអនុវត្តអន្តរាគមន៍លើជនបង្ក។
• %នៃស្ត្រីទទួលរងអំពើហិង្សាក្នុងគ្រួសារ ដែលរងគ្រោះឡើងវិញដោយសារជនបង្កដដែលក្នុងរយៈពេល ១២ ខែ។
• % នៃកុមារទទួលរងអំពើហិង្សាក្នុងគ្រួសារ ដែលរងគ្រោះឡើងវិញ ក្នុងរយៈពេល ១២ ខែ។
• % នៃឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារ ដែលជនបង្កត្រូវបានបញ្ជូនទៅសេវា ឬកម្មវិធីសមស្រប សម្រាប់ការវាយតម្លៃ។
• %នៃអំពើហិង្សាក្នុងគ្រួសារឬឧប្បត្តិហេតុផ្លូវភេទដែលត្រូវបានរាយការណ៍ឬកត់ត្រាដោយនគរបាលដែលមានចេញបទចោទប្រកាន់ (ក្នុងករណីសមស្រប)។
• % នៃជនបង្កដែលប្រព្រឹត្តបទល្មើសជាលើកដំបូង។
• %នៃជនបង្កអំពើហិង្សាក្នុងគ្រួសារដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារឬបទល្មើសផ្លូវភេទថ្មីមួយក្នុងរយៈពេល ១២ ខែក្រោយការបញ្ចប់កម្មវិធីផ្លាស់ប្តូរឥរិយាបថ (ឬអន្តរាគមន៍ផ្សេងទៀតលើជនបង្ក)។

ប្រភព ៖ "របាយការណ៍ដើមគ្រាឆ្នាំ ២០១៥-២០១៦ ស្តីពីស្តង់ដារលទ្ធផលថ្នាក់ជាតិសម្រាប់អន្តរាគមន៍លើជនបង្ក (NOSPI)" ក្រសួងវិទ្យាសាស្ត្រសង្គមអូស្ត្រាលី។ សូមមើល ៖ https://plan4womenssafety.dss.gov.au/wpcontent/ uploads/2018 /08/nationaloutcomestandardsreportweb.pdf

## ការកំណត់ប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី

ការច្បាមយកទិន្នន័យស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាការលំបាកប៉ុន្តែគួរធ្វើឡើងព្រោះសកម្មភាពនេះទាមទារការអង្កេតសំណាកតំណាងរបស់ស្ត្រី និងក្មេងស្រីក្នុងស្ថិតិសកលណាមួយដើម្បីសាកសួរអំពីបទពិសោធន៍របស់ពួកគេស្តីពីការរងគ្រោះដោយអំពើហិង្សា។

សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាគោលគំនិតបែបស្ថិតិដែលសំដៅលើចំនួននៃការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបង្កជា ឬនឹងបង្កជាគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី ដូចជា ការគំរាមកំហែងប្រព្រឹត្ត ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានក្នុងជីវិតសាធារណៈ ឬជីវិតឯកជនឡើយ[455]។

ការអង្កេតផ្អែកតាមស្ថិតិសកលសម្រាប់ទិន្នន័យស្តីពីប្រេវ៉ាឡង់ (ប្រសិនបើធ្វើឡើងបានសមស្រប និងមានការពិចារណាពីគុណភាពនិងក្រមសីលធម៌)ជាប្រភពទិន្នន័យដ៏ល្អបំផុតសម្រាប់ការប៉ាន់ស្មានភាពទូទៅនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបង្ហាញពីវិសាលភាព ឬសគល់ និងផលវិបាកនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី [456]។

នៅពេលមានទិន្នន័យស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីអ្នកផ្តល់សេវាសំខាន់ៗរួមទាំងនគរបាលនឹងមានសូចនាករកាន់តែជាក់លាក់អំពីថាតើការខិតខំរបស់ពួកគេក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កផលប៉ះពាល់ទៅតាមការចង់បានឬទេ។ ទោះជាយ៉ាងណា ការប្រមូលទិន្នន័យស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនគួរជាកិច្ចការផ្តាច់មុខរបស់នគរបាលនោះទេព្រោះជាទូទៅនគរបាលមានតួនាទីត្រឹមតែរួមចំណែកផ្តល់ព័ត៌មាន ដូចជាចំនួនករណីដែលបានរាយការណ៍ទៅនគរបាល ការធ្វើចំណាត់ថ្នាក់បទល្មើស និង ( ជាធម្មតា ) អំពើហិង្សាផ្លូវកាយដែលបានប្រព្រឹត្ត។

ការអង្កេតស្ត្រីនិងក្មេងស្រី ( ជំទង់ ) ស្តីពីបទពិសោធន៍នៃការរងគ្រោះដោយអំពើហិង្សារបស់ពួកគេដែលរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមភាពញឹកញាប់ និងកាលៈទេសៈនៃអំពើហិង្សា ផលវិបាកលើសុខភាព និងសកម្មភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការស្វែងរកជំនួយ ជាវិធីដែលគិតគូរពីអារម្មណ៍បំផុត ដែលជាញឹកញាប់ទាមទារទំនុកចិត្តក្នុងការចែករំលែក[457]។ ទំនុកចិត្តជាធាតុផ្សំដ៏សំខាន់ដែលមិនមែនស្ត្រី និងក្មេងស្រីសុទ្ធតែអាចពឹងផ្អែកលើស្ថាប័ននគរបាលទាំងអស់បាននោះទេ ជាពិសេសប្រសិនបើពួកគេមកពីសហគមន៍ក្រុមភាគតិច និង/ឬសហគមន៍ដែលមិនទទួលបានការយកចិត្តទុកដាក់។ ដូច្នេះ ការប្រមូលទិន្នន័យស្តីពីប្រេវ៉ាឡង់ទាមទារនូវអភិក្រមគ្រប់ជ្រុងជ្រោយដែលពាក់ព័ន្ធនឹងស្ថាប័នរដ្ឋាភិបាលនិងដៃគូសហការជាច្រើន។




ការធានាការច្បាមយកភាពញឹកញាប់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីសម្រាប់ជនរងគ្រោះម្នាក់ៗក្នុងការអង្កេតទាំងនេះមានសារៈសំខាន់ណាស់ព្រោះវាអាចបំពេញចំណុចខ្វះខាតក្នុងប្រព័ន្ធទិន្នន័យរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

"គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ការផលិតស្ថិតិស្តីពីអំពើហិង្សាលើស្ត្រី" (២០១៤) លើកឡើងថា ជាទូទៅទិន្នន័យនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមិនតំណាងឱ្យករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីទាំងអស់ដែលកើតឡើងនោះទេ ព្រោះជនរងគ្រោះហាក់ស្វែងរកជំនួយពីនគរបាល តែក្នុងករណីជម្រើសចុងក្រោយ និងបន្ទាប់ពីយុទ្ធសាស្ត្រផ្សេងទៀតសម្រាប់ការបញ្ឈប់អំពើហិង្សា ទទួលបរាជ័យ[458]។ គោលការណ៍ណែនាំនេះបន្ថែមទៀតថាបញ្ហានេះក៏បណ្តាលមកពីការរាយការណ៍ពីចំនួនករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក្រោមចំនួនករណីពិតប្រាកដផងដែរ។

---

455. អំពើហិង្សាលើស្ត្រីនិងក្មេងស្រីរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមអំពើហិង្សាផ្លូវកាយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្លូវចិត្តដែលកើតឡើងក្នុងគ្រួសារ ក្នុងសហគមន៍ទូទៅ និងបង្កឡើង ឬបណ្តែតបណ្តោយដោយរដ្ឋ។សូមមើលសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (សេចក្តីសម្រេចលេខ ៤៨/១០៤ របស់មហាសន្និបាត ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣)
456. គោលការណ៍ណែនាំសម្រាប់ការផលិតស្ថិតិស្តីពីអំពើហិង្សាលើស្ត្រី ៖ ការអង្កេតបែបស្ថិតិ (អង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក នាយកដ្ឋានសេដ្ឋកិច្ច និងសង្គមកិច្ចផ្នែកស្ថិតិ២០១៤)
457. Ibid
458. Ibid

ទោះជាយ៉ាងណា ស្ថាប័ននគរបាលនៅតែព្យាយាមកំណត់ប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការវាស់វែងចំនួនឧប្បត្តិហេតុដែលបានរាយការណ៍ទៅនគរបាល ដែលនេះជារង្វាស់ដ៏ងាយស្រួល ព្រោះឯកតានៃកំណត់ត្រាគឺឧប្បត្តិហេតុឬករណីមួយដែលបានរាយការណ៍ ជាជាងជនដែលរងគ្រោះ (ស្ត្រី ឬក្មេងស្រី)[459]។

សូចនាករនេះមិនត្រឹមតែមិនពិពណ៌នាពេញលេញអំពីកម្រិត ភាពធ្ងន់ធ្ងរ និងគំរូនៃអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពឹងផ្អែកយ៉ាងខ្លាំងលើកម្រិតនៃគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍ឧប្បត្តិហេតុរបស់នគរបាលទៀតផង។ ចំណុចនេះ កាន់តែស្មុគស្មាញដោយសារតែជាញឹកញាប់មិនសូវមានស្ថិតិរបស់តុលាការព្រោះនគរបាល និងអយ្យការច្រើនតែប្រើប្រាស់ឆន្ទានុសិទ្ធិផ្ទាល់ខ្លួនក្នុងការមិនបន្តនីតិវិធីលើករណីទាំងនេះ ហើយជាញឹកញាប់ទិន្នន័យរបស់នគរបាលមិនផ្សារភ្ជាប់នឹងប្រព័ន្ធប្រមូលទិន្នន័យរបស់តុលាការ[460]។

នគរបាលគួរផ្តោតលើការកាត់បន្ថយចំណុចខ្វះខាតរវាងការប៉ាន់ស្មានប្រេវ៉ាឡង់ និងករណីដែលបានរាយការណ៍។ ដូច្នេះ ស្ថាប័ននគរបាលគួរបង្កើតទំនាក់ទំនងការងារជាមួយអង្គការសង្គមស៊ីវិល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតដើម្បីលើកកម្ពស់អភិក្រមទូទាំងរដ្ឋាភិបាលក្នុងការសិក្សាពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្រៅពីនេះ ការសិក្សាពីប្រេវ៉ាឡង់អាចទាញប្រយោជន៍ពីការស្រាវជ្រាវទូលំទូលាយដែលផ្តោតសំខាន់លើឥរិយាបថក្នុងសង្គមចំពោះបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី (ការរាយការណ៍ ការស្តីបន្ទោសជនរងគ្រោះ ការអត់អោនការហាមឃាត់ ភាពស្ងៀមស្ងាត់)។ នគរបាលអាចជាដៃគូដ៏សំខាន់ក្នុងការផ្តល់ព័ត៌មានដល់ការសិក្សាទាំងនេះ និងទទួលបានអត្ថប្រយោជន៍ផ្នែកប្រតិបត្តិការសម្រាប់ការជានាលទ្ធផល។ ឧ. ការស្រាវជ្រាវទូលំទូលាយដែលផ្តោតលើឥរិយាបថក្នុងសង្គមរួមទាំងឥរិយាបថរបស់នគរបាលចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចពង្រឹងការវិភាគ និងការផ្សព្វផ្សាយទិន្នន័យបែបបរិមាណនិងទិន្នន័យបែបគុណភាពស្តីពីទម្រង់ធ្ងន់ធ្ងរនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា ការសម្លាប់ស្ត្រីដែលពាក់ព័ន្ធនឹងយេនឌ័រ ឬការសម្លាប់ទារិកាក្នុងផ្ទៃ ដែលនឹងផ្តល់មូលដ្ឋានព័ត៌មានដល់វិធីសាស្ត្រវាយតម្លៃហានិភ័យអំពើហិង្សាលើដៃគូស្និទ្ធស្នាលវិធានការការពារនិងវិធានការសុវត្ថិភាពរបស់នគរបាល និងយុទ្ធសាស្ត្រទប់ស្កាត់។

ប៉ុន្តែដើម្បីឱ្យមានភាពគ្រប់គ្រាន់ការសិក្សាពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវរួមបញ្ចូលសូចនាករនានា ដូចជា អាយុ ដើម្បីកំណើតជាតិសាសន៍ និងដើមកំណើតជាតិពន្ធុ ប្រវត្តិប្រព្រឹត្តបទល្មើសរបស់ជនបង្កទំនាក់ទំនងរវាងជនរងគ្រោះ និងជនបង្ករបៀបប្រតិបត្តិការបរិបទនិងដើមហេតុក៏ដូចជាការប្រុងប្រយ័ត្នក្នុងការដាក់បញ្ចូលរបាយការណ៍ស្តីពីអំពើហិង្សាក្នុងតំបន់ជនបទនិងតំបន់ជួបការលំបាក និងស្ថានភាពរបស់ក្រុមស្ត្រី និងជនរងគ្រោះមួយចំនួន[461]។ ការចូលរួមក្នុងការសិក្សាទាំងនេះក្រោមកិច្ចសហការជាមួយអ្នកពាក់ព័ន្ធខាងក្រៅ នឹងផ្តល់មូលដ្ឋានដល់នគរបាលក្នុងការកសាងភាពជាដៃគូយុទ្ធសាស្ត្រ ក៏ដូចជាចាត់វិធានការឆ្ពោះទៅរកភាពម្ចាស់ការលើបញ្ហា។

## ការពិនិត្យតាមដាននិងការវាយតម្លៃប្រសិទ្ធភាពនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ

### ការពិនិត្យតាមដានផលប៉ះពាល់

របៀបដែលស្ថាប័ននគរបាលវាស់វែងការអនុវត្តការងាររបស់ខ្លួន និងរបៀបដែលថ្នាក់ដឹកនាំនគរបាលរក្សាការទទួលខុសត្រូវរបស់បុគ្គលិកលើការផ្តល់សេវាធៀបនឹងអាទិភាពនិងគោលដៅពាក់ព័ន្ធជាធាតុផ្សំសំខាន់ៗដែលតម្រង់ទិសការងារប្រចាំថ្ងៃរបស់នគរបាល។

យោងតាមUNODC (2014) ការជានាការអនុវត្តអាទិភាពនៃសេវានគរបាលប្រកបដោយប្រសិទ្ធភាពទាមទារការត្រួតពិនិត្យ ការពិនិត្យតាមដាន និងការវាយតម្លៃ។

459. Ibid
460. Ibid and see: V. Jaquier, H. Johnson and B.S. Fisher, 'Research methods, measures and ethics', in Sourcebooks on Violence against Women, 2nd ed., C.M. Renzetti, J.L. Edleson and R.K. Bergen, eds. (SAGE Publications, 2010).
461. អនុសាសន៍សម្រាប់ការចាត់វិធានការលើការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ (UNODC and UN Women, 2015).

សកម្មភាពដែលមានប្រសិទ្ធភាពទាមទារនូវទិន្នន័យយ៉ាងសុក្រឹតស្តីពីវិសាលភាពនិងផលប៉ះពាល់នៃបទល្មើសនិងអំពើហិង្សា និងប្រសិទ្ធភាពរបស់នគរបាលក្នុងការធានាការទទួលខុសត្រូវរបស់ជនបង្ក និងការបំពេញតម្រូវការរបស់ប្រជាជន[462]។ UNODC បន្ថែមទៀតថា ការអភិវឌ្ឍយន្តការពិនិត្យតាមដាននិងត្រួតពិនិត្យផ្ទៃក្នុងលើនគរបាល ក៏ដូចជាការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរផ្អែកតាមគោលការណ៍តម្លាភាព និងគណនេយ្យភាពចំពោះជនរងគ្រោះ។

**ភាពប្រទាក់ក្រឡាគ្នា រាប់បញ្ចូលថាតើស្ត្រី និងក្មេងស្រីប្រឈមនឹងអំពើហិង្សាតាមរបៀបខុសគ្នាដូចម្តេចនិងថាតើពួកគេរងគ្រោះដោយបទល្មើសដោយរបៀបណា។**

ដូចការលើកឡើងពីខាងដើម ការពិនិត្យតាមដានការអនុវត្តការងាររបស់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ទាមទារនូវទិន្នន័យដើមគ្រាដើម្បីវាស់វែងផលប៉ះពាល់ ក៏ដូចជាភាព រីកចម្រើន និងការអភិវឌ្ឍរបស់ស្ថាប័ន។ នៅពេលមានទិន្នន័យដើមគ្រាដែលផ្អែកតាមព័ត៌មានត្រឹមត្រូវស្ថាប័ននគរបាលអាចចាប់ផ្តើមពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីធានាសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រកាន់តែសុក្រឹតដើម្បីបន្សីទៅនឹងកាតព្វកិច្ចរដ្ឋ ដូចជា របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតសំខាន់លើការសម្រេចបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីគ្រប់រូប ដោយវិស័យទាំងអស់របស់រដ្ឋ រួមទាំងនគរបាល[463]។

ការដាក់បញ្ចូលទស្សនៈយេនឌ័រនឹងជួយដល់ការតាក់តែងគោលនយោបាយ និង យុទ្ធសាស្ត្រ ផ្លាស់ប្តូរដែលឆ្លើយតបនឹងយេនឌ័ររួមទាំងប្រព័ន្ធពិនិត្យតាមដានដែលអមមកជាមួយដំណើរការនេះ។



ប្រព័ន្ធពិនិត្យតាមដាន សំដៅលើមុខងារបន្តជាប់ដែលមានគោលបំណងផ្តល់យោបល់ ត្រឡប់ និងការគូសបញ្ជាក់ទាន់ពេលវេលាអំពីវឌ្ឍនភាព ឬចំណុចខ្វះខាតក្នុងការសម្រេចបានលទ្ធផលរំពឹងទុកដល់អ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធសំខាន់ៗ [464]។ ក្រៅពីនេះ ការពិនិត្យតាមដានរួមបញ្ចូលការប្រមូល និងវិភាគទិន្នន័យ ដែលគិតគូរពីយេនឌ័រ និងប្រទាក់ក្រឡាគ្នា ស្តីពីដំណើរការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ និងការដាក់វិធានការកែតម្រូវ[465]។

ការពិនិត្យតាមដានយោបល់ត្រឡប់និងវិធានការកែតម្រូវដែលស្នើឡើងគួរពិចារណាពីការពិនិត្យឡើងវិញលើថវិកាដែលគិតគូរពីយេនឌ័រជានិច្ច។ ក្នុងន័យនេះ ឧបករណ៍ទី ១៥ របស់ DCAF (ការដាក់បញ្ចូលយេនឌ័រក្នុងការរៀបចំ និងត្រួតពិនិត្យគម្រោងសម្រាប់វិស័យសន្តិសុខ និងយុត្តិធម៌-២០១៩) ស្នើឱ្យសួរសំណួរសំខាន់ៗដូចតទៅ ៖ ក្នុងការបែងចែកធនធានហិរញ្ញវត្ថុនិងសម្ភារដល់ក្រុមស្ត្រី ក្រុមក្មេងស្រី ក្រុមបុរស និងក្រុមក្មេងប្រុសផ្សេងៗក្នុងគម្រោង តើថវិកានោះពង្រឹងសមភាពយេនឌ័រ ឬទេ?

- តើមានការកំណត់ចំណុចដៅនៃជំនួយមូលនិធិសម្រាប់ការងារសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី ឬទេ?
- តើថវិកានោះអាចជំរុញឱ្យមានវិសមភាព ឬទេ?
- តើថវិកានោះត្រូវបានរៀបចំឡើងតាមរបៀបដែលអាចឱ្យក្រុមស្ត្រី ក្រុមបុរស ក្រុមក្មេងប្រុស និងក្រុមក្មេងស្រីរួមចំណែកនិងទទួលបានអត្ថប្រយោជន៍ពីគម្រោងឬទេ?

ជាទូទៅប្រព័ន្ធពិនិត្យតាមដានគួរដាក់បញ្ចូលការផ្តល់មតិត្រឡប់ជាប្រចាំ និងមានប្រសិទ្ធភាពចំណាយ ដើម្បីបំផុសការរៀនសូត្រជាហូហែ។សម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា អង្គការសិទ្ធិស្ត្រី និងដៃគូផ្សេងទៀតនៅកម្រិតសហគមន៍ ក្នុងដំណើរការរៀនសូត្រក្នុងស្ថាប័ន នឹងពង្រឹង និងទទួលស្គាល់សំឡេង និងចំណេះដឹងរបស់ស្ត្រី ក៏ដូចជាផ្តល់សុពលភាពដល់បទពិសោធន៍របស់ស្ត្រី និងលុបបំបាត់វប្បធម៌ស្ងៀមស្ងាត់ជុំវិញអំពើហិង្សាលើស្ត្រី និងក្មេងស្រី[466]។

462. សៀវភៅណែនាំស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នអយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី (UN Women, UNODC 2014)។
463. សូមមើល "ការដាក់បញ្ចូលយេនឌ័រក្នុងការរៀបចំ និងត្រួតពិនិត្យគម្រោងសម្រាប់វិស័យសន្តិសុខ និងយុត្តិធម៌" ឧបករណ៍ទី ១៥ ៖ ឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ (DCAF, OSCE/ODIHR and UN Women, 2019).

ក្រៅពីនេះ ទំនុកចិត្តរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីចំពោះអ្នកពាក់ព័ន្ធខាងក្រៅដូចជាអង្គការសិទ្ធិស្ត្រីអាចជួយបង្កើនគុណភាពនៃព័ត៌មានដែលទទួលបានសម្រាប់ការរៀនសូត្រក្នុងស្ថាប័ន។ ដូចការលើកឡើងខាងលើ ការជំរុញការចូលរួមរបស់អង្គការសិទ្ធិស្ត្រីនឹងជួយដល់ការអង្កេតដែលវាស់ស្ទង់ការពេញចិត្តរបស់ជនរងគ្រោះ ក្រោយការរាយការណ៍ទៅនគរបាល។ឧ.អង្គការសិទ្ធិស្ត្រីនឹងបង្កើនទំនុកចិត្តរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងអាចច្បាមយកទិន្នន័យបែបគុណភាពបានល្អជាងនគរបាល។



ការអង្កេតជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីស្តីពីការពេញចិត្តលើសេវា នឹងផ្តល់សូចនាករដ៏សំខាន់មួយសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ប៉ុន្តែគួរធ្វើឡើងដោយមានការធានាសុវត្ថិភាពសមស្របដើម្បីកុំឱ្យមានគ្រោះថ្នាក់ណាមួយ[467]។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការបង្កើតប្រព័ន្ធពិនិត្យតាមដានដែលឆ្លើយតបនឹងយេនឌ័រសៀវភៅណែនាំនេះសូមលើកយកឯកសារខាងក្រោមដែលផលិតដោយ DCAF ដែលមានមូលដ្ឋាននៅហ្សឺណែវ ៖

- ឧបករណ៍ទី ១១ ៖ ការវាយតម្លៃកំណែទម្រង់វិស័យសន្តិសុខ ការពិនិត្យតាមដាន និងវាយតម្លៃ និងយេនឌ័រ (២០០៨)នៃឯកសារជំនួយស្មារតីស្តីពីយេនឌ័រនិងSSR។
- ឧបករណ៍ទី ១៥៖ ការដាក់បញ្ចូលយេនឌ័រក្នុងការរៀបចំ និងត្រួតពិនិត្យគម្រោងសម្រាប់វិស័យសន្តិសុខ និងយុត្តិធម៌ (២០១៩) នៃឯកសារជំនួយស្មារតីស្តីពីយេនឌ័រ និងសន្តិសុខ។

រូប ៣៖

**សមត្ថភាពដែលគិតគូរពីយេនឌ័រ ៖ គន្លឹះក្នុងការផ្លាស់ប្តូរ**




ដូចការពិភាក្សាក្នុងសៀវភៅណែនាំនេះគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ ផ្អែកលើការអនុវត្តចំណេះដឹងជំនាញនិងឥរិយាបថដែលគិតគូរពីយេនឌ័រឬសមត្ថភាពដែលគិតគូរពីយេនឌ័រដែលអាចបង្កើនភាពអង់អាចរបស់ជនទន់ខ្សោយ និងកសាងទំនុកចិត្ត និងទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធចម្រុះដោយគោរពគោលការណ៍មិនរើសអើង និង "មិនបង្កគ្រោះថ្នាក់" ក្នុងដំណើរការនេះ។វិធានការគណនេយ្យភាពដើម្បីធានាការអនុលោមតាមក្រមប្រតិបត្តិក្នុងស្ថាប័នដើម្បីធានាសុចរិតភាពរបស់នគរបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាភាពម្ចាស់ការ និងភាពធន់នៃសមត្ថភាពដែលចាំបាច់សម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

សមាសធាតុទាំង ៣ នេះពាក់ព័ន្ធគ្នា និងពង្រឹងឱ្យគ្នាទៅវិញទៅមកក្នុងការអនុវត្ត ក៏ដូចជាក្នុងការអនុលោមតាម និងលទ្ធផលនៃការអនុវត្តការងារ (រូប ៣)។ ផ្នែកខាងក្រោមផ្តោតសំខាន់លើការពិនិត្យតាមដាន និងវាយតម្លៃ (M&E) ការអនុវត្តការងារសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

ផ្នែកនេះ នឹងមិនពិភាក្សាលម្អិតពីវិធានការគណនេយ្យភាពសម្រាប់ការអនុលោមតាមក្រមប្រតិបត្តិដើម្បីធានាសុចរិតភាពរបស់នគរបាលនោះទេព្រោះប្រធានបទនេះមិនស្ថិតក្នុងវិសាលភាពនៃសៀវភៅណែនាំនេះ។ទោះជា

464. Nicola Popovic. 'Security Sector Reform Assessment, Monitoring and Evaluation and Gender' in Gender and Security Sector Reform Toolkit., Eds. Megan Bastick and Kristin Valasek (Geneva: DCAF, OSCE/ODIHR, UN-INSTRAW, 2008).
465. Ibid
466. "សេចក្តីណែនាំស្តីពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការរៀបចំកម្មវិធីស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី" (សេចក្តីណែនាំទី ៣, ក្រសួងអភិវឌ្ឍអន្តរជាតិ-DFID ឯកសារអនុវត្តន៍)
467. អនុសាសន៍ដកស្រង់ចេញពី"កិច្ចការរបស់មនុស្សគ្រប់រូប៖ ការកែលម្អការឆ្លើយតបរបស់នគរបាលទៅនឹងការរំលោភបំពានក្នុងគ្រួសារ" (អធិការដ្ឋាននៃនគរបាលមហាក្សត្រី – HMIC - 2014)។

យ៉ាងណា អនុសាសន៍សំខាន់ៗពាក់ព័ន្ធនឹងវិធានការគណនេយ្យភាពសម្រាប់ការអនុលោមតាមក្រមប្រតិបត្តិ ដើម្បីធានាសុចរិតភាពរបស់នគរបាល ត្រូវបានលើកឡើងក្នុងផ្នែកមុនៗ។

ក្នុងការធានាស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ គួរពិនិត្យតាមដានសមត្ថភាពដែលគិតគូរពីយេនឌ័រដើម្បីធានាការអនុវត្តស៊ីសង្វាក់គ្នាក្នុងស្ថាប័ន។អ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងជួរនគរបាលគួរផ្តល់ប្រព័ន្ធវាយតម្លៃការអនុវត្តការងាររួមមួយដែលដាក់បញ្ចូលការអនុវត្តសមត្ថភាពដែលគិតគូរពីយេនឌ័រ ដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាល។

គួរចាត់ទុកការវាយតម្លៃការអនុវត្តការងារជាឧបករណ៍រៀនសូត្រ មិនមែនត្រឹមតែជាមធ្យោបាយសម្រាប់ធានាគណនេយ្យភាពនោះទេ។ ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងជួរនគរបាល គួរលើកទឹកចិត្តឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្តាលពង្រឹងសមត្ថភាពដែលបានរៀនសូត្រ ដើម្បីធានាសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

៤. ប្រធានក្រុមអាចរៀបចំការប្រជុំពិភាក្សាពេញលេញក្រោយការស៊ើបអង្កេត ស្តីពីការស៊ើបអង្កេតដែលទទួលបានជោគជ័យ និងការស៊ើបអង្កេតដែលបរាជ័យ។ ការប្រជុំពិភាក្សានេះគួររួមបញ្ចូលសមាជិកទាំងអស់ដែលពាក់ព័ន្ធក្នុងករណីនេះ ចាប់ពីនគរបាលឆ្លើយតបដំបូងរហូតដល់អ្នកស៊ើបអង្កេត ឬអធិការ និងមន្ត្រីត្រួតពិនិត្យ។ ការប្រជុំពិភាក្សាអាចរួមបញ្ចូលការពិនិត្យឡើងវិញតាមលំដាប់លំដោយលើការចូលរួមរបស់មន្ត្រីឆ្លើយតបម្នាក់ៗ ដោយយោងតាមសមត្ថភាពដែលគិតគូរពីយេនឌ័រដើម្បីពិភាក្សាពីចំណុចសកម្ម និងចំណុចត្រូវកែលម្អនៅពេលក្រោយបូករួមនឹងរបាយការណ៍ក្រោយពេលបញ្ចប់សកម្មភាពដែលអាចជាវិធីសាស្ត្រដ៏ល្អបំផុតសម្រាប់ការរៀនសូត្រ និងភាពរីកចម្រើនក្នុងក្រុម និងអង្គភាព។ អាស្រ័យលើស្ថាប័ននគរបាលនីមួយៗ គេអាចដាក់បញ្ចូលមន្ត្រីគ្រប់គ្រងថ្នាក់កណ្តាលរហូតដល់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់ក្នុងការប្រជុំពិភាក្សានេះដើម្បីផ្តល់ធាតុចូលនៅកម្រិតយុទ្ធសាស្ត្រ។

ការវាយតម្លៃការអនុវត្តការងារដែលរួមបញ្ចូលសមត្ថភាពដែលគិតគូរពីយេនឌ័រ គួរបញ្ជាក់ពីប្រភេទយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជារបៀបអនុវត្ត និងមូលហេតុ។ ទន្ទឹមនឹងនេះ ការពិនិត្យតាមដានសមត្ថភាពទាំងនេះនឹងជួយកំណត់រកឧបសគ្គដែលបន្តលេចឡើង និងរឹតត្បិតផលប៉ះពាល់នៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីអាចធ្វើការកែតម្រូវទាន់ពេលវេលា។

ឧបសគ្គដែលរកឃើញ អាចពាក់ព័ន្ធផ្ទាល់នឹងចំណុចខ្វះខាតក្នុងវិធានការគណនេយ្យភាពរបស់ស្ថាប័ន ដែលមានគោលបំណងធានាក្រមប្រតិបត្តិរបស់នគរបាល រួមទាំងគោលនយោបាយ "មិនអត់អោន"។ អ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរចាត់ទុកការអនុវត្តនូវសមត្ថភាពដែលគិតគូរពីយេនឌ័រដែលមិនស៊ីសង្វាក់គ្នា គឺជាសញ្ញានៃបញ្ហាជ្រាលជ្រៅក្នុងស្ថាប័ននគរបាល។បញ្ហាទាំងនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមការលំបាកក្នុងការបណ្តុះវប្បធម៌គណនេយ្យភាព ការដឹកនាំដែលគ្មានប្រសិទ្ធភាព និងការបណ្តុះបណ្តាល និងការអប់រំនគរបាលដែលមិនលើកឡើងពីគោលការណ៍សមភាពយេនឌ័រឱ្យបានគ្រប់ជ្រុងជ្រោយ។

ដូច្នេះវិធានការកែតម្រូវគួរផ្តោតសំខាន់លើបញ្ហាប្រឈមទាំង ៣ នេះក្នុងសេវានគរបាល ដើម្បីធ្វើការកែលម្អជារួមលើការអនុវត្តសមត្ថភាពដែលគិតគូរពីយេនឌ័រ។ ការត្រួតពិនិត្យហ្មត់ចត់លើសមត្ថភាពដែលគិតគូរពីយេនឌ័រ មិនត្រឹមត្រូវជួយជំរុញការផ្លាស់ប្តូរទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយទប់ស្កាត់ការមិនពេញចិត្តចំពោះនគរបាលទៀតផង ជាពិសេសភ្នាក់ងារឆ្លើយតបដំបូងដែលភាពអសកម្មរបស់ពួកគេអាចមានន័យស្មើនឹងការរំលោភសិទ្ធិមនុស្ស។

ការងាររបស់នគរបាលជាការងារក្រុម។ដូច្នេះការវាយតម្លៃការអនុវត្តការងាររបស់បុគ្គល និងប្រព័ន្ធពិនិត្យតាមដានគួរផ្សារភ្ជាប់នឹងការសម្រេចបានគោលដៅរួមដូចខាងក្រោម៖

- ការកាត់បន្ថយចំណុចខ្វះខាតរវាងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងចំនួនករណីដែលបានរាយការណ៍។
- ការបង្កើនការយល់ឃើញរបស់ជនរងគ្រោះដោយសារ

អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងសហគមន៍របស់ពួកគេថានគរបាលជាអ្នកផ្តល់សេវាសំខាន់ៗដែលស្របច្បាប់។ ទោះជាយ៉ាងណា គោលដៅទាំងនេះត្រូវការសូចនាករដែលឆ្លុះបញ្ចាំងពីសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រជាពិសេសសមត្ថភាពចាំបាច់របស់មន្ត្រីនគរបាល។ ល្អបំផុត មេប៉ុស្តិ៍គួរមានទិន្នន័យដើមគ្រាក្នុងមូលដ្ឋានស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីវាស់វែងធៀបនឹងនិន្នាការក្នុងឯកសាររាយការណ៍នៅតាមប៉ុស្តិ៍ប្រចាំការរបស់ខ្លួន។

ការមានព័ត៌មានទាំងនេះដែលគាំទ្រដោយសូចនាករសេវានគរបាល ដែលឆ្លើយតបនឹងយេនឌ័រ នឹងបញ្ជាក់ថាតើមន្ត្រីឆ្លើយតបបានអនុវត្តសមត្ថភាពដែលគិតគូរពីយេនឌ័របានស៊ីសង្វាក់គ្នាឬទេ។ តារាងខាងក្រោម (ប្រអប់២៤) ផ្តល់ឧទាហរណ៍ពីប្រភេទសមត្ថភាពដែលគិតគូរពីយេនឌ័រដែលជាមូលដ្ឋានសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ និងអាចយកជាសំអាងក្នុងការវាយតម្លៃការអនុវត្តការងារ។

**ប្រអប់ ១៤**

| សមត្ថភាពដែលគិតគូរពីយេនឌ័រ | | | សូចនាករសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ | |
|---|---|---|---|---|
| **ចំណេះដឹងស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី** | **ជំនាញ** | **ឥរិយាបថ** | **សូចនាករបែបគុណភាព** | **សូចនាករបែបបរិមាណ** |
| ផលវិបាកផ្នែកសង្គម និងសេដ្ឋកិច្ច | ការកសាងភាពជាដៃគូ | ផ្តោតលើការទប់ស្កាត់ | ស្ត្រី និងក្មេងស្រីកាន់តែច្រើនយល់ថាមានសន្តិសុខក្នុងមូលដ្ឋាន | ការចូលរួមកាន់តែច្រើនរបស់អ្នកពាក់ព័ន្ធក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី (គម្រោង វេទិកា...) |
| ផលវិបាកផ្នែកវេជ្ជសាស្ត្រ ឬសុខភាព | ផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត | មិនបង្កគ្រោះថ្នាក់ | ជនរងគ្រោះ និង/ឬក្រុមគ្រួសាររាយការណ៍ថាមិនសូវប្រឈមនឹងការរងគ្រោះជាលើកទីពីរ | ការថយចុះការមិនពេញចិត្តចំពោះនគរបាលឆ្លើយតបបឋម |
| ភាពធ្ងន់ធ្ងរនៃអំពើហិង្សាដែលប្រឈមដោយស្ត្រី និងក្មេងស្រី | ការកំណត់អត្តសញ្ញាណជនរងគ្រោះ | ប្រតិសកម្មនិងឈ្លាសវៃក្នុងការចូលរួមជាមួយអ្នកផ្តល់សេវាសំខាន់ៗ | ដៃគូផ្តល់សេវាសំខាន់ៗកាន់តែច្រើនយល់ថានគរបាលធ្វើការមានប្រសិទ្ធភាព | ការបញ្ជូនកាន់តែច្រើន |
| ប្រជាជន ក្រុមនិងសហគមន៍ដែលគេចាត់ទុកថាងាយរងគ្រោះបំផុត | ទំនាក់ទំនងអន្តរបុគ្គល | មិនវិនិច្ឆ័យ និងដឹងពីភាពលម្អៀងអវិជ្ជមាន | ក្រុមស្ត្រី និងក្មេងស្រីភាគតិច មានការទំនុកចិត្តកាន់តែខ្លាំងលើនគរបាល | ការថយចុះអត្រារងគ្រោះរបស់ក្រុមស្ត្រី និងក្មេងស្រីភាគតិច |
| ច្បាប់ និងនីតិវិធីជាតិ | ការកំណត់អាទិភាពនៃការស៊ើបអង្កេត/អន្តរាគមន៍ឱ្យផ្តោតលើជនបង្ក | ផ្តោតសំខាន់លើការបង្កើនភាពអង់អាចនិងកិច្ចសហប្រតិបត្តិការរបស់ជនរងគ្រោះ | យោបល់ត្រឡប់របស់ជនរងគ្រោះ និង/ឬក្រុមគ្រួសារបញ្ជាក់ពីការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេ | ការថយចុះអត្រាអាទ្រីត ( attrition rate ) |

| | | | | |
|---|---|---|---|---|
| ស្តង់ដារគោលការណ៍ និងបទដ្ឋានអន្តរជាតិ | ការគ្រប់គ្រងករណី រួមទាំងការគ្រប់គ្រងភស្តុតាង និងកំណត់ត្រាអន្តរាគមន៍ | មានគណនេយ្យភាព និងតម្លាភាព | របាយការណ៍របស់នគរបាលមានគុណភាពល្អ និងត្រូវបានចាត់ទុកថាអាចជឿទុកចិត្តបានសម្រាប់ការប្រមូលទិន្នន័យ | ការថយចុះចំនួនករណីដែលជនបង្កប្រព្រឹត្តបទល្មើសជាថ្មី |

ក្នុងករណីមួយចំនួនដូចជានៅចក្រភពអង់គ្លេស មានការជំរុញឱ្យដាក់បញ្ចូលសូចនាករសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ក្នុងការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់ផ្នែក អង្គភាព និងនាយកដ្ឋាននីមួយៗ[468]។ ពាក់ព័ន្ធនឹងសមត្ថភាពនិងគុណតម្លៃ មហាវិទ្យាល័យសេវានគរបាលនៃចក្រភពអង់គ្លេស ផ្អែកតាមក្របខណ្ឌសមត្ថភាព និងគុណតម្លៃ (CVF)។ ក្របខណ្ឌនេះមានគោលបំណងជានាថាមានការរំពឹងទុកច្បាស់លាស់លើអ្នកពាក់ព័ន្ធគ្រប់រូបក្នុងសេវានគរបាល ដែលនាំទៅរកការបង្កើនស្តង់ដារដើម្បីផ្តល់អត្ថប្រយោជន៍ និង សុវត្ថិភាពដល់សាធារណជន[469]។

សមត្ថភាពដ៏សំខាន់មួយសម្រាប់សេវានគរបាលក្នុងក្របខណ្ឌនេះ គឺ "ការយល់ពីអារម្មណ៍"។ មហាវិទ្យាល័យសេវានគរបាលនៃចក្រភពអង់គ្លេស បានកំណត់ពីសារៈសំខាន់នៃនគរបាលដែលមានសមានចិត្តជាពិសេសប្រសិនបើនគរបាលត្រូវពាក់ព័ន្ធ និងចូលរួមជាមួយជនងាយរងគ្រោះបំផុត ព្រោះយើងប្រឈមនឹងបុគ្គលដែលអាចមិនបង្ហាញ ឬស្តែងគំនិត ឬអារម្មណ៍របស់ខ្លួនឱ្យបានពេញលេញ។ខាងក្រោមនេះ(ប្រអប់២៥)ជាកម្រិតនៃការយល់ពីអារម្មណ៍ដែលកំណត់ក្នុងក្របខណ្ឌសមត្ថភាព និងគុណតម្លៃ (CVF)។

នៅ British Columbia ប្រទេសកាណាដា រដ្ឋាភិបាលតាមបណ្តាខេត្ត ឬសេវាសាធារណៈ បានដាក់ចេញនូវសមត្ថភាពផ្នែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិច នៅឆ្នាំ ២០១២ ដើម្បីជួយកែលម្អសមត្ថភាពផ្ទាល់ខ្លួន និងសមត្ថភាពជារួមរបស់ពួកគេក្នុងការធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយជនជាតិដើមភាគតិចក្នុងខេត្តនេះ[471]។ ក្នុងចំណោមសមត្ថភាពផ្នែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិចទាំង ១៧ ចំណុច សមត្ថភាព ៤ ចំណុចអនុវត្តចំពោះនិយោជិតទាំងអស់ដែលផ្តល់សេវាសាធារណៈនៅ British Columbia រួមទាំងនិយោជិកក្នុងក្រសួងសុវត្ថិភាពសាធារណៈ និងអគ្គមេធាវីដែលជាស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវលើការគ្រប់គ្រងសេវានគរបាល។ សមត្ថភាពទាំង ៤ រួមមាន ៖

- ស្វ័យស្វែងយល់ និងស្វ័យយល់ដឹង
- ការរៀនសូត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
- ភាពវាងវៃផ្នែកវប្បធម៌
- ការដឹកនាំឆ្ពោះទៅរកការផ្លាស់ប្តូរ។

ពាក់ព័ន្ធនឹងអភិក្រមនៃភាពប្រទាក់ក្រឡាគ្នា សមត្ថភាពផ្នែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិចសម្រាប់ភាពវាងវៃផ្នែកវប្បធម៌ មានភាពលេចធ្លោរជាងគេ (សូមមើលប្រអប់ ២៤)។ នៅ British Columbia ជនជាតិដើមភាគតិចនៅកាណាដា អះអាងថាតាំងពីដើមមកពួកគេទទួលបានសេវានគរបាលច្រើនពេក ឬតិចពេក។ ការអភិវឌ្ឍសមត្ថភាពនេះសម្រាប់ការអនុវត្តប្រចាំថ្ងៃដោយនគរបាល និងមន្ត្រីរដ្ឋាភិបាល ជាជំហានដ៏ល្អក្នុងការធ្វើឱ្យជនជាតិភាគតិចយល់ថា នគរបាលជាអ្នកផ្តល់សេវាសំខាន់ៗដែលស្របច្បាប់។

468. យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសសម័យទំនើប (នាយកដ្ឋានកិច្ចការផ្ទៃក្នុង ២០១៦)
469. ក្របខណ្ឌសមត្ថភាពនិងគុណតម្លៃសម្រាប់សេវានគរបាល៖ខ្លឹមសារសង្ខេប(មហាវិទ្យាល័យសេវានគរបាល ២០១៦)
470. Ibid
471. ឃ្លា "ជនជាតិដើមភាគតិច" សំដៅលើជនជាតិដើមទាំងអស់ ជនជាតិ Inuit និងជនជាតិ Metis។ ជនជាតិដើមភាគតិចរួមបញ្ចូលបុគ្គល សហគមន៍ ក្រុម ប្រជាជាតិ អង្គការ និងប្រជាជននៅទីក្រុង និងទទួលស្គាល់លក្ខណៈពិសេស និងលក្ខណៈចម្រុះរបស់ពួកគេ។

**ប្រអប់ ១៥ ៖**

**ប្រអប់ ២៥ ៖ ការយល់ពីអារម្មណ៍ដែលកំណត់ក្នុងក្របខណ្ឌសមត្ថភាព និងគុណតម្លៃ (CVF) (មហាវិទ្យាល័យសេវានគរបាលនៃចក្រភពអង់គ្លេស)**

| កម្រិតទី ១ | កម្រិតទី ២ | កម្រិតទី ៣ |
|---|---|---|
| ខ្ញុំគោរព អត់អោន និងមានក្ដីមេត្តាចំពោះអ្នកដទៃ។<br>ខ្ញុំទទួលស្គាល់ និងគោរពទស្សនៈតម្លៃ និងជំនឿផ្សេងៗក្នុងអង្គច្បាប់។<br>ខ្ញុំរក្សាអារម្មណ៍និងពិចារណាពីរបៀបគ្រប់គ្រងស្ថានភាពបានល្អបំផុត នៅពេលប្រឈមនឹងការបង្កហេតុ។<br>ខ្ញុំយល់ពីអារម្មណ៍ផ្ទាល់ខ្លួន ហើយខ្ញុំដឹងស្ថានភាពដែលអាចជះឥទ្ធិពលលើសមត្ថភាពរបស់ខ្ញុំក្នុងការប្រឈមនឹងភាពតានតឹង និងសម្ពាធ។<br>ខ្ញុំស្នើសុំជំនួយនិងការគាំទ្រនៅពេលចាំបាច់។<br>ខ្ញុំយល់ពីគុណតម្លៃនៃលក្ខណៈចម្រុះ។<br>ខ្ញុំធ្វើទំនាក់ទំនងដោយប្រើភាសាច្បាស់លាស់ និងសាមញ្ញដើម្បីឱ្យអ្នកដទៃងាយយល់។<br>ខ្ញុំខិតខំស្វែងយល់ពីគំនិត និងការព្រួយបារម្ភរបស់អ្នកដទៃសូម្បីតែនៅពេលពួកគេមិនអាចស្ដែងច្បាស់ពីខ្លួនឯង។ | ខ្ញុំពិចារណាពីទស្សនៈរបស់អ្នកដទៃផ្អែកតាមសារតារចម្រុះ មុននឹងចាត់វិធានការ។<br>ខ្ញុំកែសម្រួលរចនាបទ និងវិធីសាស្ត្ររបស់ខ្ញុំទៅតាមតម្រូវការរបស់មនុស្ស។<br>ខ្ញុំធ្វើការជាមួយនិងប្រើអាកប្បកិរិយារបស់ខ្ញុំដើម្បីសម្រេចលទ្ធផលល្អបំផុត។<br>ខ្ញុំលើកកម្ពស់វប្បធម៌ដែលឱ្យតម្លៃលើលក្ខណៈចម្រុះ និងលើកទឹកចិត្តឱ្យមានការដេញដោល។<br>ខ្ញុំលើកទឹកចិត្តឱ្យមានការអនុវត្តបែបឆ្លុះបញ្ចាំងនិងចំណាយពេលជួយឱ្យអ្នកដទៃយល់ពីប្រតិកម្មតប និងអាកប្បកិរិយា។<br>ខ្ញុំទទួលខុសត្រូវលើការជួយធានាសុខុមាលភាពផ្លូវចិត្តរបស់សមាជិកក្នុងក្រុម។<br>ខ្ញុំទទួលខុសត្រូវលើការប្រឈមនឹងអាកប្បកិរិយាមិនសមស្របណាមួយ។ | ខ្ញុំខិតខំស្វែងយល់ពីមូលហេតុរយៈពេលវែងនៃការកំណត់ឥរិយាបថក្នុងស្ថាប័ន។ ចំណុចនេះអាចឱ្យខ្ញុំកែសម្រួល និងផ្លាស់ប្ដូរវប្បធម៌ស្ថាប័នក្នុងករណីសមស្រប។<br>ខ្ញុំខិតខំធានានូវវប្បធម៌គាំទ្រក្នុងស្ថាប័នដែលកត់សម្គាល់ និងឱ្យតម្លៃលក្ខណៈចម្រុះ និងសុខុមាលភាព និងដេញដោលការមិនអត់អោន។<br>ខ្ញុំយល់ពីនយោបាយផ្ទៃក្នុង និងខាងក្រៅ ហើយខ្ញុំអាចជះឥទ្ធិពលប្រកបដោយប្រសិទ្ធភាព ដោយកែសម្រួលសកម្មភាពរបស់ខ្ញុំដើម្បីសម្រេចផលប៉ះពាល់ដែលត្រូវការចាំបាច់។<br>ខ្ញុំពិចារណាដោយផ្អែកលើទស្សនៈចម្រុះ ហើយខ្ញុំប្រើប្រាស់ចំណេះដឹងនេះដើម្បីដេញដោលការគិតគុណតម្លៃ និងការសន្មតរបស់ខ្ញុំ។<br>ខ្ញុំធានាថាទស្សនៈទាំងអស់ផ្ដល់មូលដ្ឋានព័ត៌មានដល់ការធ្វើសេចក្ដីសម្រេច និងបង្ហាញមូលហេតុនៃការសម្រេចចិត្តតាមរបៀបដែលច្បាស់លាស់និងបំផុសចំណាប់អារម្មណ៍។ |

យោងតាម សេវាសាធារណៈ British Columbia សមត្ថភាពទំនាក់ទំនងជាមួយជនជាតិដើមភាគតិចបានផ្ដល់ផែនទីបង្ហាញផ្លូវសម្រាប់ការផ្លាស់ប្ដូរអាកប្បកិរិយាដែលជួយឱ្យពួកគេសម្រេចបានការប្ដេជ្ញាចិត្តរបស់ខ្លួន[472]។ សេវាសាធារណៈ British Columbia ស្នើឱ្យនគរបាលនិងមន្ត្រីរដ្ឋាភិបាលប្រើប្រាស់សមត្ថភាពទាំងនេះ ជាផែនទីបង្ហាញផ្លូវសម្រាប់ការវាយតម្លៃអាកប្បកិរិយារបស់ខ្លួន និងធ្វើការផ្លាស់ប្ដូរចាំបាច់ដើម្បីផ្ដល់សេវាជូនជនជាតិដើមភាគតិចកាន់តែប្រសើរ (សូមមើលប្រអប់ ២៦)។

472. ឯកសារណែនាំការអនុវត្តសមត្ថភាពផ្អែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិច (BC Public Service Agency, British Columbia, Canada, 2012).

## ប្រអប់ ១៦ ៖

**សមត្ថភាពផ្នែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិច ៖ ភាពវាងវៃផ្នែកវប្បធម៌**




ភាពវាងវៃផ្នែកវប្បធម៌ជាសមត្ថភាពធ្វើការប្រកបដោយការគោរព ការមានចំណេះដឹង និងប្រសិទ្ធភាពជាមួយជនជាតិដើមភាគតិច និងសំដៅលើការកត់សម្គាល់ និងការត្រៀមខ្លួនបន្សាំនឹងវប្បធម៌ដោយឡែកមួយដើម្បីបង្កើតស្មារតីសុវត្ថិភាពសម្រាប់ទាំងអស់គ្នា។ សមត្ថភាពនេះជាការបើកចំហរទទួលយកបទពិសោធន៍ថ្មី ដោយផ្លាស់ប្តូរអារម្មណ៍ភ័យព្រួយ ឬថប់បារម្ភទៅជាការចង់ស្វែងយល់ និងការឱ្យតម្លៃ។

សមត្ថភាពនេះសំដៅលើការពិនិត្យវប្បធម៌ផ្ទាល់ខ្លួន និងទស្សនៈជាសកល និងវប្បធម៌របស់សេវាសាធារណៈ British Columbia និងការកត់សម្គាល់លក្ខណៈទូទៅ និងលក្ខណៈពិសេសរបស់វប្បធម៌ទាំងនោះធៀបនឹងវប្បធម៌និងទស្សនៈជាសកលរបស់ជនជាតិដើមភាគតិច។វាជាការទទួលស្គាល់វិធីដែលគុណតម្លៃផ្ទាល់ខ្លួននិងគុណតម្លៃវិជ្ជាជីវៈអាចប្រឈមឬបន្សុីគ្នាទៅនឹងគុណតម្លៃរបស់ជនជាតិដើមភាគតិច។វាជាសមត្ថភាពផ្សារភ្ជាប់ ឬអនុញ្ញាតឱ្យមានទស្សនៈវប្បធម៌ផ្សេងៗ និងការមានឆន្ទៈដកពិសោធន៍ការផ្លាស់ប្តូរទស្សនៈផ្ទាល់ខ្លួន។

ប្រភព ៖ សមត្ថភាពផ្នែកអាកប្បកិរិយាក្នុងទំនាក់ទំនងជាមួយជនជាតិដើមភាគតិច ( BC Public Service, British Columbia, Canada 2012 )

## ករណីសិក្សាទី ១

## តើសមាគម/បណ្តាញនគរបាលជាស្ត្រីអាចគាំទ្រការអនុវត្តសេវានគរបាលដែលគិតគូរពីយេនឌ័រ និងឆ្លើយតបនឹងយេនឌ័រដោយរបៀបណា ?

ទំនុកចិត្តនិងការជឿជាក់របស់សហគមន៍មូលដ្ឋានចំពោះនគរបាលជាធាតុផ្សំដ៏សំខាន់មួយនៃការដោះស្រាយបទល្មើសទាំងអស់ ហើយក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីវាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនភាពអង់អាចដល់ជនរងគ្រោះឱ្យរាយការណ៍ពីបទល្មើសទាំងនេះ។ ស្ថាប័ននគរបាលទូទាំងពិភពលោកប្រឈមនឹងបញ្ហាដ៏ធំក្នុងការជំរុញឱ្យមានការរាយការណ៍ពីបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រោះយើងដឹងហើយថា ការរាយការណ៍ពីចំនួនករណីបទល្មើសនេះគឺទាបខ្លាំងជាងចំនួនករណីពិតប្រាកដ។ ស្ត្រី និងក្មេងស្រីមានចំនួន ៥០% នៃប្រជាជនសរុបទូទាំងពិភពលោក ប៉ុន្តែគេប៉ាន់ស្មានថា ជាមធ្យមចំនួននគរបាលជាស្ត្រីនៅទូទាំងពិភពលោកមានតែ ៩% ប៉ុណ្ណោះ។

ជាញឹកញាប់ ការព្រួយបារម្ភរបស់ស្ត្រីត្រូវបានមើលរំលងដោយសារតែសម្ពាធវប្បធម៌ឬសម្ពាធសង្គមដែលបណ្តាល

> "បុរសដែលមានលក្ខណៈសម្បត្តិប្រកបដោយគុណភាពមិនបារម្ភពីសមភាព យេនឌ័រឡើយ ហើយស្ថាប័នដែលមានគុណភាពក៏មិនខ្លាចពីសមភាពយេនឌ័រដែរ"។
>
> ( Anon ) សមាជិក IAWP ក្នុងសន្និសីទបណ្តុះបណ្តាលប្រចាំឆ្នាំរបស់សមាគមអន្តរជាតិនៃនគរបាលជាស្ត្រី ឆ្នាំ ២០១២

មកពីទស្សនៈលម្អៀង ឬទស្សនៈប្រកាន់ផ្នត់គំនិត និងកង្វះការយល់ដឹងពីតម្រូវការរបស់ស្ត្រី...។ នៅពេលមន្ត្រីជាស្ត្រីកាន់តែលេចធ្លោរស្ត្រីក្នុងសហគមន៍ច្រើនតែជឿថាកង្វល់របស់ពួកគេត្រូវបានឱ្យតម្លៃនិងដោះស្រាយ។មន្ត្រីជាស្ត្រីដែលត្រូវបាន បណ្តុះបណ្តាល និងបំពាក់បំប៉នវិជ្ជាជីវៈអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកំចាត់របាំងដែលរារាំងស្ត្រីមិនឱ្យទទួលបានយុត្តិធម៌[473]។

473. Townsley, J. ( 2014 ), 'The challenge of implementing Gender-Responsive Policing,' MDG Acceleration through Transformative Policing and Security, 58th Commission for the Status of Women Parallel Event, New York, USA 12 March 2014.

"សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនិងបរិយាបន្នស្ត្រី មិនផ្តោតលើសិទ្ធិ ឬសមភាពរបស់ស្ត្រីឡើយ ប៉ុន្តែផ្តោតលើប្រសិទ្ធភាពនៃប្រតិបត្តិការ"។

Peters, A. , 'Gender Responsive Policing and the Importance of Women Officers' Involvement in Tackling Violent Extremism', IAWP Annual Training Conference, Cardiff, UK ( 26 August, 2015 ).

នៅឆ្នាំ ២០១១ UN Women បានប្រើប្រាស់ទិន្នន័យរបស់ UNODC ( ២០០៩ ) ពី ៣៩ ប្រទេសដើម្បីបញ្ជាក់ថា វត្តមានរបស់មន្ត្រីនគរបាលជាស្ត្រីបង្ហាញពីទំនាក់ទំនងវិជ្ជមានជាមួយជនរងគ្រោះដែលរាយការណ៍ពីអំពើហិង្សាផ្លូវភេទ[474]។លទ្ធផលរកឃើញនេះគាំទ្រដោយលទ្ធផលរកឃើញស្រដៀងគ្នាពីការសិក្សាឆ្នាំ ២០១៣ (Miller and Segal)[475]។ ការសិក្សាផ្សេងទៀតរកឃើញថា វត្តមានស្ត្រីក្នុងសេវានគរបាល មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់អត្ថប្រយោជន៍ដល់នគរបាលជាបុរស និងស្ថាប័ននគរបាលផ្ទាល់ផងដែរ[476 477 478 479 480]។

ការកើនឡើងនៃចំនួនស្ត្រីក្នុងសេវានគរបាលមិនគួរធ្វើឱ្យបុរសភ័យខ្លាចនោះទេ ប៉ុន្តែបុរសគួរទទួលយក ព្រោះវាជួយទ្រទ្រង់ការផ្តល់សេវានគរបាលជារួម។

ការសិក្សាផ្សេងទៀតសន្និដ្ឋានថា សេវានគរបាលដែលគិតគូរពីយេនឌ័រអាចឆ្លើយតបទៅនឹងតម្រូវការសុវត្ថិភាព និងសន្តិសុខរបស់បុរស និងស្ត្រីបានល្អជាង តាមរយៈការបង្កើតស្ថាប័ននគរបាលដែលកាន់តែមានគណនេយ្យភាព និងវិជ្ជាជីវៈ[481 482 483 484 485]។

ដូច្នេះ ប្រសិនបើភស្តុតាងទាំងនេះបង្ហាញពីតម្រូវការស្ត្រីកាន់តែច្រើនក្នុងសេវានគរបាលដើម្បីឱ្យស្ត្រីកាន់តែលេចធ្លោរ ទទួលបានការបណ្តុះបណ្តាល និងការបំពាក់បំប៉នល្អប្រសើរ តើស្ថាប័ននគរបាលអាចទទួលបានការគាំទ្រដូចម្តេចដើម្បីសម្រេចគោលបំណងនេះ ?

"មានការផ្តោតហួសហេតុលើការរៀបចំរចនាសម្ព័ន្ធ ការបណ្តុះបណ្តាល និងការបំពាក់បំប៉ននគរបាលឡើងវិញ ដោយមិនគិតពីការផ្លាស់ប្តូរវប្បធម៌នៃសេវានគរបាលរួមទាំងការជះឥទ្ធិពលលើស្ថាប័នសន្តិសុខឱ្យក្លាយជាស្ថាប័នដែលកាន់តែគិតគូរពីយេនឌ័រ"។

Becker, J. ( 2012 ), 'Freedom through Association: Assessing the Contributions of Female Police Staff Associations to Gender-Sensitive Police Reform in West Africa' North-South Institute

សមាគម/បណ្តាញស្ត្រីមានតួនាទីជះឥទ្ធិពលលើការផ្លាស់ប្តូរ និងជួយឱ្យស្ថាប័ននគរបាលសម្រេចបានការកែលម្អជាបន្តបន្ទាប់ដើម្បីពង្រឹងការផ្តល់សេវាដល់សហគមន៍។ នៅពេលមានការពិចារណាពីភាពចាំបាច់នៃយេនឌ័រ ជនជាតិភាគតិច និងសិទ្ធិមនុស្ស សេវានគរបាលនឹងអាចបំពេញតម្រូវការរបស់សហគមន៍ដែលពួកគេផ្តល់សេវាជូនបានកាន់តែប្រសើរ។ ក្រៅពីនេះ សមាគម/បណ្តាញទាំងនេះអាចលើកឡើងពីសារតារនៃបទល្មើសយេនឌ័រ និងបញ្ហាប្រឈមរបស់ជនរងគ្រោះជាស្ត្រី ឬក្មេងស្រី។

474. UN Women វឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោក ៖ ក្នុងការស្វែងរកយុត្តិធម៌ ( UN Women, New York 2011 )
475. Miller, A. R. and Segal, C., ( 2013 ), 'Do Female Officers Improve Law Enforcement Quality ? : Effects on Crime reporting and Domestic Violence Escalation', at: http://ssrn.com/abstract=2335990
476. Lonsway, K. ( 2003 ), Hiring & Retaining More Women: The Advantages to Law Enforcement Agencies, Los Angeles: National Centre for Women and Policing.
477. Denham, T. ( 2008 ), 'Police Reform and Gender' in M. Bastick, K. Valasek ( eds ), Gender and Security Sector Reform Toolkit, Geneva: DCAF, OSCE/ODIHR, UN-INSTRAW
478. Bastrick, M. ( 2008 ), 'Integrating Gender in Post-Conflict Security Sector Reform', Policy Paper 29, Geneva: Geneva Centre for the Democratic Control of Armed Forces ( DCAF ).
479. Natarajan, M. ( 2008 ) 'Women Police in a Changing Society': Back Door to Equality, Aldershot: Ashgate Publishing Ltd.
480. Miller, A. R. and Segal, C., ( 2013 ) 'Do Female Officers Improve Law Enforcement Quality ? : Effects on Crime reporting and Domestic Violence Escalation', at: http://ssrn.com/abstract=2335990
481. Bastrick, M. ( 2008 ) Integrating Gender in Post-Conflict Security Sector Reform, Policy Paper 29, Geneva: Geneva Centre for the Democratic Control of Armed Forces ( DCAF ).
482. Denham, T. ( 2008 ) 'Police Reform and Gender' in M. Bastick, K. Valasek ( eds ), Gender and Security Sector Reform Toolkit, Geneva: DCAF, OSCE/ODIHR, UN-INSTRAW
483. Natarajan, M. ( 2008 ), 'Women Police in a Changing Society': Back Door to Equality, Aldershot: Ashgate Publishing Ltd.
484. Peters, A., 'Gender Responsive Policing and the Importance of Women Officers' Involvement in Tackling Violent Extremism', International Association of Women Police Annual Training Conference, ( Cardiff, UK, 26 August 2015 ).
485. Abbas, H., 'Women Fighting for Peace: Lessons for Toady's Conflicts', Presentation to the Committee on Foreign Affairs Relations Hearing, Washington DC: United States House of Representatives, 22 March 2016.

ខាងក្រោមនេះជាឧទាហរណ៍៣នៃរបៀបដែលសមាគម/បណ្ដាញនគរបាលជាស្ត្រីអាចជះឥទ្ធិពលលើការផ្លាស់ប្ដូរពិតប្រាកដ ៖

- នៅឆ្នាំ ២០០១ សមាគមអង់គ្លេសដើម្បីស្ត្រីក្នុងសេវានគរបាល (BAWP) បានផលិតឯកសារ "របៀបវារៈយេនឌ័រ"ដែលមានគោលបំណងជួយឱ្យសេវានគរបាលក្នុងចក្រភពអង់គ្លេសកាន់តែគិតគូរពីយេនឌ័រ។ឯកសារ "របៀបវារៈយេនឌ័រទី ២" ដែលធ្វើបច្ចុប្បន្នភាពពីឯកសារដើមកត់សម្គាល់ពីសមិទ្ធផល និងបញ្ហាប្រឈមដែលនៅសេសសល់។ ឯកសារ "របៀបវារៈយេនឌ័រទី ៣" ក្នុងសេវានគរបាលនៅចក្រភពអង់គ្លេសកំពុងត្រូវបានផលិតឡើង[486]។
- បណ្ដាញមន្ត្រីនគរបាលជាស្ត្រីក្នុងតំបន់អឺរ៉ុបអាគ្នេយ៍ (WPON) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១០ ក្រោមការគាំទ្រពីរដ្ឋាភិបាលថ្នាក់តំបន់។ នៅឆ្នាំ ២០១២ បណ្ដាញនេះបានផលិត "គោលការណ៍ណែនាំសម្រាប់សេវានគរបាលដែលគិតគូរពីយេនឌ័រ" ដោយផ្ដោតសំខាន់លើការជ្រើសរើស ការជ្រើសតាំង និងការអភិវឌ្ឍវិជ្ជាជីវៈរបស់ស្ត្រីក្នុងសេវានគរបាល[487]។ ឯកសារនេះត្រូវបានផលិតឡើងដោយប្រើប្រាស់ការស្រាវជ្រាវនៅទូទាំងតំបន់នេះតាមរយៈក្រសួងផ្សេងៗក្នុងប្រទេសជាច្រើននិងកិច្ចសហការជាមួយបណ្ដាញនគរបាលជាស្ត្រីផ្សេងទៀត ដូចជា សមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (IAWP) និង BAWP។
- នៅឆ្នាំ ២០១១ ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska បានបង្កើតបណ្ដាញមន្ត្រីនគរបាលជាស្ត្រីក្នុងតំបន់របស់ខ្លួន ក្នុងគោលបំណងលើកកម្ពស់ និងអនុវត្តគោលការណ៍សមភាពយេនឌ័រនិងគោលការណ៍ប្រជាធិបតេយ្យក្នុងសេវានគរបាល។ គម្រោងឈានមុខរបស់ក្រសួងនេះដែលមានឈ្មោះថា "អំពើហិង្សាក្នុងគ្រួសារ ៖ ការអប់រំមន្ត្រីនគរបាល-អ្នកគ្រប់គ្រង" ត្រូវបានអនុវត្តនៅឆ្នាំ២០១៧ដោយផ្ដោតសំខាន់លើមន្ត្រីនគរបាលគ្រប់ជាន់ថ្នាក់ក្នុងក្រសួងមហាផ្ទៃនេះ[488]។

សមត្ថភាពជះឥទ្ធិពលរបស់សមាគម ឬបណ្ដាញមួយពាក់ព័ន្ធផ្ទាល់នឹងរចនាសម្ព័ន្ធ "វិជ្ជាជីវៈ" និងនិរន្តរភាពរបស់សមាគម/បណ្ដាញនោះ ដែលភាគច្រើនផ្អែកលើកម្រិតនៃការគាំទ្រពីសំណាក់សមាគម ឬបណ្ដាញដូចគ្នា បុគ្គលិកជាន់ខ្ពស់ អង្គការ ឬរដ្ឋាភិបាល។

ការកំណត់តម្រូវការអភិវឌ្ឍន៍របស់សមាជិកក្នុងសមាគម/បណ្ដាញមួយ និងការបំពេញតម្រូវការទាំងនោះជួយឱ្យពួកគេក្លាយជា "ភ្នាក់ងារនៃការផ្លាស់ប្ដូរ"។ ចំណុចនេះអាចទាមទារឱ្យមានការអភិវឌ្ឍជំនាញរបស់បុគ្គលក្នុងផ្នែកដឹកនាំ យុទ្ធសាស្ត្រ និងគោលនយោបាយ ការគ្រប់គ្រងការផ្លាស់ប្ដូរ និងជំនាញតស៊ូមតិ ឬការបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ពួកគេ។

សមាគម/បណ្ដាញអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីក្នុងសហគមន៍ដែលនឹងជួយកសាងទំនុកចិត្ត និងភាពជឿជាក់លើនគរបាល។ ការបង្កើនការចូលរួមរបស់សហគមន៍អាចផ្ដល់អត្ថប្រយោជន៍ដល់ស្ថាប័ននគរបាលទាំងមូលហើយយើងដឹងហើយថាស្ត្រីត្រូវបានទទួលស្គាល់លើសមត្ថភាពជំរុញការចូលរួម។ គំរូសេវានគរបាលតាមសហគមន៍ជាអ្វីដែលស្ត្រីអាចផ្សារភ្ជាប់និងស្ទាត់ជំនាញហើយនេះក៏ជាមូលដ្ឋានសម្រាប់ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ។

---

486. សមាគមអង់គ្លេសដើម្បីស្ត្រីក្នុងសេវានគរបាល សូមមើល http://www.bawp.org
487. "គោលការណ៍ណែនាំសម្រាប់សេវានគរបាលដែលគិតគូរពីយេនឌ័រ" ដោយផ្ដោតសំខាន់លើការជ្រើសរើសការជ្រើសតាំងនិងការអភិវឌ្ឍវិជ្ជាជីវៈរបស់ស្ត្រីក្នុងសេវានគរបាល" (បណ្ដាញមន្ត្រីនគរបាលជាស្ត្រីក្នុងតំបន់អឺរ៉ុបអាគ្នេយ៍ ២០១២)
488. បណ្ដាញស្ត្រីក្នុងក្រសួងមហាផ្ទៃនៃ សាធារណរដ្ឋSrpska ៖ RS WPON "ការលើកកម្ពស់និងការអនុវត្តគោលការណ៍សមភាពយេនឌ័រ អភិក្រមយុទ្ធសាស្ត្រក្នុងការទទួលយកស្ត្រីឱ្យប្រឡូកក្នុងសេវានគរបាល ការអប់រំ ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍអាជីព និងការលើកកម្ពស់លទ្ធផលការងាររបស់មន្ត្រីក្រសួងមហាផ្ទៃនៃ Republic of Srpska" http://www.mrezazena-muprs.org/?lang=en។

### អត្ថប្រយោជន៍របស់សមាគម/បណ្តាញ ដូចជា IAWP

បណ្តាញដែលធន់និងមានប្រសិទ្ធភាព ផ្តល់មធ្យោបាយសុវត្ថិភាពដល់ស្ត្រីក្នុងការស្វែងរកការគាំទ្រនិងការណែនាំ ចែករំលែកការអនុវត្តល្អ និងសហការគ្នាបង្កើតការផ្លាស់ប្តូរ។ ដោយកត់សម្គាល់ពីតួនាទីដ៏សំខាន់របស់បុរសក្នុងការគាំទ្រដល់ស្ត្រីក្នុងសេវានគរបាល និងស្ត្រី និងក្មេងស្រីក្នុងសហគមន៍ជាញឹកញាប់សមាគម/បណ្តាញរួមបញ្ចូលមន្ត្រីនិងបុគ្គលិកជាបុរសក្នុងសមាសធាតុរបស់ខ្លួន។ IAWP ជាស្ថាប័នមួយដែលមានសមាជិកជាបុរសនិងមានបុរសដើតួនាទីគ្រប់គ្រងក្នុងស្ថាប័ន (ក្រុមប្រឹក្សាភិបាល)។ សមាគម/បណ្តាញផ្សេងទៀតបានបង្កើតស្ថាប័ន ស្រដៀងគ្នា ដើម្បីឱ្យបុរសមានភាពប្រតិសកម្មក្នុងការគាំទ្រដល់ស្ត្រីក្នុងសេវានគរបាល ក៏ដូចជាស្ត្រី និងក្មេងស្រីក្នុងសហគមន៍។ ឧទាហរណ៍មួយ គឺនៅប្រទេសអាហ្វ្រិកខាងត្បូងដែលបណ្តាញបុរស ("បុរសដើម្បីការផ្លាស់ប្តូរ") សហការ និងគាំទ្រដល់ស្ត្រីក្នុងបណ្តាញសេវានគរបាលអាហ្វ្រិកខាងត្បូង (SAPSN) និងស្ត្រី និងក្មេងស្រីក្នុងសហគមន៍។ នៅឆ្នាំ ២០១៩ បណ្តាញ "បុរសដើម្បីការផ្លាស់ប្តូរ"បានធ្វើយុទ្ធនាការកសាងការយល់ដឹងជាសាធារណៈដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ[489]។



សន្និសីទ IAWP នៅឆ្នាំ ២០១៩ Anchorage រដ្ឋអាឡាស្កា សហរដ្ឋអាមេរិក ៖ រូបថតទទួលបានពី IAWP

សមាគម/បណ្តាញនគរបាលជាស្ត្រីជាច្រើនបានជំរុញការចូលរួមបែបប្រតិសកម្មរបស់ស្ត្រី និងក្មេងស្រីក្នុងសហគមន៍មូលដ្ឋាន តាមរយៈការកសាងទំនាក់ទំនង ការបើកខ្សែទូរស័ព្ទទំនាក់ទំនង ការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី និងការកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រីនិងក្មេងស្រីក្នុងការក្លាយខ្លួនជាជនរងគ្រោះ។ សមាជិកម្នាក់ៗដើរតួនាទីជាបុគ្គលគំរូសម្រាប់ស្ត្រី និងក្មេងស្រី ហើយនេះជាឧបករណ៍ដ៏មានតម្លៃនៅពេលព្យាយាមបង្កើនចំនួនស្ត្រីក្នុងសេវានគរបាល។

សមាគមអន្តរជាតិនៃនគរបាលជាស្ត្រីមានសម្ព័ន្ធជាច្រើននៅទូទាំងសកលលោក ដែលកំពុងគាំទ្រយ៉ាងសកម្មឱ្យស្ថាប័ននគរបាលរបស់ពួកគេគិតគូរពីយេនឌ័រនិងជំរុញដល់ស្ថាប័នទាំងនោះផ្តល់ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ សម្ព័ន្ធរបស់ IAWP ផ្តល់គំរូនៃការអនុវត្តល្អជាច្រើនស្តីពីការបង្កើត និងនិរន្តរភាពរបស់សមាគម/បណ្តាញនគរបាលជាស្ត្រីនិងអត្ថប្រយោជន៍ដែលសម្ព័ន្ធទាំងនោះផ្តល់ជូនសមាជិក សហការី ស្ថាប័ននគរបាល និងសហគមន៍មូលដ្ឋាន។

ឧទាហរណ៍នៃសម្ព័ន្ធរបស់ IAWP រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម៖បណ្តាញនគរបាលជាស្ត្រីបង់ក្លាដេសសមាគមស្ត្រីក្នុងជួរនគរបាលកូសូវ៉ូ សមាគមអង់គ្លេសដើម្បីស្ត្រីក្នុងសេវានគរបាលសមាគមនគរបាលជាស្ត្រីនៅហ្គូយ៉ាណាសមាគមនគរបាលជាស្ត្រីនៅហ្កាណា សមាគមស្ត្រីក្នុងស្ថាប័នអនុវត្តន៍ច្បាប់នៅអ៊ុយក្រែនសមាគមនគរបាលជាស្ត្រីនៅទ្រីនីដាដ និង តូបាហ្គូ បណ្តាញស្ត្រីអ្នកអនុវត្តន៍ច្បាប់នៅ Kentucky សមាគមនគរបាលជាស្ត្រីនៅអេមីរ៉េតអារ៉ាប់សមាគមស្ត្រីក្នុងស្ថាប័នអនុវត្តន៍ច្បាប់នៅអាត្លង់ទិចសមាគមស្ត្រីក្នុងស្ថាប័នអនុវត្តន៍ច្បាប់នៅOntario និងសមាគមស្ត្រីក្នុងស្ថាប័នអនុវត្តន៍ច្បាប់នៅChicago[490]។

### ឧទាហរណ៍នៃការផ្លាស់ប្តូរពិតប្រាកដតាមរយៈការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងសេវានគរបាលប្រទេសលីបង់

នៅឆ្នាំ ២០១០ Major Suzanne El Hajj បានចូលរួមសន្និសីទ IAWP ជាលើកដំបូង។ នៅពេលនោះ គាត់ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រី ២ នាក់ដែលបម្រើការក្នុងកងកម្លាំងសន្តិសុខផ្ទៃក្នុងលីបង់ (ISF) ដែលមានកងកម្លាំងសរុបចំនួន ២៣.០០០ នាក់។ បន្ទាប់ពីបានចូលរួមក្នុងសន្និសីទនេះ គាត់មានបំណងធ្វើការជាមួយ ISF ដើម្បីបង្កើនចំនួនស្ត្រី។ នៅពេលចូលរួមក្នុងសន្និសីទ

489. សេវានគរបាលអាហ្វ្រិកខាងត្បូង សូមមើល http://www.saps.gov.za។
490. កម្មវិធីរបស់សម្ព័ន្ធ IAWP ៖ http://www.iawp.org/iawp-affiliates

ឆ្នាំ ២០១១ របស់ IAWP យុទ្ធនាការរបស់គាត់ចង់ជ្រើសរើសមន្ត្រីជាស្ត្រីបន្ថែមចំនួន ១.០០០ នាក់ ប៉ុន្តែមានស្ត្រីដាក់ពាក្យចូលបម្រើការរហូតដល់ ១១.០០០ នាក់។ នៅពេលវិលត្រឡប់ពីសន្និសីទឆ្នាំ ២០១១ របស់ IAWP Major Hajj និងមន្ត្រីជាន់ខ្ពស់របស់គាត់ មានបំណងរៀបចំសន្និសីទដំបូងស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រីសម្រាប់មន្ត្រីជាស្ត្រីរបស់ ISF ក្នុងប្រទេស លីបង់។

Major Hajj លើកឡើងថា "ស្ត្រីមានលក្ខណៈសម្បត្តិសំខាន់ៗដែលជួយឱ្យពួកគេទទួលបានជោគជ័យក្នុងជួរនគរបាល។ ចរិតមនុស្សធម៌ និងក្តីមេត្តារបស់ស្ត្រីរួមចំណែកដល់ការអនុវត្តសិទ្ធិមនុស្ស។ ធម្មជាតិរបស់ស្ត្រីគឺស្រឡាញ់របៀបរៀបរយនិងការរៀបចំដែលអាចឱ្យស្ត្រីធ្វើការងារជាច្រើនខុសៗគ្នា។ ក្រៅពីនេះ ស្ត្រីធាប់ធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ ដែលនាំទៅរកការអនុវត្តសេវានគរបាលក្នុងសហគមន៍ដោយជោគជ័យ និងសម្រេចបានសន្តិសុខក្នុងការទប់ស្កាត់"។



សន្និសីទ IAWP ឆ្នាំ ២០១៩ Anchorage រដ្ឋអាឡាស្កា សហរដ្ឋអាមេរិក ៖ រូបថតទទួលបានពី IAWP

## ប្រទេសអេមីរ៉ែតអារ៉ាប់ (United Arab Emirates)

បន្ទាប់ពីបានចូលរួមជាមួយ IAWP Major Amna Al Belooshi បានប្តេជ្ញាចិត្តបង្កើតសមាគមមួយនៅអេមីរ៉ែតអារ៉ាប់។ គាត់បានបង្ហាញគំនិតផ្តួចផ្តើមរបស់គាត់ឱ្យឧត្តមសេនីយ៍បានឃើញ។សំខាន់បំផុតគឺគាត់បានស្វែងរកការគាំទ្រពីព្រះអង្គម្ចាស់នាយឧត្តមសេនីយ៍ទោ Sheikh Saif bin Zayed Al Nahyan ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គាត់ត្រូវចំណាយពេល ៣ ខែ ដើម្បីបានជួបជាមួយទ្រង់ ប៉ុន្តែគាត់ដឹងថា ការទទួលបានការគាំទ្រពីកម្រិតខ្ពស់បំផុត ពិតជាសំខាន់ខ្លាំងណាស់។

នៅពេលចូលរួមសន្និសីទ IAWP ជាលើកដំបូងនៅឆ្នាំ ២០១១ គាត់បានបង្កើតសមាគមនគរបាលជាស្ត្រីនៅអេមីរ៉ែតអារ៉ាប់រួម (EWPA) រួចទៅហើយ ហើយសមាគមនេះបានក្លាយជាសម្ព័ន្ធអារ៉ាប់លើកដំបូងរបស់ IAWP ក្នុងសន្និសីទនោះ។ ក្នុងរយៈពេល ៦ ខែ នៅឆ្នាំ ២០១២ គាត់បានរៀបចំសន្និសីទបណ្តុះបណ្តាលនគរបាលអន្តរជាតិដំបូងសម្រាប់ស្ត្រីក្នុងតំបន់ឈូងសមុទ្រ។ គិតត្រឹម ឆ្នាំ ២០១៣ គាត់បានរៀបចំសន្និសីទ EWPA លើកទី ២ និងបានរៀបចំសន្និសីទផ្សេងៗទៀត។ EWPA មានសមាជិកជាង ៥.០០០ នាក់មកពីទូទាំងប្រទេសអេមីរ៉ែតអារ៉ាប់។ Major Al Belooshi បន្តកែលម្អ និងដាក់បញ្ចូលស្ត្រីទៅក្នុងសេវានគរបាលក្នុងប្រទេសរបស់គាត់ និងកំពុងធ្វើការក្នុងនាមជាប្រធាន EWPA ដើម្បីបង្កើនកម្រិតនៃការបណ្តុះបណ្តាល និងការចាត់តាំងនគរបាលជាស្ត្រីនៅអេមីរ៉ែតអារ៉ាប់។

**ប្រអប់ ១៧ ៖**

**សមាគមអន្តរជាតិនៃនគរបាលជាស្ត្រី (IAWP)**



សន្និសីទថ្នាក់តំបន់លើកទី ១៦ របស់ IAWP ឆ្នាំ ២០១២ ៖
រូបថតទទួលបានពីសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី

**ចក្ខុវិស័យ** ៖ IAWP ចង់បានពិភពលោកមួយ ដែលនគរបាលធ្វើការឆ្លុះបញ្ចាំងពីលក្ខណៈចម្រុះរបស់សហគមន៍ដែលពួកគេផ្តល់សេវាជូន និង ការពារសិទ្ធិមនុស្ស។

**បេសកកម្ម** ៖ ដើម្បីពង្រឹង បង្រួបបង្រួម និងកសាងសមត្ថភាពរបស់ស្ត្រីក្នុងសេវានគរបាលអន្តរជាតិ។

IAWP ផ្តល់ការបង្កើតបណ្តាញ និងការជួយគ្នាទៅវិញទៅមកដល់សមាជិកក្នុង ៧២ ប្រទេស ព្រមទាំងការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈការណែនាំ ការរៀបចំសន្និសីទបណ្តុះបណ្តាលថ្នាក់តំបន់ និងសន្និសីទបណ្តុះបណ្តាលប្រចាំឆ្នាំរបស់ IAWP។ IAWP មានគោលបំណង ៖

- ផ្តល់សន្និសីទបណ្តុះបណ្តាល កម្មវិធី ព្រឹត្តិការណ៍អប់រំ និងសិក្ខាសាលាដែលពាក់ព័ន្ធនឹងសេវានគរបាលទូទាំងពិភពលោក។
- ជំរុញលើកទឹកចិត្តនិងផ្តល់ការណែនាំនិងភាពជាអ្នកដឹកនាំដល់មន្ត្រីនគរបាលនៅគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍអាជីព។
- ដើម្បីឆ្ពោះទៅរកភាពមានវិជ្ជាជីវៈពិតប្រាកដតាមរយៈការអប់រំ និងការបណ្តុះបណ្តាល និងបន្តផ្តល់ព័ត៌មានស្តីពីនិន្នាការបច្ចុប្បន្ន និងបច្ចេកទេសដើម្បីផ្តល់សេវាកាន់តែប្រសើរដល់សាធារណជន។
- ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តស្តង់ដារក្រមសីលធម៌ខ្ពស់បំផុតនៃវិជ្ជាជីវៈអនុវត្តន៍ច្បាប់។
- ដើម្បីកំណត់រកទទួលស្គាល់ និងលើកទឹកចិត្តការអនុវត្តការងារ ភាពលេចធ្លោរ និងសមិទ្ធផលក្នុងចំណោមស្ថាប័នអនុវត្តន៍ច្បាប់។

www.iawp.org

## ករណីសិក្សាទី ២
## បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃក្រសួងមហាផ្ទៃនៃ សាធារណរដ្ឋ Srpska

អ្នករួមចំណែក ៖ កញ្ញា Sanja Sumonja (អធិការជាន់ខ្ពស់ក្នុងផ្នែកប្រយុទ្ធប្រឆាំងបទល្មើសដែលមានអង្គការចាត់តាំង និង បទល្មើសធ្ងន់ធ្ងរ ប្រធានក្រុមប្រឹក្សា RS MOI WPON)

នៅឆ្នាំ ២០១១ ក្រោមការជ្រោមជ្រែងពីបណ្តាញមន្ត្រីនគរបាលជាស្ត្រី (WPON) ក្នុងគំនិតផ្តួចផ្តើមតំបន់អឺរ៉ុបអាគ្នេយ៍និងស្នងការនគរបាលក្រសួងមហាផ្ទៃនៃសាធារណរដ្ឋSrpska (RS) បានបង្កើតបណ្តាញមន្ត្រីនគរបាលជាស្ត្រី (WPON) ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជីក្នុងប្រទេសរបស់ខ្លួន។ បណ្តាញនេះមានគោលដៅលើកកម្ពស់ និងអនុវត្តគោលការណ៍សមភាពយេនឌ័រ និងគោលការណ៍ប្រជាធិបតេយ្យក្នុងសេវានគរបាល[491]។

ដើម្បីសម្រេចគោលដៅខាងលើ បណ្តាញនេះបានបង្កើតអាទិភាពគាំទ្រ ៤ ចំណុចដូចខាងក្រោម៖

- ការលើកកម្ពស់ និងការអនុវត្តគោលការណ៍សមភាពយេនឌ័រ និងគោលការណ៍ប្រជាធិបតេយ្យក្នុងសេវានគរបាល។
- អភិក្រមយុទ្ធសាស្ត្រក្នុងការទទួលយកស្ត្រីឱ្យបម្រើការក្នុងជួរនគរបាល។
- ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍអាជីព និង
- ការបង្កើនលទ្ធផលរបស់មន្ត្រីនគរបាល និងលទ្ធផលរបស់មន្ត្រីក្នុងក្រសួងផ្សេងទៀត។

ក្រោយការបង្កើតឡើងមិនយូរប៉ុន្មាន បណ្តាញនេះមានសមាជិកជាង ៣០០ នាក់ដែល មន្ត្រីសុទ្ធតែជាស្ត្រីដែលបម្រើការក្នុងក្រសួងមហាផ្ទៃនិងមានតួនាទីជាមន្ត្រីនគរបាលនិងនិយោជិក។ បច្ចុប្បន្ន បណ្តាញនេះមានសមាជិក ៤៦០នាក់។ ក្រោយមកបណ្តាញនេះបានចាប់ផ្តើមចូលរួមក្នុងគម្រោង "ដោគជ័យរហ័ស" ដូចជា ការបណ្តុះបណ្តាលមន្ត្រីនគរបាលដូចគ្នានិងតួអង្គក្នុងស្ថាប័នអយ្យការ ការលើកកម្ពស់អាជីពនគរបាលក្នុងចំណោមសិស្សស្រីនៅវិទ្យាល័យ ក៏ដូចជាការចូលរួមក្នុងព្រឹត្តិការណ៍ថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ស្តីពីសេវានគរបាល។



គម្រោងរបស់បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃសាធារណរដ្ឋ Sprska ៖ "ការបង្កើនការយល់ដឹង និងការអប់រំបុគ្គលិកបង្រៀននៅបឋមសិក្សាស្តីពីបទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអាពាហ៍ពាហ៍ពិពាហ៍ និងគ្រួសារ"

មិនយូរមិនឆាប់ បណ្តាញនេះបានទាក់ទាញការគាំទ្រពីម្ចាស់ជំនួយខាងក្រៅ ដូចជា UN Women, OSCE, ស្ថានទូតអាមេរិក រដ្ឋាភិបាលន័រវែស និង UNDP ជាពិសេសការគាំទ្រលើការបណ្តុះបណ្តាល និងការយល់ដឹងស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាល/អំពើហិង្សាក្នុងគ្រួសារ។ ជាលទ្ធផលបណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃសាធារណរដ្ឋ Srpska ត្រូវបានសន្មតជាអ្នកពាក់ព័ន្ធដ៏ស្របច្បាប់ និងប្រកបដោយចំណេះដឹងក្នុងវិស័យយុត្តិធម៌ និងសន្តិសុខ និងក្នុងចំណោមតួអង្គសង្គមស៊ីវិល ដែលបណ្តាញនេះនឹងពង្រីកភាពជាដៃគូ។

បច្ចុប្បន្ន បណ្តាញនេះត្រូវបានចាត់ទុកជាសមាគមដែលដើរតួនាទីសកម្ម និងបង្កផលប៉ះពាល់ខ្លាំងបំផុតមួយសម្រាប់មន្ត្រីនគរបាលជាស្ត្រីក្នុងពិភពលោក។



សន្និសីទប៉ែលក្រាដ (២០១៩) ស្តីពីការដាក់បញ្ចូលសមភាពយេនឌ័រក្នុងស្ថាប័ននគរបាលនៅតាមបណ្តាប្រទេសក្នុងតំបន់

សកម្មភាពរបស់បណ្តាញនេះមានដូចជា ៖

- ផ្តល់មតិយោបល់ស្តីពីគោលនយោបាយស្ថាប័ននិងផលប៉ះពាល់នៃច្បាប់ថ្មី (ដូចជា ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ ២០២០)។

491. បណ្តាញស្ត្រីក្នុងក្រសួងមហាផ្ទៃ-RS WPON សូមមើល ៖ http://www.mrezazena-muprs.org/about/?lang=en

- កសាងការយល់ដឹងរបស់ស្ត្រីនិងបុរសជាច្រើនក្នុងក្រសួងមហាផ្ទៃស្តីពីសមភាពយេនឌ័រ។
- ការតស៊ូមតិឱ្យមានការអប់រំនិងការបណ្តុះបណ្តាលដែលគិតគូរពីយេនឌ័រសម្រាប់និយោជិកក្នុងក្រសួងមហាផ្ទៃ។
- ការសហការជាមួយស្ថាប័ន អង្គការ និងអង្គភាពពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិស្តីពីតួនាទីនិងស្ថានភាពរបស់ស្ត្រីក្នុងវិស័យសន្តិសុខ។
- ទប់ស្កាត់ និងដោះស្រាយគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី កុមារ និងក្រុមផ្សេងទៀតដែលប្រឈមនឹងហានិភ័យខ្ពស់នៃការរងគ្រោះដោយអំពើហិង្សា។
- ទប់ស្កាត់ និងដោះស្រាយ ដូចជា ការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀន អំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាដែលសម្រួលដោយប្រព័ន្ធបច្ចេកវិទ្យា និងសារគមនាគមន៍ ដែលជះផលអាក្រក់លើស្ត្រី កុមារ និងក្រុមផ្សេងទៀតដែលប្រឈមនឹងហានិភ័យខ្ពស់នៃការរងគ្រោះដោយអំពើហិង្សា។
- បោះពុម្ពសៀវភៅ កូនសៀវភៅព័ត៌មាន សៀវភៅណែនាំ អត្ថបទសិក្សាស្រាវជ្រាវ និងការបោះពុម្ពផ្សាយផ្សេងទៀតដែលបន្សីគ្នានឹងគោលបំណងរបស់សមាគមនេះ។

គម្រោងឈានមុខរបស់សមាគមនេះដែលមានឈ្មោះថា "អំពើហិង្សាក្នុងគ្រួសារ ៖ ការអប់រំមន្ត្រីនគរបាល និងអ្នកគ្រប់គ្រង" ត្រូវបានអនុវត្តនៅឆ្នាំ ២០១៧ និងផ្តោតសំខាន់លើមន្ត្រីនគរបាលគ្រប់ជាន់ថ្នាក់ក្នុងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska។ គម្រោងនេះ មានវគ្គបណ្តុះបណ្តាល ១២ វគ្គ និងបានបណ្តុះបណ្តាលមន្ត្រីនគរបាលសរុបចំនួន ១៤៤ នាក់[492]។

ការងារសំខាន់ៗផ្សេងទៀតរបស់បណ្តាញនេះរួមមានការរៀបចំកម្រងសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់ក្មេងស្រីនៅបឋមសិក្សា និងមធ្យមសិក្សាស្តីពីអំពើហិង្សាលើស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាលើស្ត្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍[493] វគ្គបណ្តុះបណ្តាលជាមួយបុគ្គលិកបង្រៀនស្តីពីបទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងគ្រួសារ[494] និងការដោះស្រាយការរើសអើងសមាជិកសហគមន៍ Roma និងកូនៗរបស់ពួកគេ[495]។



សមាជិកបណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃសាធារណរដ្ឋ Srpska និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក Dragan Lukac (កណ្តាល)។ ការប្តេជ្ញាចិត្ត និងការគាំទ្ររបស់លោក Lukac ដើរតួនាទីយ៉ាងសំខាន់សម្រាប់ការសម្រេចបានផលប៉ះពាល់ក្នុងក្រសួងនេះ។

492. គម្រោង "អំពើហិង្សាក្នុងគ្រួសារ ៖ ការអប់រំមន្ត្រីនគរបាល និងអ្នកគ្រប់គ្រង (២០១៧) ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋSrpska៖ http://www.mrezazena-muprs.org/project/domestic-violence-education-of-police-officers-managers/?lang=en
493. "ការទប់ស្កាត់អំពើហិង្សាផ្លូវភេទលើក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតក្នុងអនុតំបន់សាហារ៉ា"ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska ៖ https://www.mrezazena-muprs.org/project/prevention-of-online-sexual-violence-against-girls-in-suburban-areas/?lang=en
494. ការបង្កើនការយល់ដឹង និងការអប់រំបុគ្គលិកបង្រៀននៅបឋមសិក្សាស្តីពីបទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងគ្រួសារ (២០១៥) ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska៖ https://www.mrezazena-muprs.org/project/sensitization-and-education-ofelementary-schools-teaching-staff-on-criminal-offences-against-marriage-and-family/?lang=en
495. ការទប់ស្កាត់ការរើសអើងជនជាតិ Roma និងការរំលោភសិទ្ធិកុមារ Roma (២០១៩) ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska ៖ https://www.mrezazena-muprs.org/project/prevention-of-discrimination-against-roma-and-violation-ofroma-children-rights/?lang=en

ជោគជ័យសំខាន់ៗរបស់បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃនៃសាធារណរដ្ឋ Srpska ៖

- ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ក្នុងជួរនគរបាលគាំទ្រការបង្កើតបណ្តាញនេះ។ ទោះបីជាហិរញ្ញប្បទាននៅតែជាបញ្ហាប្រឈមសម្រាប់បណ្តាញនេះក្តីក៏ការគាំទ្រជាបន្តបន្ទាប់ពីថ្នាក់គ្រប់គ្រងប្រតិបត្តិក្នុងជួរនគរបាលបាន"ផ្តល់ភាពស្របច្បាប់" យ៉ាងមាន ប្រសិទ្ធភាពដល់បណ្តាញនេះក្នុងសហគមន៍អនុវត្តន៍ច្បាប់ ព្រមទាំងបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសេវានគរបាល។
- ការចុះបញ្ជីរហ័សក្នុងនាមជាស្ថាប័នស្របច្បាប់ (ក្នុងទម្រង់ជាអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមប្រជាពលរដ្ឋ) នៅខែ កញ្ញា ឆ្នាំ ២០១១ ជាមួយតុលាការនៅ Banja Luka ធ្វើឱ្យបណ្តាញនេះទទួលបានស្ថានភាពជាស្ថាប័នស្របច្បាប់ដែលនាំទៅរកការបង្កើតលក្ខន្តិកៈ ត្រាឡូហ្គោរបស់បណ្តាញ និងជាពិសេសឯកសារបញ្ជាក់ហិរញ្ញវត្ថុរួមមានគណនីធនាគារដើម្បីទទួលបានមូលនិធិសម្រាប់សកម្មភាព និងគម្រោង។
- ការយល់ពីដែនកំណត់និងចំណុចខ្លាំងរបស់បណ្តាញ។ ដោយសារតែលទ្ធភាពនៅមានកម្រិត បណ្តាញនេះកៀរគរធនធានរបស់ខ្លួនឱ្យផ្តោតលើគម្រោង"ជោគជ័យរហ័ស" ដែលអាចគ្រប់គ្រងបាន និងបញ្ចៀសការពាក់ព័ន្ធក្នុងគំនិតផ្តួចផ្តើមធំៗ។ គម្រោងទាំងនេះរួមមានការរៀបចំវគ្គបណ្តុះបណ្តាល ឬការចូលរួមក្នុងនាមជាគ្រូបង្គោលក្នុងសិក្ខាសាលាដៃគូលើប្រធានបទដូចជាការឆ្លើយតបអន្តរវិស័យទៅនឹងអំពើហិង្សាលើស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ ឬការវាយតម្លៃហានិភ័យ និងសុវត្ថិភាពរបស់ជនរងគ្រោះ។
- ការកសាងភាពជាដៃគូជាមួយសង្គមស៊ីវិលដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍ ស្តីពីសិទ្ធិកុមារ ឬសិទ្ធិរបស់សហគមន៍ LGBTQI[496] បានពង្រឹង "ភាពស្របច្បាប់" របស់បណ្តាញនេះក្នុងនាមជាដៃគូដ៏សំខាន់ក្នុងវិស័យយុត្តិធម៌ និងសន្តិសុខ ជាពិសេសលើបញ្ហាដែលពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារ ព្រោះមន្ត្រីជាស្ត្រីជាច្រើនពាក់ព័ន្ធនឹងករណីទាំងនេះ។
- ការកំណត់បណ្តាញនេះជាស្ថាប័នមួយដែលរួមចំណែកផ្តល់គុណតម្លៃដល់ស្ថាប័ននគរបាលដោយផ្អែកលើចំណេះដឹងរបស់បណ្តាញនេះស្តីពីវប្បធម៌ការងារ ក៏ដូចជាចំណុចខ្លាំង និងចំណុចខ្សោយរបស់នគរបាលក្នុងនាមជាអ្នកផ្តល់សេវាដ៏សំខាន់។ ក្រោមសកម្មភាពរបស់ខ្លួនបណ្តាញនេះបានសាងកេរ្តិ៍ឈ្មោះក្នុងនាមជាប្រភពវិជ្ជមានសម្រាប់ការផ្លាស់ប្តូរផ្ទៃក្នុង។
- ការលើកកម្ពស់ការរៀនសូត្រជាកត្តាសំខាន់។ ក្នុងអំឡុងពេលរៀបចំវគ្គបណ្តុះបណ្តាលដល់តួអង្គក្នុងវិស័យយុត្តិធម៌និងសន្តិសុខបណ្តាញនេះអាចកំណត់រកចំណុចខ្វះខាតក្នុងប្រព័ន្ធនេះដូចជានៅពេលប្រឈមដោយផ្ទាល់ជាមួយជនរងគ្រោះ (ដែលក្នុងករណីជាច្រើន មិនបានដឹងពីសិទ្ធិរបស់ពួកគេ)។ បទពិសោធន៍ខាងលើធ្វើឱ្យបណ្តាញនេះអាចផ្តល់អនុសាសន៍បែបស្ថាបនាក្នុងស្ថាប័ននគរបាល។

**មេរៀនសំខាន់ៗ ៖**

- សមាជិកដែលប្តេជ្ញាចិត្ត និងមានកម្លាំងចិត្ត គឺជាធាតុផ្សំដ៏សំខាន់ក្នុងការបំពេញមុខងាររបស់បណ្តាញនេះ ប៉ុន្តែចាំបាច់ត្រូវបង្កើតក្រុមគាំទ្រដើម្បីធានានិរន្តរភាពរបស់បណ្តាញនេះ។
- ការគាំទ្រជាបន្តបន្ទាប់ពីអ្នកគ្រប់គ្រងជាន់ខ្ពស់លើបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងដែលគាំទ្រដល់ការកែលម្អការអនុវត្តការងាររបស់នគរបាលក្នុងផ្នែកការពារសិទ្ធិមនុស្ស ជាចំណុចសំខាន់។
- ដោយសារតែបណ្តាញនេះពឹងផ្អែកលើមូលនិធិ និងការបរិច្ចាគពីខាងក្រៅ ជំនាញគ្រប់គ្រងគម្រោង និងបទពិសោធន៍របស់សមាជិកក្នុងការធ្វើទំនាក់ទំនងជាមួយម្ចាស់ជំនួយ គឺជាសមត្ថភាពគន្លឹះ។
- នៅពេលបង្កើតបណ្តាញ/សមាគមត្រូវពិចារណានិងដាក់បញ្ចូលយុទ្ធសាស្ត្រទំនាក់ទំនង(ជាពិសេសដើម្បីបង្កើនភាពលេចធ្លោរ) តាំងពីដំបូង។ ចំណុចសំខាន់គឺត្រូវចងក្រងរាល់សកម្មភាព កិច្ចការ និងគម្រោងទាំងអស់ទុកជាឯកសារនិងមានការចែករំលែកលទ្ធផលវិជ្ជមានជាសាធារណៈ ដូចជា ការចែកចាយតាមបណ្តាញសង្គម និងជាភាសាសំខាន់ៗ។
- ការចែករំលែកការអនុវត្តល្អក្នុងតំបន់ និងក្រៅពីនេះ (ឧ.សែប ម៉ុលដាវី កៀហ្ស៊ីស៊ីស្ថាន អ៊ុយក្រែន ប៊ែលហ្ស៊ិច អាល្លឺម៉ង់ កូរ៉េខាងត្បូង។ល។)។ ការអនុវត្តល្អរបស់

WPON រួមមាន ការបណ្តុះបណ្តាលមន្ត្រីដូចគ្នាស្តីពីរបៀបដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ ដែលជួយពង្រឹងស្ថាប័ននគរបាលជារួមក៏ដូចជាការបង្កើនការយល់ដឹងរបស់មន្ត្រីនគរបាលដែលអាចជាជនរងគ្រោះដោយសារអំពើហិង្សាអន្តរបុគ្គល[497]។ ក្រៅពីនេះ ការទទួលស្គាល់ និងការវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងរបស់សហការីមកពីបណ្តាប្រទេសផ្សេងទៀត ជួយពង្រឹងគោលជំហររបស់សមាគមនេះ និងផ្តល់សន្ទុះបន្ថែមសម្រាប់សកម្មភាពនាពេលអនាគត។

496. ការផ្សព្វផ្សាយសៀវភៅណែនាំដែលមានចំណងជើងថា"បទល្មើសនៃការស្អប់ខ្ពើមក្រុមLGBTI" (២០១៩) បណ្តាញមន្ត្រីនគរបាលជាស្ត្រីនៃក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ Srpska ៖ http://www.mrezazena-muprs.org/promotion-of-the-handbook-policing-hatecrimes-against-lgbti-persons/?lang=en

497. ឧ. សូមមើល ៖ Umberto Bacchi, 'Inside job: Bosnian policewomen take on abusive husbands' (Reuters, 2019) at: https://www.reuters.com/article/us-bosnia-women-police/inside-job-bosnian-policewomen-take-on-abusive-husbandsidUSKCN1PO0ZY

# ៨

## កំណត់សម្គាល់ និងអំណានបន្ថែម


1 Tool 2: Policing and Gender in *Gender and Security Toolkit* (Geneva, DCAF, OSCE/ODIHR, UN Women, 2019: see. https://www.dcaf.ch/sites/default/files/publications/documents/GSToolkit_Tool-2%20EN%20FINAL.pdf

2 'The Police', SSR Backgrounder Series (Geneva, DCAF, 2015) http://ssrbackgrounders.org/fall.php?p=16&l=EN

3 General Assembly resolution 34/169 of 17 December 1979.

4 Evaluación independiente de proyecto/evaluación en profundidad de: 'Fortalecimiento para la Seguridad de Grupos en situación de vulnerabilidad' CÓDIGO: MEXZ93-2018-005 (México, Abril 2019) at: https://www.unodc.org/documents/evaluation/Independent_Project_Evaluations/2019/MEXZ93_Final_Independent_Project_Evaluation_April_2019.pdf

5 Manual on Human Rights Monitoring (OHCHR, 2011). at: https://searchlibrary.ohchr.org/record/4835?ln=en

6 'Handbook on Police Accountability, Oversight and Integrity (UNODC, 2011) at: https://www.unodc.org/pdf/criminal_justice/Handbook_on_police_Accountability_Oversight_and_Integrity.pdf

7 'Toolkit on Police Integrity' (Geneva Centre for Security Sector Governance, 2019) at: https://www.dcaf.ch/sites/default/files/publications/documents/DCAF_PIBP_Toolkit_ENG_2019_web.pdf

8 'Police as an Entry Point to End Violence Against Women and Girls' : Lessons from Civil Society Organizations Funded by the UN Trust Fund to End Violence Against Women' (New York, UN Trust Fund to End Violence against Women, 2019).

9 'DIWA Curbs Violence against Women and Girls with Disabilities', at: http://www.diwa.ws/?p=101

10 'Promoting a safer, Gender-Based Violence Free Environment for Women and Girls with Disabilities' in Lilongwe, Malawi', (Disabled Women in Africa, 2017) at: https://www.makingitwork-crpd.org/sites/default/files/2018-05/Malawi%20-%20Promoting%20a%20safer%2C%20Gender-Based%20Violence%20free%20environment%20for%20women%20and%20girls%20with%20disabilities%20in%20Lilongwe%2C%20Malawi%20%28DIWA%29.docx

11 'Leveraging SDG 16 to Improve Implementation of SDG 5' (Background Document XIV, UNOG-DCAF Seminar 2017) at: https://www.dcaf.ch/sites/default/files/imce/Events/UNOG-DCAF%20Seminar%20Background%20document%20+%20programme.pdf

12 'Enhancing Access to Justice for Women Living in Rural and Remote Areas of British Columbia: Reviewing Practices from Canada and Abroad to Improve Our Response' (The International Centre for Criminal Law Reform and Criminal Justice Policy, 2017) at: https://icclr.org/wp-content/uploads/2019/06/BCLF-WA2J-Report-Final.pdf?x30145

13 Jenni Cross: '3 Myths of Behavior Change and Other Challenges for Sustainability', Energy and Behavior Institute for the Built Environment, (Colorado State University) at: https://www.uccs.edu/sustain/sites/sustain/files/inline-files/Myths%20of%20Behaivor%20Change_UCCS2015.pdf

14 'Safety and Dignity at Work: A Guide to the 2019 ILO Violence and Harassment Convention, No. 190' (Human Rights Watch, 2020) at: https://www.hrw.org/sites/default/files/media_2020/06/ILO_advocacy_brochure_0620.pdf

15 'Everyone's Business: Improving the Police Response to Domestic Abuse' (Her Majesty's Inspectorate of Constabulary, 2014) at: https://www.gov.uk/government/news/major-review-of-police-response-to-domestic-violence

16 Sara Rafael Almeida, Joana Sousa Lourenço, François J. Dessart and Emanuele Ciriolo, 'Insights from behavioural sciences to prevent and combat violence against women," EUR 28235 EN, doi:10.2788/412325 at: https://publications.jrc.ec.europa.eu/repository/bitstream/JRC103975/lbna28235enn.pdf

17 International Association of Chiefs of Police (2005b) 'Model Policy on Investigating Sexual Assault' (National Law Enforcement Policy Center, Alexandria, Virginia) at:http://www.evawintl.org/library/DocumentLibraryHandler.ashx?id=328.

18 'Progress of the World's Women 2011–2012: Families in a Changing World (UN Women, 2011)at: UN Women https://www.unwomen.org/en/digital-library/publications/2011/7/progress-of-the-world-s-women-in-pursuit-of-justice

19 J. Brown and F. Heidensohn (2000), 'Gender and Policing: Comparative Perspectives' Basingstoke: Macmillan.

20 A. Ward and T. Prenzler (2016). 'Good practice case studies in the advancement of women in policing,', *Police Science and Management*, 18(4), p. 242.

21Gordon, E., McHugh, C., and Townsley, J., (2020) 'Risks versus Transformational Opportunities in Gender-Responsive Security Sector Reform' *Journal of Global*

*Security Studies*, 0(0), 2020, 1–16 doi: 10.1093/jogss/ogaa028.

22 Graue, T.M., Hildie, R.E., and Weatherby, G.A., 'Women in Modern Policing', Department of Sociology and Criminal Justice, Gonzaga University, Spokane, WA, USA, in *Journal of Social Sciences and Humanities* Vol. 2, No. 3, 2016, pp. 51-62 at: http://www.aiscience.org/journal/jssh ISSN: 2381-7763 (Print); ISSN: 2381-7771.

23 'Men, Women, and Police Excessive Force: A Tale of Two Genders a Content Analysis of Civil Liability Cases, Sustained Allegations & Citizen Complaints' (The National Center for Women & Policing, 2002) at: http://womenandpolicing.com/PDF/2002_Excessive_Force.pdf

24 'A Practitioner's Toolkit on Women's Access to Justice Programming (UN Women et al., 2018), at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

25 Megan Bastick, 'Gender Self-Assessment Guide for the Police, Armed Forces and Justice Sector', (Geneva: DCAF, 2011), at: https://www.dcaf.ch/sites/default/files/publications/documents/self_assessment_guide.pdf

26 Stanko, E.A., and Bradford, B. (2009) 'Beyond Measuring 'How Good a Job' Police Are Doing: The MPS Model of Confidence in Policing' in *Policing*, Volume 3, Number 4, pp. 322–330. Oxford University Press.

27 'Guidelines for Producing Statistics on Violence against Women - Statistical Surveys' (UN Department of Economic and Social Affairs Statistics Division, New York, 2014), at: https://www.un.org/development/desa/capacity-development/tools/tool/guidelines-on-producing-statistics-on-violence-against-women-statistical-surveys/

28 V. Jaquier, H. Johnson and B.S. Fisher, 'Research methods, measures and ethics', in Sourcebooks on Violence against Women, 2nd ed., C.M. Renzetti, J.L. Edleson and R.K. Bergen, eds. (SAGE Publications, 2010).

29 'Guidance on Monitoring and Evaluation for Programming on Violence against Women and Girls', Guidance Note 3 How to Note. (DFID UK practice paper). at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/67334/How-to-note-VAWG-3-monitoring-eval.pdf

30 Modern Crime Prevention Strategy (Home Office, UK, 2016) at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/509831/6.1770_Modern_Crime_Prevention_Strategy_final_WEB_version.pdf

31 'What Works: Gender Equality by Design' (Bohent, I. Harvard University Press, 2016).

32 Flanagan, A.E., and Tanner, J.C., 'Theories in In A Framework for Evaluating Behaviour Change in International Development Operations' (World Bank, Independent Evaluation Group Working Paper 2016/No. 2, 2016)

33 Jenni Cross, '3 Myths of Behavior Change and Other Challenges for Sustainability' (Center for Energy and Behavior Institute for the Built Environment, Colorado State University, 2014) at: https://www.uccs.edu/sustain/sites/sustain/files/inline-files/Myths%20of%20Behaivor%20Change_UCCS2015_0.pdf

34 'Integrating Gender in Project Design and Monitoring for the Security and Justice Sector, in *Gender and Security Toolkit*, (Geneva: DCAF, OSCE/ODIHR, UN Women, 2019) https://www.dcaf.ch/node/13624

35 'Integrating Gender in Project Design and Monitoring for the Security and Justice Sector', Tool 15 *Gender and Security Toolkit* (DCAF, OSCE/ODIHR and UN Women, 2019).

36 Nicola Popovic, 'Security Sector Reform Assessment, Monitoring and Evaluation and Gender' Gender and Security Sector Reform Toolkit, Eds. Megan Bastick and Kristin Valasek (Geneva: DCAF, OSCE/ODIHR, UN-INSTRAW, 2008).

37 Bastick, Megan, 'Integrating Gender into Internal Police Oversight' (Geneva: DCAF, OSCE, OSCE/ODIHR, 2014).

38 Bastick, Megan, 'Integrating a Gender Perspective into Internal Oversight within Armed Forces' (Geneva: DCAF, OSCE, OSCE/ODIHR, 2014).

39 Guidelines for Gender Sensitive Policing, with an Emphasis on Recruitment, Selection and Professional Development of Women in Police Services', The Women Police Officers Network in South East Europe (WPON)- South Eastern and Eastern Europe Clearinghouse for the Control of Small Arms and Light Weapons (SEESAC, 2012) at: https://www.seesac.org/f/tmp/files/publication/812.pdf

40 RS MoI Women Network – RS WPON, 'Promotion and implementation of gender equality principles, strategic approach to the admission of women to the police, education, training and career development, and promotion of work results of RS MoI members' at: http://www.mrezazena-muprs.org/?lang=en

41 'A staggering one-in-three women, experience physical, sexual abuse', UN News, 24 November 2019, at: https://news.un.org/en/story/2019/11/1052041

42 'Provincial Policing Standards', (Provincial Government of British Columbia) at: https://www2.gov.bc.ca/gov/content/justice/criminal-justice/policing-in-bc/policing-standards

43 Foreword BCPPS 6.2 Police Stops in 'Provincial Policing Standards', (Provincial Government of British Columbia) at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminal-justice/police/standards/6-2-foreword-police-stops.pdf

44 Press Release: 'UN Women announces United Nations Police Adviser Luís Carrilho as HeForShe Advocate for gender equality', at: https://www.heforshe.org/en/un-women-announces-united-nations-police-adviser-luis-carrilho-heforshe-advocate-gender-equality

45 Competency and Values Framework for policing Overview of framework (College of Policing, 2016) at: https://www.college.police.uk/What-we-do/Development/competency-and-values-framework/Documents/Competency-and-Values-Framework-for-Policing_4.11.16.pdf

46 Gender Equality in UK Policing - First Annual Report (Sussex Police Corporate Communications 2019 in support of HeForShe UN Women Solidarity Movement for Gender Equality (2020) at: https://www.sussex.police.uk/SysSiteAssets/media/downloads/sussex/about-us/governance-and-processes/equality-and-diversity/heforshe-annual-report-2019.pdf

47 Indigenous Relations Behavioural Competencies (BC Public Service Agency, British Columbia, Canada, 2012) at: https://www2.gov.bc.ca/gov/content/careers-myhr/job-seekers/about-competencies/indigenous-relations

48 Implementation Guide Aboriginal Relations Behavioural Competencies (BC Public Service Agency, British Columbia, Canada, 2012) at: https://www2.gov.bc.ca/assets/gov/careers/for-job-seekers/about-competencies/aboriginal_relations_behavioural_competencies_implementation_guide.pdf

49 Townsley, J., 'The challenge of implementing Gender-Responsive Policing' - *MDG Acceleration through Transformative Policing and Security*, 58th Commission on the Status of Women Side-Event, New York, USA, 12 March 2014.

50 'Progress of the World's Women: In Pursuit of Justice', (UN Women, New York, 2012).

51 Miller, A. R. and Segal, C., (2013), 'Do Female Officers Improve Law Enforcement Quality? Effects on Crime reporting and Domestic Violence Escalation', at: http://ssrn.com/abstract=2335990

52 Lonsway, K. (2003), 'Hiring and Retaining More Women: *The Advantages to Law Enforcement Agencies*, Los Angeles: National Centre for Women and Policing.

53 Denham, T. (2008), 'Police Reform and Gender' in M. Bastick, K. Valasek (eds) *Gender and Security Sector Reform Toolkit*, Geneva: DCAF, OSCE/ODIHR, UN-INSTRAW.

54 Bastrick, M. (2008), 'Integrating Gender in Post-Conflict Security Sector Reform, Policy Paper 29, (Geneva Centre for the Democratic Control of Armed Forces).

55 Natarajan, M. (2008), 'Women Police in a Changing Society': *Back Door to Equality*, Aldershot: Ashgate Publishing Ltd.

56 Miller, A. R. and Segal, C., (2013), 'Do Female Officers Improve Law Enforcement Quality? Effects on Crime reporting and Domestic Violence Escalation.' at: http://ssrn.com/abstract=2335990

57 Bastrick, M. (2008), 'Integrating Gender in Post-Conflict Security Sector Reform, Policy Paper 29, Geneva: Geneva Centre for the Democratic Control of Armed Forces).

58 Denham, T. (2008), 'Police Reform and Gender' in M. Bastick, K. Valasek (eds) *Gender and Security Sector Reform Toolkit*, Geneva: DCAF, OSCE/ODIHR, UN-INSTRAW.

59 Natarajan, M. (2008), 'Women Police in a Changing Society' *Back Door to Equality*, Aldershot: Ashgate Publishing Ltd.

60 Peters, A., 'Gender Responsive Policing and the Importance of Women Officers' Involvement in Tackling Violent Extremism', *International Association of Women Police Annual Training Conference*, Cardiff, UK, 26 August 2015.

61 Abbas, H., 'Women Fighting for Peace: Lessons for Toady's Conflicts', *Presentation to the Committee on Foreign Affairs Relations Hearing*, Washington DC: United States House of Representatives, 22 March 2016.

62 British Association for Women in Policing at: http://www.bawp.org

63 'Guidelines for Gender-Sensitive Policing with an Emphasis on Recruitment, Selection and Professional Development of Women in Police Services' (Women Police Officers Network in South East Europe, 2012), at: http://www.seesac.org/f/docs/Gender-and-Security/GUIDELINES-FOR-GENDER-SENSITIVE-POLICING-EN.pdf

64 South African Police Service, at: http://www.saps.gov.za

65IAWP Affiliate Program, at: http://www.iawp.org/iawp-affiliates

66 Domestic Violence – Education of Police Officers Managers (Ministry of the Interior of the Republic of Srpska, 2017) at: http://www.mrezazena-muprs.org/project/domestic-violence-education-of-police-officers-managers/?lang=en

67Prevention of Online Sexual Violence against Girls in Suburban Areas (Ministry of the Interior of the Republic of Srpska, 2015) at: https://www.mrezazena-muprs.org/project/prevention-of-online-sexual-violence-against-girls-in-suburban-areas/?lang=en

68 Sensitization and Education of Elementary Schools Teaching Staff on Criminal Offences against Marriage and Family (Ministry of the Interior of the Republic of Srpska, 2015) at: https://www.mrezazena-muprs.org/project/sensitization-and-education-of-elementary-schools-teaching-staff-on-criminal-offences-against-marriage-and-family/?lang=en

69 'Prevention of Discrimination against Roma and Violation of Roma Children Rights (Ministry of the Interior of the Republic of Srpska, 2019) at: https://www.mrezazena-muprs.org/project/prevention-of-discrimination-against-roma-and-violation-of-roma-children-rights/?lang=en

70 'Policing Hate Crimes against LGBTI Persons' (Women Police Officer Network of the Republic of Srpska Ministry of the Interior, 2019) at: http://www.mrezazena-muprs.org/promotion-of-the-handbook-policing-hate-crimes-against-lgbti-persons/?lang=en

71Umberto Bacchi (Reuters, 2019), 'Inside job: Bosnian policewomen take on abusive husbands' at: https://www.reuters.com/article/us-bosnia-women-police/inside-job-bosnian-policewomen-take-on-abusive-husbands-idUSKCN1POoZY

11

# បញ្ហាប្រឈម និងយុទ្ធសាស្ត្រ

"មានមូលហេតុស្មុគស្មាញដែលបណ្តាលឱ្យកើតមានអំពើហិង្សាលើស្ត្រី និងក្មេងស្រីយ៉ាងច្រើននៅទូទាំងពិភពលោក ប៉ុន្តែដំណោះស្រាយមួយចំនួនគឺសាមញ្ញបំផុត។ ដំណោះស្រាយមួយគឺត្រូវផ្លាស់ប្តូររបៀបដែលនគរបាល និងសេវាយុត្តិធម៌ឆ្លើយតបទៅនឹងស្ត្រីដែលរាយការណ៍ពីករណីអំពើហិង្សា។"

សេចក្តីថ្លែងការណ៍របស់ Phumzile Mlambo-Ngucka អគ្គលេខាធិការរង និងជានាយកប្រតិបត្តិអង្គការ UN Women ក្នុងសេចក្តីប្រកាស Luis Carrillo ទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិ ជាអ្នកតស៊ូមតិយុទ្ធនាការ HeforShe ដើម្បីសមភាពយេនឌ័រ (២០១៩)

# គោលបំណងនៃជំពូកទី ១១

**រៀបចំឱ្យអ្នកគ្រប់គ្រងថ្នាក់កណ្តាលធ្វើការវិភាគនូវចំណុចខ្វះខាតក្នុងការឆ្លើយតបរបស់ស្ថាប័ននគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កើតឱ្យមានការផ្លាស់ប្តូរក្នុងស្ថាប័ន និងពិនិត្យតាមដាននូវការអនុវត្តនៃការផ្លាស់ប្តូរ។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការស្វែងយល់ពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាចំណុចស្នូលនៃការបង្កើនការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ការឆ្លើយតបរបស់នគរបាលអាចប្រសើរឡើងតាមរយៈការកំណត់ស្តង់ដារអនុវត្តន៍របស់នគរបាលដែលឆ្លើយតបនឹងយេនឌ័រ។
- ការពិគ្រោះយោបល់ជាមួយជនរងគ្រោះ ជាកត្តាសំខាន់ក្នុងការស្វែងយល់ពីចំណុចខ្វះខាតក្នុងការឆ្លើយតបរបស់ស្ថាប័ននគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- គួរចាត់ទុកថា គោលនយោបាយ និងការអនុវត្តរបស់នគរបាល អយ្យការ មន្ត្រីទទួលបន្ទុកត្រួតពិនិត្យជនល្មើសដែលកំពុងអនុវត្តការព្យួរទោស អង្គការស្ត្រី និងស្ថាប័នផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺមានភាពពាក់ព័ន្ធគ្នា។
- សុវត្ថិភាព សុខុមាលភាព និងស្វ័យភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្កគួរតែជាចំណុចស្នូលនៃការផ្លាស់ប្តូរក្នុងស្ថាប័ន។
- គណនេយ្យភាពជាគន្លឹះក្នុងការបង្កើតការផ្លាស់ប្តូរយូរអង្វែងក្នុងស្ថាប័ន។



## សេចក្តីផ្តើម

ជំពូកនេះផ្តល់ការណែនាំសម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងស្ថាប័ននគរបាល ស្តីពីការអនុវត្តមធ្យោបាយវិភាគដើម្បីសម្រេចបានសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ 498។ បច្ចុប្បន្ន សកម្មជន និងអង្គការស្ត្រីនៅជុំវិញពិភពលោកដែលធ្វើការងារពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី កំពុងដេញដោលភាពលម្អៀង និងការគៀបសង្កត់ដែលធ្វើឱ្យអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្លាយជាផ្នែកមួយនៃសង្គមរបស់យើង។ ភាពលម្អៀងទាំងនេះបានចាក់ឫសយ៉ាងជ្រៅ ដោយបានជ្រួតជ្រាបក្នុងស្ថាប័ននគរបាល និងស្ថាប័នយុត្តិធម៌ដែលមានតួនាទីការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សា។

រូបថតទទួលបានពី UNIFIL/Pasqual Gorriz (ប្រទេសលីបង់)

មានការកត់សម្គាល់កាន់តែច្រើនថា ទោះបីជាការផ្លាស់ប្តូរឥរិយាបថជាការសំខាន់ក្តី ក៏ការអនុវត្តក្នុងស្ថាប័នត្រូវតែមានការផ្លាស់ប្តូរដើម្បីបញ្ចប់ការអត់ឱនអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងសហគមន៍។ យុទ្ធនាការ HeforShe របស់អង្គការសហប្រជាជាតិជាឧទាហរណ៍មួយនៃចលនាអន្តរជាតិក្នុងការលើកកម្ពស់ការផ្លាស់ប្តូរក្នុងស្ថាប័នតាមរយៈការជំរុញការចូលរួមរបស់អ្នកដឹកនាំស្ថាប័នជាបុរសក្នុងនាមជាអ្នកតស៊ូមតិ និងជាសម្ព័ន្ធមិត្ត។ នៅឆ្នាំ ២០១៩ លោក Luis Carillho ដែលជាទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិត្រូវបានចាត់តាំងជាអ្នកតស៊ូមតិទីមួយសម្រាប់យុទ្ធនាការHeforShe។គាត់បានធ្វើជាគំរូដល់មន្ត្រីនគរបាលជាង ១០.០០០ នាក់ (៨៥% ជាបុរស) មកពីប្រទេសជាង ១០០[499]។

ការផ្លាស់ប្តូរក្នុងស្ថាប័នជាច្រើនអាចបង្កើតឡើងនិងអនុវត្តដោយថ្នាក់ដឹកនាំប្រតិបត្តិនិង/ឬអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងស្ថាប័ននគរបាល។នៅពេលមានការផ្លាស់ប្តូរដំបូងក្នុងស្ថាប័នអ្នកគ្រប់គ្រងថ្នាក់កណ្តាលត្រូវទទួលបានការគាំទ្រ និងការបង្កើនសិទ្ធិអំណាចសម្រាប់ការបង្កើតវប្បធម៌គណនេយ្យភាពក្នុងកន្លែងធ្វើការដើម្បីឱ្យមានសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រយ៉ាងពិតប្រាកដ។

ការអភិវឌ្ឍអនុវត្តនិងបញ្ជ្រាបសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រក្នុងស្ថាប័នដោយជោគជ័យអាស្រ័យលើគោលបំណងសំខាន់ៗ ២ ៖

498. វិញ្ញាចយេនឌ័រសំដៅលើ "ការស្វែងយល់ និងពិចារណាពីកត្តាសង្គម និងកត្តាវប្បធម៌ដែលពាក់ព័ន្ធនឹងការផាត់ចេញនិងការរើសអើងផ្អែកលើយេនឌ័រក្នុងទិដ្ឋភាពចម្រុះបំផុតនៃជីវិតសាធារណៈ និងជីវិតឯកជន"វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ៖https://eige.europa.eu/thesaurus/terms/1218?utm_source=newsletter&utm_medium=email&utm_campaign=how_gender_equal_is_your_parliament&utm_term=2019-11-27។ ក្នុងសៀវភៅណែនាំនេះ យុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រមានន័យថា ច្បាប់ ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងលទ្ធផលនៃយុត្តិធម៌ព្រហ្មទណ្ឌមិនរើសអើសនរណាម្នាក់ដោយសារយេនឌ័ររបស់ពួកគេឡើយ។ យុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រផ្តោតសំខាន់លើការពិចារណាពីទស្សនៈយេនឌ័រក្នុងច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាការវាយតម្លៃលទ្ធភាពទទួលបាន និងឧបសគ្គរាំងការទទួលបាននីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ស្ត្រី និងបុរស និងការអនុវត្តយុទ្ធសាស្ត្រដែលគិតគូរពីយេនឌ័រសម្រាប់ការការពារជនរងគ្រោះ និងការបង្កើនលទ្ធភាពទទួលបានយុត្តិធម៌ព្រហ្មទណ្ឌ។ សូមមើល Skinnider, Eileen.,'Towards Gender-Responsive Criminal Justice: Good Practices from Southeast Asia in responding to violence against women' (2018: Thailand Institute of Justice)។
499. 'UN Women បានប្រកាសទទួលស្គាល់លោក Luís Carrillo ទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិ ជាអ្នកតស៊ូមតិចលនា HeForShe ដើម្បីសមភាពយេនឌ័រ ៖ https://www.heforshe.org/en/un-women-announces-united-nations-police-adviser-luis-carrilho-heforshe-advocate-gender-equality

- អប់រំមន្ត្រីនគរបាលស្តីពីគោលគំនិតសង្គមវិទ្យាដែលគាំទ្រភាពចាំបាច់នៃសេវានគរបាល ដែលឆ្លើយតបនឹងយេនឌ័រ ព្រោះវាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចំណុចនេះនឹងបកស្រាយចម្លល់ថាតើហេតុអ្វីត្រូវមានការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រក្នុងស្ថាប័នរបស់ពួកគេ?
- បង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នតាមរយៈ ៖
  - ការអភិវឌ្ឍ និងដាក់បញ្ចូលសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ក្នុងការងាររបស់ស្ថាប័ន។ ក្នុងជំពូកនេះ យើងនឹងពិពណ៌នាពីមធ្យោបាយវិភាគដែលមានចំណងជើងថា "មធ្យោបាយ ៨ ចំណុចដែលប្រើប្រាស់ដោយស្ថាប័ននានាដើម្បីសម្របសម្រួលបុគ្គលិក" ដែលត្រូវបានអនុវត្តដោយជោគជ័យក្នុងការបង្កើនការឆ្លើយតបរបស់ប្រព័ន្ធទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
  - ការពិនិត្យតាមដានការអនុវត្តជាក់ស្តែងនិងការកំណត់រកចំណុចខ្វះខាតដែលត្រូវដោះស្រាយជាចាំបាច់។

## គោលបំណងទី ១ ៖ ការបង្កើតការយល់ដឹងស៊ីជម្រៅថា យេនឌ័រ និងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាបញ្ហាសង្គម

នៅពេលនគរបាលយល់ពីបទដ្ឋានសង្គម បទដ្ឋានច្បាប់ និងបទដ្ឋានវប្បធម៌ដែលពាក់ព័ន្ធនឹងយេនឌ័រ នៅកន្លែងដែលពួកគេរស់នៅ និងធ្វើការ ពួកគេនឹងអាចផ្តល់ការឆ្លើយតបដែលគិតគូរពីយេនឌ័របានកាន់តែប្រសើរ។ ជនបង្កអំពើហិង្សាក្នុងគ្រួសារប្រទូស្តកេរខ្មាសឈ្លបចាប់ជួញដូរមនុស្សនិងអំពើហិង្សាជាមួយដៃគូសង្សារបង្កឡើងក្នុង បរិបទនៃបទដ្ឋានសង្គម ដែលបង្កើតនូវបរិយាកាសថមថយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ នៅពេលនគរបាលចាត់ទុកអំពើហិង្សាលើស្ត្រីនិងក្មេងស្រីជាបញ្ហាសង្គមនិងជាបទល្មើសព្រហ្មទណ្ឌពួកគេនឹងកត់សម្គាល់បរិបទនៃអំពើហិង្សាដែលជនរងគ្រោះរងគ្រោះ និងអាចកំណត់កម្រិតហានិភ័យរបស់ជនរងគ្រោះនិងធ្វើអន្តរាគមន៍ដោយប្រសិទ្ធភាព។

### សសរស្តម្ភទាំង ៤ ដែលគាំទ្រឱ្យមានការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីយ៉ាងទូលំទូលាយ

ភាពត្រួតត្រារបស់មនុស្សមួយក្រុមលើមនុស្សមួយក្រុមផ្សេងទៀត ដែលធ្វើឱ្យមានការ កេងប្រវ័ញ្ចលើក្រុមចាញ់ប្រៀប គាំទ្រដោយកត្តាសង្គម កត្តាវប្បធម៌ និងកត្តាច្បាប់។ កត្តាទាំងនេះអាចកំណត់យកជាសសរស្តម្ភ។ ដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយប្រសិទ្ធភាព ស្ថាប័នរដ្ឋាភិបាល ដូចជា ស្ថាប័ននគរបាល ត្រូវដោះស្រាយសសរស្តម្ភទាំង ៤ នេះដែលបង្កឱ្យមានការរំលោភសិទ្ធិមនុស្ស[500] ។

### ១.គោលគំនិតឋានានុក្រម និងសិទ្ធិទទួលបាន

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទទួលស្គាល់ថាឋានានុក្រមយេនឌ័ររួមចំណែកឱ្យមានការប្រព្រឹត្តបទល្មើសលើស្ត្រី និងក្មេងស្រី។ ឋានានុក្រម និងសិទ្ធិទទួលបានរបស់បុរស ឆ្លុះបញ្ចាំងការយល់ថា បុរសមានប្រៀបជាងស្ត្រី និងក្មេងស្រី។ ក្នុងបរិបទនៃទំនាក់ទំនងបែបឋានានុក្រម បុរសជឿថា ពួកគេមានហេតុផល ឈ្លាសវៃ និងពូកែសម្រេចចិត្តជាងស្ត្រី និងក្មេងស្រី។ ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រីជឿថា ពួកគេមានសិទ្ធិទទួលបានការស្តាប់បង្គាប់ពីស្ត្រីនិងក្មេងស្រីក្នុងកម្រិតណាមួយ។ ពួកគេជឿថាប្រសិនបើពួកគេពន្យល់ពីគោលជំហរផ្ទាល់ខ្លួនដោយសមហេតុផល និងច្បាស់លាស់ ស្ត្រីជាដៃគូគួរយល់ស្របតាមពួកគេ។ ពួកគេយល់ថា ការជំទាស់របស់ស្ត្រី "មិនសមហេតុផល" ឬ "ឆ្កួតលីលា"។ គំនិតរបស់ជនបង្កដែលយល់ថា ពួកគេមានសិទ្ធិទទួលបានអំណាច គឺជាចំណុចស្នូលនៃឋានានុក្រម និងតែងត្រូវបានពង្រឹងដោយច្បាប់ ទំនៀមទម្លាប់ បណ្តាញផ្សព្វផ្សាយ និងស្ថាប័នសង្គមផ្សេងទៀត។

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រដេញដោលពីឋានានុក្រម និងសិទ្ធិទទួលបាន តាមរយៈការផ្តោតការយកចិត្តទុកដាក់លើសុវត្ថិភាព/សុខុមាលភាព និងស្វ័យភាពរបស់ជនរងគ្រោះនិងការរក្សាឱ្យជនបង្កទទួលខុសត្រូវ

500. Ellen Pence, Laura Connelly, and Melissa Scaia, 'Turning Points: A Nonviolence Curriculum for Women,' Minnesota: 2011, at: https://www.theduluthmodel.org/wp-content/uploads/2017/03/Turning-Points-Curricula-for-Women-Who-Use-Violence-Preview.pdf.

លើអំពើហិង្សារបស់ខ្លួន។ នៅពេលនគរបាលអសកម្ម ឬ គាំទ្រឥរិយាបថរើសអើងរបស់ជនបង្កចំពោះស្ត្រី និងក្មេងស្រី មានន័យថា នគរបាលសមគំនិតក្នុងបទល្មើសនោះ។

**២.សមត្ថភាពបង្ខំឱ្យអ្នកដែលមានឋានានុក្រមទាបស្តាប់តាម**
សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនឹងទទួលស្គាល់ថាភាពក្រោមបង្គាប់របស់ស្ត្រីនិងក្មេងស្រីនិងការទទួលយកស្ថានភាពតូចទាបរបស់ពួកគេ ត្រូវបានពង្រឹងក្នុងសង្គម។ ដើម្បីប្រឆាំងនឹងការពង្រឹងក្នុងសង្គមនេះ ការឆ្លើយតបរបស់នគរបាលចំពោះបទល្មើសដែលប្រព្រឹត្តលើស្ត្រីនិងក្មេងស្រី រួមទាំងអំពើហិង្សា នឹងលើកកម្ពស់សមភាពនិងភាពម្ចាស់ការរបស់ស្ត្រី និងក្មេងស្រី។

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ នឹងដោះស្រាយនិងប្រយុទ្ធប្រឆាំងជាវិជ្ជមានចំពោះទំនោររបស់ស្ត្រី និងក្មេងស្រីក្នុងការស្តីបន្ទោសខ្លួនឯងថាជាដើមហេតុនាំឱ្យមានការប្រព្រឹត្តបទល្មើសទាំងនោះ ទទួលខុសត្រូវលើអំពើហិង្សារបស់ជនបង្កនិងតម្កល់តម្រូវការរបស់ជនបង្កខ្ពស់ជាងតម្រូវការផ្ទាល់ខ្លួន។ ផ្ទុយទៅវិញ នគរបាលនឹងផ្តោតអាទិភាពលើសុវត្ថិភាព/សុខុមាលភាពនិងសមភាពរបស់ជនរងគ្រោះក៏ដូចជាការទទួលខុសត្រូវរបស់ជនល្មើស។

**៣.ការចាត់ទុកអ្នកដែលមានឋានានុក្រមទាប ជាវត្ថុ**
សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទទួលស្គាល់ថាអំពើហិង្សាលើស្ត្រី និងក្មេងស្រីគឺជាទម្រង់ធ្ងន់ធ្ងរនៃការចាត់ទុកស្ត្រីនិងក្មេងស្រីជាវត្ថុនិងទទួលស្គាល់ថាជនបង្កប្រើប្រាស់អំពើហិង្សាដើម្បីបង្កអន្តរាយដល់ភាពជាមនុស្សរបស់ជនរងគ្រោះ។ ការឆ្លើយតបរបស់នគរបាលគួរបង្ហាញថា ស្ត្រី និងក្មេងស្រីមានសិទ្ធិទទួលបានសុវត្ថិភាពសមភាព សេរីភាព យុត្តិធម៌ និងសិទ្ធិមនុស្សពេញលេញ។

ការចាត់ទុកស្ត្រី និងក្មេងស្រីជាវត្ថុ មានទម្រង់ជាច្រើន និងមានគោលបំណងផ្តល់សនិទានភាពដល់ការប្រើប្រាស់អំពើហិង្សាលើស្ត្រី និងក្មេងស្រីយ៉ាងទូលំទូលាយ។ តាមរយៈការយល់ថា ស្ត្រី និងក្មេងស្រីជាវត្ថុ មិនមែនមនុស្ស ជនបង្កជឿថា ពួកគេមានហេតុផលក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈអំពើហិង្សា។

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនឹងដាក់បញ្ចូលសារស្តីពីសមភាព និងសិទ្ធិមនុស្សក្នុងការរួចផុតពីអំពើហិង្សាតាមរយៈទំនាក់ទំនងផ្ទាល់របស់មន្ត្រីនគរបាលជាមួយជនរងគ្រោះ និងជនល្មើស។ ចំណុចនេះនឹងរំលេចក្នុងសេចក្តីបង្គាប់គោលនយោបាយ ទម្រង់ជាលាយលក្ខណ៍អក្សរនិងការអនុវត្តប្រចាំថ្ងៃដែលត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់សុវត្ថិភាព និងស្វ័យភាពរបស់ស្ត្រី និងក្មេងស្រី។

**៤.សមត្ថភាពរបស់អ្នកនៅផ្នែកខាងលើនៃឋានានុក្រមក្នុងការប្រើប្រាស់ទណ្ឌកម្ម អំពើហិង្សា ឬការបង្ខិតបង្ខំដោយមិនទទួលរងផលវិបាក**
សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រត្រូវដោះស្រាយបញ្ហាដែលកើតឡើងជាច្រើនសតវត្សរ៍ពាក់ព័ន្ធនឹងសិទ្ធិរបស់បុរសក្នុងការប្រព្រឹត្តបទល្មើសលើស្ត្រី និងក្មេងស្រីដោយគ្មានទោស។ តាមរយៈការឆ្លើយតបដែលផ្តល់ផលវិបាកឆាប់រហ័ស និងច្បាស់លាស់សម្រាប់ការប្រព្រឹត្តអំពើហិង្សា សកម្មភាពរបស់នគរបាលនឹងមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ។ នគរបាលជាតួអង្គយ៉ាងសំខាន់ដែលបង្អាក់សិទ្ធិអំណាចរបស់បុរសក្នុងការប្រើប្រាស់អំពើហិង្សា និងផ្លាស់ប្តូរការគិតរបស់សហគមន៍ចំពោះសិទ្ធិរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសិទ្ធិមនុស្ស។ គ្មានប្រព័ន្ធណាផ្សេងទៀតដែលមានអំណាចអនុវត្តន៍ច្បាប់ឬប្រព័ន្ធច្បាប់ដើម្បីរក្សាការទទួលខុសត្រូវរបស់ជនបង្កអំពើហិង្សាឡើយ។ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ បង្វែរការទទួលខុសត្រូវលើការបញ្ឈប់អំពើហិង្សាពីជនរងគ្រោះទៅរដ្ឋ។

ការឆ្លើយតបដោយមានការសម្របសម្រួលពីសហគមន៍ (CCR) ជាកិច្ចខិតខំប្រឹងប្រែងអន្តរស្ថាប័នដើម្បីផ្លាស់ប្តូរបរិយាកាសនៃការអត់ឱនអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈការបញ្ជ្រាបក្នុងស្ថាប័ននូវការអនុវត្តនិងនីតិវិធីដែលផ្តោតសំខាន់លើសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនល្មើស។ មធ្យោបាយក្នុងការឆ្លើយតបនេះដែលជាការរៀបចំការងាររវាង និងក្នុងចំណោមប្រព័ន្ធផ្សេងៗនឹងផ្តល់ឱ្យស្ថាប័ននូវចំណុចខាងក្រោម ៖

- ការផ្លាស់ប្តូរគោលនយោបាយ
- ការផ្លាស់ប្តូរនីតិវិធី
- ទីភ្នាក់ងារនីមួយៗចែករំលែកទិន្នន័យ និងពិនិត្យករណីឡើងវិញ
- ការសហការដឹកនាំដោយអង្គការស្ត្រី
- វគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងពិធីសារដែលបង្កើតឡើងថ្មី។ល។

**ការអនុវត្តច្បាប់ត្រូវខិតខំជម្រុះសសរស្តម្ភទាំង ៤ នេះដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។**
ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី យើងត្រូវដោះស្រាយសសរស្តម្ភទាំង ៤ នេះដែលបន្តជំរុញឱ្យមានការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ដើម្បីរក្សាការទទួលខុសត្រូវរបស់បុរស ស្ត្រី និងជនរងគ្រោះត្រូវយល់ថា នគរបាលគឺជាធនធានមួយ។ ខណៈដែលមន្ត្រីនគរបាលដែលគិតគូរពីយេនឌ័រអាចកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តដោយសារការរាយការណ៍ ស្ត្រី និងក្មេងស្រីនឹងមានជំនឿចិត្តលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលបំពេញតម្រូវការសុវត្ថិភាព និងបង្កើនសុខុមាលភាព និងស្វ័យភាពរបស់ពួកគេ។

ជនបង្កពឹងផ្អែកលើអំណាចដែលខ្លួនមានលើជនរងគ្រោះដើម្បីជាខែលការពារខ្លួនពីអន្តរាគមន៍ផ្លូវច្បាប់។ ដូច្នេះសមត្ថភាពធ្វើការជាមួយជនរងគ្រោះដោយសារអំពើហិង្សាអាស្រ័យលើការជឿជាក់របស់ជនរងគ្រោះ ថា ៖

- អន្តរាគមន៍របស់នគរបាលនឹងរារាំងអំណាចរបស់ជនបង្ក។
- នគរបាលខិតខំស្វែងយល់ពីតថភាពនៃបទពិសោធន៍របស់ជនរងគ្រោះ។
- នគរបាលមានវិធីសាស្ត្របែបសហការក្នុងការធ្វើការជាមួយជនរងគ្រោះ។
- នគរបាលនៅចាំជួយជានិច្ចមិនថាយូរប៉ុណ្ណានោះទេ។



ជាទូទៅស្ថាប័ននគរបាលនិងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតមានឥទ្ធិពលលើ ប្រជាជនក្នុងសហគមន៍។ សារដែលបង្ហាញជូនជនរងគ្រោះជនល្មើសនិងកុមារនៅចំណុចនីមួយៗនៃអន្តរាគមន៍ អាចធ្វើឱ្យញញើត ឬអាចបំផុសអំពើហិង្សាកាន់តែច្រើន។ រាល់ទំនាក់ទំនងរបស់នគរបាលអាចរួមចំណែកដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះឬគាំទ្រជនបង្ក។សកម្មភាពរបស់នគរបាលមិនងាយមានភាពអព្យាក្រឹត្យនោះទេ។

## គោលបំណងទី ២៖ បង្កើត និងពិនិត្យតាមដានការផ្លាស់ប្តូរក្នុងស្ថាប័នតាមរយៈ“មធ្យោបាយ ៨ ចំណុចដែលប្រើប្រាស់ដោយស្ថាប័ននានាដើម្បីសម្របសម្រួលបុគ្គលិក”

ស្ថាប័ននគរបាល (ជាញឹកញាប់រួមជាមួយនឹងស្ថាប័នផ្សេងទៀតដែលជាផ្នែកមួយនៃការឆ្លើយតបដោយមានការសម្របសម្រួលពីសហគមន៍[501]) អាចប្រើប្រាស់មធ្យោបាយចម្រុះដើម្បីបញ្ជ្រាបគោលគំនិតនិងការអនុវត្តអន្តរាគមន៍ថ្មីៗក្នុងស្ថាប័ន។ ការវិភាគមធ្យោបាយ ៨ ចំណុច ដែលបង្ហាញឡើងក្នុងជំពូកនេះ ជាវិធីជាក់ស្តែងសម្រាប់ឱ្យថ្នាក់ដឹកនាំនគរបាលបញ្ជ្រាបការផ្លាស់ប្តូរក្នុងស្ថាប័ននគរបាលនិងពង្រឹងគោលគំនិតនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។

## ហេតុអ្វីការអប់រំ និងការបណ្ដុះបណ្ដាលតែម្យ៉ាងមិនអាចនាំទៅរកការផ្លាស់ប្ដូរក្នុងស្ថាប័ន ?

ការផ្ដល់ការអប់រំនិងការបណ្ដុះបណ្ដាលដល់មន្ត្រីនគរបាលស្ដីពីការរំញោចយេនឌ័រមិនទាន់អាចផ្លាស់ប្ដូរការអត់ឱនចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីបានឡើយ ប្រសិនបើ ៗ. គ្មានការផ្លាស់ប្ដូរគោលនយោបាយ និងការអនុវត្តបែបលម្អៀង។

ការបណ្ដុះបណ្ដាលអាចបង្កើនមនសិការរបស់មន្ត្រីម្នាក់ៗ ប៉ុន្តែមន្ត្រីទាំងនោះនៅតែប្រឈមនឹងឧបសគ្គដែលបណ្ដាលមកពីគោលនយោបាយ កង្វះធនធាន ឬឧបសគ្គផ្នែកស្ថាប័នផ្សេងទៀតក្នុងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ មិនមែននគរបាលគ្រប់រូបសុទ្ធតែទទួលយកគោលគំនិតបង្កប់ក្នុងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនោះទេ ហើយនគរបាលដែលទទួលយកគោលគំនិតទាំងនោះ អាចនឹងលាឈប់ពីការងារ និងត្រូវបានជំនួសឱ្យមន្ត្រីដែលមិនបានដឹងពីបញ្ហាទាំងនេះ។

ៗ. សូមពិចារណាពីមន្ត្រីនគរបាល ៣ នាក់ក្នុងនាយកដ្ឋានតែមួយ ៖ ម៉ាគុស រ៉យ និងជ័ន។

- ម៉ាគុស ជាមន្ត្រីនគរបាលដែលមានគំនិតស៊ីគ្នានឹងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។នៅពេលគាត់ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីឌីណាមិកនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី គាត់យល់យ៉ាងច្បាស់ពីវិសមភាពយេនឌ័រ។
- រ៉យមានគំនិតដែលមិនស៊ីសង្វាក់គ្នានឹងរំញោចយេនឌ័រ។ ការផ្ដល់ការការអប់រំ និងការបណ្ដុះបណ្ដាលដល់រ៉យស្ដីពីរំញោចយេនឌ័រ មិនទាន់អាចផ្លាស់ប្ដូរគំនិតរបស់គាត់បានឡើយ។ ការបន្តផ្ដល់ការបណ្ដុះបណ្ដាល និងការអប់រំបន្ថែមប្រហែលជាគ្មានប្រសិទ្ធភាពទេ។
- ជ័នទទួលយកការបណ្ដុះបណ្ដាលស្ដីពីរំញោចយេនឌ័រ។ ក្រោយការបណ្ដុះបណ្ដាលគាត់ផ្លាស់ប្ដូរគំនិតខ្លះៗដែរ។

មន្ត្រីទាំង ៣ នាក់នេះឆ្លើយតបខុសៗគ្នាទៅនឹងការបណ្ដុះបណ្ដាលស្ដីពីរំញោចយេនឌ័រហើយនៅពេលមានតែការបណ្ដុះបណ្ដាល ពួកគេម្នាក់ៗងាយនឹងឆ្លើយតបខុសគ្នាទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ដូច្នេះ ចាំបាច់ត្រូវមានយន្តការក្នុងស្ថាប័នដើម្បីតម្រង់ទិស និងកំណត់ស្តង់ដារសកម្មភាព និងសម្របសម្រួលការងាររបស់មន្ត្រីទាំងបីនាក់នេះដោយមិនគិតពី ទស្សនៈផ្ទាល់ខ្លួនឬកម្រិតនៃការប្ដេជ្ញាចិត្តរបស់មន្ត្រីម្នាក់ៗចំពោះសុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី។

ព្រំដែនកំណត់មួយទៀតនៃការបណ្ដុះបណ្ដាលគឺពេលខ្លះការបណ្ដុះបណ្ដាលត្រូវបាន ផ្ដល់ជូនតែមន្ត្រីឯកទេសផ្នែកអំពើហិង្សាក្នុងគ្រួសារ ឬមន្ត្រីផ្នែកគ្រួសារ។ មន្ត្រីឯកទេសទាំងនោះមិនសូវមានសមត្ថភាពស៊ើបអង្កេត និងឆ្លើយតបចំពោះរាល់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីឱ្យបានគ្រប់គ្រាន់ទេ។ ផ្ទុយទៅវិញ គោលនយោបាយ និងពិធីសារស្តង់ដារ និងមានការសម្របសម្រួល បូករួមនឹងយន្តការគណនេយ្យភាពរឹងមាំ អាចផ្ដល់ការណែនាំចាំបាច់ដល់មន្ត្រីគ្រប់រូបក្នុងការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ដូចការគូសបញ្ជាក់ក្នុងជំពូកមុនៗ ភ្នាក់ងារឆ្លើយតបបឋមទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កផលប៉ះពាល់ខ្លាំងជាងគេលើរបៀបដំណើរការករណីនេះក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល។

## លើសពីការអប់រំ និងការបណ្ដុះបណ្ដាល ៖ ការជំរុញឱ្យបុគ្គលិកក្នុងស្ថាប័នមានរំញោចយេនឌ័រ

ដូចការបង្ហាញក្នុងរូបភាពខាងក្រោម ជនបង្កអំពើហិង្សាលើស្ត្រីនិងក្មេងស្រីច្រើនតែបញ្ឈប់អំពើហិង្សានៅពេលគាត់ប្រឈមនឹងការទទួលខុសត្រូវនៅគ្រប់ដំណាក់កាលនៃជីវិតរបស់គាត់។ ការផ្លាស់ប្ដូរ ក្នុងស្ថាប័នខិតខំពង្រឹងសមត្ថភាពរបស់នគរបាល និងស្ថាប័នប្រព័ន្ធយុត្តិធម៌ផ្សេងទៀតក្នុងការរក្សាការទទួលខុសត្រូវរបស់ជនបង្កលើអំពើហិង្សា។

501. សម្រាប់ខ្លឹមសារបន្ថែមស្ដីពីសារៈសំខាន់នៃការសម្របសម្រួលសូមមើលជំពូក៨៖“ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌” និងកញ្ចប់សេវាសំខាន់ៗរបស់អង្គការសហប្រជាជាតិសម្រាប់ស្ត្រីនិងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា៖គោលការណ៍ណែនាំស្ដីពីសមាសធាតុស្នូល និងគុណភាព ៖ https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence






## ប្រើប្រាស់មធ្យោបាយទូទៅក្នុងការឆ្លើយតបដោយមានការសម្របសម្រួលពីសហគមន៍ ប្រកបដោយប្រសិទ្ធភាព

ការឈានទៅបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីបាន បង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នតាមវិធីជាច្រើន ដូចជា ការលុបបំបាត់ការលើកលែងការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ក្នុងផ្លូវច្បាប់ ការបង្កើតមុខតំណែងគិលានុបដ្ឋាកត្រួតពិនិត្យសម្រាប់ករណីប្រទូស្តកេរខ្មាស[502]ក្នុងមន្ទីរពេទ្យ និងក្នុងច្បាប់ចាប់ខ្លួនជាកាតព្វកិច្ចក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។ ការផ្លាស់ប្តូរក្នុង ស្ថាប័នទាំងនេះផ្តល់ទាំងលទ្ធផលគាប់ចិត្ត និងលទ្ធផលមិនគាប់ចិត្ត។ ស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ នឹងខិតខំលុបបំបាត់ចំណុចខ្វះខាតរវាងតម្រូវការរបស់ជនរងគ្រោះ និងអ្វីដែលផ្តល់ជូនដោយស្ថាប័ន។ មានសមត្ថភាពសំខាន់ៗ និងវិធីសាស្ត្រជាច្រើនសម្រាប់ឱ្យស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ យកទៅប្រើប្រាស់ក្នុងការបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័ន។

## ការជំរុញការចូលរួមរបស់ជនរងគ្រោះ និងអង្គការស្ត្រី

ការយល់ដឹងពីបទពិសោធន៍ផ្ទាល់ និងជាក់ស្តែងរបស់ជនរងគ្រោះជាចំណុចសំខាន់ក្នុងការវិភាគគោលនយោបាយជាធរមាន ឬបង្កើតគោលនយោបាយថ្មីដែលបង្កើនសុវត្ថិភាពដល់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក។ ដើម្បីកំណត់រកបញ្ហាក្នុងការឆ្លើយតបរបស់ប្រព័ន្ធមួយ និងយល់ច្បាស់ថាតើបញ្ហាទាំងនោះកើតឡើងដោយរបៀបណានគរបាលត្រូវស្តាប់បទពិសោធន៍របស់អ្នកដែលរងគ្រោះដោយអំពើហិង្សា (និងផលប៉ះពាល់របស់វា) និងកំណត់អន្តរាគមន៍ដែលនគរបាលចង់កែលម្អ។

អង្គការស្ត្រីដែលធ្វើការដោយផ្ទាល់ជាមួយជនរងគ្រោះ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការសម្ភាសន៍ ឬក្រុមពិភាក្សាជាមួយស្ត្រី និងក្មេងស្រី។ ស្ថាប័នធ្វើការជាមួយស្ត្រីដែលរងគ្រោះដោយទម្រង់ប្រសព្វគ្នានៃការគៀបសង្កត់ (ដូចជាស្ថាប័នដែលជួយដល់សហគមន៍ជនចំណាកស្រុក និងសហគមន៍ជនភៀសខ្លួន អង្គការសិទ្ធិជនពិការ និងអង្គការដែលតំណាងឱ្យសហគមន៍ជាតិសាសន៍ ឬជាតិពន្ធុ) អាចដើរតួនាទីសំខាន់ក្នុងការ

502. គិលានុបដ្ឋាកត្រួតពិនិត្យសម្រាប់ករណីប្រទូស្តកេរខ្មាស ជាគិលានុបដ្ឋាកដែលទទួលការបណ្តុះបណ្តាលពិសេសក្នុងការផ្តល់ការថែទាំកោសលវិច័យវេជ្ជសាស្ត្រដល់អ្នកជំងឺដែលរងគ្រោះដោយការប្រទូស្តកេរខ្មាស ឬការរំលោភបំពានផ្លូវភេទ។

ជំរុញការចូលរួមរបស់ស្ត្រី និងក្មេងស្រីដែលជាញឹកញាប់មិនទទួលបានសេវាគ្រប់គ្រាន់ ឬមិនទទួលបានការយកចិត្តទុកដាក់ពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[503]។ មិនមែនស្ត្រីនិងក្មេងស្រីគ្រប់រូបសុទ្ធតែរងគ្រោះដោយអំពើហិង្សាតាមរបៀបដូចគ្នានោះទេហើយស្ត្រីនិងក្មេងស្រីជាច្រើនរងគ្រោះដោយទម្រង់ចម្រុះនៃការគៀបសង្កត់ ដោយសារជាតិសាសន៍ ជាតិពន្ធុ ស្ថានភាពចំណាកស្រុក ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ពិការភាព និងផ្នែកផ្សេងទៀតនៃអត្តសញ្ញាណរបស់ពួកគេ។ ប្រសិនបើស្ថាប័ននគរបាលស្តាប់មតិរបស់ស្ត្រីដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនិងដោះស្រាយចំណុចខ្វះខាត ឬបញ្ហាក្នុងប្រព័ន្ធ ប្រព័ន្ធនេះនឹងផ្តល់ប្រសិទ្ធភាពជាងមុនសម្រាប់ស្ត្រីគ្រប់រូប។

ការសម្ភាសន៍ឬក្រុមពិភាក្សាជាមួយជនរងគ្រោះក្រោមការសម្របសម្រួលដោយអង្គការសង្គមស៊ីវិលដែលទទួលបានទំនុកចិត្តអាចផ្តល់ព័ត៌មានដ៏មានតម្លៃស្តីពីបទពិសោធន៍ផ្ទាល់របស់ស្ត្រី និងក្មេងស្រី ពាក់ព័ន្ធនឹងការរងគ្រោះដោយអំពើហិង្សាក្នុងសហគមន៍មូលដ្ឋាន[504]។ គួរស្នើឱ្យស្ត្រីនិងក្មេងស្រីឆ្លុះបញ្ចាំងបទពិសោធន៍ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងគោលនយោបាយ ឬការអនុវត្តនានា។ ស្ត្រី និងក្មេងស្រីអាចជួយកំណត់រកចំណុចខ្វះខាតផ្សេងទៀតក្នុងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

## ការបង្កើតគោលនយោបាយពាក់ព័ន្ធគ្នាក្នុងចំណោមស្ថាប័នយុត្តិធម៌

ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ នគរបាល អយ្យការ មន្ត្រីទទួលបន្ទុកត្រួតពិនិត្យជនល្មើសដែលកំពុងអនុវត្តការព្យួរទោសនិងតុលាការមានតួនាទីពាក់ព័ន្ធគ្នាទៅវិញទៅមកក្នុងការដំណើរការករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ដូច្នេះ គេមិនអាចវិភាគវិធាន គោលនយោបាយ និងពិធីសាររបស់ស្ថាប័ននគរបាលដាច់ដោយឡែកពីគ្នាបានទេ។ គោលនយោបាយរបស់នគរបាល មេធាវី អ្នកបម្រើសេវាទូរស័ព្ទសង្គ្រោះបន្ទាន់ និងអយ្យការ ត្រូវតែបន្សីគ្នា ដើម្បីធានានូវសេវាដែលឆ្លើយតបនឹងយេនឌ័រ ចាប់ពីការទូរស័ព្ទសុំជំនួយដំបូងរហូតដល់ការដំណើរការករណីមួយក្នុងតុលាការ។ នគរបាលជាច្រើន ប្រែជាអស់សង្ឃឹមនៅពេលពួកគេធ្វើការស៊ើបអង្កេតល្អិតល្អន់លើករណីមួយ និងបង្ហាញករណីនោះទៅអយ្យការ ប៉ុន្តែអយ្យការបែរជាបដិសេធមិនបន្តបទចោទប្រកាន់ទៅវិញ។

ទន្ទឹមនឹងនេះ គោលនយោបាយរបស់នគរបាលមិនសុទ្ធតែតម្រូវឱ្យមន្ត្រីនគរបាលប្រមូលព័ត៌មានដែលអយ្យការត្រូវការដើម្បីកសាងសំណុំរឿងមួយដោយជោគជ័យនោះទេ។ ការកៀរគរឱ្យស្ថាប័នសហការគ្នាពិនិត្យឡើងវិញនិងកែសម្រួលគោលនយោបាយជាវិធីដ៏មានប្រសិទ្ធភាពក្នុងការធានាថា គោលនយោបាយពាក់ព័ន្ធគ្នា និងពង្រឹងឱ្យគ្នាទៅវិញទៅមក[505]។

នគរបាល អយ្យការ ចៅក្រម និងតួអង្គផ្សេងទៀតដែលពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក៏ដឹងពីចំណុចខ្វះខាតក្នុងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ។ យើងពឹងផ្អែកលើអ្នកពាក់ព័ន្ធទាំងនេះដើម្បីរៀនសូត្រពីជំហានពាក់ព័ន្ធក្នុងការដំណើរការសំណុំរឿងនិងស្វែងយល់ពីកត្តាដែលជះឥទ្ធិពលលើសេចក្តីសម្រេចរបស់ពួកគេលើករណីនានា។

## ការជួបជាមួយនគរបាលនៅមូលដ្ឋាន៖ការបង្កើតផែនទីនៃការដំណើរការករណី

ស្ថាប័ននគរបាលអាចផ្អែកលើជំនាញរបស់នគរបាលជួរមុខ និងអ្នកគ្រប់គ្រងថ្នាក់កណ្តាលដើម្បីកំណត់រកបញ្ហាក្នុងការដំណើរការករណីបច្ចុប្បន្ននិងស្វែងយល់ពីជម្រើសនានា។ ភាព ប៉ិនប្រសប់ក្នុងការជួបជាមួយនគរបាលជាវិធីមួយក្នុងការកសាងសម្ព័ន្ធភាព និងកាត់បន្ថយការដើរបញ្ច្រាស់គោលដៅនៃការបង្កើតឱ្យមានការផ្លាស់ប្តូរក្នុងស្ថាប័ន។

503. ឧ. នៅ Duluth រដ្ឋ Minnesota អង្គការជនជាតិដើមអាមេរិកដែលធ្វើការដោយផ្ទាល់ជាមួយស្ត្រីជនជាតិដើមភាគតិច ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការផ្តល់មតិពីស្ត្រីជនជាតិដើមភាគតិចស្តីពីបទពិសោធន៍របស់ពួកគេ ពាក់ព័ន្ធនឹងការឆ្លើយតបរបស់ស្ថាប័នអនុវត្តន៍ច្បាប់ទៅនឹងករណីប្រទូស្តកេរខ្មាស។ សូមមើល ការកែតម្រូវជំនឿសក្តិសិទ្ធ និងកម្មវិធីជួយដល់ជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាស "សវនកម្មសុវត្ថិភាព និងគណនេយ្យភាពនៃការឆ្លើយតបចំពោះស្ត្រីជនជាតិដើមដែលរាយការណ៍ករណីប្រទូស្តកេរខ្មាសនៅDuluth,Minnesota ២០០៦-២០០៨ ៖ https://praxisinternational.org/wpcontent/uploads/2015/12/TTAMSHTaAuditReport2011.pdf.

504. ឧ. នៅ Duluth រដ្ឋ Minnesota ក្រុមពិភាក្សាជាមួយជនរងគ្រោះ ជួយឱ្យនគរបាលលុបបំបាត់ការសួរចម្លើយជនរងគ្រោះ និងជនបង្កក្នុងបន្ទប់តែមួយ។

505. សម្រាប់ព័ត៌មានបន្ថែមស្តីពីគោលនយោបាយពាក់ព័ន្ធគ្នាសូមមើលជំពូក៨ស្តីពី"ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌"។

ខាងក្រោមនេះជាឧទាហរណ៍នៃសំណួរ និងចំណុចផ្តោតសំខាន់ៗសម្រាប់ការសួរចម្លើយ ៖

- តើមន្ត្រីនគរបាល/អ្នកគ្រប់គ្រងថ្នាក់កណ្តាលមានតួនាទីអ្វីក្នុងការដំណើរការករណី? សូមកត់ត្រានៅពេលមន្ត្រីនគរបាល/អ្នកគ្រប់គ្រងថ្នាក់កណ្តាល ពិពណ៌នាពីសកម្មភាពរបស់គាត់ក្នុងករណីនេះ។
- តើមន្ត្រីនគរបាល/អ្នកគ្រប់គ្រងថ្នាក់កណ្តាលផ្តោតសំខាន់លើអ្វី នៅពេលដោះស្រាយករណីមួយ?
- តើនរណាខ្លះទៀតដែលត្រូវសួរចម្លើយ?
- តើមន្ត្រីនគរបាល/អ្នកគ្រប់គ្រងថ្នាក់កណ្តាលផ្សារភ្ជាប់ជាមួយនរណា? តើនរណាទទួលសំណុំរឿងដែលមន្ត្រីនគរបាលបានដាក់?
- តើនរណាពិនិត្យតាមដានការងាររបស់មន្ត្រីនគរបាល?
- តើមន្ត្រីនគរបាលត្រូវមានធនធានអ្វីខ្លះដើម្បីដំណើរការករណី?
- តើមន្ត្រីនគរបាលត្រូវបំពេញទម្រង់បែបបទនិងឯកសារអ្វីខ្លះនៅពេលដំណើរការករណីមួយ?
- តើការងាររបស់មន្ត្រីនគរបាល/អ្នកគ្រប់គ្រងថ្នាក់កណ្តាលស្តីពីករណីអំពើហិង្សាលើស្ត្រី និងកុមារផ្អែកតាមច្បាប់ វិធាន បញ្ញត្តិ និងគោលនយោបាយអ្វីខ្លះ?

**ការវិភាគខ្លឹមសារ ៖ ការអាន និងវិភាគសំណុំរឿង**

សំណុំរឿងជាកំណត់ត្រាផ្លូវការ ឬជា "រឿងរ៉ាវ" នៃអ្វីដែលបានកើតឡើងក្នុងករណីណាមួយ។ សំណុំរឿងបង្ហាញពីសកម្មភាពឆ្លើយតបរបស់ស្ថាប័ននគរបាល។ យើងត្រូវអានសំណុំរឿងដោយពិចារណាពីទស្សនៈរបស់អ្នកអនុវត្តន៍ម្នាក់ៗដែលពាក់ព័ន្ធនឹងសំណុំរឿងនោះ និងពិចារណាពីទស្សនៈរបស់អង្គការស្ត្រីដែលផ្តល់សេវាដល់ជនរងគ្រោះផងដែរ។ ការអានសំណុំរឿង ជួយឱ្យយើងញែកបញ្ហាប្រព័ន្ធ (តើស្ថាប័នរៀបចំបុគ្គលិកដូចម្តេចដើម្បីឆ្លើយតបទៅនឹងករណីនានាតាមវិធីជាក់លាក់ តាមរយៈគោលនយោបាយ និងនីតិវិធី?) និងបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តការងាររបស់បុគ្គលិកម្នាក់ៗ (ថាតើគាត់ធ្វើការងារប្រកបដោយសមត្ថភាព ឬទេ)។ ការសំខាន់គឺត្រូវវិភាគផ្នែកប្រទាក់ក្រឡាគ្នានៃសំណុំរឿងដើម្បីយល់ច្បាស់ថាតើអ្នកអនុវត្តន៍ត្រូវបានរៀបចំដូចម្តេចក្នុងការចាត់វិធានការលើករណីមួយ។

ការវិភាគសំណុំរឿង រួមមាន៖

- ការយល់ពីរបៀបបង្កើតឯកសារ និងទម្រង់បែបបទ និងរបៀបប្រើប្រាស់
- ការវិភាគចំណុចផ្តោតសំខាន់និងខ្លឹមសាររបស់ឯកសារទាំងនោះ
- ការសួររកព័ត៌មានដែលមិនបង្ហាញក្នុងឯកសារ។ តើយើងចង់ដឹងអ្វីបន្ថែមទៀត?



**ការវិភាគអត្ថបទ ៖ ការវិភាគគោលនយោបាយ និងពិធីសាររបស់ស្ថាប័ន**

គោលនយោបាយ និងពិធីសារជាផែនទីបង្ហាញផ្លូវស្ថាប័នស្តីពីរបៀបដែលអ្នកអនុវត្តន៍គួរបន្តកិច្ចនីតិវិធីលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ គួរពិនិត្យឡើងវិញលើគោលនយោបាយ និងពិធីសារដើម្បីកំណត់ថាតើគោលនយោបាយ/ពិធីសារទាំងនោះផ្តោតសំខាន់លើតម្រូវការរបស់ជនរងគ្រោះ ឬទេ និងដោយរបៀបណា និងថាតើគោលនយោបាយ/ពិធីសារទាំងនោះរក្សាការទទួលខុសត្រូវរបស់ជនបង្កលើអំពើហិង្សាឬទេ និងដោយរបៀបណា។

**ការសង្កេតមើល ៖ ការសង្កេតមើលបរិយាកាសការងាររបស់នគរបាល**

ការសង្កេតមើលបរិយាកាសការងាររបស់នគរបាលនិងអ្នកជំនាញក្នុងប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌផ្សេងទៀត ផ្តល់ការយល់ដឹងដំបូង និងគំនិតស្តីពីសម្ពាធ និងឱកាសរបស់ពួកគេ។ ការសង្កេតមើលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមការជិះល្បាតដោយនគរបាលការជួបជនបង្កដែលកំពុងអនុវត្តការព្យួរទោស ឬកិច្ចដំណើរការនីតិវិធីតុលាការ។ អ្នកគ្រប់គ្រងថ្នាក់កណ្តាល និងអ្នកដឹកនាំជាន់ខ្ពស់ក្នុងស្ថាប័ននគរបាលអាចទទួលបានចំណេះដឹងល្អៗតាមរយៈការសង្កេតមើលការបំពេញការងាររបស់មន្ត្រីជួរមុខ។

**ប្រអប់ ១**

**"ការវិភាគមធ្យោបាយ ៨ ចំណុច"**

**បេសកកម្ម គោលបំណង និងមុខងារ** ៖ តើមន្ត្រីនគរបាលមានមុខងារ និងគោលបំណងអ្វីពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី? តើមុខងារ និងគោលបំណងទាំងនេះត្រូវបានផ្សព្វផ្សាយទៅនគរបាលដោយរបៀបណា?

ទស្សនាទាន និងទ្រឹស្តី ៖ តើនគរបាលប្រើប្រាស់គោលគំនិតអ្វីខ្លះស្តីពីយេនឌ័រ និងសេវានគរបាល នៅពេលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី?

**វិធាន និងបញ្ញត្តិ** ៖ តើមន្ត្រីនគរបាលអនុវត្តតាមច្បាប់ គោលនយោបាយ ឬពិធីសារអ្វីខ្លះនៅពេលឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី?

**ការអនុវត្តផ្នែករដ្ឋបាល** ៖ តើតារាងត្រួតពិនិត្យ និងទម្រង់បែបបទ តម្រង់ទិសឱ្យមន្ត្រីនគរបាល រួមបញ្ចូល ឬផាត់ចេញព័ត៌មានមួយចំនួនដោយរបៀបណា?

**ការផ្សារភ្ជាប់** ៖ តើទំនាក់ទំនងការងាររវាងមន្ត្រីនគរបាល និងអយ្យការ ជួយដល់ការសម្រេចបានលទ្ធផលនៃករណី ឬទេ?

**ធនធាន** ៖ តើនគរបាលត្រូវការធនធានបន្ថែមអ្វីខ្លះដើម្បីអាចឆ្លើយតប នឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព?

**គណនេយ្យភាព** ៖ តើថ្នាក់លើផ្ទាល់ក្នុងជួរនគរបាល និងអ្នកគ្រប់គ្រងថ្នាក់កណ្តាលមានតួនាទីអ្វីក្នុងការធានាថាការស៊ើបអង្កេត និងការរាយការណ៍អំពើហិង្សាលើស្ត្រី និងក្មេងស្រី បានគិតគូរពីយេនឌ័រ?

**ការអប់រំ និងបណ្តុះបណ្តាល** ៖ នៅពេលមានការផ្លាស់ប្តូរក្នុងស្ថាប័ន តើនគរបាលត្រូវបានបណ្តុះបណ្តាលស្តីពីស្តង់ដារថ្មីៗដោយរបៀបណា?

### មធ្យោបាយ ៨ ចំណុចដែលស្ថាប័ននានាប្រើប្រាស់ដើម្បីសម្របសម្រួលបុគ្គលិក

ការវិភាគមធ្យោបាយ ៨ចំណុចលើកកម្ពស់ការពិនិត្យជាប្រព័ន្ធលើគោលគំនិត គោលនយោបាយ ការអនុវត្ត និងនីតិវិធីដែលត្រូវបានបង្កើតឡើងជាយូរមកហើយដោយស្ថាប័នដែលទទួលខុសត្រូវលើការបង្កើនសុវត្ថិភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការទទួលខុសត្រូវរបស់ជនល្មើស[506]។

ការសំខាន់ត្រូវគូសបញ្ជាក់ថា មធ្យោបាយ ៨ ចំណុច ជាដំណើរការនៃការផ្លាស់ប្តូរក្នុងស្ថាប័នមិនមែនជាកម្រងនៃការអនុវត្តជាក់លាក់ ដែលអាចយកទៅអនុវត្តដូចគ្នាពីសហគមន៍មួយទៅសហគមន៍មួយទៀតនោះទេ។ នៅពេលប្រើប្រាស់មធ្យោបាយ ៨ ចំណុច ស្ថាប័ននគរបាលនីមួយៗ (ក្រោមការពិគ្រោះយោបល់ជាមួយអង្គការស្ត្រី និងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌក្នុងមូលដ្ឋានផ្សេងទៀត) នឹងកំណត់រកចំណុចខ្វះខាតផ្សេងៗក្នុងការឆ្លើយតបរបស់ខ្លួនទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផ្តល់ដំណោះស្រាយផ្សេងៗ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលសមាជិកនៃសហគមន៍សង្គមស៊ីវិល ស្ថាប័នអនុវត្តន៍ច្បាប់សេវាមនុស្សធម៌មន្ត្រីតុលាការនិងមន្ត្រីរដ្ឋាភិបាលខិតខំផ្លាស់ប្តូររបៀបដែលស្ថាប័ននានាដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈការបណ្តុះបណ្តាលបុគ្គលិកឱ្យផ្លាស់ប្តូរការគិត។ ក្នុងរយៈពេល ៤០ ឆ្នាំកន្លងមកនេះ ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នឯកជនបានចំណាយប្រាក់រាប់លានដុល្លារលើការបណ្តុះបណ្តាលនគរបាលនៅទូទាំងពិភពលោក។

ក្រោយរយៈពេលជាច្រើនឆ្នាំនៃការទទួលបានជោគជ័យតិចតួចក្នុងការបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នតាមរយៈការអប់រំ និងការបណ្តុះបណ្តាល វិធីសាស្ត្រថ្មីមួយដែលមានឈ្មោះថា "មធ្យោបាយ ៨ ចំណុច" ត្រូវបានបង្កើតឡើងនៅ Duluth រដ្ឋ Minnesota សហរដ្ឋអាមេរិក ដើម្បីបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នយូរអង្វែងលើរបៀបដែលរដ្ឋាភិបាលសង្គមស៊ីវិលនិងស្ថាប័ននគរបាលដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី [507]។ វិធីសាស្ត្រនេះគ្មានគោលបំណងទិតៀនការអនុវត្តការងាររបស់បុគ្គលម្នាក់ៗឡើយ។ ផ្ទុយទៅវិញ វិធីសាស្ត្រនេះពិនិត្យមើលថាតើ

ការឆ្លើយតបទៅនឹងបទល្មើស និងអំពើហិង្សាលើស្ត្រី និងក្មេងស្រី បង្កើនសុវត្ថិភាពជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក ឬទេ។ "មធ្យោបាយ ៨ ចំណុច" (ដែលលើកមកពិភាក្សាលម្អិតក្នុងផ្នែកខាងក្រោម) ជួយឱ្យស្ថាប័នកំណត់រកចំណុចខ្វះខាតក្នុងប្រព័ន្ធ និងបង្កើតដំណោះស្រាយដើម្បីឱ្យមានការផ្លាស់ប្តូរក្នុងស្ថាប័ន។

មធ្យោបាយ ៨ ចំណុច ជាមធ្យោបាយដែលស្ថាប័ននានាប្រើប្រាស់ដើម្បីរៀបចំរចនាសម្ព័ន្ធការងាររបស់និយោជិក។ ក្នុងករណីនេះសំដៅលើមធ្យោបាយដែលស្ថាប័ននគរបាលប្រើប្រាស់ដើម្បីរៀបចំការងាររបស់នគរបាលក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ នៅពេលសង្កេតមើលការអនុវត្តកម្រិតមធ្យម ល្អប្រសើរ ឬការអនុវត្តដែលបង្កជាបញ្ហាយើងចង់ដឹងថាតើមធ្យោបាយមួយណាក្នុងចំណោមមធ្យោបាយ ៨ ចំណុចនៃការរៀបចំការងាររបស់អ្នកអនុវត្តន៍ដែលជះឥទ្ធិពលលើការឆ្លើយតបនេះ។

ឧទាហរណ៍ ៖

- ស្ថាប័នអាចត្រួតពិនិត្យការងាររបស់នគរបាលដែលឆ្លើយតបនឹងយេនឌ័រ ដើម្បីបង្កើតស្តង់ដារល្អបំផុតមួយសម្រាប់ការឆ្លើយតបរបស់នគរបាល។ យើងអាចប្រើប្រាស់មធ្យោបាយ ៨ ចំណុចដើម្បីសួរថា "តើអាចមានការផ្លាស់ប្តូរអ្វីខ្លះដើម្បីឱ្យមន្ត្រីជួរមុខទាំងអស់ត្រៀមខ្លួនបានល្អ ទទួលបានការគាំទ្រ និងមានការទទួលខុសត្រូវដើម្បីបំពេញស្តង់ដារនោះ?"
- គេអាចកំណត់រកការអនុវត្តគោលនយោបាយ ឬពិធីសារដោយខ្វះចន្លោះ ឬមិនត្រឹមត្រូវដែលអាចបង្កគ្រោះថ្នាក់បន្ថែមទៀតដល់ជនរងគ្រោះនិងក្រុមគ្រួសាររបស់ពួកគេ ដោយប្រើប្រាស់មធ្យោបាយ ៨ ចំណុច។ ឧ. ឧបមាថា អ្នកបម្រើសេវាទូរស័ព្ទសង្គ្រោះបន្ទាន់កាត់ផ្តាច់ការហៅចូលជាជាងប្រើអ្នកបកប្រែនៅពេលគាត់ដឹងថា អ្នកទូរស័ព្ទចូលមានការលំបាកក្នុងការធ្វើទំនាក់ទំនងជាភាសាទូទៅ។ ចំណុចនេះអាចកើតឡើងដោយសារមូលហេតុជាច្រើនដូចជាស្ថាប័នខ្វះគោលនយោបាយស្តីពីការបកប្រែឬស្ថាប័នខ្វះធនធានដើម្បីជួលអ្នកបកប្រែ ឬក៏បុគ្គលិកមិនទទួលខុសត្រូវលើការអនុវត្តតាមគោលនយោបាយជាធរមាន។

មធ្យោបាយ ៨ ចំណុចដែលពិពណ៌នាខាងក្រោម ជួយឱ្យស្ថាប័នកំណត់រកប្រភពបញ្ហាឬចំណុចខ្វះខាតក្នុងការឆ្លើយតបរបស់ស្ថាប័នទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ករណីសិក្សាក្នុងជំពូកនេះពិពណ៌នាពីរបៀបអនុវត្តមធ្យោបាយ ៨ ចំណុចដោយស្ថាប័ននគរបាលនៅប្រទេសហ្សកហ្ស៊ី។

**១.បេសកកម្ម គោលបំណង និងមុខងារ**

នគរបាលត្រូវបានតម្រឹមតម្រង់ដោយបេសកកម្មនៃស្ថាប័នរបស់ពួកគេ ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គោលបំណងនៃការងាររបស់ពួកគេ និងមុខងាររបស់ពួកគេក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទូទៅ ជាពិសេស ៖

- បេសកកម្មពាក់ព័ន្ធនឹងដំណើរការទូទៅនិងគោលបំណងរួមរបស់ស្ថាប័ន។ សន្មតថា សកម្មភាពនីមួយៗ និងជំហាននៃការដំណើរការករណីក្នុងស្ថាប័ន ឆ្លុះបញ្ចាំងពីបេសកកម្មនោះ។
- គោលបំណងសំដៅលើគោលបំណងរបស់ស្ថាប័នលើដំណើរការជាក់លាក់មួយក្នុងបេសកកម្មរួមនោះ ដូចជាការឆ្លើយតបរបស់នគរបាលទៅនឹងការទូរស័ព្ទទាក់ទងក្នុងគ្រាអាសន្ន ឬនីតិវិធីចាប់ខ្លួន។
- មុខងារសំដៅលើមុខងាររបស់អ្នកអនុវត្តន៍ក្នុងបរិបទជាក់លាក់មួយ។ ឧ. តើមន្ត្រីនគរបាលម្នាក់ត្រូវបានណែនាំឱ្យធ្វើអ្វីក្រោមកាលៈទេសៈជាក់លាក់?

អ្នកគ្រប់គ្រងថ្នាក់កណ្តាលស្វែងយល់ថាតើទំនាក់ទំនងរវាងបេសកកម្ម គោលបំណង និងមុខងាររបស់អ្នកអនុវត្តន៍ក្នុងប្រព័ន្ធនិងស្ថាប័នជាក់លាក់មានសារៈសំខាន់កម្រិតណាចំពោះសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក។

506. ករណីសិក្សាដែលត្រូវបានលើកឡើងក្នុងជំពូកនេះ ពិពណ៌នាពីរបៀបប្រើប្រាស់មធ្យោបាយ ៨ ចំណុច ដើម្បីបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័នក្នុងក្រសួងមហាផ្ទៃ ប្រទេសហ្សកហ្ស៊ី។ សូមមើល "ការបង្កើតការវាយតម្លៃហានិភ័យជនល្មើស ៖ ប្រទេសហ្សកហ្ស៊ី" អង្គការសិទ្ធិជាសកលដើម្បីស្ត្រី (២០១៧) https://globalrightsforwomen.org/wp-content/uploads/2020/02/Georgia-2017-%E2%80%93-Developing-Offender-Risk-Assessment-FINAL-2.pdf

507. Ellen Pence, Ph.D. បានបង្កើត "សវនកម្មគណនេយ្យភាព និងសុវត្ថិភាព" ។ ដំណើរការសវនកម្មសុវត្ថិភាពដំបូងផ្អែកលើមធ្យោបាយ៨ចំណុចដែលប្រើប្រាស់ដោយស្ថាប័នដើម្បីកំណត់ស្តង់ដារលើសកម្មភាពរបស់បុគ្គលិកក្នុងអង្គការសង្គមស៊ីវិល ស្ថាប័ន ទីភ្នាក់ងាររដ្ឋាភិបាល រួមទាំងនគរបាល។ សូមមើល Michael Paymar, Ellen Pence, and Graham Barnes, Building a Coordinated Community Response to Domestic Violence: Trainer Guide, Praxis International, 2010។

ពេលខ្លះអ្នកគ្រប់គ្រងថ្នាក់កណ្ដាលអាចយល់ថានគរបាលមិនបំពេញមុខងាររបស់ខ្លួន ឬប៉ុនប៉ងអនុវត្តមុខងារមួយដែលសមស្របសម្រាប់ស្ថាប័នមួយប្រភេទផ្សេងទៀត។ ឧ.ក្នុងប្រទេសមួយនៅអាស៊ីកណ្ដាលក្រោយការអនុម័តច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនគរបាលយល់ថាពួកគេត្រូវរ៉ាប់រងការងារយ៉ាងច្រើនក្នុងការផ្តល់ប្រឹក្សាដល់ជនរងគ្រោះ។ ដោយមិនរក្សាការទទួលខុសត្រូវរបស់ជនបង្ក នគរបាលបែរជាខិតខំដើរតួនាទីជាអ្នកផ្តល់ប្រឹក្សាដល់ជនរងគ្រោះទៅវិញ។ នេះជាការដើរបញ្ច្រាស់បេសកកម្ម គោលបំណង និងមុខងាររបស់នគរបាល។ ដូច្នេះចាំបាច់ត្រូវមានកំណែទម្រង់ក្នុងស្ថាប័នដើម្បីបញ្ជូនជនរងគ្រោះទៅអ្នកផ្តល់ប្រឹក្សាជំនាញ ដែលទទួលការបណ្តុះបណ្តាលលើផ្នែកការតស៊ូមតិសម្រាប់ជនរងគ្រោះ។

ការផ្សព្វផ្សាយពីបេសកកម្ម គោលបំណង និងមុខងាររបស់ស្ថាប័នមួយជាលាយលក្ខណ៍អក្សរនឹងផ្តល់មូលដ្ឋានព័ត៌មាននិងតម្រង់ទិសដល់នគរបាលក្នុងការឆ្លើយតបទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ខាងក្រោមនេះជាឧទាហរណ៍មួយនៃស្ថាប័ននគរបាលនៅ Victoria ប្រទេសអូស្ត្រាលី ដែលបេសកកម្ម គោលបំណង និងមុខងាររបស់ស្ថាប័ននេះត្រូវបានសរសេរជាលាយលក្ខណ៍អក្សរ។

ក្នុងស្ថាប័ននគរបាល និងសហគមន៍មួយចំនួន អំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនត្រូវបានចាត់ទុកជាបទល្មើសធ្ងន់ធ្ងរឡើយ។ ដូច្នេះ ការចាត់តាំងឱ្យធ្វើការក្នុងអង្គភាពទទួលបន្ទុកអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាផ្លូវភេទត្រូវបានចាត់ទុកថាមិនសូវមានកិត្យានុភាពដូចការចាត់តាំងឱ្យធ្វើការក្នុងផ្នែកផ្សេងទៀត។ អ្នកគ្រប់គ្រងថ្នាក់កណ្ដាលអាចពង្រឹងសារៈសំខាន់នៃករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី តាមរយៈការឱ្យតម្លៃបទពិសោធន៍ជំនាញ និងសមត្ថភាពដែលទទួលបានក្នុងការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាផ្តល់ឱកាសឡើងតំណែងដល់មន្ត្រីដែលមានការប្តេជ្ញាចិត្តនិងជំនាញក្នុងការឆ្លើយតបទៅនឹងបទល្មើសប្រឆាំងនឹងស្ត្រី និងក្មេងស្រី។ ការគូសបញ្ជាក់ពីសារៈសំខាន់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមរយៈការចាត់វិធានការដាក់លាក់នឹងបង្ហាញសារថា ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីយ៉ាងហ្មត់ចត់ ជាធាតុផ្សំដ៏សំខាន់នៃមុខងាររបស់មន្ត្រីនគរបាល។

### ប្រអប់ ២

**បេសកកម្ម គោលបំណង និងមុខងារ ៖ សារសំខាន់ៗ**

- គួរពិនិត្យបេសកកម្មរបស់ស្ថាប័ននគរបាល គោលបំណងនៃការអនុវត្តជាក់លាក់និងមុខងាររបស់នគរបាលដើម្បីកំណត់ថាតើចំណុចទាំងនេះជួយពង្រឹងគោលដៅនៃការធានាសុវត្ថិភាពរបស់ជនរងគ្រោះនិងការទទួលខុសត្រូវរបស់ជនបង្ក ឬទេ។
- គួរបង្ហាញ/ផ្សព្វផ្សាយឱ្យបានច្បាស់លាស់នូវបេសកកម្ម គោលបំណង និងមុខងារជាលាយលក្ខណ៍អក្សរដល់នគរបាល។
- គោលនយោបាយ ការអនុវត្ត និងសេចក្តីបង្គាប់ទាំងអស់របស់ស្ថាប័ននគរបាលគួរបន្សុីគ្នាទៅនឹងបេសកកម្ម គោលបំណង និងមុខងាររបស់ស្ថាប័ននោះ ពាក់ព័ន្ធនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

### ២) ទស្សនៈ និងទ្រឹស្តី

គោលគំនិត និងទ្រឹស្តី រួមបញ្ចូលភាសា ប្រភេទ ទ្រឹស្តី ការសន្មត ក្របខណ្ឌទស្សនៈវិជ្ជា និងមធ្យោបាយផ្សេងទៀតដែលស្ថាប័នប្រើប្រាស់ដើម្បីរៀបចំរបៀបដែលបុគ្គលិកគិត និយាយ និងសរសេរស្តីពីករណី និងអ្នកពាក់ព័ន្ធ។ គោលគំនិត និងទ្រឹស្តីផ្តល់ព័ត៌មាន និងបង្កផលប៉ះពាល់លើមធ្យោបាយ ៧ ចំណុចផ្សេងទៀត។

គោលនយោបាយឬការអនុវត្តរបស់នាយកដ្ឋាននគរបាលមួយ ជំរុញដោយគោលគំនិត ទ្រឹស្តី ឬការសន្មត។ ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌទាំងអស់បញ្ជ្រាបគោលគំនិត និងទ្រឹស្តីនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងស្ថាប័ន តាមរយៈភាសាដែលស្ថាប័នទាំងនោះប្រើប្រាស់ក្នុងការបណ្តុះបណ្តាល គោលនយោបាយ នីតិវិធី និងសេចក្តីបង្គាប់ផ្សេងទៀត។ សេវានគរបាលដែល ឆ្លើយតបនឹងយេនឌ័រ ទាមទារការបង្កប់គោលគំនិត និងទ្រឹស្តីសំខាន់ៗរបស់នាយកដ្ឋាននគរបាលក្នុងការយល់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីជា"ការស្តែងទំនាក់ទំនងអំណាចមិនស្មើភាពជាយូរមកហើយរវាងបុរស និងស្ត្រី"[508]។ ចំណុច

នេះខុសប្លែកពីទ្រឹស្ដីដែលថា អំពើហិង្សាកើតចេញពីកំហឹង ជំងឺផ្លូវចិត្ត ការញៀនគ្រឿងស្រវឹង ឬកត្តាផ្សេងទៀត។ ផ្នែកនេះផ្ដោតលើទ្រឹស្ដីទូទៅជាច្រើនពាក់ព័ន្ធនឹងឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងពិភាក្សាពីវិធីដាក់បញ្ចូលទ្រឹស្ដីដែលឆ្លើយតបនឹងយេនឌ័រក្នុងគោលនយោបាយ និងការអនុវត្តរបស់ស្ថាប័ននគរបាល។ ផ្នែកនេះក៏បង្ហាញផងដែរនូវប្រភេទផ្សេងៗនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលជាទម្រង់ទូទៅបំផុតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីជុំវិញពិភពលោក[509] និងបង្ហាញពីរបៀបបង្កើតគោលនយោបាយ និងសេចក្ដីបង្គាប់ឱ្យឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងប្រភេទអំពើហិង្សានីមួយៗ។

## ទ្រឹស្ដីទូទៅនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី [510]

### ទ្រឹស្ដី ៖ អំណាច និងការគ្រប់គ្រង/ការត្រួតត្រា

ចំណុចដំបូងក្នុងផ្នែកនេះបង្ហាញពីទិដ្ឋភាពរួមនៃទ្រឹស្ដីអំណាចនិងការគ្រប់គ្រង/ការត្រួតត្រាព្រោះនេះជាទ្រឹស្ដីដែលឆ្លើយតបនឹងយេនឌ័រ ដែលនាំទៅរកគោលនយោបាយ និងពិធីសារដែលឆ្លើយតបនឹងយេនឌ័រ[511]។ ទ្រឹស្ដីនេះស្ដែងឡើងជាវដ្តនៃអំណាច និងការគ្រប់គ្រង (រូបភាពខាងក្រោម)។ ចំណុចស្នូលនៃវដ្តនេះ ជាកលវិធីទូទៅដែលកំណត់ដោយជនរងគ្រោះ ដែលជនបង្កតែងយកមកប្រើប្រាស់ក្នុងពេលប្រព្រឹត្តអំពើហិង្សាផ្លូវកាយនិង/ឬអំពើហិង្សាផ្លូវភេទលើពួកគេ។ នៅពេលជនបង្កប្រព្រឹត្ត ឬគំរាមប្រព្រឹត្តអំពើហិង្សាផ្លូវកាយ និង/ឬអំពើហិង្សាផ្លូវភេទដោយប្រើកលវិធីក្នុងវដ្តនេះ ជនបង្កនឹងមានអំណាច និងត្រួតត្រាជនរងគ្រោះ។



ទ្រឹស្តីអំណាច និងការគ្រប់គ្រង/ការត្រួតត្រា ឆ្លើយតបនឹងយេនឌ័រ ព្រោះទ្រឹស្តីនេះរៀបរាប់ពីការប្រើប្រាស់អំពើហិង្សា និងកលវិធីផ្សេងទៀតដើម្បីរក្សាការគៀបសង្កត់លើស្ត្រី និងក្មេងស្រី។ ទ្រឹស្តីនេះត្រូវបានបង្កើតឡើងក្រោមការពិគ្រោះជាមួយស្ត្រីរងគ្រោះ។ ដូច្នេះ ទ្រឹស្តីនេះឆ្លុះបញ្ចាំងពីបទពិសោធន៍ជាក់ស្តែងរបស់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា។ វដ្តនៃអំណាច និងការគ្រប់គ្រងត្រូវបានបកប្រែនិងប្រើប្រាស់ក្នុងសហគមន៍រាប់រយនៅជុំវិញពិភពលោក។

ទោះបីជាទ្រឹស្តីនិងវដ្តនេះត្រូវបានបង្កើតឡើងជាពិសេសដើម្បីពន្យល់ពីឌីណាមិកនៃអំពើហិង្សាក្នុងគ្រួសារក្តីប៉ុន្តែទ្រឹស្តីនេះក៏ពាក់ព័ន្ធនឹងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ។ ឧ. ជាញឹកញាប់ ការសំអាងហេតុផលលើការប្រព្រឹត្តអំពើហិង្សាផ្លូវភេទបង្ហាញពីសិទ្ធិអំណាចរបស់បុរសក្នុងការគ្រប់គ្រងផ្លូវភេទរបស់ស្ត្រីដោយសារតែអ្វីដែលនាងស្លៀកពាក់ ដោយសារតែនាងពុល/ស្រវឹងខ្លាំង ឬដោយសារតែបុរសមានបំណងចង់រួមភេទជាមួយនាង។ ដូចគ្នានេះដែរ ការអនុវត្តដែលបង្កគ្រោះថ្នាក់ ដូចជា ការវះកាត់ប្រដាប់បន្តពូជស្ត្រី អាពាហ៍ពិពាហ៍កុមារនិងការសម្លាប់ដើម្បីរក្សាកិត្តិយសជាសកម្មភាពគ្រប់គ្រងរាងកាយ និងផ្លូវភេទរបស់ស្ត្រី និងក្មេងស្រី[512]។

**ការអនុវត្តទ្រឹស្តីអំណាចនិងការគ្រប់គ្រង/ការត្រួតត្រាដោយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ នាំឱ្យការអនុវត្តរបស់នគរបាលឆ្លើយតបនឹងយេនឌ័រ។**

ការអនុវត្តទ្រឹស្តីអំណាច និងការគ្រប់គ្រង/ការត្រួតត្រាដោយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ នាំឱ្យការអនុវត្តរបស់នគរបាលឆ្លើយតបនឹងយេនឌ័រ។ ឧ. ដោយមិនបង្រួមការស៊ើបអង្កេតឧប្បត្តិហេតុអំពើហិង្សា នគរបាលត្រូវយល់ដឹងពីគំរូនៃការរំលោភបំពាន។នេះជាកលវិធីដែលជនបង្កប្រើប្រាស់ជាហូរហែដើម្បីគ្រប់គ្រងជនរងគ្រោះ។

អន្តរាគមន៍អាចកែសម្រួលទៅតាមស្ថានភាពដើម្បីបង្អាក់គំរូនៃការរំលោភបំពាននេះនិង ផ្តល់ការការពារយូរអង្វែងដល់ជនរងគ្រោះ។ ឧ. ប្រសិនបើមន្ត្រីម្នាក់ឆ្លើយតបទៅនឹងការប្រទូស្តរាយដែលបង្កជារបួសស្រាល ប៉ុន្តែដឹងថា ជនបង្កធ្លាប់មានប្រវត្តិរំលោភបំពានជនរងគ្រោះ និងបានគំរាមសម្លាប់នាង នាយកដ្ឋាននគរបាលនឹងអាចកត់សម្គាល់ហានិភ័យគ្រោះថ្នាក់ធ្ងន់ធ្ងរ និងឆ្លើយតបយ៉ាងសមស្រប។

អ្នកគ្រប់គ្រងថ្នាក់កណ្តាល គួរណែនាំឱ្យមន្ត្រីនគរបាលចាត់វិធានការក្រោមច្បាប់ជាធរមាន ដែលអាចបង្អាក់ឌីណាមិកយូរអង្វែងនៃអំណាច និងការគ្រប់គ្រង។ ការឆ្លើយតបរបស់នគរបាលដែលផ្តោតសំខាន់លើសុវត្ថិភាពរបស់ជនរងគ្រោះអាចរួមមានការឃុំខ្លួនជនបង្កការចេញដីកាការពារការស្នើឱ្យអយ្យការចាត់ទុកការនិយាយគំរាមសម្លាប់ ជាបទល្មើសធ្ងន់ធ្ងរ និងការស្នើឱ្យជនបង្កចូលរៀនថ្នាក់ស្តារនីតិសម្បទាដែលដេញដោលជំនឿរបស់គាត់។

### ទ្រឹស្តី ៖ បញ្ហាផ្លូវចិត្តរបស់បុគ្គល

បញ្ហាសុខភាពផ្លូវចិត្តមិនមែនជាដើមហេតុបង្កឱ្យមានអំពើហិង្សាលើស្ត្រីនិងក្មេងស្រីភាគច្រើនលើសលប់នោះទេ។ ទោះជាយ៉ាងណា ទ្រឹស្តីដំបូងមួយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី (នៅតែនិយម ប្រើប្រាស់ក្នុងសហគមន៍

508. មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី សេចក្តីសម្រេចលេខ ៤៨/១០៤ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣។ គួរកត់សម្គាល់ថា ស្ត្រី និងក្មេងស្រីជាច្រើននៅទូទាំងពិភពលោកទទួលរងផលប៉ះពាល់ដោយសារទម្រង់ប្រទាក់ក្រឡាគ្នានៃការគៀបសង្កត់ (ដោយសារជាតិសាសន៍ វណ្ណៈ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ សាសនា ពិការភាព ស្ថានភាពចំណាកស្រុក និងផ្នែកផ្សេងទៀតនៃអត្តសញ្ញាណ) ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការគៀបសង្កត់ និងអំពើហិង្សាយេនឌ័រ។ មិនមែនស្ត្រី និងក្មេងស្រីគ្រប់រូបសុទ្ធតែរងគ្រោះដោយអំពើហិង្សាតាមរបៀបដូចគ្នានោះទេ ហើយការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សា ត្រូវពិចារណាពីបទពិសោធន៍របស់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងទម្រង់ប្រសព្វគ្នានៃការគៀបសង្កត់។
509. ការស្រាវជ្រាវជាសកលនាពេលថ្មីៗនេះបង្ហាញថា ស្ត្រី ៣០% រងគ្រោះដោយអំពើហិង្សាផ្លូវកាយ ឬអំពើហិង្សាផ្លូវភេទលើដៃគូស្និទ្ធស្នាលក្នុងជីវិតរបស់ខ្លួន។ សូមមើល អង្គការសុខភាពពិភពលោក "អំពើហិង្សាលើស្ត្រី ៖ ព័ត៌មានពិតសំខាន់ៗ" ៖ https://www.who.int/news-room/fact-sheets/detail/violenceagainst-women។
510. ទ្រឹស្តីដែលពិភាក្សាក្នុងជំពូកនេះជាទ្រឹស្តីទូទៅមួយចំនួននៅជុំវិញពិភពលោកប៉ុន្តែទ្រឹស្តីផ្សេងទៀតអាចត្រូវបានអនុវត្តទូលំទូលាយក្នុងសហគមន៍មួយចំនួន។ ឧ. ក្នុងសហគមន៍ខ្លះ គេជឿថា បុរសប្រើប្រាស់អំពើហិង្សា ព្រោះពួកគេប្រាសចាកពីការប្រៀនប្រដៅក្នុងសាសនា។
511. ទ្រឹស្តីអំណាច និងការគ្រប់គ្រង/ការត្រួតត្រា ត្រូវបានបង្កើតឡើងដោយគម្រោងអន្តរាគមន៍ការរំលោភបំពានក្នុងគ្រួសារនៅ Duluth រដ្ឋ Minnesota សហរដ្ឋអាមេរិក ក្រោយការពិគ្រោះយោបល់ជាមួយស្ត្រីស្តីពីបទពិសោធន៍ជាក់ស្តែងនៃការរងគ្រោះដោយអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ សូមមើល គម្រោងអន្តរាគមន៍ការរំលោភបំពានក្នុងគ្រួសារ ៖ https://www.theduluthmodel.org។ ស្ត្រីពន្យល់ថា ក្រៅពីការប្រទូស្តផ្លូវកាយ និងការប្រទូស្តកេរខ្មាសលើពួកគេ ជនបង្កបានប្រើប្រាស់កលវិធីជាច្រើនផ្សេងទៀតដើម្បីគ្រប់គ្រងសកម្មភាព ជំនឿ ធនធាន បំលាស់ទី និងទំនាក់ទំនងរបស់ពួកគាត់ជាមួយអ្នកដទៃ។ទ្រឹស្តីអំណាចនិងការគ្រប់គ្រង/ការត្រួតត្រាជាទ្រឹស្តីដ៏ពេញនិយមក្នុងចំណោមស្ត្រី និងអ្នកតស៊ូមតិរបស់ស្ត្រីនៅជុំវិញពិភពលោក ព្រោះទ្រឹស្តីនេះឆ្លុះបញ្ចាំងពីបទពិសោធន៍ជាក់ស្តែងរបស់ស្ត្រី និងសម្របតាមបរិបទសង្គមចម្រុះ និងត្រូវបានដាក់បញ្ចូលក្នុងឧបករណ៍សិទ្ធិមនុស្សស្តីពីអំពើហិង្សាលើស្ត្រី។ សូមមើល ឧ. CEDAW/C/GC/35 កថាខណ្ឌ ១៩។
512. សូមមើលជំពូកទី ៥ ៖ ការស៊ើបអង្កេត ឧបសម្ព័ន្ធ ២ អំពើហិង្សា/ការរំលោភបំពានផ្អែកលើកិត្តិយស និងការអនុវត្តដែលបង្កគ្រោះថ្នាក់។

ជាច្រើន) គឺអំពើហិង្សាបង្កឡើងដោយជំងឺផ្លូវចិត្ត ឬការសេពគ្រឿងស្រវឹង ឬគ្រឿងញៀន[513]។

អ្នកគាំទ្រទ្រឹស្តីនេះជឿថា គេអាចបង្អាក់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយការព្យាបាលជាបុគ្គល ថ្នាំព្យាបាលជំងឺវិកលចរិត ឬការព្យាបាលអ្នកដែលញៀន។ ប្រសិនបើស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអនុវត្តទ្រឹស្តីនេះ ការឆ្លើយតបទូទៅនឹងរួមមានការស្នើឱ្យព្យាបាលជនបង្ក និងការបញ្ជូនជនរងគ្រោះទៅរកសេវាប្រឹក្សាផ្លូវចិត្ត។ ការពិនិត្យតាមដានជនបង្កនឹងផ្តោតលើការធ្វើតេស្តរកសារធាតុញៀននិងការតាមដានបន្តលើការព្យាបាលដែលស្នើឡើងជាជាងត្រួតពិនិត្យឥរិយាបថហិង្សារបស់ជនបង្ក និងហានិភ័យរបស់ជនរងគ្រោះក្នុងការប្រឈមនឹងគ្រោះថ្នាក់។

ការសិក្សាបង្ហាញថាទោះបីជាបុរសមួយចំនួនដែលប្រព្រឹត្តអំពើហិង្សាលើដៃគូស្និទ្ធស្នាល មានជំងឺផ្លូវចិត្តក្តី ក៏ជំងឺផ្លូវចិត្តរួមចំណែកត្រឹមតែ ១០% ប៉ុណ្ណោះដល់ការប្រព្រឹត្តអំពើហិង្សាលើដៃគូស្និទ្ធស្នាល[514]។ ក្រៅពីនេះ ទ្រឹស្តី "បញ្ហាផ្លូវចិត្តរបស់បុគ្គល" មិនបញ្ជាក់ពីការប្រើប្រាស់កលវិធីជាបន្តបន្ទាប់ដើម្បីគ្រប់គ្រង និងត្រួតត្រាជនរងគ្រោះដែលជាលក្ខណៈទូទៅក្នុងអំពើហិង្សាក្នុងគ្រួសារឡើយ។ ប្រសិនបើអ្នកគ្រប់គ្រងថ្នាក់កណ្តាលកត់សម្គាល់ថា ការអនុវត្តរបស់មន្ត្រីម្នាក់ៗ ឬស្ថាប័នទាំងមូលផ្អែកលើការជឿថាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីភាគច្រើនបង្កឡើងដោយជំងឺផ្លូវចិត្តចាំបាច់ត្រូវធ្វើការកែសម្រួលគោលនយោបាយជាធរមាន ពិធីសារ និងការអនុវត្តទាំងឡាយឱ្យឆ្លើយតបកាន់តែប្រសើរទៅនឹងអំពើហិង្សាដែលកើតមានលើជនរងគ្រោះភាគច្រើន។ ការពិគ្រោះជាមួយជនរងគ្រោះក្នុងសហគមន៍មូលដ្ឋានជាកត្តាដ៏សំខាន់ក្នុងការយល់ច្បាស់ពីបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។

**ទ្រឹស្តី ៖ បញ្ហាទំនាក់ទំនង**

អ្នកផ្សេងទៀតជឿថា អំពើហិង្សាលើស្ត្រី និងក្មេងស្រី (ជាពិសេសអំពើហិង្សាលើដៃគូស្និទ្ធស្នាល) បណ្តាលមកពីកង្វះជំនាញទំនាក់ទំនងនិងកង្វះការគោរពគ្នាទៅវិញទៅមក ហើយគូភាគីគឺខុសដូចគ្នា។ ប្រសិនបើទ្រឹស្តីនេះត្រូវបានយកទៅអនុវត្តក្នុងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ នគរបាលអាចស្នើឱ្យជនរងគ្រោះ និងជនបង្កចូលរួមវគ្គពិគ្រោះយោបល់ ឬវគ្គផ្សះផ្សាមួយចំនួន ឬស្នើឱ្យជនរងគ្រោះផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនឱ្យស្របតាមក្តីរំពឹងទុកផ្នែកសង្គម/វប្បធម៌។ពេលគឺត្រូវធ្វើជា "ប្រពន្ធល្អ"។ នគរបាលងាយនឹងខកខានមិនប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹង ហានិភ័យនៃអំពើហិង្សានាពេលអនាគត និងមិនចាត់វិធានការការពារជនរងគ្រោះ។ សម្រាប់ករណីប្រទូស្តកេរ្តិ៍ខ្មាស ជនរងគ្រោះអាចត្រូវបានស្តីបន្ទោសថាផ្តល់សារមិនត្រឹមត្រូវដល់ជនបង្កតាមរយៈពាក្យសម្តី សកម្មភាព ឬស្លៀកពាក់។ ទ្រឹស្តីនេះងាយនឹងផ្តល់លេសសម្រាប់ការប្រព្រឹត្តអំពើហិង្សា និងមិននាំទៅរកការអនុវត្តដែលការពារសុវត្ថិភាពរបស់ជនរងគ្រោះ និងរក្សាទទួលខុសត្រូវរបស់ជនបង្កឡើយ។



ប្រសិនបើអ្នកគ្រប់គ្រងថ្នាក់កណ្តាលកត់សម្គាល់ថា ការអនុវត្តរបស់មន្ត្រីម្នាក់ៗឬស្ថាប័នទាំងមូលផ្អែកលើការជឿថា អំពើហិង្សាបង្កឡើងដោយបញ្ហាទំនាក់ទំនង គោលនយោបាយជាធរមាន ពិធីសារ និងការអនុវត្តទាំងឡាយនឹងរួមបញ្ចូលការផ្សះផ្សាដោយមន្ត្រីនគរបាលនិងការស្នើឱ្យមានការប្រឹក្សាយោបល់។ចាំបាច់ត្រូវកែសម្រួលគោលនយោបាយ ឬការអនុវត្តទាំងនេះឱ្យឆ្លើយតបកាន់តែប្រសើរទៅនឹងអំពើហិង្សាដែលកើតមានលើជនរងគ្រោះភាគច្រើន។ការពិគ្រោះជាមួយជនរងគ្រោះក្នុងសហគមន៍មូលដ្ឋានជាកត្តាសំខាន់ក្នុងការយល់ច្បាស់ពីបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។

513. អង្គការស៊ីមតិដើម្បីសិទ្ធិមនុស្ស "ទ្រឹស្តីនៃអំពើហិង្សា" http://www.stopvaw.org/theories_of_violence។

514. Barbara J. Hart and Andrew R. Klein, 'Practical Implications of Current Intimate Partner Violence Research for Victim Advocates and Service Providers,' December 2013, 12, at: https://www.ncjrs.gov/pdffiles1/nij/grants/244348.pdf

## ទ្រឹស្តី ៖ វដ្តនៃអំពើហិង្សា និងការគ្រប់គ្រងកំហឹង

ទ្រឹស្តីទូទៅមួយទៀតគឺជនបង្កមានការលំបាកក្នុងការគ្រប់គ្រងកំហឹងឬបង្ហាញអារម្មណ៍របស់ខ្លួនតាមបែបអហិង្សា។ នៅទសវត្សរ៍ទី ៧០ បណ្ឌិត Lenore Walker បានបង្កើតទ្រឹស្តីវដ្តនៃអំពើហិង្សាដែលសន្មតទុកថាទំនាក់ទំនងបែបបំពានមានលក្ខណៈជាវដ្តបន្តជាប់ដែលគូស្វាមីភរិយាឆ្លងកាត់ដំណាក់កាល "ផ្អែមល្ហែម" ដំណាក់កាល "កសាងភាពតានតឹង" និងដំណាក់កាលហិង្សា និងផ្ទុះកំហឹង (បន្ទាប់មកគឺដំណាក់កាលផ្អែមល្ហែមដែលមានវិប្បដិសារី)។

អ្នកគាំទ្រទ្រឹស្តីនេះជឿថា គេអាចបង្អាក់អំពើហិង្សាលើដៃគូស្និទ្ធស្នាលនៅដំណាក់កាលកសាងភាពតានតឹងបាន ប្រសិនបើបុរសអាចរៀនរម្ងាប់កំហឹងរបស់ខ្លួន។ ក្នុងសេណារីយ៉ូល្អបំផុត ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌដែលផ្អែកលើទ្រឹស្តីនេះ អាចស្នើឱ្យបុរសចូលរួមវគ្គគ្រប់គ្រងកំហឹងដើម្បីបញ្ឈប់អំពើហិង្សា។ ក្នុងសេណារីយ៉ូអាក្រក់បំផុតមន្ត្រីនគរបាលដែលអនុវត្តផ្អែកតាមទ្រឹស្តីនេះអាចនឹងស្តីបន្ទោសជនរងគ្រោះដែលមិនបានទប់ស្កាត់ដំណាក់កាលកសាងភាពតានតឹង (ឬមិនបានចាកចេញមុនពេលជនបង្កប្រព្រឹត្តអំពើហិង្សា)។

ការស្រាវជ្រាវបន្ថែមទៀតបានដេញដោលសុពលភាពទ្រឹស្តីវដ្តនៃអំពើហិង្សាដូចតទៅ។ ទីមួយ ទ្រឹស្តីនេះ មិនពិចារណាថា ជនរងគ្រោះជាច្រើនមិនធ្លាប់ឆ្លងកាត់ "ដំណាក់កាលផ្អែមល្ហែម"ជាហេតុនាំឱ្យមានការស្តីបន្ទោសជនរងគ្រោះ។ ដោយសារទ្រឹស្តីនេះសន្មតថា ស្ត្រីនឹងប្រឈមនឹងដំណាក់កាលផ្សេងៗក្នុងទំនាក់ទំនង ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌនិងស្ថាប័នតស៊ូមតិដែល អនុវត្តទ្រឹស្តីនេះ ជាញឹកញាប់ដាក់បន្ទុកឱ្យស្ត្រីបង្អាក់អំពើហិង្សាឬចាកចេញក្នុងដំណាក់កាល "កសាងភាពតានតឹង"[515]។

តាមពិតស្ត្រីនិយាយថាការប្រើប្រាស់អំពើហិង្សាដោយដៃគូរបស់ខ្លួនគឺមិនអាចស្មានដឹងនិងមិនអាចគ្រប់គ្រងបានឡើយហើយកលវិធីជាច្រើនផ្សេងទៀតដែលជនបង្កប្រើប្រាស់ដើម្បីគ្រប់គ្រងដៃគូរបស់ខ្លួន មិនត្រូវបានពន្យល់ក្នុងទ្រឹស្តីវដ្តនៃអំពើហិង្សាឡើយ។

ដូចគ្នានេះដែរ អ្នកគាំទ្រទ្រឹស្តីនេះដែលយល់ថា ជនបង្កមាន "បញ្ហាក្នុងគ្រប់គ្រងកំហឹង" មិនបានពន្យល់ថាតើហេតុអ្វីជនបង្កអាចទប់មិនប្រព្រឹត្តអំពើហិង្សាលើអ្នកផ្សេងទៀត ដូចជា ចៅហ្វាយដែលប្រព្រឹត្តលម្មៀងចំពោះគាត់។

ប្រសិនបើអ្នកគ្រប់គ្រងថ្នាក់កណ្តាលកត់សម្គាល់ថា ការអនុវត្តរបស់មន្ត្រីម្នាក់ៗ ឬ ស្ថាប័នទាំងមូលផ្អែកលើការជឿថា អំពើហិង្សាបង្កឡើងដោយបញ្ហាកំហឹង ចាំបាច់ត្រូវធ្វើការកែសម្រួលគោលនយោបាយជាធរមានពិធីសារនិងការអនុវត្តទាំងឡាយឱ្យឆ្លើយតបកាន់តែប្រសើរទៅនឹងអំពើហិង្សាដែលកើតមានលើជនរងគ្រោះភាគច្រើន។ ការពិគ្រោះជាមួយជនរងគ្រោះ ក្នុងសហគមន៍មូលដ្ឋានជាកត្តាសំខាន់ក្នុងការយល់ច្បាស់ពីបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។

### តើទ្រឹស្តីអ្វីខ្លះកំពុងជំរុញការងារក្នុងស្ថាប័នរបស់អ្នក?

អ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរពិនិត្យរកទ្រឹស្តី ដែលកំពុងជះឥទ្ធិពលលើការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងស្ថាប័នរបស់ខ្លួន។ តើភាសាអ្វីខ្លះដែលត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពើហិង្សាលើស្ត្រី និងក្មេងស្រី? តើឥរិយាបថអ្វីខ្លះដែលគាំទ្រដោយការអនុវត្តរបស់ស្ថាប័នបច្ចុប្បន្ន? តើ "លេស" (ប្រសិនបើមាន) ដោះសារអំពើហិង្សាអ្វីខ្លះ ដែលគេទទួលយក?

ប្រសិនបើទ្រឹស្តីអំណាច និងការគ្រប់គ្រង/ការត្រួតត្រាមិនផ្តល់មូលដ្ឋានព័ត៌មានដល់ការងាររបស់ស្ថាប័ន អ្នកគ្រប់គ្រងថ្នាក់កណ្តាលអាចចាប់ផ្តើមបញ្ចូលទ្រឹស្តីនេះដោយស្វែងយល់បន្ថែមទៀតពីបទពិសោធន៍ជាក់ស្តែងរបស់ជនរងគ្រោះ។ជំហានដំបូងដ៏ល្អមួយគឺត្រូវសហការជាមួយអង្គការស្ត្រីក្នុងមូលដ្ឋានដើម្បីរៀបចំក្រុមពិភាក្សាជាមួយជនរងគ្រោះដែលអាចផ្តល់ការយល់ដឹងអំពីកលវិធីអំណាចនិងការគ្រប់គ្រងដែលប្រើប្រាស់ជាទូទៅក្នុងសហគមន៍របស់ពួកគេ។

515. Leigh Goodmark, 'Reframing Domestic Violence Law and Policy: An Anti-Essentialist Proposal,' Journal of Law and Policy, Vol. 31:39, 2009, 42, at: https://openscholarship.wustl.edu/law_journal_law_policy/vol31/iss1/4/

## ប្រភេទនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល

ទម្រង់ទូទៅបំផុតមួយនៃអំពើហិង្សានៅទូទាំងពិភពលោក គឺអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ គោលគំនិត និងទ្រឹស្តីស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលជំរុញការងាររបស់នាយកដ្ឋាននគរបាល នឹងបង្កផលប៉ះពាល់លើការឆ្លើយតបរបស់មន្ត្រីទៅនឹងជនរងគ្រោះ និងផលវិបាកសម្រាប់ជនបង្ក។ ឧ. សហគមន៍មួយចំនួនបានអនុម័តច្បាប់ និងគោលនយោបាយស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលតម្រូវឱ្យមន្ត្រីឆ្លើយតបទៅនឹងឧប្បត្តិហេតុទាំងអស់នេះតាមវិធីដូចគ្នា។ "ទ្រឹស្តី" បង្កប់នៃគោលនយោបាយប្រភេទនេះគឺ អំពើហិង្សាទាំងអស់ដែលកើតឡើងក្នុងផ្ទះ ឬរវាងដៃគូស្និទ្ធស្នាល មានចេតនា និងផលប៉ះពាល់ដូចគ្នា។

ការស្រាវជ្រាវបង្ហាញថា ជារឿយៗ អំពើហិង្សាលើដៃគូស្និទ្ធស្នាលជាបទល្មើសកើតឡើងដដែលៗ ដែលដៃគូម្នាក់ប្រើប្រាស់កលវិធីនៃការត្រួតត្រាដើម្បីគ្រប់គ្រងដៃគូរបស់ខ្លួនឱ្យបានយូរអង្វែង[516] ហើយដៃគូរបស់គាត់ក៏អាចប្រើប្រាស់អំពើហិង្សាជាការឆ្លើយតបឬសងសឹកវិញផងដែរ។ គោលនយោបាយដែលទាមទារឱ្យមានផលវិបាកដូចគ្នាសម្រាប់ជនបង្កអំពើហិង្សាជាបន្តបន្ទាប់ និងជនរងគ្រោះដែលប្រើប្រាស់អំពើហិង្សាម្តងម្កាលដើម្បីការពារខ្លួន នឹងមិនអាចបញ្ឈប់គំរូនៃការរំលោភបំពានប្រកបដោយប្រសិទ្ធភាពបានឡើយ។ ដើម្បីជានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាល មន្ត្រីនគរបាលត្រូវយល់ថាតើនរណាបង្កគ្រោះថ្នាក់អ្វីលើនរណា និងបង្កផលប៉ះពាល់អ្វីខ្លះ។ មន្ត្រីនគរបាលត្រូវយល់ថាតើនរណាបង្កគ្រោះថ្នាក់បំផុត និងនរណាភ័យខ្លាចបំផុត។

ដើម្បីជួយឱ្យមន្ត្រីនគរបាលផ្តល់ការឆ្លើយតបសមស្របទៅនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាលអ្នកគ្រប់គ្រងថ្នាក់កណ្តាលអាចកសាងសមត្ថភាពរបស់មន្ត្រីក្នុងការកំណត់រកប្រភេទនៃអំពើហិង្សាក្នុងគ្រួសារបង្កឡើងលើដៃគូស្និទ្ធស្នាល ដូចជា អំពើហិង្សាត្រួតត្រាដោយបង្ខំ អំពើហិង្សាប្រឆាំងតបនិងអំពើហិង្សាដែលមិនពាក់ព័ន្ធនឹងការត្រួតត្រាដោយបង្ខិតបង្ខំ។ ដូចការពិភាក្សាលម្អិតក្នុងផ្នែកស្តីពី "វិធាន និងបញ្ញត្តិ" និង "ការអនុវត្តផ្នែករដ្ឋបាល" ខាងក្រោម ស្ថាប័ន នគរបាលអាចតាក់តែងគោលនយោបាយដែលជំរុញឱ្យមន្ត្រីកំណត់រក និងឆ្លើយតបសមស្របទៅនឹងទម្រង់នីមួយៗនៃអំពើហិង្សា។

**ប្រភេទនីមួយៗនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល ទាមទារការឆ្លើយតបខុសៗគ្នា។ នគរបាលអាចរួមចំណែកដល់ការឆ្លើយតបផ្សេងៗតាមរយៈការស៊ើបអង្កេតសមស្រប និង ល្អិតល្អន់។**

អំពើហិង្សា និងការរំលោភបំពានត្រួតត្រាដោយបង្ខំ ជាការប្រើប្រាស់ការសម្លុតគំរាមការបង្ខិតបង្ខំនិងអំពើហិង្សាជាបន្តបន្ទាប់ក៏ដូចជាកលវិធីត្រួតត្រាផ្សេងទៀតដើម្បីបង្កើតនិងរក្សាទំនាក់ទំនងបែបត្រួតត្រាលើដៃគូស្និទ្ធស្នាល។

ជនបង្កដែលប្រព្រឹត្តអំពើហិង្សាត្រួតត្រាដោយបង្ខំជឿថាពួកគេមានសិទ្ធិគ្រប់គ្រងសកម្មភាព ការគិត និងការប្រព្រឹត្តរបស់ដៃគូ និងកូនៗ។ អំពើហិង្សា និងការរំលោភបំពានត្រួតត្រាដោយបង្ខំ សម្គាល់ដោយអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ និងឥរិយាបថត្រួតត្រា និង ប្រមាថ។ អំពើហិង្សានេះបង្កការភ័យខ្លាចដល់ជនរងគ្រោះនិងបង្កើតគម្លាតអំណាចដ៏ធំរវាងជនបង្ក និងជនរងគ្រោះ។ ជនរងគ្រោះគ្មាន ឬមានស្វ័យភាពតិចតួចលើទំនាក់ទំនងនេះ និងជាញឹកញាប់ យល់ថា ខ្លួនឯងជាប់ផុង។ ការត្រួតត្រាលេចឡើងនៅពេលមនុស្សម្នាក់ចាប់ផ្តើមរស់នៅក្រោមការគ្រប់គ្រងរបស់អ្នកដទៃ ដោយសារភ័យខ្លាចគ្រោះថ្នាក់ មិនថាគ្រោះថ្នាក់ផ្នែកសេដ្ឋកិច្ច ផ្លូវកាយ ផ្លូវភេទ និង/ឬផ្លូវអារម្មណ៍នោះទេ។

ដើម្បីកំណត់ថាតើជនរងគ្រោះ កំពុងរងគ្រោះដោយអំពើហិង្សាត្រួតត្រាដោយបង្ខំឬយ៉ាងណាមន្ត្រីនគរបាលត្រូវស៊ើបអង្កេតគំរូនៃការរំលោភបំពានមិនមែនស៊ើបអង្កេតត្រឹមតែឧប្បត្តិហេតុដែលមន្ត្រីនគរបាលកំពុងឆ្លើយតបនោះទេ។

ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាល និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមិនត្រឹមតែជាការឆ្លើយតបទៅ

516. Evan Stark, ‵Re-presenting Battered Women: Coercive Control and the Defense of Liberty,′ Violence Against Women: Complex Realities and New Issues in a Changing World, Les Presses de l′Université du Québec: 2012



នឹងឧប្បត្តិហេតុភ្លាមៗនៃអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការឆ្លើយតបដើម្បីបង្អាក់គំរូជាបន្តបន្ទាប់នៃការរំលោភបំពានផងដែរ ( ឧ. ការផ្តល់ការការពារជាបន្តបន្ទាប់ដល់ជនរងគ្រោះ និងការផ្តល់ឱកាសឱ្យជនបង្កផ្លាស់ប្តូរការគិត និងឥរិយាបថរបស់ខ្លួនតាមរយៈកម្មវិធីស្តារនីតិសម្បទាជនបង្ក )។

អំពើហិង្សាប្រឆាំងតបរួមបញ្ចូលទាំងការប្រើប្រាស់កម្លាំងស្របច្បាប់ និងមិនស្របច្បាប់ ដោយជនរងគ្រោះដើម្បីគ្រប់គ្រងការប្រើប្រាស់កលវិធីបង្ខិតបង្ខំនិងត្រួតត្រារបស់ជនបង្ក ឬជាការឆ្លើយតបទៅនឹងអំពើហិង្សារបស់បុរសផ្សេងទៀតលើស្ត្រី។

ភាគច្រើននៃជនរងគ្រោះដោយសារអំពើហិង្សា និងការរំលោភបំពានត្រួតត្រាដោយបង្ខំប្រើកលវិធីជាច្រើនផ្សេងទៀតដើម្បីការពារខ្លួន និងប្រឆាំងនឹងការគៀបសង្កត់ មុននឹងប្រើប្រាស់អំពើហិង្សា។ ជាញឹកញាប់ ជនរងគ្រោះនឹងដង្ហើយរកជំនួយពីគ្រួសារ និងមិត្តភក្តិ ព្យាយាមចរចាជាមួយជនបង្ក រម្ងាប់កំហឹងរបស់ជនបង្ក ឬផ្តាច់ខ្លួនចេញ មុននឹងប្រព្រឹត្តអំពើហិង្សានេះ។

**ប្រសិនបើគូភាគីបានប្រើប្រាស់អំពើហិង្សាក្នុងឧប្បត្តិហេតុមួយ មន្ត្រីនគរបាលគួរ ៖**

- កំណត់ថាតើភាគីម្ខាងបានប្រព្រឹត្តដើម្បីការពារខ្លួនឬទេ។
- ចោទសួរគូភាគីអំពីប្រវត្តិប្រព្រឹត្តអំពើហិង្សាត្រួតត្រាដោយបង្ខំនិងកលវិធីផ្សេងទៀតដើម្បីយល់ពីបរិបទនៃអំពើហិង្សានេះ។

ប្រសិនបើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនុវត្តផលវិបាកដូចគ្នាចំពោះជនរងគ្រោះ ដែលប្រព្រឹត្តអំពើហិង្សាប្រឆាំងតបដូចជនបង្កអំពើហិង្សាត្រួតត្រាដោយបង្ខំប្រព័ន្ធនេះនឹងមិនអាចបញ្ឈប់ការរំលោភបំពានបានទេ និងបន្តបង្អាក់មិនឱ្យអ្នកដែលប្រឈមនឹងហានិភ័យគ្រោះថ្នាក់បំផុត រាយការណ៍ពីការរំលោភបំពាននេះ។

ផ្ទុយទៅវិញមន្ត្រីនគរបាលដែលអាចកំណត់ករណីដែលជនរងគ្រោះ ប្រើប្រាស់អំពើហិង្សាប្រឆាំងតបអាចផ្សារភ្ជាប់ជនរងគ្រោះទៅនឹងធនធាននានាដូចជាអង្គការស្ត្រីដែលផ្តល់ការគាំទ្រនិងសេវា។សហគមន៍មួយចំនួនបានបង្កើតកម្មវិធីផ្តន្ទាទោសជាជម្រើសសម្រាប់ស្ត្រីដែលអាចឱ្យជនរងគ្រោះទទួលបានសេវា និងចូលរួមវគ្គឯកទេសជំនួសឱ្យការផ្តន្ទាទោសដាក់ពន្ធនាគារដោយសារការប្រព្រឹត្តអំពើហិង្សាប្រឆាំងតប[517]។

**អំពើហិង្សាដែលមិនពាក់ព័ន្ធនឹងការត្រួតត្រាដោយបង្ខំ** ត្រូវបានប្រើប្រាស់ដោយដៃគូស្និទ្ធស្នាលម្នាក់លើដៃគូម្នាក់ទៀត និងមិនមែនជាការប៉ុនប៉ងដាក់ការត្រួតត្រាដោយបង្ខំនោះទេ ហើយក៏មិនមែនជាការឆ្លើយតបនឹងការត្រួតត្រាដោយបង្ខំដែរ។ អំពើហិង្សានេះគ្របដណ្តប់លើគ្រប់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារ និងរួមបញ្ចូល ៖

- **អំពើហិង្សាផ្អែកតាមស្ថានភាព** ដែលភាគីម្ខាង ឬគូភាគីប្រើប្រាស់អំពើហិង្សា ប៉ុន្តែមិនមែនជាផ្នែកមួយនៃការបង្ខិតបង្ខំ និងការសម្លុតគំរាមជាបន្តបន្ទាប់។

517. ឧទាហរណ៍ នៅ Duluth រដ្ឋ Minnesota CCR បានបង្កើតវិធីសាស្ត្រផ្សេងមួយចំពោះការប្រព្រឹត្តអំពើហិង្សាប្រឆាំងតបដោយស្ត្រី។ស្ត្រីអាចចូលរួមវគ្គមួយដែលប្រើប្រាស់កម្មវិធីសិក្សាពិសេសមួយសម្រាប់ដោះស្រាយការប្រើប្រាស់អំពើហិង្សាដោយស្ត្រី ដើម្បីប្រឆាំងតបនឹងអំពើហិង្សាត្រួតត្រាដោយបង្ខំ។ សូមមើល Pence, Connelly, and Scaia, 'Turning Points: A Nonviolence Curriculum for Women.'។

- **អំពើហិង្សាផ្អែកតាមរោគសាស្ត្រ** ដែលការបញ្ឈប់ ឬការគ្រប់គ្រងរោគសាស្ត្រនឹងបញ្ឈប់អំពើហិង្សា (ជំងឺផ្លូវចិត្ត ការញៀនគ្រឿងញៀន និងគ្រឿងស្រវឹង ដោយគ្មានគំរូនៃការបង្ខិតបង្ខំនិងការល្បួងបញ្ឆោតដៃគូបញ្ហាខួរក្បាល)។
- **កង្វះក្រមសីលធម៌ ឬស្តង់ដារសង្គម** ជាអំពើហិង្សាដែលពាក់ព័ន្ធនឹងការបាត់សណ្តាប់ធ្នាប់ក្នុងសង្គម ដូចជា ការកើនឡើងនៃអំពើរំលោភសេពសន្ថវៈ និងការរំលោភបំពានស្ត្រីដោយដៃគូក្នុងស្ថានភាពសង្គមដែលមិនផ្តល់ក្តីសង្ឃឹម ដូចជា អ្នកដែលឆ្លងកាត់ ភ្លើងសង្គ្រាម គ្រោះមហន្តរាយធម្មជាតិ និងរស់នៅក្នុងជំរំជនភៀសខ្លួន។

ជាញឹកញាប់ អំពើហិង្សាជាការប៉ុនប៉ងត្រួតត្រានរណាម្នាក់ ប៉ុន្តែវាមិនមែនសុទ្ធតែជាការប៉ុនប៉ងបង្កើតទំនាក់ទំនងដើម្បីគ្រប់គ្រងឬត្រួតត្រានោះទេ។ពេលខ្លះការប្រើប្រាស់អំពើហិង្សាមានគោលបំណងគ្រប់គ្រងកាលៈទេសៈជាក់លាក់ (ឧ. ដៃគូពិសាស្រា បដិសេធមិនរួមចំណែកក្នុងគ្រួសារ ចិញ្ចឹមកូនមិនបានល្អ)។

ប្រភេទនៃអំពើហិង្សានីមួយៗ(ទោះបីជាមិនសូវកើតមានដូចអំពើហិង្សាត្រួតត្រាដោយបង្ខំ) ទាមទារនូវការឆ្លើយតបខុសៗគ្នា។ ឧ. គេអាចដោះស្រាយអំពើហិង្សាផ្អែកតាមរោគសាស្ត្រដែលបង្កឡើងដោយការញៀនគ្រឿងស្រវឹងឬថ្នាំញៀនតាមរយៈកម្មវិធីព្យាបាលប្រសិនបើជនបង្កមិនប្រើប្រាស់កលវិធីត្រួតត្រាជាបន្តបន្ទាប់។នគរបាលគួរប្រមូលព័ត៌មានស្តីពីឥរិយាបថត្រួតត្រាដោយបង្ខំកន្លងមក ក៏ដូចជាប្រវត្តិនៃការសេពគ្រឿងស្រវឹង ឬថ្នាំញៀនដើម្បីកំណត់ឫសគល់នៃអំពើហិង្សានោះ។

**គោលគំនិត និងទ្រឹស្តី ៖ សារសំខាន់ៗ**

- គោលគំនិតនិងទ្រឹស្តីជះឥទ្ធិពលលើគោលនយោបាយ ការអនុវត្ត សេចក្តីបង្គាប់ និងភាសាដែលស្ថាប័ននគរបាលប្រើប្រាស់។
- ទ្រឹស្តីដែលឆ្លើយតបនឹងយេនឌ័រ ទទួលស្គាល់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីភាគច្រើន ជាការប្រើប្រាស់អំណាច និងការត្រួតត្រាដែលពង្រឹងដោយកលវិធីត្រួតត្រាផ្សេងទៀត។
- នគរបាលដែលស៊ើបអង្កេតករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល គួរខិតខំញែកភាពខុសគ្នារវាងអំពើហិង្សាត្រួតត្រាដោយបង្ខំ អំពើហិង្សាប្រឆាំងតប និងអំពើហិង្សាដែលមិនពាក់ព័ន្ធនឹងការត្រួតត្រាដោយបង្ខំ។
- អ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរពិនិត្យទ្រឹស្តីបច្ចុប្បន្ន និងបង្កប់ទ្រឹស្តីដែលឆ្លើយតបនឹងយេនឌ័រធៀបនឹងមធ្យោបាយនីមួយៗនៃមធ្យោបាយ ៧ ចំណុចផ្សេងទៀតដែលលើកមកពិភាក្សាខាងក្រោម។

## ៣.វិធាន និងបទបញ្ញត្តិ

វិធាន និងបទបញ្ញត្តិរួមបញ្ចូលច្បាប់ បញ្ញត្តិរដ្ឋបាល គោលនយោបាយ ពិធីសារ និងសេចក្តីបង្គាប់របស់ស្ថាប័នដែលស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌត្រូវអនុវត្តតាមក្នុងការងារទប់ស្កាត់ស៊ើបអង្កេតនិងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ចាំបាច់ត្រូវវិភាគវិធាន និងបញ្ញត្តិដើម្បីកំណត់ថាតើវិធាន និងបញ្ញត្តិទាំងនោះលើកកម្ពស់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ឬទេ។

វិធាន បញ្ញត្តិ គោលនយោបាយ ឬពិធីសារនីមួយៗសុទ្ធតែមានគោលបំណង។ វិធាន និងបញ្ញត្តិដែលឆ្លើយតបនឹងយេនឌ័រមានគោលបំណងសម្រេចបានសុវត្ថិភាពរបស់ជនរងគ្រោះ និងរក្សាការទទួលខុសត្រូវរបស់ជនបង្កលើអំពើហិង្សា។ក្រោយការពិនិត្យយ៉ាងល្អិតល្អន់គោលនយោបាយមួយចំនួនអាចមានគោលបំណងបង្កើនប្រសិទ្ធផលរបស់ស្ថាប័នប៉ុន្តែមិនសូវផ្តោតលើការការពារជនរងគ្រោះ ឬរក្សាការទទួលខុសត្រូវរបស់ជនបង្កឡើយនិងអាចរាំងស្ទះដល់គោលដៅទាំងនេះ។



ឧ. នៅទូទាំងពិភពលោក សហគមន៍ជាច្រើនបានកែប្រែគោលនយោបាយដែលនាំទៅរកការចាប់ខ្លួនស្ត្រីជាច្រើន

ដែលជាជនរងគ្រោះដោយសារអំពើហិង្សាត្រួតត្រាដោយបង្ខំ។ នៅពេលច្បាប់ឬគោលនយោបាយតម្រូវឱ្យមានការចាប់ខ្លួននៅកន្លែងប្រទូស្តរាយ ជាញឹកញាប់ជនរងគ្រោះត្រូវបានចាប់ខ្លួន។ ការស្រាវជ្រាវបង្ហាញថា ស្ត្រីជាច្រើនដែលត្រូវបានចាប់ខ្លួនជាអ្នកប្រព្រឹត្តការពារខ្លួនហើយអ្នកដែលប្រើប្រាស់អំពើហិង្សាប្រឆាំងតប មិនមែនជាជនប្រព្រឹត្តចម្បងនោះទេ។ គោលនយោបាយថ្មីៗអាចតម្រូវឱ្យមន្ត្រីកំណត់រក "ស្វ័យការពារខ្លួន" និងបញ្ចៀសការចាប់ខ្លួនអ្នកដែលធ្វើសកម្មភាពដើម្បីការពារខ្លួន។ គោលនយោបាយអាចណែនាំមន្ត្រីស្តីពីរបៀបកំណត់រកជនប្រព្រឹត្តចម្បង ក្នុងឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារ និងណែនាំឱ្យមន្ត្រីទាំងនោះចាប់ខ្លួនតែជនប្រព្រឹត្តចម្បងនោះប៉ុណ្ណោះ។

គោលនយោបាយមួយចំនួនអាចពង្រឹងឌីណាមិកអំណាចរវាងជនរងគ្រោះ និងជនបង្ក ឬដាក់ការទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះ។ ឧ. ច្បាប់របស់ប្រទេសជាច្រើនមិនអនុញ្ញាតឱ្យនគរបាល ឬតុលាការចេញដីកាការពារ ដែលហាមឃាត់មិនឱ្យជនបង្កធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ។

ច្បាប់ និងគោលនយោបាយទាំងនេះមិនឆ្លើយតបនឹងយេនឌ័រនោះទេ ព្រោះច្បាប់ និងគោលនយោបាយទាំងនេះតម្រូវឱ្យជនរងគ្រោះធ្វើការជ្រើសរើសរវាងផ្ទះបិតថេរ (សម្រាប់ខ្លួនគាត់ផ្ទាល់ និងកូន) និងសុវត្ថិភាពពីអំពើហិង្សា។ គោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ ណែនាំឱ្យនគរបាលឆ្លើយតបនឹងអំពើហិង្សាតាមរបៀបដែលដាក់ការទទួលខុសត្រូវលើរដ្ឋ (ចំពោះការទប់ទល់អំពើហិង្សារបស់ជនបង្ក) និងលើជនបង្ក (ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់គាត់)។

អ្នកគ្រប់គ្រងថ្នាក់កណ្តាលដែលមានតួនាទីដាក់បទបញ្ជាអាចយល់ថាពួកគេមិនសូវមានឥទ្ធិពលលើច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណីស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬគោលនយោបាយក្នុងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌរបស់ពួកគេ។ ទោះជាយ៉ាងណា អ្នកគ្រប់គ្រងថ្នាក់កណ្តាលមានតួនាទីពិសេសក្នុងការស្វែងយល់ពីភាពពាក់ព័ន្ធនៃវិធាន និងបញ្ញត្តិទាំងនេះក្នុងសេវានគរបាល។ ក្រៅពីនេះ អ្នកគ្រប់គ្រងថ្នាក់កណ្តាលមានតួនាទីសម្របសម្រួលជាមួយអ្នកអនុវត្តន៍ផ្សេងទៀត (ដូចជា នគរបាល មន្ត្រីទទួលបន្ទុកត្រួតពិនិត្យជនល្មើសដែលកំពុងអនុវត្តការព្យួរទោស និងមេធាវីរបស់ជនរងគ្រោះ) លើការវិភាគប្រសិទ្ធភាពនៃវិធាន និងបញ្ញត្តិក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អ្នកធ្វើសេចក្តីសម្រេចចិត្តអាច និងគួរដាក់បញ្ចូលអ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងការបង្កើតគោលនយោបាយ។

**វិធាន និងបញ្ញត្តិ ៖ សារសំខាន់ៗ**

- វិធាន និងបញ្ញត្តិអាចត្រូវបានបង្កើតឡើង ឬកែប្រែដើម្បីគាំទ្រដល់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។
- វិធាននិងបញ្ញត្តិគួរផ្តោតការយកចិត្តទុកដាក់លើសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្កតាមរយៈការពិគ្រោះជាមួយជនរងគ្រោះស្តីពីបទពិសោធន៍ជាក់ស្តែងនៃការរងគ្រោះដោយអំពើហិង្សា។ ការពិគ្រោះជាមួយជនបង្កជនរងគ្រោះ គួរត្រូវបានដាក់បញ្ចូលក្នុងការបង្កើត ឬវិសោធនកម្មវិធាន/បញ្ញត្តិ។
- អ្នកគ្រប់គ្រងថ្នាក់កណ្តាលមានតួនាទីសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដើម្បីវាយតម្លៃប្រសិទ្ធភាពនៃវិធាន និងបញ្ញត្តិជាធរមាន។

## ៩.ការអនុវត្តផ្នែករដ្ឋបាល

ការអនុវត្តផ្នែករដ្ឋបាលរួមបញ្ចូលមធ្យោបាយទាំងអស់ដែលស្ថាប័នប្រើប្រាស់ ដើម្បីកំណត់ស្តង់ដារលើរបៀបដែលនគរបាលអនុវត្តគោលនយោបាយច្បាប់បញ្ញត្តិនិងអាណត្តិរបស់ស្ថាប័ននោះ។ ដំណើរការរដ្ឋបាលភាគច្រើនពាក់ព័ន្ធនឹងការប្រើប្រាស់ខ្លឹមសារជាលាយលក្ខណ៍អក្សរ ដូចជា ទម្រង់បែបបទពិនិត្យបឋម ទម្រង់បែបបទចងក្រងករណីទុកជាឯកសារ តារាង គោលការណ៍ណែនាំ ទម្រង់បែបបទនៃការសរសេររបាយការណ៍ ការចេញសេចក្តីណែនាំ និងពិធីសារ និងឧទាហរណ៍ផ្សេងទៀតដែលអ្នកអនុវត្តន៍កំណត់ជា "សំណៅឯកសារ"។ វិធាន និងបញ្ញត្តិគឺជាអាណត្តិ។ ដំណើរការរដ្ឋបាល ជាសេចក្តីណែនាំសម្រាប់នគរបាលស្តីពីរបៀបអនុវត្តអាណត្តិទាំងនោះ។

ទន្ទឹមនឹងសេចក្តីណែនាំបែបយន្តការស្តីពីការគ្រប់គ្រងករណីដំណើរការរដ្ឋបាលអាចមានមូលដ្ឋានទស្សនាទានបញ្ជាក់ច្បាស់លាស់ដែលផ្តោតសំខាន់ឬមិនផ្តោតសំខាន់លើបទពិសោធន៍ជាក់ស្តែង និងតម្រូវការសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រី។ ទម្រង់របាយការណ៍នគរបាល កម្រងសំណួរវាយតម្លៃហានិភ័យ និងតារាងត្រួតពិនិត្យការប្រមូលភស្តុតាងសុទ្ធតែជាឧទាហរណ៍នៃការអនុវត្តផ្នែករដ្ឋបាលដែលកំណត់ពីរបៀបពិចារណានិងការចាត់វិធានការលើករណី[518]។

**ឧទាហរណ៍នៃការកែប្រែការអនុវត្តផ្នែករដ្ឋបាល ៖ ប្រទេសហ្សកហ្ស៊ី (Georgia)**

ការអនុវត្តផ្នែករដ្ឋបាលទូទៅ គឺការបង្កើតឧបករណ៍វាយតម្លៃហានិភ័យសម្រាប់ឱ្យមន្ត្រីនគរបាលប្រើប្រាស់។ នៅប្រទេសហ្សកហ្ស៊ី Global Rights for Women បានសហការជាមួយមន្ត្រីនគរបាលដើម្បីបង្កើតការវាយតម្លៃហានិភ័យថ្មីមួយក្នុងគោលបំណងជួយឱ្យមន្ត្រីទាំងអស់កំណត់រកកត្តាហានិភ័យ និងភស្តុតាងនៃអំពើហិង្សាត្រួតត្រាដោយបង្ខំក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ជនរងគ្រោះត្រូវបានជំរុញឱ្យចូលរួមតាមរយៈក្រុមពិភាក្សាដើម្បីផ្តល់មតិស្តីពីឌីណាមិកនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងសហគមន៍មូលដ្ឋាន។ នគរបាល និងអយ្យការត្រូវបានសម្ភាសន៍ដើម្បីទទួលបានព័ត៌មានស្តីពីចំណុចខ្វះខាតក្នុងការអនុវត្តផ្នែករដ្ឋបាលបច្ចុប្បន្ន និងបង្កើតការវាយតម្លៃហានិភ័យថ្មីដែលបង្កើនការការផ្តល់ព័ត៌មានស្តីពីហានិភ័យ សំខាន់ៗដល់អយ្យការ។ លទ្ធផលដែលទទួលបានគឺការវាយតម្លៃហានិភ័យដែលឆ្លុះបញ្ចាំងពីបទពិសោធន៍ជាក់ស្តែងរបស់ស្ត្រីដែលទទួលរងអំពើហិង្សាលើដៃគូស្និទ្ធស្នាលនៅប្រទេសហ្សកហ្ស៊ីដែលផ្តោតសំខាន់លើសុវត្ថិភាពរបស់ជនរងគ្រោ និងជួយឱ្យនគរបាល និងអយ្យការរក្សាការទទួលខុសត្រូវរបស់ជនបង្ក។

ការអនុវត្តផ្នែករដ្ឋបាលដែលបន្សុីគ្នានឹងទ្រឹស្តីដែលឆ្លើយតបនឹងយេនឌ័រក្នុងសេវានគរបាល នឹងជះឥទ្ធិពលលើការដំណើរការករណី លើសពីការអំពាវនាវរកជំនួយពីដំបូងរបស់ជនរងគ្រោះ។ ព័ត៌មានដែលនគរបាលប្រមូលបានអាចត្រូវបានប្រើប្រាស់ដោយអយ្យការ មន្ត្រីទទួលបន្ទុកត្រួតពិនិត្យជនល្មើសដែលកំពុងអនុវត្តការព្យួរទោស បុគ្គលិកការពារកុមារ ចៅក្រម និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីធ្វើសេចក្តីសម្រេចចិត្តល្អិតល្អន់ពាក់ព័ន្ធនឹងសុវត្ថិភាពរបស់ស្ត្រី និងកូនៗរបស់ពួកគេ។ ការបង្កើតទម្រង់ ផ្ទាំងបង្ហាញលើកុំព្យូទ័រ ការវាយតម្លៃ និងតារាងត្រួតពិនិត្យដែលរៀបរាប់ពីអំណាចការគ្រប់គ្រងនិងការត្រួតត្រាលើស្ត្រី និងក្មេងស្រី នឹងកំណត់ស្តង់ដារលើសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ការអនុវត្តផ្នែករដ្ឋបាល ៖ សារសំខាន់ៗ**

- ការអនុវត្តផ្នែករដ្ឋបាល កំណត់ពីរបៀបពិចារណា និងចាត់វិធានការលើករណី។
- ការអនុវត្តផ្នែករដ្ឋបាល ដូចជា ទម្រង់របាយការណ៍នគរបាលជះឥទ្ធិពលយ៉ាងខ្លាំងលើ សុវត្ថិភាពរបស់ជនរងគ្រោះនិងការទទួលខុសត្រូវរបស់ជនបង្កព្រោះព័ត៌មានដែលប្រមូលបានត្រូវបានប្រើប្រាស់ក្នុងពេលដំណើរការករណី។
- ពិនិត្យ និងកែសម្រួលការអនុវត្តផ្នែករដ្ឋបាលដើម្បីធានាថា ការអនុវត្តទាំងនោះផ្តោតសំខាន់លើសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក។

## ៥.ធនធាន

ធនធានរួមបញ្ចូលរបៀបដែលសហគមន៍ ទីភ្នាក់ងារ ឬស្ថាប័ននគរបាលបែងចែក និងធានាគុណភាពនៃការផ្តល់ជំនួយហិរញ្ញវត្ថុ សម្ភារ ដំណើរការ និងបុគ្គលិកចាំបាច់សម្រាប់ការដោះស្រាយបញ្ហាមួយដែលក្នុងករណីនេះសំដៅលើអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ធនធានរួមបញ្ចូលអ្វីទាំងអស់ដែលចាំបាច់សម្រាប់ការសម្រេចបានចំណុចដូចខាងក្រោម ៖

- បុគ្គលិកបំពេញការងារដោយមិនធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ជនរងគ្រោះ ឬការទទួលខុសត្រូវរបស់ជនបង្ក។ ចំណុចនេះរួមមានទំហំនៃបន្ទុកករណី បច្ចេកវិទ្យា ការត្រួតពិនិត្យគ្រប់គ្រាន់ និងសេវាគាំទ្រ។
- ជនរងគ្រោះដោយសារការរំលោភបំពានទទួលបានស្ថាន

518. ការវាយតម្លៃហានិភ័យក៏ត្រូវបានលើកមកពិភាក្សាក្នុងជំពូកទី ៦ ( សុវត្ថិភាព និងការការពារ ) នៃសៀវភៅណែនាំនេះផងដែរ។

ភាពដែលមានសុវត្ថិភាពជាងមុន តាមរយៈមធ្យោបាយទាំងនេះដូចជាការថែទាំវេជ្ជសាស្ត្រលំនៅដ្ឋានការពិគ្រោះយោបល់ដោយអ្នកជំនាញ ជំនួយហិរញ្ញវត្ថុ និងភាពជាតំណាងគ្រប់គ្រាន់ក្នុងផ្លូវច្បាប់។

- ប្រព័ន្ធអន្តរាគមន៍រក្សាការទទួលខុសត្រូវរបស់ជនបង្ក។ ចំណុចនេះរួមមានចន្លោះគ្រប់គ្រាន់ក្នុងពន្ធនាគារលទ្ធភាពងាយស្រួលក្នុងការទទួលបានព័ត៌មានស្ដីពីប្រវត្តិបទល្មើសរបស់ជនបង្ក បុគ្គលិកគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យជនបង្កដែលត្រូវបានដាក់ឱ្យនៅក្រៅឃុំរង់ចាំបទចោទព្រហ្មទណ្ឌ សេវាស្ដារនីតិសម្បទាដែលមានគុណភាពខ្ពស់ និងអ្នកអនុវត្តន៍ដែលត្រៀមខ្លួនបានល្អក្នុងការធ្វើការជាមួយជនបង្កដែលមានសាវតារ សេដ្ឋកិច្ចជាតិពន្ធុ និងសាសនាចម្រុះ។

ជាញឹកញាប់ មន្ត្រីនគរបាលមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីឡើយ។ ប្រសិនបើមន្ត្រីគ្មានពេលប្រមូលព័ត៌មានពីជនរងគ្រោះពាក់ព័ន្ធនឹងបរិបទ និងភាពធ្ងន់ធ្ងរនៃអំពើហិង្សាមន្ត្រីទាំងនោះនឹងមិនអាចការពារជនរងគ្រោះឬចងក្រងភស្តុតាងចាំបាច់សម្រាប់ឱ្យអយ្យការដោះស្រាយករណីព្រហ្មទណ្ឌដោយជោគជ័យបានឡើយ។បច្ចេកទេសស៊ើបអង្កេតមួយចំនួនគឺចាំបាច់ណាស់ក្នុងករណីប្រទូស្តកេរខ្មាសដែលមន្ត្រីត្រូវស្ទួរចម្លើយជនរងគ្រោះនៅពេលដែលពួកគេមិនអាចផ្ដល់ព័ត៌មានលម្អិត ឬចាំបាច់ត្រូវមានភស្តុតាង គ្លីនិក ដូចជាភស្តុតាងដែលប្រមូលបានក្នុង“ឃីតសម្រាប់ករណីរំលោភសេពសន្ថវៈ”[519]។

ការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃ ឬការប៉ះទង្គិចផ្លូវចិត្តបន្ទាប់បន្សំដែលកើតមានលើមន្ត្រីនគរបាល ជាបញ្ហាផ្នែកធនធានមួយផ្សេងទៀតដែលកំពុងទទួលបានចំណាប់អារម្មណ៍នៅជុំវិញពិភពលោក។ ការប្រឈមនឹងការប៉ះទង្គិចផ្លូវចិត្តរបស់អ្នកដទៃ ឬការប្រឈមផ្ទាល់ទៅនឹងស្ថានភាពគំរាមកំហែងអាយុជីវិតអាចបង្កផលប៉ះពាល់យូរអង្វែងលើមន្ត្រីនគរបាល។ នាយកដ្ឋាននគរបាលអាចបែងចែកធនធានដើម្បីគាំទ្រដល់មន្ត្រីដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត និងធានាថា លក្ខខណ្ឌការងារកាត់បន្ថយ ជាជាងបង្កើនការប៉ះទង្គិចផ្លូវចិត្តរបស់មន្ត្រីនគរបាល[520]។

ស្ថាប័ននគរបាលជាច្រើននៅជុំវិញពិភពលោកធ្វើប្រតិបត្តិការដោយមានធនធានតិចតួចនិងមិនគ្រប់គ្រាន់។សំខាន់បំផុតត្រូវដោះស្រាយបញ្ហាកង្វះធនធានដើម្បីឱ្យនគរបាលអាចធានាសុវត្ថិភាពរបស់ជនរងគ្រោះនិងការទទួលខុសត្រូវរបស់ជនបង្កដោយជោគជ័យ។ឧ. ស្ថាប័ន នគរបាលនៅអឺរ៉ុបខាងកើតទទួលស្គាល់ថា ពន្ធនាគារ និងកន្លែងឃុំឃាំងរបស់ខ្លួនមិនសូវមានធនធាន។ ដូច្នេះហើយទើបតុលាការមិនមានការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ។

ក្នុងករណីដែលកង្វះធនធានបង្កបញ្ហាប្រឈមធ្ងន់ធ្ងរអ្នកគ្រប់គ្រងថ្នាក់កណ្ដាលត្រូវធ្វើការវាយតម្លៃយ៉ាងប្រុងប្រយ័ត្នថាតើធនធានណាខ្លះបង្កផលប៉ះពាល់ខ្លាំងជាងគេ លើការសម្រេចបានសុវត្ថិភាពរបស់ជនរងគ្រោះនិងការទទួលខុសត្រូវរបស់ជនបង្ក។ ទាំងក្រុមពិភាក្សាជាមួយជនរងគ្រោះ និងការសម្ភាសន៍នគរបាលជួរមុខសុទ្ធតែអាចផ្ដល់ចំណេះដឹងដ៏មានតម្លៃសម្រាប់ការកំណត់អាទិភាពនៃការប្រើប្រាស់ធនធាន។

**ធនធាន ៖ សារសំខាន់ៗ**

- ធនធានគ្រប់គ្រាន់ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារជនរងគ្រោះនិងរក្សាការទទួលខុសត្រូវរបស់ជនបង្ក។
- ធនធានរួមមានពេលវេលារបស់មន្ត្រី បច្ចេកវិទ្យា ការត្រួតពិនិត្យ ការគាំទ្រសម្រាប់នគរបាល ការគាំទ្រសម្រាប់ជនរងគ្រោះ និងយន្តការរក្សាការទទួលខុសត្រូវរបស់ជនបង្ក។
- ក្រុមពិភាក្សាជាមួយជនរងគ្រោះ និងការសម្ភាសន៍នគរបាលជួរមុខអាចផ្ដល់ចំណេះដឹងដ៏មានតម្លៃស្ដីពីចំណុចខ្វះខាតផ្នែកធនធាន។

## ៦.ការផ្សារភ្ជាប់

ការផ្សារភ្ជាប់ (ពេលខ្លះត្រូវបានពិពណ៌នាជាការសម្របសម្រួល)សំដៅលើគ្រប់វិធីនៃការផ្សារភ្ជាប់នគរបាលទៅ

519. សូមមើល RAINN, at: https://www.rainn.org/articles/rape-kit
520. សូមមើល ឧ.ការិយាល័យគាំពារជនរងគ្រោះដោយសារបទល្មើស“ឯកសារជំនួយស្មារតីស្ដីពីការប៉ះទង្គិចផ្លូវចិត្តដោយសារការគិតពីអារម្មណ៍/ស្ថានភាពអ្នកដទៃ” https://vtt.ovc.ojp.gov/tools-for-law-enforcement/managementand-supervision?fbclid=IwAR32qSintkuMtP_icolLYpdmnHymwgSyzqKLYwy6XT0_SFdR-LF1Y-sVB_s។

នឹងអ្នកធ្វើអន្តរាគមន៍ និងអ្នកផ្តល់សេវាពីមុន ជាបន្តបន្ទាប់ និងស្របគ្នា ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ករណីនីមួយៗនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចពាក់ព័ន្ធនឹងស្ថាប័នផ្សេងៗជាច្រើនក្នុងសហគមន៍មួយ រួមទាំងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ "ការផ្សារភ្ជាប់" សំដៅលើរបៀបដែលស្ថាប័នត្រូវបានផ្សារភ្ជាប់នឹងបុគ្គលដែលបានដាក់ករណីទៅស្ថាប័ននោះ របៀបដែលអ្នកអនុវត្តន៍ផ្សារភ្ជាប់នឹងមន្ត្រីផ្សេងទៀតក្នុងប្រព័ន្ធនេះ របៀបប្រមូល និងចែកចាយព័ត៌មាន និងរបៀបដោះស្រាយបញ្ហា។

ឧ. ការផ្សារភ្ជាប់យ៉ាងរឹងមាំរវាងអ្នកបម្រើសេវាទូរស័ព្ទសង្គ្រោះបន្ទាន់ នគរបាល និងអយ្យការ អាចបង្កើនសមត្ថភាពរបស់ប្រព័ន្ធក្នុងការរក្សាសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រី និងរក្សាការទទួលខុសត្រូវរបស់ជនបង្ក។ ក្នុងសហគមន៍ជាច្រើន អ្នកបម្រើសេវាទូរស័ព្ទសង្គ្រោះបន្ទាន់ជាទំនាក់ទំនងដំបូងសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សា។ ដូច្នេះ ចាំបាច់ត្រូវមានគោលនយោបាយដែលផ្តល់ការណែនាំដល់អ្នកបម្រើសេវាទូរស័ព្ទទាំងនេះ ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធដល់នគរបាលនៅពេលឆ្លើយតបទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ឧ.ប្រសិនបើអាចនគរបាលអាចណែនាំឱ្យអ្នកបម្រើសេវាទូរស័ព្ទស្វែងរកកំណត់ត្រាតាមប្រព័ន្ធអ៊ីនធឺណិតដើម្បីកំណត់ថាតើធ្លាប់មានការទូរស័ព្ទចូលដែលពាក់ព័ន្ធនឹងជនបង្ក និងជនរងគ្រោះតែមួយ ឬទេ និងផ្សព្វផ្សាយព័ត៌មាននេះដល់មន្ត្រីនគរបាលឆ្លើយតបដើម្បីឱ្យពួកគេអាចឆ្លើយតបដោយមានការប្រុងប្រយ័ត្នខ្ពស់។

ដូចគ្នានេះដែរ អ្នកគ្រប់គ្រងថ្នាក់កណ្តាលត្រូវធ្វើទំនាក់ទំនងជាមួយអយ្យការដើម្បីកំណត់ព័ត៌មានដែលអយ្យការតម្រូវឱ្យនគរបាលប្រមែប្រមូលដើម្បីគាំទ្រដល់បទចោទព្រហ្មទណ្ឌ ឬវិធានការផ្សេងទៀតដែលរក្សាការទទួលខុសត្រូវរបស់ជនបង្ក។អយ្យការអាចផ្តល់ការណែនាំល្អៗស្តីពីភាពអាចទទួលយកបាននៃភស្តុតាងក្នុងតុលាការ និងសមត្ថភាពរបស់អយ្យការក្នុងការប្រើប្រាស់ព័ត៌មានដែលប្រមូលដោយនគរបាលក្នុងទម្រង់ជាក់លាក់។ គេអាចបង្កើតគោលនយោបាយស្តីពីនគរបាលនិងអយ្យការឱ្យបន្ស៊ីគ្នាដើម្បីធានាការដំណើរការករណីបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដោយផ្តោតសំខាន់លើសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក[521]។

សហគមន៍មួយចំនួនបានបង្កើនការផ្សារភ្ជាប់ តាមរយៈការបង្កើតក្រុមពហុវិស័យដែលចូលរួមដោយតំណាងមកពីកងកម្លាំងនគរបាល ការិយាល័យអយ្យការ ផ្នែកអនុវត្តន៍ការព្យួរទោស អង្គការតស៊ូមតិដើម្បីស្ត្រី និងស្ថាប័នផ្សេងទៀត។



ឧ. នៅ Duluth រដ្ឋ Minnesota សហរដ្ឋអាមេរិក ក្រុមពហុវិស័យឆ្លើយតបនឹងអំពើហិង្សាក្នុងគ្រួសារបានពិនិត្យឡើងវិញលើករណីនីមួយៗនៃអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលស៊ើបអង្កេតដោយនគរបាល ដើម្បីរួមគ្នាកំណត់យុទ្ធសាស្ត្រលើករណីនីមួយៗ និងធ្វើការផ្លាស់ប្តូរចាំបាច់លើគោលនយោបាយ និងការអនុវត្តដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក។

អ្នកគ្រប់គ្រងថ្នាក់កណ្តាលក្នុងនាយកដ្ឋាននគរបាលអាចដើរតួនាទីសំខាន់ក្នុងក្រុមទាំងនេះព្រោះមន្ត្រីទាំងនេះស្ថិតនៅកៀកកិតនឹងប្រតិបត្តិការប្រចាំថ្ងៃរបស់នគរបាលហើយពួកគេមានចំណេះដឹងស្តីពីគោលនយោបាយដែលគ្របដណ្តប់លើការអនុវត្តរបស់នគរបាល។ ឧ. ជាញឹកញាប់ អ្នកគ្រប់គ្រងថ្នាក់កណ្តាលមានលទ្ធភាពច្រើនជាងនគរបាល

521. សូមមើលជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) និងជំពូកទី ១២ (ខ្សែសង្វាក់យុត្តិធម៌) ក្នុងសៀវភៅណែនាំនេះសម្រាប់ព័ត៌មានបន្ថែមស្តីពីការសម្របសម្រួលរវាងនគរបាល និងអយ្យការ។

ជួរមុខក្នុងការជួបជាមួយថ្នាក់ដឹកនាំក្នុងការិយាល័យអយ្យការ។ ដូច្នេះ មន្ត្រីទាំងនេះអាចបង្កើនការផ្សារភ្ជាប់ជាប់ជាប្រចាំ។

អ្នកគ្រប់គ្រងថ្នាក់កណ្ដាលគួរខិតខំកែលម្អមធ្យោបាយផ្សារភ្ជាប់អ្នកអនុវត្តន៍ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដោយផ្ដោតការយកចិត្តទុកដាក់លើ ៖

- របៀបបញ្ជូន និងចែកចាយព័ត៌មាន។
- របៀបដែលព័ត៌មានដែលបានចែកចាយបង្ហាញគោលគំនិត ឬទ្រឹស្ដីជាក់លាក់ស្ដីពីករណីនោះ។
- ថាតើកិច្ចប្រជុំជាប្រចាំរវាងស្ថាប័ននគរបាល និងស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតនឹងបង្កើនការសម្របសម្រួល ឬទេ។
- ព័ត៌មានដែលស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតត្រូវការជាចាំបាច់សម្រាប់ការបញ្ជូនករណីដោយប្រសិទ្ធភាពនិងសម្រេចបានសុវត្ថិភាពរបស់ជនរងគ្រោះនិងការទទួលខុសត្រូវរបស់ជនបង្ក។
- របៀបកែលម្អគោលនយោបាយ និងការអនុវត្តរបស់នគរបាលដើម្បីពង្រឹងការផ្សារភ្ជាប់។
- របៀបដែលអ្នកអនុវត្តន៍ក្នុងស្ថាប័នផ្សេងទៀត(ដូចជាអយ្យការ) ត្រូវបានផ្សារភ្ជាប់ជាមួយជនរងគ្រោះនិងជនបង្ក៖ តើសំណុំរឿងតំណាងឱ្យអ្នកពាក់ព័ន្ធក្នុងករណីនោះ ឬទេ (សន្មតថា អ្នកអនុវត្តន៍មួយចំនួនមិនដែលបានជួបពួកគេ)?
- ថាតើមានការបំពេញតម្រូវការជាក់លាក់របស់ជនរងគ្រោះ ឬទេ។ ប្រសិនបើទេ ប្រហែលជាត្រូវបង្កើតការផ្សារភ្ជាប់ថ្មីៗ។

ស្ថាប័ននគរបាលមួយក្នុងប្រទេសអូស្ត្រាលីខិតខំប្រមូលព័ត៌មានយ៉ាងច្រើនស្ដីពីបរិបទ និងហានិភ័យពីជនរងគ្រោះដើម្បីឱ្យតុលាការយកទៅប្រើប្រាស់ក្នុងការចេញសេចក្ដីសម្រេច។ នគរបាលចាប់ផ្ដើមកត់សម្គាល់ថា តុលាការមិនប្រើប្រាស់ព័ត៌មានដែលនគរបាលបានផ្ដល់ជូន។នៅពេលនគរបាលសាកសួរពីមូលហេតុ តុលាការប្រាប់ថាព័ត៌មានដែលផ្ដល់ជូននោះមានភាពទូលំទូលាយពេក និងមិនសូវមានប្រយោជន៍។ គេអាចបង្កើនការផ្សារភ្ជាប់នេះតាមរយៈទំនាក់ទំនងរវាងនគរបាល និងតុលាការស្ដីពីព័ត៌មានដែលគួរប្រមូល និងរបៀបបង្ហាញព័ត៌មានទាំងនោះជូនតុលាការ។

**ការផ្សារភ្ជាប់ ៖ សារសំខាន់ៗ**

- ការផ្សារភ្ជាប់ជាវិធីដែលនគរបាលត្រូវបានសម្របសម្រួល ជាមួយអ្នកផ្ដល់សេវាផ្សេងទៀត និងអ្នកអនុវត្តន៍ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។
- ក្នុងការបង្កើនការផ្សារភ្ជាប់ ស្ថាប័ននគរបាលត្រូវធ្វើទំនាក់ទំនងជាមួយអ្នកអនុវត្តន៍ផ្សេងទៀតដើម្បីឱ្យដឹងថាតើពួកគេត្រូវការព័ត៌មានអ្វីខ្លះ ដើម្បីឈានទៅសម្រេចបាននូវសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្ក។
- ប្រហែលជាត្រូវបង្កើតការផ្សារភ្ជាប់ថ្មីៗដើម្បីផ្ដល់សេវាដែលជនរងគ្រោះត្រូវការ។



**៧.គណនេយ្យភាព**

គណនេយ្យភាពជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំសំខាន់ៗក្នុងការវិភាគមធ្យោបាយ ៨ ចំណុចសម្រាប់ស្ថាប័ននគរបាល។ អ្នកគ្រប់គ្រងថ្នាក់កណ្ដាលត្រូវផ្ដោតសំខាន់លើគម្លាតរវាងបទពិសោធន៍ និងតម្រូវការរបស់ប្រជាជនក្នុងសហគមន៍ និងអ្វីដែលផ្ដល់ជូនដោយស្ថាប័ននគរបាល។ ចំណុចស្នូលនៃការងាររបស់អ្នកគ្រប់គ្រងថ្នាក់កណ្ដាលគឺការខិតខំកំណត់រកគម្លាតនេះ ផ្អែកតាមទស្សនៈរបស់ជនរងគ្រោះ និងរបៀបដែលគម្លាតនេះកើតចេញពីការគ្រប់គ្រងករណី។ តាមរយៈការកំណត់របៀបដែលបញ្ហាមួយកើតចេញពីការអនុវត្តក្នុងស្ថាប័នអ្នកគ្រប់គ្រងថ្នាក់កណ្ដាលនឹងដឹងពីរបៀបដោះស្រាយ

បញ្ហានោះ។ ដូច្នេះ គួរផ្សារភ្ជាប់អនុសាសន៍ដោយផ្ទាល់ទៅនឹងការបង្កើតស្តង់ដារសម្រាប់ការអនុវត្តថ្មីដូចជាវិធានគោលនយោបាយ នីតិវិធី ទម្រង់បែបបទ និងការបណ្តុះបណ្តាលថ្មី។

គណនេយ្យភាព មានអត្ថន័យជាក់លាក់ពាក់ព័ន្ធនឹងមធ្យោបាយ ៨ ចំណុច ដូចជារបៀបរៀបចំការអនុវត្តក្នុងស្ថាប័នដើម្បីសម្រេចចំណុចខាងក្រោម ៖

- ឱ្យជនបង្កទទួលខុសត្រូវលើគ្រោះថ្នាក់ដែលពួកគេបានបង្ក ក៏ដូចជាគ្រោះថ្នាក់ដែលពួកគេអាចនឹងបង្កឡើងដោយគ្មានអន្តរាគមន៍ដែលមានប្រសិទ្ធភាព។
- ឱ្យនគរបាលទទួលខុសត្រូវចំពោះជនរងគ្រោះ។
- ឱ្យនគរបាលទទួលខុសត្រូវចំពោះអ្នកផ្តល់សេវាផ្សេងទៀតក្នុងប្រព័ន្ធនេះ។

ថ្មីៗនេះ ស្ថាប័ននគរបាលមួយបានធ្វើការវាយតម្លៃលើករណីអំពើហិង្សាក្នុងគ្រួសារ។ នៅពេលនគរបាលអនុវត្តមធ្យោបាយ ៨ ចំណុច ពួកគេរកឃើញថា ស្ថាប័ននគរបាលមានបេសកកម្មមោះមុត គោលនយោបាយគ្រប់គ្រាន់ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ធនធានសមស្រប និងការអនុវត្តផ្នែករដ្ឋបាលដ៏ល្អបំផុត។ ទោះជាយ៉ាងណា ស្ថាប័ននគរបាលមិនសូវមានគណនេយ្យភាពនិងការត្រួតពិនិត្យសមស្របនោះទេ។ ដូច្នេះហើយទើបមានករណីអំពើហិង្សាក្នុងគ្រួសារមិនដល់ ២០% ទេដែលនគរបាលបានសរសេររបាយការណ៍ ឬធ្វើការចាប់ខ្លួន[522]។

**សហគមន៍មួយចំនួនបានបង្កើនការផ្សារភ្ជាប់ តាមរយៈការបង្កើតក្រុមពហុវិស័យដែលចូលរួមដោយតំណាងមកពីកងកម្លាំងនគរបាល ការិយាល័យអយ្យការ ផ្នែកអនុវត្តទណ្ឌកម្ម អង្គការតស៊ូមតិដើម្បីស្ត្រី និងស្ថាប័នផ្សេងទៀត។**

គណនេយ្យភាពក្នុងស្ថាប័ននគរបាលទាមទារឱ្យមានការកំណត់ផលវិបាកជាក់លាក់ និងច្បាស់លាស់សម្រាប់នគរបាលដែលមិនអនុវត្តតាមគោលនយោបាយការអនុវត្ត ឬពិធីសារជាធរមាន។ ឧ. ប្រសិនបើគោលនយោបាយតម្រូវឱ្យនគរបាលសួរសំណួរមួយចំនួនទៅជនរងគ្រោះ តែនគរបាលមិនអនុវត្តតាម មន្ត្រីគ្រប់គ្រង ឬមន្ត្រីត្រួតពិនិត្យអាចតម្រូវឱ្យនគរបាលនោះត្រឡប់ទៅជួបជនរងគ្រោះជាថ្មីដើម្បីបំពេញទម្រង់ដែលចាំបាច់ ឬអាចដាក់វិធានការវិន័យ។ វិធានការគណនេយ្យភាពគួរត្រូវបានកំណត់ច្បាស់ក្នុងគោលនយោបាយរបស់នាយកដ្ឋានមួយ។

វិធានការគណនេយ្យភាពដ៏ល្អរបស់ស្នងការដ្ឋាននគរបាលនៅ British Columbia កាណាដា គឺការបង្កើតគោលនយោបាយស្តីពីសេវានគរបាលដោយមិនលម្អៀងបន្ទាប់ពីសហគមន៍ពាក់ព័ន្ធនឹងការប្រព្រឹត្តដោយលម្អៀងលើជនជាតិដើមភាគតិច/ជនជាតិដើម[523]។ ដូចគ្នានេះ ដែរគោលនយោបាយដែលផ្តោតលើការហាមឃាត់ ភាពលម្អៀងយេនឌ័រដោយនគរបាល អាចមានប្រសិទ្ធភាពប្រសិនបើអនុវត្តរួមជាមួយនឹងវិធានការគណនេយ្យភាព។

**គណនេយ្យភាព ៖ សារសំខាន់ៗ**

- គណនេយ្យភាពជាធាតុផ្សំដ៏សំខាន់សម្រាប់ការផ្លាស់ប្តូរស្ថាប័នដោយជោគជ័យ។ប្រសិនបើមធ្យោបាយនីមួយៗនៃមធ្យោបាយ ៧ ចំណុចផ្សេងទៀតត្រូវបានកែលម្អ ប៉ុន្តែនគរបាលគ្មានគណនេយ្យភាពចំពោះស្តង់ដារថ្មី ជនរងគ្រោះនឹងមិនទទួលបានលទ្ធផលល្អប្រសើរនោះទេ។
- អ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរបង្ហាញពីក្តីពឹងទុក និងប្រើប្រាស់វិធានការជាក់លាក់ ដូចជាការត្រួតពិនិត្យ និងវិន័យ ដើម្បីរក្សាការទទួលខុសត្រូវរបស់នគរបាល។
- ស្ថាប័ននគរបាលទាំងមូលគួរធានាគណនេយ្យភាពចំពោះជនរងគ្រោះ និងអ្នកអនុវត្តន៍ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀត និងគួររក្សាការទទួលខុសត្រូវរបស់ជនបង្កផងដែរ។

## ៨.ការអប់រំ និងបណ្តុះបណ្តាល

បន្ទាប់ពីស្ថាប័ននគរបាលបានអនុម័តទ្រឹស្តីគោលនយោបាយ ទម្រង់រដ្ឋបាល ឬនីតិវិធីថ្មី ធនធាន ឬការផ្លាស់ប្តូរផ្សេងទៀតអ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរបណ្តុះបណ្តាល

522. នគរបាល Minneapolis ធ្វើបេសកកម្មត្រួតពិនិត្យ "ការស្រាវជ្រាវ និងការសិក្សាស្តីពីការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ" ២០១៨ ៖ https://mn.gov/mdhr/assets/2018.01.11%20Oversight%20Commission%20-%20Domestic%20Violence_tcm1061-457059.pdf។។ របាយការណ៍នេះរួមបញ្ចូលប្រភេទផ្សេងៗនៃករណីដែលចាត់ទុកជា "អំពើហិង្សាក្នុងគ្រួសារ" ក្រោមច្បាប់នៅរដ្ឋ Minnesota សហរដ្ឋអាមេរិក។

523. ស្តង់ដារសេវានគរបាលថ្នាក់ខេត្ត ផ្នែក ៦.២.១ British Columbia ៖ https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminaljustice/police/standards/6-2-1-police-stops.pdf

មន្ត្រីនគរបាលលើការអនុវត្តការផ្លាស់ប្តូរទាំងនោះ។ ៤. ក្រោយការបង្កើតកម្រងសំណួរថ្មីសម្រាប់នគរបាលនៅប្រទេសហ្សកហ្ស៊ី (Georgia) មន្ត្រីនគរបាលត្រូវបានបណ្តុះបណ្តាលអំពីគោលបំណងនៃកម្រងសំណួរនោះ និងរបៀបប្រើប្រាស់។

ជាធម្មតា វគ្គបណ្តុះបណ្តាលផ្តោតសំខាន់លើការផ្លាស់ប្តូរផ្នត់គំនិតរបស់មន្ត្រីនគរបាលដែលមានភារៈពង្រឹងការអនុវត្តច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ទោះជាយ៉ាងណា ការបណ្តុះបណ្តាលគោលគំនិតតែម្យ៉ាងមិនអាចនាំទៅរកការផ្លាស់ប្តូរយូរអង្វែងក្នុងនាយកដ្ឋាននគរបាលបានឡើយ។ មន្ត្រីត្រូវយល់ថា ការផ្លាស់ប្តូរថ្មីៗនឹងប៉ះពាល់ដល់មុខងាររបស់ពួកគេក្នុងស្ថាប័ននគរបាល ហើយពួកគេត្រូវទទួលបានការបណ្តុះបណ្តាលជាក់ស្តែងស្តីពីការអនុវត្តការផ្លាស់ប្តូរទាំងនោះ។ ពួកគេគួរទទួលបានការបណ្តុះបណ្តាលស្តីពីវិធានការគណនេយ្យភាពដែលនាយកដ្ឋាននគរបាលនឹងយកមកប្រើប្រាស់ ដើម្បីធានាការអនុវត្តគោលនយោបាយ វិធានការ ឬធនធានថ្មីៗទាំងនោះបានដោយប្រសិទ្ធភាព។

ក្រៅពីនេះ នគរបាលគួរទទួលបានការអប់រំ និងការបណ្តុះបណ្តាលស្តីពីចំណុចខាងក្រោម ៖

- របៀបដែលស្ថាប័នមួយរៀបចំនគរបាលឱ្យយល់ពីការងាររបស់ពួកគេ និងបាតុភូតសង្គមដែលពាក់ព័ន្ធនឹងការងាររបស់ពួកគេ ដូចជា ការរំលោភបំពានស្ត្រីក្នុងចំណងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងស្និទ្ធស្នាល។
- វិធីផ្លូវការដែលស្ថាប័ននគរបាលបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនឱ្យពិចារណានិងចាត់វិធានការលើករណីនានា។
- វិធីក្រៅផ្លូវការដែលមន្ត្រីឆ្លើយតបអាចរៀនសូត្រពីការងាររបស់ពួកគេ តាមរយៈបទពិសោធន៍ និងការបណ្តុះបណ្តាលដោយបុគ្គលិកតាមវេរកាល។
- ការស្វែងយល់ពីគោលគំនិត ទ្រឹស្តី និងការអនុវត្តគោលគំនិតផ្សេងៗ។
- ការកសាងជំនាញជាប្រចាំដែលផ្តល់លទ្ធភាពឱ្យមន្ត្រីធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងប្រជាជនចម្រុះ។

**ការអប់រំ និងបណ្តុះបណ្តាល ៖ សារសំខាន់ៗ**

- មន្ត្រីនគរបាលគួរទទួលបានការអប់រំ និងការបណ្តុះបណ្តាលស្តីពីគោលនយោបាយការអនុវត្តផ្នែករដ្ឋបាល ធនធាន ឬការផ្សារភ្ជាប់ថ្មីៗដែលត្រូវបានអនុវត្ត របៀបដែលការផ្លាស់ប្តូរទាំងនេះផ្សារភ្ជាប់ទៅនឹងមុខងាររបស់ពួកគេក្នុងនាមជានគរបាលនិងរបៀបរក្សាការទទួលខុសត្រូវរបស់នគរបាលលើការអនុវត្តការផ្លាស់ប្តូរនោះ។
- ការអប់រំ និងបណ្តុះបណ្តាលគួរគ្របដណ្តប់លើគោលបំណងនៃការផ្លាស់ប្តូរក្នុងស្ថាប័ន និងរបៀបអនុវត្តការផ្លាស់ប្តូរនោះ។

## សេចក្តីសន្និដ្ឋាន

ដោយសារតែភាពលម្អៀងយេនឌ័រចាក់ឫសយ៉ាងជ្រៅក្នុងស្ថាប័ន ការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រទាមទារការវិភាគ និងការផ្លាស់ប្តូរក្នុងស្ថាប័ន។ មធ្យោបាយ ៨ ចំណុច ផ្តល់ក្របខណ្ឌដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាលសម្រាប់ការវិភាគចំណុចខ្វះខាត ក្នុងការឆ្លើយតបរបស់ស្ថាប័ននគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការបង្កើតការផ្លាស់ប្តូរក្នុងស្ថាប័ន។ ការជំរុញការចូលរួមរបស់ជនរងគ្រោះជាពិសេសជនរងគ្រោះដែលរងគ្រោះដោយទម្រង់ប្រទាក់ក្រឡាគ្នានៃការគៀបសង្កត់ជាកត្តាដ៏សំខាន់ក្នុងការស្វែងយល់ពីបទពិសោធន៍ជាក់ស្តែងរបស់ស្ត្រីនិងក្មេងស្រីនិងគម្លាតសេវាដែលផ្តល់ដោយស្ថាប័ននគរបាល។ ការសម្របសម្រួលជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀត ក៏ដើរតួនាទីសំខាន់ផងដែរក្នុងការធានាថាការផ្លាស់ប្តូរការអនុវត្តរបស់នគរបាលនឹងជួយពង្រឹងសុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលខុសត្រូវរបស់ជនបង្កក្នុងការដំណើរការករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ក្រៅពីនេះអ្នកគ្រប់គ្រងថ្នាក់កណ្តាលត្រូវអប់រំនគរបាលអំពីការផ្លាស់ប្តូរមុខងាររបស់ពួកគេក្នុងស្ថាប័ន និងត្រូវផ្សព្វផ្សាយ និងអនុវត្តវិធានការគណនេយ្យភាពយ៉ាងតឹងរ៉ឹងដើម្បីសម្រេចបានការផ្លាស់ប្តូរក្នុងស្ថាប័ន។ ការផ្លាស់ប្តូរក្នុងស្ថាប័នអាចបង្កើនការឆ្លើយតបរបស់នគរបាលគ្រប់រូបដែលធ្វើឱ្យស្ត្រី និងក្មេងស្រីក្នុងសហគមន៍កាន់តែមានសុវត្ថិភាព ។

# កំណត់សម្គាល់ និងអំណានបន្ថែម


1. Ellen Pence, 'St. Louis County Sheriff's Office Domestic Violence Handbook and Training Guide for Patrol Deputies,' 2001, at: https://praxisinternational.org/wpcontent/uploads/2015/12/sheriffhandbook-1.pdf

2. Ellen Pence, Laura Connelly, and Melissa Scaia, 'Turning Points: A Nonviolence Curriculum for Women,' Minnesota: 2011, at: https://www.theduluthmodel.org/wp-content/uploads/2017/03/Turning-Points-Curricula-for-Women-Who-Use-Violence-Preview.pdf

3. Evan Stark, 'The Dangers of Dangerous Assessment,' *Family & Intimate Partner Violence Quarterly*, November 2013, at: http://www.ncdsv.org/FIPVQ_Dangers-of-dangerousness-assessment_11-20-2013.pdf.

4. Evan Stark, 'Re-presenting Battered Women: Coercive Control and the Defense of Liberty,' *Violence Against Women: Complex Realities and New Issues in a Changing World*, Les Presses de l'Université du Québec: 2012

5. Mending the Sacred Hoop/Minnesota Development Project, Inc, 'Community Based Analysis of the U.S. Legal System's Interventions in Domestic Abuse Cases Involving Indigenous Women: Final Report to the National Institute of Justice, December 2002, at: https://praxisinternational.org/wp-content/uploads/2015/12/Final-1.pdf

6. Mending the Sacred Hoop & The Program to Aid Victims of Sexual Assault, 'Safety and Accountability Audit of the response to Native women who report sexual assault in Duluth, Minnesota, 2006-2008,' at: https://praxisinternational.org/wp-content/uploads/2015/12/TTAMSHTaAuditReport2011.pdf

7. Michael Paymar, Ellen Pence, and Graham Barnes, *Buiding a Coordinated Community Response to Domestic Violence: Trainer Guide*, Praxis International, 2010.

8. Minneapolis Police Conduct Oversight Commission, 'Domestic Violence Response Research and Study,' 2018, at: http://www.ci.minneapolis.mn.us/www/groups/public/@civilrights/documents/webcontent/wcmsp-211936.pdf

9. Office for Victims of Crime, 'The Vicarious Trauma Toolkit,' at: https://vtt.ovc.ojp.gov/tools-for-law-enforcement/management-and-supervision?fbclid=IwAR32qSintkuMtP_icolLYpdmnHymwgSyzqKLYwy6XTo_SFdR-LF1Y-sVB_s

10. Provincial Policing Standards, Section 6.2.1, British Columbia, at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminal-justice/police/standards/6-2-1-police-stops.pdf

11. *The Duluth Blueprint for Safety,* adopted January 29, 2015, at: https://www.theduluthmodel.org/wp-content/uploads/2017/03/1-Duluth-Intro.pdf.

# ១២

# ការបន្តផ្តល់យុត្តិធម៌

"អ្វីដែលខុសឆ្គងបំផុតនោះគឺជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រីយ៉ាងច្រើនលើសលប់មិនប្រឈមនឹងផលវិបាកអ្វីទាំងអស់។ មានតែករណីមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានរាយការណ៍ទៅនគរបាល ហើយមានករណីកាន់តែតិចដែលនាំទៅរកការចោទប្រកាន់ ដែលក្នុងនោះ ករណីមួយចំនួនតូចឈានដល់ការផ្តន្ទាទោស។ ស្ថាប័ននគរបាល និងស្ថាប័នតុលាការត្រូវពិចារណា ល្អិតល្អន់លើរបាយការណ៍ និងផ្តោតអាទិភាពលើសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ដូចជា តាមរយៈការមានមន្ត្រីជាស្ត្រីកាន់តែច្រើនសម្រាប់ស្ត្រីដែលរាយការណ៍ពីអំពើហិង្សា"។

Phumzile Mlambo-Ngcuka អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជានាយកប្រតិបត្តិអង្គការ UN Women ក្នុងឱកាសទិវាអន្តរជាតិលុបបំបាត់អំពើហិង្សាលើស្ត្រី (២០១៨)

# គោលបំណងនៃជំពូកទី ១២

**នគរបាលនឹងក្លាយជាអ្នកផ្តល់សេវាសំខាន់ៗដែលកាន់តែមានប្រសិទ្ធភាព នៅពេលពួកគេយល់ពីតួនាទីរបស់ខ្លួនក្នុងស្ថាប័នយុត្តិធម៌ និងស្ថាប័នសន្តិសុខ ក្នុងការដោះស្រាយ អំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការបន្តផ្តល់យុត្តិធម៌ ផ្តល់លម្អិតពីស្ថាប័នពាក់ព័ន្ធក្នុង យុត្តិធម៌ និង សន្តិសុខ ដែលធ្វើអន្តរកម្មជាមួយជនរងគ្រោះដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ចាំបាច់ត្រូវគោរព ការពារ លើកស្ទួយ និងបំពេញសិទ្ធិរបស់ស្ត្រីកុំឱ្យទទួលរងនូវការរើសអើងនិងទទួលបានសមភាពជាមួយបុរសនៅពេលប្រឈមនឹងករណីដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- តាមធម្មតា ដំណើរការយុត្តិធម៌មានភាពស្មុគស្មាញ និងស្ថិតក្នុងយុត្តាធិការផ្សេងៗដែលតួនាទីរបស់នគរបាលនិងអយ្យការអាចមានភាពខុសគ្នាយ៉ាងខ្លាំង។
- ចាំបាច់ត្រូវមានចក្ខុវិស័យដែលប្រទាក់ក្រឡាគ្នា និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ដើម្បីធ្វើការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីបានដោយប្រសិទ្ធភាព។
- ច្បាប់ក្នុងយុត្តាធិការរបស់អ្នកគឺជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ មិនមែនយុត្តាធិការទាំងអស់សុទ្ធតែមានច្បាប់សម្រាប់ដោះស្រាយទម្រង់ជាក់លាក់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនោះទេ។ ដូច្នេះ អ្នកគួរកំណត់រកផ្នែកបញ្ហាដែលលេចឡើង និងចែករំលែកការអនុវត្តល្អបំផុតជាមួយប្រធានក្រុម/អង្គភាពរបស់អ្នក។
- ការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈ បង្កការលំបាកដល់នគរបាលស៊ើបអង្កេត។
- ការធ្វើការជាមួយអយ្យការ សេវាតុលាការ និងសេវាអនុវត្តន៍ការព្យួរទោស (ទោះក្នុងទម្រង់អ្វីក៏ដោយ) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងករណីចាំបាច់នឹងផ្តល់លទ្ធផលកាន់តែប្រសើរដល់ជនរងគ្រោះ។
- ដំណោះស្រាយផ្អែកតាមសហគមន៍អាចផ្តល់ការផ្លាស់ប្តូរដ៏មានប្រសិទ្ធភាពក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។



## សេចក្តីផ្តើម

**សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ សំដៅលើការទទួលបានព័ត៌មានជាប្រចាំ ការវិភាគ ការយោគយល់ទូលំទូលាយ និងភាពរស់រវើកក្នុងការកសាងភាពជាដៃគូ និងផ្អែកលើការយល់ដឹងរបស់ស្ថាប័នស្តីពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាក និងថាតើអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។ ថ្នាក់ដឹកនាំនគរបាលត្រូវដឹងពីតួនាទីដ៏សំខាន់របស់ខ្លួនក្នុងប្រព័ន្ធយុត្តិធម៌ ដែលរួមបញ្ចូលផ្នែក និងស្ថាប័នចម្រុះ។ ស្ថាប័នទាំងអស់ក្នុងវិស័យយុត្តិធម៌ និងសន្តិសុខ រួមទាំងសេវានគរបាល សុទ្ធតែបំពេញតួនាទីរបស់ខ្លួនដើម្បីជំរុញឱ្យមានលទ្ធផលដ៏យុត្តិធម៌សម្រាប់អ្នកពាក់ព័ន្ធក្នុងវិស័យទាំងនេះ។ (រូប ១)**

រូបថតទទួលបានពី UN Women

ផ្តល់ភាពលម្អិតពីស្ថាប័នពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ និងសន្តិសុខ ដែលធ្វើអន្តរកម្មជាមួយជនរងគ្រោះ និងធ្វើការជាមួយប្រព័ន្ធយុត្តិធម៌រដ្ឋប្បវេណី។ ស្ថាប័នយុត្តិធម៌នីមួយៗ និងតុលាការមានការទទួលខុសត្រូវរៀងៗខ្លួន ប៉ុន្តែស្ថាប័នទាំងនេះត្រូវសហការគ្នាដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ នគរបាល ជួបបញ្ហាប្រឈមខុសៗគ្នា នៅមុនដំណាក់កាលមុនជំនុំជម្រះ ក្នុងពេលជំនុំជម្រះ និងក្រោយពេលជំនុំជម្រះ។

អន្តរកម្មរបស់ជនរងគ្រោះជាមួយក្របខណ្ឌច្បាប់ជាតិ ឬប្រព័ន្ធយុត្តិធម៌ជាតិ គ្របដណ្តប់លើដំណើរការយុត្តិធម៌ទាំងមូលដែលជាទូទៅចាប់ផ្តើមពីការលាតត្រដាងរឿងរ៉ាវបង្ហាញដល់នគរបាល។ ដំណើរការនេះបន្តរហូតដល់ការចូលរួមរបស់តំណាងស្របច្បាប់ក្នុងតុលាការ ការចូលរួមរបស់ស្ត្រីក្នុងតុលាការព្រហ្មទណ្ឌ និងតុលាការគ្រួសារ និងការប្រឈមនឹងតុលាការ។ ក្នុងករណីមានការផ្តន្ទាទោស ដំណើរការនេះបញ្ចប់ត្រឹមជនបង្កទទួលទោសក្នុងតុលាការ ដូចជារយៈពេលជាប់ពន្ធនាគារ ឬការផ្តន្ទាទោសដោយគ្មានការឃុំខ្លួន ដូចជា ការពិន័យ ឬការអនុវត្តន៍ការព្យួរទោសជាមួយសេវាសហគមន៍។ ជារួមប្រព័ន្ធយុត្តិធម៌ និងដំណើរការយុត្តិធម៌ជួយបង្កើតបានជាការបន្តផ្តល់យុត្តិធម៌ដែលកត់សម្គាល់ភាពចាំបាច់ក្នុងការធានាការគោរព ការការពារ និងការបំពេញសិទ្ធិរបស់អ្នកដែលរងផលប៉ះពាល់ដោយសារប្រព័ន្ធយុត្តិធម៌នៅដំណាក់កាលនីមួយៗនៃសង្វាក់ដំណើរការយុត្តិធម៌។

ក្នុងតុលាការព្រហ្មទណ្ឌរដ្ឋកសាងសំណុំរឿងប្រឆាំងនឹងជនបង្កដែលប្រព្រឹត្តបទល្មើសចំណែកក្នុងតុលាការគ្រួសារការដោះស្រាយផ្តោតលើករណីដែលពាក់ព័ន្ធនឹងការកាត់ផ្តាច់ទំនាក់ទំនងគ្រួសារ ដូចជា ការលែងលះ និងការការពារកូន។

524. កញ្ចប់សេវាសំខាន់ៗកំណត់និយមន័យនៃការបន្តផ្តល់យុត្តិធម៌ថាគ្របដណ្តប់ចាប់ពីលទ្ធភាពរបស់ជនរងគ្រោះក្នុងការចូលទៅក្នុងប្រព័ន្ធយុត្តិធម៌ រហូតដល់ការបិទបញ្ចប់បញ្ហា។ ដំណើរការរបស់ស្ត្រីមានលក្ខណៈខុសៗគ្នាទៅតាមតម្រូវការរបស់ស្ត្រី។ ស្ត្រីអាចស្វែងរកជម្រើសយុត្តិធម៌ផ្សេងៗ ចាប់ពីការរាយការណ៍ ឬការដាក់បណ្តឹងដែលធ្វើឱ្យមានការស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើស ឬស្វែងរកការការពារ និង/ឬបន្តការទាមទារបណ្តឹងរដ្ឋប្បវេណី ដូចជាការលែងលះ និងសិទ្ធិចិញ្ចឹមកូន និង/ឬការទូទាត់សំណងសម្រាប់ការខូចខាតផ្ទាល់ខ្លួន ឬការខូចខាតផ្សេងទៀត ដូចជា គ្រោងការរដ្ឋបាលសាធារណៈ ដែលធ្វើឡើងដំណាលគ្នា ឬពីពេលមួយទៅពេលមួយ។

### រូប ១៖
### ការបន្តផ្តល់យុត្តិធម៌[524]




សម្រាប់ជនរងគ្រោះជាច្រើន ការដោះលែងជនបង្ក ជាពិសេសជនបង្កដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាបញ្ហាកង្វល់ និងអាចបង្ខំឱ្យជនរងគ្រោះផ្លាស់ប្តូរតិយាបថរបស់ខ្លួននិងបង្កភាពថប់បារម្ភយ៉ាងខ្លាំង ដូចជា ការឱ្យកូនឈប់រៀនដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន ឬការឈប់ធ្វើការដើម្បីធានាសុវត្ថិភាពរបស់កូនពេលចេញពីរៀន។ នីតិវិធីក្នុងការរក្សាឱ្យជនរងគ្រោះបានដឹងព័ត៌មានអំពីការដោះលែងជនបង្ក ជាគន្លឹះសម្រាប់ការការពារជនរងគ្រោះជាបន្តបន្ទាប់។ **សូមមើលជំពូកទី ៦ (សុវត្ថិភាព និងការការពារ)។**

តុលាការគ្រួសារស្ថិតក្នុងប្រព័ន្ធយុត្តិធម៌ ហើយសេវានគរបាលអាចពាក់ព័ន្ធក្នុងការទទួលបានវិធានការការពារដើម្បីការពារស្ត្រី និងកូនៗពីអំពើហិង្សាក្នុងគ្រួសារដែលបង្កឡើងដោយបុរសជាដៃគូស្និទ្ធស្នាលរបស់ស្ត្រីឬសមាជិកគ្រួសារផ្សេងទៀតក្នុងផ្ទះ។ មានន័យថា សេវានគរបាលដើរតួនាទីយ៉ាងសំខាន់ក្នុងតុលាការគ្រួសារ និងតុលាការព្រហ្មទណ្ឌ។

**រឿងរ៉ាវរបស់ស្ត្រី និងក្មេងស្រីម្នាក់ៗពីខុសៗគ្នា និងអាស្រ័យលើតម្រូវការបុគ្គល។**

ថ្វីបើនគរបាលដើរតួនាទីផ្សេងៗគ្នាក្នុងប្រព័ន្ធតុលាការ ប៉ុន្តែថ្នាក់ដឹកនាំនគរបាលត្រូវយល់ពីគោលការណ៍រួមដែលគ្របដណ្តប់លើការងាររបស់នគរបាលដោយមិនគិតពីរបៀបបំពេញការងារ។ ចាំបាច់ត្រូវគោរព ការពារ លើកស្ទួយ និងបំពេញសិទ្ធិរបស់ស្ត្រីក្នុងការមិនទទួលរងការរើសអើងនិងការទទួលបានសមភាពជាមួយបុរសដូចការលម្អិតក្នុងអនុសាសន៍រួមលេខ ២៨ ស្តីពីកាតព្វកិច្ចសំខាន់ៗរបស់រដ្ឋភាគីក្រោមមាត្រា ២ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (អនុសញ្ញា CEDAW)[525]។

ក្នុងករណីដែលផលប៉ះពាល់យូរអង្វែងនៃការរើសអើងធ្វើឱ្យស្ត្រី និងក្មេងស្រីជួបការលំបាកធ្ងន់ធ្ងរ ចំណុចនេះអាចទាមទារនូវវិធានការដែលផ្តល់ឱ្យស្ត្រីនូវការប្រព្រឹត្តចំពោះ ដោយស្មើភាពដូចបុរស ក៏ដូចជាការអនុគ្រោះជាផ្លូវការ ដើម្បីបង្កើតសមភាព និងសមធម៌ពិតប្រាកដសម្រាប់ស្ត្រី។ ការកំណត់ និងការអនុវត្តវិធានការទាំងនេះឱ្យបានសមស្រប មានពិពណ៌នាក្នុងមាត្រា ៤ នៃអនុសញ្ញានេះនិងត្រូវបានបរិយាយបន្ថែមក្នុងអនុសាសន៍រួមលេខ ២៥ របស់គណៈកម្មាធិការ CEDAW[526]។

ដូច្នេះ ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ និងដំណើរការយុត្តិធម៌គឺសំខាន់ខ្លាំងណាស់ព្រោះទំនុកចិត្តនេះលើកទឹកចិត្តឱ្យជនរងគ្រោះចូលរួមនិងរាយការណ៍ពីការប្រព្រឹត្តបទល្មើសលើពួកគេ។

ថ្នាក់ដឹកនាំនគរបាលត្រូវយល់ថា ជាធម្មតាដំណើរការយុត្តិធម៌មានភាពស្មុគស្មាញ ហើយក្នុងយុត្តាធិការផ្សេងៗ តួនាទីអាចខុសគ្នា។ ឧ. នៅប្រទេសទួរគី អយ្យការជាអ្នកណែនាំដល់ការស៊ើបអង្កេតរបស់នគរបាល[527] ខណៈដែលក្នុងចក្រភពអង់គ្លេសនគរបាលស៊ើបអង្កេតបទល្មើស ចំណែកសេវាអយ្យការCrown (CPS) ជាអ្នកសម្រេចបទចោទក្នុងករណីស្មុគស្មាញជាពិសេសករណីដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[528]។

ថ្នាក់ដឹកនាំនគរបាលត្រូវកសាងការយល់ដឹងកាន់តែច្រើនអំពីដំណើរការយុត្តិធម៌។ ខណៈដែលជនរងគ្រោះកំពុងឆ្លងកាត់ដំណើរការដ៏លំបាកនេះ ច្បាប់ បទដ្ឋានសង្គម និង គោលនយោបាយរដ្ឋាភិបាលកំណត់ពីវិឌ្ឍនភាពនៃការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនេះ។ ការគាំទ្ររបស់អង្គការសង្គមស៊ីវិលក៏មានសារៈសំខាន់សម្រាប់ជនរងគ្រោះផងដែរ។ជនរងគ្រោះគាត់អាចស្វែងរកជម្រើសយុត្តិធម៌ផ្សេងៗ ចាប់ពីការរាយការណ៍ ឬការដាក់បណ្ដឹងដែលធ្វើឱ្យមានការស៊ើបអង្កេត និងផ្ដន្ទាទោសជនល្មើស ឬស្វែងរកការការពារ និង/ឬបន្តការទាមទារបណ្ដឹងរដ្ឋប្បវេណី ដូចជាការលែងលះ និងសិទ្ធិចិញ្ចឹមកូន និង/ឬការទូទាត់សំណងសម្រាប់ការខូចខាតផ្ទាល់ខ្លួន ឬការខូចខាតផ្សេងទៀត ដូចជា គ្រោងការរដ្ឋបាលសាធារណៈដែលធ្វើឡើងដំណាលគ្នា ឬពីពេលមួយទៅពេលមួយ។

អ្នកចូលរួមសំខាន់ៗក្នុងប្រព័ន្ធយុត្តិធម៌មានបង្ហាញក្នុងគំរូSarkariaស្ដីពីអ្នកចូលរួមក្នុងប្រព័ន្ធយុត្តិធម៌បូករួមនឹងកត្តាជុំវិញឱ្យមានការផ្លាស់ប្តូរនៅដំណាក់កាលណាមួយ។

**រូប ២ ៖**

**គំរូ Sarkaria ស្ដីពីអ្នកចូលរួមក្នុងប្រព័ន្ធយុត្តិធម៌**




525. អនុសាសន៍រួមលេខ ២៨ ស្ដីពីកាតព្វកិច្ចសំខាន់ៗរបស់រដ្ឋភាគីក្រោមមាត្រា ២ នៃអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (២០១០) UN Doc CEDAW/C/2010/47/GC.2 : https://www2.ohchr.org/english/bodies/cedaw/docs/CEDAW-C-2010-47-GC2.pdf

526. អនុសាសន៍រួមលេខ ២៥ ក្នុងមាត្រា ៤ កថាខណ្ឌ ១ នៃអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទស្ដីពីវិធានការពិសេសបណ្ដោះអាសន្ន។OHCHR https://www.un.org/womenwatch/daw/cedaw/recommendations/General%20recommendation%2025%20(English).pdf

527. ក្រោមមាត្រា ១៦១/១ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ (ច្បាប់លេខ ៥២៧១) អយ្យការសារធារណៈអាចធ្វើការស៊ើបអង្កេតគ្រប់ប្រភេទដោយផ្ទាល់ឬតាមរយៈមន្ត្រីនគរបាលតុលាការ។អយ្យការសាធារណៈនឹងស៊ើបអង្កេតលើបញ្ហាដើម្បីសម្រេចថាតើចាំបាច់ត្រូវផ្ដួចផ្ដើមករណីព្រហ្មទណ្ឌឬទេ ហើយប្រសិនបើភស្តុតាងដែលទទួលបានក្នុងពេលស៊ើបអង្កេត បណ្ដាលឱ្យមានការសង្ស័យគ្រប់គ្រាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស នឹងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ (មាត្រា ១៦០/១)។ ទោះជាយ៉ាងណា ប្រសិនបើគ្មានភស្តុតាងគ្រប់គ្រាន់ អយ្យការសាធារណៈនឹងមិនធ្វើការផ្ដន្ទាទោសឡើយ (មាត្រា ១៧០/២)។

528. CPS ផ្ដន្ទាទោសករណីព្រហ្មទណ្ឌដែលត្រូវបានស៊ើបអង្កេតដោយនគរបាល និងស្ថាប័នស៊ើបអង្កេតផ្សេងទៀតនៅប្រទេសអង់គ្លេស និងវែល។ CPS ជាស្ថាប័នឯករាជ្យ ហើយយើងធ្វើសេចក្ដីសម្រេចដោយមិនពាក់ព័ន្ធនឹងនគរបាល និងរដ្ឋាភិបាល។ អំពី CPS ៖ The Crown Prosecution Service, at: https://www.cps.gov.uk/about-cps

## ការណែនាំគ្នាទៅវិញទៅមក

ថ្នាក់ដឹកនាំគរបាលគួរដឹងថា ការទទួលបានយុត្តិធម៌គឺជាសិទ្ធិមនុស្សដែលផ្តល់មធ្យោបាយក្នុងការសម្រេចបានសិទ្ធិផ្សេងទៀតនៅពេលស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ឧបសគ្គរាំងយុត្តិធម៌ ដូចជា ឧបសគ្គផ្នែកច្បាប់ ស្ថាប័ន សង្គមសេដ្ឋកិច្ច និងវប្បធម៌ អាចធ្វើឱ្យជនរងគ្រោះ មិនទទួលបានលទ្ធផលដែលយុត្តិធម៌។

**ការគិតគូរពីយេនឌ័រ ជាការផង និងតម្រូវការ ផលប្រយោជន៍ និងការយល់ឃើញរបស់ស្ត្រីក្នុងនាមជាស្ត្រី និងតម្រូវការ ផលប្រយោជន៍ និងការយល់ឃើញរបស់បុរសក្នុងនាមជាបុរស។**

អ្នកត្រូវធានាថា បុគ្គលិករបស់អ្នកបានដឹងពីទំនាក់ទំនងរវាងការទទួលបានដំណើរការយុត្តិធម៌ និងផលវិបាកសម្រាប់នគរបាលនៅជំហាននីមួយៗ។ ឧ. អយ្យការ និងចៅក្រមអាចប្រើប្រាស់អភិក្រមដែលគិតគូរពីយេនឌ័រដែល៖

- ទទួលស្គាល់នូវភាពខុសគ្នានៃបទពិសោធន៍របស់ស្ត្រី និងបុរសរួមទាំងបទពិសោធន៍ពាក់ព័ន្ធនឹងការរំលោភសិទ្ធិ ក៏ដូចជាទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌។
- កត់សម្គាល់ថាតើតម្រូវការរបស់បុរស និងស្ត្រីខុសគ្នា និងប្រទាក់ក្រឡាគ្នាដូចម្តេច ពាក់ព័ន្ធនឹងឧបាស្រ័យ និងដំណោះស្រាយ។
- យល់ពីលក្ខណៈសាយភាយនៃផ្នត់គំនិតយេនឌ័រ និងកត្តាប្រទាក់ក្រឡាគ្នានៃ ផ្នត់គំនិតទាំងនោះ សូម្បីតែកត្តាដែលយើងទាំងអស់គ្នាមើលមិនដឹង[529]។

អភិក្រមនេះអាចអនុវត្តដោយបុគ្គលិករបស់អ្នកក្នុងការផ្តល់អភិក្រមដែលគិតគូរពីយេនឌ័រ នៅពេលធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ និងស្ថាប័នផ្សេងទៀតក្នុងប្រព័ន្ធយុត្តិធម៌។

បុគ្គលិករបស់អ្នកត្រូវយល់ថា តួនាទីរបស់ពួកគេ (និងតួនាទីរបស់ស្ថាប័នផ្សេងទៀតក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ) គឺត្រូវធានាថា ជនរងគ្រោះត្រូវបានបញ្ជូនទៅរកនិងទទួលបានការគាំទ្រដែលពួកគេត្រូវការជាចាំបាច់ នៅមុនពេល ក្នុងពេល និងក្រោយពេលបញ្ចប់ដំណើរការយុត្តិធម៌។

មានភាពខុសគ្នាជាច្រើនក្នុងច្បាប់ព្រហ្មទណ្ឌស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅទូទាំងសកលលោក ដែលរារាំងមិនឱ្យស្ថាប័នអនុវត្តន៍ច្បាប់ផ្តល់សេវាដល់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹង "អំពើហិង្សាក្នុងគ្រួសារ" និងរារាំងមិនឱ្យជនរងគ្រោះស្វែងរកការគាំទ្រដែលពួកគេត្រូវការ។ គួរកត់សម្គាល់ថា ច្បាប់ត្រូវបានតាក់តែងឡើងជាប្រព័ន្ធ និងជាញឹកញាប់នៅតែឆ្លុះបញ្ចាំងពីភាពលម្អៀងទៅខាងបុរស និងមានការរើសអើងជាប្រព័ន្ធលើស្ត្រី និងក្មេងស្រី។

"ច្បាប់ដែលតាក់តែងឡើងដោយបុរស សម្រាប់បុរស និងតាងនាមឱ្យបុរស បង្កប់ភាពលម្អៀងទៅខាងបុរស និងមានការរើសអើងជាប្រព័ន្ធលើស្ត្រី និងក្មេងស្រី តាមរយៈការមិនខ្វាយខ្វល់ពីទស្សនៈរបស់ស្ត្រី។ បច្ចុប្បន្ន ច្បាប់នេះត្រូវបានអនុវត្តបកស្រាយនិងគ្រប់គ្រងដោយបុរស។ ដូច្នេះ ច្បាប់នេះបម្រើឱ្យផលប្រយោជន៍របស់បុរសក្នុងនាមជាក្រុមមួយ។ស្ត្រីក៏ទទួលយកភាពលម្អៀងទៅខាងបុរសក្នុងច្បាប់នេះដែរក្នុងទម្រង់ជាយុត្តិធម៌បែបសត្យានុម័ត នៅពេលស្ត្រីដែលជាសមាជិកនៃក្រុមប្រឹក្សាតុលាការ មេធាវី ចៅក្រម។ល។ អនុវត្តស្តង់ដារបុរស។ មិនថាស្តង់ដាររបស់បុរសបង្កជាការរើសអើងភេទ ឬផលប៉ះពាល់ដោយប្រយោលនៃការមានទស្សនៈដូចបុរសឬយ៉ាងណានោះទេ លទ្ធផលសម្រាប់ស្ត្រីគឺដូចគ្នា។ ពោលគឺនៅដំណាក់កាលនីមួយៗ ស្ត្រីមិនទទួលបានការការពារស្មើភាពក្រោមច្បាប់នេះឡើយ"។

ប្រភព ៖ Jones (1980) as cited in The Justice, Law and Order Sector Programme, Government of Uganda 'Study on Gender and Access to Justice' in Guidance note for UNODC staff Gender mainstreaming in the work of UNODC (2013)

529. សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់ចៅក្រមនិងអយ្យការស្តីពីការធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ (វិទ្យាស្ថានអឺរ៉ុប និងក្រុមប្រឹក្សាអឺរ៉ុប ២០១៧)៖ https://rm.coe.int/training-manual-women-access-to-justice/16808d78c5

អ្វីដែលសំខាន់ផងដែរក្នុងការស្វែងយល់ពីរបៀបដែលច្បាប់ណាមួយ អាចបង្កប់ភាពលម្អៀងទៅខាងបុរស និងមានការរើសអើងជាប្រព័ន្ធលើស្ត្រី និងក្មេងស្រី គឺសមត្ថភាពក្នុងការកំណត់រកកត្តាប្រទាក់ក្រឡាគ្នា និងត្រួតគ្នាដែលបន្តធ្វើឱ្យជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជួបការលំបាកបន្ថែមទៀតក្នុងការទទួលបានយុត្តិធម៌។ ឧ. បុគ្គលនិងក្រុមអាចមិនទទួលបានការយកចិត្តទុកដាក់ដោយសារតែយេនឌ័រ ជាតិពន្ធ ទំនោរផ្លូវភេទ ដើមកំណើតជាតិ និង/ឬពិការភាព ហើយចំណុចនេះអាចបង្កផលប៉ះពាល់ផ្ទាល់លើលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសុវត្ថិភាព និងយុត្តិធម៌។

**"បញ្ហាលំបាករបស់ស្ត្រី និងក្មេងស្រីម្នាក់ៗ គឺខុសៗគ្នា និងអាស្រ័យលើតម្រូវការរបស់បុគ្គលម្នាក់ៗ"។**

ការអនុវត្តភាពប្រទាក់ក្រឡាគ្នានៅពេលអនុវត្តច្បាប់ពាក់ព័ន្ធសម្រាប់សេវានគរបាល ជាពិសេសច្បាប់ប្រឆាំងការរើសអើងនិងនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នឹងជួយឱ្យមន្ត្រីកំណត់រករបៀបដែលបទពិសោធន៍របស់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងវិសមភាពមិនស៊ីសង្វាក់គ្នានឹងគំរូទូទៅនិងអត្ថន័យរបស់វាសម្រាប់ការការពារ និងសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រីក្នុងចំណោមសេវាសំខាន់ៗផ្សេងទៀតដែលពួកគេមានសិទ្ធិទទួលបាន។

ការអនុវត្តភាពប្រទាក់ក្រឡាគ្នាមិនត្រឹមតែគូសបញ្ជាក់ពីមុខងារជិះជាន់ ឬបង្ខិតបង្ខំនៃអំណាចពីលើចុះក្រោមប៉ុណ្ណោះទេប៉ុន្តែថែមទាំងអាចឱ្យមន្ត្រីយល់កាន់តែច្បាស់ថាតើទំនាក់ទំនងអំណាចតាមឋានានុក្រមកាន់តែរីកធំឡើងនៅពេលច្បាប់មិនបានកត់សម្គាល់ពីអត្តសញ្ញាណពេញលេញរបស់កម្មវត្ថុ តួនាទី ឬភាពស្មុគស្មាញ ឬភាពរប៉ាត់រប៉ាយនៃបទពិសោធន៍របស់ស្ត្រី និងក្មេងស្រី[530]។ ដូច្នេះ ចាំបាច់ត្រូវមានអភិក្រមប្រទាក់ក្រឡាគ្នា និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ (សូមមើលជំពូកទី២៖ ការធ្វើឱ្យមានភាពខុសគ្នាក្នុងនាមជាប្រធានគ្រប់គ្រងនិងប្រធានក្រុម)។

## ជនរងគ្រោះ

ការយល់ពីតម្រូវការរបស់ជនរងគ្រោះ ជាកត្តាសំខាន់សម្រាប់ឱ្យបុគ្គលិករបស់អ្នកបំពេញតួនាទីយ៉ាងមានប្រសិទ្ធភាព។ បញ្ហាលំបាករបស់ជនរងគ្រោះអាចនាំទៅរកការប្រព្រឹត្ត ដោយមិនស្មើភាព ដោយសារតែទំនាក់ទំនងនិងភាពពាក់ព័ន្ធចម្រុះដែលការរើសអើងអាចកើតចេញពីប្រព័ន្ធអំណាច ដូចជា ការរើសអើងជាតិសាសន៍ ទស្សនៈបិតាធិបតេយ្យ ការគៀបសង្កត់ វណ្ណៈ ការរើសអើងផ្លូវភេទ អាយុ ទំនោរផ្លូវភេទ ពិការភាព និងប្រព័ន្ធនៃការរើសអើងផ្សេងទៀត។ សារសំខាន់សម្រាប់បុគ្គលិករបស់អ្នកគឺជនរងគ្រោះមានបទពិសោធន៍ផ្ទាល់ខ្លួនចេញពីអត្តសញ្ញាណផ្សេងៗ[531]។
ថ្នាក់ដឹកនាំនគរបាលដែលចង់ដឹងបន្ថែមទៀតអំពីបញ្ហាប្រឈមរបស់ស្ត្រី ដែលជាជនរងគ្រោះដោយសារអំពើហិង្សាក្នុងដំណើរការយុត្តិធម៌ គួរអានម៉ូឌុលទី ៣ នៃឯកសារជំនួយស្មារតីរបស់អ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌ (UN Women et al.)[532] ស្តីពីការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ឯកសារជំនួយស្មារតីនេះកំណត់ការណែនាំជាក់ស្តែងលើរបៀបដោះស្រាយបញ្ហាប្រឈមទាំងនោះក្នុងប្រព័ន្ធយុត្តិធម៌ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ឯកសារជំនួយស្មារតីនេះត្រូវបានបង្កើតឡើងសម្រាប់បុគ្គលិកក្នុងស្ថាប័នអង្គការសហប្រជាជាតិប៉ុន្តែវាផ្តល់ជម្រើសយ៉ាងច្រើនសម្រាប់ការឆ្លើយតបទៅនឹងបញ្ហាបច្ចុប្បន្ន ដែលពាក់ព័ន្ធនឹងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌និងភាពចាំបាច់នៃជំនួយបច្ចេកទេសក្នុងផ្នែកនេះ។
ខ្លឹមសារសង្ខេបខាងក្រោមផ្តល់ចំណុចចាប់ផ្តើមយ៉ាងល្អដល់ថ្នាក់ដឹកនាំនគរបាល ក្នុងការវិភាគដំណើរការយុត្តិធម៌និងនគរបាលដែលមានតួនាទីស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

530. Emily Grabham with Didi Herman, Davina Cooper and Jane Krishnadas "Introduction" in Intersectionality and Beyond: Law, power and the politics of location, Edited by Emily Grabham, Davina Cooper, Jane Krishnadas and Didi Herman (2009: Routledge-Cavendish).
531. សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់ចៅក្រមនិងអយ្យការស្តីពីការធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ (២០១៧) សហភាពអឺរ៉ុប និងក្រុមប្រឹក្សាអឺរ៉ុប ៖ https://www.ohchr.org/Documents/Issues/Women/WRGS/TrainingManualAccessJustice_EN.pdf
532. ឯកសារជំនួយស្មារតីរបស់អ្នកអនុវត្តន៍ស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការរៀបចំកម្មវិធីយុត្តិធម៌ (UN Women, UNODC, OHCHR, UNDP, 2018) ម៉ូឌុលទី ៣ ស្តីពីការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ https://www.unwomen.org/en/digital-library/publications/2018/5/a-practitioners-toolkit-on-womens-access-to-justice-programming

**ប្រអប់ ១**

**បញ្ហាប្រឈមសម្រាប់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងដំណើរការយុត្តិធម៌** [533]

### ការទប់ស្កាត់

- មិនមែនគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី សុទ្ធតែអាចផ្តន្ទាទោសព្រហ្មទណ្ឌបាននោះទេ (ឧ. ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍)។

### ការកត់សម្គាល់ពីដំបូង និងការរាយការណ៍

- ជាញឹកញាប់ នេះជាបន្ទុករបស់ជនរងគ្រោះក្នុងការចោទប្រកាន់ ដាក់បណ្តឹងផ្លូវការ ឬស្នើសុំការផ្តន្ទាទោស (ក្នុងផ្លូវច្បាប់ ឬក្នុងការអនុវត្ត)។
- ភាពលម្អៀង និងផ្នត់គំនិតយេនឌ័រទូលំទូលាយក្នុងចំណោមមន្ត្រីអនុវត្តន៍ច្បាប់ នាំទៅរកការមិនរាយការណ៍ពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹង យេនឌ័រលើស្ត្រី។

### ការស៊ើបអង្កេត

- លក្ខន្តិកៈនៃព្រំដែនកំណត់ ឬបទញ្ញត្តិច្បាប់ផ្សេងទៀតរារាំងមិនឱ្យជនរងគ្រោះដាក់ការចោទប្រកាន់ក្រោយអំឡុងពេលជាក់លាក់មួយ។
- ជាញឹកញាប់ ជនរងគ្រោះត្រូវរង់ចាំជាច្រើនម៉ោងនៅប៉ុស្តិ៍នគរបាល ហើយជនរងគ្រោះត្រូវបានសួរចម្លើយជាច្រើនដងដោយមន្ត្រីនគរបាលជាបុរស ត្រួតពិនិត្យដោយមន្ត្រីកោសលវិច័យជាបុរស មិនទទួលបានការគោរព និងគ្មានឯកជនភាព នៅពេលត្រូវបានសួរចម្លើយ និងនៅពេលផ្តល់ចម្លើយ។
- ជាញឹកញាប់ភស្តុតាងផ្អែកតាមអង្គហេតុគឺមិនអាចទទួលយកបានដែលធ្វើឱ្យជនរងគ្រោះក្លាយជាប្រភពភស្តុតាងតែមួយគត់។
- ជារឿយៗវិធានផ្នែកភស្តុតាងចាត់ទុកវត្តុតាងជាភស្តុតាងសំខាន់ក្នុងកិច្ចដំណើរការនីតិវិធីលើបទចោទព្រហ្មទណ្ឌដែលជាការលំបាកក្នុងករណីដែលមានការពន្យារពេលរាយការណ៍ ឬអំពើហិង្សាពាក់ព័ន្ធ មានលក្ខណៈជាអំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវអារម្មណ៍ ឬអំពើហិង្សាផ្នែកសេដ្ឋកិច្ច។
- ជាញឹកញាប់ គ្មានលទ្ធភាពទទួលបានវិធានការការពារភ្លាមៗ បន្ទាន់ ឬយូរអង្វែង ក៏ដូចជាការវាយតម្លៃហានិភ័យ ឬផែនការសុវត្ថិភាពសម្រាប់ជនរងគ្រោះ។
- ជនរងគ្រោះត្រូវបានតម្រូវឱ្យផ្តល់សក្ខីកម្មជាច្រើនដង និងជាញឹកញាប់ ដោយមានវត្តមានរបស់ជនជាប់ចោទ។
- នគរបាលអាចស្នើឱ្យបង់សាហ៊ុយធ្វើដំណើរ និងប្រេងឥន្ធនៈ (សាំង/ប្រេង) ដើម្បីស៊ើបអង្កេតបទល្មើស។
- ក្នុងប្រទេសជាច្រើននគរបាលចែកទម្រង់បែបបទមួយកញ្ចប់ដល់ជនរងគ្រោះសម្រាប់ដាក់ជូនសេវាសុខភាពក្នុងពេលពិនិត្យផ្នែកវេជ្ជសាស្ត្រ (ផ្នែកមួយនៃដំណើរការប្រមូលភស្តុតាង) និងការថែទាំបង្ការោគ។ ពេលខ្លះ ទម្រង់បែបបទទាំងនេះមិនផ្តល់ភាពងាយស្រួលដល់អ្នកពិនិត្យផ្នែកវេជ្ជសាស្ត្រឡើយ និងអាចមិនផ្តល់ព័ត៌មានចាំបាច់សម្រាប់ការប្រមូលភស្តុតាង។

### មុនពេលជំនុំជម្រះ

- ជនរងគ្រោះភាគច្រើនមិនសូវបានដឹងពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ គ្មានលទ្ធភាពទទួលបានសេវាជំនួយផ្លូវច្បាប់ ហើយដូច្នេះ មិនដឹងថា ពួកគេគួរធ្វើអ្វីខ្លះនោះទេ។
- ជាទូទៅនីតិវិធីព្រហ្មទណ្ឌនិងរដ្ឋបាលតុលាការមិនអនុញ្ញាតឱ្យមានការពិចារណាពីភាពងាយរងគ្រោះជាក់លាក់របស់ជនរងគ្រោះជាស្ត្រីឡើយ និងជាញឹកញាប់ គ្មានការបំពេញតម្រូវការជាក់លាក់របស់ស្ត្រី។

### ក្នុងពេលជំនុំជម្រះ និងផ្តន្ទាទោស

- ជាញឹកញាប់ ការអនុវត្តរបស់តុលាការ ឬលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី នាំទៅរកសេចក្តីសម្រេចដែលមិនគិតគូរពី

ជនរងគ្រោះ និងនាំឱ្យមានការញែកជនរងគ្រោះចេញពីដំណើរការនេះ និងចុងបញ្ចប់ដកករណី ឬបោះបង់ពាក់កណ្ដាលផ្លូវ។

- វិធានផ្នែកភស្តុតាងអាចអនុញ្ញាតឱ្យមានការចោទសួរលម្អិតស្ដីពីប្រវត្តិផ្ទាល់ខ្លួន ឬប្រវត្តិផ្លូវភេទ ទាមទារការបញ្ជាក់បន្ថែម ឬអនុញ្ញាតឱ្យមានការសន្និដ្ឋានមិនល្អដែលបណ្ដាលមកពីការពន្យារពេលរាយការណ៍។

**ការកែប្រែ**

- ជនរងគ្រោះមិនទទួលបានព័ត៌មានស្ដីពីការដោះលែងជនល្មើសសូម្បីតែក្នុងករណីដែលជនរងគ្រោះនិងជនល្មើសមកពីសហគមន៍តែមួយ។

## ការដោះស្រាយបញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ចាប់ផ្ដើមពីការកំណត់រកចំណុចខ្វះខាតលើការអនុវត្តការងារក្នុងក្រុមរបស់អ្នក

### តួនាទីរបស់ច្បាប់ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់

ថ្នាក់ដឹកនាំនគរបាលគួរដឹងថា ចាំបាច់ត្រូវមានមូលដ្ឋានត្រឹមត្រូវសម្រាប់ឱ្យនគរបាលស៊ើបអង្កេតដោយប្រសិទ្ធភាពលើករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី រួមទាំងបទបញ្ញត្តិច្បាប់ និងក្របខណ្ឌទូលំទូលាយ និងគោលនយោបាយ និងក្របខណ្ឌដែលឆ្លើយតបនឹងយេនឌ័រ ដូចការរៀបរាប់លម្អិតក្នុងកញ្ចប់សេវាសំខាន់ៗ, ម៉ូឌុលទី ៦៖ ការណែនាំអំពីការអនុវត្ត។ ឧបសគ្គផ្នែករចនាសម្ព័ន្ធស្ថាប័នប្រហែលជាត្រូវដោះស្រាយនៅថ្នាក់ជាតិដោយប្រធានសេវានគរបាលដើម្បីគាំទ្រឱ្យមានបរិយាកាសអំណោយផល ៖ ច្បាប់ គោលនយោបាយ ថវិកា អ្នកផ្ដល់សេវាដែលមានលទ្ធភាពអ្នកទាមទារសេវាដែលផ្អែកតាមព័ត៌មានត្រឹមត្រូវ និងការគ្រប់គ្រងគុណភាព[534]។

**ច្បាប់ប្រាប់ពីរបៀបដែលអ្នកផ្ដល់សេវានគរបាលមិនមែនពីទំនៀមទម្លាប់នៅមូលដ្ឋាននោះទេ។**

ក្នុងនាមជាថ្នាក់ដឹកនាំនគរបាល អ្នក និងបុគ្គលិករបស់អ្នកត្រូវ ៖

- យល់ពីតួនាទីនៃច្បាប់ក្នុងសង្គមជាពិសេសក្នុងការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- យល់ថា ច្បាប់នេះជាមូលដ្ឋានដ៏សំខាន់សម្រាប់ការស៊ើបអង្កេតរបស់នគរបាល ព្រោះវាផ្ដល់ក្របខណ្ឌសម្រាប់ការស៊ើបអង្កេតការចោទប្រកាន់និងវិធានការសុវត្ថិភាពសម្រាប់ជនរងគ្រោះ។
- យល់ថា ច្បាប់ទាំងឡាយជាវិធានដែលអាចត្រូវបានបង្កើតចេញពីទំនៀមទម្លាប់សង្គមអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ឬជាវិធានដែលកំណត់ដោយច្បាប់ និងទទួលយកជាកាតព្វកិច្ច។

### តួនាទីនៃច្បាប់

ច្បាប់ក្នុងសង្គមនីមួយៗរួមបញ្ចូលបទដ្ឋានដែលគ្របដណ្ដប់លើតួនាទីរបស់នគរបាល ដែលទទួលខុសត្រូវលើសេវានគរបាលអនុលោមតាមច្បាប់នោះ។សហគមន៍អាចមានទំនៀមទម្លាប់សង្គមដែលកំណត់ឥរិយាបថ ដែលក្នុងករណីខ្លះ អាចបញ្ច្រាស់គ្នានឹងវិធានកំណត់ដោយច្បាប់។ថ្នាក់ដឹកនាំនគរបាលគួររំលឹកបុគ្គលិករបស់ខ្លួនថាវាជាច្បាប់ដែលកំណត់ការអនុវត្តរបស់នគរបាល។

**ប្រអប់ ២**

"ច្បាប់ព្រហ្មទណ្ឌក្នុងប្រទេសជាច្រើនឆ្លុះបញ្ចាំងពីគំរូមានស្រាប់ និងទំនៀមទម្លាប់សង្គមនៃវិសមភាពរវាងបុរស និងស្ត្រី។ ឧ. ច្បាប់មួយចំនួនផ្ដល់តម្លៃ ឬភាពអាចជឿទុកចិត្តបានកម្រិតទាបលើសក្ខីកម្មដែលផ្ដល់ដោយជនរងគ្រោះឬសាក្សីជាស្ត្រីជាងសក្ខីកម្មដែលផ្ដល់ដោយបុរស។ឧទាហរណ៍មួយទៀតគឺច្បាប់ដែលអនុញ្ញាតឱ្យជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រីគេចវេសពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមរយៈការសំអាងលើ"កិត្តិយស"

533. Ibid.s
534. ម៉ូឌុលទី ៦ ៖ ការណែនាំអំពីការអនុវត្ត ៖ កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា។កម្មវិធីសកលរួមរបស់អង្គការសហប្រជាជាតិស្ដីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥។

"ការបង្កហេតុ" ប្រការដែលលើកលែងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ឬតាមរយៈការរៀបការជាមួយជនរងគ្រោះ"។ ច្បាប់ទាំងនេះ នៅតែមានក្នុងតំបន់ជាច្រើនជុំវិញពិភពលោករួមទាំងអឺរ៉ុប និងអាមេរិកខាងជើង។

ប្រទេសផ្សេងទៀត ដូចជា អាមេនី បានចាត់វិធានការជំហានៗក្នុងការធ្វើវិសោធនកម្មក្រម ព្រហ្មទណ្ឌរបស់ខ្លួនដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដោយបានផ្តល់សារច្បាស់លាស់ដល់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងភាពមិនអាចទទួលយកបាននៃអំពើហិង្សាក្នុងគ្រួសារនៅអាមេនី[535]។

**ប្រអប់ ៣**

អាមេនីជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនដែលទើបតែបានធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរបស់ខ្លួនឱ្យរួមបញ្ចូលនូវបញ្ហាអំពើហិង្សាលើស្ត្រី (២០១៧)[536]។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារនិងការស្តារសន្តិភាពក្នុងគ្រួសារ មានគោលបំណងបង្កើតយន្តការច្បាប់សម្រាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ធានាសុវត្ថិភាព និងការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងធានាសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគេ។ សំខាន់ជាងនេះ ច្បាប់នេះកំណត់ថា អំពើហិង្សាក្នុងគ្រួសារជាការប្រព្រឹត្តអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ផ្នែកសេដ្ឋកិច្ច និងការមិនអើពើ។ ច្បាប់នេះកំណត់ពីវិធានការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ រួមទាំងការព្រមានជនបង្ក និងការសម្រេចលើអន្តរាគមន៍សង្គ្រោះបន្ទាន់។

## ភាពមិនច្បាស់លាស់នៃច្បាប់ដែលពាក់ព័ន្ធនឹងបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី

អាចមានបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលចោទជាបញ្ហាក្នុងពេលស៊ើបអង្កេតជាពិសេសក្នុងករណីដែលច្បាប់នោះចែងមិនច្បាស់លាស់។ ចំណុចនេះរាំងស្ទះដល់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនិងទប់ស្កាត់ការផ្តន្ទាទោសជនបង្កដែលរងការចោទប្រកាន់។ ថ្នាក់ដឹកនាំនគរបាលគួរដឹងថា នេះជាបញ្ហាប្រឈមសម្រាប់បុគ្គលិករបស់ខ្លួននិងអាចរារាំងមិនឱ្យសេវានគរបាលការពារជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ជាច្រើនដែលរងគ្រោះដោយអំពើហិង្សាផ្លូវភេទ មិនសូវរាយការណ៍បទល្មើសទៅនគរបាលឡើយ។**

ថ្នាក់ដឹកនាំនគរបាលគួរកសាងការយល់ដឹងអំពីក្របខណ្ឌច្បាប់សម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលដំណើរការក្នុងយុត្តាធិការរបស់ខ្លួន និងដឹងពីចំណុចដែលច្បាប់ចែងមិនច្បាស់លាស់។ករណីនេះនឹងអាចឱ្យថ្នាក់ដឹកនាំនគរបាលផ្តល់យោបល់ត្រឡប់ដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ ឬអ្នកគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួនស្តីពីបញ្ហាដែលជះឥទ្ធិពលលើការកែប្រែច្បាប់នាពេលអនាគត។
អំពើរំលោភសេពសន្ថវៈគឺជាបទល្មើសមួយ។

**ប្រអប់ ៤**

**អំពើរំលោភសេពសន្ថវៈ ៖ ឧទាហរណ៍**

អំពើរំលោភសេពសន្ថវៈជាសកម្មភាពផ្លូវភេទខុសច្បាប់ដែលជាទូទៅពាក់ព័ន្ធនឹងការរួមសង្វាស ឬទម្រង់ផ្សេងទៀតនៃសកម្មភាពឈ្លានពានដែលប្រឆាំងនឹងឆន្ទៈរបស់នរណាម្នាក់។ អំពើរំលោភសេពសន្ថវៈជាបញ្ហាទូទាំងពិភពលោក។

ខណៈដែលប្រទេសជាច្រើនមានច្បាប់ប្រឆាំងនឹងការប្រទូស្តកេរ្តិ៍ខ្មាស និងអំពើហិង្សាផ្លូវភេទ ច្បាប់ជាច្រើនក្នុងចំណោមនោះមានភាពខ្វះចន្លោះ មិនស៊ីសង្វាក់គ្នា និងមិនត្រូវបានអនុវត្តជាប្រព័ន្ធ។ ស្ត្រីចំនួន ៣៥% នៅទូទាំងពិភពលោករងគ្រោះដោយអំពើហិង្សាផ្លូវកាយ និង/ឬអំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទបង្កឡើងដោយអ្នកមិនមែនជាដៃគូ (មិនរួមបញ្ចូលការបៀតបៀនផ្លូវភេទ) នៅដំណាក់កាលមួយចំនួនក្នុងជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណា ការសិក្សាថ្នាក់ជាតិមួយចំនួនបង្ហាញថា ស្ត្រីរហូតដល់ ៧០% រងគ្រោះដោយអំពើហិង្សាផ្លូវកាយ និង/ឬអំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាលម្នាក់ក្នុងជីវិតរបស់ពួកគេ[537]។

535. ប្រទេសអាមេនី ក្រមព្រហ្មទណ្ឌ ជំពូក ២០, មាត្រា ១៦៥- ១៧៤។
536. Ibid

ភស្តុតាងបង្ហាញថា ស្ត្រីដែលរងគ្រោះដោយអំពើហិង្សាផ្លូវកាយ ឬអំពើហិង្សាផ្លូវភេទលើដៃគូស្និទ្ធស្នាល លើកឡើងពីអត្រាខ្ពស់នៃការធ្លាក់ទឹកចិត្ត ការរំលូតកូន និងការឆ្លងមេរោគអេដស៍ ជាងស្ត្រីដែលមិនរងគ្រោះដោយអំពើហិង្សាទាំងនេះ[538]។

ស្ត្រីដែលមានអាយុ១៦-១៩ឆ្នាំងាយក្លាយជាជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈឬការប្រទូស្តកេរខ្មាសរហូតដល់ ៤ ដងលើសស្ត្រីធម្មតា ហើយនិស្សិតស្រីដែលមានអាយុ ១៨-២៤ ឆ្នាំ ងាយរងគ្រោះដោយការប្រទូស្តកេរខ្មាស រហូតដល់ ៣ ដងលើសស្ត្រីធម្មតា។ អ្នកប្តូរយេនឌ័រនិងអ្នកមានពិការភាពងាយក្លាយជាជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសឬអំពើរំលោភសេពសន្ថវៈរហូតដល់ ២ដងលើសមនុស្សធម្មតា។ នៅសហរដ្ឋអាមេរិក អំពើរំលោភសេពសន្ថវៈចំនួន ៧០% ប្រព្រឹត្តឡើងដោយនរណាម្នាក់ដែលជនរងគ្រោះ ស្គាល់[539]។

### បញ្ហាប្រឈមក្នុងការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈ

ថ្នាក់ដឹកនាំគរបាលគួរជានាថាបុគ្គលិករបស់ខ្លួនអនុវត្តអភិក្រមដែលគិតគូរពីយេនឌ័រក្នុងការស្វែងយល់ពីក្របខណ្ឌច្បាប់ស្តីពីការរំលោភសេពសន្ថវៈនិងការស៊ើបអង្កេតបទល្មើសនេះ ទាំងក្នុងស្ថានភាពមានសន្តិភាព និងក្នុងស្ថានភាពមានជម្លោះ។ អំពើរំលោភសេពសន្ថវៈគឺទម្រង់មួយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលត្រូវបានលើកមកពិភាក្សាតាំងពីជំបូងក្នុងសៀវភៅណែនាំនេះ។ អំពើនេះជាការរំលោភសិទ្ធិមនុស្សនិងជាទម្រង់នៃទារុណកម្មដូចការរៀបរាប់លម្អិតក្នុងលិខិតុបករណ៍អន្តរជាតិ។ **សូមមើល ជំពូកទី ៥ (ការស៊ើបអង្កេត)។**

## ប្រអប់ ៥

នៅខែ វិច្ឆិកា ឆ្នាំ ២០១៩ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UN OHCHR) បានប្រកាសថា ទាំងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋក៏ដូចជាអង្គការអន្តរជាតិនិងយន្តការពិនិត្យតាមដានឯករាជ្យ អង្គការសង្គមស៊ីវិល និងចលនាសិទ្ធិស្ត្រី ត្រូវចាត់វិធានការបន្ទាន់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទដេញដោលផ្ចត់គំនិតយេនឌ័រនិងឥរិយាបថនិងអាកប្បកិរិយាអវិជ្ជមានដែលជាមូលដ្ឋាន និងជំរុញឱ្យមានអំពើហិង្សា និងគាំទ្រ និងផ្តល់ដំណោះស្រាយដល់ស្ត្រីដែលហ៊ាននិយាយ។

វេទិកាយន្តការទាំង ៧ នៃអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ និងអ្នកជំនាញថ្នាក់តំបន់ស្តីពីអំពើហិង្សាលើស្ត្រី និងសិទ្ធិស្ត្រី បានអំពាវនាវរួមគ្នាឱ្យរដ្ឋទាំងអស់ និងអ្នកពាក់ព័ន្ធនៅទូទាំងពិភពលោកចាត់វិធានការលើអំពើរំលោភសេពសន្ថវៈក្នុងទម្រង់ជាអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងការរំលោភសិទ្ធិមនុស្សនិងធានថាការកំណត់និយមន័យនៃអំពើរំលោភសេពសន្ថវៈផ្អែកលើការគ្មានការយល់ព្រម និងស៊ីសង្វាក់គ្នានឹងស្តង់ដារអន្តរជាតិ។ ត្រូវមានការប្រឹងប្រែងកាន់តែច្រើនដើម្បីធានាការផ្តន្ទាទោសករណីរំលោភសេពសន្ថវៈទាំងក្នុងស្ថានភាពមានសន្តិភាព និងក្នុងស្ថានភាពមានជម្លោះ[540]។

បុគ្គលិករបស់អ្នកត្រូវដឹងថា ការកើតមានឡើងយ៉ាងទូលំទូលាយនិងជាប្រព័ន្ធនៃអំពើរំលោភសេពសន្ថវៈនិងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទលើស្ត្រី និងក្មេងស្រីសូម្បីតែក្នុងប្រទេសដែលបានប្រកាសថាមិនអត់អោនចំពោះអំពើហិង្សាលើស្ត្រីនិងក្មេងស្រីបង្ហាញថាអំពើហិង្សាផ្លូវភេទបានចាក់ឫសយ៉ាងជ្រៅក្នុងសង្គមបិតាធិបតេយ្យលើសលប់របស់យើង។

បុគ្គលិករបស់អ្នកគួរយល់ថា ៖

- អំណាច និងការត្រួតត្រានៅតែបង្កើតជាបរិយាកាសសង្គមដែលអត់ឱនអំពើហិង្សានេះ ហើយផ្ចត់គំនិតផ្អែកលើយេនឌ័រស្តីពីតួនាទីរបស់ស្ត្រីក្នុងសង្គមបានរាំងស្ទះ និងបន្ទាបបន្ថោកតម្លៃស្ត្រី។
- កត្តាទាំងនេះ រួមចំណែកដល់ការអត់ឱនចំពោះអំពើរំលោភសេពសន្ថវៈដែលមិនអាចទទួលយកបាន រួមទាំងក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលជាញឹកញាប់នាំទៅរកនិទណ្ឌភាពសម្រាប់ជនបង្កដែលរងការចោទប្រកាន់។

537. អង្គការសុខភាពពិភពលោក នាយកដ្ឋានស្រាវជ្រាវ និងសុខភាពបន្តពូជ សាលាអនាម័យ និងវេជ្ជសាស្ត្រត្រូពិចទីក្រុងឡុងដ៍ ក្រុមប្រឹក្សាស្រាវជ្រាវវេជ្ជសាស្ត្រអាហ្វ្រិកខាងត្បូង (២០១៣) ៖ ការប៉ាន់ស្មានជាសកល និងថ្នាក់តំបន់ស្តីពីអំពើហិង្សាលើស្ត្រី ៖ ប្រេវ៉ាឡង់ និងផលប៉ះពាល់ផ្នែកសុខភាពនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលនិងអំពើហិង្សាផ្លូវភេទមិនបង្កឡើងដោយដៃគូ។
538. Ibid
539. ស្ថិតិករណីរំលោភសេពសន្ថវៈបែងចែកតាមប្រទេស ឆ្នាំ ២០២០ ។ ការពិនិត្យឡើងវិញលើប្រជាជនទូទាំងសកលោក https://worldpopulationreview.com/country-rankings/rape-statistics-by-country
540. ទិវាអន្តរជាតិលុបបំបាត់អំពើហិង្សាលើស្ត្រី ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ៖ ការគ្មានការយល់ព្រមត្រូវតែក្លាយជាស្តង់ដារជាសកលសម្រាប់ការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ (២០១៩) OHCHR https://www.achpr.org/public/Document/file/English/International%20Day%20on%20the%20Elimination%20of%20Violence%20against%20Women_ENG.pdf

**ស្វែងយល់ពីនិយមន័យនៃអំពើរំលោភសេពសន្ថវៈក្នុងប្រទេសរបស់អ្នក និងភស្តុតាងដែលអ្នកត្រូវប្រមូលដើម្បីបញ្ជាក់បទល្មើសនោះសំដៅពង្រឹងការស៊ើបអង្កេតលើករណីរំលោភសេពសន្ថវៈ។**

ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងប្រទេសរបស់អ្នក អាចកំណត់និយមន័យនៃអំពើរំលោភសេពសន្ថវៈដោយផ្អែកលើការប្រើកម្លាំង ដែលអាចទាមទារភស្តុតាងបញ្ជាក់ថាជនបង្កដែលរងការចោទប្រកាន់បានប្រើប្រាស់ការបង្ខិតបង្ខំហើយជនរងគ្រោះមិនបានប្រយុទ្ធតបត។ដូច្នេះនេះជាបន្ទុករបស់ស្ត្រីក្នុងការបញ្ជាក់ថានាងបានប្រឆាំងតបត។ ប្រសិនបើមិនអាចបញ្ជាក់បានទេជនបង្កដែលរងការចោទប្រកាន់នឹងគ្មានទោស ចំណែកជនរងគ្រោះនឹងទទួលរងការមាក់ងាយ។ សូមមើលជំពូកទី ៩ (ទំនាក់ទំនង)។

ក្នុងប្រទេសរបស់អ្នក យុទ្ធនាការ ដូចជា #MeToo, #TimesUp, #Niunamenos, #NotOneMore និងយុទ្ធនាការផ្សេងទៀត សំឡេងរបស់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈទាំងក្នុងស្ថានភាពមានសង្គ្រាម និងក្នុងស្ថានភាពមានសន្តិភាព អាចគូសបញ្ជាក់ពីអំពើរំលោភសេពសន្ថវៈ និងបទល្មើសផ្សេងទៀត។ ថ្នាក់ដឹកនាំនគរបាលគួរចាត់វិធានការជាជំហានៗក្នុងការស្វែងយល់ថាតើយុទ្ធនាការនេះមានភាពសកម្មក្នុងប្រទេសឬទេ ហើយប្រសិនបើមានភាពសកម្ម តើវាផ្តោតសំខាន់លើបទល្មើសណាខ្លះ។ចំណុចនេះនឹងអាចឱ្យអ្នកកំណត់បទល្មើសដែលនឹងក្លាយជាប្រធានបទចំណាប់អារម្មណ៍នៅថ្នាក់ជាតិ។

## តើស្ថាប័នក្នុងវិស័យយុត្តិធម៌និងវិស័យសន្តិសុខសហការគ្នាដោយរបៀបណាដើម្បីធ្វើឱ្យមានភាពខុសប្លែក?

ថ្នាក់ដឹកនាំនគរបាលគួរដឹងថាក្រោមការគាំទ្រដោយច្បាប់ និងសេវាគាំទ្រផ្សេងទៀតសម្រាប់ស្ត្រី និងក្មេងស្រី ស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ អាចសហការគ្នាលុបបំបាត់គម្លាតរវាងបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិស្តីពីអំពើរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទ។

ក្នុងនាមជាថ្នាក់ដឹកនាំនគរបាលអ្នកប្រហែលជាមិនអាចជះឥទ្ធិពលលើអភិក្រមថ្នាក់ជាតិក្នុងប្រទេសរបស់អ្នកបានឡើយ ប៉ុន្តែអ្នកអាចចាត់វិធានការជាជំហានៗនៅកម្រិតមូលដ្ឋានដើម្បីធ្វើឱ្យមានភាពខុសគ្នាយ៉ាងពិតប្រាកដសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ថ្នាក់ដឹកនាំនគរបាលគួរ ៖

- កសាងការយល់ដឹងពីព្រំដែនកំណត់ ដូចជា ការគ្មានបទបញ្ញត្តិគ្រប់ជ្រុងជ្រោយស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងបទបញ្ញត្តិស្តីពីអំពើរំលោភសេពសន្ថវៈឬក្រមព្រហ្មទណ្ឌដែលមិនរួមបញ្ចូលអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ក្នុងប្រទេសរបស់អ្នក។ ចំណុចនេះអាចបង្កបញ្ហាប្រឈមដល់បុគ្គលិករបស់អ្នក នៅពេលពួកគេពាក់ព័ន្ធនឹងជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។
- អាចផ្តល់ការណែនាំដល់បុគ្គលិកស្តីពីអ្វីដែលពួកគេត្រូវធ្វើនៅពេលប្រឈមមុខជាមួយស្ត្រីដែលត្រូវបានរំលោភសេពសន្ថវៈដោយប្តី/ដៃគូនៅពេលច្បាប់មិនការពារស្ត្រីក្នុងស្ថានភាពទាំងនេះ។
- ធានាថា បុគ្គលិករបស់អ្នកដឹងថាតើមានអង្គការគាំទ្រក្នុងមូលដ្ឋានសម្រាប់ស្ត្រីដែលផ្តល់ការគាំទ្រចាំបាច់បំផុតដល់ជនរងគ្រោះ។

UNHCHR លើកឡើងថា អភិក្រមមួយក្នុងករណីទាំងនេះនិងផ្នែកគន្លឹះសម្រាប់ថ្នាក់ដឹកនាំនគរបាលគឺគួរផ្តល់សេវាគាំទ្រឯកទេស (ប្រសិនបើមាន) រួមទាំងការគាំទ្រដល់ការប៉ះទង្គិចផ្លូវចិត្តនិងលទ្ធភាពទទួលបានសេវាសុខាភិបាល។ សេវាទាំងនេះអាចផ្តល់ភាពខុសប្លែកពិតប្រាកដដល់ជនរងគ្រោះ[541]។ថ្នាក់ដឹកនាំនគរបាលគួរកំណត់រកសេវាគាំទ្រការប៉ះទង្គិចផ្លូវចិត្តក្នុងតំបន់របស់ខ្លួននិងពិចារណាពីករណីដែលត្រូវបញ្ជូនទៅរកសេវាសុខាភិបាលឯកទេសដើម្បី ផ្តល់សុខុមាលភាពសំខាន់ៗ និងការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះ។

541. Ibid

## តួនាទីរបស់រដ្ឋាភិបាលក្នុងការកំណត់គោលនយោបាយ និងក្របខណ្ឌច្បាប់

ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនិងការផ្តន្ទាទោសករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទាមទារការគាំទ្ររបស់ Atate។ ទោះជាយ៉ាងណា ថ្នាក់ដឹកនាំនគរបាលអាចចាត់វិធានការនៅថ្នាក់មូលដ្ឋានដើម្បីធ្វើឱ្យមានភាពខុសប្លែកពិតប្រាកដ។

ថ្នាក់ដឹកនាំនគរបាលគួរកំណត់រករបៀប និងផ្នែកដែលពួកគេអាចរួមចំណែកដល់ការតាក់តែងគោលនយោបាយ និងក្របខណ្ឌច្បាប់របស់រដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការកំណត់រកបញ្ហាដែលលេចឡើង និងការចែករំលែកការអនុវត្តល្អបំផុតជាមួយប្រធានក្រុម/អង្គភាពរបស់ពួកគេ។

**អភិក្រមដែលគិតគូរពីយេនឌ័រ សម្រាប់ជនរងគ្រោះជាជំហានដ៏សំខាន់ក្នុងការកសាងទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ នៅពេលដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។**

### ថ្នាក់ដឹកនាំនគរបាលគួរ ៖

- អនុវត្តអភិក្រមដែលគិតគូរពីយេនឌ័រនៅពេលធ្វើទំនាក់ទំនងជាមួយជនរងគ្រោះដើម្បីធានាថាទំនាក់ទំនងដំបូងរបស់ពួកគេជាមួយសេវានគរបាល កសាងទំនុកចិត្ត និងលើកទឹកចិត្តឱ្យជនរងគ្រោះហ៊ានរាយការណ៍ពីបទល្មើស។
- ទាញចំណាប់អារម្មណ៍របស់នគរបាលឱ្យផ្តោតលើបទល្មើសដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ថាការមិនចាត់វិធានការលើរបាយការណ៍ដំបូងនៃអំពើហិង្សាក្នុងគ្រួសារអាចបណ្តាលឱ្យស្ត្រីដែលពាក់ព័ន្ធ ស្លាប់បាត់បង់ជីវិត។ ការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ (ឬ "ការសម្លាប់ទារិកា")ជាទម្រង់មួយនៃបទល្មើសនេះដែលអាចកើតឡើង។

### ការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ពីប្រេវ៉ាឡង់ខ្ពស់នៃការសម្លាប់ស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រនៅទូទាំងសកលលោកនិងគួរកំណត់ថាតើមានការប្រមូលទិន្នន័យតាមមូលដ្ឋានក្នុងប្រទេស/តំបន់របស់ពួកគេ ឬទេ។

ក្នុងចំណោមស្ត្រី ៨៧.០០០ នាក់ដែលត្រូវបានសម្លាប់តាមបណ្តាប្រទេសនានានៅឆ្នាំ ២០១៧ ស្ត្រីជាងពាក់កណ្តាល (៥០.០០០ នាក់ ឬ ៥៨%) ត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល ឬសមាជិកគ្រួសារ។ មានន័យថាក្នុងមួយថ្ងៃៗ ស្ត្រីចំនួន ១៣៧ នាក់នៅជុំវិញពិភពលោកត្រូវបានសម្លាប់ដោយសមាជិកម្នាក់ក្នុងគ្រួសារ។ នៅឆ្នាំ ២០១៧ មានស្ត្រីជាង ១/៣ (៣០.០០០ នាក់) ត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬពីអតីត [542]។

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ថា ច្បាប់ត្រូវបានដាក់ចេញក្នុងប្រទេសមួយចំនួនដើម្បីគាំទ្រដល់ការងាររបស់នគរបាលក្នុងការដោះស្រាយ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ៦**

ប្រទេសមួយចំនួនបានដាក់ចេញបទបញ្ញត្តិជាក់លាក់ដែលដាក់ទោសព្រហ្មទណ្ឌលើការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រក្រោមស្លាក"ការសម្លាប់ទារិកា" (ប្រទេសភាគច្រើននៅអាមេរិកឡាទីន)។ ប្រទេសផ្សេងទៀតបានកំណត់ស្ថានទម្ងន់ទោសដែលពាក់ព័ន្ធនឹងយេនឌ័រសម្រាប់អំពើមនុស្សឃាត និងបទល្មើសផ្សេងទៀត។ ស្ថានទម្ងន់ទោសអាចរួមបញ្ចូលមូលហេតុជាក់លាក់ (ដូចជាភាពលម្អៀង ការស្អប់ខ្ពើម និងការរើសអើងពាក់ព័ន្ធនឹងភេទរបស់មនុស្សម្នាក់ ដូចជានៅប្រទេសប៊ែលហ្សិកកាណាដា និងអេស្ប៉ាញ ឬមូលហេតុកិត្តិយស និងទំនៀមទម្លាប់ដូចជានៅប្រទេសទួរគី) និងកាលៈទេសៈនៃអង្គហេតុ (ដូចជាការមានផ្ទៃពោះដូចជានៅសហព័ន្ធរុស្ស៊ី និងប្រទេសទួរគី ឬនាមជាប្តី/ប្រពន្ធរបស់ជនរងគ្រោះដូចជានៅប្រទេសប៊ែលហ្សិក អេស្ប៉ាញ និងទួរគី)[543]។

542. ការសិក្សាជាសកលស្តីពីអំពើមនុស្សឃាត (UNODC, 2019),p.10.
543. UNODC/CCPCJ/EG.8/2014/CRP.1, "វិធានការថ្នាក់ជាតិដើម្បីទប់ស្កាត់ ស៊ើបអង្កេត ផ្តន្ទាទោស និងដាក់ទោសការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ" កថាខណ្ឌ ១២។

ថ្នាក់ដឹកនាំនគរបាលត្រូវណែនាំដល់បុគ្គលិករបស់ខ្លួន ដើម្បីធានាថា ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖

- គួរអនុវត្តដីកាហាមឃាត់បណ្តោះអាសន្ននិងគួរទទួលបានដីកាពីតុលាការនៅពេលមានការរាយការណ៍ពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលដើម្បីកុំឱ្យមានការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ។
- ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់ដីកាហាមឃាត់បណ្តោះអាសន្នត្រូវបានចែករំលែកជាមួយមន្ត្រីនគរបាលនៅទូទាំងតំបន់សមត្ថកិច្ចរបស់ពួកគេដើម្បីការពារជនរងគ្រោះ និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសបន្ថែមទៀត។
- ដីកាហាមឃាត់បណ្តោះអាសន្នត្រូវបានផ្តល់ជូនព្រះរាជអាជ្ញា និងចៅក្រមដែលអាចនឹងដឹកនាំការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងជនបង្កដដែលសម្រាប់បទល្មើសអំពើហិង្សាលើដៃគូស្និទ្ធស្នាល។

ទាំងនេះជាវិធានការសំខាន់ៗដែលអាចជួយទប់ស្កាត់ការស្លាប់បាត់បង់ជីវិតក្រោយការរងគ្រោះដោយអំពើហិង្សាលើដៃគូស្និទ្ធស្នាលជាបន្តបន្ទាប់[544]។

ថ្នាក់ដឹកនាំនគរបាលអាចពិនិត្យ ថាតើអាចប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកសម្រាប់ពិនិត្យតាមដានជនល្មើសឬទម្រង់ផ្សេងទៀតនៃការពិនិត្យតាមដាន ដូចជា ការរាយការណ៍ទៅនគរបាល បានដែរ ឬទេ។ ឧ. ការប្រមូលទិន្នន័យអាចត្រូវបានប្រើប្រាស់ជាឧបករណ៍នៃការបង្កើនការអនុវត្តការងាររបស់បុគ្គលិក និងជាវិធីផ្លាស់ប្តូរឥរិយាបថរបស់ពួកគេក្នុងការដោះស្រាយបទល្មើសទាំងនេះ។ អភិក្រមណាក៏ដោយត្រូវតែគិតគូរពីយេនឌ័រ។

ក្នុងឆាកអន្តរជាតិ Atates ចាប់ផ្តើមដាក់ចេញនូវច្បាប់ជាក់លាក់ដើម្បីដោះស្រាយការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ។ ឧ. ប្រទេសបារាំងទើបតែបានដាក់ចេញវិធានការដោះស្រាយបទល្មើសប្រភេទនេះ។

**ប្រអប់ ៧**

រដ្ឋាភិបាលបារាំងបានណែនាំឱ្យនគរបាលចាត់វិធានការជាក់លាក់នៅពេលស៊ើបអង្កេត និងដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ វិធានការបន្ទាន់ដែលបានប្រកាសនៅខែ កញ្ញា ឆ្នាំ ២០១៩ រួមមាន ៖

- ការដកហូតកាំភ្លើងពីជនសង្ស័យដែលបានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ និងការផ្តោតអាទិភាពលើការបណ្តុះបណ្តាលនគរបាល ដើម្បីកុំឱ្យពួកគេច្រានចោលបណ្តឹងរបស់ស្ត្រីដោយចាត់ទុកថាវាជារឿងឯកជន។
- ការបង្កើនកិច្ចខិតខំប្រឹងប្រែងនៅតាមសាលារៀន ដើម្បីកសាងការយល់ដឹងស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ។
- ការបើកខ្សែទូរស័ព្ទបន្ទាន់ ២៤ ម៉ោងសម្រាប់ការរាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារ។
- ការជួលបុគ្គលិកសង្គមកិច្ចឯកទេសកាន់តែច្រើនឱ្យធ្វើការនៅប៉ុស្តិ៍នគរបាល។
- ការបង្កើនការព្យាបាលដៃគូដែលប្រព្រឹត្តអំពើហិង្សាដើម្បីបញ្ចៀសការប្រព្រឹត្តបទល្មើសដដែលៗ។
- ការកែប្រែច្បាប់ដើម្បីឱ្យទទួលស្គាល់ថាជនរងគ្រោះដោយសារការរំលោភបំពានអាចស្ថិតនៅក្រោមការគ្រប់គ្រងផ្លូវចិត្តដោយជនបំពាន និងមិនអាចធ្វើសកម្មភាពដោយឯករាជ្យបាន។
- ការសហការជាមួយវេជ្ជបណ្ឌិតដើម្បីសម្រួលដល់ការរឹតត្បិតព័ត៌មាន ក្នុងករណីមាន "គ្រោះថ្នាក់ភ្លាមៗ" ដោយសារការប្រព្រឹត្តអំពើហិង្សាជាថ្មីលើជនរងគ្រោះ ដែលអាចឱ្យអ្នកអនុវត្តន៍បង្ហាញករណីទៅកាន់អាជ្ញាធរច្បាប់ ដោយគ្មានការយល់ព្រមពីអ្នកជំងឺ។បច្ចុប្បន្នវេជ្ជបណ្ឌិតអាចធ្វើបានតែប៉ុណ្ណឹងនៅពេលអ្នកជំងឺជាអនីតិជនឬ"ងាយរងគ្រោះ" ជាពាក្យទូទៅដែលអាចសំដៅលើជនមានពិការភាពឬនៅពេលជីវិតរបស់នរណាម្នាក់ជិតប្រឈមនឹងហានិភ័យ។

នៅអឺរ៉ុប ប្រទេសបារាំងមានអត្រាអំពើហិង្សាក្នុងគ្រួសារខ្ពស់ជាងគេ មួយផ្នែកដោយសារតែកង្វះការឆ្លើយតបរបស់នគរបាលទៅនឹងរបាយការណ៍នៃការរំលោភបំពាន។ ស្ត្រីជាច្រើនដែលត្រូវបានសម្លាប់នៅឆ្នាំ ២០១៩ ធ្លាប់ស្វែងរកជំនួយពីនគរបាល ហើយនៅឆ្នាំ ២០១៨ ស្ត្រីចំនួន ១២១ នាក់ ត្រូវបានសម្លាប់ដោយដៃគូបច្ចុប្បន្ន ឬពីអតីត។ គេប៉ាន់ស្មានថា ក្នុងមួយឆ្នាំៗ ស្ត្រីនៅប្រទេសបារាំងចំនួន ២១៩.០០០ នាក់ដែលមានអាយុ ១៨-៧៥ ឆ្នាំ បានក្លាយជាគោលដៅនៃអំពើហិង្សាផ្លូវកាយឬអំពើហិង្សាផ្លូវភេទពីសំណាក់ដៃគូបច្ចុប្បន្នឬពីអតីតប៉ុន្តែស្ថិតិរបស់រដ្ឋាភិបាលបង្ហាញថាមានស្ត្រីតែ ២០% ប៉ុណ្ណោះដែលបានដាក់បណ្តឹងជាផ្លូវការ[545]។

ថ្នាក់ដឹកនាំនគរបាលនឹងទទួលបានគំនិតល្អៗពីករណីស្លាប់របស់ Julie Douib នៅប្រទេសបារាំង។ ករណីនេះគូសបញ្ជាក់ពីសារៈសំខាន់នៃការដែលនគរបាលពិចារណាជិតដល់លើការរាយការណ៍ពីអំពើហិង្សា និងកាន់កាប់កាំភ្លើង។ បន្ទាប់ពី Julie Douib ត្រូវបានដៃគូបង្ខំឱ្យបោះបង់ការគ្រប់គ្រងកូនទាំង ២ សម្រាប់ថ្ងៃចុងសប្តាហ៍ នាងបានប្រាប់នគរបាលថា គាត់មានលិខិតអនុញ្ញាតឱ្យកាន់កាំភ្លើង និងថា នាងខ្លាចថា គាត់នឹងបាញ់នាង។ យោងតាមឪពុករបស់ Douib មន្ត្រីនគរបាលតបថា "លោកស្រីឱ្យខ្ញុំសូមទោសប៉ុន្តែយើងមិនអាចដកហូតលិខិតអនុញ្ញាតនោះបានទេ លុះត្រាតែគាត់ភ្ជង់លោកស្រី"។ រយៈពេល ៤៨ ម៉ោងក្រោយមក ដៃគូនោះបានភ្ជង់ និងបាញ់ ២ គ្រាប់ចំទ្រូង និងដៃរបស់ Douib ដែលមានអាយុ ៣៤ ឆ្នាំ។ MaryseSantiniអ្នកជិតខាងរស់នៅជាន់ក្រោមដែលបានឃើញលោកស្រី Douib បានឱ្យដឹងថា Douib បាននិយាយមុនពេលផុតដង្ហើមថា "គាត់បានសម្លាប់ខ្ញុំ"[546]។

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ថា អភិក្រមក្នុងប្រទេសបារាំងបង្ហាញថា គោលនយោបាយ រដ្ឋាភិបាលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី គួរត្រូវបានពង្រឹងតាមរយៈការបង្កើនការទប់ស្កាត់ និងការឆ្លើយតបក្នុងផែនការជាតិ។

ថ្នាក់ដឹកនាំនគរបាលគួរ ៖

- ស្រាវជ្រាវថាតើប្រទេសរបស់អ្នកមានផែនការជាតិពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ ដើម្បីស្វែងយល់ពីក្របខណ្ឌធំទូលាយដែលគ្របដណ្តប់លើការងារអ្នក។ ផែនការទាំងនោះអាចលម្អិតពីតួនាទីរបស់ស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ និងសង្គមស៊ីវិលដើម្បីឆ្លើយតប និងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងប្រទេស។
- នៅពេលមានការយល់ដឹងកាន់តែច្រើនអំពីផែនការជាតិ រួមទាំងតួនាទីរបស់ស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ និងអង្គការសង្គមស៊ីវិល ណែនាំមន្ត្រីជួរមុខរបស់អ្នកឱ្យធានាថាការវាយតម្លៃហានិភ័យរបស់អ្នកពិចារណាពីករណីរំលោភបំពានក្នុងគ្រួសារនាពេលកន្លងមក ដែលពាក់ព័ន្ធនឹងជនបង្កដដែល។
- រៀនសូត្រពីករណីកន្លងមកនៃការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ ដែលគ្មានការវាយតម្លៃហានិភ័យប្រកបដោយប្រសិទ្ធភាព។

## និយមន័យ និងក្របខណ្ឌ

ម៉ូឌុលទី ៥ នៃកញ្ចប់សេវាសំខាន់ៗស្តីពីការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួលរៀបរាប់ពីសារៈសំខាន់នៃការឆ្លើយតបដោយមានការសម្របសម្រួលសម្រាប់ជនរងគ្រោះ ដែលបង្កើនសុវត្ថិភាព តាមរយៈការដាក់ជនរងគ្រោះជាចំណុចស្នូលនៃអន្តរាគមន៍ ឬការឆ្លើយតបរបស់ស្ថាប័ន[547]។

ថ្នាក់ដឹកនាំនគរបាលគួរដឹងថា ការឆ្លើយតបដោយមានការសម្របសម្រួលផ្តល់លទ្ធភាពឱ្យជនរងគ្រោះចូលដល់អ្នកអនុវត្តន៍ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ និងមានជំនាញដែលចែករំលែកចំណេះដឹងតាមរបៀបដែលមានការលះបង់ និងផ្តល់ការគាំទ្រ។ ការឆ្លើយតបដោយមានការសម្របសម្រួលអាចកត់សម្គាល់និងបំពេញតម្រូវការចម្រុះរបស់ជនរងគ្រោះតាមរយៈការសហការគ្នាកំណត់រកសេវានិងបណ្តាញបញ្ជូន។ ឧ.ក្នុងកងកម្លាំងនគរបាលមួយចំនួន មានអង្គការស្ត្រី ផ្តល់ការគាំទ្រដល់ស្ត្រីទៅតាមតម្រូវការ ដូចជា ការស្តារនីតិសម្បទាគ្រឿងញៀន លំនៅដ្ឋាន ឬការរំលោភបំពានក្នុងគ្រួសារ។

544. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះអ្នកនិពន្ធប្រើពាក្យ"អំពើហិង្សាលើដៃគូស្និទ្ធស្នាល" ជាជាង "អំពើហិង្សាក្នុងគ្រួសារ" និងផ្តោតអាទិភាពលើពាក្យ "អំពើហិង្សាលើដៃគូស្និទ្ធស្នាល" លុះត្រាតែពាក្យ "អំពើហិង្សាក្នុងគ្រួសារ" ត្រូវបានប្រើប្រាស់ក្នុងឯកសារដើម។ អំពើហិង្សាក្នុងគ្រួសារជាពាក្យទូទៅដែលពាក់ព័ន្ធនឹងឌីណាមិកសង្គម និងចិត្តសាស្ត្រ និងភាពខុសគ្នានៃអំណាច និងគ្របដណ្តប់លើទម្រង់ផ្សេងៗ ដូចជា ការរំលោភបំពានកុមារ ការរំលោភបំពានចាស់ជរា និងការរំលោភបំពានអន្តរបុគ្គល ឬការរំលោភបំពានដៃគូ។ ផ្ទុយទៅវិញ អំពើហិង្សាលើដៃគូស្និទ្ធស្នាលធ្វើឱ្យស្ត្រីរងគ្រោះខ្លាំងជាងបុរស ខណៈដែលជនបង្កយ៉ាងច្រើនលើសលប់គឺជាបុរស។ អំពើហិង្សាលើដៃគូស្និទ្ធស្នាលក៏ពាក់ព័ន្ធខ្លាំងនឹងភាពខុសគ្នានៃអំណាចដែលត្រូវបានកំណត់ក្នុងសង្គមរវាងបុរស និងស្ត្រីផងដែរ។ សូមមើល ក្រុមប្រឹក្សាអឺរ៉ុប គណៈរដ្ឋមន្ត្រី កិច្ចប្រជុំលេខ ១០៣៧ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ គណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកបញ្ហាបទល្មើស ការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់អនុសញ្ញាប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ។

545. Les Chiffres de Référence sur les Violences Faites aux Femmes (2019). Secrétariat d´Etat chargé de l´égalité entre les femmes et les hommes et de la lutte contre les discriminations, at : https://arretonslesviolences.gouv.fr/je-suis-professionnel/chiffres-de-reference-violences-faites-aux-femmes.

546. Fourquet, L. (2019), `As Deaths Mount, France Tries to Get Serious About Domestic Violence´ for the New York Times, at: https://www.nytimes.com/2019/09/03/world/europe/france-domestic-violence.html.

547. កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព (កម្មវិធីរួមជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ២០១៥) https://www.unwomen.org/en/digitallibrary/publications/2015/12/essential-services-package-for-women-and-girlssubject-to-violence

ថ្នាក់ដឹកនាំនគរបាលគួរធានាថា បុគ្គលិករបស់ខ្លួន ៖

- យល់ពីតួនាទីនិងការទទួលខុសត្រូវរបស់នគរបាលនៅពេលដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- យល់ថា ការអនុលោមតាមស្តង់ដារអប្បបរមា ដោយស្ថាប័នដៃគូក្នុងវិស័យយុត្តិធម៌ អាចផ្តល់ការឆ្លើយតបកាន់តែស៊ីសង្វាក់គ្នា។
- យល់ថា ភាពច្បាស់លាស់នៃតួនាទី និងការទទួលខុសត្រូវ មានន័យថា ស្ថាប័នយុត្តិធម៌នីមួយៗអាចមានភាពស្ទាត់ជំនាញលើផ្នែករបស់ខ្លួនហើយការងាររបស់អ្នកជំនាញម្នាក់ៗត្រូវបានបំពេញបន្ថែមដោយការងាររបស់ស្ថាប័ន និងអ្នកជំនាញផ្សេងទៀត។

**យោងតាម WHO ការវះកាត់ប្រដាប់បន្តពូជស្ត្រី រួមបញ្ចូលនីតិវិធីទាំងអស់ដែលពាក់ព័ន្ធនឹងការកាត់ចេញដោយផ្នែកឬទាំងស្រុងនូវប្រដាប់ភេទខាងក្រៅរបស់ស្ត្រីឬរបួសផ្សេងទៀតលើសរីរាង្គប្រដាប់ភេទរបស់ស្ត្រី ដោយសារមូលហេតុមិនមែនវេជ្ជសាស្ត្រ។**

ការសម្របសម្រួលជាមួយវិស័យផ្សេងទៀត នឹងបង្កើនសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការរក្សាការទទួលខុសត្រូវរបស់ជនបង្កលើគ្រប់ទម្រង់នៃអំពើហិង្សា រួមទាំងអំពើហិង្សាដែលជនបង្កអាចកំណត់ជា"ប្រពៃណី" ដូចជា ការវះកាត់ប្រដាប់បន្តពូជស្ត្រី ។

ជំហានដំបូងសម្រាប់ថ្នាក់ដឹកនាំនគរបាលគឺត្រូវធានាថា បុគ្គលិករបស់ខ្លួនយល់ច្បាស់ថាអ្វីជាការវះកាត់ប្រដាប់បន្តពូជស្ត្រី ផលប៉ះពាល់របស់វា និងប្រេវ៉ាឡង់ក្នុងសហគមន៍ដែលពួកគេធ្វើប្រតិបត្តិការ។ បន្ទាប់មក ទើបអាចព្រាងពិធីសាររួមដើម្បីធានាយន្តការផ្សព្វផ្សាយ និងគណនេយ្យភាពច្បាស់លាស់និងមានតម្លាភាពរវាងស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ ( សូមមើលជំពូកទី ៥ ៖ "ការស៊ើបអង្កេត" ដែលលើកឡើងពីការវះកាត់ប្រដាប់បន្តពូជស្ត្រី )។ នៅទូទាំងពិភពលោក មានការសិក្សាពីបរិបទនៃការអនុវត្តការវះកាត់ប្រដាប់បន្តពូជស្ត្រី។ នៅចក្រភពអង់គ្លេស ពិធីសារស្តីពីការដោះស្រាយបទល្មើសនៃការវះកាត់ប្រដាប់បន្តពូជស្ត្រីរវាងក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល និងសេវាអយ្យការ Crown ត្រូវបានបង្កើតឡើង ដើម្បីកែលម្អរបៀបធ្វើការរវាងនគរបាល និងអយ្យការ កែលម្អការស៊ើបអង្កេត និងបង្កើនការផ្តន្ទាទោសបទល្មើសទាំងនេះ[548]។




Campbell et al. បានផ្តល់ព័ត៌មានបន្ថែមស្តីពីការកំណត់អភិក្រមល្អបំផុតឆ្ពោះទៅរកការបញ្ឈប់ និងការផ្តន្ទាទោសការអនុវត្តដែលបង្កគ្រោះថ្នាក់រួមទាំងការវះកាត់ប្រដាប់បន្តពូជស្ត្រី អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ ការសម្លាប់ និងការរំលោភបំពាន "ដើម្បីរក្សាកិត្តិយស" ការអុចដើមទ្រូងអំពើអាបធ្មប់និងការរំលោភបំពានក្នុងជំនឿសាសនា មានបង្ហាញក្នុង ការអនុវត្តបែបប្រពៃណីដែលបង្កគ្រោះថ្នាក់ ៖ ការទប់ស្កាត់ ការការពារ និងសេវានគរបាល (២០២០)។ឯកសារនេះមានគោលបំណងបង្កើនការយល់ដឹងតាមរយៈការផ្តល់ចំណេះដឹងល្អៗអំពីទស្សនៈយល់ឃើញរបស់ជនរងគ្រោះ ដែលអាចពង្រឹងចំណេះដឹង និងទំនុកចិត្តរបស់មន្ត្រីនគរបាលក្នុងការ ដោះស្រាយបទល្មើសទាំងនេះ[549]។

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ថា និយមន័យអាចជាកម្មវត្ថុនៃការជជែកវែកញែក និងទស្សនៈផ្សេងៗ។ ឧ. ពាក្យអំពើហិង្សា "ដើម្បីរក្សាកិត្តិយស" នៅចក្រភពអង់គ្លេសត្រូវបានតវ៉ាដោយអ្នកអត្ថាធិប្បាយមួយចំនួន ព្រោះពាក្យនេះផ្តោតគោលដៅលើសហគមន៍មួយចំនួនដែលនាំទៅរកការឃ្លាំមើល និងសេវានគរបាលកាន់តែច្រើនក្នុងសហគមន៍ទាំងនោះ។ ចំណុចនេះ បានផ្សារភ្ជាប់សហគមន៍ទៅនឹងរបៀបវារៈដែលមិនទាក់ទិននឹងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ពោលគឺពួកគេផ្អែកលើការកំណត់ផ្នត់គំនិត និងការចាត់ប្រភេទបែបរើសអើងផ្សេងទៀតដែលកំណត់បុគ្គល និងសហគមន៍ជាគោលដៅ ហើយច្បាប់ដោយឡែកៗត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហា

ដោយមានវិធានការដាក់ទណ្ឌកម្មដែលត្រូវបានអនុវត្ត ដោយមិនសមមាត្រ និងមិនបន្សីគ្នានឹងច្បាប់ផ្សេងទៀត ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[550]។

ថ្នាក់ដឹកនាំនគរបាលនឹងអនុវត្តតាមម៉ូឌុលទី៥នៃកញ្ចប់សេវាសំខាន់ៗដែលលម្អិតពីសមាសធាតុទូទៅនៃការឆ្លើយតបដោយមានការសម្របសម្រួល។ អ្នកគ្រប់គ្រងផ្នែកប្រតិបត្តិការជាអ្នកទទួលខុសត្រូវលើការធ្វើការជាមួយថ្នាក់លើរបស់ខ្លួនដើម្បីបង្កើតការឆ្លើយតបទាំងនេះ[551]។ ខ្លឹមសារដកស្រង់មានបង្ហាញក្នុងដ្យាក្រាមខាងក្រោម ៖

**រូប ៣ ៖**

## សមាសភាគរួមនៃការឆ្លើយតបដែលមានការសម្របសម្រួលបានល្អ




| ជាធម្មតា ការឆ្លើយតបដែលមានការសម្របសម្រួលបានល្អ ត្រូវមានចំណុចខាងក្រោមបញ្ចូលគ្នា ៖ | ភាពជាដៃគូរវាងវិស័យ និងស្ថាប័ននានា ជារឿយៗត្រូវបានលើកកម្ពស់តាមរយៈមធ្យោបាយខាងក្រោម ៖ |
|---|---|
| • ក្របខណ្ឌសម្រាប់កិច្ចសហការពហុវិស័យរវាងស្ថាប័ននានា។<br>• គណៈកម្មាធិការឬស្ថាប័នសម្របសម្រួលមួយដែលមានតួនាទីពិនិត្យតាមដាន វឌ្ឍនភាព និងរៀបចំគោលនយោបាយ។<br>• យន្តការក្នុងការគ្រប់គ្រង ការធ្វើការងារជាមួយ និងដាក់ទោសជនល្មើស។<br>• សេវាសម្រាប់ជនរងគ្រោះ មានដូចជា សេវាសុខភាព ជម្រកសុវត្ថិភាពនិងការគាំទ្រលើសកម្មភាពទាក់ទាញការគាំទ្រមតិដោយមានបញ្ចូលការផ្តល់កិច្ចការពារទៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ | • កិច្ចប្រជុំផ្ទាល់ទល់មុខគ្នា។<br>• គោលនយោបាយ និងពិធីសាររួមគ្នា ត្រូវបានរៀបចំឡើងដោយស្ថាប័នសំខាន់ៗ។<br>• ការរៀបចំផែនការសកម្មភាព និងអន្តរាគមន៍នានាជាមួយគ្នា។<br>• ការបណ្តុះបណ្តាលរួមគ្នាដល់បុគ្គលិកក្នុងអង្គការវិស័យជាដៃគូ។<br>• ការចែករំលែកព័ត៌មានអំពីជនរងគ្រោះនិងជនបង្កហើយក្នុងពេលជាមួយគ្នាគោរពឯកជនភាព និងធានាសុវត្ថិភាពដល់ជនរងគ្រោះ។<br>• បន្តធ្វើការប្រមូលទិន្នន័យ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពរបស់ករណី និងលទ្ធផលរបស់ករណី ក៏ដូចជាកំណត់ពីការអនុវត្តល្អៗ និងការអនុវត្តមិនល្អ។ |
| **ការឆ្លើយតបពហុជំនាញដែលមានការសម្របសម្រួលបានល្អ ទាមទារឱ្យមាន ៖** | **ស្ថាប័នដែលទទួលខុសត្រូវលើការសម្របសម្រួលអាចជា ៖** |
| • ការចូលរួមឱ្យបានសកម្មពីអ្នកពាក់ព័ន្ធជាច្រើន។<br>• ការឯកភាពគ្នាពីវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការការឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រី។<br>• ការសហការ ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានរវាងស្ថាប័ននានា។ | • ស្ថាប័នឯករាជ្យ ឬស្ថាប័នឯកទេសដែលមានតួនាទីសម្របសម្រួលវិស័យសំខាន់ៗ។<br>• សម្ព័ន្ធភាពស្ថាប័នដែលជួបប្រជុំគ្នាទៀងទាត់ ដែលគេហៅម្យ៉ាងទៀតថាជាក្រុមប្រឹក្សាគណៈកម្មាធិការឬក្រុមការងារ។<br>• ស្ថាប័នកម្រិតខ្ពស់ ដូចជា រដ្ឋមន្ត្រី និង/ឬមន្ត្រីប្រតិបត្តិរបស់ស្ថាប័នសំខាន់ៗ |

548. ពិធីសារស្តីពីការដោះស្រាយបទល្មើសនៃការវះកាត់ប្រដាប់បន្តពូជស្ត្រី រវាងក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល និងសេវាអយ្យការ Crown (២០១៦)។ ក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល https://www.cps.gov.uk/sites/default/files/documents/publications/FGM-Protocol-june-2016.docx

549. ការអនុវត្តបែបប្រពៃណីដែលបង្កគ្រោះថ្នាក់ ៖ ការទប់ស្កាត់ ការការពា និងសេវានគរបាល (២០២០) Campbell, G., Roberts, K.A., Sarkaria, N. Palgrave Macmillan.

550. សូមមើល 'ពីចំណុចសើៗឆ្ពោះទៅរកចំណុចស្នូល ៖ ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជម្រើសផ្សេងទៀត' (Imkaan, October 2018) https://829ef90d-0745-49b2-b404-cbea85f15fda.filesusr.com/ugd/2f475d_91a5eb3394374f24892ca1e1ebfeea2e.pdf

551. ម៉ូឌុលទី ៥ ៖ ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល កញ្ចប់សេវាសំខាន់ៗ

## ស្ថាប័នក្នុងប្រព័ន្ធយុត្តិធម៌

បុគ្គលិករបស់អ្នកត្រូវយល់ថា ការស៊ើបអង្កេតតំណាងឱ្យចំណុចចាប់ផ្ដើមក្នុងប្រព័ន្ធ យុត្តិធម៌។ការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយ និងគិតគូរពីយេនឌ័រមានសារៈសំខាន់ណាស់ក្នុងការជានាការទទួលខុសត្រូវចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីលុបបំបាត់និទណ្ឌភាព និងផ្ដល់ការការពារដល់ជនរងគ្រោះ។

តាមពិត ការស៊ើបអង្កេតដែលគិតគូរពីយេនឌ័រគួរតែជាធាតុផ្សំដ៏សំខាន់មួយក្នុងការធ្វើសកម្មភាពដែលឆ្លើយតបនឹងយេនឌ័រដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ពោលគឺសំដៅលើការជានាថា ច្បាប់ ស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងលទ្ធផលនៃយុត្តិធម៌ព្រហ្មទណ្ឌ មិនរើសអើងនរណាម្នាក់ដោយសារយេនឌ័រ។ ចាំបាច់ត្រូវពិចារណាពីទស្សនៈយេនឌ័រក្នុងច្បាប់ព្រហ្មទណ្ឌ និងការវាយតម្លៃលទ្ធភាព និងឧបសគ្គរាំងការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ស្ត្រី និងបុរស និងការអនុវត្ត យុទ្ធសាស្ត្រដែលគិតគូរពីយេនឌ័រសម្រាប់ការពារជនរងគ្រោះ និងបង្កើនលទ្ធភាពទទួលបានយុត្តិធម៌ព្រហ្មទណ្ឌ[552]។

យុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រ មិនត្រឹមតែសំដៅលើការយល់ពីទំនាក់ទំនងរវាងយេនឌ័រ និងបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំដៅលើថាតើស្ត្រី និងបុរសទទួលរងផលប៉ះពាល់ខុសគ្នាដូចម្ដេចដោយបទល្មើស និងអំពើហិង្សាទៀតផង។ ចំណុចនេះ ក៏តម្រូវឱ្យមានវិធានការដាក់លាក់ដើម្បីបំពេញតម្រូវការរបស់ស្ត្រីឬបុរសក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដូចជាដោះស្រាយឫសគល់បង្កជាវិសមភាពយេនឌ័រដែលបង្កើតឡើង ឬជំរុញដោយប្រព័ន្ធនេះ[553]។ការសិក្សាជាសកលរកឃើញថាជាញឹកញាប់ បុរសគឺជាជនរងគ្រោះដោយសារអំពើមនុស្សឃាតនិងការប្រទូស្តរ៉ាយក្រៅពីការប្រទូស្តកេរខ្មាសដែលជាញឹកញាប់ ស្ត្រីគឺជាជនរងគ្រោះ[554]។

ទោះជាយ៉ាងណា ស្ត្រីច្រើនតែប្រឈមនឹងអំពើហិង្សា និងការរំលោភបំពានក្នុងជីវិតគ្រួសារឯកជន ដែលបង្កឡើងដោយនរណាម្នាក់ដែលពួកគេស្គាល់និងជាញឹកញាប់ដៃគូផ្ទាល់ខ្លួនរបស់ពួកគេ។ ជនបង្កអំពើហិង្សា មិនថាជាអំពើហិង្សាលើបុរស ឬលើស្ត្រីនោះទេ ច្រើនតែបង្កឡើងដោយបុរស។ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រជាប្រព័ន្ធដែលផ្ដល់ទំនុកចិត្តក្នុងការរាយការណ៍ពីអំពើហិង្សា ហើយបន្ទាប់ពីការរាយការណ៍ ផ្ដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយហានិភ័យគ្រោះថ្នាក់បន្ថែមទៀត។ ក្រៅពីនេះ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រ ផ្ដល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ក៏ដូចជា ការគាំទ្រនិងការប្រព្រឹត្តប្រកបដោយសេចក្ដីថ្លៃថ្នូរក្នុងការបន្តផ្ដល់យុត្តិធម៌ព្រហ្មទណ្ឌ។

## ១.អយ្យការ

អាស្រ័យលើក្របខណ្ឌច្បាប់ជាតិ ឬប្រព័ន្ធយុត្តិធម៌អយ្យការនឹងដើរតួនាទីសំខាន់ក្នុងការសម្រេចពីចំណុចផ្ដោតនៃកិច្ចដំណើរការនីតិវិធីច្បាប់ជំនួសមុខឱ្យរដ្ឋលើជនបង្កដែលរងការចោទប្រកាន់ពីបទអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ក្នុងប្រទេសមួយចំនួន អយ្យការស៊ើបអង្កេត និងជំនុំជម្រះករណី ហើយក្នុងប្រទេសផ្សេងទៀត នគរបាលជាអ្នកធ្វើការស៊ើបអង្កេត មុននឹងបញ្ជូនករណីទៅអយ្យការជំនុំជម្រះ។**

ថ្នាក់ដឹកនាំនគរបាលគួរកត់សម្គាល់ថា ៖

- ពួកគេចាំបាច់ត្រូវកសាងទំនាក់ទំនងការងាររឹងមាំជាមួយអយ្យការដើម្បីផ្ដល់ការជំនុំជម្រះនិងលទ្ធផលប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ដើម្បីយល់ច្បាស់ពីតួនាទីរបស់អយ្យការក្នុងប្រព័ន្ធយុត្តិធម៌របស់ពួកគេ។ ២. ពួកគេអាចបង្កើតវគ្គកសាងការយល់ដឹងរួមដើម្បីកសាងទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពរវាងនគរបាល និងអយ្យការ[555]។

---

552. Skinnider, Eileen, 'Towards Gender-Responsive Criminal Justice: Good practices from Southeast Asia in responding to violence against women' (2018: Thailand Institute of Justice).
553. "វិមាត្រនៃការវាយតម្លៃដែលឆ្លើយតបនឹងយេនឌ័រ" លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃកម្មវិធី និងគោលនយោបាយ" ក្នុងការបញ្ជ្រាបយេនឌ័រសម្រាប់អ្នកគ្រប់គ្រងផ្នែកសុខភាព ៖ អភិក្រមអនុវត្តន៍/ឧបករណ៍វិភាគយេនឌ័ររបស់ WHO។ សៀវភៅណែនាំអ្នកសម្របសម្រួល។ កំណត់សម្គាល់របស់អ្នកចូលរួម (Who, 2011) at: https://www.ncbi.nlm.nih.gov/books/NBK559709/table/ch2.t1/?report=objectonly
554. "ការសិក្សាជាសកលស្ដីពីអំពើមនុស្សឃាត" ២០១៣ ស្ត្រី និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (UNODC, 2011). Mahony, T.H., Jacob, J., and Hobson, H. for the Government of Canada.

ដោយមិនគិតពីប្រព័ន្ធច្បាប់ដែលមានស្រាប់អ្នកគួរដឹងថា អយ្យការដើរតួនាទីយ៉ាងសកម្មក្នុងការពិនិត្យពិច័យភាពស្របច្បាប់ និងការអនុលោមតាមនៃការស៊ើបអង្កេត និងការប្រមូលភស្តុតាង និងការពិនិត្យតាមដានការប្រតិបត្តិសិទ្ធិមនុស្សដោយអ្នកស៊ើបអង្កេត យ៉ាងហោចណាស់ការសម្រេចថាតើគួរចាប់ផ្តើម ឬបន្តការផ្តន្ទាទោសឬទេ។

ថ្នាក់ដឹកនាំនគរបាលគួរជានាថា បុគ្គលិករបស់ខ្លួនយល់ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងទទួលបានការបណ្តុះបណ្តាលចាំបាច់ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ពួកគេនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយអយ្យការ។ ដូច្នេះ ពួកគេត្រូវដឹងពីកិច្ចការរបស់អយ្យការ។

៥.ក្នុងបណ្តាប្រទេសដែលអយ្យការត្រួតពិនិត្យការស៊ើបអង្កេតរបស់នគរបាល ថ្នាក់ដឹកនាំនគរបាលគួរជានាថា នគរបាលបាន ៖

- ប្រើប្រាស់បច្ចេកទេសស៊ើបអង្កេត និងស្រាវជ្រាវសមស្របដើម្បីឱ្យភស្តុតាងអាចទទួលយកបានក្នុងតុលាការ។
- សួរចម្លើយជនរងគ្រោះ និងសាក្សី ដោយលម្អិត មានលក្ខណៈឯកជន និងផ្តល់ការគោរព។
- ធានាផ្តល់មន្ត្រីដែលជាស្ត្រី ប្រសិនបើជនរងគ្រោះចង់បានដូច្នោះ។
- បំពេញរបាយការណ៍នគរបាលស្តីពីឧប្បត្តិហេតុនេះឱ្យបានពេញលេញ។
- សួរចម្លើយបន្តដើម្បីទទួលបានព័ត៌មាន និងភស្តុតាងបន្ថែម។
- យល់ថា ច្បាប់ពាក់ព័ន្ធស្តីពីអំពើហិង្សាលើស្ត្រី (រួមទាំងជាតុផ្សំនៃបទល្មើសនិងនីតិវិធីព្រហ្មទណ្ឌពិសេសដែលអាចអនុវត្តបានចំពោះបទល្មើសទាំងនេះ) និង
- យល់ និងអនុវត្តគោលគំនិតនៃការការពារខ្លួន និងគោលនយោបាយស្តីពីជនប្រព្រឹត្តដែលមានឥរិយាបថត្រួតត្រា ក្នុងករណីពាក់ព័ន្ធ។



ពន្ធនាគារជាតិហៃទី ៖ រូបថតទទួលបានពី MINUSTAH/Victoria Hazou

555. ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពក្នុងករណីដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ តួនាទីរបស់អយ្យការក្នុងសៀវភៅណែនាំស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នអយ្យការទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី" កម្រងសៀវភៅណែនាំស្តីពីយុត្តិធម៌ព្រហ្មទណ្ឌ (UNODC, 2014) : https://www.unwomen.org/en/digital-library/publications/2014/12/handbook-effective-prosecution-of-vaw

ថ្នាក់ដឹកនាំនគរបាលគួរយល់ពីតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការត្រួតពិនិត្យការស៊ើបអង្កេតអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដើម្បីធានាថា ៖

- បានបញ្ជូនព័ត៌មានត្រឹមត្រូវទៅអយ្យការឱ្យបានឆាប់បំផុត។
- បុគ្គលិកយល់ពីស្តង់ដាររួមក្នុងមូលដ្ឋានសម្រាប់បញ្ជូនព័ត៌មានទៅអយ្យការ។
- បុគ្គលិកយល់ពីស្តង់ដារគុណភាពដែលអ្នកបានកំណត់។
- មានការបំពេញតម្រូវការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការយល់ដឹងពីបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- អយ្យការដើរតួនាទីសំខាន់ក្នុងការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី ព្រោះអយ្យការអាចកំណត់ថាតើមានការចោទសួរចាំបាច់និងសមហេតុផលឬទេ មុននឹងសម្រេចផ្តន្ទាទោស ឬមុននឹងចេញសេចក្តីសម្រេចផ្សេងទៀតដែលអាចប៉ះពាល់ដល់យុត្តិធម៌[556]។

ក្នុងយុត្តាធិការដែលអយ្យការនិងអ្នកស៊ើបអង្កេតមានតួនាទីឯករាជ្យ (អ្នកស៊ើបអង្កេតទទួលខុសត្រូវលើការស៊ើបអង្កេតដោយឯករាជ្យ) ជាទូទៅមានវិធានជាស្រេចក្នុងការធានាកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងអយ្យការ។ ក្នុងប្រព័ន្ធយុត្តិធម៌ទាំងនេះ អយ្យការមិនបង្គាប់បញ្ជាអ្នកស៊ើបអង្កេតទេប៉ុន្តែអាចផ្តល់ការណែនាំដល់អ្នកស៊ើបអង្កេតដោយផ្អែកលើលទ្ធផលស៊ើបអង្កេតរបស់អ្នកស៊ើបអង្កេត និងការពិនិត្យឡើងវិញបែបសត្យានុម័តរបស់អយ្យការលើលទ្ធផលទាំងនេះ ដោយផ្អែកលើច្បាប់ និងគោលការណ៍ណែនាំ។

**ផ្តោតលើការកសាងសំណុំរឿងរបស់អ្នក និងធានាថា អ្នកមិនធ្វើឱ្យជនរងគ្រោះអាប់ឱន។**

ថ្នាក់ដឹកនាំនគរបាលក្នុងយុត្តាធិការទាំងនេះអាចស្វែងរកការណែនាំពីអយ្យការនៅពេលប្រឈមនឹងការលំបាកផ្នែកភស្តុតាង។ ក្នុងស្ថានភាពផ្សេងទៀត អយ្យការអាចទទួលរបាយការណ៍របស់នគរបាល ឬឯកសារណែនាំសម្រាប់ការពិគ្រោះយោបល់ ដោយសារតែករណី "ដែលមិនសូវមានភស្តុតាងបញ្ជាក់"ឬមតិយោបល់ចំពោះទស្សនៈរបស់អ្នកស៊ើបអង្កេតដែលយល់ថាគ្មានការផ្តន្ទាទោស[557]។

ថ្នាក់ដឹកនាំនគរបាលត្រូវធានាថា បុគ្គលិករបស់ខ្លួនមិនបញ្ចេញទស្សនៈផ្ទាល់ខ្លួនពាក់ព័ន្ធនឹងចំណុចខ្លាំងនៃករណី និងគួរគូសបញ្ជាក់ និងវាយតម្លៃការលំបាកផ្នែកភស្តុតាងធៀបនឹងច្បាប់ជាធរមាន។

ក្នុងយុត្តាធិការផ្សេងទៀត អយ្យការដើរតួនាទីកាន់តែសកម្មក្នុងការស៊ើបអង្កេត និងអាចចូលរួមអនុវត្តណែនាំ ឬត្រួតពិនិត្យការស៊ើបអង្កេត។ រដ្ឋមួយចំនួនអនុញ្ញាតឱ្យអយ្យការផ្តល់ការណែនាំ និងដំបូន្មានសមស្របដល់នគរបាលដើម្បីអនុវត្តអាទិភាពគោលនយោបាយស្តីពីបទល្មើសបែងចែកករណីនិងធនធានផ្តោតអាទិភាពលើករណី និងអនុវត្តមធ្យោបាយស៊ើបអង្កេត។

ក្នុងយុត្តាធិការមួយចំនួននគរបាលទាក់ទងទៅអយ្យការបន្ទាប់ពីទំនាក់ទំនងដំបូងជាមួយជនរងគ្រោះ ហើយអយ្យការអាចចុះទៅទីតាំងត្រួតពិនិត្យដើម្បីយល់ច្បាស់ពីករណី និងជួយតម្រែតម្រង់ការស៊ើបអង្កេត។ ក្នុងយុត្តាធិការទាំងនេះ ថ្នាក់ដឹកនាំនគរបាលគួរធានាថា បុគ្គលិករបស់ខ្លួនគាំទ្រតួនាទីរបស់អយ្យការក្នុងការប្រមូលភស្តុតាង និងផ្តល់ជំនួយដែលជនរងគ្រោះត្រូវការដើម្បីបន្តចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

ជារួម ថ្នាក់ដឹកនាំនគរបាលគួរធានាថា ៖

- បុគ្គលិករបស់ខ្លួនកសាងសំណុំរឿងដែលមានភស្តុតាងគ្រប់គ្រាន់ ឬគាំទ្រដល់អយ្យការក្នុងការធ្វើកិច្ចការនេះ។
- កិច្ចសហប្រតិបត្តិការជាមួយ និងរវាងនគរបាល និងអយ្យការ ដើម្បីដោះស្រាយបទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- បុគ្គលិកមិនធ្វើឱ្យអាប់ឱនដល់ជនរងគ្រោះ និងផ្តោតលើការកសាងសំណុំរឿងប្រឆាំងនឹងជនបង្កដែលរងការចោទប្រកាន់។

556. Ibid
557. Ibid
558. សម្រាប់ព័ត៌មានបន្ថែមស្តីពីការអនុវត្តល្អបំផុតនិងស្តង់ដារអប្បបរមាសម្រាប់ការកសាងករណីដែលមានភស្តុតាងគ្រប់គ្រាន់សម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី សូមមើល "គំរូនៃការឆ្លើយតបទៅនឹងអំពើហិង្សាផ្លូវភេទសម្រាប់អយ្យការ (RSVP Model) ៖ ការអញ្ជើញឱ្យដឹកនាំ (AEquitas, the Justice Management Institute (JMI), and the Urban Institute, 2016), at: https://aequitasresource.org/wp-content/uploads/2020/01/RSVP-Vol.-I-1.8.20.pdf

- ទំនាក់ទំនងការងារត្រូវបានបង្កើតឡើងជាមួយសមភាគីរបស់ពួកគេក្នុងការិយាល័យអយ្យការ។

ការសិក្សាបង្ហាញថា ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីមួយចំនួន (ឧ.ការប្រទូស្តកេរខ្មាស) មិនសូវមានការប៉ុនប៉ងកសាងសំណុំរឿងឡើយ ប៉ុន្តែវាស្តែងឱ្យឃើញនូវការស៊ើបអង្កេតមិនគ្រប់ជ្រុងជ្រោយភាពលម្អៀងយេនឌ័រ[559] និងការយល់ដឹងអំពីច្បាប់។ កិច្ចសហប្រតិបត្តិការរឹងមាំរវាងនគរបាល និងអយ្យការមានសារៈណាស់ក្នុងករណីទាំងនេះ ព្រោះវាធានាថា នគរបាលខិតខំកសាងសំណុំរឿង ជាជាងបង្កភាពអាប់ឱនដល់ជនរងគ្រោះ[560]។

**ប្រអប់ ៨**

នៅខែ មិថុនា ឆ្នាំ ២០១៧ UNODC បានរៀបចំវគ្គបណ្តុះបណ្តាលរួមសម្រាប់នគរបាល និងអយ្យការនៅប្រទេសណាមីប៊ី ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ ដើម្បីគូសបញ្ជាក់ពីការងារ និងកិច្ចសហការរួមគ្នាចាំបាច់ក្នុងការសម្រេចបានលទ្ធផលជោគជ័យសម្រាប់ជនរងគ្រោះ។ សិក្ខាកាមមានការយល់ដឹងកាន់តែច្រើនអំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ និងបានបង្កើនទំនាក់ទំនងការងាររួមគ្នា។

**ប្រអប់ ៩**

នៅប្រទេសហ្វាំងឡង់នគរបាលនិងអយ្យការបានទទួលការបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតប្រកបដោយបច្ចេកទេស និងកលយុទ្ធពាក់ព័ន្ធនឹងអំពើមនុស្សឃាត ឬបទល្មើសហិង្សាផ្សេងទៀត។ នគរបាលអង់ហ្គោឡា (អគ្គស្នងការដ្ឋាននគរបាលជាតិ) បានខិតខំកសាងការយល់ដឹងដល់មន្ត្រីនគរបាលដោយផ្តល់ចំណេះដឹង និងជំនាញដែលត្រូវការចាំបាច់ក្នុងស្ថានភាពអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ថ្នាក់ដឹកនាំនគរបាលគួរផ្តល់ការណែនាំច្បាស់លាស់ដល់បុគ្គលិករបស់ខ្លួន ៖

- ស្តីពីការដោះស្រាយករណីដូចជាការរំលោភបំពានក្នុងគ្រួសារ ដើម្បីធានាថា ទំនាក់ទំនងដំបូងរបស់ជនរងគ្រោះជាមួយស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខលើកទឹកចិត្តឱ្យជនរងគ្រោះបន្តករណីរបស់ខ្លួន ប្រសិនបើមានការចោទប្រកាន់។
- ស្តីពីការបែងចែកប្រភេទនិងការរក្សាខ្សែអាត់សំឡេងខ្សែទូរស័ព្ទបន្ទាន់ក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាលព្រោះខ្សែអាត់សំឡេងទាំងនោះអាចមានភស្តុតាងដែលនឹកស្មានមិនដល់។ គួរកត់សម្គាល់ថា ភាគច្រើនការទូរស័ព្ទចូលដើម្បីសុំជំនួយពីនគរបាល ធ្វើឡើងដោយជនរងគ្រោះ។
- ពាក់ព័ន្ធនឹងពិធីសារស្តីពីការចែករំលែកព័ត៌មានរវាងតុលាការព្រហ្មទណ្ឌនិងតុលាការគ្រួសារ។
- ស្តីពីការផ្តល់ជូនអយ្យការនូវខ្លឹមសារលម្អិតនៃដីកាការពារជនស៊ីវិលដែលសេវានគរបាលបានទទួលជំនួសមុខឱ្យជនរងគ្រោះ ដើម្បីពង្រឹងការជំនុំជម្រះករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ក្នុងប្រទេសមួយចំនួនអយ្យការអាចពិនិត្យមើលសំណុំរឿងរដ្ឋប្បវេណីព្រោះអយ្យការអាចជួយដល់នគរបាលក្នុងការវាយតម្លៃហានិភ័យរបស់ជនរងគ្រោះ និងផ្តល់ជំនួយនៅពេលសម្រេចពីបទចោទ និងការផ្តន្ទាទោសត្រឹមត្រូវ។

អយ្យការអាចប្រជុំពិភាក្សាពន្យល់ដល់ក្រុមស៊ើបអង្កេតក្នុងមូលដ្ឋាន ស្តីពីការអនុវត្តតាមមូលដ្ឋាន និងគួរពិចារណារៀបចំវគ្គបណ្តុះបណ្តាល[561]។

559. "ការកាត់ទោសករណីរំលោភសេពសន្ថវៈ ៖ ការស្វែងយល់ពីការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាផ្លូវភេទនៅប្រទេសថៃ និងវៀតណាម" (UN Women, UNDP and UNODC, 2017) https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2019/08/ap-trial-of-rape_26aug2019_lowrescompressed.pdf?la=en&vs=1916
560. Ibid
561. សៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់ចៅក្រមនិងអយ្យការស្តីពីការធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌។ ភាពជាដៃគូដើម្បីអភិបាលកិច្ចល្អ។សហភាពអឺរ៉ុប https://rm.coe.int/training-manual-women-access-to-justice/16808d78c5

**ប្រអប់ ១០**

**ការអនុវត្តល្អក្នុងប្រទេសថៃ ៖ ការបណ្តុះបណ្តាលកងរាជតម្រួតថៃ អយ្យការ និងមន្ត្រីតុលាការ ក្រោមភាពជាដៃគូជាមួយ UN Women**

ច្បាប់ថ្មីស្តីពីសមភាពយេនឌ័រ (GEL) ត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១៥ដែលធានាថា បុគ្គលមិនប្រឈមនឹងការរើសអើងដោយផ្ទាល់ និងដោយប្រយោលដោយសារភេទ ឬផ្លូវភេទ។ ច្បាប់នេះចែងថា គោលនយោបាយ វិធាន បទបញ្ញត្តិ ដីកា វិធានការ គម្រោង ឬការអនុវត្តរបស់អង្គការ ឬបុគ្គលសាធារណៈ ឬឯកជន ដែលមានលក្ខណៈរើសអើងយេនឌ័រ មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែសម្រាប់គោលបំណងនៃការលុបបំបាត់របាំងរារាំងការទទួលបានសិទ្ធិ និងសេរីភាពដោយស្មើភាព គោលការណ៍សាសនា និងសន្តិសុខជាតិ។

ច្បាប់នេះបានកំណត់ពីការបង្កើតគណៈកម្មាធិការលើកកម្ពស់សមភាពយេនឌ័រ ដែលមានអាណត្តិកែលម្អគំរូឥរិយាបថក្នុងសង្គម និងវប្បធម៌ ដើម្បីលុបបំបាត់ភាពលម្អៀងយេនឌ័រ និងការអនុវត្តបែបរើសអើង ក៏ដូចជាអំពើហិង្សាផ្អែកលើយេនឌ័រ សំដៅលុបបំបាត់របាំងរារាំងការទទួលបានសិទ្ធិផ្សេងៗ។

កងរាជតម្រួតថៃ ក្រោមភាពជាដៃគូជាមួយ UN Women ក្រសួងកិច្ចការនារី និងអភិវឌ្ឍន៍គ្រួសារ និងមូលនិធិ Friend of Women បាន និងកំពុងពង្រីកការបណ្តុះបណ្តាលមន្ត្រីនគរបាលសួរចម្លើយចំនួន ៩០០ នាក់នៅគ្រប់តំបន់ទូទាំងប្រទេសថៃ ស្តីពីការការពារស្ត្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សា អំពើហិង្សាក្នុងគ្រួសារ និងការជួញដូរ។

ផ្អែកតាមមេរៀនពីវគ្គបណ្តុះបណ្តាលទាំងនេះ និងវគ្គបណ្តុះបណ្តាលកន្លងមកក្នុងរយៈពេលប៉ុន្មានមកឆ្នាំនេះ ម៉ូឌុលបណ្តុះបណ្តាលពិសេសកំពុងត្រូវបានបង្កើតឡើងសម្រាប់ការអនុវត្តក្នុងស្ថាប័នកងរាជតម្រួតថៃ។តាមរយៈការសិក្សានេះវិទ្យាស្ថានយុត្តិធម៌ថៃបានបែងចែកជំនួយមូលនិធិបន្ថែមដើម្បីពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍកម្រងឧបករណ៍ និងយុទ្ធនាការសាធារណៈដើម្បីផ្តល់ព័ត៌មានដល់ជនរងគ្រោះ និងអ្នកមានកាតព្វកិច្ចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ក៏ដូចជាច្បាប់ពាក់ព័ន្ធ និងផ្នែកដែលអាចស្វែងរកការគាំទ្រក្នុងប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ និងសេវាគាំទ្រនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

ប្រភព ៖ "ការកាត់ទោសករណីរំលោភសេពសន្ថវៈ ៖ ការស្វែងយល់ពីការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាផ្លូវភេទនៅប្រទេសថៃ និងវៀតណាម (UNWomen, UNDP and UNODC, 2017)។

## ២.តុលាការ [562]

តុលាការ ឬប្រព័ន្ធតុលាការ ជាប្រព័ន្ធដែលគ្រប់គ្រងយុត្តិធម៌តាងនាមឱ្យមហាក្សត្រ ឬរដ្ឋ។

### ដីកាការពារ

អាស្រ័យលើយុត្តាធិការ តុលាការអាចមានអំណាចចេញដីកាការពារឬពិនិត្យឡើងវិញ និងពង្រីកឬដកដីកាហាមឃាត់ដែលចេញដោយនគរបាល សម្រាប់អនុវត្តលើជនបង្កអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលរងការចោទប្រកាន់[563]។ ជាទូទៅ ចៅក្រមជាប្រធាននៃអង្គសវនាការជាពេលដែលជនរងគ្រោះ និងជនបង្កដែលរងការចោទប្រកាន់ បង្ហាញភស្តុតាង។ ការសម្រេចដោយចៅក្រមថាតើជនរងគ្រោះត្រូវការវិធានការការពារ ឬយ៉ាងណាមានសារៈសំខាន់ទាំងសម្រាប់សុវត្ថិភាពរបស់ជនរងគ្រោះ និងសមាជិកគ្រួសារផ្សេងទៀត និងសម្រាប់ការបង្កើតលក្ខខណ្ឌល្អបំផុតសម្រាប់សំណុំរឿងដែលបញ្ជូនទៅលើ និងនាំទៅរកការផ្តន្ទាទោស។ សវនាការដីកាការពារជាឱកាសដំបូងដ៏សំខាន់ដែលចៅក្រមអាចវិនិច្ឆ័យសមស្រប និងបង្ហាញថា រដ្ឋយកចិត្តទុកដាក់លើការបញ្ចៀសគ្រោះថ្នាក់ចំពោះជនរងគ្រោះក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល។

ថ្នាក់ដឹកនាំនគរបាលគួរធានាថា បុគ្គលិកយល់ពី ៖

- តួនាទីសំខាន់របស់ខ្លួនក្នុងការទប់ស្កាត់អំពើហិង្សាលើ

562. Ibid

563. ឧទាហរណ៍ ក្នុងប្រទេសអូទ្រីស។ សូមមើល៖ "សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការគាំទ្រ និងការការពារពីអំពើហិង្សា (២០១៣)។ បទបញ្ញត្តិសម្រាប់ការការពារពីអំពើហិង្សាប្រទេសអូទ្រីស (២០១៩)។ Domestic Abuse Intervention Centre and the Association of Austrian Autonomous Women's Shelters. https://www.interventionsstelle-wien.at/download/?id=692

ស្ត្រី និងក្មេងស្រី ក្នុងករណីមានរបាំងសង្គម និងរបាំងវប្បធម៌ក្នុងសហគមន៍ដែលប្រកាន់ខ្ជាប់ការអនុវត្តដែលបង្កគ្រោះថ្នាក់ ដែលរារាំងមិនឱ្យជនរងគ្រោះរាយការណ៍បទល្មើសណាមួយ។

- ដីកាការពារដែលមានសម្រាប់បទល្មើសអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងវិធានការដែលពួកគេត្រូវធ្វើឡើងដើម្បីពង្រឹងការអនុវត្តដីកាទាំងនោះ ប្រកបដោយប្រសិទ្ធភាព។
- តួនាទីរបស់តុលាការរដ្ឋប្បវេណី ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ភាពចាំបាច់ក្នុងការបន្តកសាងទំនុកចិត្តរបស់សហគមន៍ដែលពួកគេផ្តល់សេវាជូន។

**ការរងគ្រោះលើកទីពីរកើតឡើងមិនមែនដោយសារលទ្ធផលផ្ទាល់នៃអំពើឧក្រិដ្ឋនោះទេ ប៉ុន្តែតាមរយៈការឆ្លើយតបមិនគ្រប់គ្រាន់របស់ស្ថាប័ននគរបាល ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និងបុគ្គល ចំពោះជនរងគ្រោះ។**

ក្នុងយុត្តាធិការមួយចំនួនវិធានការការពារសម្រាប់បទល្មើសមួយចំនួនដែលទទួលបានពីតុលាការគ្រួសារ អាចលើសពីការកាត់ទោសព្រហ្មទណ្ឌ។ ឧ. នៅចក្រភពអង់គ្លេស ចំនួនដីកាការពារករណីវះកាត់ប្រដាប់បន្តពូជស្ត្រី បានបង្កើនការកាត់ទោសម្តងដោយជោគជ័យ។

ថ្នាក់ដឹកនាំនគរបាលគួរធានាថាបុគ្គលិករបស់ខ្លួនបានដឹងពីភាពចាំបាច់ក្នុងការសហការជាមួយអាជ្ញាធរគាំពារសង្គម អាជ្ញាធរសុខភាព និងអាជ្ញាធរអប់រំ។

**ប្រអប់ ១១**

**ឧទាហរណ៍នៅចក្រភពអង់គ្លេស**

អ្នកអត្ថាធិប្បាយបានគូសបញ្ជាក់ពីភាពចាំបាច់នៃកិច្ចសហការរវាងសេវានគរបាល កិច្ចគាំពារសង្គម និងតុលាការនៅចក្រភពអង់គ្លេសក្នុងការការពារជនរងគ្រោះ ក្នុងករណីដែលមិនសូវមានការកំណត់អត្តសញ្ញាណជនរងគ្រោះដែលកំពុងប្រឈមនឹងផលវិបាកនៃការវះកាត់ប្រដាប់បន្តពូជស្ត្រីដោយអ្នកជំនាញក្នុងវិស័យយុត្តិធម៌។ ក្រៅពីនេះអ្នកជំនាញផ្នែកសុខភាពអប់រំនិងគាំពារសង្គមអាចមិនសូវមានទំនុកចិត្តលើរបៀបដែលនគរបាលឆ្លើយតបនឹងរបាយការណ៍ស្តីពីការវះកាត់ប្រដាប់បន្តពូជស្ត្រី[564]។

ចៅក្រមក្នុងដំណើរការព្រហ្មទណ្ឌ អាចប្រើប្រាស់ឆន្ទានុសិទ្ធិនៅដំណាក់កាលដំបូងនៃដំណើរការព្រហ្មទណ្ឌ ដើម្បីចាត់វិធានការជាជំហានក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់ជនរងគ្រោះ/សាក្សី និងធានាថា ពួកគេមិនរងគ្រោះលើកទីពីរ ដូចជាការផាត់សាធារណជនចេញពីសវនាការ ប្រសិនបើសំណុំរឿងនេះពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងទាមទារឱ្យមានការរក្សាការសម្ងាត់ (ដំណាក់កាលស៊ើបអង្កេតដំបូង សវនាការដីកាការពារ សវនាការបង់ប្រាក់ធានានៅក្រៅឃុំ។ល។)[565]។

អយ្យការនិងចៅក្រមសុទ្ធតែអាចចាត់វិធានការជាជំហានៗចាប់ពីការផ្តួចផ្តើមបណ្តឹងព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីធានាថា គ្មានការពន្យារពេលនៅដំណាក់កាលស៊ើបអង្កេតនិងដំណាក់កាលប្រមូលភស្តុតាង (ជាពិសេសពាក់ព័ន្ធនឹងការប្រមូល និងការធ្វើតេស្តភស្តុតាងកោសលវិច័យ) ដែលនឹងបង្កអន្តរាយដល់ការជំនុំជម្រះ និងការកាត់សេចក្តី។

គួរប្រើប្រាស់កិច្ចដំណើរការនីតិវិធីរហ័ស (ដូចជា តុលាការរហ័ស និងតុលាការឯកទេស) ក្នុងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចៅក្រមអាចធ្វើកិច្ចការនេះបាន ប្រសិនបើចៅក្រមទទួលបានព័ត៌មានពាក់ព័ន្ធពីនគរបាល ជាពិសេសការវាយតម្លៃហានិភ័យដើម្បីធានាថាជនរងគ្រោះនៅតែចូលរួមក្នុងដំណើរការកាត់ទោស។

**អ្នកគួរតែពិនិត្យមើលថា តើជនបង្កដែលរងការការចោទប្រកាន់នោះមិនស្ថិតនៅក្រោមការឃុំខ្លួន ឧទាហរណ៍ដូចជាការបំពេញការងារនៅក្នុងសហគមន៍ ឬបំពេញការងារសាកល្បង។**

564. The Tip of the Iceberg´, Sarkaria, N. and Campbell, G. for Counsel Magazine https://www.counselmagazine.co.uk/articles/tip-of-the-iceberg-the-family-court-ready-surge-activity-fgm

565. ការចងក្រងការអនុវត្តល្អដើម្បីកាត់បន្ថយឧបសគ្គបច្ចុប្បន្ននិងសម្រួលដល់លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ (ក្រុមប្រឹក្សាអឺរ៉ុប គណៈកម្មការសមភាពយេនឌ័រ Strasbourg, 2015) pp. 24-26.

ថ្នាក់ដឹកនាំនគរបាលគួរធានាថា បុគ្គលិក ៖

- ដឹងពីគោលបំណងនៃកិច្ចដំណើរការនីតិវិធីរហ័សនិង
- របៀបដែលនគរបាលអាចជួយដល់អយ្យការ និងចៅក្រមក្នុងការបន្តកិច្ចដំណើរការនីតិវិធីទាំងនេះ។

## ៣.តួនាទីនៃការអនុវត្តការព្យួរទោស

ថ្នាក់ដឹកនាំនគរបាលគួរយល់ពីតួនាទីនៃការអនុវត្តការព្យួរទោសក្នុងដំណើរការយុត្តិធម៌ ក្នុងយុត្តាធិការដែលមានសេវានេះ។ ជាទូទៅ សេវាអនុវត្តន៍ការព្យួរទោសមានអាណត្តិអនុវត្តវិធានការដោយគ្មានការឃុំខ្លួនដែលកំណត់ដោយច្បាប់ និងអនុវត្តចំពោះជនល្មើស[566]។ វិធានការទាំងនេះអាចរួមមានជម្រើសក្រៅពីការឃុំខ្លួន នៅមុនពេល និងក្នុងពេលជំនុំជម្រះឬការកាត់ទោសជាប់ពន្ធនាគារក៏ដូចជាការចាប់ដោះលែងពីពន្ធនាគារ។ ជាទូទៅ វិធានការទាំងនេះពាក់ព័ន្ធនឹងការត្រួតពិនិត្យ ការណែនាំ និងជំនួយដែលផ្តោតចម្បងលើការដាក់បញ្ចូលជនល្មើសទៅក្នុងសង្គម ក៏ដូចជារួមចំណែកដល់សុវត្ថិភាពសហគមន៍។

ថ្នាក់ដឹកនាំនគរបាលគួរដឹងថា ពួកគេនឹងដើរតួនាទីយ៉ាងសំខាន់នៅពេលចាប់ខ្លួន/ចោទប្រកាន់ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីពិនិត្យថាតើគួរអនុវត្តវិធានការដោយគ្មានការឃុំខ្លួនជនបង្កឬទេ (ឧ. ការដោះលែងមុនពេលកំណត់ប្រសិនបើជនបង្កទើបតែត្រូវបានដោះលែងពីពន្ធនាគារ)។

ថ្នាក់ដឹកនាំនគរបាលគួរពិនិត្យឡើងវិញ និងយល់ច្បាស់ពីវិធានអប្បបរមាស្តង់ដាររបស់អង្គការសហប្រជាជាតិសម្រាប់ការអនុវត្តវិធានការដោយគ្មានការឃុំខ្លួន (វិធានតូក្យូ) ដែលផ្តល់ការណែនាំលម្អិតស្តីពីប្រភេទវិធានការផ្សេងៗ ដែលអាចអនុវត្តនៅដំណាក់កាលនីតិវិធីផ្សេងៗ អាស្រ័យលើយុត្តាធិការនីមួយៗ។ ឧ. វិធាននេះរៀបរាប់ពីវិធាន ១២ ចំណុចដែលអាជ្ញាធរតុលាការអាចអនុវត្តក្នុងដំណើរការកាត់ទោស[567] ដូចខាងក្រោម ៖

- ទណ្ឌកម្មជាពាក្យសម្តី ដូចជា ការដាស់តឿន ការស្តីបន្ទោស និងការព្រមាន។
- ការដោះលែងដោយមានលក្ខខណ្ឌ។
- ទណ្ឌកម្មលើស្ថានភាព។
- ទណ្ឌកម្មសេដ្ឋកិច្ច និងការពិន័យជាប្រាក់ ដូចជា ប្រាក់ពិន័យ និងការពិន័យតាមចំនួនថ្ងៃ។
- ដីកាដកហូត ឬរឹបអូស។
- ដីកាបដិទាន ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ។
- ការផ្អាក ឬពន្យារពេលកាត់ទោស។
- ការអនុវត្តការព្យួរទោស និងការត្រួតពិនិត្យដោយតុលាការ
- ដីកាផ្តល់សេវាដល់សហគមន៍។
- ការបញ្ជូនទៅសិក្សារៀនសូត្រ។
- ការឃុំខ្លួនក្នុងផ្ទះ។
- ទម្រង់ផ្សេងទៀតនៃការប្រព្រឹត្តចំពោះនៅក្រៅស្ថាប័ន។

ជាទូទៅ ការពិនិត្យតាមដានតាមប្រព័ន្ធអេឡិចត្រូនិកមិនមែនជាទម្រង់នៃការប្រព្រឹត្តចំពោះទេប៉ុន្តែជាមធ្យោបាយត្រួតពិនិត្យការអនុវត្តការព្យួរទោសក្នុងជម្រើសនៃកាត់ទោសដោយគ្មានការឃុំខ្លួនដូចជាការព្យួរការកាត់ទោសឱ្យជាប់ពន្ធនាគារ។

ក្រៅពីនេះ ថ្នាក់ដឹកនាំនគរបាលគួរពិនិត្យឡើងវិញ និងយល់ច្បាស់ពីយុទ្ធសាស្រ្តគំរូ និងវិធានការអនុវត្តន៍បច្ចុប្បន្នភាពដែលតម្រូវឱ្យ ៖

- សេចក្តីសម្រេចលើការចាប់ខ្លួន ការឃុំខ្លួន និងលក្ខខណ្ឌនៃការដោះលែងជនបង្ក ពិចារណាពីភាពចាំបាច់នៃសុវត្ថិភាពរបស់ជនរងគ្រោះ និងអ្នកផ្សេងទៀត។
- ហានិភ័យសុវត្ថិភាព រួមទាំងភាពងាយរងគ្រោះរបស់ជនរងគ្រោះ ត្រូវបានយកមកពិចារណាក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងការកាត់ទោសដោយគ្មានឃុំខ្លួន ឬការកាត់ទោសដែលប្រហាក់ប្រហែលនឹងការឃុំខ្លួន ការអនុញ្ញាតឱ្យបង់ប្រាក់ធានានៅក្រៅឃុំ ការដោះលែងដោយមានលក្ខខណ្ឌ ការដោះលែងមុនពេលកំណត់ ឬការអនុវត្តការព្យួរទោស ជាពិសេសនៅពេលប្រឈមជាមួយនឹងជនល្មើសដដែលៗ និងបង្កគ្រោះថ្នាក់។
- ជនរងគ្រោះដោយសារអំពើហិង្សា មានសិទ្ធិទទួលបានដំណឹងស្តីពីការដោះលែងជនល្មើសពីការឃុំឃាំង ឬពន្ធនាគារ។

566. HM Inspectorate of Probation Academic Insights 2019/02 European Probation Rules Rob Canton at: https://www.justiceinspectorates.gov.uk/hmiprobation/wp-content/uploads/sites/5/2019/03/Academic-Insights-Canton-Jan-19-final.pdf

567. វិធានអប្បបរមាស្តង់ដាររបស់អង្គការសហប្រជាជាតិសម្រាប់ការអនុវត្តវិធានការដោយគ្មានការឃុំខ្លួន (វិធានតូក្យូ) ដែលត្រូវបានអនុម័តដោយមហាសន្និបាត សេចក្តីសម្រេចលេខ ៤៥/១១០ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩០ https://www.penalreform.org/priorities/alternativestoimprisonment/international-standards/

## ប្រអប់ ១២

**ការអនុវត្តល្អបំផុតនៅចក្រភពអង់គ្លេស** [568]

រដ្ឋាភិបាលរបស់មហាក្សត្រី និងប្រព័ន្ធយុត្តិធម៌អង់គ្លេស និងវែល សេវាអយ្យការ Crown និងស្ថាប័នអនុវត្តន៍ច្បាប់កត់សម្គាល់ពីតម្លៃនៃការដើរតួនាទីឯករាជ្យក្នុងការការពារស្ត្រី និងក្មេងស្រីដែលទទួលរងអំពើហិង្សា និងការរំលោភបំពាន។ យូរៗទៅ មានការអនុវត្តល្អដើម្បីគាំទ្រ និងការពារស្ត្រី ក៏ដូចជារក្សាការទទួលខុសត្រូវរបស់ជនបង្កក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនិងប្រព័ន្ធយុត្តិធម៌រដ្ឋប្បវេណី។លទ្ធផលនេះពឹងផ្អែកលើស្ថាប័ននិងទីភ្នាក់ងារនីមួយៗដែលកំពុងបំពេញតួនាទីប្រកបដោយគុណភាព។ ការអនុវត្តល្អរួមមាន ៖

- រដ្ឋាភិបាលរបស់មហាក្សត្រីបានបង្កើតឯកសារណែនាំយុទ្ធសាស្ត្រជាច្រើនដើម្បីបង្កើនអភិក្រមពហុស្ថាប័នសម្រាប់ប្រធានបទនានា រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ ការវះកាត់ប្រដាប់បន្តពូជស្ត្រី និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ។ ឯកសារទាំងនេះផ្តល់ព័ត៌មានដ៏មានតម្លៃដល់អ្នកអនុវត្តន៍ជួរមុខស្តីពី "ប្រការគួរ" និង "ប្រការមិនគួរ" រួមទាំង "សញ្ញា" និង "រោគសញ្ញា" ដើម្បីអាចឱ្យអ្នកអនុវត្តន៍កំណត់អត្តសញ្ញាណជនរងគ្រោះ។
- ឯកសារណែនាំនេះត្រូវបានបំពេញបន្ថែមនៅកម្រិតយុទ្ធសាស្ត្រ ដោយសេចក្តីណែនាំសម្រាប់នគរបាល ដែលបង្កើតឡើងដោយមហាវិទ្យាល័យសេវានគរបាល និង NPCC។ មហាវិទ្យាល័យនេះបានអភិវឌ្ឍចំណេះដឹងស្តង់ដារប្រតិបត្តិភាពជាអ្នកដឹកនាំ និងភាពមានវិជ្ជាជីវៈដែលជាលក្ខខណ្ឌតម្រូវសម្រាប់មន្ត្រីនគរបាលដែលត្រូវបានបង្កើតឡើងតាមរយៈការអនុវត្តវិជ្ជាជីវៈដែលទទួលបានការអនុញ្ញាត។

NPCC មានមុខងារសំខាន់ៗជាច្រើន ដូចជា ការសម្របសម្រួលប្រតិបត្តិការថ្នាក់ជាតិ រួមទាំងការកំណត់ ការពិនិត្យតាមដាននិងការធ្វើតេស្តការរួមចំណែកដល់លក្ខខណ្ឌតម្រូវនៃសេវានគរបាលជាយុទ្ធសាស្ត្រការសម្របសម្រួលការឆ្លើយតបរបស់នគរបាលជាតិទៅនឹងគ្រោះអាសន្នថ្នាក់ជាតិ និងការសម្របសម្រួលការកៀរគរធនធានតាមព្រំដែន និងជាអន្តរជាតិ ការអនុវត្តស្តង់ដារ និងគោលនយោបាយប្រតិបត្តិការថ្នាក់ជាតិដែលកំណត់ដោយមហាវិទ្យាល័យសេវានគរបាល និងរដ្ឋាភិបាល និងសហការជាមួយមហាវិទ្យាល័យនេះក្នុងការបង្កើតអភិក្រមរួមនៅថ្នាក់ជាតិស្តីពីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តការងារ។

មហាវិទ្យាល័យសេវានគរបាល បានបង្កើតការអនុវត្តវិជ្ជាជីវៈដែលទទួលបានការអនុញ្ញាតដើម្បីផ្តល់ភាពជាអ្នកដឹកនាំ ទិសដៅ និងស្តង់ដារសម្រាប់ការស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចខាងក្រោម ៖

ការរំលោភបំពានក្នុងគ្រួសារ
អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាដើម្បីរក្សាកិត្តិយស
ការវះកាត់ប្រដាប់បន្តពូជស្ត្រី (មហាវិទ្យាល័យសេវានគរបាល)
ការកេងប្រវ័ញ្ចផ្លូវភេទកុមារ
ទាសភាពសម័យទំនើប
ការឈ្លបចាប់ និងការបៀតបៀន
បទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសផ្លូវភេទ។

សម្រាប់អំពើរំលោភសេពសន្ថវៈ មានការបង្កើតសេចក្តីណែនាំបន្ថែមទៀតស្តីពីការឆ្លើយតបដំបូងទៅនឹងអំពើរំលោភសេពសន្ថវៈ ការដេញដោលការយល់ខុស និងផ្ទត់គំនិត និងកម្រងឧបករណ៍របស់នគរបាលស៊ើបអង្កេតក្នុងការដោះស្រាយបញ្ហានៃការយល់ព្រម។

568. ជំពូកស្តីពីប្រទេសអង់គ្លេស និងវែលក្នុងសៀវភៅណែនាំស្តីពីច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី (២០១៨) Sarkaria, N., and Campbell, G. European Lawyers Foundation. https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relatingto-violence-against-women.pdf

ដើម្បីបំពេញបន្ថែមលើការអនុវត្តវិជ្ជាជីវៈដែលមានការអនុញ្ញាតរបស់មហាវិទ្យាល័យ នេះ NPCCបានបង្កើតយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការរំលោភបំពានដើម្បីរក្សាកិត្តិយស អាពាហ៍ពិពាហ៍ដោយបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី ដែលផ្តល់ការណែនាំផ្នែកគោលនយោបាយដល់អធិការនគរបាល ៤៣នាក់ មកពីប្រទេសអង់គ្លេស វែល និងអៀកឡង់ខាងជើង។

- សេវាអយ្យការ Crown បានផ្តល់ការណែនាំផ្នែកគោលនយោបាយច្បាប់ដល់អយ្យការរបស់ខ្លួនឱ្យពិចារណាពីករណីខាងក្រោម ក្នុងការកាត់ទោសបទល្មើសដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖
  ការរំលោភបំពានក្នុងគ្រួសារ
  ការរំលោភផ្លូវភេទកុមារ
  ការណែនាំផ្លូវច្បាប់ស្តីពីការវះកាត់ប្រដាប់បន្តពូជស្ត្រី
  ការណែនាំពាក់ព័ន្ធនឹងអ្នកប្រកបរបបផ្លូវភេទ
  ការឈ្លបចាប់ និងការបៀតបៀន
  ការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងទាសភាព។

ការណែនាំផ្នែកគោលនយោបាយច្បាប់នេះ បំពេញបន្ថែមដោយការបណ្តុះបណ្តាល។ ឧ. សេវាអយ្យការ Crown បានបង្កើតម៉ូឌុលរៀនសូត្រជាកាតព្វកិច្ចតាមប្រព័ន្ធអេឡិចត្រូនិកចំនួន ២ ស្តីពីការរំលោភបំពានក្នុងគ្រួសារពាក់ព័ន្ធនឹងការកាត់ទោសផ្នែកតាមភស្តុតាង និងការគ្រប់គ្រងឥរិយាបថសម្រាប់អយ្យការទាំងអស់។ ក្រៅពីនេះ មានការផ្តល់ឯកសារជំនួយស្មារតីផ្នែកលើការរៀនសូត្រនេះជូននគរបាលផងដែរ។

- នៅប្រទេសអង់គ្លេស និងវែល មានទំនាក់ទំនងការងារយ៉ាងស្អិតរមួតជាមួយសេវាអយ្យការ Crown កងកម្លាំងនគរបាល មហាវិទ្យាល័យសេវានគរបាល និង NPCC។ ទំនាក់ទំនងការងារប្រកបដោយវិជ្ជាជីវៈនេះមានភាពរឹងមាំក្នុងបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលមានការទទួលស្គាល់ថា ត្រូវតែមានអភិក្រមរួមក្នុងការធានាទំនុកចិត្ត និងការជឿជាក់របស់ជនរងគ្រោះដែលងាយរងគ្រោះ ក៏ដូចជាទទួលបានភស្តុតាងល្អៗបំផុតដើម្បីធានាការកាត់ទោសប្រកបដោយជោគជ័យ។ ផ្នែកចុងក្រោយនេះក៏មានសារៈសំខាន់សម្រាប់ធានា លទ្ធភាពរបស់ជនរងគ្រោះដែលងាយរងគ្រោះ ក្នុងការទទួលបានយុត្តិធម៌ ក៏ដូចជាពង្រឹងទំនុកចិត្ត និងការជឿជាក់របស់ជនរងគ្រោះផងដែរ។
- ដើម្បីសម្រេចបានគោលដៅខាងលើ សេវាអយ្យការ Crown NPCC និងកងកម្លាំងនគរបាល បានរៀបចំវគ្គបណ្តុះបណ្តាលរួមគ្នាមួយ និងបង្កើតពិធីសាររួមក្នុងការស៊ើបអង្កេត និងកាត់ទោសករណីរំលោភសេពសន្ថវៈ ការរំលោភបំពានផ្អែកលើយេនឌ័រ អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និងការវះកាត់ប្រដាប់បន្តពូជស្ត្រី។

**ប្រអប់ ១៣**

ប្រទេសម៉ុងតេណេហ្គ្រោ បានដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងពហុស្ថាប័នដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី។ នៅឆ្នាំ ២០១៨ "ក្រុមប្រតិបត្តិការ" មួយត្រូវបានបង្កើតឡើងដើម្បីផ្តោតសំខាន់លើកង្វះការផ្សារភ្ជាប់គ្នាក្នុងចំណោមស្ថាប័ន ដែលប្រឈមជាមួយនឹងករណីអំពើហិង្សាក្នុងគ្រួសារ។ ក្រុមនេះមានសមាជិក ១៩ នាក់មកពីស្ថាប័នផ្សេងៗដូចជាតំណាងរបស់ក្រសួងមហាផ្ទៃ ស្នងការដ្ឋាននគរបាលក្រសួងការងារនិងសុខុមាលភាពសង្គមក្រសួងសុខាភិបាល តុលាការបទល្មើសមជ្ឈិមជាន់ខ្ពស់ តុលាការកំពូល ការិយាល័យអយ្យការរដ្ឋ ក្រុមប្រឹក្សាពលរដ្ឋដើម្បីគ្រប់គ្រងប្រតិបត្តិការនគរបាល និងតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥ ដែលធ្វើការងារពាក់ព័ន្ធនឹងការការពារជនរងគ្រោះដោយសារអំពើហិង្សា។ ក្រុមនេះដើរតួនាទីជាស្ថាប័នសម្របសម្រួលដែលមានគោលបំណងដោះស្រាយបញ្ហាក្នុងខ្សែសង្វាក់នៃអំពើហិង្សាក្នុងគ្រួសារ តាមរយៈការផ្សព្វផ្សាយគោលការណ៍ណែនាំ និងគំនិតផ្តួចផ្តើមពាក់ព័ន្ធ។

## ការសម្របសម្រួលដោយមានការសម្របសម្រួលជាមួយតួអង្គផ្សេងៗ ក្នុងការបន្តផ្តល់យុត្តិធម៌

### ការរអាក់រអួលក្នុងដំណើរការយុត្តិធម៌

ថ្នាក់ដឹកនាំនគរបាលគួរដឹងថា នៅកម្រិតមូលដ្ឋាន អាចមានការអាក់ខានក្នុងដំណើរការយុត្តិធម៌ នៅពេលស្ត្រីមិនទាក់ទងទៅសេវាវេជ្ជសាស្ត្រ ឬនគរបាលក្រោយមានឧប្បត្តិហេតុអំពើហិង្សា។ ដូច្នេះ ថ្នាក់ដឹកនាំនគរបាលត្រូវកសាងការយល់ដឹងពីបញ្ហាក្នុងមូលដ្ឋានតាមរយៈការផ្សារភ្ជាប់ជាមួយសង្គម ស៊ីវិល និងអង្គការស្ត្រី ដែលយើងនឹងលើកមកពិភាក្សាដោយសង្ខេប។

១. ស្ត្រីមកពីក្រុមភាគតិច និងស្ត្រីដែលមានការលំបាកផ្នែកហិរញ្ញវត្ថុលើកឡើងថា ការភ័យខ្លាចការរើសអើងជាមូលហេតុទូទៅមួយដែលធ្វើឱ្យពួកគេមិនទាក់ទងទៅសេវាវេជ្ជសាស្ត្រ ឬទូរស័ព្ទប្តឹងនគរបាល ក្រោយឧប្បត្តិហេតុអំពើហិង្សា។ ផ្អែកតាមការអង្កេតមួយនាពេលថ្មីៗនេះ ស្ត្រីមកពីសហគមន៍ Roma ព្រួយបារម្ភថា អាជ្ញាធរមិនជួយដល់ពួកគេដោយសារតែជំនឿចាក់ឫសយ៉ាងជ្រៅថាអំពើហិង្សាជារឿងធម្មតាក្នុងសហគមន៍ Roma[569]។

---

**ប្រអប់ ១៩**

**ការអង្កេតដឹកនាំដោយ OSCE ស្តីពីអំពើហិង្សាលើស្ត្រី ៖ បទពិសោធន៍របស់ស្ត្រីដែលជួបការលំបាក (២០១៩)**

ការអង្កេតនេះរកឃើញថា ក្រុមស្ត្រីមួយចំនួនកាន់តែងាយរងគ្រោះដោយអំពើហិង្សា ហើយជាញឹកញាប់ ស្ត្រីមកពីក្រុមជួបការលំបាក ប្រឈមនឹងការលំបាកមួយចំនួន។ កត្តាបង្កការរើសអើងជាច្រើនដែលបង្កផលប៉ះពាល់លើស្ត្រី មានភាពប្រទាក់ក្រឡាគ្នា។ ភាពក្រីក្រ កម្រិតអប់រំទាប និងអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ សុទ្ធតែជាកត្តាសំខាន់ៗដែលរួមចំណែកធ្វើឱ្យស្ត្រី និងក្មេងស្រីងាយប្រឈមនឹងអំពើហិង្សា និងផលប៉ះពាល់កាន់តែខ្លាំងលើរាងកាយ និងផ្លូវចិត្ត។ ការស្ថិតក្នុងក្រុមភាគតិច ការមានពិការភាព ឬការមានឋានៈជាជនភៀសខ្លួន ឬជនបាត់បង់ទីលំនៅ ដែលសុទ្ធតែជាកត្តាដែលជាញឹកញាប់ពាក់ព័ន្ធនឹងភាពក្រីក្រ និងការរើសអើង បានបង្កើនហានិភ័យ និងបទពិសោធន៍នៃការរងគ្រោះដោយអំពើហិង្សាខុសៗគ្នា។

ក្រៅពីនេះ បទដ្ឋានសង្គម និងឥរិយាបថបង្កប់ដែលលេចឡើងជាទូទៅក្នុងចំណោមក្រុមជួបការលំបាកមួយចំនួន និងជាញឹកញាប់ ត្រូវបានជំរុញដោយភាពក្រីក្រ បានរួមចំណែកឱ្យមានវិសមភាពយេនឌ័រ និងអំពើហិង្សាលើស្ត្រី។ បទដ្ឋាន និងឥរិយាបថដែលយល់ស្របទៅនឹងភាពក្រោមបង្គាប់របស់ស្ត្រី ការស្តីបន្ទោសជនរងគ្រោះ និងចាត់ទុកអំពើហិង្សាជាបញ្ហាឯកជនលេចឡើងជាទូទៅក្នុងចំណោមអតីតជនភៀសខ្លួន/ជនបាត់បង់ទីលំនៅជាស្ត្រី ស្ត្រីដែលមានកម្រិតអប់រំត្រឹមបឋមសិក្សានិងស្ត្រីដែលស្ថិតក្នុងក្រុមសាសនា/ជាតិពន្ធុភាគតិច។ខណៈដែលទស្សនៈទាំងនេះមិនស៊ីសង្វាក់គ្នានឹងការរាយការណ៍ពីប្រេវ៉ាឡង់ខ្ពស់ អំពើហិង្សានៅតែកើតមានជាទូទៅ ហើយបទដ្ឋានសង្គម និងឥរិយាបថទំនងជាកត្តារួមចំណែក។

ភាពទូលំទូលាយនៃបទដ្ឋានទាំងនេះក៏អាចរួមចំណែកដល់វិសមភាពយេនឌ័រទូទៅការអត់ឱនការរំលោភបំពាន និងការមិនហ៊ាននិយាយក្នុងសង្គម។ ស្ត្រីមកពីក្រុមជួបការលំបាកប្រឈមនឹងឧបសគ្គបន្ថែមក្នុងការទទួលបានសេវាគាំទ្រ។ ក្នុងករណីមួយចំនួន ឧបសគ្គទាំងនេះលេចឡើងដោយសារការភ័យខ្លាច ការរើសអើងក្នុងស្ថាប័នដែលបណ្តាលមកពីសេវា និងអាជ្ញាធរដែលគួរជួយដល់ស្ត្រី។ ការស្រាវជ្រាវបែបគុណភាពបង្ហាញថា នេះជាការពិតសម្រាប់ស្ត្រីមកពីក្រុមជាតិពន្ធុភាគតិចមួយចំនួន ដូចជា ស្ត្រី Roma។ ស្ត្រីជួបការលំបាកជាច្រើននិយាយថាពួកគេមិនអាចទទួលបានសេវាដោយសាតែការពឹងផ្អែកផ្នែកសេដ្ឋកិច្ច។ ចំណុចនេះគូសបញ្ជាក់ពីភាពចាំបាច់នៃការផ្តល់សំណាញ់សុវត្ថិភាពហិរញ្ញវត្ថុដល់ស្ត្រីគ្រប់រូប[570] ។

---

569. ការអង្កេតដឹកនាំដោយ OSCE ស្តីពីអំពើហិង្សាលើស្ត្រី ៖ បទពិសោធន៍របស់ស្ត្រីដែលជួបការលំបាក (OSCE, 2019), https://www.osce.org/secretariat/430007?download=true

570. Ibid

ថ្នាក់ដឹកនាំនគរបាលអាចជួយស្តារទំនាក់ទំនងរបស់ជនរងគ្រោះ ជាមួយដំណើរការយុត្តិធម៌ឡើងវិញ ដោយ ៖

- ផ្តល់ព័ត៌មាននិងសេវាជាភាសារបស់ជនជាតិភាគតិច។
- ពិនិត្យថាតើមានសេវាស្រាប់(នៅមួយកន្លែងឬចល័ត) ក្នុងតំបន់ជនបទ និងដាច់ស្រយាល ឬទេ។
- បង្កើនលទ្ធភាពទទួលបានព័ត៌មាន និងសេវាសម្រាប់ស្ត្រី និងក្មេងស្រីមានពិការភាព (សូមមើលប្រអប់ ១៥៖ បច្ចេកទេសទូទៅសម្រាប់ការសួរចម្លើយជនមានពិការភាព)
- ធានាថា សេវាទាំងអស់ត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃ និងកាត់បន្ថយចំណាយបន្ថែមសម្រាប់ស្ត្រីមកពីក្រុមជួបការលំបាក (ចំណាយពាក់ព័ន្ធនឹងការធ្វើដំណើរការ ការថែទាំកុមារ ឬថ្លៃសេវាពេទ្យ។ល។)
- ជូនដំណឹងដល់ស្ត្រី និងក្មេងស្រីស្តីពីសេវាដែលមានតាមរយៈបណ្តាញផ្សព្វផ្សាយផ្សេងទៀត(ទាំងអនឡាញ និងអហ្វឡាញ)។
- ដាក់បញ្ចូលតម្រូវការនិងបញ្ហាប្រឈមជាក់លាក់របស់ស្ត្រីមកពីក្រុមជួបការលំបាកទៅក្នុងការបណ្តុះបណ្តាលសម្រាប់នគរបាល និងតុលាការ ស្តីពីរបៀបការពារ និងគាំទ្រជនរងគ្រោះ អនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងកែលម្អប្រព័ន្ធរាយការណ៍។
- សហការជាមួយតំណាងក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ដើម្បីកសាងការយល់ដឹងរបស់នគរបាល និងតុលាការស្តីពីតម្រូវការជាក់លាក់របស់ស្ត្រីជួបការលំបាកគួបផ្សំនឹងការប្រឆាំងផ្នត់គំនិតអំពីស្ត្រីទាំងនេះ។

**ប្រអប់ ១៥**

បច្ចេកទេសទូទៅសម្រាប់ការសួរចម្លើយជនមានពិការភាព ៖

- ផ្តល់ការគោរព និងសេចក្តីថ្លៃថ្នូរដល់ជនរងគ្រោះ ដូចអ្នកផ្សេងទៀតដែរ។
- ផ្តល់ពេលវេលាបន្ថែមសម្រាប់ការប្រាស្រ័យទាក់ទង និងសួរចម្លើយ។
- ប្រើភាសាសាមញ្ញ ជាក់លាក់ និងខ្លីៗច្បាស់ៗ។
- ប្រើសំណួរទម្រង់បើក មិនមែនសំណួរទម្រង់បិទដែលអ្នកឆ្លើយត្រឹម "បាទ/ចាស" ឬ "ទេ" នោះទេ។
- កុំសួរសំណួរស្នើយោបល់ដែលបង្កប់ការឆ្លើយតបជាក់លាក់
- កែសម្រួលសំណួររបស់អ្នក ប្រសិនបើជនរងគ្រោះមិនយល់សំណួរ។ ថាព័ត៌មានឡើងវិញ ប្រសិនបើចាំបាច់។
- ប្រើរូបភាព និមិត្តសញ្ញា ភាសាកាយវិការ (អ្វីក៏ដោយឱ្យតែអាចទៅរួច) ដើម្បីសម្រួលដល់ទំនាក់ទំនង។
- ធានាថាតើជនរងគ្រោះយល់ពីអ្នក ឬទេ ដោយសុំឱ្យពួកគេពន្យល់ព័ត៌មានដែលអ្នកផ្តល់ឱ្យ។
- បង្ហាញការគាំទ្រ និងការលើកទឹកចិត្ត។ សូមអត់ធ្មត់នៅពេលសួរចម្លើយ។

ប្រភព ៖ ការស៊ើបអង្កេត ការការពារ និងវិធានការគាំទ្រសម្រាប់ជនរងគ្រោះ ដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ។ សៀវភៅធនធាន ៖ បទពិសោធន៍ និងគោលការណ៍ណែនាំសម្រាប់នគរបាលកូរ៉េ (UNDP Seoul Policy Centre, 2019)

## ការធ្វើការជាមួយសង្គមស៊ីវិល

ថ្នាក់ដឹកនាំនគរបាលគួរធ្វើការក្នុងអង្គច្បាប់ និងជាមួយស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ សុខាភិបាល និងកិច្ចគាំពារសង្គម ដើម្បីផ្តល់លទ្ធផលដ៏យុត្តិធម៌ដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ចាំបាច់ត្រូវកែសម្រួលការគាំទ្រ និងជំនួយដោយពិចារណាពេញលេញពីបទពិសោធន៍ពាក់ព័ន្ធគ្នារបស់ស្ត្រី។ ឧទាហរណ៍នៃការគាំទ្រដែលត្រូវបានកែសម្រួលរួមមានលទ្ធភាពចូលដល់ក្រុមគាំទ្រដែលមានឯកទេសផ្នែកការរំលោភបំពានក្នុងគ្រួសារ និងអាចចូលដល់ស្ត្រីដែលរស់នៅទីជនបទ ដោយសារតែពួកគេតែងផ្លាស់ទី។

### ប្រអប់ ១៦
### (UNFPA ខែ មករា ឆ្នាំ ២០១៩)[571]

**Sloviansk ប្រទេសអ៊ុយក្រែន**

ក្រុមចល័តរបស់UNFPAដែលផ្តល់ការគាំទ្រផ្នែកចិត្តសង្គមបានផ្តល់ជំនួយយ៉ាងច្រើនដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ។ក្រុមនេះអាចជួយដល់ជនរងគ្រោះដោយសារការរំលោភបំពានក្នុងគ្រួសារឱ្យជម្លៀសទៅកាន់ជម្រកសុវត្ថិភាព និងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ស្ត្រីដែលពិបាកចូលដល់ ជាពិសេសស្ត្រីនៅទីជនបទ។ ក្រុមចល័តនីមួយៗមានអ្នកឯកទេស ៣ នាក់ (អ្នកសម្របសម្រួល ចិត្តវិទូ និងបុគ្គលិកសង្គមកិច្ច) ដែលចុះជួបគ្រួសារខ្វះខាតដោយផ្តោតសំខាន់លើអ្នករងផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ។ក្រុមចល័តនេះអាចពិនិត្យតាមដានស្ថានភាពរបស់គ្រួសារមួយ ចុះជួបជាច្រើនលើកច្រើនសារនៅតាមផ្ទះរបស់ពួកគេ បញ្ជូនជនរងគ្រោះដោយសារអំពើហិង្សាទៅមជ្ឈមណ្ឌលផ្តល់សេវាសង្គម ឬបញ្ជូនករណីទៅស្ថាប័នរដ្ឋផ្សេងទៀត ឬមេធាវីដែលអាចផ្តល់ជំនួយចាំបាច់។

### ប្រអប់ ១៧

**ទីក្រុងរបស់ស្ត្រី** ៖ ជាអភិក្រមថ្មីមួយសម្រាប់សេវា និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលបង្កើតឡើងដោយលេខាធិការដ្ឋានបរិយាបន្នសង្គម (SIS) នៅប្រទេសអែលសាល់វ៉ាឌ័រ។ ទីក្រុងរបស់ស្ត្រីជាគំរូពិសេសមួយសម្រាប់បង្កើនភាពអង់អាចរបស់ស្ត្រីដោយផ្តល់សេវាចម្រុះដល់ស្ត្រីក្រោមដំបូលតែមួយ (មជ្ឈមណ្ឌលទីក្រុងរបស់ស្ត្រី)។ សេវាទាំងនោះផ្តល់ជូនដោយស្ថាប័នសាធារណៈផ្សេងៗ (អ្នកផ្តល់សេវា) ក្រោមការដឹកនាំរបស់ SIS។ សេវាក្នុងមជ្ឈមណ្ឌលទីក្រុងរបស់ស្ត្រីរួមមាន ៖

- ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី
- សេវាសុខាភិបាលផ្លូវភេទ និងបន្តពូជ
- ការគាំទ្រសម្រាប់ការបង្កើតស្វ័យភាពសេដ្ឋកិច្ច
- ការអប់រំក្រុមដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និង
- ការថែទាំកុមារសម្រាប់កុមារអាយុក្រោម ១២ ឆ្នាំ ខណៈដែលស្ត្រីប្រើប្រាស់សេវានៅមជ្ឈមណ្ឌលផ្ទាល់។

តាមរយៈការច្របាច់បញ្ចូលគ្នានូវសេវាជាច្រើនក្នុងទីតាំងតែមួយគំរូនេះបានកាត់បន្ថយការចំណាយពេលវេលា និងធនធានដោយស្ត្រីក្នុងការស្វែងរកសេវាសាធារណៈដែលរប៉ាត់រប៉ាយ។អភិក្រមទីក្រុងរបស់ស្ត្រីបានផ្តល់កញ្ចប់សេវាឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលត្រូវបានកែសម្រួលទៅតាមតម្រូវការ និងមានការសម្របសម្រួលដោយផ្តោតទាំងស្រុងលើស្ត្រីម្នាក់ៗ។អភិក្រមនេះជំរុញការផ្តល់សេវាដែលមានគុណភាពខ្ពស់ព្រោះអភិក្រមនេះអនុវត្តខ្សែសង្វាក់នៃការផ្តល់សេវាដែលត្រូវបានសម្របសម្រួលទូទាំងស្ថាប័ននេះ។

ក្រៅពីទទួលបានសេវាឆ្លើយតប (ដូចជា ការព្យាបាលរបួសរាងកាយ ការគាំទ្រផ្នែកចិត្តសង្គម។ល។) ស្ត្រីបានចូលរួមក្នុងសកម្មភាពនានាដើម្បីមានស្វ័យភាពផ្នែកសេដ្ឋកិច្ចដោយបានបង្កើនជម្រើសរបស់ស្ត្រីក្នុងការចាកចេញពីស្ថានភាពហិង្សា។ ការសម្របសម្រួលអន្តរស្ថាប័នក្នុងចំណោមអ្នកផ្តល់សេវាក្នុងមជ្ឈមណ្ឌលទាំងនេះ បានបង្កើនឱកាសសម្រាប់ការកំណត់អត្តសញ្ញាណ និងបញ្ជូនស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សា តាមរយៈការដើរតួនាទីជាចំណុចចាប់ផ្តើមសម្រាប់អ្នកស្វែងរកសេវាដែលមិនពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[572]។

571. ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារប្រទេសអ៊ុយក្រែនបានពឹងផ្អែកលើក្រុមផ្តល់ជំនួយចល័តរបស់ UNFPA (UNFPA ២០១៩) https://www.unfpa.org/news/tackle-domestic-violence-ukraine-looks-unfpas-mobile-assistance-teams។

572. "ការអនុវត្តល្អក្នុងការបង្កើតអភិក្រមផ្អែកតាមសហគមន៍ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ"ឯកសារជំនាញកិច្ចប្រជុំក្រុមអ្នកជំនាញដែលរៀបចំឡើងដោយផ្នែកបង្កើនវឌ្ឍនភាពស្ត្រីរបស់អង្គការសហប្រជាជាតិ ក្រោមកិច្ចសហការជាមួយ UNODC (ថ្ងៃទី ១៧-២៩ ខែឧសភា ឆ្នាំ ២០០៥ ទីក្រុងវីយែន ប្រទេសអូទ្រីស) រៀបចំឡើងដោយ Lori Michau Raising Voices Kampala, Uganda, at: https://www.un.org/womenwatch//daw/egm/vaw-gp-2005/docs/FINALREPORT.goodpractices.pdf

## ការប្រើប្រាស់ទិន្នន័យ

ទោះបីជានគរបាលអាចទទួលខុសត្រូវលើការសម្រេចចិត្តដំបូង ដើម្បីធ្វើការចោទប្រកាន់ក្នុងយុត្តាធិការមួយចំនួន ការចោទប្រកាន់ដែលបានធ្វើឡើងនិងការប្រមូលភស្តុតាងគាំទ្រយ៉ាងមានប្រសិទ្ធភាពក្តីក៏នគរបាលមិនមែនជាអ្នកទទួលខុសត្រូវទាំងស្រុងនោះទេ។ ឧ. ក្នុងប្រទេសមួយចំនួន ដូចជា អេហ្ស៊ីប អយ្យការជាអ្នកដឹកនាំដំណើរការស៊ើបអង្កេត និង ចោទប្រកាន់។ការកើនឡើងនៃការកាត់ទោសដោយជោគជ័យ គឺជាសូចនាករមួយ (ទោះបីជាវង្វាស់តំណាងក្តី)ដែលបញ្ជាក់ពីប្រសិទ្ធភាពរបស់នគរបាល និងអយ្យការក្នុងការចោទប្រកាន់ និងការប្រមូល ភស្តុតាង។

ទិន្នន័យក្នុងមូលដ្ឋានអាចជួយដល់ថ្នាក់ដឹកនាំនគរបាលក្នុងការកំណត់រកបទល្មើសជាក់លាក់ដែលត្រូវមានការកែលម្អការអនុវត្តការងាររបស់បុគ្គលិកពាក់ព័ន្ធ។ឧ. នៅចក្រភពអង់គ្លេស ក្រុមប្រឹក្សាភិបាលយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុក ប្រមូលទិន្នន័យក្នុងមូលដ្ឋានពាក់ព័ន្ធនឹងការចាប់ខ្លួន និង ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។ បច្ចុប្បន្នមានការផ្តោតសំខាន់លើការកែលម្អរបៀបស៊ើបអង្កេត និងចោទប្រកាន់បទល្មើសរំលោភសេពសន្ថវៈ។ នគរបាលដែលដើរតួនាទីជាស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌជាសមាជិកមួយនៃក្រុមប្រឹក្សាភិបាលយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិ និងក្រុមប្រឹក្សាភិបាលយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់មូលដ្ឋាន។

**ប្រអប់ ១៥**

នៅចក្រភពអង់គ្លេស អាជ្ញាធរជំនុំជម្រះទោស ផលិតរបាយការណ៍អនុវត្តន៍ការងារប្រចាំឆ្នាំស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលគូសបញ្ជាក់ពីចំនួនករណីដែលត្រូវបានកាត់ទោស និងលទ្ធផលដែលទទួលបាន។ ការប្រមូលទិន្នន័យទាំងនេះបានកែលម្អការកំណត់អត្តសញ្ញាណ ការចោទប្រកាន់ និងការកាត់ទោសបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

## សូចនាករ

ថ្នាក់ដឹកនាំនគរបាល គួរកសាងការយល់ដឹងអំពីសូចនាករថ្នាក់ជាតិសម្រាប់ការផ្ទៀងផ្ទាត់ព័ត៌មានដែលពួកគេអាចរួមចំណែកក្នុងការបង្កើតទិដ្ឋភាពរួមស្តីពីការអនុវត្តការងាររបស់ស្ថាប័នក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខ និងលទ្ធផលសម្រាប់ជនរងគ្រោះក្នុងដំណើរការយុត្តិធម៌។ ឧ.សូចនាកររួមមានអវត្តមានរបស់ជនរងគ្រោះក្នុងបន្ទប់សវនាការ នគរបាលមិនផ្តល់ភស្តុតាងវីដេអូដែលមានដែលនាំទៅរកការបញ្ឈប់សំណុំរឿងដោយចៅក្រម ឬការមិនទទួលបានភស្តុតាងបណ្តាញសង្គមដែលមាន និងការទប់ស្កាត់ការលាតត្រដាងសម្ភារ/ឯកសារដែលមិនបានប្រើប្រាស់។

នៅចក្រភពអង់គ្លេស ក្រុមប្រឹក្សាភិបាលយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិបានកំណត់អាទិភាពជាតិសម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលបន្ទាប់មកត្រូវបានដាក់ឱ្យក្រុមប្រឹក្សាយុត្តិធម៌ព្រហ្មទណ្ឌតាមមូលដ្ឋាន គ្រប់គ្រង និងអនុវត្ត។

សូមមើល ជំពូកទី ១០ (ការកសាងស្ថាប័ន)ផងដែរ សម្រាប់ការពិភាក្សាបន្ថែមស្តីពីការប្រមូលទិន្នន័យដែលគិតគូរពីយេនឌ័រដោយស្ថាប័ននគរបាល។

### ការបង្កប់ការអនុវត្តល្អក្នុងទម្រង់ជាការសហការគ្នាក្នុងការប្រមូលភស្តុតាង ដោយនគរបាល និងអយ្យការក្នុងគោលនយោបាយនីតិវិធីនិងបទបញ្ញត្តិគាំទ្រ(ក្នុងករណីសមស្រប)។

ថ្នាក់ដឹកនាំនគរបាលគួរពិនិត្យថាតើមានការណែនាំក្នុងមូលដ្ឋាន ស្តីពីការប្រមូលភស្តុតាងសម្រាប់ឱ្យនគរបាល និងអយ្យការបង្កើនការយល់ដឹងអំពីការទទួលខុសត្រូវរបស់ស្ថាប័ន លើកស្ទួយវប្បធម៌នៃកិច្ចសហការប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជានាការអនុលោមតាមការអនុវត្តល្អបំផុត។ ប្រសិនបើគ្មានការណែនាំក្នុងមូលដ្ឋាន អ្នកអាចពិចារណាថាតើគួរមានកិច្ចព្រមព្រៀងដើម្បីកែលម្អការអនុវត្តក្នុងមូលដ្ឋាន ឬទេ។ ថ្នាក់ដឹកនាំនគរបាលគួរពិចារណាសហការជាមួយអយ្យការដើម្បីកែលម្អរបៀបធ្វើការជាមួយគ្នា។

៤. នៅចក្រភពអង់គ្លេស ក្រោយការទទួលស្គាល់ថា នគរបាល និងអយ្យការត្រូវសហការគ្នាដោះស្រាយការរំលោភបំពានក្នុងគ្រួសារ នគរបាលត្រូវផ្តល់តារាងត្រួតពិនិត្យភស្តុតាងរួមដែលបានបំពេញរួចជូនសេវាអយ្យការ Crown ក្នុងករណីរំលោភបំពាន ក្នុងគ្រួសារនីមួយៗ ដែលចាំបាច់ត្រូវមានការណែនាំពីការចោទប្រកាន់ឬការសម្រេចពីការចោទប្រកាន់។

## ប្រអប់ ១៩

### ឧទាហរណ៍នៅចក្រភពអង់គ្លេស ៖ តារាងត្រួតពិនិត្យភស្តុតាងរួម

តារាងត្រួតពិនិត្យនេះត្រូវបានបង្កើតឡើងដើម្បីធានាថា នគរបាល និងអយ្យការ ពិចារណាជិតដល់លើបទល្មើសរំលោភបំពានក្នុងគ្រួសារ ហើយពួកគេសហការគ្នាអនុវត្តវិធានការផ្សេងទៀតដើម្បីកែលម្អការផ្តន្ទាទោសករណីរំលោភបំពានក្នុងគ្រួសារ។

អត្រាកាត់ទោសក្នុងតំបន់មួយចំនួនកើនឡើងជិត ១០% តាមរយៈការប្រើប្រាស់បច្ចេកទេសដែលបានបង្កើតឡើងក្នុងគម្រោងសាកល្បងនៅរយៈពេល ២ ឆ្នាំកន្លងមក រួមទាំងការផ្តល់លទ្ធភាពឱ្យសាក្សីផ្តល់ភស្តុតាងពីខាងក្រោយរបាំង។

វិធានការកាត់ទោសថ្មីត្រូវបានបង្កើតឡើងក្នុងគម្រោងសាកល្បងរបស់សេវាអយ្យការ Crown នៅទីក្រុងឡុងដ៍ Nottingham និង Yorkshire តាំងពីឆ្នាំ ២០១៦។ វិធានការទាំងនោះរួមមាន ៖

- ការធានាថា ជនរងគ្រោះអាចទៅកាន់តុលាការមុនការជំនុំជម្រះដើម្បីឱ្យពួកគេស៊ាំនឹងមជ្ឈដ្ឋានជុំវិញ។
- ការអនុញ្ញាតឱ្យជនរងគ្រោះ (ឱ្យតែតុលាការអនុញ្ញាត) ផ្តល់ភស្តុតាងពីខាងក្រោយរបាំង។
- ការផ្តល់ច្រកចូលបន្ទប់សវនាការដោយឡែកសម្រាប់ជនរងគ្រោះ និងជនល្មើស (ប្រសិនបើអាច) និងកន្លែងថែទាំកុមារ។
- ការគាំទ្រកាន់តែប្រសើរដោយទីប្រឹក្សាឯករាជ្យផ្នែកការរំលោភបំពានក្នុងគ្រួសារ (IDVA) ដើម្បីគាំទ្រដល់ជនរងគ្រោះ[574]។

តារាងត្រួតពិនិត្យភស្តុតាងរួមគ្នាជាឧបករណ៍ដ៏មានប្រយោជន៍ដែលថ្នាក់ដឹកនាំនគរបាលអាចកែសម្រួលឱ្យសមស្របទៅនឹងការអនុវត្តការងារក្នុងមូលដ្ឋាននិងមានតម្រុយជាច្រើនពាក់ព័ន្ធនឹងការប្រមូលភស្តុតាងសម្រាប់នគរបាល និងការណែនាំសម្រាប់អយ្យការដែលពិនិត្យឡើងវិញលើករណីទាំងនេះ។ តារាងនេះអាចប្រើប្រាស់ជាឧបករណ៍សម្រាប់ផ្លាស់ប្តូរវប្បធម៌នៃការស្តីបន្ទោសជនរងគ្រោះ និងផ្តោតលើជនបង្កដែលរងការចោទប្រកាន់។

តម្រុយទាំងនេះគឺដើម្បីធានាថា មានការចេញសេចក្តីសម្រេចទាន់ពេលវេលា មានការបំពេញតារាងត្រួតពិនិត្យការចោទប្រកាន់សម្រាប់ដើមបណ្តឹងម្នាក់ៗដែលពាក់ព័ន្ធនឹងមនុស្សលើសពីម្នាក់ហើយការចោទប្រកាន់ជារួមត្រូវបានពិចារណាតាមរយៈការវាយតម្លៃភស្តុតាងដែលមានទាំងអស់រួមទាំងតួនាទីនិងឥរិយាបថរបស់ជនបង្កដែលរងការចោទប្រកាន់។ សុវត្ថិភាពរបស់ដើមបណ្តឹង និងកូនៗរបស់គាត់ ឬមនុស្សក្នុងបន្ទុកផ្សេងទៀត ក៏ត្រូវបានរៀបរាប់លម្អិតជាការពិចារណាបឋមផងដែរហើយជនរងគ្រោះត្រូវបានបញ្ជូនទៅរកសេវាគាំទ្រពីអ្នកឯកទេសឱ្យបានឆាប់បំផុត។

## ដំណោះស្រាយផ្អែកតាមសហគមន៍

ថ្នាក់ដឹកនាំនគរបាលគួរដឹងថា បុគ្គលិករបស់ខ្លួនពាក់ព័ន្ធជាមួយសហគមន៍ដែលពួកគេកំពុងផ្តល់សេវាជូនដើម្បីជួយដល់ការកំណត់ដំណោះស្រាយផ្អែកតាមសហគមន៍សំដៅដោះស្រាយបទល្មើសដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ១. ការចុះទៅទីគោរពបូជាក្នុង

573. "ការប្រមូលភស្តុតាង" តារាងត្រួតពិនិត្យភស្តុតាងរួមដោយនគរបាល និងសេវាអយ្យការ crown" គោលការណែនាំសម្រាប់អយ្យការស្តីពីការរំលោភបំពានក្នុងគ្រួសារ (២០២០) សេវាអយ្យការ Crown : https://www.cps.gov.uk/sites/default/files/documents/publications/npcc_cps_joint_evidence_gathering_checklist_2015.docm

574. សេវាអយ្យការ Crown ពង្រីកគម្រោងកាត់ទោសអំពើហិង្សាក្នុងគ្រួសារប្រកបដោយប្រសិទ្ធភាព។ បច្ចេកទេសដែលបានបង្កើតឡើងក្នុងគម្រោងសាកល្បង បានបង្កើនអត្រាផ្តន្ទាទោស (២០១៨) Bowcott, O. for The Guardian, at: https://www.theguardian.com/law/2018/dec/18/cps-to-extendeffective-domestic-violence-prosecution-scheme

សាសនាអាចឱ្យថ្នាក់ដឹកនាំនគរបាលផ្សារភ្ជាប់ជាមួយប្រធានសហគមន៍រួមទាំងស្ត្រីចំណាស់ ដើម្បីផ្តល់ព័ត៌មានដល់សហគមន៍ស្តីពីឥរិយាបថដែលអាចទទួលយកបានក្នុងសង្គម ហើយសហគមន៍អាចផ្តល់មូលដ្ឋានព័ត៌មានដល់អភិក្រមសេវានគរបាលក្នុងមូលដ្ឋាន។

ភាពជោគជ័យយូរអង្វែងក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី អាស្រ័យលើ អភិក្រមគ្រប់ជ្រុងជ្រោយនៅគ្រប់កម្រិត (នៃគំរូអេកូឡូស៊ី) (Krug et al., 2002:16)។ Krug et al បានផ្តល់ទិដ្ឋភាពរួមស្តីពីកត្តាពាក់ព័ន្ធ។គំរូអេកូឡូស៊ីផ្តល់ការវិភាគជារួមលើកត្តាផ្សេងៗដែលរួមចំណែកដល់ការសម្រេចចិត្តរបស់នរណាម្នាក់ក្នុងការប្រើប្រាស់អំពើហិង្សា (Heise, 1998)។ គំរូនេះបង្ហាញថា ឥរិយាបថហិង្សាកើតចេញពីទំនាក់ទំនងស្មុគស្មាញនៃឌីណាមិកបុគ្គល ទំនាក់ទំនង សមូហភាព និងឌីណាមិកសង្គម។ គំរូនេះអះអាងថា អំពើហិង្សាមិនកើតចេញពីកត្តាមួយក្នុងដែនឥទ្ធិពលមួយនៃដែនឥទ្ធិពលទាំង ៤ នោះទេ ប៉ុន្តែមានលក្ខណៈស្មុគស្មាញ ព្រោះមានកត្តាចម្រុះក្នុងដែនផ្សេងៗដែលជះឥទ្ធិពលលើឥរិយាបថអាកប្បកិរិយា និងជម្រើសរបស់មនុស្សម្នាក់។
មូលដ្ឋានគ្រឹះនៃដំណោះស្រាយផ្អែកតាមសហគមន៍ គឺភាពចាំបាច់ក្នុងការកៀរគរសហគមន៍។ គោលការណ៍ណែនាំសម្រាប់ការកៀរគរសហគមន៍ រួមមាន ៖

- **ការទប់ស្កាត់** ៖ ដើម្បីជះឥទ្ធិពលលើការផ្លាស់ប្តូរយូរអង្វែង និងមាននិរន្តរភាព ស្ថាប័នត្រូវមានជំហរបែបប្រតិសកម្ម ជាជាងជំហរបែបប្រតិកម្ម។ ការទប់ស្កាត់បឋមរួមមានការដោះស្រាយឫសគល់នៃអំពើហិង្សាលើស្ត្រីតាមរយៈការវិភាគផ្អែកលើយេនឌ័រស្តីពីមូលហេតុដែលនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារ។ ពោលគឺការទទួលស្គាល់ស្ថានភាពរបស់ស្ត្រីក្នុងសង្គមអតុល្យភាពអំណាច និងតួនាទីយេនឌ័រដ៏តឹងរ៉ឹងដែលជាឫសគល់នៃអំពើហិង្សាក្នុងគ្រួសារ។
- ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារជារួម ទាមទារការប្តេជ្ញាចិត្ត និងការចូលរួមរបស់សហគមន៍ទាំងមូល។ ពោលគឺស្ថាប័ននានាត្រូវទទួលស្គាល់ប្រវត្តិ វប្បធម៌ និងទំនាក់ទំនងសាំញ៉ាំដែលជះឥទ្ធិពលលើសហគមន៍ និងបុគ្គលដែលរស់នៅក្នុងសហគមន៍ និងរួមបញ្ចូលនគរបាល ឬអ្នកផ្តល់សេវាថែទាំសុខភាព។ល។ ដើម្បីបង្កើតសន្ទុះគ្រប់គ្រាន់សម្រាប់ការផ្លាស់ប្តូរ។
- **ដំណើរការនៃការផ្លាស់ប្តូរសង្គម** ៖ ការផ្លាស់ប្តូរបទដ្ឋានសហគមន៍ជាដំណើរការមួយ មិនមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកមួយនោះទេ។ គំនិតផ្តួចផ្តើមដែលផ្អែកលើការយល់ពីរបៀបដែលបុគ្គលឆ្លងកាត់ដំណើរការផ្លាស់ប្តូរអាចមានប្រសិទ្ធភាពជាងការផ្តល់សារចៃដន្យដល់សហគមន៍។ ដូច្នេះ ការប្រឹងប្រែងជះឥទ្ធិពលលើការផ្លាស់ប្តូរក្នុងសង្គម ត្រូវធ្វើឡើងជាប្រព័ន្ធ។ ស្ថាប័នដែលខិតខំបំពេញការងារនេះអាចក្លាយជាអ្នកសម្របសម្រួលយ៉ាងជំនាញលើការផ្លាស់ប្តូរបុគ្គល និងការផ្លាស់ប្តូរជារួមតាមរយៈការធ្វើការជាមួយ ការណែនាំ ការសម្របសម្រួល និងការគាំទ្រដល់សហគមន៍ឆ្ពោះទៅរកការផ្លាស់ប្តូរ។
- **ការប្រឈមនឹងគំនិតនានាជាច្រើនលើកច្រើនសា** ៖ ត្រូវផ្តល់សារដែលពង្រឹងឱ្យគ្នាទៅវិញទៅមក និងជាប្រចាំដល់សមាជិកសហគមន៍ ចេញពីប្រភពចម្រុះក្នុងរយៈពេលជាប់លាប់មួយ។
- **ក្របខណ្ឌសិទ្ធិមនុស្ស** ៖ អភិក្រមផ្អែកតាមសិទ្ធិដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ជាការបង្កើនភាពអង់អាចរបស់ស្ត្រី និងសហគមន៍។
- **ភាពម្ចាស់ការរបស់សហគមន៍** ៖ គម្រោងដែលមានប្រសិទ្ធភាពដែលផ្តោតលើការផ្លាស់ប្តូរជំនឿ និងការអនុវត្តដែលបង្កគ្រោះថ្នាក់ក្នុងសហគមន៍ ត្រូវតែចូលរួម និងដឹកនាំដោយសមាជិកសហគមន៍នោះ[575]។

ថ្នាក់ដឹកនាំនគរបាលនឹងកត់សម្គាល់ថា ភាពម្ចាស់ការ និងការដឹកនាំរបស់សហគមន៍ អាចជំរុញការផ្លាស់ប្តូរ និងជះឥទ្ធិពលលើការឆ្លើយតបរបស់សង្គមទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការបង្កើនការយល់ដឹង។

575. "ការអនុវត្តល្អក្នុងការបង្កើតអភិក្រមផ្អែកតាមសហគមន៍ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ"ឯកសារជំនាញកិច្ចប្រជុំក្រុមអ្នកជំនាញដែលរៀបចំឡើងដោយផ្នែកបង្កើនវឌ្ឍនភាពស្ត្រីរបស់អង្គការសហប្រជាជាតិ ក្រោមកិច្ចសហការជាមួយ UNODC (ថ្ងៃទី ១៧-២៩ ខែឧសភា ឆ្នាំ ២០០៥ ទីក្រុងវីយែន ប្រទេសអូទ្រីស) រៀបចំឡើងដោយ Lori Michau Raising Voices Kampala, Uganda, at: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/michau.community.pdf

**ប្រអប់ ២០**

នៅប្រទេសបង់ក្លាដេសការសិក្សាដ៏សំខាន់មួយបានភ្ជាប់ការពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងបានកំណត់ការស្នើយោបល់ជាក់លាក់មួយចំនួន ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[576]។ យោបល់ទាំងនេះអាចចែកចេញជាការពង្រឹង និងការកែប្រែរចនាសម្ព័ន្ធមានស្រាប់ និងការបង្កើតរចនាសម្ព័ន្ធថ្មី។

ការសិក្សានេះបង្ហាញថា ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅតែជាការលំបាក ព្រោះរចនាសម្ព័ន្ធបិតាធិបតេយ្យនិងមនោគមវិជ្ជាបានបង្កើតវប្បធម៌ស្ងៀមស្ងាត់ជុំវិញអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ស្ថានភាពនេះកាន់តែដុនដាប ដោយសារកង្វះធនធានឌីណាមិកអំណាចក្នុងភូមិ និងលើសពីនេះទៀត អនុគ្រោះដល់ជនបង្ក និងអំពើពុករលួយនៅគ្រប់ជាន់ថ្នាក់។ដំណោះស្រាយដែលផ្តល់ដោយប្រជាជនក្នុងសហគមន៍រួមបញ្ចូលក្របខណ្ឌអេកូឡូស៊ីគ្រប់កម្រិត (ឧ. បុគ្គល គូស្វាមីភរិយា គ្រួសារ សហគមន៍ និងសង្គម) និងគ្របដណ្តប់លើការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

អ្នកចូលរួមក្នុងការសិក្សានេះ បានផ្តល់ចំណេះដឹង និងយោបល់ថ្មីៗសម្រាប់ដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។អ្នកផ្តល់ព័ត៌មានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការងារទប់ស្កាត់ដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រសមធម៌ និងការផ្លាស់ប្តូរឥរិយាបថ។ ខណៈដែលស្ត្រី និងបុរសសុទ្ធតែបានលើកឡើងពីយុទ្ធនាការសហគមន៍ ស្ត្រីបានស្នើឱ្យចាត់ទុកអ្នកដែលអាចក្លាយជាជនបង្ក និងបុរស និងក្មេងប្រុស ជាសម្ព័ន្ធមិត្ត។

ស្ត្រីយល់ថាចាំបាច់ត្រូវជំរុញការចូលរួមរបស់ប្រជាជនក្នុងមូលដ្ឋាន ជាពិសេសក្មេងប្រុស និងបុរស ក្លឹបយុវជន សាលារៀន វិហារឥស្លាម អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងរដ្ឋាភិបាលកម្រិតខ្ពស់។ ស្ត្រីបានលើកឡើងពីវិធីចម្រុះនៃការជំរុញការផ្លាស់ប្តូរនេះ ដូចជា ការជួបជុំក្រៅផ្លូវការ កិច្ចប្រជុំ សិក្ខាសាលា វគ្គដែលរៀបចំឡើងដោយសមាជិកនៃក្រុមអង្គការមិនមែនរដ្ឋាភិបាល រឿងកំប្លែងខ្លី ការសម្តែងល្ខោនតាមដងផ្លូវ ការបញ្ចាំងភាពយន្ត និងការផ្ញើសារតាមទូរស័ព្ទចល័ត។ ខណៈដែលបុរសលើកឡើងពីការកាត់បន្ថយភាពក្រីក្រ និងជាពិសេសឱកាសការងាររបស់បុរសសម្រាប់ជាយុទ្ធសាស្ត្រទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ស្ត្រីស្នើឱ្យមានការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ពួកគេ និងបង្កើនសិទ្ធិអំណាចក្នុងផ្នែកផ្សេងទៀតសម្រាប់ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

អនុសាសន៍របស់ស្ត្រីស៊ីសង្វាក់គ្នានឹងការពិនិត្យនាពេលថ្មីៗនេះលើអន្តរាគមន៍ ១៤ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលបង្ហាញថាការប្រចាប់បញ្ចូលគ្នានូវការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ក្មេងស្រីជំទង់ជាមួយនឹងអន្តរាគមន៍សម្រាប់ការកសាងប្រសិទ្ធផលផ្ទាល់ខ្លួន និងជំនាញផ្សេងទៀត បានកាត់បន្ថយអំពើហិង្សាលើស្ត្រីក្មេងស្រីជំទង់[577]។

មានការលើកឡើងពីវិធានការមួយចំនួនសម្រាប់ការកែប្រែរចនាសម្ព័ន្ធឡើងវិញ និងការពង្រឹងប្រព័ន្ធយុត្តិធម៌ផ្លូវការនិងក្រៅផ្លូវការដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងការរងគ្រោះឡើងវិញឬការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តឡើងវិញលើជនរងគ្រោះក្នុងដំណើរការស្វែងរកដំណោះស្រាយ។ ស្ត្រី និងក្មេងស្រីបានកំណត់ភាពត្រួតត្រារបស់បុរសក្នុងប្រព័ន្ធនេះជាកត្តារាំងស្ទះការឆ្លើយតបសមស្របទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ស្ត្រី និងក្មេងស្រីណែនាំថា ការបង្កើនសិទ្ធិអំណាចរបស់សមាជិក UP សម្រាប់ការពារជនដែលរងការបំពារបំពាន ការមានតំណាងជាស្ត្រីកាន់តែច្រើនក្នុង shalish ការមាន matbor ជាស្ត្រីដឹកនាំ shalish ការអនុញ្ញាតឱ្យស្ត្រីធ្វើជាសាក្សីនៅគ្រប់កម្រិតការបង្កើតបរិយាកាសអំណោយផលសម្រាប់ឱ្យជនរងគ្រោះបង្ហាញករណីរបស់ខ្លួននិងបង្ហាញតម្រូវការផ្ទាល់ខ្លួន។ អភិបាលកិច្ចល្អគួបផ្សំនឹងវិធានការតឹងរ៉ឹងនៃការដាក់ទោស (ឧ. ការពិន័យជាប្រាក់ ការផ្អាក/ព្យួរឬការបណ្តេញចោល) និងរង្វាន់ជាអ្វីដែលលើកឡើងដោយថ្នាក់ដឹកនាំសហគមន៍នគរបាលនិងមេធាវីសម្រាប់ការដោះស្រាយអំពើពុករលួយ។

576. ពីអំពើហិង្សាឆ្ពោះទៅរកគោលនយោបាយ ៖ ការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី និងក្មេងស្រីនៅប្រទេសបង់ក្លាដេស (២០១៣) របាយការណ៍ដាក់ជូនក្រសួងអភិវឌ្ឍន៍អន្តរជាតិ ដោយ icddr, b ក្រោមកិច្ចសហការជាមួយក្រុមប្រឹក្សាប្រជាជន https://assets.publishing.service.gov.uk/media/57a08a16ed915d3cfd0005a4/VAWG_Bangladesh_Final_Report.pdf

577. ការពិនិត្យឡើងវិញលើកស្តុតាងស្តីពីអន្តរាគមន៍ពហុវិស័យដើម្បីកាត់បន្ថយអំពើហិង្សាលើក្មេងស្រីជំទង់ (២០១៣) Blanc, A.K.,Melnikas, A., Chau, M., and Stoner, M. Integrated Approaches to Improving the Lives of Adolescent Girls Issue Papers Series: Girl Hub.

ការមាក់ងាយថ្នាក់ដឹកនាំភូមិដែលពុករលួយ តាមរយៈរឿងកំប្លែងខ្លី ក៏ត្រូវបានលើកឡើងផងដែរ។ តាមរយៈការលើកឡើងពីកង្វះការគ្រប់គ្រងរបស់ស្ត្រីលើការស្វែងរកដំណើរការដោះស្រាយទាំងក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ និងក្រៅផ្លូវការ ស្ត្រី និងក្មេងស្រីបានគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្តល់សំឡេងដល់ជនរងគ្រោះ។ គោលគំនិតនៃការផ្តល់សំឡេងស៊ីសង្វាក់គ្នានឹងអភិក្រមគោលជំហរជនស្ត្រីនិយមដែលចាប់ផ្តើមពីការយល់ថាសមាជិកសង្គមដែលមិនសូវមានអំណាច ប្រឈមនឹងតថភាពផ្សេងៗ ដោយសារការគៀបសង្កត់លើពួកគេ (Belknap, 2007)។

ការបង្ហាញ និងការយល់ពីទស្សនៈនេះជាកត្តាសំខាន់សម្រាប់ការបង្កើត និងអនុវត្តវិធានការសង្គមជំនួសមុខឱ្យជនរងគ្រោះ។ ប្រជាជននៅកម្រិតសហគមន៍មិនយល់ពីច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ (ការទប់ស្កាត់ និងការការពារ) (២០១០) ទេ។ ស្ត្រីក្នុងការសិក្សារបស់យើងបានគូសបញ្ជាក់យ៉ាងត្រឹមត្រូវថា ក្នុងស្ថានភាពបច្ចុប្បន្ន ស្ត្រីប្រឈមនឹងហានិភ័យខ្លាំងបំផុតក្នុងការស្នើសុំដីកាការពារដើម្បីអាចស្នាក់នៅក្នុងផ្ទះដែលនាងធ្លាប់រស់នៅជាមួយស្វាមីបាន។ ក្នុងការអនុវត្តច្បាប់នេះចាំបាច់ត្រូវពិចារណាពីចំណុចនេះ។ ការធានាសុវត្ថិភាពរបស់ស្ត្រីដែលរងការរំលោភបំពាន គួរតែចំណុចស្នូលនៃអន្តរាគមន៍នានា។ ចាំបាច់ត្រូវអនុវត្តយុទ្ធសាស្ត្រដែលបានបង្កើតឡើងសម្រាប់ចំណុចនេះ ក្នុងពេល និងក្រោយពេលស្វែងរកជំនួយ ដើម្បីកុំឱ្យជនរងគ្រោះ ទទួលរងគ្រោះថ្នាក់ជាថ្មី។

**ប្រអប់ ២១**

មកទល់បច្ចុប្បន្ននេះ គំរូផ្អែកតាមសហគមន៍ដ៏ជោគជ័យបំផុតមួយក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺអភិក្រមដែលបង្កើតឡើងដោយ Tostan ដែលជាអង្គការមិនមែនរដ្ឋាភិបាលនៅ Thies ប្រទេសសេណេហ្គាល់។ អន្តរាគមន៍នេះខិតខំកាត់បន្ថយការកាត់ប្រដាប់បន្តពូជស្ត្រី តាមរយៈកម្មវិធីអប់រំតាមមូលដ្ឋាន និងត្រូវបានយកទៅអនុវត្តបន្តក្នុងប្រទេសជាច្រើននៅអនុតំបន់អាហ្វ្រិកសាហារ៉ា។

ប្រធានបទក្នុងកម្មវិធីនេះរួមមានសុខភាពអក្ខរភាពនិងសិទ្ធិមនុស្សខណៈដែលមធ្យោបាយបែបចូលរួមអនុញ្ញាតឱ្យសមាជិកសហគមន៍ជ្រើសរើសបញ្ហា ដែលត្រូវបានចាត់ទុកជាអាទិភាពក្នុងភូមិរបស់ពួកគេ។ ការកាត់ប្រដាប់បន្តពូជស្ត្រី និងអំពើហិង្សាលើដៃគូស្និទ្ធស្នាលសុទ្ធតែជាបញ្ហាសំខាន់។ ក្នុងករណីជាច្រើន ភូមិនានាបានសន្យាបោះបង់ការកាត់ប្រដាប់បន្តពូជស្ត្រី និងលើកទឹកចិត្តឱ្យភូមិជិតខាងអនុវត្តដូចគ្នា។

ការវាយតម្លៃដូចគ្នានឹងការធ្វើពិសោធន៍លើកម្មវិធីនេះក្នុងប្រទេសសេណេហ្គាល់រកឃើញថាស្ត្រីក្នុងភូមិដែលមានអន្តរាគមន៍នេះរាយការណ៍ពីការកើតមានករណីអំពើហិង្សាតិចតួចបំផុតក្នុងរយៈពេល ១២ ខែកន្លងមក ធៀបនឹងស្ត្រីក្នុងភូមិដែលគ្មានអន្តរាគមន៍នេះ។ ម្តាយរបស់ក្មេងស្រី (អាយុ ០-១០ ឆ្នាំ) ក៏លើកឡើងផងដែរថាមិនសូវមានការកាត់ប្រដាប់បន្តពូជស្ត្រីក្នុងភូមិដែលមានអន្តរាគមន៍។ គួរកត់សម្គាល់ថា ស្ត្រីក្នុងភូមិដែលស្ថិតក្នុងអន្តរាគមន៍ដែលមិនពាក់ព័ន្ធផ្ទាល់ក្នុងកម្មវិធីអប់រំ Tostan ក៏លើកឡើងផងដែរថា មិនសូវមានករណីអំពើហិង្សា និងការកាត់ប្រដាប់បន្តពូជស្ត្រី។ មានន័យថា កម្មវិធីនេះបានពង្រីកផលផលប៉ះពាល់ដោយជោគជ័យ[578]។

**វគ្គបណ្តុះបណ្តាលជារួមសម្រាប់នគរបាល និងអយ្យការដើម្បីពង្រឹងការសហការគ្នា និងការដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព** នគរបាលនិងអយ្យការគួរទទួលបានការបណ្តុះបណ្តាលជារួម ហើយប្រសិនបើអាចអនុវត្តបាន គួរអញ្ជើញឱ្យសមាជិកមកពីស្ថាប័នផ្សេងទៀតក្នុងវិស័យយុត្តិធម៌ និងវិស័យសន្តិសុខចូលរួមដើម្បីបង្កើនការយល់ដឹងពីតួនាទីរបស់ពួកគេ[579]។

578. កម្មវិធី Tostan ការវាយតម្លៃកម្មវិធីអប់រំតាមសហគមន៍នៅប្រទេសសេណេហ្គាល់ Diop, N. J., Faye, M. M., Moreau, A., Cabral, J., & Benga, H. (2004). New York: Population Council. https://namati.org/resources/the-tostan-program-evaluation-of-a-community-based-education-program-in-senegal/

579. UN Women ប្រចាំនៅប្រទេសអេត្យូពី បាន និងកំពុងខិតខំកសាងសមត្ថភាពរបស់វិស័យយុត្តិធម៌ (នគរបាល អយ្យការរដ្ឋ និងចៅក្រម) ហើយអភិក្រមនៃការកៀរគរស្ថាប័នអនុវត្តន៍ច្បាប់ទាំង ៣ នេះ ត្រូវបានកំណត់ដោយរដ្ឋាភិបាលថ្នាក់តំបន់ជាអភិក្រមថ្មីមួយក្នុងដោះស្រាយបញ្ហាប្រឈមរួមឱ្យបានឆាប់រហ័ស។

## សូចនាករយោងសម្រាប់នគរបាលដែលផ្តល់សេវាសំខាន់ៗ៖ ការគាំទ្រ និងជំនួយ

ការសម្របសម្រួលមានទម្រង់ផ្សេងៗ ដោយការសម្របសម្រួលខ្លះមានលក្ខណៈផ្លូវការ និងមានភាពពាក់ព័ន្ធជាង សម្រាប់ការតាក់តែងគោលនយោបាយ ហើយការសម្របសម្រួលផ្សេងទៀតមិនសូវមានលក្ខណៈផ្លូវការ និងផ្តោតសំខាន់លើការជំរុញការចូលរួមរបស់ជនរងគ្រោះម្នាក់ៗឱ្យកាន់តែមានប្រសិទ្ធភាព។ ការឆ្លើយតបដោយមានការសម្របសម្រួលជាកត្តាសំខាន់ ព្រោះការរក្សាសុវត្ថិភាពរបស់ជនរងគ្រោះពីអំពើហិង្សានិងការរក្សាការទទួលខុសត្រូវរបស់ជនល្មើសមានប្រសិទ្ធភាពជាងការណ៍ដែលវិស័យផ្សេងៗក្នុងសង្គមធ្វើការដាច់ដោយឡែកពីគ្នាដើម្បីដោះស្រាយបញ្ហានេះ។ ការសម្របសម្រួលផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះទីភ្នាក់ងារនិងស្ថាប័នដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងសហគមន៍របស់ពួកគេ[580]។

ដូចការពិភាក្សាក្នុងជំពូកទី២កញ្ចប់សេវាសំខាន់ៗតម្រូវឱ្យសេវាយុត្តិធម៌ និងសេវាគាំទ្រទាំងអស់សម្រាប់ជនរងគ្រោះមានលក្ខណៈទូទៅនិងសកម្មភាពរួមដើម្បីធានាផលប៉ះពាល់ជាអតិបរមា។ លក្ខណៈទូទៅ និងសកម្មភាពរួមទាំងនេះអាចអនុវត្តបានដោយមិនគិតពីវិស័យ"ជាក់លាក់" ដែលអាចឆ្លើយតបនឹងស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា។អំណានខាងក្រោមត្រូវបានដកស្រង់ចេញពីលក្ខណៈទូទៅ និងសកម្មភាពរួមនៃកញ្ចប់សេវាសំខាន់ៗ និងផ្តល់សូចនាករយោងមួយចំនួនសម្រាប់សកម្មភាពរបស់នគរបាលនៅពេលខិតខំផ្តល់សេវាសំខាន់ៗក្នុងការឆ្លើយតបដោយមានការសម្របសម្រួលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីនិងដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងគិតគូរពីយេនឌ័រ។

580. ម៉ូឌុលទី ៥ ៖ ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល កញ្ចប់សេវាសំខាន់ៗ។

# ៩

## កំណត់សម្គាល់ និងអំណានបន្ថែម


1 Statement from Phumzile Mlambo-Ngcuka for the International Day for the Elimination of Violence against Women (2018). UN Women. https://unwomen.org.au/statement-from-phumzile-mlambo-ngcuka-for-the-international-day-for-the-elimination-of-violence-against-women/

2 General Recommendation No. 28 on the Core Obligations of States Parties under Article 2 of the Convention on the Elimination of All Forms of Discrimination against Women (2010). UN Doc CEDAW/C/2010/47/GC.2. https://www2.ohchr.org/english/bodies/cedaw/docs/CEDAW-C-2010-47-GC2.pdf

3 General recommendation No. 25, on Article 4, Paragraph 1, of the Convention on the Elimination of All Forms of Discrimination against Women, on Temporary Special Measures. OHCHR https://www.un.org/womenwatch/daw/cedaw/recommendations/General%20recommendation%2025%20%28English%29.pdf

4 About the CPS. The Crown Prosecution Service. https://www.cps.gov.uk/about-cps

5 Training Manual for Judges and Prosecutors on Ensuring Women's Access to Justice. Partnership for Good Governance. European Union https://www.ohchr.org/Documents/Issues/Women/WRGS/TrainingManualAccessJustice_EN.pdf

6 A Practitioner's Toolkit on Women's Access to Justice Programming. UN Women 2018. https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

7 Implementation Guide Essential services package for women and girls subject to violence. UN Joint Global Programme on Essential Services for Women and Girls Subject to Violence (2015). UN Women.

8 UPR of IRAN – 34th session – November 2019 Fact sheet on discrimination against women in Iran, Minority Rights Group International. https://minorityrights.org/wp-content/uploads/2019/09/FACTSHEET-Discrimination-against-women-in-Iran-October-2019.pdf

9 Criminal Code of Armenia (2003). https://cis-legislation.com/document.fwx?rgn=7472

10 World Health Organization, Department of Reproductive Health and Research, London School of Hygiene and Tropical Medicine, South African Medical Research Council (2013). Global and regional estimates of violence against women: prevalence and health effects of intimate partner violence and non-partner sexual violence

11 Gender Mainstreaming for Health Managers: A Practical Approach / WHO Gender Analysis Tools. Facilitators' guide. Participant's notes (2011). WHO https://www.who.int/gender-equity-rights/knowledge/health_managers_guide/en/

12 World Population Review (2019) http://worldpopulationreview.com/countries/rape-statistics-by-country/

13 International Day on the Elimination of Violence against Women 25 November 2019. Absence of Consent Must Become the Global Standard for Definition of Rape. OHCHR https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25340&LangID=E

14 Global Study on Homicide (2019). UNODC. https://www.unodc.org/unodc/en/data-and-analysis/global-study-on-homicide.html

15 "National measures taken to prevent, investigate, prosecute and punish gender-related killings of women and girls" (2014). UNODC/CCPCJ/EG.8/2014/CRP.1. https://www.unodc.org/documents/justice-and-prison-reform/IEGM_GRK_BKK/UNODC.CCPCJ.EG.8.2014.CRP.1.pdf

16 Les Chiffres de Référence sur les Violences Faites aux Femmes (2019). Secrétariat d'Etat chargé de l'égalité entre les femmes et les hommes et de la lutte contre les discriminations. https://www.egalite-femmes-hommes.gouv.fr/le-secretariat-d-etat/

17 As Deaths Mount, France Tries to Get Serious About Domestic Violence (2019). Fourquet, L. for the New York Times https://www.nytimes.com/2019/09/03/world/europe/france-domestic-violence.html

18 Protocol on the handling of Female Genital Mutilation (FGM) offences between the National Police Chiefs' Council and the Crown Prosecution Service (2016). National Police Chief's Council. https://www.cps.gov.uk/sites/default/files/documents/publications/FGM-Protocol-june-2016.docx

19 Imkaan From the Margin to the Centre. Addressing Violence Against Women and Girls https://829ef90d074549b2b404cbea85f15fda.filesusr.com/ugd/2f475d_91a5eb3394374f24892ca1e1ebfeea2e.pdf

20 Effective Responses in Cases Involving VAWG: The Role of the Prosecutor Handbook on Effective Prosecution Responses to Violence against Women and Girls (2014). UNODC.https://www.unodc.org/

documents/justice-and-prison-reform/Handbook_on_effective_prosecution_responses_to_violence_against_women_and_girls.pdf

21 The Tip of the Iceberg. Sarkaria, N. and Campbell, G. for Counsel Magazine https://www.counselmagazine.co.uk/articles/tip-of-the-iceberg-the-family-court-ready-surge-activity-fgm

22 Compilation of good practices to reduce existing obstacles and facilitate women's access to justice (2015). Council of Europe Gender Equality Commission. https://edoc.coe.int/en/gender-equality/6695-gender-equality-commission-compilation-of-good-practices-to-reduce-existing-obstacles-and-facilitate-women-s-access-to-justice.html

23 European Probation Rules (2019). Canton, R. HM Inspectorate of Probation Academic Insights 2019/02 https://www.justiceinspectorates.gov.uk/hmiprobation/wp-content/uploads/sites/5/2019/03/Academic-Insights-Canton-Jan-19-final.pdf

24 United Nations Standard Minimum Rules for Non-custodial Measures (The Tokyo Rules), adopted by General Assembly resolution 45/110 of 14 December 1990. https://www.penalreform.org/priorities/alternatives-toimprisonment/international-standards/

25 England and Wales Chapter in Manual on the Law Relating to Violence against Women (2018), Sarkaria, N., and Campbell, G. European Lawyers Foundation. https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

26 OSCE-led Survey on Violence against Women: Experiences of Disadvantaged Women (2019). Organisation for the Security and Co-operation in Europe. https://www.osce.org/secretariat/430007?download=true

27 To Tackle Domestic Violence, Ukraine Looks to UNFPA's Mobile Assistance Teams (2019). UNFPA https://www.unfpa.org/news/tackle-domestic-violence-ukraine-looks-unfpa-mobile-assistance-teams

28 Cuidad Mujer, Secretaria de Inclusión Social. Gobierno de El Salvador. http://www.ciudadmujer.org/en/index.html

29 "Evidence gathering - Joint Police-CPS Evidence Checklist" Domestic Abuse Guidelines for Prosecutors (2020). Crown Prosecution Service. https://www.cps.gov.uk/sites/default/files/documents/publications/npcc_cps_joint_evidence_gathering_checklist_2015.docm

30 CPS to Extend Effective Domestic Violence Prosecution Scheme. Techniques Developed in Pilot Projects have Improved Conviction Rates (2018). Bowcott, O. for The Guardian. https://www.theguardian.com/law/2018/dec/18/cps-to-extend-effective-domestic-violence-prosecution-scheme

31 Good Practice in Designing a Community-based Approach to Prevent Domestic Violence Expert Paper: Expert Group Meeting Organized by UN Division for the Advancement of Women in Collaboration with UN Office on Drugs and Crime 17 to 20 May 2005 Vienna, Austria. Prepared by Lori Michau for Raising Voices. Kampala, Uganda. https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/michau.community.pdf

32 From Evidence to Policy: Addressing Gender-Based Violence against Women and Girls in Bangladesh: A Report Submitted to Department for International Development by: ICDDR,B in Collaboration with Population Council January 2013 https://assets.publishing.service.gov.uk/media/57a08a16ed915d3cfd0005a4/VAWG_Bangladesh_Final_Report.pdf

33 The TOSTAN Program. Evaluation of a Community based Education Program in Senegal. Diop, N. J., Faye, M. M., Moreau, A., Cabral, J., & Benga, H. (2004). New York: Population Council. https://namati.org/wp-content/uploads/2015/12/Tostan-Senegal-2004-evaluation.pdf

34 FGM and the relationship between the Family Courts and the Criminal Courts (2015). Sarkaria, N., and Campbell, G. International Family, law and Practice Journal.

35 Harmful Traditional Practices: Prevention, Protection, and Policing (2020). Campbell, G., Roberts, K.A., Sarkaria, N. Palgrave Macmillan.

36 Guidance Note for UNODC Staff Gender Mainstreaming in the Work of UNODC (2013). UNODC https://www.unodc.org/documents/Gender/UNODC-GuidanceNote-GenderMainstreaming.pdf

37 Global Study on Homicide (2013). UNODC. https://www.unodc.org/documents/data-and-analysis/statistics/GSH2013/2014_GLOBAL_HOMICIDE_BOOK_web.pdf

38 Women and the Criminal Justice System (2011). Mahony, T.H., Jacob, J., and Hobson, H. for the Government of Canada. https://www150.statcan.gc.ca/n1/en/pub/89-503-x/2015001/article/14785-eng.pdf?st=Nyr7c4ce

39 Towards Gender-Responsive Criminal Justice: Good practices from Southeast Asia in responding to violence against women (2018). Skinnider, E. Thailand Institute of Justice. https://icclr.org/wp-content/uploads/2019/06/Towards-Gender-Responsive-Criminal-Justice.pdf?x37853

40 Feasibility Study for a Convention against Domestic Violence (2008). Council of Europe, Committee of Ministers, 1037 Meeting, 8 October 2008 European Committee on Crime Problems.

41 Intersectionality and Beyond: Law, power and the politics of location (2009). Edited by Grabham, E., Herman, D., Cooper, D., and Krishnadas, J., Routledge-Cavendish.

42 The Trial of Rape. Understanding the Criminal Justice System Response to Sexual Violence in Thailand and Viet Nam (2017). UN Women, UNDP and UNODC. https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2019/08/ap-trial-of-rape_26aug2019_lowres-compressed.pdf?la=en&vs=1916

43 Manual on the Law Relating to Violence against Women England and Wales Greece Ireland Italy Northern Ireland Poland Spain (2018). European Lawyers Foundation and European Union. https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

44 Investigation, Protection, and Support Measures for GBV Victims (2019). Resource Book: Experience and Guidelines of the Korean Police. UNDP Seoul Policy Centre

45 A Review of the Evidence on Multi-sectoral Interventions to Reduce Violence against Adolescent Girls (2013)" Blanc, A.K., Melnikas, A., Chau, M., and Stoner, M. Integrated Approaches to Improving the Lives of Adolescent Girls Issue Papers Series: Girl Hub.

46 Victims' Rights to Support and Protection from Violence (2013). Legislation for the Protection from Violence in Austria (2019). Domestic Abuse Intervention Centre and the Association of Austrian Autonomous Women's Shelters. https://www.interventionsstelle-wien.at/download/?id=692

# 13

# បញ្ហាដែលលេចឡើងក្នុងការស៊ើបអង្កេត អំពើហិង្សាលើស្ត្រី និងក្មេងស្រី

“ស្ត្រីដែលត្រូវបានបង្កើនភាពអង់អាចក្នុងសេវានគរបាល នឹងជួយបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីផងដែរក្នុងសហគមន៍។ មន្ត្រីជាស្ត្រីដែលទទួលបានការបណ្តុះបណ្តាល និងការបំពាក់បំប៉នវិជ្ជាជីវៈ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់របាំងរារាំងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ព្រហ្មទណ្ឌ។IAWPគាំទ្រដល់ស្ត្រីក្នុងសេវានគរបាល និងស្ថាប័ននគរបាលឱ្យសម្រេចបានការផ្តល់សេវាដែលគិតគូរពីយេនឌ័រ និងឆ្លើយតបនឹងយេនឌ័រដល់សហគមន៍ទូទាំងពិភពលោក”។

Deborah Friedl ប្រធានសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី ខែ មីនា ឆ្នាំ ២០២០

# គោលបំណងនៃជំពូកទី ១៣

## ផ្តល់ការណែនាំស្តីពីរបៀបកែសម្រួលសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រឱ្យបន្សុីគ្នានឹងបញ្ហាដែលលេចឡើងក្នុងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

### សារ និងចំណុចរៀនសូត្រសំខាន់ៗ

- ការយល់ថាការបៀតបៀនផ្លូវភេទជាបញ្ហាមួយ នឹងជានាការឆ្លើយតបសមស្រប ដោយនគរបាល និងអាជ្ញាធរផ្សេងទៀត។
- ក្នុងករណីនៃការបៀតបៀនផ្លូវភេទ និង/ឬការឈ្លបចាប់ ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យមានសារៈសំខាន់ជាងសុវត្ថិភាព និងការការពារជនរងគ្រោះទៅទៀត។
- ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ទាមទារនូវវិសាលភាពជំទូលាយ នៅពេលបង្កើតនូវខ្សែសង្វាក់នៃការទទួលខុសត្រូវក្នុងការដាក់បទបញ្ជា ដែលជំរុញនូវការប្រព្រឹត្តដែលចោទប្រកាន់។
- ភាពជាដៃគូរវាងនគរបាលនិងស្ថាប័នផ្សេងទៀតដែលធ្វើការក្នុងផ្នែកមនុស្សធម៌ ជាគន្លឹះក្នុងការកសាងទំនុកចិត្តនិងការជឿជាក់ក្នុងចំណោមជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផ្តល់ការគាំទ្រដល់នគរបាល។
- ត្រូវចាត់ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ថាមានលក្ខណៈធ្ងន់ធ្ងរដូចអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្រៅប្រព័ន្ធអ៊ីនធឺណិតដែរ។ ផលប៉ះពាល់របស់វាអាចបង្កអន្តរាយដល់ជនរងគ្រោះ ដូចការរំលោភបំពាន/អំពើហិង្សាដោយផ្ទាល់ដែរ។
- សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រតាមប្រព័ន្ធអ៊ីនធឺណិត ដែលផ្តោតសំខាន់លើអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាត្រូវមានលក្ខណៈប្រតិសកម្មក្នុងការកសាងភាពជាដៃគូជាមួយវិស័យឯកជនដែលជាកាតាលីករនៃប្រព័ន្ធបច្ចេកវិទ្យា។



## សេចក្តីផ្តើម

**សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ សំដៅលើការទទួលបានព័ត៌មានជាប្រចាំ ការពិគ្រោះយោបល់ទូលំទូលាយ និងភាពសស្ររើកក្នុងការកសាងភាពជាដៃគូ និងផ្អែកលើការយល់ដឹងរបស់ស្ថាប័នស្តីពីឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាក និងថាតើអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។**

រូបថតទទួលបានពីសមាគមនគរបាលជាស្ត្រីអន្តរជាតិ (ប្រទេសបង់ក្លាដេស)

ផ្អែកលើការយល់ដឹងនេះ សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រផ្តោតលើក្របខណ្ឌនៃគោលការណ៍ និងលក្ខណៈរួម (រូប ១) ដើម្បីកំណត់រកគន្លឹះឈានទៅរកភាពម្ចាស់ការលើបញ្ហាអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការជំរុញដំណោះស្រាយដែលនាំឱ្យមានការឆ្លើយតបដែលមានប្រសិទ្ធភាពជាងមុន។

រូប ១៖

**ក្របខណ្ឌគោលការណ៍ និងលក្ខណៈទូទៅសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ**

| | | | |
|---|---|---|---|
| គោលការណ៍ | អភិក្រមផ្អែកតាមសិទ្ធិ | ការពង្រឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី | សមស្រប និងគិតគូរពីវប្បធម៌ និងអាយុ |
| | អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ | សុវត្ថិភាពជាចម្បង | ការទទួលខុសត្រូវរបស់ជនបង្ក |

| | | |
|---|---|---|
| លក្ខណៈទូទៅ | ភាពអាចរកបាន | ភាពអាចទទួលបាន |
| | ភាពអាចសម្របតាមបាន | ភាពសមស្រប |
| | សុវត្ថិភាពជាចម្បង | ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ |
| | ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន | ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |
| | ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល | |

នៅពេលមានមូលដ្ឋាន និងក្របខណ្ឌនេះ នគរបាលនឹងមានគោលជំហររឹងមាំក្នុងការឆ្លើយតប[581] ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចជា ការអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា នៅពេលមានអំពើហិង្សាកើតឡើង។

ភាពធន់នៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រកើតចេញពីសមត្ថភាពក្នុងការបន្តឆ្លុះបញ្ចាំង និងរៀនសូត្រពីរបៀបឆ្លើយតបទៅនឹងបញ្ហាប្រឈមបច្ចុប្បន្ននិងបញ្ហាដែលលេចឡើង។

ជំពូកមុនៗក្នុងសៀវភៅណែនាំនេះ ផ្តោតសំខាន់លើការផ្តល់ការណែនាំអំពីអភិក្រមសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ប៉ុន្តែជំពូកនេះនឹងផ្តោតសំខាន់លើការស្វែងយល់ពីបញ្ហាដែលលេចឡើងពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផ្តល់ការណែនាំពីរបៀបកែសម្រួលសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រឱ្យបន្សុីគ្នានឹងបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធភាព ក្នុងការអនុវត្តអភិក្រមពហុមុខព្រួញជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត។

មានបញ្ហាលេចឡើងជាច្រើនពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ប៉ុន្តែសៀវភៅណែនាំនេះនឹងផ្តោតសំខាន់លើប្រធានបទ ៣ ៖

១. ការបៀតបៀនផ្លូវភេទ
២. អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ
៣. អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍។

ឧទាហរណ៍ទាំង ៣ នៃបញ្ហាដែលលេចឡើងនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ការបង្ហាញថាតើការណែនាំដែលឆ្លើយតបនឹងយេនឌ័រក្នុងសៀវភៅណែនាំនេះ គឺជាការសំអាងសមស្របសម្រាប់នគរបាលដែលឆ្លើយតបទៅនឹងអំពើហិង្សានេះដោយរបៀបណា។

581. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ពាក់ព័ន្ធនឹងការទប់ស្កាត់ និងការឆ្លើយតប។

## មូលហេតុដែលជនរងគ្រោះផ្តល់ការឆ្លើយតបអវិជ្ជមាន

**រូប ២ ៖ មូលហេតុដែលនាំឱ្យគ្មានការរាយការណ៍ពីការបៀតបៀនផ្លូវភេទទៅនគរបាលក្នុងប្រទេសអេហ្ស៊ីប (ការសិក្សារបស់ UN Women)**




ការបៀតបៀនផ្លូវភេទជាការស្តែងឡើងយ៉ាងទូលំទូលាយ និងសុសសាយនូវអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងឆ្លុះបញ្ចាំងពីបទដ្ឋានសង្គមបែបរើសអើង ផ្នត់គំនិត និទណ្ឌភាព និងវិសមភាពយេនឌ័រដែលប្រឈមដោយស្ត្រី និងក្មេងស្រី។ ការគំរាមបៀតបៀនផ្លូវភេទបង្កផលប៉ះពាល់យ៉ាងខ្លាំងលើការសម្រេចចិត្តប្រចាំថ្ងៃរបស់ស្ត្រី និងក្មេងស្រីដូចជាមធ្យោបាយធ្វើដំណើរសាធារណៈដែលត្រូវជិះ និងវិជ្ជាជីវៈដែលត្រូវសិក្សា។ចំណុចនេះពាក់ព័ន្ធបំផុតនឹងវិជ្ជាជីវៈដែលមានសមាសធាតុបុរសយ៉ាងច្រើនលើសលប់ដែលផ្តល់សេវាដល់សាធារណជនដូចជានគរបាលដែលទោះបីជាយល់ពីអត្ថប្រយោជន៍នៃការមានសមាជិកជាស្ត្រីក្នុងស្ថាប័នរបស់ខ្លួនក្តី ក៏នៅតែព្យាយាមធានាដល់ស្ត្រីនូវបរិយាកាសការងារដែលគ្មានការបៀតបៀន។ចំណុចនេះជះឥទ្ធិពលលើស្ត្រី និងក្មេងស្រីជាច្រើនដែលមានបំណងចង់ក្លាយជាមន្ត្រីនគរបាល ឬបន្តធ្វើការក្នុងស្ថាប័ននេះ។ ក្នុងសេណារីយ៉ូផ្សេងទៀត ការបៀតបៀនផ្លូវភេទអាចផ្តល់មូលហេតុដែលនាំឱ្យស្ត្រី និងក្មេងស្រីវ័យក្មេងត្រូវនៅផ្ទះ ឬត្រូវឈប់រៀន។

ការរាយការណ៍ពីចំនួនករណីបៀតបៀនផ្លូវភេទគឺតិចជាងចំនួនករណីពិតប្រាកដរួមទាំងនៅពេលដែលករណីនេះកើតឡើងក្នុងស្ថាប័ននគរបាល និងមានមូលហេតុខុសៗគ្នានៃការមិនរាយការណ៍។ ឧ. ការសិក្សារួមគ្នាដោយ UN Women និងសហភាពអឺរ៉ុបស្តីពីការបៀតបៀនផ្លូវភេទនៅអេហ្ស៊ីប បានចងក្រងឯកសារស្តីពីមូលហេតុទូទៅបំផុតដែលស្ត្រីនិងក្មេងស្រីមិនរាយការណ៍ទៅនគរបាលនៅពេលករណីនេះកើតឡើង (រូប ២)[582]។ មូលហេតុដែលត្រូវបានលើកឡើងភាគច្រើនគឺការកើត

មានការបៀតបៀនផ្លូវភេទត្រូវបានចាត់ទុកជារឿងធម្មតាដែលអាចកើតឡើងចំពោះមនុស្សគ្រប់រូប។

ការយល់ថា អំពើហិង្សានេះជាបញ្ហាមួយក្នុងសង្គម នឹងជានាការឆ្លើយតបសមស្របដោយនគរបាល និងស្ថាប័នផ្សេងទៀត។ ទោះជាយ៉ាងណា គំនិតផ្តួចផ្តើមបង្កើនការរាយការណ៍ពីការបៀតបៀនផ្លូវភេទ និងយុទ្ធសាស្ត្រដោះស្រាយបញ្ហានេះ គួរផ្អែកតាមព័ត៌មានត្រឹមត្រូវក្រោមការពិគ្រោះយោបល់ទូលំទូលាយជាមួយសាធារណជន និងក្នុងស្ថាប័ននគរបាលផ្ទាល់ដើម្បីធានាប្រសិទ្ធផល និងប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងនេះ។សមាគមនគរបាលជាស្ត្រី ដូចជា សមាគមដែលត្រូវបានបង្កើតឡើងនៅកូសូវ៉ូ បង់ក្លាដេស អេក្វាឌ័រ និងហ្កាណា អាចជាប្រភពនៃការពិគ្រោះយោបល់ដ៏មានតម្លៃសម្រាប់បង្កើនការឆ្លើយតបទៅនឹងការបៀតបៀនផ្លូវភេទ(សូមមើលករណីសិក្សាក្នុងជំពូកទី១០ស្តីពីរបៀបដែលសមាគម/បណ្តាញនគរបាលជាស្ត្រីអាចគាំទ្រដល់សេវានគរបាលដែលគិតគូរពីយេនឌ័រ និងឆ្លើយតបនឹងយេនឌ័រ)។

ការពិគ្រោះយោបល់ខាងក្រៅគួរផ្តោតអាទិភាពលើប្រជាជន និង/ឬក្រុមដែលចាត់ទុកថាងាយរងគ្រោះ និង/ឬជាក្រុមភាគតិចក្នុងសង្គម ដើម្បីយល់ពីតម្រូវការសន្តិសុខរបស់ពួកគេ។ ឧ. ជនមានពិការភាពងាយរងគ្រោះដោយការបៀតបៀនផ្លូវភេទ និងការប្រទូស្តកេរខ្មាសគ្រប់ទម្រង់ជាងជនគ្មានពិការភាព។ក្នុងការអង្កេតថ្នាក់ជាតិមួយក្នុងឆ្នាំ ២០១៨ នៅសហរដ្ឋអាមេរិក លទ្ធផលរកឃើញគួសបញ្ជាក់ថា ស្ត្រីមានពិការភាពចំនួន ៨៧% ក្នុងការអង្កេតនេះ រងគ្រោះដោយការបៀតបៀនផ្លូវភេទ(ការបៀតបៀនជាពាក្យសម្តីតាមប្រព័ន្ធបច្ចេកវិទ្យានិងផ្លូវកាយ)ធៀបនឹងស្ត្រីគ្មានពិការភាពចំនួន៦៦%ក្នុងការអង្កេតនេះ[583]។ក្នុងក្រុមដូចគ្នានេះ ស្ត្រីមានពិការភាពចំនួន ៦៦% ក្នុងការអង្កេតនេះប្រឈមនឹងការបៀតបៀនផ្លូវភេទយ៉ាងគឃ្លើនលើរូបរាងកាយ[584]ធៀបនឹងស្ត្រីគ្មានពិការភាពចំនួន ៥៧% ក្នុងការអង្កេតនេះ។ ការសិក្សានេះលើកឡើងថា ការបៀតបៀនផ្លូវភេទក្នុងទីលំនៅឯកជន និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ងាយកើតឡើងចំពោះស្ត្រីមានពិការភាពជាងស្ត្រីគ្មានពិការភាព[585]។

ការយល់ពីវិសាលភាពនិងផលប៉ះពាល់នៃការបៀតបៀនផ្លូវភេទជាពាក្យសម្តីនិងលើរូបរាងកាយគឺជាផ្នែកមួយនៃដំណោះស្រាយ។ ក្រៅពីនេះ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការបៀតបៀនផ្លូវភេទសំដៅលើការយល់ថាតើច្បាប់ណាខ្លះដែលត្រូវពង្រឹងការអនុវត្ត និងវិសាលភាពនៃច្បាប់ទាំងនោះ។ ឧ. ក្នុងប្រទេសមួយចំនួនការបៀតបៀនមិនត្រូវបានកំណត់ជាបទល្មើសឡើយ ចំណែកក្នុងប្រទេសផ្សេងទៀត ចាំបាច់ត្រូវមានវត្តមានរបស់សាក្សីដើម្បីចាប់ផ្តើមការស៊ើបអង្កេត ឬការចុះបញ្ជីឧប្បត្តិហេតុនោះជាផ្លូវការ ត្រូវធ្វើឡើងនៅប៉ុស្តិ៍នគរបាល។ ក្នុងឧទាហរណ៍ទាំង ៣ នេះ ជនរងគ្រោះដោយការបៀតបៀនមានការលំបាកក្នុងការបញ្ជាក់ថា អំពើទាំងនេះពិតជាបានកើតឡើង និងស្វែងរកការការពារក្នុងទម្រង់ជាដីកាហាមឃាត់បណ្តោះអាសន្ន ឬដីកាហាមឃាត់។

ផ្ទុយទៅវិញ ក្នុងប្រព័ន្ធច្បាប់មួយចំនួន ការបៀតបៀនផ្លូវភេទជាទម្រង់មួយនៃការរើសអើងដោយផ្អែកលើភេទ និងជាអំពើខុសច្បាប់។ ក្នុងប្រព័ន្ធផ្សេងទៀត ការបៀតបៀនផ្លូវភេទ ត្រូវបានលើកឡើងក្នុងច្បាប់ការងារដែលផ្តោតលើបរិយាកាសកន្លែងធ្វើការ ដែលជាញឹកញាប់ទាមទារឱ្យស្ថាប័នឯកជន និងស្ថាប័នសាធារណៈបង្កើតគោលនយោបាយផ្ទៃក្នុងសម្រាប់"ការមិនអត់ឱន"ដោយមានយន្តការបណ្តឹង និងវិធានការដោះស្រាយ។ ការបង្កើតគោលនយោបាយទាំងនេះជាចំណុចចាប់ផ្តើមសម្រាប់ឱ្យនគរបាលសហការជាមួយវិស័យសាធារណៈ និងវិស័យឯកជនដើម្បីបន្ទុចបង្អាក់និងដាក់ទណ្ឌកម្មលើការបៀតបៀនផ្លូវភេទ។

ការផ្លាស់ប្តូរឥរិយាបថក្នុងវប្បធម៌ ចំពោះការបៀតបៀនផ្លូវភេទ អាចជាឧបករណ៍ដ៏មានតម្លៃក្នុងការប្រយុទ្ធប្រឆាំង

582. ការសិក្សាពីវិធី និងមធ្យោបាយលុបបំបាត់ការបៀតបៀនផ្លូវភេទនៅអេហ្ស៊ីប សេចក្តីសង្ខេបលទ្ធផល និងអនុសាសន៍ (UN women និងសហភាពអឺរ៉ុប) https://www.peacewomen.org/node/90812

583. ការវាស់វែង #MeToo៖ ការសិក្សាថ្នាក់ជាតិស្តីពីការបៀតបៀនផ្លូវភេទ និងការប្រទូស្តកេរខ្មាស (២០១៩) UC San Diego Center on Gender Equity and Health។

584. ការសិក្សានេះកំណត់ថាការបៀតបៀនផ្លូវភេទយ៉ាងគឃ្លើនលើរូបរាងកាយរួមបញ្ចូលនរណាម្នាក់ដែលបង្ហាញប្រដាប់ភេទរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីអ្នកដទៃការតាមនរណាម្នាក់ដោយគ្មានការអនុញ្ញាត និង/ឬចេតនាប៉ះពាល់ ឬត្រដុសជាមួយរាងកាយរបស់នរណាម្នាក់តាមបែបដែលគេមិនចង់ និងមានលក្ខណៈផ្លូវភេទ។ ការវាស់វែង #MeToo៖ ការសិក្សាថ្នាក់ជាតិស្តីពីការបៀតបៀនផ្លូវភេទ និងការប្រទូស្តកេរខ្មាស (២០១៩) UC San Diego Center on Gender Equity and Health។

585. Ibid

នឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីនេះ តាមរយៈការបង្កើតស្មារតីទទួលខុសត្រូវ និងគណនេយ្យភាពរួមរវាងវិស័យសាធារណៈ និងវិស័យឯកជន។ ការស្វែងរកភាពជាដៃគូជាមួយតួអង្គឯកជនដើម្បីបន្ទុចបង្អាក់ការបៀតបៀនផ្លូវភេទ នឹងផ្តល់លទ្ធភាពកាន់តែច្រើនដល់នគរបាលក្នុងការឆ្លើយតបទៅនឹងការបៀតបៀនផ្លូវភេទ និងក្នុងដំណើរការនេះ អាចកំណត់រកឥរិយាបថដែលគួសបញ្ជាក់ពីទម្រង់កាន់តែហិង្សានៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សាបន្ថែមទៀត។

## ការណែនាំគ្នាទៅវិញទៅមក[586]

ក្នុងករណីនៃការឈ្លបចាប់ និង/ឬការបៀតបៀន អ្នក និងបុគ្គលិករបស់អ្នកត្រូវផ្តោតអាទិភាពលើសុវត្ថិភាព និងការការពារ ដោយមានការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ។ ក្នុងករណីឈ្លបចាប់ ការវាយតម្លៃហានិភ័យត្រូវតែជាដំណើរការបន្តជាប់ ដោយកត់សម្គាល់ថា ទង្វើអាក្រក់អាចកើតឡើងបានគ្រប់ពេលវេលា។ ការទប់ស្កាត់ទង្វើអាក្រក់ទាំងនេះ ទាមទារអន្តរាគមន៍តាំងពីដំបូង។

សម្រាប់បទល្មើសទាំងអស់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ការសំខាន់ត្រូវ "ស្តាប់ជនរងគ្រោះយ៉ាងយកចិត្តទុកដាក់" ដើម្បីយល់ពីបរិបទនៃឥរិយាបថរបស់ជនបង្កដែលរងការចោទប្រកាន់ និងផលប៉ះពាល់លើជនរងគ្រោះ។ គ្រប់ករណីនៃការឈ្លបចាប់ ទាមទារការគ្រប់គ្រងហានិភ័យយ៉ាងល្អិតល្អន់ ព្រោះឥរិយាបថទាំងនោះអាចជាសូចនាករនៃហានិភ័យគ្រោះថ្នាក់កាន់តែខ្លាំង ដែលអាចផ្ទុះឡើងបានគ្រប់ពេលវេលា។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការវាយតម្លៃហានិភ័យ និងការរៀបចំផែនការសុវត្ថិភាព សូមមើលជំពូកទី ៦ (សុវត្ថិភាព និងការការពារ) នៃសៀវភៅណែនាំនេះ រួមទាំងតារាងត្រួតពិនិត្យហានិភ័យ។

បុគ្គលិករបស់អ្នកត្រូវកំណត់ថាតើអំពើទាំងនេះមានន័យស្មើនឹងការឈ្លបចាប់ ឬការបៀតបៀន ឬ (ឧ. ការឈ្លបចាប់ហាក់ផ្តោតលើបុគ្គលម្នាក់ចំណែកការបៀតបៀនអាចពាក់ព័ន្ធនឹងជម្លោះរវាងគូភាគី)។

> "ខ្ញុំឱ្យតម្លៃទស្សនៈនិងការយល់ឃើញរបស់មនុស្សគ្រប់រូបតាមរយៈការយកចិត្តទុកដាក់ស្តាប់ដើម្បីយល់ពីគំនិតរបស់ពួកគេ"។
>
> ឥរិយាបថដែលឆ្លុះបញ្ចាំងពីគុណតម្លៃនៃសុចរិតភាពរបស់នគរបាល
> (មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស ២០១៦)

ខាងក្រោមនេះជាមគ្គុទេសក៍ដ៏ល្អមួយ ដែលដកស្រង់ចេញពីការអនុវត្តវិជ្ជាជីវៈដែលទទួលបានការអនុញ្ញាតរបស់មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស (ប្រអប់ ២)។

586. ដកស្រង់ចេញពីការអនុវត្តវិជ្ជាជីវៈដែលទទួលបានការអនុញ្ញាតរបស់មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស ៖ http://library. college.police.uk/docs/appref/Stalking_or_harassment_guidance_200519.pdf p. 2

ប្រអប់ ១

| ការឈ្លបចាប់ | ការបៀតបៀន |
|---|---|
| **ការពិចារណាលើជនសង្ស័យ**<br>ឥរិយាបថសំខាន់ៗ ៤ ដែលបង្ហាញពីការឈ្លបចាប់៖ ងប់ងល់ គិតមមៃ មិនប្រាថ្នាចង់បាន ដដែលៗ?<br>តើជនសង្ស័យបានផ្លាស់ប្តូរទម្លាប់របស់ខ្លួនដើម្បីសម្រួលដល់ការឈ្លបចាប់ ឬទេ?<br>តើគំនិតនិងសកម្មភាពពួកគេផ្តោតសំខាន់លើជនរងគ្រោះ ឬទេ?<br>តើទំហំនៃពេលវេលា/ការប្រឹងប្រែង/ធនធានដែលជនសង្ស័យលះបង់ ប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់ពួកគេ ឬទេ?<br>តើមានឥរិយាបថផ្សេងៗដែលផ្តោតលើជនរងគ្រោះឬទេ?<br>តើជនសង្ស័យហាក់មិនបញ្ឈប់ឥរិយាបថរបស់ខ្លួន ឬទេ?<br>តើជនសង្ស័យហាក់ជឿជាក់ថា ខ្លួនឯងមានសិទ្ធិ/ការប្តេជ្ញាចិត្ត ឬទេ?<br>ជនសង្ស័យមិនខ្វាយខ្វល់ពីទុក្ខព្រួយដែលបង្កឡើងដោយឥរិយាបថរបស់ខ្លួន។<br><br>**ការពិចារណាលើជនរងគ្រោះ**<br>តើជនរងគ្រោះយល់ថា ពួកគេទទួលរងផលប៉ះពាល់ផ្លូវកាយ/ផ្លូវចិត្ត និង/ឬផ្លូវអារម្មណ៍ដោយសារឥរិយាបថនោះ ឬទេ?<br>តើជនរងគ្រោះមានការភ័យខ្លាចជាប់ជានិច្ចចំពោះអ្វីដែលអាចកើតឡើង ឬទេ?<br>តើឥរិយាបថនោះកំពុងរំខានដល់ជីវិតរបស់ជនរងគ្រោះ ឬទេ?<br>តើឥរិយាបថនោះបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើសកម្មភាពប្រចាំថ្ងៃរបស់ជនរងគ្រោះ ឬទេ? | **ការពិចារណាលើជនសង្ស័យ**<br>តើមានភស្តុតាងនៃការប្រព្រឹត្តដដែលៗដែលមិនសមហេតុផល ប៉ុន្តែមិនផ្តោតតែលើជនរងគ្រោះ ឬទេ?<br>តើឥរិយាបថរបស់ជនសង្ស័យ ដែលទោះបីជាធ្វើឡើងដដែលៗ មិនប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃរបស់គាត់ ឬទេ?<br>តើជាទូទៅឥរិយាបថនោះផ្តោតលើការដោះស្រាយទំនាស់ (ហិរញ្ញវត្ថុ អ្នកជិតខាង ការងារ។ល។)ជាជាងផ្តោតលើបុគ្គលម្នាក់ ឬទេ?<br>តើឥរិយាបថរបស់ជនសង្ស័យងាយនឹងបន្ត ប្រសិនបើបញ្ហាឬសគល់នៅបន្ត ប៉ុន្តែពាក់ព័ន្ធនឹងបុគ្គលផ្សេងៗ ឬទេ?<br>តើមានភស្តុតាងបញ្ជាក់ថា ឥរិយាបថនោះនឹងបញ្ឈប់ ប្រសិនបើបញ្ហាឬសគល់ត្រូវបានដោះស្រាយ ឬទេ?<br><br>**ការពិចារណាលើជនរងគ្រោះ**<br>តើជនរងគ្រោះយល់ថារងការគៀបសង្កត់ ប៉ុន្តែមិនសូវដឹងខ្លួន ឬរងទុក្ខខ្លាំងដោយសារឥរិយាបថនោះ ឬទេ?<br>តើជនរងគ្រោះភ័យខ្លាចពីទង្វើមួយចំនួនប៉ុន្តែគ្មានអារម្មណ៍ភ័យខ្លាចជាប់ជាប្រចាំ ឬទេ? |

វិធីដ៏ល្អមួយសម្រាប់ឱ្យបុគ្គលិករបស់អ្នកពិចារណាថាតើឥរិយាបថនោះ មានន័យស្មើនឹងការឈ្លបចាប់ ឬទេ គឺត្រូវផ្អែកតាមពាក្យពាក់ព័ន្ធគ្នា ៤។ តើឥរិយាបថទាំងនោះ ៖

- ងប់ងល់
- គិតមមៃ
- មិនប្រាថ្នាចង់បាន
- ដដែលៗ ឬទេ?

អ្នក និងបុគ្គលិករបស់អ្នកត្រូវទទួលព័ត៌មានឱ្យបានច្រើនពីជនរងគ្រោះ ប៉ុន្តែត្រូវមានភាពអត់ធ្មត់ គិតពីអារម្មណ៍ និងជំនាញស្តាប់យ៉ាងយកចិត្តទុកដាក់។ដូចគ្នានឹងបទល្មើសផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែរ អ្នកប្រហែលជាត្រូវចំណាយពេលកសាងទំនុកចិត្ត និងទំនាក់

ទំនងល្អជាមួយជនរងគ្រោះ និងត្រូវយល់ និងជួយដោះស្រាយផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តដែលអាចលេចឡើងនៅពេលធ្វើទំនាក់ទំនងដំបូង។ ការសំខាន់គឺអ្នកអាចយល់យ៉ាងទូលំទូលាយអំពីឥរិយាបថដែលនាំឱ្យមានការដាក់បណ្តឹង មិនមែនគ្រាន់តែផ្តោតលើឧប្បត្តិហេតុមួយនោះទេ។

ព័ត៌មានសារវតារខាងក្រោម មានសារៈសំខាន់ក្នុងករណីឈ្លបចាប់ ៖

- តើអ្វីបានកើតឡើងពីមុនមក រួមទាំងចំពោះបុគ្គលផ្សេងទៀត ដូចជា សមាជិកគ្រួសារ?
- តើមកទល់បច្ចុប្បន្ននេះ ឥរិយាបថរបស់ជនបង្កដែលរងការចោទប្រកាន់ មានភាពពុះកញ្ជ្រោល ឬទេ?

កុំភ្លេចពិនិត្យប្រភពព័ត៌មានផ្សេងទៀត ដូចជា គ្រួសារ មិត្តភក្តិ សហការី និងបណ្តាញសង្គម ព្រោះប្រភពទាំងនេះអាចផ្តល់ព័ត៌មានសារវតារក៏ដូចជាភស្តុតាងពាក់ព័ន្ធសម្រាប់ការស៊ើបអង្កេត។

ធនធានដ៏ល្អមួយទៀតពីមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេសគឺ តារាងត្រួតពិនិត្យការសាកសួរ[587] (សូមមើលប្រអប់៣)ដែលផ្តល់គោលការណ៍ណែនាំល្អៗពាក់ព័ន្ធនឹងករណីឈ្លបចាប់ និងការបៀតបៀនផ្លូវភេទដើម្បីអាចឱ្យនគរបាលស្វែងយល់យ៉ាងទូលំទូលាយពីប្រវត្តិនៃការរំលោភបំពាន។ យោងតាមមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស គំរូនៃការរំលោភបំពានមិនសុទ្ធតែលេចឡើងនោះទេ ព្រោះឧប្បត្តិហេតុនាពេលកន្លងមកអាចត្រូវបានកត់ត្រាជាពាក្យសម្តីតែប៉ុណ្ណោះ ឬត្រូវបានចាត់ទុកថាជារឿងកំប៉ិចកំប៉ុក។ ដូច្នេះ មន្ត្រីឆ្លើយតបគួរទទួលបានព័ត៌មានលម្អិតឱ្យបានច្រើនដើម្បីយល់ពីបរិបទនិងកំណត់រកសញ្ញានៃឥរិយាបថបង្ខិតបង្ខំត្រួតត្រា ឬគំរាមកំហែង។ លើសពីនេះ ការស្វែងយល់ពីប្រវត្តិនិងការបំពេញការវាយតម្លៃហានិភ័យអាចនាំទៅរកការលាតត្រដាងការរំលោភបំពាន ឬបទល្មើសផ្លូវភេទពីមុនមក[588]។សូមមើលប្រអប់៣)ដែលផ្តល់គោលការណ៍ណែនាំល្អៗពាក់ព័ន្ធនឹងករណីឈ្លបចាប់និងការបៀតបៀនផ្លូវភេទដើម្បីអាចឱ្យនគរបាលស្វែងយល់យ៉ាងទូលំទូលាយពីប្រវត្តិនៃការរំលោភបំពាន។ យោងតាមមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស គំរូនៃការរំលោភបំពានមិនសុទ្ធតែលេចឡើងនោះទេ ព្រោះឧប្បត្តិហេតុនាពេលកន្លងមកអាចត្រូវបានកត់ត្រាជាពាក្យសម្តីតែប៉ុណ្ណោះ ឬត្រូវបានចាត់ទុកថាជារឿងកំប៉ិចកំប៉ុក។ ដូច្នេះ មន្ត្រីឆ្លើយតបគួរទទួលបានព័ត៌មានលម្អិតឱ្យបានច្រើនដើម្បីយល់ពីបរិបទនិងកំណត់រកសញ្ញានៃឥរិយាបថបង្ខិតបង្ខំត្រួតត្រា ឬគំរាមកំហែង។ លើសពីនេះ ការស្វែងយល់ពីប្រវត្តិនិងការបំពេញការវាយតម្លៃហានិភ័យអាចនាំទៅរកការលាតត្រដាងការរំលោភបំពាន ឬបទល្មើសផ្លូវភេទពីមុនមក[589] ។

### ប្រអប់ ២

**តារាងត្រួតពិនិត្យ ៖ ខ្សែសង្វាក់នៃការសាកសួរ**

មន្ត្រីគួរពិចារណាពីខ្សែសង្វាក់នៃការសាកសួរដូចខាងក្រោម ៖

- ប្រវត្តិទំនាក់ទំនង (ប្រសិនបើមាន)។
- ឧប្បត្តិហេតុរំលោភបំពានពីមុនមក រួមទាំងការរំលោភបំពានជាមួយដៃគូពីមុន (ឧ. កំណត់ត្រានៃការទូរស័ព្ទទៅនគរបាលកន្លងមក)។
- ប្រព័ន្ធចារកម្មនគរបាលក្នុងមូលដ្ឋាន ប្រព័ន្ធជាតិ និងអន្តរជាតិ។
- ពិនិត្យការផ្តន្ទាទោសឧក្រិដ្ឋជនក្នុងប្រទេសដែលប្រព្រឹត្តល្មើសនៅក្រៅប្រទេស ប្រសិនបើជនសង្ស័យ ជនរងគ្រោះឬសាក្សីជាជនបរទេស។
- សាក្សីដែលអាចនឹងទទួលបានព័ត៌មានពីដំបូងទី។
- ព័ត៌មានវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រដែលអាចបង្កើតបានជាភស្តុតាង ៖ គួរទទួលបានការយល់ព្រម ក្នុងករណីពាក់ព័ន្ធ។
- ភស្តុតាងពីប្រភពទិន្នន័យណាមួយស្តីពីជនរងគ្រោះពីមុន។
- លេខទូរស័ព្ទ និងអ៊ីមែល។
- បណ្តាញសង្គម។

ប្រភព ៖ ដកស្រង់ចេញពីមហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស (តារាងត្រួតពិនិត្យការសាកសួរ)

587.ការស៊ើបអង្កេតសំខាន់ៗ និងការការពារសាធារណជន ៖ ការបង្កើតការស៊ើបអង្កេត ៖ ខ្សែសង្វាក់នៃការសាកសួរ មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស។

588. Ibid

589. Ibid

រាល់បញ្ហាសុខភាពផ្លូវចិត្តដែលរកឃើញ មិនថាពាក់ព័ន្ធនឹងជនបង្កដែលរងការចោទប្រកាន់ឬជនរងគ្រោះនោះទេ គួរផ្តល់មូលដ្ឋានព័ត៌មានដល់ដំណើរការវាយតម្លៃហានិភ័យ និងផែនការសុវត្ថិភាព ប៉ុន្តែមិនត្រូវបង្កការរាំងស្ទះដល់ការស៊ើបអង្កេតឡើយ។ ជនរងគ្រោះអាចមានបញ្ហាសុខភាពផ្លូវចិត្ត ដោយសារឥរិយាបថឈ្លបចាប់ ឬក៏ពួកគេអាចក្លាយជាចំណុចផ្តោតដោយសារតែភាពងាយរងគ្រោះបន្ថែមទៀត។ ក្នុងករណីណាក៏ដោយ អ្នកត្រូវធានាផ្តល់ការគាំទ្រសមស្របទៅតាមតម្រូវការជាក់លាក់របស់ជនរងគ្រោះក្នុងពេលស៊ើបអង្កេត។

ដូចគ្នានឹងគ្រប់ករណីនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែរ ដំណើរការវាយតម្លៃហានិភ័យគួរនាំទៅរកការបង្កើតផែនការសុវត្ថិភាពដែលចូលរួមដោយជនរងគ្រោះ ដែលជាធាតុផ្សំយ៉ាងសំខាន់នៃការរៀបចំផែនការនោះ។ ការឆ្លើយតបក្នុងទម្រង់ជាការធានាសុវត្ថិភាពត្រូវសមាមាត្រទៅនឹងកម្រិតហានិភ័យដែលបានរកឃើញ។ អ្នក និងបុគ្គលិករបស់អ្នកទទួលខុសត្រូវលើការចាត់វិធានការវិជ្ជមានក្នុងការរក្សាសុវត្ថិភាពរបស់ជនរងគ្រោះ។

កាលៈទេសៈរបស់ជនរងគ្រោះម្នាក់ៗគឺខុសគ្នា។ ដូច្នេះជនរងគ្រោះប្រហែលជាមិនអនុវត្តតាមដំបូន្មានសុវត្ថិភាពរបស់អ្នកហូតនោះទេ។ ចំណុចនេះ មិនមានន័យថាជនរងគ្រោះមិនសហការនោះទេ ហើយអ្នក និងបុគ្គលិករបស់អ្នកមិនគួរវិនិច្ឆ័យលើពួកគេដោយសារចំណុចនេះឡើយ។ ជនរងគ្រោះអាចជឿថា ដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន គាត់ត្រូវប្រព្រឹត្តតាមរបៀបជាក់លាក់។ នេះជាមូលហេតុមួយផ្សេងទៀតដែលចាំបាច់ត្រូវធ្វើការវាយតម្លៃហានិភ័យល្អិតល្អន់ជាមួយជនរងគ្រោះ និងកំណត់ផែនការសុវត្ថិភាពដែលបំពេញតម្រូវការជាក់លាក់របស់គាត់។

មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេសបានផ្តល់ការណែនាំល្អៗមួយចំនួនសម្រាប់ការពិចារណាពីការធានាសុវត្ថិភាពដែលជាមូលដ្ឋាននៃចំណុចខាងក្រោម[590]៖

- ចាប់ខ្លួននិងបញ្ជូនទៅឃុំខ្លួនវិញឬលក្ខខណ្ឌសមស្របនៃការបង់ប្រាក់ធានានៅក្រៅឃុំ។
- លេខទូរស័ព្ទសង្គ្រោះបន្ទាន់។
- ក្រើនរំលឹកមិត្តភក្តិ គ្រួសារ និយោជកអំពីហានិភ័យ។
- សញ្ញាប្រកាសអាសន្ននៅពេលស្លន់ស្លោ(ប្រសិនបើមាន)
- ប្រសិនបើចាំបាច់ត្រូវដកហូតទូរស័ព្ទចល័តរបស់ជនរងគ្រោះដើម្បីទុកជាភស្តុតាង សូមពិចារណាផ្តល់ទូរស័ព្ទថ្មីដល់ពួកគេ។
- ការបញ្ជូនទៅរកសេវាគាំទ្រផ្សេងទៀត។
- ប្រើដីកាការពារ (ប្រសិនបើមាន)។

ការណែនាំចំពោះជនរងគ្រោះ ៖

- ក្រើនរំលឹកមិត្តភក្តិ គ្រួសារ និយោជកអំពីហានិភ័យ។
- ប្រើកាមេរ៉ាសុវត្ថិភាព (CCTV) ប្រសិនបើមាន និងសមស្រប។
- សញ្ញាប្រកាសអាសន្នផ្ទាល់ខ្លួននៅពេលមានការវាយប្រហារ។
- ផ្លាស់ប្តូរពេលវេលា/ផ្លូវទៅធ្វើការ មជ្ឈមណ្ឌលសង្គម ឬមជ្ឈមណ្ឌលអប់រំ។

ជាទូទៅ ឥរិយាបថតាមប្រព័ន្ធអ៊ីនធឺណិតរបស់ជនបង្កពាក់ព័ន្ធនឹងករណីឈ្លបចាប់ និងការបៀតបៀន។ ដូច្នេះគួរផ្តល់ដំបូន្មានស្តីពីបច្ចេកវិទ្យាឌីជីថលដល់ជនរងគ្រោះ។

ចំណុចខាងក្រោម ត្រូវបានដកស្រង់ចេញពីសេចក្តីណែនាំរបស់មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស ៖

- ពិនិត្យរកកម្មវិធី spyware, maleware ឬឧបករណ៍តាមដាន។
- ធានា ឬកែសម្រួល privacy setting។
- រក្សាសុវត្ថិភាពព័ត៌មានដែលបានចែកចាយ មិនបង្ហាញអាសយដ្ឋាន លេខទូរស័ព្ទ។ល។ និងសុំកុំឱ្យមិត្តភក្តិបង្ហាញព័ត៌មានលម្អិតទាំងនេះ។
- កុំបង្ហាញព័ត៌មានដែលអ្នកមិនចង់ឱ្យជនបង្កដែលរងការចោទប្រកាន់ដឹងដូចជាទំនាក់ទំនងថ្មីការងារ។ល។

ដូចគ្នានឹងប្រភេទទាំងអស់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែរ បុគ្គលិករបស់អ្នកមិនត្រូវធ្វើឱ្យជនរងគ្រោះយល់ថា ពួកគេជាអ្នកដែលត្រូវបានស្តីបន្ទោសឡើយ។

អ្នកត្រូវធានាថា បុគ្គលិករបស់អ្នក ជាពិសេសអ្នកទទួល

ទូរស័ព្ទនិងបុគ្គលិកផ្តល់ព័ត៌មាននៅប៉ុស្តិ៍នគរបាលដឹងពីអ្វីដែលពួកគេត្រូវធ្វើនៅពេលជនរងគ្រោះរាយការណ៍ពីករណីឈ្លបចាប់ ឬការបៀតបៀន ដើម្បីឱ្យពួកគេអាចផ្តល់ព័ត៌មានច្រើនតាមដែលអាចធ្វើទៅបាន ដល់មន្ត្រីឆ្លើយតប។ ចាំបាច់ត្រូវធានាថា ស្នៀវភៅបញ្ជីកត់ត្រាឧប្បត្តិហេតុ (លាយលក្ខណ៍អក្សរ ឬអេឡិចត្រូនិក) មិនត្រូវបានបិទ ឬកត់ត្រា មុនធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ និងវាយតម្លៃហានិភ័យឡើយ។

អាទិភាពរបស់មន្ត្រីដែលធ្វើទំនាក់ទំនងដំបូងជាមួយជនរងគ្រោះ គឺត្រូវវាយតម្លៃលើលក្ខណៈនៃឧប្បត្តិហេតុ/បទល្មើសនោះ ភាពងាយរងគ្រោះរបស់ជនរងគ្រោះ និងអ្វីដែលត្រូវការចាំបាច់សម្រាប់ការឆ្លើយតបដែលមានប្រសិទ្ធភាព និងការគ្រប់គ្រងហានិភ័យដែលបានរកឃើញ។

ក្នុងប្រអប់ ៤ ខាងក្រោម មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេសផ្តល់កម្រងសំណួរពិនិត្យបឋមសម្រាប់កំណត់អត្តសញ្ញាណការឈ្លបចាប់។

### ប្រអប់ ៣

**ការប្រមូលព័ត៌មានពីអ្នករាយការណ៍**

ក្នុងករណីនៃការឈ្លបចាប់ មានគំរូនៃឥរិយាបថដែលមិនប្រាថ្នាចង់បាន ងប់ងល់ និងគិតមមៃ ដែលបង្កការរំខាន។ ការបៀតបៀន អាចមានន័យស្មើនឹងការឈ្លបចាប់ ហើយការឈ្លបចាប់អាចបង្កការភ័យខ្លាចអំពើហិង្សា ឬភាពតក់ស្លុត ឬទុក្ខព្រួយ។

ការបៀតបៀនជាឥរិយាបថគ្មានហេតុផល និងគៀបសង្កត់ដែលធ្វើឡើងដដែលៗនិងអាចបង្កភាពតក់ស្លុត ឬទុក្ខព្រួយ ឬការភ័យខ្លាចអំពើហិង្សាលើជនរងគ្រោះ។

- តើជនរងគ្រោះភ័យខ្លាច ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ពាក់ព័ន្ធក្នុងការបៀតបៀន/ការឈ្លបចាប់កន្លងមកជាមួយជនរងគ្រោះ ឬអ្នកផ្សេងទៀត ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ធ្លាប់បំផ្លាញឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់បានទៅលេងជនរងគ្រោះនៅកន្លែងធ្វើការ នៅផ្ទះ។ល។ លើសពី ៣ដងក្នុងមួយសប្តាហ៍ឬទេ? (ការស្រាវជ្រាវកំណត់ថា ប្រសិនបើទៅលេងលើសពី ៣ ដងក្នុងមួយសប្តាហ៍ អាចមានការវាយប្រហារលើរាងកាយ)[591]
- តើជនបង្កដែលរងការចោទប្រកាន់មាន ឬអាចប្រើប្រាស់កាំភ្លើង ឬអាវុធផ្សេងទៀត ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ដើរត្រេតត្រតជុំវិញផ្ទះ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់បានគំរាមប្រព្រឹត្តអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ក្នុងឧប្បត្តិហេតុបៀតបៀន/ឈ្លបចាប់ថ្មីៗនេះ ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់បានគំរាមកំហែងដោយប្រើកាំភ្លើង ឬអាវុធផ្សេងទៀត ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ ពាក់ព័ន្ធ ឬផ្តោតលើភាគីទីបីណាមួយ តាំងពីការចាប់ផ្តើមការបៀតបៀន/ការឈ្លបចាប់ ឬទេ? (ឧ. មិត្តភក្តិ គ្រួសារ កូនសហការី ដៃគូ ឬអ្នកជិតខាង)
- តើជនបង្កដែលរងការចោទប្រកាន់បានបញ្ចុះបញ្ចូលអ្នកដទៃឱ្យជួយគាត់(ស្គាល់គ្នាឬមិនស្គាល់គ្នា)ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ ត្រូវបានគេដឹងលឺថាកំពុងសេពគ្រឿងញៀន និង/ឬគ្រឿងស្រវឹង ឬទេ?
- តើជនបង្កដែលរងការចោទប្រកាន់ ត្រូវបានគេដឹងលឺថាធ្លាប់ប្រព្រឹត្តបំពាន ឬទេ (ផ្លូវកាយ ឬផ្លូវចិត្ត)?

ប្រភព ៖ ដកស្រង់ចេញពី ការឈ្លបចាប់ ឬការបៀតបៀន (២០១៩) មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស

## ការបៀតបៀនផ្លូវភេទ

ការបៀតបៀនផ្លូវភេទមានទម្រង់ជាច្រើន និងអាចប្រព្រឹត្តឡើងនៅទីសាធារណៈ កន្លែងធ្វើការ និងតាមប្រព័ន្ធអ៊ីនធឺណិត ទោះបីជាគេអាចទុកអ៊ីនធឺណិតជាទីកន្លែងសាធារណៈ និងទីកន្លែងឯកជនក្តី។ យោងតាមការស្រាវជ្រាវ ការបៀតបៀនផ្លូវភេទជាទម្រង់ទូទៅបំផុតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី[592]។ ប្រទេសមួយចំនួនមានច្បាប់ដែលកំណត់ការបៀតបៀនផ្លូវភេទជាបទល្មើស

590. ការឈ្លបចាប់ ឬការបៀតបៀន (២០១៩) មហាវិទ្យាល័យសេវានគរបាលចក្រភពអង់គ្លេស
591. Ibid

ព្រហ្មទណ្ឌ ដូចជា ព័រទុយហ្គាល់ (២០១៥) បារាំង (២០១៨) និងអេហ្ស៊ីប (២០១៤)។ ការសិក្សាមួយរបស់ UN Women នៅប្រទេសអេហ្ស៊ីបរកឃើញថា ស្ត្រីចំនួន ៩៦,៥% រាយការណ៍ថា ពួកគេរងគ្រោះដោយការបៀតបៀនផ្លូវភេទជាពាក្យសម្តី។ លទ្ធផលដ៏គួរឱ្យភ្ញាក់ផ្អើលពីការសិក្សានេះគឺអ្នកតបសម្ភាសន៍អះអាងថា ជនបង្កចំនួន ១៦,៩% គឺជាមន្ត្រីនគរបាល[593]។

ខណៈដែលនៅចក្រភពអង់គ្លេស គ្មានច្បាប់ព្រហ្មទណ្ឌជាក់លាក់ពាក់ព័ន្ធនឹងការបៀតបៀនផ្លូវភេទមានឧទាហរណ៍មួយចំនួននៃចំណុចវិជ្ជមានក្នុងការដាក់បញ្ចូលការស្អប់ស្ត្រីជា "បទល្មើសនៃការស្អប់ខ្ពើម"។ នគរបាលNottinghamshire បានផ្តល់ករណីសិក្សាអនុវត្តន៍ដ៏ល្អស្តីពីគំនិតផ្តួចផ្តើមជាវិជ្ជមាននេះដោយកំណត់និយមន័យនៃការស្អប់ស្ត្រីជា "ឧប្បត្តិហេតុប្រឆាំងនឹងស្ត្រីដែលជំរុញដោយឥរិយាបថរបស់បុរសចំពោះស្ត្រីនិងរួមបញ្ចូលអាកប្បកិរិយារបស់បុរសដែលផ្តោតលើស្ត្រី ដោយសារតែពួកគេជាស្ត្រី"។ គោលជំហររបស់នគរបាល Nottinghamshire ត្រូវបានវាយតម្លៃក្នុងរបាយការណ៍ឆ្នាំ ២០១៨ ដោយសាកលវិទ្យាល័យ Nottingham Trent និងសាកលវិទ្យាល័យ Nottingham[594]។

សម្រាប់ព័ត៌មានបន្ថែម សូមមើលករណីសិក្សារបស់នគរបាល Nottinghamshire ដែលចាត់ទុកឥរិយាបថហិង្សាចំពោះស្ត្រីជាបទល្មើសនៃការស្អប់ខ្ពើម ក្នុងជំពូកទី ៩ (ទំនាក់ទំនង)។

ការបៀតបៀនផ្លូវភេទ អាចមានន័យស្មើនឹងទម្រង់ផ្សេងទៀតនៃបទល្មើសផ្លូវភេទ ដូចជា ការប្រទូស្តកេរខ្មាស ប៉ុន្តែមិនមែនឥរិយាបថដែលមិនមានន័យស្មើនឹងបទល្មើសមិនសូវបង្កគ្រោះថ្នាក់ចំពោះជនរងគ្រោះឡើយ។ ជាញឹកញាប់ មនុស្សប្រឈមនឹងការបៀតបៀនផ្លូវភេទតាំងពីក្មេងដែលអាចធ្វើឱ្យពួកគេយល់ថា វាជា "រឿងធម្មតា"។ ការបៀតបៀនផ្លូវភេទក៏ជះឥទ្ធិពលលើការយល់ឃើញរបស់ក្មេងប្រុស និងក្មេងស្រីស្តីពីអាកប្បកិរិយាដែលអាចទទួលយកបានផងដែរ។ ចំណុចនេះ អាចនាំឱ្យស្ត្រីរឹតត្បិតសេរីភាពផ្ទាល់ខ្លួននៅទីសាធារណៈ និងជឿថា ពួកគេជាអ្នកទទួលខុសត្រូវលើការបញ្ចៀសស្ថានភាព "ដែលមានហានិភ័យ"។

**ប្រអប់ ៤**

**ដឹងពីសិទ្ធិរបស់អ្នកនៅកន្លែងធ្វើការ ៖ ការបៀតបៀនផ្លូវភេទ**

ឧទាហរណ៍នៃអាកប្បកិរិយាដែលអាចជាការបៀតបៀនរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ៖

- ការដាក់សំណើផ្លូវភេទឬការណាត់ជួបដែលគេមិនចង់។
- ការនិយាយមិនសមរម្យអំពីរាងកាយឬកិនភាគរបស់នរណាម្នាក់។
  ការនិយាយរឿងមិនល្អ ឬការចំអកនរណាម្នាក់ ឬមនុស្សទាំងអស់ដែលមានយេនឌ័រឬទំនោរផ្លូវភេទជាក់លាក់(ឧ."ស្ត្រីគឺ..."ឬ"មនុស្សខ្ទើយសុទ្ធតែ...")។
- ការនិយាយដើកផ្អែកលើយេនឌ័រ ឬផ្តោតលើផ្លូវភេទ (ពាក្យជេរប្រទេច)។
- ការនិយាយកំប្លែងគ្រោតគ្រាត បំពាន ឬជាក់លាក់អំពីភេទ ឬទង្វើផ្លូវភេទ។
- ការផ្ញើ ឬចែកចាយអ៊ីមែល អត្ថបទ ឬសារដែលមានលក្ខណៈផ្លូវភេទដើម្បីនិយាយដើមអំពីទំនាក់ទំនងផ្ទាល់ខ្លួន ឬជីវិតផ្លូវភេទរបស់នរណាម្នាក់។
- ការប៉ះពាល់ដោយមិនចង់ឬមិនសមរម្យលើផ្នែកណាមួយនៃរាងកាយ សម្លៀកបំពាក់ ផ្ទៃមុខ ឬសក់ រួមទាំងការអោប ការថើប ឬការប្រទូស្តរាយ។
- ការសំឡក់ ការលួចមើលកន្ទុយភ្នែក ឬការធ្វើកាយវិការដែលមានលក្ខណៈផ្លូវភេទដើម្បីរារាំងបំលាស់ទីរបស់នរណាម្នាក់។
- ការបង្ហាញ ការផ្ញើ ឬការចែកចាយរូបភាពគ្រោតគ្រាត ឬរូបអាសអាភាស។

ប្រភព ៖ Equal Righs Advocates

592. ទីភ្នាក់ងារអឺរ៉ុបដើម្បីសិទ្ធិជាសារវន្ត (២០១៥) អំពើហិង្សាលើស្ត្រី ៖ ការអង្កេតទូទាំងសហភាពអឺរ៉ុប។
593. ការសិក្សារបស់ UN Women (គ្មានកាលបរិច្ឆេទ) ស្តីពីវិធី និងមធ្យោបាយលុបបំបាត់ការបៀតបៀនផ្លូវភេទនៅប្រទេសអេហ្ស៊ីប ៖ សេចក្តីសង្ខេបលទ្ធផល និងអនុសាសន៍។
594. របាយការណ៍វាយតម្លៃបទល្មើសនៃការស្អប់ស្ត្រីសម្រាប់មជ្ឈមណ្ឌលស្ត្រី Nottingham ក្រោមជំនួយមូលនិធិពីការិយាល័យនគរបាលNottinghamshireនិងស្នងការបទល្មើសMullany, L. and Trickett, L. June 2018
595. House of Commons Women and Equalities Committee (UK), (2018) Sexual Harassment of Women and Girls in public spaces: 6th Report of session 2017-2019.


PROMUNDO

UNMASKING SEXUAL HARASSMENT

How Toxic Masculinities Drive Men's Abuse in the US, UK, and Mexico and What We Can Do to End It

A PROMUNDO RESEARCH BRIEF PRODUCED FOR WORLD ECONOMIC FORUM ANNUAL MEETING 2018

ABOUT THE STUDY

1 HARASSMENT STARTS YOUNG AND TAKES MANY FORMS

ការបៀតបៀនផ្លូវភេទអាចប្រទាក់ក្រឡាគ្នានឹងទម្រង់ផ្សេងទៀតនៃការរំលោភបំពាន ដូចជា ការបៀតបៀនដែលពាក់ព័ន្ធនឹងពិការភាព និងការបៀតបៀនផ្លូវភេទដោយសារជាតិសាសន៍[596]។ ឧ. ស្ត្រីម្នាក់ដែលមានពណ៌សម្បុរជាក់លាក់អាចទទួលរងការបៀតបៀនខុសពីស្ត្រីស្បែកស។ នាងអាចក្លាយជាគោលដៅ ដោយសារតែភេទ និងជាតិសាសន៍ ឬជាតិពន្ធុរបស់នាង[597]។

Promundo គឺជាអង្គការថ្នាក់សកលដែលផ្តោតលើភាពជាបុរស និងសមភាពយេនឌ័រ។ នៅឆ្នាំ ២០១៦ អង្គការនេះបានចេញផ្សាយការសិក្សាមួយដែលមានចំណងជើងថា "ការលាតត្រដាងការបៀតបៀនផ្លូវភេទ" ដែលផ្តោតសំខាន់លើទស្សនៈរបស់បុរសវ័យក្មេងស្តីពីភាពជាបុរសនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងម៉ិចស៊ិក។ ផ្អែកតាមអ្នកចូលរួមក្នុងការអង្កេតនេះ ការសិក្សារកឃើញថាការបៀតបៀនផ្លូវភេទចាប់ផ្តើមតាំងពីវ័យក្មេង និងមានទម្រង់ផ្សេងៗគ្នាជា ច្រើន។ ការសិក្សានេះក៏រកឃើញផងដែរថា ជនបង្កការបៀតបៀនផ្លូវភេទ មានសាវតារ កម្រិតប្រាក់ចំណូល និងសាវតារអប់រំចម្រុះ និងគ្រប់វ័យ។ឥទ្ធិពលដ៏ធំជាងគេលើអាកប្បកិរិយារបស់ពួកគេគឺឥរិយាបថចំពោះអត្ថន័យនៃភាពជាបុរស[598] ។

ដូចគ្នានឹងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែរ ការបៀតបៀនផ្លូវភេទនៅទីសាធារណៈ មានការវិវត្ត ព្រោះបច្ចេកវិទ្យា និងវេទិកាអនឡាញបានសម្រួលដល់ទម្រង់ថ្មីៗនៃការបៀតបៀន និងរបៀបប្រព្រឹត្ត។ ឧទាហរណ៍នៃការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត រួមមាន ការមើលរូបអាសអាភាសលើ smart phone នៅទីសាធារណៈ និង "ការលួចថតក្រោមសំពត់មនុស្សស្រី" ដែលពាក់ព័ន្ធនឹងការថតរូបភាព ឬវីដេអូក្រោមសំពត់នរណាម្នាក់ដោយគ្មានការអនុញ្ញាត។ ជាញឹកញាប់ ការបៀតបៀនកើតមានច្រើននៅលើមធ្យោបាយធ្វើដំណើរសាធារណៈដែលមមាញឹកជាពិសេសនៅពេលមានមនុស្សច្រើនធ្វើដំណើរ ជាពេលដែលជាញឹកញាប់ មនុស្សនៅកៀកគ្នាបំផុតក្នុងកន្លែងឃ្លុំបិទជិត និងមានមនុស្សតាន់តាប់។ ជារឿយៗ ស្ត្រីអាចមិនស្គាល់អ្នកដែលរំលោភសិទ្ធិរបស់គាត់តាមរបៀបនេះ និង/ឬប្រហែលជាមិនអាចតបតដោយសារ "ការជាប់ផុង" ហើយដូចទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែរ ការរាយការណ៍ពីចំនួនករណីឧប្បត្តិហេតុទាំងនេះគឺទាបជាងចំនួនករណីពិតប្រាកដ។

ក្នុងផ្នែកមួយនៃការពិនិត្យឡើងវិញនៅឆ្នាំ២០១៨ដោយ UK House of Commons Women and Equalities Committee "ការបៀតបៀនផ្លូវភេទលើស្ត្រី និងក្មេងស្រីនៅទីសាធារណៈ"[599] បណ្តាញសង្គមត្រូវបានពិពណ៌នាជា "ទីសាធារណៈ" ។ ការស្រាវជ្រាវដោយអង្គការលើកលែងទោសអន្តរជាតិ (២០១៧) រកឃើញថា ក្នុងចំណោមស្ត្រី ៥ នាក់ មានស្ត្រីម្នាក់ប្រឈមនឹងការរំលោភបំពាន ឬការបៀតបៀនតាមបណ្តាញសង្គម ហើយស្ត្រីវ័យក្មេងដែលមានអាយុ ១៨-២៤ ឆ្នាំទទួលរងផលប៉ះពាល់ខ្លាំងជាងគេ[600]។

---

596. Equal Rights Advocates (2019) Know your rights at work: Sexual Harassment.

597. ការលាតត្រដាងការបៀតបៀនផ្លូវភេទ ៖ តើភាពជាបុរសយ៉ាងងប់ងល់ជំរុញឱ្យមានការការបំពារបំពានរបស់បុរសនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងម៉ិចស៊ិកដោយរបៀបណា? តើយើងអាចធ្វើអ្វីខ្លះដើម្បីបញ្ឈប់បញ្ហានេះ?ឯកសារសង្ខេបការស្រាវជ្រាវរបស់Promundo សម្រាប់ជាក់ជូនកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសេដ្ឋកិច្ចសកល ឆ្នាំ ២០១៨, Promundo។

598. House of Commons Women and Equalities Committee (UK), (2018) Sexual Harassment of Women and Girls in public spaces: 6th Report of session 2017-2019.

599. អង្គការនេះបានបង្ហាញពីផលប៉ះពាល់ដ៏គួរឱ្យព្រួយបារម្ភនៃការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតលើស្ត្រី។ អង្គការលើកលែងទោសអន្តរជាតិ។

ក្រៅពីនេះ ការបៀតបៀនផ្លូវភេទក៏ជាបញ្ហាចោទក្នុងគ្រឹះស្ថានអប់រំផងដែរនិងអាចបង្កផលប៉ះពាល់យូរអង្វែងជាពិសេសក្នុងឆ្នាំដំបូងៗនៃជីវិត។ ស្ត្រីដែលរងគ្រោះដោយការបៀតបៀនផ្លូវភេទនៅសាកលវិទ្យាល័យច្រើនតែរស់នៅ និង/ឬសិក្សានៅកៀកនឹងជនបង្ក ។

នៅឆ្នាំ ២០១៩ ការសិក្សាមួយដែលធ្វើឡើងក្នុងប្រទេសឥណ្ឌូនេស៊ី សម្រាប់សម្ព័ន្ធដើម្បីទីសាធារណៈមានសុវត្ថិភាព(KRPA)[601] រកឃើញថាក្នុងចំណោមស្ត្រី ៥ នាក់មានស្ត្រី ៣ នាក់រងគ្រោះដោយការបៀតបៀនផ្លូវភេទនៅទីសាធារណៈ ហើយទម្រង់នៃការបៀតបៀនគឺខុសៗគ្នា ចាប់ពីការបៀតបៀនជាពាក្យសម្ដី រហូតដល់ការបៀតបៀនរាងកាយ និងការបៀតបៀនដែលគ្មានការប៉ះពាល់រាងកាយ និងរួមបញ្ចូល ៖

- ការហួចដាក់
- ការធ្វើសំឡេងថើប
- រឿងកំប្លែងអាសអាភាស ឬការនិយាយពាក់ព័ន្ធនឹងផ្លូវភេទអំពីរាងកាយ ឬសំលៀកបំពាក់
- ការចាប់កញ្ចក់
- ការត្រដុស
- ការបង្ហាញផ្នែកណាមួយនៃរាងកាយ។

សម្រាប់ជាដំណោះស្រាយរយៈពេលខ្លី រដ្ឋាភិបាលទីក្រុងហ្សាការតាចាប់ផ្ដើមដំណើរការមធ្យោបាយដឹកជញ្ជូនតែស្ត្រី សម្រាប់ខ្សែរថយន្តក្រុងឆ្លងកាត់ទីក្រុងហ្សាការតា និងខ្សែរថយន្តក្រុងទៅមក ជាវិធានការការពារ។

ការបៀតបៀនផ្លូវភេទក្នុងកន្លែងធ្វើការក៏ជាបញ្ហាជាសកលផងដែរ ហើយស្ថាប័ននគរបាល និងស្ថាប័នអនុវត្តន៍ច្បាប់ក៏មានករណីបៀតបៀនផ្លូវភេទដូចគ្នានេះដែរ។តាមពិត គេអាចលើកឡើងថាដោយសារតែស្ថាប័នទាំងនេះសំបូរដោយបុរស និងវប្បធម៌ឋានានុក្រម ស្ត្រីដែលធ្វើការក្នុងស្ថាប័ននគរបាល និងស្ថាប័នអនុវត្តន៍ច្បាប់ កាន់តែងាយប្រឈមនឹងការបៀតបៀនផ្លូវភេទ។

ក្នុងនាមជាថ្នាក់ដឹកនាំនគរបាល អ្នកត្រូវធានាថា បុគ្គលិករបស់អ្នកយល់ថា ការបៀតបៀនផ្លូវភេទនឹងមិនត្រូវបានអត់ឱននោះទេហើយប្រសិនបើករណីនេះកើតឡើងអ្នកត្រូវធ្វើអន្តរាគមន៍ភ្លាមៗដើម្បីទប់ស្កាត់ការរីកសាយ និងផ្ដល់សារច្បាស់លាស់ថាអ្នកប្រព្រឹត្តទង្វើនេះត្រូវប្រឈមនឹងវិធានការតឹងរ៉ឹង។

តើអ្នកបានបង្ហាញដល់បុគ្គលិករបស់អ្នកនូវឥរិយាបថសមរម្យចំពោះសហការី និងបង្ហាញថាពួកគេគួរប្រព្រឹត្តចំពោះគ្រប់គ្នាដោយការគោរព និងសេចក្ដីថ្លៃថ្នូរ ឬទេ? ប្រសិនបើស្ថាប័នរបស់អ្នកមានក្រមសីលធម៌ដែលតម្រែតម្រង់អាកប្បកិរិយា ចរិយា សកម្មភាព និងការសម្រេចចិត្ត អ្នកត្រូវធានាថា គ្រប់គ្នាបានដឹងពីខ្លឹមសារពាក់ព័ន្ធ និងធ្វើយ៉ាងណាឱ្យពួកគេអនុវត្តតាម។

តើស្ថាប័នរបស់អ្នកមានគោលនយោបាយប្រឆាំងការបៀតបៀន ឬទេ? ប្រសិនបើមាន តើគោលនយោបាយនោះ ៖

- ងាយស្រួលប្រើប្រាស់និងបង្ហាញដល់បុគ្គលិកគ្រប់រូប ឬទេ?
- ងាយយល់ ឬទេ?
- មានប្រសិទ្ធភាពកម្រិតណា?

តើស្ថាប័នរបស់អ្នកមាននីតិវិធីបណ្ដឹងសាទុក្ខ/បណ្ដឹងសម្រាប់ការរាយការណ៍ពីការបៀតបៀនផ្លូវភេទ ឬការបៀតបៀនក្នុងទម្រង់ផ្សេងទៀត ឬទេ?

- តើនីតិវិធីនោះងាយស្រួលប្រើប្រាស់សម្រាប់បុគ្គលិកគ្រប់រូប ឬទេ?
- តើនីតិវិធីនោះកំណត់ពីការរាយការណ៍ដោយសម្ងាត់ ឬទេ?
- តើនីតិវិធីនោះមានប្រសិទ្ធភាពកម្រិតណា?

គោលនយោបាយ និងនីតិវិធីទាំងនេះគួរត្រូវបានពិនិត្យឡើងវិញជាប្រចាំ និងគួររួមបញ្ចូលបុគ្គលិកដែលមាន

600. "ត្រូវបានកត់សម្គាល់ ៖ កាតព្វកិច្ចការពារសុវត្ថិភាព និងសមភាពរបស់សិស្សនិស្សិតជាស្ត្រីដោយប្រើប្រាស់ច្បាប់ស្ដីពីភារកិច្ចធានាសមភាព និងសិទ្ធិមនុស្សក្នុងវិស័យសាធារណៈ នៅគ្រឹះស្ថានឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ដើម្បីកែលម្អគោលនយោបាយ និងការអនុវត្តស្ដីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី"ឯកសារសង្ខេបផ្លូវច្បាប់ដែលរៀបចំឡើងដោយLouise Whitfield និង Holly Dustin សម្រាប់ដាក់ជូនសម្ព័ន្ធបញ្ឈប់អំពើហិង្សាលើស្ត្រី ខែ មករា ឆ្នាំ ២០១៥។
601. Widadio, N. A, (2019) Many Indonesian Women face sexually harassment: Survey, Coalition for Safe Public Space.

សាវតារ និង/ឬតម្រូវការចម្រុះក្នុងដំណើរការពិនិត្យឡើងវិញនេះ[602]។

អ្នកត្រូវកត់សម្គាល់ថារឿងកំប្លែងឬការចំអែចំអន់អំពីស្ត្រី ក្រុម LGBTQI ជនមានពិការភាព និងក្រុមផ្សេងទៀត អាចបង្កអន្តរាយដល់បរិយាកាសការងាររបស់អ្នកដូចឥរិយាបថជាក់ស្តែង ឬឥរិយាបថផ្លូវភេទដែរ[603]។

ស្ថាប័នសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ជាស្ថាប័នដែលឆ្លើយតបទៅនឹងសហគមន៍ (ទាំងផ្ទៃក្នុង និងខាងក្រៅ) តាមរបៀបដែលគិតគូរពីយេនឌ័រ។ គួរឱ្យសោកស្តាយដែលស្ថាប័នមួយចំនួន ដូចជា នគរបាល "ដែលការពារកិត្តិយសស្ថាប័នរបស់ខ្លួន (close ranks)" ហើយក្នុងករណីមួយចំនួនបែរជាខិតខំស្តីបន្ទោសជនរងគ្រោះទៅវិញ។ ចំណុចនេះ អាចបង្កើតបរិយាកាសការងារបែបអរិភាព ដែលបង្កអន្តរាយដល់ការអនុវត្តការងាររបស់ក្រុម និងបុគ្គល បង្កើនការឈឺថ្កាត់ និងអវត្តមាន និងនាំទៅរកការផ្តល់សេវានគរបាលដែលមិនសូវមានប្រសិទ្ធភាពដល់សហគមន៍មូលដ្ឋាន។

ការស្រាវជ្រាវជាច្រើនឆ្នាំរកឃើញថា ជនរងគ្រោះដោយសារការបៀតបៀនផ្លូវភេទ ប្រឈមនឹងបញ្ហាជាច្រើន ដូចជា ការថប់បារម្ភ ការធ្លាក់ទឹកចិត្ត បញ្ហាពាក់ព័ន្ធនឹងការញ៉ាំអាហារ ការសេពគ្រឿងញៀន និងគ្រឿងស្រវឹង ការផ្លាស់ប្តូរការងារ និងជំងឺបាក់ស្បាត[604]។

អភិក្រមទូទៅមួយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ សម្រាប់ការទប់ស្កាត់ការបៀតបៀនផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃការបៀតបៀន គឺការអប់រំ និងការកសាងការយល់ដឹង ជាពិសេសការអប់រំដែលផ្តោតលើបុរស និងក្មេងប្រុស។ មានការទទួលស្គាល់កាន់តែច្រើនថា ការបណ្តុះបណ្តាលស្តីពីអន្តរាគមន៍របស់អ្នកនៅជិតកន្លែងកើតហេតុ គឺជាទម្រង់ដ៏មានប្រសិទ្ធភាពក្នុងការកសាងការយល់ដឹង និងបង្កើនគណនេយ្យភាព។ អ្នកនៅជិតកន្លែងកើតហេតុ ដូចជា និយោជិក សហការី និងសិស្សនិស្សិតមកពីការអប់រំគ្រប់កម្រិត គួរហ៊ាននិយាយនៅពេលពួកគេ មើលឃើញ ឬបានដឹងពីការបៀតបៀន ឬដាក់បណ្តឹងនៅពេលពួកគេមើលឃើញការបៀតបៀនផ្លូវភេទលើអ្នកដទៃ។ ឧទាហរណ៍ដ៏ល្អមួយនៃអភិក្រមនេះមានបង្ហាញក្នុងជំពូកទី ៩ (ទំនាក់ទំនង)[605]។

## ការរក្សាសុវត្ថិភាពរបស់ស្ត្រី និងក្មេងស្រីពីការបៀតបៀន រួមបញ្ចូលសុវត្ថិភាពរបស់មន្ត្រីនគរបាលជាស្ត្រី

មន្ត្រីនគរបាលគ្រប់ជាន់ថ្នាក់ ត្រូវដើរតួនាទីផ្លាស់ប្តូរក្នុងសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ មន្ត្រីនគរបាលជាស្ត្រីដើរតួនាទីយ៉ាងសំខាន់ ព្រោះពួកគេមានលក្ខណៈសម្បត្តិពិសេសក្នុងការធ្វើឱ្យស្ថាប័ននគរបាលក្លាយជាអ្នកផ្តល់សេវាសំខាន់ៗដែលស្របច្បាប់ និងមានភាពជាតំណាង។ ទោះជាយ៉ាងណា ប្រសិនបើមន្ត្រីនគរបាលជាស្ត្រី មិនត្រូវបានធានាសុវត្ថិភាពក្នុងបរិយាកាសការងាររបស់ពួកគេទេនោះ នគរបាលមុខជាមិនអាចផ្តល់សេវាសំខាន់ៗដល់ស្ត្រី និងក្មេងស្រីបានឡើយ។

> "ជំហររបស់យើងគឺ ប្រសិនបើអ្នកមិនអាចធានាសុវត្ថិភាពស្ត្រីក្នុងជួរនគរបាលបានទេ តើអ្នកអាចកែលម្អស្ថានភាពរបស់ស្ត្រីក្នុងសហគមន៍នេះបានដោយរបៀបណា?"
>
> Jane Townsley (២០១៤) ប្រធានសមាគមអន្តរជាតិនៃនគរបាលជាស្ត្រី

ដូចការពិភាក្សាក្នុងជំពូកទី១០ (ការកសាងស្ថាប័នដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងគណនេយ្យភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី) គោលនយោបាយ "មិនអត់ឱន" ចំពោះការបៀតបៀនផ្លូវភេទមានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ គោលនយោបាយនេះត្រូវធានាថាមន្ត្រីប្រតិបត្តិការនិងអ្នកគ្រប់គ្រង មានឧបករណ៍ពង្រឹងការមិនអត់ឱនចំពោះករណីបៀតបៀនផ្លូវភេទ និងបទល្មើសផ្សេងទៀតដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងស្ថាប័ននេះ ដោយ

602. Pietsch, N (2015), 'Sexual Harassment and Public Space Learning Brief' (27) London, Ontario: Learning Network, Center for Research and Education on Violence against Women and Children.
603. Ibid
604. Smith B. L (2018), 'What it really takes to stop sexual harassment', American Psychological Association, Vol 49 (No.2).
605. Bystander Approach. Graham Goulden for Cultivating Minds UK.

ផ្តោតសំខាន់លើតួនាទីរបស់ពួកគេក្នុងការរក្សាការទទួលខុសត្រូវរបស់មន្ត្រីក្រោមឱវាទ។

ឧបករណ៍ទាំងនោះរួមមានវិធានការការពារសម្រាប់ដើមបណ្តឹង និងអ្នកផ្តល់ព័ត៌មាន ដែលត្រូវគាំទ្រដោយការផ្តល់សារច្បាស់លាស់ដោយថ្នាក់ដឹកនាំអំពីដំណើរការដែលយុត្តិធម៌ និងបន្សុីគ្នានឹងគុណតម្លៃស្ថាប័ន។ តាមរបៀបនេះការរាយការណ៍ពីការបៀតបៀនផ្លូវភេទត្រូវបានចាត់ទុកជាការពង្រឹងរចនាសម្ព័ន្ធក្នុងស្ថាប័នជាជាងប្រឆាំងនឹងវប្បធម៌ស្ងៀមស្ងាត់ដែលត្រូវបានសន្មតមិនត្រឹមត្រូវថាជួយពង្រឹងសម្ព័ន្ធភាពរួម។ ចំណុចនេះរួមបញ្ចូលការប្រកាន់គោលជំហររឹងមាំដោយនគរបាលជាន់ខ្ពស់ និងថ្នាក់ដឹកនាំប្រតិបត្តិចំពោះការមិនអត់ឱនលើទង្វើសងសឹក។ ជាទូទៅ បណ្តឹងលើការបៀតបៀនផ្លូវភេទប្រឈមនឹងការសងសឹកពីបុគ្គលដែលពួកគេចោទប្រកាន់ ដែលមិនត្រូវបានបណ្តេញចេញពីការងារ តាមរយៈការធ្វើឱ្យជីវិតការងាររបស់ពួកគេកាន់តែប្រឈមនឹងការលំបាក រហូតសម្រេចចិត្តឈប់ធ្វើការ។

> "ការអនុវត្តយន្តការរាយការណ៍ដែលគួរឱ្យទុកចិត្ត ជាធាតុផ្សំដ៏សំខាន់មួយក្នុងការធានាទីសុវត្ថិភាពសម្រាប់ឱ្យជនរងគ្រោះរាយការណ៍ពីការប្រព្រឹត្តមិនសមរម្យ"។
>
> ការពិនិត្យឡើងវិញដោយឯករាជ្យលើគោលនយោបាយ និងនីតិវិធីរបស់ UN Women សម្រាប់ការដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (SEA) និងការបៀតបៀនផ្លូវភេទ (SH) របាយការណ៍ចុងក្រោយ ឆ្នាំ ២០១៩

ក្នុងការពង្រឹងទស្សនៈវិស័យនៃ "ការមិនអត់ឱន" របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងរបៀបវារៈអាទិភាពដើម្បីដោះស្រាយការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការក្រុមប្រតិបត្តិគំរូត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៩ដើម្បីទប់ស្កាត់ការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទក្នុងព្រឹត្តិការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិ។ ការសំខាន់គឺក្រុមប្រតិបត្តិគំរូត្រូវបានបង្កើតចេញពីក្រុមការងារកម្រិតខ្ពស់ទទួលបន្ទុកការបៀតបៀនផ្លូវភេទ ដែលចូលរួមក្នុងដំណើរការពិគ្រោះយោបល់ទូលំទូលាយដែលពាក់ព័ន្ធនឹងប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល[606] ។

ក្រមប្រតិបត្តិគំរូរបស់អង្គការសហប្រជាជាតិ ផ្តល់និយមន័យច្បាស់លាស់នៃការបៀតបៀន និងការបៀតបៀនផ្លូវភេទ ដូចខាងក្រោម៖

- **ការបៀតបៀន**ជាទង្វើមិនសមស្រប ឬមិនត្រូវបានស្វាគមន៍ដែលអាច ឬសន្មតថាបង្កការអាក់អន់ចិត្ត ឬការប្រមាថចំពោះនរណាម្នាក់។ ការបៀតបៀនក្នុងទម្រង់ណាក៏ដោយ ដោយសារយេនឌ័រ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ទំនោរផ្លូវភេទ សមត្ថភាពរាងកាយ ភិនភាគ ជាតិពន្ធុ ជាតិសាសន៍ ដើមកំណើតជាតិ សម្ព័ន្ធភាពនយោបាយ អាយុ សាសនាឬមូលហេតុផ្សេងទៀត ត្រូវបានហាមឃាត់ក្នុងព្រឹត្តិការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិ។
- **ការបៀតបៀនផ្លូវភេទ**ជាប្រភេទទង្វើជាក់លាក់ដែលត្រូវបានហាមឃាត់។ ការបៀតបៀនផ្លូវភេទជាទង្វើមិនសមរម្យដែលមានលក្ខណៈផ្លូវភេទ ដែលអាច ឬសន្មតថាបង្កការអាកអន់ចិត្ត ឬការប្រមាថ។ ការបៀតបៀនផ្លូវភេទអាចពាក់ព័ន្ធនឹងទង្វើជាពាក្យសម្តី មិនមែនពាក្យសម្តី ឬពាក់ព័ន្ធនឹងរាងកាយ រួមទាំងទំនាក់ទំនងជាលាយលក្ខណ៍អក្សរនិងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកនិងអាចកើតឡើងរវាងមនុស្សដែលមានយេនឌ័រដូចគ្នា ឬខុសគ្នា។

ក្រមប្រតិបត្តិគំរូរបស់អង្គការសហប្រជាជាតិរៀបរាប់ពីដំណើរការបណ្តឹងរួមទាំងលក្ខខណ្ឌតម្រូវសម្រាប់អ្នករៀបចំព្រឹត្តិការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិក្នុងការចាត់វិធានការសមស្របអនុលោមតាមគោលនយោបាយ បទបញ្ញត្តិ និងវិធានជាធរមានរបស់អង្គការសហប្រជាជាតិ[607]។ វិធានការសមស្របដែលស្នើឡើងដោយក្រមប្រតិបត្តិគំរូរបស់អង្គការសហប្រជាជាតិរួមមាន ៖

- ការស្វែងរកការពិត។
- ការស្នើឱ្យជនបង្កបញ្ឈប់អំពើល្មើសរបស់ខ្លួនភ្លាមៗ។
- ការព្យួរ ឬការបញ្ឈប់លទ្ធភាពរបស់ជនបង្កមិនឱ្យចូលរួមព្រឹត្តិការណ៍របស់ប្រព័ន្ធ អង្គការសហប្រជាជាតិ ឬ

606. ការបញ្ឈប់ការបៀតបៀនផ្លូវភេទក្នុងព្រឹត្តិការណ៍របស់អង្គការសហប្រជាជាតិ (២០១៩) នាយកដ្ឋានយុទ្ធសាស្ត្រគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ គោលនយោបាយ និងអនុលោមភាព។
607. ក្រមប្រតិបត្តិរបស់អង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ការបៀតបៀនរួមទាំងការបៀតបៀនផ្លូវភេទ ក្នុងព្រឹត្តិការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិ។

ការបដិសេធការចុះឈ្មោះចូលរួមក្នុងព្រឹត្តិការណ៍របស់ប្រព័ន្ធអង្គការសហប្រជាជាតិនាពេលអនាគតឬសរុបទាំងពីរ។

- ការបញ្ជូនបណ្តឹងទៅអាជ្ញាធរស៊ើបអង្កេត ឬអាជ្ញាធរវិន័យដែលមានយុត្តាធិការលើជនដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តការបៀតបៀន។
- ការបញ្ជូនរបាយការណ៍ទៅនិយោជក ឬស្ថាប័នដែលមានយុត្តាធិការលើជនដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តការបៀតបៀន ដើម្បីចាត់វិធានការតាមដានបន្តសមស្រប។

ការផ្តល់ជម្រើសរាយការណ៍ដល់ជនរងគ្រោះរួមទាំងការរាយការណ៍ដោយអនាមិក និងជម្រើសមិនរាយការណ៍ក៏ដូចជាជម្រើសផ្លូវការ/ក្រៅផ្លូវការសម្រាប់ដំណោះស្រាយលើករណីបៀតបៀនផ្លូវភេទ អាចជួយពង្រឹងការប្រើប្រាស់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ លើសពីនេះ គោលនយោបាយនៃការបៀតបៀនផ្លូវភេទគួររួមបញ្ចូលយន្តការ ដើម្បីធានាការផ្សព្វផ្សាយជាបន្តបន្ទាប់ស្តីពីវឌ្ឍនភាពករណីដល់ជនរងគ្រោះ រួមទាំងការផ្តល់ព័ត៌មានបច្ចុប្បន្នភាពសង្ខេបជាប្រចាំស្តីពីស្ថានភាព និងក្រោយបញ្ចប់ការស៊ើបអង្កេតដោយមិនធ្វើឱ្យរាំងស្ទះដល់ដំណើរការស៊ើបអង្កេត ដើម្បីពង្រឹងទំនុកចិត្តលើដំណើរការនេះ និងប្រព័ន្ធផ្ទៃក្នុង[608]។

ដំណើរការពិគ្រោះយោបល់ដោយក្រុមការងារកម្រិតខ្ពស់ទទួលបន្ទុកការបៀតបៀនផ្លូវភេទគឺជាផ្នែកដ៏សំខាន់ដែលធានាភាពច្បាប់នៃក្រមប្រតិបត្តិអង្គការសហប្រជាជាតិ ព្រោះដំណើរការនេះបង្ហាញពីភាពម្ចាស់ការរបស់អង្គការសហប្រជាជាតិលើបញ្ហានេះ និងកិច្ចខិតខំប្រឹងប្រែងអនុវត្តគោលការណ៍តម្លាភាពក្នុងដំណើរការនេះ។

នគរបាលដែលខិតខំបង្កើតគោលនយោបាយស្រដៀងគ្នានិងយន្តការពាក់ព័ន្ធអាចទាញប្រយោជន៍យ៉ាងច្រើនពីការពិគ្រោះយោបល់ទូលំទូលាយនិងប្រកបដោយតម្លាភាពស្តីពីការបង្កើតគោលនយោបាយនោះ។ ប្រអប់ ៨ ខាងក្រោមផ្តល់ឧទាហរណ៍មួយនៃការពិនិត្យឡើងវិញ លើការបៀតបៀននៅកន្លែងធ្វើការ ក្នុងកងរាជអាវុធហត្ថកាណាដា (RCMP)។

**ប្រអប់ ៩**

| **ការរងគ្រោះឡើងវិញ** [609] | **ការរងគ្រោះលើកទីពីរ** |
|---|---|
| ការកើតមានអំពើហិង្សាក្នុងជីវិតរបស់មនុស្សពេញវ័យដែលរួមបញ្ចូលជាពិសេសអំពើហិង្សាផ្លូវភេទលើបុគ្គលដែលធ្លាប់រងគ្រោះដោយការរំលោភបំពានផ្លូវភេទនៅវ័យកុមារភាព។ | ការរងគ្រោះដែលកើតឡើងមិនមែនដោយសារលទ្ធផលផ្ទាល់នៃអំពើនោះទេប៉ុន្តែតាមរយៈការឆ្លើយតបមិនគ្រប់គ្រាន់របស់ស្ថាប័ន និងបុគ្គលចំពោះជនរងគ្រោះ។ |

608. ការពិនិត្យឡើងវិញដោយឯករាជ្យលើគោលនយោបាយនិងនីតិវិធីរបស់អង្គការសហប្រជាជាតិសម្រាប់ការដោះស្រាយការ កេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (SEA) និងការបៀតបៀនផ្លូវភេទ (SH)។ របាយការណ៍ចុងក្រោយ ថ្ងៃទី ២៤ខែ ឧសភា ឆ្នាំ ២០១៩ កូប៊ិនហាក។
609. ទិន្នន័យពីការអង្កេតថ្នាក់ជាតិនៅសហរដ្ឋអាមេរិកស្តីពីអំពើហិង្សាលើស្ត្រី(NVAW)(១៩៩៥-១៩៩៩) ក្នុងរបាយការណ៍ដែលលើកឡើងថា ស្ត្រីជាច្រើនទទួលរងអំពើហិង្សាជាលើកដំបូងនៅវ័យកុមារភាព។ ស្ត្រី ៤០% រាយការណ៍ពីការរំលោភបំពានផ្លូវកាយ និង ៩% រាយការណ៍ពីការរំលោភបំពានផ្លូវភេទ។ ស្ត្រីដែលរងគ្រោះដោយការរំលោភបំពានផ្លូវភេទនៅវ័យកុមារភាព ងាយរងគ្រោះដោយការប្រទូស្តកេរខ្មាសមួយផ្សេងទៀតនៅពេលចម្រើនវ័យ រហូតដល់ ២,៥-៤ ដង ជាងស្ត្រីដែលមិនធ្លាប់រងគ្រោះដោយបញ្ហានេះ។ សូមមើល Cividanes GC, Mello AF, Mello MF. Revictimization as a high-risk factor for development of posttraumatic stress disorder: a systematic review of the literature. Braz J Psychiatry. 2018; 00:000-000. https://pubmed.ncbi.nlm.nih.gov/30328955/
610. ការិយាល័យការបរទេស និងខំមិនវែល (២០១៤)ពិធីសារអន្តរជាតិស្តីពីការចងក្រងឯកសារ និងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ ៖ ស្តង់ដារគោលនៃការអនុវត្តល្អបំផុតស្តីពីការចងក្រងឯកសារស្តីពីអំពើហិង្សាផ្លូវភេទជាបទល្មើសក្រោមច្បាប់អន្តរជាតិទីក្រុងឡុងដ៍ ៖ ការិយាល័យការបរទេស និងខំមិនវែល ។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ

ជាទូទៅ អំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានជម្លោះប្រដាប់អាវុធត្រូវបានប្រើប្រាស់ជាមធ្យោបាយសង្គ្រាម ដែលជាញឹកញាប់បង្កឡើងដោយគ្រប់ភាគីក្នុងជម្លោះ។ ដោយសារតែជម្លោះប្រដាប់អាវុធបំផ្លិចបំផ្លាញប្រព័ន្ធនៅមូលដ្ឋានដែលផ្តល់សេវាសំខាន់ៗជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានគេទុកចោលដោយមិនទទួលបាន ឬទទួលបានការគាំទ្រ ឬការការពារឯកទេសតិចតួច។ ក្នុងកាលៈទេសៈទាំងនេះ ទាំងការរងគ្រោះឡើងវិញ និងការរងគ្រោះលើកទីពីរ បានក្លាយជារឿងធម្មតា ព្រោះនគរបាលមានការលំបាកក្នុងការឆ្លើយតបអស់ពីសមត្ថភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលបានកើតឡើងនៅមុននិងក្រោយពេលជម្លោះ ឬក្នុងពេលដែលអរិភាពថយចុះ។ ប្រអប់ ៩ ខាងក្រោមផ្តល់និយមន័យនៃការរងគ្រោះឡើងវិញ និងការរងគ្រោះលើកទីពីរ។

### ប្រអប់ ៦

**ការរាយការណ៍ពីការបៀតបៀននៅកន្លែងធ្វើការក្នុងកងរាជអាវុធហត្ថនៅប្រទេសកាណាដា** (RCMP)

នៅឆ្នាំ ២០១៦ ក្រសួងសុវត្ថិភាពសាធារណៈ បានស្នើឱ្យគណៈកម្មការបណ្តឹង និង ត្រួតពិនិត្យប្រជាពលរដ្ឋ ធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើគោលនយោបាយ និងនីតិវិធីរបស់ RCMPស្តីពីការបៀតបៀននៅកន្លែងធ្វើការព្រមទាំងពិនិត្យនិងវាយតម្លៃការអនុវត្តអនុសាសន៍ដែលលើកឡើងក្នុងរបាយការណ៍ស៊ើបអង្កេតផលប្រយោជន៍សាធារណៈ (២០១៣) ស្តីពីការបៀតបៀននៅកន្លែងធ្វើការរបស់RCMP។របាយការណ៍នេះបញ្ជាក់ថាការបៀតបៀននៅកន្លែងធ្វើការនៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរមួយក្នុង RCMP។ ក្នុងលទ្ធផលរកឃើញរបស់ខ្លួន គណៈកម្មការនេះរកឃើញថា ខណៈដែលថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុង RCMP ខិតខំទប់ស្កាត់ការបៀតបៀន ជាពិសេសនៅកម្រិតផ្នែក គំនិតផ្តួចផ្តើមទាំងនេះនៅមានកម្រិត មានលក្ខណៈបណ្តោះអាសន្ន និងមិនទទួលបានការគាំទ្រចាំបាច់ពីបញ្ជាការដ្ឋាននៅថ្នាក់ជាតិ។ របាយការណ៍នេះបានកំណត់ចំណុចខ្វះខាតជាច្រើន ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ RCMP ក្នុងការទប់ស្កាត់ការបៀតបៀននៅកន្លែងធ្វើការ។ ខាងក្រោមនេះជាឧទាហរណ៍តំណាងនៃចំណុចខ្វះខាតមួយចំនួន ៖

- អសមត្ថភាពក្នុងការអនុវត្តកំណែទម្រង់ ត្រូវបានបង្កប់ក្នុងលក្ខណៈសំខាន់ៗនៃវប្បធម៌អង្គការ និងរចនាសម្ព័ន្ធរបស់ RCMP។
- RCMP មិនបានពង្រឹងវប្បធម៌នៃភាពជាអ្នកដឹកនាំ។ ខណៈដែលអាចមានអ្នកដឹកនាំគំរូជាច្រើនក្នុង RCMP ស្ថាប័ននេះមិនសូវលើកកម្ពស់វប្បធម៌នៃភាពជាអ្នកដឹកនាំក្នុងចំណោមអ្នកគ្រប់គ្រង ប្រធានត្រួតពិនិត្យ និងមន្ត្រីប្រតិបត្តិរបស់ខ្លួននោះទេ។
- ស្តង់ដារកម្រិតខ្ពស់បែបនិម្មិតសម្រាប់ការសន្និដ្ឋានពីការបៀតបៀន។
- មន្ត្រីបញ្ជាការតាមផ្នែក ស្ទើរតែមិនទទួលបានការបណ្តុះបណ្តាលស្តីពីការធ្វើសេចក្តីសម្រេចក្នុងបណ្តឹងស្តីពីការបៀតបៀន។
- ការបៀតបៀននៅកន្លែងធ្វើការ ការរករឿងរំខាន ការបំភិតបំភ័យ និងការបៀតបៀនផ្លូវភេទអាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរលើសមាជិកម្នាក់ៗនិងនិយោជិតនៅRCMPដែលក្នុងករណីខ្លះបង្កអន្តរាយដល់អាជីព និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើផ្លូវចិត្ត និង រូបរាងកាយ។ បញ្ហានេះក៏អាចបង្កផលប៉ះពាល់លើប្រសិទ្ធភាពប្រតិបត្តិការរបស់ RCMP ផងដែរ រួមទាំងការបង្កបញ្ហារ៉ាំរ៉ៃកាន់តែធ្ងន់ធ្ងរពាក់ព័ន្ធនឹងកង្វះនិយោជិត។
- ការបៀតបៀននៅកន្លែងធ្វើការជះផលអវិជ្ជមានលើទំនុកចិត្តរបស់ប្រជាជនកាណាដា ដែលចោទសួរថាតើបញ្ហាផ្ទៃក្នុងរបស់ RCMP បាន "ជ្រួតជ្រាបទៅខាងក្រៅ" និងប៉ះពាល់ដល់ការប្រព្រឹត្តចំពោះសាធារណជន ឬទេ។ របាយការណ៍នេះបានផ្តល់អនុសាសន៍ជាច្រើនដល់RCMP។ខាងក្រោមនេះជាឧទាហរណ៍តំណាងនៃអនុសាសន៍

មួយចំនួន៖
- ពង្រឹងវប្បធម៌នៃភាពជាអ្នកដឹកនាំតាមរយៈការដាក់ចេញលក្ខណៈវិនិច្ឆ័យសម្រាប់ការដំឡើងឋានៈដែលទទួលស្គាល់ជំនាញគ្រប់គ្រង និងតាមរយៈការបង្កើតកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដ៏តឹងរ៉ឹង និងជាកាតព្វកិច្ចសម្រាប់ប្រធានត្រួតពិនិត្យ អ្នកគ្រប់គ្រង និងមន្ត្រីប្រតិបត្តិទាំងចាស់ និងថ្មីទាំងអស់ រួមទាំងវគ្គកម្រិតសាកលវិទ្យាល័យ។
- តាក់តែងឯកសារគោលនយោបាយច្បាស់លាស់និងបន្សុីគ្នាស្តីពីការបៀតបៀនដោយប្រើភាសាសាមញ្ញនិងអាចរកបានក្នុងគេហទំព័រខាងក្រៅរបស់ស្ថាប័ននេះ។
- រៀបចំវគ្គបណ្តុះបណ្តាលដោយផ្ទាល់ជាប្រចាំស្តីពីការបៀតបៀនដោយអ្នកជំនាញដែលមានការបណ្តុះបណ្តាលនិងគុណវុឌ្ឍិ។ គួរតម្រូវឱ្យប្រធានត្រួតពិនិត្យ អ្នកគ្រប់គ្រង និងមន្ត្រីប្រតិបត្តិទាំងចាស់ និងថ្មីទាំងអស់ ចូលរួមវគ្គបណ្តុះបណ្តាលឯកទេសជាប្រចាំ។
- រក្សាទុកអ្នកស៊ើបអង្កេតផ្នែករដ្ឋបាល (មិនមែនបុគ្គលិកស្លៀកឯកសណ្ឋាន) ដែលមានជំនាញ សមត្ថភាព និងការប្តេជ្ញាចិត្តដែលមិនពាក់ព័ន្ធនឹងខ្សែសង្វាក់បញ្ជា ឱ្យធ្វើការស៊ើបអង្កេតករណីបៀតបៀន។
- ធ្វើវិសោធនកម្មគោលនយោបាយនិងនីតិវិធីស្តីពីការបៀតបៀនដើម្បីតម្រូវឱ្យអ្នកស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងភាពអាចជឿទុកចិត្តបាន និងថាតើមានការរំលោភគោលនយោបាយស្តីពីការបៀតបៀន ឬទេ និងត្រូវរាយការណ៍សេចក្តីសន្និដ្ឋានទាំងនេះទៅអ្នកធ្វើសេចក្តីសម្រេចចិត្ត និងតម្រូវឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តកំណត់ថាតើត្រូវទទួលយកសេចក្តីសន្និដ្ឋានរបស់អ្នកស៊ើបអង្កេត ឬទេ? និងសម្រេចថាតើគួរចាត់វិធានការកែខៃ និង/ឬវិធានការវិន័យ ឬទេ។
- ធានាថា មន្ត្រីបញ្ជាការតាមផ្នែកទទួលបានការបណ្តុះបណ្តាលក្នុងថ្នាក់ជាប្រចាំស្តីពីការធ្វើសេចក្តីសម្រេចចិត្តជាពិសេសពាក់ព័ន្ធនឹងការវាយតម្លៃបណ្តឹងលើការបៀតបៀននៅកន្លែងធ្វើការរួមទាំងការធ្វើតេស្តផ្លូវច្បាប់សមស្របដែលត្រូវធ្វើឡើង និងផ្តត់គំនិតដែលពាក់ព័ន្ធនឹងទង្វើរបស់ជនរងគ្រោះដោយសារការបៀតបៀន។

ប្រភព ៖ របាយការណ៍ស្តីពីការបៀតបៀននៅកន្លែងធ្វើការក្នុង RCMP (រដ្ឋាភិបាលកាណាដា ២០១៧)

ជម្លោះប្រដាប់អាវុធបានបន្ថែមភាពស្មុគស្មាញនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬសគល់ និងផលវិបាកនៃអំពើហិង្សា និងរបៀបដែលអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាលើស្ត្រី និងក្មេងស្រី។ ភាពស្មុគស្មាញទាំងនេះទាមទារឱ្យនគរបាលកែសម្រួលយុទ្ធសាស្ត្រស៊ើបអង្កេតរបស់ខ្លួន។ក្នុងពេលមានសន្តិភាពនគរបាលច្រើនតែប្រឈមជាមួយនឹងជនបង្កផ្ទាល់តែម្នាក់ដែលជាទូទៅមានភាពឆ្លាតវៃក្នុងការទទួលខុសត្រូវលើអំពើដែលបានប្រព្រឹត្ត ដូចជា ករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាលនិងការបៀតបៀនផ្លូវភេទដែលជាទម្រង់ទូទៅបំផុតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅជុំវិញពិភពលោក។

ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ទាមទារវិសាលភាពធំទូលាយនៅពេលកំណត់ថាតើមានជនបង្កដោយប្រយោលដែលមានការទទួលខុសត្រូវ លើការបញ្ជា ឬទេ ព្រោះពួកគេអាចខុសពីជនបង្កជាក់ស្តែងដែលរងការចោទប្រកាន់។ យោងតាមពិធីសារអន្តរជាតិស្តីពីការចងក្រងឯកសារ និងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះ (២០១៤) ជនបង្កដោយប្រយោលរួមបញ្ចូលជនដែល "...គ្រប់គ្រងលើឆន្ទៈរបស់ជនបង្កផ្ទាល់ ឬតាមរយៈការគ្រប់គ្រងលើបរិធានអំណាចដែលមានអង្គការចាត់តាំងដូចជា របចនាសម្ព័ន្ធនគរបាល ឬកងទ័ព"[610]។ តួអង្គប្រដាប់អាវុធអាចប្រើប្រាស់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាផ្លូវភេទជាឧបករណ៍សង្គ្រាមដើម្បីគ្រប់គ្រង ឬដាក់ទណ្ឌកម្មលើប្រជាជន[611]។ ដូច្នេះការកំណត់ការទទួលខុសត្រូវលើការបញ្ជាសម្រាប់អំពើដែលប្រព្រឹត្តដោយអ្នកផ្សេងទៀតសម្រាប់ជាមធ្យោបាយឬជាលេសសង្គ្រាមជាលក្ខណៈសំខាន់នៃការស៊ើបអង្កេតដែលផ្តោតលើជនបង្ក។

ទោះជាយ៉ាងណាផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធបង្កការលំបាកដល់ការចូលដល់ជនបង្ក ជាពិសេសជនបង្ក

អំពើហិង្សាដោយប្រយោល និងស្ទើរតែមិនអាចប្រមូលភស្តុតាងជីវសាស្ត្រ ឬភស្តុតាងសម្ភារបាន។ ជាញឹកញាប់ នគរបាលស៊ើបអង្កេតត្រូវផ្អែកលើសក្ខីកម្មរបស់ជនរងគ្រោះ និងសាក្សីដែលហ៊ាននិយាយ ដែលជាទូទៅត្រូវផ្តល់ព័ត៌មាន និងសក្ខីកម្មនៅទីតាំងដែលមិនផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដូចជាជំរំផ្តល់ជម្រកសុវត្ថិភាពដល់ជនដែលត្រូវបាន បណ្តេញចេញពីទីលំនៅដោយបង្ខំ។

អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ជាពិសេសអំពើហិង្សាផ្លូវភេទ ក៏ធ្វើឱ្យនគរបាលមានការលំបាកក្នុងការផ្តល់ការការពារផងដែរ។ ក្នុងបរិបទទាំងនេះ នគរបាល និងកងកម្លាំងសន្តិសុខរដ្ឋផ្សេងទៀតច្រើនតែគ្មានសមត្ថភាពធានាការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះ និង/ឬសាក្សីនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬក៏ពួកគេផ្ទាល់ស្រុះស្រួល ឬសមគំនិតគ្នាក្នុងអំពើហិង្សាដែលរងការចោទប្រកាន់ ឬករណីទាំងពីរ។ ដូច្នេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការសាយភាយអាវុធធុនតូចដែលបង្កើនហានិភ័យរបស់ស្ត្រី និងក្មេងស្រីនិងបង្កហានិភ័យដល់មន្ត្រីនគរបាលឆ្លើយតប។

"សម្រាប់ស្ត្រីភាគច្រើនក្នុងមជ្ឈដ្ឋានក្រោយពេលជម្លោះ អំពើហិង្សាមិនបញ្ចប់ទៅតាមបទឈប់បាញ់ផ្លូវការឬការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពឡើយ និងជាញឹកញាប់ កើនឡើងក្នុងមជ្ឈដ្ឋានក្រោយពេលជម្លោះទៅវិញ"។

អនុសាសន៍រួមលេខ ៣០ របស់គណៈកម្មាធិការ CEDAW

ការបញ្ចប់ជម្លោះប្រដាប់អាវុធមិនមានន័យថាជាការបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនោះទេ។ អ្នកជំនាញបានចងក្រងឯកសារស្តីពីការកើនឡើងយ៉ាងខ្លាំងនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះក្រោយការបញ្ចប់សង្គ្រាមនិងក្នុងអំឡុងពេល"សន្តិភាព"[612]។ ការសិក្សាមួយចំនួនគូសបញ្ជាក់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ នៅតែបង្កឡើងដោយក្រុមប្រដាប់អាវុធរដ្ឋ និងក្រុមប្រដាប់អាវុធមិនមែនរដ្ឋក្នុងរយៈពេល ៥ ឆ្នាំក្រោយជម្លោះ ហើយបទល្មើសភាគច្រើនបង្កឡើងដោយកងកម្លាំងរដ្ឋ[613]។

ការកើនឡើងយ៉ាងខ្លាំងនៃការប្រព្រឹត្តអំពើហិង្សាក្រោយពេលជម្លោះ ឬក្នុងបរិបទនៃការកសាងសន្តិភាព ត្រូវបានជំរុញដោយការសាយភាយអាវុធធុនតូច និងធុនស្រាល (SALW) និងការប្រើប្រាស់អាវុធមិនបានត្រឹមត្រូវ។ ឧ. ការស្រាវជ្រាវពីប្រទេសស៊ែបបង្ហាញថា ជនបង្កដែលធ្លាប់ប្រឡូកក្នុងសង្គ្រាម/ជម្លោះយោធា (២២,២%) ងាយនឹងប្រើអាវុធធុនតូច និងធុនស្រាល ក្នុងករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាលជាងជនបង្កអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលមិនធ្លាប់ប្រឡូកក្នុងជម្លោះយោធា (៨,៨%)[614]។

ផលប៉ះពាល់នៃសង្គ្រាមលើជនស៊ីវិលមានលក្ខណៈផ្អែកខ្លាំងតាមយេនឌ័រ។ រាងកាយរបស់ស្ត្រី និងក្មេងស្រីបានក្លាយជាផ្នែកមួយនៃសមរភូមិ ព្រោះស្ត្រី និងក្មេងស្រីគឺជាគោលដៅនៃការចាប់ជំរិតការប្រើប្រាស់ជាទាសករផ្លូវភេទដែលបំពេញតម្រូវការកងទ័ពនិងចម្អិនអាហារឱ្យកងទ័ព ក៏ដូចជាលីសែងរបស់របរកងទ័ពពីជំរំមួយទៅជំរំមួយ[615]។ ក្រៅពីការប្រឈមនឹងអំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទ ស្ត្រី និងក្មេងស្រីក៏ងាយរងគ្រោះខ្លាំងដោយសារជំងឺកាមរោគ ដូចជា មេរោគអេដស៍/ជំងឺអេដស៍ និងមិនទទួលបានការយកចិត្តទុកដាក់ដោយសារអំពើហិង្សានេះផងដែរ។ ការជម្លៀសចេញដោយបង្ខំដោយសារជម្លោះប្រដាប់អាវុធ និងវិបត្តិមនុស្សធម៌ផ្សេងទៀត បានបង្កើនហានិភ័យនៃ

611. អ្នកនិពន្ធសៀវភៅណែនាំនេះទទួលស្គាល់ទាំងស្រុងថា បុរស និងក្មេងប្រុសក៏ប្រឈមនឹងអំពើហិង្សាផ្លូវភេទក្នុងជម្លោះប្រដាប់អាវុធដែរ។ សម្រាប់ករណីទាំងនេះ សៀវភៅណែនាំនេះលើកយកឯកសារបោះពុម្ពផ្សាយដែលមានចំណងជើងថា "ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារលើបុរស៖ សេចក្តីណែនាំសម្រាប់ស្ថាប័នក្នុងវិស័យសន្តិសុខ។ Watson, C. Geneva: DCAF, 2014។

612. សូមមើល Swaine, Aisling (2018), Conflict-Related Violence Against Women: Transforming Transition, Cambridge: Cambridge University Press; Hossain, Naomi (2012), Security and the Pathways of Women's Empowerment: Findings from a Thematic Synthesis of the Pathways of Women's Empowerment Research, IDS Working Paper 406, Brighton: Institute of Development Studies.

613. សូមមើល Cohen, Dara Kay, Amelia Hoover Green and Elisabeth Jean Wood (2013), Wartime sexual violence: misconceptions, implications and ways forward, Special Report, Washington D.C.: US Institute for Peace. Also see: Aolain, Fionnuala Ni, and Eilish Rooney (2007)," Under enforcement and Intersectionality: Gendered Aspects of Transition for Women," International Journal of Transitional Justice, Vol. 1, Issue 3, pp. 338–54 in Women's Meaningful Participation in Negotiating Peace and the Implementation of Peace Agreements Report of the Expert (2018). Convened by UN Women in preparation for the UN Secretary-General's report on Women and Peace and Security, New York, U.S.

614. យេនឌ័រ និងអាវុធធុនតូច និងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍ (២០១៦) មជ្ឈមណ្ឌលត្រួតពិនិត្យអាវុធធុនតូចនិងធុនស្រាលនៅអឺរ៉ុបអាគ្នេយ៍និងបូព៌ា (SEESAC).https://www.seesac.org/f/docs/Armed-Violence/Gender_and_SALW_publication_eng-web.pdf

615. ស្ត្រី សង្គ្រាម និងសន្តិភាព៖ ការវាយតម្លៃរបស់អ្នកជំនាញឯករាជ្យស្តីពីផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធលើស្ត្រី និងតួនាទីរបស់ស្ត្រីក្នុងការកសាងសន្តិភាព (២០០២)។ Rehn, E., and Sirleaf, E.J. United Nations Development Fund for Women (UNIFEM)។

អំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសអំពើហិង្សាលើដៃគូស្និទ្ធស្នាល[616]។ នគរបាលត្រូវឆ្លើយតបទៅនឹងការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលកំពុងរស់នៅក្នុងជំរំ។ ក្នុងស្ថានភាពទាំងនេះការបំពេញតម្រូវការចាំបាច់ប្រចាំថ្ងៃដូចជាទឹក អាហារ ឬបង្គន់អនាម័យ អាចបង្កគ្រោះថ្នាក់ដល់ស្ត្រីនិងក្មេងស្រី។ ការឆ្លើយតប (ការទប់ស្កាត់ និងការស៊ើបអង្កេត) ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងជំរំទាំងនោះ តម្រូវឱ្យនគរបាលសហការជាមួយជនដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តខ្លាំង ដែលអាចគ្មានអ្នកដឹកនាំតំណាង។រាល់អន្តរាគមន៍របស់នគរបាលត្រូវពិចារណាពីភាពផុយស្រួយនៃទំនាក់ទំនងសង្គមថ្មីៗទាំងនេះ និងអត្ថន័យនៃទំនាក់ទំនងនេះចំពោះសុខុមាលភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

វិទ្យាស្ថានស្រាវជ្រាវអំពើហិង្សាផ្លូវភេទ (SVRI) លើកឡើងថា ក្នុងស្ថានការណ៍មិនទៀងទាត់ទាំងនេះ គឺជាញឹកញាប់អំពើហិង្សាផ្លូវភេទកាន់តែកើនឡើង អាពាហ៍ពិពាហ៍កុមារអាចកើនឡើង ហើយស្ត្រី និងក្មេងស្រីងាយរងគ្រោះខ្លាំងដោយសារអំពើហិង្សានៅដំណាក់កាលនីមួយៗនៃដំណើរជីវិតរបស់ពួកគេ ដូចជា ក្នុងពេលរត់គេច ក្នុងពេលស្វែងរកទីជម្រក ក្នុងប្រទេសឆ្លងកាត់ និងនៅពេលពួកគេវិលត្រឡប់ទៅស្រុកកំណើតដែលរងការបំផ្លិចបំផ្លាញដោយសង្គ្រាម[617]។

ទោះបីជាមានបញ្ហាប្រឈមទាំងនេះក្តី ក៏ច្បាប់អន្តរជាតិតម្រូវឱ្យរដ្ឋទាំងឡាយស៊ើបអង្កេតការចោទប្រកាន់ទាំងអស់ដែលពាក់ព័ន្ធនឹងករណីអំពើហិង្សាផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលបានកើតឡើងក្នុងពេលមានជម្លោះប្រដាប់អាវុធក្នុងដែនដីរបស់ខ្លួន។ ជាក់ស្តែងគឺរដ្ឋភាគច្រើនដែលងើបចេញពីជម្លោះប្រដាប់អាវុធខិតខំធ្វើការស៊ើបអង្កេតនិងផ្តន្ទាទោសអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះដោយមិនគិតពីទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលបានកើតឡើងជារៀងរាល់ថ្ងៃ និងអំពើហិង្សាដែលបានកើតឡើងនាពេលកន្លងមកនោះទេ។



រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

ដើម្បីដោះស្រាយនិទណ្ឌភាពនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ និងក្នុងករណីដែលរដ្ឋទាំងឡាយមិនអាចឬគ្មានឆន្ទៈស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី សហគមន៍ អន្តរជាតិដែលជាទូទៅដឹកនាំដោយអង្គការសហប្រជាជាតិ អាចធ្វើការស៊ើបអង្កេតដំណាលគ្នានៅក្រៅប្រព័ន្ធតុលាការ ឬគាំទ្រដល់រដ្ឋពាក់ព័ន្ធក្នុងការស៊ើបអង្កេតបទព្រហ្មទណ្ឌលើករណីទាំងនេះ។ អន្តរាគមន៍នៃយន្តការស៊ើបអង្កេតអន្តរជាតិទាមទារការគាំទ្រក្នុងស្រុក ជាពិសេសនគរបាលជាតិ នៅពេលមិនពាក់ព័ន្ធនឹងការរំលោភបំពាន។ អន្តរាគមន៍ទាំងនេះនឹងទាញប្រយោជន៍ពីសមត្ថភាពរបស់អ្នកគ្រប់គ្រងក្នុងជួរនគរបាលក្នុងការចូលរួមជាមួយអ្នកដែលដឹកនាំ និងធ្វើការងារស៊ើបអង្កេតអន្តរជាតិលើករណីទាំងនេះ។ ក្នុងករណីដែលរដ្ឋទទួលខុសត្រូវជាហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ICC មានយុត្តាធិការក្នុងការស៊ើបអង្កេតលើការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សនៅពេលប្រព័ន្ធតុលាការជាតិរបស់រដ្ឋនោះមិនអាច ឬគ្មានឆន្ទៈធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសដោយខ្លួនឯងបាន[618]។

616. អន្តរាគមន៍ដើម្បីកាត់បន្ថយអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងមជ្ឈដ្ឋានមនុស្សធម៌(២០១៩) វិទ្យាស្ថានស្រាវជ្រាវអំពើហិង្សាផ្លូវភេទ និងក្រុមធនាគារពិភពលោក។

617. Ibid

618. សូមមើលមាត្រា ១៧ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិ A/CONF.183/9 ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ 37 I.L.M. 1002, 1030 (ចូលជាធរមាន ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០២) (ហៅកាត់ថា លក្ខន្តិកៈទីក្រុងរ៉ូម)។

### ប្រអប់ ៧

**និយមន័យនៃជនភៀសខ្លួន និងជនបាត់បង់ទីលំនៅក្នុងប្រទេស (IDP)**

| ជនភៀសខ្លួន | ជនបាត់បង់ទីលំនៅក្នុងប្រទេស |
|---|---|
| ជនភៀសខ្លួន ជានរណាម្នាក់ដែលស្ថិតនៅក្រៅប្រទេសកំណើតរបស់ខ្លួនដែលត្រូវការការពារពីអន្តរជាតិដោយសារតែការគំរាមកំហែងធ្ងន់ធ្ងរលើអាយុជីវិត បូរណភាពរាងកាយឬសេរីភាពក្នុងប្រទេសកំណើតដែលបណ្តាលមកពីការធ្វើទុក្ខបុកម្នេញ ជម្លោះប្រដាប់អាវុធ អំពើហិង្សា ឬចលាចល ដែលអាជ្ញាធរក្នុងប្រទេសកំណើតរបស់ពួកគេមិនអាច ឬនឹងមិនការពារពួកគេ។ | បុគ្គល ឬក្រុមដែលត្រូវបានបង្ខំ ឬតម្រូវឱ្យរត់គេចឬចាកចេញពីផ្ទះសម្បែង ឬទីជម្រក ជាពិសេសដោយសារតែ ឬដើម្បីបញ្ចៀសផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ ស្ថានភាពអំពើហិង្សាទូទៅ ការរំលោភសិទ្ធិមនុស្ស ឬគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស និងមិនបានឆ្លងព្រំដែនរដ្ឋដែលទទួលស្គាល់ជាអន្តរជាតិ។ |
| ប្រភព៖A/AC96/830និងអាណត្តិការពារជនភៀសខ្លួនរបស់UNHCRអនុលោមតាមកថាខណ្ឌ 6 A (ii) នៃលក្ខន្តិកៈរបស់ UNHCR (សេចក្តីសម្រេចលេខ ៤២៨ (V) របស់មហាសន្និបាត ឧបសម្ព័ន្ធ) | ប្រភព ៖ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបាត់បង់ទីលំនៅក្នុងប្រទេស (១៩៩៨) |




ដោយមិនគិតពីថាតើនរណាជាអាជ្ញាធរមានសមត្ថកិច្ចសេចក្តីណែនាំដែលឆ្លើយតបនឹងយេនឌ័រដែលលើកឡើងក្នុងសៀវភៅណែនាំនេះជាការសំអាងសមស្របសម្រាប់នគរបាលដែលស៊ើបអង្កេតករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ព្រោះទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិសុទ្ធតែអនុវត្តក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ[619]។ សមត្ថភាពដែលគិតគូរពីយេនឌ័រដែលបានលើកឡើងក្នុងសៀវភៅណែនាំនេះ ក៏អាចអនុវត្តបានផងដែរចំពោះអ្នកជំនាញផ្នែកពលរដ្ឋក្រោមអាណត្តិរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដូចជា គណៈកម្មការស្រាវជ្រាវអន្តរជាតិបេសកកម្មស្វែងរកការពិតនិងស្ថាប័នស៊ើបអង្កេតផ្សេងទៀតដែលខិតខំស៊ើបអង្កេតការចោទប្រកាន់លើការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ (IHRL) ច្បាប់មនុស្សធម៌អន្តរជាតិ (IHL) ឬច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ទៅតាមភាពពាក់ព័ន្ធ) និងផ្តល់អនុសាសន៍សម្រាប់វិធានការកែតម្រូវដោយផ្អែកតាមសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់។

សមត្ថភាពដែលគិតគូពីយេនឌ័រដែលបានលើកឡើងក្នុងសៀវភៅណែនាំនេះ គឺជាសសរស្តម្ភសំខាន់ៗសម្រាប់ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹង ជម្លោះ។ ទោះបីជាការប្រើប្រាស់អំពើហិង្សាលើស្ត្រី និងក្មេងស្រីជាមធ្យោបាយសង្គ្រាម មានការវិវត្តក្តី ប៉ុន្តែបរិបទប្រែប្រួលទៅតាមការអភិវឌ្ឍបច្ចេកវិទ្យា ហើយជនបង្កដោយប្រយោលនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ រិះរកវិធីគេចវេសពីការទទួលខុសត្រូវ។ អ្នកស៊ើបអង្កេត ឬមន្ត្រីឆ្លើយតបអាចជានាការចូលរួមប្រកបដោយអត្ថន័យពីជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ គួបផ្សំនឹងការយល់ច្បាស់ពីវិសាលភាពបន្ថែមទៀតនៃជម្លោះប្រដាប់អាវុធលើឫសគល់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនិងផលវិបាកនៃអំពើហិង្សា និងរបៀបដែលអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាលើស្ត្រី និងក្មេងស្រី នគរបាលនិងអ្នកស៊ើបអង្កេតជាជនស៊ីវិលអាចរួមចំណែកល្អបំផុតដល់អាណត្តិស៊ើបអង្កេត។ដូច្នេះ និទណ្ឌភាពមិនលេចឡើងក្នុងពេលមានជម្លោះប្រដាប់អាវុធនោះទេ។

ចំណុចចុងក្រោយគឺ ការប្រើប្រាស់សៀវភៅណែនាំនេះក្នុងវិបត្តិមនុស្សធម៌គួរបំពេញបន្ថែមដោយគោលការណ៍ណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារស្តីពីអន្តរាគមន៍អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងមជ្ឈដ្ឋាន

មនុស្សធម៌ដោយផ្ដោតសំខាន់លើការទប់ស្កាត់និងការឆ្លើយតបទៅនឹងអំពើហិង្សាផ្លូវភេទក្នុងគ្រាអាសន្ន(២០០៥)[620]។

### ការណែនាំគ្នាទៅវិញទៅមក ៖ ការឆ្លើយតបនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការជម្លៀសចេញដោយបង្ខំ

ស្ថានភាពសន្តិសុខនៅជុំវិញពិភពលោកចេះតែវិវត្ត ហើយយើងមើលឃើញជម្លោះក្នុងតំបន់ជាច្រើន ដែលខ្លះជាជម្លោះថ្មី ហើយជម្លោះជាច្រើនអូសបន្លាយពេលជាច្រើនឆ្នាំ ដែលបណ្ដាលឱ្យមានការជម្លៀសប្រជាជនកាន់តែច្រើន ឬមិនថយចុះ។ ចំណុចនេះបានបង្កបញ្ហាប្រឈមដល់នគរបាលនិងសេវាអនុវត្តន៍ច្បាប់ក្នុងប្រទេសផ្ដល់ជម្រកដល់ជនភៀសខ្លួនដែលរត់គេចពីជម្លោះក្នុងប្រទេសរបស់ពួកគេ។

សុវត្ថិភាពនិងការការពារជនបាត់បង់ទីលំនៅរួមទាំងជនបាត់បង់ទីលំនៅក្រៅប្រទេស ដូចជា ជនភៀសខ្លួនបានក្លាយជាបន្ទុករបស់ប្រទេសទទួលយកជនទាំងនោះ។ ក្នុងនាមជាមន្ត្រីនគរបាលអ្នកមិនអាចគេចវេសមិនទទួលខុសត្រូវលើសុវត្ថិភាព និងការការពារពួកគេ ដោយសារតែពួកគេត្រូវបានបង្ខាំងក្នុងជំរំជនភៀសខ្លួនដែលគ្រប់គ្រងដោយអង្គការអន្តរជាតិ ដូចជា UNHHCR បានឡើយ។



រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

លំហូរចូលជនភៀសខ្លួនយ៉ាងច្រើន បានបង្កបញ្ហាប្រឈមជាច្រើនដល់ប្រទេសពាក់ព័ន្ធក្នុងការផ្ដល់សេវានគរបាលដែលមានប្រសិទ្ធភាពដល់ជនភៀសខ្លួន និងសហគមន៍ម្ចាស់ស្រុក។ បញ្ហាប្រឈមមួយបានលេចឡើងនៅស្រុក Cox's Bazar ប្រទេសបង់ក្លាដេសដែលមានជនភៀសខ្លួនរ៉ូហ៊ីនយ៉ាចំនួន ៨៥៤.៧៤០ នាក់។ ជនភៀសខ្លួនទាំងនេះបានរត់គេចតាមព្រំដែនប្រទេស មីយ៉ាន់ម៉ា និងកំពុងរស់នៅក្នុងជំរំជនភៀសខ្លួនចំនួន ៣៤ ក្នុងប្រទេសបង់ក្លាដេស។

នគរបាលបង់ក្លាដេសកំពុងប្រឈមនឹងបញ្ហាប្រឈមធំៗជាពិសេសមន្ត្រីនៅប៉ុស្តិ៍នគរបាលដែលត្រូវពង្រាយធនធានមានកម្រិតរបស់ខ្លួនដល់ប្រជាជនយ៉ាងច្រើន។ ខណៈដែលមានការដាក់ពង្រាយធនធាននគរបាលបន្ថែមទៅ

---

619. សម្រាប់ព័ត៌មានបន្ថែម សូមមើល ការការពារសិទ្ធិមនុស្សផ្អែកតាមច្បាប់អន្តរជាតិក្នុងជម្លោះប្រដាប់អាវុធ (UNHCHR, ២០១១).
620. ក្រោមការបង្កើតឡើងដោយសេចក្ដីសម្រេចលេខ ៤៦/១៨២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៩១ គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ ជាវេទិកាសម្របសម្រួលមនុស្សធម៌យូរអង្វែងជាងគេនិងកម្រិតខ្ពស់ជាងគេនៃប្រព័ន្ធអង្គការសហប្រជាជាតិដែលកៀរគរប្រធានផ្នែកប្រតិបត្តិមកពីស្ថាប័នក្នុងអង្គការសហប្រជាជាតិនិងស្ថាប័នខាងក្រៅចំនួន ១៨ ដើម្បីធានាសនិទ្ធភាពនៃការត្រៀមខ្លួន និងកិច្ចខិតខំប្រឹងប្រែងឆ្លើយតប គាក់តែងគោលនយោបាយ និងកំណត់អាទិភាពសម្រាប់ការពង្រឹងសកម្មភាពមនុស្សធម៌។ សូមមើលគណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ។

ស្រុក Cox's Bazar ចំនួននគរបាលនៅតែតិច បើធៀបនឹងចំនួនមនុស្សយ៉ាងច្រើនដែលបានចូលមកក្នុងតំបន់នេះ មិនមែនត្រឹមតែជនភៀសខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបុគ្គលិកទីភ្នាក់ងារជំនួយយ៉ាងច្រើនដែលភាគច្រើនមកពីក្រៅប្រទេសបង់ក្លាដេសទៀតផង។

ក្នុងនាមជាអធិការនគរបាលក្នុងតំបន់ដែលមានជនភៀសខ្លួនយ៉ាងច្រើនអ្នកនឹងត្រូវពង្រីកធនធានមានកម្រិតរបស់អ្នក ហើយការស្នើសុំបុគ្គលិកបន្ថែមមិនមែនជាដំណោះស្រាយងាយស្រួលឡើយ ប្រសិនបើអ្នកគ្មានហេដ្ឋារចនាសម្ព័ន្ធដើម្បីសម្រួលដល់ពួកគេ។ នេះជាការពិតក្នុងករណីដែលចាំបាច់ត្រូវបង្កើនចំនួនមន្ត្រីជាស្ត្រីដើម្បីគាំទ្រដល់ចំនួនយ៉ាងច្រើននៃជនរងគ្រោះ ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលជាញឹកញាប់ លេចឡើងក្នុងស្ថានភាពមានជម្លោះ និងស្ថានភាពក្រោយជម្លោះ។

ដោយសារការរត់គេចពីជម្លោះគ្រួសាររបស់ជនភៀសខ្លួនជាច្រើនត្រូវបានដឹកនាំដោយស្ត្រីព្រោះប្ដីនិង/ឬកូនប្រុសអាចត្រូវបានសម្លាប់ក្នុងជម្លោះ ឬកំពុងប្រយុទ្ធក្នុងប្រទេសកំណើតនៅឡើយ។ គ្រួសារយ៉ាងច្រើនដែលមានស្ត្រីជាមេគ្រួសារអាចបង្កើនភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារជាពិសេសក្នុងបរិបទវប្បធម៌ផ្សេងៗ។ ដូចការលើកឡើងពីខាងដើមក្នុងសៀវភៅណែនាំនេះអ្នកនិងបុគ្គលិករបស់អ្នកត្រូវស្វែងយល់ពីជាតុផ្សំនៃវប្បធម៌ក្នុងសហគមន៍ដែលអ្នកផ្ដល់សេវាជូន រួមទាំងជាតុផ្សំនៃវប្បធម៌របស់ជនភៀសខ្លួន និងជនបរទេសផ្សេងទៀតដែលកំពុងរស់នៅក្នុងស្រុកដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់អ្នក។

អាចមានជនរងគ្រោះយ៉ាងច្រើនដែលមានពិការភាពផ្សេងៗដោយសារតែភាពយង់ឃ្នងដែលពួកគេទទួលរង និងរត់គេច។ដូច្នេះវាបានបន្ថែមការលំបាកដល់អ្នកនិងបុគ្គលិករបស់អ្នកក្នុងការផ្ដល់ លទ្ធភាពទទួលបានសេវាយុត្តិធម៌។

សូមមើលជំពូកទី ៤ (ទំនាក់ទំនងដំបូង) ជំពូកទី ៥ (ការស៊ើបអង្កេត) និងជំពូកទី ៨ (ការគាំទ្រ និងជំនួយ) ដើម្បីទទួលបានការណែនាំបន្ថែមស្ដីពីការធានាថាជនរងគ្រោះអាចទទួលបានសេវាពាក់ព័ន្ធ។

បញ្ហាផ្សេងទៀតដែលអ្នក និងបុគ្គលិករបស់អ្នកអាចប្រឈមក្នុងការផ្ដល់សេវានគរបាលដល់ជនភៀសខ្លួនយ៉ាងច្រើន រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ៖

- ឧបសគ្គផ្នែកភាសា។
- កង្វះលទ្ធភាពទទួលបាននីតិវិធីភស្តុតាង ដូចជា អ្នកពិនិត្យកោសលវិច័យ។
- កង្វះការយល់ដឹងពីវប្បធម៌ និងប្រពៃណីរបស់ជនភៀសខ្លួន។
- កង្វះការយល់ដឹងរបស់ជនភៀសខ្លួនជាស្ត្រី និងក្មេងស្រីស្ដីពីសិទ្ធិរបស់ពួកគេ។
- កង្វះការយល់ដឹងរបស់ជនភៀសខ្លួនស្ដីពីលទ្ធភាពទទួលបានយុត្តិធម៌ និងសេវាគាំទ្រដើម្បីទទួលបានសិទ្ធិរបស់ពួកគេ។
- ភាពតានតឹងកាន់តែខ្លាំងក្នុងសហគមន៍ម្ចាស់ស្រុកចំពោះជនភៀសខ្លួន។
- ការកើនឡើងនូវក្រុមជនល្មើសដែលមានអង្គការចាត់តាំងក្នុងតំបន់នោះ ដែលតែងតែកេងប្រវ័ញ្ចជនងាយរងគ្រោះ។
- កង្វះទំនុកចិត្តរបស់សហគមន៍ជនភៀសខ្លួនលើបុគ្គលិកផ្ដល់សេវា "ដែលស្លៀកឯកសណ្ឋាន" (ឧ. ជនភៀសខ្លួនរ៉ូហ៊ីនយ៉ាអាចផ្សារភ្ជាប់បុគ្គលិកស្លៀកឯកសណ្ឋានទៅនឹងអំពើហិង្សា និងភាពយង់ឃ្នងក្នុងប្រទេសកំណើតរបស់ពួកគេ)។
- កង្វះមូលដ្ឋានវេជ្ជសាស្ត្រ និងធនធានចាំបាច់ផ្សេងទៀតដើម្បីធានាសុវត្ថិភាពរបស់ជនរងគ្រោះនិងទទួលបានភស្តុតាងសម្រាប់ការស៊ើបអង្កេត។

ខណៈដែលមានបញ្ហាប្រឈមក្នុងការផ្ដល់សេវានគរបាលប្រកបដោយប្រសិទ្ធភាពក្នុងស្ថានភាពវិបត្តិជនភៀសខ្លួនមានឱកាសដែលអ្នកត្រូវចាប់យកដើម្បីផ្ដល់ប្រយោជន៍ដល់ជនរងគ្រោះក៏ដូចជារូបអ្នកផ្ទាល់និងបុគ្គលិករបស់អ្នក។

ឱកាសទាំងនេះច្រើនតែលេចឡើង តាមរយៈទីភ្នាក់ងារផ្ដល់ជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលតែងផ្ដល់ការគាំទ្រទាំងក្នុងជំរំជនភៀសខ្លួន និងដល់សហគមន៍ម្ចាស់ស្រុក។ អ្នកគួរលើកទឹកចិត្តឱ្យបុគ្គលិករបស់អ្នកចូលរួមក្នុងមូលដ្ឋានជាមួយអ្នកដែលធ្វើការក្នុងទីភ្នាក់ងារ និងអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ។


រូបថតទទួលបានពី UNAMID/Albert Gozalez Farran (តំបន់ដាហ្វួរ ប្រទេសស៊ូដង់)

ការបង្កើតទំនាក់ទំនងតាមមូលដ្ឋានអាចផ្តល់មធ្យោបាយជំរុញការចូលរួមជាមួយជនភៀសខ្លួន និងសហគមន៍មូលដ្ឋានតាមរយៈគម្រោងនិងគំនិតផ្តួចផ្តើមដែលអនុវត្តដោយភាគីផ្សេងទៀត។ តាមរយៈការចូលរួមបែបប្រតិសកម្មជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ អ្នកអាចរិះរកវិធីសហការដែលបម្រើឱ្យផលប្រយោជន៍ល្អបំផុតរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។កិច្ចសហការអាចបង្កើនលទ្ធភាពរបស់ជនរងគ្រោះក្នុងការរាយការណ៍ពីការប្រព្រឹត្តបទល្មើសលើពួកគេតាមរយៈការនិយាយជាមួយអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវា ដូចជាវេជ្ជសាស្ត្រ ការអប់រំ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដែលបន្ទាប់មកអាចបញ្ជូនទៅរកអ្នកផ្តល់សេវាយុត្តិធម៌។

ក្រៅពីនេះកិច្ចសហការអាចនាំទៅរកការផ្តល់ហេដ្ឋារចនាសម្ព័ន្ធបន្ថែមដើម្បីសម្រួលដល់នគរបាលក្នុងជំរំ ឬនៅទីតាំងជិតជំរំ។ ឧទាហរណ៍មួយគឺការបង្កើត "ផ្នែកផ្តល់ជំនួយដល់ស្ត្រី" នៅប៉ុស្តិ៍នគរបាលក្នុងជំរំជនភៀសខ្លួន ២ នៅស្រុក Cox's Bazar ប្រទេសបង់ក្លាដេស និងសេវាបន្ថែមទៀត។ ក្រោមការគាំទ្រដោយ UN Women ហេដ្ឋារចនាសម្ព័ន្ធទាំងនេះបានផ្តល់កន្លែងស្នាក់នៅសម្រាប់មន្ត្រីជាស្ត្រីដែលអាចឱ្យមន្ត្រីទាំងនោះផ្តល់សេវា ២៤ ម៉ោងក្នុងជំរំ និងផ្តល់ការគាំទ្រយ៉ាងច្រើនទៅតាមតម្រូវការរបស់ជនរងគ្រោះ ក៏ដូចជាស្នងការនគរបាល និងអ្នកស៊ើបអង្កេត។

ការចូលរួមជាមួយដៃគូជាតិនិងដៃគូអន្តរជាតិមិនត្រឹមតែកសាងទំនាក់ទំនងនិងបណ្តាញទំនាក់ទំនងក្នុងមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់វិធីផ្សេងទៀតដល់អ្នកក្នុងការចូលរួមដោយផ្ទាល់ជាមួយសហគមន៍ផ្សេងៗតាមរយៈកម្មវិធីផ្សព្វផ្សាយតាមសហគមន៍ទៀតផង។ នៅពេលអ្នកកសាងទំនុកចិត្ត និងភាពជឿជាក់ជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត និងសហគមន៍ អ្នកនឹងអាចកសាងការយល់ដឹងស្តីពីរបៀបដែលស្ថាប័នដៃគូអាចគាំទ្រគ្នាទៅវិញទៅមក និងផ្តល់ការគាំទ្ររួមដល់ជនរងគ្រោះ។ ការកសាងទំនុកចិត្ត និងភាពជឿជាក់របស់ប្រជាជនក្នុងមូលដ្ឋាននឹងអាចឱ្យអ្នក និងបុគ្គលិករបស់អ្នកប្រមូលព័ត៌មាន និងចារកម្មស្តីពីបទល្មើសផ្សេងទៀតដែលបានប្រព្រឹត្ត និងផ្តល់ឱកាសសម្រាប់កសាងការយល់ដឹងស្តីពីការទប់ស្កាត់បទល្មើស។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការធ្វើការងារបែបសហការ និងដំណោះស្រាយក្នុងសហគមន៍ សូមមើលជំពូកទី ៣ (ការទប់ស្កាត់) ជំពូកទី ៦ (សុវត្ថិភាព និងការការពារ) និងជំពូកទី ៧ (ការគាំទ្រ និងជំនួយ)។

### ប្រអប់ ៩

## ស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន



រូបថតទទួលបានពី Force International (ប្រទេសបង់ក្លាដេស)

មន្ត្រីនគរបាលដែលធ្វើការក្នុង និងជុំវិញជំរំជនភៀសខ្លួន/ជនបាត់បង់ទីលំនៅក្នុងប្រទេសអាចប្រឈមនឹងបញ្ហាយ៉ាងច្រើនទាំងក្នុងការអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក។ កង្វះធនធានក្នុងដំណើរការយុត្តិធម៌ អាចនាំទៅរកការផ្តោតអាទិភាពលើបទល្មើសធ្ងន់ធ្ងរបំផុត ទោះបីជាជនរងគ្រោះអាចទទួលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរក្រោយឧប្បត្តិហេតុដែលអាចបង្កើតជាបទល្មើសមិនសូវធ្ងន់ធ្ងរក្នុងច្បាប់ជាតិក្តី។

ចំណុចផ្តោតក្នុងស្ថានភាពទាំងនេះត្រូវតែជាសុវត្ថិភាព និងការការពារជនរងគ្រោះពីគ្រប់ទម្រង់នៃអំពើហិង្សា និង/ឬការរំលោភបំពាន ព្រមទាំងកុមារដែលអាចជាជនរងគ្រោះ ឬសាក្សី។ នៅត្រង់ចំណុចនេះហើយដែលកិច្ចសហការជាមួយអ្នកផ្តល់សេវាផ្សេងទៀតអាចផ្តល់អត្ថប្រយោជន៍ពិតប្រាកដដល់ជនរងគ្រោះ ក៏ដូចជានគរបាលផ្ទាល់ ដែលអាចឱ្យនគរបាលប្រើប្រាស់ធនធានស៊ើបអង្កេតដែលមានកម្រិតរបស់ខ្លួន ផ្តោតលើជនបង្ក។

ខណៈដែលកសាងទំនាក់ទំនងក្នុងមូលដ្ឋានរវាងនគរបាលនិងអ្នកផ្តល់សេវាផ្សេងទៀតគួរធ្វើឡើងនៅគ្រប់ទីតាំងជាញឹកញាប់ សេវានៅក្នុង និងជុំវិញជំរំជនភៀសខ្លួន ឬជនបាត់បង់ទីលំនៅក្នុងប្រទេស ត្រូវប្រឈមនឹងតម្រូវការជំនួយយ៉ាងច្រើនលើសលប់។ ដើម្បីធានាការប្រើប្រាស់ធនធានមានកម្រិតប្រកបដោយប្រសិទ្ធភាព ការធ្វើការក្នុងភាពជាដៃគូនឹងផ្តល់លទ្ធផលវិជ្ជមាន។ ការអនុវត្តការងារដូច្នេះធានាការបង្កើត និងរក្សាបណ្តាញទំនាក់ទំនងដើម្បីបញ្ចៀសសារប្រឫកប្របល់ ឬសារអវិជ្ជមានរវាង និងពីស្ថាប័នផ្សេងៗដែលត្រូវបានដាក់ពង្រាយ។

ទំនាក់ទំនងទាំងនេះជួយកសាងការយល់ដឹងយ៉ាងទូលំទូលាយស្តីពីបញ្ហាប្រឈមរបស់មនុស្សគ្រប់រូបនិងកសាងទំនុកចិត្ត និងភាពជឿជាក់ក្នុងស្ថាប័នដែលអាចផ្តល់ប្រយោជន៍ដល់ការឆ្លើយតបផ្នែកមនុស្សធម៌ទាំងមូល។ គេអាចលើកឡើងថា នគរបាលដែលធ្វើការក្នុង និងជុំវិញជំរំជនភៀសខ្លួន នឹងទទួលបានការគាំទ្រ និងជំនួយសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយសារតែជាញឹកញាប់ មានស្ថាប័នជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលយ៉ាងច្រើនធ្វើការពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។ ស្ថាប័នដែលផ្តល់ជំនួយវេជ្ជសាស្ត្រប្រហែលជាអាចជួយដល់ជនរងគ្រោះដែលត្រូវការការព្យាបាលឬចន្លោះសុវត្ថិភាពដើម្បីនិយាយជាមួយនគរបាលឬអាស្រ័យលើជំនាញដែលមាន ទទួលការពិនិត្យផ្នែកវេជ្ជសាស្ត្រដោយមិនចាំបាច់ចាកចេញ ឬធ្វើដំណើរឆ្ងាយពីជំរំ។

ស្ថាប័នដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ឬការបង្កើនភាពអង់អាចដល់ស្ត្រី ប្រហែលជាអនុញ្ញាតឱ្យមាននគរបាលនិយាយជាមួយជនរងគ្រោះក្នុងជំរំ ជាជាងតម្រូវឱ្យពួកគេទៅកាន់ប៉ុស្តិ៍នគរបាល ដែលអាចបង្កការលំបាកដល់ពួកគេ។ ចំណុចសំខាន់គឺមន្ត្រីនគរបាលត្រូវមានភាពប្រតិសកម្មក្នុងការចូលរួមជាមួយអ្នកដែលអាចក្លាយជាដៃគូដើម្បីបញ្ជាក់ថាតើកិច្ចសហការអាចផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះដោយរបៀបណា?

### ឧទាហរណ៍ជាក់ស្តែងដែលត្រូវពិចារណា

អាម៉េណា បានភៀសខ្លួនចេញពីប្រទេសមីយ៉ាន់ម៉ាជាមួយកូនតូចៗ ៣ នាក់។ បច្ចុប្បន្ន នាងជាមេគ្រួសារដែលរស់នៅក្នុងជំរំជនភៀសខ្លួនមួយនៅស្រុក Cox's Bazar។ ប្តីរបស់នាងបានស្លាប់នៅពេលព្យាយាមការពារកុំឱ្យគេដុតផ្ទះរបស់គាត់ ក្នុងអំឡុងនៃការវាយប្រហារភូមិកំណើតក្នុងរដ្ឋ Rakhine។ សព្វថ្ងៃ នាងទទួលខុសត្រូវទាំងស្រុងលើការផ្គត់ផ្គង់គ្រួសារ និងទៅកន្លែងផ្តល់ជំនួយជារៀងរាល់ថ្ងៃ ដើម្បីទទួលបានអាហារ និងទឹកសម្រាប់ចិញ្ចឹម

កូន។ រសៀលថ្ងៃមួយ បន្ទាប់ពីបានបើកទឹក និងអង្ករួចហើយ នាងបានត្រឡប់មកជម្រកក្នុងជំរំវិញ ប៉ុន្តែនៅតាមផ្លូវ មានអ្នកវាយប្រហារលួចយកទឹក និងអាហាររបស់នាង។

ជនជាតិរ៉ូហ៊ីនយ៉ាមួយគ្រួសារបានឃើញ អាម៉េណា ដេកដួលលើដៃដោយមានសំលៀកបំពាក់រញ៉េរញ៉ៃ។ នាងមានទឹកមុខក្រៀមក្រំ និងពោរពេញដោយទុក្ខព្រួយ។ ពួកគេបាននាំនាងទៅកាន់មជ្ឈមណ្ឌលរបស់ UN Women ហើយនាងបានទទួលការព្យាបាលផ្នែក វេជ្ជសាស្ត្រ។ បុគ្គលិក UN Women បានរាយការណ៍ឧប្បត្តិហេតុនេះទៅនគរបាល។

ពេលទៅដល់មជ្ឈមណ្ឌលរបស់ UN Women អ្នកដឹងថា អាម៉េណា ត្រូវបានទៅមន្ទីរពេទ្យ ហើយនាងមានកូនតូច ៣ នាក់ដែលរស់នៅតែលតោល។ អ្នកជួបជាមួយគ្រួសារជនជាតិរ៉ូហ៊ីនយ៉ាដែលបានឃើញ អាម៉េណា ហើយពួកគេបាននាំអ្នកទៅកន្លែងកើតហេតុ។ មានមនុស្សជាច្រើនដើរទៅមក ហើយអ្នកបានធ្វើការកត់សម្គាល់ក្នុងការពិនិត្យបឋមនៅជិតៗតំបន់នោះនិងរកឃើញថាតំបន់នោះមិនសូវមានភ្លើងបំភ្លឺប៉ុន្តែនៅឆ្ងាយពីទីនោះបន្តិចគឺជម្រករបស់គ្រួសារជនភៀសខ្លួនយ៉ាងច្រើនស្អេកស្កះ។ អ្នកកត់សម្គាល់ទៀតថា មានបង្គន់ និងកន្លែងលាងសម្អាតដៃដែលនៅមិនឆ្ងាយប៉ុន្មានទេ។

**តើអ្វីជាអាទិភាពចំពោះមុខរបស់អ្នក?** សុវត្ថិភាព និងការការពារជនរងគ្រោះ និងកូនទាំង ៣ របស់នាង និងត្រូវអនុវត្តដំណើរការវាយតម្លៃហានិភ័យភ្លាមៗ។

**តើអ្នកនឹងប្រឈមជាមួយនឹងបទល្មើសអ្វីខ្លះ?** ការប្រទូស្តកេរខ្មាស (សំលៀកបំពាក់ជនរងគ្រោះរញ៉េរញ៉ៃ) ការឆក់ប្លន់ ចោរកម្ម។

**នៅចំណាក់កាលចំបូងនេះ តើមានកន្លែងកើតហេតុប៉ុន្មានកន្លែង?** កន្លែងរកឃើញ អាម៉េណា អាម៉េណាផ្ទាល់ក៏ជាកន្លែងកើតហេតុដែរ កន្លែងប្រព្រឹត្តបទល្មើស ប្រសិនបើមិនមែនទេ កន្លែងដែលគេរកឃើញនាង។ ក្រៅពីនេះ អាចជាកន្លែងដែលនាងស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់ UN Women និងយានជំនិះដែលដឹកបញ្ជូននាងទៅមន្ទីរពេទ្យ ប្រសិនបើមានប្រើអាវុធទីតាំងរកឃើញអាវុធអាចជាកន្លែងកើតហេតុ។

**តើអាចមានភស្តុតាងអ្វីខ្លះ?** សក្ខីកម្មរបស់ជនរងគ្រោះ សក្ខានុពលនៃភស្តុតាងរបស់សាក្សី អាចជាអ្នកដែលបានមើលឃើញការវាយប្រហារផ្ទាល់ ឬមើលឃើញនរណាម្នាក់ធ្វើអ្វីគួរឱ្យសង្ស័យ ឬគេចចេញពីកន្លែងកើតហេតុ ដូចជាអ្នកចេញចូលបង្គន់ឬកន្លែងលាងសម្អាតដៃប្រហែលជាបានមើលឃើញអ្វីមួយភស្តុតាងវេជ្ជសាស្ត្រនិង/ឬកោសលវិច័យភស្តុតាងនៃ បណ្តឹងទីមួយ/ជំបូងពីគ្រួសារជនជាតិ រ៉ូហ៊ីនយ៉ាដែលរកឃើញ អាម៉េណា និងបុគ្គលិក UN Women អ្វីក៏អាចជាភស្តុតាងដែរ។ ពោលគឺគួរពិចារណាពីចំណុចគ្រប់យ៉ាង។

**តើអ្នកនឹងធានាសុវត្ថិភាព និងរក្សាទុកអ្វីដែលអាចក្លាយជាភស្តុតាងដោយរបៀបណា?** ធានាសុវត្ថិភាពតំបន់ជុំវិញដែលគេរកឃើញ អាម៉េណា ដោយឈរជើងនៅទីនោះ ឬចាត់ឱ្យសហការីការពារកុំឱ្យនរណាម្នាក់ប៉ះពាល់/ចេញចូលកន្លែងកើតហេតុការប្រើខ្សែហ៊ុមព័ទ្ធឬខ្សែចងផ្សេងទៀតដើម្បីហ៊ុមព័ទ្ធនឹងកាត់បន្ថយចំនួនធនធានមនុស្សចាំបាច់(ត្រឹមតែម្នាក់)។

កំណត់ថាតើអាចមានសាក្សីណាម្នាក់ (យ៉ាងតិច) ទទួលបានខ្លឹមសារលម្អិតសង្ខេបស្តីពីព័ត៌មានដែលពួកគេអាចនឹងដឹង ឬទេ ឬថាតើអាចទាក់ទងទៅពួកគេនៅពេលក្រោយបានដែរ ឬទេ ប្រសិនបើចាំបាច់។ ពិចារណាដាក់នគរបាលល្បាតក្នុងតំបន់នេះនិងជុំវិញបង្គន់ និងកន្លែងលាងសម្អាតដៃ ដើម្បីផ្តល់ការធានាឡើងវិញដល់សហគមន៍ និងកិច្ចខិតខំប្រឹងប្រែងស្វែងរកសាក្សី ក៏ដូចជាទប់ស្កាត់មិនឱ្យមានបទល្មើសស្រដៀងគ្នានេះកើតឡើងជាថ្មី។

សេណារីយ៉ូខាងលើផ្តល់ដោយ Force International Limited និងមិនផ្អែកលើឧប្បត្តិហេតុជាក់ស្តែងណាមួយ ឬមនុស្សណាម្នាក់ឡើយ។

## ការសម្របសម្រួលការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងប្រភពនៃជម្លោះ

ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ(CR-VAWG) ជាពិសេសនៅពេលដែលមានការពាក់ព័ន្ធនឹងសកម្មភាពដែលប្រព្រឹត្តដោយប៉ូលីសប្រដាប់អាវុធនៅក្នុងជម្លោះ នឹងទាមទារឲ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីរបៀបដែល VAWG ត្រូវបានប្រើប្រាស់ក្នុងសង្គ្រាម។ បើទោះបីវាជាបញ្ហាប្រឈមរបស់ប៉ូលីស ប៉ុន្តែការស៊ើបអង្កេតលើអំពើហិង្សាលើស្ត្រី និងក្មេងស្រីពាក់ព័ន្ធនឹងជម្លោះ នឹងទាមទារឲ្យមានជំនាញសំខាន់ៗដើម្បីធ្វើការវិភាគដោយផ្អែកលើភស្តុតាងទាក់ទងនឹងអំពើហិង្សាបែបនេះ រួមទាំងបរិបទូលំទូលាយដែលបញ្ជាក់យ៉ាងច្បាស់ថា អំពើហិង្សាផ្លូវភេទគឺជា ផ្នែកសំខាន់មួយនៃបទល្មើសដែលមានការរៀបចំជាជាងគ្រាន់តែជាឧប្បត្តិហេតុ "ចៃដន្យ" ឬ "ឱកាសនិយម" ដែលជាចំនុច "ស្នូល" នៃឧក្រិដ្ឋកម្មផ្សេងទៀតដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃសង្គ្រាម ៤១។

ឧ. ការសិក្សាមួយស្ដីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះដោយ WHO (២០០៥) នៅប្រទេសលីបេរីយ៉ា[623] បង្ហាញថា ក្នុងចំណោមអ្នកចូលរួម ១.២១៦នាក់មានអ្នកចូលរួម៩៥%ធ្លាប់រងគ្រោះដោយទម្រង់មួយចំនួននៃអំពើហិង្សាផ្អែកលើយេនឌ័រ។ ក្នុងនោះអ្នកតបសម្ភាសន៍ចំនួន ៧៣,៩% ត្រូវបានគេរំលោភសេពសន្ថវៈក្នុងពេលមានសង្គ្រាម និងចំនួន ១៣,០% ត្រូវបានគេរំលោភសេពសន្ថវៈក្រោយពេលជម្លោះ[624]។ ក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងក្រោយជម្លោះ ជនបង្កគឺជាអតីតយុទ្ធជន។ នៅឆ្នាំ ២០០៧ ករណីចំនួន ៤៦% ដែលត្រូវបានរាយការណ៍ទៅនគរបាលជាតិលីបេរីយ៉ា ពាក់ព័ន្ធនឹងកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ។ ដូចគ្នានេះដែរ ក្នុងចំណោមករណីការពារចំនួន ៥.០០០ ករណីដែលត្រូវបានរាយការណ៍ករណី ៣៨% មានលក្ខណៈជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ ហើយក្នុងរយៈពេល ៣ ខែដំបូងនៃឆ្នាំ ២០០៨ មានការរាយការណ៍ពីករណីចំនួន ១.៩៣៥។ ក្នុងនោះ ករណី ៣៤% ពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ[652]។ ករណីអំពើរំលោភសេពសន្ថវៈមានចំនួនច្រើនជាងគេក្នុងចំណោមបទល្មើសផ្លូវភេទផ្សេងទៀត ដែលត្រូវបានកត់ត្រានៅអំឡុងខែ កញ្ញា-វិច្ឆិកា ឆ្នាំ ២០០៨[626]។

ក្នុងរបាយការណ៍របស់គាត់ស្ដីពីអំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ (S/2017/249) អគ្គលេខាធិការអង្គការសហប្រជាជាតិបានកំណត់និយមន័យពាក្យ "អំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ" ថាសំដៅលើ ការរំលោភសេពសន្ថវៈ ទាសករផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានផ្ទៃពោះដោយបង្ខំ ការបង្ខំឱ្យរំលូតកូន ការក្រៀវដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាដែលបង្កលើស្ត្រី បុរស ក្មេងស្រី ឬក្មេងប្រុសដែលពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលនឹងជម្លោះ[627]។

របាយការណ៍នេះបង្ហាញទៀតថា ភាពពាក់ព័ន្ធនេះអាចលេចឡើងក្នុងសារតាររបស់ជនបង្ក (ដែលជាញឹកញាប់ពាក់ព័ន្ធនឹងក្រុមប្រដាប់អាវុធរដ្ឋ ឬមិនមែនរដ្ឋ រួមទាំងស្ថាប័ន ឬបណ្ដាញភេរវករ) សារតាររបស់ជនរងគ្រោះ (ដែលជាញឹកញាប់ជាសមាជិកជាក់ស្ដែងឬជាសមាជិកសន្មតរបស់ក្រុមជនជាតិភាគតិចនយោបាយ ជាតិពន្ធុ ឬសាសនាដែលទទួលរងការធ្វើទុក្ខបុកម្នេញ ឬក្លាយជាគោលដៅដោយសារទំនោរផ្លូវភេទជាក់ស្ដែង ឬតាមការសន្មត និង អត្តសញ្ញាណយេនឌ័រ) បរិយាកាសនិទណ្ឌភាព (ដែលជាទូទៅពាក់ព័ន្ធនឹងភាពអសកម្មរបស់រដ្ឋ) ផលវិបាកឆ្លងដែន (ដូចជា ការបណ្ដេញចេញពីទីលំនៅ ឬការជួញដូរមនុស្ស) និង/ឬការរំលោភបទបញ្ញត្តិនៃកិច្ចព្រមព្រៀងឈប់បាញ់។ ពាក្យនេះក៏រួមបញ្ចូលការជួញដូរមនុស្ស នៅពេលត្រូវបានប្រព្រឹត្តក្នុងស្ថានភាពជម្លោះសម្រាប់គោលបំណងនៃអំពើហិង្សា/ការកេងប្រវ័ញ្ចផ្លូវភេទផងដែរ[628]។

ដើម្បីកែសម្រួលទៅតាមការវិវត្តនៃជម្លោះ និងការប្រើប្រាស់អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះដោយតួអង្គប្រដាប់អាវុធ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតបណ្ដាញវិធានការរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះនៅឆ្នាំ២០០៧ សម្រាប់ជាគំនិតផ្ដួចផ្ដើមរួមនៅ

623. របាយការណ៍ស្ដីពីអំពើហិង្សាផ្លូវភេទផ្អែកលើយេនឌ័រនិងការវាយតម្លៃតម្រូវការមូលដ្ឋានសុខភាព (Lofa, Nimba, Grand Gedeh and Grand Bassa counties) in Liberia (2005). Omanyondo, M.O. for the World Health Organisation។
624. កម្មវិធីរបស់រដ្ឋាភិបាលសហការជាមួយអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់និងឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨)។ ព័ត៌មានត្រូវបានចែករំលែកដោយ Dr. Sadiq Syed អនុប្រធានកម្មវិធីរបស់ UN Women ប្រចាំតំបន់អាហ្វ្រិចខាងត្បូង។
625. Ibid
626. បទល្មើសផ្លូវភេទ ដែលបានប្រព្រឹត្តនៅខែ កញ្ញា តុលា និងវិច្ឆិកា ឆ្នាំ ២០០៨ នៅប្រទេសលីបេរីយ៉ា (UNPOL-ខែ ធ្នូ ឆ្នាំ ២០០៨) ព័ត៌មានត្រូវបានចែករំលែកដោយ Dr. Sadiq Syed អនុប្រធានកម្មវិធីរបស់ UN Women ប្រចាំតំបន់អាហ្វ្រិចខាង ត្បូង។
627. របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្ដីពីអំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ (២០១៧) ឯកសារអង្គការសហប្រជាជាតិ S/2017/249។
628. Ibid



រូបថតទទួលបានពី UNMIL/Christopher Herwig (ប្រទេសលីបេរីយ៉ា)

ទូទាំងប្រព័ន្ធអង្គការសហប្រជាជាតិ ដើម្បីជាត្រីវិស័យសម្រាប់ប្រព័ន្ធកសាងចំណេះដឹង និងសម្របសម្រួលក្នុងចំណោមតួអង្គផ្សេងទៀតដោយកត់សម្គាល់ថាកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់និងឆ្លើយតបដែលមានលក្ខណៈរប៉ាត់រប៉ាយគឺជាចំណុចរាំងស្ទះដល់ការដោះស្រាយអំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធនឹងជម្លោះ។ ចាប់ពីពេលនោះមកប្រព័ន្ធអង្គការសហប្រជាជាតិ រួមទាំងស្ថាប័ននានា ដូចជា នាយកដ្ឋានប្រតិបត្តិការសន្តិភាព (DPO),OHCHR, UN Women និង UNDP បាបអង្កេតអំពើហិង្សាលើស្ត្រីដែលពាក់ព័ន្ធនឹងជម្លោះដែលផ្តល់អត្ថប្រយោជន៍ដល់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ ឧទាហរណ៍បន្ថែមទៀត រួមមាន ៖

- ការផ្តល់ជម្រើសដល់ជនរងគ្រោះ/សាក្សីក្នុងការនិយាយជាមួយអ្នកស៊ើបអង្កេតជាស្ត្រីឬបុរសនិង/ឬអ្នកបកប្រែជាការអនុវត្តល្អ។ ដូច្នេះ ក្រុមស៊ើបអង្កេតដែលមានយេនឌ័រចម្រុះ គឺល្អបំផុត។ ក្រុមចម្រុះមានប្រយោជន៍បំផុតក្នុងករណីដែលអ្នកឃ្លាំមើលនៅកម្រិតកណ្តាលគឺជាបុរស។
- គួរបញ្ចៀសការសន្មតពាក់ព័ន្ធនឹងការចង់បានរបស់ជនរងគ្រោះក្នុងការសម្ភាសន៍ រួមទាំងការគិតរបស់ពួកគេចំពោះការនិយាយជាមួយបុរស។
- ការបង្កើតទំនាក់ទំនងការងារជាមួយអង្គការមូលដ្ឋាននិងអង្គការអន្តរជាតិដែលផ្តល់សេវាវេជ្ជសាស្ត្រក្នុងគ្រាអាសន្ន គួរតែជាអាទិភាព។ ឧ. អង្គការ គ្រូពេទ្យគ្មានព្រំដែនគឺជាដៃគូដ៏សំខាន់ក្នុងការកំណត់អត្តសញ្ញាណនិងគាំទ្រជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ។
- ផ្តោតលើការផ្តល់ជម្រើសដើម្បីឱ្យជនរងគ្រោះចូលរួមប្រកបដោយអត្ថន័យជាជាងការផ្តោតដោយចំហលើ "លទ្ធផល" ស៊ើបអង្កេតដែលនឹងរឹតត្បិតជម្រើសរបស់ជនរងគ្រោះ។
- ទស្សនៈនៃភាពប្រទាក់ក្រឡាគ្នាគឺសំខាន់ណាស់សម្រាប់ការស៊ើបអង្កេត។ ឧ. អ្នកស៊ើបអង្កេតងាយនឹងមើលរំលងមូលហេតុនៃការសម្លាប់ស្ត្រីចំណាស់នៅពេលដែលស្ត្រីទាំងនោះក្លាយជាគោលដៅរបស់ជនប្រដាប់អាវុធ ដែលមានគោលបំណងលុបបំបាត់ប្រវត្តិសាស្ត្ររបស់សហគមន៍នោះ




- ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ សំដៅលើការធានាថាជនរងគ្រោះបានដឹងពីផលវិបាកផ្លូវច្បាប់នៃអំពើហិង្សាដែលប្រព្រឹត្តលើពួកគេ។ ក្នុងករណីខ្លះ ស្ត្រីមិនបានដឹងថាអំពើដែលបានប្រព្រឹត្តលើពួកគេ បង្កើតបានជាអំពើហិង្សាផ្លូវភេទឡើយ។
- ការពឹងផ្អែកខ្លាំងពេកលើភស្តុតាងជីវសាស្ត្រសម្រាប់ការបញ្ជាក់ករណីរំលោភសេពសន្ថវៈអាចប្រែជាអសារបង់។ ព័ត៌មានតាមបរិបទដែលត្រូវបានប្រមូលយ៉ាងល្អ និងប៉ិនប្រសប់ អាចគាំទ្រដល់ធាតុផ្សំចាំបាច់សម្រាប់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព។ ឧ. អ្នកជំនាញអង្គការសហប្រជាជាតិដែលស៊ើបអង្កេតបទចោទប្រកាន់អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះមានភាពប៉ិនប្រសប់ក្នុងការផ្តល់ឯកសារយោងដែលលម្អិតពីប្រភេទយានជំនិះយោធាដែលយកមកប្រើប្រាស់ និងឯកសណ្ឋានរបស់ជនប្រដាប់អាវុធក្នុងការសម្ភាសន៍ជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីជួយកសាងភស្តុតាងផ្អែកតាមកាលៈទេសៈដែលគាំទ្រដល់ការផ្តល់សក្ខីកម្ម។
- ការកសាងភាពជាដៃគូជាមួយតួអង្គចម្រុះ ជាបណ្តុំជំនាញដែលគួរមានការវិនិយោគយូរអង្វែងជាពិសេសភាពជាដៃគូជាមួយតួអង្គមូលដ្ឋាននិងតួអង្គអន្តរជាតិ

ដែលផ្តល់ជំនួយមនុស្សធម៌។

- ធានាថា ការវិភាគយេនឌ័រពង្រឹងការស៊ើបអង្កេតតាមរយៈការរួមចំណែកដល់ការវិភាគដែលលើកឡើងពីផលប៉ះពាល់នៃស្ថានភាពមនុស្សធម៌ ឬវិបត្តិមួយចំនួនលើបុគ្គល ឬប្រជាជនផ្សេងៗ រួមទាំងស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស ក៏ដូចជាក្រុមភាគតិច។ ការវិភាគដែលគិតគូរពីយេនឌ័រអាចរួមចំណែកដល់ការកំណត់រកតម្រូវការ និងផ្តល់អនុសាសន៍សមស្របសម្រាប់ការការពារ ក៏ដូចជាការគាំទ្រ និងជំនួយ។
- ការវាស់វែងភាពល្អប្រសើរនៃសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ជាកត្តាសំខាន់។ ចំណុចនេះគួរចាប់ផ្តើមពីការកំណត់ការបណ្តុះបណ្តាលដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់បណ្ឌិតសភានគរបាលដោយមានម៉ូឌុលបណ្តុះបណ្តាលជាក់លាក់ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងកត្តាជំរុញអំពើហិង្សានេះ ដូចជា ជម្លោះប្រដាប់អាវុធ សម្រាប់សិក្ខាកាមទាំងអស់ដើម្បីធានាថា នគរបាលមិនចាត់ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រីជារឿងធម្មតាទាំងក្នុងពេលមានសន្តិភាព និងក្នុងពេលមានវិបត្តិ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការអនុវត្តល្អបំផុតនៃអភិក្រមផ្អែកតាមសិទ្ធិសម្រាប់ការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ សូមមើលឯកសាររបស់ OHCHR ដែលមានចំណងជើងថា ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការណែនាំនិងការអនុវត្តការស៊ើបអង្កេតសិទ្ធិមនុស្ស (២០១៨)។

## យន្តការសម្រាប់ការកសាងភាពជាដៃគូ

ដូចការពិភាក្សាខាងលើការស៊ើបអង្កេតពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ អាចជាដំណើរការលំបាក ជាពិសេសនៅពេលគ្មានបទបញ្ជាជាក់លាក់ពីជនបង្កអំពើហិង្សាដោយប្រយោលឱ្យអ្នកដទៃទៀតប្រព្រឹត្តអំពើហិង្សានោះ។ នគរបាលស៊ើបអង្កេតត្រូវមានភាពប៉ិនប្រសប់ក្នុងការប្រមូលភស្តុតាងដើម្បីបញ្ជាក់បន្ថែមលើសកម្មភាពរបស់ជនរងគ្រោះ និងសាក្សី សំខាន់ៗផ្សេងទៀត ដើម្បីធានាការទទួលខុសត្រូវរបស់ជនបង្កដោយប្រយោលនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះតាមរយៈបទបញ្ជាជាក់លាក់របស់ពួកគេភាពអសកម្មនៃការទទួលខុសត្រូវលើបទបញ្ជារបស់ពួកគេ និង/ឬតាមរយៈឥរិយាបថរបស់ពួកគេក្នុងតួនាទីសិទ្ធិអំណាចដែលញុះញង់ឱ្យមានអំពើហិង្សានោះ។

> "មិនចាំបាច់បញ្ជាក់ថា បទល្មើសនេះនឹងមិនត្រូវបានប្រព្រឹត្តឡើងដោយគ្មានការពាក់ព័ន្ធជាមួយជនជាប់ចោទនោះទេ។ (ផ្ទុយទៅវិញ) គេអាចបង្ហាញថា ការញុះញង់គឺជាកត្តាមួយដែលរួមចំណែកយ៉ាងច្រើនដល់ទង្វើរបស់បុគ្គលម្នាក់ផ្សេងទៀតដែលប្រព្រឹត្តបទល្មើសនេះ។"
>
> អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordi ć & Čerkez
> សំណុំរឿងលេខ IT -95-14/2-A សាលដីកា ២៧ (ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤)

ការប្រមូលភស្តុតាងទាំងនេះនឹងទាមទារការសហការជាមួយស្ថាប័ននានា ទាំងស្ថាប័នក្នុងស្រុក និងស្ថាប័នអន្តរជាតិដែលអាចចូលដល់ជនរងគ្រោះ និងសាក្សីសំខាន់ៗតាមរយៈតួនាទីគាំទ្រផ្នែកមនុស្សធម៌របស់ស្ថាប័នទាំងនោះក្នុងជម្លោះប្រដាប់អាវុធ។ ទោះជាយ៉ាងណា នគរបាលត្រូវខិតខំកសាងទំនុកចិត្តជាមួយស្ថាប័នទាំងនេះដែលតំណាងឱ្យផលប្រយោជន៍របស់ជនរងគ្រោះ និងសហគមន៍របស់ពួកគេដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តដោយសារជម្លោះ។ វិធីមួយដែលនគរបាលអាចកសាងទំនុកចិត្ត និងភាពជាដៃគូក្រោយជម្លោះគឺត្រូវគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងយន្តការដែលខិតខំបង្កើនភាពអង់អាចរបស់ស្ត្រី រួមទាំងមន្ត្រីនគរបាលជាស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព។

សូមមើលជំពូកទី ៨ (ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌) សម្រាប់ការពិភាក្សានានា រួមទាំងឧទាហរណ៍នៃភាពជាដៃគូដែលអាចជាមូលដ្ឋានសម្រាប់ការឆ្លើយតបដែលកាន់តែមានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

ក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះនគរបាលត្រូវស្តាប់មតិរបស់ជនរងគ្រោះដោយផ្ទាល់ដើម្បីឱ្យដឹងថាតើជម្លោះប្រដាប់អាវុធបង្កផលប៉ះពាល់ដូចម្តេចលើពួកគេនិងថាតើពួកគេយល់យ៉ាងណា



រូបថតទទួលបានពី MINUSMA (ប្រទេសម៉ាលី)

ចំពោះគន្លឹះឆ្ពោះទៅមុខក្នុងការកសាងសន្តិភាព។ ព័ត៌មានទាំងនេះគឺសំខាន់ណាស់ក្នុងការកំណត់អាទិភាពនៃសេវានគរបាលរួមទាំងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរបៀបដែលឆ្លើយតបនឹងយេនឌ័រ។ ការកំណត់អាទិភាពគួររួមបញ្ចូលភាពចាំបាច់ដែលនគរបាលស៊ើបអង្កេតត្រូវនាំខ្លួនជនបង្កដែលប្រព្រឹត្តបទល្មើសបច្ចុប្បន្ន និងបទល្មើសពីមុនទៅកាត់ទោស។ ការកសាងទំនុកចិត្តជាមួយសហគមន៍ និងការធានាថា នគរបាលមានភាពជឿជាក់និងសមត្ថភាពក្នុងការអនុវត្តសកម្មភាពនេះ ពិតជាសំខាន់ខ្លាំងណាស់។

ការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ និង ១៨២០របស់ក្រុមប្រឹក្សាសន្តិសុខអង្គការ សហប្រជាជាតិ (UN SCR) ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីសេចក្តីសម្រេចទាំងនេះ (ប្រសិនបើមាន) ទៅតាមបរិបទប្រទេសនីមួយៗ អាចផ្តល់ឱកាសដ៏សំខាន់ដល់នគរបាលក្នុងការបង្កើតភាពជាដៃគូចាំបាច់ដែលបង្កផលប៉ះពាល់កាន់តែខ្លាំងលើការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ[629]។ សេចក្តីសម្រេចលេខ ១៣២៥ និង ១៨២០ (UN SCR) មិនត្រឹមតែបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងនាមជាអ្នកកសាងសន្តិភាពនិងអ្នកធ្វើសេចក្តីសម្រេច (មិនមែនជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធ) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឧបករណ៍ និងគោលនយោបាយគាំទ្រដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រទៀតផង។ នៅខែ មករា ឆ្នាំ ២០២០ ប្រទេសចំនួន ៨៣ បានអនុម័តផែនការសកម្មភាពជាតិដើម្បីគាំទ្រដល់សេចក្តីសម្រេចលេខ១៣២៥[630]។

ឧ. សេចក្តីសម្រេចលេខ ១៣២៥ (២០០០) ទទូចឱ្យរដ្ឋសមាជិកចាត់វិធានការនៅថ្នាក់ជាតិលើផ្នែកផ្នែកសំខាន់ៗដូចខាងក្រោម ៖

- វិធានការគាំទ្រគំនិតផ្តួចផ្តើមកសាងសន្តិភាពរបស់ស្ត្រីក្នុងមូលដ្ឋាន និងដំណើរការរបស់ជនជាតិដើមភាគតិចសម្រាប់ការដោះស្រាយជម្លោះ និងជំរុញការចូលរួមរបស់ស្ត្រីក្នុងយន្តការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពទាំងអស់។
- ការការពារ និងការគោរពសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រីតាមរយៈវិធានការពិសេសដើម្បីការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រជាពិសេស ការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទ និងរាល់ទម្រង់ផ្សេងទៀតនៃអំពើហិង្សាក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ។ចំណុចនេះរួមបញ្ចូលការផ្តល់ការពិចារណាពិសេសលើតម្រូវការជាក់លាក់របស់ស្ត្រី និងក្មេងស្រី ក្នុងការធ្វើមាតុភូមិនិវត្តន៍ ការតាំងទីលំនៅឡើងវិញ ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មឡើងវិញ និងការកសាងឡើងវិញក្រោយជម្លោះ។
- ដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងវិធានការកសាងសន្តិភាព និងរក្សាសន្តិភាព និងលើកឡើងពីការការពារ សិទ្ធិ និងតម្រូវការជាក់លាក់របស់ស្ត្រី។

តាមរយៈការចូលរួមក្នុងគំនិតផ្តួចផ្តើមកសាងសន្តិភាពជាអាទិ៍ ការអនុវត្តសេចក្តីសម្រេចលេខ១៣២៥ និង ១៨២០ (UN SCR) ទៅតាមបរិបទប្រទេសនីមួយៗ ដូចជាគំនិតផ្តួចផ្តើមដែលបង្កើតឡើងដោយបណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី (GNWP) នគរបាលអាចដើរតួនាទីបានយ៉ាងល្អក្នុងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលជាប្រព័ន្ធរវាងអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានបង្កើនកិច្ចសហប្រតិបត្តិការ និងកិច្ចសហការពហុវិស័យក្នុងចំណោមអង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋាភិបាល ស្ថាប័នអង្គការសហប្រជាជាតិ និងតួអង្គពាក់ព័ន្ធផ្សេងទៀតក៏ដូចជាកសាងការយល់ដឹងស្តីពី

629. ការអនុវត្តក្នុងមូលដ្ឋាន និងការបំផុសជាសកល ៖ ការអនុវត្ត UNSCR 1325 ក្នុងប្រទេសកូឡុំប៊ី នេប៉ាល់ ហ្វីលីពីន សៀរ៉ាឡេអូន និងអ៊ុយហ្គង់ដា (២០១៣) បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី។
630. សូមមើលផែនការសកម្មភាពជាតិសម្រាប់ការអនុវត្តសេចក្តីសម្រេចលេខ១៣២៥ (UNSCR) ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ ក្រុមស្ត្រីអន្តរជាតិដើម្បីសន្តិភាព និងសេរីភាព។

សេចក្តីសម្រេចលេខ ១៣២៥ និង ១៨២០(UNSCR) និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនិងគោលនយោបាយជាតិក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ[631]។

ប្រអប់១៤ខាងក្រោមជាឧទាហរណ៍ស្តីពីរបៀបដែលការចូលរួមរបស់នគរបាល អ៊ុយហ្កង់ដា ក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ (UNSCR) ទៅតាម បរិបទប្រទេសនេះបានបង្កើនការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

### ប្រអប់ ៩

**នគរបាលអ៊ុយហ្កង់ដា និងការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ ទៅតាមបរិបទប្រទេសនេះ**

ប្រទេសអ៊ុយហ្កង់ដា ធ្លាប់ឆ្លងកាត់សង្គ្រាមស៊ីវិលជាយូរណាស់មកហើយ និងកំពុងប្រឈមនឹងជម្លោះផ្ទៃក្នុងជាបន្តបន្ទាប់ ដែលជម្លោះជាច្រើនជាអំពើហិង្សានយោបាយ ការបះបោរប្រដាប់អាវុធ និងអំពើហិង្សាដែលពាក់ព័ន្ធនឹងការបោះឆ្នោត។ ឧ. ការបះបោររបស់ Lord's Resistance Army (LRA) នៅប្រទេសអ៊ុយហ្កង់ដាភាគខាងជើងនៅអំឡុងឆ្នាំ ១៩៨៧-២០០០ បានបណ្តាលឱ្យប្រជាជនរាប់សែននាក់បាត់បង់ជីវិត។ កុមារចំនួន ២០.០០០ នាក់ត្រូវបានចាប់ពង្រត់ ហើយប្រជាជនជិត ២ លាននាក់ បានបាត់បង់ទីលំនៅ។

ទោះបីជាសន្តិសុខក្នុងប្រទេសនេះមានភាពប្រសើរឡើងច្រើនក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់អរិភាពរវាង LRA និងរដ្ឋាភិបាលអ៊ុយហ្កង់ដានៅឆ្នាំ ២០០៦ ក្តីក៏ស្ត្រីនៅតែទទួលរងផលប៉ះពាល់ខ្លាំងដោយសារអំពើហិង្សា និងអសន្តិសុខដែលមិនទាន់បញ្ចប់ និងកាន់តែរីកសាយ។

នៅឆ្នាំ ២០០៨ រដ្ឋាភិបាលអ៊ុយហ្កង់ដាបានអនុម័តផែនការសកម្មភាពជាតិសម្រាប់ការអនុវត្តសេចក្តីសម្រេច (UNSCR) លេខ ១៣២៥ និង ១៨២០ និងសេចក្តីប្រកាស Goma ស្តីពីការលុបបំបាត់អំពើហិង្សាផ្លូវភេទ និងការបញ្ឈប់និទណ្ឌភាពក្នុងតំបន់ Great Lakes។

ក្នុងផ្នែកមួយនៃការអនុវត្តផែនការសកម្មភាពនេះតាមមូលដ្ឋានប្រទេសអ៊ុយហ្កង់ដាបានបង្កើតគណៈកម្មាធិការសម្របសម្រួលទាំងនៅថ្នាក់ស្រុក និងថ្នាក់ឃុំ (sub-county)។ នៅថ្នាក់ស្រុក អង្គភាពនគរបាលការពារកុមារ និងគ្រួសារអ៊ុយហ្កង់ដា បានចូលរួមជាមួយអភិបាលស្រុកផ្សេងទៀតលើផ្នែកអភិបាលកិច្ច ការអភិវឌ្ឍ ការអប់រំ មេរោគអេដស៍ និងសិទ្ធិបន្តពូជ យេនឌ័រ និងការអភិវឌ្ឍសហគមន៍ ការស៊ើបអង្កេតព្រហ្មទណ្ឌ ពន្ធនាគារ និងតុលាការដើម្បីធ្វើការពិភាក្សាជារៀងរាល់ខែអំពីស្ថានភាព និងសកម្មភាព/វិធានការពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ឬអំពើហិង្សាផ្លូវភេទទាក់ទងនឹងយេនឌ័រក្នុងស្រុក។

ផែនការសកម្មភាពមូលដ្ឋាន (LAPs) ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ និងអនុម័តដោយក្រុមប្រឹក្សាមូលដ្ឋានថ្នាក់ស្រុកដែលចូលរួម។ លទ្ធផលជាបន្តបន្ទាប់ពីការអនុវត្តដំណើរការ LAP រួមមានការយល់ដឹងកាន់តែច្រើនអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសហគមន៍ និងក្នុងវិស័យសន្តិសុខ។ ដោយសារតែផែនការសកម្មភាពមូលដ្ឋាន និងការចូលរួមរបស់នគរបាលក្នុងការបង្កើត និងអនុវត្តផែនការនេះ អធិការដ្ឋាននគរបាលស្រុកបានបង្កើតការិយាល័យអំពើហិង្សាទាក់ទងនឹងយេនឌ័រដោយមានមន្ត្រីទំនាក់ទំនងសហគមន៍នៅតាមស្រុកនីមួយៗដែលមានការអនុវត្តផែនការនេះ។ កិច្ចខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាលមូលដ្ឋាន បានរួមចំណែកបង្កើនការរាយការណ៍ពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងធ្វើឱ្យនគរបាលទទួលបានទំនុកចិត្តកាន់តែច្រើនពីសាធារណជនក្នុងការគ្រប់គ្រងបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

យោងតាមរបាយការណ៍បទល្មើសនៅឆ្នាំ ២០១៧ មានការរាយការណ៍ពីករណីអំពើហិង្សាក្នុងគ្រួសារចំនួន ២៥ ករណី កើនពី ១៣.១៣២ ករណីនៅឆ្នាំ ២០១៦ ស្មើនឹងកំណើន ១៦,៧%។ ក្រៅពីនេះ យោងតាម

631. ការអនុវត្តក្នុងមូលដ្ឋាន និងការបំផុសជាសកល ៖ ការអនុវត្ត UNSCR 1325 ក្នុងប្រទេសកូឡុំប៊ី នេប៉ាល់ ហ្វីលីពីន សៀរ៉ាឡេអូន និងអ៊ុយហ្កង់ដា (២០១៣) បណ្តាញសកលនៃអ្នកកសាងសន្តិភាពជាស្ត្រី។

របាយការណ៍នគរបាលឆ្នាំ ២០១៤ ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបានរាយការណ៍ទៅនគរបាល កើន ២៥,៨% នៅឆ្នាំ ២០១៤ បើធៀបនឹងឆ្នាំ ២០១៣។ តួលេខនេះបន្តកើនឡើងយ៉ាងខ្លាំងតាំងពីពេលនោះមក។

"នៅស្រុក Kitgum ការិយាល័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងមន្ត្រីទំនាក់ទំនងបានជួយលុបបំបាត់គម្លាតរវាងនគរបាល និងសហគមន៍ដែលធ្វើឱ្យមានទំនុកចិត្តលើការរាយការណ៍ពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ក្រៅពីនេះមានការថយចុះនៃករណីចរចានៅកម្រិតគ្រួសារ(ជនបង្កចរចាជាមួយគ្រួសារជនរងគ្រោះដើម្បីដោះស្រាយបញ្ហានៅកម្រិតគ្រួសារ សម្រាប់ករណីរំលោភសេពសន្ថវៈ ការបំផ្លាញព្រហ្មចារី និងអាពាហ៍ពិពាហ៍កុមារ)។ កន្លងមក ការរាយការណ៍ធ្វើឡើងបន្ទាប់ពីការចរចាបរាជ័យ ប៉ុន្តែបច្ចុប្បន្នគឺខុសពីនេះ។ ការរាយការណ៍ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រកើនពីចំនួន ៤៣៥ ករណីនៅឆ្នាំ ២០១៤ រហូតដល់ជាង ២.៥០០ ករណីក្នុងមួយឆ្នាំ ចាប់តាំងពីការអនុវត្តផែនការនេះក្នុងមូលដ្ឋាន"។

អធិការនគរបាលស្រុក Kitgum

ប្រភព ៖ Localization: Rumbimbwa, R., Assessing the impact Uganda Case Study ( 2018 ), . Global Network of Women Peacebuilders.

## អំពើហិង្សាលើស្ត្រី និង ក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

ការរីកចម្រើននៃប្រព័ន្ធអ៊ីនធឺណិត និងការពង្រីកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ កំពុងផ្លាស់ប្តូរជីវិតរស់នៅប្រចាំថ្ងៃ។ បច្ចុប្បន្ន លទ្ធភាពទទួលបាន និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍមនុស្ស ព្រោះបច្ចេកវិទ្យានេះសម្រួលដល់ការបញ្ចេញមតិជាបន្តបន្ទាប់ នវានុវត្តន៍ និងបំណងប្រាថ្នា។ ស្ត្រី និងក្មេងស្រីនៅទូទាំងពិភពលោក មិនមានលទ្ធភាពដូចគ្នានោះទេក្នុងការទទួលបានមធ្យោបាយអភិវឌ្ឍន៍ខ្លួនក្នុងការងារ ការអប់រំ និងការ កំសាន្តតាមរយៈបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ ការរក្សាអនាមិកភាពតាមប្រព័ន្ធអ៊ីនធឺណិតមានសារៈសំខាន់ណាស់ ព្រោះវាអាចឱ្យស្ត្រីប្រើប្រាស់វេទិកាផ្សេងៗក្នុងប្រព័ន្ធអ៊ីនធឺណិតនិងបំពេញតួនាទីជាសកម្មជនការងារនយោបាយនិងចលនាកសាងដែលមានសារៈសំខាន់ក្នុងសង្គមប្រជាធិបតេយ្យ។

"លទ្ធភាពប្រើប្រាស់អ៊ីនធឺណិត កាន់តែមានភាពចាំបាច់សម្រាប់សុខុមាលភាពសេដ្ឋកិច្ច និងកំពុងត្រូវបានចាត់ទុកជាសិទ្ធិមនុស្សជាសារវន្ត។ ដូច្នេះ ចាំបាច់ត្រូវធានាថា វេទិកាឌីជីថលសាធារណៈនេះជាទីមានសុវត្ថិភាព និងបង្កើនភាពអង់អាចសម្រាប់មនុស្សគ្រប់រូប រួមទាំងស្ត្រី និងក្មេងស្រី"។

អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ

ទោះជាយ៉ាងណា នៅគ្រប់ឱកាសទាំងអស់ ស្ត្រី និងក្មេងស្រីតែងប្រឈមនឹងអំពើហិង្សាដែលបន្តកើតឡើងក្នុងជីវិតប្រចាំថ្ងៃ (ក្រៅប្រព័ន្ធអ៊ីនធឺណិត)។ អំពើហិង្សាលើស្ត្រី ដូចជា ការប្រទូស្តកេរខ្មាស ការឈ្លបចាប់ ការប្រើប្រាស់រូបភាព/វីដេអូដោយខុសច្បាប់និង/ឬគ្មានការយល់ព្រមនិងការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិតធ្វើឱ្យស្ត្រីនិងក្មេងស្រីគ្មានសុវត្ថិភាពនៅពេលចូលរួមក្នុងវេទិកាឌីជីថល។ ហានិភ័យនៃអំពើហិង្សាកើនឡើងយ៉ាងខ្លាំងនៅពេលមានធាតុផ្សំអនាមិកភាព។

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយអំពើហិង្សានេះ ប៉ុន្តែត្រូវពង្រីកវិសាលភាពនៃសេវានគរបាលតាមរបៀបដែលអាចវាស់វែងបាន។ ក្នុងន័យនេះ ចាំបាច់ត្រូវអនុលោមតាមបទដ្ឋានដែលដាក់កំហិតលើព័ត៌មានបុគ្គល និងទិន្នន័យរបស់ភាគីទីបី និងកសាងភាពជាដៃគូយ៉ាងសំខាន់ដើម្បីច្បាមយកព័ត៌មានចារកម្មស្តីពីជនបង្ក ជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិត និងក្រុមហ៊ុនបច្ចេកវិទ្យា ដែលគ្រប់គ្រងការសាយភាយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍។ អ្វីដែលសំខាន់ផងដែរនោះគឺវត្តមាននគរបាលក្នុងប្រព័ន្ធអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពីការណែនាំសុវត្ថិភាព និងយុទ្ធសាស្ត្រនានា ដូចជា យន្តការរាយការណ៍ដែលនឹងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា និងលើកទឹកចិត្តឱ្យរាយការណ៍នៅពេលមានអំពើហិង្សានេះ។

សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះអ្នកនិពន្ធនឹងប្រើនិយមន័យនៃបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ដែលស្នើឡើងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)[632]៖

> "បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ជាឧបករណ៍ចាត់ចែងព័ត៌មានមូលដ្ឋាន (បណ្តុំទំនិញ កម្មវិធី និងសេវាផ្សេងៗដែលត្រូវបានប្រើប្រាស់ដើម្បីផលិត រក្សាទុកដំណើរការចែកចាយនិងផ្លាស់ប្តូរព័ត៌មាន)។ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍រួមបញ្ចូលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ "បែបប្រពៃណី" ដូចជា វិទ្យុ ទូរទស្សន៍ និងទូរស័ព្ទ និងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ "ថ្មី" ដូចជា កុំព្យូទ័រ ផ្កាយរណប និងបច្ចេកវិទ្យាគ្មានខ្សែ (wireless) និងអ៊ីនធឺណិត។ បច្ចុប្បន្ន ឧបករណ៍ខុសៗគ្នាទាំងនេះអាចធ្វើការជាមួយគ្នា និងរួមបញ្ចូលគ្នាដើម្បីបង្កើតជា "ពិភពបណ្តាញ" របស់យើង ដែលជាហេដ្ឋារចនាសម្ព័ន្ធដ៏ធំមហិមានៃបណ្តាញសេវាទូរស័ព្ទ ហាដវែរកុំព្យូទ័រស្តង់ដារ និងទូរទស្សន៍ ដែលផ្សព្វផ្សាយដល់គ្រប់ច្រកល្ហកទូទាំងពិភពលោក"។

## ការណែនាំគ្នាទៅវិញទៅមក

ផលប៉ះពាល់នៃបច្ចេកវិទ្យា

ដោយសារតែប្រភេទបទល្មើស និងមធ្យោបាយប្រព្រឹត្តបទល្មើសនៅជុំវិញពិភពលោក មានការវិវត្ត អ្នក និងបុគ្គលិករបស់អ្នកគួរប្រុងប្រយ័ត្នខ្ពស់ចំពោះអាកប្បកិរិយា/សកម្មភាពផ្សេងៗរបស់ជនបង្ក។ ខណៈដែលការផ្លាស់ប្តូរគំរូបទល្មើសនិងអាកប្បកិរិយាមួយចំនួនអាចទាមទារការឆ្លើយតបពីអ្នកឯកទេសការសំខាន់គឺត្រូវចងចាំគោលការណ៍មូលដ្ឋាននៅពេលប្រឈមជាមួយនឹងជនរងគ្រោះ។ នេះជាចំណុចសំខាន់ក្នុងសេវានគរបាលបច្ចុប្បន្ន ដែលប្រឈមនឹងបញ្ហាពាក់ព័ន្ធនឹងភាពជឿនលឿននៃបច្ចេកវិទ្យាដោយសារតែភាពស្មុគស្មាញនិងភាពប្រទាក់ក្រឡាគ្នាក្នុងការប្រឈមជាមួយនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា។ ខណៈដែលភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាផ្តល់អត្ថប្រយោជន៍ដល់សេវានគរបាលក្នុងការផ្តល់ការឆ្លើយតបផ្នែកបច្ចេកវិទ្យាសម្រាប់ការស៊ើបអង្កេតបទល្មើសត្រូវរក្សាតុល្យភាពរវាងអត្ថប្រយោជន៍និងបញ្ហាដែលបង្កឡើងដោយបច្ចេកវិទ្យាជាពិសេសពាក់ព័ន្ធនឹងរបៀបដែលជនល្មើសរិះរកវិធីថ្មីៗក្នុងការប្រព្រឹត្តបទល្មើស។ ចំណុចនេះបានបង្កបញ្ហាប្រឈមសម្រាប់អ្នក និងបុគ្គលិករបស់អ្នក ជាពិសេសប្រសិនបើស្ថាប័នរបស់អ្នកគ្មានធនធាន និងលទ្ធភាពសមស្របក្នុងការទទួលបានបច្ចេកវិទ្យាសំខាន់ៗ។

**រូប ៣ ៖**

**ភាពស្មុគស្មាញ និងភាពប្រទាក់ក្រឡាគ្នានៃបញ្ហាក្នុងការប្រឈមជាមួយនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមប្រព័ន្ធបច្ចេកវិទ្យា** (UN 2015)




រូប ៣ ជាទិដ្ឋភាពកម្រិតខ្ពស់នៃភាពស្មុគស្មាញ និងភាពប្រទាក់ក្រឡាគ្នានៃបញ្ហាក្នុងការប្រឈមជាមួយនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាដែលផ្តល់ដោយគណៈកម្មការប្រដប់ៃននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល ក្រុមការងារប្រដប់ៃន និងយេនឌ័រ (២០១៥)។

គ្មានតុល្យភាពរវាងអ្វីដែលស្ថាប័ននគរបាលអាចផ្តល់ដល់បុគ្គលិករបស់ខ្លួននិងអ្វីដែលប្រជាពលរដ្ឋអាចទទួលបាន។

632. ឧបករណ៍សម្រាប់ការអភិវឌ្ឍដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍ ៖ ឯកសារស្រាវជ្រាវ ក្រុមការងារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍អង្គការសហប្រជាជាតិ ខែ ធ្នូ ឆ្នាំ ២០០៣។

ក្នុងប្រទេសជាច្រើន បណ្តាញចល័ត និងលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតតាមបច្ចេកវិទ្យា smart phone មានភាពរីកចម្រើន។ ដូច្នេះ ប្រជាពលរដ្ឋអាចចូលប្រើប្រាស់បណ្តាញសង្គម និងគេហទំព័របានយ៉ាងងាយស្រួល ប៉ុន្តែស្ថាប័ននគរបាលនិងស្ថាប័នអនុវត្តន៍ច្បាប់មិនសុទ្ធតែទទួលបានលទ្ធភាពដូចគ្នានេះទេ។ ដូច្នេះ វាបានបង្កើតបញ្ហាប្រឈមបន្ថែមទៀតចំពោះអ្នក និងបុគ្គលិករបស់អ្នកក្នុងការផ្តល់សេវានគរបាលដល់សហគមន៍មូលដ្ឋាន។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ កាន់តែមានប្រេវ៉ាឡង់ខ្ពស់នៅទូទាំងពិភពលោក ប៉ុន្តែការអនុវត្តច្បាប់ជាអន្តរជាតិកំពុងខិតខំដោះស្រាយបញ្ហានេះ ព្រោះមិនទាន់មានការកំណត់និយមន័យជាសកលសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យានោះទេ។ ទោះជាយ៉ាងណា មានការកំណត់រួមពីប្រភេទជាច្រើននៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ដូចតទៅ ៖ ការឈ្លបចាប់តាមប្រព័ន្ធបច្ចេកវិទ្យា ការរំលោភបំពានជារូបភាពដោយគ្មានការយល់ព្រម (ដែលគេតែងសំដៅលើ "រូបអាសអាភាសដែលថតសម្រាប់សងសឹក") ការថ្លែងបែបស្អប់ខ្ពើម និងការបៀតបៀន "ការបង្កភាពអាម៉ាស់ដល់មនុស្សស្រីដែលមានចរិតមិនល្អ" រូបអាសអាភាសដែលបង្កការរំខាន ការកំហែងទារប្រាក់ជាថ្នូរនឹងការមិនបង្ហាញកស្តុតាងផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការគំរាមសម្លាប់ ការប្រមូលព័ត៌មានស្តីពីជនរងគ្រោះការបង្ហាញព័ត៌មានឯកជនរបស់ជនរងគ្រោះតាមប្រព័ន្ធអ៊ីនធឺណិត និងតាមប្រព័ន្ធអេឡិចត្រូនិចដើម្បីសម្រួលដល់ការជួញដូរមនុស្ស[633 634 635]។

ក្នុងរបាយការណ៍ អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ការអំពាវនាវឱ្យភ្ញាក់រលឹកទូទាំងពិភពលោក (២០១៥) ក្រុមការងារប្រដប៊ែន និងយេនឌ័រក្នុងគណៈកម្មការប្រដប៊ែននៃអង្គការសហប្រជាជាតសម្រាប់ការអភិវឌ្ឍវិស័យឌីជីថលបានផ្តល់លក្ខណៈនិងសាវតារនានាដែលបង្ហាញថាអ្វីជាអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា (រូប ៤)។

រូប ៤ ៖

**លក្ខណៈ និងសាវតារពិសេសនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា (គណៈកម្មការ ប្រដប៊ែន នៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល ២០១៥)**

**អនាមិកភាព**
ជនរងគ្រោះប្រហែលជាមិនស្គាល់ជនប្រព្រឹត្តបំពាន។

**ការធ្វើសកម្មភាពពីចម្ងាយ**
ការរំលោភបំពានអាចធ្វើឡើងដោយគ្មានការប៉ះពាល់រាងកាយនិងចេញពីកន្លែងណាមួយ។

**ស្វ័យប្រវត្តិកម្ម**
សកម្មភាពបំពានដែលប្រើប្រាស់បច្ចេកវិទ្យា ទាមទារពេលវេលា និងការប្រឹងប្រែងតិចតួច។

**ភាពអាចទទួលបាន**
ភាពចម្រុះនិងភាពអាចលៃលកបាននៃបច្ចេកវិទ្យាជាច្រើន ធ្វើឱ្យជនបង្កងាយស្រួលប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ។

**ការចែកចាយ និងការបន្តមិនចេះចប់**
អត្ថបទនិងរូបភាពត្រូវបានចែកចាយនិងមានអត្ថិភាពយូរអង្វែង ឬគ្មានដែនកំណត់។

633. គណៈកម្មការប្រដប៊ែននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល (២០១៥) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ការអំពាវនាវឱ្យភ្ញាក់រលឹកទូទាំងពិភពលោក ៖ របាយការណ៍របស់គណៈកម្មការប្រដប៊ែននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល ក្រុមការងារប្រដប៊ែន និងយេនឌ័រ។
634. EIGE (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ។ សូមមើលផងដែរ Cybersafe (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ៖ របាយការណ៍ សាកលវិទ្យាល័យ Ljubljana មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម។
635. សូមមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រី ឫសគល់ និងផលវិបាកនៃលើអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត https://undocs.org/A/HRC/38/47។

អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍គឺជាអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលប្រព្រឹត្តឡើងតាមប្រព័ន្ធអេឡិចត្រូនិកនិងប្រព័ន្ធអ៊ីនធឺណិត[636]និងគួរត្រូវបានចាត់ទុកថាមិនខុសពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្រៅប្រព័ន្ធអ៊ីនធឺណិត ប៉ុន្តែភាពខុសគ្នាតែមួយគត់គឺមធ្យោបាយនៃការប្រព្រឹត្តអំពើហិង្សានេះ។ យោងតាមវិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ (EIGE) គេមិនគួរពិចារណាពីអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត (ប្រព័ន្ធបច្ចេកវិទ្យា) ដាច់ដោយឡែកឡើយ ប៉ុន្តែគួរចាត់ទុកអំពើហិង្សានេះថាជាការបន្តប្រព្រឹត្តអំពើហិង្សាក្រៅប្រព័ន្ធអ៊ីនធឺណិត។វិទ្យាស្ថាននេះរកឃើញថា ជាញឹកញាប់ នគរបាលចាត់ទុកឧប្បត្តិហេតុនីមួយៗនៃទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិត ជាអំពើដាច់ដោយឡែកមួយ ជាជាងពិចារណាអំពើហិង្សានេះក្នុងបរិបទធំទូលាយនៃការបង្កផលប៉ះពាល់កាន់តែច្រើនឡើងដោយសារការរំលោភបំពាន[637]។

ជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវចិត្តដូចគ្នាប្រសិនបើគ្មានការកត់សម្គាល់នៅពេលមានការប្រព្រឹត្តអំពើហិង្សានេះតាមប្រព័ន្ធអ៊ីនធឺណិតដែលពេលខ្លះបណ្ដែតបណ្ដោយឱ្យមានការប៉ះទង្គិចផ្លូវចិត្តជាអចិន្ត្រៃយ៍ដោយសារតែវាមានលក្ខណៈជាសាធារណៈ[638]។ ទោះជាយ៉ាងណា ការស្រាវជ្រាវរកឃើញថា ជាញឹកញាប់ មន្ត្រីនគរបាលធ្វេសប្រហែសនិងកាត់បន្ថយគ្រោះថ្នាក់ដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា តាមរយៈការចាត់ទុកបទពិសោធន៍របស់ជនរងគ្រោះជាឧប្បត្តិហេតុដាច់ពីគ្នា ជាជាងកត់សម្គាល់ថាអំពើហិង្សានេះ ជាគំរូឥរិយាបថដែលបានប្រព្រឹត្តក្នុងអំឡុងពេលមួយ[639]។ ក្នុងរបាយការណ៍ឆ្នាំ ២០១៨ ស្តីពីអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតអ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រី កត់សម្គាល់ថាជាញឹកញាប់ស្ថាប័នអនុវត្តន៍ច្បាប់ចាត់ទុកអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យាលើស្ត្រីជារឿងតូចតាច ហើយសកម្មភាពរបស់ស្ថាប័នទាំងនោះច្រើនតែមានចរិតស្តីបន្ទោសជនរងគ្រោះនៅពេលប្រឈមជាមួយករណីទាំងនេះ។ លទ្ធផលនៃឥរិយាបថនេះគឺវប្បធម៌ស្ងៀមស្ងាត់ និងការរាយការណ៍ពីចំនួនករណីក្រោមចំនួនករណីពិតប្រាកដនៅពេលដែលជនរងគ្រោះជាស្ត្រីស្ទាក់ស្ទើរមិនហ៊ាននិយាយ ដោយសារខ្លាចគេស្តីបន្ទោស[640]។

ដោយសារតែជាញឹកញាប់ ជនបង្កមានភាពងាយស្រួលក្នុងការរក្សាអនាមិកភាពតាមរយៈការប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត ហើយជនបង្កងាយចូលដល់ជនរងគ្រោះ ជនបង្កកាន់តែងាយរួចខ្លួនពីការដាក់ទោស។ អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតងាយស្រួលប្រព្រឹត្ត និងមិនទាមទារ ឬទាមទារការយល់ដឹងតិចតួចអំពីបច្ចេកវិទ្យា[641] ។ អ្វីដែលធ្ងន់ធ្ងរជាងនេះគឺហាដវែរបច្ចេកវិទ្យាកាន់តែមានតម្លៃសមរម្យ (ដូចជាការប្រើប្រាស់ smart phone និងឧបករណ៍ឌីជីថលផ្សេងទៀតកាន់តែច្រើន)។
ការប្រើប្រាស់អ៊ីនធឺណិតយ៉ាងច្រើននៅទូទាំងសកលលោក និងភាពងាយស្រួលប្រើប្រាស់កាន់តែខ្លាំង ធ្វើឱ្យជនបង្កអាចទាក់ទងទៅអ្នកដទៃនៅទីណាក៏បាន។ដូច្នេះ វាធ្វើឱ្យមានជនរងគ្រោះកាន់តែច្រើន កាត់បន្ថយលទ្ធភាពរកមុខជនបង្កនិងកាត់បន្ថយឱកាសរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌[642]។

គួរអនុវត្តការណែនាំដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ដែលមានបង្ហាញក្នុងសៀវភៅណែនាំនេះ មិនថាអំពើហិង្សាលើស្ត្រី និងក្មេងស្រីត្រូវបានប្រព្រឹត្តតាមប្រព័ន្ធ អ៊ីនធឺណិត ក្រៅប្រព័ន្ធអ៊ីនធឺណិត ឬទាំងពីរនោះទេ ហើយតម្រូវការរបស់ជនរងគ្រោះ សុវត្ថិភាព និងការការពារជនរងគ្រោះ ត្រូវតែជាអាទិភាពទីមួយ។ ទាំងទម្រង់ជាក់ស្តែង និងទម្រង់អនឡាញ(ប្រព័ន្ធបច្ចេកវិទ្យា) នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី សុទ្ធតែអាចប្រទាក់

636. Cybersafe (២០១៧) អំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា៖ របាយការណ៍សាកលវិទ្យាល័យ Ljubljana មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម។
637. EIGE (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ។
638. Cybersafe (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា៖ របាយការណ៍សាកលវិទ្យាល័យ Ljubljana មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម។
639. EIGE (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ។
640. https://undocs.org/A/HRC/38/47
641. Cybersafe (២០១៧) អំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា៖ របាយការណ៍សាកលវិទ្យាល័យ Ljubljana មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម។
642. Ibid

ក្រឡាគ្នាព្រោះទម្រង់មួយចំនួននៃការរំលោភបំពានអាចរួមបញ្ចូលការបៀតបៀនក្រៅប្រព័ន្ធអ៊ីនធឺណិត[643]។

អន្តរាគមន៍សំខាន់ៗសម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាហាក់ផ្តោតសំខាន់លើកុមារ និងយុវជន ដោយកត់សម្គាល់ថា ការអប់រំអ្នកប្រើប្រាស់បច្ចេកវិទ្យាជំនាន់ក្រោយ ទាំងក្មេងប្រុស និងក្មេងស្រីជាកត្តាសំខាន់ក្នុងការបង្កើនការយល់ដឹងពីភាពឧក្រិដ្ឋនៃអំពើទាំងនោះ ក៏ដូចជាផលអន្តរាយរបស់វាលើជនរងគ្រោះ។ ការអប់រំទាំងនេះត្រូវតែផ្តល់ជូនជាផ្នែកមួយនៃអភិក្រមសង្គមធំទូលាយលើបញ្ហានេះ តាមរយៈឪពុកម្តាយ គ្រូបង្រៀន នគរបាល ស្ថាប័នយុត្តិធម៌ និងសហគមន៍ទាំងមូល[644]។ ក្នុងផ្នែកមួយនៃគំនិតផ្តួចផ្តើមអប់រំដើម្បីយុត្តិធម៌ UNODC បានបោះពុម្ពផ្សាយម៉ូឌុលស្តីពីបទល្មើសបច្ចេកវិទ្យាអន្តរបុគ្គលសម្រាប់សាស្ត្រាចារ្យសាកលវិទ្យាល័យ ដែលលើកឡើងពីអំពើហិង្សាលើស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសបច្ចេកវិទ្យាអន្តរបុគ្គលផ្អែកលើយេនឌ័រផ្សេងទៀត[645]។

ក្រុមការងារប្រដប៊ែន និងយេនឌ័រក្នុងគណៈកម្មាធិការប្រដប៊ែននៃអង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍវិស័យឌីជីថល (២០១៥) បានផ្តល់អនុសាសន៍ដែលអាចអនុវត្តបានចំពោះអ្នកផ្តល់សេវាសំខាន់ៗរួមទាំងនគរបាលស្តីពីការអនុវត្តអភិក្រមពហុកម្រិតសម្រាប់ការដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា (រូប ៥)។ ក្រុមការងារនេះបានស្នើឱ្យមានកិច្ចខិតខំប្រឹងប្រែងលើសកម្មភាពមួយក្នុងចំណោមសកម្មភាព៣ខាងក្រោម ៖

១.វិធានការទប់ស្កាត់តាមរយៈការបង្កើនការយល់ដឹងជាសាធារណៈ និងការកសាងការភ្ញាក់រលឹក។
២.ការលើកកម្ពស់ការការពារដើម្បីជានាសុវត្ថិភាព និងសមភាពតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ស្ត្រីនិងក្មេងស្រី។
៣.ការបង្កើតឱ្យមាន និងអនុវត្តន៍ការដាក់ទណ្ឌកម្ម។

**រូប ៥ ៖ អន្តរាគមន៍ ៣ ប្រភេទសម្រាប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ដែលលើកឡើងដោយក្រុមការងារប្រដប៊ែន និងយេនឌ័រក្នុងគណៈកម្មាធិការប្រដប៊ែននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល**

|  ការទប់ស្កាត់អំពើហិង្សា លើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា តាមរយៈការផ្លាស់ប្តូរឥរិយាបថក្នុងសង្គម |  ការត្រួតពិនិត្យ និងតាមដាន ដើម្បីកាត់បន្ថយហានិភ័យសម្រាប់ស្ត្រី និងក្មេងស្រី |  ការកែសម្រួល និងអនុវត្តច្បាប់ និងបទបញ្ញត្តិ |
| --- | --- | --- |
| **ការបង្កើនការយល់ដឹង** | **ការការពារ** | **ការដាក់ទណ្ឌកម្ម** |
| សង្គមត្រូវទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា តាមរយៈការបណ្តុះបណ្តាល ការរៀនសូត្រ ការធ្វើយុទ្ធនាការ និងការអភិវឌ្ឍសហគមន៍ | ឧស្សាហកម្មត្រូវរក្សាការទទួលខុសត្រូវលើហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតនិងការអនុវត្តដែលគិតគូរពីអតិថិជន | បង្កើតច្បាប់ បទបញ្ញត្តិ និងយន្តការអភិបាលកិច្ច<br>តុលាការ និងប្រព័ន្ធច្បាប់ត្រូវពង្រឹងអនុលោមភាព និងការដាក់ទណ្ឌកម្មដែលមានប្រសិទ្ធភាពលើជនបង្ក |
| មន្ត្រីយុត្តិធម៌ និងសន្តិសុខ/នគរបាល ត្រូវបញ្ចូលការព្រួយបារម្ភពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលទាំងអស់ស្តីពីបទព្រហ្មទណ្ឌនិងសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា | ការអភិវឌ្ឍដំណោះស្រាយផ្នែកបច្ចេកទេស<br>ការលើកកម្ពស់ការយកចិត្តទុកដាក់ខ្ពស់ និងភារកិច្ចរាយការណ៍ពីការរំលោភបំពាន | ការពិគ្រោះយោបល់ស្តីពីរបៀបវារៈសិទ្ធិពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យា |

643. គណៈកម្មការប្រដប៊ែននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល (២០១៥) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ការអំពាវនាវឱ្យភ្ញាក់រលឹកទូទាំងពិភពលោក៖ របាយការណ៍របស់គណៈកម្មការប្រដប៊ែននៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យឌីជីថល ក្រុមការងារប្រដប៊ែន និងយេនឌ័រ។

644. Ibid សូមមើលផងដែរ Networked Intelligence for Development 2015
645. https://www.unodc.org/e4j/en/cybercrime/module-12/key-issues/gender-based-interpersonal-cybercrime.html

## សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រៈ ភាពជំរុញគន្លឹះឆ្ពោះទៅមុខ

នៅពេលប្រឈមនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ជាញឹកញាប់ ជម្រើសសម្រាប់ស្ត្រី និងក្មេងស្រីមានត្រឹមតែការផ្លាស់ប្តូរព័ត៌មានលម្អិតឬសារតៃរបុគ្គលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ឬការប៉ុនប៉ងមិនអើពើឥរិយាបថបំពានឬការរាយការណ៍ពីឥរិយាបថនោះទៅអ្នកផ្តល់សេវាអ៊ីនធឺណិត(ISP)ដែលប្រហែលជាអាចគ្រប់គ្រងគណនីរបស់ជនបំពានបាន។

ក្នុងករណីនៅតែមានឥរិយាបថបំពានជាញឹកញាប់នគរបាលស្នើឱ្យជនរងគ្រោះចងក្រងភស្តុតាងស្តីពីគំរូឥរិយាបថបំពាន មុននឹងទៅជួបនគរបាល ឬរាយការណ៍ទៅ ISP។ ជារឿយៗ ជនរងគ្រោះមិនដឹងច្បាស់ពីអ្វីដែលត្រូវចងក្រងទុក និងពេលវេលាសមស្របដែលត្រូវទៅជួបនគរបាល ហើយជាទូទៅជនរងគ្រោះមិនបានដឹងថាតើឥរិយាបថបំពានបែបត្រួតត្រា និងពាក់ព័ន្ធគ្នាតាមប្រព័ន្ធអ៊ីនធឺណិតនិងក្រៅប្រព័ន្ធអ៊ីនធឺណិតមានទំនាក់ទំនងគ្នាបែបណានោះទេ។ជាញឹកញាប់ជនរងគ្រោះមិនដឹងច្បាស់ថាតើអ្នក"គួរអត់ឱន"ចំពោះឥរិយាបថបំពានកម្រិតណា និងអ្វីខ្លះដែលអាចកំណត់ជាឥរិយាបថ "បំពាន" តាមប្រព័ន្ធអ៊ីនធឺណិតនោះទេ។ ក្នុងបញ្ហានោះ តាមធម្មតា ISP មិនបានត្រៀមបុគ្គលិកដើម្បីទទួលបណ្តឹងពីស្ត្រី និងក្មេងស្រីដោយប្រើប្រាស់អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះឡើយ ហើយជាទូទៅ ISPs ក៏មិនទទួលបានព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្តដែរ។ជនរងគ្រោះប្រហែលជាមិនបានរាយការណ៍ជាប្រចាំទៅISP។

ក្នុងរបាយការណ៍ស្តីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា (២០១៧) EIGE គូសបញ្ជាក់ថាឥរិយាបថស្តីបន្ទោសជនរងគ្រោះកើតមានជាទូទៅដោយសារកង្វះការយល់ដឹង និងការដឹងលឺដែលគួបផ្សំនឹងការពិតដែលថា (យោងតាមការអង្កេតឆ្នាំ ២០១៤ នៅសហរដ្ឋអាមេរិក) ជាងពាក់កណ្តាលនៃជនរងគ្រោះដោយសារការឈ្លបចាប់តាមប្រព័ន្ធបច្ចេកវិទ្យា និងការឈ្លបចាប់ជាក់ស្តែង មិនដឹងថា ការឈ្លបចាប់ទាំងនេះជាបទល្មើសនោះទេ[646]។

> "នៅក្នុងរដ្ឋដែលកំណត់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាជាបទល្មើសព្រហ្មទណ្ឌ ទិន្នន័យដែលប្រមូលបានមិនសូវមានការបែងចែកជាប្រភេទទៅតាមភេទរបស់ជនរងគ្រោះ និងជនបង្ក និងទំនាក់ទំនងរវាងពួកគេ។ ចំណុចនេះបានរឹតត្បិត សារៈប្រយោជន៍នៃទិន្នន័យទាំងនោះ។កង្វះទិន្នន័យធ្វើឱ្យរាំងស្ទះដល់លទ្ធភាពធ្វើការវិភាគផ្អែកតាមយេនឌ័រ លើអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា និងការប្រៀបធៀបរវាងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្រៅប្រព័ន្ធអ៊ីនធឺណិត"។
>
> អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ (២០១៧)

ដូច្នេះ ការរាយការណ៍ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ទៅនគរបាល ឬ ISPs ដូចជាការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត ការឈ្លបចាប់ និងការគំរាមកំហែងទូទៅ ច្រើនតែជាដំណើរការតាមទំនើងចិត្តដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការប្រមូលទិន្នន័យស្តីពីប្រេវ៉ាឡង់នៃករណីទាំងនេះ។ ក្នុងរបាយការណ៍ដដែល (២០១៧) EIGE ទទួលស្គាល់ថា នៅសហភាពអឺរ៉ុប មិនសូវមានទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធ បច្ចេកវិទ្យានោះទេ។ ដូច្នេះហើយទើបគេមិនសូវដឹងពីភាគរយជាក់ស្តែងនៃជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា និងប្រេវ៉ាឡង់នៃគ្រោះថ្នាក់[647]។

ទន្ទឹមនឹងនេះ ដោយសារតែប្រទេសនានាបន្តកែសម្រួលប្រព័ន្ធច្បាប់របស់ខ្លួនទៅតាមវិសាលភាពនៃបទល្មើសបច្ចេកវិទ្យាជាញឹកញាប់នគរបាលយល់ថាពួកគេមិនបានត្រៀមខ្លួនបំពេញតម្រូវការទាំងនេះឡើយ។ ចំណុចនេះអាចលេចឡើងក្នុងករណីដែលត្រូវពង្រឹងដីកាបញ្ឈប់ និងដីកាដកបណ្តឹង (ជម្រើសមួយក្នុងប្រព័ន្ធច្បាប់មួយចំនួនសម្រាប់ឱ្យស្ត្រី និងក្មេងស្រីទប់ស្កាត់ការបោះពុម្ពផ្សាយ និងការចែកចាយរូបភាពរបស់ពួកគាត់បន្តទៀត)។ ការ

646. EIGE (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ។

647. Ibid

ទប់ស្កាត់ការរីករាលដាលនៃការរំលោភបំពានផ្អែកលើរូបភាពដោយគ្មានការយល់ព្រម (ជាញឹកញាប់សំដៅលើ "រូបអាសអាភាសដែលថតសម្រាប់សងសឹក")[648]ជាអ្វីដែលដាក់សម្ពាធយ៉ាងខ្លាំងលើនគរបាល ព្រោះនគរបាលមិនសុទ្ធតែមានជំនាញក្នុងការឆ្លើយតបនោះទេ។ ក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រី (២០១៨) ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា កត់សម្គាល់ថា សូម្បីតែក្នុងករណីដែលមានក្របខណ្ឌច្បាប់ឯកទេសក្តី ក៏យន្តការច្បាប់ និងបទបញ្ញត្តិ រួមទាំងមន្ត្រីអនុវត្តន៍ច្បាប់មិនសុទ្ធតែទទួលបានការ បណ្តុះបណ្តាល ឬការបំពាក់បំប៉នដើម្បីអនុវត្តក្របខណ្ឌទាំងនោះប្រកបដោយប្រសិទ្ធភាពនោះឡើយ ដោយសារតែកង្វះការបណ្តុះបណ្តាលដែលគិតគូពីយេនឌ័រ និងការយល់ឃើញជាទូទៅថា ការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិតមិនមែនជាបទល្មើសធ្ងន់ធ្ងរ[649]។ យោងតាម UNODC លិខិតបករណ៍ច្បាប់ទូទៅបំផុត គឺច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ច្បាប់ព្រហ្មទណ្ឌ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ច្បាប់ស្តីពីការថ្លែងបែបស្អប់ខ្ពើម និងច្បាប់ស្តីពីការការពារទិន្នន័យ និងឯកជនភាព[650]។ ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃច្បាប់ទាំងនេះទាមទារការបណ្តុះបណ្តាលគ្រប់គ្រាន់ និងការបង្កើនការយល់ដឹងសម្រាប់នគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត។ សម្រាប់នគរបាល ការមានពិធីសារ ឬនីតិវិធីប្រតិបត្តិស្តង់ដារដែលផ្តល់ប៉ារ៉ាម៉ែត្រច្បាស់លាស់ គាំទ្រដោយការបណ្តុះបណ្តាលឯកទេសសម្រាប់ការចូលប្រើប្រាស់ និងគ្រប់គ្រងទិន្នន័យបុគ្គល គឺជាការសំខាន់ ព្រោះវាជួយឱ្យមន្ត្រីនគរបាលធានាការគោរពគោលការណ៍សមាមាត្រភាព នីត្យានុកូលភាព គណនេយ្យភាព និងភាពចាំបាច់ក្នុងពេលអនុវត្តអន្តរាគមន៍របស់ខ្លួន។ ក្នុងរបាយការណ៍ឆ្នាំ ២០១៨ ស្តីពីអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត អ្នករាយការណ៍ពិសេស[651]លើកឡើងថា ៖

- រដ្ឋគួរផ្តល់ការបណ្តុះបណ្តាលសម្រាប់ចៅក្រម មេធាវី នគរបាល និងមន្ត្រីអនុវត្តន៍ច្បាប់ផ្សេងៗទៀត និងបុគ្គលិកជួរមុខ ដើម្បីឱ្យពួកគេមានសមត្ថភាពស៊ើបអង្កេត និងផ្តន្ទាទោសជនបង្ក។
- រដ្ឋគួរបង្កើតពិធីសារ និងក្រមប្រតិបត្តិផ្ទៃក្នុង និងខាងក្រៅដែលមានលក្ខណៈឯកទេស ច្បាស់លាស់ មានប្រសិទ្ធផល និងតម្លាភាពសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ក្នុងការដោះស្រាយអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតលើស្ត្រីដើម្បីឱ្យមន្ត្រីទាំងនោះអាចយល់កាន់តែច្បាស់ថាអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតជាទម្រង់មួយនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដែលសមនឹងទទួលបានការឆ្លើយតបយ៉ាងហ្មត់ចត់ និងផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត។

សម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្រៅប្រព័ន្ធអ៊ីនធឺណិតចំណុចចាប់ផ្តើមសម្រាប់ឱ្យការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត (ប្រព័ន្ធបច្ចេកវិទ្យា) កាន់តែមានប្រសិទ្ធភាព គឺការងាកទៅរកសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ដែលគួរផ្អែកលើការយល់ដឹងក្នុងស្ថាប័ន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ[652] អំពីថាតើឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាកនៃអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។

សូមមើលជំពូកទី ១០ (ការកសាងស្ថាប័នដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី) សម្រាប់បង្កើតការយល់ដឹងក្នុង ស្ថាប័ន និងផ្អែកតាមព័ត៌មានត្រឹមត្រូវអំពីថាតើឫសគល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាកនៃអំពើហិង្សាបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី។

---

648. EIGIពិពណ៌នារូបអាសអាភាសដោយគ្មានការយល់ព្រម (ទម្រង់ទូទៅបំផុតនៃ "រូបអាសអាភាសដែលថតសម្រាប់សងសឹក") ថាពាក់ព័ន្ធនឹងការចែកចាយរូបភាព ឬវីដេអូផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិតដោយគ្មានការយល់ព្រមពីបុគ្គលក្នុងរូបភាពទាំងនោះ។ ជាញឹកញាប់ ជនបង្កជាអតីតដៃគូដែលទទួលបានរូបភាព ឬវីដេអូក្នុងទំនាក់ទំនងពីមុន និងមានគោលបំណងបង្កភាពអាម៉ាស់ជាសាធារណៈ និងប្រមាថជនរងគ្រោះ ដោយសារតែការបញ្ចប់ទំនាក់ទំនង។ ទោះជាយ៉ាងណា ជនបង្កមិនសុទ្ធតែជាដៃគូ ឬអតីតដៃគូនោះទេ ហើយមូលហេតុនៃការធ្វើដូច្នេះ ក៏មិនមែនសុទ្ធតែដើម្បីសងសឹកដែរ។ សូមមើលពាក្យ "Revenge porn" ក្នុងសទ្ទានុក្រម និងកម្រងវចនៈស័ព្ទ https://eige.europa.eu/thesaurus/ terms/1488?lang=en
649. https://undocs.org/A/HRC/38/47
650. សូមមើល សៀវភៅណែនាំសម្រាប់តុលាការស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឆាំងនឹងស្ត្រីនិងក្មេងស្រី (២០១៩) UNODC
651. សូមមើល n. 69។
652. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ "ផ្អែកតាមព័ត៌មានត្រឹមត្រូវ" មានន័យថា វាពាក់ព័ន្ធនឹងបរិបទ និងមានការផ្តល់ធាតុចូលជាប្រចាំ (ទិន្នន័យបែបបរិមាណ និងទិន្នន័យបែបគុណភាព) ពីនគរបាលជំនាញ និងអ្នកពាក់ព័ន្ធខាងក្រៅ ដូចជា អ្នកផ្តល់សេវាសំខាន់ៗ និង/ឬអង្គការសង្គមស៊ីវិល។

**រូប ៦ ៖**

**វដ្តជីវិតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី (UNODC ២០១៩)**




## ការអនុវត្តលក្ខណៈទូទៅនិងគោលការណ៍នៃកញ្ចប់សេវាសំខាន់ៗចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត (ប្រព័ន្ធបច្ចេកវិទ្យា)

សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រនឹងដើរតួនាទីសំខាន់ក្នុងការទទួលខុសត្រូវលើបញ្ហានេះ ប៉ុន្តែចាំបាច់ត្រូវស្វែងឡើងតាមប្រព័ន្ធអ៊ីនធឺណិតក្នុងទម្រង់ជាអន្តរាគមន៍ដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដោយផ្អែកតាមលក្ខណៈខាងក្រោម ៖

- អាចរកបាន និងអាចទទួលបាន ៖ គ្មានការរើសអើង និងមិនដាក់បន្ទុកហិរញ្ញវត្ថុលើជនរងគ្រោះនៅគ្រប់ដំណាក់កាលទាំងអស់ នៃវដ្តជីវិតអំពើហិង្សាទាក់ទងនឹងយេនឌ័រ (រូប ៦)[653]។
- អាចសម្របតាមបាន ៖ ផ្តល់ជម្រើសទូលំទូលាយដែលគិតគូរពីវប្បធម៌ ដែលឆ្លើយតបទៅនឹងផលប៉ះពាល់ផ្សេងៗនៃអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត (ប្រព័ន្ធបច្ចេកវិទ្យា) លើស្ត្រី និងក្មេងស្រី។
- សមស្រប៖កាត់បន្ថយការរងគ្រោះលើកទីពីរនិងបង្កើនភាពអង់អាចរបស់ជនរងគ្រោះក្នុងដំណើរការនេះ។
- សុវត្ថិភាពជាចម្បង ៖ គ្រប់គ្រងហានិភ័យ និងរៀបចំផែនការសុវត្ថិភាពដែលពិចារណាថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត ជាការបន្ត

653. សូមមើលសៀវភៅណែនាំសម្រាប់តុលាការស្តីពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រី និងក្មេងស្រី (UNODC ២០១៩) ៖ https://www.unodc.org/pdf/criminal_justice/HB_for_the_Judiciary_on_Effective _Criminal_Justice_Women_and_Girls_E_ebook.pdf p.9. See also https://www.endvawnow.org/en/articles/298-the-life-cycle-and-violence.html.

ប្រព្រឹត្តអំពើហិង្សាជាក់ស្តែងដែលកំណត់យកស្ត្រី និងក្មេងស្រីជាគោលដៅ តាមប្រព័ន្ធអ៊ីនធឺណិត ឬក្រៅប្រព័ន្ធអ៊ីនធឺណិត។

- ទទួលបានព័ត៌មានបន្តជាប់ តាមរយៈការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ៖ មធ្យោបាយ ឬវេទិការបស់អ្នកសម្របសម្រួលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ឬ ផតថល (គ្រប់ទម្រង់) សម្រាប់រាយការណ៍ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ត្រូវបានបង្ហាញឡើងដោយគ្មានការវិនិច្ឆ័យ និងផ្តល់ការគាំទ្រ។
- បន្សុីគ្នានឹងការអនុវត្តល្អបំផុតនិងច្បាប់ជាតិនៅពេលធានាថា យន្តការរាយការណ៍របស់ជនរងគ្រោះ រួមបញ្ចូលការយល់ព្រមចាំបាច់និងវិធានការរក្សាការសម្ងាត់សម្រាប់ឯកជនភាព និងការការពារទិន្នន័យ។
- ផ្សារភ្ជាប់នឹងការប្រមូលទិន្នន័យ និងដំណើរការគ្រប់គ្រងព័ត៌មាន (ទិន្នន័យបុគ្គល) ដែលមានសន្តិសុខ អនុលោមតាមបទដ្ឋាន និងជួយដល់ការយល់ដឹងពីប្រវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ក៏ដូចជាការវាយតម្លៃនិន្នាការនៃការឆ្លើយតបរបស់សេវាសំខាន់ៗនិងផ្តល់មូលដ្ឋានព័ត៌មានដល់វិធានការទប់ស្កាត់។
- គាំទ្រពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ISPs អ្នកផ្តល់សេវាបណ្តាញសង្គម ក្រុមហ៊ុនបច្ចេកវិទ្យា និងស្ថាប័នរដ្ឋាភិបាលដើម្បីធានាឯកសណ្ឋានភាពនៃការរាយការណ៍ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការបញ្ជូននៅពេលមានការចោទប្រកាន់ពីករណីអំពើហិង្សលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា។

**អ្នក និង ក្រុមរបស់អ្នកគួរខិតខំប្រេដ្ឋាធ្វើជាភ្នាក់ងារជំរុញការផ្លាស់ប្តូរឆ្ពោះទៅរកវឌ្ឍនភាព។**

ដើម្បីមានភាពម្ចាស់ការលើបញ្ហា នគរបាលត្រូវចាត់ទុកបទពិសោធន៍របស់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតជាផ្នែកមួយនៃបរិបទធំទូលាយនៃវិសមភាពទំនាក់ទំនងអំណាចនិងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរើសអើងជាប្រព័ន្ធ។ សំណួរសម្រាប់នគរបាលគឺ៖ តើអ្វីជាធម្មជាតិនៃការបន្តប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត? តើឫសគល់និងផលវិបាកនៃអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាក្រៅប្រព័ន្ធអ៊ីនធឺណិត បង្កផលប៉ះពាល់ខុសគ្នានិងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី? សំណួរតាមដានបន្តគួរមានគោលបំណងកំណត់ស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះបំផុតក្នុងបរិបទនៃការរីកសាយលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងអ៊ីនធឺណិត និងវិធានការនានាដើម្បីទប់ស្កាត់ និងឆ្លើយតបកាន់តែមានប្រសិទ្ធភាព នៅពេលមានអំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលងាយរងគ្រោះខ្លាំងបំផុត EIGE កំណត់ថា ស្ត្រី ជាពិសេសស្ត្រីវ័យក្មេងដែលស្ថិតក្នុងក្រុមមនុស្សវ័យជំទង់និងក្រុមមនុស្សដល់វ័យបន្តពូជនៃវដ្តជីវិតអំពើហិង្សាទាក់ទងនឹងយេនឌ័រ (សូមមើលរូប ៦) រងគ្រោះដោយទម្រង់ធ្ងន់ធ្ងរនៃការបៀតបៀនតាមប្រព័ន្ធបច្ចេកវិទ្យា ដូចជា ការឈ្លបចាប់តាមប្រព័ន្ធបច្ចេកវិទ្យា និងការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត[654]។

ក្នុងឧទាហរណ៍មួយផ្សេងទៀត ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលស្នាក់នៅក្នុងផ្ទះសុវត្ថិភាព និងមណ្ឌលគាំពារអំពើហិង្សាក្នុងគ្រួសារ ឬទីកន្លែងស្រដៀងគ្នា ងាយប្រឈមនឹងហានិភ័យកាន់តែខ្លាំង ព្រោះជនបង្កអាចប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីតាមដានជនរងគ្រោះដែលធ្វើឱ្យនគរបាលមានការលំបាកក្នុងការការពារ និងធានាសុវត្ថិភាពរបស់ជនរងគ្រោះ និងត្រូវប្រើធនធានច្រើន។

មាននិន្នាការកាន់តែច្រើនដែលស្ត្រីដែលជាបុគ្គលសាធារណៈ អ្នកសារព័ត៌មាន[655] និងអ្នកការពារសិទ្ធិមនុស្ស ត្រូវបានកំណត់ជាគោលដៅនៃការបំបិទមាត់ និងការបំភិតបំភ័យ។ ដោយសារតែមិនអាចរក្សាអនាមិកភាពតាមប្រព័ន្ធអ៊ីនធឺណិតបាន អ្នកនយោបាយ សកម្មជន អ្នកស្រាវ

655. EIGE (២០១៧) អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា វិទ្យាស្ថានអឺរ៉ុបដើម្បីសមភាពយេនឌ័រ។

ជ្រាវ និងអ្នកសារព័ត៌មានជាច្រើនដែលធ្វើការងារលើផ្នែកសិទ្ធិមនុស្ស និង/ឬអំពើពុករលួយ ត្រូវប្រឈមនឹងអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត ដែលពេលខ្លះជាការគំរាមកំហែងដោយផ្ទាល់ (មិនត្រឹមតែចំពោះពួកគេនោះទេប៉ុន្តែថែមទាំងចំពោះក្រុមងាយរងគ្រោះដែលពួកគេធ្វើជាតំណាងទៀតផង)[656] ។ UNICEF លើកឡើងថា ជារៀងរាល់ថ្ងៃកុមារជាង ១៧៥.០០០ នាក់បានចូលប្រើប្រាស់អ៊ីនធឺណិតជាលើកដំបូង។ មនុស្សចំនួន ៧៥០.០០០នាក់ចូលប្រើប្រាស់អ៊ីនធឺណិតនៅពេលណាមួយ ដើម្បីលួងលោមកុមារសម្រាប់ធ្វើការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ[657]។

ពិធីសារនិងក្រមប្រតិបត្តិដែលបង្កើតឡើងដោយនគរបាលដើម្បីឆ្លើយតបទៅនឹងអំពើហិង្សលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា គួរជួយដល់ភ្នាក់ងារឆ្លើយតបបឋមក្នុងការកំណត់រកវិសាលភាពបន្ថែមទៀតនៃអំពើហិង្សាដែលសម្រួលដោយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងរបៀបដែលកត្តាប្រទាក់ក្រឡាគ្នា ដូចជាពិការភាព ជាតិពន្ធុ ទំនោរផ្លូវភេទ និងអាយុ ជះឥទ្ធិពលលើភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត។ ការបណ្តុះបណ្តាលដោយផ្អែកតាមការប៉ះទង្គិចផ្លូវចិត្តមានប្រយោជន៍បំផុតសម្រាប់ស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយសារការប្រទូស្តកេរខ្មាសផ្ទាល់ឬតាមប្រព័ន្ធបច្ចេកវិទ្យាហើយការបង្កើតអង្គភាពឯកទេសផ្នែកបទល្មើសបច្ចេកវិទ្យាឱ្យផ្តោតលើការយល់ដឹងទូទៅស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងការបន្តប្រព្រឹត្តអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ គឺជាជំហានដ៏ត្រឹមត្រូវ។

## ការបង្កើតបច្ចេកវិទ្យាទូទៅ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងករណីឆ្លងដែននៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា

ស្ថាប័ននគរបាលភាគច្រើនគ្មានសមត្ថភាពគ្រប់គ្រាន់នោះទេក្នុងការឆ្លើយតបទៅនឹងការរីកសាយនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ដែលអាចមានចាប់ពីការឈ្លបចាប់តាមប្រព័ន្ធអ៊ីនធឺណិតដោយអតីតដៃគូស្និទ្ធស្នាលដែលមានចរិតបំពាន រហូតដល់កាផលិតទ្រង់ទ្រាយធំ និងការផលិតឡើងវិញនូវរូបភាពនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារនិងការរំលោភបំពានផ្លូវភេទដោយក្រុមជនល្មើសអន្តរជាតិ។ ការតាមដាន និងការត្រួតពិនិត្យអំពើហិង្សានេះមានការលំបាកដូចការតាមដាន និងការត្រួតពិនិត្យអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យាលើស្ត្រី និងក្មេងស្រីដែលមិនត្រូវបានកំណត់ជាបទព្រហ្មទណ្ឌដែរ (ឧ.ការរករឿងរំខានតាមប្រព័ន្ធបច្ចេកវិទ្យាដែលងាយបង្កជាការគំរាមប្រព្រឹត្តអំពើហិង្សានិងការរំលោភបំពានបែបស្អប់ខ្ពើមស្ត្រី។ ក្នុងរបាយការណ៍ឆ្នាំ ២០១៨ ស្តីពីអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត[658] អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រី និងក្មេងស្រី កត់សម្គាល់ថានៅពេលការរំលោភបំពានត្រូវបានប្រព្រឹត្តហួសពីព្រំដែន និងយុត្តាធិការរបស់រដ្ឋវាបានបង្កការលំបាកដល់អាជ្ញាធររួមទាំងស្ថាប័នអនុវត្តន៍ច្បាប់ក្នុងការកំណត់អត្តសញ្ញាណស៊ើបអង្កេត និងផ្តន្ទាទោសជនបង្ក និងផ្តល់ដំណោះស្រាយដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

វេទិកាបណ្តាញសង្គមដែលមានប្រជាប្រិយភាពនិងបណ្តាញអនឡាញផ្សេងទៀតងាយក្លាយជាប្រភពសម្រាប់ឱ្យជនកេងប្រវ័ញ្ចផ្លូវភេទ កំណត់អត្តសញ្ញាណ លួងលោម និងបង្ខំឱ្យស្ត្រីវ័យក្មេង និងក្មេងស្រីចែកចាយព័ត៌មានផ្ទាល់ខ្លួនរួមទាំងរូបភាពផ្លូវភេទរបស់ពួកគេដើម្បីជម្រិតទារប្រាក់និងគ្រប់គ្រងពួកគេសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ និងផលប្រយោជន៍ហិរញ្ញវត្ថុ។បទល្មើសដែលមានការរៀបចំក៏លេចឡើងច្រើនក្នុងវេទិកាសង្គមដែលពេញនិយមផងដែរ តាមរយៈការព្យាយាម "ជ្រើសរើស" ស្ត្រី និងក្មេងស្រីឱ្យប្រឡូកក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជា ការជួញដូរ ក្នុងចំណោមសកម្មភាពខុសច្បាប់ផ្សេងទៀត។ យោងតាម UNODC ស្ត្រី និងក្មេងស្រីគឺជាក្រុមគោលដៅចម្បងនៃការរំលោភបំពានផ្លូវភេទផ្អែកលើរូបភាពដោយគ្មានការ

656. សម្រាប់ព័ត៌មានបន្ថែម សូមមើល ការវាយប្រហារ និងការបៀតបៀន ៖ ផលប៉ះពាល់លើអ្នកសារព័ត៌មានជាស្ត្រី និងការរាយការណ៍របស់ពួកគេ (២០១៨) ៖ Troll-busters.com and international women's media foundation
657. អំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា និងការថ្លែងបែបស្អប់ខ្ពើមស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត ៖ ការសិក្សា (២០១៨) នាយកដ្ឋានគោលនយោបាយដើម្បីសិទ្ធិពលរដ្ឋ និងកិច្ចការរដ្ឋធម្មនុញ្ញនៃសភាអឺរ៉ុប។
658. https://undocs.org/A/HRC/38/47

យល់ព្រម (IBSA) ដែលត្រូវបានចាត់ទុកជាទម្រង់មួយនៃការបៀតបៀនតាមប្រព័ន្ធបច្ចេកវិទ្យា ដែលពាក់ព័ន្ធនឹង "ការបង្កើត ការចែកចាយ និងការគំរាមចែកចាយរូបភាពអាក្រាត ឬផ្លូវភេទដោយគ្មានការយល់ព្រម" ក្នុងគោលដៅបង្កទុក្ខព្រួយ និងការប្រមាថផ្សេងៗលើជនរងគ្រោះ[659]។

នៅពេលកសាងភាពជាដៃគូ នគរបាលត្រូវតែអាចពឹងផ្អែកលើអ្នកដែលជះឥទ្ធិពលលើការសាយភាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ចាប់ពីក្រុមហ៊ុនបច្ចេកវិទ្យា រហូតដល់វិស្វករនិងមន្ត្រីសាធារណៈដែលទទួលខុសត្រូវលើបទបញ្ញត្តិរបស់ខ្លួន រួមទាំងប្រព័ន្ធចារកម្ម សិប្បនិម្មិតរបស់ពួកគេ ដើម្បីជានាសុវត្ថិភាពសាធារណៈ។ អ្វីដែលសំខាន់ផងដែរនោះគឺការកសាងភាពជាដៃគូរបស់នគរបាលជាមួយស្ថាប័នសិក្សាស្រាវជ្រាវនិងអ្នកជំនាញដែលខិតខំចងក្រងឯកសារស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា និងឥទ្ធិពលនៃប្រព័ន្ធចារកម្មសិប្បនិម្មិតសម្រាប់សេវានគរបាលបែបព្យាករណ៍[660] ដែលអាចបង្កើនភាពលម្អៀងនិងការរើសអើងនិងនាំទៅរកការលើកកម្ពស់ឬការពង្រឹងដោយអចេតនានូវភាពងាយរងគ្រោះទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា។

អភិក្រមចម្រុះដែលទាមទារភាពជាដៃគូរវាងវិស័យឯកជននិងវិស័យសាធារណៈមានសារៈសំខាន់ណាស់ក្នុងការប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានកុមារតាមប្រព័ន្ធអ៊ីនធឺណិតនិងការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។ អភិក្រមចម្រុះនេះនឹងទាមទារភាពជាដៃគូឆ្លងដែនរវាងវិស័យឯកជននិងវិស័យសាធារណៈ ព្រោះការរងគ្រោះរបស់កុមារអាចលេចឡើងក្នុងប្រទេសមួយនៅពេលណាមួយ ប៉ុន្តែតាមរយៈការផ្សព្វផ្សាយឯកសារ/សម្ភាររំលោភបំពានផ្លូវភេទកុមារ វាអាចបន្តលេចឡើងក្នុងប្រទេសជាច្រើននៅពេលវេលាផ្សេងគ្នា។ ចំណុចនេះនឹងតម្រូវឱ្យនគរបាលមានយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបអភិក្រមដែលឆ្លើយតបនឹងយេនឌ័ររបស់ខ្លួនក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងវិស័យសាធារណៈ និងដៃគូអនុវត្តន៍ច្បាប់អន្តរជាតិ។

នេះជាការសំខាន់ព្រោះជនរងគ្រោះទទួលរងព្យសនកម្មជាបន្តបន្ទាប់និងជាច្រើនលើកច្រើនសាដោយសារការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត។ យោងតាមគោលការណ៍ណែនាំរបស់ប្រទេសលុចហ្សំបួរ គំនិតផ្តួចផ្តើមមួយរបស់អង្គការអន្តរជាតិចំនួន ១៨ ក្នុងការសម្រេចយកពាក្យ និងនិយមន័យរួមដែលពាក់ព័ន្ធនឹងការការពារកុមារ រូបភាពរំលោភបំពានផ្លូវភេទរបស់កុមារអាចស្ថិតក្នុងប្រព័ន្ធអ៊ីនធឺណិតយូរទៀតបន្ទាប់ពីគាត់ចម្រើនវ័យ និងត្រូវបានយកទៅប្រើប្រាស់បន្ត (ឧ. ចែកចាយ ដោះដូរ លក់ និងទិញ)[661]។ ដូច្នេះ នគរបាលគួរពិចារណាលើការបើកមើលច្រើនដងក្នុងមួយលើកៗ និង/ឬការចែកចាយសម្ភារ/ឯកសារទាក់ទងនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិតដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌថ្មី។

ក្នុងការបញ្ជ្រាបអភិក្រមដែលឆ្លើយតបនឹងយេនឌ័រក្នុងភាពជាដៃគូអន្តរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងករណីឆ្លងដែននៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា ដូចជាការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិតការកំណត់វាក្យស័ព្ទរួមគឺជាការសំខាន់ ព្រោះវាអាចឱ្យស្ថាប័ននគរបាលផ្តល់ការសម្របសម្រួលកាន់តែមានប្រសិទ្ធផល។ ដើម្បីជួយដល់ការកំណត់វាក្យស័ព្ទរួមសម្រាប់ការឆ្លើយតបកាន់តែមានប្រសិទ្ធភាពនិងគ្រប់គ្រាន់ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យាសៀវភៅណែនាំនេះស្នើឱ្យអានឯកសារខាងក្រោម ៖

១. គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ

659. បទល្មើសបច្ចេកវិទ្យាអន្តរបុគ្គលទាក់ទងនឹងយេនឌ័រ UNODC - University Module Series Cybercrime; Also, see: Powell, A, Henry, N & Flynn, A (2018) 'Image-based sexual abuse', in W DeKeseredy and M Dragiewicz (Eds), Routledge Handbook of Critical Criminology : 2nd Edition, pp. 305-315, Routledge: London and Cyber criminology. Maras, M. Oxford Press, November 2016 ISBN: 9780190278441.

660. ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកពិពណ៌នាសេវានគរបាលបែបព្យាករណ៍ជាដំណើរការដែលមានគោលដៅប្រើប្រាស់អំណាចនៃបច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រនិងគំរូអន្តរាគមន៍ផ្អែកតាមភស្តុតាង ដើម្បីកាត់បន្ថយបទល្មើស និងបង្កើនសុវត្ថិភាពសាធារណៈ តាមរយៈការវិភាគកម្រិតខ្ពស់លើបណ្តុំទិន្នន័យផ្សេងៗ បូករួមនឹងគំរូអន្តរាគមន៍ដែលអាចឱ្យការអនុវត្តច្បាប់ផ្លាស់ប្តូរពីការឆ្លើយតបទៅនឹងបទល្មើស ទៅជាការព្យាករណ៍លទ្ធភាពកើតឡើងដើម្បីដាក់ពង្រាយធនធានឱ្យបានសមស្រប។សូមមើល៖ទិដ្ឋភាពរួមនៃសេវានគរបាលបែបព្យាករណ៍ ៖ វិទ្យាស្ថានជាតិយុត្តិធម៌ ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។

661. គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដែលត្រូវបានអនុម័តដោយក្រុមការងារអន្តរស្ថាប័នក្នុងប្រទេសលុចហ្សំបួរ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦។ គម្រោងវាក្យស័ព្ទ និងការសិក្សាពីអត្ថន័យក្នុងភាសាស្តីពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ និង ECPAT International។

ដែលត្រូវបានអនុម័តដោយក្រុមការងារអន្តរស្ថាប័នក្នុងប្រទេសលុចហ្សំបួរ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦។ គម្រោងវាក្យស័ព្ទ និងការសិក្សាពីអត្ថន័យក្នុងភាសាស្តីពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារ និង ECPAT International។

២.អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធបច្ចេកវិទ្យា (២០១៧) ៖ គម្រោង CyberSafe សាកលវិទ្យាល័យ Ljubljana មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម។

៣.ការសិក្សាពីផលប៉ះពាល់នៃបច្ចេកវិទ្យាព័ត៌មានថ្មីៗលើការរំលោភបំពាននិងការកេងប្រវ័ញ្ចកុមារ(UNODC ២០១៥)។

៨

# កំណត់សម្គាល់ និងអំណានបន្ថែម


1 Study on Ways and Methods to Eliminate Sexual Harassment in Egypt Results / Outcomes and Recommendations Summary. UN Women and European Union, at: https://web.law.columbia.edu/sites/default/files/microsites/gender-sexuality/un_womensexual-harassment-study-egypt-final-en.pdf

2 Measuring #MeToo: A National Study on Sexual Harassment and Assault (2019). UC San Diego Center on Gender Equity and Health.

3 Major investigation and public protection: Investigative Development-Lines of Enquiry. UK College of Policing, at: https://www.app.college.police.uk/app-content/major-investigation-and-public-protection/domestic-abuse/investigative-development/#checklist-lines-of-enquiry

4 Stalking or Harassment (2019). UK College of Policing, at: http://library.college.police.uk/docs/appref/Stalking_or_harassment_guidance_200519.pdf

5 European Agency for Fundamental Rights (2015) ,Violence Against Women: An EU-wide survey, at: https://www.equalrights.org/issue/economic-workplace-equality/sexual-harassment/

6 Misogyny Hate Crime Evaluation Report for Nottingham Women's Centre Funded by the Office of Nottinghamshire Police and Crime Commissioner. Mullany, L. and Trickett, L. June 2018, at: http://www.nottinghamwomenscentre.com/wp-content/uploads/2018/07/Misogyny-Hate-Crime-Evaluation-Report-June-2018.pdf

7 House of Commons Women and Equalities Committee (UK), (2018) Sexual Harassment of Women and Girls in public spaces: 6th Report of session 2017-2019.

8 Equal Rights Advocates (2019) Know your rights at work: Sexual Harassment, at: https://www.equalrights.org/issue/economic-workplace-equality/sexual-harassment/

9 Unmasking Sexual Harassment How Toxic Masculinities Drive Men's Abuse in the US, UK, and Mexico and What We Can Do to End It: A Promundo Research Brief Produced for World Economic Forum Annual Meeting 2018, Promundo, at: https://promundoglobal.org/wp-content/uploads/2018/01/Sexual-Harrassment-Brief-Final-To-Post.pdf

10 Amnesty reveals alarming impact of online abuse against women. Amnesty International, at: https://www.amnesty.org/en/latest/news/2017/11/amnesty-reveals-alarming-impact-of-online-abuse-against-women/

11 Spotted: Obligations to Protect Women Students' Safety & Equality Using the Public Sector Equality Duty & the Human Rights Act in Higher and Further Education Institutions to Improve Policies and Practices on Violence Against Women and Girls. Legal Briefing prepared by Louise Whitfield and Holly Dustin for the End Violence Against Women Coalition January 2015, at: https://www.endviolenceagainstwomen.org.uk/wp-content/uploads/Spotted-Obligations-to-Protect-Women-StudentsEy-Safety-Equality.pdf

12 Widadio, N. A, (2019) Many Indonesian Women face sexually harassment: survey, Coalition for Safe Public Space.

13 Pietsch, N (2015) Sexual Harassment and Public Space Learning Brief (27) London, Ontario: Learning Network, Center for Research and Education on Violence against Women and children, at: http://www.vawlearningnetwork.ca/our-work/briefs/briefpdfs/LB-27.pdf

14 Smith B. L (2018) What it really takes to stop sexual harassment, Vol 49 (No.2), American Psychological Association

15 Bystander Approach. Graham Goulden for Cultivating Minds UK, at: https://grahamgoulden.com/cultivating-minds-uk/about/

16 Ending sexual harassment at UN events (2019). UN Department of Management Strategy, Policy and Compliance, at:. https://www.un.org/management/news/ending-sexual-harassment-un-events

17 UN Code of Conduct To Prevent Harassment, Including Sexual Harassment, at UN System Events

18 Independent review of UN Women's policies and procedures for tackling Sexual Exploitation and Abuse (SEA) and Sexual Harassment (SH). Final Report - Confidential May 24, 2019, Copenhagen.

19 Report into Workplace Harassment in the RCMP (2017). Government of Canada, at: https://www.crcc-ccetp.gc.ca/pdf/harassmentFinR-eng.pdf

20 Cividanes GC, Mello AF, Mello MF. Revictimization as a high-risk factor for development of posttraumatic stress disorder: a systematic review of the literature. Braz J Psychiatry. 2018; 00:000-000,at: http://dx.doi.org/10.1590/1516-4446- 2017-0013

21 Foreign & Commonwealth Office, (2014) International Protocol on the Documentation and Investigation of Sexual Violence in Conflict: Basic Standards of Best Practice on the Documentation of Sexual Violence as a Crime under International Law, London: Foreign & Commonwealth Office, at: https://assets.publishing.

service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

22 Women's Meaningful Participation in Negotiating Peace and the Implementation of Peace Agreements Report of the Expert (2018). Convened by UN Women in preparation for the UN Secretary-General's report on Women and Peace and Security, New York, U.S., at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/egm-womens-meaningful-participation-in-negotiating-peace-en.pdf?la=en&vs=3047

23 Implementing Locally, Inspiring Globally: Localizing UNSCR 1325 in Colombia, Nepal, the Philippines, Sierra Leone, and Uganda (2013). Global Network of Women Peacebuilders, at: https://gnwp.org/publications/implementing-locally-inspiring-globally-localizing-unscr-1325-in-colombia-nepal-the-philippines-sierra-leone-and-uganda/

24 Evaluation of the Project "From words to actions: An integrated approach towards effective implementation of UNSCR 1325 and 1820 at local, national and global levels" implemented by the Global Network of Women Peacebuilders with support from the Austrian Development Cooperation. Evaluation Report March 10, 2017 Annalise Moser, Consultant

25 Interventions to Reduce Gender-based Violence in Humanitarian Settings (2019). Sexual Violence Research Institute and World Bank Group, at: https://www.svri.org/sites/default/files/attachments/2019-11-20/InterventionstoReduceGBVinHumanitarianSettings.pdf

26 SáCouto, Susana and Katherine Cleary. "Importance of Effective Investigation of Sexual Violence and Gender-Based Crimes at the International Criminal Court." American University Journal of Gender, Social Policy & the Law. 17, no. 2 (2009): 337-359

27 Swaine, Aisling (2018), Conflict-Related Violence Against Women: Transforming Transition, Cambridge: Cambridge University Press;

28 Hossain, Naomi (2012), Security and the Pathways of Women's Empowerment: Findings from a Thematic Synthesis of the Pathways of Women's Empowerment Research, IDS Working Paper 406, Brighton: Institute of Development Studies.

29 Cohen, D, Green, A.H., and Wood, E.J. (2013), Wartime sexual violence: misconceptions, implications and ways forward, Special Report, Washington D.C.: US Institute for Peace.

30 Gender and SALW in South East Europe (2016). South Eastern and Eastern Europe Clearinghouse for the Control of Small Arms and Light Weapons (SEESAC), at: https://www.seesac.org/f/docs/Armed-Violence/Gender_and_SALW_publication_eng-web.pdf

31 Aolain, Fionnuala Ni, and Eilish Rooney (2007)," Under enforcement and Intersectionality: Gendered Aspects of Transition for Women," International Journal of Transitional Justice, Vol. 1, Issue 3, pp. 338–54.

32 Watson, Callum. Preventing and Responding to Sexual and Domestic Violence against Men: A Guidance Note for Security Sector Institutions. Geneva: DCAF, 2014, at: https://www.dcaf.ch/sites/default/files/publications/documents/SDVAM_FINAL%20online.pdf

33 International Legal Protection of Human Rights in Armed Conflict (UNHCHR, 2011), at: https://www.ohchr.org/Documents/Publications/HR_in_armed_conflict.pdf

34 Report of the Secretary-General on conflict-related sexual violence (2017). UN Doc S/2017/249, at: https://undocs.org/S/2017/249

35 Women, War and Peace: The Independent Experts' Assessment on the Impact of Armed Conflict on Women and Women's Role in Peace-building (2002). Rehn, E., and Sirleaf, E.J. United Nations Development Fund for Women (UNIFEM), at: https://www.unfpa.org/sites/default/files/pub-pdf/3F71081FF391653DC1256C69003170E9-unicef-WomenWarPeace.pdf

36 Rome Statute of the International Criminal Court U.N. Doc. A/CONF.183/9, July 17, 1998, 37 I.L.M. 1002, 1030 (entered into force July 1, 2002)

37 Inter-Agency Standing Committee, at: https://interagencystandingcommittee.org/the-inter-agency-standing-committee

38 Kelly Dawn Askin, Prosecuting Gender Crimes Committed in Darfur: Holding Leaders Accountable for Sexual Violence, in Genocide in Darfur 141, 144 (Samuel Totten et al. eds., 2006).

39 Report on Sexual Gender based Violence and Health Facility Needs Assessment (Lofa, Nimba, Grand Gedeh and Grand Bassa counties) in Liberia (2005). Omanyondo, M.O. for the World Health Organisation.

40 Government/UN Joint Programme to prevent and respond to GBV (June 13, 2008). Information shared by Dr Sadiq Syed, Deputy Regional Program Director with UN Women in Southern Africa.

41 Sexual Crimes, committed on September, October, November 2008 in Liberia (UNPOL-December 2008).

Information shared by Dr Sadiq Syed, Deputy Regional Program Director with UN Women in Southern Africa.

42 SGBV Capacity-building in Peace Operations: Specialized Police Teams. Caparini, M and Osland, K.M. Policy Brief (35/ 2016) Norwegian Institute of International Affairs.

43 National Action Plans for the Implementation of UNSCR 1325 on Women, Peace and Security. Women's International League of Peace and Freedom, at: https://www.peacewomen.org/member-states

44 Tools for Development Using Information and Communications Technology to Achieve the Millennium Development Goals Working Paper United Nations ICT Task Force December 2003, at: https://www.itu.int/net/wsis/stocktaking/docs/activities/1103056110/ICTMDGFinal.pdf

45 UN Broadband Commission for Digital Development (2015) Cyber Violence Against Women and Girls *A worldwide wake-up call:* A report by the UN Broadband Commission for the Digital Development Working Group on Broadband and Gender, at: https://en.unesco.org/sites/default/files/genderreport2015final.pdf

46 Cyber Violence against women and girls (2017). European Institute for Gender Equality, at: https://eige.europa.eu/publications/cyber-violence-against-women-and-girls

47 Cyber Violence against Women and Girls: Report (2017) CyberSafe. University of Ljubljana, Faculty of Social Sciences, at: https://www.wave-network.org/wp-content/uploads/WP2-Report-on-Cyber-VAWG.pdf

48 UN Broadband Commission for Digital Development (2015) Cyber Violence Against Women and Girls *A worldwide wake-up call:* A report by the UN Broadband Commission for the Digital Development Working Group on Broadband and Gender; at: https://www.broadbandcommission.org/Documents/reports/bb-wg-gender-discussionpaper2015-executive-summary.pdf

49 Handbook for the Judiciary on Effective Criminal Justice Responses to Gender-based Violence against Women and Girls (UNODC, 2019)at: https://www.unodc.org/pdf/criminal_justice/HB_for_the_Judiciary_on_Effective_Criminal_Justice_Women_and_Girls_E_ebook.pdf

50 Attacks and Harassment: The Impact on Female Journalists and Their Reporting (2018). Troll-busters.com and international women's media foundation, at: https://www.iwmf.org/wp-content/uploads/2018/09/Attacks-and-Harassment.pdf

51 Cyber violence and hate speech online against women: Study (2018). European Parliament's Policy Department for Citizens' Rights and Constitutional Affairs, at: https://www.europarl.europa.eu/RegData/etudes/STUD/2018/604979/IPOL_STU(2018)604979_EN.pdf

52 More than 175,000 children go online for the first time every day, tapping into great opportunities, but facing grave risks. UNICEF, at: https://www.unicef.org/eap/press-releases/more-175000-children-go-online-first-time-every-day-tapping-great-opportunities

53 Gender-based interpersonal cybercrime. UNODC-University Module Series Cybercrime, at: https://www.unodc.org/e4j/en/cybercrime/module-12/key-issues/gender-based-interpersonal-cybercrime.html.

54 Powell, A, Henry, N & Flynn, A (2018) 'Image-based sexual abuse', in W DeKeseredy and M Dragiewicz (Eds), Routledge Handbook of Critical Criminology: 2nd Edition, pp. 305-315, Routledge: London

55 Cybercriminology. Maras, M. Oxford Press, November 2016 ISBN: 9780190278441.

56 National Institute of Justice. U.S. Department of Justice, at: https://nij.ojp.gov/topics/articles/overview-predictive-policing

57 Terminology Guidelines for the Protection of Children from Sexual Exploitation and Sexual Abuse. Adopted by the Interagency Working Group in Luxembourg, 28 January 2016. Interagency Terminology and Semantics Project on the Sexual Exploitation and Sexual Abuse of Children & ECPAT International, at: http://luxembourgguidelines.org/

14

# វិបត្តិសុខភាពសាធារណៈ និងវិបត្តិមនុស្សធម៌ ក្នុងស្ថានភាពមិនមែនជម្លោះ

"ជំងឺកូវីដ ១៩ បានបង្កផលប៉ះពាល់ខុសគ្នាលើស្ត្រី និងបុរស។ ជំងឺនេះបានបង្កើនវិសមភាពដែលមានស្រាប់សម្រាប់ស្ត្រី និងក្មេងស្រី ក៏ដូចជាការរើសអើងលើក្រុមជួបការលំបាកផ្សេងទៀត ដូចជា ជនមានពិការភាព និងជនក្រីក្រខ្លាំង និងបង្កជាហានិភ័យដែលរាំងស្ទះដល់ការសម្រេចបាន សិទ្ធិមនុស្សសម្រាប់ស្ត្រី និងក្មេងស្រី។ ការចូលរួម ការការពារ និងសក្តានុពលរបស់ស្ត្រី និងក្មេងស្រីគ្រប់រូបត្រូវតែជាចំណុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងឆ្លើយតប។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវតែឆ្លើយតបនឹងយេនឌ័រ និងពិចារណាពីផលប៉ះពាល់ផ្សេងៗជុំវិញការកំណត់រកការធ្វើរោគវិនិច្ឆ័យ និងលទ្ធភាពទទួលបានការព្យាបាលសម្រាប់ស្ត្រី និងបុរសទាំងអស់"។

ការការពារសិទ្ធិ និងសុខភាពផ្លូវភេទ និងបន្តពូជ និងការលើកកម្ពស់ភាពឆ្លើយតបនឹងយេនឌ័រក្នុងវិបត្តិជំងឺកូវីដ ១៩
សេចក្តីប្រកាសព័ត៌មានរួមជាសកល (ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០២០)

# គោលបំណងនៃជំពូកទី ១៤

## ផ្តល់ការណែនាំស្តីពីរបៀបកែសម្រួលសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ទៅតាមវិបត្តិសុខភាពសាធារណៈ និង/ឬគ្រោះមហន្តរាយមនុស្សធម៌ក្នុងស្ថានភាពជម្លោះមិនមែនប្រដាប់អាវុធ។

## សារ និងចំណុចរៀនសូត្រសំខាន់ៗ

- វិបត្តិ និងគ្រោះអាសន្ន ពង្រីកវិសមភាពមានស្រាប់ដែលនាំឱ្យមានការកើនឡើងនៃប្រេវ៉ាឡង់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាអន្តរបុគ្គល។
- ក្នុងពេលមានវិបត្តិចាំបាច់ត្រូវពិនិត្យនិងវាយតម្លៃឡើងវិញលើផែនការឆ្លើយតបមានស្រាប់ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីធានាថា សុវត្ថិភាព និងការការពារជាចំណុចស្នូលនៃការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការ និងការផ្តល់សេវា។
- ភាពជាដៃគូកន្លងមករវាងនគរបាល និងអ្នកពាក់ព័ន្ធសំខាន់ៗនៅមូលដ្ឋាន នឹងដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់នៃបញ្ហាប្រឈមយ៉ាងច្រើនក្នុងពេលមានវិបត្តិ។
- ការរៀបចំផែនការមុនស្ថានភាពវិបត្តិ នឹងជួយកំណត់រកហានិភ័យ វិធានការសម្រាលផលប៉ះពាល់និងយថាហេតុសម្រាប់ការឆ្លើយតបដែលមានការសម្របសម្រួលស្រាប់។
- ស្ថាប័ននគរបាលដែលអាចទទួលបានប្រភពព័ត៌មាននិងទិន្នន័យប្រទាក់ក្រឡាគ្នាជាប់ជាប្រចាំនិងអាចជឿទុកចិត្តបានស្តីពីប្រជាជន"ដែលប្រឈមនឹងហានិភ័យ" ប្រាកដជាអាចឆ្លើយតបបានល្អទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- គួរដាក់បញ្ចូលមេរៀនដែលចងក្រងដោយនគរបាល ក្នុងការវិភាគទិន្នន័យថ្មីៗដែលរៀបរាប់ពីបរិបទជាក់លាក់និងគំរូប្រទាក់ក្រឡាគ្នានៃការរើសអើងផ្អែកលើយេនឌ័រ។

---

លុចហ្សំបួរ ម៉ាដាហ្គាស្កា ម៉ុងតេណេហ្គ្រោ ហូឡង់ ម៉ាសេដូនាខាងជើង ណាមីប៊ី នូវែលហ្សេឡង់ ន័រវែស ព័រទុយហ្គាល់ រ៉ូម៉ានី ស៊ែប អេស្ប៉ាញ ស្វីស និងចក្រភពអង់គ្លេសបានចេញសេចក្តីថ្លែងការណ៍រួមនេះជំនួសមុខឱ្យប្រជាជន និងរដ្ឋាភិបាល ៥៩ ប្រទេស រួមមាន អាល់បានី អាហ្សង់ទីន អាមេនី អូស្ត្រាលី អូទ្រីស បែលហ្ស៊ិក បូលីវី បូស្នី និងហឺហ្ស៊ីហ្គូវីណា ប៊ុលការី កាណាដា កាបវែរ កូស្តារីកា ក្រូអាតស៊ី ស៊ីប សាធារណរដ្ឋឆែក ដាណឺម៉ាក អេក្វាឌ័រ អេស្តូនី ហ្វីជី ហ្វាំងឡង់ បារាំង ហ្សកហ្ស៊ី អាល្លឺម៉ង់ ក្រិច ហ្គីណេ អៀកឡង់ អ៊ីស្លង់ អ៊ីតាលី ជប៉ុន ឡាតវី លីបង់ លីបេរីយ៉ា លិចទេនស្តែន លីតូអានី លុចហ្សំបួរ ម៉ាដាហ្គាស្កា ម៉ិចស៊ិក ម៉ុលដាវី ម៉ុងតេណាហ្គ្រោ ណាមីប៊ី ហូឡង់ ម៉ាសេដូនាខាងជើង នូវែលហ្សេឡង់ ន័រវែស ប៉េរូ ព័រទុយហ្គាល់ សាធារណរដ្ឋកូរ៉េ រ៉ូម៉ានី ស៊ែប អាហ្វ្រិកខាងត្បូង ស្លូវ៉ានី អេស្ប៉ាញ ស៊ុយអែត ទុយនីស៊ី ទូវ៉ាលូ ស្វីស ចក្រភពអង់គ្លេស អ៊ុយក្រែន និងអ៊ុយរ៉ាហ្គាយ។



## សេចក្តីផ្តើម

**នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ អាជ្ញាធរប្រទេសចិនបានជូនដំណឹងដល់អង្គការសុខភាពពិភពលោក (WHO) ថា ជំងឺរលាកសួតមួយប្រភេទដែលគ្មានប្រភពច្បាស់លាស់កំពុងឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅទូទាំងប្រទេសចិនដោយផ្ទុះចេញដំបូងពីទីក្រុងវូហានក្នុងខេត្តហ៊ឺប៉ី។**

រូបថតទទួលបានពី UN Women/Ploy Phutpheng (ប្រទេសថៃ)

ភ្លាមៗបន្ទាប់ពីបានកំណត់អត្តសញ្ញាណវីរុសកូរ៉ូណាថ្មី[663] (ដំបូងមានឈ្មោះថា "2019-nCov") ដោយអ្នកជំនាញក្នុងស្រុកអាជ្ញាធរមូលដ្ឋានបានបញ្ជាឱ្យប្រជាជនធ្វើចត្តាឡីស័កដើម្បីព្យាយាមគ្រប់គ្រងការផ្ទុះឡើងនៃជំងឺកូវីដ ១៩ និងបង្ការមិនឱ្យស្លាប់ ក៏ដូចជាការដួលរលំនៃប្រព័ន្ធសុខាភិបាល។

ប្រទេសជិតខាងចិន បានចាប់ផ្តើមរាយការណ៍ពីករណីជំងឺនេះដែលត្រូវបានចម្លងបន្តទៅប្រទេសផ្សេងទៀតយ៉ាងឆាប់រហ័សនៅពេលក្រោយមកទៀតក្នុងតំបន់ផ្សេងៗជុំវិញពិភពលោក។ នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០ អង្គការសុខភាពពិភពលោកបានធ្វើចំណាត់ថ្នាក់ជំងឺកូវីដ ១៩ ជាងជំងឺឆ្លងរាតត្បាត និងបានជូនដំណឹងដល់រដ្ឋសមាជិកថា អង្គការសុខភាពពិភពលោកមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះកម្រិតគួរឱ្យបារម្ភនៃការឆ្លងរាលដាលនិងភាពធ្ងន់ធ្ងររបស់វានិងកម្រិតអាសន្ននៃភាពអសកម្ម។ ប្រទេសនានានៅជុំវិញពិភពលោកបានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធ្វើចត្តាឡីស័ក រឹតត្បិតការធ្វើដំណើរ និងវិធានការរក្សាគម្លាតសង្គម។ គិតត្រឹមខែ មីនា ឆ្នាំ ២០២០ ប្រជាជនទូទាំងពិភពលោកជិតពាក់កណ្តាលស្ថិតក្រោមការបិទខ្ទប់។

អង្គការសហប្រជាជាតិ ដែលមានបទពិសោធន៍ក្នុងការប្រឈមមុខជាមួយនឹងការផ្ទុះឡើងនៃជំងឺឆ្លងស្រដៀងគ្នាដូចជា អេបូឡា[664] នៅអាហ្វ្រិកភាគខាងលិច ជំងឺហ្ស៊ីកានៅអាមេរិកឡាទីន និងជំងឺសារ នៅអាស៊ី បានសម្តែងការព្រួយបារម្ភចំពោះផលប៉ះពាល់នៃវិធានការឆ្លើយតបទៅនឹងជំងឺកូវីដ ១៩ លើប្រជាជនងាយរងគ្រោះ ដូចជាប្រជាជនដែលស្ថិតក្នុងតំបន់ជម្លោះ និង/ឬតំបន់មនុស្សធម៌ និង

662. រដ្ឋមន្ត្រីមកពីប្រទេសអាហ្វ្រិកខាងត្បូង ស៊ុយអែត អាហ្សង់ទីន អូស្ត្រាលី អាល់បានី ប៊ែលហ្ស៊ិក បូលីវី បូស្នី និងហឺហ្ស៊ីហ្គូវីណា កាបវែរ កាណាដា ស៊ីប សាធារណរដ្ឋឆែក ដាណឺម៉ាក ហ្វាំងឡង់ ហ្វីជី បារាំង អាល្លឺម៉ង់ ក្រិច ហ្គីណេ អ៊ីតាលី ឡាតវី លីបង់ លីបេរីយ៉ា លិចទេនស្តែន

663. វីរុសកូរ៉ូណា (Cov) ជាស្រទាប់វីរុសដ៏ធំមួយដែលបង្កជំងឺនានា ចាប់ពីគ្រុនផ្តាសាយធម្មតារហូតដល់ជំងឺធ្ងន់ធ្ងរ។ វីរុសកូរ៉ូណាថ្មី (nCov) ជាស្រទាប់ថ្មីដែលគេមិនធ្លាប់រកឃើញក្នុងខ្លួនមនុស្ស។ សូមមើល ៖ ការផ្ទុះឡើងនៃជំងឺកូវីដ ១៩ (Covid-19) (២០២០) ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំនៅអឺរ៉ុប ៖ http://www.euro.who.int/en/healthtopics/health-emergencies/coronavirus-covid-19/novel-coronavirus-2019-ncov




របៀបដែលវិធានការឆ្លើយតបជះឥទ្ធិពលលើឫសគល់នៃអំពើហិង្សាដែលប្រព្រឹត្តលើស្ត្រី និងក្មេងស្រី។

ការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិ កើតចេញពីភស្តុតាងច្បាស់លាស់ពីការផ្ទុះឡើងនៃជំងឺ អេបូឡា និងហ្ស៊ីកានាពេលថ្មីៗនេះ[665]ដែលគូសបញ្ជាក់ថាវិបត្តិសង្គមសេដ្ឋកិច្ច ទុក្ខវេទនារបស់ជនស៊ីវិល និងវិបត្តិសុខភាពសាធារណៈបានបង្កើនវិសមភាពដែលមានស្រាប់។ចំណុចនេះនាំទៅរកការកើនឡើងនៃប្រេវ៉ាឡង់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងការមានផ្ទៃពោះក្នុងចំណោមក្មេងស្រី[666]។

ដោយកត់សម្គាល់ពីផលប៉ះពាល់ធ្ងន់ធ្ងរនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងគ្រោះអាសន្ន និងក្នុងបរិបទដែលប្រព័ន្ធសុខាភិបាលបំពេញមុខងារមិនពេញលេញ នីតិរដ្ឋទន់ខ្សោយ និងវិសមភាពយេនឌ័រមានកម្រិតខ្ពស់ លោក Antonio Guterres អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានទទូចឱ្យរដ្ឋាភិបាលទាំងអស់ធ្វើការទប់ស្កាត់និងដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងផ្នែកដ៏សំខាន់មួយនៃផែនការឆ្លើយតបថ្នាក់ជាតិទៅនឹងជំងឺកូវីដ១៩[667]។

ដោយកត់សម្គាល់ពីប្រេវ៉ាឡង់ជាសកលនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលមានកម្រិតយ៉ាងខ្ពស់[668] UN Women បានកំណត់ផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើស្ត្រីនិងក្មេងស្រីដោយសារជំងឺរាតត្បាតកូវីដ១៩ ជា "ជំងឺរាតត្បាតអន្ទោលតាមប្រាណ"[669]។

សៀវភៅណែនាំនេះផ្អែកតាមនិយមន័យនៃជំងឺរាតត្បាត[670] ដែលផ្តល់ដោយ WHO (២០១០) ដែលកំណត់ ជំងឺរាតត្បាតជាការសាយភាយភាសពេញពិភពលោកនូវជំងឺថ្មីមួយដែលត្រូវបានកំណត់ដោយវិមាត្រភូមិសាស្ត្រ និងវិសាលភាពរបស់វា(និងនៅពេលដែលមនុស្សភាគច្រើនគ្មានភាពស៊ាំ) ជាជាងភាពធ្ងន់ធ្ងរនៃជំងឺនោះ[671]។

ជំពូកនេះផ្តោតលើផលប៉ះពាល់នៃវិបត្តិមនុស្សធម៌មិនមែនជម្លោះលើអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយផ្តោតជាសំខាន់លើជំងឺរាតត្បាតកូវីដ ១៩ នាពេលបច្ចុប្បន្ន និងចំណុចដូចគ្នាទៅនឹងការផ្ទុះឡើងនៃជំងឺឆ្លងផ្សេងទៀត ដូចជា ជំងឺអេបូឡា ដែលបណ្តាលឱ្យមាន ឬពង្រីកវិបត្តិក្នុងតំបន់ដែលមានពីមុនមក។ ទោះបីជាវិបត្តិសុខភាពសាធារណៈដោយសារជំងឺកូវីដ ១៩ នាពេលបច្ចុប្បន្ន

664. វីរុសអេបូឡា (EVD) កម្រកើតមាន ប៉ុន្តែមានសភាពធ្ងន់ធ្ងរ ដែលជាញឹកញាប់ធ្វើឱ្យមនុស្សឈឺស្លាប់។ វីរុសនេះត្រូវបានចម្លងពីសត្វព្រៃទៅមនុស្ស រួចចម្លងបន្តពីមនុស្សទៅមនុស្ស។ អត្រាស្លាប់ដោយសារករណី EVD ជាមធ្យមគឺប្រហែល ៥០%។ អត្រាករណីស្លាប់ប្រែប្រួលចន្លោះពី ២៥% ទៅ ៩០% ក្នុងការផ្ទុះឡើងនាពេលកន្លងមក។ ជំងឺអេបូឡា៖ ព័ត៌មានសំខាន់ៗ (WHO ២០២០) https://www.who.int/news-room/fact-sheets/detail/ebola-virus-disease
665. បណ្តោះអាសន្ន។ការក្រើនរំលឹកពីយេនឌ័រសម្រាប់ការផ្ទុះឡើងនៃជំងឺកូវីដ១៩៖https://interagencystandingcommittee.org/inter-agency-standing-committee/interim-guidance-gender-alert-covid-19-outbreak-developed-iasc
666. CARE(ខែមីនា ឆ្នាំ២០២០)៖ឯកសារគោលនយោបាយស្តីពីផលប៉ះពាល់នៃជំងឺកូវីដ១៩លើយេនឌ័រ៖ https://www.care.org/newsroom/press/pressreleases/covid-19s-gender-implications-examined-in-policy-brief-care
667. សារវីដេអូរបស់លោកអគ្គលេខាធិការស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជំងឺកូវីដ ១៩។ អង្គការសហប្រជាជាតិ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២០ https://www.un.org/sg/en/content/sg/statement/2020-04-05/secretary-generals-video-message-gender-based-violenceand-covid-19-scroll-down-for-french
668. យោងតាមស្ថិតិអង្គការសហប្រជាជាតិ ក្នុងចំណោមស្ត្រី ៣ នាក់នៅទូទាំងពិភពលោក មានស្ត្រីម្នាក់រងគ្រោះដោយអំពើហិង្សាផ្លូវកាយ ឬ ផ្លូវភេទនៅដំណាក់កាលមួយចំនួនក្នុងជីវិតរបស់ពួកគេ ហើយក្នុងចំណោមស្ត្រី១០នាក់ដែលត្រូវបានសម្លាប់ដោយចេតនានៅជុំវិញពិភពលោក មានស្ត្រីជិត ៦ នាក់ត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល ឬសមាជិកគ្រួសារផ្សេងទៀត។ សូមមើល ៖ ការសិក្សាជាសកលរបស់ UNODC ស្តីពីអំពើមនុស្សឃាត ៖ ការសម្លាប់ស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងយេនឌ័រ (UNODC ២០១៨) https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf
669. Un Women (២០២០) "ជំងឺកូវីដ ១៩ និងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី "https://www.unwomen.org/en/digitallibrary/publications/2020/04/issue-brief-covid-19-and-ending-violence-against-women-and-girls
670. ការត្រៀមខ្លួន ការឆ្លើយតបក្នុងគ្រោះអាសន្ន ៖ តើអ្វីជាជំងឺរាតត្បាត? (WHO ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២០)
671. Ibid

ខុសគ្នាខ្លាំងពីការផ្ទុះឡើងនៃជំងឺឆ្លងផ្សេងទៀតនាពេលថ្មីៗនេះក៏ដោយក៏មានបញ្ហាប្រឈមរួមជាច្រើនសម្រាប់ស្ថាប័ននគរបាល និងដៃគូផ្តល់សេវាសំខាន់ៗពាក់ព័ន្ធនឹងវិធីបញ្ជូនជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ជំពូកនេះនឹងពិភាក្សាពីបញ្ហាប្រឈមដែលកើតចេញពីកាលៈទេសៈមិនធ្លាប់មានទាំងនេះដើម្បីផ្តល់ការណែនាំផ្អែកតាមព័ត៌មានត្រឹមត្រូវសម្រាប់សេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ ក្នុងស្ថានភាពដ៏លំបាកនេះ។

ដើម្បីជួយដល់ស្ថាប័ននគរបាលក្នុងការសម្រាលហានិភ័យនៃការឆ្លើយតបដែលគ្មានប្រសិទ្ធភាពទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក្នុងពេលមានវិបត្តិផ្នែកខាងក្រោមនឹងផ្តល់ការណែនាំគ្នាទៅវិញទៅមកដោយផ្អែកលើក្របខណ្ឌកញ្ចប់សេវាសំខាន់ៗ (ESP) នៃគោលការណ៍ និងលក្ខណៈទូទៅសម្រាប់ការឆ្លើយតបដោយមានការសម្របសម្រួលដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។

**រូប ១ ៖**

**កញ្ចប់សេវាសំខាន់ៗ ៖ ដ្យាក្រាមក្របខណ្ឌរួម**

| | | | |
|---|---|---|---|
| គោលការណ៍ | អភិក្រមផ្អែកតាមសិទ្ធិ | ការពង្រឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី | សមស្រប និងគិតគូរពីវប្បធម៌ និងអាយុ |
| | អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ | សុវត្ថិភាពជាចម្បង | ការទទួលខុសត្រូវរបស់ជនបង្ក |

| | | |
|---|---|---|
| លក្ខណៈទូទៅ | ភាពអាចរកបាន | ភាពអាចទទួលបាន |
| | ភាពអាចសម្របតាមបាន | ភាពសមស្រប |
| | សុវត្ថិភាពជាចម្បង | ការផ្តល់ការយល់ព្រមត្រឹមត្រូវ និងការរក្សាការសម្ងាត់ |
| | ការប្រមូលទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន | ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |
| | ការផ្សារភ្ជាប់ទៅនឹងវិស័យ និងស្ថាប័នផ្សេងទៀតតាមរយៈការបញ្ជូន និងការសម្របសម្រួល | |

## ការណែនាំគ្នាទៅវិញទៅមក

ក្នុងវិបត្តិសុខភាពសាធារណៈឬវិបត្តិមនុស្សធម៌ចាំបាច់ត្រូវពិនិត្យឡើងវិញលើរបៀបឆ្លើយតបទៅនឹងការអំពាវនាវរកសេវា ដើម្បីធានាថា យើងអាចឆ្លើយតបទៅនឹងវិបត្តិ ក៏ដូចជាបន្តផ្តល់សេវានគរបាលដល់សហគមន៍នៅមូលដ្ឋានដោយយកត់សម្គាល់ថាអាចមានការប៉ះពាល់ដល់សមត្ថភាពរបស់យើងក្នុងការរក្សា "ប្រតិបត្តិការជាប្រក្រតី"។ ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី សមត្ថភាពរបស់យើងក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះត្រូវតែមានប្រសិទ្ធភាពបំផុតដើម្បីឱ្យយើងអាចបន្តផ្តល់សុវត្ថិភាព និងការការពារដល់ពួកគេ។ ទន្ទឹមនឹងនេះ យើងមានភារកិច្ចយកចិត្តទុកដាក់លើបុគ្គលិករបស់យើងនិងសហគមន៍ទាំងមូល។

ការណែនាំដែលលើកមកបង្ហាញក្នុងជំពូកនេះមានភាពពាក់ព័ន្ធទៅនឹងពេលមានវិបត្តិ ក៏ដូចជា "ពេលគ្មានវិបត្តិ" ឱ្យតែស្ថិតក្នុងបរិបទដែលអ្នកធ្វើការ។ ផ្នែកផ្សេងៗនៃការណែនាំនេះអាចមានភាពពាក់ព័ន្ធខ្លាំងទៅនឹងពេលមានវិបត្តិ ហើយការឆ្លើយតបរបស់អ្នកត្រូវតែផ្តោតលើបញ្ហាប្រឈមទាំងអស់។

ក្នុងនាមជាថ្នាក់ដឹកនាំនគរបាល អ្នកទទួលខុសត្រូវលើការផ្តល់សុវត្ថិភាព និងការការពារដល់សហគមន៍នៅមូលដ្ឋាន



រូបថតទទួលបានពី UN MONUSCO (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ)

របស់អ្នកសូម្បីតែនៅពេលមានវិបត្តិប៉ុន្តែអ្នកក៏មានភារកិច្ចយកចិត្តទុកដាក់លើបុគ្គលិកក្នុងអង្គភាព/ប៉ុស្តិ៍នគរបាលរបស់អ្នកផងដែរ ដើម្បីធានាថា ពួកគេអាចបន្តផ្តល់សេវាយ៉ាងមានប្រសិទ្ធភាព។ប្រភេទបទល្មើសអាចប្រែប្រួលក្នុងពេលមានវិបត្តិ ជាពិសេសប្រសិនបើមានការរឹតត្បិតការដើរហើរ ដូចអ្វីដែលបានអនុវត្តក្នុងវិបត្តិជំងឺកូវីដ ១៩។ ខណៈដែលសកម្មភាពគាស់ផ្ទះ ចោរកម្មតាមផ្លូវ និងបទល្មើសហិង្សាអាចនឹងថយចុះ បទពិសោធន៍កន្លងមកបង្ហាញថា អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាលើ ដៃគូស្និទ្ធស្នាលកើនឡើង។ ដូច្នេះ អ្នកត្រូវពិនិត្យឡើងវិញជាបន្តបន្ទាប់លើការផ្តល់សេវា ឬផែនការប្រតិបត្តិការរបស់អ្នក។

ជាទូទៅ វិបត្តិបណ្តាលឱ្យមានសម្ពាធមិនធ្លាប់មានលើធនធានរបស់អ្នក ដែលក្នុងករណីជាច្រើន ត្រូវបានពង្រីកដោយមិនគិតពីបញ្ហាបន្ថែមទៀតដែលបង្កឡើងដោយវិបត្តិសុខភាពឬវិបត្តិមនុស្សធម៌។ដូច្នេះការសំខាន់គឺអ្នកអាចពឹងផ្អែកលើភាពទំនេរនៃបុគ្គលិករបស់អ្នក ដើម្បីសម្រាលហានិភ័យសម្រាប់ពួកគេដូចជាការស្លាប់ដោយសារបញ្ហាសុខភាព និងកាត់បន្ថយធនធានដែលអ្នកមាន។

ប្រហែលជាបុគ្គលិករបស់អ្នកត្រូវធ្វើការយូរម៉ោងជាញឹកញាប់ក្នុងស្ថានការណ៍លំបាកៗ ដែលធ្វើឱ្យពួកគេមិនសូវមានពេលសម្រាក និងពេលជួបជុំគ្រួសារ។ ដូច្នេះ ទោះបីជាពួកគេមិនស្លាប់ដោយសារជំងឺក៏ដោយ ប៉ុន្តែអ្នករឹតតែត្រូវពិចារណាពីសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់អ្នកពួកគេក្នុងពេលមានវិបត្តិ។ នេះជាពេលដែលការដឹកនាំថ្មីមនឹងធ្វើឱ្យមានភាពខុសគ្នាចំពោះបុគ្គលិករបស់អ្នកតាមរយៈការជួយឱ្យពួកគេមានក្រមសីលធម៌ និងបង្កើនសិទ្ធិអំណាចរបស់ពួកគេតាមរយៈការឱ្យតម្លៃ។ការនិយាយពាក្យសាមញ្ញៗ ដូចជា "សូមអរគុណ" មិនខាតអ្វីទេ ប៉ុន្តែមានអត្ថន័យខ្លាំងណាស់។

## ការបន្តប្រតិបត្តិការ ការរៀបចំផែនការយថាភាព និងគ្រោះអាសន្ន

ក្នុងនាមជាមន្ត្រីនគរបាលយើងសុំនឹងការប្រឈមជាមួយស្ថានភាពអាសន្ន ដែលទាមទារការដាក់កិច្ចការផ្ទាល់ និងការអនុវត្តផែនការប្រតិបត្តិការ និងផែនការគ្រោះអាសន្ន ប៉ុន្តែវិបត្តិសុខភាពសាធារណៈ និងវិបត្តិមនុស្សធម៌អាចបន្តយូរអង្វែងដោយបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើជីវិតប្រចាំថ្ងៃ។ ដូច្នេះ ការរក្សានិរន្តរភាពនៃការឆ្លើយតបរបស់នគរបាលគឺជាបញ្ហាចោទ។

ផ្អែកតាមបទពិសោធន៍របស់យើងក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩ ស្ថាប័ននគរបាលនៅជុំវិញពិភពលោកត្រូវរិះរកវិធីថ្មីក្នុងការបំពេញការងារ។ស្ថាប័ននគរបាលខ្លះមានសំណាងល្អដែលអាចប្រើប្រាស់បច្ចេកវិទ្យាថ្មីៗជាជំនួយខណៈដែលស្ថាប័ននគរបាលផ្សេងទៀតប្រហែលជាគ្មានសំណាងទេ។ មិនថាអ្នកមានធនធានអ្វីខ្លះនោះទេ អ្នកត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យមានប្រសិទ្ធភាពហើយអ្នកត្រូវបង្ហាញភាពជាអ្នកដឹកនាំបែបនវានុវត្តន៍ដោយរិះរកវិធីថ្មីៗក្នុងការបំពេញការងារ។
យើងតែងតែអាចរៀនសូត្រពីអ្វីដែលបានកើតឡើងប៉ុន្តែប្រសិនបើអ្នកគ្មានផែនការគ្រោះអាសន្ន ឬផែនការយថា



រូបថតទទួលបានពី MINUSTAH/Logan Abassi (ប្រទេសហៃទី)

ភាពសម្រាប់ផ្នែកនៃការទទួលខុសត្រូវរបស់អ្នកដើម្បីឱ្យអ្នកអាចប្រឈមមុខប្រកបដោយប្រសិទ្ធភាពជាមួយនឹងវិបត្តិ និងបន្តផ្តល់សេវាបាន អ្នកត្រូវបង្កើតផែនការទាំងនោះ។ សូម្បីតែនៅពេលដែលអ្នកស្ថិតក្នុងវិបត្តិ ក៏អ្នកនៅតែអាចប្រជុំពិភាក្សាពន្យល់ជាមួយបុគ្គលិកដើម្បីឆ្លុះបញ្ចាំងពីសកម្មភាពរបស់អ្នក និងចាប់ផ្តើមបូកសរុបមេរៀនកន្លងមក ដើម្បីឱ្យអ្នកអាចបង្កើតផែនការត្រៀមទុកសម្រាប់ព្រឹត្តិការណ៍ស្រដៀងគ្នា ដូចជា រលកថ្មីនៃជំងឺណាមួយ។

**រូប ២ ៖**

**វដ្ត Townsley សម្រាប់ការរៀបចំផែនការដែលឆ្លើយតបនឹងយេនឌ័រ និងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានវិបត្តិ**




រូប ២ (វដ្ត Townsley) ជាឧបករណ៍ដែលអាចយកទៅប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តការរៀបចំផែនការ និងការធ្វើប្រតិបត្តិការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានវិបត្តិ។ ឧបករណ៍នេះ គឺជាដំណើរការជារង្វង់ដែលតម្កល់សុវត្ថិភាពនិងការការពារជាចំណុចស្នូល។ គេអាចប្រើឧបករណ៍នេះសម្រាប់ពិនិត្យឡើងវិញលើផែនការឆ្លើយតបមានស្រាប់ដើម្បីធានាថាផែនការទាំងនោះ "សមស្របតាមគោលបំណង" ក្នុងពេលមានវិបត្តិឬបង្កើតផែនការក្នុងពេលមានវិបត្តិ។យកល្អគួរប្រើឧបករណ៍នេះសម្រាប់ការរៀបចំផែនការជាមុនដើម្បីបង្កើតការឆ្លើយតបក្នុងគ្រាអាសន្នទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ប្រសិនមានវិបត្តិនាពេលអនាគត។ ក្រៅពីនេះ អ្នកអាចប្រើឧបករណ៍នេះសម្រាប់ឱ្យមន្ត្រីឆ្លើយតបធ្វើការសម្រេចចិត្តបានយ៉ាងរស់រវើក ។

សម្រាប់ព័ត៌មានបន្ថែមនិងការណែនាំស្តីពីការប្រើប្រាស់វដ្ត Townsley សម្រាប់ការរៀបចំផែនការដែលឆ្លើយតបនឹងយេនឌ័រ និងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងវិបត្តិសុខភាពសាធារណៈ (ជំងឺរាតត្បាត/ជំងឺឆ្លង) ឬវិបត្តិមនុស្សធម៌ សូមមើល**ឧបសម្ព័ន្ធ ១**។

ប្រសិនបើអ្នកមានផែនការស្រាប់ អ្នកត្រូវពិនិត្យផែនការទាំងនោះជាបន្តបន្ទាប់ក្នុងពេលមានវិបត្តិ ដើម្បីធានាថាផែនការទាំងនោះ "សមស្របតាមគោលបំណង" ដោយធ្វើការកែសម្រួលទៅតាមភាពចាំបាច់។

មិនថាអ្នកមានផែនការឬកំពុងរៀបចំផែនការនោះទេអ្នកត្រូវពិចារណាពីសំណួរសំខាន់ៗជាច្រើនដូចខាងក្រោម ៖

- តើផែនការនោះត្រូវបានរក្សាទុកនៅទីណា?

- តើនរណាខ្លះដែលត្រូវដឹងនិងយល់ពីខ្លឹមសារផែនការនោះ?តើពួកគេមានភារកិច្ចស្វែងយល់ពីខ្លឹមសារទាំងនោះ ឬទេ?
- តើបានកំណត់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវក្នុងផែនការនោះ បូករួមនឹងគណនេយ្យភាព ឬទេ?
- តើត្រូវមានការបណ្តុះបណ្តាលអ្វីខ្លះស្តីពីផែនការនោះ?
- តើផែនការនោះត្រូវបានសាកល្បងទៀងទាត់កម្រិតណា?
- តើផែនការនោះត្រូវបានសាកល្បងចុងក្រោយនៅពេលណា?
- តើផែនការនោះត្រូវបានពិនិត្យតាមដាន ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយរបៀបណា?
- តើមេរៀនត្រូវបានដាក់បញ្ចូលក្នុងផែនការនោះដោយរបៀបណា? (អាចជាមេរៀនពីថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬអន្តរជាតិ)
- តើការប្រជុំពិភាក្សាមុនចាប់ផ្តើមសកម្មភាព និងការប្រជុំពិភាក្សាក្រោយចប់សកម្មភាពត្រូវបានដាក់បញ្ចូលក្នុងការអនុវត្តផែនការនោះដោយរបៀបណា?

សំណួរខាងលើគ្រាន់តែជាឧទាហរណ៍មួយចំនួននៃចំណុចដែលអ្នកត្រូវពិចារណា។ សម្រាប់ការរៀបចំផែនការយថាហេតុ (ចុះបើ?) នៃការរៀបចំផែនការប្រតិបត្តិការទាំងអស់ អ្នកគួរអនុវត្តប្រចាំថ្ងៃ មិនថាសម្រាប់ឧប្បត្តិហេតុដែលមិនទាន់កើតឡើង ឬឧប្បត្តិហេតុកើតឡើងភ្លាមៗនោះទេ។

ផែនការបន្តប្រតិបត្តិការគឺខុសពីនេះបន្តិចព្រោះផែនការនេះមានគោលបំណងធានាថា អ្នកអាចរក្សាបាននូវ "ប្រតិបត្តិការជាធម្មតា" ឬមុខងារប្រតិបត្តិការស្នូលរបស់អ្នកក្នុងពេលមានវិបត្តិ។ ចំណុចនេះមានភាពពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដូចបញ្ហាផ្សេងទៀតដែលអាចមានការអំពាវនាវឱ្យអ្នកធ្វើការឆ្លើយតបដែរ។ អ្នកត្រូវពិចារណាពីអ្វីដែលអ្នកមានសម្រាប់ឆ្លើយតបទៅនឹងជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រីហើយរបៀបរក្សាការឆ្លើយតបនេះនៅពេលមានការពង្រីកធនធានរបស់អ្នក លទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធមានកម្រិត និងការចូលដល់ដើមបណ្តឹងនិងសាក្សីគឺជាហានិភ័យព្រោះអាចមានការចម្លងជំងឺ។ អ្នកត្រូវអនុវត្តអភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក (សូមមើលជំពូកទី ៥ ៖ ការស៊ើបអង្កេត)។ ការពិចារណាពីចំណុចទាំងនេះក្នុងពេលមានឬគ្មានវិបត្តិនិងការបង្កើតផែនការឆ្លើយតប នឹងជួយដល់អ្នកក្នុងការធ្វើការសម្រេចចិត្តច្បាស់លាស់ក្នុងស្ថានភាពដ៏តានតឹង។

## សុវត្ថិភាព និងការការពារ

សុវត្ថិភាព និងការការពារ (សូមមើលជំពូកទី ៦ ៖ សុវត្ថិភាព និងការការពារ) ជាផ្នែកដ៏សំខាន់មួយនៃការឆ្លើយរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីប៉ុន្តែវាកាន់តែសំខាន់ក្នុងពេលមានវិបត្តិដែលចាំបាច់ត្រូវមានការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត។ អ្នក និងបុគ្គលិករបស់អ្នកត្រូវពិចារណារាល់ហានិភ័យពាក់ព័ន្ធទាំងអស់ចំពោះជនរងគ្រោះ និងបុគ្គលិករបស់អ្នកផ្ទាល់តាមរយៈការវាយតម្លៃហានិភ័យដោយផ្អែកលើកាលៈទេសៈពាក់ព័ន្ធនៅពេលនោះ។ បុគ្គលិករបស់អ្នកអាចមានអារម្មណ៍ភ័យខ្លាច ប្រសិនបើពួកគេប្រឈមនឹងហានិភ័យ។ ដូច្នេះ អ្នកត្រូវបញ្ជាក់អះអាង និងលើកទឹកចិត្តពួកគេ។ការមិនចូលរួមមិនមែនជាជម្រើសឡើយព្រោះជីវិតរបស់នរណាម្នាក់អាចអាស្រ័យលើការចូលរួមនោះ។ ហេតុនេះ អ្នកត្រូវសម្រាលហានិភ័យដែលកើតឡើងចំពោះបុគ្គលិករបស់អ្នក។ វិធីមួយគឺត្រូវផ្តល់បរិក្ខារការពារបុគ្គលសមស្របដល់ពួកគេ (ដែលអាចខ្វះខាតក្នុងពេលមានវិបត្តិ) និងពង្រឹងការរៀបចំផែនការយថាហេតុ និងផែនការគ្រោះអាសន្ន។

> "ដូចបុគ្គលិកវេជ្ជសាស្ត្រដែរ មន្ត្រីនគរបាលមិនអាចធ្វើការនៅផ្ទះបានឡើយ។ ដូច្នេះ ពួកគេក៏ស្ថិតនៅជួរមុខដែរ។ ការទទួលខុសត្រូវទីមួយរបស់យើងគឺត្រូវរក្សាសុខភាព និងសុវត្ថិភាព។ ដូច្នេះ យើងត្រូវមានទាំងបរិក្ខារ និងឥរិយាបថការពារខ្លួន។
> ការការពារខ្លួនអាចឱ្យយើងការពារអ្នកដទៃបាន។ យើងត្រូវធានាថា យើងមិនចម្លងជំងឺទៅអ្នកដទៃ ហើយយើងកំពុងការពារជនងាយរងគ្រោះបំផុតដោយសហការជាមួយកងកម្លាំងនគរបាល"។
>
> លោកអធិការ Luis Carrilho ទីប្រឹក្សានគរបាលអង្គការសហប្រជាជាតិនិងជាអតីតអធិការនគរបាលនៃបេសកកម្ម
> អង្គការសហប្រជាជាតិនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល (MINUSCA)

ការបំពាក់បរិក្ខារការពារបុគ្គលតែម្យ៉ាងមិនអាចកាត់បន្ថយហានិភ័យបានឡើយ ប្រសិនបើបុគ្គលិករបស់អ្នកមិនត្រូវបានប្រជុំពិភាក្សាពន្យល់អំពីរបៀបប្រើប្រាស់ រក្សាទុក និងបោះចោល ត្រឹមត្រូវ។ ចំណុចមួយទៀតគឺត្រូវធានាថាបរិក្ខារការពារបុគ្គលដែលផ្តល់ជូនគឺសមល្មមសម្រាប់មន្ត្រីទាំងពីរភេទ និងអាចប្រើប្រាស់បានដោយគ្មានការរើសអើង។ ប្រអប់ ២ ផ្តល់ឧទាហរណ៍មួយនៃការណែនាំប្រតិបត្តិការដោយក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (NPCC) និងមហាវិទ្យាល័យសេវានគរបាលស្តីពីការប្រើប្រាស់បរិក្ខារការពារបុគ្គល។

**ប្រអប់ ១**

**ការណែនាំប្រតិបត្តិការស្តីពីបរិក្ខារការពារបុគ្គល (ចក្រភពអង់គ្លេស)**

ក្នុងពេលឆ្លើយតបនឹងជំងឺកូវីដ ១៩ សេវានគរបាលទូទាំងចក្រភពអង់គ្លេសទទួលបានការណែនាំប្រតិបត្តិការពីក្រុមប្រឹក្សាជាតិនៃស្នងការនគរបាល (NPCC) និងមហាវិទ្យាល័យ សេវានគរបាលស្តីពីការប្រើប្រាស់បរិក្ខារការពារបុគ្គល។ ការណែនាំនោះរួមបញ្ចូលសេណារីយ៉ូប្រតិបត្តិការដើម្បីជួយឱ្យបុគ្គលិកយល់ពីការប្រើប្រាស់បរិក្ខារការពារបុគ្គលបានត្រឹមត្រូវ។ឧទាហរណ៍មួយចំនួនដែលដកស្រង់ពីការណែនាំនោះមានបង្ហាញដូចខាងក្រោម។ការណែនាំនេះអាចយកទៅអនុវត្តបន្ត ឬកែសម្រួលក្នុងវិបត្តិសុខភាពសាធារណៈផ្សេងទៀត។

- មន្ត្រីគ្រប់រូបគួរមានម៉ាស់ និងស្រោមដៃមិនជ្រាបទឹក (គ្មានជាតិកៅស៊ូ) និងក្នុងករណីដែលមន្ត្រីត្រូវបានដាក់ពង្រាយតាមរថយន្តល្បាតដែលមានបុគ្គលិក និងបរិក្ខារបំពាក់គ្រប់គ្រាន់ ឬក្នុងយានជំនិះដឹកបុគ្គលិក។ គួរមានបរិក្ខារការពារបុគ្គលជាស្រេចសម្រាប់មន្ត្រីម្នាក់ៗ ដើម្បីអាចយកមកបំពាក់បានលឿនក្នុងករណីចាំបាច់។
- អ្នកទទួលទូរស័ព្ទ និងអ្នកបញ្ជូនភ្នាក់ងារ ត្រូវកំណត់ថាតើមានករណីសង្ស័យ ឬករណីបញ្ជាក់ជំងឺកូវីដ ១៩ ឬទេ ដើម្បីអាចឱ្យមន្ត្រីឆ្លើយតបទទួលបានព័ត៌មានជាមុន និងអាចពាក់បរិក្ខារការពារបុគ្គលសមស្រប។
- នៅពេលចូលក្នុងបរិវេណអគារ មន្ត្រីត្រូវដឹងថា មនុស្សមួយចំនួនក្នុងអគារអាចមិនដឹងថា ពួកគេឆ្លងជំងឺ។ ដូច្នេះមន្ត្រីត្រូវធ្វើការវាយតម្លៃហានិភ័យយ៉ាងរស់រវើកជាបន្តបន្ទាប់។
- ក្នុងករណីមិនអាចរក្សាគម្លាតសង្គមបាន និងអាចមាន "ទំនាក់ទំនងជិតស្និទ្ធ" ជាមួយសាធារណជន មន្ត្រីគួរពាក់ម៉ាស់ និងស្រោមដៃមិនជ្រាបទឹក (គ្មានជាតិកៅស៊ូ)។ ប្រសិនបើបុគ្គលនោះមានរោគសញ្ញា ការប្រើប្រាស់វ៉ែនតាការពារ និងសំពត់ទ្រនាប់ត្រូវតែជាផ្នែកមួយនៃការវាយតម្លៃហានិភ័យ។

ប្រភព ៖ ការណែនាំប្រតិបត្តិការស្តីពីបរិក្ខារការពារបុគ្គល (ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០) មហាវិទ្យាល័យសេវានគរបាល ចក្រភពអង់គ្លេស។

## ការទប់ស្កាត់

ក្នុងស្ថានភាពប្រឈម ដែលធនធានរបស់នគរបាលត្រូវបានប្រើប្រាស់សម្រាប់ការប្រឈមជាមួយវិបត្តិ ការជំរុញការចូលរួមរបស់សហគមន៍កាន់តែមានសារៈសំខាន់សម្រាប់ការការពារ សហគមន៍មូលដ្ឋានរបស់អ្នកពីផលប៉ះពាល់នៃវិបត្តិ ក៏ដូចជារក្សាអាទិភាពនៃសេវានគរបាលផ្សេងទៀត។ ការអប់រំ និងការកសាងការយល់ដឹងរបស់សហគមន៍ស្តីពីអ្វីដែលពួកគេត្រូវធ្វើដើម្បីការពារខ្លួនពីផលប៉ះពាល់នៃវិបត្តិ នឹងផ្តល់ឱកាសសម្រាប់ការកសាងការយល់ដឹងរបស់ពួកគេស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី អ្វីដែលត្រូវរិះរក និងរបៀបគាំទ្រជនរងគ្រោះ និងសម្រួលដល់ការរាយការណ៍។ អ្នកនឹងពឹងផ្អែកលើសហគមន៍ឱ្យធ្វើជា "ភ្នែកច្រមុះ" នៅមូលដ្ឋានជាពិសេសក្នុងពេលរក្សាគម្លាតសង្គម ឬការរឹតត្បិតការដើរហើរ។

ធានាថា នៅពេលប្រជុំពិភាក្សាពន្យល់បុគ្គលិករបស់អ្នកស្តីពីភារកិច្ចរបស់ពួកគេពាក់ព័ន្ធនឹងវិបត្តិ ពួកគេយល់ពីភាពងាយរងគ្រោះបន្ថែមទៀតដោយសារអំពើហិង្សាលើ



រូបថតទទួលបានពីនាយកដ្ឋានទំនាក់ទំនងកងកម្លាំងនគរបាលនីហ្សេរីយ៉ា

ស្ត្រីនិងក្មេងស្រីដូចជាកង្វះអាហារបរិភោគនិងតម្រូវការរស់រានផ្សេងទៀតដែលអាចនាំទៅរកការកេងប្រវ័ញ្ច និងភាពតានតឹងកាន់តែខ្លាំង។ រំលឹកបុគ្គលិករបស់អ្នកថា ពួកគេមានការទទួលខុសត្រូវនិងគណនេយ្យភាពផ្ទាល់ខ្លួនក្នុងការ "មិនបង្កគ្រោះថ្នាក់" យកចិត្តទុកដាក់លើសាធារណជន និងសហការី និងឃ្លាំមើល និងកត់សម្គាល់សញ្ញានៃអំពើហិង្សា ឬការរំលោភបំពាន ដែលមិនសុទ្ធតែលេចឡើងនោះទេ (សូមមើលជំពូកទី ៥ ៖ ការស៊ើបអង្កេត)។

ការចូលរួមរបស់អ្នកជាមួយសហគមន៍ក្នុងពេលមានវិបត្តិអាចកសាង ឬបំផ្លាញទំនុកចិត្ត និងភាពជឿជាក់របស់ពួកគេលើសេវានគរបាលដែលផ្តល់ដោយរូបអ្នកផ្ទាល់ និងបុគ្គលិករបសអ្នក។ ប្រសិនបើមន្ត្រីរបស់អ្នកបំពានសិទ្ធិអំណាចក្នុងការពង្រឹងការរឹតត្បិតដែលកំណត់ដោយរដ្ឋាភិបាលវានឹងបង្កផលវិបាកជ្រាលជ្រៅលើទំនាក់ទំនងជាមួយសហគមន៍យូរអង្វែងក្រោយវិបត្តិផុតរលត់ដែលនឹងធ្វើឱ្យការងាររបស់អ្នកកាន់តែលំបាក។ ការជំរុញការចូលរួមរបស់សហគមន៍ក្នុងការអប់រំ និងការកសាងការយល់ដឹង ដោយប្រើការបញ្ចុះបញ្ចូលជាជាងការបង្ខិតបង្ខំ នឹងបង្កើនទំនុកចិត្ត និងភាពជឿជាក់ដែលជាប្រយោជន៍សម្រាប់អ្នកក្រោយពេលវិបត្តិផុតរលត់។

ការជំរុញការចូលរួមរបស់វិស័យមួយចំនួនក្នុងសហគមន៍អាចជួយការពារជនរងគ្រោះមិនឱ្យប្រឈមនឹងអំពើហិង្សា ឬការរំលោភបំពានជាបន្តបន្ទាប់ (សម្រាប់ឧទាហរណ៍ជាក់លាក់ សូមមើលប្រអប់ ៤ ស្តីពីភាពជាដៃគូរវាងនគរបាល និងប្រជាពលរដ្ឋ)។ ឧ. ឱសថស្ថានអាចផ្តល់បន្ទប់ពិគ្រោះជំងឺដែលជាទីសុវត្ថិភាពសម្រាប់ឱ្យជនរងគ្រោះរាយការណ៍ពីអំពើហិង្សា ឬការរំលោភបំពាន ចំណែកបុគ្គលិកហាងលក់គ្រឿងទេសអាចទទួលការអប់រំស្តីពីអ្វីដែលត្រូវឃ្លាំមើលដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះក្នុងចំណោមអតិថិជនរបស់ខ្លួននិងរបៀបផ្តល់ការគាំទ្រសមស្របដែលអាចត្រឹមតែជាការទាក់ទងទៅឱ្យនគរបាល ឬអ្នកផ្តល់សេវាផ្សេងទៀត ជំនួសមុខឱ្យជនរងគ្រោះ។

ក្នុងអំឡុងវិបត្តិជំងឺកូវីដ១៩នៅប្រទេសអូស្ត្រាលីនគរបាលមានភាពប្រតិសកម្មក្នុងការកំណត់អត្តសញ្ញាណស្ត្រីដែលងាយរងគ្រោះ ជាពិសេសស្ត្រីដែលធ្លាប់រាយការណ៍ពីអំពើហិង្សា ឬការរំលោភបំពាន និងចុះជួបជាប្រចាំដើម្បីពិនិត្យសុវត្ថិភាពរបស់ពួកគេ។ សកម្មភាពនេះត្រូវធ្វើឡើងដោយ



រូបថតទទួលបានពីនាយកដ្ឋានទំនាក់ទំនងកងកម្លាំងនគរបាលនីហ្សេរីយ៉ា

ប្រុងប្រយ័ត្នដើម្បីបញ្ចៀសការបង្កើតហានិភ័យបន្ថែមទៀតលើពួកគេ។

អ្នកត្រូវបញ្ជាក់ច្បាស់ជាមួយបុគ្គលិករបស់អ្នកថា ពួកគេត្រូវប្រឈមមុខភ្លាមៗនិងប្រកបដោយប្រសិទ្ធភាពជាមួយអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនមែនត្រឹមតែក្នុងអំឡុងវិបត្តិបច្ចុប្បន្ននោះទេ ប៉ុន្តែត្រូវជានាប្រសិទ្ធភាពនៃការឆ្លើយតបទាំងក្នុងពេល និងក្រោយពេលវិបត្តិនេះ។ សូមមើលជំពូកទី៣សម្រាប់ព័ត៌មានបន្ថែមស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

## ទំនាក់ទំនងដំបូង

ដើម្បីរក្សាគម្លាតសង្គម អ្នកប្រហែលជាត្រូវពិចារណាពីជម្រើសផ្សេងៗក្រៅពី"ទំនាក់ទំនងជិតស្និទ្ធ"ដោយរិះរកវិធីថ្មីៗសម្រាប់ឱ្យជនរងគ្រោះរាយការណ៍ ឬស្វែងរកការការពារពីអំពើហិង្សា ឬការរំលោភបំពាន ជាពិសេសប្រសិនបើពួកគេត្រូវបានកាត់ផ្តាច់ផ្តាច់ពីអ្នកដទៃដោយសារការរឹតត្បិតការដើរហើរ។លើកកម្ពស់ការប្រើប្រាស់ខ្សែទូរស័ព្ទជំនួយ ហើយប្រសិនបើនគរបាលគ្រប់គ្រងខ្សែទូរស័ព្ទទាំងនោះ សូមពិចារណាបង្កើនចំនួនបុគ្គលិកសម្រាប់ទទួល និងប្រឈមនឹងការទូរស័ព្ទចូល។

បង្កើត ឬពង្រឹងកិច្ចព្រមព្រៀងជាមួយស្ថាប័ន/អ្នកផ្តល់សេវាផ្សេងទៀតវិស័យយុត្តិធម៌ក្រៅផ្លូវការ ក្រុមសហគមន៍ និងសហគមន៍ធំទូលាយ ដូចជា អ្នកជិតខាង មិត្តភក្តិ ម្ចាស់ហាងដើម្បីផ្តល់ឱកាសងាយស្រួលដល់ជនរងគ្រោះក្នុងការរាយការណ៍។បុគ្គលិកដែលត្រូវបានដាក់ពង្រាយឱ្យបំពេញតួនាទីធ្វើតេស្ត និងតាមដានជំងឺឆ្លង អាចផ្តល់ការផ្សារភ្ជាប់ដ៏សំខាន់មួយរវាងជនរងគ្រោះ និងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានយុត្តិធម៌ និងការគាំទ្រឱ្យតែពួកគេត្រូវបានប្រជុំពិភាក្សាពន្យល់សមស្រប។ អាទិភាពចម្បងរបស់អ្នកត្រូវតែជាសុវត្ថិភាព និងការការពារជនរងគ្រោះនិងមនុស្សក្នុងបន្ទុកគ្រួសាររបស់ពួកគេ។

ធានាថា បុគ្គលិករបស់អ្នកត្រូវបានប្រជុំពិភាក្សាពន្យល់ពេញលេញស្តីពីសញ្ញានៃអំពើហិង្សា ឬការរំលោភបំពាន និងចងចាំពីសញ្ញាទាំងនោះនៅពេលប្រឈមជាមួយសាធារណជនលើបញ្ហាផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ សូមមើលជំពូកទី ៤ សម្រាប់ព័ត៌មានបន្ថែមស្តីពីទំនាក់ទំនងដំបូង(លទ្ធភាពទទួលបានយុត្តិធម៌)។

## ការស៊ើបអង្កេត

ពិចារណាពីមធ្យោបាយប្រមូលភស្តុតាងផ្សេងទៀតដែលអាចជួយរក្សាគម្លាតសង្គម ដូចជា បច្ចេកវិទ្យាតាមប្រព័ន្ធអ៊ីនធឺណិតដែលអ្នកអាចទាក់ទងទៅពួកគេបាន។ការបង្កប់ម៉ាស៊ីនថតលើរាងកាយដែលអាចកត់ត្រារបាយការណ៍របស់ជនរងគ្រោះ បូករួមនឹងភស្តុតាងកន្លែងកើតហេតុ និងរបួសស្នាមអាចកាត់បន្ថយភាពចាំបាច់នៃទំនាក់ទំនងជិតស្និទ្ធ។ សូមចាំថា ឯកភាព និងការរក្សាការសម្ងាត់របស់ជនរងគ្រោះនៅតែជាចំណុចចាំបាច់។ ដូច្នេះ សូមពិចារណាពីបរិយាកាសនេះ សូម្បីតែនៅពេលប្រើប្រាស់បច្ចេកវិទ្យា។ នៅពេលអ្នកមិនអាចទទួលបានធនធានទាំងនេះ អ្នកត្រូវខិតខំសម្រាលហានិភ័យតាមដែលអាចធ្វើទៅបាន ដូចជា ការប្រើប្រាស់បរិក្ខារការពារបុគ្គល និងការអនុវត្តវិធានការរក្សាគម្លាតសង្គម។

គួរពិចារណាទុកជាមុននូវករណីដែលបុគ្គលិករបស់អ្នកអាចនិយាយជាមួយជនរងគ្រោះដែលផ្តល់"ចន្លោះសុវត្ថិភាព" ដូចជាការយកចិត្តទុកដាក់លើជនរងគ្រោះការផ្តល់ឯកជនភាព និងការអនុញ្ញាតឱ្យពួកគេ និងមន្ត្រីស៊ើបអង្កេតកាត់បន្ថយហានិភ័យសុខភាពចំពោះគ្នាទៅវិញទៅមក។ សូមគិតពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត ការបញ្ចៀសឱ្យបាននូវការបន្ថែមការប៉ះទង្គិចផ្លូវចិត្ត ដោយសារការចាត់

វិធានការបន្ថែមទៀតក្នុងវិបត្តិដែលអ្នកកំពុងប្រឈម។

ប្រសិនបើត្រូវបញ្ជូនជនរងគ្រោះ ឬជនបង្កតាមរថយន្តនគរបាលសូមពិចារណាបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តនោះនៅពេលបន្ទាប់មកទៀត ប៉ុន្តែមិនមែនមុនពេលប្រមូលភស្តុតាងកោសលវិច័យឬអ្វីដែលអាចជាភស្តុតាងពីរថយន្តនោះទេ។ យកល្អគួរសម្អាតរថយន្តនគរបាលទាំងអស់នៅពេលចាប់ផ្តើម និងក្រោយវេននីមួយៗ ឬនៅពេលផ្លាស់ប្តូរអ្នកប្រើប្រាស់យានជំនិះក្នុងពេលមានវិបត្តិសុខភាពសាធារណៈអាស្រ័យលើហានិភ័យនៃវិបត្តិនោះ។ សូមមើលជំពូកទី ៥ សម្រាប់ព័ត៌មានបន្ថែមស្តីពីការស៊ើបអង្កេតអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

## ការគាំទ្រ និងជំនួយ

ការធ្វើការបែបសហការជាការសំខាន់ក្នុងពេលមានវិបត្តិ។ អ្នកត្រូវពិចារណាថាតើភាពជាដៃគូមានស្រាប់របស់អ្នកអាចបន្តទៅមុខដោយសុវត្ថិភាពឬអាចកាត់បន្ថយហានិភ័យឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ឬទេ។ ដោយសារការរក្សាគម្លាតសង្គម ការរឹតត្បិតការដើរហើរ និងវិធានការចត្តាឡីស័ក អ្នកត្រូវរិះរកវិធីផ្សេងទៀតក្នុងការទាក់ទងទៅជនរងគ្រោះនិងសម្របសម្រួលយន្តការរាយការណ៍មិនស្មុគស្មាញ/ការសម្រាប់ពួកគេ ដែលអាចធ្វើឡើងតាមរយៈស្ថាប័ន និងអ្នកផ្តល់សេវាផ្សេងទៀត។ល។ សូមមើលករណីសិក្សានៅចុងបញ្ចប់នៃជំពូកនេះ។

កិច្ចសហការជាមួយដៃគូថ្មីៗ នឹងទាមទារការកសាងការយល់ដឹងអំពីសញ្ញានៃការរំលោភបំពាននិងអ្វីដែលពួកគេត្រូវធ្វើដើម្បីការពារជនរងគ្រោះ។ ក្រៅពីនេះ ការកសាងកម្រិតយល់ដឹងស្តីពីអ្វីដែលមិនត្រូវធ្វើដើម្បីទប់ស្កាត់ការចម្លង ការបំផ្លាញ ឬការបាត់បង់ភស្តុតាង នឹងអាចជួយដល់ជនរងគ្រោះបានយូរអង្វែង។

កំណត់តាំងពីដំបូង ជាពិសេសនៅពេលរៀបចំផែនការយថាហេតុ ឬផែនការគ្រាអាសន្ន នូវធនធាន ឬសេវាផ្សេងទៀតដែលអាចផ្តល់ជូនជនរងគ្រោះនៅពេលដែលលទ្ធភាពផ្តល់ការគាំទ្រ និងជំនួយដល់ពួកគេអាចរងផលប៉ះពាល់ដោយសារវិបត្តិ។ ឧ. អ្នកគួរសន្មតថា ជម្រកសុវត្ថិភាពឬទីស្នាក់អាចមានកម្រិត។ ដូច្នេះ ក្រោមការសហការជាមួយអ្នកដទៃ តើអ្នកអាចកំណត់រកអ្វីខ្លះដែលអាចផ្តល់កន្លែងសុវត្ថិភាពសម្រាប់ជនរងគ្រោះបាន?ការពិចារណានិងការរៀបចំផែនការសម្រាប់ព្រឹត្តិការណ៍ទាំងនេះនឹងសម្រាលបន្ទុករបស់អ្នកក្នុងស្ថានភាពវិបត្តិ ក៏ដូចជាផ្តល់សុវត្ថិភាព និងការការពារដល់អ្នកខ្វះខាត។ សូមមើលជំពូកទី៧សម្រាប់ព័ត៌មានបន្ថែមស្តីពីការគាំទ្រនិងជំនួយ។

## ការសម្របសម្រួលក្នុងចំណោមស្ថាប័នយុត្តិធម៌

អ្នកគួរពិនិត្យឡើងវិញនិងប្រសិនបើសមស្របកែសម្រួលអនុស្សរណៈយោគយល់គ្នាឬកិច្ចព្រមព្រៀងស្តីពីរបៀបធ្វើការជាមួយស្ថាប័នយុត្តិធម៌ផ្សេងទៀតដែលអាចប្រឈមនឹងការលំបាកដោយសារវិបត្តិនេះ ដូចអ្នកដែរ។ តើអ្នកអាចបន្តសហការគ្នាដូចម្តេចដើម្បីផ្តល់សេវាយុត្តិធម៌ដែលមានប្រសិទ្ធភាព និងអាចទទួលបាន?

ប្រសិនបើអ្នកគ្មានកិច្ចព្រមព្រៀងពីមុនមកទេអ្នកប្រហែលជាត្រូវពិចារណាបង្កើតរបៀបធ្វើការក្នុងគ្រាអាសន្នតាមមូលដ្ឋាន ឬយ៉ាងហោចណាស់លើកឡើងពីបញ្ហានេះតាមរយៈខ្សែសង្វាក់បញ្ជារបស់អ្នកដែលត្រូវពិចារណានៅកម្រិតយុទ្ធសាស្ត្រ។

គោលដៅចុងក្រោយសម្រាប់អ្នក និងស្ថាប័នយុត្តិធម៌ផ្សេងទៀតគួរតែជាការទទួលយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ដូច្នេះ អ្នកគួរពិភាក្សា និងសម្រេចយកចំណុចអាទិភាពដើម្បីអាចឱ្យអ្នកឆ្លងផុតវិបត្តិចំពោះមុខនិងរបៀបដែលអ្នកវិលត្រឡប់ទៅរកប្រក្រតីភាពវិញទោះបីនោះជាការរស់នៅធម្មតាតាមបែបគន្លងថ្មី ក្រោយពេលវិបត្តិផុតរលត់ក្តី។ សូមមើលជំពូកទី៨សម្រាប់ព័ត៌មានបន្ថែមស្តីពីការសម្របសម្រួលជាមួយស្ថាប័នយុត្តិធម៌។

## ទំនាក់ទំនង

ការផ្តល់សារច្បាស់លាស់ ខ្លី និងស៊ីសង្វាក់គ្នា តែងតែជាកត្តាសំខាន់ ប៉ុន្តែវាសំខាន់បំផុតក្នុងពេលមានវិបត្តិ។ ការរក្សាឱ្យមនុស្សគ្រប់រូបទទួលបានព័ត៌មាន នឹងធានាការអនុលោមតាមការណែនាំ ការរឹតត្បិត ឬដំបូន្មានសុវត្ថិភាព ហើយវាអាចជះឥទ្ធិពលលើទំនុកចិត្តរបស់សហគមន៍នៅ




រូបថតទទួលបានពី UN Women/Louie Parcardo (ប្រទេសហ្វីលីពីន)

មូលដ្ឋានលើសមត្ថភាពរបស់អាជ្ញាធរក្នុងការប្រឈមមុខជាមួយវិបត្តិ។ ការផ្តល់ព័ត៌មានសុក្រឹត និងពាក់ព័ន្ធអាចបង្កើនគណនេយ្យភាព និងនិរន្តរភាព។

ការផ្តល់សារត្រូវតែមានភាពស៊ីសង្វាក់គ្នាក្នុងវិស័យទាំងអស់ និងនៅពេលផ្សព្វផ្សាយពីវិបត្តិ ព្រោះវាផ្តល់ឱកាសសម្រាប់ការផ្តល់ព័ត៌មានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការកសាងការយល់ដឹងអំពីហានិភ័យកាន់តែច្រើន និងការបង្ហាញយ៉ាងច្បាស់ថា អំពើហិង្សានឹងមិនត្រូវបានអត់ឱនសូម្បីតែក្នុងពេលប្រឈមជាមួយវិបត្តិ។ ចំណុចនេះក៏ផ្តល់ឱកាសសម្រាប់ការអំពាវនាវដោយផ្ទាល់ឱ្យសមាជិកសហគមន៍ទាំងអស់ជួយការពារជនងាយរងគ្រោះផងដែរ។

រូបភាពអាចជាវិធីដ៏ល្អប្រសើរក្នុងការផ្តល់សារសំខាន់ៗ បូករួមនឹងពាក្យស្លោក ដូចជា នៅចក្រភពអង់គ្លេសក្នុងវិបត្តិជំងឺកូវីដ ១៩ ពាក្យស្លោក "អ្នកមិនឯកោរ" (#YouAreNotAlone) ផ្តោតសំខាន់លើជនរងគ្រោះដោយសារការរំលោភបំពានក្នុងគ្រួសារនិងអំពើហិង្សាលើដៃគូស្និទ្ធស្នាល ជាពិសេសក្នុងពេលរឹតត្បិតការដើរហើរ ចំណែកពាក្យស្លោក"គ្មានការដោះសារចំពោះការរំលោភបំពាន"(#NoExcuseForAbuse) ផ្តោតលើជនបង្ក។ នគរបាលកូសូវ៉ូ និងដៃគូ (សូមមើលករណីសិក្សា) ប្រើប្រាស់ពាក្យស្លោកបានយ៉ាងល្អ៖ "រួមគ្នាប្រឆាំងអំពើហិង្សាក្នុងគ្រួសារ" និង "គ្រួសារមិនមែនជាអ្វីដែលសំខាន់ឡើយ ប៉ុន្តែគ្រួសារជាអ្វីៗគ្រប់យ៉ាង"។

ចែករំលែកព័ត៌មានស្តីពីជំនួយដែលមានសម្រាប់ជនរងគ្រោះ និងរបៀបទទួលបានជំនួយយ៉ាងទូលំទូលាយ និងតាមមធ្យោបាយផ្សេងៗ។ សូមប្រុងប្រយ័ត្នចំពោះការផ្តល់សារផ្ទាល់ពីផ្ទះមួយទៅផ្ទះមួយ ព្រោះវាអាចក្រើនរំលឹកដល់ជនបង្ក។ ទោះជាយ៉ាងណា ការចុះជួបអ្នកដែលត្រូវបានកំណត់ជាជនងាយរងគ្រោះ ឬធ្លាប់ជាជនរងគ្រោះដោយសារអំពើហិង្សា ឬការរំលោភបំពាន និងបច្ចុប្បន្នបានវិលមកជួបជុំឬស្នាក់នៅជាមួយជនបង្ក អាចផ្តល់សារសំខាន់ថាវិបត្តិនេះមិនបានបង្វែរការទទួលខុសត្រូវរបស់អ្នកលើសុវត្ថិភាព និងការការពារនោះទេ។ ដូច្នេះ វាអាចទប់ស្កាត់មិនឱ្យជនបង្កប្រព្រឹត្តការរំលោភបំពានបន្តទៀត។កលវិធីនេះត្រូវអនុវត្តដោយហ្មត់ចត់ដើម្បីកុំឱ្យជនងាយរងគ្រោះប្រឈមនឹងហានិភ័យបន្ថែម ដោយអនុវត្តតាមគោលការណ៍ "មិនបង្កគ្រោះថ្នាក់"។

ការផ្តល់សារមិនត្រឹមតែត្រូវឱ្យស៊ីសង្វាក់គ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវធានាឱ្យបានទាំងក្នុងពេល និងក្រោយពេលវិបត្តិទៀតផង។ កុំអនុញ្ញាតឱ្យបុគ្គលិករបស់អ្នក "បោះបង់ការយកចិត្តទុកដាក់" ក្រោយចប់វិបត្តិឱ្យសោះ។ បទពិសោធន៍កន្លងមកបង្ហាញថា អំពើហិង្សា និងការរំលោភបំពានមិនបញ្ចប់នោះទេព្រោះស្ថានភាពអាចប្រែប្រួល (សូមមើលផ្នែកស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងជម្លោះ ក្នុងជំពូកទី ១៣)។ សូមមើលជំពូកទី ៩ សម្រាប់ព័ត៌មានបន្ថែមស្តីពីទំនាក់ទំនង។ សេវានគរបាលក្នុងពេលមានវិបត្តិអាចបង្កបញ្ហាប្រឈមបន្ថែមដល់យើង ហើយបញ្ហាមួយចំនួនគឺថ្មីសម្រាប់យើង។

- តើអ្នកនឹងរក្សាតុល្យភាពរវាងការធានាការអនុលោមតាមការណែនាំដំបូន្មានឬការរឹតត្បិតរបស់រដ្ឋាភិបាល និងការបន្តបង្កើតនិង/ឬរក្សាទំនុកចិត្តនិងភាពជឿជាក់របស់សហគមន៍មូលដ្ឋានដោយរបៀបណា?
- តើអ្នកនឹងរក្សាការទទួលខុសត្រូវរបស់បុគ្គលិករបស់អ្នកលើការបំពានសិទ្ធិអំណាចដែលរងការចោទប្រកាន់ដោយរបៀបណា?
- តើអ្នកបានធានាថា បុគ្គលិកទាំងអស់បានដឹងពីផលប៉ះពាល់យូរអង្វែងដែលអាចកើតឡើងដោយសារការបំពានសិទ្ធិអំណាច ឬទេ?
- តើអ្នកនឹងធានាថា សាធារណជននៅតែអាចប្រើប្រាស់

យន្តការបណ្ដឹង ជាពិសេសក្នុងពេលមានសេចក្ដីណែនាំលើការរដើរហើរ ឬទេ?

- តើអ្នកបានឱ្យបុគ្គលិកទាំងអស់បានដឹងពីក្ដីរំពឹងរបស់អ្នក និងស្ដង់ដារសេវាចាំបាច់ បូករួមនឹងការទទួលខុសត្រូវរបស់ពួកគេក្នុងការប្រកាន់ខ្ជាប់សិទ្ធិមនុស្ស និងតំណាងឱ្យអ្នក និងស្ថាប័ននគរបាលរបស់អ្នកប្រកបដោយវិជ្ជាជីវៈ និងសុចរិតភាព ឬទេ?

កុំរង់ចាំដល់ពេលវិបត្តិកើតឡើងទើបអ្នកពិចារណា និងគ្រោងការឆ្លើយតបរបស់អ្នក ព្រោះវាជាកត្តាកំណត់ជោគជ័យរបស់អ្នក។

## ជំងឺរាតត្បាត (កូវីដ ១៩)

ទិន្នន័យដែលប្រមូលដោយប្រព័ន្ធអង្គការសហប្រជាជាតិនៅត្រីមាសទីមួយនៃឆ្នាំ ២០២០ បានផ្ដល់ភស្ដុតាងជាក់លាក់ថា ជំងឺរាតត្បាតកូវីដ ១៩ បានបង្កផលវិបាកពហុវិស័យលើប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។ ផលវិបាករយៈពេលខ្លីពាក់ព័ន្ធនឹងការដាក់វិធានការចត្តាឡីស័កភ្លាមៗ និងដាកាតព្វកិច្ចលើប្រជាជនដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩និងកាត់បន្ថយផលប៉ះពាល់លើសេវាសុខាភិបាលសង្គ្រោះបន្ទាន់។ វិធានការទាំងនេះបានដាក់សម្ពាធយ៉ាងខ្លាំងលើទំនាក់ទំនងអន្តរបុគ្គលក្នុងគ្រួសារ ដែលវិវត្តទៅជាការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីកាន់តែខ្លាំង។

សម្រាប់គ្រួសារដែលមានសមាជិកជាជនពិការវិធានការចត្តាឡីស័កជាកាតព្វកិច្ចអាចនាំឱ្យមានភាពតានតឹងបន្ថែមទៀតដោយសារការបាត់បង់ជាបណ្ដោះអាសន្ននូវអ្នកថែទាំ ឬសេវាខាងក្រៅ ឬដោយសារតែពួកគេលែងអាចរ៉ាប់រងចំណាយលើការទំនុកបម្រុងបន្ថែមដោយសារផលប៉ះពាល់លើសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺកូវីដ១៩។ ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីយល់ថា ពួកគេត្រូវបានកាត់ផ្ដាច់ពីមនុស្ស និងធនធានដែលជួយដល់ពួកគេ និង/ឬទប់ស្កាត់អំពើហិង្សាមិនឱ្យកើតឡើង ឬមិនឱ្យកើតឡើងវិញ។ ឧ. នៅខែ មីនា ឆ្នាំ ២០២០ UN Women បានបង្ហាញការរាយការណ៍កាន់តែច្រើនពីអំពើហិង្សាក្នុងគ្រួសារ ចាប់តាំងពីការបញ្ជាឱ្យបិទខ្ទប់ក្នុងប្រទេសបារាំង (៣០%) អាហ្សង់ទីន (២៥%) ស៊ីប (៣០%) និងសិង្ហបុរី (៣៣%)[672]។ ប្រទេសនានា ដូចជា កាណាដា អាល្លឺម៉ង់ អេស្ប៉ាញ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក បានរាយការណ៍ពីការកើនឡើងនៃករណីអំពើហិង្សាក្នុងគ្រួសារនិងតម្រូវការទីជម្រកក្នុងគ្រាអាសន្ន[673] ។
ផ្ទុយទៅវិញ វិធានការបិទខ្ទប់ និងការរឹតត្បិតលើការដើរហើរអាចបង្កផលប៉ះពាល់លើសមត្ថភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងការរាយការណ៍ករណី ឬគេចវេសពីដៃគូដែលបំពានជាបណ្ដោះអាសន្ន។ ឧ. ខ្សែទូរស័ព្ទជំនួយសម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារនៅប្រទេសអ៊ីតាលីរាយការណ៍ថាបានទទួលការទូរស័ព្ទចូលតិចជាងមុនរហូតដល់ ៥៥% ក្នុងរយៈពេល ២ សប្ដាហ៍ដំបូងនៃខែ មីនា ព្រោះជនរងគ្រោះជាច្រើនយល់ថាមានការលំបាកក្នុងការស្នើសុំជំនួយនៅអំឡុងពេលបិទខ្ទប់[674]។ ក្នុងករណីមួយចំនួន ជនបំពានអាចគ្រប់គ្រង និងផ្ដាច់ខ្លួនជនរងគ្រោះកាន់តែងាយស្រួល។

សេណារីយ៉ូទាំងនេះផ្ដល់ទិដ្ឋភាពមិនត្រឹមត្រូវស្ដីពី ប្រេវ៉ាឡង់ជាក់ស្ដែងនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក្នុងពេលអនុវត្តវិធានការឆ្លើយតបទៅនឹងជំងឺ កូវីដ ១៩ ដែលអាចជះឥទ្ធិពលលើរបៀបដែលនគរបាល និងអ្នកផ្ដល់សេវាសំខាន់ៗផ្សេងទៀតគ្រប់គ្រងអាទិភាពក្នុងវិបត្តិ និងបែងចែកធនធាន។

## ចំណុចដូចគ្នារវាងវិបត្តិសុខភាពសាធារណៈ និងផលប៉ះពាល់ភ្លាមៗលើសេវានគរបាល

ផ្អែកលើភស្ដុតាងកាន់តែច្រើនពីបទពិសោធន៍ជំងឺកូវីដ ១៩ នាពេលបច្ចុប្បន្ន បូករួមនឹងព័ត៌មានពីមុន និងវិបត្តិមនុស្សធម៌ជាបន្តបន្ទាប់ដូចជាជម្លោះប្រដាប់អាវុធគ្រោះមហន្តរាយ ធម្មជាតិ និង/ឬវិបត្តិសុខភាពសាធារណៈ (ដូចជាការផ្ទុះឡើងនៃជំងឺអេបូឡា) ការកើនឡើងយ៉ាងគំហុកនៃបទល្មើស និងអំពើហិង្សាក៏នាំទៅរកការកើន

672. ជំងឺកូវីដ ១៩ និងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ ឯកសាររបស់ UN Women ខែ មេសា ឆ្នាំ ២០២០ https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/issue-brief-covid-19-and-ending-violence-against-women-and-girls-en.pdf?la=en&vs=5006
673. Ibid
674. Ibid

ឡើងនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ[675]។ ឧ. Peterman, A. et all (២០២០) លើកឡើងថា រយៈពេលពីរឆ្នាំក្រោយគ្រោះរញ្ជួយដីឆ្នាំ ២០១០ នៅប្រទេសហៃទី ស្ត្រីដែលរស់នៅក្នុងតំបន់ដែលរងការបំផ្លិចបំផ្លាញខ្លាំងដោយសារគ្រោះមហន្តរាយនេះ រាយការណ៍ពីករណីយ៉ាងច្រើននៃអំពើហិង្សាផ្លូវកាយនិងអំពើហិង្សាផ្លូវភេទលើដៃគូស្និទ្ធស្នាល ដោយដកស្រង់កត្តាសេដ្ឋកិច្ច និងកត្តាសង្គមមួយចំនួន[676]។

"ជំងឺឆ្លងរាតត្បាតកន្លងមក សុទ្ធតែនាំឱ្យមានការកើនឡើងនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ មានន័យថា គំរូស្រដៀងគ្នាអាចកើតឡើងនៅពេលបច្ចុប្បន្ន។ យោងតាមឯកសារស្រាវជ្រាវរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សកល (CGD) ការផ្ទុះឡើងនៃជំងឺអេបូឡា (នៅអាហ្វ្រិកខាងលិចនិងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) ជំងឺអាសន្នរោគ (នៅយេមែន) និងជំងឺហ្ស៊ីកា (នៅឈូងសមុទ្រការ៉ាអ៊ីប អាមេរិកកណ្តាល និងអាមេរិកខាងត្បូង) ពាក់ព័ន្ធនឹងការកើនឡើងនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្លូវភេទលើអ្នកឆ្លើយតបដំបូង និងបុគ្គលិកថែទាំសុខភាព ជាពិសេសគិលានុបដ្ឋាកយិកា"។

យុត្តិធម៌សម្រាប់ស្ត្រីក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩ (ឯកសារសង្ខេបការស្រាវជ្រាវរបស់UN Women ឆ្នាំ ២០២០)

នៅពេលតម្រូវឱ្យអនុវត្តវិធានការបិទខ្ទប់ជាកាតព្វកិច្ច និងការរឹតត្បិតខុសប្រក្រតីលើការដើរហើរជាសាធារណៈរួមទាំងនៅតាមព្រំដែនជាតិ និងព្រំដែនតំបន់ជាញឹកញាប់តួនាទីរបស់នគរបាលក្នុងកាលៈទេសៈទាំងនេះមិនត្រូវបានកំណត់ច្បាស់ និង/ឬបង្កើតឡើងក្នុងនីតិវិធីប្រតិបត្តិស្តង់ដារដែលមានស្រាប់នោះទេ។ ចំណុចនេះបង្កការលំបាកដល់ការបណ្តុះបណ្តាល និងការត្រៀមខ្លួនទុកជាមុន។មានន័យថាក្នុងពេលមានវិបត្តិស្ថាប័ននគរបាលមួយចំនួនប្រហែលជាមិនបានត្រៀមខ្លួនឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការកើនឡើងនៃហានិភ័យអំពើហិង្សាលើស្ត្រីនិងក្មេងស្រីឡើយ។ក្រៅពីនេះវាបានបង្កផលប៉ះពាល់លើសមត្ថភាពរបស់ស្ថាប័នទាំងនេះក្នុងការធានាថាជំនួយ និងទម្រង់នៃការចូលរួមមិនមានការរើសអើងដោយសារកត្តាប្រទាក់ក្រឡាគ្នា ដូចជា ជាតិពន្ធុ និងពិការភាព។ គួបផ្សំនឹងនិន្នាការបទល្មើសដែលលេចឡើងផ្សេងទៀត នគរបាលនិងតួអង្គក្នុងវិស័យយុត្តិធម៌អាចទទួលរងបន្ទុកធ្ងន់ធ្ងរ នៅពេលឆ្លើយតបនឹងចលាចលសាធារណៈ និងបទល្មើសផ្សេងទៀតជាពិសេសបទល្មើសដែលបណ្តាលមកពីផលវិបាកនៃវិបត្តិលើសេដ្ឋកិច្ច និងសង្គម។ ការពង្រីកសេវាឆ្លើយតបអាចកាត់បន្ថយកម្រិតនៃការផ្តល់ការការពារ និងសុវត្ថិភាពដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងទម្រង់ផ្សេងទៀតនៃបទល្មើស និងអំពើហិង្សា។ ចំណុចនេះកាន់តែធ្វើឱ្យជនបង្កយល់ថា ពួកគេអាចរួចខ្លួនពីការដាក់ទោស[677]។

ក្នុងករណីវិបត្តិសុខភាពសាធារណៈដែលបណ្តាលមកពីការផ្ទុះឡើងនៃជំងឺឆ្លង នៅពេលនគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ពួកគេត្រូវពិចារណាពីអនុសាសននៃការរក្សាគម្លាតសង្គម។ ចំណុចនេះនឹងបង្កការលំបាកដល់នគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលបានរាយការណ៍ (សម្រាប់ព័ត៌មានលម្អិតសូមមើលការណែនាំគ្នាទៅវិញទៅមក)។ ឧ.នគរបាលឆ្លើយតបនឹងមានភាពប្រុងប្រយ័ត្ននៅពេលចូលក្នុងផ្ទះ ដែលមានការរាយការណ៍ករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាល ព្រោះបារម្ភពីការឆ្លងជំងឺ ឬវីរុស។

មន្ត្រីឆ្លើយតបអាចគេចវេសពីពិធីសារនានា ដូចជាការវាយតម្លៃហានិភ័យជាកាតព្វកិច្ច (លើជនរងគ្រោះដែលរងការចោទប្រកាន់) ឬមិនឆ្លើយតបតែម្តងដើម្បីកាត់បន្ថយទំនាក់ទំនងអន្តរបុគ្គល។ ចំណុចនេះអាចកើតឡើងក្នុង

675. See Weitzman, A., and J.A. Behrman (2016): 'Disaster, Disruption to Family Life and Intimate Partner Violence: The Case of the 2010 Earthquake in Haiti'. Sociological Science, 3: 167-189 in Pandemics and Violence Against Women and Children (2020). Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

676. ជំងឺកូវីដ ១៩ និងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ៖ ឯកសាររបស់ UN Women ខែ មេសា ឆ្នាំ ២០២០ https://www.unwomen .org/-/media/headquarters/attachments/sections/library/publications/2020/issue-brief-covid-19-and-ending-violence-against-women-and-girls-en.pdf?la=en&vs=5006

ករណីដែលស្ថាប័ននគរបាលមិនអាចផ្តល់បរិក្ខារការពារបុគ្គលសមស្របដល់មន្ត្រីជួរមុខ។

យោងតាម UNDP (២០១៥) មន្ត្រីនគរបាលមិនសូវកំណត់ករណីអំពើហិង្សាលើដៃគូស្និទ្ធស្នាលជាអាទិភាពខ្ពស់សម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនក្នុងពេលផ្ទុះជំងឺអេបូឡានៅអាហ្វ្រិកខាងលិចនោះទេព្រោះមន្ត្រីនគរបាលស្ទាក់ស្ទើរមិនហ៊ានចូលក្នុងផ្ទះដើម្បីធ្វើការស៊ើបអង្កេតល្អិតល្អន់ ដោយសារខ្លាចឆ្លងជំងឺនេះ នឹងចម្លងបន្តទៅសមាជិកគ្រួសាររបស់ខ្លួន[678]។

ពន្ធនាគារ មណ្ឌលកែប្រែ និងមន្ទីរឃុំឃាំងក្លាយជាតំបន់ដែលអាដ្ឋាធរព្រួយបារម្ភខ្លាំង ដោយសារតែស្ថានភាព



ថតទទួលបានពី UNMEER/Samuel Shilajiru (ប្រទេសលីបេរីយ៉ា)

បញ្ជៀតគ្នា និងសុខភាពទ្រុឌទ្រោមរបស់អ្នកទោសក្នុងប្រទេសជាច្រើន។ចំណុចនេះអាចនាំទៅរកការកាត់បន្ថយការផ្តន្ទាទោស ដើម្បីកុំឱ្យចំនួនអ្នកទោសកើនឡើង។

ក្នុងករណីមួយចំនួន ជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រីអាចត្រូវបានដោះលែងក្នុងផ្នែកមួយនៃវិធានការគ្រប់គ្រងវិបត្តិក្នុងគ្រោះអាសន្ន ដែលចុងក្រោយធ្វើឱ្យស្ត្រី និងក្មេងស្រីកាន់តែងាយប្រឈមនឹងហានិភ័យនៃអំពើហិង្សា។ ក្នុងករណីទាំងនេះ UNODC ទទូចឱ្យរដ្ឋទាំងឡាយវាយតម្លៃ និងលើកឡើងពីហានិភ័យសុវត្ថិភាពរបស់ជនរងគ្រោះក្នុងការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការដោះលែងនិងវិធានការមិនមែនការឃុំខ្លួនផ្សេងទៀតដូចជាការអនុញ្ញាតឱ្យបង់ប្រាក់ធានានៅក្រៅឃុំ ការដោះលែងដោយមានលក្ខខណ្ឌ ការដោះលែងមុនពេលកំណត់ ឬការ អនុវត្តការព្យួរទោសជាពិសេសនៅពេលប្រឈមជាមួយនឹងជនល្មើសដដែលៗ និងគ្រោះថ្នាក់ ក៏ដូចជាធានាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មានស្តីពីការដោះលែងជនបង្កពីការឃុំឃាំង ឬពន្ធនាគារ[679]។

ក្នុងន័យនេះ មន្ត្រីត្រួតពិនិត្យការដោះលែងមុនពេលកំណត់ប្រហែលជាត្រូវផ្តោតអាទិភាពលើការរក្សាគម្លាតសង្គម និងធ្វើទំនាក់ទំនងជាសំឡេង ឬវីដេអូ។ ដូច្នេះ ពួកគេមិនសូវអាចធ្វើការវាយតម្លៃពេញលេញលើឱកាសនៃការប្រព្រឹត្តខុសជាថ្មីរួមទាំងឱកាសដែលអាចនាំឱ្យជនរងគ្រោះប្រឈមនឹងហានិភ័យខ្លាំងជាងមុន[680]។

លើសពីនេះ ការបិទសាលារៀនដែលអាចជាប្រភពនៃការកំណត់មុខសញ្ញា និងការបញ្ជូនករណីដែលអាចជាការរំលោភបំពាន និងការធ្វើបាបកុមារ នឹងធ្វើឱ្យនគរបាលមានលទ្ធភាពតិចតួចក្នុងការពឹងផ្អែកលើបណ្តាញអប់រំ និងបណ្តាញសហគមន៍ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។នៅអាហ្វ្រិកខាងលិចការបិទសាលារៀនដោយសារការផ្ទុះជំងឺអេបូឡា ធ្វើឱ្យក្មេងស្រីងាយប្រឈមនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សា និងនាំទៅរក "ការកើនឡើងយ៉ាងគំហុក" នៃការមានផ្ទៃពោះក្នុងវ័យជំទង់និងអាពាហ៍ពិពាហ៍វ័យក្មេងក្នុងតំបន់រងផលប៉ះពាល់មួយចំនួន ព្រោះក្មេងស្រីកាន់តែច្រើនបានបោះបង់ការសិក្សា[681]។

ដូចគ្នានេះដែរផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដោយសារវិបត្តិសុខភាព ឬវិបត្តិមនុស្សធម៌ នឹងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់អង្គការស្ត្រីតាមមូលដ្ឋាន ដែលជាញឹកញាប់អង្គការទាំងនោះជាដៃគូយុទ្ធសាស្ត្ររបស់នគរបាលក្នុងការ

677. ទិដ្ឋភាពយេនឌ័រក្នុងវិបត្តិជំងឺរាតត្បាតកូវីដ ១៩ (ក្រុមធនាគារពិភពលោក ២០២០) http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic
678. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O´Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការផ្តល់សេវាដល់ជនរងគ្រោះក្នុងរយៈពេលវែង។ អង្គការស្ត្រីតាមមូលដ្ឋានដើរតួនាទីសំខាន់ក្នុងការកំណត់រកការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបទដ្ឋានយេនឌ័រដែលអាចជំរុញឱ្យមានទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដូចជា ការកើនឡើងនៃអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ និង/ឬអាពាហ៍ពិពាហ៍កុមារ និងការកើនឡើងនៃអត្រាអំពើហិង្សាលើដៃគូស្និទ្ធស្នាល រួមទាំងអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ក្នុងមជ្ឈដ្ឋានមានវិបត្តិ[682]។

ក្នុងករណីនៃអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ ភស្តុតាងពីបរិបទគ្រោះអាសន្ន និងមនុស្សធម៌ គូសបញ្ជាក់ថា នៅពេលបាត់បង់បណ្តាញសង្គម គ្រួសារ និងសហគមន៍ងាយនឹងគ្រប់គ្រងផ្លូវភេទរបស់ស្ត្រី និងការពារ "កិត្តិយស" របស់ពួកគេ។ ដូច្នេះ ជាញឹកញាប់ អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាការការពារក្មេងស្រី និងគ្រួសាររបស់ពួកគេពីការមាក់ងាយក្នុងសង្គមដោយសារការរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ឬការប្រទូស្តកេរខ្មាស[683]។

"នេះជាលើកដំបូងដែល IDMC ធ្វើការប៉ាន់ស្មានពីចំនួនប្រជាជនដែលនៅតែបាត់បង់ទីលំនៅក្នុងប្រទេសដោយសារគ្រោះមហន្តរាយក្នុង ៩៥ ប្រទេស (ចំនួន ៥,១ លាននាក់ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩")។

មជ្ឈមណ្ឌលត្រួតពិនិត្យការបាត់បង់ទីលំនៅក្នុងប្រទេស (IDMC ២០២០)

ក្នុងវិបត្តិមនុស្សធម៌ដែលបណ្តាលមកពីជម្លោះប្រដាប់អាវុធ ជំរំជនភៀសខ្លួន/ជនបាត់បង់ទីលំនៅ និងតំបន់ជំនួយមនុស្សធម៌ច្រើនតែជាតំបន់ដែលពិបាកផ្តល់សេវានគរបាល ជាពិសេសនៅពេលអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសដែលទាមទារភាពជាដៃគូជាមួយសហគមន៍និងការកសាងទំនុកចិត្ត។ ក្នុងមជ្ឈដ្ឋានទាំងនេះ ភស្តុតាងបង្ហាញថា អត្រាអំពើហិង្សាលើស្ត្រី និងក្មេងស្រីកើនឡើង នៅពេលសមាជិកគ្រួសារស្នាក់នៅជិតគ្នាកាន់តែយូរ ក្រោមស្ថានភាពនៃការគំរាមកំហែង[684]។

គួបផ្សំនឹងវិបត្តិសុខភាពសាធារណៈដែលបណ្តាលមកពីការផ្ទុះជំងឺឆ្លង និងការលំបាកផ្នែកសេដ្ឋកិច្ចដោយសារបញ្ហានេះ ហានិភ័យនៃការប្រឈមនឹងអំពើហិង្សាដោយស្ត្រីនិងក្មេងស្រីដែលកំពុងរស់នៅក្នុងស្ថានភាពមិនទៀងទាត់ គួរតែជាចំណុចអាទិភាពសម្រាប់នគរបាល និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត។ ចំណុចនេះទាមទារឱ្យនគរបាល (និងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត) ធ្វើការកែសម្រួលភ្លាមៗលើយុទ្ធសាស្ត្រអន្តរាគមន៍ដើម្បីធានាការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពដោយអនុលោមតាមពិធីសារនិងគ្មានការរើសអើងទន្ទឹមនឹងការផ្តល់វិធានការសុវត្ថិភាពបុគ្គលដល់មន្ត្រីឆ្លើយតប។

**ការវិភាគយេនឌ័រជាការពិនិត្យល្អិតល្អន់ថាតើភាពខុសគ្នានៃតួនាទីយេនឌ័រ សកម្មភាពតម្រូវការ ឱកាស និងសិទ្ធិ/សិទ្ធិទទួលបាន ជះឥទ្ធិពលដូចម្តេចលើបុរស ស្ត្រី ក្មេងស្រី និងក្មេងប្រុសក្នុងស្ថានភាព ឬបរិបទមួយចំនួន។**

ការកែសម្រួលយុទ្ធសាស្ត្រអន្តរាគមន៍ក៏សំដៅលើការកែសម្រួលវិធានការប្រកបដោយគណនេយ្យភាពនិងតម្លាភាពផងដែរ។ ការវិភាគយេនឌ័រក្នុងការបង្កើត និងរៀបចំយុទ្ធសាស្ត្រអន្តរាគមន៍ថ្មីៗមានសារៈសំខាន់បំផុតសម្រាប់ការពិចារណាពីផលប៉ះពាល់ខុសគ្នានៃយុទ្ធសាស្ត្រទាំងនោះ

679. ការឆ្លើយតបទៅនឹងជំងឺកូវីដ ១៩ ៖ ឯកសារសង្ខេបតាមប្រធានបទរបស់ UNODC ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រីនិងក្មេងស្រី (UNODC២០២០) https://www.unodc.org/documents/Advocacy-Section/GBVAW_and_UNODC_in_COVID19_final_7Apr2020.pdf
680. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O´Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N.,Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children
681. ផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី (២០២០) Fraser, E. (2020) for UKAid, WAG Helpdesk Research Report, at: https://www.dmeforpeace.org/peacexchange/wp-content/uploads/2020/04/vawg-helpdesk-284-covid-19-and-vawg.pdf
682. ក្នុងប្រយុទ្ធជួរមុខជាមួយនឹងជំងឺកូវីដ ១៩ អង្គការស្ត្រីផ្តល់សេវាសំខាន់ៗក្នុងនាមជាអ្នកឆ្លើយតបដំបូង នៅពេលដែលករណីអំពើហិង្សាលើស្ត្រីកើនឡើងខ្លាំង (UN Women ២០២០) https://www.unwomen.org/en/news/stories/2020/5/feature-womensorganizations-provide-vital-services-as-violence-against-women-spikes
683. ជំងឺកូវីដ ១៩ និងកុមារអាពាហ៍ពិពាហ៍វ័យក្មេងដោយការបង្ខិតបង្ខំ ៖ របៀបវារៈសកម្មភាព (ក្មេងស្រីមិនមែនជាកូនក្រមុំភាពជាដៃគូសកលដើម្បីបញ្ឈប់អាពាហ៍ពិពាហ៍កុមារ២០២០), https://www.thecompassforsbc.org/sbcc-tools/covid-19-and-child-early-and-forced-marriage-agenda-action
684. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O´Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

លើស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី។ ទន្ទឹមនឹងនេះ គួរកែសម្រួលយន្តការរាយការណ៍ពីការប្រព្រឹត្តមិនសមរម្យ និងការប្រើប្រាស់កម្លាំងមិនសមស្របដោយនគរបាល ដើម្បីធានាថា យន្តការទាំងនោះនៅតែអាចប្រើប្រាស់បាននិងផ្តល់ជូនប្រជាជនដោយគ្មានការរើសអើងនៅពេលអនុវត្តវិធានការរដ្ឋាភិបាលក្នុងអំឡុងវិបត្តិសុខភាពសាធារណៈ និង/ឬវិបត្តិមនុស្សធម៌។

បទពិសោធន៍នៃជំងឺកូវីដ ១៩ បានបង្ហាញច្បាស់ពីភាពងាយរងគ្រោះទូទៅរបស់មនុស្សគ្រប់រូប ដោយមិនគិតពីកន្លែងរស់នៅ ក្នុងវិបត្តិសុខភាពសាធារណៈជាសកល។ Peterman, A. et al (២០២០) លើកឡើងថា អ្នកជំនាញព្យាករណ៍ថា ជំងឺចម្លងពីសត្វ[685] និងការផ្ទុះជំងឺទាំងនេះនឹងបន្តលេចឡើងដោយសារកំណើនប្រជាជន និងភាពពាក់ព័ន្ធគ្នានៃប្រជាជនទូទាំងសកលលោក ក៏ដូចជាការប្រើប្រាស់ និងការបំផ្លាញបរិស្ថាន[686]។ Peterman, A. et all បន្ថែមទៀតថា ផ្អែកលើបទពិសោធន៍កន្លងមក ការផ្ទុះឡើងនៃជំងឺឆ្លង ដូចជា ជំងឺកូវីដ ១៩ ជំងឺអេបូឡា ឬជំងឺហ្ស៊ីកា បានធ្វើឱ្យមានការមាក់ងាយ ការស្អប់ជនបរទេស និងការរើសអើងកាន់តែខ្លាំង។ កត្តាទាំងនេះនឹងកាត់បន្ថយ និង/ឬរាំងស្ទះយ៉ាងខ្លាំងដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ និងធ្វើអន្តរាគមន៍លើអំពើហិង្សាលើស្ត្រី និងក្មេងស្រី (សម្រាប់ការណែនាំ សូមមើលជំពូកទី ៣ ៖ ការទប់ស្កាត់)។

ព័ត៌មានលក្ខណៈបុគ្គលបង្ហាញថា ស្ត្រីមិនអាចទទួលបានការគាំទ្រដោយសុវត្ថិភាពឡើយ (ឧ. ទូរស័ព្ទទៅនគរបាល ឬទទួលបានការគាំទ្រឯកទេស) ដោយសារការផ្តាច់ខ្លួនជាមួយជនបង្កចេញពីការផ្ទុះជំងឺឆ្លង។តាមពិត Peteman, A. et all រាយការណ៍ថា ជាទូទៅ ស្ត្រីមិនសូវស្វែងរកសេវាសុខភាពមាតា និងទារកឡើយ ដោយសារភ័យខ្លាចជំងឺឆ្លង និងលទ្ធភាពនៃការចម្លងវីរុសទៅក្រុមគ្រួសារ[687]។

ដូចគ្នានេះដែរ ស្ត្រីអាចមិនរាយការណ៍ពីដៃគូស្និទ្ធស្នាលដែលប្រព្រឹត្តបំពានដោយសារភ័យខ្លាចថាការឃុំខ្លួននឹងបង្កើនហានិភ័យនៃការចម្លងជំងឺទៅដៃគូរបស់ខ្លួនរូបនាងផ្ទាល់ និងកូនៗ។

685. ស្ទើរតែ ៧៥% នៃជំងឺដែលលេចឡើង រួមទាំងជំងឺដែលបណ្តាលឱ្យមានជំងឺរាតត្បាតភាគច្រើន មានប្រភពពីសត្វ និងត្រូវបានចម្លងទៅមនុស្ស (ហៅថា ជំងឺចម្លងពីសត្វ)។ សូមមើល Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L. et al. (2008). Global trends in emerging infectious diseases. Nature 451: 990-94.
686. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children
687. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

## ភាពពាក់ព័ន្ធនៃសៀវភៅណែនាំនគរបាល និងកញ្ចប់សេវាសំខាន់ៗរបស់ UN Women

សៀវភៅណែនាំនេះលើកទឹកចិត្តឱ្យស្ថាប័ននគរបាល ចាប់ផ្តើមធ្វើការផ្លាស់ប្តូរឆ្ពោះទៅរកអ្នកផ្តល់សេវាសំខាន់ៗដែលឆ្លើយតបនឹងយេនឌ័រ តាមរយៈការបង្កើតការយល់ដឹងផ្អែកតាមព័ត៌មានត្រឹមត្រូវ[688] អំពីថាតើធម្មជាតិនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឫសគល់ និងផលវិបាកនៃអំពើហិង្សានេះបង្កផលប៉ះពាល់ខុសគ្នា និងមិនសមាមាត្រគ្នាដូចម្តេចលើស្ត្រី និងក្មេងស្រី ក្នុងស្ថាប័ននគរបាល។

សូមមើលជំពូកទី ១០ (ការកសាងស្ថាប័នដើម្បីជានាការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពនិងគណនេយ្យភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី) និងជំពូកទី ១១ (បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ) សម្រាប់ការណែនាំស្តីពីការបង្កើតការយល់ដឹងរួម។

ការបង្កើតការយល់ដឹងរួមស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងស្ថាប័ននគរបាល នឹងអាចឱ្យស្ថាប័ននេះឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងអំពើហិង្សានេះ និងបទល្មើសនានាសូម្បីតែក្នុងពេលមានវិបត្តិ។ផ្ទុយទៅវិញ កង្វះការយល់ដឹងជារួមនឹងរឹតត្បិតការយល់ដឹងរបស់មន្ត្រីឆ្លើយតបអំពីទំហំនៃបញ្ហាក្នុងពេលមានវិបត្តិ និងធ្វើឱ្យពួកគេមិនយល់ថាការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាការសង្គ្រោះអាយុជីវិត។ ក្នុងវិបត្តិមនុស្សធម៌ និងវិបត្តិសុខភាពសាធារណៈបញ្ហានេះបង្កផលប៉ះពាល់អវិជ្ជមានកាន់តែខ្លាំង។

ក្នុងករណីនៃវិធានការផ្តាច់ចេញពីសង្គម និងវិធានការចត្តាឡីស័កដែលដាក់ចេញដោយរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងជំងឺរាតត្បាត/ជំងឺឆ្លង ដូចជា ជំងឺកូវីដ ១៩ ឬជំងឺអេបូឡា ឧបករណ៍សម្រាប់អ្នកអនុវត្តន៍ ដូចជា វដ្តនៃអំណាច និងការគ្រប់គ្រង[689] អាចយកមកកែសម្រួលសម្រាប់ជួយដល់នគរបាល និងដៃគូផ្តល់សេវាសំខាន់ៗក្នុងការវិភាគឱណាមិកថ្មីៗនៃអំពើហិង្សាដែលបង្កផលប៉ះពាល់លើស្ត្រី និងក្មេងស្រី។ វដ្តនៃអំណាច និងការគ្រប់គ្រង អាចឱ្យអ្នកជំនាញផ្តល់សេវាសំខាន់ៗ រួមទាំង



រូបថតទទួលបានពី UN Women/Louie Pacardo (ប្រទេសហ្វីលីពីន)

នគរបាល យល់ពីកលវិធីដែលជនបង្កប្រើប្រាស់ដើម្បីទទួលបានអំណាច និងការគ្រប់គ្រងលើជនរងគ្រោះ។

ឧបករណ៍នេះអាចកែសម្រួលបាន និងត្រូវបានផ្លាស់ប្តូរទៅជា "វដ្ត" ជាច្រើនដើម្បីស្វែងយល់កាន់តែច្បាស់ពីស្ថានភាពផ្សេងៗនៃភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រី[690]។ ឧ. ឧបករណ៍នេះត្រូវបានកែសម្រួល ដើម្បីស្វែងយល់ពីរបៀបដែលជនបង្កប្រព្រឹត្តអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ទេសន្តរប្រវេសន៍ (សូមមើលប្រអប់ ៥) និងជនមានពិការភាព និងអ្នកថែទាំរបស់ពួកគេ[691]។

688. សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ "ផ្អែកតាមព័ត៌មានត្រឹមត្រូវ" មានន័យថា វាពាក់ព័ន្ធនឹងបរិបទ និងមានការផ្តល់ធាតុចូលជាប្រចាំ (ទិន្នន័យបែបបរិមាណ និងទិន្នន័យបែបគុណភាព) ពីនគរបាលជំនាញ និងអ្នកពាក់ព័ន្ធខាងក្រៅ ដូចជា អ្នកផ្តល់សេវាសំខាន់ៗ និង/ឬអង្គការសង្គមស៊ីវិល។
689. បង្កើតឡើងដោយកម្មវិធីអន្តរាគមន៍ការរំលោភបំពានក្នុងគ្រួសារនៅ Duluth, MN (U.S.) ប៉ុន្តែបច្ចុប្បន្នត្រូវបានប្រើប្រាស់ដោយអ្នកផ្តល់សេវាសំខាន់ៗជុំវិញពិភពលោក។សម្រាប់ព័ត៌មានបន្ថែម សូមមើលជំពូកទី ១១ ៖ "បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការអនុវត្តសេវានគរបាលដែលឆ្លើយតបនឹងយេនឌ័រ" ក្នុងសៀវភៅណែនាំនេះ។
690. សូមមើល "វដ្ត" ដែលត្រូវបានដកស្រង់ចេញពីគំរូវដ្តនៃអំណាច និងការគ្រប់គ្រង។ មជ្ឈមណ្ឌលជាតិទទួលបន្ទុកកិច្ចការអំពើហិង្សាក្នុងគ្រួសារនិងអំពើហិង្សាផ្លូវភេទ http://209.198.129.131/publications_wheel.html
691. សូមមើល "វដ្តនៃអំណាច និងការគ្រប់គ្រង ៖ ជនមានពិការភាព និងអ្នកថែទាំរបស់ពួកគេ" ដែលដកស្រង់ចេញពី "គំរូវដ្តនៃអំណាច និងការគ្រប់គ្រង"។ មជ្ឈមណ្ឌលជាតិទទួលបន្ទុកកិច្ចការអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទhttp://www.ncdsv.org/images/DisabledCaregiverPCwheel.pdf

**រូបទី ៣a**

**វដ្តនៃអំណាច និងការគ្រប់គ្រង (ទម្រង់ដើម)**




ប្រភព ៖ "វដ្ត" ដែលដកស្រង់ចេញពីគំរូវដ្តនៃអំណាច និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិទទួលបន្ទុកកិច្ចការអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ

**រូបទី ៣៦**

**វង្គនៃអំណាច និងការគ្រប់គ្រងពាក់ព័ន្ធនឹងជនទេសន្តរប្រវេសន៍ (កែសម្រួល)**




ប្រភព ៖ "វង្គ" ដែលដកស្រង់ចេញពីគំរូវង្គនៃអំណាច និងការគ្រប់គ្រងមជ្ឈមណ្ឌលជាតិទទួលបន្ទុកកិច្ចការអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ

តាមរយៈការខិតខំកែសម្រួលឧបករណ៍ពាក់ព័ន្ធ ដូចជា វដ្តនៃអំណាច និងការគ្រប់គ្រង ទៅតាមបរិបទក្នុងមូលដ្ឋាន ដែលកំពុងប្រឈមនឹងវិបត្តិមនុស្សធម៌/វិបត្តិសុខភាព សាធារណៈ នគរបាលនឹងអាចកំណត់គំរូនៃអំពើហិង្សា លើស្ត្រី និងក្មេងស្រីដែលពាក់ព័ន្ធនឹងកត្តាបំផុស ដូចជា ការកើនឡើងនៃអសន្តិសុខសេដ្ឋកិច្ច និកម្មភាពភ្លាមៗ ឬ យូរអង្វែងក្នុងចំណោមស្ត្រី និងបុរស និងយុទ្ធសាស្ត្រ ដោះស្រាយអវិជ្ជមានដែលបណ្តាលមកពីវិធានការ ចត្តាឡីស័ក (ឧទាហរណ៍) បានប្រសើរជាងមុន។

ក្រោយការកែសម្រួលការយល់ដឹងរួមអំពីអំពើហិង្សាលើ ស្ត្រី និងក្មេងស្រី ទៅតាមបរិបទថ្មីដែលកើតចេញពីវិបត្តិ ស្ថាប័ននគរបាលនឹងអាចអនុវត្តការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពនិងសមស្របទៅនឹងហានិភ័យនិងតម្រូវការ បានប្រសើរជាងមុន។ ប្រអប់ ៦ (ខាងក្រោម) ផ្តល់ ឧទាហរណ៍មួយចំនួនស្តីពីភាពប្រតិសកម្មរបស់នគរបាល ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនៅ អំឡុងពេលនៃការតម្រូវឱ្យធ្វើចត្តាឡីស័កក្នុងវិបត្តិជំងឺ កូវីដ ១៩។

**ប្រអប់ ២**

**សកម្មភាពបែបប្រតិសកម្មរបស់នគរបាលក្នុងអំឡុងពេល "បិទខ្ទប់" ៖ អឺរ៉ុប**

សេវានគរបាល និងសន្តិសុខជាតិអៀកឡង់ ឬ An Garda Siochana បានបង្កើនកិច្ចខិតខំប្រឹងប្រែង តាមរយៈ Operation Faoiseamh ដើម្បីបញ្ជាក់ឡើងវិញដល់ជនរងគ្រោះថា "ឧប្បត្តិហេតុនៃការរំលោភបំពាន ក្នុងគ្រួសាររួមទាំងការត្រួតត្រាដោយបង្ខំនៅតែទទួលបានអាទិភាពខ្ពស់បំផុតក្នុងសេវាឆ្លើយតប"។Operation Faoiseamh (ការឆ្លើយតបទៅនឹងជំងឺកូវីដ ១៩ ចូលរួមដោយសហគមន៍) ត្រូវបានអនុវត្តនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០២០។ ប្រតិបត្តិការនេះមានគោលបំណងទប់ស្កាត់ការបាត់បង់ជីវិត និងធានាថា ជនរងគ្រោះ ដោយសារការរំលោភបំពានក្នុងគ្រួសារទទួលបានការការពារ និងការគាំទ្រក្នុងពេលតម្រូវឱ្យធ្វើចត្តាឡីស័ក។ អង្គការគាំពារជនរងគ្រោះក្នុងមូលដ្ឋាន និងអង្គការសប្បុរសធម៌បានស្វាគមន៍គំនិតផ្តួចផ្តើមនេះ ជាពិសេសការ បន្តផ្តល់សេវាដោយការិយាល័យសេវាជនរងគ្រោះ (នគរបាល) នៅទូទាំងប្រទេសដើម្បីសម្រួលដល់ទំនាក់ ទំនងតាមទូរស័ព្ទជាមួយជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារពីមុន សំដៅបញ្ជាក់ច្បាស់ពីបញ្ហាកង្វល់ ចំពោះមុខ។

នៅបារាំង ក្រុមហ៊ុន Lille Gendarmerie បានបើកករណីអំពើហិង្សាក្នុងគ្រួសារទាំងអស់ឡើងវិញកាលពី ប៉ុន្មានខែមុន (រួមទាំងករណីដែលត្រូវបានដោះស្រាយដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ)។ អង្គភាពនគរបាល យកការទូរស័ព្ទទៅប្រជាជនជាមធ្យោបាយដើម្បីចូលដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដែលយល់ថា ពួកគេមិនអាចអំពាវនាវរកជំនួយបាន។ ក្នុងករណីមានមន្ទិលសង្ស័យ ដូចជា ការស្ទាក់ស្ទើរមិន ហ៊ានទូរស័ព្ទ ឬមិនសូវឆ្លើយសំណួរ នគរបាលមួយក្រុមនឹងចុះទៅផ្ទះរបស់ជនរងគ្រោះ។ ប្រសិនបើមន្ត្រី ឆ្លើយតបរកឃើញ ភស្តុតាងនៃអំពើហិង្សាផ្លូវកាយក្នុងពេលចុះផ្ទាល់នោះ ពួកគេនឹងដោះស្រាយករណីនេះ យ៉ាងឆាប់រហ័សបំផុត។

នៅប៊ែលហ្សិក នគរបាលមូលដ្ឋានមួយចំនួន មានភាពសកម្មក្នុងការទាក់ទងទៅជនរងគ្រោះដែលបាន ដាក់បណ្តឹងនៅប៉ុស្តិ៍នគរបាលក្នុងរយៈពេល ៣ ខែកន្លងមកពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារតាម រយៈសេវាជួយដល់ជនរងគ្រោះដែលផ្តល់ដោយនគរបាលផ្ទាល់។ ចំណុចនេះអាចឱ្យនគរបាលក្នុងមូលដ្ឋាន ពិនិត្យតាមដានការវិវត្តនៃស្ថានភាពរបស់ជនរងគ្រោះ ក្នុងពេលធ្វើចត្តាឡីស័ក។ ទន្ទឹមនឹងនេះ នគរបាលបាន ទាក់ទងទៅសមាគមផ្សេងៗដែលធ្វើការងារពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារដើម្បីផ្តល់ព័ត៌មានអំពីផែនការ បន្តប្រតិបត្តិការរបស់ពួកគេ។

## ការវិភាគទិន្នន័យ និងផលប៉ះពាល់ដើម្បីជានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងសមស្របទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី

"ការសំខាន់ត្រូវកត់សម្គាល់ថាកុមារដែលមើលឃើញការរំលោភបំពានក៏ជាជនរងគ្រោះដោយសារអំពើហិង្សាផងដែរ"។

ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩៖ឯកសារសង្ខេបតាមប្រធានបទរបស់UNODC ស្តីពីអំពើហិង្សាផ្អែកលើ យេនឌ័រប្រឆាំងនឹងស្ត្រី និងក្មេងស្រី (UNODC ២០២០)

នគរបាលនិងអ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀតគួររៀបចំ និងកែសម្រួលយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយកត់សម្គាល់ពីផលប៉ះពាល់អវិជ្ជមាននៃវិធានការចត្តាឡីស័ក និងការផ្តាច់ខ្លួនចេញពីសង្គម ដូចជា ដីកាបញ្ជាឱ្យស្នាក់នៅផ្ទះ ឬ "ការបិទខ្ទប់" ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមងាយរងគ្រោះបំផុត ដូចជា កុមារ និងជនមានពិការភាព។

ការផ្តោតការយកចិត្តទុកដាក់លើក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះបំផុត គួរកំណត់ថា ស្ត្រី និងក្មេងស្រីមិនមែនជាក្រុមតែមួយ ហើយពួកគេមិនគួរត្រូវបានចាត់បញ្ចូលក្រុមជាមួយគ្នានៅពេលទប់ស្កាត់ ឬដោះស្រាយអំពើហិង្សាឡើយ ជាពិសេសស្ត្រី និងក្មេងស្រីមានពិការភាព ឬសមាជិកសហគមន៍ LGBTQI។ ទាំងនេះជាចំណុចសំខាន់ៗដែលនគរបាលត្រូវចងចាំនៅពេលធ្វើទំនាក់ទំនងផ្ទាល់ជាមួយស្ត្រីនិងក្មេងស្រីមកពីសហគមន៍ភាគតិច ដូចជា ស្ត្រី និងក្មេងស្រីមានពិការភាព ឬសហគមន៍ LGBTQI និងជាមួយអង្គការតស៊ូមតិដែលតំណាងឱ្យពួកគេ។

**ការចូលរួមប្រកបដោយអត្ថន័យទាមទារឱ្យបុគ្គលមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលផ្ទាល់លើពួកគេ រួមទាំងការសម្រេចចិត្តក្នុងការបង្កើត ការអនុវត្ត និងការពិនិត្យតាមដានអន្តរាគមន៍ (WHO ២០១៩)។**

ដូច្នេះ យុទ្ធសាស្ត្រទាំងនេះត្រូវធានាថា ចំណុចស្នូលនៃអន្តរាគមន៍ទាំងឡាយ អនុវត្តអភិក្រមផ្អែកតាមព័ត៌មានត្រឹមត្រូវ ឆ្លើយតបនឹងយេនឌ័រ ប្រកបដោយបរិយាបន្ន និងមានភាពប្រទាក់ក្រឡាគ្នា។ ការចូលរួមប្រកបដោយអត្ថន័យពីមេធាវីដែលតំណាងឱ្យសិទ្ធិនិងតម្រូវការរបស់ស្ត្រី និងក្មេងស្រីមកពីសាវតារចម្រុះ និងសមត្ថភាពរាងកាយ/សមត្ថភាពផ្នែកបញ្ញាស្មារតី ក្នុងការផ្តល់មូលដ្ឋានព័ត៌មានដល់របៀបវារៈ វិស័យសន្តិសុខដែលជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រនឹងជួយកំណត់តួនាទីបានច្បាស់លាស់។

ចំណុចនេះចាប់ផ្តើមពីការទទួលស្គាល់ថា ការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីជាការសង្គ្រោះជីវិតដោយមានការខិតខំទប់ស្កាត់ដែលត្រូវបានកំណត់ជាអាទិភាពក្នុងការឆ្លើយតបទៅនឹងវិបត្តិសុខភាពសាធារណៈតាំងពីដំបូង ដើម្បីផ្តល់ចន្លោះសុវត្ថិភាពដល់ស្ត្រី និងក្មេងស្រីគ្រប់រូបដោយគ្មានការរើសអើង។ ដូច្នេះ ស្ថាប័ននគរបាលត្រូវមានលទ្ធភាពទទួលបានប្រភពព័ត៌មាន និងទិន្នន័យជាប់ជាប្រចាំ និងអាចជឿទុកចិត្តបាន ស្តីពីថាតើក្រុមប្រជាជនណាខ្លះងាយប្រឈមខ្លាំងបំផុតទៅនឹងអំពើហិង្សាកាន់តែច្រើននិងថាតើស្ត្រីនិងក្មេងស្រីរងផលប៉ះពាល់ដូចម្តេចពីភាពងាយរងគ្រោះមានស្រាប់ក៏ដូចជាវិសមភាពសេដ្ឋកិច្ច ឬសង្គមកាន់តែខ្លាំង (ដូចជា ភេទ អាយុ ជាតិពន្ធុ/ជាតិសាសន៍ ពិការភាព ស្ថានភាពសេដ្ឋកិច្ច ។ល។) ដែលបណ្តាលមកពី វិបត្តិ។

ខាងក្រោមនេះ ជាការពិចារណាដែលត្រូវដាក់បញ្ចូលក្នុងការវិភាគផលប៉ះពាល់ នៅពេលកំណត់បរិបទនៃកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ និងសេវាក្នុងផែនការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានវិបត្តិមនុស្សធម៌ និងការផ្ទុះជំងឺឆ្លង។

"សារគួរបង្ហាញក្នុងផ្ទាំងធំៗដែលបង្ហាញព័ត៌មានស្តីពីការទប់ស្កាត់ជំងឺកូវីដ១៩ដើម្បីកុំឱ្យមានការផ្តោតការយកចិត្តទុកដាក់លើធនធានរបស់ជនរងគ្រោះ"។

ផ្តើមចេញពីការសម្របសម្រួលជាសកលឆ្ពោះទៅរកយុទ្ធសាស្ត្រក្នុងមូលដ្ឋាន អភិក្រមអនុវត្តន៍ក្នុងការទប់ស្កាត់ ដោះស្រាយ និងចងក្រងឯកសារស្តីពីអំពើហិង្សាក្នុងគ្រួសារក្នុងវិបត្តិជំងឺកូវីដ១៩ឯកសារពន្យល់ពិភាក្សា (២០២០)។

### បង្កើនទំនាក់ទំនងខាងក្រៅក្នុងទម្រង់ផ្សេងៗដែលផ្តល់ភាពងាយស្រួល

- ដោយសារតែរដ្ឋាភិបាលមានគោលបំណងផ្តល់ព័ត៌មានដល់សហគមន៍ ស្តីពីវិធានការសុវត្ថិភាព សុខភាពសាធារណៈ និងកសាងការយល់ដឹងស្តីពីស្ថានភាពវិបត្តិនេះ បែបបទផ្សេងៗនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើនវិសាលភាពជាអតិបរមាដែលមានចាប់ពីយុទ្ធនាការតាមប្រព័ន្ធបច្ចេកវិទ្យា (ប្រសិនបើសមស្រប)[692] វិទ្យុ និងទូរទស្សន៍ សំណៅឯកសារ[693] ការដាក់សញ្ញាលើផ្ទាំងប៉ាណូផ្សាយពាណិជ្ជកម្មឬការប្រកាសតាមមេក្រូតាមទីសាធារណៈ។ ស្ថាប័ននគរបាលអាចសហការជាមួយកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់រដ្ឋាភិបាល ដើម្បីបង្កើនការយល់ដឹងពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ សំខាន់បំផុត នគរបាលត្រូវដឹងថា សារមានទម្រង់រួម ដោយយល់ច្បាស់ថា អំពើហិង្សាលើស្ត្រី និងក្មេងស្រីមិនមែនជាបាតុភូតថ្មីឡើយ ហើយនៅពេលមានអំពើហិង្សានគរបាលនឹងខិតខំដោះស្រាយឧប្បត្តិហេតុនោះ។
- នៅទូទាំងពិភពលោក ឧបសគ្គផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ រារាំង ឬរឹតត្បិតលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានប្រើប្រាស់ និងទាញប្រយោជន៍ពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍[694]។ បាតុភូតនេះត្រូវបានកំណត់ជាការបែងចែកយេនឌ័រក្នុងវិស័យឌីជីថល។ ក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសដែលប្រឈមនឹងការរើសអើងក្នុងទម្រង់ចម្រុះនៃការរើសអើង ស្ត្រី និងក្មេងស្រីអាចគ្មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័ត កុំព្យូទ័រ ឬអ៊ីនធឺណិតដើម្បីទទួលបានសេវា ឬអាចប្រើប្រាស់បច្ចេកវិទ្យាទាំងនេះដោយសុវត្ថិភាពនៅផ្ទះ ព្រោះពួកគេស្ថិតក្រោមការត្រួតពិនិត្យតឹងរ៉ឹងដោយជនបំពាន និងសមាជិកគ្រួសារផ្សេងទៀត។ សូមមើលប្រអប់ ៩ ស្តីពី អនុសាសន៍របស់ UNICEF សម្រាប់ជម្រើសមិនប្រើ ឬមិនសូវប្រើបច្ចេកវិទ្យា ដែលអាចសម្រួលដល់ការរាយការណ៍របស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

**ប្រអប់ ៣**

**UNICEF ៖ មិនត្រឹមតែជាខ្សែទូរស័ព្ទជំនួយ និងទូរស័ព្ទចល័ត ៖**
**ការផ្តល់សេវាសម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩**

ខណៈដែលប្រជាជនកាន់តែច្រើន មាន និងអាចប្រើប្រាស់ទូរស័ព្ទចល័តនៅជុំវិញពិភពលោក ជាពិសេសក្នុងមជ្ឈដ្ឋានមានប្រាក់ចំណូលទាប ចំនួនស្ត្រីដែលមានទូរស័ព្ទប្រើប្រាស់គឺតិចជាងបុរស។ គេប៉ាន់ស្មានថា នៅទូទាំងពិភពលោក ស្ត្រីពេញវ័យចំនួន ៤៤៣ លាននាក់ "គ្មានទូរស័ព្ទប្រើប្រាស់"។

UNICEF បានកំណត់ចំណុចចាប់ផ្តើមជាច្រើនសម្រាប់ការផ្តល់ជម្រើសគ្មាន ឬមានបច្ចេកវិទ្យាតិចតួចដល់ជនរងគ្រោះដែលគ្មានទូរស័ព្ទប្រើដើម្បីក្រើនរំលឹកដល់អ្នកពាក់ព័ន្ធសំខាន់ៗស្តីពីតម្រូវការសេវាអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ស្ត្រី ក្រោមការរឹតត្បិតការដើរហើរក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩។ ជម្រើសទាំងនោះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម៖

- ការដាក់បញ្ចូលចន្លោះសុវត្ថិភាពរូបវន្តមានស្រាប់សម្រាប់ស្ត្រី និងក្មេងស្រី ក្នុងស្ថានីយ៍បញ្ជូរទូរស័ព្ទស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ស្ថានីយ៍ទាំងនេះអាចផ្តល់ចន្លោះសុវត្ថិភាពបានឱ្យតែមានបំពាក់ដោយបញ្ជរ/ទូទូរស័ព្ទសាងសង់ឡើងតាមបែបធម្មតា និងមានលក្ខណៈឯកជន ដែលជនរងគ្រោះអាចទូរស័ព្ទទៅអ្នកផ្តល់សេវាសំខាន់ៗ រួមទាំងនគរបាលដែលប្រចាំការតាមពេលវេលាកំណត់ និងទទួលបានការគាំទ្រ។ ស្ថានីយ៍ទាំងនេះអាចស្ថិតនៅ

692. ការងាកទៅរកការគាំទ្រតាមប្រព័ន្ធអ៊ីនធឺណិតបង្កការលំបាកជាពិសេសពាក់ព័ន្ធនឹងបណ្តុំបច្ចេកវិទ្យាឌីជីថលជាសកលដ៏ធំ។ ការផាត់ចេញពីប្រព័ន្ធឌីជីថលដោយផ្អែកលើយេនឌ័របណ្តាលមកពីកត្តាជាច្រើន។ ការលំបាកក្នុងការចូលប្រើប្រាស់ ភាពអាចលៃលកបាន (កង្វះ) ការអប់រំ និងជំនាញ និងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងភាពលម្អៀងយេនឌ័រដែលបង្កប់មកជាមួយ និងបទដ្ឋានសង្គម-វប្បធម៌ ជាឫសគល់នៃការផាត់ចេញពីប្រព័ន្ធឌីជីថលដោយផ្អែកលើយេនឌ័រ។ការបង្កើនលទ្ធភាពប្រើប្រាស់ឧបករណ៍ឌីជីថលឱ្យកាន់តែមានសុវត្ថិភាព និងអាចលៃលកបាន គឺសំខាន់ដូចអន្តរាគមន៍គោលនយោបាយដែលដោះស្រាយភាពលម្អៀងផ្នែករចនាសម្ព័ន្ធយូរអង្វែងដែរ។សូមមើល http://www.oecd.org/internet/bridging-the-digital-gender-divide.pdf

693. សំណៅឯកសារគួរមានទម្រង់ចម្រុះ រួមទាំងអក្សរសម្រាប់ជនពិការភ្នែក និងប្រើប្រាស់ភាសា និងរូបភាពធម្មតាៗ។

694. វិធីលុបបំបាត់ការបែងចែកយេនឌ័រក្នុងវិស័យឌីជីថលចេញពីទស្សនៈវិស័យសិទ្ធិមនុស្ស (២០១៦)។សារណានៃគម្រោងសិទ្ធិមនុស្សទិន្នន័យធំៗនិងបច្ចេកវិទ្យានៅមជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Essex ក្រោមជំនួយមូលនិធិពីក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម៖ https://www.ohchr.org/Documents/Issues/Women/WRGS/GenderDigital/HRBDT_submission.pdf។ សូមមើលផងដែរ មូលនិធិ World Wide Web សិទ្ធិស្ត្រីតាមប្រព័ន្ធអ៊ីនធឺណិត។ ការប្រែក្លាយលទ្ធភាពទទួលបានទៅជាការបង្កើនភាពអង់អាច (២០១៥) http://webfoundation.org/docs/2015/10/womens-rights-online21102015.pdf.

តំបន់ប្រមូលផ្តុំ ដូចជា ផ្សារ និងហាង។

- ការបង្កើតចំណុចចូល និងប្រព័ន្ធ ដែលជនរងគ្រោះអាចប្រើប្រាស់ ឬបង្ហាញពីតម្រូវការការគាំទ្រតាមរយៈការដំណើរការ "ខ្សែសង្វាក់នៃការជូនដំណឹង"។ ប្រព័ន្ធទាំងនេះរួមមានតុផ្តល់ព័ត៌មាន "បណ្តោះអាសន្ន" នៅទីតាំងដែលទទួលបានការអនុញ្ញាត ឬសេវាកណ្តាលវាល ដូចជា ឱសថស្ថាន ហាងលក់គ្រឿងទេស/ផ្សារអាហារ/កន្លែងចែកចាយចំណីអាហារ/ស្ថានីយ៍បូមទឹក។ល។ ដែលជនរងគ្រោះអាចជូនដំណឹងដល់នគរបាលចុះល្បាត និងអ្នកផ្តល់សេវាសំខាន់ៗដើម្បីទទួលបានជំនួយ។
- ការផ្សព្វផ្សាយពីប្រព័ន្ធជូនដំណឹងដែលមិនសូវប្រើបច្ចេកវិទ្យា។ មានប្រយោជន៍បំផុតក្នុងមជ្ឈដ្ឋានមនុស្សធម៌/មានប្រាក់ចំណូលទាប ដែលវត្ថុជូនដំណឹង (ឧ. ការស្លៀកសំលៀកបំពាក់ដែលមានពណ៌ជាក់លាក់) អាចត្រូវបានដាក់បញ្ចូលក្នុងឃីតសម្រាប់សង្គ្រោះក្រោយរងការរំលោភបំពានដែលស្ត្រីនិងក្មេងស្រីទទួលបានប្រសិនបើមានការចែកជូនជាបន្តបន្ទាប់។ការជូនដំណឹងដែលមិនសូវប្រើបច្ចេកវិទ្យាអាចរួមមានពាក្យសម្ងាត់កញ្ចែ/សញ្ញារំលឹកការដាក់វត្ថុសោះកក្រោះនៅក្រៅផ្ទះ ដូចជា ក្រណាត់/ធុងពណ៌។ល។ ដែលអាចជូនដំណឹងដល់នគរបាលក្នុងមូលដ្ឋាន អង្គការស្ត្រី/សមាជិកសហគមន៍សំខាន់ៗដើម្បីទទួលបានជំនួយ។

**ការពិចារណាសំខាន់ៗ សម្រាប់នគរបាលនៅពេលធ្វើប្រតិបត្តិការក្នុងបរិបទនៃជម្រើសដែលគ្មាន ឬមិនសូវប្រើបច្ចេកវិទ្យា៖**

- ពិនិត្យបឋមយ៉ាងយកចិត្តទុកដាក់ជ្រើសរើសនិងបណ្តុះបណ្តាលមន្ត្រីនគរបាលឆ្លើយតប/បុគ្គលិកសំខាន់ៗផ្សេងទៀតដែលគ្រប់គ្រងសេវានេះ ដូចជា ស្តីពីការផ្លាស់ប្តូរការបំពេញមុខងារនៃវិធីបញ្ជូនករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីធានាការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយអ្នកផ្តល់សេវាជំនាញ ដូចជា អ្នកផ្តល់សេវាទីជម្រក/ពិគ្រោះយោបល់ក្នុងគ្រាអាសន្ន។
- មិនត្រូវបង្ខំឱ្យជនរងគ្រោះដាក់បណ្តឹងព្រហ្មទណ្ឌលើជនបំពាន ជាថ្នូរនឹងការទទួលបានការគាំទ្របន្តឡើយប្រសិនបើសេវាត្រូវបានផ្តល់ជូនជាមួយនឹងសេវានគរបាល ឬសេវាសន្តិសុខផ្លូវការ។
- រៀបចំផែនការហ្មត់ចត់សម្រាប់ការបង្ហាញនិងការផ្សព្វផ្សាយ/លើកកម្ពស់សេវាដែលរក្សាតុល្យភាពរវាងការចូលដល់ជនរងគ្រោះឱ្យបានច្រើនបំផុត និងហានិភ័យដែលជនបង្កអាចប្រើប្រាស់ចំណេះដឹងពីប្រព័ន្ធនេះ ដើម្បីរារាំងលទ្ធភាពរបស់ជនរងគ្រោះក្នុងការទទួលបានសេវាទាំងនោះ។ ឧទាហរណ៍មួយគឺការផ្សព្វផ្សាយប្រព័ន្ធនេះដល់ស្ត្រី និងក្មេងស្រី នៅពេលចែកសម្ភារដល់ស្ត្រី ដូចជា អាហារ ឬឃីតសម្រាប់សង្គ្រោះក្រោយរងការរំលោភបំពាន។
- ការពារយ៉ាងហ្មត់ចត់នូវទិន្នន័យ និងគោលនយោបាយឯកជនភាព និងដំណើរការពាក់ព័ន្ធ។
- ការសម្របសម្រួលជាមួយ "ក្រុមសមាជិកសហគមន៍" ដែលទទួលបានទំនុកចិត្ត ដែលជនរងគ្រោះស្គាល់ ឬ "មន្ត្រីទំនាក់ទំនង" ប្រសិនបើប្រើប្រាស់ប្រព័ន្ធជូនដំណឹងស្ងៀមស្ងាត់ដែលមិនសូវប្រើបច្ចេកវិទ្យា តាមរយៈការដាក់វត្ថុផ្តល់ដំណឹងនៅក្រៅផ្ទះ។ល។ក្នុងពេលបិទខ្ទប់ពួកគេអាចជាសមាជិកនិងមន្ត្រីដែលត្រូវបានអនុញ្ញាតឱ្យដើរហើរដោយសេរីដើម្បីកត់សម្គាល់ពីការផ្តល់ដំណឹង និងបញ្ជូនទៅរកជំនួយ។

ប្រភព ៖ មិនមែនត្រឹមតែជាខ្សែទូរស័ព្ទជំនួយ និងទូរស័ព្ទចល័ត ៖ ការផ្តល់សេវាសម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩ (២០២០)
Erskine, D. for UNICEF and Global Rapid Gender Analysis for COVID-19 (2020) international Rescue Committee and CARE International

## សេវាសំខាន់ៗ

- ជាធម្មតា ប្រព័ន្ធសុខាភិបាលដែលផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចប្រឈមនឹងការដួលរលំដែលនឹងបង្កផលប៉ះពាល់លើយន្តការឆ្លើយតបដោយមានការសម្របសម្រួលរវាងវិស័យផ្សេងៗ ដូចជា សុខាភិបាល នគរបាល និងយុត្តិធម៌ និងការឆ្លើយតបនៃសេវាសង្គម។
- ក្នុងសេណារីយ៉ូករណីល្អបំផុតជម្រកសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាលនឹងត្រូវបានប្រើប្រាស់អស់លទ្ធភាព(នៅអំឡុងពេលធម្មតាក្នុងបរិបទជាច្រើនជាញឹកញាប់អ្នកផ្តល់ជម្រកត្រូវបដិសេធជនរងគ្រោះ និងកូនៗរបស់



រូបថតទទួលបានពី UN Women/Pathumporn Thongking (ប្រទេសថៃ)

ពួកគេដែលស្វែងរកការការពារដោយសារកង្វះចន្លោះទំនេរ)។

- ការពន្យារពេលចេញដីកាហាមឃាត់បណ្ដោះអាសន្ន កិច្ចដំណើរការនីតិវិធីសម្រាប់ការបែកផ្លូវគ្នា និងការលែងលះ និងសវនាការស្ដីពីសិទ្ធិចិញ្ចឹមកូន រួមទាំងសវនាការដែលជាមូលដ្ឋានសម្រាប់ឱ្យជនរងគ្រោះដោយសារអំពើហិង្សាលើដៃគូស្និទ្ធស្នាល អាចផ្ដាច់ខ្លួនឬចាកចេញពីដៃគូដែលប្រព្រឹត្តបំពាន[695]។ មន្ត្រីឆ្លើយតបត្រូវដាក់បញ្ចូលការពន្យារពេលទាំងនេះក្នុងការវាយតម្លៃហានិភ័យរបស់ខ្លួន និងអនុសាសន៍ជាបន្តបន្ទាប់សម្រាប់ប្រភេទ និងកម្រិតនៃដីកាការពារដែលត្រូវការចាំបាច់[696]។

## ការបន្តផ្ដល់យុត្តិធម៌ ៖ ឧទាហរណ៍នៃផលប៉ះពាល់ និងការផ្លាស់ប្ដូរចាំបាច់ក្នុងវិបត្តិសុខភាព សាធារណៈ ឧទាហរណ៍នៃផលប៉ះពាល់

- ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ ១៩ តុលាការបានពន្យារពេលកាត់ទោសកាត់បន្ថយការផ្ដន្ទាទោស និងបិទសំណុំរឿងជាបណ្ដោះអាសន្ន។ ចំណុចនេះបង្កផលប៉ះពាល់លើការចេញដីកាការពារដោយតុលាការដែលហាមឃាត់ជនបង្កអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមិនឱ្យមានទំនាក់ទំនងជាក់លាក់ជាមួយជនរងគ្រោះ ការកើនឡើងនៃចំនួនករណីដែលមិនត្រូវបានដោះស្រាយ និងចំនួន និង/ឬរយៈពេលសម្រាប់អ្នកជាប់ឃុំមុនពេលកាត់ទោស។ ដូច្នេះ ស្ថាប័ននគរបាលក៏ដូចជាស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត (ដូចជាបុគ្គលិកមន្ទីរឃុំឃាំង) គួររៀបចំកិច្ចប្រជុំសម្របសម្រួលពិសេសជាមួយមន្ត្រីតុលាការដើម្បីកំណត់រកហានិភ័យនៃការឆ្លងរាលដាល និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ដូចជា នីតិវិធីពិនិត្យបឋម និងធ្វើតេស្ត ក៏ដូចជាករណីដែលត្រូវចាត់ទុកជា "ករណីបន្ទាន់" ឬ"មានអាទិភាពខ្ពស់" ដើម្បីឱ្យពួកគេអាចបញ្ចៀសវិធានការបិទខ្ទប់/ចត្តាឡីស័ក។

695. ជំងឺរាតត្បាត និងអំពើហិង្សាលើស្ត្រី និងកុមារ (២០២០) Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

696. ផ្នែកលើកត្តានានា ដូចជា អ្នកចេញដីកា (នគរបាល ឬតុលាការ) ថាតើដីកាការពារជាផ្នែកមួយនៃករណីព្រហ្មទណ្ឌ ឬករណី រដ្ឋប្បវេណី ថាតើត្រូវមានសនាការ ឬទេ ថិរវេលានៃដីកានោះ ការការពារជាក់លាក់ អ្នកដែលអាចទទួលបានដីកាការពារ (ប្ដី/ប្រពន្ធ ឬដៃគូស្និទ្ធស្នាលផ្សេងទៀត សមាជិកគ្រួសារ អ្នករួមបន្ទប់។ល។) និងរបៀបអនុវត្តដីកានោះ និងថាតើមានផលវិបាកផ្នែកព្រហ្មទណ្ឌសម្រាប់ការរំលោភដីកា ឬទេ។ សូមមើល ការឆ្លើយតបរបស់តុលាការទៅនឹងអំពើហិង្សាលើស្ត្រីក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩។ កម្រងសិក្ខាសាលាតាមប្រព័ន្ធអ៊ីនធឺណិត ៖ ការកែសម្រួលការឆ្លើយតបផ្នែកច្បាប់ និងជាប្រព័ន្ធក្នុងអំឡុងវិបត្តិកូវីដ ១៩ ការដោះស្រាយអំពើហិង្សាលើស្ត្រី ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២០។ Global Rights for Women, https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf

- ស្ថាប័ននគរបាល ក៏ដូចជាស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀតគួរពិចារណារៀបចំកិច្ចប្រជុំសម្របសម្រួលពិសេសជាមួយអ្នកជំនាញយុត្តិធម៌ផ្សេងទៀតដូចជាគ្រូពេទ្យកោសល្យវិច័យ និងអ្នកជំនាញផ្នែកចិត្តសង្គម ដើម្បីធានាថា ពួកគេទំនេរ និងអាចទាក់ទងបាន។ របាយការណ៍ថ្មីៗដែលគាំទ្រដោយអង្គការសហប្រជាជាតិបានចងក្រងសក្ខីកម្មរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយគូសបញ្ជាក់ថាជនរងគ្រោះទាំងនោះមិនអាចស្វែងរកដំណោះស្រាយផ្លូវច្បាប់ប្រឆាំងនឹងជនបង្កបានឡើយ ព្រោះគ្រូពេទ្យកោសលវិច័យមិនអាច ឬគ្មានឆន្ទៈពិនិត្យការរំលោភបំពានរាងកាយរបស់ជនរងគ្រោះនៅប៉ុស្តិ៍នគរបាលដោយសារខ្លាចឆ្លងជំងឺកូវីដ ១៩[697] ។
- ក្រោមវិធានការចត្តាឡីស័ក/បិទខ្ទប់ដែលបណ្តាលមកពីជំងឺកូវីដ ១៩ មន្ទីរឃុំឃាំង និងសេវាកាត់ទោសប្រហែលជាត្រូវរក្សាតុល្យភាពរវាងបទល្មើស/អំពើហិង្សារបស់ជនល្មើស ក៏ដូចជាការប្រព្រឹត្តបទល្មើសជាថ្មី និងហានិភ័យនៃការឆ្លងជំងឺដែលអាចកើតឡើងក្នុងមន្ទីរឃុំឃាំងនិងអត្ថន័យនៃចំណុចនេះសម្រាប់ជនល្មើសជាពិសេសនៅពេលពិចារណាពីបញ្ហាសុខភាពពីមុនមក និងអាយុ ក្នុងចំណោមកត្តាផ្សេងទៀត។ ការសម្រេចមិនឃុំខ្លួនជនបង្កអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្រោយការវិភាគដូច្នេះ អាចធ្វើឱ្យជនរងគ្រោះ (និងសមាជិកគ្រួសារ) ប្រឈមនឹងហានិភ័យបន្ថែមទៀត។ការស៊ើបអង្កេតល្អិតល្អន់ដែលផ្អែកតាមប៉ះទង្គិចផ្លូវចិត្ត (ដោយប្រើឧបករណ៍នានា ដូចជា វដ្តនៃអំណាចនិងការគ្រប់គ្រង) និងផ្តោតសំខាន់លើជនបង្ក ដើម្បីធានាថា មិនបង្កគ្រោះថ្នាក់ (បន្ថែមទៀត) ពិតជាសំខាន់ខ្លាំងណាស់។ សូមមើលជំពូកទី ៥ (ការស៊ើបអង្កេត)សម្រាប់ព័ត៌មានបន្ថែមស្តីពីការស៊ើបអង្កេតពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលផ្អែកតាមការប៉ះទង្គិចផ្លូវចិត្ត និងផ្តោតសំខាន់លើជនបង្ក។

**គោលការណ៍ "មិនបង្កគ្រោះថ្នាក់" ទាមទារការវាយតម្លៃសមស្របលើឌីណាមិកយេនឌ័រ និង បទដ្ឋានវប្បធម៌ដែលអាចធ្វើឱ្យជនរងគ្រោះនិងសាក្សីប្រឈមនឹងគ្រោះថ្នាក់បន្ថែមទៀត ដូចជា ការប៉ះទង្គិចផ្លូវចិត្តជាថ្មី ឬការមាក់ងាយ អំពើហិង្សា និងការមិនទទួលបានការយកចិត្តទុកដាក់ ដែលបង្កដោយជនបង្កដែលរងការចោទប្រកាន់ ឬគ្រួសារ និងសហគមន៍របស់ជនរងគ្រោះ (UNHCR ២០១៤)។**

- ទោះបីជាមានការកើនឡើងនៃការរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងប្រទេសនានាក្តី ក៏បរិបទមួយចំនួនអាចបង្ហាញថា សេវាគាំទ្រ ដូចជាជម្រកសុវត្ថិភាព មណ្ឌលតស៊ូមតិឱ្យជនរងគ្រោះ និងសំណើសុំដីកាការពារ មិនកើនឡើង ឬទទួលបានទៅតាមការរំពឹងទុកនោះទេ។ ក្នុងករណីខ្លះ សំណើសុំសេវាគាំទ្រអាចថយចុះក្នុងពេលអនុវត្តវិធានការទប់ស្កាត់ការចម្លងក្នុងអំឡុងវិបត្តិសុខភាពសាធារណៈ។ បាតុភូតនេះបណ្តាលមកពីមូលហេតុខុសៗគ្នា ប៉ុន្តែនគរបាលគួរពិចារណាថាតើការផ្តាច់ចេញពីសង្គម កង្វះចន្លោះសុវត្ថិភាពដើម្បីអាចទទួលបានសេវាសំខាន់ៗដោយសារវិធានការបិទខ្ទប់ លក្ខខណ្ឌតម្រូវសម្រាប់សវនាការក្នុងតុលាការផ្ទាល់ ឬការដាក់ពាក្យសុំជំនួយសង្គ្រោះសម្រាប់សិទ្ធិចិញ្ចឹមកូន និងកង្វះជម្រើសថែទាំកុមារ (រួមទាំងនៅតុលាការ) ជះឥទ្ធិពលដូចម្តេច។

## ឧទាហរណ៍នៃការផ្លាស់ប្តូរចាំបាច់

- បង្កើនការផ្តល់សារសាធារណៈរួមជាមួយស្ថាប័នយុត្តិធម៌ស្តីពីការរកបាននិងលទ្ធភាពទទួលបានសេវាសំខាន់ៗក្នុងការបន្តផ្តល់យុត្តិធម៌ ដើម្បីឱ្យប្រជាជនបានដឹងពីម៉ោងប្រតិបត្តិការ និងដំណើរការ ក្នុងអំឡុងវិបត្តិសុខភាពសាធារណៈ។លើសពីនេះ ការផ្តល់សារជាសាធារណៈគួរអមមកជាមួយនូវការផ្សព្វផ្សាយថ្មីៗស្តីពីការប្តេជ្ញាចិត្តរបស់នគរបាលក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផលវិបាកនៃការរំលោភដីកាការពារ។
- ការបង្កើតនីតិវិធីប្រតិបត្តិស្តង់ដារនិងការបណ្តុះបណ្តាលពាក់ព័ន្ធ[698] ដល់អ្នកគ្រប់គ្រងក្នុងជួរនគរបាល និង

697. របាយការណ៍រួមរបស់អង្គការសហប្រជាជាតិ "យុត្តិធម៌សម្រាប់ស្ត្រីក្នុងវិបត្តិជំងឺកូវីដ ១៩" (២០២០)។ UN Women, IDLO, UNDP, UNODC, WB និង Pathfinders for Justice ៖ https://www.idlo.int/sites/default/files/pdfs/publications/Justice-for-Women_Full-Report-English.pdf។សូមមើលផងដែរគណៈកម្មការជាតិលីបង់ដើម្បីស្ត្រី, UN Women , WHO, UNFPA, ២០២០។ ការក្រើនរំលឹកពីយេនឌ័រក្នុងវិបត្តិជំងឺកូវីដ ១៩។ចំណុចផ្តោតសំខាន់ ៖ លទ្ធភាពទទួលបានយុត្តិធម៌ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០ លេខ ១ ៖ https://www2.unwomen.org/-/media/field%20office%20arab%20states/attachments/publications/2020/04/gender%20and%20covid-19%20in%20lebanon/updated/gender%20alert%20on%20covidlebanon%20english.pdf?la=en&vs=1838

បុគ្គលិកជួរមុខដែលអនុវត្តវិធានការកម្រិតកណ្តាលក្នុងការបន្តផ្តល់យុត្តិធម៌ ដូចជា បន្ទប់សវនាការ ឬកិច្ចដំណើរការនីតិវិធីពីចម្ងាយឬតាមប្រព័ន្ធអ៊ីនធឺណិតដែលអាចមានការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបញ្ជូនរូបភាព និងសំឡេង (video-conferencing) ក៏ដូចជាដំណើរការ និងការរៀបចំ សុវត្ថិភាពសមស្រប។ ការអនុវត្តទម្រង់បែបបទពីចម្ងាយទាំងនេះគួរចាត់ទុកជាការឆ្លើយតបភ្លាមៗ ទៅនឹងផលវិបាកដែលតុលាការមិនអាចបំពេញមុខងារជាប្រក្រតី ដោយសារវិបត្តិដូចជា ជំងឺរាតត្បាតកូវីដ១៩ និងក្នុងបរិបទនៃការរៀបចំផែនការ រយៈពេលមធ្យម និងរយៈពេលវែង។ ចំណុចនេះអាចរួមមានការបង្កើនសេវាសន្តិសុខនិងសេវាជនរងគ្រោះនៅជុំវិញតុលាការឬប្រអប់សំបុត្រាយការណ៍អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលត្រូវមានទំនាក់ទំនងផ្ទាល់ខ្លះៗ។

## ក្រុមងាយរងគ្រោះ និងសហគមន៍ភាគតិច

- ផ្អែកតាមបទពិសោធន៍នៃការផ្ទុះជំងឺឆ្លងកន្លងមក[699] វិបត្តិ ដូចជា ការផ្ទុះជំងឺឆ្លងអាច បណ្តាលឱ្យមានការមាក់ងាយ ការស្អប់ជនបរទេស និងការរើសអើងដោយសារជាតិសាសន៍ យេនឌ័រ ទំនោរផ្លូវភេទ និងស្ថានភាពទេសន្តរប្រវេសន៍ កាន់តែខ្លាំង។
- ចាំបាច់ត្រូវវាយតម្លៃឡើងវិញលើស្ថានភាពរបស់ប្រជាជនដែលមានហានិភ័យខ្ពស់ដោយសារតែវិបត្តិមនុស្សធម៌/វិបត្តិសុខភាពសាធារណៈធំៗ។ ចំណុចនេះរួមបញ្ចូលក្រុមប្រជាជនដែលពឹងផ្អែកខ្លាំងលើសេដ្ឋកិច្ចក្រៅប្រព័ន្ធសហគមន៍ដែលមិនសូវមានលទ្ធភាពទទួលបានសេវាសង្គមឬឥទ្ធិពលនយោបាយនិងមិនសូវមានសមត្ថភាព និងឱកាសក្នុងការដោះស្រាយ និងបន្សាំរួមទាំងការគ្មាន ឬមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់បច្ចេកវិទ្យា។ ក្នុងន័យនេះ UNOHCA, WHO និងសហព័ន្ធកាកបាទក្រហមនិងអឌ្ឍចន្ទក្រហមអន្តរជាតិ បានផ្តល់ការណែនាំ[700]សម្រាប់ស្ថាប័នឆ្លើយតបដែលធ្វើការងារក្រោមវិធានការទប់ស្កាត់ជំងឺកូវីដ ១៩ (សូមមើលប្រអប់ ១១)។

ជនដែលកំណត់អត្តសញ្ញាណជាស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកដែលមិនកំណត់ថាខ្លួនជាមនុស្សប្រុស ឬមនុស្សស្រី ឬអ្នកដែលកើតមកមានប្រដាប់បន្តពូជទាំងពីរភេទ (LGBTQI) គឺជាញឹកញាប់ប្រឈមនឹងហានិភ័យខ្ពស់នៃការរើសអើង ការមាក់ងាយ និងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្លូវកាយ"។

The Sphere Handbook (2018)

- បទពិសោធន៍កន្លែងមកក្នុងសហគមន៍រងផលប៉ះពាល់បង្ហាញថា ស្ត្រី និងក្មេងស្រីត្រូវបានកំណត់ឱ្យបំពេញតួនាទីយេនឌ័របែបប្រពៃណី ក្នុងនាមជាម្តាយ ឬអ្នកថែទាំ និងភាគច្រើនត្រូវបានផាត់ចេញពីឱកាសក្នុងសហគមន៍ ដែលមានការធ្វើសេចក្តីសម្រេចលើការរៀបចំផែនការ និងការរៀបចំជំនួយសង្គ្រោះបន្ទាន់[701]។ ចំណុចនេះធ្វើឱ្យគ្មានការពិចារណាពីតម្រូវការសន្តិសុខរបស់ស្ត្រី និងបញ្ហាផ្សេងទៀត ក្រោយពេលកើតមានគ្រោះអាសន្ន[702]។ ចំណុចខ្លាំង នៃការចូលរួមរបស់នគរបាលជាមួយស្ត្រី និងក្មេងស្រីក្នុងសហគមន៍នឹងត្រូវបានសាកល្បងក្រោមស្ថានភាពទាំងនេះហើយជា

698. អាចរួមមានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ហាដវែរ និងសុសវែរចាំបាច់សម្រាប់ការរៀបចំសវនាការពីចម្ងាយដោយអ្នកចូលរួមទាំងអស់រួមទាំងបុគ្គលិកតុលាការនិងសមាជិកក្នុងអង្គតុលាការ។ សូមមើល ៖ សវនាការតុលាការពីចម្ងាយ និងដំណើរការយុត្តិធម៌ក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក្នុងបេសកកម្ម និងមជ្ឈដ្ឋានផុយស្រួល សេវាយុត្តិធម៌ និងកែប្រែ។ ការិយាល័យនីតិរដ្ឋសហប្រជាជាតិ និងវិទ្យាស្ថានសន្តិសុខ (OROLSI)/នាយកដ្ឋានប្រតិបត្តិការសន្តិភាព (DPO) ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២០ ៖ https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf
699. និន្នាការជាសកលនៃជំងឺឆ្លងថ្មីៗ។ Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L. et al. (2008). Nature 451: 990-94, see : https://www.cgdev.org/publication/pandemics-and-violence-against-women-andchildren
700. ជំងឺកូវីដ ១៩ ៖ របៀបដាក់បញ្ចូលប្រជាជនដែលមិនទទួលបានការយកចិត្តទុកដាក់ និងងាយរងគ្រោះ ក្នុងការផ្សព្វផ្សាយ ហានិភ័យ និងការជំរុញការចូលរួមរបស់សហគមន៍ (២០២០)។សហព័ន្ធកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌ និងអង្គការសុខភាពពិភពលោក៖ https://reliefweb.int/sites/reliefweb.int/files/resources/COVID-19_CommunityEngagement_130320.pdf
701. ករណីសិក្សានៅប្រទេសអេក្វាឌ័រ ៖ ច្បាប់ និងគោលនយោបាយដែលមានប្រសិទ្ធភាពស្តីពីសមភាពយេនឌ័រ និងការការពារពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រោះមហន្តរាយ (២០២០)។ សហព័ន្ធកាកបាទក្រហម និង អឌ្ឍចន្ទក្រហមអន្តរជាតិ (IFRC) ៖ https://www.ifrc.org/media/13646
702. ករណីសិក្សានៅប្រទេសអេក្វាឌ័រ ៖ ច្បាប់ និងគោលនយោបាយដែលមានប្រសិទ្ធភាពស្តីពីសមភាពយេនឌ័រ និងការការពារពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រោះមហន្តរាយ(២០២០)។សហព័ន្ធកាកបាទក្រហមនិងអឌ្ឍចន្ទក្រហមអន្តរជាតិ (IFRC) ៖ https://www.ifrc.org/media/13646
703. របាយការណ៍ឆ្នាំ ២០១៩ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើស្ត្រីដែលជាពលករទេសន្តរប្រវេសន៍ (A/74/235)

មួយនិងទំនាក់ទំនងជាវិជ្ជមាននឹងធ្វើឱ្យមានភាពខុសគ្នាដ៏សំខាន់មួយលើការឆ្លើយតបដោយសេវាសំខាន់ៗ។

- ភស្តុតាងពីវិបត្តិជំងឺកូវីដ១៩ បង្ហាញថាបទពិសោធន៍នៃការប្រឈមនឹងជំងឺរាតត្បាត (ដូចវិបត្តិសុខភាពសាធារណៈផ្សេងទៀតដែរ) ធ្វើឱ្យពលករចំណាកស្រុក[703] ជាស្ត្រីកាន់តែប្រឈមនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុក។ នេះជាការពិតសម្រាប់ស្ត្រីដែលធ្វើចំណាកស្រុកមិនទៀងទាត់ ឬក្រុមផ្លូវភេទ និងយេនឌ័រភាគតិចដែលមិនសូវរាយការណ៍ពីការប្រឈមនឹងអំពើហិង្សាដោយសារការរើសអើង ឬការភ័យខ្លាចការចាប់ខ្លួន ឬការនិរទេស[704]។ ជាញឹកញាប់ ស្ត្រី និងក្មេងស្រីទាំងមានការលំបាកក្នុងការស្វែងរកសេវាថែទាំសុខភាពនិងសេវាគាំទ្រសំខាន់ៗ ដោយការរឹតត្បិតការដើរហើរ ការបិទគ្លីនិក និងការភ័យខ្លាចឆ្លងជំងឺ[705]។
- ស្ត្រី និងក្មេងស្រីក្នុងឧស្សាហកម្មផ្លូវភេទច្រើនតែត្រូវបានបង្ខំឱ្យល្មើសវិធានការចត្តាឡីស័ក ឬប្រឈមនឹងអសន្តិសុខហិរញ្ញវត្ថុ និងអសន្តិសុខស្បៀងអាហារយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីជាច្រើន អសមត្ថភាពក្នុងការចូលរួមក្នុងសហគមន៍នេះនឹងបង្កផលប៉ះពាល់លើកុមារដែលពឹងផ្អែកលើពួកគេ។ ក្នុងករណីផ្សេងទៀត ស្ត្រី និងក្មេងស្រីប្រឈមនឹងពេស្យាកម្មដោយបង្ខំ ដែលតម្រូវឱ្យពួកគេបំពានវិធានការចត្តាឡីស័ក។នៅពេលចូលរួមជាមួយជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីទាំងនេះ នគរបាលត្រូវកំណត់ពីធម្មជាតិនៃទំនាក់ទំនងបែបកេងប្រវ័ញ្ចទាំងនេះ និងខិតខំធានាសុវត្ថិភាព និងការពារពួកគេ។ស្ថាប័ននគរបាលត្រូវកំណត់ស្ត្រីនិងក្មេងស្រីទាំងនេះជាក្រុមដែលងាយរងគ្រោះខ្លាំងបំផុតដោយសារការរំលោភបំពានដោយមន្ត្រីរដ្ឋរួមទាំងសមាជិកនៃកងកម្លាំងសន្តិសុខ។
- លើសពីនេះ នគរបាលគួរពិចារណាថាតើអំពើហិង្សាលើស្ត្រី អាចធ្វើឱ្យជនរងគ្រោះប្រព្រឹត្តបទល្មើស និងជាប់ពន្ធនាគារដោយរបៀបណា។យោងតាមអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើស្ត្រីស្រី ឫសគល់ និងផលវិបាកនៃអំពើហិង្សាមានភាពពាក់ព័ន្ធគ្នាយ៉ាងខ្លាំងរវាងអំពើហិង្សាលើស្ត្រី និងការដាក់ស្ត្រីក្នុងពន្ធធនាគារ[706] ជាពិសេសរបៀបដែលការប្រឈមទៅនឹងព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ អាចបណ្តាលឱ្យ ឬរួមចំណែកបង្កជាជំងឺដែលមិនអាចគ្រប់គ្រងដែនកំណត់អារម្មណ៍របស់ខ្លួនបាន (borderline personality disorder) ជំងឺប្រឆាំងច្បាប់ទំលាប់ក្នុងសង្គម (antisocial person ality disorder) ការបំពានគ្រឿងញៀន និងរោគសញ្ញានៃជំងឺបាក់ស្បាតដែលពាក់ព័ន្ធផ្ទាល់នឹងឥរិយាបថហិង្សា និងជាញឹកញាប់នាំទៅរកការជាប់ពន្ធនាគារ[707]។ ឧទាហរណ៍ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល ស្ត្រីអាចប្រើកម្លាំងបាយលើជនបំពាន ដោយសារព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពរបស់កូន[708]។

704. ការដោះស្រាយផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ ១៩ លើពលករចំណាកស្រុកជាស្ត្រី (២០២០) សេចក្តីណែនាំរបស់ UN Women ៖ https://www.unwomen.org/en/digital-library/publications/2020/04/guidance-note-addressing-the-impacts-of-the-covid-19-pandemic-on-women-migrant-workers
705. Ibid
706. អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាលើស្ត្រីបានបញ្ចប់បេសកកម្មនៅចក្រភពអង់គ្លេស និងអៀកឡង់ខាងជើង និងបានអំពាវនាវឱ្យចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហាកង្វះគណនេយ្យភាពនិងផលប៉ះពាល់អវិជ្ជមាននៃការផ្លាស់ប្តូរជំនួយមូលនិធិនិងសេវា (២០១៤) https://www.ohchr.org/en/statements/2014/04/special-rapporteur-violence-against-women-finalizes-country-mission-united
707. ពេលវេលាលំបាកៈរបៀបដែលស្ត្រីឈានទៅរកបទល្មើសនិងការជាប់ពន្ធនាគារ(២០១២) Artz, L., Hoffman-Wanderer, Y., and Moult, K, at: https://genderlinks.org.za/wp-content/uploads/imported/articles/attachments/18024_hard_times.pdf
708. ការរើសអើងផ្អែកលើយេនឌ័រ និងស្ត្រីដែលមានទំនាស់ជាមួយច្បាប់ (UNODC ២០២០) https://www.unodc.org/e4j/en/crime-prevention-criminal-justice/module-9/key-issues/1--gender-based-discriminationand-women-in-conflict-with-the-law.html



**ប្រអប់ ៤ ៖**

**ជំងឺកូវីដ ១៩ ៖ របៀបដាក់បញ្ចូលប្រជាជនដែលមិនទទួលបានការយកចិត្តទុកដាក់ និងងាយរងគ្រោះ ក្នុងការផ្សព្វផ្សាយពីហានិភ័យ និងការជំរុញការចូលរួមរបស់សហគមន៍ សហព័ន្ធកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ការិយាល័យអង្គការសហប្រជាជាតិ សម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌ និងអង្គការសុខភាពពិភពលោក**

| កុមារ | ជនមានពិការភាព | ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី |
|---|---|---|
| ពិគ្រោះជាមួយកុមារ និងមនុស្សជំទង់ រួមទាំងកុមារដែលគ្មានអ្នកមកជាមួយ និងត្រូវបានបំបែកចេញ ដើម្បីយល់ពីការព្រួយបារម្ភ ការភ័យខ្លាច និងតម្រូវការរបស់ពួកគេ។ | ផ្សព្វផ្សាយព័ត៌មានដែលប្រើភាសាច្បាស់លាស់ និងសាមញ្ញ។ | ធ្វើបច្ចុប្បន្នភាពរបៀបនៃការបញ្ជូនករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យឆ្លុះបញ្ចាំងពីមូលដ្ឋានថែទាំសុខភាពបឋម និងបន្ទាប់បន្សំ។ |
| រៀបចំឯកសារ/សម្ភារព័ត៌មាន និងផ្សព្វផ្សាយតាមបែបកុមារមេត្រី។ | ផ្តល់ព័ត៌មានក្នុងទម្រង់ដែលផ្តល់ភាពងាយស្រួល ដូចជា អក្សរសម្រាប់ជនពិការភ្នែក តួអក្សរធំៗ។ | ផ្តល់ព័ត៌មានដល់សហគមន៍ និងអ្នក<br>ផ្តល់សេវាសំខាន់ៗស្តីពីរបៀបថ្មីៗ។ |
| តស៊ូមតិឱ្យមានការពិគ្រោះយោបល់ និងសេវាគាំទ្រសម្រាប់អ្នករងផលប៉ះពាល់។ | ផ្តល់ការផ្សព្វផ្សាយក្នុងទម្រង់ចម្រុះ ដូចជាចំណងជើងរងឬវីដេអូជាភាសាសញ្ញា ចំណងជើងរងសម្រាប់អ្នកមានកម្សោយក្នុងការស្តាប់ ឯកសារ/សម្ភារតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់អ្នកប្រើបច្ចេកវិទ្យាជំនួយ។ | ធានាថាមានវិធានការកាត់បន្ថយហានិភ័យអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកន្លែងធ្វើចត្តាឡីស័និងដំណើរការជម្លៀសចេញ។ |
| ពិចារណាពីតម្រូវការផ្សេងៗដោយផ្អែកលើយេនឌ័រ បរិបទ និងសហគមន៍ជួបការលំបាក។ | ជំរុញការចូលរួមរបស់អង្គការជនពិការក្នុងការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចចិត្ត។ | ពង្រឹងសមត្ថភាពគាំទ្រ ដូចជា បុគ្គលិកផ្នែកខ្សែទូរស័ព្ទជំនួយក្នុងគ្រាអាសន្ន។ |
| | ផ្តល់អភិក្រមដែលសមស្របទៅនឹងតម្រូវការរបស់បុគ្គលធ្វើការជាមួយអ្នកថែទាំផ្ទាល់ និងបណ្តាញគាំទ្រសង្គមផ្សេងទៀត។ | ផ្សព្វផ្សាយក្រមប្រតិបត្តិនិងវិធានការធានាសុវត្ថិភាពផ្សេងទៀត និងរំលឹកមន្ត្រីពីភាពចាំបាច់នៃការអនុលោមតាមវិធានការទាំងនោះ។ |

## ភាពជាដៃគូជាមួយសហគមន៍ រដ្ឋាភិបាលមូលដ្ឋាន និងតួអង្គឯកជន

- អាជ្ញាធររដ្ឋាភិបាលមូលដ្ឋាន អាចអនុវត្តយន្តការគ្រប់គ្រងសន្តិសុខនៅមូលដ្ឋានដូចជាក្រុមប្រឹក្សាសន្តិសុខក្រុង ឬមូលដ្ឋាន (LSCs) ដើម្បីជួយសម្រួលដល់ការឆ្លើយតបទៅនឹងវិបត្តិ។នេះជាឱកាសសម្រាប់ឱ្យនគរបាលក្នុងមូលដ្ឋានលើកកម្ពស់ និងពង្រឹងភាពជាដៃគូដ៏សំខាន់។ ក្នុងករណីជាច្រើន ក្រុមប្រឹក្សាទាំងនេះមិនត្រូវបានជំរុញដោយអាជ្ញាធររដ្ឋាភិបាលក្រុង/មូលដ្ឋានឡើយទោះបីជាពួកគេមានអាណត្តិបំពេញការងារនេះក្តីឬក៏ពួកគេត្រូវបានជំរុញប៉ុន្តែមិនសកម្ម។ក្នុងករណីទាំងនេះវិបត្តិសុខភាពសាធារណៈអាចបំផុសឱ្យមានការប្រើប្រាស់ក្រុមប្រឹក្សាទាំងនេះ ដែលផ្តល់វេទិកាដ៏សំខាន់ដល់នគរបាលក្នុងការសម្របសម្រួលនិងរៀប

ចំផែនការយុទ្ធសាស្ត្រសម្រាប់អភិក្រមដែលកាន់តែមានគណនេយ្យភាព និងឆ្លើយតបនឹងយេនឌ័រក្នុងសេវានគរបាល។ សូមមើលករណីសិក្សាស្តីពីក្រុមប្រឹក្សាសន្តិសុខនៅមូលដ្ឋាន ក្នុងប្រទេសកុងហ្គោ អេក្វាឌ័រ និងម៉ិចស៊ិក ក្នុងជំពូកទី ៣ (ការទប់ស្កាត់)។

- ក្រោមវិធានការចត្តាឡីស័ក សហគមន៍ អ្នកដឹកនាំសាសនា និងបុគ្គលមានឥទ្ធិពល នៅតែអាចធ្វើជាដៃគូដ៏សំខាន់ជាមួយស្ថាប័ននគរបាលនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសក្នុងការកសាងការយល់ដឹងពីកត្តាហានិភ័យដែលជំរុញនិងបង្កើនអំពើហិង្សាក្នុងពេល និងក្រោយពេលវិបត្តិ។ គេអាចប្រើវេទិកាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍តាមប្រព័ន្ធអ៊ីនធឺណិត ដូចជា Facetime ឬ Skype សម្រាប់ការផ្តល់សាររួមដើម្បីជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី អមជាមួយនឹងព័ត៌មានស្តីពីយន្តការរាយការណ៍ថ្មីៗ។ លើសពីនេះ ការផ្តល់សាររួមតាមមធ្យោបាយមិនមែនឌីជីថលឬក្រៅប្រព័ន្ធអ៊ីនធឺណិតអាចធ្វើឡើងតាមការនិយាយពីមាត់មួយទៅមាត់មួយឬមេក្រូឬសកម្មភាពក្រុមដែលធ្វើឡើងក្នុងគម្លាតសុវត្ថិភាព[709]។

**ប្រអប់ ៥**

**គណៈកម្មាធិការឃ្លាំមើលជំងឺអេបូឡា**



រូបថតទទួលបានពីអង្គការ Heart to Heart International (ប្រទេសលីបេរីយ៉ា)

ផ្អែកតាមបទពិសោធន៍ នៅអាហ្វ្រិកខាងលិច ក្នុងពេលផ្ទុះជំងឺអេបូឡា អង្គការតាមមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតគណៈកម្មាធិការភូមិឃ្លាំមើលជំងឺអេបូឡាដែលដឹកនាំដោយស្ត្រីក្នុងមូលដ្ឋាន និងមេដឹកនាំសាសនា ដើម្បីបង្កើនការឆ្លើយតប និងការងារនៅមូលដ្ឋានឱ្យដើរទន្ទឹមគ្នានឹងកិច្ចខិតខំប្រឹងថ្នាក់ជាតិ។

ប្រភព ៖ ជំងឺកូវីដ ១៩ ៖ របៀបដាក់បញ្ចូលប្រជាជនដែលមិនទទួលបានការយកចិត្តទុកដាក់ និងងាយរងគ្រោះក្នុងការផ្សព្វផ្សាយពីហានិភ័យ និងការជំរុញការចូលរួមរបស់សហគមន៍ (២០២០) សហព័ន្ធកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌និងអង្គការសុខភាពពិភពលោក។

- នៅពេលទទួលបានសម្ភារផ្សព្វផ្សាយដែលផ្តល់ភាពងាយស្រួលដល់អ្នកអាន និងអាចទទួលបាន ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជំនួយមនុស្សធម៌នៅមូលដ្ឋានអ្នកផ្តល់សេវាថែទាំសុខភាពនិងបណ្តាញផ្សព្វផ្សាយនៅមូលដ្ឋានអាចជាដៃគូយ៉ាងសំខាន់សម្រាប់នគរបាលនៅពេលខិតខំចូលដល់គ្រួសារដែលពិបាកទាក់ទង។ ចំណុចនេះ រួមមានការជួយចែកខិតប័ណ្ណ (ទាំងលាយលក្ខណ៍អក្សរ និងក្រាហ្វ និងក្នុងទម្រង់ផ្សេងៗដែលងាយស្រួលប្រើប្រាស់) ដោយមានព័ត៌មានដែលទប់ស្កាត់ឥរិយាបថហិង្សានៅផ្ទះ និងផ្តល់លេខទូរស័ព្ទជំនួយឬធនធានផ្សេងទៀតដើម្បីឱ្យជនរងគ្រោះទទួលបានធនធានដែលបំពេញតម្រូវការរបស់ពួកគេ[710]។

"ការបង្កើតភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈក្នុងអំឡុងជំងឺរាតត្បាត ជួយធានាថា ស្ត្រីគ្រប់រូបអាចប្រើប្រាស់ទូរស័ព្ទចល័ត។ ប្រព័ន្ធយុត្តិធម៌អាចមានភាពសកម្មឡើងវិញ៖ យើងត្រូវចាប់ផ្តើមរិះរកវិធីដែលកាន់តែមាននិរន្តរភាពក្នុងការផ្តល់យុត្តិធម៌ ដូចជា ការប្រើប្រាស់ដីកាបណ្តោះអាសន្នដើម្បីទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការរំលោភសិទ្ធិ"។

Phumzile Mlambo-Ngcuka នាយកប្រតិបត្តិ UN Women (2020)

- ភាពជាដៃគូជាមួយក្រុមហ៊ុន និងគ្លីនិកវេជ្ជសាស្ត្រ ដើម្បីជំរុញការចូលរួមរបស់បុគ្គលិកជួរមុខសំខាន់ៗ[711] ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីក្រោមស្ថានភាពវិបត្តិសុខភាពសាធារណៈ ទាមទារការចូលរួមបែបសហការរបស់នគរបាលក្នុងការផ្តល់ការណែនាំ និងការបណ្តុះបណ្តាលដល់បុគ្គលិកទាំងនេះ ស្តីពីតួនាទី ក្នុងនាមជាអ្នកនៅជិតកន្លែងកើតហេតុ[712]។ ចំណុចចាប់ផ្តើមសំខាន់ៗសម្រាប់អ្នកនៅជិតកន្លែងកើតហេតុ ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី អាចលេចឡើងក្នុងពេលធ្វើអន្តរាគមន៍ជាមួយប្រជាជនយ៉ាងច្រើន ដូចជា នៅស្ថានីយ៍ធ្វើតេស្តរក និងតាមដានជំងឺកូវីដ ១៩។ ទោះជាយ៉ាងណា គំនិតផ្តួចផ្តើមនេះត្រូវផ្តោតអាទិភាពលើគោលការណ៍"មិនបង្កគ្រោះថ្នាក់" ក្នុងមធ្យោបាយកំណត់អត្តសញ្ញាណជនរងគ្រោះ (ឧ. ក្នុងកម្រងសំណួរ)។ ទន្ទឹមនឹងនេះ ស្ថានីយ៍ធ្វើតេស្តរកនិងតាមដានជំងឺកូវីដ ១៩ អាចកសាងការយល់ដឹងស្តីពីអំពើហិង្សាលើស្ត្រី និងយេនឌ័រ និងផ្តល់ព័ត៌មានស្តីពីយន្តការរាយការណ៍។
- ការបន្តភាពជាដៃគូរឹងមាំជាមួយក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ឬអន្តរការីអ៊ីនធឺណិត អាចផ្តល់ប្រយោជន៍យ៉ាងច្រើនដល់នគរបាល។ ឧ. ការគាំទ្រការដាក់ឱ្យប្រើប្រាស់កម្មវិធី (app) ស្តីពីអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងទូរស័ព្ទចល័តដើម្បីបំពេញបន្ថែមលើខ្សែទូរស័ព្ទជំនួយ គឺជាជម្រើសដ៏ល្អសម្រាប់ជនរងគ្រោះដែលជាប់នៅផ្ទះជាមួយជនបំពានពេញមួយថ្ងៃ។ ឱកាសបង្កើតភាពជាដៃគូផ្សេងទៀតអាចរួមមានការសហការគ្នាចែករំលែកដំបូន្មានសុវត្ថិភាពអនឡាញ តាមរយៈបណ្តាញសង្គម GSP ទូរស័ព្ទ។ល។ សម្រាប់ស្ត្រី យុវជន និងកុមារ និង/ឬផ្តល់នីតិវិធីរាយការណ៍ និងដាក់បណ្តឹងដែលមានតម្លាភាពនិងងាយស្រួលប្រើប្រាស់សម្រាប់ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍[713]។
- ដោយសារផលប៉ះពាល់យូរអង្វែងនៃជំងឺរាតត្បាត/ជំងឺឆ្លង លើសមត្ថភាពរបស់តុលាការផ្លូវការក្នុងការឆ្លើយតបទៅនឹងតម្រូវការយុត្តិធម៌របស់ស្ត្រីបូករួមនឹងការសន្មតពីការគ្មានលទ្ធភាពទទួលបានយន្តការយុត្តិធម៌ក្នុងពេលមានវិបត្តិ ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រីអាចស្វែងរកជំនួយពីប្រព័ន្ធយុត្តិធម៌បែបទំនៀមទម្លាប់និងក្រៅផ្លូវការសម្រាប់ការការពារ និងដោះស្រាយ[714]។ ដូច្នេះ ស្ថាប័ននគរបាលគួរប្រមាលមើល និងទទួលខុសត្រូវលើរបៀបដែលនិន្នាការថ្មីនេះអាចបង្កផលប៉ះពាល់លើការរាយការណ៍ក្នុងតំបន់មួយចំនួន និងពង្រីក ឬពង្រឹងភាពជាដៃគូជាមួយតួអង្គនៃប្រព័ន្ធយុត្តិធម៌ក្រៅផ្លូវការ ឬ បែបទំនៀមទម្លាប់ក្នុងដំណើរនេះ[715]។

### ប្រអប់ ៦

**ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩៖ ភាពជាដៃគូរវាងនគរបាលនិងសង្គមស៊ីវិល**

នៅប្រទេសប្រេស៊ីល កម្មវិធី (apps) ជាច្រើន ដូចជា SOS Mulher ក្នុងរដ្ឋ Sao Paulo កំពុងត្រូវបានបង្កើតឡើងក្រោមភាពជាដៃគូរវាងនគរបាល និងសង្គមស៊ីវិល ដើម្បីរាយការណ៍ពីឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារក្នុងពេលផ្តាច់ចេញពីសង្គម ក៏ដូចជាការមិនអនុលោមតាមវិធានការការពារក្នុងគ្រាអាសន្នដែលបានដាក់លើជនល្មើស

709. ចេញពីការសម្របសម្រួលជាសកលទៅជាយុទ្ធសាស្ត្រក្នុងមូលដ្ឋាន៖វិធីសាស្ត្រអនុវត្តន៍ក្នុងការទប់ស្កាត់ដោះស្រាយនិងចងក្រងករណីអំពើហិង្សាក្នុងគ្រួសារក្នុងវិបត្តិជំងឺកូវីដ១៩ ឯកសារពន្យល់ពិភាក្សា (២០២០) MADRE, Media Matters for Women, MenEngage Alliance, Nobel Women´s Initiative, OutRight Action International, Women Enabled International, and Women´s International League for Peace and Freedom (WILPF), at: https://www.wilpf.org/wp-content/uploads/2020/04/MADRE-Domestic-Violence-Under-COVID-19-Briefing-Paper_4.21.20.pdf
710. ជំងឺកូវីដ ១៩ ៖ របៀបដាក់បញ្ចូលប្រជាជនដែលមិនទទួលបានការយកចិត្តទុកដាក់ និងងាយរងគ្រោះ ក្នុងការផ្សព្វផ្សាយពីហានិភ័យ និងការជំរុញការចូលរួមរបស់សហគមន៍ (២០២០)។ សហព័ន្ធកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌ និងអង្គការសុខភាពពិភពលោក ៖ https://reliefweb.int/sites/reliefweb.int/files/resources/COVID-19_CommunityEngagement_130320.pdf
711. អាស្រ័យលើបរិបទបុគ្គលិកសំខាន់ៗអាចរួមមាន ឱសថការី បុគ្គលិកហាងលក់គ្រឿងទេស គិលានុបដ្ឋាក អ្នកទទួលភ្ញៀវនៅគ្លីនិកវេជ្ជសាស្ត្រ។ល។
712. សូមមើលអភិក្រម "អ្នកនៅជិតកន្លែងកើតហេតុ" Graham Goulden for Cultivating Minds UK, https://grahamgoulden.com/cultivating-mindsuk/about/
713. អំពើហិង្សាលើស្ត្រីនិងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតនិងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ក្នុងវិបត្តិជំងឺកូវីដ១៩(២០២០) ឯកសារសង្ខេបរបស់ UN Women https://www.unwomen.org/en/digital-library/publications/2020/04/brief-online-and-ict-facilitated-violence-againstwomen-and-girls-during-covid-19
714. យុត្តិធម៌សម្រាប់ស្ត្រីក្នុងវិបត្តិជំងឺកូវីដ ១៩ (២០២០) ឯកសារសង្ខេបរបស់ UN Women /media/headquarters/attachments/sectionslibrary/publications/2020/justice-for-women-amidst-covid-19-en.pdf?la=en&vs=4857
715. យុត្តិធម៌សម្រាប់ស្ត្រីក្នុងវិបត្តិជំងឺកូវីដ១៩ (២០២០) ឯកសារសង្ខេបរបស់ UN Women /media/headquarters/attachments/sections/library/publications/2020/justice-for-women-amidst-covid-19-en.pdf?la=en&vs=4857

ដែលអាចនាំឱ្យមានការឃុំខ្លួន និងការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។

នៅចក្រភពអង់គ្លេស នគរបាល Cumbria បានស្នើឱ្យអ្នករត់សំបុត្រអ្នកដឹកជញ្ជូនឥវ៉ាន់ក្រុមហ៊ុនដឹកជញ្ជូនអាហារ និងបុគ្គលិកសំខាន់ៗដែលចុះដល់ផ្ទះប្រជាជនពិនិត្យមើលសញ្ញានៃការរំលោភបំពានរួចរាយការណ៍ទៅនាយកដ្ឋាននគរបាល។

នគរបាលអ៊ីតាលី កំពុងប្រើប្រាស់កម្មវិធី YouPol ដើម្បីជួយដល់យុវជនក្នុងការរាយការណ៍ពីការរករឿងរ៉ៃខាន និងការជួញដូរថ្នាំញៀន ប៉ុន្តែបច្ចុប្បន្ន កម្មវិធីនេះត្រូវបានកែសម្រួលដើម្បីផ្តល់ជម្រើសមួយដល់ជនរងគ្រោះក្នុងការផ្ញើសារទៅនគរបាលដោយមិនឱ្យដៃគូរបស់ខ្លួនដឹង។បណ្តាញជាតិអ៊ីតាលីសម្រាប់ការផ្តល់ជម្រកដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ (DiRe) បានបើកខ្សែទូរស័ព្ទបន្ទាន់ និង Skype calls ដើម្បីផ្តល់ជំនួយ ហើយអង្គការដែលធ្វើការងារពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារនៅអ៊ីតាលីប្រហែល២/៣មានខ្សែទូរស័ព្ទជំនួយ។

នៅរដ្ឋ Maharashtra ក្នុងប្រទេសឥណ្ឌា នគរបាលរដ្ឋបានចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន Akshara និងក្រុមការងារពិសេសទទួលបន្ទុកកិច្ចការនារី និងកុមារ (TISS) នៃក្រសួងអភិវឌ្ឍន៍ស្ត្រី និងកុមារ (ស្ថិតក្នុងប៉ុស្តិ៍នគរបាល) ដើម្បីរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានស្តីពីលេខសង្គ្រោះបន្ទាន់របស់នគរបាល (១០០) (ជាទូទៅមិនពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ) សម្រាប់ដាក់បណ្តឹងនិងផ្តល់ការគាំទ្រក្នុងពេលបិទខ្ទប់ដើម្បីជានាវិសាលភាពជំទូលាយ និងផ្សព្វផ្សាយគំនិតផ្តួចផ្តើមនេះដល់ឥស្សរជន និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត។ឥស្សរៈជនដែលមានប្រជាប្រិយភាព ដូចជា តារា Bollywood ជួរមុខ និងអត្តពលិកត្រូវបានស្នើឱ្យជំរុញស្ត្រី "រាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារ"ដើម្បីឱ្យមានការញញើតនិងកំណត់ថាអំពើនេះជាបទល្មើស។

ប្រភព ៖ ជំងឺកូវីដ ១៩ និងការផ្តល់សេវាសំខាន់ៗដល់ជនរងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងក្មេងស្រី (២០២០) ឯកសារសង្ខេបរបស់ UN Women និងយុត្តិធម៌សម្រាប់ស្ត្រីក្នុងវិបត្តិជំងឺកូវីដ ១៩ (២០២០) ឯកសារសង្ខេបរបស់ UN Women និងផលប៉ះពាល់នៃការបិទខ្ទប់លើអំពើហិង្សាក្នុងគ្រួសារ (២០២០) Akshara Center។

## អំពើហិង្សាលើស្ត្រី និង ក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

- យោងតាម EUROPOL[716] ក្នុងវិបត្តិជំងឺកូវីដ ១៩ និងការរឹតត្បិតការដើរហើរ មានការកើនឡើងយ៉ាងគំហុកនៃការប៉ុនប៉ងចូលប្រើប្រាស់វេទិកាខុសច្បាប់តាមប្រព័ន្ធអ៊ីនធឺណិត ដែលបង្ហាញសម្ភាររំលោភបំពានផ្លូវភេទកុមារ និងសកម្មភាពរបស់អ្នកដែលព្យាយាមបញ្ចុះបញ្ចូលយុវជនឱ្យធ្លាក់ក្នុងស្ថានភាពកេងប្រវ័ញ្ច។ និន្នាការនេះទាមទារឱ្យស្ថាប័ននគរបាលពង្រឹងពិធីសារផ្ទៃក្នុង និងក្រៅ ប្រកបដោយឯកទេស ច្បាស់លាស់ និងមានប្រសិទ្ធផល និងក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ដែលដោះស្រាយករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិតក្នុងគ្រាអាសន្ន[717]។
- អ្នករាយការណ៍ពិសេសទទួលបន្ទុកការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទកុមារ រាយការណ៍ថា ការរឹតត្បិតការធ្វើដំណើរដោយសារជំងឺកូវីដ៩បានបង្កើតទម្រង់ថ្មីនៃការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានកុមាររួមទាំងការប៉ុនប៉ងបង្កើតសេវា "ដឹកជញ្ជូន" ឬសេវា "ក្នុងរថយន្ត" សម្រាប់ការការកេងប្រវ័ញ្ចផ្លូវភេទកុមារ[718]។
- ទម្រង់ផ្សេងៗនៃអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិតមានការកើនឡើង (ចាប់ពីការឈ្លបចាប់ ការរករឿងរ៉ៃខាន ការបៀតបៀនផ្លូវភេទ និងការស្វែងរកការរួមភេទ) ដោយសារស្ត្រី និងក្មេងស្រីរាប់លាននាក់កំពុងប្រើប្រាស់សេវាបញ្ជូនរូបភាព និងសំឡេង (video conferencing) សម្រាប់ការធ្វើការ និងសិក្សា។ ក្នុងករណីដែលបានរាយការណ៍មួយចំនួន សមាជិកមួយចំនួននៃអង្គការសិទ្ធិស្ត្រីបានទទួលវីដេអូអាសអាភាសយ៉ាងច្រើនក្នុងពេលដែលពួកគេចុះឈ្មោះចូលរួមក្នុងព្រឹត្តិការណ៍សង្គមតាមរយៈកម្មវិធី Chat[719]។ សម្រាប់ឧទាហរណ៍ សូមមើលប្រអប់១៥ (ខាងក្រោម)។

716. ការបិទខ្ទប់ដោយសារវីរុសកូរ៉ូណា បង្កើនហានិភ័យនៃការរំលោភបំពានកុមារតាមប្រព័ន្ធអ៊ីនធឺណិត(ការលើកឡើងដោយអង្គការសប្បុរសធម៌)។ The Guardian (2020) https://www.theguardian.com/world/2020/apr/02/coronavirus-lockdown-raises-risk-of-online-child-abuse-charity-says

717. អំពើហិង្សាលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធអ៊ីនធឺណិត និងអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលសម្រួលដោយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិបត្តិជំងឺកូវីដ ១៩ (២០២០) ឯកសារសង្ខេបរបស់ UN Women https://www.unwomen.org/en/digital-library/publications/2020/04/brief-online-and-ict-facilitated-violence-against-women-and-girls-during-covid-

### ប្រអប់ ៧

**ការវាយប្រហារក្នុងកម្មវិធី Zoom និងគ្រោះថ្នាក់ចំពោះសង្គមស៊ីវិល**

ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើសិទ្ធិស្ត្រី និងដឹកនាំដោយស្ត្រី ដែលកំពុងខិតខំពង្រឹងមូលដ្ឋានភស្តុតាង និងកសាងសមត្ថភាពស្តីពីអំពើហិង្សាលើស្ត្រី និងអំពើហិង្សាលើកុមារនៅទូទាំងពិភពលោក គំនិតផ្តួចផ្តើមស្រាវជ្រាវពីអំពើហិង្សាផ្លូវភេទ (SVRI) បានប្រឈមនឹងការរំលោភបំពាននេះដោយផ្ទាល់។ ថ្មីៗនេះ សិក្ខាសាលាតាមប្រព័ន្ធអ៊ីនធឺណិតស្តីពីការពន្លឿនការស្រាវជ្រាវដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីរងការវាយប្រហារតាមកម្មវិធី Zoom។ កិច្ចប្រជុំត្រូវបានគេលួចចូលប្រើប្រាស់ និងបង្ហាញសម្ភារផ្លូវភេទនិងរើសអើងពូជសាសន៍។ទម្រង់នៃអំពើហិង្សាដែលបង្កឡើងលើអ្នកដែលចូលរួម ធ្វើបទបង្ហាញ និងរៀបចំព្រឹត្តិការណ៍នេះ អាចបង្កផលវិបាកយ៉ាងជ្រាលជ្រៅលើសុខុមាលភាពរបស់បុគ្គលដែលរងគ្រោះដោយអំពើហិង្សានេះ និងអង្គការនេះ ក្នុងការរៀបចំព្រឹត្តិការណ៍នាពេលអនាគតដែលមានលក្ខណៈបើកទូលាយ ប្រកបដោយបរិយាបន្ន និងងាយស្រួលប្រើប្រាស់សម្រាប់មនុស្សគ្រប់រូប។

ប្រភព ៖ សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិតក្នុងពិភពដែលពោរពេញដោយការផ្លាស់ប្តូរ ៖ ជំងឺកូវីដ ១៩ និងអំពើហិង្សាតាមប្រព័ន្ធបច្ចេកវិទ្យា (២០២០) SVRI

## ទំនាក់ទំនងបែបកេងប្រវ័ញ្ច

- ការស្រុតចុះនៃសេដ្ឋកិច្ចដែលអាចបណ្តាលមកពីវិធានការតម្រូវឱ្យធ្វើចត្តាឡីស័កអាចបង្កការរើសអើងយ៉ាងខ្លាំងលើស្ត្រី និងក្មេងស្រី ពាក់ព័ន្ធនឹងអំពើហិង្សា និងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងចំណោមបញ្ហាផ្សេងទៀត។ ចំណុចនេះអាចបណ្តាលមកពីពីការបិទសាលារៀន ឬគ្រួសារដែលឱ្យក្មេងស្រីឈប់រៀនដើម្បីធ្វើការ ដែលអាចនាំទៅកេពលកម្មដោយបង្ខំដូចជាការកេងប្រវ័ញ្ចផ្លូវភេទ[720]។ ក្រៅពីនេះ អសន្តិសុខស្បៀង ឬការពឹងផ្អែកកាន់តែខ្លាំងលើជំនួយដើម្បីចិញ្ចឹមជីវិតបានធ្វើឱ្យស្ត្រី និងក្មេងស្រីប្រឈមនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន ឬពលកម្មដោយបង្ខំពីសំណាក់បុគ្គលិកជំនួយ និងមន្ត្រីរដ្ឋគ្រប់ជាន់ថ្នាក់[721]។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលកំពុងលេចឡើង

- ក្នុងករណីមួយចំនួន មនុស្សវ័យជំទង់ពាក់ព័ន្ធនឹងឥរិយាបថហិង្សានៅផ្ទះ ហើយស្ត្រី (ម្តាយ) ក្លាយជាគោលដៅនៃអំពើហិង្សានេះ។ ទោះជាយ៉ាងណា ប្រេវ៉ាឡង់នៃអំពើហិង្សាទម្រង់នេះមិនសុទ្ធតែត្រូវបានកត់សម្គាល់ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនោះទេ។ ហានិភ័យចំពោះសុវត្ថិភាពរបស់ស្ត្រីច្រើនតែកើនឡើងក្នុងបរិបទដែលកុមារជំទង់ដែលមានឥរិយាបថហិង្សាត្រូវបានបង្ខំឱ្យស្ថិតក្រោមការបិទខ្ទប់នៅផ្ទះ[722]។
- ក្រៅពីនេះ មានហានិភ័យកាន់តែច្រើននៃអំពើហិង្សា និងការបៀតបៀនលើបុគ្គលិក សុខាភិបាលជួរមុខជាស្ត្រី។ របាយការណ៍ពីប្រទេសសិង្ហបុរី និងចិន បង្ហាញពីកម្រិតខ្ពស់នៃការបំភិតបំភ័យនិងភាពគឃ្លើនចំពោះអ្នកជំនាញសុខភាពជាស្ត្រី ជាពិសេស គិលានុបដ្ឋាក ក្នុងអំឡុងវិបត្តិជំងឺរាតត្បាតកូវីដ ១៩[723]។
- ការដាក់ពង្រាយកងទ័ពក្នុងតំបន់ស៊ីវិល អាចបង្កើនហានិភ័យនៃការរំលោភសិទ្ធិមនុស្សលើស្ត្រី និងកុមារ រួមទាំងទំនាក់ទំនងបែបកេងប្រវ័ញ្ច។ ការគ្រប់គ្រងហានិភ័យនគរបាល និងការវិភាគយេនឌ័រពាក់ព័ន្ធ គួរជានាការដាក់បញ្ចូល និងការពិភាក្សាពីវិធានការកាត់បន្ថយហានិភ័យ ដូចជា នីតិវិធីប្រតិបត្តិស្តង់ដារ និងក្រមប្រតិបត្តិដើម្បីដោះស្រាយហានិភ័យសិទ្ធិមនុស្សជាមួយមេបញ្ជាការកងទ័ពដើម្បីសម្របសម្រួល និងផ្តោតសំខាន់លើយុទ្ធសាស្ត្រទប់ស្កាត់។

718. ជំងឺកូវីដ ១៩ ៖ តម្រូវការបន្ទាន់នៃសេវាការពារកុមារដើម្បីកាត់បន្ថយហានិភ័យនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារទូទាំងពិភពលោក (២០២០)។ Mama Fatima Singhateh អ្នករាយការណ៍ពិសេសទទួលបន្ទុកការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ៖ https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25865&LangID=E
719. ហានិភ័យនៃការស្វែងរកការរួមភេទតាមប្រព័ន្ធអ៊ីនធឺណិតកើនឡើងនៅពេលដែលវីរុសកូរ៉ូណាជំរុញឱ្យមានការធ្វើការនៅផ្ទះ។ Reuters (2020) https://www.reuters.com/article/us-women-rights-cyberflashing-trfn-idUSKBN2153HG
720. នៅអាហ្វ្រិកខាងលិចការបិទសាលារៀនដោយសារជំងឺរាតត្បាតអេបូឡាបានធ្វើឱ្យក្មេងស្រីប្រឈមនឹងការកេងប្រវ័ញ្ចផ្លូវភេទនិងអំពើហិង្សានិងបណ្តាលឱ្យមាន"ការកើនឡើងយ៉ាងគំហុក"នៃការមានផ្ទៃពោះវ័យជំទង់ និងការឆាប់រៀបការ ក្នុងតំបន់មួយចំនួនដែលរងផលប៉ះពាល់ដោយសារក្មេងស្រីកាន់តែច្រើនបានបោះបង់ការសិក្សា។ Fraser, E. (2020). Impact of COVID-19 Pandemic on Violence against Women and Girls. UKAid, WAG Helpdesk Research Report in World Bank. 2020. Gender Dimensions of the COVID-19 Pandemic. Washington, D.C.: World Bank Group : http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic
721. របាយការណ៍ស្តីពីវិបត្តិជំងឺអេបូឡានៅប្រទេសសៀរ៉ាឡេអូននិងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ គូសបញ្ជាក់ថា ការកេងប្រវ័ញ្ចផ្លូវភេទកើតមានជាទូទៅ និងបង្កឡើងដោយមន្ត្រីរដ្ឋ និងសមាជិកសហគមន៍ដែលមានតួនាទីពង្រឹងវិធានការ ចត្តាឡីស័ក។ សូមមើល Gender Dimensions of the COVID-19 Pandemic (English). Washington, D.C. : World Bank Group 2020, at: http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic and Fraser, E. (2020). Impact of COVID-19 Pandemic on Violence against Women and Girls. UKAid, WAG Helpdesk Research Report, at: http://www.sddirect.org.uk/media/1881/vawg-helpdesk-284-covid-19-and-vawg.pdf

## ការប្រមូលទិន្នន័យ

**អ្នកមិនអាចគ្រប់គ្រងអ្វីដែលអ្នកមិនអាចវាស់វែង ឬ អ្វីដែលអ្នកមិនវាស់វែងបានឡើយ។**

- ការច្បាមយកព័ត៌មានស្ដីពីគ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី នឹងបង្កើនការយល់ដឹងទូទៅស្ដីពីលក្ខណៈនៃអំពើហិង្សា និងជួយកំណត់រកផ្នែកដែលត្រូវមានការឆ្លើយតបដែលកែសម្រួលទៅតាមតម្រូវការ[724]។ ការរៀបចំជាស្រេចនូវប្រព័ន្ធដែលតាមដាន និងវិភាគនិន្នាការក្នុងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី នឹងកំណត់រកនិន្នាការថ្មីៗដែលលេចឡើងក្នុងអំឡុងវិបត្តិសុខភាពសាធារណៈនិង/ឬវិបត្តិមនុស្សធម៌។
- ក្នុងការដោះស្រាយគំរូថ្មីៗនិងកំពុងវិវត្តនិងប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីដោយប្រុងប្រយ័ត្នគួរមានប្រព័ន្ធតាមដានលើទំហំ និងលក្ខណៈនៃការអំពាវនាវរកជំនួយ។
- វិធានការក្នុងពេលមានវិបត្តិ ដូចជាវិធានការដែលត្រូវបានអនុវត្តក្នុងវិបត្តិជំងឺរាតត្បាតកូវីដ ១៩ ឬការផ្ទុះជំងឺអេបូឡា ធ្វើឱ្យការបកស្រាយទិន្នន័យអំពើហិង្សាលើស្ត្រី និងក្មេងស្រីមានការលំបាក។ ឧ. ក្នុងប្រទេសមួយចំនួន ការរាយការណ៍ ការអំពាវនាវ និងការប្រើប្រាស់សេវាមានការថយចុះក្នុងពេលធ្វើចត្តាឡីស័ក ព្រោះស្ត្រីនិងក្មេងស្រីយល់ថាពួកគេមិនអាចចាកចេញពីផ្ទះ ឬភ័យខ្លាចដៃគូដែលប្រព្រឹត្តបំពាន ស្ដាប់លឺការសន្ទនាតាមទូរស័ព្ទ។ ចំណុចនេះធ្វើឱ្យមានភាពខុសគ្នានៅពេលបកស្រាយអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសអំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលធ្វើឱ្យគេមិនទុកចិត្តលើប្រភពទិន្នន័យតែមួយ ដូចជា លេខទូរស័ព្ទជំនួយសម្រាប់ប្រើប្រាស់ជាសូចនាករតំណាងក្នុងការកំណត់ និងយល់ពីប្រេវ៉ាឡង់[725]។
- Sphere Handbook (២០១៨) ស្នើឱ្យមានការបែងចែកទិន្នន័យជាប្រភេទសមស្របទៅតាមបរិបទដើម្បីយល់ពីភាពខុសគ្នាដោយផ្អែកលើភេទ ឬយេនឌ័រ អាយុ ពិការភាព ភូមិសាស្ត្រ ជាតិពន្ធុ សាសនា វណ្ណៈ ឬកត្តាផ្សេងទៀតដែលអាចរឹតត្បិតលទ្ធភាពទទួលបានជំនួយដោយមិនលម្អៀង[726]។
- មិនបង្កគ្រោះថ្នាក់ ៖ ត្រូវគោរពសុវត្ថិភាព ឯកជនភាព និងការរក្សាការសម្ងាត់របស់អ្នកតបសម្ភាសន៍ជាស្ត្រី និងក្មេងស្រីជានិច្ច ព្រោះការវាស់វែងអំពើហិង្សាជាកិច្ចការដែលធ្វើឱ្យរំជួលអារម្មណ៍នៅគ្រប់កាលៈទេសៈទាំងអស់។ សុវត្ថិភាពផ្ទាល់ខ្លួនត្រូវតែមានអាទិភាពជាងការប្រមូលទិន្នន័យ។

722. ការឆ្លើយតបទៅនឹងវីរុសកូរ៉ូណា (កូវីដ១៩)៖ឯកសារសង្ខេបតាមប្រធានបទរបស់UNODC ស្ដីពីអំពើហិង្សាផ្អែកតាមយេនឌ័រលើស្ត្រី និងក្មេងស្រី (២០២០) UNODC។
723. See Fraser, E. (2020). Impact of COVID-19 Pandemic on Violence against Women and Girls. UKAid, WAG Helpdesk Research Report in World Bank. 2020. Gender Dimensions of the COVID-19 Pandemic. Washington, D.C. : World Bank Group, at: http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic
724. ផ្ដើមចេញពីការសម្របសម្រួលជាសកលឆ្ពោះទៅរកយុទ្ធសាស្ត្រក្នុងមូលដ្ឋាន ៖ អភិក្រមអនុវត្តន៍ក្នុងការទប់ស្កាត់ ដោះស្រាយ និងចងក្រងឯកសារស្ដីពីអំពើហិង្សាក្នុងគ្រួសារ ក្នុងវិបត្តិជំងឺកូវីដ ១៩ ឯកសារពន្យល់ពិភាក្សា (២០២០) MADRE, Media Matters for Women, MenEngage Alliance, Nobel Women's Initiative, OutRight Action International, Women Enabled International, and Women's International League for Peace and Freedom (WILPF), at: https://www.wilpf.org/wp-content/uploads/2020/04/MADRE-Domestic-Violence-Under-COVID-19-Briefing-Paper_4.21.20.pdf
725. 'Has it become too dangerous to measure violence against women?' Kelli Rogers, 06 May 2020, https://asiapacific.unfpa.org/en/news/covid-19-has-it-become-too-dangerous-measure-violence-against-women
726. Sphere Association. The Sphere Handbook: Humanitarian Charter and Minimum Standards in Humanitarian Response,

## ប្រអប់ ៨

**ហេតុអ្វីចាំបាច់ត្រូវប្រមូលទិន្នន័យក្នុងអំឡុងមានវិបត្តិសុខភាពសាធារណៈ?**



រូបថតទទួលបានពី ៖ ILO/Jennifer A. Patterson (ប្រទេសកូដឌីវ័រ)

ទិន្នន័យជាឧបករណ៍ដ៏សំខាន់សម្រាប់ស្វែងយល់ពីរបៀប និងមូលហេតុដែលជំងឺរាតត្បាត ដូចជា ជំងឺកូវីដ ១៩ អាចធ្វើឱ្យករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី មានការកើនឡើង។ ទិន្នន័យអាចជួយកំណត់រកកត្តាហានិភ័យថាតើការរកបានសេវាសម្រាប់ជនរងគ្រោះជាស្ត្រីដែលប្រឈមនឹងអំពើហិង្សា រងផលប៉ះពាល់ដូចម្តេច ថាតើលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាទាំងនេះ និងការស្វែងរកជំនួយពីប្រភពផ្លូវការ និងក្រៅផ្លូវការ រងផលប៉ះពាល់ដូចម្តេច និងតម្រូវការថ្មីៗ (រយៈពេលខ្លី និងរយៈពេលមធ្យម) ដែលលេចឡើង។ ទិន្នន័យទាំងនេះមានសារៈសំខាន់សម្រាប់ការរៀបចំយុទ្ធសាស្ត្រផ្អែកតាមភស្តុតាង ដែលឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី កាត់បន្ថយហានិភ័យ និងសម្រាលផលប៉ះពាល់អវិជ្ជមានទាំងក្នុង និងក្រោយវិបត្តិជំងឺរាតត្បាត។ ទិន្នន័យទាំងនេះនឹងផ្តល់ចំណេះដឹងសំខាន់ៗនិងមូលដ្ឋានព័ត៌មានសម្រាប់ការបង្កើតអន្តរាគមន៍ដែលកែសម្រួលតាមតម្រូវការ ដែលអាចមានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងគ្រាអាសន្ន និងវិបត្តិសុខភាពសាធារណៈនាពេលអនាគត។

ប្រភព ៖ ការប្រមូលទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងវិបត្តិជំងឺកូវីដ ១៩ (UN Women and WHO, 2020)

## ការបន្ធូរបន្ថយការបិទខ្ទប់ ៖ ការឆ្លុះបញ្ចាំង និងការរៀនសូត្រ

ក្នុងពេលរៀបរៀងឯកសារនេះ ជំងឺរាតត្បាតកូវីដ ១៩ បានបង្កភាពមិនប្រាកដប្រជាជាសកល មិនដឹងពេលណាទើបបញ្ចប់ ហើយពេលណាអាចវិលត្រឡប់ទៅរកភាពប្រក្រតីវិញបាន។

ខណៈប្រទេសនានាចាប់ផ្តើមបន្ធូរបន្ថយវិធានការតម្រូវឱ្យធ្វើចត្តាឡីស័ក/បិទខ្ទប់ ហើយសេដ្ឋកិច្ចចាប់ផ្តើមងើបឡើងវិញដោយសន្សឹមៗ ប្រទេសផ្សេងទៀតកំពុងប្រឈមនឹងការកើនឡើងនៃករណីជំងឺកូវីដ ១៩ និងករណីស្លាប់ដោយសារជំងឺនេះ។ ទន្ទឹមនឹងនេះ ប្រទេសមួយចំនួនកំពុងប្រឈមនឹងរលកទីពីរ (ទោះជាមានទំហំតូចជាងមុនក្តី) នៃជំងឺរាតត្បាតនេះ ក្រោយការបន្ធូរបន្ថយវិធានការ។

**ពិចារណាពីតួនាទីរបស់អង្គការស្ត្រីក្នុងផែនការស្តារឡើងវិញ និងដំណោះស្រាយរយៈពេលវែងលើការកើនឡើងនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងវិបត្តិជំងឺកូវីដ ១៩។**

សម្រាប់បណ្តាប្រទេសដែលអាចគ្រប់គ្រងការឆ្លងរាលដាលជំងឺរាតត្បាតដោយជោគជ័យនិងអាចរក្សាសេដ្ឋកិច្ចបើកទូលាយទន្ទឹមនឹងការទប់ស្កាត់ដែលមានសម្ពាធយ៉ាងខ្លាំងលើប្រព័ន្ធសុខាភិបាលជាតិ ប្រព័ន្ធយុត្តិធម៌អាចចាប់ផ្តើមវិលទៅរកសកម្មភាពប្រក្រតីវិញ ទោះបីជាត្រូវគោរពវិធានការសុខាភិបាលសាធារណៈធូរស្រាលជាងមុនក្តី។ សម្រាប់អ្នកផ្តល់សេវាសំខាន់ៗទាំងអស់ក្នុងការបន្តផ្តល់យុត្តិធម៌ការបន្ធូរបន្ថយវិធានការនឹងផ្តល់ឱកាសថ្មីៗសម្រាប់ធ្វើការឆ្លុះបញ្ចាំង និងរៀនសូត្រ។

១.ទោះបីជាមានបញ្ហាប្រឈមនិងផលប៉ះពាល់អវិជ្ជមាននៃជំងឺរាតត្បាតកូវីដ ១៩ ក្តី ក៏ជំងឺនេះបានរំលេចតួនាទីផ្តល់ "សេវាសាធារណៈ" របស់នគរបាលមូលដ្ឋាន រួមទាំងតួនាទីដ៏សំខាន់របស់ពួកគេក្នុងស្ថានភាពវិបត្តិសុខភាពសាធារណៈមិនមែនត្រឹមតែតួនាទីដែលត្រូវបានផ្តល់ដែលមិនពាក់ព័ន្ធនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះបំផុត និងក្រុមភាគតិចនោះទេ។ ស្ថាប័ននគរបាលមួយចំនួនអាចទទួលបានការគាំទ្រមិនធ្លាប់មានពីសាធារណជនលើការងាររបស់ខ្លួន រួមទាំងការទទួលស្គាល់ហានិភ័យបន្ថែមដែលនគរបាល និងក្រុមគ្រួសាររបស់ពួកគេបានប្រឈមជារៀងរាល់ថ្ងៃក្នុងពេលដែលជំងឺរាតត្បាតនេះផ្ទុះឡើងខ្លាំង។ ស្ថាប័ននគរបាលមួយចំនួនប្រហែលជាអាចបង្កើតទំនាក់

ទំនងកាន់តែរឹងមាំ ជាមួយស្ថាប័នគាំទ្រជនរងគ្រោះ និងអង្គការសង្គមស៊ីវិល ឬយ៉ាងហោចណាស់បណ្តុះភាពជាដៃគូនាពេលអនាគត ក្នុងពេលប្រឈមនឹងបញ្ហារួមនៅពេលមានវិបត្តិ។

ទោះជាយ៉ាណា ការផ្ទុះបញ្ហាំងតែម្យ៉ាងមិនអាចទាញប្រយោជន៍ពីចំណុចវិជ្ជមានដែលច្បាមចេញពីបទពិសោធន៍ឆ្លើយតបនឹងជំងឺកូវីដ ១៩ ឡើយ។ ដើម្បីរក្សាភាពជាដៃគូសំខាន់ៗដែលបង្កផលប៉ះពាល់យ៉ាងខ្លាំងនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី នគរបាលត្រូវបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការរៀនសូត្រប្រកបដោយតម្លាភាព និងបរិយាបន្ន។
សំខាន់បំផុតស្ថាប័ននគរបាលគួរផ្អែកលើកម្លាំងផ្តួបដែលកើតចេញពីការជំរុញការចូលរួមយ៉ាងសកម្មរបស់អ្នកផ្តល់សេវាសំខាន់ៗផ្សេងទៀត រួមទាំងអង្គការសង្គមស៊ីវិល និងអ្នកជំនាញសិក្សាស្រាវជ្រាវក្នុងការពិនិត្យឡើងវិញលើវិធានការដែលបានធ្វើឡើងក្នុងអំឡុងវិបត្តិជំងឺរាតត្បាត/ជំងឺឆ្លងនេះជាពិសេសនៅពេលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ អនុសាសន៍ដែលទទួលបានពីការពិនិត្យឡើងវិញផ្ទៃក្នុង និងខាងក្រៅលើវិធានការរបស់នគរបាលក្នុងពេលបិទខ្ទប់/ធ្វើចត្តាឡីស័កដោយសារជំងឺកូវីដ១៩នឹងជួយដល់ការបង្កើតយុទ្ធសាស្ត្រនិងវិធានការថ្មីៗសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងតថភាពថ្មីរបស់យើងរួមទាំងការបណ្តុះបណ្តាលនិងអប់រំចាំបាច់សម្រាប់ស្ថាប័ននគរបាលដែលឆ្លើយតបនឹងយេនឌ័រ។ ប្រអប់ ១៧ និង ១៨ ( ខាងក្រោម ) ផ្តល់ឧទាហរណ៍ពីការវិភាគដោយឯករាជ្យលើការឆ្លើយតបដោយកងកម្លាំងពាក់ព័ន្ធទៅនឹងការផ្ទុះឡើងនៃជំងឺអេបូឡានៅអាហ្វ្រិកខាងលិច។

**ប្រអប់ ៩**

**មេរៀន និងអនុសាសន៍សម្រាប់វិស័យសន្តិសុខ ចេញពីបទពិសោធន៍នៃជំងឺអេបូឡានៅអាហ្វ្រិកខាងលិច (២០១៤-២០១៥)**[727]




នៅឆ្នាំ ២០១៧ DCAF ( មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការគ្រប់គ្រងវិស័យសន្តិសុខដែលក្រោយមកប្តូរទៅជាមជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធ តាមបែបប្រជាធិបតេយ្យ ) បានចេញផ្សាយរបាយការណ៍មានចំណងជើងថា "តួនាទីរបស់វិស័យសន្តិសុខក្នុងការឆ្លើយតបទៅនឹងវិបត្តិសុខភាព។មេរៀនពីជំងឺរាតត្បាតអេបូឡា២០១៤-២០១៥ និងអនុសាសន៍សម្រាប់សហភាពទន្លេ Mano និងរដ្ឋសមាជិក"។ រយៈពេលជាង ២ ឆ្នាំក្រោយមក ឯកសារនេះមានភាពពាក់ព័ន្ធបំផុតសម្រាប់ជំងឺកូវីដ ១៩ ដែលរាតត្បាតទូទាំងពិភពលោក និងផលវិបាកនៃជំងឺនេះលើកងកម្លាំងសន្តិសុខជុំវិញពិភពលោក។

របាយការណ៍នេះរួមបញ្ចូលតួអង្គក្នុងវិស័យសន្តិសុខដែលចូលរួមក្នុងការឆ្លើយតបនេះ ដូចតទៅ ៖ កងកម្លាំងប្រដាប់អាវុធជាតិ សេវាចារកម្ម សេវានគរបាល/អាវុធហត្ថ ឆ្មាំព្រំដែន និងការគ្រប់គ្រងព្រំដែន តួអង្គសន្តិសុខនៅមូលដ្ឋាន ដូចជា កងឈ្លប ការរៀបចំសន្តិសុខអន្តរជាតិ រដ្ឋាភិបាលជាតិ តួអង្គសង្គមស៊ីវិល (បណ្តាញផ្សព្វផ្សាយ ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់។ល។) អង្គការរដ្ឋាភិបាលថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិ ព្រមទាំងស្ថាប័នច្បាប់ និងរដ្ឋសភា។

របាយការណ៍នេះផ្តោតសំខាន់លើការផ្ទុះជំងឺអេបូឡា (EVD) នៅឆ្នាំ ២០១៤-២០១៥ នៅប្រទេសហ្គីណេ លីបេរីយ៉ា និងសៀរ៉ាឡេអូន ដែលសរុបមានជាង ២៨.០០០ ករណី និងស្លាប់ ១១.០០០ ករណី។ របាយការណ៍នេះលើកឡើងពីចំណុចខ្វះខាតជាច្រើនក្នុងការឆ្លើយតបរបស់កងកម្លាំងសន្តិសុខទៅនឹងការផ្ទុះជំងឺអេបូឡាដែលជាទូទៅត្រូវបានចែករំលែកដោយបណ្តាប្រទេសសំខាន់ៗ ដូចខាងក្រោម ៖

- ការពង្រឹងលក្ខន្តិកៈ និងបទបញ្ញត្តិសុខភាពកាន់តែមានការលំបាក ជាពិសេស លក្ខន្តិកៈ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការរក្សាសិទ្ធិមនុស្ស ទន្ទឹមនឹងការពង្រឹងបទបញ្ញត្តិ និងការការពារអាយុជីវិត និងទ្រព្យសម្បត្តិ។
- ជាទូទៅ គ្មានក្របខណ្ឌច្បាស់លាស់ស្តីពីតួនាទី និងការទទួលខុសត្រូវក្នុងពេលផ្ទុះឡើងដំបូង ដោយមិនសូវមានកិច្ចសហប្រតិបត្តិការរវាងបុគ្គលិកសុខាភិបាល និងបុគ្គលិកវេជ្ជសាស្ត្រ។

- សមត្ថភាពរបស់មណ្ឌលកែប្រែក្នុងការទប់ស្កាត់ ឬគ្រប់គ្រងការផ្ទុះជំងឺអេបូឡា និងជំងឺឆ្លងផ្សេងទៀត នៅខ្វះចន្លោះច្រើន។
- វិស័យសន្តិសុខមិនសូវមានសមត្ថភាពគ្រប់គ្រងហ្វូងមនុស្សប្រកបដោយប្រសិទ្ធភាព និងការពារផ្ទះដែលស្ថិតក្រោមវិធានការចត្តាឡីស័ក និងមណ្ឌលព្យាបាល។
- វិស័យសន្តិសុខមិនសូវមានសមត្ថភាពដាក់ពង្រាយបុគ្គលិកតាមច្រកព្រំដែន។ ទាមទារបុគ្គលិក (សន្តិសុខ) បន្ថែមទៀតសម្រាប់កិច្ចការដែលពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងភស្តុភារ។
- ក្នុងករណីមួយ នៅពេលមិនសូវមានការបណ្តុះបណ្តាល និងការត្រៀមខ្លួនមន្ត្រីនគរបាលជាតិដែលប្រឈមជាមួយនឹងជំងឺអេបូឡា គណៈកម្មាធិការជាតិកាកបាទក្រហម (ICRC) ចាប់ផ្តើមបណ្តុះបណ្តាលមន្ត្រីទាំងនោះ ស្តីពីរបៀបថែទាំនគរបាលដែលប្រឈមនឹងជំងឺអេបូឡា។
- ជាញឹកញាប់មន្ទីរពេទ្យយោធាដែលត្រូវបានរៀបចំសម្រាប់ព្យាបាលកងទ័ពជួរមុខដែលប្រយុទ្ធប្រឆាំងនឹងការផ្ទុះជំងឺអេបូឡា គ្មានការបំពាក់សម្ភារគ្រប់គ្រាន់ ឬគ្មានសមត្ថភាពគ្រប់គ្រាន់។
- កិច្ចសហប្រតិបត្តិការថ្នាក់តំបន់លើសកម្មភាពនគរបាល គ្មានប្រសិទ្ធភាពក្នុងបរិបទនៃវិបត្តិនេះ ហើយការចែករំលែកព័ត៌មាន និងមេរៀនក្នុងបណ្តាប្រទេសនានា នៅមានកម្រិតទាប (ប្រសិនបើមាន)។
- កង្វះការចូលរួមរបស់ស្ត្រីក្នុងសហគមន៍ នៅដំណាក់កាលដំបូងនៃការផ្ទុះជំងឺនេះ ដែលជាទូទៅ គ្មានការអំពាវនាវឱ្យសហគមន៍ចូលរួមនៅពេលផ្ទុះជំងឺរាតត្បាតដំបូង។
- ការប៉ុនប៉ងបិទព្រំដែនគ្មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងការដើរហើរដោយសេរីព្រោះព្រំដែនធម្មជាតិរបស់បណ្តាប្រទេសក្នុងតំបន់ហាក់មានចំណុចខ្វះខាតច្រើន។

ទោះជាយ៉ាងណានៅពេលមានការឆ្លើយតបកាន់តែច្រើនទៅនឹងការផ្ទុះជំងឺអេបូឡា កិច្ចសហការរវាងសហគមន៍ នគរបាល និងកងទ័ព មានភាពប្រសើរឡើង ដោយមានការចូលរួមរបស់កងកម្លាំងប្រដាប់អាវុធដែលផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងដល់ការដោះស្រាយជំងឺរាតត្បាតនេះ។

របាយការណ៍នេះបានផ្តល់អនុសាសន៍ជាច្រើនសម្រាប់វិស័យសន្តិសុខដោយផ្អែកតាមការវិភាគការឆ្លើយតបជាសមូហភាព។ ខាងក្រោមនេះជាអនុសាសន៍សម្រាប់កងកម្លាំងនគរបាល ៖

- រួមបញ្ចូលការគ្រប់គ្រងវិបត្តិក្នុងកម្មវិធីបណ្តុះបណ្តាលកងកម្លាំងនគរបាលគ្រប់រូបក្នុងតំបន់។
- បង្កើនទំនាក់ទំនងជាមួយតួអង្គសង្គមស៊ីវិលតាមរយៈការចូលរួមបែបស្ថាបនា។
- ពង្រឹងសមត្ថភាពរបស់កងកម្លាំងនគរបាល ស្តីពីការទទួលខុសត្រូវរបស់ពួកគេលើការការពារសាធារណជន។
- បណ្តុះបណ្តាលនគរបាលស្តីពីនីតិវិធីសមស្របសម្រាប់ការពិនិត្យបឋមផ្នែកវេជ្ជសាស្ត្រក្នុងវិបត្តិសុខភាពសាធារណៈ។
- ពង្រឹងទស្សនាទាន និងការអនុវត្តសេវានគរបាលក្នុងសហគមន៍។
- បង្កើតគោលការណ៍ណែនាំច្បាស់លាស់ស្តីពីសុខភាព និងសុវត្ថិភាពសម្រាប់បុគ្គលិកសន្តិសុខ។
- បង្កើតនីតិវិធីប្រតិបត្តិស្តង់ដារ ដើម្បីសម្របសម្រួលការចូលរួមបែបស្ថាបនារបស់នគរបាល ក្នុងការទប់ស្កាត់ និងគ្រប់គ្រងវិបត្តិសុខភាព។
- ផ្តល់ការបណ្តុះបណ្តាលស្តីពីការបកស្រាយ និងការអនុវត្តលក្ខន្តិកៈក្នុងមូលដ្ឋានដើម្បីបញ្ចៀសការយល់ខុស។
- ផ្តល់ការកសាងសមត្ថភាពដល់មន្ត្រីគ្រប់គ្រងព្រំដែន។

## ប្រអប់ ១០

### UNDP ៖ ការវាយតម្លៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងវិបត្តិជំងឺអេបូឡានៅប្រទេសសៀរ៉ាឡេអូន

នៅឆ្នាំ ២០១៦ កម្មវិធី "លទ្ធភាពទទួលបានយុត្តិធម៌" របស់ UNDP បានធ្វើការសិក្សាមួយស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅមុនពេល និងក្នុងពេលផ្ទុះជំងឺអេបូឡានៅប្រទេសសៀរ៉ាឡេអូនភាគខាងកើត។ការសិក្សានេះខិតខំរំលេចប្រភេទជាក់លាក់នៃអំពើហិង្សាដែលកើតមានទូទៅបំផុតក្នុងពេលផ្ទុះជំងឺនេះ និងកម្រិតនៃការ ផ្តល់ ឬមិនផ្តល់សេវាដល់ជនរងគ្រោះក្នុងអំឡុងវិបត្តិនេះ។

727. តួនាទីរបស់វិស័យសន្តិសុខក្នុងការឆ្លើយតបទៅនឹងវិបត្តិសុខភាព។ មេរៀនពីជំងឺរាតត្បាតអេបូឡា ២០១៤-២០១៥ និង អនុសាសន៍សម្រាប់សហភាពទន្លេ Mano និងរដ្ឋសមាជិក (២០១៧) Sandy, J., Schnabel, A., Sovula, H., Trepp, U., and Zumsteg, R. The Geneva Centre for the Democratic Control of Armed Forces (DCAF) at: https://www.dcaf.ch/securitysectors-role-responding-health-crises-lessons-2014-2015-ebola-epidemic

ការសិក្សានេះរួមបញ្ចូលចំណុចផ្តោតសំខាន់មួយស្តីពីការងាររបស់អង្គភាពគាំពារគ្រួសារ(FSU)របស់នគរបាលសៀរ៉ាឡេអូន (SLP) និងដៃគូផ្តល់សេវាសំខាន់ៗរបស់អង្គភាពនេះ រួមទាំងដៃគូក្នុងវិស័យយុត្តិធម៌។ អង្គភាពនេះដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានកុមារ។ លទ្ធផលរកឃើញសំខាន់ៗមួយចំនួនពីការសិក្សនេះរួមមាន ៖

- ខុសពីស្ថិតិផ្លូវការនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែលចងក្រងដោយតួអង្គផ្តល់សេវានៅមូលដ្ឋានដែលគួសបញ្ជាក់ពីការថយចុះបន្តិចនៃករណីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអំឡុងវិបត្តិនេះ ធៀបនឹងឆមាសទីមួយនៃឆ្នាំនោះ ព័ត៌មានបែបគុណភាពដែលទទួលបានពីការសម្ភាសន៍ បានបង្ហាញពីការកើនឡើងជាក់ស្តែងនៃអំពើហិង្សា ៥ ទម្រង់ក្នុងចំណោមអំពើហិង្សាលើស្ត្រី និងក្មេងស្រីទាំង ១៥ ទម្រង់ (ដូចជា ការស៊ិកបញ្ចូលអង្គជាតិក្នុងប្រដាប់ភេទកុមារ អំពើហិង្សាក្នុងគ្រួសារ ការបៀតបៀនផ្លូវភេទ និងការបោះបង់ចោល/ការមិនអើពើ។
- សហគមន៍មួយចំនួនបានរាយការណ៍ពីការកើនឡើងនៃការមានផ្ទៃពោះវ័យជំទង់ ប្រមាណ ៤០%-៦០% ក្នុងអំឡុងពេលដូចគ្នា។ ផ្ទុយទៅវិញ ស្ថិតិផ្លូវការរបស់អង្គភាពគាំពារគ្រួសារបង្ហាញពីការប្រែប្រួលចំនួនករណីស៊ិកបញ្ចូលអង្គជាតិក្នុងប្រដាប់ភេទកុមារ ដែលបានរាយការណ៍នៅឆ្នាំ ២០១៤។
- ភាពអាចទទួលបាន និងភាពអាចរកបានសេវាសំខាន់ៗ ដូចជា សេវាតុលាការ បានរួមចំណែកដល់ការកើនឡើងនៃការសម្រុះសម្រួលករណីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរយៈនគរបាល និងអ្នកដឹកនាំក្នុងមូលដ្ឋាន។ ចំណុចនេះហាក់បង្កើននិទណ្ឌភាពសម្រាប់ជនបង្កដែលរងការចោទប្រកាន់។
- ស្ត្រីនិងក្មេងស្រីនិងស្ត្រីមេម៉ាយក្រីក្រជាក្រុមដែលងាយប្រឈមនឹងហានិភ័យខ្ពស់ដោយសារភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំងដែលបណ្តាលមកពីការផ្ទុះជំងឺនេះ។
- ជនបង្កដែលរងការចោទប្រកាន់ញឹកញាប់បំផុតនៅក្រៅផ្ទះជាពិសេសការចោទប្រកាន់ពីបទស៊ិកបញ្ចូលអង្គជាតិក្នុងប្រដាប់ភេទក្មេងស្រីអាយុក្រោម ១៨ ឆ្នាំ គឺជាបុរសដែលមានសិទ្ធិអំណាច និង/ឬតួនាទីដែលទទួលបានទំនុកចិត្ត ដូចជា ប្រធានសហគមន៍ អ្នកដឹកនាំសាសនា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងពាណិជ្ជករ។
- សម្រាប់ក្មេងស្រីដែលមានអាយុ ១៣-១៧ ឆ្នាំ គ្រូបង្រៀនក៏ត្រូវបានកំណត់ផងដែរជាជនបង្កញឹកញាប់ដែលប្រឡូកក្នុងការរួមភេទដោយមានការស្រុះស្រួលគ្នា ជាមួយសិស្សរបស់ខ្លួនជាថ្នូរនឹងការប្រឡងជាប់ ឬពិន្ទុល្អជាពិសេសនៅពេលប្រឡង។

ផ្អែកតាមបទពិសោធន៍នៃជំងឺអេបូឡាការសិក្សានេះបានដាក់ចេញវិធានការខាងក្រោមសម្រាប់នគរបាលសៀរ៉ាឡេអូន៖

- ជំរុញការចូលរួមរបស់អ្នកដឹកនាំសហគមន៍ដើម្បីធានាថា ករណីព្រហ្មទណ្ឌនៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ មិនត្រូវបានសម្រុះសម្រួល ប៉ុន្តែត្រូវបានដោះស្រាយតាមរយៈប្រព័ន្ធយុត្តិធម៌ផ្លូវការ។
- បង្កើនសមត្ថភាពប្រតិបត្តិការរបស់អង្គភាពគាំពារគ្រួសារដើម្បីផ្តល់ការឆ្លើយតបគ្រប់គ្រាន់ទៅនឹងករណីនានា។
- បង្កើនសមត្ថភាពផ្នែកបច្ចេកទេសរបស់បុគ្គលិកអង្គភាពគាំពារគ្រួសារ ពាក់ព័ន្ធនឹងការគ្រប់គ្រងករណី និងការប្រមូលទិន្នន័យស្តីពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- ផ្អែកលើការអនុវត្តការផ្អាកការវះកាត់ប្រដាប់បន្តពូជស្ត្រី ដើម្បីជួយដល់ការឈានឆ្ពោះទៅរកការកាត់បន្ថយ/ការបោះបង់ការអនុវត្តនេះ។ ចំណុចនេះគួររួមបញ្ចូលការចូលរួមជាយុទ្ធសាស្រ្តជាមួយសហគមន៍ និង Soweis។ គួរជំរុញការរក្សាការអនុវត្តបែបប្រពៃណីប៉ុន្តែគ្មានការវះកាត់ប្រដាប់បន្តពូជស្ត្រីប្រសិនបើគ្មានការពង្រឹងការអនុវត្ត។


រូបថតទទួលបានពី undp/anne kennedy (ប្រទេសសៀរ៉ាឡេអូន)

- ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងបឋមក្នុងការទប់ស្កាត់ដែលផ្តោតលើការបង្កើនស្ថានភាពរបស់ស្ត្រីតាមរយៈការជំរុញការចូលរួមរបស់បុរសនិងស្ត្រី។អនុសាសន៍នេះក៏គួរអនុវត្តចំពោះនគរបាលសៀរ៉ាឡេអូនផងដែរ។
- បង្កើនចំនួនហេដ្ឋារចនាសម្ព័ន្ធដែលស្រដៀងគ្នានឹងមជ្ឈមណ្ឌលឥន្ទនូ ឬមជ្ឈមណ្ឌលផ្តល់សេវាចម្រុះសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងធានាលទ្ធភាពរបស់ស្ត្រីសូម្បីតែស្ត្រីរស់នៅតំបន់ដាច់ស្រយាលបំផុត

ក្នុងការទទួលបានសេវាតាមរយៈអង្គការសង្គមស៊ីវិល និងស្ថាប័នមូលដ្ឋានផ្សេងទៀត។ក្នុងករណីទាំងនេះនគរបាលសៀរ៉ាឡេអូនគួររៀបចំផែនការសម្រាប់ការបែងចែកធនធានមនុស្សគ្រប់គ្រាន់ក្នុងមជ្ឈមណ្ឌលផ្ដល់សេវាចម្រុះ។

- ត្រូវបង្កើនការផ្ដល់មូលនិធិរបស់រដ្ឋាភិបាលដល់អង្គភាពគាំពារគ្រួសារ ដើម្បីអាចឱ្យស្ថាប័ននេះបំពេញមុខងារសមស្រប។
- ដៃគូអង្គការសង្គមស៊ីវិលដែលធ្វើការងារលើបញ្ហាអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវទទួលបានការបណ្តុះបណ្តាលសមត្ថភាពបន្ថែមទៀតដើម្បីបង្កើនជំនាញក្នុងការផ្ដល់សេវា ការតស៊ូមតិ និងការចងក្រងឯកសារ។ ក្នុងករណីនេះ នគរបាលសៀរ៉ាឡេអូនគួរដើរតួនាទីជាដៃគូដ៏សកម្ម ដើម្បីជានាការសម្របសម្រួលដោយប្រសិទ្ធភាព ជាមួយអង្គការសង្គមស៊ីវិល។



រូបថតទទួលបាន UNMEER/Martine Perret (ប្រទេសសៀរ៉ាឡេអូន)

ប្រភព ៖ ការវាយតម្លៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិបត្តិជំងឺអេបូឡានៅសៀរ៉ាឡេអូន (UNDP and Irish Aid, 2015)

## ករណីសិក្សា
## ការឆ្លើយតបបែបសហការរបស់ប្រទេសកូសូវ៉ូទៅនឹងករណីអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍ក្នុងពេលអនុវត្តវិធានការបិទខ្ទារជំងឺកូវីដ ១៩

**ផ្នែកទី ១ ៖ គម្រោង "ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ" នគរបាលកូសូវ៉ូ តំបន់ Mitrovica ភាគខាងត្បូង**
**ដោយ វរសេនីយឯក Aferdita Mikullovci ស្នងការនគរបាលតំបន់ Mitrovica ភាគខាងត្បូង**

ក្រោយការវិភាគស្ថិតិមួយចំនួនស្តីពីអំពើហិង្សាក្នុងគ្រួសារនៅអំឡុងវិបត្តិជំងឺកូវីដ ១៩ កាលពីថ្ងៃទី ២៩ ខែ មេសា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃនគរបាលតំបន់ Mitrovia ភាគខាងត្បូងបានផ្តួចផ្តើមជំហានបន្ថែមទៀតដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។



រូបថតទទួលបានពីនគរបាលកូសូវ៉ូ

គំនិតផ្តួចផ្តើមដ៏សំខាន់នេះគឺគម្រោងពហុវិស័យ (គម្រោងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ) ដែលផ្តែកលើការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានដែលផ្តោតសំខាន់លើសិទ្ធិស្ត្រី សិទ្ធិមនុស្ស និងសមភាពយេនឌ័រក្នុងតំបន់ Mitrovica (ខាងត្បូង និងខាងជើង)។ ការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានមានលក្ខណៈវិជ្ជមាន និងនាំទៅរកការបង្កើតបាវចនារបស់គម្រោង "រួមគ្នាប្រឆាំងអំពើហិង្សាក្នុងគ្រួសារ" បូករួមនឹងការផ្តល់សារយ៉ាងច្បាស់ថា "គ្រួសារមិនមែនជាអ្វីដែលសំខាន់ឡើយ ប៉ុន្តែគ្រួសារជាអ្វីៗគ្រប់យ៉ាង"។

ដៃគូគម្រោង និងអ្នកទទួលផលរួមមាន ៖

- នគរបាលកូសូវ៉ូ
- អយ្យការទទួលបន្ទុកករណីអំពើហិង្សាក្នុងគ្រួសារ
- តំណាងសាសនា (សាសនាអ៊ីស្លាមនិងសាសនាគ្រិស្ត)
- មន្ត្រីការពារជនរងគ្រោះ
- ការិយាល័យតុល្យភាពយេនឌ័រក្នុងទីក្រុង Mitrovica
- សិស្សវិទ្យាល័យ
- សិស្សបឋមសិក្សា
- អង្គការមិនមែនរដ្ឋាភិបាល "ជំងឺខ្សោយប្រាជ្ញាពីកំណើត"
- អង្គការមិនមែនរដ្ឋាភិបាល "កុមារកូសូវ៉ូ"
- អង្គការមិនមែនរដ្ឋាភិបាល "DIAKONIA" (មជ្ឈមណ្ឌល

ប៉ះទង្គិចផ្លូវចិត្តនៅ Mitrovica)
- អង្គការមិនមែនរដ្ឋាភិបាល "Mundesia" (ឱកាស)
- អង្គការមិនមែនរដ្ឋាភិបាល "Zenska Pravo" (សិទ្ធិស្ត្រី) តំបន់ Mitrovica ភាគខាងជើង
- អង្គការមិនមែនរដ្ឋាភិបាល "REC" (ការផ្សះផ្សារដែលបង្កើនសិទ្ធិអំណាចសហគមន៍)
- អង្គការមិនមែនរដ្ឋាភិបាល "MWAHR" (សិទ្ធិស្ត្រី និងសិទ្ធមនុស្សនៅ Mitrovica)
- អង្គការមិនមែនរដ្ឋាភិបាល "CBM" (ការកសាងសហគមន៍នៅ Mitrovica)។

នៅខែបន្ទាប់ និងក្រោមកិច្ចសហការយ៉ាងសកម្មពីគ្រប់ដៃគូនិងអ្នកទទួលផលទាំងអស់គម្រោងនេះអាចអនុវត្តសកម្មភាពដូចខាងក្រោម ៖

- បបកថាតាមប្រព័ន្ធអ៊ីនធឺណិតជាមួយសិស្សវិទ្យាល័យក្រោមការសម្របសម្រួលដោយនគរបាលកូសូវ៉ូនិងអ្នកចិត្តវិទ្យា លើប្រធានបទស្តីពីអំពើហិង្សាក្នុងគ្រួសារ និងផលវិបាកនៃអំពើហិង្សានេះ។សកម្មភាពនេះបានជំរុញឱ្យសិស្សានុសិស្សសហការជាមួយនគរបាលកូសូវ៉ូ និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូគម្រោងក្នុងការចែកចាយពំនោល/សម្រង់សម្តីផ្សេងៗស្តីពីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្អែកលើយេនឌ័រ។ ក្រៅពីនេះ សិស្សានុសិស្សបានសរសេរពំនោល/សម្រង់សំដី និងគូររូបភាពសម្រាប់យកទៅចែករំលែកជារៀងរាល់ថ្ងៃក្នុងរយៈពេល ១ ខែពេញ។



ការផ្សព្វផ្សាយគម្រោង Bashkë kundër dhunës៖ រូបថតទទួលបានពីនគរបាលកូសូវ៉ូ




- ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារត្រូវបាននគរបាលកូសូវ៉ូទាក់ទងតាមទូរស័ព្ទ ដោយបង្ហាញចំណាប់អារម្មណ៍លើសុខុមាលភាពរបស់ជនរងគ្រោះ និងជូនដំណឹងដល់ពួកគេ អំពីការជួបជាមួយអ្នកចិត្តវិទ្យាមកពីមជ្ឈមណ្ឌលប៉ះទង្គិចផ្លូវចិត្តនៅមូលដ្ឋានក្នុងករណីចាំបាច់ (ឧ. ការផ្តល់លេខទូរស័ព្ទរបស់អ្នកចិត្តវិទ្យាដល់ជនរងគ្រោះដែលរាយការណ៍ពីទំនាក់ទំនងជាមួយជនរងគ្រោះដែលបានទាក់ទងទាំងនេះ)។
- ការផ្សព្វផ្សាយដល់តំណាងសាសនា (សាសនាអ៊ីស្លាម និងសាសនាគ្រិស្ត) ដើម្បីឱ្យពួកគេលើកឡើងពីប្រធានបទអំពើហិង្សាក្នុងគ្រួសារនិងផលវិបាកនៃអំពើហិង្សានេះ ក្នុងអំឡុងកិច្ចប្រជុំតាមប្រព័ន្ធអ៊ីនធឺណិតជាមួយសហគមន៍ និងមន្ត្រីបណ្តាញសង្គមរបស់ពួកគេ។
- ការផ្សព្វផ្សាយឯកសារ/សម្ភារជាភាសាផ្លូវការ (អាល់បានី និងស៊ែប) ដូចជា បដា អាចម៉ូរបាន សៀវភៅកត់ត្រា ខិតប័ណ្ណ អាវយឺតដៃខ្លី ខ្មៅដៃដែលមានសរសេរបាវចនា និងសារ "រួមគ្នាប្រឆាំងអំពើហិង្សាក្នុងគ្រួសារ" "គ្រួសារមិនមែនជាអ្វីដែលសំខាន់ឡើយ ប៉ុន្តែគ្រួសារជាអ្វីៗគ្រប់យ៉ាង"។ឯកសារ/សម្ភារផ្សព្វផ្សាយទាំងនេះទទួលបានការគាំទ្រនិងត្រូវបានចែកចាយនៅតំបន់ Mitrovica ភាគខាងត្បូង និងភាគខាងជើង ដោយនគរបាលកូសូវ៉ូ។ បេសកកម្មនីតិរដ្ឋរបស់សហភាពអឺរ៉ុបនៅកូសូវ៉ូ (EULEX)[728] ក៏បានគាំទ្រគំនិតផ្តួចផ្តើមនេះផងដែរ។
- វីដេអូមួយ[729] ដែលមានចំណងជើងថា Bashkë kundër dhunës (រួមគ្នាប្រឆាំងអំពើហិង្សា) ត្រូវបានផលិត

728. EULEX កូសូវ៉ូ បានចាប់ផ្តើមនៅឆ្នាំ ២០០៨ ក្នុងនាមជាបេសកកម្មជនស៊ីវិលដ៏ធំជាងគេក្រោមគោលនយោបាយទូទៅស្តីពីសន្តិសុខ និងការការពារជាតិនៃសហភាពអឺរ៉ុប។ បេសកកម្មរបស់EULEXគឺជួយដល់អាជ្ញាធរកូសូវ៉ូក្នុងការបង្កើតស្ថាប័ននីតិរដ្ឋប្រកបដោយនិរន្តរភាព និងឯករាជ្យភាព។ អំពី EULEX សូមមើល https://www.eulex-kosovo.eu/?page=2,60។

729. Bashkë kundër dhunës (Together against Violence). Kosovo Police Official Channel, at: https://www.youtube.com/watch?v=LSnomZVgD_w

ឡើង និងរំលេចដោយសារសំខាន់ៗរបស់ដៃគូធំៗ ដូចជា តំណាងនគរបាលកូសូវ៉ូ អយ្យការរដ្ឋ តំណាងសាសនាអ៊ីស្លាមនិងសាសនាគ្រិស្តមេជារីជ៍នរងគ្រោះ តំណាងមកពីបណ្តាញអង្គការសិទ្ធិស្ត្រីនិងអ្នកជំនាញគាំទ្រជនរងគ្រោះ ក៏ដូចជាគំនូរ និងកំណាព្យរបស់កុមារស្តីពីសុខុមាលភាពគ្រួសារ។

ភាពជោគជ័យនៃគម្រោងបែបសហការនេះ កើតចេញពីការលះបង់របស់មន្ត្រីនគរបាល កូសូវ៉ូចំពោះប្រធានបទនេះ តាមរយៈការខិតខំធ្វើការយូរជាងមុនដោយសារវិបត្តិជំងឺរាតត្បាតកូវីដ ១៩ បូករួមនឹងរដ្ឋា-ភិបាល និងតួអង្គសង្គមស៊ីវិលដែលមានការប្តេជ្ញាចិត្តខ្ពស់។ សំខាន់បំផុតគឺស្មារតីសហការគ្នារវាងអង្គការនិងស្ថាប័នផ្សេងៗដែលមានសញ្ជាតិផ្សេងគ្នា (អាល់បានីស៊ែបប៊ូស្នៀ។ល។)

## ផ្នែកទី២៖ ការគាំទ្ររបស់អន្តរជាតិចំពោះការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងអំឡុងជំងឺរាតត្បាតកូវីដ ១៩

**ដោយ UN Women**

ករណីដំបូង ២ នៃជំងឺកូវីដ ១៩ នៅកូសូវ៉ូ ត្រូវបានរកឃើញនៅពាក់កណ្តាលខែ មីនា ជាពេលដែលចាប់ផ្តើមអនុវត្តវិធានការដាក់ដាច់ដោយឡែក។ នៅគ្រប់ទីកន្លែងលើភពផែនដីវិបត្តិនេះបានបង្កផលវិបាកលើជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាអន្តរបុគ្គល។តាំងពីពេលចាប់ផ្តើមវិធានការនេះក្រោមអន្តរាគមន៍ពីអ្នកសម្របសម្រួលការអភិវឌ្ឍរបស់ UN Women ដោយសហការជាមួយទីភ្នាក់ងារដើម្បីសមភាពយេនឌ័រ និងក្រសួងយុត្តិធម៌ UN Women បានធ្វើទំនាក់ទំនងជារៀងរាល់ថ្ងៃជាមួយជម្រកសុវត្ថិភាពទាំង ៨ ទីតាំង សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅជុំវិញប្រទេស កូសូវ៉ូ។ UN Women បានប្រមូលសំណើរភ្លាមៗរបស់អ្នកស្នាក់នៅក្នុងជម្រកសុវត្ថិភាពទាំងនេះ និងបានសម្របសម្រួលការឆ្លើយតបរបស់ស្ថាប័នអង្គការសហប្រជាជាតិ។ UNFPA, UNDP, UNHCR និង UNICEFបានចែកអាហារឃើតរក្សាអនាម័យស្ត្រីនិងបរិក្ខារការពារបុគ្គលដល់អ្នករស់នៅក្នុងជម្រកសុវត្ថិភាព។

ក្រោមកិច្ចខិតខំប្រឹងប្រែងរួមរបស់ UNKT ក្នុងរយៈពេល ២ សប្តាហ៍ដំបូងនៃការអនុវត្តវិធានដាក់ដាច់ដោយឡែក ស្ត្រី/ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារប្រមាណ ៥៥០ នាក់ដែលរស់នៅក្នុងជម្រកសុវត្ថិភាព ទទួលបានជំនួយ ដូចជា អាហារ និងឃីតរក្សាអនាម័យស្ត្រី។ UN Women បានពិនិត្យតាមដានស្ថានភាពរបស់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ/អំពើហិង្សាផ្អែកលើយេនឌ័រ ដែលមកពីសហគមន៍ជនជាតិភាគតិច និងមានទំនាក់ទំនងជាមួយអង្គការស្ត្រីនិងយន្តការសម្របសម្រួលក្នុងទីក្រុងដែលមានជនជាតិភាគតិច។មានការចែកសម្ភារដល់ជម្រកជនជាតិភាគតិចមួយកន្លែងនៅ Novobrdo តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមរបស់ UNKT។

ដើម្បីសម្រួលដល់ដំណើរការរៀនសូត្រតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់កុមារ ដែលរស់នៅក្នុងជម្រកសុវត្ថិភាពនៅកូសូវ៉ូ UN Women ក្រោមការគាំទ្រពីបេសកកម្មអង្គការសហប្រជាជាតិនៅកូសូវ៉ូ បានបរិច្ចាគបរិក្ខារបច្ចេកទេស ដូចជាទូរទស្សន៍ កុំព្យូទ័រយួរដៃ និងម៉ាស៊ីនព្រីន កម្រាលពូក និងស្រោមខ្នើយ ខ្នើយ ភួយ កន្សែងពោះគោ ខោអាវគេងយប់ ខោក្នុង និងសម្ភារផ្សេងទៀត។ សម្ភារទាំងនេះក៏ត្រូវបានផ្តល់ជូនជម្រកសុវត្ថិភាពសម្រាប់កុមារនិងជម្រកសុវត្ថិភាព



UN Women ផ្តល់ម៉ាស៊ីនថតបំពាក់តាមខ្លួនដល់នគរបាលកូសូវ៉ូ(ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២០)។
រូបថតទទួលបានពី UN Women ប្រចាំនៅកូសូវ៉ូ



UN Women ផ្តល់សម្ភារ និងបរិក្ខារ (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០)។
រូបថតទទួលបានពី UN Women ប្រចាំនៅកូសូវ៉ូ

សម្រាប់ជនរងគ្រោះដោយសារការជួញដូរមនុស្សផងដែរ។

UN Women បានសហការជាមួយ UNFPA ដើម្បីជួយដល់ក្រសួងយុត្តិធម៌ក្នុងការបង្កើតពិធីសារនៅគ្រាអាសន្នសម្រាប់ការដោះស្រាយករណីអំពហិង្សាក្នុងគ្រួសារនៅអំឡុងវិបត្តិជំងឺកូវីដ ១៩។ UN Women និង UNFPA បានចែកឃីតរក្សាអនាម័យស្ត្រី សម្លៀកបំពាក់ កម្រាលពូក និងស្រោមខ្នើយកន្សែងពោះគោនិងសម្ភារផ្សេងទៀតដល់កន្លែងធ្វើចត្តាឡីស័កបណ្ដោះអាសន្នសម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារ មុននឹងទទួលឱ្យចូលស្នាក់នៅ។ ការបង្កើតកន្លែងធ្វើចត្តាឡីស័កបណ្ដោះអាសន្នកើតចេញពីកិច្ចសន្ទនាពហុវិស័យ ដែលផ្ដួចផ្ដើមឡើងដោយ UNFPA និងចូលរួមដោយតួអង្គចម្រុះ ដូចជា ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងទីភ្នាក់ងារដើម្បីសមភាពយេនឌ័រ/ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

UNWomenបានសហការយ៉ាងជិតស្និទ្ធជាមួយនគរបាលកូសូវ៉ូតាំងពីការផ្ទុះជំងឺកូវីដ១៩ដំបូងដើម្បីពិនិត្យតាមដានស្ថានភាពនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ UN Women បានបរិច្ចាគម៉ាស៊ីនថតដាក់តាមខ្លួនចំនួន ៤០ គ្រឿងដល់អង្គភាពអំពើហិង្សាក្នុងគ្រួសារនៃនគរបាល កូសូវ៉ូ ដើម្បីបង្កើនសុវត្ថិភាពនិងសន្តិសុខរបស់ភ្នាក់ងារឆ្លើយតបដំបូង និងជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារតាមរយៈបច្ចេកវិទ្យាទំនើប។

ក្នុងគោលបំណងកសាងការយល់ដឹង និងលើកទឹកចិត្តឱ្យមានការរាយការណ៍ពីករណីអំពើហិង្សាក្នុងគ្រួសារ នៅខែមីនា ឆ្នាំ ២០២០ UN Women បានចាប់ផ្ដើមយុទ្ធនាការកសាងការយល់ដឹងដោយមានវីដេអូបង្ហាញសារជាពាភាសាពីនាយករដ្ឋមន្ត្រីកូសូវ៉ូ អ្នកនាំពាក្យរដ្ឋសភា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌រដ្ឋមន្ត្រីក្រសួងសុខាភិបាលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនគរបាលកូសូវ៉ូអ្នកសម្របសម្រួលការអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ និងប្រធានការិយាល័យ UN Women និងតាមរយៈការចែករំលែកលើផ្ទាំងបង្ហាញនូវលេខទូរស័ព្ទដែលផ្ដល់ដោយស្ថាប័នកូសូវ៉ូ និងបើកដំណើរការ ២៤ ម៉ោង/៧ ថ្ងៃ។ យុទ្ធនាការនេះត្រូវបានផ្សព្វផ្សាយតាមប៉ុស្ដិ៍ទូរទស្សន៍ក្នុងស្រុក និងបណ្ដាញសង្គម ដើម្បីធានាថាជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារទទួលបានការគាំទ្រចាំបាច់ពីស្ថាប័ននានា។ក្នុងរយៈពេល ២សប្ដាហ៍ ដំបូងយុទ្ធនាការនេះបានផ្សព្វផ្សាយដល់ប្រជាជនជាង ១ លាននាក់។



UN Women ផ្ដល់ជំនួយដល់ជម្រកសុវត្ថិភាព (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០)
រូបថតទទួលបានពី UN Women ប្រចាំនៅកូសូវ៉ូ

## ឧបសម្ព័ន្ធ ១

## វដ្ដ Townsley

### ការរៀបចំផែនការដែលឆ្លើយតបនឹងយេនឌ័រ និងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងអំឡុងមានវិបត្តិសុខភាពសាធារណៈ (ជំងឺឆ្លង/ជំងឺរាតត្បាត) ឬវិបត្តិមនុស្សធម៌

#### ការវិភាគទិន្នន័យ

- ទិន្នន័យស្ដីពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនៅមុនពេលនិងក្នុងពេលវិបត្តិ។
- ការប្រៀបធៀបទិន្នន័យយ៉ាងប្រុងប្រយ័ត្ន *។
- ទិន្នន័យដែលពាក់ព័ន្ធនឹងវិបត្តិ(ការបកស្រាយផ្នែកវិទ្យាសាស្ត្រ?)។
- ព័ត៌មាន ៖ ការណែនាំ/ការរឹតត្បិតរបស់រដ្ឋាភិបាល។
- ចារកម្ម ៖ និន្នាការបទល្មើស សាវតារជនរងគ្រោះជនបង្ក ។ល។
- ពិនិត្យឡើងវិញលើនីតិវិធីប្រតិបត្តិស្តង់ដារដែលមានស្រាប់(SOP)គោលនយោបាយ។ល។

*ការថយចុះចំនួននៃការរាយការណ៍ពីករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលបិទខ្ទប់ ឬការរឹតត្បិតការដើរហើរ មិនមានន័យថា មិនសូវមានឧប្បត្តិហេតុនោះទេ ប៉ុន្តែអាចដោយសារតែប្រភេទបទល្មើសប្រែប្រួលឬក៏ជនរងគ្រោះមិនបានរាយការណ៍។

#### ការពិនិត្យឡើងវិញ និងការរៀនសូត្រ

- ការប្រជុំពិភាក្សាពន្យល់ក្រោយចប់សកម្មភាព។
- តើអន្តរាគមន៍ "សមស្របនឹងគោលបំណង" ឬទេ?
- មិនទុកនរណាម្នាក់ចោល៖តើអាទិភាពត្រូវបានកំណត់យ៉ាងត្រឹមត្រូវ ឬទេ?
- គណនេយ្យភាព។
- ការត្រួតពិនិត្យ។
- ការដឹកនាំតាមបែបនវានុវត្តន៍។
- មេរៀន។
- កែសម្រួលផែនការ។
- ការបណ្ដុះបណ្ដាល/ការប្រជុំពិភាក្សាពន្យល់មុនចាប់ផ្ដើមសកម្មភាព។




#### ការវិភាគផលប៉ះពាល់

- ការវាយតម្លៃហានិភ័យ។
- ការវាយតម្លៃយេនឌ័រ/លក្ខណៈចម្រុះ។
- ការវាយតម្លៃនិរន្តរភាពប្រតិបត្តិការ**។
- ការវាយតម្លៃផលប៉ះពាល់លើសហគមន៍។

**ការវាយតម្លៃនិរន្តរភាពប្រតិបត្តិការគួរផ្សារភ្ជាប់នឹងសមត្ថភាពក្នុងការរក្សាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងពេលមានវិបត្តិ។

#### ការអនុវត្ត

ផែនការមានស្រាប់ ថ្មី ឬត្រូវបានកែសម្រួល ៖

- អភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ។
- ការស៊ើបអង្កេតដែលផ្ដោតសំខាន់លើជនបង្ក។
- មិនបង្កគ្រោះថ្នាក់។
- ការផ្សព្វផ្សាយផែនការ/អន្តរាគមន៍ភាពស៊ីសង្វាក់គ្នានៃការផ្ដល់សារតាមស្ថាប័ន និង សហគមន៍។
- ការប្រជុំពិភាក្សាពន្យល់មុនចាប់ផ្ដើមសកម្មភាព៖ ច្បាស់លាស់ និងស៊ីសង្វាក់គ្នា។

#### ការរៀបចំផែនការ

- កំណត់យុទ្ធសាស្ត្រ និងផែនការ។
- តើមានផែនការអនុវត្តន៍ស្រាប់ ឬថ្មីៗ "ដែលសមស្របនឹងគោលបំណង" ឬទេ?
- និរន្តរភាពប្រតិបត្តិការ ៖ របៀបផ្ដល់ការឆ្លើយតប "ជាប្រក្រតី" ទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- ផែនការគ្រាអាសន្ន/យថាភាព ៖ ពិនិត្យឡើងវិញលើផែនការមានស្រាប់ ឬបង្កើតថ្មី ឬពង្រឹងផែនការដោយផ្អែកតាមការវិភាគផលប៉ះពាល់។
- អន្តរាគមន៍ ៖ អភិក្រមដែលផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ ការស៊ើបអង្កេតដែលផ្ដោតសំខាន់លើជនបង្ក។
- យន្តការអភិបាលកិច្ចនិងគណនេយ្យភាព។

#### យថាភាព និងការកាត់បន្ថយផលប៉ះពាល់

- កំណត់ជម្រើសក្នុងការបំពេញស្ថានភាព"ចុះបើ?"
- កិច្ចសហការជាមួយសេវាសំខាន់ៗផ្សេងទៀត ស្ថាប័នយុត្តិធម៌ សហគមន៍ទូទៅ ដូចជា អ្នកដឹកនាំសាសនាអ្នកជិតខាងបណ្ដាញផ្សព្វផ្សាយ។ល។
- ចន្លោះសុវត្ថិភាពសម្រាប់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌។
- កំណត់រកសេវា/ឱកាសផ្សេងទៀតដែលមានក្នុងពេលមានវិបត្តិ ដូចជា ម្ចាស់ហាង អ្នករត់សំបុត្រ ឱសថការី។ល។
- ពិធីសារថ្មី/ការអនុវត្តការងារបែបថ្មីរវាងអ្នកផ្ដល់សេវាផ្សេងទៀត និង/ឬស្ថាប័នយុត្តិធម៌។
- បរិក្ខារការពារបុគ្គល។

## ការរៀបចំផែនការដែលឆ្លើយតបនឹងយេនឌ័រ និងការឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្នុងអំឡុងមានវិបត្តិសុខភាពសាធារណៈ

**(ជំងឺឆ្លង/ជំងឺរាតត្បាត) ឬវិបត្តិមនុស្សធម៌**

គំរូនេះជាវដ្តវិលទៅមកនិងអាចប្រើប្រាស់ទាំងសម្រាប់ការឆ្លើយតបមុនពេលរៀបចំផែនការនិងការឆ្លើយតបដោយឯកឯង។ គំរូនេះអាចប្រើប្រាស់ក្នុងព្រឹត្តិការណ៍/វិបត្តិណាក៏បាននិងមានភាពបត់បែនគ្រប់គ្រាន់ក្នុងការពង្រីកទៅតាមការវិវត្តនៃវិបត្តិឬបង្រួមក្រោយវិបត្តិស្រាកស្រាន្តហើយអ្នកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពវិញទោះបីនោះជាជីវិតរស់នៅធម្មតាតាមបែបគន្លងថ្មីក្តី។ នៅចំណុចកណ្តាលនៃដំណើរការនេះ អ្នកត្រូវពិចារណាពីវិធានការសុវត្ថិភាព និងការពារ និងត្រូវពិចារណាពីចំណុចនេះនៅដំណាក់កាលនីមួយៗនៃដំណើរការ។

**១.ការវិភាគទិន្នន័យ** ៖ ធ្វើឡើងនៅពេលចាប់ផ្តើមដំណើរការ និងជាផ្នែកដែលព័ត៌មាន និងចារកម្មត្រូវបានប្រមូលដើម្បីកំណត់ពីបញ្ហាដែលអ្នកកំពុងព្យាយាមដោះស្រាយ។ ការសំខាន់ត្រូវធានាថា អ្នកមិនបកស្រាយទិន្នន័យខុសដោយសារផលប៉ះពាល់នៃវិបត្តិ។ ឧ. ការថយចុះនៃចំនួនការរាយការណ៍ពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្នុងពេលបិទខ្ទប់ ឬការរឹតត្បិតការដើរហើរ មិនមានន័យថាមិនសូវមានឧប្បត្តិហេតុនោះទេ ប៉ុន្តែអាចបណ្តាលមកពីការប្រែប្រួលប្រភេទបទល្មើស ឬក៏ជនរងគ្រោះមិនអាចប្រើប្រាស់យន្តការរាយការណ៍តាមធម្មតា។

**២.ការវិភាគផលប៉ះពាល់** ៖ ការវិភាគទិន្នន័យជួយកំណត់រកផលប៉ះពាល់ដែលអាចកើតឡើងដោយសារវិបត្តិ និងទាមទារការវាយតម្លៃលើសពីមួយប្រភេទ។ ឧទាហរណ៍មួយចំនួនមានបង្ហាញនៅក្រោមប្រភេទនីមួយៗនៃការវាយតម្លៃផលប៉ះពាល់ ប៉ុន្តែមិនទាន់រៀបរាប់អស់សេចក្តីនោះទេ។ ផលប៉ះពាល់ដែលរកឃើញ អាចខុសៗគ្នាក្នុងបរិបទផ្សេងៗនិងច្រើនតែប្រែប្រួលទៅតាមពេលវេលា។ នេះជាមូលហេតុដែលវាបង្កើតបានជាដំណើរការបន្តជាប់ក្នុងគំរូនេះ។

### ការវាយតម្លៃហានិភ័យ

- ការកើនឡើងនៃហានិភ័យអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។
- ការកើនឡើងនៃប្រភេទអំពើហិង្សា/ការរំលោភបំពាន។
- ការថយចុះការគាំទ្រពីបណ្តាញ។
- សុវត្ថិភាពផ្ទាល់ខ្លួនសម្រាប់នគរបាលជួរមុខនិងកង្វះបរិក្ខារការពារបុគ្គល។

### ការវាយតម្លៃយេនឌ័រ/លក្ខណៈចម្រុះ

- ការរំលោភសិទ្ធិមនុស្ស។
- តើផែនការឬការផ្លាស់ប្តូរដែលលើកឡើងអាចបង្កផលប៉ះពាល់ដូចម្តេចលើស្ត្រី និងក្មេងស្រី រួមទាំងជនមានពិការភាព និង/ឬជនមានតម្រូវការផ្សេងទៀត?
- ផលប៉ះពាល់ធ្ងន់ធ្ងរនៃវិបត្តិលើភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រី។

### ការវាយតម្លៃនិរន្តរភាពប្រតិបត្តិការ

- សមត្ថភាពផ្តល់ការឆ្លើយតបជាប្រក្រតីទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។
- សុខុមាលភាព និងការរកបានបុគ្គលិក។
- អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។
- ការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក។
- មិនបង្កគ្រោះថ្នាក់។
- និរន្តរភាព។

### ការវាយតម្លៃផលប៉ះពាល់លើសហគមន៍

- តើសហគមន៍មួយចំនួនងាយរងផលប៉ះពាល់ខ្លាំងដោយសារការផ្លាស់ប្តូរការ ឆ្លើយតបរបស់នគរបាលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឬទេ?
- តើការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនឹងបង្កផលប៉ះពាល់អ្វីខ្លះលើទំនុកចិត្ត និងភាពជឿជាក់របស់សហគមន៍ ទាំងក្នុងពេល និងក្រោយពេលវិបត្តិ?
- តើត្រូវអនុវត្តការជំរុញការចូលរួមរបស់សហគមន៍គោលដៅ ឬទេ?

**៣.ការរៀបចំផែនការ**៖នេះជាដំណាក់កាលដែលផែនការថ្មីៗត្រូវបានបង្កើតឡើង និងជាពេលពិនិត្យឡើងវិញលើផែនការកំណត់ជាមុន ផែនការគ្រោះអាសន្ន ឬផែនការយថាហេតុ ដោយផ្អែកលើការវិភាគទិន្នន័យ និងការវាយតម្លៃផលប៉ះពាល់ ដើម្បីធានាថា ផែនការទាំងនោះ

"សមស្របនឹងគោលបំណង"។គោលបំណងនៃផែនការនេះត្រូវតែជាការផ្តល់អតិក្រមរួមដែល ផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ និងការស៊ើបអង្កេតដែលផ្តោតសំខាន់លើជនបង្ក ដើម្បីធានាថាការឆ្លើយតបស៊ីសង្វាក់គ្នានឹងគោលគំនិត "មិនបង្កគ្រោះថ្នាក់"។

**៤.យថាភាព និងការកាត់បន្ថយផលប៉ះពាល់** ៖ ការសំខាន់ត្រូវកំណត់អ្វីដែលអាចត្រូវការចាំបាច់ ប្រសិនបើមានអ្វីមួយកើតឡើង នៅពេលអនុវត្តផែនការរបស់អ្នក។ ខណៈដែលយថាភាព និងការកាត់បន្ថយផលប៉ះពាល់ ប្រដំប្រសងនឹងការរៀបចំផែនការ វាអាចជាផ្នែកដោយឡែកមួយនៃដំណើរការនេះ។ នៅដំណាក់កាលរៀបចំផែនការ អ្នកគួរពិចារណាពីស្ថានភាព "ចុះបើ?" និងបន្តធ្វើដូច្នេះរហូតដល់ពេលអនុវត្ត។

**៥.ការអនុវត្ត** ៖ ចាប់ផ្តើមការអនុវត្តផែនការ ដែលអាចត្រូវបានរៀបចំឡើងទុកមុនជាផែនការឆ្លើយតបក្នុងគ្រាអាសន្ន ផែនការថ្មី ឬផែនការមានស្រាប់ដែលត្រូវបានកែសម្រួលទៅតាមលទ្ធផលពីជំហាន ៣ ពីមុននៃដំណើរការនេះ។ ការផ្សព្វផ្សាយជាផ្នែកដ៏សំខាន់មួយនៃការអនុវត្ត ដោយមានការប្រជុំពិភាក្សាពន្យល់ច្បាស់លាស់ និងស៊ីសង្វាក់គ្នា និងសង្គតភាពនៃការផ្តល់សារទៅប្រភពខាងក្រៅ និងក្នុងស្ថាប័ន និងសហគមន៍នានា។

**៦.ការពិនិត្យឡើងវិញ និងការរៀនសូត្រ** ៖ ចំណុចនេះគួរធ្វើក្រោយគេជានិច្ចនិងផ្តល់មូលដ្ឋានព័ត៌មានដល់ការវិភាគទិន្នន័យនៅពេលដំណើរការកំពុងបន្ត។ វដ្តនេះត្រូវបន្តជាប់រហូតដល់បញ្ចប់បញ្ហាដែលអ្នកកំពុងដោះស្រាយ។ ការប្រជុំពិភាក្សាក្រោយចប់សកម្មភាពគួរចាប់ផ្តើមនៅពេលអនុវត្តដើម្បីអាចដាក់បញ្ចូលលទ្ធផលរកឃើញក្នុងដំណាក់កាលចុងក្រោយនេះ។ពេលគឺនៅពេលមានការពិនិត្យឡើងវិញជាផ្លូវការបន្ទាប់ពីវិបត្តិផុតរលត់។ ស្ថានការណ៍ងាយនឹងប្រែប្រួលរហូតក្នុងអំឡុងព្រឹត្តិការណ៍/វិបត្តិមួយ។ នេះជាមូលហេតុដែលដំណើរការនេះមានលក្ខណៈវិលទៅវិលមក។ ក្នុងស្ថានភាពរស់រវើក ប្រហែលជាត្រូវបញ្ចប់ដំណាក់កាលនីមួយៗឱ្យកាន់តែលឿន។

8

# កំណត់សម្គាល់ និងអំណានបន្ថែម


1 oint press statement Protecting Sexual and Reproductive Health and Rights and Promoting Gender-responsiveness in the COVID-19 Crisis (2020). Government Offices of Sweden, at: https://www.government.se/statements/2020/05/joint-press-statement-protecting-sexual-and-reproductive-health-and-rights-and-promoting-gender-responsive-ness-in-the-covid-19-crisis/

2 Coronavirus Disease (COVID-19) Outbreak (2020). WHO Regional Office for Europe, at: http://www.euro.who.int/en/health-topics/health-emergencies/coronavirus-covid-19/novel-coronavirus-2019-ncov

3 Ebola virus disease: Key Facts (2020) WHO, at: https://www.who.int/news-room/fact-sheets/detail/ebola-virus-disease

4 Inter-Agency Standing Committee (March 2020). Interim Guidance; Gender alert for COVID-19 out-break, at: https://interagencystandingcommittee.org/inter-agency-standing-committee/interim-guidance-gender-alert-covid-19-outbreak-developed-iasc

5 CARE (March 2020). A policy paper on COVID-19's gender implications, at: https://www.care.org/news-room/press/press-releases/covid-19s-gender-implica-tions-examined-in-policy-brief-care

6 Secretary-General's video message on gender-based violence and COVID-19. United Nations April 5, 2020, at: https://www.un.org/sg/en/content/sg/state-ment/2020-04-05/secretary-generals-video-message-gender-based-violence-and-covid-19-scroll-down-for-french

7 UNODC's Global Study on Homicide: Gender-related killing of women and girls (UNODC, 2018), at:https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_wom-en_and_girls.pdf

8 Violence against women and girls: the shadow pandemic (2020). Statement by Phumzile Mlambo-Ngcuka, Executive Director of UN Women, at: https://www.unwomen.org/en/news/stories/2020/4/state-ment-ed-phumzile-violence-against-women-during-pandemic

9 Emergencies preparedness, response. What is a pan-demic? WHO 24 February 2010 https://www.who.int/csr/disease/swineflu/frequently_asked_questions/pandemic/en/

10 Policing the Pandemic: How UN Police are Maintaining Law, Order, and Public Health. UN News Peace and Security 23 May 2020, at: https://news.un.org/en/story/2020/05/1064812

11 COVID-19 and Ending Violence Against Women and Girls. UN Women Issue Brief April 2020 https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/issue-brief-covid-19-and-ending-violence-against-women-and-girls-en.pdf?la=en&vs=5006

12 Justice for women amidst COVID-19 (2020). UN Women Issue Brief. https://www.unwomen.org/-/me-dia/headquarters/attachments/sections/library/pub-lications/2020/justice-for-women-amidst-covid-19-en.pdf?la=en&vs=4857

13 Weitzman, A., and J.A. Behrman (2016). Disaster, Disruption to Family Life and Intimate Partner Violence: The Case of the 2010 Earthquake in Haiti. Sociological Science, 3: 167-189. https://www.sociolog-icalscience.com/download/vol-3/march/SocSci_v3_167to189.pdf

14 Pandemics and Violence Against Women and Children (2020). Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

15 World Bank. 2020. *Gender Dimensions of the COVID-19 Pandemic (English)*. Washington, D.C. : World Bank Group, at:. http://documents.world-bank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic

16 Coronavirus Disease (COVID-19) response – UNODC Thematic Brief on gender-based violence against women and girls (UNODC, 2020), at: https://www.unodc.org/documents/Advocacy-Section/GBVAW_and_UNODC_in_COVID19_final_7Apr2020.pdf

17 Impact of COVID-19 Pandemic on Violence against Women and Girls (2020). Fraser, E. (2020) for UKAid, WAG Helpdesk Research Report, at: https://www.dmeforpeace.org/peacexchange/wp-content/up-loads/2020/04/vawg-helpdesk-284-covid-19-and-vawg.pdf

18 On the Front Lines of COVID-19, Women's Organizations Provide Vital Services as First Responders as Violence against Women Spikes (UN Women, 2020), at: https://www.unwomen.org/en/news/stories/2020/5/feature-womens-organiza-tions-provide-vital-services-as-violence-against-wom-en-spikes

19 Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L. et al. (2008). Global trends in emerging infectious diseases. Nature 451: 990-94.

20 'Wheels', adapted from the Power and Control Wheel Model. The National Center on Domestic and Sexual Violence. http://209.198.129.131/publications_wheel.html

21 Bridging the Digital Gender Divide Include, Upskill, Innovate (2018). Organisation for Economic Co-operation and Development (OECD). http://www.oecd.org/internet/bridging-the-digital-gender-divide.pdf

22 Ways to Bridge the Gender Digital Divide from a Human Rights Perspective (2016). Submission by the Human Rights, Big Data and Technology Project at the Human Rights Centre of the University of Essex, Funded by the Economic and Social Research Council, at: https://www.ohchr.org/Documents/Issues/Women/WRGS/GenderDigital/HRBDT_submission.pdf.

23 World Wide Web Foundation, 'Women's Rights Online. Translating Access into Empowerment' (2015). http://webfoundation.org/docs/2015/10/womens-rights-online21102015.pdf.

24 Pandemics and Violence Against Women and Children (2020). Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

25 Remote Court Hearings and Judicial Processes in Response to COVID-19 in Mission and other Fragile Settings Justice and Correction Service. UN Office of Rule of Law and Security Institutions (OROLSI)/Department of Peace Operations (DPO) 13 April 2020. https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf

26 COVID-19: How to include marginalized and vulnerable people in risk communication and community engagement (2020). International Federation of Red Cross and Red Crescent Societies, UN Office for the Coordination of Humanitarian Affairs and the World Health Organization, at: https://reliefweb.int/sites/reliefweb.int/files/resources/COVID-19_CommunityEngagement_130320.pdf

27 Global trends in emerging infectious diseases. Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L. et al. (2008). Nature 451: 990-94. https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

28 Ecuador Country Case Study. Effective law and policy on gender equality and protection from sexual and gender-based violence in disasters (2020). The International Federation of Red Cross and Red Crescent Societies (IFRC). https://media.ifrc.org/ifrc/document/effective-law-policy-gender-equality-protection-sexual-gender-based-violence-disasters-ecuador/

29 Special Rapporteur on violence against women finalizes country mission to the United Kingdom and Northern Ireland and calls for urgent action to address the accountability deficit and also the adverse impacts of changes in funding and services (2014), at:https://www.ohchr.org/en/newsevents/pages/displaynews.aspx?newsid=14514&

30 Hard times: Women's pathways to crime and incarceration (2012). Artz, L., Hoffman-Wanderer, Y., and Moult, K., at: https://genderlinks.org.za/wp-content/uploads/imported/articles/attachments/18024_hard_times.pdf

31 Gender-Based Discrimination & Women in Conflict with the Law (UNODC, 2020), at: https://www.unodc.org/e4j/en/crime-prevention-criminal-justice/module-9/key-issues/1--gender-based-discrimination-and-women-in-conflict-with-the-law.html

32 2019 Report of the Secretary-General on violence against women migrant workers (A/74/235), at: https://www.unwomen.org/en/digital-library/publications/2019/07/a-74-235-sg-report-violence-against-women-migrant-workers

33 Addressing the Impacts of the COVID-19 Pandemic on Women Migrant Workers (2020). UN Women Guidance Note, at: https://www.unwomen.org/en/digital-library/publications/2020/04/guidance-note-addressing-the-impacts-of-the-covid-19-pandemic-on-women-migrant-workers

34 From Global Coordination to Local Strategies A Practical Approach to Prevent, Address and Document Domestic Violence under COVID-19 Briefing Paper (2020). MADRE, Media Matters for Women, MenEngage Alliance, Nobel Women's Initiative, OutRight Action International, Women Enabled International, and Women's International League for Peace and Freedom (WILPF), at: https://www.wilpf.org/wp-content/uploads/2020/04/MADRE-Domestic-Violence-Under-COVID-19-Briefing-Paper_4.21.20.pdf

35 Coronavirus lockdown raises risk of online child abuse, charity says. The Guardian (2020) https://www.theguardian.com/world/2020/apr/02/coronavirus-lockdown-raises-risk-of-online-child-abuse-charity-says

36 COVID-19: Urgent need for child protection services to mitigate the risk of child sexual abuse

and exploitation worldwide (2020), Mama Fatima Singhateh, the Special Rapporteur on the sale and sexual exploitation of children, at: https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25865&LangID=E

37 Risk of online sex trolling rises as coronavirus prompts home working. Reuters (2020), at: https://www.reuters.com/article/us-women-rights-cyberflashing-trfn-idUSKBN2153HG

38 Gender Dimensions of the COVID-19 Pandemic (2020). Washington, D.C.: World Bank Group, at: http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic

39 Has it become too dangerous to measure violence against women? Kelli Rogers, 6 May 2020, at: https://asiapacific.unfpa.org/en/news/covid-19-has-it-become-too-dangerous-measure-violence-against-women

40 The Sphere Handbook: Humanitarian Charter and Minimum Standards in Humanitarian Response, fourth edition, Geneva, Switzerland, 2018, at: https://spherestandards.org/wp-content/uploads/Sphere-Handbook-2018-EN.pdf

41 Bystander Approach. Graham Goulden for Cultivating Minds UK., at: https://grahamgoulden.com/cultivating-minds-uk/about/

42 The Security Sector's Role in Responding to Health Crises. Lessons from the 2014–2015 Ebola Epidemic and Recommendations for the Mano River Union and Its Member States (2017). Sandy, J., Schnabel, A., Sovula, H., Trepp, U., and Zumsteg, R. The Geneva Centre for the Democratic Control of Armed Forces (DCAF), at: https://www.dcaf.ch/security-sectors-role-responding-health-crises-lessons-2014-2015-ebola-epidemic

43 Court Response to Violence Against Women During COVID-19. Webinar Series: Adapting Legal and Systemic Responses During COVID-19 Addressing Violence Against Women April 3, 2020. Global Rights for Women, at: https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf

44 Policy Brief: The Impact of COVID-19 on children (2020). UN Sustainable Development Group https://unsdg.un.org/resources/policy-brief-impact-covid-19-children

45 COVID-19 and violence against women What the health sector/system can do (WHO, 2020), at: https://www.who.int/reproductivehealth/publications/emergencies/COVID-19-VAW-full-text.pdf?ua=1

46 Jhumka Gupta, "What does coronavirus mean for violence against women?," Women's Media Centre, March 19, 2020, at: https://womensmediacenter.com/news-features/what-does-coronavirus-mean-for-violence-against-women

47 COVID-19 and Gender Equality and Women, Peace and Security (WPS). UN Department of Peace Operations, at: https://peacekeeping.un.org/sites/default/files/covid-19_and_wps.pdf

48 Christian Aid, CAFOD, Tearfund, and Islamic Relief (2015) Keeping the Faith: The Role of Faith Leaders in the Ebola Response, London: Christian Aid, at: http://learn.tearfund.org/~/media/files/tilz/research/keeping_the_faith_july_2015.pdf

49 Ebola Recovery in Sierra Leone Tackling the Rise in Sexual and Gender Based Violence And Teenage Pregnancy During The Ebola Crisis, New York: UNDP (2015a), at: https://www.undp.org/content/dam/sierraleone/docs/Ebola%20Docs./SL%20FS%20SGBV.pdf

50 Confronting the gender impact of the Ebola Virus Disease on Guinea, Liberia and Sierra Leone. Africa Policy Note, Vol. 2, No. 1, 30 January 2015, p.4., at: https://reliefweb.int/sites/reliefweb.int/files/resources/RBA%20Policy%20Note%20Vol%202%20No%201%202015_Gender.pdf

51 Conflict, Displacement and IPV: Findings from Two Congolese Refugee Camps in Rwanda. Violence Against Women. Wako, E., Elliott, L., De Jesus, S., Zotti, M.E., Swahn, M.H., and J. Beltrami. (2015). Violence Against Women. 21(9): 1087-101.

52 Violence against refugee women along the Thai-Burma border. Falb, K.L., McCormick, M.C., Hemenway, D., Afinson, K., and J.G. Silverman. (2013). International Journal of Gynecology & Obstetrics. 120(3): 279-283 http://support.arcrelief.org/site/DocServer/VAW_on_the_Thai-Myanmar_Border.pdf?docID=2622

53 Horn, R. (2010). Responses to intimate partner violence in Kakuma a refugee camp: Refugee interactions with agency systems. Social Science & Medicine. 70(1): 160-168.

54 A New Scourge to Afghan Women: COVID-19 Oxfam Briefing Note (2020), at: https://asia.oxfam.org/latest/policy-paper/new-scourge-afghan-women-covid-19

55 UNICEF Helpdesk Gender Based Violence in Emergencies: Emergency Responses to Public Health Outbreaks (UNICEF, 2018), at: http://www.sddirect.org.uk/media/1617/health-responses-and-gbv-short-query-v2.pdf

56 Increased Gender-based Violence Among Women Internally Displaced in Mississippi 2 Years

Post-Hurricane Katrina. Anastario, M., Shehab, N., and Lawry, L. (2013). Disaster Medicine and Public Health Preparedness. 3 (1): 18-26.

57 Converging drivers of interpersonal violence: Findings from a qualitative study in post-hurricaine Haiti. Bermudez, L.G, Stark, L., Bennouna, C., Jensen, C., Potts, A., Kaloga, I.F., et al. (2019). Child Abuse & Neglect, 89:178-191.

58 Gender-based violence and environment linkages: Castañeda Camey.I., Sabater, L., Owren, C. and Boyer, A.E. (2020). The violence of inequality. Wen, J. (ed.). Gland, Switzerland: IUCN. 272pp.

59 International Rescue Committee (IRC) and Global Women's Institute (GWI). (2015) Responding to Typhoon Haiyan: Women and Girls Left Behind. A study on violence against women and girls' prevention and mitigation in the response to Typhoon Haiyan, at: https://www.whatworks.co.za/documents/publications/17-responding-to-typhoon-haiyan-women-and-girls-left-behind/file

60 Sitting on a Volcano: Domestic Violence in Indonesia Following Two Volcano Eruptions. Schwefer, M. (2018). Ifo Working Paper Series 263, ifo Institute – Leibniz Institute for Economic Research at the University of Munich, at: https://www.cesifo.org/DocDL/wp-2018-263-schwefer-domestic-violence.pdf

61 Prevalence of Sexual Violence among Female Refugees in Complex Humanitarian Emergencies: A Systematic Review and Meta-Analysis. Vu, A., Adam, A., Wirtz, A., Pham, K., Rubenstein, L., Glass, N., Beyrer, C. and S. Singh. (2014). The PLoS Curr. Edition 1. doi: 10.1371/currents.dis.835f10778fd80ae031aac12d3b533ca7 http://currents.plos.org/disasters/index.html%3Fp=11337.html

62 International Rescue Committee (IRC, 2015), at: https://www.rescue.org/sites/default/files/document/564/ircpvpcfinalen.pdf .

63 A systematic review of prevalence studies of gender-based violence in complex emergencies. Stark, L. and A. Ager. (2011). Trauma Violence Abuse 12 (3): 127-34.

64 Everything on her Shoulders: Rapid Assessment on Gender and Violence against Women and Girls in Beni, DRC, (International Rescue Committee, New York, 2019), at: https://www.rescue.org/report/everything-her-shoulders-rapid-assessment-gender-and-violence-against-women-and-girls-ebola

65 Ebola Recovery in Sierra Leone: Tackling the rise in sexual and gender-based violence and teenage pregnancy during the Ebola crisis, (UNDP, 2015), at: https://www.undp.org/content/dam/sierraleone/docs/Ebola%20Docs./SL%20FS%20SGBV.pdf

66 UNICEF Helpdesk Gender Based Violence in Emergencies: Emergency Responses to Public Health Outbreaks. (UNICEF, 2018), at: http://www.sddirect.org.uk/media/1617/health-responses-and-gbv-short-query-v2.pdf

67 Vulnerability in an Influenza Pandemic: Looking Beyond Medical Risk. Technical Report. O'Sullivan, T. and M. Bourgoin. (2010). March 28, 2020, at: https://www.semanticscholar.org/paper/Vulnerability-inan-Influenza-Pandemic-%3A-Looking-%2C-O%E2%80%99SullivanBourgoin/48b390413d140b148a598a81dc4ec4515f1d458e

68 Integrating a Gender Perspective into Human Rights Investigations Guidance and Practice (UN Office of the High Commission for Human Rights, New York and Geneva, 2018), at: https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegrationintoHRInvestigations.pdf

69 Prevention: Violence against women and girls and COVID-19 (2020). UN Women Issue Brief, at: https://www.unwomen.org/en/digital-library/publications/2020/05/brief-prevention-violence-against-women-and-girls-and-covid-19

70 COVID-19 and Essential Services Provision for Survivors of Violence Against Women and Girls (2020). UN Women Issue Brief, at: https://www.unwomen.org/en/digital-library/publications/2020/04/brief-covid-19-and-essential-services-provision-for-survivors-of-violence-against-women-and-girls

71 Online and ICT* facilitated violence against women and girls during COVID-19 (2020). UN Women Issue Brief, at: https://www.unwomen.org/en/digital-library/publications/2020/04/brief-online-and-ict-facilitated-violence-against-women-and-girls-during-covid-19

72 Guidelines for Mobile and Remote Gender-Based Violence (GBV) Service Delivery (2018). International Rescue Committee (IRC), at: https://reliefweb.int/sites/reliefweb.int/files/resources/GBV-Mobile-and-Remote-Service-Delivery-Guidelines_-final.pdf

73 Identifying and Mitigating Gender-based Violence Risks within the COVID-19 Response Last updated: 6 April 2020. Inter-Agency Standing Committee (IASC), at: https://gbvguidelines.org/wp/wp-content/uploads/2020/04/Interagency-GBV-risk-mitigation-and-Covid-tipsheet.pdf

74 Personal Protective Equipment (PPE) operational guidance (April 8, 2020). UK College of Policing UK. https://www.college.police.uk/What-we-do/COVID-19/

Documents/Personal-Protective-Equipment-Operational-Guidance-1.pdf

75 Lockdown on Domestic Violence (Akshara Centre, 2020), at: https://www.aksharacentre.org/lockdown-logs/

76 Online Safety in a Changing World – COVID-19 and Cyber Violence (2020). Sexual Violence Research Initiative, at: https://www.svri.org/blog/online-safety-changing-world-%E2%80%93-covid-19-and-cyber-violence

77 COVID-19 at the Intersection of Gender and Disability: Findings of a Global Human Rights Survey, March to April 2020 Women Enabled International (2020). Women Enabled International. https://womenenabled.org/pdfs/Women%20Enabled%20International%20COVID-19%20at%20the%20Intersection%20of%20Gender%20and%20Disability%20May%202020%20Final.pdf

78 COVID-19 and Child, Early and Forced Marriage: An Agenda for Action (2020). Girls not Brides. The Global Partnership to End Child Marriage, at: https://www.girlsnotbrides.org/wp-content/uploads/2020/04/COVID-19-and-child-early-and-forced-marriage_FINAL-4.pdf

79 A Girl No More: The Changing Norms of Child marriage in Conflict (2016). Women's Refugee Commission, at: https://reliefweb.int/sites/reliefweb.int/files/resources/Changing-Norms-of-Child-Marriage-in-Conflict.pdf

80 Did You Know That Millions of People Around the World Are Still Uprooted from Their Homes By Disasters (2020)? André, C., Ginnetti, J., and Ponserre, S. for the Internal Displacement Monitoring Centre, at: https://www.internal-displacement.org/expert-opinion/did-you-know-that-millions-of-people-around-the-world-are-still-uprooted-from-their

81 Washington Group Questionnaire, at : http://www.washingtongroup-disability.com/washington-group-question-sets/

82 UN joint report "Justice for Women amidst COVID-19" (2020). UN Women, IDLO, UNDP, UNODC, World Bank and the Pathfinders for Justice, at: https://www.idlo.int/sites/default/files/pdfs/publications/Justice-for-Women_Full-Report-English.pdf.

83 National Commission for Lebanese Women, UN Women, WHO, UNFPA, 2020. Gender Alert on COVID-19, Lebanon. In Focus: Access to Justice and Gender Based Violence. April 10, 2020. Issue No. 1., at: https://www2.unwomen.org/-/media/field%20office%20arab%20states/attachments/publications/2020/04/gender%20and%20covid-19%20in%20lebanon/updated/gender%20alert%20on%20covidlebanon%20english.pdf?la=en&vs=1838

84 Operation Faoiseamh - Domestic Abuse 9th June 2020. Ireland's National Police and Security Service, at: https://www.garda.ie/en/about-us/our-departments/office-of-corporate-communications/press-releases/2020/june/operation%20faoiseamh%20-%20domestic%20abuse%209th%20june%202020%20.html#:~:text=Operation%20Faoiseamh%2C%20which%20commenced%20as,protected%20during%20this%20extraordinary%20time.

85 Safe Ireland Welcomes Garda Prioritisation of Domestic Abuse and Coercive Control. Safe Ireland, at: https://www.safeireland.ie/safe-ireland-welcomes-garda-prioritisation-of-domestic-abuse-and-coercive-control/

86 Measures and Practices by Country. Promoting and Protecting Women's Rights at National Level. Council of Europe, at: https://www.coe.int/en/web/genderequality/promoting-and-protecting-women-s-rights#{%2263001324%22:[14]}

87 Assessing Sexual and Gender Based Violence during the Ebola Crisis in Sierra Leone (2015). UNDP and Irish Aid, at: https://www.sl.undp.org/content/sierraleone/en/home/library/crisis_prevention_and_recovery/assessing-sexual-and-gender-based-violence-during-the-ebola-cris.html

88 Not just hotlines and mobile phones: GBV Service provision during COVID-19 (2020). Erskine, D. for UNICEF, at: https://www.unicef.org/media/68086/file/GBV%20Service%20Provision%20During%20COVID-19.pdf

89 Global Rapid Gender Analysis for COVID-19 (2020) international Rescue Committee and CARE International, at: https://www.rescue.org/report/global-rapid-gender-analysis-covid-19

# 15

# សទ្ទានុក្រម និង ឯកសារយោង
# (Glossary and Bibliography)

## សន្ទានុក្រម និង ឯកសារយោង
## (Glossary and Bibliography)

***អភិក្រមផ្អែកតាមសិទ្ធិ*** ក្នុងការផ្តល់សេវាសំខាន់ៗប្រកបដោយគុណភាពទទួលស្គាល់ថារដ្ឋមានការទទួលខុសត្រូវចម្បងក្នុងការគោរព ការពារ និងបំពេញសិទ្ធិរបស់ស្ត្រី និងក្មេងស្រី។អំពើហិង្សាលើស្ត្រីគឺជាការរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋានស្ត្រី ជាពិសេសសិទ្ធិទទួលបានជីវិតដែលគ្មានការភ័យខ្លាច និងអំពើហិង្សា។ អភិក្រមសិទ្ធិមនុស្សទាមទារនូវសេវាដែលផ្តោតអាទិភាពលើសុវត្ថិភាពនិងសុខុមាលភាពរបស់ស្ត្រីនិងការផ្តល់សេចក្តីថ្លៃថ្នូរ ការគោរព និងការយកចិត្តទុកដាក់ដល់ស្ត្រី។ ក្រៅពីនេះ អភិក្រមនេះទាមទារឱ្យមានស្តង់ដារខ្ពស់បំផុតនៃសេវាសុខាភិបាល សង្គម យុត្តិធម៌ និងសេវានគរបាលដែលអាចសម្រេចបានពោលគឺសេវាប្រកបដោយគុណភាពអាចផ្តល់អាចទទួលបាននិងអាចទទួលយកបានសម្រាប់ស្ត្រី។ ការសម្រេចបានសេវាប្រកបដោយគុណភាព អាចផ្តល់ អាចទទួលបាន និងអាចទទួលយកបានសម្រាប់ជនរងគ្រោះ ត្រូវតែជាចំណុចស្នូលនៃអភិក្រមនេះ[730]។

***អភិក្រមដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ*** ផ្តោតសំខាន់លើសិទ្ធិ តម្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងការផ្តល់សេវា ក៏ដូចជាការប្រមូលនិងប្រើប្រាស់ទិន្នន័យរដ្ឋបាល។ចំណុចនេះត្រូវមានការពិចារណាពីតម្រូវការចម្រុះរបស់ជនរងគ្រោះ ហានិភ័យ និងភាពងាយ រងគ្រោះផ្សេងៗ ផលប៉ះពាល់នៃសេចក្តីសម្រេចចិត្ត និងវិធានការដែលធ្វើឡើង[731]។

***សេចក្តីថ្លៃថ្នូរ*** ជាគុណតម្លៃ គោលការណ៍ និងសិទ្ធិជាសារវន្ត ដែលជាមូលដ្ឋាន និងលក្ខខណ្ឌនៃរាល់ចំណុចផ្សេងទៀត។ សេចក្តីថ្លៃថ្នូរបង្កប់អត្ថន័យថា បុគ្គលជាម្ចាស់ និងជាកម្មវត្ថុនៃសិទ្ធិដែលមិនគួរប្រឈមនឹងអំពើហិង្សាឬភាពតាមអំពើចិត្តរបស់រដ្ឋ ឬបុគ្គល។ ផ្អែកតាមសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ អាជ្ញាធររដ្ឋទាំងអស់មានកាតព្វកិច្ចគោរពស្វ័យភាពនៃសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់ពេលវេលានិងគោរពនិងចាត់ទុកសេចក្តីថ្លៃថ្នូរជាតម្លៃស្នូលនៃទង្វើរបស់ខ្លួន។ ទន្ទឹមនឹងនេះ អាជ្ញាធររដ្ឋទាំងអស់មានកាតព្វកិច្ចជានាទីថា អត្ថិភាពទាបបំផុតដែលជនរងគ្រោះមានសិទ្ធិទទួលបាន មិនត្រូវបានកាត់បន្ថយ ហើយចំណុចស្នូលដ៏សំខាន់នៃសិទ្ធិរបស់ពួកគេមិនត្រូវឱ្យរងផលប៉ះពាល់[732]។

***អំពើហិង្សាក្នុងគ្រួសារ*** ជាពាក្យជំទូលាយដែលពាក់ព័ន្ធនឹងឌីណាមិកផ្សេងៗក្នុងផ្នែកសង្គម និងចិត្តវិទ្យា និងភាពខុសគ្នានៃអំណាច និងគ្របដណ្តប់លើទម្រង់ផ្សេងៗដូចជា ការរំលោភបំពានកុមារ ការរំលោភបំពានចាស់ជរា និងការរំលោភបំពានអន្តរបុគ្គល ឬការរំលោភបំពានដៃគូ។

***សេវាសំខាន់ៗ*** គ្របដណ្តប់លើសំណុំសេវាដែលផ្តល់ដោយវិស័យថែទាំសុខភាព សេវាសង្គម និងសេវាយុត្តិធម៌ និងនគរបាល។ ក្នុងកម្រិតអប្បបរមា សេវាទាំងនេះត្រូវធានាសិទ្ធិ សុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ[733]។

***ប្រព័ន្ធយុត្តិធម៌ផ្លូវការ*** ជាប្រព័ន្ធយុត្តិធម៌ដែលជាការទទួលខុសត្រូវរបស់រដ្ឋ និងស្ថាប័នរបស់រដ្ឋ។ ប្រព័ន្ធនេះរួមមានច្បាប់របស់រដ្ឋាភិបាល និងស្ថាប័ននានា ដូចជា នគរបាល សេវាអយ្យការតុលាការនិងពន្ធនាគារដែលទទួលខុសត្រូវលើការជំរុញការអនុវត្តច្បាប់របស់រដ្ឋ និងដាក់ទណ្ឌកម្មលើការរំលោភច្បាប់[734]។

***សមភាពយេនឌ័រ*** ជាគោលគំនិតដែលកំណត់ថា មនុស្សគ្រប់រូប (ដោយមិនគិតភេទ) មានសេចក្តីថ្លៃថ្នូរ និង

---

730. Kendall, T. 2020. `A Synthesis of Evidence on the Collection and Use of Administrative Data on Violence against Women: Background Paper for the Development of Global Guidance.´ New York: UN Women.
731. Kendall, T. 2020. `A Synthesis of Evidence on the Collection and Use of Administrative Data on Violence against Women: Background Paper for the Development of Global Guidance.´ New York: UN Women.
732. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf។
733. UN Women (២០១៥) កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subjectto-violence។
734. UN Women (២០១៥) កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subjectto-violence។

សិទ្ធិស្មើភាព និងសេរីភាពក្នុងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនបន្តអាជីពវិជ្ជាជីវៈរបស់ខ្លួននិងធ្វើការជ្រើសរើសដោយគ្មានការរើសអើង និងការដាក់កំហិតដោយផ្នត់គំនិតតួនាទី និង ភាពលម្អៀង យេនឌ័រតឹងរ៉ឹង[735]។

**អត្តសញ្ញាណយេនឌ័រ** សំដៅលើអារម្មណ៍ និងបទពិសោធន៍ជ្រាលជ្រៅរបស់បុគ្គលម្នាក់អំពីយេនឌ័ររបស់ខ្លួន ដែលអាចឆ្លើយតបឬមិនឆ្លើយតបនឹងភេទដែលកំណត់ពីកំណើត។ អត្តសញ្ញាណយេនឌ័ររួមបញ្ចូលការយល់ឃើញរបស់បុគ្គលចំពោះរាងកាយ និងការបង្ហាញយេនឌ័រផ្សេងទៀត ដូចជា សំលៀកបំពាក់ ការនិយាយ និងចរិយាមាយាទ។ មនុស្សគ្រប់រូបសុទ្ធតែមានអត្តសញ្ញាណយេនឌ័រ។ អ្នកប្តូរយេនឌ័រជាពាក្យទូទៅដែលសំដៅលើអ្នកដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ទូលំទូលាយដែលមិនកំណត់អត្តសញ្ញាណដោយភេទដែលត្រូវបានកំណត់ពីកំណើត។ អ្នកប្តូរយេនឌ័រអាចត្រូវបានកំណត់អត្តសញ្ញាណដោយអត្តសញ្ញាណយេនឌ័រផ្សេងៗ ដូចជា បុរស ស្ត្រី បុរសប្តូរយេនឌ័រ ស្ត្រីប្តូរយេនឌ័រ និងមានពាក្យហៅជាក់លាក់ រួមទាំងអត្តសញ្ញាណដែលមិនពាក់ព័ន្ធនឹងភាពជាបុរស និងភាពជាស្ត្រី ដូចជា hijra, fa'afafine, two-spirit ។ល។ Cisgender ជាពាក្យសំដៅលើមនុស្សដែលមានអត្តសញ្ញាណយេនឌ័រដូចនឹងភេទពីកំណើត[736]។

**វិសមភាពយេនឌ័រ** សំដៅលើបទដ្ឋានយេនឌ័រ តួនាទី ការអនុវត្តក្នុងវប្បធម៌ គោលនយោបាយ និងច្បាប់ កត្តាសេដ្ឋកិច្ច និងការអនុវត្តក្នុងស្ថាប័នដែលរួមចំណែកជារួមដល់និងបណ្តោយឱ្យមានទំនាក់ទំនងអំណាចមិនស្មើភាពរវាងស្ត្រី និងបុរស។ វិសមភាពនេះធ្វើឱ្យស្ត្រីជួបការលំបាកខ្លាំងក្នុងសង្គមភាគច្រើន[737]។

**យេនឌ័រ** សំដៅលើគុណលក្ខណៈក្នុងសង្គម និងឱកាសដែលពាក់ព័ន្ធនឹងភាពជាបុរស និងភាពជាស្ត្រី ទំនាក់ទំនងរវាងស្ត្រី និងបុរស និងទំនាក់ទំនងរវាងក្មេងស្រីនិងក្មេងប្រុស ក៏ដូចជា ទំនាក់ទំនងរវាងស្ត្រី និងបុរស។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងទាំងនេះត្រូវបានកំណត់ក្នុងសង្គម និងត្រូវបានរៀនសូត្រក្នុងដំណើរការសង្គមនីយកម្ម។ យេនឌ័រផ្អែកតាមបរិបទ/ពេលវេលា និងអាចប្រែប្រួល[738]។

**ផ្នត់គំនិតយេនឌ័រ**ជាទស្សនៈ ឬបុរេនិច្ឆ័យជារួមចំពោះគុណលក្ខណៈ ឬបុគ្គលិកលក្ខណៈដែលស្ត្រី និងប្រុសគួរមាន ឬតួនាទីដែលត្រូវបាន និងគួរត្រូវបានបំពេញដោយបុរស និងស្ត្រី[739]។

**អភិក្រមប្រកបដោយទស្សនទានយេនឌ័រ** ជំរុញលើកទឹកចិត្តឱ្យមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីតួនាទីនិងបទដ្ឋានយេនឌ័រ។ អភិក្រមនេះរួមបញ្ចូលរបៀបផ្លាស់ប្តូរបទដ្ឋានយេនឌ័រអវិជ្ជមានដើម្បីពង្រឹងទំនាក់ទំនងអំណាចដែលកាន់តែមានសមធម៌រវាងស្ត្រីនិងបុរសនិងរវាងស្ត្រីនិងអ្នកផ្សេងទៀតក្នុងសហគមន៍។ អភិក្រមនេះលើកកម្ពស់សិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ស្ត្រីដេញដោលការបែងចែកធនធានដោយលម្អៀង និងគ្មានសមភាព និងការបែងចែកភារកិច្ចរវាងបុរសនិងស្ត្រីនិងពិចារណាពីតម្រូវការជាក់លាក់របស់ស្ត្រី និងបុរស។ អភិក្រមទាំងនេះអាចអនុវត្តដាច់ដោយឡែកពីគ្នាជាមួយស្ត្រីនិងក្មេងស្រីនិងជាមួយបុរសនិងក្មេងប្រុស។ ទោះជាយ៉ាងណា អភិក្រមនេះកំពុងត្រូវបានអនុវត្តកាន់តែច្រើនឡើងទាំងជាមួយស្ត្រីនិងក្មេងស្រីនិងជាមួយបុរស និងក្មេងប្រុស និងពីមួយជំនាន់ទៅមួយជំនាន់ក្នុងពេលដំណាលគ្នា ឬតាមរបៀបដែលមានការសម្របសម្រួលដើម្បីដេញដោលបទដ្ឋានអវិជ្ជមាននៃភាពជាបុរស និងភាពជាស្ត្រី និងទំនាក់ទំនងអំណាចមិនស្មើភាពដែលអាចប្រកាន់ខ្ជាប់ដោយបុគ្គលគ្រប់រូបក្នុងសហគមន៍[740]។

735. UN Women (២០១៥) "ក្របខណ្ឌគាំទ្រការទប់ស្កាត់អំពើហិង្សាលើស្ត្រី" ៖ https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework។
736. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf។
737. UN Women (២០១៥) "ក្របខណ្ឌគាំទ្រការទប់ស្កាត់អំពើហិង្សាលើស្ត្រី" ៖ https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework។
738. ការិយាល័យទីប្រឹក្សាពិសេសទទួលបន្ទុកបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រី ២០០១។
739. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHR Investigations.pdf។
740. WHO (2013b) ១៦ គំនិតសម្រាប់ការដោះស្រាយអំពើហិង្សាលើស្ត្រីក្នុងបរិបទនៃមេរោគអេដស៍ ៖ ឧបករណ៍រៀបចំកម្មវិធី-http://www.who.int/reproductivehealth/publications/violence/vaw_hiv_epidemic/en/.

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** ជាអំពើហិង្សាដែលផ្តោតលើឬបង្កផលប៉ះពាល់ខ្លាំងលើនរណាម្នាក់ដោយសារតែយេនឌ័រ ឬភេទរបស់ពួកគេ។ អំពើហិង្សានេះមានទម្រង់ចម្រុះរួមទាំងអំពើឬភាពអសកម្មដែលមានគោលបំណងឬអាចនឹងបង្ក ឬបណ្តាលឱ្យស្លាប់ ឬគ្រោះថ្នាក់ ឬការរងគ្រោះផ្លូវកាយ ផ្លូវភេទ ឬផ្នែកសេដ្ឋកិច្ច ការគំរាមកំហែងប្រព្រឹត្ត ការបៀតបៀន ការបង្ខិតបង្ខំ និងការដកហូតសេរីភាពតាមទំនើងចិត្ត[741]។

**យុត្តិធម៌ព្រហ្មទណ្ឌដែលឆ្លើយតបនឹងយេនឌ័រ** សំដៅលើការធានាថា ច្បាប់ ស្ថាប័នយុត្តិធម៌ ព្រហ្មទណ្ឌ ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងលទ្ធផលយុត្តិធម៌ព្រហ្មទណ្ឌ មិនរើសអើងនរណាម្នាក់ដោយសារយេនឌ័រ។ ពាក្យនេះផ្តោតលើការពិចារណាពីទស្សនៈយេនឌ័រក្នុងច្បាប់ព្រហ្មទណ្ឌក៏ដូចជាការវាយតម្លៃលទ្ធភាពទទួលបាន និងឧបសគ្គរារាំងស្ត្រី និងបុរសក្នុងការទទួលបាននីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តយុទ្ធសាស្ត្រដែលគិតគូរពីយេនឌ័រសម្រាប់ការការពារជនរងគ្រោះនិងការលើកកម្ពស់លទ្ធភាពទទួលបានយុត្តិធម៌ព្រហ្មទណ្ឌ[742]។

**ភាពប្រទាក់ក្រឡាគ្នា** ជាឧបករណ៍វិភាគ និងមធ្យោបាយបដិបត្តិដែលដេញដោលគំនិតនៃ "ភាពដូចគ្នា"។ ពាក្យនេះសំដៅលើ "ទម្រង់ជាក់លាក់នៃការគៀបសង្កត់ដែលប្រទាក់ក្រឡាគ្នា ដូចជា ភាពប្រទាក់ក្រឡាគ្នានៃជាតិសាសន៍ និងយេនឌ័រ ឬផ្លូវភេទ និងប្រជាជាតិ។ គំរូប្រទាក់ក្រឡាគ្នារំលឹកយើងថា ការគៀបសង្កត់មិនអាចត្រូវបានកាត់បន្ថយត្រឹមប្រភេទដ៏សំខាន់មួយនោះទេ ហើយការគៀបសង្កត់នាំទៅរកភាពអយុត្តិធម៌"[743]។អភិក្រមប្រទាក់ក្រឡាគ្នាសម្រាប់អំពើហិង្សាលើស្ត្រីរួមបញ្ចូលការពិចារណាពីករណីដែលយេនឌ័រប្រទាក់ក្រឡាគ្នានឹងវិសមភាព/ការគៀបសង្កត់ផ្សេងទៀត (ផ្លូវភេទ អត្តសញ្ញាណ យេនឌ័រ ជាតិសាសន៍ ជាតិពន្ធុ ស្ថានភាពជាជនជាតិដើមភាគតិច ស្ថានភាពទេសន្តរប្រវេសន៍ ពិការភាព) ដើម្បីបង្ហាញបទពិសោធន៍នៃការរងគ្រោះដោយអំពើហិង្សា[744]។

**អំពើហិង្សាលើដៃគូស្និទ្ធស្នាល** ជាអាកប្បកិរិយារបស់បុរស ឬស្ត្រីម្នាក់ ឬក្មេងប្រុស ឬក្មេងស្រីម្នាក់ ក្នុងទំនាក់ទំនងស្និទ្ធស្នាល ដែលបង្កគ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តលើអ្នកដទៃទៀតដែលមានទំនាក់ទំនងជាមួយខ្លួន។ នេះជាទម្រង់ទូទៅបំផុតនៃអំពើហិង្សាលើស្ត្រី។ ពេលខ្លះអំពើហិង្សាលើដៃគូស្និទ្ធស្នាលអាចសំដៅលើ "អំពើហិង្សាក្នុងគ្រួសារ" ទោះបីជាពាក្យទាំងនេះរួមបញ្ចូលអំពើហិង្សាដែលប្រព្រឹត្តដោយ និងលើសមាជិកគ្រួសារផ្សេងទៀតក្តី[745]។ អំពើហិង្សាលើដៃគូស្និទ្ធស្នាលធ្វើឱ្យស្ត្រីរងគ្រោះខ្លាំងជាងបុរស ខណៈដែលជនបង្កយ៉ាងច្រើនលើសលប់គឺជាបុរស។ អំពើហិង្សានេះក៏ពាក់ព័ន្ធនឹងភាពខុសគ្នានៃអំណាចដែលកំណត់ក្នុងសង្គមរវាងបុរស និងស្ត្រីផងដែរ[746]។

**ការចូលរួមប្រកបដោយអត្ថន័យ** ទាមទារឱ្យបុគ្គលមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលជះឥទ្ធិពលផ្ទាល់លើពួកគេរួមទាំងការធ្វើសេចក្តីសម្រេចចិត្តក្នុងការបង្កើត ការអនុវត្ត និងការពិនិត្យតាមដានអន្តរាគមន៍សុខភាព។ក្នុងការអនុវត្តការចូលរួមប្រកបដោយអត្ថន័យអាចមានទម្រង់ខុសៗគ្នាជាច្រើន ដូចជា ការផ្តល់ព័ត៌មានដែលមានតុល្យភាព និងសត្យានុម័ត ការពិគ្រោះជាមួយសហគមន៍ដើម្បីទទួលបានយោបល់ត្រឡប់ពីប្រជាជនរងផលប៉ះពាល់ ការជំរុញការចូលរួម ឬការធ្វើការដោយផ្ទាល់ជាមួយសហគមន៍ការសហការតាមរយៈការចាប់ដៃជាមួយសហគមន៍ដែលរងផលប៉ះពាល់ក្នុងផ្នែកនីមួយៗ

---

741. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf។
742. Skinnider, Eileen. 'Towards Gender-Responsive Criminal Justice: Good practices from Southeast Asia in responding to violence against women' (2018: Thailand Institute of Justice).
743. Hill Collins, P., 1990. 'Black Feminist Thought: Knowledge, Consciousness, and the Politics of Empowerment. Routledge', New York; cited in Imkaan and UN Women (2019), 'The Value of Intersectionality in Understanding Violence against Women and Girls', at: https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339.
744. Imkaan and UN Women (2019), 'The Value of Intersectionality in Understanding Violence against Women and Girls', at: https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20 intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339.
745. UN Women (២០១៥) "ក្របខណ្ឌគាំទ្រការទប់ស្កាត់អំពើហិង្សាលើស្ត្រី" ៖ https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2015/prevention_framework_unwomen_nov2015.pdf?la=en&vs=5223
746. ក្រុមប្រឹក្សាអឺរ៉ុប គណៈកម្មាធិការរដ្ឋមន្ត្រី កិច្ចប្រជុំលេខ ១០៣៧ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ គណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកបញ្ហាបទល្មើស ការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់អនុសញ្ញាប្រឆាំងអំពើហិង្សាក្នុងគ្រួសារ។

នៃការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងការបង្កើតជម្រើស និងការរិះរកដំណោះស្រាយនិងការបង្កើនភាព អង់អាចរបស់សហគមន៍ ដើម្បីរក្សាការគ្រប់គ្រងចុងក្រោយលើការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ ដែលបង្កផលប៉ះពាល់លើសុខុមាលភាពរបស់ពួកគេ[747]។

**នគរបាល** ជាពាក្យទូទៅសម្រាប់ស្ថាប័នទាំងអស់ដែលមានអំណាចបង្ខំតាមផ្លូវច្បាប់។

**ភេទ** ជាបណ្តុំលក្ខណៈផ្នែកជីវសាស្ត្រ និងចិត្តសាស្ត្រដែលកំណត់លក្ខណៈជាមនុស្សប្រុស និងមនុស្សស្រី ដូចជាសរីរាង្គបន្តពូជ សមាសជាតុអរម៉ូន គំរូក្រូម៉ូសូម គំរូនៃការដុះសក់ របាយសាច់ដុំ និងខ្លាញ់ សណ្ឋានរាងកាយ និងសំណង់គ្រោងឆ្អឹង។ ជាញឹកញាប់ ឯកសារនេះនឹងសំដៅលើស្ត្រី បុរស និងអ្នកផ្សេងទៀតដើម្បីរួមបញ្ចូលស្វ័យកំណត់អត្តសញ្ញាណផ្លូវភេទដែលពាក់ព័ន្ធនឹងភាពជាបុរស ឬភាពជាស្ត្រី និងមិនពាក់ព័ន្ធនឹងភាពជាបុរស ឬភាពជាស្ត្រី[748]។

**ទិន្នន័យបែងចែកតាមភេទ** ជាទិន្នន័យដែលត្រូវបានប្រមូល និងបង្ហាញដោយឡែកពីគ្នាស្តីពីស្ត្រី និងក្មេងស្រី និងស្តីពីបុរស និងក្មេងប្រុស។ ទិន្នន័យនេះរួមចំណែកដល់ការរំលេចកាន់តែសុក្រិតនូវតួនាទី ស្ថានភាពជាក់ស្តែង និងលក្ខខណ្ឌទូទៅរបស់ស្ត្រី និងបុរសក្នុងទិដ្ឋភាពនីមួយៗរបស់សង្គម ដូចជា អត្រាអក្ខរភាព កម្រិតអប់រំ ការកាន់កាប់ជំនួញ ការងារ ប្រាក់ឈ្នួល មនុស្សក្នុងបន្ទុក ផ្ទះសម្បែង និងកម្មសិទ្ធិដីធ្លី ប្រាក់កម្ចី ឥណទាន និងបំណុល។ ទិន្នន័យបែងចែកតាមភេទក៏សំខាន់សម្រាប់ទិន្នន័យដែលត្រូវបង្ហាញស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់បុគ្គលផ្សេងទៀតដែលមិនប្រើប្រាស់ឬយល់ថាមានតំណាងក្នុងប្រភេទ ភេទ/យេនឌ័រដែលពាក់ព័ន្ធនឹងភាពជាបុរស ឬភាពជាស្ត្រីផងដែរ[749]។

**អ្នករស់រានមានជីវិត (survivor)** សំដៅលើស្ត្រី និងក្មេងស្រីដែលធ្លាប់រងគ្រោះឬកំពុងរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងការឆ្លុះបញ្ចាំងវាក្យស័ព្ទដែលប្រើប្រាស់ក្នុងដំណើរការច្បាប់ផង និងអ្នកដែលតំណាងឱ្យស្ត្រី និងក្មេងស្រីទាំងនេះ ក្នុងការស្វែងរកសេវាសំខាន់ៗផង[750]។

**គោលការណ៍មិនបង្កគ្រោះថ្នាក់** ទាមទារការវាយតម្លៃសមស្របលើឌីណាមិកយេនឌ័រនិងបទដ្ឋានវប្បធម៌ដែលអាចធ្វើឱ្យជនរងគ្រោះ និងសាក្សីប្រឈមនឹងគ្រោះថ្នាក់បន្ថែមទៀត រួមទាំងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ឬការមាក់ងាយ អំពើហិង្សា និងការមិនទទួលបានការយកចិត្តទុកដាក់ ដោយសារជនបង្ក ឬគ្រួសារ និងសហគមន៍របស់ជនរងគ្រោះ[751]។

**ជនរងគ្រោះ (victim)** បុគ្គលដែលទទួលរងគ្រោះថ្នាក់ជាលក្ខណៈបុគ្គលឬជាសមូហភាពរួមទាំងរបួសផ្លូវកាយឬរបួសផ្លូវចិត្ត ការរងគ្រោះផ្លូវចិត្ត ការខាតបង់ផ្នែកសេដ្ឋកិច្ច ឬការថយចុះយ៉ាងខ្លាំងនៃសិទ្ធិជាសារវន្តរបស់ខ្លួនដោយសារអំពើឬភាពអកម្មដែលរំលោភច្បាប់ព្រហ្មទណ្ឌដែលមានចែងក្នុងរដ្ឋសមាជិក រួមទាំងច្បាប់ដែលបដិសេធការបំពានអំណាចប្រព្រឹត្តដោយជនល្មើស[752]។

**អំពើហិង្សាលើស្ត្រី** សំដៅលើ "ការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបង្កជាឬនឹងបង្កជាគ្រោះថ្នាក់ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី ដូចជា ការគំរាមកំហែងប្រព្រឹត្ត ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានក្នុងជីវិតសាធារណៈ ឬជីវិតឯកជនឡើយ"[753]។

747. WHO ការចូលរួមក្នុងសង្គម ៖ https://www.euro.who.int/en/health-topics/health-determinants/social-determinants/publications/2019/participation-as-a-driver-of-health-equity-2019 ។

748. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf

749. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf

750. UN Women (២០១៥) កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ https://www.unwomen.org/ en/digitallibrary/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence។

751. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf

752. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (២០១៨) ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការស៊ើបអង្កេតសិទ្ធិមនុស្ស ៖ ការណែនាំ និងការអនុវត្ត ៖ https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegration intoHRInvestigations.pdf

**ផលងាយរងគ្រោះ** សំដៅលើអ្នកដែលមានការលំបាកក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួននៅចំពោះមុខប្រព័ន្ធយុត្តិធម៌ដែលត្រូវបានច្បាប់ទទួលស្គាល់ ដោយសារអាយុ យេនឌ័រ ស្ថានភាពផ្លូវកាយ ឬផ្លូវចិត្ត ឬដោយសារកាលៈទេសៈសង្គម សេដ្ឋកិច្ច ជាតិពន្ធុ និង/ឬវប្បធម៌។ ចំណុចដូចតទៅនេះអាចបង្កជាភាពងាយរងគ្រោះ ៖ អាយុ ពិការភាព ភាពជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ឬជនជាតិភាគតិច ការធ្វើឱ្យរងគ្រោះ ការធ្វើចំណាកស្រុក និងការបាត់បង់ទីលំនៅក្នុងប្រទេស ភាពក្រីក្រ យេនឌ័រ និងការដកហូតសេរីភាព។ និយមន័យជាក់លាក់នៃក្រុមងាយរងគ្រោះក្នុងប្រទេសនីមួយៗនឹងអាស្រ័យលើលក្ខណៈជាក់លាក់ ក៏ដូចជាកម្រិតនៃការអភិវឌ្ឍសង្គម ឬសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ[754]។

753. សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី មាត្រា ១។
754. UNODC (២០១៣) ឯកសារបញ្ហា ៖ ការរំលោភគោលជំហរនៃភាពងាយរងគ្រោះ និង "មធ្យោបាយ" ផ្សេងទៀតក្នុងការកំណត់និយមន័យនៃការជួញដូរមនុស្ស៖https://www.unodc.org/documents/human-trafficking/2012/UNODC_2012_Issue_Paper_-_Abuse_of_a_ Position _of_Vulnerability.pdf

# BIBLIOGRAPHY

## CHAPTER 2: Making a Difference as a Manager and Team Leader


1. 'Secretary-General says Violence against Women never Acceptable, Never Excusable, Never Tolerable, as He Launches Global Campaign on Issue (2008). UN Press Release at: https://www.un.org/press/en/2008/sgsm11437.doc.htm

2. Domestic Abuse Strategy (2015-2020). The production of this document, and the contribution of resources to support the Strategy's development and ongoing maintenance, is sponsored by the States of Guernsey Home Department. See: https://www.gov.gg/CHttpHandler.ashx?id=98929&p=0

3. 'A Practitioner's Toolkit on Women's Access to Justice Programming (UN Women, 2018), at: https://www.unwomen.org/en/digital-library/publications/2018/5/a-practitioners-toolkit-on-womens-access-to-justice-programming

4. 'Everyone's business: Improving the police response to domestic abuse (Her Majesty's Inspectorate of Constabulary and Fire & Rescue Services (now HMICFRS formally HCIM) (2014) at: https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/2014/04/improving-the-police-response-to-domestic-abuse.pdf

5. 'How to Design Projects to End Violence against Women and Girls a Step-by-Step Guide to Taking Action' (UN Women, 2015), at: https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2015/07/evaw%20toolkit%20unw_finalcompressed.pdf?la=en&vs=2418

6. Justice Department Issues Guidance on Identifying and Preventing Gender Bias in Law Enforcement Response to Sexual Assault and Domestic Violence (US Department of Justice, Office of Public Affairs, 2015) at: https://www.justice.gov/opa/pr/justice-department-issues-guidance-identifying-and-preventing-gender-bias-law-enforcement

7. 'Why do some men use violence against women and how can we prevent it?' (Partners for prevention, 2013). A UNDP, UNFPA, UN Women and UNV regional joint programme for gender-based violence prevention in Asia and the Pacific Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific at: http://www.partners4prevention.org/sites/default/files/resources/p4p-report.pdf

8. 'Gender Toolkit: Standardised Best Practices on Gender Mainstreaming in Peacekeeping Handbook' (United Nations Police, 2015) at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Handbook.pdf?sequence=51&isAllowed=y

9. OSCE-Led survey on violence against women: Main report (Organization for Security and Co-operation in Europe, 2019) at: https://www.osce.org/secretariat/413237?download=true

10. National Outcome Standards for Perpetrator Interventions (NOSPI) Baseline Report 2015-2016. Australian Department for Social Sciences, at: https://plan4womenssafety.dss.gov.au/wp-content/uploads/2018/08/nationaloutcomestandardsreportweb.pdf

11. 'Rape and Sexual Assault', ed. Welch, J. and F. Mason. 2007 in the British Medical Journal 334, no. 7604: 1154–1158.

12. Progress of the World's Women in Pursuit of Justice (UN Women, 2011) at: https://www.unwomen.org/en/digital-library/publications/2011/7/progress-of-the-world-s-women-in-pursuit-of-justice

13. Demarginalizing the Intersection of Race and Sex: A Black Feminist Critique of Antidiscrimination Doctrine, Feminist Theory and Antiracist Politics. Crenshaw, K. University of Chicago Legal Forum Volume 1989, Issue 1 Article 8, at: https://chicagounbound.uchicago.edu/cgi/viewcontent.cgi?article=1052&context=uclf

14. Glossary of Terms and Concepts (UNICEF Regional Office for South Asia, 2017) at: https://www.unicef.org/rosa/media/1761/file/Gender%20glossary%20of%20terms%20and%20concepts%20.pdf.

15. The Sphere Handbook: Humanitarian Charter and Minimum Standards in Humanitarian Response (The Sphere Association, 2015), fourth edition, Geneva, Switzerland, at: www.spherestandards.org/handbook

16. Security Sector Reform Assessment, Monitoring and Evaluation and Gender. Gender and SSR Toolkit (2008), Bastick, M., and Valasek, K., Geneva Centre for Security Sector Governance, at: https://www.dcaf.ch/gender-security-sector-reform-toolkit

17. Gender-based Violence Resource Pack. A Standardized Training Tool for Duty Bearers, Stakeholders, and Rights Holders (UN Women, 2019), at: https://www.

genderinkenya.org/wp-content/uploads/2019/11/GBV-Resource-Pack-13-Sept-w-3mm-bleed.pdf

18. Case Study: Imkaan—Supporting Asian, Black, Minority, Ethnic, and Refugee Survivors (UK), at: http://www.endvawnow.org/uploads/browser/files/shelter_uk_case_study_imkaan.pdf

19. How the police are letting sexual assault victims down (2014). Bates, L., for The Guardian at: https://www.theguardian.com/lifeandstyle/womens-blog/2014/nov/21/police-letting-rape-victims-down-too

20. From the Margin to the Centre: Addressing Violence Against Women and Girls Alternative Bill October (Imkaan, 2018), see: https://829ef90d-0745-49b2-b404-cbea85f15fda.filesusr.com/ugd/2f475d_91a5eb-3394374f24892ca1e1ebfeea2e.pdf

21. Tool 2: Policing and Gender in Gender and Security Toolkit. Geneva (DCAF, OSCE/ODIHR, UN Women, 2019), at: https://www.dcaf.ch/sites/default/files/publications/documents/GSToolkit_Tool-2%20EN%20FINAL.pdf

22. 'The Police', SSR Backgrounder Series, Geneva, (DCAF, 2015), at: http://ssrbackgrounders.org/fall.php?p=16&l=EN

23. 'Integrating gender into internal police oversight' (DCAF, OSCE, OSCE/ODIHR, 2014), at: https://www.dcaf.ch/integrating-gender-internal-police-oversight

24. 'Police as an Entry Point to End Violence Against Women and Girls. Lessons from Civil Society Organizations Funded by the UN Trust Fund to End Violence Against Women', (UN Trust Fund to End Violence against Women. New York (UN Women, 2019).

25. 'The Value of Intersectionality in Understanding Violence against Women and Girls (VAWG)', (Imkaan, UN Women and the European Union, 2019) at: https://www2.unwomen.org/-/media/field%20office%20eca/attachments/publications/2019/10/the%20value%20of%20intersectionality%20in%20understanding%20violence%20against%20women%20and%20girls.pdf?la=en&vs=3339

26. 'Thematic study on the issue of violence against women and girls and disability', Report of the Office of the United Nations High Commissioner for Human Rights, 30 March 2012, A/HRC/20/5, at: https://www2.ohchr.org/english/issues/women/docs/A.HRC.20.5.pdf

27. 'The Trial of Rape. Understanding the Criminal Justice System Response to Sexual Violence in Thailand and Viet Nam' (UN Women, UNDP and UNODC, 2017), at: https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2019/08/ap-trial-of-rape_26aug2019_lowres-compressed.pdf?la=en&vs=1916

28. 'Intimate Partner Violence Response Policy and Training Content Guidelines 6' (International Association of Chiefs of Police, 2015), at: https://www.theiacp.org/sites/default/files/all/i-j/IACPIntimatePartnerViolenceResponsePolicyandTrainingGuidelines2017.pdf

29. Glossary of Common Terms in Gender Equality and Feminist Theory (2015), Šribar, R., in Gendering Science: Slovenian Surveys and Studies in the EU Paradigms, Vienna, Echoraum. Ule, M., Šribar, R., and Venturini, A.U., eds.

30. 'Gender sensitivity', (European Institute for Gender Equality, 2019) at: https://eige.europa.eu/thesaurus/terms/1218?utm_source=newsletter&utm_medium=email&utm_campaign=how_gender_equal_is_your_parliament&utm_term=2019-11-27

## CHAPTER 3: Prevention

1. 'The Rule of Law and Transitional Justice in Conflict and Post-Conflict Societies', Report of the Secretary-General. -United Nations (S/2004/616, para. 4), at: https://www.securitycouncilreport.org/atf/cf/%7B65B-FCF9B-6D27-4E9C-8CD3-CF6E4FF96FF9%7D/PCS%20S%202004%20616.pdf

2. 'Code of Conduct for Law Enforcement Officials', Adopted by General Assembly resolution 34/169 of 17 December 1979, see: https://www.ohchr.org/EN/ProfessionalInterest/Pages/LawEnforcementOfficials.aspx

3. 'Aspects of violence against women that pertain directly to the Commission on Crime Prevention and Criminal Justice' (UNODC, 2018), Commission on Crime Prevention and Criminal Justice V.08-52191 (E) *0852191* Seventeenth session Vienna, at: https://www.unodc.org/pdf/criminal_justice/Note_by_the_Secretariat_on_Aspects_of_Violence_against_Women_that_Pertain_Directly_to_the_CCPCJ.pdf

4. 'Recommendations for action against gender-related killing of women and girls' (UNODC, 2015), at: https://www.undc.org/documents/justice-and-prison-reform/15-08233_A4-GRK_eBook.pdf

5. UN General Assembly in the 2010 Updated Model Strategies and Practical Measures on the Elimination of Violence against Women in the Field of Crime Prevention and Criminal Justice (2011, General Assembly resolution 65/228, annex), at: https://www.unodc.org/documents/justice-and-prison-reform/

crimeprevention/Model_Strategies_and_Practical_Measures_on_the_Elimination_of_Violence_against_Women_in_the_Field_of_Crime_Prevention_and_Criminal_Justice.pdf

6. 'United Nations Guidelines for the Prevention of Crime', Economic and Social Council resolution 2002/13, annex, at: https://www.unodc.org/documents/justice-and-prison-reform/crimeprevention/resolution_2002-13.pdf

7. 'United Nations Standards and Norms in Crime Prevention At Your Finger Tips', at: https://www.unodc.org/pdf/criminal_justice/UN_standards_and_norms_in_crime_prevention_at_your_fingertips.pdf

8. 'Handbook on the Crime Prevention Guidelines Making Them Work (UNODC, 2010), at: https://www.unodc.org/pdf/criminal_justice/Handbook_on_Crime_Prevention_Guidelines_-_Making_them_work.pdf

9. 'Police–victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research (2017), Birdsall, N., Kirby, S., and McManus, M., 18:1, 75-86, DOI: 10.1080/15614263.2016.1230061

10. 'Understanding Public Attitudes to Criminal Justice' (2005). Roberts, J., & Hough, M. Maidenhead: Open University Press.

11. 'Guidelines on Police Operations in United Nations Peacekeeping Operations and Special Political Missions (UN DPKO-DFS, 2015), at: https://police.un.org/sites/default/files/sgf-guidelines_police_operations-2015.pdf

12. Global Report Police Station Visiting Week 2012: Advancing Human Rights Standards in Police Stations. (Altus Global Alliance) at: https://issat.dcaf.ch/download/29464/413964/Altus%20Global%20Report%202012%20(2).pdf

13. Secretary-General's study on violence against women (A/61/122/Add.1).

14. 'A Framework to Underpin Action to Prevent Violence against Women (UN Women et al., 2015), at: https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework

15. Reinforcing community and local security structures in Suzak, Kyrgyzstan (Saferworld, 2015), at: https://www.saferworld.org.uk/en-stories-of-change/reinforcing-community-and-local-security-structures-in-suzak-kyrgyzstan

16. 'Police Integrity Toolkit', (The Geneva Centre for Security Sector Governance, 2012), at: https://www.dcaf.ch/sites/default/files/publications/documents/Toolkit_ENG_screen.pdf

17. The Austrian Model of intervention in Cases of Domestic Violence, Logar, R., paper presented at the UN Expert Group Meeting: Violence against women: Good practice in combating and eliminating violence against women 17–20 May 2005, Vienna, 2005, see: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/logar.dv.pdf

18. 'Ending violence against women and girls: The world's best laws and policies' (Future Policy Award) (UN Women, World Future Council and Inter Parliamentary Union, 2014), see: https://www.worldfuturecouncil.org/wp-content/uploads/2016/01/WFC_2014_Future_Policy_Award_En.pdf

19. 'Eliminating Violence Against Women in the Asia Pacific: It's all of our responsibility' (UN Women, 2015) at: https://www.aidsdatahub.org/sites/default/files/publication/UN_Women_2015_Eliminating_violence_against_women_in_the_Asia_Pacific.pdf

20. 'Ten Years of Austrian Anti-Violence Legislation' (2017), International Conference in the Context of the Council of Europe Campaign to Combat Violence Against Women, Including Domestic Violence 5 to 7 November 2007 Vienna and St. Pölten, Austria, see: https://www.interventionsstelle-wien.at/download/?id=406

21. 'A Study for Creating a Multidisciplinary Response Mechanism to Violence Against Women in Egypt' (UNODC, 2015).

22. 'A Framework to Underpin Action to Prevent Violence against Women' (UN Women et al., 2015), at: https://www.unwomen.org/en/digital-library/publications/2015/11/prevention-framework

23. 'Engagement and Communication Authorised Professional Practice' (UK College of Policing) at: https://www.app.college.police.uk/app-content/engagement-and-communication/engaging-with-communities

24. 'Gender-Based Violence (Violence Against Women and Girls)', (The World Bank, 2019), at: https://www.worldbank.org/en/topic/socialdevelopment/brief/violence-against-women-and-girls

25. 'Guidelines to Estimate the Economic Cost of Domestic Violence in the Arab Region (UNFPA, 2019), at: https://www.unescwa.org/sites/www.unescwa.org/files/publications/files/guidelines-estimate-economic-cost-domestic-violence-arab-region-english_0.pdf

26. 'Estimating Costs of Marital Violence in the Arab Region Operational Model' (Un Women, 2017),

E/ESCWA/ECW/2017/Technical Paper.4, 18 July 2017, at: https://www.unescwa.org/file/66255/download?token=fGod_SpM.

27. 'Understanding local security councils in two minutes', Coginta for Police Reforms, at: https://www.youtube.com/watch?v=7fGFo_nteGA

28. 'Qu'est-ce qu'un CLSPD - CISPD?' Government of France, at: http://www.isere.gouv.fr/Politiques-publiques/Securites/Securite-publique/Prevention-de-la-delinquance2/Qu-est-ce-qu-un-CLSPD-CISPD

29. 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée' (Coginta for Police Reform, 2017) at: http://www.coginta.org/uploads/documents/cedd246fbc7d133bcf29135bec8a66d561202ae4.pdf

30. 'Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR?' Fernandez, M., Piaget, K., Hernandez, T., and Berthoud, S. ISSAT HRBA Working Group Paper 3 (2017), at: https://issat.dcaf.ch/download/111714/2027474/HRBA%20Working%20Group%20Paper%203.pdf

31. 'Intersectionality and the inclusive approach to dealing with gender-based violence. A Position Paper from Women Against Violence Europe' (WAVE, 2018), at: http://fileserver.wave-network.org/researchreports/WAVE%20_positionpaper_intersectionality2018.pdf

32. World Health Organization Violence, 'Prevention: the evidence', at: https://www.who.int/violence_injury_prevention/violence/the-evidence/en/

33. 'ACES too High' News, at: https://acestoohigh.com/

34. 'Adverse Childhood Experiences (ACEs)', Martinez Calvo., S., at: https://www.70-30.org.uk/18737-2/

35. 'Combating violence against women: minimum standards for support services' (Directorate General of Human Rights and Legal Affairs, Council of Europe, Strasbourg, 2008), at: https://www.coe.int/t/dg2/equality/domesticviolencecampaign/Source/EG-VAW-CONF(2007)Study%20rev.en.pdf

36. 'Analytical study of the results of the 4th round of monitoring the implementation of Recommendation Rec (2002) 5 on the protection of women against violence in Council of Europe member states' (Council of Europe, 2014), at: https://rm.coe.int/16805915e9

37. 'What Is G.R.E.A.T.?' at: https://www.great-online.org/GREAT-Home

38. 'School-based Violence Prevention: A Practical Handbook', Geneva (World Health Organization, 2019), at: https://apps.who.int/iris/bitstream/handle/10665/324930/9789241515542-eng.pdf?sequence=1&isAllowed=y

39. 'Preventing Adverse Childhood Experiences (ACEs): Leveraging the Best Available Evidence' (Division of Violence Prevention National Center for Injury Prevention and Control Centers for Disease Control and Prevention Atlanta, Georgia, 2019) at: https://www.cdc.gov/violenceprevention/pdf/preventingACES-508.pdf

40. 'Project Tool 130: Checklist on problem resolution using the SARA model' in UNPOL Gender Toolkit Standardised Best Practices on Gender Mainstreaming in Peacekeeping - Compendium of Project Tools (2015), available at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Geder%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

## CHAPTER 4: Initial Contact

1. 'End Rape – An Intolerable Cost to Society', UN Women Executive Director's Statement for the International Day for the Elimination of Violence against Women (25 November 2019), see: https://eca.unwomen.org/pt/news/stories/2019/11/statement-ed-phumzile-day-for-the-elimination-of-violence-against-women

2. Module 3 Justice and Policing Essential Services Package for Women and Girls Subject to Violence. (UN Women, UNODC, UNFPA, WHO and UNDP, 2015), at: https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

3. 'Recommended Principles and Guidelines on Human Rights at International Borders' (OHCHR, 2015), at: https://www.ohchr.org/EN/Issues/Migration/Pages/InternationalBorders.aspx

4. 'United Nations Economic and Social Council in the Guidelines on Justice in Matters Involving Child Victims and Witnesses of Crime' (ECOSOC Resolution 2005/20), at: https://www.un.org/en/ecosoc/docs/2005/resolution%202005-20.pdf

5. 'OSCE-Led Survey on Violence Against Women: Main Report', (Organisation for the Security and Co-operation in Europe, Vienna, 2019), at: https://www.osce.org/secretariat/413237?download=true

6. 'Code of Conduct for Law Enforcement Officials', adopted by General Assembly resolution 34/169 of 17 December 1979, at: https://www.ohchr.org/en/

professionalinterest/pages/lawenforcementofficials.aspx

7. 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 1. End Violence Against Women International (EVAWI, 2017), Huhtanen, H., Lonsway, K.A., Archambault, J., at: https://www.evawintl.org/Library/DocumentLibraryHandler.ashx?id=934

8. 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 2. End Violence Against Women International (EVAWI, 2017), Huhtanen, H., Lonsway, K.A., Archambault, J.

9. 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 3. End Violence Against Women International (EVAWI, 2017), Huhtanen, H., Lonsway, K.A., Archambault, J.

10. 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 4. End Violence Against Women International (EVAWI, 2017), Huhtanen, H., Lonsway, K.A., Archambault, J.

11. 'Gender-Based Violence Training Manual for Judicial Officers in Uganda' (UN Women, 2019, unpublished).

12. 'Assessing the Extent of Crime Displacement and Diffusion of Benefits: A Review of Situational Crime Prevention Evaluations' (2009), Guerette, R.T., Bowers, K.J., in Criminology, 47(4), pp.1331-1368.

13. 'A Practitioner's Toolkit on Women's Access to Justice Programming (UN Women et al., 2018), at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

14. Declaration on the Elimination of Violence against Women; UN Committee on the Elimination of Discrimination Against Women, CEDAW General Recommendation No. 19 (1992): Violence against women. New York: CEDAW. Paras 7, 9, 24(a). https://www.un.org/en/genocideprevention/documents/atrocity-crimes/Doc.21_declaration%20elimination%20vaw.pdf

15. 'Strengthening Crime Prevention and Criminal Justice Response to Violence against Women' (UNODC, 2014), at: https://www.unodc.org/documents/justice-and-prison-reform/Strengthening_Crime_Prevention_and_Criminal_Justice_Responses_to_Violence_against_Women.pdf

16. 'Integrating a Gender Perspective into Human Rights Investigations Guidance and Practice' (UN Office of the High Commission for Human Rights, New York and Geneva, 2018) at: https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegrationintoHRInvestigations.pdf

17. 'Everyone's business: Improving the police response to domestic abuse' (Her Majesty's Inspectorate of Constabulary and Fire & Rescue Services (now HMICFRS formally HCIM) (2014) at: https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/2014/04/improving-the-police-response-to-domestic-abuse.pdf

18. 'Code of Conduct for Law Enforcement Officials', adopted by General Assembly resolution 34/169 of 17 December 1979, at: https://www.ohchr.org/EN/ProfessionalInterest/Pages/LawEnforcementOfficials.aspx

19. 'The Impact of Trauma on Adult Sexual Assault Victims', report Submitted to: Justice Canada. (2019). Haskell, L. and Randell, M., at: https://www.justice.gc.ca/eng/rp-pr/jr/trauma/trauma_eng.pdf

20. Sexual Assault Law, Credibility, and "Ideal Victims": Consent, Resistance, and Victim Blaming (2010). Randall, M. Canadian Journal of Women and the Law, 22(2), 397-43

21. Memory consolidation and the amygdala: a systems perspective (2002), McGaugh, J. L., in Trends Neurosci. 2002 Sep;25(9):456.

22. 'Start by Believing to Improve Responses to Sexual Assault and Prevent Gender Bias' (2017), Tanner, at: H. https://www.evawintl.org/Library/DocumentLibraryHandler.ashx?id=919

23. 'International Protocol on the Documentation and Investigation of Sexual Violence in Conflict. Best Practice on the Documentation of Sexual Violence as a Crime or Violation of International Law', 2nd Edition: Sara Ferro Ribeiro and Danaé van der Straten Ponthoz on behalf of the UK Foreign and Commonwealth Office, March 2017, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

24. 'Children and informal interpreting: Many children to take on an informal interpretation or translation role for their family', (The Children's Society, UK) at: https://www.childrenssociety.org.uk/youngcarer/refugee-toolkit/children-and-informal-interpreting

25. False Accusations (Rape Crisis Scotland), at: https://www.rapecrisisscotland.org.uk/false-allegations/

26. 'The CSW 57 Agreed Conclusions on the elimination and prevention of all forms of violence against women and girls uphold the holistic response of the Istanbul Convention and its progressive understanding of violence against women and States responsibilities' at: https://rm.coe.int/168063bc34

27. Minority Rights Group International, at: https://minorityrights.org/2019/12/10/marginalized-and-violated-gbv/

28. 'Principles and Guidelines, supported by practical guidance, on the human rights protection of migrants in vulnerable situations' (OHCHR and the Global Migration Group), at: https://www.ohchr.org/Documents/Issues/Migration/PrinciplesAndGuidelines.pdf

29. UNPOL Gender Toolkit Standardised Best Practices on Gender Mainstreaming in Peacekeeping Compendium of Project Tools (2015), at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

## CHAPTER 5: Investigation

1. UN General Assembly in the 2010 Updated Model Strategies and Practical Measures on the Elimination of Violence against Women in the Field of Crime Prevention and Criminal Justice (2011), General Assembly resolution 65/228, annex), at: https://www.unodc.org/documents/justice-and-prison-reform/crimeprevention/Model_Strategies_and_Practical_Measures_on_the_Elimination_of_Violence_against_Women_in_the_Field_of_Crime_Prevention_and_Criminal_Justice.pdf

2. Investigation Process (College of Policing, UK) at: https://www.app.college.police.uk/app-content/investigations/investigation-process/

3. 'Gender Bias in Sexual Assault Response and Investigation', Training Bulletin Series: Part 1. End Violence Against Women International (EVAWI, 2017), Huhtanen, H., Lonsway, K.A., Archambault, J.

4. 'Unbiased Policing' (Provincial Government of British Columbia), at: https://engage.gov.bc.ca/unbiasedpolicing/work-to-date/

5. 'Measuring Performance in a Modern Police Organization' in New Perspectives in Policing, Malcolm K. Sparrow 2015, National Institute of Justice https://www.ncjrs.gov/pdffiles1/nij/248476.pdf

6. SGBV Investigation Planning (2015) Erin Gallagher. Institute for International Criminal *Investigations (*IICI) and the Justice Rapid Response.

7. 'Police–victim engagement in building a victim empowerment approach to intimate partner violence cases', Police Practice and Research (2017), Birdsall, N., Kirby, S., and McManus, M., 18:1, 75-86, DOI: 10.1080/15614263.2016.1230061 Understanding public attitudes to criminal justice.

8. Office of the United Nations High Commissioner for Refugees; Office of the UN Secretary-General's Envoy on Youth, at: https://www.un.org/youthenvoy/2013/09/office-of-the-united-nations-high-commissioner-for-refugees/

9. 'Major Investigation and Public Protection: First Response' (College of Policing, UK), at: https://www.app.college.police.uk/app-content/major-investigation-and-public-protection/domestic-abuse/first-response/

10. 'Handbook on Effective Police Responses to Violence against Women' (UNODC, 2010) at: https://www.unodc.org/documents/justice-and-prison-reform/Handbook_on_Effective_police_responses_to_violence_against_women_English.pdf

11. 'Training Programme on the Treatment of Child Victim/survivors and Child Witnesses of Crime for Law Enforcement Officials' (UNODC, 2015), at: https://www.unodc.org/documents/justice-and-prison-reform/Training_Programme_on_the_Treatment_of_Child_Victim/survivors_and_Child_Witnesses_of_Crime_-_Law_Enforcement.pdf

12. United Nations Police Gender Toolkit (UN Department of Peace Operations - DPO/ DPET/Integrated Training Service, 2015) at: http://repository.un.org/handle/11176/387374

13. 'Essential Services Package for Women and Girls Subject to Violence: Core Elements and Quality Guidelines' (UN Women, UNODC, WHO, UNFPA and UNDP) at: https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

14. Glossary and Thesaurus, 'Gender Sensitivity' (European Institute for Gender Equality) at: https://eige.europa.eu/thesaurus/terms/1218?utm_source=newsletter&utm_medium=email&utm_campaign=how_gender_equal_is_your_parliament&utm_term=2019-11-27

15. 'A Handbook for Police Responding to Domestic Violence: Promoting Safer Communities by Integrating Research and Practice', Department of Justice Canada and the Royal Canadian Mounted Police (RCMP) (2004), at: https://isc.idaho.gov/dv_courts/articles/Handbook_for_Police.pdf

16. 'Training Manual for Police Officers Strengthening Program for the Security of Vulnerable Groups'

(UNODC in partnership with the Government of Mexico, 2017), at: http://www.policia-mas.org/manuales/Manual_Policias_INGLES_PREVIO_090817.pdf

17. WHO Guidelines for Medico-Legal Care for Victim/survivors of Sexual Violence (2003), at: https://www.who.int/violence_injury_prevention/publications/violence/med_leg_guidelines/en/

18. Honor Based Violence: Policing and Prevention (2013), Roberts, K., Campbell, G., and Lloyd, G., Routledge; 1 edition.

19. 'Sexual Assault Response Policy and Training Content Guidelines' (International Association of Chiefs of Police, 2015), National Law Enforcement Leadership Initiative on Violence Against Women at: https://www.theiacp.org/resources/sexual-assault-response-policy-and-training-content-guidelines

20. 'Guidelines for Medico-legal Care for Victim/survivors of Sexual Violence' (World Health Organisation, 2003) at: https://www.who.int/violence_injury_prevention/publications/violence/med_leg_guidelines/en/

21. 'Do No Harm' (UN Women, 2010) at: https://endvawnow.org/en/articles/200-do-no-harm.html

22. 'Gender-based Violence Resource Pack. A Standardized Training Tool for Duty Bearers, Stakeholders, and Rights Holders' (UN Women, 2019) at: https://www.genderinkenya.org/wp-content/uploads/2019/11/GBV-Resource-Pack-13-Sept-w-3mm-bleed.pdf

23. 'Toolkit on Strengthening the Medico-Legal Response to Sexual Violence (WHO/UNODC, 2015) at: https://www.who.int/reproductivehealth/publications/violence/medico-legal-response/en/

24. Gender Guidelines (2018). Adams, L., and Sera, Y. Disability Rights Fund & Disability Rights Advocacy Fund, at: http://disabilityrightsfund.org/wp-content/uploads/DRF-DRAF-Gender-Guidelines-Print.pdf

25. 'More than just a ramp: a guide for women's refuges to develop disability discrimination act action plans' (Women with Disabilities Australia (WWDA), 2007) at: http://wwda.org.au/wp-content/uploads/2013/12/More_Than_Just_A_Ramp.pdf

26. 'Guiding Principles for the Search for Disappeared Persons', CED/C/7, United Nations, at: https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CED/C/7&Lang=en

27. 'Cultivating Minds UK' at: https://grahamgoulden.com/cultivating-minds-uk/about/

28. 'Investigation, Protection, and Support Measures for GBV Victims. Resource Book: Experience and Guidelines of the Korean Police' (UNDP Seoul Policy Centre, 2019).

29. Submission to the Special Rapporteur on the Rights of Persons with Disabilities: Good Practices for Increasing Effective Access to Justice for Women and Girls with Disabilities (August 9, 2019), Women Enabled International at: https://www.womenenabled.org/pdfs/WEI%20Access%20to%20Justice%20Good%20Practices%20Submission%20to%20UN%20Special%20Rapporteur%20on%20Persons%20with%20Disabilities,%20Aug%209,%202019.pdf

30. Cape Mental Health. Western Cape Government, at: https://www.westerncape.gov.za/facility/cape-mental-health

31. 'Women and Young Persons with Disabilities: Guidelines for Providing Rights-Based and Gender-Responsive Services to Address Gender-Based Violence and Sexual and Reproductive Health and Rights' (UNFPA-WEI, 2018) at: https://www.unfpa.org/featured-publication/women-and-young-persons-disabilities

32. Harmful Traditional Practices Affecting the Health of Women and Children. UN, Fact Sheet No.23, at: https://www.ohchr.org/Documents/Publications/FactSheet23en.pdf

33. A Submission Highlighting the Harmful Practices Targeted at Persons with Disabilities, and in Particular Women and Girls with Disabilities (International Disability Alliance, 2017), at: http://www.internationaldisabilityalliance.org/resources/submission-highlighting-harmful-practices-targeted-persons-disabilities-and-particular

34. Prosecuting domestic violence without victim participation (2002). Ellison, L. Modern Law Review, 65, 834–858.

35. 'Male honor and female fidelity: Implicit cultural scripts that perpetuate domestic violence' (2003), Vandello, J. A., and Cohen, D., in Journal of Personality and Social Psychology 84, at p 997.

36. 'Honor and Social Status,' by Pitt-Rivers, J., in 'Honour and Shame: The Values of Mediterranean Society' (ed. J. G. Peristiany, Weidenfeld and Nicolson, 1965).

37. Impunity for domestic violence, 'honour killings' cannot continue – UN official (2010). UN News 4, at: https://news.un.org/en/story/2010/03/331422

38. 'Global Study on Homicide, Gender related killing of women and girls' (UNODC, 2018) at: https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf

39. UN Secretary General's In-depth study of all forms of violence against women (A/61/122/Add.1) (2006), at: https://www.un.org/womenwatch/daw/vaw/SGstudyvaw.htm

40. Harmful Traditional Practices Affecting the Health of Women and Children (1995). UN, Fact Sheet No.23, https://www.ohchr.org/Documents/Publications/FactSheet23en.pdf

41. HM Government Multi-agency practice guidelines, Handling cases of Forced Marriage (June 2014)

42. Girls Not Brides (2014) at: https://www.girlsnotbrides.org/700-million-women-married-children-reveals-new-unicef-data/

43. Adolescents: health risks and solutions (World Health Organization, 2013) at: https://www.who.int/en/news-room/fact-sheets/detail/adolescents-health-risks-and-solutions

44. 115 million boys and men around the world married as children (UNICEF UK, 2019) at: https://www.unicef.org.uk/press-releases/115-million-boys-and-men-around-the-world-married-as-children-unicef/

45. The United Nations Convention on the Rights of the Child (1990), at: https://www.ohchr.org/en/professionalinterest/pages/crc.aspx

46. Multi-agency practice guidelines: Handling cases of Forced Marriage (2014). Her Majesty's Government (HM Government) UK, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/322307/HMG_MULTI_AGENCY_PRACTICE_GUIDELINES_v1_180614_FINAL.pdf

47. 'An Overview of 28 African Countries' (2018); Thomson Reuters Foundation and 28TooMany, 'The Law and FGM' at: https://www.28toomany.org/static/media/uploads/Law%20Reports/the_law_and_fgm_v1_(september_2018).pdf

48. Female genital mutilation (World Health Organization, 2018), at: https://www.who.int/news-room/fact-sheets/detail/female-genital-mutilation

49. National Police Chiefs Council (UK), at: https://www.npcc.police.uk

50. The Crown Prosecution Service (UK), at: https://www.cps.gov.uk

51. Protocol on the handling of Female Genital Mutilation (FGM) offences between the National Police Chiefs' Council and the Crown Prosecution Service (National Police Chiefs Council (UK), 2016) at: https://www.cps.gov.uk/sites/default/files/documents/legal_guidance/hbv_and_fm_protocol_nov_16.pdf

52. Honour based Abuse, Forced Marriage and Female Genital Mutilation: A Policing Strategy for England, Wales and Northern Ireland - Eradicating Honour Based Abuse, Forced Marriage and Female Genital Mutilation Together (National Police Chiefs Council (UK), 2015) https://www.npcc.police.uk/Publication/Final%20NPCC%20HBA%20strategy%202015%202018December%202015.pdf

## CHAPTER 6: Safety and Protection

1. Report of the Secretary-General, In-depth study on all forms of violence against women, United Nations (A/61/122/Add.1) (6 July 2006), paras. 111- 112, at : https://www.un.org/womenwatch/daw/vaw/SGstudyvaw.htm

2. National Outcome Standards for Perpetrator Interventions (NOSPI) Baseline Report 2015-2016). Australian Department for Social Sciences, at: https://plan4womenssafety.dss.gov.au/wp-content/uploads/2018/08/nationaloutcomestandardsreportweb.pdf

3. The Impact of Trauma on Adult Sexual Assault Victims: Report Submitted to: Justice Canada. (2019). Haskell, L. and Randell, M., at: https://www.justice.gc.ca/eng/rp-pr/jr/trauma/trauma_eng.pdf

4. 'Why Do Some Men Use Violence Against Women and How Can We Prevent It?' (Partners For Prevention, 2013). A UNDP, UNFPA, UN Women and UNV regional joint programme for gender-based violence prevention in Asia and the Pacific - Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific, at: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/womens_empowerment/RBAP-Gender-2013-P4P-VAW-Report.pdf

5. 'Intimate partner violence and women's physical and mental health in the WHO multi-country study on women's health and domestic violence: An observational study' (2008). Ellsberg, M., Jansen, H. A. F. M., Heise, L., Watts, C.H., and Garcia Moreno, C., in The Lancet, vol. 371, pp. 1165-1172.

6. Ethical and Safety Recommendations for Interviewing Trafficked Women (World Heath Organization, 2013) at: https://www.who.int/mip/2003/other_documents/en/Ethical_Safety-GWH.pdf

7. Guidelines on the Protection of Child Victims of Trafficking (UNICEF, 2006) at: https://www.unicef.org/protection/Unicef_Victims_Guidelines_en.pdf

8. ‘Problems and Process’ (1994). R. Higgins. Clarendon Press, Oxford.

9. ‘Basic Principles on the Use of Force and Firearms by Law Enforcement Officials’ (1990), adopted by the Eighth United Nations Congress on the Prevention of Crime and the Treatment of Offenders, Havana, Cuba, 27 August to 7 September 1990, at: https://www.ohchr.org/en/professionalinterest/pages/useofforceandfirearms.aspx

10. UN Police Gender Toolkit (UN Department of Peace Operations - DPO/ DPET/Integrated Training Service, 2015) at: http://repository.un.org/handle/11176/387374

11. ‘A Practitioner’s Toolkit on Women’s Access to Justice Programming (UN Women et al., 2018) at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

12. The End of Project (‘EoP’) Evaluation Report of the Project ‘Multi-Sectoral Gender Based Violence Response at the District Level in Nepal’ Project Period: August 2009-July 2013 supported by Eliminate Violence against Women Trust Fund, at: https://www2.unwomen.org/-/media/field%20office%20untf/publications/2018/evaluation%20digital%20library/3%20onplunctfecompressed.pdf?la=en&vs=832

13. Briefing Paper: Sex matters - A gender perspective on internal displacement (The Internal Displacement Monitoring Centre, 2019), at: http://www.internal-displacement.org/sites/default/files/publications/documents/201902-gender-dimension.pdf

14. IDP Health in Colombia: Needs and Challenge (2009), Quintero and Culler, Forced Migration Review, at: https://www.fmreview.org/protracted/quintero-culler

15. ‘The Hidden Pandemic: Firearms and Intimate Partner Violence Killing Women’, Bozanic, D. for UNDP SEESAC, 2020 at: https://www.eurasia.undp.org/content/rbec/en/home/blog/2020/hidden-pandemic-firearms-killing-women.html

16. Challenges of IDP Protection. Research study on the protection of internally displaced persons in Afghanistan (Internal Displacement Monitoring Centre, Norwegian Refugee Council and Samuel Ha, 2012) at: https://reliefweb.int/report/afghanistan/challenges-idp-protection-research-study-protection-internally-displaced-persons

17. Measuring police performance in domestic and family violence (2008). Rollings, K., and Taylor, N., for Trends and Issues in Crime and Criminal Justice No. 367 December 2008. Australian Government. Australian Institute of Criminology, at: https://aic.gov.au/publications/tandi/tandi367

18. Violence against women: Good practices in combating and eliminating violence against women (2005): Austrian Model of Intervention in Domestic Violence Cases. Loger, R., Report to the Expert Group Meeting at the UN Division for the Advancement of Women in collaboration with UN Office on Drugs and Crime in Vienna, Austria, at: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/logar.dv.pdf

19. Intimate Partner Violence as a Risk Factor for Mental Disorders: A Meta-Analysis (1999). Golding, JM., Journal of Family Violence. 1999; 14:99–132.

20. Policing Domestic Violence: A Review of the Evidence (2018). Dowling, C., Morgan, A., Boyd, C., Voce, I. Australian Institute of Criminology. AIC reports Research Report 13, at: https://aic.gov.au/file/6650/download?token=CgV__eGo

21. ‘Training Manual for Police Officers Strengthening Program for the Security of Vulnerable Groups’ (UNODC in partnership with the Government of Mexico, 2017) at: http://www.policia-mas.org/manuales/Manual_Policias_INGLES_PREVIO_090817.pdf

22. Guidelines on Inclusion of Persons with Disabilities in Humanitarian Action (2019). The Inter-Agency Standing Committee (Task Team on Inclusion of Persons with Disabilities in Humanitarian Action. Inter-Agency Standing Committee (IASC), at: https://interagencystandingcommittee.org/iasc-task-team-inclusion-persons-disabilities-humanitarian-action/documents/iasc-guidelines

23. ‘Everyone’s business: Improving the police response to domestic abuse’ (Her Majesty’s Inspectorate of Constabulary and Fire and Rescue Services (now HMICFRS formally HCIM), 2014) at: https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/2014/04/improving-the-police-response-to-domestic-abuse.pdf

24. ‘Handbook on effective prosecution responses to violence against women and girls’ (UNODC, UN Women, 2014) at: https://www.unodc.org/documents/justice-and-prison-reform/14-02565_Ebook_new.pdf

25. PROTECT II ‘Capacity Building in Risk Assessment and Safety Management to Protect High Risk Victims’ – A Learning Resource (Women Against Violence Europe, European Network, Vienna, 2012): http://fileserver.wave-network.org/trainingmanuals/PROTECTII_Risk_Assessment_and_Safety_2012_English.pdf

26. Frequently asked questions Multi-Agency Risk Assessment Conferences (MARAC) (Save Lives, 2014) at: http://www.safelives.org.uk/sites/default/files/resources/MARAC%20FAQs%20General%20FINAL.pdf

27. DASH Risk Model, at: https://www.dashriskchecklist.co.uk/

28. 'A guide to risk assessment and risk management of intimate partner violence against women for police' (European Institute for Gender Equality, 2019) at: https://eige.europa.eu/sites/default/files/documents/20191701_mh0119277enn_pdf.pdf

29. Report of the Special Rapporteur on violence against women, its causes and consequences on online violence against women and girls from a human rights perspective (2018) (A/HRC/38/47) at: http://ap.ohchr.org/documents/dpage_e.aspx?si=A/HRC/38/47

30. Domestic violence and multiagency risk assessment conferences (MARACs): a scoping review (2014). Robbins, R., McLaughlin, H., Banks, C., Bellamy, C., Thackray, D., in The Journal of Adult Protection, Vol. 16 Issue 6 pp. 389 – 398, at: https://www.researchgate.net/publication/280194675_Domestic_violence_and_multi-agency_risk_assessment_conferences_MARACs_A_scoping_review

31. Dashing Hopes? the Predictive Accuracy of Domestic Abuse Risk Assessment by Police (2019). Turner, E., Medina, J., Brown, G., *The British Journal of Criminology*, Volume 59, Issue 5, September 2019, Pages 1013–1034, at: https://doi.org/10.1093/bjc/azy074

32. 'Risk assessment and risk management by police' (European Institute for Gender Equality) at: https://eige.europa.eu/gender-based-violence/risk-assessment-risk-management/principle-3-establishing-evidence-based-approach

33. Amnesty reveals alarming impact of online abuse against women (2017), at: https://www.amnesty.org/en/latest/news/2017/11/amnesty-reveals-alarming-impact-of-online-abuse-against-women/

## CHAPTER 7: Support and Assistance

1. 'Participation: Gender, equity and human rights' (WHO), at: https://www.who.int/gender-equity-rights/understanding/participation-definition/en/

2. 'Good Practices in Supporting Victims of Terrorism within the Criminal Justice Framework' (UNODC, 2015), at: https://www.unodc.org/documents/terrorism/Publications/Good%20practices%20on%20victims/good_practices_victims_E.pdf

3. UN General Assembly in the 2010 Updated Model Strategies and Practical Measures on the Elimination of Violence against Women in the Field of Crime Prevention and Criminal Justice (2011, General Assembly resolution 65/228, annex) at: https://www.unodc.org/documents/justice-and-prison-reform/crimeprevention/Model_Strategies_and_Practical_Measures_on_the_Elimination_of_Violence_against_Women_in_the_Field_of_Crime_Prevention_and_Criminal_Justice.pdf

4. 'Essential Services Package for Women and Girls Subject to Violence : Core Elements and Quality Guidelines (UN Women, UNODC, WHO, UNFPA and UNDP, 2015) at: https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

5. Mapping and Analysis of Domestic Legal Remedies to issues of Violence against Women (VAW) undertaken by the Women's Legal and Human Rights Bureau (WLB) and supported by UN Women (2010).

6. Dialectic of Rights and Politics (1986). Schneider, Elizabeth. Feminist Legal Theory Foundations at: https://brooklynworks.brooklaw.edu/cgi/viewcontent.cgi?article=1355&context=faculty

7. Glossary of Terms and Concepts (UNICEF Regional Office for South Asia, 2017) at: https://www.unicef.org/rosa/media/1761/file/Gender%20glossary%20of%20terms%20and%20concepts%20.pdf

8. Abuse of a position of vulnerability and other 'means' within the definition of trafficking in persons (Issue Paper UNODC, 2013) at: https://www.unodc.org/documents/human-trafficking/2012/UNODC_2012_Issue_Paper_-_Abuse_of_a_Position_of_Vulnerability.pdf

9. Declaration of Basic Principles of Justice for Victims of Crime and Abuse of Power, adopted by General Assembly resolution 40/34 of 29 November 1985 at: https://www.un.org/en/genocideprevention/documents/atrocity-crimes/Doc.29_declaration%20victims%20crime%20and%20abuse%20of%20power.pdf

10. 'Strengthening Crime Prevention and Criminal Justice Response to Violence against Women' (UNODC, 2014), at:https://www.unodc.org/documents/justice-and-prison-reform/Strengthening_Crime_Prevention_and_Criminal_Justice_Responses_to_Violence_against_Women.pdf

11. Policing Domestic Violence: A Review of the Evidence (2018). Dowling, C., Morgan, A., Boyd, C., Voce, I. Australian Institute of Criminology. AIC reports Research Report 13 https://aic.gov.au/file/6650/download?token=CgV__eGo

12. 'Sexual Assault Response Policy and Training Content Guidelines' (The International Association of Chiefs of Police, 2015) at: https://www.theiacp.org/sites/default/files/all/i-j/IACP%20Sexual%20Assault%20

Response%20Policy%20and%20Training%20Content%20Guidelines.2017.3.23.pdf

13. 'Crime Victims: International and Serbian Perspective', Lindgren, M., and Nikolić-Ristanović, V., (Organization for Security and Cooperation in Europe (OSCE), 2013), Mission to Serbia, Law Enforcement Department at: https://www.osce.org/serbia/85268?download=true

14. Violence against women: Good practices in combating and eliminating violence against women (2005): Austrian Model of Intervention in Domestic Violence Cases, Loger, R., Report to the Expert Group Meeting at the UN Division for the Advancement of Women in collaboration with UN Office on Drugs and Crime in Vienna, Austria, at: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/logar.dv.pdf

15. Police-Community Partnerships to Address Domestic Violence (2006), Reuland, M., Schaefer-Morabito, M., Preston, C., Cheney, J. U.S. Department of Justice Office of Community Oriented Policing Services at: https://cops.usdoj.gov/RIC/Publications/cops-p091-pub.pdf

16. PROTECT II 'Capacity Building in Risk Assessment and Safety Management to Protect High Risk Victims' – A Learning Resource (Women Against Violence Europe, European Network, Vienna, 2012) at: http://fileserver.wave-network.org/trainingmanuals/PROTECTII_Risk_Assessment_and_Safety_2012_English.pdf

17. Research will review support offered to sexual assault victims (University of Birmingham, UK, 2018) at: https://www.birmingham.ac.uk/university/colleges/mds/news/2018/08/Research-sex-assault-victims-support.aspx

18. Family Killing Fields: Honor Rationales in the Murder of Women (1999). Barker, N., Gregware, P.R., Cassidy, M.A., Violence against Women Journal (Volume 5 Issue 2, February 1999).

19. From the Margin to the Centre: Addressing Violence Against Women and Girls Alternative Bill October (Imkaan, 2018) at: https://829ef90d-0745-49b2-b404-cbea85f15fda.filesusr.com/ugd/2f475d_91a5eb3394374f24892ca1e1ebfeea2e.pdf

20. Family Liaison Officer. College of Policing, UK at: https://profdev.college.police.uk/professional-profile/family-liaison-officer-flo/#role-purpose

21. 'What is Active Listening?' The United States Institute of Peace at: https://www.usip.org/public-education/educators/what-active-listening

22. 'Basic Principles on the Use of Force and Firearms by Law Enforcement Officials', adopted by the Eighth UN Congress on the Prevention of Crime and the Treatment of Offenders, Havana, Cuba, 27 August to 7 September 1990 at: https://www.ohchr.org/en/professionalinterest/pages/useofforceandfirearms.aspx

23. 'Exclusion of evidence obtained through torture', Association for the Prevention of Torture at: https://apt.ch/en/evidence-obtained-through-torture/

## CHAPTER 8:
## Coordination among Justice Agencies

1. Good Practices in Building Police-Public Partnerships by the Senior Police Adviser to the OSCE Secretary General (The Organization for Security and Co-operation in Europe (OSCE), 2008) at: https://www.osce.org/secretariat/32547?download=true

2. Understanding Policing: A Resource for Human Rights Activists (2006). Osse, A., for Amnesty International at: https://www.amnesty.org/download/Documents/HRELibrary/sec010112007eng.pdf

3. Community-Oriented Policing in United Nations Peace Operations Manual (2018), UN Department of Peacekeeping Operations Department of Field Support Ref. 2018.04, at: https://police.un.org/sites/default/files/manual-community-oriented-poliicing.pdf

4. Guidelines for Integrating Gender-Based Violence Interventions in Humanitarian Action: Reducing risk, promoting resilience and aiding recovery (Inter-Agency Standing Committee, 2015) at: https://gbvguidelines.org/wp/wp-content/uploads/2015/09/2015-IASC-Gender-based-Violence-Guidelines_lo-res.pdf

5. Module 5: Coordination and Governance of Coordination from the 'Essential Services Package for Women and Girls Subject to Violence : Core Elements and Quality Guidelines' (UN Women, UNODC, WHO, UNFPA and UNDP, 2015) at : https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

6. 'Understanding Local Security Councils in Two Minutes' (Coginta for Police Reforms), at: https://www.youtube.com/watch?v=7fGF0_nteGA

7. 'Qu'est-ce qu'un CLSPD - CISPD ?' Government of France at: http://www.isere.gouv.fr/Politiques-publiques/Securites/Securite-publique/Prevention-de-la-delinquance2/Qu-est-ce-qu-un-CLSPD-CISPD

8. 'Guide pratique conseil local de sécurité et de prévention de la délinquance en république de guinée' (Coginta for Police Reform, 2017) at: http://www.

coginta.org/uploads/documents/cedd246fbc7d133bcf-29135bec8a66d561202ae4.pdf

9. Decentralisation of Security Governance: Facilitator of a Human Rights-based Approach (HRBA) to SSR (2017)? Fernandez, M., Piaget, K., Hernandez, T., and Berthoud, S. ISSAT HRBA Working Group Paper 3, at: https://issat.dcaf.ch/download/111714/2027474/HRBA%20Working%20Group%20Paper%203.pdf

10. Aspects of violence against women that pertain directly to the Commission on Crime Prevention and Criminal Justice. Commission on Crime Prevention and Criminal Justice V.08-52191 (E) *0852191* Seventeenth session Vienna, 14-18 April 2008, at: https://www.unodc.org/pdf/criminal_justice/Note_by_the_Secretariat_on_Aspects_of_Violence_against_Women_that_Pertain_Directly_to_the_CCPCJ.pdf

11. UN Women Flagship Programme Initiatives, at : https://www.unwomen.org/en/how-we-work/flagship-programmes

12. Benefits of Coordination. Stop Violence against Women: A Project of The Advocates for Human Rights, at: http://www.stopvaw.org/Benefits_of_Coordination.html

13. 'A Study for Creating a Multidisciplinary Response Mechanism to Violence Against Women in Egypt' (UNODC, 2015).

14. Manual on the law relating to violence against women: England and Wales, Greece, Ireland, Italy, Northern Ireland, Poland, Spain (European Lawyers Foundation, 2018) at: https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

15. 'Thematic study on the issue of violence against women and girls and disability', Report of the Office of the United Nations High Commissioner for Human Rights, 30 March 2012 (A/HRC/20/5) at: https://www2.ohchr.org/english/issues/women/docs/A.HRC.20.5.pdf

16. Submission to the Special Rapporteur on the Rights of Persons with Disabilities: Good Practices for Increasing Effective Access to Justice for Women and Girls with Disabilities, August 9, 2019, Women Enabled International (WEI) at: https://www.womenenabled.org/pdfs/WEI%20Access%20to%20Justice%20Good%20Practices%20Submission%20to%20UN%20Special%20Rapporteur%20on%20Persons%20with%20Disabilities,%20Aug%209,%202019.pdf

17. Manual: Community-Oriented Policing in United Nations Peace Operations (2018). UB Department of Peacekeeping Operations Department of Field Support Ref. 2018.04, at: https://police.un.org/en/manual-community-oriented-policing-in-peace-operations

18. Compendium of Project Tools - UN police Gender Toolkit: Standardised Best Practices on Gender Mainstreaming in Peacekeeping (2015) at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

19. Prosecutor Protocol for Responding to Victims with Disabilities and Older Adults who Experience Sexual Assault, Domestic Violence, Abuse, Neglect or Exploitation (2018). State of Illinois, Illinois Criminal Justice Information Authority, at: http://www.icjia.state.il.us/assets/ifvcc/Model%20Protocols/PWD_OA_Prosecutor_Protocol_113018.pdf

20. Illinois: Family Violence Coordinating Councils (IFVCC), at: http://www.icjia.state.il.us/ifvcc

21. 'Providing a coordinated response to survivors of sexual violence in the Oromia Region, Ethiopia' (2019), Kefetew, K., for UNICEF at: https://www.unicef.org/ethiopia/stories/providing-coordinated-response-survivors-sexual-violence-oromia-region

## CHAPTER 9: Communication

1. Why More American Men Feel Discriminated Against. Cassino, D. Harvard Business Review. September 29, 2016. https://hbr.org/2016/09/why-more-american-men-feel-discriminated-against

2. The Report of the Missing Women Commission of Inquiry VOLUME IIB Nobodies: 'How and Why We Failed the Missing and Murdered Women Part 3, 4 and 5' (2012), The Honourable Wally T. Oppal, at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/about-bc-justice-system/inquiries/forsaken-vol_2b.pdf

3. Global Study on Homicide (UNODC, 2019) at: https://www.unodc.org/documents/data-and-analysis/gsh/Booklet1.pdf

4. Global Study on Homicide: Gender-related killing of women and girls (UNODC, 2018), at: https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf

5. Backlash in Gender Equality and Women's and Girls' Rights. Women's Rights and Gender Equality. Policy Department for Citizens' Rights and Constitutional Affairs Directorate General for Internal Policies of the Union PE 604.955, June 2018, at: http://www.europarl.europa.eu/RegData/etudes/STUD/2018/604955/IPOL_STU(2018)604955_EN.pdf

6. Communication: Engagement and Communication (College of Policing, UK) at: https://www.app.college.police.uk/app-content/engagement-and-communication/communications/

7. 'Perceptions of Gender Discrimination across Six Decades: The Moderating Roles of Gender and Age', Kehn, A., and Ruthig, J.C., 16 June 2013 # Springer Science and Business, Media New York (2013)

8. UN Police Gender Toolkit, (UN Department of Peace Operations - DPO/ DPET/Integrated Training Service, 2015)

9. UN Police Gender Toolkit Standardised Best Practices on Gender Mainstreaming in Peacekeeping Compendium of Project Tools (2015), at: http://repository.un.org/bitstream/handle/11176/387374/United%20Nations%20Police%20Gender%20Toolkit%20Compendium%20of%20Project%20Tools.pdf?sequence=55&isAllowed=y

10. International Protocol on the Documentation and Investigation of Sexual Violence in Conflict. Best Practice on the Documentation of Sexual Violence as a Crime or Violation of International Law 2nd Edition: Ferro Ribeiro, S., and van der Straten Ponthoz, D., on behalf of the UK Foreign & Commonwealth Office, March 2017, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

11. 'Community Policing: A Practical Guide for Police Officials (1989)', Lee P., U.S. Department of Justice, Office of Justice Programs, Washington, DC, at: https://www.ncjrs.gov/pdffiles1/nij/118001.pdf

12. Good Practices in Building Police-Public Partnerships by the Senior Police Adviser to the OSCE Secretary General (The Organization for Security and Co-operation in Europe (OSCE), 2008), at: https://www.osce.org/secretariat/32547?download=true

13. 'What is rape and sexual assault?' (Metropolitan Police, UK) at: https://www.met.police.uk/advice/advice-and-information/rsa/rape-and-sexual-assault/what-is-rape-and-sexual-assault/

14. 'When it comes to consent, there are no blurred lines' (UN Women, 2019) at: https://www.unwomen.org/en/news/stories/2019/11/feature-consent-no-blurred-lines

15. 'Measuring police performance in domestic and family violence' (2008), Rollings, K., and Taylor, N., for Trends and Issues in Crime and Criminal Justice, No. 367 December 2008. Australian Government. Australian Institute of Criminology at: https://aic.gov.au/publications/tandi/tandi367

16. 'The police response to domestic abuse: An update report' (Her Majesty's Inspectorate of Constabulary and Fire and Rescue Services (HMICFRS), February 2019) at: https://www.justiceinspectorates.gov.uk/hmicfrs/wp-content/uploads/the-police-response-to-domestic-abuse-an-update-report.pdf

17. 'Nottinghamshire Police records misogyny as a hate crime' (BBC) at: https://www.bbc.com/news/uk-england-nottinghamshire-36775398

18. Misogyny Hate Crime Evaluation Report for Nottingham Women's Centre, Funded by the Office of Nottinghamshire Police and Crime Commissioner. Mullany, L., and Trickett, L., (June 2018), at: http://www.nottinghamwomenscentre.com/wp-content/uploads/2018/07/Misogyny-Hate-Crime-Evaluation-Report-June-2018.pdf

19. 'Six things we've learned about misogyny as a hate crime' (2016), Bates, L., for The Guardian, at: https://www.theguardian.com/lifeandstyle/womens-blog/2016/sep/22/six-things-weve-learned-about-misogyny-as-a-hate

20. 'Overwhelming public support for Misogyny Hate Crime Policy' (2018), University of Nottingham, UK, at: https://www.nottingham.ac.uk/news/pressreleases/2018/july/overwhelming-public-support-for-misogyny-hate-crime-policy.aspx

21. Hate Crime. The Crown Prosecution Service (CPS), UK, at: https://www.cps.gov.uk/hate-crime

22. Hate Crime, England and Wales, 2017/18 Statistical Bulletin 20/18 16 October 2018. Home Office Crime and Policing Statistics, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/748598/hate-crime-1718-hosb2018.pdf

23. 'What is Hate Crime?' (Metropolitan Police, UK) at: https://www.met.police.uk/advice/advice-and-information/hco/hate-crime/what-is-hate-crime/

24. 'Upskirting' now a specific crime as bill receives Royal Assent (2019), Ministry of Justice, UK, at: https://www.gov.uk/government/news/upskirting-now-a-specific-crime-after-bill-receives-royal-assent

25. 'Handbook on Effective Police Responses to Violence against Women' (UNODC, 2010), at: https://www.unodc.org/documents/justice-and-prison-reform/Handbook_on_Effective_police_responses_to_violence_against_women_English.pdf

26. 'Handbook on effective prosecution responses to violence against women and girls', (UNODC, UN Women,

2014) at: https://www.unodc.org/documents/justice-and-prison-reform/14-02565_Ebook_new.pdf

27. 'Towards Gender-Responsive Criminal Justice: Good Practices from Southeast Asia in responding to violence against women' (2018). Skinnider, E., Thailand Institute of Justice, at: http://on.myunwomen.website/docs/TIJ_Towards%20Gender-Respondsive.pdf

## CHAPTER 10: Institution Building for an Effective and Accountable Police Response to VAWG

1. UN Women Executive Director's Statement for the International Day for the Elimination of Violence against Women (5 November 2019) 'End rape—an intolerable cost to society. UN Women', at: https://eca.unwomen.org/pt/news/stories/2019/11/statement-ed-phumzile-day-for-the-elimination-of-violence-against-women

2. Tool 2: Policing and Gender in Gender and Security Toolkit. Geneva: DCAF, OSCE/ODIHR, UN Women, 2019) at: https://www.dcaf.ch/sites/default/files/publications/documents/GSToolkit_Tool-2%20EN%20FINAL.pdf

3. 'The police', SSR Backgrounder Series (Geneva: DCAF, 2015) at: http://ssrbackgrounders.org/fall.php?p=16&l=EN

4. 'Code of Conduct for Law Enforcement Officials', General Assembly resolution 34/169 of 17 December 1979, at: https://digitallibrary.un.org/record/10639?ln=en

5. Evaluación independiente de proyecto/evaluación en profundidad de: 'Fortalecimiento para la Seguridad de Grupos en situación de vulnerabilidad' CÓDIGO: MEXZ93-2018-005 México, Abril 2019, at: https://www.unodc.org/documents/evaluation/Independent_Project_Evaluations/2019/MEXZ93_Final_Independent_Project_Evaluation_April_2019.pdf

6. Manual on Human Rights Monitoring (UN OHCHR, 2011) at: https://searchlibrary.ohchr.org/record/4835?ln=en

7. Handbook on Police Accountability, Oversight and Integrity (UNODC, 2011) at: https://www.unodc.org/pdf/criminal_justice/Handbook_on_police_Accountability_Oversight_and_Integrity.pdf

8. Toolkit on Police Integrity (DCAF, 2019) at: https://www.dcaf.ch/sites/default/files/publications/documents/DCAF_PIBP_Toolkit_ENG_2019_web.pdf

9. 'Police as an Entry Point to End Violence Against Women and Girls. Lessons from Civil Society Organizations Funded by the UN Trust Fund to End Violence Against Women' (UN Trust Fund to End Violence against Women. New York, UN Women, 2019).

10. 'DIWA curbs violence against women and girls with disabilities' (Disabled Women in Africa (DIWA)) at: http://www.diwa.ws/?p=101

11. 'Promoting a safer, Gender-Based Violence free environment for women and girls with disabilities in Lilongwe, Malawi' (Disabled Women in Africa (DIWA), 2017) at: https://www.makingitwork-crpd.org/sites/default/files/2018-05/Malawi%20-%20Promoting%20a%20safer%2C%20Gender-Based%20Violence%20free%20environment%20for%20women%20and%20girls%20with%20disabilities%20in%20Lilongwe%2C%20Malawi%20%28DIWA%29.docx

12. Background Document XIV UNOG-DCAF seminar 2017 Leveraging SDG 16 to Improve Implementation of SDG 5, at: https://www.dcaf.ch/sites/default/files/imce/Events/UNOG-DCAF%20Seminar%20Background%20document%20+%20programme.pdf

13. 'Enhancing Access to Justice for Women Living in Rural and Remote Areas of British Columbia: Reviewing Practices from Canada and Abroad to Improve Our Response (The International Centre for Criminal Law Reform and Criminal Justice Policy (ICCLR), 2017) at: https://icclr.org/wp-content/uploads/2019/06/BCLF-WA2J-Report-Final.pdf?x30145

14. '3 Myths of Behavior Change & Other Challenges for Sustainability', Jenni Cross, Center for Energy and Behavior Institute for the Built Environment and the Colorado State University, at: https://www.uccs.edu/sustain/sites/sustain/files/inline-files/Myths%20of%20Behaivor%20Change_UCCS2015.pdf

15. 'Safety and Dignity at Work: A Guide to the 2019 ILO Violence and Harassment Convention, No. 190' (Human Rights Watch, 2020) at: https://www.hrw.org/sites/default/files/media_2020/06/ILO_advocacy_brochure_0620.pdf

16. 'Everyone's business: Improving the police response to domestic abuse (Her Majesty's Inspectorate of Constabulary (HMIC), 2014), at: https://www.gov.uk/government/news/major-review-of-police-response-to-domestic-violence

17. Insights from behavioural sciences to prevent and combat violence against women, Almeida, S.R., Lourenço, J.S., Dessart, F.J., and Ciriolo, E. EUR 28235 EN, doi:10.2788/412325 https://publications.jrc.ec.europa.eu/repository/bitstream/JRC103975/lbna28235enn.pdf

18.‘Model Policy on Investigating Sexual Assault’, International Association of Chiefs of Police, (2005b). Alexandria, VA: National Law Enforcement Policy Center, at: http://www.evawintl.org/library/DocumentLibraryHandler.ashx?id=328.

19. Progress of the World’s Women 2011–2012: Families in a changing world (UN Women, 2011), at: https://www.unwomen.org/en/digital-library/publications/2011/7/progress-of-the-world-s-women-in-pursuit-of-justice

20. Gender and Policing: Comparative Perspectives (2000). Brown, J., and Heidensohn, F. Basingstoke: Macmillan

21.‘Good practice case studies in the advancement of women in policing’ (2016), Ward, A., and Prenzler, T., in Police Science and Management, 18(4), p. 242.

22. Women in Modern Policing. Graue, T.M., Hildie, R.E., and Weatherby, G.A. Department of Sociology & Criminal Justice, Gonzaga University, Spokane, WA, USA Journal of Social Sciences and Humanities Vol. 2, No. 3, 2016, pp. 51-62 http://www.aiscience.org/journal/jssh ISSN: 2381-7763 (Print); ISSN: 2381-7771

23. ‘Men, Women, and Police Excessive Force: A Tale of Two Genders a Content Analysis of Civil Liability Cases, Sustained Allegations and Citizen Complaints (The National Center for Women and Policing, 2002) at: http://womenandpolicing.com/PDF/2002_Excessive_Force.pdf

24. A Practitioner’s Toolkit on Women’s Access to Justice Programming (UN Women et al., 2018), at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

25. Gender Self-Assessment Guide for the Police, Armed Forces and Justice Sector (2011), Bastick, M., for DCAF Geneva, available at: https://www.dcaf.ch/sites/default/files/publications/documents/self_assessment_guide.pdf

26. Beyond Measuring ‘How Good a Job’ Police Are Doing: The MPS Model of Confidence in Policing (2009), Stanko, E.A., and Bradford, B. 2009. Policing, Volume 3, Number 4, pp. 322–330. Oxford University Press.

27.Guidelines for Producing Statistics on Violence against Women— Statistical Surveys (UN Department of Economic and Social Affairs Statistics Division, New York, 2014) at: https://www.un.org/development/desa/capacity-development/tools/tool/guidelines-on-producing-statistics-on-violence-against-women-statistical-surveys/

28. ‘Research methods, measures and ethics’, Jaquier, V., Johnson, H., and Fisher, B.S. in ‘Sourcebooks on Violence against Women’, 2nd ed., Renzetti, C.M., Edleson, J.L. and Bergen, R.K. eds. SAGE Publications, 2010.

29. Guidance on Monitoring and Evaluation for Programming on Violence against Women and Girls. Guidance Note 3 How to Note. A Department for International Development (DFID) practice paper, at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/67334/How-to-note-VAWG-3-monitoring-eval.pdf

30. Modern Crime Prevention Strategy (Home Office, UK, 2016) at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/509831/6.1770_Modern_Crime_Prevention_Strategy_final_WEB_version.pdf

31.‘What Works: Gender Equality by Design’, Bohent, I., Harvard University Press (2016)

32. ‘Theories in In A Framework for Evaluating Behavior Change in International Development Operations’, Flanagan, A.E., and Tanner, J.C., for the World Bank. Independent Evaluation Group Working Paper 2016/ No. 2 (2018).

33. ‘Guidelines for Gender Sensitive Policing, with an E mphasis on Recruitment, Selection and Professional Development of Women in Police Services’ (The Women Police Officers Network in South East Europe (WPON)- South Eastern and Eastern Europe Clearinghouse for the Control of Small Arms and Light Weapons (SEESAC, 2012) at: https://www.seesac.org/f/tmp/files/publication/812.pdf

34. RS MoI Women Network – RS WPON. Promotion and implementation of gender equality principles, strategic approach to the admission of women to the police, education, training and career development, and promotion of work results of RS MoI members, at: http://www.mrezazena-muprs.org/?lang=en

35. ‘3 Myths of Behavior Change & Other Challenges for Sustainability’, Jenni Cross, Center for Energy and Behavior Institute for the Built Environment, Colorado State University (2012) at: https://www.uccs.edu/sustain/sites/sustain/files/inline-files/Myths%20of%20Behaivor%20Change_UCCS2015_0.pdf

36. ‘Integrating Gender in Project Design and Monitoring for the Security and Justice Sector’ in Gender and Security Toolkit (Geneva: DCAF, OSCE/ODIHR, UN Women, 2019), at: https://www.dcaf.ch/node/13624

37.‘Security Sector Reform Assessment, Monitoring and Evaluation and Gender’, Popovic, N. Gender and Security Sector Reform Toolkit’, Eds. Bastick, M., and Valasek, K. (Geneva: DCAF, OSCE/ODIHR, UN-INSTRAW, 2008) at: https://www.dcaf.ch/

security-sector-reform-assessment-monitoring-evaluation-and-gender-tool-11

38. 'Integrating Gender into Internal Police Oversight', Bastick, M., in Gender and SSR Guidance Notes (Geneva: DCAF, OSCE, OSCE/ODIHR, 2014) at: https://www.osce.org/odihr/118326?download=true

39. 'Integrating a Gender Perspective into Internal Oversight within Armed Forces', Bastick, M., in Gender and SSR Guidance Notes (Geneva: DCAF, OSCE, OSCE/ODIHR, 2014) at: https://www.osce.org/odihr/118325?download=true

40. A staggering one-in-three women, experience physical, sexual abuse. UN News 24 November 2019. https://news.un.org/en/story/2019/11/1052041

41. 'Provincial Policing Standards' (Provincial Government of British Columbia) at: https://www2.gov.bc.ca/gov/content/justice/criminal-justice/policing-in-bc/policing-standards

42. Foreword BCPPS 6.2 Police Stops in 'Provincial Policing Standards' (Provincial Government of British Columbia) at: https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminal-justice/police/standards/6-2-foreword-police-stops.pdf

43. Press Release: 'UN Women announces United Nations Police Adviser Luís Carrilho as HeForShe Advocate for Gender Equality (25 November 2019) at: https://www.heforshe.org/en/un-women-announces-united-nations-police-adviser-luis-carrilho-heforshe-advocate-gender-equality

44. Competency and Values Framework for policing Overview of framework (College of Policing, UK, 2016) at: https://www.college.police.uk/What-we-do/Development/competency-and-values-framework/Documents/Competency-and-Values-Framework-for-Policing_4.11.16.pdf

45. 'Gender Equality in UK Policing First Annual Report' (2020). Sussex Police Corporate Communications 2019 in support of HeForShe UN Women Solidarity Movement for Gender Equality, available at: https://www.sussex.police.uk/SysSiteAssets/media/downloads/sussex/about-us/governance-and-processes/equality-and-diversity/heforshe-annual-report-2019.pdf

46. Indigenous Relations Behavioural Competencies (BC Public Service Agency, British Columbia, Canada, 2012) at: https://www2.gov.bc.ca/gov/content/careers-myhr/job-seekers/about-competencies/indigenous-relations

47. Implementation Guide Aboriginal Relations Behavioural Competencies (BC Public Service Agency, British Columbia, Canada, 2012) at: https://www2.gov.bc.ca/assets/gov/careers/for-job-seekers/about-competencies/aboriginal_relations_behavioural_competencies_implementation_guide.pdf

48. 'The Challenge of Implementing Gender-Responsive Policing', Townsley, J., MDG Acceleration through Transformative Policing and Security, 58th Commission for the Status of Women Parallel Event, New York, USA 12 March 2014.

49. Progress of the World's Women: In Pursuit of Justice (UN Women, New York: UN Entity for Gender Equality and the Empowerment of Women, 2011) at: https://www.unwomen.org/en/digital-library/publications/2011/7/progress-of-the-world-s-women-in-pursuit-of-justice

50. 'Do Female Officers Improve Law Enforcement Quality? Effects on Crime reporting and Domestic Violence Escalation', Miller, A. R. and Segal, C., (2013) at: http://ssrn.com/abstract=2335990

51. Hiring and Retaining More Women: The Advantages to Law Enforcement Agencies', Lonsway, K., Los Angeles: National Centre for Women & Policing (2003).

52. 'Police Reform and Gender' in M. Bastick, K. Valasek (eds) 'Gender and Security Sector Reform Toolkit' (Geneva: DCAF, OSCE/ODIHR, UN-INSTRAW, 2008), at: https://www.files.ethz.ch/isn/143070/Tool%2002_Police%20Reform%20and%20Gender.pdf

53. 'Integrating Gender in Post-Conflict Security Sector Reform', Bastick, M., Policy Paper 29 (Geneva: Geneva Centre for the Democratic Control of Armed Forces (DCAF), 2008) at: https://www.dcaf.ch/sites/default/files/publications/documents/pp29.pdf

54. 'Risks versus Transformational Opportunities in Gender-Responsive Security Sector Reform' (2020), Gordon, E., McHugh, C., and Townsley, J. Journal of Global Security Studies, 0(0), 2020, 1–16 doi: 10.1093/jogss/ogaa028.

55. 'Women Police in a Changing Society': Back Door to Equality (2008) Natarajan, M. Aldershot: Ashgate Publishing Ltd.

56. 'Gender Responsive Policing and the Importance of Women Officers', Peters, A. in Involvement in Tackling Violent Extremism', International Association of Women Police Annual Training Conference, Cardiff, UK, 26 August 2015.

57. 'Women Fighting for Peace: Lessons for Today's Conflicts', Abbas, H. in Presentation to the Committee on Foreign Affairs Relations Hearing, Washington DC: United States House of Representatives, 22 March 2016, at: https://foreignaffairs.house.gov/2016/3/women-fighting-peace-lessons-today-s-conflicts

58. British Association for Women in Policing, at: http://www.bawp.org

59. 'Guidelines for Gender Sensitive Policing with an Emphasis on Recruitment, Selection and Professional Development of Women in Police Services' (Women Police Officers Network in South East Europe, 2012) at: http://www.seesac.org/f/docs/Gender-and-Security/GUIDELINES-FOR-GENDER-SENSITIVE-POLICING-EN.pdf

60. South African Police Service at: http://www.saps.gov.za

61. IAWP Affiliate Program at: http://www.iawp.org/iawp-affiliates

62. 'Domestic Violence – Education of Police Officers Managers', Ministry of the Interior of the Republic of Srpska (2017) at: http://www.mrezazena-muprs.org/project/domestic-violence-education-of-police-officers-managers/?lang=en

63. 'Prevention of Online Sexual Violence against Girls in Suburban Areas', Ministry of the Interior of the Republic of Srpska 92015), at: https://www.mrezazena-muprs.org/project/prevention-of-online-sexual-violence-against-girls-in-suburban-areas/?lang=en

64. 'Sensitization and Education of Elementary Schools Teaching Staff on Criminal Offences against Marriage and Family', Ministry of the Interior of the Republic of Srpska (2015), at: https://www.mrezazena-muprs.org/project/sensitization-and-education-of-elementary-schools-teaching-staff-on-criminal-offences-against-marriage-and-family/?lang=en

65. 'Prevention of Discrimination against Roma and Violation of Roma Children Rights', Ministry of the Interior of the Republic of Srpska (2019), at: https://www.mrezazena-muprs.org/project/prevention-of-discrimination-against-roma-and-violation-of-roma-children-rights/?lang=en

66. Promotion of the Handbook 'Policing Hate Crimes against LGBTI Persons', Women Police Officers' Network of the Republic of Srpska Ministry of the Interior (2019), at: http://www.mrezazena-muprs.org/promotion-of-the-handbook-policing-hate-crimes-against-lgbti-persons/?lang=en

67. 'Inside job: Bosnian policewomen take on abusive husbands' (2019), Umberto Bacchi for Reuters, available at: https://www.reuters.com/article/us-bosnia-women-police/inside-job-bosnian-policewomen-take-on-abusive-husbands-idUSKCN1POOZY

## CHAPTER 11:
## Challenges and Strategies to Implementing Gender-Responsive Policing

1. UN Women announces United Nations Police Adviser Luís Carrilho as HeForShe Advocate for gender equality. UN Press Release (25 November 2019), at: https://www.heforshe.org/en/un-women-announces-united-nations-police-adviser-luis-carrilho-heforshe-advocate-gender-equality

2. St. Louis County Sheriff's Office Domestic Violence Handbook and Training Guide for Patrol Deputies (2001), Pence, E. St. Louis County Sheriff's Office's Safety and Accountability Audit available at: http://www.ncdsv.org/images/StLouisSheriffsOffice_DVHandbookTrainingGuidePatrolDep_2001.pdf

3. 'Turning Points: A Nonviolence Curriculum for Women' (2011), Pence, E., Connelly, L., and Scaia, M. Minnesota, at: https://www.theduluthmodel.org/wp-content/uploads/2017/03/Turning-Points-Curricula-for-Women-Who-Use-Violence-Preview.pdf

4. 'The Dangers of Dangerous Assessment' (2013). Stark, E., in Family and Intimate Partner Violence Quarterly (November 2013) at: http://www.ncdsv.org/FIPVQ_Dangers-of-dangerousness-assessment_11-20-2013.pdf

5. 'Re-presenting Battered Women: Coercive Control and the Defense of Liberty', Stark, E. in 'Violence Against Women: Complex Realities and New Issues in a Changing World' (Les Presses de l'Université du Québec, 2012), at: https://www.stopvaw.org/uploads/evan_stark_article_final_100812.pdf

6. 'Community Based Analysis of the U.S. Legal System's Interventions in Domestic Abuse Cases Involving Indigenous Women: Final Report to the National Institute of Justice' (2002). Mending the Sacred Hoop/Minnesota Development Project, Inc., at: https://praxisinternational.org/wp-content/uploads/2015/12/Final-1.pdf

7. 'Safety and Accountability Audit of the response to Native women who report sexual assault in Duluth, Minnesota, 2006-2008' (2011). Mending the Sacred Hoop and The Program to Aid Victims of Sexual Assault, at: https://www.bwjp.org/assets/documents/pdfs/executive_summary_native_women_sexual_assault_audit.pdf

8. 'Building a Coordinated Community Response to Domestic Violence: Trainer Guide' (2010), Paymar, M., Pence, E., and Barnes, G. Praxis International.

9. 'Domestic Violence Response Research and Study' (2018), Minneapolis Police Conduct Oversight Commission at: http://www.ci.minneapolis.mn.us/www/groups/public/@civilrights/documents/web-content/wcmsp-211936.pdf

10. 'The Vicarious Trauma Toolkit', Office for Victims of Crime at: https://vtt.ovc.ojp.gov/tools-for-law-enforcement/management-and-supervision?fbclid=IwAR32qSintkuMtP_icolLYpdmnHymwgSyzqKLYwy6XTo_SFdR-LF1Y-sVB_s

11. Provincial Policing Standards, Section 6.2.1, British Columbia, https://www2.gov.bc.ca/assets/gov/law-crime-and-justice/criminal-justice/police/standards/6-2-1-police-stops.pdf

12. The Duluth Blueprint for Safety, adopted January 29, 2015 at: https://www.theduluthmodel.org/wp-content/uploads/2017/03/1-Duluth-Intro.pdf

13. Developing Offender Risk Assessment (Georgia, 2017), Global Rights for Women, at: https://globalrightsforwomen.org/wp-content/uploads/2020/02/Georgia-2017-%E2%80%93-Developing-Offender-Risk-Assessment-FINAL-2.pdf

## CHAPTER 12:
## The Justice Continuum

1. Statement from Phumzile Mlambo-Ngcuka on the International Day for the Elimination of Violence against Women (20 November 2018) at: https://unwomen.org.au/statement-from-phumzile-mlambo-ngcuka-for-the-international-day-for-the-elimination-of-violence-against-women/

2. General Recommendation No. 28 on the Core Obligations of States Parties under Article 2 of the Convention on the Elimination of All Forms of Discrimination against Women (2010), UN Doc CEDAW/C/2010/47/GC.2, at: https://www2.ohchr.org/english/bodies/cedaw/docs/CEDAW-C-2010-47-GC2.pdf

3. General recommendation No. 25, on Article 4, Paragraph 1, of the Convention on the Elimination of All Forms of Discrimination against Women, on Temporary Special Measures, at: https://www.un.org/womenwatch/daw/cedaw/recommendations/General%20recommendation%2025%20%28English%29.pdf

4. 'About the CPS', The Crown Prosecution Service at: https://www.cps.gov.uk/about-cps

5. 'Training Manual for Judges and Prosecutors on Ensuring Women's Access to Justice' (Partnership for Good Governance, European Union) at: https://www.ohchr.org/Documents/Issues/Women/WRGS/TrainingManualAccessJustice_EN.pdf

6. A Practitioner's Toolkit on Women's Access to Justice Programming' (UN Women et al., 2018), at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/wa2j-complete-toolkit-en.pdf?la=en&vs=2654

7. Module 6: Implementation Guide, Essential Services Package for Women and Girls Subject to Violence : Core Elements and Quality Guidelines (2015), available at: https://www.unwomen.org/en/digital-library/publications/2015/12/essential-services-package-for-women-and-girls-subject-to-violence

8. UPR of IRAN (34th session, November 2019) Fact sheet on discrimination against women in Iran, Minority Rights Group International, available at: https://minorityrights.org/wp-content/uploads/2019/09/FACTSHEET-Discrimination-against-women-in-Iran-October-2019.pdf

9. Criminal Code of Armenia (2003) at: https://cis-legislation.com/document.fwx?rgn=7472

10. World Health Organization, Department of Reproductive Health and Research, London School of Hygiene and Tropical Medicine, South African Medical Research Council (2013), Global and regional estimates of violence against women: prevalence and health effects of intimate partner violence and non-partner sexual violence

11. Gender Mainstreaming for Health Managers: A Practical Approach / WHO Gender Analysis Tools. Facilitators' Guide. Participant's notes (WHO, 2011), at: https://www.who.int/gender-equity-rights/knowledge/health_managers_guide/en/

12. World Population Review (2019), at: http://worldpopulationreview.com/countries/rape-statistics-by-country/

13. 'Absence of Consent Must Become the Global Standard for Definition of Rape' (International Day on the Elimination of Violence against Women 25 November 2019), at: https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25340&LangID=E

14. Global Study on Homicide (UNODC, 2019), at: https://www.unodc.org/unodc/en/data-and-analysis/global-study-on-homicide.html

15. 'National measures taken to prevent, investigate, prosecute and punish gender-related killings of

women and girls' (2014) (UNODC/CCPCJ/EG.8/2014/CRP.1., at: https://www.unodc.org/documents/justice-and-prison-reform/IEGM_GRK_BKK/UNODC.CCPCJ.EG.8.2014.CRP.1.pdf

16. Les Chiffres de Référence sur les Violences Faites aux Femmes (2019). Secrétariat d'Etat chargé de l'égalité entre les femmes et les hommes et de la lutte contre les discriminations at : https://www.egalite-femmes-hommes.gouv.fr/le-secretariat-d-etat/

17. 'As Deaths Mount, France Tries to Get Serious About Domestic Violence' (2019). Fourquet, L. for the New York Times, at: https://www.nytimes.com/2019/09/03/world/europe/france-domestic-violence.html

18. Protocol on the handling of Female Genital Mutilation (FGM) offences between the National Police Chiefs' Council and the Crown Prosecution Service (National Police Chief's Council, 2016) at: https://www.cps.gov.uk/sites/default/files/documents/publications/FGM-Protocol-june-2016.docx

19. 'From the Margin to the Centre. - Addressing Violence Against Women and Girls (IMKAAN) at: https://829ef90d074549b2b404cbea85f15fda.filesusr.com/ugd/2f475d_91a5eb3394374f24892ca1e1ebfeea2e.pdf

20. 'Effective Responses in Cases Involving VAWG: The Role of the Prosecutor Handbook on Effective Prosecution Responses to Violence against Women and Girls' (UNODC, 2014) at: https://www.unodc.org/documents/justice-and-prison-reform/Handbook_on_effective_prosecution_responses_to_violence_against_women_and_girls.pdf

21. 'The Tip of the Iceberg' Sarkaria, N., and Campbell, G., for Counsel Magazine at: https://www.counselmagazine.co.uk/articles/tip-of-the-iceberg-the-family-court-ready-surge-activity-fgm

22. 'Compilation of Good Practices to Reduce Existing Obstacles and Facilitate Women's Access to Justice (Council of Europe Gender Equality Commission, 2015), at: https://edoc.coe.int/en/gender-equality/6695-gender-equality-commission-compilation-of-good-practices-to-reduce-existing-obstacles-and-facilitate-women-s-access-to-justice.html

23. European Probation Rules (2019), Canton, R. HM Inspectorate of Probation Academic Insights 2019/02, at: https://www.justiceinspectorates.gov.uk/hmiprobation/wp-content/uploads/sites/5/2019/03/Academic-Insights-Canton-Jan-19-final.pdf

24. United Nations Standard Minimum Rules for Non-custodial Measures ('The Tokyo Rules'), adopted by General Assembly resolution 45/110 of 14 December 1990, at: https://www.penalreform.org/priorities/alternatives-toimprisonment/international-standards/

25. 'England and Wales' Chapter in 'Manual on the Law Relating to Violence against Women' (2018), Sarkaria, N., and Campbell, G., European Lawyers Foundation, at: https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

26. OSCE-led Survey on Violence against Women: Experiences of Disadvantaged Women (Organisation for the Security and Co-operation in Europe, 2019), at: https://www.osce.org/secretariat/430007?download=true

27. 'To Tackle Domestic Violence, Ukraine Looks to UNFPA's Mobile Assistance Teams' (UNFPA, 2019) at: https://www.unfpa.org/news/tackle-domestic-violence-ukraine-looks-unfpa-mobile-assistance-teams

28. Cuidad Mujer, Secretaria de Inclusión Social. Gobierno de El Salvador, at: http://www.ciudadmujer.org/en/index.html

29. Evidence gathering - Joint Police-CPS Evidence Checklist Domestic Abuse Guidelines for Prosecutors (Crown Prosecution Service, UK, 2020) at: https://www.cps.gov.uk/sites/default/files/documents/publications/npcc_cps_joint_evidence_gathering_checklist_2015.docm

30. 'CPS to Extend Effective Domestic Violence Prosecution Scheme. Techniques Developed in Pilot Projects have Improved Conviction Rates' (2018), Bowcott, O., for The Guardian, at: https://www.theguardian.com/law/2018/dec/18/cps-to-extend-effective-domestic-violence-prosecution-scheme

31. 'Good Practice in Designing a Community-based Approach to Prevent Domestic Violence', Expert Paper: Expert Group Meeting Organized by UN Division for the Advancement of Women in Collaboration with UN Office on Drugs and Crime 17 to 20 May 2005 Vienna, Austria. Prepared by Lori Michau for Raising Voices. Kampala, Uganda, at: https://www.un.org/womenwatch/daw/egm/vaw-gp-2005/docs/experts/michau.community.pdf

32. 'From Evidence to Policy: Addressing Gender-Based Violence against Women and Girls in Bangladesh': A Report Submitted to Department for International Development by: ICDDR, in Collaboration with the Population Council (January 2013) at: https://assets.publishing.service.gov.uk/media/57a08a16ed915d3cf-d0005a4/VAWG_Bangladesh_Final_Report.pdf

33. The TOSTAN Program. Evaluation of a Community based Education Program in Senegal. Diop, N. J., Faye, M. M., Moreau, A., Cabral, J., & Benga, H., (New York:

Population Council, 2004) at: https://namati.org/wp-content/uploads/2015/12/Tostan-Senegal-2004-evaluation.pdf

34. 'FGM and the relationship between the Family Courts and the Criminal Courts', Sarkaria, N., and Campbell, G., International Family, law and Practice Journal (2015).

35. 'Harmful Traditional Practices: Prevention, Protection, and Policing', Campbell, G., Roberts, K.A., Sarkaria, N., Palgrave Macmillan (2020).

36. Guidance Note for UNODC Staff Gender Mainstreaming in the Work of UNODC (UNODC, 2013), at: https://www.unodc.org/documents/Gender/UNODC-GuidanceNote-GenderMainstreaming.pdf

37. Global Study on Homicide (UNODC, 2013) at: https://www.unodc.org/documents/data-and-analysis/statistics/GSH2013/2014_GLOBAL_HOMICIDE_BOOK_web.pdf

38. 'Women and the Criminal Justice System' (Mahony, T.H., Jacob, J., and Hobson, H. for the Government of Canada, 2011) at: https://www150.statcan.gc.ca/n1/en/pub/89-503-x/2015001/article/14785-eng.pdf?st=Nyr7c4ce

39. 'Towards Gender-Responsive Criminal Justice: Good practices from Southeast Asia in responding to violence against women' Skinnider, E., Thailand Institute of Justice (2018), at: https://icclr.org/wp-content/uploads/2019/06/Towards-Gender-Responsive-Criminal-Justice.pdf?x37853

40. Feasibility Study for a Convention against Domestic Violence (2008), Council of Europe, Committee of Ministers, 1037 Meeting, 8 October 2008 European Committee on Crime Problems.

41. 'Intersectionality and Beyond: Law, Power and the Politics of Location', Edited by Grabham, E., Herman, D., Cooper, D., and Krishnadas, J., Routledge-Cavendish (2009).

42. 'The Trial of Rape. Understanding the Criminal Justice System Response to Sexual Violence in Thailand and Viet Nam (UN Women, UNDP, UNODC, 2017) available at: https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2019/08/ap-trial-of-rape_26aug2019_lowres-compressed.pdf?la=en&vs=1916

43. 'Manual on the Law Relating to Violence against Women: England and Wales, Greece, Ireland, Italy, Northern Ireland, Poland, Spain' (European Lawyers Foundation and European Union, 2018) at: https://elf-fae.eu/wp-content/uploads/2018/06/Manual-on-the-law-relating-to-violence-against-women.pdf

44. 'Investigation, Protection, and Support Measures for GBV Victims. Resource Book: Experience and Guidelines of the Korean Police' (UNDP Seoul Policy Centre, 2019).

45. 'A Review of the Evidence on Multi-sectoral Interventions to Reduce Violence against Adolescent Girls', Blanc, A.K., Melnikas, A., Chau, M., and Stoner, M. Integrated Approaches to Improving the Lives of Adolescent Girls Issue Papers Series: Girl Hub (2013).

46. Victims' Rights to Support and Protection from Violence (2013); Legislation for the Protection from Violence in Austria (2019), Domestic Abuse Intervention Centre and the Association of Austrian Autonomous Women's Shelters at: https://www.interventionsstelle-wien.at/download/?id=692

## CHAPTER 13: Emerging Issues in Investigating VAWG

1. 'Study on Ways and Methods to Eliminate Sexual Harassment in Egypt Results / Outcomes and Recommendations Summary' (UN Women, European Union et. al), at: https://web.law.columbia.edu/sites/default/files/microsites/gender-sexuality/un_women-sexual-harassment-study-egypt-final-en.pdf

2. 'Measuring #MeToo: A National Study on Sexual Harassment and Assault (UC San Diego Center on Gender Equity and Health, 2019)

3. 'Major Investigation and Public Protection: Investigative Development-Lines of Enquiry (College of Policing, UK) at: https://www.app.college.police.uk/app-content/major-investigation-and-public-protection/domestic-abuse/investigative-development/#checklist-lines-of-enquiry

4. 'Stalking or Harassment (College of Policing, UK, 2019) at: http://library.college.police.uk/docs/appref/Stalking_or_harassment_guidance_200519.pdf

5. 'Violence Against Women: An EU-wide Survey' (European Agency for Fundamental Rights, 2015), at: https://www.equalrights.org/issue/economic-workplace-equality/sexual-harassment/

6. 'Misogyny Hate Crime Evaluation Report for Nottingham Women's Centre', Funded by the Office of Nottinghamshire Police and Crime Commissioner, Mullany, L., and Trickett, L., (June 2018) at: http://www.nottinghamwomenscentre.com/wp-content/

uploads/2018/07/Misogyny-Hate-Crime-Evaluation-Report-June-2018.pdf

7. Sexual Harassment of Women and Girls in public spaces: 6th Report of Session 2017-2019, House of Commons Women and Equalities Committee (UK) (2018).

8. Know Your Rights at Work: Sexual Harassment (Equal Rights Advocates, 2019) at: https://www.equalrights.org/issue/economic-workplace-equality/sexual-harassment/

9. Unmasking Sexual Harassment How Toxic Masculinities Drive Men's Abuse in the US, UK, and Mexico and What We Can Do to End It: A Promundo Research Brief Produced for World Economic Forum Annual Meeting 2018, Promundo, available at: https://promundoglobal.org/wp-content/uploads/2018/01/Sexual-Harrassment-Brief-Final-To-Post.pdf

10. 'Amnesty reveals alarming impact of online abuse against women' Amnesty International, at: https://www.amnesty.org/en/latest/news/2017/11/amnesty-reveals-alarming-impact-of-online-abuse-against-women/

11. 'Spotted: Obligations to Protect Women Students' Safety and Equality Using the Public Sector Equality Duty and the Human Rights Act in Higher and Further Education Institutions to Improve Policies and Practices on Violence Against Women and Girls': Legal Briefing prepared by Louise Whitfield and Holly Dustin for the End Violence Against Women Coalition (January 2015), at: https://www.endviolenceagainstwomen.org.uk/wp-content/uploads/Spotted-Obligations-to-Protect-Women-StudentsEy-Safety-Equality.pdf

12. Widadio, N. A., (2019), 'Many Indonesian Women face sexually harassment: Survey', Coalition for Safe Public Space.

13. Pietsch, N., (2015), 'Sexual Harassment and Public Space Learning Brief' (27) London, Ontario: Learning Network, Center for Research and Education on Violence against Women and Children, at: http://www.vawlearningnetwork.ca/our-work/briefs/briefpdfs/LB-27.pdf

14. Smith B. L (2018), 'What it really takes to stop sexual harassment', Vol 49 (No.2), American Psychological Association.

15. Bystander Approach, Graham Goulden for Cultivating Minds, UK, at: https://grahamgoulden.com/cultivating-minds-uk/about/

16. 'Ending Sexual Harassment at UN Events' (UN Department of Management Strategy, Policy and Compliance, 2019), at: https://www.un.org/management/news/ending-sexual-harassment-un-events

17. UN Code of Conduct to Prevent Harassment, Including Sexual Harassment, at UN System Events.

18. Independent review of UN Women's policies and procedures for tackling Sexual Exploitation and Abuse (SEA) and Sexual Harassment (SH). Final Report - Confidential (Copenhagen, 24 May 2019).

19. Report into Workplace Harassment in the RCMP, Government of Canada (2017) at: https://www.crcc-ccetp.gc.ca/pdf/harassmentFinR-eng.pdf

20. Cividanes G.C., Mello A.F., Mello M.F., 'Revictimization as a high-risk factor for development of posttraumatic stress disorder: a systematic review of the literature', Braz J Psychiatry, 2018; 00:000-000. http://dx.doi.org/10.1590/1516-4446- 2017-0013

21. International Protocol on the Documentation and Investigation of Sexual Violence in Conflict: Basic Standards of Best Practice on the Documentation of Sexual Violence as a Crime under International Law, (London: Foreign and Commonwealth Office, 2014) at: https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/598335/International_Protocol_2017_2nd_Edition.pdf

22. Women's Meaningful Participation in Negotiating Peace and the Implementation of Peace Agreements Report of the Expert (2018). Convened by UN Women in preparation for the UN Secretary-General's report on Women and Peace and Security, New York, U.S., at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2018/egm-womens-meaningful-participation-in-negotiating-peace-en.pdf?la=en&vs=3047

23. Implementing Locally, Inspiring Globally: Localizing UNSCR 1325 in Colombia, Nepal, the Philippines', Sierra Leone, and Uganda' (Global Network of Women Peacebuilders, 2013) at: https://gnwp.org/publications/implementing-locally-inspiring-globally-localizing-unscr-1325-in-colombia-nepal-the-philippines-sierra-leone-and-uganda/

24. Evaluation of the Project 'From words to actions: An integrated approach towards effective implementation of UNSCR 1325 and 1820 at local, national and global levels', implemented by the Global Network of Women Peacebuilders with support from the Austrian Development Cooperation (Evaluation Report, 10 March 2017, Consultant: Annalise Moser).

25. 'Interventions to Reduce Gender-based Violence in Humanitarian Settings' (Sexual Violence Research Institute and World Bank Group, 2019) at: https://www.svri.org/sites/default/files/attachments/2019-11-20/InterventionstoReduceGBVinHumanitarianSettings.pdf

26. SáCouto, Susana and Cleary Katherine, 'Importance of Effective Investigation of Sexual Violence and Gender-Based Crimes at the International Criminal Court' American University Journal of Gender, Social Policy and the Law. 17, no. 2 (2009): 337-359.

27. Swaine, Aisling (2018), 'Conflict-Related Violence Against Women: Transforming Transition', Cambridge: Cambridge University Press;

28. Hossain, Naomi (2012),' Security and the Pathways of Women's Empowerment: Findings from a Thematic Synthesis of the Pathways of Women's Empowerment Research', IDS Working Paper 406, Brighton: Institute of Development Studies.

29. Cohen, D, Green, A.H., and Wood, E.J., 'Wartime sexual violence: misconceptions, implications and ways forward: Special Report' (2013), US Institute for Peace. Washington, D.C.

30. Gender and SALW in South East Europe (South Eastern and Eastern Europe Clearinghouse for the Control of Small Arms and Light Weapons (SEESAC), 2016) at: https://www.seesac.org/f/docs/Armed-Violence/Gender_and_SALW_publication_eng-web.pdf

31. Aolain, Fionnuala Ni, and Rooney Eilish (2007), 'Under Enforcement and Intersectionality: Gendered Aspects of Transition for Women,' International Journal of Transitional Justice, Vol. 1, Issue 3, pp. 338–54.

32. Watson, Callum, 'Preventing and Responding to Sexual and Domestic Violence against Men: A Guidance Note for Security Sector Institutions' (Geneva: DCAF, 2014), at: https://www.dcaf.ch/sites/default/files/publications/documents/SDVAM_FINAL%20online.pdf

33. 'International Legal Protection of Human Rights in Armed Conflict' (OHCHR, 2011) at: https://www.ohchr.org/Documents/Publications/HR_in_armed_conflict.pdf

34. Report of the Secretary-General on conflict-related sexual violence (2017), UN Doc S/2017/249, at: https://undocs.org/S/2017/249

35. 'Women, War and Peace: The Independent Experts' Assessment on the Impact of Armed Conflict on Women and Women's Role in Peace-Building', Rehn, E., and Sirleaf, (United Nations Development Fund for Women (UNIFEM), 2002) at: https://www.unfpa.org/sites/default/files/pub-pdf/3F71081FF391653DC1256C69003170E9-unicef-WomenWarPeace.pdf

36. Rome Statute of the International Criminal Court U.N. Doc. A/CONF.183/9, July 17, 1998, 37 I.L.M. 1002, 1030 (entered into force July 1, 2002).

37. Inter-Agency Standing Committee, at: https://interagencystandingcommittee.org/the-inter-agency-standing-committee

38. Kelly Dawn Askin, 'Prosecuting Gender Crimes Committed in Darfur: Holding Leaders Accountable for Sexual Violence', in 'Genocide in Darfur', 141, 144 (Samuel Totten et al. eds., 2006).

39. Report on Sexual Gender-based Violence and Health Facility Needs Assessment (Lofa, Nimba, Grand Gedeh and Grand Bassa counties) in Liberia, Omanyondo, M.O. for the World Health Organization (2005).

40. Government/UN Joint Programme to prevent and respond to GBV (June 13, 2008). Information shared by Dr Sadiq Syed, Deputy Regional Program Director with UN Women in Southern Africa.

41. Sexual Crimes, committed on September, October, November 2008 in Liberia (UNPOL-December 2008). Information shared by Dr Sadiq Syed, Deputy Regional Program Director with UN Women in Southern Africa.

42. 'SGBV Capacity-building in Peace Operations: Specialized Police Teams', Caparini, M., and Osland, K.M., Policy Brief (35/ 2016), Norwegian Institute of International Affairs.

43. National Action Plans for the Implementation of UNSCR 1325 on Women, Peace and Security. Women's International League of Peace and Freedom, at: https://www.peacewomen.org/member-states

44. Tools for Development Using Information and Communications Technology to Achieve the Millennium Development Goals: Working Paper, United Nations ICT Task Force December 2003, at: https://www.itu.int/net/wsis/stocktaking/docs/activities/1103056110/ICTMDGFinal.pdf

45. UN Broadband Commission for Digital Development (2015), 'Cyber Violence Against Women and Girls: A worldwide wake-up call' – a report by the UN Broadband Commission for the Digital Development Working Group on Broadband and Gender, at: https://en.unesco.org/sites/default/files/genderreport2015final.pdf

46. Cyber Violence against women and girls (European Institute for Gender Equality, 2017) at: https://eige.europa.eu/publications/cyber-violence-against-women-and-girls

47. 'Cyber Violence against Women and Girls: Report' (CyberSafe, University of Ljubljana, Faculty of Social

Sciences, 2017) at: https://www.wave-network.org/wp-content/uploads/WP2-Report-on-Cyber-VAWG.pdf

48. UN Broadband Commission for Digital Development (2015), 'Cyber Violence Against Women and Girls A worldwide wake-up call' - a report by the UN Broadband Commission for the Digital Development Working Group on Broadband and Gender, at: https://en.unesco.org/sites/default/files/genderreport2015final.pdf

49. 'Handbook for the Judiciary on Effective Criminal Justice Responses to Gender-based Violence against Women and Girls' (UNODC, 2019), at: https://www.unodc.org/pdf/criminal_justice/HB_for_the_Judiciary_on_Effective_Criminal_Justice_Women_and_Girls_E_ebook.pdf

50. 'Attacks and Harassment: The Impact on Female Journalists and Their Reporting' (2018), Troll-busters.com and international women's media foundation, at: https://www.iwmf.org/wp-content/uploads/2018/09/Attacks-and-Harassment.pdf

51. 'Cyber violence and hate speech online against women: Study' (European Parliament's Policy Department for Citizens' Rights and Constitutional Affairs, 2018) at: https://www.europarl.europa.eu/RegData/etudes/STUD/2018/604979/IPOL_STU(2018)604979_EN.pdf

52. 'More than 175,000 children go online for the first time every day, tapping into great opportunities, but facing grave risks', UNICEF press release (1 February 2018) at: https://www.unicef.org/eap/press-releases/more-175000-children-go-online-first-time-every-day-tapping-great-opportunities

53. 'Gender-based interpersonal cybercrime' (UNODC University Module Cybercrime Series) at: https://www.unodc.org/e4j/en/cybercrime/module-12/key-issues/gender-based-interpersonal-cybercrime.html

54. Powell, A., Henry, N., and Flynn, A., (2018) 'Image-based sexual abuse', in De Keseredy, W., and Dragiewicz, M., (Eds), Routledge Handbook of Critical Criminology: 2nd Edition, pp. 305-315, Routledge: London

55. Cyber criminology. Maras, M., Oxford Press, November 2016 ISBN: 9780190278441.

56. National Institute of Justice, U.S. Department of Justice, at: https://nij.ojp.gov/topics/articles/overview-predictive-policing

57. Terminology Guidelines for the Protection of Children from Sexual Exploitation and Sexual Abuse, adopted by the Interagency Working Group in Luxembourg (28 January 2016). Interagency Terminology and Semantics Project on the Sexual Exploitation and Sexual Abuse of Children and ECPAT International, at: http://luxembourgguidelines.org/

58. Thakur, Dhanaraj (2018), 'How do ICTs mediate gender-based violence in Jamaica?', in Gender and Development, 26:2.

59. 'Global Landscape Analysis Report on Online and ICT facilitated Violence against Women and Girls' (UN Women, 2021).

## CHAPTER 14:
## Public Health Emergencies and Non-Conflict Humanitarian Crises

1. 'Protecting Sexual and Reproductive Health and Rights and Promoting Gender-responsiveness in the COVID-19 Crisis', Joint Press Release, Government Offices of Sweden (2020), at: https://www.government.se/statements/2020/05/joint-press-statement-protecting-sexual-and-reproductive-health-and-rights-and-promoting-gender-responsiveness-in-the-covid-19-crisis/

2. Coronavirus Disease (COVID-19) Outbreak (WHO Regional Office for Europe, 2020) at: http://www.euro.who.int/en/health-topics/health-emergencies/coronavirus-covid-19/novel-coronavirus-2019-ncov

3. Ebola virus disease: Key Facts (WHO, 2020) at: https://www.who.int/news-room/fact-sheets/detail/ebola-virus-disease

4. Interim Guidance; Gender alert for COVID-19 outbreak, Inter-Agency Standing Committee (March 2020), at: https://interagencystandingcommittee.org/inter-agency-standing-committee/interim-guidance-gender-alert-covid-19-outbreak-developed-iasc

5. 'A policy paper on COVID-19's gender implications', (CARE, March 2020), at: https://www.care.org/newsroom/press/press-releases/covid-19s-gender-implications-examined-in-policy-brief-care

6. Secretary-General's video message on gender-based violence and COVID-19 (United Nations, 5 April, 2020), at: https://www.un.org/sg/en/content/sg/statement/2020-04-05/secretary-generals-video-message-gender-based-violence-and-covid-19-scroll-down-for-french

7. UNODC's Global Study on Homicide: Gender-related killing of women and girls (UNODC, 2018) at: https://www.unodc.org/documents/data-and-analysis/GSH2018/GSH18_Gender-related_killing_of_women_and_girls.pdf

8. 'Violence against women and girls: the shadow pandemic', Statement by Phumzile Mlambo-Ngcuka, Executive Director of UN Women (6 April 2020) at: https://www.unwomen.org/en/news/stories/2020/4/statement-ed-phumzile-violence-against-women-during-pandemic

9. 'Emergencies preparedness, response. What is a pandemic?' (WHO, 24 February 2010 at: https://www.who.int/csr/disease/swineflu/frequently_asked_questions/pandemic/en/

10. 'Policing the Pandemic: How UN Police are Maintaining Law, Order, and Public Health' (UN News Peace and Security, 23 May 2020) at: https://news.un.org/en/story/2020/05/1064812

11. 'COVID-19 and Ending Violence Against Women and Girls' (UN Women Issue Brief, April 2020) at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/issue-brief-covid-19-and-ending-violence-against-women-and-girls-en.pdf?la=en&vs=5006

12. 'Justice for women amidst COVID-19' (UN Women Issue Brief, May 2020) at: https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2020/justice-for-women-amidst-covid-19-en.pdf?la=en&vs=4857

13. Weitzman, A., and Behrman, J.A., (2016), 'Disaster, Disruption to Family Life and Intimate Partner Violence: The Case of the 2010 Earthquake in Haiti', in Sociological Science, 3: 167-189, at : https://www.sociologicalscience.com/download/vol-3/march/SocSci_v3_167to189.pdf

14. 'Pandemics and Violence Against Women and Children', Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development (2020), at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

15. 'Gender Dimensions of the COVID-19 Pandemic' (English), (Washington, D.C., World Bank Group, 2020) at: http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic

16. Coronavirus Disease (COVID-19) response – UNODC Thematic Brief on gender-based violence against women and girls (UNODC, 2020), at: https://www.unodc.org/documents/Advocacy-Section/GBVAW_and_UNODC_in_COVID19_final_7Apr2020.pdf

17. 'Impact of COVID-19 Pandemic on Violence against Women and Girls' (2020), Fraser, E. for UKAid, WAG Helpdesk Research Report, at: https://www.dmeforpeace.org/peacexchange/wp-content/uploads/2020/04/vawg-helpdesk-284-covid-19-and-vawg.pdf

18. 'On the Front Lines of COVID-19, Women's Organizations Provide Vital Services as First Responders as Violence against Women Spikes' (UN Women, 27 May 2020) at: https://www.unwomen.org/en/news/stories/2020/5/feature-womens-organizations-provide-vital-services-as-violence-against-women-spikes

19. Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L. et al. (2008), 'Global trends in emerging infectious diseases', Nature 451: 990-94.

20. 'Wheels', adapted from the Power and Control Wheel Model (The National Center on Domestic and Sexual Violence) at: http://209.198.129.131/publications_wheel.html

21. 'Bridging the Digital Gender Divide Include, Upskill, Innovate' (Organisation for Economic Co-operation and Development (OECD), 2018) at: http://www.oecd.org/internet/bridging-the-digital-gender-divide.pdf

22. 'Ways to Bridge the Gender Digital Divide from a Human Rights Perspective' (2016), submission by the Human Rights, Big Data and Technology Project at the Human Rights Centre of the University of Essex, funded by the Economic and Social Research Council at: https://www.ohchr.org/Documents/Issues/Women/WRGS/GenderDigital/HRBDT_submission.pdf.

23. 'Women's Rights Online. Translating Access into Empowerment' (World Wide Web Foundation, 2015) at: http://webfoundation.org/docs/2015/10/womens-rights-online21102015.pdf.

24. Pandemics and Violence Against Women and Children (2020), Peterman, A., Potts, A., O'Donnell, M., Thompson, K., Shah, N., Oertelt-Prigione, S., and van Gelder, N., Center for Global Development at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

25. 'Remote Court Hearings and Judicial Processes in Response to COVID-19 in Mission and other Fragile Settings Justice and Correction Service' (UN Office of Rule of Law and Security Institutions (OROLSI)/Department of Peace Operations (DPO), 13 April 2020) at: https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf

26. 'COVID-19: How to include marginalized and vulnerable people in risk communication and community engagement' (International Federation of Red Cross and Red Crescent Societies, UN Office for the Coordination of Humanitarian Affairs and the World Health Organization 2020) at: https://reliefweb.

int/sites/reliefweb.int/files/resources/COVID-19_CommunityEngagement_130320.pdf

27. 'Global trends in emerging infectious diseases', Jones, K.E., Patel, N., Levy, M., Storeygard, A., Balk, D., Gittleman, J.L., et al. (2008), in Nature 451: 990-94, at: https://www.cgdev.org/publication/pandemics-and-violence-against-women-and-children

28. Ecuador Country Case Study. Effective law and policy on gender equality and protection from sexual and gender-based violence in disasters (The International Federation of Red Cross and Red Crescent Societies (IFRC), 2020 at: https://media.ifrc.org/ifrc/document/effective-law-policy-gender-equality-protection-sexual-gender-based-violence-disasters-ecuador/

29. Special Rapporteur on violence against women finalizes country mission to the United Kingdom and Northern Ireland and calls for urgent action to address the accountability deficit and also the adverse impacts of changes in funding and services (2014) at: https://www.ohchr.org/en/newsevents/pages/displaynews.aspx?newsid=14514&

30. 'Hard times: Women's pathways to crime and incarceration (2012)', Artz, L., Hoffman-Wanderer, Y., and Moult, K., at: https://genderlinks.org.za/wp-content/uploads/imported/articles/attachments/18024_hard_times.pdf

31. 'Gender-Based Discrimination and Women in Conflict with the Law' (UNODC, 2020), at: https://www.unodc.org/e4j/en/crime-prevention-criminal-justice/module-9/key-issues/1--gender-based-discrimination-and-women-in-conflict-with-the-law.html

32. UN Secretary-General's report on violence against women migrant workers (2019) (A/74/235), at: https://www.unwomen.org/en/digital-library/publications/2019/07/a-74-235-sg-report-violence-against-women-migrant-workers

33. 'Addressing the Impacts of the COVID-19 Pandemic on Women Migrant Workers' (UN Women Guidance Note, 2020) at: https://www.unwomen.org/en/digital-library/publications/2020/04/guidance-note-addressing-the-impacts-of-the-covid-19-pandemic-on-women-migrant-workers

34. 'From Global Coordination to Local Strategies A Practical Approach to Prevent, Address and Document Domestic Violence under COVID-19', Briefing Paper (MADRE, Media Matters for Women, MenEngage Alliance, Nobel Women's Initiative, OutRight Action International, Women Enabled International, and Women's International League for Peace and Freedom (WILPF), 2020) at: https://www.wilpf.org/wp-content/uploads/2020/04/MADRE-Domestic-Violence-Under-COVID-19-Briefing-Paper_4.21.20.pdf

35. 'Coronavirus lockdown raises risk of online child abuse, charity says' The Guardian (2020) at: https://www.theguardian.com/world/2020/apr/02/coronavirus-lockdown-raises-risk-of-online-child-abuse-charity-says

36. 'COVID-19: Urgent need for child protection services to mitigate the risk of child sexual abuse and exploitation worldwide' (6 May 2020), Mama Fatima Singhateh, the Special Rapporteur on the sale and sexual exploitation of children at: https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25865&LangID=E

37. 'Risk of online sex trolling rises as coronavirus prompts home working', Reuters (2020) at: https://www.reuters.com/article/us-women-rights-cyberflashing-trfn-idUSKBN2153HG

38. 'Gender Dimensions of the COVID-19 Pandemic (Washington, D.C.: World Bank Group, 2020) at: http://documents.worldbank.org/curated/en/618731587147227244/Gender-Dimensions-of-the-COVID-19-Pandemic

39. 'Has it become too dangerous to measure violence against women? Kelli Rogers (6 May 2020) at: https://asiapacific.unfpa.org/en/news/covid-19-has-it-become-too-dangerous-measure-violence-against-women

40. The Sphere Handbook: Humanitarian Charter and Minimum Standards in Humanitarian Response, fourth edition (Geneva, Switzerland, 2018) at: https://spherestandards.org/wp-content/uploads/Sphere-Handbook-2018-EN.pdf

41. Bystander Approach, Graham Goulden for Cultivating Minds, UK, at: https://grahamgoulden.com/cultivating-minds-uk/about/

42. 'The Security Sector's Role in Responding to Health Crises. Lessons from the 2014–2015 Ebola Epidemic and Recommendations for the Mano River Union and Its Member States', Sandy, J., Schnabel, A., Sovula, H., Trepp, U., and Zumsteg, R., (The Geneva Centre for the Democratic Control of Armed Forces (DCAF), 2017) at: https://www.dcaf.ch/security-sectors-role-responding-health-crises-lessons-2014-2015-ebola-epidemic

43. Court Response to Violence Against Women During COVID-19 - Webinar Series: 'Adapting Legal and Systemic Responses During COVID-19 Addressing Violence Against Women' (3 April 2020), Global Rights for Women at: https://globalrightsforwomen.org/wp-content/uploads/2020/04/Court-Response-to-Violence-Against-Women-During-COVID-19-Powerpoint_compressed.pdf

44. Policy Brief: 'The Impact of COVID-19 on Children' (UN Sustainable Development Group, 2020) at: https://unsdg.un.org/resources/policy-brief-impact-covid-19-children

45. 'COVID-19 and violence against women What the health sector/system can do' (World Health Organization, 2020) at: https://www.who.int/reproductivehealth/publications/emergencies/COVID-19-VAW-full-text.pdf?ua=1

46. Jhumka Gupta, 'What does coronavirus mean for violence against women?, Women's Media Centre, 19 March 2020 at: https://womensmediacenter.com/news-features/what-does-coronavirus-mean-for-violence-against-women

47. 'COVID-19 and Gender Equality and Women, Peace and Security' (UN Department of Peace Operations) at: https://peacekeeping.un.org/sites/default/files/covid-19_and_wps.pdf

48. 'Keeping the Faith: The Role of Faith Leaders in the Ebola Response', (London: Christian Aid, CAFOD, Tearfund, and Islamic Relief, 2015) at: http://learn.tearfund.org/~/media/files/tilz/research/keeping_the_faith_july_2015.pdf

49. 'Ebola Recovery in Sierra Leone Tackling the Rise in Sexual and Gender Based Violence and Teenage Pregnancy During The Ebola Crisis,' (New York: UNDP, 2015a) at: https://www.undp.org/content/dam/sierraleone/docs/Ebola%20Docs./SL%20FS%20SGBV.pdf

50. Confronting the gender impact of the Ebola Virus Disease on Guinea, Liberia and Sierra Leone. Africa Policy Note, Vol. 2, No. 1, 30 January 2015, p.4, at: https://reliefweb.int/sites/reliefweb.int/files/resources/RBA%20Policy%20Note%20Vol%202%20No%201%202015_Gender.pdf

51. 'Conflict, Displacement and IPV: Findings from Two Congolese Refugee Camps in Rwanda', Wako, E., Elliott, L., De Jesus, S., Zotti, M.E., Swahn, M.H., and J. Beltrami, (2015), Violence Against Women. 21(9): 1087-101.

52. 'Violence against refugee women along the Thai-Burma border', Falb, K.L., McCormick, M.C., Hemenway, D., Afinson, K., and J.G. Silverman (2013), in the International Journal of Gynecology and Obstetrics. 120(3): 279-283, at: http://support.arcrelief.org/site/DocServer/VAW_on_the_Thai-Myanmar_Border.pdf?docID=2622

53. Horn, R., (2010), 'Responses to intimate partner violence in Kakuma a refugee camp: Refugee interactions with agency systems' in Social Science and Medicine. 70(1): 160-168.

54. 'A New Scourge to Afghan Women' - COVID-19 Oxfam Briefing Note (Oxfam, 2020) at: https://asia.oxfam.org/latest/policy-paper/new-scourge-afghan-women-covid-19

55. UNICEF Helpdesk Gender-Based Violence in Emergencies: Emergency Responses to Public Health Outbreaks (UNICEF, 2018) at: http://www.sddirect.org.uk/media/1617/health-responses-and-gbv-short-query-v2.pdf

56. 'Increased Gender-based Violence Among Women Internally Displaced in Mississippi 2 Years Post-Hurricane Katrina', Anastario, M., Shehab, N., and Lawry, L., (2013) in Disaster Medicine and Public Health Preparedness. 3 (1): 18-26.

57. 'Converging drivers of interpersonal violence: Findings from a qualitative study in post-hurricane Haiti', Bermudez, L.G., Stark, L., Bennouna, C., Jensen, C., Potts, A., Kaloga, I.F., et al. (2019), in Child Abuse and Neglect, 89:178-191.

58. 'Gender-based violence and environment linkages', Castañeda Camey, I., Sabater, L., Owren, C., and Boyer, A.E., (2020) in 'The violence of inequality', Wen, J. (ed.). Gland, Switzerland: IUCN. 272pp.

59. 'Responding to Typhoon Haiyan: Women and Girls Left Behind. A Study on Violence against Women and Girls Prevention and Mitigation in the Response to Typhoon Haiyan', (International Rescue Committee (IRC) and Global Women's Institute (GWI), 2015), at: https://www.whatworks.co.za/documents/publications/17-responding-to-typhoon-haiyan-women-and-girls-left-behind/file

60. 'Sitting on a Volcano: Domestic Violence in Indonesia Following Two Volcano Eruptions', Schwefer, M., (2018), IFO Working Paper Series 263, IFO Institute – Leibniz Institute for Economic Research at the University of Munich, at: https://www.cesifo.org/DocDL/wp-2018-263-schwefer-domestic-violence.pdf

61. 'Prevalence of Sexual Violence among Female Refugees in Complex Humanitarian Emergencies: A Systematic Review and Meta-Analysis', Vu, A., Adam, A., Wirtz, A., Pham, K., Rubenstein, L., Glass, N., Beyrer, C., and Singh, S., (2014), The PLoS Curr. Edition 1. doi: 10.1371/currents.dis.835f10778fd80ae031aac12d3b-533ca7, available at: http://currents.plos.org/disasters/index.html%3Fp=11337.html

62. International Rescue Committee (IRC), (2015) at: https://www.rescue.org/sites/default/files/document/564/ircpvpcfinalen.pdf

63. 'A systematic review of prevalence studies of gender-based violence in complex emergencies', Stark,

L., and Ager, A., (2011) in Trauma Violence Abuse 12 (3): 127-34.

64. 'Everything on her Shoulders: Rapid Assessment on Gender and Violence against Women and Girls in Beni, DRC', (New York: International Rescue Committee (IRC), 2019) at: https://www.rescue.org/report/everything-her-shoulders-rapid-assessment-gender-and-violence-against-women-and-girls-ebola

65. 'Ebola Recovery in Sierra Leone: Tackling the rise in sexual and gender-based violence and teenage pregnancy during the Ebola crisis' (UNDP, 2015) at: https://www.undp.org/content/dam/sierraleone/docs/Ebola%20Docs./SL%20FS%20SGBV.pdf

66. UNICEF Helpdesk Gender Based Violence in Emergencies: Emergency Responses to Public Health Outbreaks, (UNICEF, 2018) at: http://www.sddirect.org.uk/media/1617/health-responses-and-gbv-short-query-v2.pdf

67. 'Vulnerability in an Influenza Pandemic: Looking Beyond Medical Risk. Technical Report'. O'Sullivan, T., and Bourgoin, M., (2010) (28 March 2020), at: https://www.semanticscholar.org/paper/Vulnerability-inan-Influenza-Pandemic-%3A-Looking-%2C-O%E2%80%99SullivanBourgoin/48b390413d140b148a598a81dc4ec4515f1d458e

68. 'Integrating a Gender Perspective into Human Rights Investigations Guidance and Practice' (New York and Geneva: UN Office of the High Commissioner for Human Rights, 2018) at: https://www.ohchr.org/Documents/Issues/Women/Publications/GenderIntegrationintoHRInvestigations.pdf

69. 'Prevention: Violence against women and girls and COVID-19' (UN Women Issue Brief, 2020) at: https://www.unwomen.org/en/digital-library/publications/2020/05/brief-prevention-violence-against-women-and-girls-and-covid-19

70. 'COVID-19 and Essential Services Provision for Survivors of Violence Against Women and Girls' (UN Women et al., Issue Brief, 2020) at: https://www.unwomen.org/en/digital-library/publications/2020/04/brief-covid-19-and-essential-services-provision-for-survivors-of-violence-against-women-and-girls

71. 'Online and ICT-facilitated violence against women and girls during COVID-19' (UN Women Issue Brief, 2020) at: https://www.unwomen.org/en/digital-library/publications/2020/04/brief-online-and-ict-facilitated-violence-against-women-and-girls-during-covid-19

72. 'Guidelines for Mobile and Remote Gender-Based Violence (GBV) Service Delivery' (International Rescue Committee (IRC), 2018) at: https://reliefweb.int/sites/reliefweb.int/files/resources/GBV-Mobile-and-Remote-Service-Delivery-Guidelines_-final.pdf

73. 'Identifying and Mitigating Gender-based Violence Risks within the COVID-19 Response', last updated: 6 April 2020, Inter-Agency Standing Committee (IASC), at: https://gbvguidelines.org/wp/wp-content/uploads/2020/04/Interagency-GBV-risk-mitigation-and-Covid-tipsheet.pdf

74. Personal Protective Equipment (PPE) Operational Guidance (8 April 2020), College of Policing, UK, at: https://www.college.police.uk/What-we-do/COVID-19/Documents/Personal-Protective-Equipment-Operational-Guidance-1.pdf

75. 'Lockdown on Domestic Violence' (Akshara Centre, 2020) at: https://www.aksharacentre.org/lockdown-logs/

76. 'Online Safety in a Changing World – COVID-19 and Cyber Violence' (Sexual Violence Research Initiative, 2020), at: https://www.svri.org/blog/online-safety-changing-world-%E2%80%93-covid-19-and-cyber-violence

77. 'COVID-19 at the Intersection of Gender and Disability: Findings of a Global Human Rights Survey, March to April 2020' (Women Enabled International, 2020) at: https://womenenabled.org/pdfs/Women%20Enabled%20International%20COVID-19%20at%20the%20Intersection%20of%20Gender%20and%20Disability%20May%202020%20Final.pdf

78. 'COVID-19 and Child, Early and Forced Marriage: An Agenda for Action' (Girls not Brides, The Global Partnership to End Marriage, 2020) at: https://www.girlsnotbrides.org/wp-content/uploads/2020/04/COVID-19-and-child-early-and-forced-marriage_FINAL-4.pdf

79. 'A Girl No More: The Changing Norms of Child marriage in Conflict (Women's Refugee Commission, 2016), at: https://reliefweb.int/sites/reliefweb.int/files/resources/Changing-Norms-of-Child-Marriage-in-Conflict.pdf

80. 'Did You Know That Millions of People Around the World Are Still Uprooted from Their Homes by Disasters (2020)?', André, C., Ginnetti, J., and Ponserre, S., for the Internal Displacement Monitoring Centre at: https://www.internal-displacement.org/expert-opinion/did-you-know-that-millions-of-people-around-the-world-are-still-uprooted-from-their

81. Washington Group Questionnaire, at : http://www.washingtongroup-disability.com/washington-group-question-sets/

82. 'Justice for Women amidst COVID-19' (UN Women, IDLO, UNDP, UNODC, World Bank and the Pathfinders for Justice, 2020) at: https://www.idlo.int/sites/default/files/pdfs/publications/Justice-for-Women_Full-Report-English.pdf

83. 'Gender Alert on COVID-19, Lebanon' - In Focus: Access to Justice and Gender Based Violence, April 10, 2020. Issue No. 1 (National Commission for Lebanese Women, UN Women, WHO, UNFPA, 2020) at: https://www2.unwomen.org/-/media/field%20office%20arab%20states/attachments/publications/2020/04/gender%20and%20covid-19%20in%20lebanon/updated/gender%20alert%20on%20covidlebanon%20english.pdf?la=en&vs=1838

84. Operation Faoiseamh - Domestic Abuse (9 June 2020), Ireland's National Police and Security Service at: https://www.garda.ie/en/about-us/our-departments/office-of-corporate-communications/press-releases/2020/june/operation%20faoiseamh%20-%20domestic%20abuse%209th%20june%202020%20.html#:~:text=Operation%20Faoiseamh%2C%20which%20commenced%20as,protected%20during%20this%20extraordinary%20time

85. 'Safe Ireland Welcomes Garda Prioritisation of Domestic Abuse and Coercive Control' at: https://www.safeireland.ie/safe-ireland-welcomes-garda-prioritisation-of-domestic-abuse-and-coercive-control/

86. 'Measures and Practices by Country. Promoting and Protecting Women's Rights at National Level' (Council of Europe at: https://www.coe.int/en/web/genderequality/promoting-and-protecting-women-s-rights#{%2263001324%22:[14]}

87. 'Assessing Sexual and Gender-Based Violence during the Ebola Crisis in Sierra Leone' (UNDP and Irish Aid, 2015) at: https://www.sl.undp.org/content/sierraleone/en/home/library/crisis_prevention_and_recovery/assessing-sexual-and-gender-based-violence-during-the-ebola-cris.html

88. 'Not just hotlines and mobile phones: GBV Service provision during COVID-19' (2020), Erskine, D., for UNICEF at: https://www.unicef.org/media/68086/file/GBV%20Service%20Provision%20During%20COVID-19.pdf

89. 'Global Rapid Gender Analysis for COVID-19' (International Rescue Committee and CARE International, 2020) at: https://www.rescue.org/report/global-rapid-gender-analysis-covid-19